# ប្រវត្តិសាស្ត្រប្រទេសកម្ពុជា

*ចាប់តាំងពីសតវត្សរ៍ទី១ នៃគ្រិស្តសករាជរហូតមក*

*ដោយផ្អែកតាមសិលាចារឹក, កំណត់ត្រារបស់ចិន និងអាណ្ណាម,*
*និងតាមឯកសារអឺរ៉ុបដែលមានក្នុង៦សតវត្សរ៍ចុងក្រោយនេះ*

**និពន្ធដោយ លោក អាដេម៉ារ ឡឺក្លែរ**
*អតីតរ៉េស៊ីដង់បារាំងប្រចាំកម្ពុជា*

*ប៉ារីស*
*បណ្ណាគារប៉ូលហ្គឺតនែរ*
*ផ្ទះលេខ១៣ ផ្លូវហ្សាកុប ១៣*
*១៩១៤*

**ប្រែសម្រួលដោយ ទេព ម៉េងឃាន ហៅ ទីឃាយុ**
*មជ្ឈមណ្ឌលឯកសារកម្ពុជា*
*បោះពុម្ពលើកទីមួយ ឆ្នាំ២០០៥*

ឯកសារបកប្រែទី៤នៃមជ្ឈមណ្ឌលឯកសារកម្ពុជា

**◆អាដេម៉ារ ឡឺក្លែរ : ប្រវត្តិសាស្ត្រប្រទេសកម្ពុជា**

◆បកប្រែជាភាសាខ្មែរដោយ ទេព ម៉េងឃាន ហៅ ទីឃាយុ ◆ ពិនិត្យកែសម្រួលឃ្លោងឃ្លា និងអក្ខរាវិរុទ្ធដោយ ឆាំង យុ ◆ ក្រាហ្វិក និងកុំព្យូទ័រការីដោយ គីម សុវណ្ណ ដានី ◆ រចនាក្រប និងតួសៀវភៅដោយ ឆាំង យុ ◆ បោះពុម្ពនៅកម្ពុជា ឆ្នាំ២០០៥ ◆ រក្សាសិទ្ធិ ◆

Translation Series No.4 ◆ Documentation Center of Cambodia

◆Adhémard Leclère: History of Cambodia

◆Translated by Tep Mengkhean ◆ Edited by Youk Chhang ◆ Graphic by Kim Sovann Dany ◆ Cover and Book design by Youk Chhang ◆ Printed in Cambodia 2005 ◆ Copyright ◆

The History of Cambodia translation project was initiated in early Fall 2004 with personal support from the author of the book. The publication was funded in 2004 by the author.

មជ្ឈមណ្ឌលឯកសារកម្ពុជា

*Searching for the truth.*

Documentation Center of Cambodia
P.O. Box 1110, Phnom Penh, Cambodia
Tel.: + 855 (23) 211-875
Fax.: + 855 (23) 210-358
Email: dccam@online.com.kh
Homepage: www.dccam.org

1- Cambodia - History. I. Tittle: Histoire du Cambodge depuis le 1er siècle de notre ère...
DS 554.5.L4 1975 959.6 73.1792 17
ISBN 0-404-54845-8

# HISTOIRE

DU

# CAMBODGE

## DEPUIS LE 1er SIÈCLE DE NOTRE ÈRE

D'APRÈS LES INSCRIPTIONS LAPIDAIRES,
LES ANNALES CHINOISES ET ANNAMITES ET LES DOCUMENTS
EUROPÉENS DES SIX DERNIERS SIÈCLES

PAR

ADHÉMARD LECLÈRE
ANCIEN RÉSIDENT DE FRANCE AU CAMBODGE

PARIS
LIBRAIRIE PAUL GEUTHNER
13, RUE JACOB, 13

1914

# មាតិកា


## អារម្ភកថា

## បុព្វកថារបស់អ្នកប្រែសម្រួល

## ក្បាលទី១ : ប្រទេសកម្ពុជា តាមរឿងនិទាន និងសិលាចារឹក

*ជំពូកដើម : ឥណ្ឌូចិន និងប្រជាជន នៅដើមគ្រិស្តសករាជ និងនៅដើមមហាសករាជហិណ្ឌូ ................. ១*

*ជំពូកទី១ ................. ១៥*

*ជំពូកទី២ : វយធបុរៈ និងសម្ភុបុរៈ ................. ៣១*

*ជំពូកទី៣ : អំពីកម្ពុជា ឬ ស្រុកខ្មែរ ................. ៣៥*

*ជំពូកទី៤ : កំណត់សម្គាល់អំពីប្រជាជនដែលមានទំនាក់ទំនងជាមួយកម្ពុជាមុនសតវត្សរ៍ទី៨ ចាម្ប៉ា, អាណ្ណាម-តុងកឹង, ទៀបកោះម៉ាឡាកា, ឈេទូ ឬសៀម, ឥណ្ឌា និងចិន ................. ៤៧*

*ជំពូកទី៥ : ប្រទេសកម្ពុជា ពីសតវត្សរ៍ទី៧ ដល់ សតវត្សរ៍ទី១០ ................. ៦៧*

*ជំពូកទី៦ : ប្រទេសកម្ពុជា ឬ ស្រុកខ្មែរ ................. ៧១*

*ជំពូកទី៧ : កំណត់សម្គាល់អំពីប្រជាជនដែលមានទំនាក់ទំនងជាមួយកម្ពុជា ពីសតវត្សរ៍ទី៨ ដល់ សតវត្សរ៍ទី១០ : ចាម្ប៉ា, អាណ្ណាម-តុងកឹង, ចិន និងឥណ្ឌា ................. ៨៥*

*ជំពូកទី៨ : ប្រទេសកម្ពុជា ពីសតវត្សរ៍ទី១០ ដល់ សតវត្សរ៍ទី១៤ ................. ៩៣*

*ជំពូកទី៩ : បដិវត្តន៍នៅសតវត្សរ៍ទី១៤ ................. ១១៥*

*ជំពូកទី១០ : កំណត់សម្គាល់អំពីប្រជាជនដែលមានទំនាក់ទំនងជាមួយកម្ពុជា ពីសតវត្សរ៍ទី១០ ដល់ សតវត្សរ៍ទី១៤ ................. ១២៩*

## ក្បាលទី២ : ប្រទេសកម្ពុជាតាមរាជពង្សាវតារ និងឯកសារប្រវត្តិសាស្ត្រផ្សេងទៀត

*ជំពូកទី១ : ប្រទេសកម្ពុជាចាប់ពីឆ្នាំ១៣៤០ រហូតដល់ការបែកបន្ទាយលង្វែក ................. ១៧៣*

*ជំពូកទី២ : អំពីប្រជាជនដែលមានទំនាក់ទំនងជាមួយកម្ពុជានៅសតវត្សរ៍ទី១៤, ១៥ និង១៦ ................. ២៥៣*

*ជំពូកទី៣ : ពីការបែកបាក់បន្ទាយលង្វែកនៅក្នុងឆ្នាំ១៥៨៥ រហូតមកដល់សព្វថ្ងៃនេះ ................. ២៨៣*

*ជំពូកទី៤ : កំណត់សម្គាល់ស្ដីអំពីប្រជាជនដែលមានទំនាក់ទំនងជាមួយកម្ពុជា ពីសតវត្សរ៍ទី១៦ រហូតដល់សព្វថ្ងៃ ................. ៤១៣*

# អារម្ភកថា

ខ្ញុំបានមករស់នៅប្រទេសកម្ពុជាចំនួនម្ភៃប្រាំឆ្នាំហើយ ។ ខ្ញុំបានសិក្សាច្បាប់ផ្សេងៗរបស់ប្រទេសនេះជាបន្តបន្ទាប់ ។ ការសិក្សានេះទាមទារឲ្យខ្ញុំចំណាយពេលអស់ដប់ប្រាំឆ្នាំ និងបោះពុម្ពសៀវភៅជាប្រាំក្បាល គឺពីរក្បាលសម្រាប់អត្ថបទច្បាប់ដែលបកប្រែចេញពីឯកសារដើម និងបីក្បាលទៀតសម្រាប់ការអត្ថាធិប្បាយ ។ បន្ទាប់ពីច្បាប់ ខ្ញុំបានសិក្សាទំនៀមទម្លាប់ប្រពៃណីរបស់ប្រទេសនេះ ដោយផ្អែកទៅតាមអ្វីដែលខ្ញុំសង្កេតមើលឃើញ និងតាមក្រមច្បាប់សីលធម៌ ដែលគេបានសរសេរសម្រាប់ប្រដៅសាធារណជន ។ បន្ទាប់មកទៀតខ្ញុំបានសរសេរអត្ថបទផ្សេងៗ ស្តីអំពីកាយវិភាគសាស្ត្រ, វេជ្ជសាស្ត្រ, ធ្មប់, ការអប់រំ, តារាសាស្ត្រ, សីលធម៌, លេខនព្វន្ត និងការដាំស្រូវរបស់ប្រជាជនកម្ពុជា ចុះផ្សាយនៅក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រ[១], ព្រឹត្តបត្រនៃសមាគមនរវិទ្យាទីក្រុងប៉ារីស[២], និងទស្សនាវដ្ដីប្រវត្តិសាស្ត្រច្បាប់បារាំង និងបរទេស[៣] ។

ការសិក្សានេះនៅមានផងដែរនូវអត្ថបទខ្លីៗចំនួនម្ភៃ, សៀវភៅចំនួនដប់ក្បាល និងសម្រង់រឿងនិទានចំនួនបួនក្បាល ដែលជារឿងនិទានហិណ្ឌូ តែគេបានកែសម្រួលឲ្យទៅជារឿងរ៉ាវប្រជាប្រិយ៍ខ្មែរ ។ ការសិក្សាទាំងនេះហាក់ដូចជាត្រូវបានបញ្ចប់ជាមួយនឹងការបោះពុម្ពសៀវភៅមួយក្បាលធំ ដែលមានចំណងជើងថា ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ។ ខ្ញុំអាចនឹងបញ្ចប់ការសិក្សារបស់ខ្ញុំត្រឹមនេះ ក៏ប៉ុន្តែខ្ញុំនៅចង់ដឹងអំពីការរៀបចំប្រទេសបែបថ្មី ថាតើរាជរដ្ឋាភិបាលនោះរាយ៉ាងណា ហើយវាំងស្តេចកម្ពុជានោះយ៉ាងដូចម្តេច ។ ការសិក្សាបន្ថែមថ្មីនេះ បានក្លាយជាកម្មវត្ថុនៃកិច្ចការមួយទៀត ដែលមួយចំណែកបានបោះពុម្ពចេញជាសៀវភៅរួចហើយ ហើយចំណែកទីពីរកំពុងរៀបចំបោះពុម្ព ។

ក៏ប៉ុន្តែនៅមានសៀវភៅចាំបាច់មួយទៀត ដែលទាមទារឲ្យខ្ញុំត្រូវតែសរសេរ គឺប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់តាំងពីសតវត្សរ៍ទី១នៃគ្រិស្តសករាជរហូតមកទល់សព្វថ្ងៃ ដែលជាកិច្ចការដ៏ធំមួយ ។ ខ្ញុំនៅរាវែកអស់ពេលជាយូរទម្រាំសម្រេចចិត្តប្រើប្រាស់កំណត់ត្រា និងឯកសារជាច្រើនដែលខ្ញុំប្រមូលបានក្នុងរយៈពេលម្ភៃពីរឆ្នាំកន្លងមក ព្រោះវានៅមានការខ្វះចន្លោះជាច្រើន និងមានទំព័រខ្លះមើលមិនយល់ផង ។ ការខ្វះចន្លោះនេះបានធ្វើឲ្យខ្ញុំខូចទឹកចិត្តជាច្រើនលើកច្រើនសា ។ ខ្ញុំមាននៅក្នុងដៃរួចហើយនូវអត្ថបទបកប្រែនៃសៀវភៅឈ្មោះ Corpus របស់ប៊ែហ្គែន និងបាថ, អត្ថបទចារឹកលើថ្មបកប្រែដោយអ្នកប្រាជ្ញភាសាសំស្ក្រឹត, និងអ្វីៗដែលគេបានដឹងពីប្រទេសកម្ពុជាតាមរយៈពួកចិន អាណ្ណាម និងសៀម, រួចមានសាស្ត្រាស្លឹករឹត, មានសៀវភៅស្តីអំពីកំណត់ត្រារបស់អឺរ៉ុប, ស្នាដៃរបស់បញ្ញវន្តសម័យថ្មីដែលខិតខំប្រមែប្រមូលទុកនូវអ្វីៗដែលគេបានកត់ត្រាទុកពីមុន, ហើយខ្ញុំមានសេចក្តីបកស្រាយផ្ទាល់មាត់ មានរឿងព្រេងនិទានទាក់ទិននៅនឹងវត្ថុផ្សេងៗទាំងអស់ មានអនុស្សាវរីយ៍ទាំងឡាយដែលបានកប់បាត់ក្នុងដួងព្រលឹងរបស់ប្រជាជនកម្ពុជាយូរមកហើយ ហើយដែលត្រូវ

សើរើយកមកវិញ ។ ទាំងអស់នេះដូចជានៅតិចតួច មិនទាន់គ្រប់គ្រាន់នៅឡើយ តែស្នាដៃនេះហាក់ដូចជាគួរតែសាកល្បងលមើលណាស់ ។ ទីបញ្ចប់ នៅឆ្នាំ១៩០៧ ខ្ញុំក៏បានចាប់ផ្ដើមសរសេរកិច្ចការដ៏ធំធេងនេះឡើង ដែលខ្ញុំសូមដាក់ជូនសាធារណជននាពេលនេះ ។ ខ្ញុំនៅបានទទួលអត្ថបទសរសេរដោយដៃដែលមិនធ្លាប់មានអ្នកណាដឹងដូចជារឿងស្ដេចកន ហើយនិងរឿងខ្លីៗចំនួនដប់ទៀតដែលគេបោះបង់ចោលនៅតាមវត្តអារាមនានា ។ ខ្ញុំបានធ្វើការទាក់ទងជាញឹកញយ ជូនកាលជាប្រចាំ ជាមួយបញ្ញវន្តមួយចំនួន ជាមួយសាសនិកជនចាស់ៗ ដែលចេះចាំរឿងរ៉ាវពីអតីតកាល និងជាមួយចាស់ព្រឹទ្ធាចារ្យ សម្រាប់ប្រវត្តិសាស្ត្រសម័យថ្មី រួចខ្ញុំក៏ចាប់ផ្ដើមសរសេរ ។

សៀវភៅថ្មីនេះជាលទ្ធផលនៃកិច្ចសហការរបស់ជនគ្រប់រូប ។ នេះគឺជាការកែតម្រូវនូវអ្វីៗដែលជនបារាំង និងកម្ពុជាខ្លះបានសិក្សាមុនខ្ញុំ កែតម្រូវនូវសំឡេងនៃអតីតកាលដែលខ្សឹបតៗគ្នា ពីសម័យមួយទៅសម័យមួយ ពីទីកន្លែងមួយទៅទីកន្លែងមួយទៀត អំពីទំព័រប្រវត្តិសាស្ត្រដែលគេមិនដែលបានសរសេរទុក ហើយមិនបានចេះចាំល្អ ឬចេះមិនប្រាកដ ឬក៏មិនបានចេះដឹងទាល់តែសោះ ។

ខ្ញុំបានខិតខំប្រឹងអស់ពីសមត្ថភាពដើម្បីស្រាវជ្រាវរកឲ្យឃើញនូវការពិត និងនិយាយឲ្យងាយយល់ថែមទៀត ។ ក៏ប៉ុន្តែខ្ញុំមិនដឹងថា តើខ្ញុំសម្រេចបានជោគជ័យក្នុងការធ្វើឲ្យមានពន្លឺខ្លះ នៅក្នុងសន្ទិប្រកាសនៃប្រទេសមួយដែលប្រហែលជាធ្លាប់តែមានកេរ្ដិ៍ឈ្មោះល្បីល្បាញដែរ ឬយ៉ាងណាទេ ។ ហើយក៏មិនដឹងថាតើខ្ញុំបានសរសេរសៀវភៅប្រវត្តិសាស្ត្រមួយមែនដែរឬក៏អត់ ។ តែខ្ញុំសង្ឃឹមថាយ៉ាងដូច្នេះ ទោះបីជាខ្ញុំដឹងច្បាស់ថា មានការងារប្រសើរជាងនេះ ដែលត្រូវធ្វើ និងហេតុការណ៍ជាច្រើនដែលត្រូវរកឲ្យឃើញ និងមានរឿងពិតខ្លះដែលខ្ញុំមិនបានបញ្ចេញក៏ដោយ ។

ខ្ញុំសូមអភ័យទោសពីសំណាក់អ្នកអានទាំងអស់ ចំពោះកំហុសឆ្គងដែលអាចមាន ភាពមិនគ្រប់គ្រាន់នៃឯកសារ ដែលខ្ញុំសរសេរឡើង ។ សូមមេត្តាជ្រាបថា ក្នុងការសរសេរសៀវភៅនេះឡើង ខ្ញុំគ្មានចេតនានឹងបង្ខិតបង្ខំអ្នកឯកទេសដ៏កម្រចំពោះការសិក្សាបែបនេះ ថាត្រូវតែទទួលយកនូវអ្វីដែលខ្ញុំសរសេរនោះទេ ។ ខ្ញុំសប្បាយរីករាយជានិច្ច នឹងទទួលយកនូវការទិតៀនទាំងឡាយ ជាពិសេសនឹងអានប្រវត្តិសាស្ត្រប្រទេសកម្ពុជាមួយ ដែលសរសេរគ្រប់គ្រាន់ និងល្អជាងសៀវភៅរបស់ខ្ញុំនេះ ។

នៅមានកិច្ចការជាច្រើនទៀតសម្រាប់អ្នកដែលមកបន្តវេនពីខ្ញុំ ។ មានឯកសារជាច្រើនដែលត្រូវរៀបចំជាថ្មី ដែលខ្ញុំគ្មានពេលនឹងប្រមែប្រមូលយកដោយវ័យជរារបស់ខ្ញុំ ។ សូមបញ្ជាក់ពីឯកសារខ្លះដែលប្រវត្តិវិទូបន្តពីខ្ញុំត្រូវសិក្សា ៖ ជាដំបូងគឺរាជពង្សាវតារសម្ងាត់មួយដែលពួកគេថារក្សាទុកនៅក្នុងព្រះបរមរាជវាំង ហើយដែលហាក់ដូចជាមានអាថ៌កំបាំងផង ។ ស្ដេចនរោត្តមបានចាក់សោឯកសារនេះទុក ហើយហាមឃាត់មិនឲ្យគេផ្សព្វផ្សាយវាទេ បើពុំនោះទេនឹងត្រូវទទួលទោសយ៉ាងធ្ងន់ធ្ងរ ។ តែស្ដេចស៊ីសុវត្ថិ ដែលឆ្លាតជាងបង និងស្ដេចមុនៗ ឬបើពុំនោះទេអាចនិយាយថាដែលមានគំនិតទាន់សម័យជាង ហាក់ដូចជានឹកចង់ប្រគល់ឯកសារនេះឲ្យទៅអ្នកណា

ម្នាក់ដែលចេះទូលសុំពីព្រះអង្គ និងចេះបង្ហាញឲ្យឃើញថា ជនជាតិកម្ពុជា ដែលធ្លាប់មានតួនាទីធំមួយ នៅក្នុងឥណ្ឌូចិន នៅក្នុងអតីតកាល តែងតែចង់ផ្សព្វផ្សាយនូវអ្វីដែលខ្លួនចេះដឹងអំពីប្រវត្តិសាស្ត្រ ព្រមទាំងឯកសារផ្សេងៗដែលខ្លួនមានផងដែរ ។

បន្ទាប់មកទៀតមានសាស្ត្រាថែងអំពីប្រវត្តិសាស្ត្រស្រុកនីមួយៗ ដែលនៅកប់តាមវត្តអារាម តែអាចនឹងមានសារសំខាន់ខ្លាំង ដូចជារឿងស្តេចកន ឬកនមេក្បត់ និងធម្មនុញ្ញក្រុងសំបុក (អាណាខេត្តក្រចេះ) ដែលខ្ញុំបានកែសម្រួល ហើយលើកឡើងនៅក្នុងសៀវភៅនេះ ផងដែរ ។

ជាទីបញ្ចប់ មានរឿងនិទានតាមមូលដ្ឋាន រឿងខ្លីៗទាក់ទិនទៅនឹងទីកន្លែងមួយដែលគ្មាននរណាស្គាល់ តែរៀបរាប់អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយ ដែលគេមិនដឹងថាកើតមាននៅពេលណានៅទីណាផងទេ ។

នៅមានឯកសារអឺរ៉ុបខ្លះទៀត ដែលនៅកប់នៅម៉ានីល ជប៉ុន ម៉ាកាវ និងនៅក្នុងកាលប្បវត្តិប្រទេសអឺរ៉ុបមួយចំនួនដែលធ្លាប់មានទំនាក់ទំនងជាមួយឥណ្ឌូចិនកាលពីសតវត្សរ៍ទី១៧រហូតដល់១៩ ហើយដែលមិនទាន់មានអ្នកណាស្រាវជ្រាវនៅឡើយ ។ លោក កាបាតុង បានចាប់ផ្តើមការបកប្រែឯកសារដែលគាត់រកឃើញនៅប្រទេសអេស្ប៉ាញ ព័រទុយហ្គេ អ៊ីតាលី (នៅរ៉ូមជាពិសេស) នៅឡាអេ ឡុង និងឯកសារមួយចំនួនទៀតដែលគាត់កំពុងតាមដានរកនៅកោះជ្វា (ហ្សាវ៉ា) កោះហ្គូអា (ឥណ្ឌា) ម៉ានីល និងទីកន្លែងផ្សេងៗទៀត ។ បើសិនជាគាត់ធ្វើការងារនេះ នោះលោក កាបាតុង នឹងបង្ហាញឲ្យយើងឃើញពីសារសំខាន់របស់ឯកសារទាំងនោះដែលគេត្រូវដឹង ហើយដែលខ្ញុំមិនអាចធ្វើបាន ។ ហើយខ្ញុំសូមធ្វើគារវកិច្ចដោយរីករាយចំពោះសៀវភៅនេះ រួចខ្ញុំសប្បាយចិត្តបើសិនជាអារម្មកថា នេះជំរុញថាត្រូវតែសរសេរវាឡើង ។

អាដេម៉ារ ឡឺក្លែរ

ប៉ារីស, ថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩១៣

1 Revue scientifique

2 Bulletin de la Société d'Ethnographie de Paris

3 Revue de l'histoire du droit francais et étranger

# បុព្វកថារបស់អ្នកប្រែសម្រួល

*សៀវភៅ “ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់តាំងពីសតវត្សរ៍ទី១ នៃគ្រិស្តសករាជរហូតមក”* (L'histoire du Cambodge depuis le 1er siècle de Notre Ere) *ដែលនិពន្ធដោយលោក* ADHEMARD LECLÈRE *អតីតរ៉េស៊ីដង់បារាំងប្រចាំប្រទេសកម្ពុជា ត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ១៩១៨ គឺនៅមុនពេលប្រទេសកម្ពុជាទទួលបានឯករាជ្យពីបារាំងទៅទៀត ។*

*ក្រោយពីបានអានសៀវភៅនេះចប់ ខ្ញុំឃើញថា ស្នាដៃនិពន្ធរបស់លោក* ADHEMARD LECLÈRE *មានលក្ខណៈទូលំទូលាយ និងមានការស្រាវជ្រាវយ៉ាងហ្មត់ចត់ ។ លក្ខណៈសម្បត្តិបែបនេះ មានប្រយោជន៍យ៉ាងច្រើនសម្រាប់អ្នកសិក្សាស្រាវជ្រាវ អ្នកនិពន្ធ ពិសេសសិស្សានុសិស្ស និស្សិតខ្មែរយើង ។ ជាការពិត ការសិក្សានៅសាលាចំណេះទូទៅ នៅមហាវិទ្យាល័យ អំពីមុខវិជ្ជាប្រវត្តិសាស្ត្រនេះពិតជាពុំគ្រប់គ្រាន់ទេ ដើម្បីយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាមួយ ដែលគ្រប់ជ្រុងជ្រោយយកជាការបាន ។ សម្រាប់យើងជាប្រជាជាតិខ្មែរ ដែលមានប្រវត្តិសាស្ត្រដ៏រុងរឿងកន្លងមក ការយល់ដឹង និងការទទួលបាននូវពត៌មានជាច្រើនផ្សេងទៀត ទាក់ទិននៅនឹងប្រវត្តិសាស្ត្ររបស់ខ្លួន គឺជាការបំពេញបន្ថែមដ៏សំខាន់ សម្រាប់កាយល់ដឹងកាន់តែជ្រៅជ្រះថែមទៀត នូវអត្តសញ្ញាណរបស់ជាតិខ្លួន ។*

*ស្ថិតលើហេតុផលខាងលើ និងដោយយល់ឃើញថា សៀវភៅនេះមានគុណប្រយោជនយ៉ាងច្រើនសម្រាប់ អ្នកសិក្សាស្រាវជ្រាវ និងប្រជាពលរដ្ឋខ្មែរយើងទូទៅ ទើបខ្ញុំសម្រេចចិត្តចំណាយពេលវេលាធ្វើការប្រែសម្រួលពីភាសាបារាំងមកជាភាសាខ្មែរ និងបោះពុម្ពជាសៀវភៅតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជានូវស្នាដៃនិពន្ធនេះ ដើម្បីបម្រើដល់ការអាន និងបំពេញបន្ថែមចំណេះដឹងសម្រាប់សាធារណជនទូទៅ ។*

*ម៉្យាងទៀត ខ្ញុំសូមបញ្ជាក់ថា ការបកប្រែឈ្មោះមនុស្ស និងទីកន្លែងពីភាសាបារាំង ដែលមាននៅក្នុងសៀវភៅនេះ ពិតជាល្អៀងខុសគ្នាពីឯកសារ ឬសៀវភៅប្រវត្តិសាស្ត្រកម្ពុជា របស់អ្នកស្រាវជ្រាវពីមុនៗបន្តិចបន្តួចមិនខាន ទោះជាខ្ញុំខំផ្ទៀងផ្ទាត់យ៉ាងណាក៏ដោយ ។*

*ខ្ញុំសង្ឃឹមថា សៀវភៅមួយនេះ នឹងរួមចំណែកផ្តល់នូវពុទ្ធិអំពីប្រវត្តិសាស្ត្រប្រជាជាតិយើង និងធ្វើឲ្យយើងមានមោទនភាពជាតិកាន់តែខ្ពស់ថែមទៀតជាមិនខាន ។*

*ប្រជាជាតិមួយដែលមិនស្គាល់ប្រវត្តិសាស្ត្រពិតរបស់ខ្លួន*<br>
*ប្រជាជាតិនោះ នឹងត្រូវប្រវត្តិសាស្ត្រដដែលៗ ថ្កោលទោស ។*

# ក្បាលទី១
# ប្រទេសកម្ពុជា តាមរឿងនិទាន និងសិលាចារឹក

## ជំពូកដើម
## ឥណ្ឌូចិន និងប្រជាជន នៅដើមគ្រិស្តសករាជ និងនៅដើមមហាសករាជហិណ្ឌូ

### ១- *អំពីទឹកដី*

*ប្រសិនបើគេពិនិត្យមើលផែនទីទ្វីបអាស៊ី ជាដំបូងគេសង្កេតឃើញមានឧបទ្វីបធំៗបីស្ថិតនៅភាគខាងត្បូង ៖ ឧបទ្វីបមួយនៅខាងលិចគឺឧបទ្វីបអារ៉ាប់ ដែលយើងនឹងមិនយកចិត្តទុកដាក់ទេ ។ ឧបទ្វីបមួយទៀតនៅកណ្តាល គឺឧបទ្វីបឥណ្ឌា ដែលមានរាងត្រីកោណ និងមានកោះសិរីលង្កានៅត្រង់កំពូល តែខិតមកខាងឆ្វេងបន្តិច កោះនោះប្រៀបបានទៅនឹងពេជ្រមួយគ្រាប់ ដែលផ្លែឡើងដោយដាងមកពីប្រទេសហុល្លង់ ។ ឧបទ្វីបទីបីនៅខាងកើតនោះគឺឧបទ្វីបឥណ្ឌូចិន ។ ឧបទ្វីបនេះមានរាងដូចជាថង់វែអង្កាសប្រាក់ ហើយមានឧបទ្វីបមួយតូចព្យួរជាប់នឹងចង្កេះ មានរាងដូចជាខ្សែបន្តោងដែលមានខាងចុងរីកធំដូចជាថ្នក់អ្វីមួយ ៖ នោះគឺឧបទ្វីបម៉ាឡាកា រាងវែងហើយវៀវ ដែលមានឈ្មោះថា ដែនដីសុវណ្ណភូមិ នៅក្នុងដែនទីរបស់ ផ្តូលេមេ ។ តាមមើលទៅ ឧបទ្វីបនេះប្រហែលជានៅដាច់ផុតពីទ្វីបនៅឡើយ កាលពីដើមគ្រិស្តសករាជ ដោយដៃសមុទ្រមួយត្រង់ប្ញូរដី មានឈ្មោះថា ក្រា ។*

*បើគេទុកផែនទីដែលបង្ហាញប្រទេសជាច្រើននេះ រួចយកផែនទីដែលបង្ហាញពីឥណ្ឌូចិនក្នុងមាត្រដ្ឋានធំព្រមទាំងមានកោះទាំងឡាយនៅក្នុងសមុទ្រខាងត្បូង ពោលគឺ អាំងស៊ុយឡាំងដងមកមើលវិញ គេឃើញមានសមុទ្រតូចមួយនៅចន្លោះឧបទ្វីបឥណ្ឌូចិន និងឧបទ្វីបម៉ាឡាកា សមុទ្រនោះមានឈូងមួយនៅពីខាងជើង ៖ សមុទ្រនោះគឺសមុទ្រសៀម រីឯឈូងសមុទ្រគឺឈូងសមុទ្របាងកក ។ នៅពីខាងនិរតីនៃឧបទ្វីបម៉ាឡាកា ដ៏វែងមានកោះធំមួយ គឺកោះស៊ូម៉ាត្រា ហើយនៅខាងចុងកោះនេះ គឺកោះជ្វាដ៏ល្អត្រកាល ។ ទៅខាងកើតនោះទៀតគឺកោះប៊័រណេអូដែលជាកោះធំជាងគេនៅលើលោករួចហើយ មានកោះរាប់ពាន់ មានតូចមានធំ នៅប្រមូលផ្តុំគ្នាជាប្រជុំកោះ ដែលតភ្ជាប់ចេញពីឧបទ្វីបម៉ាឡាកា និងកោះទាំងឡាយរបស់ម៉ាឡេស៊ី ទៅទិសខាងកើតចម្ងាយប្រហែល៨០០គីឡូម៉ែត្រ ។ កោះតូចធំទាំងអស់នេះ អាចជាកំពូលភ្នំនៃទ្វីបធំមួយ ដែលបានលិចកប់បាត់ទៅនៅក្រោមទឹកសមុទ្រ រីឯវាលទំនាប និងជ្រលងភ្នំ ស្ថិតក្នុងទីជម្រៅ ។*

*នៅពេលដែលគេពិនិត្យឃើញថាឧបទ្វីបម៉ាឡាកាដ៏វែងនេះ នៅផ្តុំគ្នាជាមួយនឹងឧបទ្វីបឥណ្ឌូចិនដ៏ធំ ដែលមានព្រំប្រទល់ខាងជើងជាប់នឹងប្រទេសចិននោះ គេអាចយល់បានអំពីភាពទាក់ទងគ្នាខាងប្រវត្តិសាស្ត្រ នៃបណ្តា*

ប្រជាជន ដែលកកើតបានជាជាតិសាសន៍ផ្សេងៗ ឡើង នៅលើទឹកដីដ៏ធំទូលាយនេះ ។ ហើយគេក៏យល់បានដែរ ថា គេមិនអាចនិយាយអំពីជាតិសាសន៍ណាមួយ ដោយមិននិយាយអំពីជាតិសាសន៍ផ្សេងទៀតសោះនោះទេ ។

ឥឡូវនេះ សូមបែរមកពិនិត្យមើលផែនទីលម្អិតរបស់ឧបទ្វីបឥណ្ឌូចិនវិញម្តង ។ បើលោកអ្នកពិនិត្យជួរភ្នំដ៏វែង ដែលលាតសន្ធឹងនៅលើឧបទ្វីបនេះ លោកអ្នកនឹងឃើញថាមានទន្លេស្ទឹងធំៗ ដែលហូរកាត់ជួរភ្នំនេះ ទន្លេស្ទឹងទាំងនោះ ហូរនាំទឹកចេញពីជ្រលងភ្នំទាំងឡាយ ដែលបញ្ជាក់ឲ្យឃើញថាឥណ្ឌូចិន គឺជាកូនស្រីនៃទន្លេទាំងអស់នោះ នឹងថា ជាតិសាសន៍ប្រកបដោយអារ្យធម៌ទាំងឡាយ ដែលគេប្រទះឃើញនៅទីនេះ សុទ្ធតែបានកកើតឡើងនៅលើដីល្បប់ដែលទន្លេស្ទឹងហូរនាំយកមកចាក់បំពេញបន្តិចម្តងៗ ហើយទឹកទន្លេស្ទឹងទាំងអស់នោះ បានហួតស្ងួតអស់ទៅដោយកម្តៅព្រះអាទិត្យ ។

យ៉ាងណាមិញ តុងកឹងគឺជាកូនរបស់ទន្លេក្រហម និងទន្លេសុងម៉ា ។ កម្ពុជាគឺជាកូនរបស់ទន្លេមេគង្គ (ឬមេទឹក) ។ ប្រទេសសៀម គឺជាកូននៃទន្លេមេណាម ដែលមានន័យថាមេទឹកដែរ ។ ប្រទេសភូមា ជាកូនរបស់ទន្លេឥរាវតី និងទន្លេសាលូអង់ ។ ទន្លេទាំងអស់សុទ្ធតែមានប្រភពចេញពីភ្នំដ៏ធំ គឺភ្នំហិមាល័យ (ខ្មែរហៅ ភ្នំហេមពាន្ត) នៅទីបេ ។

ក្រោយពីបានពិនិត្យមើលភ្នំ និងសិក្សាទន្លេទាំងឡាយរួច នោះគេនឹងមិនលំបាកនឹងគិតស្រមៃក្នុងចិត្តទេ ដើម្បីគូសវាសដែនទីនៃប្រទេសទៅតាមដែលព្រះឥន្ទ្រលោកអាចនឹងពិនិត្យមើលឃើញ ពេលលោកគង់ នៅលើទីដ៏ខ្ពស់ ដោយក្រឡេកតែមួយភ្លែតអាចមើលឃើញឧបទ្វីបទាំងមូល ។ ជាដំបូង នៅខាងជើងគឺភ្នំធំក្រាស់ ដែលលាតសន្ធឹងពីកើតទៅលិច ព័ទ្ធជុំវិញឈូងសមុទ្រតុងកឹង ។ ចុះមកខាងត្បូងភ្នំធំក្រាស់នេះ សណ្ឋានដីបានត្រូវកត់សម្គាល់ដោយជួរភ្នំអាណ្ណាម ដែលចោតបន្តិចពីខាងកើត ប៉ុន្តែ រាងទេរនៅខាងលិច មានខ្ពង់រាបខ្ពស់ទាបបន្តបន្ទាប់ បន្ទាយត្រង់កន្លែងខ្លះរហូតជិតដល់ទន្លេមេគង្គ ។ នៅខាងទិសនិរតី ជួរភ្នំអាណ្ណាមរីកជាភ្នំធំក្រាស់ ដែលលាតសន្ធឹងពីសមុទ្ររហូតដល់ខាងត្បូងដាឡាត់ និងទៅដល់កូសាំងស៊ីនទៀត ។ នៅទិសខាងលិចវិញ មានជួរភ្នំ ភ្នំតូចៗ និងខ្ពង់រាបដែលបន្តភ្ជាប់ចេញពីភ្នំហិមាល័យដែរ ហើយញែកប្រទេសសៀម ចេញពីប្រទេសលាវ និងកម្ពុជា និងជាបន្ទាត់ខណ្ឌចែកទឹករវាងអាងទន្លេមេគង្គ និងទន្លេមេណាម ។

ទីបំផុត មានជួរភ្នំទីបីមួយទៀត ដែលបែកចេញពីភ្នំធំក្រាស់ហិមាល័យនៅទីបេដែរ ។ ជួរភ្នំដ៏វែងតែតូចចង្អៀតនេះ លាតសន្ធឹងចេញពីប្រទេសភូមាខាងលើ បែងចែកភូមាជាពីរ ហើយជាទ្រនុងឆ្អឹងរបស់ទៀបកោះម៉ាឡាកា បន្តមកបញ្ចប់នៅក្នុងសមុទ្រខាងត្បូងជាកោះជាច្រើន ខណ្ឌដោយដៃសមុទ្រតូចធំ ឬដោយសមុទ្រតូចៗ និងស្ងប់ស្ងាត់ ។

ដូច្នេះ គេពិនិត្យឃើញថាមានជួរភ្នំបីនៅឥណ្ឌូចិន ជួរភ្នំទាំងនោះមានប្រភពចេញពីភ្នំធំក្រាស់ ហិមាល័យនៅទីបេ ហើយសន្ធឹងមកខាងត្បូងទាំងអស់គ្នា បង្កើតបានជាអាងធំៗបួន ដែលមានទន្លេវែងៗបួន ហូរកាត់

អាងទន្លេទាំងនោះជាជម្រករស់នៅនៃជាតិសាសន៍ប្រាំគឺ ៈ អាងទន្លេមេគង្គ ដែលជាជម្រកនៃប្រទេសលាវនៅខាងជើង រួចប្រទេសកម្ពុជា និងកូសាំងស៊ីននៅខាងត្បូង អាងទន្លេមេណាម ជាជម្រកនៃប្រទេសសៀម អាងទន្លេឥរាវតី ជាជម្រកនៃប្រទេសភូមា និងអាងនៃទន្លេក្រហម ដែលជាជម្រកនៃប្រទេសតុងកឹង ។

នៅមានជួរភ្នំមួយទៀត ដែលជាព្រំដែនរវាងប្រទេសកម្ពុជា និងខេត្តមួយចំនួនរបស់ប្រទេសសៀមនោះគឺភ្នំដងរែក ។ ភ្នំនេះមានចង្កេះខាងត្បូងចោតខ្លាំង ក៏ប៉ុន្តែតាមពិតភ្នំនេះជាខ្ពង់រាបដ៏ធំមួយ ដែលនៅជាប់នឹងឈូងសមុទ្រដ៏ជ្រៅមួយកាលពីសម័យដើម ។ ជួរភ្នំនេះសន្ធឹងកាត់អាងទន្លេមេគង្គពីកើតទៅលិច ក៏ប៉ុន្តែ វាមិនបានបង្វែរទិសរបស់ទន្លេនេះទេ ។ ទឹកហូរនាំយកដីគ្រប់ទិសទីចាក់ទៅក្នុងទន្លេ រួចហូរពីទន្លេសំដៅទៅសមុទ្រខាងត្បូង ។

តាមមើលទៅ កាលពីសម័យមួយដ៏យូរលង់ ដែលនៅពេលនោះប្រទេសកម្ពុជា និងកូសាំងស៊ីនមិនទាន់កកើតនៅឡើយ ទឹកសមុទ្របានឡើងមកដល់ត្រឹមជើងភ្នំដងរែកនេះឯង រីឯមាត់ពាមរបស់ទន្លេមេគង្គ គឺស្ថិតនៅត្រង់ចន្លោះបាសាក់ និងខោន ។ ពេលនោះទឹកដីកូសាំងស៊ីន និងកម្ពុជាស្ថិតនៅក្នុងបាតឈូងសមុទ្រនៅឡើយ កន្លែងឈូងសមុទ្រនោះ សព្វថ្ងៃនេះគឺបឹងទន្លេសាប ។

កាលនោះ មានបឹងធំមួយនៅខាងជើងភ្នំដងរែក ។ ទឹកបឹងនេះរីងខះបន្តិចម្តងៗ ក្លាយទៅជាវាលទំនាបមួយប្រកបដោយដីជាតិ ដែលលោក បារតេឡេមី បានបរិយាយនៅឆ្នាំ១៩០៧ ហើយដែលមានទន្លេសេមូននិងដៃរបស់ទន្លេនេះគឺ ស្ទឹងសេស៊ី ហូរកាត់សព្វថ្ងៃនេះ ។ ទាំងអស់នេះ គឺជាកាកសំណល់ដែលនៅសេសសល់ពីកូនសមុទ្រមេឌីទែរ៉ាណេតូចមួយ ដែលទឹកសមុទ្របានស្រកថយបាត់អស់ទៅ តែឡើងមកលិចម្តងៗដែរ កាលណាទឹកជោរ ។ ដីនៅទីនេះរាបស្មើ តែនៅរក្សាជាតិប្រៃនៅឡើយ ។ ក្រោយរដូវភ្លៀងម្តងៗ គេឃើញមានឡើងក្រាមជាតិប្រៃក្រាលនៅលើដី ដែលអ្នកស្រុករមែងប្រមូលយកមកស្ងួជាអំបិល គ្រប់គ្រាន់សម្រាប់តម្រូវការនៅក្នុងតំបន់ ។ បាតុភាពនេះអាចនឹងកើតមានឡើងដូចគ្នា នៅក្នុងអនាគត ដប់ ឬដប់ប្រាំសតវត្សរ៍ តទៅមុខទៀតចំពោះបឹងទន្លេសាប ដែលទឹកពីមុនប្រៃ ហើយការដែលគេដាក់ឈ្មោះថា សាប នេះ អាចជាការបញ្ជាក់ថា ទឹកទន្លេនេះកាលពីមុននៅប្រៃតិចៗ ឬមិនស្រួលទទួលទានប៉ុន្មានទេ ទោះបីជាឥឡូវ ទឹកនេះបានសាបទៅហើយក៏ដោយ ។

នៅប្រទេសសៀមឯណោះវិញ កាលពីសម័យនោះ ទឹកសមុទ្រប្រហែលជាឡើងរហូតមកដល់ត្រឹមនគរសុវណ្ណ ត្រង់ខាងលើចំណុចដែលមានស្ទឹងពីរហូរចូលមកក្នុងទន្លេមេណាមឥឡូវ ។ ប្រជាជនដែលរស់នៅទីនេះកាលពីពេលនោះ មានដីខ្ពស់តែត្រង់ផ្នែកខាងលើនៃអាងទន្លេមេណាមនៅខាងជើងប៉ុណ្ណោះ និងចម្រៀកដីធំទូលាយមួយ នៅតាមជើងភ្នំប៉ាតាវី, ប៉េទ្រូ និងប៉ាយ៉ង់ នៅខាងកើត និងនៅតាមជើងភ្នំតេណាសេរីម នៅខាងលិច ។ តំបន់ទាំងអស់ជុំវិញអយុធ្យា ត្រង់កោះណងស្នោ ដែលជាទីតាំងរបស់ទីក្រុងនេះ ហើយនិងតំបន់ជុំវិញបាងកក ដែលជាទីក្រុងទំនើបរបស់សៀមសព្វថ្ងៃ កាលនោះស្ថិតនៅក្រោមទឹកសមុទ្រនៅឡើយ ។ ដីកន្លែងនេះចាប់លេចចេញពីទឹកនៅដើមគ្រិស្តសករាជយើងនេះ ប៉ុន្តែ បាងកកនៅតែជាតំបន់សម្បូរទៅដោយបឹងបួដដែល ។

ហេតុការណ៍ដូចគ្នានេះក៏កើតមាននៅឯរ៉ង់ហ្គូន នៅបាសេន និងហេងសាដា របស់ប្រទេសភូមាផងដែរ ។ ទឹកដីទាំងអស់នេះផ្ទៀងទម្លាក់ខ្លួននៅចន្លោះភ្នំអារៈកយ្យម៉ានៅខាងលិចចុះទៅត្បូង រហូតដល់ជ្រោយនេហ្គ្រេ និងភ្នំពេគូយ៉ាម៉ា នៅខាងកើត បង្កើតបានជាឈូងសមុទ្រមួយ ដែលទន្លេឥរាវតី ហូរចូលមក ។

ឥឡូវ យើងត្រលប់មកមើលប្រទេសកម្ពុជា និងទន្លេមេគង្គ ដែលជាទន្លេមួយក្នុងបណ្ដាទន្លេដែលវែងជាងគេនៅលើលោកនេះវិញម្ដង ។

សូមពិនិត្យមើលផ្លូវទឹករបស់ទន្លេមេគង្គនៅលើផែនទី ។ ទន្លេនេះមានប្រវែង៣០០០គីឡូម៉ែត្រ និងមានផ្លូវទឹកបត់បែនយ៉ាងខ្លាំង ។ ជលមាគ៌ានេះ ទទួលយកបរិមាណទឹកភ្លៀងចំនួនពាក់កណ្ដាល ដែលធ្លាក់មកលើឥណ្ឌូចិន ហើយដែលមិនបានហួតអស់ទៅដោយកម្ដៅព្រះអាទិត្យទេ ។ ទន្លេនេះហូរចេញពីភ្នំហិមាល័យនៅទីបេ ប្រទេសចិន ដោយមានជម្រាលចោទយ៉ាងខ្លាំង និងមានដៃទន្លេច្រើនរាប់រយ ។ នៅចម្ងាយ៥០គីឡូម៉ែត្រ ពីខាងក្រោមព្រំប្រទល់រវាងចិន និងឥណ្ឌូចិន ទន្លេមេគង្គរីកធំតែរាក់ ទឹកនៅតែត្រឹមជង្គង់ មនុស្សអាចដើរកាត់បាននៅរដូវរងា ។ ចាប់ពីត្រឹមនេះទៅ ទន្លេមេគង្គបានចូលមកដល់ទឹកដីឥណ្ឌូចិនហើយ នៅត្រង់ខាងលើទន្លេក្រុនហុងដោយហូរកាត់របាំងថ្មធម្មជាតិខ្ពស់ៗ ចង្អៀត និងជ្រៅ មិនអាចធ្វើនាវាចរបានទេ ។

មកដល់ត្រង់ហ្លួងប្រាបាង ទន្លេមេគង្គប្រែជាល្អឡើងវិញ ហើយរឹតតែល្អឆើតឆាយនៅត្រង់វៀងច័ន្ទ ។ ក៏ប៉ុន្តែ នៅចន្លោះពីហ្លួងប្រាបាងមកដល់វៀងច័ន្ទ ការធ្វើនាវាចរពេលខ្លះមានការលំបាក គេត្រូវផ្ទេរទំនិញយ៉ាងតិចម្ដង បើគេចង់ធ្វើដំណើរចុះឡើង ។

ចាប់ពីក្រោមវៀងច័ន្ទចុះមកក្រោម ទន្លេមេគង្គល្អត្រកាលណាស់ ហើយនាវាសមុទ្រ និងនាវាចម្បាំងអាចធ្វើនាវាចរបាននៅរដូវប្រាំង រហូតមកដល់សុវណ្ណខែត្រ ។ ចុះទៅក្រោមទៀត ផ្ទៃទន្លេរីកធំ ក៏ប៉ុន្តែទឹករាក់កន្លែងខ្លះមានដុំថ្មរដិបរដុប ឬមានផ្លូវទឹកហូរខ្លាំង ប្រកបដោយគ្រោះថ្នាក់ រហូតដល់ដូនសា[១] ។ បន្ទាប់មក ទឹកចាប់ជ្រៅគ្មានប្រទះដុំថ្មទៀតទេ កប៉ាល់ប្រើចំហាយអាចប្រើពេលតែមួយថ្ងៃប៉ុណ្ណោះ ដើម្បីចុះមកដល់កេង (ល្បាក់ទឹកធ្លាក់) កាឡាហៃ[២] ។

គេអាចចុះផ្លូវទាំងអស់នេះបានតែដោយសារទូកតូចៗ ដោយប្រើពេល៤ម៉ោង នៅពេលទឹកស្រក ។ ចុះទៅក្រោមទៀត គឺជាទន្លេមួយដ៏ល្អ ដែលគេត្រូវប្រើពេល២ថ្ងៃ ដើម្បីចុះពីកេងយ៉ាពើត មកដល់កោះខុង ។ នៅចន្លោះខុង និងកោះខោន ផ្ទៃទន្លេមានកោះជាច្រើន ទឹករាក់ និងមានដុំថ្មលិចប៉ប្រះៗ បាតទូក នៅរដូវសម្រក ។ នាវា

---

[១] ពាក្យឡាវ «ដូន» មានន័យថា ភូមិ

[២] កេង មានន័យថាល្បាក់ ។ កាឡាហៃ ជាពាក្យត្រាប់តាមសំឡេងទឹកជួ ដែលហូរនៅចន្លោះដុំថ្ម ត្រូវនឹងពាក្យខ្មែរថា ឆាយ, កាឆាយ ។

ប្រើចំហាយអាចធ្វើដំណើរបានតែពេលទឹកឡើង ពីខែកក្កដា ដល់ ខែវិច្ឆិកា ។ បន្ទាប់មកទៀត គឺល្បាក់ខោន ដែលប្រៀបបាននៅនឹងសន្ទះរាំងទឹក ធ្វើឲ្យទឹកហូរធ្លាក់ចុះយ៉ាងខ្លាំង ដូចបាក់ទំនប់បញ្ចេញសំឡេងទ្រហឹងអឺងអាប់ បែកផ្កាត្រែងសក្បុស នៅសងខាងកោះខោន ។ គេឆ្លងកាត់កោះនេះតាមផ្លូវដែកតូចមួយ មានប្រវែងប្រហែល ៥គីឡូម៉ែត្រ ។

ចុះទៅខាងត្បូងកោះខោន ទន្លេមេគង្គរីកធំ គ្មានកោះគ្មានត្រើយ ទូកតូចៗអាចឆ្លងកាត់បានតែនៅរដូវសម្រក ។ នៅរដូវទឹកធំ ផ្ទៃទន្លេមានទទឹងពី៥ ទៅ៦គីឡូម៉ែត្រ ។ នាវាចរប្រព្រឹត្តទៅកាត់ព្រៃលិចទឹក ដែលគេមើលឃើញតែចុងឈើប៉ុណ្ណោះ ។

នៅខាងក្រោមស្ទឹងត្រែង និងដៃទន្លេខាងឆ្វេង មានផ្លូវព្រះត្រពាំង រួចកោះរ៉ុងហ្សូដ៏ធំ ដែលមានប្រវែង៤០ គីឡូម៉ែត្រ រួចហើយគឺសម្បូរ ដែលជារាជធានីសម្ភុបុរៈពីមុន ហើយដែលពួកហុល្លង់ហៅថា សំបាប្បឿ ។ បន្ទាប់មកគឺផ្លូវសម្បុកសម្បូរ រួចសម្បុកដែលចាប់ពីនេះទៅ ទឹកទន្លេហូរជាធម្មតា មានទទឹងពី ១៥០០ម៉ែត្រ ដល់ ២០០០ ម៉ែត្រ ហើយគេអាចធ្វើនាវាចរបានគ្រប់រដូវ ។

មកដល់ភ្នំពេញចតុម្មុខ ទន្លេមេគង្គបែកផ្លូវទឹកជាពីរធំៗ ដើម្បីរសាយហូរចូលទៅសមុទ្រ ។ នៅរដូវទឹកឡើង ទឹកទន្លេមេគង្គហូរចាក់តាមទន្លេសាបបញ្ច្រាសទៅជើង ចូលទៅបឹងទន្លេសាប ។ ដោយអំណាចទឹកហូរចូលដ៏ច្រើននេះ ទឹកបឹងទន្លេសាបឡើងរហូតដល់កម្ពស់៥ , ៦ ឬ៨ម៉ែត្រ ជន់លិចផ្ទៃដីដែលនៅជុំវិញ រហូតដល់ទៅចម្ងាយ ៥០ គីឡូម៉ែត្រ ។ ទឹកបឹងទន្លេសាបគ្របដណ្តប់វាលទំនាបធំធេង ពោរពេញទៅដោយទូក និងហ្វូងក្អែកទឹក ហ្វូងទុង ចចាតក្រសា ទោម ពណ៌ប្រផេះឬពណ៌កូលាប ដែលហិចហែលចាប់ត្រីដ៏សម្បូរ ។ អ្នកនេសាទខ្មែរ យួន និងចិន រាប់ពាន់នាក់ ចាប់យកត្រីទាំងអស់នេះ នៅខែកុម្ភៈ មីនា និងមេសា ។

ពេលផុតរដូវភ្លៀង វាលទំនាបទាំងឡាយរីងស្ងួតអស់ដោយកាំរស្មីព្រះអាទិត្យ មិនមានទឹកហូរចាក់ចូលដៃទន្លេទៀតទេ ។ នៅពេលនោះ ទឹកទន្លេសាបចាប់ហូរបញ្ច្រាសពីជើងមកត្បូងវិញម្តងក្នុងរយៈពេល៦ខែ ដើម្បីបញ្ចេញទឹកដែលហូរចូលកាលពី៦ខែមុន ។ ទឹកចាប់ស្រកចេញពីវាលទំនាបលិចទឹកនៅជុំវិញបឹងទន្លេសាបបន្តិចម្តងៗ រួចកាន់តែឆាប់រហ័សឡើងៗ ។ ទឹកបឹងទន្លេសាបក៏ស្រកចុះដែរ មកត្រឹមមាត់ទន្លេខ្លួនឯង រួចស្រកចុះថែមទៀត រហូតទាល់តែនៅសល់ជម្រៅត្រឹម ១ ឬ២ម៉ែត្រ ប៉ុណ្ណោះ នៅត្រង់កន្លែងខ្លះ ។ អាងទឹកដ៏ធំនេះ ក៏ប្រែក្លាយខ្លួនមកត្រឹមជាសមុទ្រតូចមួយ ដែលមានប្រវែងបណ្តោយ ១៥០គីឡូម៉ែត្រ និងទទឹង ៤៥គីឡូម៉ែត្រ ។

ទឹកហូរចូលមកក្នុងបឹងទន្លេសាបត្រាំត្រែងអស់រយៈពេល៦ខែ រួចទើបហូរចេញទៅវិញ នាំយកទាំងដីល្បាប់ទៅកាន់សមុទ្រផង បង្កើតបានជាដីដុះថ្មីនៅខាងត្បូងកូសាំងស៊ីន ។ ការបម្រើនដីល្បប់ឥតឈប់ឈរបានធ្វើឲ្យដីដុះកាន់តែច្រើនឡើងៗ ឯដើមកោងកាងប្រកបដោយឫសស្មុញស្មាញក៏ចាប់ដុះ ដូចជារឹតតែជួញទប់ល្បប់ឲ្យកកនៅ រួចមនុស្សក៏មកតាំងទីលំនៅបង្កើតបានជាភូមិស្រុកឡើង ។

ទឹកដីកម្ពុជាទាំងមូលចាប់កកើតឡើងតាមរបៀបនេះ ពីត្រឹមសម័យកាលមួយដែលមានរយៈពេលមិនជាយូរប៉ុន្មានពីយើងទេ គឺកកើតឡើងដោយដីល្បប់ ដែលធ្វើឲ្យទឹកទន្លេមេគង្គប្រែពណ៌ទៅជាលឿង ដីល្បប់នោះមិនមែនមកតាំងពីភ្នំហិមាល័យឯទីបេនោះទេ ព្រោះទឹកដែលហូរចេញពីភ្នំហិមាល័យមកនោះ មានតែប្រមាណជាមួយភាគមួយរយនៃទឹកទន្លេមេគង្គទាំងមូលប៉ុណ្ណោះ ។ តាមពិត ដីល្បប់ទាំងនោះបានមកពីដីនៃអាងទន្លេមេគង្គទាំងមូល ដែលទឹកភ្លៀងហូរនាំចូលមកក្នុងទន្លេ តាមរយៈដៃទន្លេទាំងឡាយ រួចហូរនាំរហូតទៅដល់សមុទ្រ ។ ទឹកដីកូសាំងស៊ីនសព្វថ្ងៃ ក៏កកើតឡើងរបៀបនេះដែរ ក្នុងសម័យកាលមុននេះបន្តិច ។

សូមពិនិត្យមើលផែនទីឥណ្ឌូចិន នោះលោកនឹងសង្កេតឃើញវិសាលភាពនៃអាងទន្លេគង្គាឥណ្ឌូចិន សម្បូរទៅដោយដៃទន្លេ ដែលគ្របដណ្តប់ពាសពេញផ្ទៃដីប្រមាណជា៨០០.០០០គីឡូម៉ែត្រក្រឡា ដៃទន្លេទាំងអស់នោះ ទទួលទឹកហូរមកពីស្ទឹងរាប់ពាន់ ហើយលោកអាចប្រមើលមើលឃើញទំហំទឹកយ៉ាងច្រើន ដែលហូរសំដៅមករកភ្នំពេញ ។ គឺទឹកទាំងនេះហើយដែលហូរនាំយកដីល្បាប់មកចាក់ តាំងពីច្រើនសតវត្សរ៍ មុនគ្រិស្តសករាជទៅទៀត បង្កើតបានជាប្រទេសកម្ពុជាទាំងមូល ហើយដែលយើងនឹងធ្វើការសិក្សាអំពីប្រវត្តិសាស្ត្រ ប្រទេសនេះនៅខាងមុខទៀត ។ គឺជាដីល្បាប់ ដែលផុសលេចចេញពីក្នុងទឹកមក ។ អ្នកស្រុកដែលមករស់នៅទីនេះចាំបាច់ត្រូវតែសង់ផ្ទះបន្តើតឲ្យខ្ពស់ផុតពីទឹកនៅពេលទឹកធំ ហើយផ្ទះមួយត្រូវមានទូកមួយ ។ ដីនេះល្អណាស់សម្រាប់ដំណាំស្រូវ ហើយទន្លេ ស្ទឹង បឹងបួ ត្រពាំង សម្បូរទៅដោយត្រីច្រើនឥតគណនា ទាំងអស់នេះអាចចិញ្ចឹមប្រជាជនបានច្រើនជាងសព្វថ្ងៃ ៦ដង ។ គឺជាដីមានជីជាតិ សើមហើយក្តៅ កាលបើទទួលបាននូវអារ្យធម៌ឥណ្ឌា ក៏រីកចម្រើនលើសម្ចាស់ដើម ទៅជាស្ថាបត្យកម្មមួយដ៏សម្បើមមហស្ចារ្យ ចម្លែកពោរពេញទៅដោយអត្ថន័យ ។ នេះជាអារ្យធម៌មួយគួរឲ្យចង់ស្គាល់នៅចុងបូព៌ា ដែលបានមកសណ្ឋិតនៅលើប្រជាជនប្រមាណជាសាមសិបលាននាក់ នៅក្នុងឥណ្ឌូចិនអស់រយៈកាល៨សតវត្សរ៍ ។ នោះគឺអាណាចក្រខ្មែរ ដែលមានទឹកដីកកើតឡើងអាស្រ័យដោយ «មេទឹក» ដោយទន្លេ គង្គានៃឥណ្ឌូចិន សម្បូរភោគផលមិនចាញ់ទន្លេនីល[៣] ដែលវែងជាង ធំជាង និងមានគុណប្រយោជន៍ល្អដូចទន្លេគង្គា នៅឥណ្ឌាដែរ ។ មុននឹងប្រគល់ឲ្យនូវគុណប្រយោជន៍ទាំងអស់ ដែលខ្លួនមានទន្លេមេគង្គត្រូវរង់ចាំនូវការកែឆ្នៃដូចដែលពួកហិណ្ឌូ ពួកមហាម៉ាត់ និងពួកអង់គ្លេស បានធ្វើទៅលើទន្លេគង្គា ដែលផ្តល់ទឹកទាំងអស់ បីដង បួនដង ផ្តល់នូវជីជាតិទៅឲ្យវាលទំនាបដែលស្ងួតហែងទៅដោយកម្តៅថ្ងៃ ។ វាលទំនាបទាំងនោះ នឹងមិនផ្តល់ផលស្រូវសូម្បីតែមួយគ្រាប់ បើគ្មានទន្លេទឹកមេនេះទេ ។ គឺទន្លេនេះឯង ដែលគ្របដណ្តប់ទឹកដីទាំងអស់នោះ ដើម្បីផ្តល់ទៅឲ្យនូវទឹកដោះ ពោលគឺ ទឹកសម្រាប់បាចស្រោចស្រព ផ្តល់ឲ្យនូវចំណីអាហារ ពោលគឺ ដីជាតិដែល

[៣] ទន្លេមេគង្គមានកម្លាំងចម្រើនដីល្បប់ស្មើនឹងទន្លេនីល គឺ១៥ភាគ១០.០០០, ១០ដងខ្លាំងជាងទន្លេរ៉ាំង, ៨ដងខ្លាំងជាងទន្លេសែន ។

ធ្វើឲ្យទឹកល្អក់កករ  ក៏ប៉ុន្តែធ្វើឲ្យទឹកមានជីជាតិ ។

អាស្រ័យហេតុនេះ សូមគោរពចំពោះទន្លេគង្គានៃឥណ្ឌូចិន ចំពោះមេទឹកដែលបានបង្កបង្កើតកម្ពុជា និងកូសាំងស៊ីនឡើង ។ ដើម្បីធ្វើឲ្យទឹកដីនេះក្លាយទៅជាប្រទេសមួយមានភោគទ្រព្យដូចជាប្រទេសអេហ្ស៊ីប គេនៅគ្រាន់តែត្រូវការការកែឆ្នៃពីមនុស្សដែលមករស់នៅទីនេះតែប៉ុណ្ណោះ ។ មនុស្សដែលមករស់នៅទីនេះនឹងមានសិរីដែលគេអាចសុំពីទន្លេនេះបាន ។

ទាំងអស់នេះ គឺជាឧបទ្វីបឥណ្ឌូចិន ដែលយើងនឹងពិនិត្យមើលប្រជាជនកកើតឡើង រីកធំធាត់ លាស់ផ្លែផ្កាបង្កបង្កើតផល រួចហើយស្រយុតស្រយង់ រលត់បាត់បង់ទៅ បន្ទាប់ពីបានរស់រានមានជីវិត បានធ្វើសង្គ្រាមបំផ្លិចបំផ្លាញរវាងគ្នានឹងគ្នា ដណ្តើមទឹកដីគ្នាបំពេញមហិច្ឆតារៀងៗខ្លួន ។ អ្វីទាំងអស់មានលក្ខណៈជាបណ្តោះអាសន្ន និងកើតមានឡើងតែមួយរយៈពេលប៉ុណ្ណោះ ។

ឥឡូវនេះ យើងពិនិត្យមើលបណ្តាប្រជាជនផ្សេងៗទៀត ដែលរស់នៅលើទឹកដីនេះកាលពីសតវត្សរ៍ទី១ ថាតើគេធ្វើយ៉ាងណានៅលើទឹកដីល្បាប់ដ៏ធំធេង ស្ទើរទឹកស្ទើរគោកនេះ ដែលត្រូវតែសង់ផ្ទះបន្តើតឲ្យផុតទឹក តើពួកគេធ្វើយ៉ាងណាទើបអាចបង្កើតជាក្រុម ជាប្រទេសមានអំណាច ដែលយើងនឹងសរសេរជាប្រវត្តិសាស្ត្រនេះ ។

## ២- អំពីប្រជាជន

នៅដើមគ្រិស្តសករាជរបស់អឺរ៉ុប និងដើមមហាសករាជ[៤] របស់ពួកហិណ្ឌូ ប្រជាជនដែលមករស់នៅក្នុងឥណ្ឌូចិនហាក់ដូចជាបញ្ច្រាបខ្លួនក្នុងហ្វូងប្រជាជនសព្វថ្ងៃនេះ ក៏ប៉ុន្តែនៅពេលនោះពួកគេរស់នៅបែកគ្នាជាកុលសម្ព័ន្ធ ឬជារដ្ឋអធិបតេយ្យតូចៗ  ច្បាំងគ្នាទៅវិញទៅមក  ហើយមិនទាន់ស៊ីវិល័យនៅឡើយទេ ។

### ពួកខ្មែរ ឬ កម្ពុជៈ

ប្រជាជនដែលកសាងប្រជាជាតិខ្មែរឡើង រស់នៅលើទឹកដីដែលមានឈ្មោះសព្វថ្ងៃថា កូសាំងស៊ីន និងកម្ពុជា  បើហោចណាស់ក៏រហូតដល់ល្បាក់ខោន និងប្រទេសសៀម[៥]  ផងដែរ ។

ប្រវត្តិសាស្ត្រដែលយើងនឹងសរសេរ គឺជាប្រវត្តិសាស្ត្ររបស់ប្រជាជនទាំងនោះ ដោយហេតុនេះ យើងមិនទាន់ចាំបាច់ត្រូវនិយាយពីពួកនេះ  ច្រើនពេកទេ  នៅពេលនេះ ។

---

[៤] មហាសករាជចាប់ផ្តើមនៅថ្ងៃទី២១ ខែមីនា ឆ្នាំ៧៩ នៃគ្រិស្តសករាជ ។

[៥] តាមមើលទៅ ពួកលេស្តែនៅក្នុងដែនទីរបស់ផ្តូលេមេ គឺជាប្រជាជនដែលរស់នៅលើទឹកដីកម្ពុជា និងកូសាំងស៊ីនបច្ចុប្បន្ន ។ រីឯទឹកដីរបស់ពួក សកៈនៅក្នុងរឿងមហាភារតៈ  ក៏គឺទឹកដីនេះដែរ ។

## ពួកចាម ឬ ចាម្ប៉ា

នៅពីខាងកើតពួកខ្មែរឬកម្ពុជៈ មានពួកចាមដែលជាពួកអ្នកផ្សងព្រេងឬជាចោរសមុទ្រ ធ្វើដំណើរចេញពីកោះធំៗដែលមានឈ្មោះសព្វថ្ងៃថា កោះស៊ូម៉ាត្រា កោះជ្វា និងប្រហែលជាចេញកោះតូចៗក្បែរៗនោះផងដែរ ។ ពួកនេះមកតាំងទីនៅតាមមាត់សមុទ្រ រួចហើយបានដណ្តើមយកទឹកដីមាត់សមុទ្រ ត្រង់កន្លែងកូសាំងស៊ីន និងអាណ្ណាមសព្វថ្ងៃ[៦] ទាំងស្រុងឬក៏មួយចំណែក មុនពួកហិណ្ឌូមកដល់ ។ បន្ទាប់មក អាស្រ័យដោយចំណងមេត្រីភាពជាមួយអ្នកស្រុកដែលរស់នៅតាមមាត់សមុទ្រនេះ ក៏សម្រេចបង្កើតបានជាជាតិមួយនៅរវាងសតវត្សរ៍ទី២ មុនគ្រិស្តសករាជ ដែលពួកចិនហៅថានគរលីនយី ហើយដែលក្រោយមកមានឈ្មោះថា ចាម្ប៉ា[៧] ។ ពួកនេះចេញមកពីប្រទេសដែលមិនទាន់ស៊ីវិល័យ គេពិតជាមិនទាន់ទទួលយកអារ្យធម៌ព្រាហ្មណ៍នៅឡើយ នៅពេលមកដល់ឥណ្ឌូចិន ក៏ប៉ុន្តែបន្ទាប់មក ពួកនេះបានទទួលយកការគោរពបូជា និងប្រពៃណីព្រហ្មញ្ញសាសនាខ្លះៗ គឺប្រហែលជានៅសតវត្សរ៍ទី១ នៃគ្រិស្តសករាជរបស់អឺរ៉ុប ។

ពួកនេះបានបង្កើតរដ្ឋសក្តិភូមិជាច្រើននៅតាមមាត់សមុទ្រ ជារដ្ឋពាក់កណ្តាលឯករាជ មានមេកោយរៀងៗខ្លួន ក៏ប៉ុន្តែ ចំណុះឲ្យស្តេចអធិរាជណាមួយជាផ្លូវការ តាមទំនៀមទម្លាប់ ទោះបីជាមិនសូវមានប្រសិទ្ធភាពក៏ដោយ ។ ពួកនេះក៏មានទីតាំងមួយចំនួននៅខាងទិសទក្សិណ និងនិរតី ផងដែរ ចាប់ពីបិញធន់រហូត ដល់កំពតដែយក្រោយមកត្រូវពួកកម្ពុជៈមកពីឥណ្ឌូដណ្តើមយក[៨] ។

---

[៦] សិលាចារឹក វ៉ូកាញ់ បញ្ជាក់ថា មានពួកចាមរស់នៅជ្រលងភ្នំញ៉ាត្រាង នៅសតវត្សរ៍ទី៣, ឯសិលាចារឹកមីសឺនថា មានចាមនៅឆកសមុទ្រ ទូរ៉ាន ។ ពួកចាមអាចនឹងមានវត្តមាននៅ ដានរ៉ាង និងបិញធន់ រួចហើយ ។

[៧] គេមិនបានដឹងអំពីឈ្មោះដែលប្រទេសនេះដាក់ឲ្យខ្លួនឯង មុននឹងប្រកាន់យកឈ្មោះចាម្ប៉ានេះទេ ។ ចំពោះឈ្មោះចាម្ប៉ានេះវិញ ប្រហែលជាគេដាក់តាមរដ្ឋចាម្ប៉ារបស់ពួកហិណ្ឌូមួយ ដែលស្ថិតនៅជិតភ្នំហិមាល័យ នៅផ្នែកខាងជើងរដ្ឋបញ្ចាប ។ អាចនិយាយថាឈ្មោះចាម្ប៉ានេះវា ប្រហាក់ប្រហែលនឹងឈ្មោះដើមថា ជាម ឬដែម ឬសាន នៅរវាងសតវត្សរ៍ទី២ ។ លោក ផ្តូលេមេ ដូចជាបានស្គាល់តែឈ្មោះរាជធានីបាលអង់វៃ ដែលលោកហៅថា សាបាន មានន័យថារាជធានីរបស់ចា ឬសានប៉ុណ្ណោះ ។ តាមមើលទៅ គឺឈ្មោះ សាន នេះឯង ដែលក្លាយមកជា ចាម្ប៉ា ហើយដែលពួកអ្នកនិពន្ធអារ៉ាប់ហៅថា ហ្សាង នៅសតវត្សរ៍ទី៨ ។

[៨] រឿងព្រេងកម្ពុជានិយាយថាមានស្តេចចាម៦អង្គសោយរាជ្យ ហើយមានពួកខ្មែរចេញមកពីឥន្ទ្រប្រាស្ថៈ ក្បែរទីក្រុងដេល្លីសព្វថ្ងៃ មកសុំរស់នៅត្រង់កន្លែងដែលពួកគេរៀបចំរួចស្រេចហើយ ក្រោយមកពួកខ្មែរនេះត្រូវរ៉ូវជាមួយពួកនាគ បះបោរប្រឆាំងដេញពួកចាមចេញទៅ ។ តាមពួកបញ្ញវន្តកម្ពុជាមួយចំនួនដែលជឿទៅលើរឿងព្រេង បានរៀបរាប់ទៀតថាពួកចាមបានគេចខ្លួនទៅដល់ប្រទេសលាវ រួចបង្កើតរដ្ឋចំប៉ាសាក់នៅទីនោះ ។ រឿងស្តេចចាម៦អង្គពិតជាមានសារសំខាន់ណាស់ ក៏ប៉ុន្តែរឿងព្រេងគ្មានអ្វីជាសំអាងច្បាស់លាស់ទេ ។ យើងនឹងត្រលប់មកមើលរឿងនេះទៀត នៅពេលក្រោយ ។

## ពួកលាវ

នៅពីខាងជើងទឹកដីដែលពួកខ្មែរ ឬកម្ពុជៈរស់នៅ មានប្រជាជនផ្សេងទៀតដែលមិនសូវជាស៊ីវិល័យរស់នៅដែរ គឺពួកលាវដើម ចាប់ពីខោនរហូតដល់ព្រំប្រទល់ខេត្តយុនណាន (ប្រទេសចិន) ។

រឿងព្រេងរបស់លាវនិយាយថា ពួកវិប្រជា (ក្រុមមនុស្សដែលមានការរៀបចំមិនទាន់គ្រប់សព្វ) នៅប្រទេសលាវមានដើមកំណើតចេញមកពីបុព្វបុរសរួមតែមួយ ។ ពាក្យថាវិប្រជាលាវនេះ មិនមែនសំដៅយកតែប្រជាជនលាវសព្វថ្ងៃប៉ុណ្ណោះទេ គឺរាប់បញ្ចូលទាំងប្រជាជនដែលរស់នៅក្នុងអាងទន្លេមេណាមខាងលើផងដែរ មុនពេលដែលពួកថៃមកដល់ ពួកមួងនៅតុងកឹង ពួកម៉ង់ ពួកចាវជី ឬពួកធុក មុនពេលជ័យជម្នះរបស់ពួកង៉ាមណន់ ឬអាណ្ណាម ព្រមទាំងរដ្ឋសាន មុនពេលពួកសានដែលមានដើមកំណើតថៃ មកដល់ ។

តាមរឿងព្រេងទាំងនោះ មេៗរបស់ពួកគេមានឋានៈជាគួន ដែលមាននៅបន្តរហូតមកដល់សព្វថ្ងៃនៅលាវក៏ដូចជានៅថៃ និងកម្ពុជាផងដែរ គឺជាឋានៈមន្ត្រីថ្នាក់ទាប ។

## ពួកមន ឬ ប៉ាំកាន

ពួកមនរស់នៅលើច្រាំងខាងត្បូងនៃទន្លេឥរាវតី និងទន្លេសាលូអង់ ។ ក្រោយពីរៀបចំកសាងរាជធានីប៉េហ្គូរួច ពួកនេះដាក់ឈ្មោះខ្លួនឯងថា ប៉េហ្គូ ដែរ ហើយបានត្រូវពួកអឺរ៉ុបកែដាក់ថាប៉ាំកាន[៩] វិញ ដើម្បីកុំឲ្យច្រឡំនឹងឈ្មោះរាជធានី និងឈ្មោះស្រុកផង ។

ពួកនេះធ្វើដំណើរចេញមកពីរមញ្ញទេស ៈ ដែលស្ថិតនៅតាមមាត់សមុទ្របឹងហ្កាល់ ។ នៅទីនោះមានទីក្រុងផ្សេងទៀត គឺតាវ័យ, តេណាស់សេរីម, មែរគុយ និងម៉ាតាបាន[១០] ដែលកំបាំងបាត់នៅពីក្រោយកោះជាច្រើនរយ ។ តាមពិត ពួកនេះមានដើមកំណើតនៅឥណ្ឌា គឺប្រហែលជានៅតាមមាត់សមុទ្រកូរ៉ូម៉ង់ដែល ឬអូរីស្សា ដែលពីមុនហៅថាកលិង្គៈ[១១] ។ ពួកនេះបានកសាងរាជធានីទីមួយរបស់គេ មានឈ្មោះថា តាលីង តាំងពីមុនគ្រិស្តសករាជ

---

[៩] ពាក្យប៉េហ្គូនេះ ប្រហែលជាត្រូវនឹងពាក្យខែសេរបស់ដែនទីដូលេមេ និងពាក្យបទសាទ្វីបរបស់ពួកហិណ្ឌូ ។

[១០] ភាសាអ្នកស្រុកហៅថា តាវ័យ, ទនៈស្រី, មន្ត្ត និងមធមៈ ។

[១១] កលិង្គៈជារដ្ឋមួយក្នុងឥណ្ឌាសម័យបុរាណ ស្ថិតនៅលើច្រាំងខាងកើតនៃឧបទ្វីបឥណ្ឌា បែរមុខមករកឥណ្ឌូចិនពីម្ខាងនៃឈូងសមុទ្របឹងហ្កាល់ ។ រដ្ឋនេះមានស្រុក៣ ដែលគេហៅរួមគ្នាថា ត្រៃលិង្គៈ ក្រោយមកក្លាយជា តិលិង្គៈ ឬតាលិង្គៈ ទីបញ្ចប់ជា តាលីង ដែលជាស្រុកដើមរបស់ពួកហិណ្ឌូដែលមករស់នៅឥណ្ឌូចិន ។ តាលីង ក៏ជាឈ្មោះដំបូងរបស់ពួកប៉ាំកាននៅភូមាផងដែរ ។ ទាល់តែច្រើនសតវត្សរ៍ក្រោយពេល ដែលគេមកដល់ឥណ្ឌូចិន ទើបពួកកលិង្គៈដូរឈ្មោះទៅជា មន, ម៉ង់ ឬម៉ាង វិញ ដែលជាឈ្មោះស្រុកចំណុះឥណ្ឌាសម័យបុរាណ គឺរមនញ្ញៈ ក្លាយទៅជារមញ្ញៈ ជាម័ញ ។

ហើយក៏ត្រូវបានគេហៅថាតាលីង១យ៉ាងនេះ រហូតដល់សតវត្សរ៍ទី១៨ តែពួកអឺរ៉ុបហៅថា តាលៀង ។ គឺចាប់ពីរាជធានីនេះហើយ ដែលពួកគេចេញទៅលុកលុយទឹកដីសុវណ្ណភូមិ គឺប្រទេសភូមាភាគខាងត្បូងសព្វថ្ងៃ ។ នៅសុវណ្ណភូមិនេះ ពួកកលិង្គៈដែលមកពីខាងត្បូង នឹងជួបជាមួយពួកភូមា ដែលចុះមកពីខាងជើង ។

មានពួកតាលីងមួយចំនួន ដើរកាត់ភ្នំតេណាស់សេរីម ទៅរស់នៅច្របូកច្របល់ជាមួយប្រជាជន ដែលមានដើមកំណើតជាខ្មែរនៅត្រង់ទឹកដីសៀមសព្វថ្ងៃ ។ មួយក្រុមទៀតចុះទៅក្រោម ទៅកាន់ទៀបកោះម៉ាឡាកា ទៅរស់នៅជាមួយអ្នកស្រុកដើមដែលមានរួចទៅហើយ ។

## ពួកសៀម ឬ ថៃ

នៅសតវត្សរ៍ទី១នៃគ្រិស្តសករាជ មិនទាន់មានពួកសៀមឬថៃ មកនៅជាមួយពួកខ្មែរ ចាមឬចាម្ប៉ា និងអាណ្ណាមទេ ។ មានប្រភពដើមចេញពីឥណ្ឌូ ត្រង់និរតីប្រទេសចិនពីសម័យកាលដ៏យូរលង់មួយ[១២] ពួកនេះ បានមកដណ្តើមយកទឹកដីនៅចន្លោះ យុនណានពីខាងកើត ទីបេពីខាងលិច និងភូមាភាគខាងលើពីខាងត្បូង ។ ពួកនេះ បានបង្កើតជាក្សត្រប្រទេស (Principauté) របស់ថៃបានចំនួន៦ នៅសតវត្សរ៍ទី២នៃសករាជយើង ដែលពួកចិនដាក់ឈ្មោះថា ណានឆាវ មានន័យថា ក្សត្រទិសខាងត្បូង ។ ពេលនោះពួកថៃមិនទាន់មានគំនិតចង់ធ្វើដំណើរមកត្បូង គឺមកកាន់ឥណ្ឌូចិននៅឡើយទេ ។ ពួកនេះ ប្រហែលជាធ្លាប់មានធ្វើចម្បាំងជាមួយ នឹងពួកភូមាខ្លះហើយនៅពេលនោះ ក៏ប៉ុន្តែ គ្មានឯកសារណាបញ្ជាក់ពីរឿងនេះទេ នៅសតវត្សរ៍ដំបូង១នៃគ្រិស្តសករាជ ហើយវាហាក់ដូចជាមិនទាន់មានសង្គ្រាមធំដុំទេ មុនសតវត្សរ៍ទី៩ ។ យើងមានតែពត៌មានស្តីពីរឿងណានឆាវ ចុះមកវាយភូមានៅសតវត្សរ៍ទី៧ប៉ុណ្ណោះ ។

ចំណែកទឹកដីដែលសព្វថ្ងៃយើងហៅថា សៀម កាលពីពេលនោះមានប្រជារាស្ត្ររួចហើយ គឺពួកដែលរស់នៅតាមមាត់ទន្លេមេណាមខាងក្រោម ដូចគ្នាទៅនឹងប្រជាជនដែលរស់នៅតាមមាត់ទន្លេមេគង្គខាងក្រោម រីឯពួកដែលរស់នៅតាមមាត់ទន្លេមេណាមខាងលើ ដូចគ្នាទៅនឹងប្រជាជនដែលរស់តាមមាត់ទន្លេមេគង្គ ក្នុងប្រទេសលាវដែរ ។

នាពេលនោះ តាមមើលទៅវាហាក់ដូចជាមានពួកបរទេស ចូលមករស់លាយឡំជាមួយពួកខ្មែរនៅត្រង់មេណាមភាគខាងក្រោម និងកណ្តាលស្រេចទៅហើយ គឺពួកមន ដែលយើងបានរៀបរាប់ពីខាងលើរួចហើយ

ពាក្យកលិង្គៈ ឬក្លីងនេះ សព្វថ្ងៃប្រជាជនកម្ពុជាប្រើសម្រាប់ហៅពួកហិណ្ឌូ រីឯស្រុកក្លីងគឺសំដៅយកឥណ្ឌាជាទូទៅ ។ ទាំងអស់នេះគឺដោយហេតុថា ពួកគេកន្លងមក ធ្លាប់មានទំនាក់ទំនងតែជាមួយពួកហិណ្ឌូនៅកូរ៉ូម៉ង់ដែល គឺពួកកលិង្គៈនេះឯង ។

[១២] ប្រហែលជា ៨សតវត្សរ៍ មុនគ្រិស្តសករាជ ។

តែការលាយឡំនេះ មិនអំណោយផលល្អដល់ការត្រួតត្រារបស់ពួកកម្ពុជៈទេ ដែលលាយសព្វល្អជាង ។ ចាប់ពីដំបូងម៉្លេះ ពួកមនខ្មែរនេះដូចជាប្រាកដខ្លួនឡើងជារដ្ឋមិនចំណុះ ហើយប្រដែនជាមួយនគរកម្ពុជា ។ដល់ពេលដែលពួកថៃ ឬសៀម ចុះមកច្បាំងដណ្ដើមយកទឹកដីនេះបាន ពួកថៃ ឬសៀមនេះ បានទទួលជាមរតកនូវកំហឹងរបស់ប្រជាជនដែលត្រូវគេត្រួតត្រា ហើយចាប់បន្តការប្រឆាំងទល់នឹងការត្រួតត្រារបស់ខ្មែរ រហូតដល់ពួកគេទទួលបាននូវជោគជ័យមកទល់នឹងសព្វថ្ងៃ គឺ៧សតវត្សរ៍ក្រោយពេលដណ្ដើមបានឥន្ទបត្តជាលើកទី១ ។

## បណ្ដាក្រុមខបនិវេសន៍ហិណ្ឌូ

នៅដើមនៃគ្រិស្តសករាជ វាហាក់ដូចជាមានក្រុមខបនិវេសន៍ (អ្នកចេញទៅនៅប្រទេសក្រៅ) ជ្វា-ម៉ាឡេ និងហិណ្ឌូ ដែលចេញផ្ទាល់មកពីប្រជុំកោះ អាំងស៊ុយឡាំង និងកលិង្គៈ មកតាំងនៅតាមមាត់សមុទ្រខាងត្បូង និងខាងលិចនៃឥណ្ឌូចិនរួចទៅហើយ ។ ក្រោយមក ពួកនេះបានច្របល់លាយគ្នាចូលជាមួយអ្នកស្រុកដើម គឺពួកខ្មែរនេះឯង ។ គឺក្រុមខបនិវេសន៍កលិង្គៈទាំងអស់នេះ ហើយដែលបានកសាងរាជាណាចក្រតូចៗ ប្រកបដោយអារ្យធម៌ហិណ្ឌូ នៅផ្នែកខាងត្បូងនៃឥណ្ឌូចិន រាជាណាចក្រទាំងនោះក្រោយមកក្លាយជាប្រទេសកម្ពុជា ឬស្រុកខ្មែរ ។ ចំណែកនៅតាមមាត់សមុទ្រខាងលិចនៃឥណ្ឌូចិន ដែលបែរមុខទៅរកឈូងសមុទ្របឹងហ្កាល់វិញ មានរាជាណាចក្រតូចៗ ដែលពួកព័រទុយហ្គេ ហៅថាមែរតាបាន, មែរគុយ, តាវ៉យ, តេណាស់សេរីម ព្រមទាំងរាជាណាចក្រតូចៗនៅតាមឆ្នេរសមុទ្រខាងកើតនៃឧបទ្វីបកោះម៉ាឡាកា មានលីហ្គ័រ ឬស្រីធម្មរាជនគរជាដើម ។

## អាណ្ណាម ឬ តុងកឹង

កាលពី២សតវត្សរ៍មុនគ្រិស្តសករាជ នៅប៉ែកពាយ័ព្យនៃតុងកឹងសព្វថ្ងៃ មានរាជាណាចក្រតូចមួយដែលពួកចិនហៅថាធុក ឬណាមយែ ។ អ្នកស្រុករដ្ឋនេះមានអម្បូរជាមន ប៉ុន្តែ ពួកនេះប្រហែលជាស្ថិតនៅក្រោមការត្រួតត្រារបស់ពួកអាណ្ណាម ដែលមកពីភាគខាងត្បូងនៃទន្លេយ៉ង់សេក្យាង ឬទន្លេខៀវ ។ រាជធានី គឺភានធូ ។

ព្រះរាជាមួយអង្គនៃរាជាណាចក្រនេះ ព្រះនាមមន ឬ យ៉ាវជី បានប្រកាសសង្គ្រាមជាមួយចិន រួចវាយដណ្ដើមយកបានខេត្តក្វាងទុង (កាលនោះមានឈ្មោះថា តៃវៀត), ខេត្តក្វាងសេ និងភូគៀន (កាលនោះ មានឈ្មោះថា ដុងអូ), ព្រមទាំងរដ្ឋតូចៗមួយចំនួនទៀត ។ ព្រះអង្គត្រូវបានព្រះចៅអធិរាជចិនទទួលស្គាល់ថា ជាព្រះរាជានៃណានណាម ឬអាណ្ណាមដែរ ។ អាណ្ណាមនាពេលនោះ គឺតុងកឹងសព្វថ្ងៃនេះឯង ។

ចាប់ពីពេលនោះមក រាជាណាចក្រធុក ក្រោមឈ្មោះថ្មីថា អាណ្ណាម ឬណានណាម មានទឹកដីលាតសន្ធឹងចាប់ពីព្រំដែនភាគខាងត្បូងយុនណាន រហូតដល់ឈូងសមុទ្រតុងកឹង និងរហូតដល់ព្រំដែនភាគខាងជើងនគរចាម្ប៉ា គឺអាណ្ណាមសព្វថ្ងៃ ។

រាជាណាចក្រនេះ ដែលចិនហៅថាណាមយែប្មុណាមវៀតនៅឆ្នាំ១១១ (មានន័យថាទក្សិណាបែកខ្វែក) បន្ទាប់មក បានត្រូវធ្លាក់នៅក្រោមការត្រួតត្រារបស់ឧត្តមសេនិយមេទ័ពចិន ដែលព្រះចៅអធិរាជចិនតែងតាំងឲ្យធ្វើជាចៅហ្វាយខែត្រ ។ ពួកនេះគ្រប់គ្រងអំណាចតៗគ្នា ពីឪពុកដល់កូន ហើយពង្រឹងអំណាចតែក្នុងត្រួសារឯងយ៉ាងដូច្នេះ ។

ពួកឧត្តមសេនិយ ចៅហ្វាយខែត្រទាំងនេះ បានបែងចែកទឹកដីព្រះរាជាណាចក្រអាណ្ណាមជា ៩ខែត្រ ហៅថាក្វាន់ ក្នុងនោះមាន ៤ស្ថិតនៅចិនភាគខាងត្បូង ៣នៅតុងកឹងខាងក្រោម និង២ទៀតនៅតុងកឹងខាងលើ ។ ចំណែកឯផ្នែកកណ្ដាលនៃរាជាណាចក្រអាណ្ណាម ដែលសោយរាជ្យដោយឧបរាជចិន មានចែកចេញជា ៣ក្វាន់ គឺ ក្វាន់យ៉ាវជី, គូជឿន និងញូតណាម ។ ក្វាន់ទាំងនេះ គេហៅថាទួងក្វាង ក្រោយមកក្លាយជា តុងកឹង ដែលសព្វថ្ងៃនេះជាឈ្មោះរបស់ប្រទេសទាំងមូល និងស្ថិតនៅចន្លោះ យុនណាន លាវ ឈូងសមុទ្រតុងកឹង ដូវភ្នំអាណ្ណាម និងមាត់ប្រកអាណ្ណាម ។

គេដំណាលថា នៅឆ្នាំ១៦៦នៃគ្រិស្តសករាជ មានពួកឈ្មួញដែលអះអាងថា ខ្លួនជារាជទូតរបស់ព្រះអធិរាជរ៉ូម៉ាំង ព្រះនាមថាម៉ាក់អូរ៉ែល ហើយដែលប្រហែលមិនមែនមានសញ្ជាតិរ៉ូម៉ាំងទេ[១៣] បានមកចុះសំពៅនៅខាងត្បូងនគរយ៉ាវជី ឬអាណ្ណាមនេះ ។

តាមមើលទៅ នៅក្នុងដែនទីរបស់ផ្តូលេមេ ហាណូយគឺអាកាណាការ៉ា ហើយប្រជាជនដែលរស់នៅត្រង់ពាមទន្លេក្រហម បានហៅខ្លួនឯងតាមរបៀបសាមញ្ញថា អ៊ិនដូយ ។

## ពួកម៉ាក៉ាម៉ា ឬ មិយ៉ាម៉ា ឬ ភូមា

នៅពាយ័ព្យឥណ្ឌូចិន មានទឹកដីដែលមានឈ្មោះសព្វថ្ងៃថា ភូមាខាងលើ ដែលមានពួកម៉ាក៉ាម៉ារស់នៅ ពួកនេះក្រោយមកបានដូរឈ្មោះជាភូមាវិញ ។ ពួកនេះចុះមកពីទីបេ កាលពីរវាង២ ឬ៣សតវត្សរ៍មុនគ្រិស្តសករាជ រួចមកដណ្ដើមយកទឹកដីរបស់ពួកការ៉ែននៅ ។ ពួកការ៉ែននេះ ជាប្រជាជនគ្មានអារ្យធម៌ស្លូត ចូលចិត្តធ្វើកសិកម្ម ។ អាស្រ័យដោយភាពអៀនប្រៀន និងទំនៀមទម្លាប់អន់ថយ ពួកគេត្រូវរស់នៅឆ្ងាយពីទីក្រុងរហូតមកដល់សព្វថ្ងៃនេះ ។

វត្តមានរបស់ពួកម៉ាក៉ាម៉ា នៅត្រង់ផ្នែកខាងលើនៃទន្លេឥរាវតីនេះ បានបង្ខំឲ្យពួកសាន ដែលមានអម្បូរថៃដែរ ហើយដែលយើងនឹងលើកមកនិយាយខាងក្រោមនេះ ត្រូវគេចខ្លួនទៅរស់នៅឯស្រុកលាវ ហើយពេលធ្វើ

---

[១៣] នៅឥណ្ឌា គេហៅទាំងពួកក្រិក ពួកអ្នកស្រុកទៀបកោះអារ៉ាប់ និងពួកអ្នករស់នៅខាងលិចស្រុកពែរ្ស ថាជា រ៉ូម៉ាំង រហូតមកដល់ពេលថ្មីៗនេះ ពីព្រោះពួកនោះធ្លាប់ជាចំណុះរបស់រ៉ូម ។

ដំណើរទៅដល់ឥណ្ឌូចិន ក៏បង្កើតបានជាក្សត្រប្រទេសជាច្រើន រស់នៅឆ្ងាយពីសមុទ្រ ពីទន្លេដោយមិនគិតពីការអភិវឌ្ឍន៍ឡើយ ។

ពួកម៉ាវ៉ាម៉ា បានទុកឲ្យពួកសានរស់នៅលើទឹកដីផ្នែកខាងជើង ហើយមិនបានរំខានពួកនេះក្នុងការវាតយកទឹកដីឯខាងកើតទេ ពីព្រោះពួកម៉ាវ៉ាម៉ាមានបំណងចង់តែចុះមកខាងក្រោមទន្លេឥរាវតី សំដៅមករកសមុទ្រ ដោយគ្មានចង់វាតយកទឹកដីប្រទេសលាវឡើយ ។

តាមមើលទៅ នៅដើមសតវត្សរ៍នៃគ្រិស្តសករាជ ពួកភូមា ឬម៉ាវ៉ាម៉ាបានដណ្ដើមយកបានទឹកដី ដែលសព្វថ្ងៃនេះ គឺប្រទេសភូមាភាគខាងលើរួចទៅហើយ ។

## ពួកសាន

នៅខាងលិចប្រទេសលាវភាគខាងលើ បន្ទាប់ពីទឹកដីមួយកន្លែងនៅលើច្រាំងខាងស្ដាំនៃទន្លេមេគង្គ ដែលជាចំណែកមួយនៃព្រះរាជាណាចក្រហ្លួងប្រាបាងសព្វថ្ងៃនេះ មានប្រជាជនមួយក្រុមរស់នៅ គឺពួកសាន ។ ដូចដែលបានរៀបរាប់ពីខាងលើរួចមកហើយ ពួកសាននេះមានអម្បូរជាមួយពួកថៃ ឬសៀម ។ ប្រជាជនសាននេះចុះមកពីកន្លែងមួយ ដែលក្រោយមកក្លាយជារាជាណាចក្រតាលី ។ ពួកនេះបានមករស់នៅពីខាងកើតពួកភូមា នៅពេលដែលពួកភូមានេះកំពុងវាយដណ្ដើមយកទឹកដីពីពួកមន ឬប៉ាកាន តែត្រូវពួកមនវាយដេញឲ្យរត់ឡើងទៅផ្នែកខាងលើនៃទន្លេឥរាវតីវិញទៅ ជាកន្លែងដែលពួកមននេះធ្លាប់នៅកាលពី ពីរ-បីសតវត្សរ៍មុន ។

នៅដើមគ្រិស្តសករាជ ពួកសាន បានត្រួតត្រាពេញទឹកដីដែលពួកគេរស់នៅសព្វថ្ងៃនេះ ដោយបង្កើតបានជាក្សត្រប្រទេសមួយចំនួន មានស្វ័យភាពរៀងៗខ្លួន ក៏ប៉ុន្តែទាំងអស់គ្នាស្ថិតនៅក្រោមការត្រួតត្រារបស់ព្រះចៅអធិរាជមួយអង្គ ការត្រួតត្រានោះអាចមានតែនាម និងអាចជាការត្រួតត្រាពិតប្រាកដតែនៅក្នុងកាលៈទេសៈខ្លះប៉ុណ្ណោះ ។

ក្សត្រប្រទេសទាំងអស់នោះស្ថិតនៅឆ្ងាយពីសមុទ្រ ពីទន្លេធំៗ និងពីពាណិជ្ជកម្មផងដែរ ដូចនេះពួកគេមិនសូវជាលូតលាស់ប៉ុន្មានទេ ។ ដោយហេតុនោះ ពួកគេខិតខំបង្កបង្កើនផលតែលើដីដែលគេដណ្ដើមបានពីពួកលាវប៉ុណ្ណោះ ហើយមិនបានយកចិត្តទុកដាក់នឹងស្ថាបនាផ្លូវថ្នល់ធ្វើដំណើរអ្វីឡើយ ។

គេគិតថា មានកុលសម្ព័ន្ធសានមួយនៅផ្នែកខាងលើរដ្ឋអាសាមដែរ ប៉ុន្តែគឺជាក្សត្រប្រទេសមួយ ដែលមិនសូវជាមានសារសំខាន់ ប៉ុន្មានទេ ។

## អំពីប្រទេសចិន

នៅដើមគ្រិស្តសករាជ ប្រទេសចិនបានមានអត្ថិភាពប្រហែលជា៣០០០ឆ្នាំរួចមកហើយ ។ ពួកចិន មាន

អារ្យធម៌រីកចម្រើនខ្លាំងណាស់ទៅហើយ គឺមានទស្សនវិជ្ជាប្រកបដោយគតិបណ្ឌិតតាំងពី៥សតវត្សរ៍មុនមកម៉្លេះ និងមានសាសនាច្រើន ដែលមានមូលដ្ឋានស្ថិតនៅលើសីលធម៌ប្រកបដោយវិចារណញ្ញាណ និងនៅលើការគោរពបូជាបុព្វបុរសព្រមទាំងទំនៀមទម្លាប់បុរាណផង ។

ពេលនោះ ប្រទេសចិនមិនធំដូចសព្វថ្ងៃនេះទេ ។ បណ្តាខែត្រខាងលិចមិនស្ថិតនៅក្រោមអាណាព្យាបាលរបស់ពួកគេទេ ។ ប្រទេសទីបេកាលនោះ នៅឯករាជ មិនទាន់ជាទឹកដីរបស់ចិននៅឡើយ ។ ហើយចិនប្រហែលជាត្រួតត្រាបណ្តាខែត្រដែលនៅឆ្ងាយពីរាជធានី មិនជាច្រើនប៉ុន្មានទេ ។ អំណាចរបស់ចិននៅពេលនោះ គឺជាអំណាចដែលមានតែឈ្មោះប៉ុណ្ណោះ ចំពោះប្រជាជនជាច្រើននៅទិសខាងជើង និងខាងនិរតី ។ ពួកអាណ្ណាមនៅខាងត្បូង និងពួកកូរ៉េនៅខាងជើង ដែលមិនត្រឹមតែមិនទទួលយកអនុត្តរភាពរបស់ចិនប៉ុណ្ណោះទេ ថែមទាំងបះបោរប្រឆាំងទៀតផង ។

ទោះជាយ៉ាងនេះក្តី នៅកន្លែងណាដែលចិនរាតអំណាចទៅដល់ ពួកគេផ្សព្វផ្សាយអារ្យធម៌របស់គេ ហើយប្រជាពលរដ្ឋទទួលយកទំនៀមទម្លាប់ ឧត្តមគតិ ប្រពៃណី និងទស្សនវិជ្ជារបស់គេ ។

អ្វីដែលបានរៀបរាប់មកខាងលើនេះគឺជាអ្វីដែលមាននៅលើទឹកដីឥណ្ឌូចិន នៅដើមគ្រិស្តសករាជ គឺមានប្រជាជនដែលរស់នៅក្នុងឧបទ្វីបឥណ្ឌូចិន ប្រជាជនដែលគំរាមកំហែងមកពីខាងត្បូង និងប្រជាជន ដែលរស់នៅភាគខាងជើងដែលនៅតែមានឥទ្ធិពលយ៉ាងខ្លាំង និងមានប្រសិទ្ធភាពមកលើឥណ្ឌូចិន រហូតដល់សព្វថ្ងៃនេះ ។

នៅពេលដែលនិយាយអំពីប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជា យើងត្រូវតែនិយាយអំពីប្រទេសទាំងអស់នោះដែរ ពីព្រោះក្រៅតែពីប្រទេសចិន និងប្រទេសឥណ្ឌាដែលច្រើនតែមានទំនាក់ទំនងមិត្តភាពជាមួយកម្ពុជា ប្រទេសជិតខាងឯទៀតច្រើនតែមានចម្បាំងជាមួយកម្ពុជា និងមានប្រទេសជាច្រើនដែលកម្ពុជាបានវាយកាន់កាប់ដាក់ជាចំណុះ ។

ឥឡូវនេះ យើងពិនិត្យមើលថាតើអាណាចក្រខ្មែរដ៏ខ្លាំងក្លាមួយនេះចាប់ផ្តើមឡើងយ៉ាងដូចម្តេច រីកចម្រើនយ៉ាងណា ហើយតើក្រោយពីដណ្តើមបានទឹកដីឥណ្ឌូចិនភាគកណ្តាល តាំងពីជើងរហូតមកដល់ត្បូង ពោលគឺអាងទន្លេមេគង្គទាំងមូលរួចហើយ ហេតុអ្វីក៏ស្រាប់តែត្រូវកាត់ផ្តាច់អំពីនគរចំណុះទាំងឡាយអស់រលីង នៅសល់តែទឹកដីតូចមួយយ៉ាងដូច្នេះ ។ យើងនឹងស្រាវជ្រាវមើល បន្ទាប់មក ថាតើការមកដល់របស់ពួកបារាំងបានជួយស្រោចស្រង់ប្រទេសនេះពីកណ្តាប់ដៃពួកសៀមដែលជាសត្រូវ១០០០ឆ្នាំ និងពីកណ្តាប់ដៃពួកអាណ្ណាម ដែលឈ្លោះជាមួយខ្មែរ៣សតវត្សរ៍រួចមកហើយដោយរបៀបណា ។ នៅទីបញ្ចប់ យើងនឹងពិនិត្យមើលថា ក្រោមឥទ្ធិពលនៃអារ្យធម៌បារាំង ប្រទេសនេះហាក់ដូចប្រែជាមានវាសនាមួយផ្សេង ដទៃពីវាសនានៃការធ្លាក់ចុះរបស់ខ្លួនដែលត្រៀមទុកដោយខ្សែកកាលពីថ្មីៗនៅឡើយ ។

# ជំពូកទី១

## ១- អំពីប្រទេសហ្វូណន

ពួកចិន ដែលស្គាល់ឥណ្ឌូចិនតាំងតែពី២០០០ឆ្នាំមុន ដោយមានពួកអ្នកដើរសំពៅមកចុះចតជាញឹកញយផងនោះ បានហៅទឹកដីនៃអាងទន្លេមេគង្គខាងក្រោមរហូតដល់មាត់សមុទ្រខាងត្បូងថា ហ្វូណន ឬប៉ូណន ។ តាមមើលទៅ ពួកវិប្រជាឬកុលសម្ព័ន្ធដែលរស់នៅទីនោះ មិនបានស្គាល់ឈ្មោះដែលចិនដាក់ឲ្យគេនេះទេ[១] ។

បើតាមប្រជាជនកម្ពុជា និងតាមរឿងព្រេង អ្នកស្រុកបានហៅចំណែកដែលត្រូវនឹងកម្ពុជាសព្វថ្ងៃថា គោកធ្លក ឬនគរគោកធ្លក[២] ។

គឺពេលក្រោយយូរមកទៀតទើប អ្នកស្រុកប្រែហៅថា ស្រុកខ្មែរវិញ រួចក្រោយៗមកទៀតហៅ កម្ពុជា ជាសំស្ក្រឹតថា កម្ពុជា ជាឈ្មោះដែលជ្រើសរើសដោយពួកអ្នកមកច្បាំងដណ្តើមស្រុក និងអ្នកដែលនាំអារ្យធម៌ហិណ្ឌូមកផ្តល់ឲ្យ ។

ប៉ុន្តែ បើទោះជាឈ្មោះនោះជាពាក្យចិន ជាពាក្យរបស់អ្នកស្រុក ឬក៏ជាពាក្យសំស្ក្រឹតក្តី ក៏នៅឥណ្ឌាភាគខាងជើងគេស្គាល់ប្រទេសខ្មែរក្រោមឈ្មោះថា សក្កទ្វីប មានន័យថា ទ្វីប ឬទឹកដីរបស់ដើមសកៈ គឺដើមម៉ៃសាក់ ។ ដើមម៉ៃសាក់ខុសគ្នាពីដើមធ្លក ក៏ប៉ុន្តែដើមឈើទាំង២មានផ្លែដូចគ្នា ដែលពួកក្មេងៗតែងយកមកកកេរ ហើយគេអាចយកមកចម្រាញ់យកប្រេងបាន ។ បើដូច្នេះ គេអាចទទួលស្គាល់ថា ឈ្មោះដែលគេដាក់ឲ្យកម្ពុជា ទោះជាដាក់ឲ្យដោយប្រជាជនខ្លួនឯង ឬក៏ដាក់ឲ្យដោយពួកហិណ្ឌូក្តី គឺជាពាក្យតែមួយ ហើយដោយហេតុនេះ ប្រពៃណីរបស់ប្រជាជន គឺពិតជាត្រូវនឹងសញ្ញាណរបស់ហិណ្ឌូដែរ ។

គួរកត់សម្គាល់ថា នៅសតវត្សរ៍ទី២នៃគ្រិស្តសករាជ ពួកក្រិក និងរ៉ូម៉ាំង ស្គាល់ស្រុកខ្មែរ ដោយដែនទីរបស់

---

[១] ក៏ប៉ុន្តែពាក្យនេះហាក់ដូចជាមិនមែនជាពាក្យរបស់ចិនទេ ។ វាមិនមានន័យថាខែត្រខាងត្បូង ដូចដែលគេបាននិយាយនោះទេ ពីព្រោះថា តាម ធម្មតា នៅក្នុងភាសាចិន គុណនាមនៅពីមុខនាមជានិច្ច ។ ម្យ៉ាងទៀត ពាក្យ ហ្វូ មិនមានន័យថាខែត្រទេ គឺមានន័យថា ទីក្រុងតូច លំដាប់ថ្នាក់ទី៣ តែប៉ុណ្ណោះ ។ ដូចនេះពាក្យ ហ្វូណន គ្មានន័យទេ ។ តែពាក្យនេះអាចជាការសសេរចម្លងឈ្មោះតាមពាក្យអ្នកស្រុកណាមួយ ដែលចិនអានមិនច្បាស់ ។ នៅសតវត្សរ៍ទី២ នៃគ្រិស្តសករាជ ហ្វូណន ជាទម្រង់ចុងក្រោយរបស់ ប៉ូណន ។ ក៏ប៉ុន្តែ តើត្រូវពន្យល់ការដែលបាត់ពាក្យ ប៉ូណន ទៅដោយរបៀបណា ក្នុងភាសានិយាយ ក្នុងរឿងព្រេង ឬក្នុងសិលាចារឹក?

[២] តាមកំណត់ត្រាមួយដែលផ្ញើពីទីក្រុងវ៉េនៅឆ្នាំ១៩០៨ ជូនលោក លូស ជារ៉េស៊ីដង់ជាន់ខ្ពស់បារាំងប្រចាំកម្ពុជាបាននិយាយថា ខែត្រ យ៉ាឌិញ កាលពីអតីតកាលដ៏យូរមកហើយមានឈ្មោះថា ភូណន ។ ក្រោយមកដូរជា ធុងចានឡាប់ និងក្រោយមកទៀតថា ត្រាយដុងដូ ។ ចាប់ពីឆ្នាំ១៧០១មក ក៏ប្រែទៅជា ភូយ៉ាឌិញ រហូតមក ។

ផ្លូលេមេ ដែលគូសឡើងតាមការនិទានរបស់អ្នកធ្វើដំណើរតាមសមុទ្រ ដែនទីនោះដាក់ឈ្មោះឲ្យថា ជាស្រុករបស់ពួកលេស្តៃ[៣] ដែលខុសគ្នាឆ្ងាយណាស់នឹងពាក្យកម្ពុជា ។ លោកវរសេនីយ៍ឯក ហ្សេរីនី បានសន្និដ្ឋានថា ឈ្មោះនេះមិនមែនជាឈ្មោះដែលថាតាមពាក្យអ្នកស្រុកដើមនោះទេ តែគឺជាពាក្យប្រែទៅវិញ ។ បើនិយាយដូច្នេះ លេស្តៃជាពាក្យក្រិកដែលមានន័យថា ចោរ ឬចោរសមុទ្រ ។ ខ្ញុំនៅមិនទាន់យល់នៅឡើយអំពីនិរុត្តិសាស្ត្រ ដ៏ប៉ិនប្រសប់បែបនេះ តែខ្ញុំហាក់ដូចជាទាល់ប្រាជ្ញ ក្នុងការដែលចង់ពន្យល់ពាក្យខ្មែរ បែរជាលេចពាក្យ លេស្តៃ ទៅវិញ ។ តែលោកវរសេនីយ៍ឯកបានរំលឹកថា ពាក្យកម្ពុ ដែលមាននៅក្នុងសិលាចារឹកជាឈ្មោះរបស់ទេវៈបុព្វបុរសរបស់ កម្ពុស្វ័យម្ភុ ដែលមានន័យថាកើតមានឡើងដោយខ្លួនឯង ពោលគឺ ព្រះព្រហ្ម ។ ហើយពាក្យនេះជាភាសាសំស្ក្រឹតមានន័យថា ចោរ ឬចោរសមុទ្រ ។ ដោយហេតុនេះ លោកវរសេនីយ៍សន្និដ្ឋានថា ពាក្យក្រិកថា លេស្តៃ ត្រូវគ្នានឹងពាក្យកម្ពុ ពាក្យទាំងពីរម៉ាត់នេះមានន័យថា ចោរ, ចោរសមុទ្រ ឬបើហោចណាស់ ក៏សំដៅយកពួកអ្នកដែលរស់នៅជាក្រុមប្រដាប់ដោយអាវុធដែរ ។ លោកសន្និដ្ឋានបន្តទៀតថា នៅស្រុកនេះ អ្នកស្រុកប្រកបមុខរបរជាចោរសមុទ្រ ឬបើពុំនោះទេ ក៏ត្រូវជាកូនចៅរបស់មេចោរសមុទ្រ ឬចោរប្លន់តាមសមុទ្រណាម្នាក់ ដែលបុគ្គលិកលក្ខណៈ បានរលុបបាត់តាមពេលវេលាទៅហើយ នៅសតវត្សរ៍ទី៥[៤] ។

ទាំងរឿងព្រេង ទាំងប្រពៃណីកម្ពុជា និយាយថា ពួកអ្នករស់នៅក្នុងនគរគោកធ្លកមានឈ្មោះថា នាគ ដែលក្រោយមកដូរជាខ្មែរ រួចជាកម្ពុជាវិញ[៥] ។ តែវាមានមូលហេតុដែលអាចឲ្យជឿបានថា ពាក្យ«នាគ»នេះ មិនមែនជាឈ្មោះដើមដែលគេហៅខ្លួនគេនោះទេ ប៉ុន្តែ គឺជាពាក្យដែលពួកនិរប្រវេសន៍ហិណ្ឌូដាក់ឲ្យ ។ ពាក្យដែលគេហៅ

---

[៣] ស្រុកនេះមានរាជធានីឈ្មោះ សាបេ ស្ថិតនៅខាងជើងព្រៃនគរ ។ ឈ្មោះនេះ ប្រហែលជាពាក្យម៉ាឡេ ហើយដាក់យ៉ាងនេះគឺយកតាមទីក្រុងសាបេនៅកោះស៊ូម៉ាត្រា ។

[៤] ការបកស្រាយនេះអាចនឹងត្រឹមត្រូវ ក៏ប៉ុន្តែដូចជាគួរឲ្យសង្ស័យខ្លាំងណាស់ ។ គឺជាការពន្យល់ដែលអង់អាចហួស ហើយក៏គ្មានភស្តុតាងបញ្ជាក់ច្បាស់លាស់ដែរ ។

[៥] នៅក្នុងសិលាចារឹក គេសរសេរ កម្វុជា ក៏ប៉ុន្តែកម្ពុជាមានគេនិយមច្រើនជាង ។ មានគេពន្យល់ថា កម្វុជា ឬកម្ពុជា អាចក្លាយមកពីពាក្យម៉ាឡេថា សិមបូជៈ ដែលជាឈ្មោះ របស់ប៉ាឡាំបាង កាលពីយូរយារណាស់មកហើយ ហើយដែលចិនហៅមិនច្បាស់ថាសានហ្វុស៊ី ។ ខ្ញុំមិនឲ្យតម្លៃដល់ការបកស្រាយនេះទេ តែខ្ញុំជឿថា ទោះជាពាក្យកម្ពុជាក្លាយមកពីឈ្មោះជាភាសាម៉ាឡេរបស់ទីក្រុងមួយ ឬក៏ក្លាយមកពីទេវៈបុព្វបុរសកម្ពុក្តី ពួកខ្មែរទទួលយកពាក្យនេះសម្រាប់ការចារុំលើថ្មពីព្រោះវាធ្វើឲ្យនឹកឃើញជាតិសាសន៍មួយនៃឥណ្ឌារបស់ពួកអារ្យាង ហើយធ្វើឲ្យពួកគេមានប្រភពដើមថ្លៃថ្នូរ និងប្រកបដោយជោគជ័យ ។ គឺដូចគ្នាបែបនេះឯង ដែលក្រោយមក ពួកគេហៅអង្គរធំ ឬមហានគរ ថា ជាឥន្ទ្រប្រាស្ថៈ-ឥន្ទបាទ ដែលជាឈ្មោះរបស់ទីក្រុងមួយនៅហិណ្ឌូស្ថាន ប្រហែល ១៥គីឡូ-ម៉ែត្រ ខាងត្បូងទីក្រុងដែលី ។

ខ្ជូនគេនោះ គឺប្រហែលជាពាក្យដែលមាននៅរហូតដល់សព្វថ្ងៃ គឺខ្មែរនេះឯង គ្រាន់តែពាក្យនេះ មានសរសេរប្លែកៗគ្នា ទៅតាមពេលវេលា ទីកន្លែង និងតាមគ្រាមភាសារបស់អ្នកស្រុកនីមួយៗ គឺមានពាក្យ ខម, កៅមេ, ក្មេន, ក្មឺ, គិមី, គួរ, ក្មៀរ, កុមារ ដែលជាពាក្យតាមភាសាអ្នកវិប្រជាដើម[៦] ។

នៅចំពោះមុខពួកបរទេសហិណ្ឌូ ដែលមានអារ្យធម៌ជឿនលឿនជាងពួកអ្នករដ្ឋវាសី (អ្នកនៅក្នុងរដ្ឋ) ដែលមិនសូវមានអាវុធផង ហើយក៏អាចជាអ្នកចូលចិត្តសន្តិភាពជាងផង មិនបានវាយតបតទេ គេដកថយទុកកន្លែងឲ្យពួកនោះ តាំងទីលំនៅកសាងបានជាក្រុមខបនិវេសន៍ពាណិជ្ជករ ដែលធ្វើដំណើរចេញចូលស្រុកដោយស្ថិតនៅដាច់ស្រឡះពីអ្នកស្រុកដើម តែក្រោយមកបានក្លាយទៅជាមេដឹកនាំស្រុកវិញ ។

ក្រុមខបនិវេសន៍ដំបូងៗជាក្រុមខបនិវេសន៍ពួកជ្វាមកពីកោះជ្វា ឬពួកម៉ាឡេមកពីកោះស៊ូម៉ាត្រា ដែលបានទទួលអារ្យធម៌ហិណ្ឌូរួចមកហើយ ។ ពួកក្រុមខបនិវេសន៍ដែលមកបន្ទាប់ទៀត គឺពួកហិណ្ឌូមកពីរដ្ឋកលិង្គៈ ។

ឯកសារចិនបានរក្សាទុកនូវរឿងរ៉ាវដ៏សំខាន់មួយ ដែលអាចជាការចងចាំសេសសល់ពីការឈ្លានពានលើកទីមួយរបស់ពួកម៉ាឡេ មកលើកម្ពុជា នៅត្រង់មុំចុងដុក ពីព្រោះថា មាត់ពាមរបស់ទន្លេមេគង្គកាលពីពេលនោះប្រហែលជានៅខ្ពស់ជាងសព្វថ្ងៃ ហើយដីដែលអាចសង់លំនៅស្ថានបាន នៅកាន់តែឆ្ងាយបន្តិច ទៅខាងជើង ។ រឿងរ៉ាវដែលពួកចិនបានរក្សាទុកនោះ បានត្រូវគេរៀបរាប់នៅសតវត្សរ៍ទី៣នៃគ្រិស្តសករាជ ក៏ប៉ុន្តែ រឿងនោះប្រហែលជាអាចមានឫសគល់តាំងពី១០០ ឬ២០០ឆ្នាំមុន ។

កាលនោះ ប្រទេសនេះដឹកនាំដោយក្សត្រីមួយអង្គ ព្រះនាមថា លីវយី[៧] ប្រែថាស្លឹកស្រូល ។ ពេលនោះមានបុរសម្នាក់ឈ្មោះ ហ្វូនហ៊ី ឬ ហ៊ុនទៀន ដែលគោរពបូជាព្រហ្មញ្ញសាសនា ធ្វើដំណើរមកពីទិសទក្សិណ គឺចេញពីសមុទ្រខាងត្បូង[៨] មកចតសំពៅនៅនីងរាជធានី ហើយបានវាយឈ្នះទ័ពដែលព្រះនាងលីវយីបានបញ្ជូនទៅទប់

---

[៦] ពាក្យ នាគ ដែលគេប្រើជាប្រពៃណីសម្រាប់ហៅអ្នកស្រុកដើមរបស់នគរគោកធ្លក អាចនឹងត្រូវបានដាក់ឲ្យដោយពួកហិណ្ឌូ តាំងតែពីពេលដែលពួកនេះមកដល់ដំបូងម្ល៉េះ ។ នៅឥណ្ឌា ពាក្យនេះជាឈ្មោះជនជាតិមួយក្រុម ដែលមានរហូតមកដល់សព្វថ្ងៃ គឺពួកគេមានទីលំនៅៗចន្លោះខេត្រឈីតតាហ្គុង និងអាសាម ។ ពួកនេះមានផ្ទះសង់បន្តើត ដូចជាផ្ទះពួកខ្មែរដែរ ។ មានគេនិយាយថា ពួកនាគនៅឥណ្ឌានេះ មានអម្បូរជាដេរ៉ាស ឬ សិរាស ដែលប្រហែលគ្នានឹងពាក្យចារ៉ាយ និងស៊ីរ៉ាយ ដែលគេតែងឮនៅកម្ពុជា ។ ចារ៉ាយ ជាឈ្មោះដែលជនជាតិភាគតិចគួយដាក់ឲ្យខ្មែរ រីឯពាក្យ ស៊ីរ៉ាយ ជាពាក្យដែលពួកស្មៀង និងពួកម៉យនៅភាគខាងកើតកូសាំងស៊ីន ប្រើសម្រាប់ហៅខ្មែរ ។ ដូច្នេះ វាអាចជាការត្រឹមត្រូវ ដែលថាពាក្យនាគជាឈ្មោះដែលពួកនិរប្រវេសន្តហិណ្ឌូដាក់អ្នកស្រុកគោកធ្លក ។

[៧] អ្នកខ្លះថាឈ្មោះ ដៀបលីយើ ។

[៨] លោក ពែលីយ៉ូ បានរកឃើញឯកសារដែលនិយាយថា ព្រាហ្មណ៍នោះមកពី វ៉ូវែម ឬគឺ នឹងរាជណាចក្រគាវ ។ ជននោះ អាចធ្វើដំណើរមកពីឥណ្ឌា ដោយធ្វើដំណើរកាត់តាមច្រកសិង្ហបុរី ក៏ប៉ុន្តែខ្ញុំជឿថាគ្រាន់តែដឹងថាមកពីទិសខាងត្បូង គឺគ្រប់គ្រាន់ហើយ ។

ទល់ ។ ក្រោយពីបានរៀបចំស្រុកឲ្យមានសន្តិភាពរួចហើយ ព្រាហ្មណ៍នោះក៏រៀបអាពាហ៍ពិពាហ៍ជាមួយព្រះនាងលីវយី រួចឡើងសោយរាជ្យនៅនគរហ្វូណន ដែលអ្នកស្រុកដើមហៅថា គោកធ្លក តទៅ ។

ដូចនេះព្រះនាងលីវយីគឺជាស្តេចសោយរាជ្យដំបូងនៅនគរគោកធ្លក ។ ព្រះរាជាទី២គឺព្រះបាទហ៊ុនទៀន ដែលជាជនបរទេសបានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះនាងលីវយី គឺអាចជាម៉ាឡេ ឬជ្វា ព្រោះធ្វើដំណើរមកពីទិសខាងត្បូង ហើយនៅពីត្បូងកម្ពុជាពេលនោះគឺកោះជ្វា ឬកោះស៊ូម៉ាត្រា ឬបើពុំនោះទេ គឺសិង្ហបុរី ។

ព្រះបាទហ៊ុនទៀន និងព្រះនាងលីវយីមានព្រះរាជបុត្រមួយព្រះអង្គ ។ ពេលព្រះរាជបុត្រានេះចម្រើនព្រះជន្មធំឡើង ព្រះបាទហ៊ុនទៀនបានរៀបចំដីសាមន្តរាជមួយ មានទីក្រុង៧ ឲ្យគ្រប់គ្រងដីនេះដែលជាដីសាមន្តរាជទីមួយនៃព្រះរាជាណាចក្រ ។ ក្រោយមក មានស្តេចស្នងរាជ្យបន្តពីព្រះបាទហ៊ុនទៀនមួយអង្គ ព្រះនាមហ៊ុនប៉ាងហួង បានប្រើល្បិចបំបែកបំបាក់ទីក្រុងទាំង៧ រួចក៏វាយយកដាក់ជាចំណុះ ទើបទ្រង់ចាត់តាំងព្រះរាជបុត្រព្រះរាជនត្តាឲ្យទៅសោយរាជ្យលើទីក្រុងនីមួយៗនោះទៀត ។ សរុបមកដីសាមន្តរាជមួយដែលព្រះបាទហ៊ុនទៀនបានរៀបចំឲ្យព្រះរាជបុត្ររបស់ព្រះអង្គសោយរាជ្យ តែស្តេចទឹកដីមួយៗចង់រើខ្លួនឲ្យបានឯករាជ្យ បានត្រូវព្រះអង្គវាយដាក់ជាចំណុះឡើងវិញ រួចបែងចែកឲ្យស្តេចត្រាញ់៧រូបសោយរាជ្យ ។

ព្រះរាជាអង្គនេះបានគ្រងរាជ្យរហូតដល់ព្រះជន្ម៩០ព្រះវស្សាទើបសោយទិវង្គតទៅ ពេលនោះព្រះរាជបុត្រទី២របស់ព្រះអង្គ ព្រះនាមថា ផាន់ ផាន់[៩] ត្រូវបានជ្រើសតាំងឲ្យឡើងសោយរាជ្យបន្តពីព្រះបិតា ។ ប៉ុន្តែស្តេចអង្គនេះ មិនបានយកចិត្តទុកដាក់នឹងកិច្ចការប្រទេសជាតិទេ ទ្រង់បានប្រគល់កិច្ចការទាំងអស់ឲ្យមេទ័ពព្រះអង្គឈ្មោះ ហ្វាន់ចេម៉ាន់ ឬ ហ្វាន់ម៉ាន់ កាន់កាប់ជំនួសវិញ ហើយព្រះអង្គបានសោយទិវង្គតទៅក្រោយពីសោយរាជ្យបាន៣ឆ្នាំ ។ ពេលនោះសេនាមុខមន្ត្រីក៏បានលើកមេទ័ពហ្វាន់ម៉ាន់ឲ្យឡើងសោយរាជ្យបន្ត ។ ការលើក ហ្វាន់ម៉ាន់ឲ្យសោយរាជ្យនេះ មិនបានទទួលការគាំទ្រពីមហាជនទេ ជាពិសេសពីពួកស្តេចត្រាញ់ដែលសោយរាជ្យ នគរចំណុះទាំងឡាយ ពីព្រោះឯកសារចិនបានបញ្ជាក់ថា ក្រោយពីបានឡើងសោយរាជ្យព្រះបាទហ្វាន់ម៉ាន់ ដ៏អង់អាចនិងមានសមត្ថភាព បានធ្វើសឹកសង្គ្រាម វាយបង្ក្រាបប្រទេសចំណុះទាំងឡាយ ឲ្យរាបទាបឡើងវិញ ។ មើលទៅព្រះរាជាអង្គនេះ ជាក្សត្រអង់អាចក្លាហាន និងជាអ្នកចម្បាំងផង ។ ព្រះអង្គបានចាត់ឲ្យកសាងនាវាធំៗ ដែល

---

[៩] ពាក្យនេះ ដែលចិនហៅថាហ្វាន អាណ្ណាមថាផាន គេប្រើសម្គាល់ឋានៈព្រះរាជា ប្រៀបបានទៅនឹងពាក្យស្រី ឬព្រះ ដែលគេតែងប្រើនៅកម្ពុជា និងចាម្ប៉ា អ៊ីចឹងដែរ ។ ក៏ប៉ុន្តែពាក្យនេះ គេមិនបានប្រើយូរប៉ុន្មានទេ គឺមានប្រើចំពោះតែព្រះរាជាកម្ពុជា៣ព្រះអង្គប៉ុណ្ណោះនៅសតវត្សរ៍ទី៣ និងប្រើនៅចាម្ប៉ាចាប់ពីសតវត្សរ៍ទី៣មក ។ ខ្ញុំមិនដឹងថាពាក្យ នេះមានប្រភពដើមពីពាក្យសំស្ក្រឹត ឬចាម ឬម៉ាឡេ ឬក៏ចិន ណាមួយម៉ាត់ទេ ។ ប្រហែលជាពាក្យនេះជាការអានពាក្យ វរ្ម័ន មិនបានច្បាស់ក៏មិនដឹង ។

ព្រះអង្គជិះកាត់សមុទ្រជ្រៅៗ ធ្វើចម្បាំងវាយប្រទេសលើសពី១០ ក្នុងនោះ មួយចំនួនធំស្ថិតនៅក្នុងទៀបកោះ ដែលពួកអឺរ៉ុបហៅថា ម៉ាឡាកា ។

ព្រះអង្គមានរាជធានីដែលហៅ និងសរសេរតាមភាសាចិនថា តូមូ[១០] នៅចម្ងាយប្រមាណជា១៨០គីឡូម៉ែត្រពីមាត់ពាមទន្លេមេគង្គ និងមាត់ច្រាំងនៃទន្លេដ៏ធំមួយ ដែលនាវាសមុទ្រអាចចូលចតបានយ៉ាងស្រួល ។

ព្រះបាទហ្វាន់ម៉ាន់ បានប្រឈួននៅពេលកំពុងធ្វើសង្គ្រាមមួយ ទ្រង់បានចាត់ឲ្យព្រះរាជបុត្រច្បង ព្រះនាម គិនចេង បញ្ជាទ័ពជំនួសព្រះអង្គ ហើយទ្រង់ទុកព្រះភាគិនេយ្យព្រះអង្គព្រះនាមចាន់ ជាបុត្ររបស់ព្រះអនុជក្សត្រីព្រះអង្គ ឲ្យកាន់ទ័ព ២០០០នាក់ នៅការពារព្រះអង្គ ។ ព្រះភាគិនេយ្យនេះបានឆ្លៀតយកឱកាស ដែលព្រះបាទហ្វាន់ម៉ាន់ ប្រឈួន ក៏ប្រកាសខ្លួនជា ហ្វាន់ចាន់ គឺជាព្រះរាជានៃនគរហ្វូណន ឬហ្វូណន ។ រួចព្រះអង្គបានចាត់កម្លាំងឲ្យទៅធ្វើឃាតរជ្ជទាយាទ គិនចេង ដើម្បីកុំឲ្យមកដណ្តើមរាជ្យពីព្រះអង្គវិញ ប្រហែលជានៅឆ្នាំ២៣០នៃគ្រិស្តសករាជ ។

ព្រះបាទហ្វាន់ម៉ាន់នៅមានព្រះរាជបុត្រមួយអង្គទៀត ដែលនៅជាព្រះរាជឱរសនៅឡើយ ពេលព្រះបិតាសុគត ។ ពេលទ្រង់ចម្រើនវ័យគ្រប់២០ព្រះវស្សា ព្រះអង្គក៏សម្រេចចិត្តដណ្តើមរាជ្យសម្បត្តិពីព្រះរៀមជីដូនមួយ ដែលបានជ្រែករាជ្យ និងសម្លាប់ព្រះបិតាព្រះអង្គ ។ ព្រះអង្គកទ័ព ជ្រើសរើសយកពលទាហានសុទ្ធតែអ្នកអង់អាចក្លាហាន រួចធ្វើឃាតព្រះបាទហ្វាន់ចាន់ទៅ ។ ត្រង់នេះគេមិនបានដឹងថា តើព្រះអង្គធ្វើឃាតនៅក្នុងសង្គ្រាមតតាំងទល់មុខគ្នា ឬក៏នៅក្នុងការលបវាយប្រហារស្ងាត់ៗទេ ។ ពេលនោះ មេទ័ពរបស់ព្រះបាទហ្វាន់ចាន់ ឈ្មោះស៊ីយុន ដោយយកលេសថាសង់សឹកថ្វាយព្រះរាជា បានសម្លាប់ឃាតករ រួចហើយក៏ប្រកាសខ្លួនជា ហ្វាន់ស៊ីយុន[១១] ជាព្រះរាជានៃនគរហ្វូណន នៅឆ្នាំ២៥០នៃគ្រិស្តសករាជ ត្រូវនឹងឆ្នាំ១៧២នៃមហាសករាជ ។

ឯកសារប្រវត្តិសាស្ត្រចិនរៀបរាប់អំពីព្រះបាទហ្វាន់ស៊ីយុននេះ ថាជាស្តេចកសាងប្រទេស យកចិត្តទុកដាក់នឹងរាជកិច្ចខ្លាំងណាស់ ។ ទ្រង់បើកសវនាការឲ្យប្រជារាស្ត្រចូលគាល់រាល់ថ្ងៃ នៅពេលព្រឹក និងថ្ងៃត្រង់ ។

តាមមើលទៅ ព្រះរាជាដែលសោយរាជ្យនៅនគរហ្វូណនទាំងអស់ រួមទាំងស្តេចជ្រែករាជ្យផង សុទ្ធតែមានខ្សែលោហិតរាជវង្សតែមួយ ព្រោះយើងមកដល់ពាក់កណ្តាលសតវត្សរ៍ទី៣ហើយ ហើយតាមឯកសារប្រវត្តិសាស្ត្រចិនបាននិយាយថា បច្ឆាញាតិរបស់ព្រះនាងលីវយី និងព្រះបាទហ៊ុនទៀន បានគ្រប់គ្រងរាជសម្បត្តិ

[១០] ប្រហែលជាឈ្មោះពិតប្រាកដគឺ តូម៉ូហ្វូ ដែលជាឈ្មោះតាមភាសាម៉ាឡេនៃទីក្រុងមួយនៅកោះជ្វា ។

[១១] លោក ពែលីយ៉ូ ក្នុងសៀវភៅឈ្មោះថា នគរហ្វូណន បានបញ្ជាក់តាមសំដីលោក ឆាវ៉ាន ថា ស្តេចនគរហ្វូណន បានបញ្ជូនរាជទូតឲ្យទៅគាល់ស្តេចស្រុកចិន នៅឆ្នាំ២៤៣ និងក្រោយៗមកទៀត ។

នៅហ្វូណនអស់រយៈកាល២សតវត្សរ៍[១២] ។

បើសិនជាការប្រកាន់តាមប្រពៃណីខ្មែរ ដែលលើកឡើងថា មានស្តេចចាម៦អង្គសោយរាជ្យមុនគេ នៅកម្ពុជា –ស្តេចទាំងអស់នោះមានព្រះនាមថា យួយូវរ៍្មនទិ, កវាលរាជកុមារ, សុរិយាវរ៍្មនទិ, ទរនិន្ទ្រាវរ៍្មនទិ, អាទិត្យវរ៍្មនទិ និងអស្សកៃ– ជាការពិត នោះមានន័យថា ព្រះរាជាទាំងអស់នោះជាបច្ឆាញាតិរបស់ព្រះនាង លីវយី និងជូហ៊ុនទៀន ទាំងអស់ ហើយមិនមែនជាចាមទេ ព្រោះនៅពេលនោះមិនទាន់មានពួកចាមនៅឡើយ តែជា ជូរ ឬម៉ាឡេ គឺជាអម្បូរជនដែលក្រោយពីបានត្រូវដេញចេញពីកម្ពុជាទៅ បានគេចទៅនៅចំប៉ាសាក់ខាងជើងកម្ពុជា ឬក៏ទៅនៅខាងកើតត្រង់ដែលចិនហៅថា លីនយី ដែលក្រោយមកទើបក្លាយទៅជាចាម្ប៉ានោះឯង ។ ឈ្មោះ ចាម្ប៉ានេះ ខ្មែរនៅចងចាំនៅឡើយ រហូតមកដល់២សតវត្សរ៍មុននេះ ។

ឯកសារប្រវត្តិសាស្ត្រចិនក៏មានរៀបរាប់ជាច្រើនដែរ អំពីស្រុកហ្វូណន ទោះបីជាការរៀបរាប់នីមួយៗ មិនគ្រប់ជ្រុងជ្រោយ ហើយសរសេរនៅពេលខុសៗគ្នាក៏ដោយ តែបើយកមកផ្គុំគ្នា អាចឲ្យយល់ដឹងបានខ្លះអំពីប្រទេសនោះ នៅសតវត្សរ៍ទី៣ និងទី៤ ។ ដូចនេះ វាមានសារសំខាន់នៅពេលនេះ ដែលត្រូវអធិប្បាយសង្ខេបអំពីឯកសារទាំងនោះ ។

ឯកសារនោះនិយាយថា មុនដែលស្តេចហ៊ុនទៀន មកដល់ អ្នកស្រុកហ្វូណនច្រើនសាក់ខ្លួនដូចដែលពួកភូមា និង លាវ នៅអនុវត្តរហូតដល់សព្វថ្ងៃ ។ ការសាក់ខ្លួននេះហាក់ដូចជាគ្មានទៀតទេ ពេលដែលស្តេចហ៊ុនទៀន មកដល់ តែអ្នកស្រុកនៅដើរស្រាត មិនទាន់មានស្លៀកពាក់នៅឡើយ ។ ស្តេចហ៊ុនទៀន ដែលចេញមកពីប្រទេសមួយមានអារ្យធម៌រួចហើយ ម្យ៉ាងទៀតជាព្រាហ្មណ៍ផង ទ្រង់មិនសប្បាយចិត្តនឹងឃើញព្រះជាយានៅស្រាត ដូច្នេះទេ ទ្រង់ក៏យកក្រណាត់មួយផ្ទាំងមកស្លៀកឲ្យ ដោយចោះប្រហោងកណ្តាលសម្រាប់ច្រកព្រះកេស[១៣] ។

ក្រោយមក នៅដើមសតវត្សរ៍ទី៣ ស្រីៗអ្នកស្រុកក៏ប្រកាន់យកសម្លៀកបំពាក់នេះរហូត ហើយស្តេច

---

[១២] ដោយហេតុនេះ គេត្រូវបំភ្លេចចោលនូវការដែលគិតថាហ៊ុនទៀន និងកោណ្ឌញ្ញៈជាមនុស្សតែមួយ ដូចដែលបានស្នើឡើងដោយស្ទែហ្វេល បន្ទាប់មក ដោយពែលីយ៉ូ និងហ៊ីណូត៍ ។ អ្នកទាំង២រស់នៅចន្លោះពីគ្នាប្រហែល៤សតវត្សរ៍យ៉ាងតិច ។ លោក ពែលីយ៉ូ ដឹងរឿងនេះច្បាស់ណាស់ ព្រោះលោកបានលើកពីអត្ថបទរបស់ម៉ង់ស៊ីចាន់ ដែលរៀបរាប់អំពី ស្តេចមួយចំនួនដែលសោយរាជ្យចន្លោះពីហ៊ុនទៀន នៅសតវត្សរ៍ទី១ ដល់កោណ្ឌញ្ញៈ ដែលឡើងសោយរាជ្យក្រោយឆ្នាំ៤៧៨ ហើយមានទាំងនិយាយអំពីស្តេចជ្រែករាជ្យ ដែលសោយរាជ្យពី ២២២ ដល់ ២៨០ផង ។

[១៣] អ្នកប្រាជ្ញខ្មែរនិយាយថា ដោយហេតុនេះហើយបានជាក្រោយៗមកស្ត្រីៗបានចៀរក្រណាត់នោះ ហើយដេរបន្ថែមដៃ ក៏បានជាអាវបំពង់ពាក់រហូតមក ។ ក៏ប៉ុន្តែការលើកឡើង ដូច្នេះមិនត្រឹមត្រូវ ព្រោះអាវបំពង់នេះ គេទើបតែពាក់មិនទាន់បាន១៥០ឆ្នាំផងទេ ។

ហ្វាន់ស៊ីយុនក៏បានហាមមិនឲ្យប្រុសៗស្រាតទៀតដែរ ដោយឲ្យបិទបាំងកេរ្តិ៍ខ្មាសនឹងក្រណាត់ប៉ឹង ដែលចិនហៅថា កេនម៉ាន ហើយពួកម៉ាឡេហៅថាកំបាន[១៨] ។ ពួកអ្នកមានគេប្រើក្រណាត់ប៉ាក់ រីឯអ្នកក្រប្រើក្រណាត់ផាឌិប ។

ឯកសារប្រវត្តិសាស្ត្រចិនដដែលនិយាយថា អ្នកស្រុកហ្វូណន គគ្រិច សម្បុរខ្មៅ ហើយមានសក់ក្រញ៉ាញ់[១៥] ។ ពួកនេះចូលចិត្តការចារ៉ុ និងចម្លាក់ ។ ឧបករណ៍របស់គេជាច្រើនធ្វើអំពីប្រាក់ គេបង់ពន្ធជាមាស, ប្រាក់ ឬជាគ្រាប់គជ់ និងទឹកអប់ ។ គេមានសៀវភៅ និងកន្លែងសម្រាប់ទុកដាក់ឯកសារ និងសម្ភារផ្សេងៗ ។ គេមានអក្សរ ហើយគេចូលចិត្តប្រជល់មាន់ និងប្រជល់ជ្រូក ។

អ្នកស្រុកនេះចូលចិត្តអនុវត្តការស្បថស្បែ និងការសាកល្បងផ្សេងៗ ដូចជាឲ្យអ្នកជាប់ចោទកាន់ដែ្កពូថៅដែលដុតឡើងក្រហម ហើយដើរឲ្យបាន៧ជំហាន ឬដាក់ចិញ្ចៀនឬពងមាន់នៅក្នុងទឹកពុះ ហើយឲ្យយកដៃលូកចាប់យកចេញជាដើម ។ ការអនុវត្តន៍បែបនេះ នៅមានគេប្រតិបត្តិនៅឡើយ ក្នុងចំណោមជនជាតិដើម ។ នៅកម្ពុជាពេលមុននេះបន្តិច ក៏នៅមានអនុវត្តបែបនេះដែរ ។

ឯកសារប្រវត្តិសាស្ត្រចិនរៀបរាប់ទៀតថា នៅមានវិញ្ញាសាមួយទៀត ដែលគេអនុវត្តចំពោះតែម្ចាស់ និងខ្ញុំបម្រើប៉ុណ្ណោះ ក្នុងករណីសង្ស័យថាខ្ញុំនោះលួចរបស់ៈ គឺឲ្យខ្ញុំនោះស៊ីស្រូវ ។ បើខ្ញុំនោះបានលួចមែន ស្រូវនឹងមុតមាត់ចេញឈាម ប៉ុន្តែ បើមិនបានលួចទេ គឺអាចទំពាស្រូវលេបចូលពោះដោយស្រួល ។

---

[១៨] តាមមើលទៅ ការបិទបាំងបែបនេះ ប្រហែលជាដូចអ្វីដែលបុរសៗនៃវិប្រជាដែលរស់នៅឆ្ងាយៗពីទីក្រុងក្នុងប្រទេសឥណ្ឌាសព្វថ្ងៃ នៅប្រើនៅឡើយ គឺថាក្រណាត់មួយ ផ្ទាំងវាងជាត្រីកោណដែលគេដាក់ពីខាងមុខ ចុងសងខាងភ្ជាប់នឹងខ្សែរុំព័ទ្ធចង្កេះ ឯចុងមួយទៀតភ្ជាប់នឹងខ្សែដែរ តែវាត់ពីក្រោមតាមចន្លោះភ្លៅ ។

[១៥] ការរៀបរាប់ នេះបញ្ជាក់ថា នៅសតវត្សរ៍ទី១នៃគ្រិស្តសករាជ អ្នកស្រុកហ្វូណនជាក្រុមមនុស្សណេគ្រីតូ ។ បើដូច្នេះមែននោះបានសេចក្តីថាអ្នកស្រុកនេះបានទទួលការវិវត្តន៍យ៉ាងខ្លាំង ព្រោះគេកម្រនឹងប្រទះឃើញជនកម្ពុជាដែលមានសក់រួញណាស់ សព្វថ្ងៃនេះ ។ ក៏ប៉ុន្តែក្នុងចំណោមប្រជាជនដែលមិនទាន់ស៊ីវិល័យទាំងអស់នៅក្នុងឥណ្ឌូចិន ដែលជាអ្នកស្រុកដើម គេនៅមានឃើញមានអ្នកដែលមានសក់រួញ ហើយរួញខ្លាំងទៀតផង ។ ជាទូទៅ ពួកនេះមិនមានសក់បះទេ គឺច្រើនតែរួញតិចៗ តែសម្បុរមិនខ្មៅដូចពួកខ្មែរពេកទេ ។ ខ្ញុំសូមថែមទៀតថា ក្នុងស្មារតីរបស់អ្នកស្រុកនេះ ការដែលមានសក់រួញគឺជាសញ្ញាបញ្ជាក់ថាទាបថោក ជាប្រការមានគ្រោះថ្នាក់ ។ ប្រការនេះរឹតតែមានន័យដូច្នេះថែមទៀតចំពោះស្រីៗ ដោយហេតុនេះហើយបានជាពួកគេតែងតែស្វែងរកប្រេងមកលាបដើម្បីធ្វើឲ្យសក់លាត្រង់វិញ ។ ម្យ៉ាងទៀត តាមការនិយាយតៗគ្នា ពួកខ្មែរដើមមានសម្បុរខ្មៅខ្លាំងជាងខ្មែរសព្វថ្ងៃ ។

វាជាការពិតប្រាកដណាស់ថា បើពួកខ្មែរមានប្រភពចេញមកពីប្រទេសឥណ្ឌា គឺចេញពីឆ្នេរកូរ៉ូម៉ង់ដែល ឬឆ្នេរអូរីស្សា ឬក៏ចេញពីមាត់សមុទ្របឹងហ្គាល់មែននោះ ពួកនេះ ប្រាកដជាខ្មៅជាងពួកអ្នកស្រុកដើមដែលគេប្រទះឃើញនៅឥណ្ឌូចិន ពិសេស គឺកម្ពុជាសព្វថ្ងៃ ដែលមានស្បែកលឿងទៅទៀត ។

ពេលនោះមិនទាន់មានគុកដាក់អ្នកទោសទេ ។ ជនខក្រិដ្ឋត្រូវបោះឲ្យក្រពើស៊ី ដែលគេចិញ្ចឹមនៅក្នុងប្រឡាយជុំវិញទីក្រុង ឬសត្វសាហាវ ដែលគេចិញ្ចឹមដាក់ក្នុងទ្រុងពិសេស ។

អ្នកស្រុកមិនជីកអណ្ដូងយកទឹកទេ ក៏ប៉ុន្តែគេមានស្រះទឹកតាមក្រុមគ្រួសារ ហើយប្រើធុងសម្រាប់ដងទឹកយកមកប្រើ កាលណាគេត្រូវការ ។

គេគោរពបូជាអាទិទេពដែលរស់នៅលើមេឃ ហើយសាងរូបសំណាកតំណាងអំពីសិរីទ្ធ ដែលជួនកាល មានមុខពីរ និងដៃបួន ជួនកាលទៀត មានមុខបួន និងដៃប្រាំបី ។ តាមពិតទាំងអស់នេះ គឺជាបដិមាតំណាងឲ្យអាទិទេពនៃព្រហ្មញ្ញសាសនា ដែលមានដូច្នេះរហូតដល់សព្វថ្ងៃនៅឥណ្ឌា និងមានក្បាលមិនតិចជាងដៃប៉ុន្មានទេ ។ នៅកម្ពុជាគេបានរកឃើញបដិមាបែបនេះជាច្រើន ដែលគេយកមកទុកនៅសារមន្ទីរសព្វថ្ងៃ ។

ព្រះរាជាជិះដំរី កាលណាត្រូវយាងចេញពីវាំង ។ មហេសី និងស្រីស្នំទាំងឡាយ ក៏ដូច្នោះដែរ ។ កាលណាព្រះអង្គទ្រង់គង់ទម្រេតព្រះកាយបន្តិច បញ្ឈរជង្គង់ស្ដាំ ឯជង្គង់ឆ្វេងទម្លាក់ដល់ដី[១៦] ។ នៅពីមុខព្រះភ័ក្ត្រព្រះអង្គគេលាតក្រណាត់ស រួចដាក់ព្រះរាជសង្ហារ ភាជន៍មាស និងជើងដុតឈើក្រអូប ។

ការបូជាខ្មោច និងអាពាហ៍ពិពាហ៍របស់អ្នកស្រុកហ្វូណន ប្រព្រឹត្តទៅដូចនៅលីនយី ឬចាម្ប៉ាដែរ ។ គេកាន់ទុក្ខដោយកោរសក់ និងកោរពុកមាត់ ។ មានវិធីយ៉ាងសម្រាប់ទុកដាក់សព ៖ បោះសពចូលក្នុងទឹកទន្លេ, បូជាដោយភ្លើង, កប់, និងទុកចោលកណ្ដាលវាលឲ្យសត្វស៊ី ។ នេះគឺជាអ្វីដែលជនកម្ពុជាហៅរហូតមកដល់សព្វថ្ងៃថា "ការបំបែកធាតុទាំងបួន" ។

ចុងក្រោយបង្អស់ ឯកសារចិនបានកត់សម្គាល់ថា អ្នកស្រុកហ្វូណនលោភលន់ណាស់ ។ គេមិនគោរពពិធី ឬចរិយាធម៌អ្វីទេ ។ ទំនៀមទម្លាប់គ្មាន ហើយកុមារីក៏ដូចកុមារា ធ្វើអ្វីតាមតែអំពើចិត្ត ។

ឯកសារក៏បានបញ្ជាក់ផងដែរថា នគរហ្វូណន ពេលនោះធំណាស់ លាតសន្ធឹងពីនគរចាម្ប៉ានៅខាងកើតរហូតដល់ទ្វារវតី[១៧] នៅខាងលិច - ប្រទេសនេះគឺអយុធ្យាឬសៀមសព្វថ្ងៃ ពេលនោះប្រហែលជាគ្រប់គ្រងដោយក្រុមខបនិវេសន៍ហិណ្ឌូមួយរួចទៅហើយ -និងលាតសន្ធឹងរហូតដល់ព្រំប្រទល់ខែត្រយេណាននរបស់ចិន- គឺខែត្រក្វាងប៊ិញរបស់តុងកឹងសព្វថ្ងៃ[១៨] ។ ក៏ប៉ុន្តែ វាហាក់ដូចជាពិបាកនឹងជឿណាស់ ដែលនិយាយថា ស្ដេចនៃនគរហ្វូណន

[១៦] ខ្ញុំជឿថានេះគឺជាអ្វីដែលខ្មែរនិយាយថាអង្គុយបត់ជើង កាលណាគេអង្គុយលើកម្រាលព្រំ កន្ទេល ឬក្រណាត់ដោយបត់ជើងទាំង២ ស្របគ្នាមកតែម្ខាង ។

[១៧] ទ្វារវតី មកពីសំស្ក្រឹត ធ្វារវតី ជាឈ្មោះទីក្រុងដែលក្រោយពីបានកសាងរួចទៅជាអយុធ្យា ។

[១៨] ខែត្រនេះពីមុនឈ្មោះថា ស្យង់ក្បួន រួច គាវតូ មុននឹងមានឈ្មោះថា យេណាន នេះ ។

ដែលមានទីតាំងនៅតំបន់ចូវដុក ឬក្នុងខេត្រព្រៃកប្បាស អាចវាតអំណាចទៅបានឆ្ងាយពីរាជធានីបែបនេះ ។

## ២- រឿងព្រេង

រឿងព្រេងខ្មែរចាប់កំណើតអស់កាលជាយូរលង់ណាស់មកហើយ ហើយបានក្លាយទៅជាប្រពៃណីរបស់ជាតិខ្មែរផងដែរ ។ រឿងព្រេងទាំងនោះមានប្រជាប្រិយភាពខ្លាំងណាស់ ហើយបានត្រូវប្រជាជនខ្មែរជឿជាក់ និងចាត់ទុកដូចជាព្រះឱង្ការរបស់ព្រះ ដែលពួកគេការពារយ៉ាងខ្លាំង ថ្វីបើនៅមានការប្រទាំងប្រទើសគ្នាខ្លះក៏ដោយ ។

តើរឿងព្រេងទាំងអស់នោះគ្រាន់តែជារឿងដែលគេប្រឌិតឡើងតាមតែការស្រមើស្រមៃ គ្មានទាក់ទិនទៅនឹងហេតុការណ៍ប្រវត្តិសាស្ត្រអ្វីសោះ ឬយ៉ាងណា? មិនមែនទេ ។ តាមមើលទៅ រឿងព្រេងទាំងអស់នោះហាក់ដូចជាមានចំណែកខ្លះជារឿងពិតតាមប្រវត្តិសាស្ត្រ ដែលគេយកមកប្រឌិតបំផ្លើស ផ្សំធ្វើឲ្យមានភាពអច្ឆរិយៈខ្លះ ទោះជារឿងទាំងនោះចាប់កំណើតចេញពីការនិទានតៗគ្នា ពីមាត់មួយទៅមាត់មួយ រួចបានត្រូវគេត្រងត្រាប់ទុកតែរចនាបទ ឬក៏ជាប្រវត្តិពិតពីបុរាណកាល ដែលបានរលុបស្ទើរបាត់អស់ទៅហើយក្តី[១៩] ។

ទោះជាយ៉ាងណាក្តី ថ្វីបើគេមិនឃើញមានចំណារនៅលើសិលាចារឹក ឬក៏មិនមានរៀបរាប់នៅក្នុងកំណត់ត្រារបស់ប្រវត្តិវិទូចិនក៏ដោយ ក៏គេមិនអាចបដិសេធមិនទទួលស្គាល់រឿងរ៉ាវដែលគេនិទានផ្ទាល់មាត់តៗគ្នា និងរឿងព្រេងដែលគេបានសរសេរកត់ត្រាទុកមកថា ពួកចាមមានវត្តមាននៅកម្ពុជាមុនពួកឥណ្ឌា ។ គឺរឿងទាំងអស់នោះ ហើយដែលជំរុញឲ្យប្រជាជនខ្មែរបច្ចុប្បន្នហ៊ានកំណត់នៅពេលដែលគេជួបសិលាចារឹកមួយថា សិលាចារឹកនេះជារបស់ចាម សិលាចារឹកនោះជារបស់ខ្មែរ ។ គេអាចនឹងទទួលស្គាល់បានដូចដែលគេបានឃើញពីខាងលើរួចមកហើយថា ពួកចាមបានមកដល់កម្ពុជាមុនពួកកម្ពុជៈ ដោយគ្មានប៉ះពាល់អ្វីដល់ប្រវត្តិសាស្ត្រ ដែលផ្អែកទៅលើកំណត់ត្រារបស់ពួកចិន ពីព្រោះថា កំណត់ត្រាទាំងនោះ មិនមែនសុទ្ធតែរៀបរាប់ប្រាប់យើងទាំងអស់ អំពីអ្វីដែលចិនបានដឹងពីប្រជាជនដែលគេលើកឡើងនោះទេ ។

ប៉ុន្តែខ្ញុំជឿថា ការដែលចង់អះអាងថាប្រវត្តិសាស្ត្រដែលទាក់ទងទៅនឹងរឿងព្រេងពីរ ដែលយើងបានដឹង គឺរឿងជុះព្រាហ្មណ៍ និងរឿងព្រះថោងនាងនាគ ដែលខ្ញុំនឹងរៀបរាប់ខាងក្រោម គឺជារឿងដែលកើតឡើង បន្តបន្ទាប់គ្នា នៅក្នុងក្សត្រប្រទេសតែមួយ គឺព្រះរាជាណាចក្រខ្មែរ ពីព្រោះថា នៅពេលនោះមានក្សត្រប្រទេសជាច្រើន

---

[១៩] ខ្ញុំមានជំនឿថាព្រះរាជាដែលយើងស្គាល់ព្រះនាមជាភាសាសំស្ក្រឹតតាមសិលាចារឹក ក៏ទ្រង់មានព្រះនាមជាភាសាសាមញ្ញដែលប្រជាជននិយមហៅ ដូចដែលមានក្នុងរឿងព្រេងអ៊ីចឹងដែរ ក៏ប៉ុន្តែព្រះនាមនោះមិនបានត្រូវគេចារលើថ្មទេ ព្រោះជាព្រះនាមក្រៅផ្លូវការ ។

ទៀតក្រៅពី ហ្វូណន ។ ខ្ញុំគិតថា រឿងដែលកើតមានក្នុងក្សត្រប្រទេសនីមួយៗ ដល់ពេលយូរក្រោយមក ក៏បានក្លាយទៅប្រវត្តិរួមរបស់ប្រទេសទាំងមូល ។ ដោយហេតុនេះ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលកើតមានឡើង ហើយដែលកប់បាត់ទៅតាមពេលវេលា មិនចាំបាច់ត្រូវតែឆ្លើយតបគ្នា និងកើតមានបន្តបន្ទាប់គ្នា ដើម្បីបញ្ជាក់ថា ជាការពិតនោះទេ ។

រហូតមកដល់សព្វថ្ងៃនេះ មានការបញ្ជាក់ច្បាស់ហើយថា ហ្វូណន[២០] គឺជាអាណាចក្រមួយដែលរួមផ្សំឡើងដោយក្សត្រប្រទេសជាច្រើន ដែលមានព្រះរាជានៃក្សត្រប្រទេសតូចមួយជាអធិរាជ ហើយបើមិនមែនដូច្នេះ តាំងពីដើមដំបូងមកទេនោះ ក៏ចាប់តាំងពីពេលដែលព្រះបាទហ្វាន់ម៉ាន់ បានធ្វើសង្គ្រាមដណ្ដើមទឹកដីមកដែរ ។

ហើយខ្ញុំក៏ដូចជាមានជំនឿច្រើនថា គឺពួកម៉ាឡេ ដែលជាបុព្វបុរសរបស់ពួកចាមនៅពេលក្រោយមក ដែលជាស្ថាបនិកនៃបណ្ដាក្សត្រប្រទេសទាំងអស់នោះ ។ រាជាណាចក្រចាម ឬចាម្ប៉ា នេះ ស្ថិតនៅពីខាងកើត ហើយបានកកើតឡើង យ៉ាងតិចណាស់ក៏២សតវត្សរ៍មុនកម្ពុជាដែរ ពីព្រោះគេបានរកឃើញសិលាចារឹកសំស្ក្រឹត ដែលមានវ័យចំណាស់ជាងគេនៅក្នុងឥណ្ឌូចិន នៅចាម្ប៉ានេះឯង ។ បើតាមសិលាចារឹកទាំងនោះ ប្រទេសចាម្ប៉ា មានអរិយធម៌ជឿនលឿនជាងហ្វូណន នៅសតវត្សរ៍ទី៤ ។

## **អំពីជ្វាព្រាហ្មណ៍**

ប្រសិនបើគេទទួលស្គាល់ថា ការលុកលុយរបស់ពួកម៉ាឡេ ឬជ្វា ជាការលុកលុយពីខាងក្រៅ ដែលកើតមានមុនគេមកលើកម្ពុជានោះ រឿងរ៉ាវដែលនិទានអំពីការលុកលុយរបស់ពួកជ្វាព្រាហ្មណ៍ គឺជារឿងមួយក្នុងបណ្ដារឿងទាំងនោះ ។ រឿងនេះរៀបរាប់អំពីការលុកលុយរបស់ស្ដេចហ៊ុនទៀន ដែលយាងមកពីទិសខាងត្បូង ដូចដែលបានលើកនៅខាងលើ ។ ទោះជាយ៉ាងណាក៏ដោយ ពួកជ្វាព្រាហ្មណ៍ ឬព្រាហ្មណ៍ នៅកោះជ្វាទាំងនោះ ធ្វើដំណើរចេញមកពីប្រជុំកោះអាំងស៊ូឡាំង ។ ពួកនោះប្រហែលជាបច្ឆាញាតិរបស់ពួកព្រាហ្មណ៍ប្រមាណជា ២ម៉ឺនគ្រួសារ ដែលបានធ្វើនិរប្រវេសន៍ចេញពីប្រទេសឥណ្ឌានៅដើមមហាសករាជ មកតាំងទីលំនៅលើកោះជ្វា ហើយផ្សព្វផ្សាយព្រហ្មញ្ញសាសនាដល់ប្រជាជនដើមនៅទីនោះ ។ រឿងនិទានរៀបរាប់ថា ក្រៅពីប្រជាជន ឬពួកពលទាហាន និងពួកសំពៅ ពួកព្រាហ្មណ៍ដែលជាមេគេទាំងនោះ មានសក់វែង មានសម្បុរខ្មៅ ហើយបានអះអាងថា ពួកគេមកពីនគរពារាណសី ។ រឿងនិទានក៏បានរៀបរាប់ផងដែរថា នគរដែលពួកជ្វាព្រាហ្មណ៍ទាំងនោះបានបង្កើតឡើង គឺនគរគោកធ្លក គឺស្រុកខ្មែរនេះឯង និងថា មានព្រះមហាក្សត្រចាម៦ព្រះអង្គសោយរាជ្យបន្តបន្ទាប់គ្នា ព្រះមហា

---

[២០] ហ្វូណន ក្នុងទីនេះ សំដៅយកតែផ្នែកខាងក្រោម ដែលរួមមានប្រទេសកម្ពុជាបច្ចុប្បន្ន និងកូសាំងស៊ីន តែប៉ុណ្ណោះ ។

ក្សត្រទាំងនោះជាបច្ឆាញាតិរបស់ព្រះនាងលីវយី និងព្រះបាទហ៊ុនទៀន ដែលជាជួរ ។

ស្តេចជ័យវរ្ម័ន សោយរាជ្យ៥០ឆ្នាំ ។ តាមរឿងនិទាន ព្រះអង្គគោរពបូជាព្រះវិស្ណុ ហើយទ្រង់សោយទិវង្គតទៅ ក្នុងព្រះជន្មាយុ៧០ឆ្នាំ ។

រាជបុត្ររបស់ព្រះបាទជ័យវរ្ម័នព្រះនាម កវលៈរាជកុមារ បានសោយរាជ្យបន្តពីព្រះបិតា ហើយគោរពបូជាថ្មស្វ័យម្ភូ[២១] ដែលមានន័យថា កើតមានឡើងដោយឯង១ ។ ព្រះរាជាអង្គនេះ សោយរាជ្យបាន២០ឆ្នាំ ។

ព្រះរាជាចាមទី៣ ទ្រង់ព្រះនាមថា សុរិយាវរ្ម័ន ទ្រង់គ្រងរាជ្យបាន២០ឆ្នាំដែរ និងគោរពបូជាថ្មស្វ័យម្ភូដូចគ្នា ។

ព្រះរាជាទី៤ ទ្រង់ព្រះនាមថា ធរនិន្ទ្រៈវរ្ម័ន ។ ទ្រង់សោយរាជ្យបាន២០ឆ្នាំ ។

ព្រះរាជាទី៥ គឺព្រះបាទអាទិត្យវរ្ម័ន សោយរាជ្យបាន២០ឆ្នាំ ។

ព្រះរាជាចាមទី៦ និងចុងក្រោយគេ គឺព្រះបាទអសជ្ជ័យ ដែលសោយរាជ្យបានតែ១១ឆ្នាំប៉ុណ្ណោះ ។

## រឿងព្រះថោង

តាមមើលទៅ រឿងរបស់ពួកហិណ្ឌូ ស្តីអំពីព្រះថោង ក៏ដូចជារឿងជួរព្រាហ្មណ៍ដែរ គឺមិនមែនជាការប្រឌិតសុទ្ធសាធនោះទេ ។ បើកុំគិតអំពីភាពអស្ចារ្យដែលគេបន្ថែមឲ្យ រឿងនេះហាក់ដូចជារំលឹកនូវហេតុការណ៍ប្រវត្តិសាស្ត្រមួយ នោះគឺការឈ្លានពានរបស់ពួកហិណ្ឌូ ដែលបានមកវាយយកជ័យជម្នះ រួចបណ្តេញពួកចាមចេញពីនគរគោកធ្លក ។

ដំណើររឿងត្រួសៗមានដូចតទៅ ៖ មានស្តេចមួយព្រះអង្គសោយរាជ្យនៅនគរឥន្ទ្រប្រទេស[២២] មានព្រះរាជបុត្រា៥ព្រះអង្គ ។ ព្រះអង្គបានបែងចែកខែត្រខ័ណ្ឌ៤ចំណែកឲ្យព្រះរាជបុត្រាច្បងទាំងបួនគ្រប់គ្រង ឯព្រះរាជបុត្រាពៅនៅជាមួយនឹងព្រះអង្គ ។ ដល់ពេលព្រះរាជបុត្រាពៅនេះចម្រើនវ័យធំឡើង ព្រះរាជាក៏ដាក់រាជ្យថ្វាយព្រះរាជបុត្រាពៅនេះ ឲ្យសោយរាជ្យបន្តពីព្រះអង្គ ។ ធ្វើយ៉ាងនេះបានសេចក្តីថា ព្រះអនុជពៅនេះជាអធិរាជលើព្រះរៀមទាំង៤ព្រះអង្គ ។ ព្រះរៀម៣ព្រះអង្គយល់ព្រមទទួលយកស្ថានភាពបែបនេះ ប៉ុន្តែព្រះរៀមទី៤ព្រះនាមថា ព្រះថោង មិនយល់ព្រមទេ ហើយទ្រង់មិនព្រមយាងមកកាន់ឥន្ទ្រប្រទេសចូលរួមក្នុងពិធី

---

[២១] តាមធម្មតាគឺព្រះព្រហ្ម ក៏ប៉ុន្តែជួនកាលក៏អាចជាព្រះសិវៈឬព្រះវិស្ណុផងដែរ ។ ខ្ញុំគិតថាប្រហែលជាព្រះសិវៈ ជាពិសេសគឺសិវៈលិង្គ ហេតុនេះហើយបានជាមានពាក្យថា ថ្ម ។

[២២] គឺជារាជាណាចក្រមួយនៅប្រទេសឥណ្ឌាខាងជើង ប្រហែលជា ២៩គីឡូម៉ែត្រ ខាងត្បូងទីក្រុងដេលី ។

អភិសេកព្រះអនុជឡើយ ។ ដំបូងឡើយ ព្រះវររាជបិតាប្រុងនឹងបញ្ជូនព្រះរាជបុត្រាទាំងបួនអង្គទៀត ឲ្យលើកទ័ពមកច្បាំងនឹងព្រះថោង ដែលទ្រង់ចាត់ទុកថា បានបះបោរប្រឆាំង ។ ក៏ប៉ុន្តែ ដោយព្រះថោង មានការគាំពារច្រើនពីប្រជាជន ព្រះអង្គក៏ប្រែព្រះទ័យ គ្រាន់តែសម្រេចបណ្តេញព្រះថោង ព្រមទាំងបរិវារទាំងអស់ចេញពីព្រះនគរប៉ុណ្ណោះ ហើយទ្រង់ឲ្យនាំយកប្រជាជនពីខេត្រទ័ណ្ឌ៤ទៀត មករស់នៅបំពេញវិញ ។ ព្រះថោង ដែលត្រូវបានគេចាត់ទុកថា កាត់សាសនា ក៏ដឹកនាំប្រជារាស្ត្ររបស់ព្រះអង្គចាកចេញពីប្រទេស មកតាំងនៅលើទឹកដីនគរគោកធ្លក ដែលមានពួកចាមរស់នៅមុនរួចទៅហើយ ។ ការរស់នៅលើទឹកដីគោកធ្លកនេះមិនបានស្រួលទេ ដោយចេះតែមានទំនាស់រវាងពួកចាមម្ចាស់ស្រុក ជាមួយប្រជារាស្ត្ររបស់ព្រះថោង ក៏ក្លាយទៅជាជម្លោះប្រយុទ្ធគ្នាស្លាប់រស់ ។ ពេលនោះ ប្រហែលជាដោយសារមានជំនួយពីជនជាតិដើមផង ព្រះថោង ក៏វាយបណ្តេញពួកចាមបង្ខំឲ្យពួកនេះចាកចេញពីចំប៉ាសាក់ទៅ ។ ព្រះអង្គក៏ឡើងគ្រងរាជ្យជាព្រះរាជា រួចបានអភិសេកបុត្រីរបស់ស្តេចនាគ ជាអគ្គមហេសី ។ ពាក្យថា “នាគ” នេះ ប្រហែលសំដៅយកអ្នកស្រុកដើម គឺពួកខ្មែរនេះឯង ។ ព្រះថោង មិនគ្រាន់តែគ្រប់គ្រងលើទឹកដីក្រុមខុបនិវេសន៍ជ្វាហិណ្ឌូ ដែលព្រះអង្គដណ្តើមបានប៉ុណ្ណោះទេ ប៉ុន្តែ ក៏គ្រប់គ្រងលើទឹកដីដែលស្ថិតក្រោមអំណាចរបស់ព្រះបិតាក្មេកព្រះអង្គផងដែរ ។ ហេតុការណ៍នេះ ជាភស្តុតាងបញ្ជាក់អំពីឃ្លានៃរឿងនិទានដំបូងៗ ដែលនិយាយថា ព្រះថោងជាព្រះរាជាទីមួយរបស់ពួកខ្មែរ បានសេចក្តីថា ពួកជនជាតិដើម ដែលបានរួបរួមជាមួយពួកហិណ្ឌូ ។

## កម្ពុ

ក្រៅពីរឿងនិទានទាំងពីរខាងលើនេះ ដែលគេនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយរហូតមកដល់យើងសព្វថ្ងៃ ប្លែកៗពីគ្នាខ្លះ ក៏ប៉ុន្តែ រក្សាបាននូវរចនាបទដើម ហើយដែលគ្មានសិលាចារឹកណាមួយបានលើកឡើងសោះ ។

នៅមានរឿងព្រេងមួយទៀតស្តីអំពីទេវបុព្វបុរសរបស់ប្រជាជនកម្ពុជា ហើយដែលសិលាចារឹកមួយ បានលើកឡើងដែរ ។ បុព្វបុរសនោះ អាចចាត់ទុកបានថា ជាមនុរបស់ឥណ្ឌូចិន ទ្រង់មានព្រះនាមថា កម្ពុ ហើយជាជីទួតជីលួតរបស់រាល់ព្រះរាជាវង្សនៃក្រោយៗមក ។ ព្រះអង្គបង្ហាញរូបរាងឡើងក្នុងឋានៈជាទេវកថាមួយរបស់ជាតិ ។

តាមកំណត់សម្គាល់មួយនៅទំព័រខាងលើ គេបានឃើញថាពាក្យសំស្ក្រឹត “កម្ពុ” មានន័យថា “ចោរ, ចោរសមុទ្រ” ដែលលោក ហ្សេរីនី បានបកតម្រូវនឹងពាក្យក្រិច “លេស្តៃ” ដែលដែនទីរបស់ ផ្តូលេមេ ប្រើសម្រាប់សម្គាល់ប្រជាជនដែលរស់នៅកូសាំងស៊ីន និងកម្ពុជា ។ ក្នុងករណីនេះ ពាក្យ “លេស្តៃ” គ្រាន់តែជាពាក្យបកប្រែប៉ុណ្ណោះ មិនមែនជាពាក្យសរសេរតាមឈ្មោះដើមរបស់ប្រជាជនដែលរស់នៅទីនោះទេ ។ ខ្ញុំគ្មានជំនឿថា ការដែលមានរឿងប្រហាក់ប្រហែលគ្នានេះ វាមានមូលដ្ឋានច្បាស់លាស់នោះទេ ក៏ប៉ុន្តែការដែលទេវបុព្វបុរសរបស់

ប្រជាជនកម្ពុជាមានឈ្មោះដូចពាក្យដែលមានប្រើនៅលើដែនទីក្រិច ជាកត្តាគ្រប់គ្រាន់សម្រាប់គាំទ្រមតិរបស់លោក ហេរូរីនី ស្តីអំពីបុព្វបុរសរបស់ប្រជាជនដែលយើងកំពុងធ្វើការសិក្សានេះ ។

## ៣- កោណ្ឌញ្ញជ័យវរ្ម័ន

ថ្វីបើមានរឿងព្រេងដែលបានក្លាយទៅជាប្រពៃណីរបស់ប្រជាជនកម្ពុជាទៅហើយ ហើយបើទោះជារឿងព្រេងទាំងនោះ មានមូលដ្ឋានផ្អែកទៅលើប្រវត្តិសាស្ត្រខ្លះក៏ដោយ ក៏គេមិនអាចយករឿងទាំងអស់នោះជាគោល ដើម្បីសរសេរប្រវត្តិសាស្ត្រនៃសម័យកាលនោះ បានទាំងស្រុងដែរ ។

ក៏ប៉ុន្តែ ជាសំណាងល្អសម្រាប់សតវត្សរ៍ទី៥ ដែលយើងនៅមានប្រភពពត៌មានច្បាស់លាស់ផ្សេងទៀត គឺដំបូងមានសិលាចារឹក និងបន្ទាប់មកទៀតមានឯកសារប្រវត្តិសាស្ត្រចិន ដែលយើងបានប្រើប្រាស់ជាច្រើនណាស់មកហើយ សម្រាប់សតវត្សរ៍មុនៗ ។

មកដល់ត្រឹមនេះ រឿងរ៉ាវដែលយើងបានដឹងអំពីព្រាហ្មណ៍ឈ្មោះ កោណ្ឌញ្ញៈ ឬក៏ព្រាហ្មណ៍ត្រកូលកោណ្ឌញ្ញៈ ដែលធ្វើដំណើរចេញពីប្រទេសឥណ្ឌា មកសោយរាជ្យនៅប្រទេសកម្ពុជា មានព្រះនាមថាជ័យវរ្ម័ន មិនប្រាកដថា សុទ្ធតែជារឿងព្រេងទាំងអស់នោះទេ ។

តាមមើលទៅ វាហាក់ដូចជាមានការលុកលុយរបស់ពួកហិណ្ឌូ ប្រហែលជានៅពាក់កណ្ដាលសតវត្សរ៍ទី៥ នៃគ្រិស្តសករាជ ។ ពួកនោះចេញមកពីប្រទេសឥណ្ឌាភាគខាងត្បូង គឺចេញពីតំបន់ដេកង់ ធ្វើដំណើរកាត់ រាជាណាចក្រប៉ានប៉ាន នៅខាងជើងឧទ្វីបកោះម៉ាឡាកា មកកាន់កម្ពុជា ។ មេកោយរបស់ពួកនោះ ឈ្មោះ កោណ្ឌញ្ញៈ បានត្រូវប្រកាសលើកជាស្តេច តាំងតែពីពេលមកដល់ភ្លាម រួចហើយបានប្រកាន់យកឋានៈជាវរ្ម័ន មានន័យថា "អ្នកការពារ" ដូចដែលស្តេចនៃនគរបល្លវៈ នៅឥណ្ឌា និងស្តេចចាម នៅតាមមាត់សមុទ្រខាងកើត នៃឥណ្ឌូចិន តែងតែប្រកាន់យករួចមកហើយ ។ ស្តេចចាមដែលសោយរាជ្យនៅហ្វូណន ដូចដែលរៀបរាប់ពីខាងលើសុទ្ធតែបានប្រកាន់យកឋានៈនេះដូចគ្នា ទោះជាសោយរាជ្យនៅវ្យាធបុរៈ ឬនៅសម្ភុបុរៈ ឬនៅទូទាំងព្រះរាជាណាចក្រទាំងមូលផងក៏មិនដឹង បើរដ្ឋទាំងពីរនេះស្ថិតនៅក្រោមអាណាព្យាបាលរបស់ព្រះរាជាតែមួយព្រះអង្គ ។

រាជធានីរបស់ព្រះបាទកោណ្ឌញ្ញៈ នៅហ្វូណននាពេលនោះ មានឈ្មោះថា អនិន្ទិតបុរៈ ដែលគេមិនទាន់កំណត់រកឃើញទីតាំងពិតប្រាកដបាននៅឡើយ ។ កំណត់ត្រារបស់ពួកចិនហៅរាជធានីនេះថា តូមូ ដែលក្រោយមក គឺជារាជធានីវ្យាធបុរៈ គឺស្រុកព្រៃកប្បាស សព្វថ្ងៃ ។

ព្រះរាជាអង្គនេះ បានក្លាយទៅជាអធិរាជដ៏មានអំណាច មានស្តេចចំណុះជាច្រើន ព្រោះសិលាចារឹកព្រះឥន្ទ្រកោសីយ៍ ដែលខ្ញុំបានរៀបរាប់ខាងលើ ហើយដែលគេចារុំ៨សតវត្សរ៍ក្រោយមក បានរៀបរាប់ថា "ក្រចកព្រះបាទ របស់ព្រះអង្គទៅជារលោងភ្លឺចិញ្ចាច អាស្រ័យដោយប៉ះនឹងមកុដដាំពេជ្ររបស់ស្តេចចំណុះទាំងឡាយ

នៅលើលោកនេះ ដែលចូលមកក្រាបថ្វាយបង្គំគាល់ព្រះអង្គ ។ ព្រះអង្គប្រៀបបានទៅនឹងព្រះអាទិត្យ ទើបនឹងរះ ឬព្រះច័ន្ទពេញវង់ ដែលល្អលើសផ្កាឈូកនៃពូជដូវទាំងឡាយ ។ ព្រះអង្គជាព្រះច័ន្ទនៃត្រកូលកោណ្ឌញ្ញៈ ជាទីប្រជុំនៃគុណធម៌ ។ ជោគជ័យរបស់ព្រះអង្គមានពន្លឺចាំងដូចជាស្វេតច្ឆត្រ ហើយរាជធានីមានពន្លឺភ្លឺចិញ្ចាច ដោយស្នាព្រះហស្តដ៏ខ្លាំងក្លារបស់ព្រះអង្គ ។ មហារាជទាំងឡាយដែលចំណុះព្រះអង្គ គោរពបូជាព្រះអង្គ ប្រៀបបានទៅនឹងទេវតា ស្រីរបាំ និងតន្ត្រីករនៅស្ថានសួគ៌គោរពបូជាព្រះអាទិត្យ» ។

ព្រះបាទកោណ្ឌញ្ញៈគោរពបូជាព្រះសិវៈ ។ សិលាចារឹកបានឲ្យយើងដឹងថា ព្រះអង្គបានកសាង និងសម្ពោធលិង្គប្រមាណជា១០០នៅពាសពេញដែនដីនេះ ពោលគឺ នៅក្នុងព្រះរាជាណាចក្ររបស់ព្រះអង្គ ។

ឯកសារប្រវត្តិសាស្ត្រចិនហៅព្រះអង្គថាការវេនយូ គឺកោណ្ឌញ្ញៈ តាមត្រកូលរបស់ព្រះអង្គ ឬក៏ហៅថា ចូយេប៉ាម៉ូ គឺ ជ័យវរ្ម័ន[២៣] តាមព្រះនាមរបស់ព្រះអង្គពេលគ្រងរាជ្យ ហើយបានកំណត់រជ្ជកាលរបស់ព្រះអង្គចាប់ពីចុងសតវត្សរ៍ទី៥ ដល់ដើមសតវត្សរ៍ទី៦ ពីព្រោះព្រះអង្គបានបញ្ជូនសួយសារអាករថ្វាយស្ដេចក្រុងចិន ២ដង គឺម្ដងនៅឆ្នាំ៤៨៣ និងម្ដងទៀតនៅឆ្នាំ៥០៣ ។ ប្រទេសចិនតែងតែចាត់ទុកប្រទេសជិតខាង ទោះជានៅឆ្ងាយបន្តិចក៏ដោយ ថាជានគរចំណុះ ហើយបានដាក់ឋានៈថ្វាយព្រះបាទកោណ្ឌញ្ញៈ ថាជា «ឧត្តមសេនីយ៍នៃទក្សិណសន្តិភាព ជាព្រះរាជានៃនគរហ្វូណន» ។

ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន បានធ្វើសង្គ្រាមជាមួយប្រទេសចាម នៅរវាងឆ្នាំ៤៨៤ ។ អគ្គរាជទូត ដែលព្រះអង្គបានបញ្ជូនទៅគាល់ស្ដេចក្រុងចិននាពេលនោះ គឺដើម្បីសុំជំនួយពីស្ដេចស្រុកចិនធ្វើសង្គ្រាម ។

អគ្គរាជទូតដែលព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន បញ្ជូនទៅប្រទេសចិនជាពុទ្ធសាសនិកជនម្នាក់ មានឈ្មោះថា សក្យនាគសេន រីឯរាជសារដែលផ្ញើទៅនោះជាលិខិតសាមញ្ញ បង្ហាញអំពីជីវិតមនុស្សម្នាក់ ដែលត្រូវការនូវជំនួយជាចាំបាច់ ។ ព្រះរាជសារនោះ បានបង្ហាញឲ្យយើងដឹងអំពីព្រឹត្តការណ៍សំខាន់មួយ នៅប្រទេសចាម្ប៉ា គឺថាព្រះរាជាចាមពេលនោះ ជាស្ដេចជ្រែករាជ្យ ដែលមានកំណើតជាខ្មែរ គឺពីដើមជាទាសករ ឬបើហៅចណាស់ ក៏ជាអ្នកបម្រើដែរ (ខ្ញុំ) ។ មានឯកសារខ្លះនិយាយថា ស្ដេចចាមនោះ ជារាជបុត្ររបស់ព្រះបាទកោណ្ឌញ្ញៈ មានព្រះនាមថា គាវឈាវឡូ ។ ក្រោយពីបានភៀសខ្លួនចេញពីហ្វូណន ខ្ញុំបម្រើនេះបានបញ្ចុះបញ្ចូលពួកបះបោរ ហើយធ្វើដំណើរទៅកាន់ប្រទេសលីយី ឬចាម ដែលធ្លាប់ច្បាំងចាញ់ម្ដងរួចទៅហើយនៅឆ្នាំ៤៤៦ ដោយ តាន់ហូឆេ រួចក៏ឡើងគ្រងរាជ្យខ្លួនឯងទៅ ។ ពួកចាមក្រោមរជ្ជកាលនៃស្ដេចជ្រែករាជ្យនេះ ធ្លាប់បានវាយប្រហារទៅលើក្បួន

---

[២៣] អ្នកខ្លះនិយាយថា កោណ្ឌញ្ញៈ និងជ័យវរ្ម័ន ជាស្ដេចពីរព្រះអង្គផ្សេងគ្នា ។ តាមពិត ព្រះនាមទាំង២ ជាព្រះនាមរបស់ព្រះអង្គតែម្នាក់ ។

ដង្ហែរាជទូត សក្យនាគសេន ពេលត្រលប់មកពីប្រទេសចិនវិញលើកទី១ ប្ដូរយកទ្រព្យសម្បត្តិទាំងអស់ដែលស្ដេចចិន ផ្ញើថ្វាយស្ដេចនគរហ្វូណន ។ ព្រះបាទកោណ្ឌញ្ញៈ បានបញ្ជូនរាជទូតទៅរាយការណ៍ថ្វាយស្ដេចស្រុកចិន ដោយទូលថា ទ្រព្យសម្បត្តិទាំងឡាយជាទ្រព្យរបស់ស្ដេចស្រុកចិន និងទូលថា ក្នុងនាមខ្ញុំជាស្ដេចចាមនេះព្រងើយកន្តើយមិនបានបញ្ជូនសួយសារអាករថ្វាយព្រះចៅអធិរាជចិនទេ ។ ព្រះរាជសារស្ដេចហ្វូណនចែងថា «បើព្រះអង្គជាម្ចាស់ ទ្រង់ចង់ចាត់តាំងព្រះរាជាថ្មីឲ្យសោយរាជ្យនៅនគរចាម្ប៉ានោះ ទូលព្រះបង្គំជាខ្ញុំទទួលព្រះរាជបញ្ជាដោយគោរព» ។ រាជសារបានបញ្ចប់ ដោយស្នើសុំឲ្យមានការចាត់បញ្ជូនទ័ពមួយកង តាមហែហមស្ដេចហ្វូណនគ្រប់ទិសទីដើម្បីដាក់ទោសពួកក្បត់ និងជួយសង្គ្រោះអ្នកស្លូតត្រង់ ។

តាមមើលទៅ ស្ដេចចិនប្រហែលជាបានបញ្ជូនទ័ពតាមការស្នើសុំមែន ហើយនៅពេលដែលនគរចាម្ប៉ាបានត្រូវបង្ក្រាបធ្វើឲ្យមានសន្តិភាពរួចមក ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័នក៏ត្រូវបានស្ដេចស្រុកចិនដាក់ព្រះឋានៈឲ្យជា«ឧត្ដមសេនីយ៍នៃទក្សិណសន្តិភាព ជាព្រះរាជានគរហ្វូណន» ។

ព្រះរាជាអង្គនេះ បានសោយទិវង្គតនៅឆ្នាំ៥១៤នៃគ្រិស្ដសករាជ ត្រូវនឹងឆ្នាំ៤៣៦នៃមហាសករាជ ។

## ៤- រុទ្រវរ្ម័ន

ព្រះរាជបុត្រាច្បងរបស់ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន ព្រះនាម រុទ្រវរ្ម័ន -ពួកចិនហៅថា លាវតូប៉ាម៉ូ- ជាព្រះរាជបុត្រជាមួយនឹងស្រីស្នំម្នាក់ បានធ្វើគុតព្រះអនុជដែលជាព្រះរាជបុត្ររបស់ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័នជាមួយព្រះរាជអគ្គមហេសី រួចហើយដណ្ដើមយករាជ្យសម្បត្តិ[២៨] ។

ឯកសារចិននាពេលនោះ លែងរៀបរាប់អំពីព្រះរាជាដែលសោយរាជ្យបន្តពីព្រះបាទកោណ្ឌញ្ញជ័យវរ្ម័នទៀតហើយ ។ បើមាននិយាយពីនគរហ្វូណន គឺមានរៀបរាប់តែអំពីទំនៀមទម្លាប់ និងការប្រកបកិច្ចការផ្សេងៗដូចដែលខ្ញុំបានរៀបរាប់ពីខាងលើរួចមកហើយ ។ គ្មាននិយាយអ្វីដែលទាក់ទងដល់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ឬរឿងរ៉ាវអ្វីសំខាន់ទេ ។

---

[២៨] នៅក្នុងតណ្ហចិន និងកម្ពុជាពីមុន ក្សត្រាមួយអង្គអាចនឹងត្រូវជ្រើសរើសឲ្យឡើងសោយរាជ្យបាន លុះត្រាណាតែទ្រង់ជារាជបុត្រប្រសូត្រពីម្ចាស់ក្សត្រីដែលជាប់ខ្សែស្រឡាយជាមួយព្រះរាជា បានសេចក្ដីថាការឡើងស្នងរាជ្យប្រព្រឹត្តទៅតាមខ្សែស្រឡាយខាងស្រី ។ បើទោះជាព្រះក្សត្រានោះជាក្សត្រាច្បងក៏ដោយ តែបើទ្រង់ជាបុត្ររបស់ស្រីស្នំ មិនអាចឡើងសោយរាជ្យបានទេ លើកលែងតែជ្រែករាជ្យ ឬត្រូវជ្រើសរើសដោយនឹងក្រឹត្យក្រម ។

រហូតទាល់តែដល់គ្រិស្តសតវត្សរ៍ទី៦ ទើបឯកសារប្រវត្តិសាស្ត្រចិនមានរៀបរាប់អំពីស្ថានភាពនយោបាយឡើងវិញ ។ នេះគឺមកពីមានព្រឹត្តិការណ៍ធ្ងន់ធ្ងរមួយ បានកើតឡើងនៅហ្វូណន ដែលធ្វើឲ្យប៉ះពាល់ដល់ពាណិជ្ជកម្មរបស់ពួកចិន ។

# ជំពូកទី២
# វយធបុរៈ និងសម្ភុបុរៈ

ដូចដែលខ្ញុំបាននិយាយពីខាងដើមរួចមកហើយ តាមមើលទៅពួកចិនប្រើពាក្យហ្វូណនសម្រាប់ហៅទឹកដីទាំងមូល ដែលលាតសន្ធឹងពីសមុទ្រខាងត្បូង និងពាមនៃទន្លេមេគង្គ រហូតទៅដល់ល្បាក់ខោននៅខាងជើង និងចាប់ពីជួរភ្នំអាណ្ណាមនៅខាងកើត ដែលរួមមានទាំងទឹកដីបិញធន់សព្វថ្ងៃផង រហូតទៅដល់ឈូងសមុទ្រសៀម និងជួរភ្នំតេណាស់សេរីម នៅខាងលិច ហើយអាចរាប់បញ្ចូលទាំងដែនដីចំណុះហិណ្ឌូ មាននៅ តេណាស់សេរីម សមុទ្រមែរហ្គុយ តាវ៉យ និងម៉ាតា ផងដែរ ។

ទឹកដីដ៏ធំធេងនេះជាអាណាចក្រមួយ គ្រប់គ្រងដោយពួកហិណ្ឌូ ពោលគឺ មានប្រជារាស្ត្រជាអ្នកស្រុកដើមដែលកំពុងតែទទួលយកទំនៀមទម្លាប់ប្រពៃណីពួកបរទេស ដែលមកឈ្លានពាន ។ ម្យ៉ាងទៀត អាណាចក្រដ៏ធំនេះនៅមិនទាន់បានបង្រួបបង្រួមដោយព្រះរាជាហ្វូណន មួយអន្តណាមួយនៅឡើយដែរ ។ មានក្សត្រប្រទេសជាច្រើន ដែលក្សត្រមួយអង្គៗ យល់ព្រមធ្វើជាចំណុះនគរហ្វូណន ក៏ដោយសារប្រទេសនេះមានអំណាចខ្លាំងក្លាជាង ព្រោះគ្រប់គ្រងមាត់ពាមទន្លេមេគង្គ ។ ក៏ប៉ុន្តែ ក្សត្រប្រទេសនីមួយៗឯករាជដាច់ៗពីគ្នា មិនមានចំណុះគ្នាទេ គឺស្ថិតនៅក្រោមការត្រួតត្រារបស់មហាក្សត្ររបស់ខ្លួន ដែលចំណុះឲ្យព្រះរាជាហ្វូណន ។

ម្យ៉ាងទៀត វាហាក់ដូចជាបណ្តាក្សត្រប្រទេសទាំងអស់នោះ មានស្តេចសោយរាជ្យ ឬក៏មេកោយជាក្សត្រដែលមានឈាមជ័រជាហិណ្ឌូ ចេញពីត្រកូលតែមួយ បើហោចណាស់ ក៏ចំពោះបណ្តាប្រទេសដែលនៅជាប់នឹងមាត់សមុទ្រខាងត្បូងដែរ ។ ក្សត្រទាំងអស់នោះមានព្រះឋានៈជា "វរ្ម័ន" មានន័យថា "អ្នកការពារ"[១] ។ ពួកគេច្រើន

---

[១] ពាក្យថា វរ្ម័ន នេះ ជាឋានៈសម្រាប់ភ្ជាប់ពីខាងចុងឈ្មោះ ពួកក្សត្រិយៈ ដូចជាពាក្យ ស៍ម័ន សម្រាប់ភ្ជាប់ទៅនឹងឈ្មោះពួកព្រាហ្មណៈ ពាក្យ គុប្តៈ សម្រាប់ភ្ជាប់ពីខាងចុងឈ្មោះ ពួកវេស្សៈ និងពាក្យ ទាសៈ សម្រាប់ភ្ជាប់ពីខាងចុងឈ្មោះរបស់ ពួកសូទ្រៈ អីចឹងដែរ ។ វរ្ម័នដូចជា ព្រហ្ម័ន និងស៍ម័នដែរ គឺដូរំឡើងពីពាក្យ វរៈ មានន័យថា គ្របដណ្តប់ លាក់ ។ រីឯពាក្យ ម័ន ជាពាក្យឥណ្ឌូអឺរ៉ុបត្រូវនឹងពាក្យឡាតាំងថា men ដូចពាក្យថា ag-men, car-men, no-men គឺជានាមនបុំសកលិង្គ កម្រជានាមបុំលិង្គណាស់ និងជាការណនាមដូចជាពាក្យ kar-man មានន័យថាសកម្មភាព ពាក្យ pre-man មានន័យថា ស្នេហា ។ ពាក្យនេះក៏អាចសំដៅយកវត្ថុដែលគេប្រើសម្រាប់ធ្វើសកម្មភាពអ្វីមួយផងដែរ ដូចពាក្យថា tokh-man មានន័យថាគ្រាប់ពូជ ។ ពាក្យសំស្ក្រឹត វរ្ម័ន អាចមានន័យថា ប្រើសម្រាប់ការពារ ដូចជាអាវុធការពារ ខែល ប្រៀបបានទៅនឹងពាក្យ គុបតិ ប្រែថា ការពារ ហើយបានក្លាយទៅជាសំណាង់ការពារ ។ ន័យដើមរបស់ពាក្យនេះបានប្រែប្រួលទៅតាមពាក្យក្លាយនីមួយៗ ដូចជា នម័ន ឡាតាំងថា no-men ប្រែថានាម ពាក្យ ពែក្ស as-men ប្រែថា មេឃ ។ ពាក្យ នបុំសកលិង្គ នេះ ត្រូវគ្នានឹងពាក្យជាការកនាម ដូចជា ព្រហ្ម័ន, វរ្ម័ន មានន័យថា អ្នកដែលការពារ ។ ព្រហ្ម័ន និងក្សត្រិយៈ

គោរពបូជាព្រះសិវៈ ឬព្រះវិស្ណុ ក៏ប៉ុន្តែ ប្រជាជនបានកាន់ព្រះពុទ្ធសាសនារួចទៅហើយ[២] ។

តាមមើលទៅ បណ្តាក្សត្រប្រទេសទាំងអស់នោះ ប្រហែលជាមានច្បាំងគ្នាទៅវិញទៅមកជាញឹកញាប់ ដូចនៅប្រទេសបារាំងកាលពីសម័យយុគកណ្តាលអឺរ៉ុបដែរ ដែលស្តេចត្រាញ់ច្បាំងគ្នាទៅវិញទៅមក តែព្រះចៅអធិរាជ មិនមានធ្វើអន្តរាគមន៍អ្វីទេ ដរាបណាស្តេចត្រាញ់នីមួយៗនោះមិនបានគេចវេះចេញពីការគ្រប់គ្រងរបស់ព្រះអង្គ ឬក៏មិនបានលះបង់កាតព្វកិច្ចជាសម្ភារៈ ឬជាស្មារតី ដែលមានផលប្រយោជន៍ដល់ព្រះអង្គទេ ។ មានក្សត្រប្រទេសពីរដែលប្រកួតប្រជែងគ្នាជាពិសេស ៖ មួយគឺរដ្ឋដែលមានរាជធានីនៅវ្យាធបុរៈ គឺនៅត្រង់អង្គរបុរី (នគររាជបុរី) នៅក្នុងខេត្តព្រៃកប្បាសសព្វថ្ងៃ ដែលមានសំណល់ប្រាសាទនៅឡើយ ។ ក្សត្រប្រទេសមួយទៀតមានរាជធានីនៅសម្ភុបុរៈ (មានន័យថារាជធានីរបស់សម្ភុ – គឺព្រះសិវៈ) ដែលមានគឹកគាំងប្រាសាទសេសសល់នៅសម្បូរសព្វថ្ងៃ ជាទីរួមស្រុកមួយនៅក្នុងខេត្តក្រចេះ ។

## ១- ស្រីស្រុតវរ្ម័ន

នៅសតវត្សរ៍ទី៥ នៃសករាជ ព្រះរាជានៃនគរវ្យាធបុរៈ (មានន័យថានគរអ្នកប្រមាញ់) ព្រះនាមព្រះបាទស្រីស្រុតវរ្ម័ន (មានន័យថា អ្នកការពារពពួកវេទ) បានច្បាំងបង្រួបបង្រួម ហើយសោយរាជ្យលើក្សត្រប្រទេសទាំងពីរ ។

## ២- ស្រីស្រេស្ឋវរ្ម័ន

ព្រះរាជាដែលសោយរាជ្យបន្តពីព្រះបាទស្រីស្រុតវរ្ម័ន មានព្រះនាមថា ព្រះបាទស្រីស្រេស្ឋវរ្ម័ន (មានន័យថា អ្នកការពារដ៏ប្រសើរ) ។

ឯកសារប្រវត្តិសាស្ត្រចិននៅចុងសតវត្សរ៍ទី៦ បាននិយាយអំពីរាជាណាចក្រថ្មី ដែលកើតឡើងពីការបង្រួបបង្រួមក្សត្រប្រទេសទាំងពីរ ដោយដាក់ឈ្មោះថា ចេនឡា ។ ឯកសារបានលើកឡើងថា រាជាណាចក្រនេះពីមុនជាចំណុះរបស់នគរហ្វូណន ហើយព្រះរាជារបស់រាជាណាចក្រនេះទ្រង់មានព្រះឋានៈជាព្រះអធិរាជ ទោះបី

---

គឺជាជម្រក (ស៍ម័ន) និងជាអ្នកការពារ (វរ្ម័ន) របស់ពួកវេស្សៈ ដែលមានឋានៈ គុប្តៈ មានន័យថាអ្នកដែលគេការពារ ។

[២] កោះសិរីលង្កាដូចជាដូរកាន់ព្រះពុទ្ធសាសនានៅរវាងឆ្នាំ៤៣០ ហើយ ជ្វា និងចាម្ប៉ា ក៏ប្រហែលជាបានទទួលឥទ្ធិពលនាពេលនោះដែរ ។ រីឯប្រទេសចិនវិញ បានទទួលព្រះពុទ្ធសាសនា៣សតវត្សរ៍រួចមកហើយ ហើយសតវត្សរ៍ទី៤ ទី៥ និងទី៦ ជាសម័យដែលមហារាជចិនបញ្ជូនរាជទូតទៅប្រទេសឥណ្ឌាចម្លងគម្ពីរ និងធ្វើទស្សនកិច្ចទៅកាន់ទីកន្លែងកំណើតរបស់ព្រះពុទ្ធ ។

ព្រះអង្គចំណុះ និងលើកសួយសារអាករឲ្យនគរហ្វូណន ក៏ដោយ ។ ព្រះអង្គបានវាយដណ្តើមយកសម្ភុបុរៈ ដាក់បញ្ចូលមកក្នុងវ្យាធបុរៈរបស់ព្រះអង្គ ហើយប្រហែលជាបានវាយយកក្សត្រប្រទេសច្រើនទៀតផងដែរ គឺដោយហេតុនោះ ទើបព្រះអង្គទ្រង់ប្រកាន់យកព្រះឋានៈជាព្រះអធិរាជ ព្រោះព្រះអង្គ និងបុព្វបុរសរបស់ព្រះអង្គបានធ្វើឲ្យក្សត្រឯទៀតៗចូលមកជាចំណុះ ។

## ៣- ស្រីវីរវរ្ម័ន

ព្រះរាជាដែលសោយរាជ្យបន្តពីព្រះបាទស្រីស្រេស្ឋវរ្ម័ន អាចជាព្រះបាទស្រីវីរវរ្ម័ន[៣] ដែលតាមមើលទៅគឺជាព្រះរាជាចុងក្រោយរបស់វ្យាធបុរៈ ដែលលើកសួយសារអាករថ្វាយព្រះបាទរុទ្រវរ្ម័ន (មានន័យថា អ្នកការពាររុទ្រ) នៃនគរហ្វូណន ជាបច្ឆាញាតិព្រាហ្មណ៍កោណ្ឌញ្ញៈ ។

[៣] ព្រះរាជាអង្គនេះមិនមានព្រះនាមនៅក្នុងបណ្តាព្រះរាជានៃប្រទេសកម្ពុជា សម័យមុនអាណាចក្រខ្មែរ របស់លោក ម៉ាស្ពេរ៉ូ ទេ ។ ខ្ញុំគិតថាលោក ម៉ាស្ពេរ៉ូគួរ តែរាប់បញ្ចូលព្រះអង្គផង ។

# ជំពូកទី៣
# អំពីកម្ពុជា ឬ ស្រុកខ្មែរ

## ៤- ស្រីភវវរ្ម័ន

ព្រះរាជបុត្រ និងជាអ្នកស្នងរាជ្យបន្តពីព្រះបាទស្រីវីរវរ្ម័ន គឺព្រះបាទស្រីភវវរ្ម័ន (មានន័យថា អ្នកការពារភវៈ) ។ ព្រះរាជាអង្គនេះក្លាហានលើសពីព្រះបិតារបស់ព្រះអង្គទៅទៀត ។ ឆ្លៀតឱកាសដែលព្រះបាទរុទ្រវរ្ម័នសោយទិវង្គតទៅនៅរវាងដើមសតវត្សរ៍ទី៧ ព្រះអង្គបានចាប់ធ្វើការវាយប្រហារទៅលើនគរហ្វូណន កាន់កាប់រាជធានី រួច «ដណ្ដើមអំណាចប្រកបដោយវីរភាព» ។ បន្ទាប់មក អាស្រ័យដោយភាពអង់អាចរបស់ពលរេហ៍របស់ព្រះអង្គ ទ្រង់បានប្រមូលយកបណ្ដារដ្ឋទាំងឡាយដែលធ្លាប់ចំណុះនគរហ្វូណនពីមុន ដែលប្រហែលជាកំពុងតែរើបម្រះខ្លួនរកឯករាជ្យជាមួយនឹងព្រឹត្តិការណ៍ដែលកើតឡើងថ្មីៗ ដាក់មកក្រោមអាណាព្យាបាលរបស់ព្រះអង្គវិញ ។

សិលាចារឹកបានពិពណ៌នាពីព្រះរាជាអង្គនេះថា «ជាអ្នកចម្បាំងដ៏អង់អាចក្លាហាន, ជាវីរបុរសមានចិត្តសប្បុរស មិនចេះចាញ់ វិសេសប្រៀបបានទៅនឹងភ្នំព្រះសុមេរុ, ជាប់អម្បូរព្រះអាទិត្យ, អាចវាយបង្ក្រាបទាំងសត្រូវខាងក្នុង[១] និងខាងក្រៅបាន, ជាទ្រមាក់ដ៏វីរដ៏ពូកែ, ជាអ្នកដាក់ទានដែលមានព្រះហស្តសើមជានិច្ច - អាស្រ័យដោយទឹកដែលគេចាក់លើព្រះហស្ត រាល់ពេលដែលទ្រង់ដាក់ទាន[២] ។ សិលាចារឹកបានបន្ថែមទៀតថា ទឹកន្លែងណាដែលព្រះអង្គទ្រង់បានប្រើព្រះកាយពលដណ្ដើមយកបាន ហើយទីនោះនឹងត្រូវបានទទួលនូវការសន្ដោសប្រណីពីព្រះអង្គ ហើយបណ្ដាសត្រូវទាំងឡាយ នាំគ្នាមកថ្វាយបង្គំគាល់ព្រះអង្គនៅក្នុងព្រះរាជវាំង ទោះជាអ្នកទាំងនោះមិនបានត្រូវព្រះអង្គវាយបង្ក្រាបឲ្យចុះចាញ់ក្នុងសង្គ្រាមក៏ដោយ[៣] ។

ព្រះបាទភវវរ្ម័នប្រហែលជាបានវាតព្រះនគររហូតទល់ភ្នំដងរែក ហើយបានវាយបង្ក្រាប «បណ្ដាស្ដេចភ្នំ» ពោលគឺ បណ្ដាវិប្រជាមិនទាន់ស៊ីវិល័យ ដែលរស់នៅតាមជងភ្នំ និងខ្ពង់រាប ដូចជាសព្វថ្ងៃនេះដែរ តាមមើលទៅ គឺពួកជង ដែលរស់នៅសម្បូរក្នុងបណ្ដាខេត្រខាងលិច ចាប់ពីកែបនៅមាត់ឈូងសមុទ្រសៀម រហូតដល់ភាគខាងលើចន្ទគាប៊ុន ក្នុងនោះ មានទាំងជួរភ្នំខាងលិចខេត្រពោធិសាត់ផងដែរ និងពួកស៊ូឡាង ប្ញឡាងហ្វូង ដែលជាបុព្វបុរស

---

[១] គឺពួកបះបោរ មិនមែនតណ្ហា ដូចដែលអ្នកខ្លះបកប្រែ នោះទេ ។

[២] តាមសិលាចារឹកភ្នំហាន់ជ័យ ។

[៣] សិលាចារឹកអង្គជំនឹក ។

របស់ពួកម័យ ឬម្ន័យ ឬរ៉ម័យសព្វថ្ងៃ ដែលរស់នៅលើជម្រាលជួរភ្នំអាណ្ណាម នៅចន្លោះនគរ ចាម្ប៉ា និងកម្ពុជា ។

មានសិលាចារឹកមួយ ចារ៉ុក្នុងរជ្ជកាលរបស់ព្រះរាជាអង្គនេះ ជាសិលាចារឹកដែលមានវ័យចំណាស់ជាងគេនៅកម្ពុជា ហើយដែលគេរកឃើញនៅក្នុងខេត្របាត់ដំបង តែឆ្ងាយពីរាជធានី គឺនៅរហូតដល់ខេត្រ ព្រៃកប្បាស បានបញ្ជាក់ពីហេតុការណ៍ខាងលើនេះ ។ ព្រះបាទភវវរ្ម័ន ទ្រង់ប្រហែលជាបានលើកទ័ពធ្វើសង្គ្រាមឆ្ងាយ ទៅទិសខាងជើង ដើម្បីវាយយកបណ្ដាប្រទេសនៅខាងត្បូងភ្នំដងរែក និងប្រមូលយកហ្វូណនខាងត្បូង ទាំងមូល ដាក់នៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គ ។ នៅពេលនោះ វាហាក់ដូចជាថាបណ្ដាប្រទេសដែលយើង ហៅសព្វថ្ងៃថាជាសៀម ដែលចិនហៅថា ឈេទូ បានឆ្លៀតយកឱកាសនោះ ក្នុងពេលដែលព្រះបាទភវវរ្ម័ន ជាព្រះរាជានៃ វយធបុរៈ ធ្វើសង្គ្រាមដណ្ដើមយកហ្វូណន ដើម្បីរើបម្រះចេញពីអាណាព្យាបាលរបស់ស្ដេចតូមូ ហើយប្រកាសឯករាជ្យ ។ ឯកសារប្រវត្តិសាស្ត្រចិនបានឲ្យយើងដឹងថា រាជាណាចក្រឈេទូ ដែលដំបូងឡើយ ជារដ្ឋឯករាជបន្ទាប់មក បានត្រូវហ្វាន់ម៉ាន់ បង្ក្រាបដាក់ឲ្យចំណុះនគរហ្វូណន នាពេលនោះទទួលបាននូវសេរីភាព ឡើងវិញ ។ ដោយហេតុនេះ មានរាជាណាចក្រធំៗពីរកើតឡើងនៅដើមសតវត្សរ៍ទី៦ ជាជំនួសនគរហ្វូណន[៤] គឺ ចេនឡាដែលក្រោយមកក្លាយជាកម្ពុជា និងឈេទូ ដែលក្រោយមក គឺប្រទេសសៀម ។

នៅពេលដែលស្ដេចស្រី ភវវរ្ម័ន ទ្រង់សោយទិវង្គតទៅ គេបានប្រមើលថា ព្រះអង្គទ្រង់បានទៅចាប់កំណើតឯស្ថានសួគ៍របស់ព្រះសិវៈ ព្រោះព្រះអង្គទ្រង់ប្រកាន់យកព្រះនាមថា ជាភវៈ ដែលជាព្រះនាមមួយរបស់ព្រះសិវៈ ហើយគេបានថ្វាយព្រះនាមថា ជាភវៈបទ ។

គម្ពីរវិស្ណុបុរណៈ ហាក់ដូចជាមាននិយាយពីព្រះបាទភវវរ្ម័ននេះផងដែរ ត្រង់វគ្គស្ដីពីសក្កទ្វីប ដែលយើងបាន ឃើញពីខាងលើរួចមកហើយ គឺជាឈ្មោះសំដៅយក កម្ពុជា នេះឯង ដោយបានលើកឡើងថា ព្រះរាជាទ្រង់ព្រះនាមថា ភវ្យៈ ទ្រង់បានរៀបចំព្រះរាជាណាចក្ររបស់ព្រះអង្គជា៣ស្រុក ដែលមានឈ្មោះថា ជលទៈ, កុមារៈ

[៤] គឺនៅសម័យនោះហើយ ដែលឯកសារប្រវត្តិសាស្ត្រចិនឈប់ហៅប្រទេសដែលពួកគេតែងដាក់ឈ្មោះឲ្យថា “ព្រះរាជាណាចក្រនៃមនុស្សស្រាត” ថាជា ហ្វូណន ទៀតហើយៗបែរមកហៅថាប៉ូណនវិញ ។ លោក ពែលីយ៉ូ ក្នុងសៀវភៅរបស់គាត់ឈ្មោះហ្វូណន ត្រង់ទំព័រទី២៨៤ បាននិយាយថា ខ្ញុំគិតថា “ព្រះរាជាណាចក្រនៃមនុស្សស្រាត”នេះ មិនមែនជា ឈ្មោះរបស់ស្រុកទេ គឺគ្រាន់តែជាការហៅដោយពួកចិនដែលភ្ញាក់ផ្អើលនឹងឃើញអ្នកស្រុកគ្មានសម្លៀកបំពាក់ប៉ុណ្ណោះ ។ ម្យ៉ាងទៀត ចិនក៏មានហៅស្រុកច្រើនទៀតដូច្នេះដែរ ។ ទោះជាយ៉ាងណាក្ដី ឈ្មោះដែលចិនដាក់ឲ្យកម្ពុជានាពេលនោះ មិនមែនជាឈ្មោះដែលអ្នកស្រុកដាក់ខ្លួនឯងទេ ទាំងឈ្មោះចេនឡាទាំងឈ្មោះ ហ្វូណន គឺអ្នកស្រុកមិនបានស្គាល់ដូចគ្នា ។ មិនមានឯកសារបញ្ជាក់ថា ឈ្មោះទាំងអស់នេះបានត្រូវគេចងចាំនៅក្នុងប្រពៃណីរបស់ប្រទេសទេ ហើយឈ្មោះនោះសោតទៀតក៏គ្មានប្រហាក់ប្រហែលអ្វីសូម្បីតែបន្តិច ទៅនឹងពាក្យខ្មែរ បុហិណ្ឌូ បុម៉ាឡេ ដែរ ។

*និងសុកាមារៈ ។ លោកវរសេនីយ៍ឯក ហ្សេរីនី បានផ្គួផ្គងស្រុកទី១ ទៅនឹងចេនឡាទឹក គឺដែនដីសណ្តទន្លេមេគង្គ, រីឯស្រុកទី២ និងទី៣ក៏ជាស្រុកនៅភាគខាងត្បូងកម្ពុជាដែរ ។ គម្ពីរវិស្ណុបុរណៈបានប្រដៅថែមទៀតថា ស្រុកនោះមានជួរភ្នំដែលមានឈ្មោះថា ឧទ័យគិរី, ស្យាមៈ និងអាស្តៈគិរី ដែលធ្វើឲ្យយើងនឹកឃើញ ដល់ឧទ័យៈ, សៀម និងលេស្តែ ដែលយើងបានឃើញពីខាងលើរួចមកហើយ ហើយដែលជាឈ្មោះរបស់កម្ពុជា និងខបសម្ព័ន្ធសៀមនោះឯង ។ តាមពិតទៅ ការប្រើពាក្យ«ស្យាមៈ»នៅសតវត្សរ៍ទី៦ ហាក់ដូចជាមិនទាន់ត្រឹមត្រូវទេ បើសិនជាថា គេចង់សំដៅយកប្រទេសរបស់ពួកថៃ ឬសៀម ។ ប៉ុន្តែ នោះប្រហែលជាការសំដៅយកកុលសម្ព័ន្ធមួយ ដែលប្រជាជនមានស្បែកខ្មៅជាងអ្នកជិតខាងបន្តិច ហើយរស់នៅជិតភ្នំ ដូចជាកុលសម្ព័ន្ធសាមរដ្ឋៈ ដែលមានរាជធានីនៅខាងពាយ័ព្យឆកសមុទ្រសៀម ត្រង់កន្លែងស្រីវិជ័យសព្វថ្ងៃ ។*

*គម្ពីរវិស្ណុបុរណៈ ក៏មានរៀបរាប់ផងដែរ អំពីទន្លេឈ្មោះ សុកុមារិ, កុមារិ និងនាលិនិ ទន្លេក្រោយនេះ លោក ហ្សេរីនី ថា គឺជាទន្លេមេគង្គនេះឯង ។*

## ៥- ចិត្រសេនា-ស្រីមហេន្ទ្រវរ្ម័ន (... -៦១០)

*ព្រះរាជបុត្ររបស់ព្រះបាទភវវរ្ម័ន មិនបានសោយរាជ្យទេ ប៉ុន្តែ គឺព្រះរាជបុត្រពៅរបស់ព្រះបាទវីរវរ្ម័ន ព្រះនាមថា ចិត្រសេនា «ដែលទ្រង់ប្រកបទៅដោយកេតនភណ្ឌជាព្រះករុណាជាម្ចាស់»[៥] ដែលឡើងគ្រងរាជ្យសម្បត្តិក្រោមព្រះនាមថាស្រីមហេន្ទ្រវរ្ម័ន (ព្រះឥន្ទ្រជាអ្នកការពារ) ហើយប្រហែលចាប់តាំងពីពេលនោះមក នៅកម្ពុជាក៏ដូចជានៅចាម្ប៉ា និងម៉ាឡាយូ ទំនៀមទម្លាប់ចង់ឲ្យព្រះអនុជឡើងសោយរាជ្យបន្តពីព្រះរៀម ដើម្បីឲ្យមានព្រះរាជាជាបុរសរហូតតទៅ ។*

*ព្រះបាទមហេន្ទ្រវរ្ម័នទ្រង់បានបន្តនយោបាយរបស់ព្រះរៀម ហើយបានបញ្ចប់ការវាយបង្ក្រាបបណ្តូខែត្រ ដែលព្រះបាទភវវរ្ម័នមិនទាន់បានដណ្តើមដាក់ជាចំណុះ ។*

*ទ្រង់មានមន្ត្រី២នាក់បម្រើព្រះអង្គ គឺធម្មទេវៈ និងសីម្ហទេវៈ ដែលជាបងប្អូនជីដូនមួយនឹងគ្នា ព្រោះជាកូន*

---

*[៥] បាថ, សិលាចារឹកសំស្ក្រឹតនៅភូឡូខាន់, ចុះផ្សាយក្នុងព្រឹត្តប័ត្រសាលាបារាំងចុងបូព៌ា ខែកក្កដា-កញ្ញា ។ ឯកសារប្រវត្តិសាស្ត្រចិនពីឆ្នាំ៥៨៩ ដល់ ៦១៨ ថ្វាយព្រះនាមថា ជាក្សត្រិយៈ -ឆាលី- ដែលតាមពិតគឺជាវណ្ណៈរបស់ព្រះអង្គ ហើយបាននិយាយទៀតថា ព្រះនាមផ្ទាល់ព្រះអង្គគឺឆេតូសឺណា គឺត្រសេន ក៏ប៉ុន្តែមិនបានប្រាប់ព្រះអភិសេកនាមទេ ។ ឯកសារបាននិយាយទៀតថា ព្រះអង្គមានសញ្ជាតិជាគូឡុង ។ ពាក្យគូឡុងនេះ ភាសាម៉ាឡេថាគួនលួន គឺសំដៅយកពួកម៉ាឡេនេះឯង ។ តែខ្ញុំឯកភាពតាមលោក អែម៉ូនីញេ ថា ពាក្យគូឡុងនេះជាការអានមិនច្បាស់នូវពាក្យខ្មែរ-ម៉ាឡេថា ក្រុង មានន័យថារដ្ឋ, ទីក្រុង, រាជធានី តែក៏មានន័យថាស្តេច ផងដែរ ។ បើដូច្នេះ សញ្ជាតិគូឡុង មានន័យថា សញ្ជាតិជាស្តេច ។*

របស់ព្រាហ្មណ៍២នាក់បងប្អូន ព្រាហ្មទត្តៈ និងព្រាហ្មសីម្ហៈ ។ អ្នកទាំង២នេះធ្លាប់ជាមន្ត្រីរបស់ព្រះបាទភវវរ្ម័ន ហើយព្រះបាទមហេន្ទ្រវរ្ម័នពិនិត្យឃើញថាជាទីប្រឹក្សាល្អ ទ្រង់ក៏រក្សាទុក ព្រោះ «ពួកគេនេះ ចេះចាំច្បាស់លាស់ អំពីវិទ្យាសាស្ត្រត្រឹមត្រូវ និងវិទ្យាសាស្ត្រមានផលប្រយោជន៍» មានន័យថា ជាអ្នកអនុវត្តជាក់ស្តែង និងត្រឹមត្រូវ ។ មន្ត្រីទាំង២នាក់នេះ ជាជំនួយដែលជួយឲ្យព្រះអង្គទទួលបាននូវជ័យជម្នះ ។ ទ្រង់បានចាត់ឲ្យសីម្ហទេវៈ ទៅធ្វើការចរចាជាមួយនគរចាម្ប៉ា ដើម្បីរក្សាចំណងមេត្រីភាពរវាងព្រះរាជាកម្ពុជានឹងព្រះរាជាចាម ។ បេសកកម្មនេះ ទទួលបានជោគជ័យ ហើយសន្តិភាពត្រូវបានធានា[6] ។

ព្រះបាទមហេន្ទ្រវរ្ម័នទ្រង់សោយទិវង្គតនៅឆ្នាំ៦១០នៃគ្រិស្តករាជ ត្រូវនឹងឆ្នាំ៥៣២នៃមហាសករាជ ។

## ៦- ឦសានវរ្ម័ន (៦១០-...)

ព្រះរាជបុត្ររបស់ព្រះបាទមហេន្ទ្រវរ្ម័ន បានឡើងសោយរាជ្យបន្តពីព្រះអង្គក្រោមព្រះនាមថា ស្រីឦសានវរ្ម័ន (មានន័យថា ព្រះឦសាន[7]ជាអ្នកការពារ ឬព្រះរាជាជាអ្នកការពារ) ។ ទ្រង់បានប្រកាសព្រះអង្គថា «ជាដៃគូរបស់ចក្រៈ (គឺព្រះឥន្ទ្រ) អំពីកម្លាំង, និងជាដៃគូរបស់ហរិ (គឺវិស្ណុ) អំពីកិត្តិគុណ[8], ជាព្រះធិរាជលើស្តេចទាំង៣ និងជាម្ចាស់នៃរាជធានីមិនរង្គើទាំង៣[9]» តាមមើលទៅគឺចក្រានកបុរៈ, អមោឃរបុរៈ និងភីមបុរៈ[10]

---

[6] សិលាចារឹកអង្គជំនីក កម្រងក្បាលទី១ ទំព័រ៦៨-៧០ ។

[7] ឦសានៈ ក៏ជាឈ្មោះមួយរបស់ព្រះសិវៈដែរ ។

[8] សិលាចារឹកវត្តចក្រឹត កម្រងក្បាលទី១ ទំព័រ៤២ ។

[9] សិលាចារឹកស្វាយឆ្នូ កម្រងក្បាលទី១ ទំព័រ៤៦ ។

[10] ចក្រានបុរៈ =ទីក្រុងនៃទម្រថាស ឬទីក្រុងរបស់ព្រះវិស្ណុ ប្រហែលគឺជីក្រែង ។ អមោឃរបុរៈ =ទីក្រុងរបស់អមឃៈ ដែលជាឈ្មោះមួយទៀតរបស់ព្រះសិវៈ មានន័យដែរថា ដែលកសាងឡើងមិនអត់ប្រយោជន៍ ប្រហែលគឺបាត់ដំបង ។ ភីមបុរៈ =ទីក្រុងរបស់ ភីមៈ មានន័យថា ទីក្រុងចម្លែក ប្រហែលជាភីម៉ៃ នៅលើទន្លេសេមូន ។ សូមអានសៀវភៅរបស់លោក អែម៉ូនីញេ ដែលមានឈ្មោះថា កម្ពុជា ក្បាលទី២ ទំព័រ១១៨ និង៣០២ ។

តទៅនេះគឺជាឈ្មោះទីក្រុងមួយចំនួន ដែលមានចែងនៅក្នុងសិលាចារឹក ៖ អគ្របុរៈ =ទីក្រុងបវរ, អទ្រិវ្យបុរៈ ឬវ្យាធបុរៈ =ទីក្រុងនៃព្រានព្រៃភ្នំ (អង្គរបុរី នៅក្នុងព្រៃកប្បាស), អនិន្ទិតបុរៈ =ទីក្រុងមិនចេះជិនឆ្អន់, អទ្យបុរៈ =ទីក្រុងសម្បូរសប្បាយ, អមរទេវី =នៅខាងជើង, បណ្តូរង្គ =ដានរ៉ាង នៅខាងត្បូង, រនទ័យមទៈ =នៅខាងលិច, អវិតគ្រាមៈ =ទីក្រុងពាពែ, ឥន្ទ្របុរៈ =ទីក្រុងព្រះ ឥន្ទ្រ, ខគ្របុរៈ =ទីក្រុងនៃខគ្រៈ គឺព្រះសិវៈ, កម្ពុបុរី =ទីក្រុងរបស់កម្ពុ គឺប្រហែលជាឦសានបុរី, យសោធបុរី ឬឥន្ទបត្ត =អង្គរធំ, អមោឃបុរៈ =ទីក្រុងដែលសង់ឡើងមិនអត់ប្រយោជន៍ ឬទីក្រុងរបស់អមោឃៈ គឺព្រះសិវៈ មិនរសាត់អណ្តែត, ចក្រានកបុរៈ =ទីក្រុងទម្រថាស គឺជីក្រែង, វរទគ្រាមៈ =ទីក្រុងនៃឧបការីបុគ្គល, ភីមបុរៈ =ទីក្រុងនៃអ្នកគួរឲ្យខ្លាច គឺព្រះសិវៈ,

ដែលទ្រង់វាយដណ្ដើមយកបាន ប៉ុន្តែ ទុកឲ្យស្ដេចរាជធានីនីមួយៗនៅគ្រប់គ្រងដដែលគ្រាន់តែស្ដេចទាំងនោះនៅជាចំណុះព្រះអគ្គ ។ ព្រះរាជាអគ្គនេះទ្រង់ជាស្ដេចវាតទឹកដីដូចជាព្រះរាជាមុនៗដែរ ។ ទ្រង់បានពង្រីកព្រះរាជាណាចក្ររបស់ព្រះអគ្គពាសពេញទាំងទឹកដីហ្វូណន ។

ព្រះអគ្គមានរាជធានីដែលមានឈ្មោះតាមព្រះអគ្គ គឺឦសានបុរៈ មានន័យថា រាជធានីរបស់ឦសាន ។ មើលទៅ ប្រហែលជាទ្រង់មានរាជធានីមួយផ្សេងទៀត រាជធានីឦសានបុរៈនេះគ្រាន់តែជារាជធានីបណ្ដោះអាសន្ន ហើយឈ្មោះ ឦសាន នេះ ជាហៅក្រៅ ។ ឯកសារប្រវត្តិសាស្ត្រចិន[11]និយាយថា រាជធានីនេះ មានផ្ទះ២ម៉ឺនខ្នង និងមានសាលធំមួយនៅកណ្ដាល ជាទីកន្លែងដែលព្រះរាជាធ្វើសវនាការ ។

ឯកសារចិនដដែលនិយាយថា រាជាណាចក្ររបស់ព្រះអគ្គមានចែកជាក្រុងចំនួន៣០[12] ក្រុងនីមួយៗ មានអភិបាលម្នាក់ មានឋានៈដូចគ្នានឹងឋានៈអភិបាលក្រុងនគរលីនយី (ចាម្ប៉ា) ហើយមានមន្ត្រីធំៗចែកជា ៥ ប្រភេទ គឺ គូតូឈី, កាវសៀងភីង, ដូតូតូទីង, ចេម៉ាលីង និងយ៉ានតូប៉ូ[13] ។ នៅពីក្រោមអ្នកមានបណ្ដាសក្តិទាំងនេះ មានមន្ត្រីថ្នាក់ក្រោមជាច្រើនទៀត ។

ព្រះរាជាទ្រង់គង់នៅក្នុងសាលាដែលនិយាយខាងលើរាល់៣ថ្ងៃម្ដង ប្រថាប់លើគ្រែលម្អទៅដោយគ្រឿងក្រអូប៥យ៉ាង និងត្បូងមានតម្លៃ៧ប្រភេទ នៅពីក្រោមបុស្បុកមួយធ្វើអំពីក្រណាត់ ។ សសរទ្រូបុស្បុកនេះធ្វើពីឈើមានតម្លៃ តែងលម្អទៅដោយភ្លុកនឹងផ្កាមាស ។ ដូចជានៅវាំងស្ដេចឈេទូដែរ (គឺប្រទេសសៀម) មានសេនា២នាក់កាន់ជើងក្រានមាសដុតគ្រឿងក្រអូប ឈរនៅជិតព្រះរាជាជាប្រចាំ ។

---

វរយេទ្រូបុរៈ =ទីក្រុងពួកព្រាហ្មណ៍, ទ្វីរទបុរៈ =ទីក្រុងដំរី គឺលផ្នែក, ទ្វនវីរបុរៈ =ទីក្រុងស្រូវ, ទ្វរបុរៈ =ទីក្រុងចោរ ប្រហែលតែមួយជាមួយ ហវបុរៈ =ទីក្រុងនៃយញ្ញ, នរវរនគរ =រាជធានីអ្នកយាម, នរេន្ទ្រគ្រាម =ទីក្រុងព្រះអគ្គម្ចាស់, ភីមបុរៈ =ទីក្រុងអស្ចារ្យ, ភូវនគ្របុរៈ, លិង្គបុរៈ =ទីក្រុងនៃលិង្គ, ហរិបុរៈ =ទីក្រុងព្រះវិស្ណុ, វីរបុរៈ, ហវបុរី =ទីក្រុងសួយសារអាករ, សម្ភុបុរៈ =ទីក្រុងរបស់អ្នកប្រាជ្ញ ។

[11] រាជពង្សាវតាររាជវង្សស៊ុយ ដែលសោយរាជ្យពីឆ្នាំ៥៨៩ ដល់ ៦១៨ ។ សូមអានសៀវភៅលោក ពែលីយ៉ូ ឈ្មោះ នគរហ្វូណន ទំព័រ២៧២ និងទំនៀមទម្លាប់ខ្មែរ ភាគ២ ទំព័រ១២៣ ។

[12] ទីក្រុងមួយដណ្ដើមបានពីស្ដេចពាលមួយអគ្គ មានឈ្មោះថាទម្របុរី =ទីក្រុងស្ពាន់ (សិលាចារឹកវត្តចក្រឹត កម្រងក្បាលទី១ ទំព័រ៤២-៤៣, ទីក្រុងមួយទៀតឈ្មោះថា អធ្យបុរី =ទីក្រុងអ្នកមាន (សិលាចារឹកអគ្គជំនឹក កម្រងក្បាលទី១ ទំព័រ៧១) ។

[13] គេអាចកំណត់ឃើញយ៉ាងច្បាស់នូវឈ្មោះពិតប្រាកដរបស់ឋានៈនីមួយៗ ដែលចិនអានបំភ្លៃខុសជាខ្លាំង ដូចជាដូតូតូទីង ត្រូវនឹងពហុទេព ឬពហុទេវៈ, ចេម៉ាលីង ត្រូវនឹង យោមរាជ, ឋានៈទីមួយសំដៅយកមន្ត្រីទទួកបន្ទុកពន្ធអាករ, ឋានៈទី២ សំដៅយកមន្ត្រីយុត្តិធម៌ ។

រាជពង្សាវតារស៊ើបញ្ជាក់ទៀតថា ៖ ពេលទ្រង់ចេញជួបជាមួយប្រជារាស្ត្រ ព្រះរាជាទ្រង់គ្របដណ្តប់ព្រះកាយដោយក្រណាត់ត្បាញពីកប្បាសត្រឹមចង្កេះចុះដល់ក្បាលជង្គង់ និងទ្រង់ពាក់មកុដលម្អទៅដោយគជ់និងត្បូងមានតម្លៃ ។ ព្រះស្រោត (ត្រចៀក) ព្រះអង្គមានលម្អទៅដោយបន្តោងមាស ។ ទ្រង់គ្រងព្រះពស្ត្រពណ៌សជានិច្ច រីឯព្រះសុព័ណ៌បាទធ្វើអំពីចំបើងគ្រប់ពណ៌មានលម្អទៅដោយភ្លុក ។

នាម៉ឺនសព្វមុខមន្ត្រីមានសម្លៀកបំពាក់ប្រហាក់ប្រហែលនឹងព្រះរាជាដែរ ហើយថ្វាយបង្គំក្បាលដល់ដី ៣ដង នៅនឹងកាំជណ្តើរព្រះរាជបល្ល័ង្ក ពេលចូលគាល់ព្រះអង្គម្តងៗ ។ កាលណាព្រះរាជាបញ្ជាឲ្យក្រោកឡើង ពួកគេលូនឡើង រួចលុតជង្គង់ ដាក់ដៃប្រណម្យលើដើមទ្រូង អង្គុយផ្ទាល់ដី លើកន្ទេលប្ញកម្រាលដែលក្រាលនៅជុំវិញព្រះមហាក្សត្រ ដើម្បីពិភាក្សាកិច្ចការព្រះរាជាណាចក្រជាមួយព្រះអង្គ ។ ចប់សវនាការ មន្ត្រីទាំងនោះ ក្រាបថ្វាយបង្គំព្រះរាជាម្តងទៀត មុននឹងចាកចេញទៅ ។ ក្នុងពេលធ្វើសវនាការ មានពលសេនារាប់ពាន់នាក់ប្រដាប់ទៅដោយ ខែល និងលំពែង ឈរយាមនៅមាត់ច្រកចូល ។

ឯកសារចិនបាននិយាយថែមទៀតថា ក្រោមការគ្រប់គ្រងរបស់ព្រះរាជាអង្គនេះ ព្រះរាជាណាចក្រកម្ពុជាបានចងសម្ព័ន្ធមេត្រីភាពជាមួយនគរចាម្ប៉ា (សានប៉ាន) និងឈូក្រង (?) ក៏ប៉ុន្តែ បានធ្វើសង្គ្រាមជារឿយៗជាមួយនគរលីនយី[១៤] និងថូយន់[១៥] (គឺចាម្ប៉ាធំ និងចាម្ប៉ា នៅផានរ៉ាង) ។ ឯកសារនោះបានបន្តទៀតថា កាលណាមានព្រះរាជាមួយអង្គឡើងសោយរាជ្យ គេត្រូវកាត់ម្រាមដៃមួយ ឬកាត់ច្រមុះព្រះរៀម និងព្រះអនុជទាំងអស់ រួចយកព្រះរៀម ឬព្រះអនុជទាំងអស់នោះ ទៅទុកមួយកន្លែង ប៉ុន្តែ មានការថែទាំបានល្អ ។ ការដែលឯកសារចិននិយាយពីព្រឹត្តការណ៍ពិសេសបែបនេះ តែចាត់ទុកដូចជារឿងធម្មតាដូច្នេះ ប្រហែលជាមានមូលហេតុអ្វីមួយមិនខាន ។

ឯកសាររាជវង្សថាង (៦២៥) ហៅប្រជាជនកម្ពុជាថា គីម៉ាយ គឺខ្មែរ ហើយថា ពួកនេះមានរាងទាប (គឺទាបជាងចិន) មានសម្បុរខ្មៅ ប៉ុន្តែ ស្រីៗភាគច្រើនស ។ ទាំងប្រុសទាំងស្រីបួងសក់ និងពាក់ក្រវិលនៅត្រចៀក ។

---

[១៤] ពាក្យថាសានប៉ានជាពាក្យថ្មីដែលចិនហៅចាម្ប៉ា ។ តាមធម្មតា ពាក្យលីនយីរបស់ចិនសំដៅយកនគរចាម្ប៉ាទាំងមូល តែពេលនេះសានប៉ាន ប្រហែលសំដៅយកចាម្ប៉ាតាមឆ្នេរសមុទ្រកណ្តាល រីឯលីនយីសំដៅយកចាម្ប៉ាតាមឆ្នេរសមុទ្រខាងជើង ។

ឯកសារឈ្មោះ ត្សហ្វ៊ូយន់កុ្វ និយាយថា នៅឆ្នាំ៦៤២ ស្តេចនគរលីនយីបានបញ្ជូនទូតទៅគាល់ស្តេចចិន ដោយទូលថា នគរលីនយី ត្រូវនគរហ្វូណនវាយប្រហារ និងស្នើសុំជំនួយពីស្តេចចិន ។ សេចក្តីត្រង់នេះមានសារសំខាន់ណាស់ ព្រោះវាបញ្ជាក់ពីអរិភាពរវាង ហ្វូណន និងលីនយីនៅពាក់កណ្តាលទី១នៃសតវត្សរ៍ទី៧ ។ ខ្ញុំមិនដឹងថា តើនៅឆ្នាំ៦៤២ នោះ ស្តេចភ្ញាសានវរ្ម័ន ដែលឡើងសោយរាជ្យនៅឆ្នាំ៦១០ នៅសោយរាជ្យសម្បត្តិនៅឡើយ ឬក៏ព្រះបាទជ័យវរ្ម័ន បានឡើងគ្រងរាជ្យបន្តពីព្រះអង្គទៅហើយទេ ។

[១៥] តាមមើលទៅ ពាក្យធន់ នៅក្នុងឈ្មោះបឹញធន់សព្វថ្ងៃ ប្រហែលក្លាយមកពីថូយន់តាមចិនហៅនេះឯង ។

ពួកគេមានមាឌមាំ ហើយសកម្ម ។ ផ្ទះបែរមុខទៅកើត ហើយដូចផ្ទះពួកឈេទូ (សៀម) ដែរ ។

ដៃស្ដាំជាដៃបរិសុទ្ធ ឯដៃឆ្វេងមិនបរិសុទ្ធទេ នេះប្រហែលមកពីគេប្រើដៃឆ្វេងជុសលាងក្រោយបន្ទោរបង់ ។ ពួកគឺម៉ាយខស្សរាហ៍ផ្លូតទឹក និងយកចិត្តទុកដាក់ថែរក្សាធ្មេញណាស់ ដោយដុសសម្អាតនឹងច្រាសធ្វើពីឈើទន់ៗ ដូចដែលគេនៅអនុវត្តសព្វថ្ងៃនៅឥណ្ឌាអឺចីង ។

ក្រោយពីបានអានគម្ពីរ និងសូត្រធម៌រួច គេផ្លូតទឹក ដុសធ្មេញ រួចទើបទទួលទានអាហារ ។ ទទួលទានអាហាររួច គេដុសធ្មេញ រួចសូត្រធម៌ទៀត ។ ទាំងអស់នេះជាពិធីតាមព្រហ្មញ្ញសាសនា ហើយបញ្ជាក់ថា បុព្វបុរសរបស់ពួកខ្មែរនាសម័យនោះគោរពព្រះព្រហ្ម ដូចដែលពួកគេគោរពសាសនាព្រះពុទ្ធសព្វថ្ងៃនេះដែរ ។ តែត្រូវដឹងថា នេះជាទំនៀមទម្លាប់របស់ថ្នាក់ដឹកនាំតែប៉ុណ្ណោះ ប្រហែលមិនមែនសម្រាប់អ្នកស្រុក និងអ្នកស្រែចម្ការនោះទេ ។

អ្នកសរសេរប្រវត្តិសាស្ត្រចិនបាននិយាយទៀតថា ៖ កូនកំលោះមិនលើកជំនូនអាពាហ៍ពិពាហ៍ឲ្យខាងកូនក្រមុំទេ ក្រៅតែពីសំពត់មួយ ។ មេអណ្ដើក (មហា) ទៅជួបកូនស្រី ហើយគ្រួសារទាំង២មិនចេញពីផ្ទះ អស់រយៈពេល៨ថ្ងៃ ដោយអង្គុយនៅកណ្ដាលពន្លឺចង្កៀង ។ ពេលរៀបការរួច ប្ដីប្រពន្ធថ្មីនាំគ្នាទៅរស់នៅលើផ្ទះថ្មីរបស់គេ ដោយនាំយកទៅជាមួយនូវកេរ្តិ៍ដែលម៉ែឪចែកឲ្យ ។ ដល់ម៉ែឪស្លាប់ទៅ កូនកំលោះនោះអាចបែង ចែកកេរ្តិ៍ឪពុកជាមួយបងប្អូនប្រុសស្រីរបស់គេឯទៀត ដោយមិនគិតពីទ្រព្យដែលគេបានទទួលនៅពេលរៀបការនោះឡើយ ។ នៅកម្ពុជាសព្វថ្ងៃ គេនៅតែអនុវត្តដូច្នេះនៅឡើយ ។

ខុសពីសព្វថ្ងៃ គេមិនកោរសក់ទេ កាលណាឪពុកម្ដាយស្លាប់[១៦] គឺគេទុកសក់ឲ្យដុះកន្ទ្រើង ។ តែគេយំស្រែកខ្លាំងៗ ដូចដែលនៅមានអនុវត្តនៅឡើយនៅតាមស្រុកស្រែចម្ការខ្លះ ។ គេបូជាសព រើសយកធាតុដាក់ក្នុងកោដិធ្វើអំពីមាស ប្រាក់ ឬដីតាមតែលទ្ធភាពដែលគេមាន រួចយកទៅទម្លាក់កណ្ដាលស្ទឹងទន្លេ ។ ជួនកាល (សព្វថ្ងៃនៅមានអនុវត្តដូចនេះដែរ) គេមិនបូជាទេ តែទុកសពចោលក្នុងព្រៃឲ្យសត្វសាហាវស៊ី ។ នេះចាត់ទុកដូចជាទុករាងកាយបុគ្គលឲ្យសត្វស៊ី, ឲ្យត្រូវខ្យល់ គឺធាតុមួយក្នុងបណ្ដាធាតុទាំង៤, គឺដូចជាការធ្វើទានដូច្នេះដែរ[១៧] ។

មានឯកសារប្រវត្តិសាស្ត្រចិនផ្សេងៗទៀត ដែលរៀបរាប់ចំណុចប្លែកៗថា ៖ តាមធម្មតា គេដាក់ស្លា ទៀនធូប

---

[១៦] គេបានឃើញពីខាងលើថាគេកោរសក់ក្នុងឱកាសនេះ ។ អាចថាគេបកប្រែច្រឡំ ឬមួយក៏ថាទំនៀមនេះមានបន្តបន្ទាប់គ្នាដូច្នេះ ចំពោះប្រជាជនមានសញ្ជាតិ២ផ្សេងគ្នា ។ ជាក់ស្ដែង ពួកខ្មែរកោរសក់នៅពេលកាន់ទុក្ខ រីឯពួកពួនវិញ គេលែងសក់មិនបួងទេ គឺទុកសក់ឲ្យគ្មានសណ្ដាប់ធ្នាប់ និងមិនយកចិត្តទុកដាក់ក្នុងការថែទាំខ្លួនឯងទេ ដូចដែលពួកជ្វីហ្វប្រកាន់យកពីមុនដែរ ។

[១៧] សព្វថ្ងៃនេះពួកពុទ្ធសាសនិកជននិយាយថា «ទុកសាកសពឲ្យជាចំណីសត្វលើផែនដី និងក្នុងអាកាស» ដូចដែលព្រះពោធិសត្វមួយព្រះអង្គបានធ្វើទានខ្លួនព្រះអង្គឲ្យសត្វស៊ី, ក៏ប៉ុន្តែជួនកាលគេនិយាយតាមទំនៀមព្រហ្មញ្ញសាសនាថា «ដាក់ទានសាច់របស់ខ្លួនថ្វាយខ្យល់, ព្រះពាយ ។ល ។»

និងទឹកអប់ទទួលភ្ញៀវ ។ គេមិនដែលដាក់សុរាទទួលភ្ញៀវទេ ព្រោះសុរានេះគេផឹកលាក់លៀមតែជាមួយប្រពន្ធ កំបាំងពីភ្នែកឪពុកម្ដាយប៉ុណ្ណោះ ។ ម្យ៉ាងទៀត ពេលជួបអ្នកធំដោយចៃដន្យនៅកន្លែងណាមួយ គេត្រូវបែរខ្នងឲ្យ ដើម្បីជាការសំដែងការគោរព និងដើម្បីកុំឲ្យរំខានអ្នកធំនោះផង ។

មានរឿងមួយដែលឯកសារចិននោះបានរៀបរាប់ ហើយធ្វើឲ្យយើងមានការងឿងឆ្ងល់ជាខ្លាំង គឺថានៅក្នុងប្រទេសនេះ ដែលជាប្រទេសមួយសម្បូរហូរហៀរ និងមានអារ្យធម៌ទៅហើយនោះ ប្រជារាស្ត្រមិនស្លៀកសម្លៀកបំពាក់ទេ ដើរទៅណាមកណាននលគកខ្លួនទទេ[១៨] ហើយសើចចំអកឲ្យអ្នកដែលស្លៀកសម្លៀកបំពាក់ទៅវិញ ។ ពួកគេមិនបរិភោគអំបិល មិនប្រើប្រាស់ដែកទេ គេបាញ់សត្វនឹងព្រួញធ្នូដែលធ្វើពីឫស្សី ។ ត្រង់នេះគេត្រូវយល់ថា គេនិយាយតែអំពីអ្នកស្រុក អ្នកស្រែចម្ការ ពោលគឺ អ្នកស្រុកដើម ដែលនៅមិនទាន់ស៊ីវិល័យប៉ុណ្ណោះ មិនសំដៅយកអ្នកទីក្រុងដែលមានដើមកំណើតហិណ្ឌូ ឬកាត់ហិណ្ឌូជាមួយនឹងស្រីស្រុកអាយ ឬអ្នករដ្ឋវាសី ដែលស៊ីវិល័យរួចទៅហើយ អាស្រ័យដោយមានទំនាក់ទំនងជាមួយជនបរទេសនោះទេ ។ ម្យ៉ាងទៀត គេត្រូវគិតផងដែរថា រាជធានីថ្មីបានផ្លាស់ប្ដូរទៅកន្លែងថ្មី នៅឆ្ងាយពីរាជធានីចាស់ដែលហ្វាន់ស៊ីយុនបានបញ្ជាឲ្យប្រុសៗទម្លាប់ស្លៀកពាក់បិទបាំងកេរ្តិ៍ភេទ[១៩] ។

មានការកត់សម្គាល់សំខាន់មួយដោយជនជាតិចិនម្នាក់នៅដើមសតវត្សរ៍ទី១២ ថាទីក្រុងទាំងអស់សុទ្ធតែមានកំផែងការពារព័ទ្ធជុំវិញ និងថាអ្នកស្រុកមានទំនៀមទម្លាប់ដូចអ្នកស្រុកឈេនឈីង[២០] ដែរ គឺនគរចាម្ប៉ាដែលគេហៅតាមឈ្មោះរាជធានី ។ គួររំលឹកថា គេបានឃើញពីខាងលើថាមានចិនម្នាក់បានសរសេរនៅរវាងឆ្នាំ

---

[១៨] យើងបានឃើញពីខាងលើហើយ ថាគេបានបញ្ជាឲ្យប្រុសៗស្លៀកប៉ឹង ដូចគ្នានឹងកានម៉ាន ឬអាវទ្រនាប់ស្រីៗ ។

[១៩] ភស្តុតាងនៃហេតុការណ៍ស្ថិតនៅលើត្រង់ថា មានឯកសារមួយមានឈ្មោះថា "អភិប្រាយស្ដីពីពួកអនារ្យជន" ដែលពួកចិនសរសេរប៉ុន្មានសតវត្សរ៍ក្រោយមក គឺនៅសតវត្សរ៍ ទី១២ តែដកស្រង់ព័ត៌មានចេញពីអ្នកនិពន្ធមុនៗនូវអ្វីដែលពួកគេបានដឹងអំពីកម្ពុជា បានរៀបរាប់ថា "អ្នកស្រុកមិនដើរលែងខ្លួនទទេនោះទេ គឺស្លៀកសម្លៀកបំពាក់ខ្លីៗ និង មានខ្សែក្រវាត់ធ្វើពីក្រណាត់ ។ ប៉ុន្តែនៅតាមបណ្ដាស្រុកចំណុះដែលនៅឆ្ងាយពីរាជធានី មានអ្នកស្រុកនៅលែងខ្លួនទទេ ហើយសើចចំអកឲ្យអ្នកណាដែលស្លៀកសម្លៀកបំពាក់ ។ ពត៌មាននេះ ដែលមានតាំងពីសតវត្សរ៍ទី១២មកម្ល៉េះ បើផ្ទួជាមួយពត៌មានដែលមាននៅសតវត្សរ៍ទី៧ បញ្ជាក់ឲ្យយើងដឹងថា អ្នកស្រុកដែលរស់នៅជិតទីក្រុង ទីប្រជុំជនធំៗ ចាប់ផ្ដើមស្លៀកសម្លៀកបំពាក់ជាបណ្ដើរៗ ។ អ្នកដែលមិនស្លៀកសម្លៀកបំពាក់មានតែនៅទីឆ្ងាយៗ ក្នុងបណ្ដាវិប្រជាចំណុះផ្សេងៗ ។ រឿងនេះគ្មានអ្វីធ្វើឲ្យយើងងឿងឆ្ងល់នោះទេ ព្រោះរហូតមកដល់សព្វថ្ងៃនេះ ក៏នៅមានប្រជារាស្ត្រដែលស្លៀកប៉ឹងនៅឡើយ នៅកម្ពុជា ហើយក៏មានអ្នកខ្លះ ដូចជាពួកព្នង ស្ទៀង និងស្អូច ដែលរស់នៅវាលរញេញជាដើម នៅដើរលែងខ្លួនទទេដផងដែរកាលពីមួយសតវត្សរ៍មុននេះ ។

[២០] ឈេនឈីង នេះ ជាឈ្មោះរាជធានីរបស់នគរចាម្ប៉ាកាលពីសតវត្សរ៍ទី១១ ហើយក៏ប្រហែលជាដើមកំណើតរបស់ពាក្យ កូសាំងស៊ីន ដែលគេប្រើសម្រាប់ហៅអាណ្ណាមរហូតមកទល់សតវត្សរ៍មុននេះ ។

៦១៧ថា ទម្លាប់បវេណីដែលគេប្រើនៅរាជវាំងស្តេចកម្ពុជា ដូចគ្នាទៅនឹងទម្លាប់បវេណីនៅវាំងស្តេច ឈេទូ គឺប្រទេសសៀមសព្វថ្ងៃដែរ ។ ដោយហេតុនេះ យើងអាចសន្និដ្ឋានបានថា នគរចាម្ប៉ា, សៀម និងកម្ពុជា នៅសម័យនោះ រួមគ្នាបង្កើតបានជាអាណាខេត្រដ៏ធំមួយនៅក្នុងឥណ្ឌូចិន ដែលមានទំនៀមទម្លាប់ប្រពៃណី សម្លៀកបំពាក់ និងសាសនា មិនសូវខុសគ្នាប៉ុន្មានទេ ។ អ្នកស្រុក គឺជាប្រជារាស្ត្រដើម ដែលទទួលយកសាសនា ឬក៏អារ្យធម៌ហិណ្ឌូហើយតាំងទីលំនៅ នៅតាមមាត់សមុទ្រខាងត្បូងនៃឥណ្ឌូចិន និងមានពួកកុលសម្ព័ន្ធរដ្ឋវាសី រស់នៅព័ទ្ធជុំវិញពួកនេះកំពុងទទួលនូវអារ្យធម៌ពីពួកមុន ហើយចាប់អនុវត្តតាមទម្លាប់ថ្មី ដូចគ្នាជាបណ្តើរៗដែរ ។

អ្នកប្រវត្តិសាស្ត្ររបស់រាជវង្សស៊ុំ បានបញ្ចប់ការពណ៌នារបស់ខ្លួន ដោយនិយាយថា នៅជិតរាជធានី ដែលគេហៅថា ត្បូសានៈតាមព្រះនាមរបស់ព្រះរាជា មានភ្នំមួយឈ្មោះថា លិងគាប៉ូហ្វូ ដែលនៅពីលើកំពូលភ្នំ នោះ មានប្រាសាទមួយ មានពលទាហាន៥០០០នាក់ការពារ ។ មានប្រាសាទមួយទៀតនៅពីខាងកើតរាជធានី កសាងឡើងដើម្បីឧទ្ទិសថ្វាយព្រលឹងហ្វូតូលី មានសេនា១០០០ការពារ ជាទីកន្លែងដែលព្រះរាជាបូជាមនុស្ស ម្នាក់ រាល់ៗឆ្នាំ ។ សេចក្តីត្រង់នេះនៃឯកសារប្រវត្តិសាស្ត្រចិនធ្វើឲ្យយើងគិតឃើញថា ព្រះបាទត្បូសានវរ្ម័ន គឺជា ព្រះរាជាខ្មែរទី១ ដែលបានប្តូររាជធានីទៅនៅខាងជើងបឹងទន្លេសាប ដើម្បីឲ្យបាននៅចំកណ្តាលព្រះនគរ ត្រង់ កន្លែងដែលមានប្រាសាទបុរាណបាក់បែកសល់ពីរាជធានីខ្មែរពីមុន គឺអង្គរធំ ឬមហានគរ ។ បើដូច្នេះមែន ប្រាសាទទី១ខាងលើគឺប្រាសាទភ្នំបាខែង ដែលសង់ឡើងបូជាដល់ព្រះសិវៈ ដោយគោរពបូជាក្រោមរូបភាពជា លិង្គ (លិងគា) ឯប្រាសាទទី២ គឺប្រាសាទសង់បូជាព្រះនាងកាឡី (ហ្វូតូលី) ដែលនៅក្រៅនគរធំពីខាងកើត ។ ព្រះ បាទត្បូសានវរ្ម័ន ពិតជាបានផ្លាស់រាជធានីទៅនៅមាត់បឹងទន្លេសាបមែន ក៏ប៉ុន្តែគេមិនត្រូវសន្និដ្ឋានថា ព្រះអង្គជា អ្នកកសាងរាជធានីអង្គរធំនោះទេ ហើយត្បូសានបុរៈក៏មិនមែនជារាជធានីដែលមានរបងព័ទ្ធជុំវិញ ដូចដែលយើង ស្គាល់ដោយសំណល់បាក់បែកសព្វថ្ងៃនេះដែរ ។

យើងបានឃើញពីខាងដើមថាព្រះពុទ្ធសាសនាមានគេគោរពបូជាហើយនៅក្នុងនគរហ្វូណន ចាប់តាំង ពីពេលចាប់ផ្តើមនៃរាជាណាចក្រនេះម៉្លេះ និងថាព្រះបាទកោណ្ឌញ្ញជ័យវរ្ម័នក៏ទ្រង់គោរពសាសនានេះដែរ ថ្វីបើ ព្រះអង្គជាអ្នកគោរពបូជាព្រះសិវៈ (ព្រះអង្គបានឲ្យគេកសាងលិង្គ១០០ដាក់ពាសពេញរាជធានី) ក៏ដោយ ។ គឺពុទ្ធសាសនិកម្នាក់ឈ្មោះ សក្យនាគសេន មានដើមកំណើតហិណ្ឌូ ដែលព្រះអង្គចាត់ជារាជទូតទៅគាល់ស្តេចចិន សុំជំនួយប្រឆាំងស្តេចជ្រែករាជ្យនៅចាម្ប៉ា (ជាខ្មែរម្នាក់ ដែលអាចជាបុត្រព្រះអង្គផង) ។

តាមពិតសាសនាទាំង២និកាយនេះអាចនៅជាមួយគ្នាបាន ហើយគេតែងតែឃើញរូបព្រះពុទ្ធនៅលាយឡំ គ្នាជាមួយអាទិទេពខាងព្រហ្មញ្ញសាសនា នៅតាមសាលាសំណាក់នានាដែលអ្នកដំណើរចូលស្នាក់អាស្រ័យដែរ ។ បូជនីយេសក៍ជាតិចិនម្នាក់ឈ្មោះ យីស៊ីង ដែលធ្វើដំណើរកាត់បណ្តារាជាណាចក្រនៅតាមមាត់សមុទ្រខាងត្បូង ពីឆ្នាំ៦៧១ដល់៦៩៥ បាននិយាយថា «ធម៌ព្រះពុទ្ធបានចម្រុងចម្រើន និងរីករាលដាល ស្រាប់តែមានស្តេច

កំណាចមួយអង្គមកបំបែកបំបាក់បំផ្លាញអស់ទៅ»[២១] ។

ការបំបែកបំបាក់ពុទ្ធសាសនិកជននេះប្រហែលជាកើតមាននៅក្រោមរាជ្យព្រះរាជាដែលកាន់ព្រហ្មញ្ញសាសនាព្រះនាមស្រីឦសានៈ ព្រោះវាត្រូវនឹងពេលដែលកើតមាននូវជំនឿថ្មីមួយ គឺការគោរពបូជាហរិហរៈ ជាការតំណាងព្រះសិវៈ និងព្រះវិស្ណុក្រោមទម្រង់ជា «សម្ភូ រួមគ្នាក្នុងរាងកាយព្រះហរិ» ប៉ុន្តែ ក៏អាចមាននៅក្រោមព្រះរាជាដែលសោយរាជ្យតពីព្រះអង្គ គឺព្រះបាទជ័យវរ្ម័ន ដែលសោយរាជ្យនៅរវាងឆ្នាំ៦៦១ ។ មិនមានសិលាចារឹក ឬរឿងព្រេងនិទានណា ដែលបញ្ជាក់អំពីការបំបែកបំបាក់ពុទ្ធសានិកជននេះទេ ក៏ប៉ុន្តែ ព្រះពុទ្ធសាសនាបានត្រូវបំផ្លិចបំផ្លាញខ្ទេចខ្ទី ស្ទើរគ្មានសល់ ។ យើងនឹងបានឃើញតទៅទៀតថា និកាយសាសនានេះ ក្រោយពីមានជ័យជម្នះលើព្រហ្មញ្ញសាសនារួចហើយ មិនចេះតែឈ្នះរហូតដោយគ្មានការប្រយុទ្ធនោះទេ ហើយថាមានបរាជ័យខ្លះៗដែរ មុននឹងត្រូវបានការពារដោយនាម៉ឺនសព្វមុខមន្ត្រី និងព្រះរាជា ហើយនៅទីបញ្ចប់មានស្ដេចជ្រែករាជ្យមួយអង្គ ប្រកាន់យកជាសាសនាជាផ្លូវការរបស់មហានគរ ។

## ៧- ជ័យវរ្ម័ន (៦៦៧-...)

ព្រះរាជាដែលឡើងសោយរាជ្យបន្តពីព្រះបាទឦសានវរ្ម័ន គឺព្រះបាទជ័យវរ្ម័នទី១ «អ្នកការពារប្រកបដោយជ័យជម្នះ» ។ ទ្រង់ហាក់ដូចជាព្រះរាជាសន្តិភាពនិយមមួយអង្គ យកចិត្តទុកដាក់ក្នុងការគ្រប់គ្រងប្រទេស និងថែរក្សាទឹកដីដែលព្រះរាជាមុនៗដណ្ដើមបាន ជាជាងការវាតទឹកដីជាបន្តទៀត ។ អ្វីដែលគេបានដឹងពីព្រះអង្គ គឺទ្រង់សោយរាជ្យពីឆ្នាំ៦៦៤ ដល់ ៦៦៧ ហើយសិលាចារឹកបាននិយាយពីព្រះអង្គថា «ជាស្ដេចសិង្ហអបរាជ័យ បរិបូណ៌ដោយកិត្តិគុណ» និងថា «ព្រះអង្គប៉ិនប្រសប់ក្នុងការការពារពិភពលោក» ទ្រង់មានចក្ខុវិស័យឈ្លាសវៃ ដែលធ្វើឲ្យព្រះអង្គក្លាយជាសហស្រាស្កសៈ មានន័យថា «មានព្រះនេត្រមួយពាន់» ដែលជាព្រះនាមមួយរបស់ព្រះឥន្ទ្រាធិរាជ ។

ព្រះអង្គមានបុត្ររបស់ព្រាហ្មទត្តៈ និងសីម្ហទេវៈ ដែលជាមន្ត្រីរបស់ព្រះរាជាមុនៗ ជាមន្ត្រីនៅក្នុងវាំងព្រះអង្គ ។ បុត្ររបស់ព្រាហ្មណ៍ទីមួយមានឈ្មោះថា សីម្ហវីរៈ មានន័យថាជា «សត្វសិង្ហព្រៃពីកំណើត តែជាអ្នកប្រាជ្ញដែលបណ្ឌិតទាំងឡាយតាមចូលរៀនសូត្រ» ធ្លាប់ជាមន្ត្រីរបស់ព្រះបាទឦសានវរ្ម័ន ហើយបន្តមកធ្វើជាមន្ត្រីរបស់ព្រះបាទជ័យវរ្ម័នទៀត ។ រីឯបុត្ររបស់ព្រាហ្មណ៍ទី២ មានឈ្មោះថា សីម្ហទត្តៈ ជាគ្រូពេទ្យរបស់ព្រះរាជា ។ ព្រាហ្មណ៍នេះ «ចេះចាំនូវអ្វីទាំងអស់ដែលគេអាចចេះដឹងបាន» ។ ព្រះរាជាបានប្រគល់ព្រាហ្មណ៍នេះ ថ្វាយព្រះ

---

[២១] តាមលោក ពែលីយ៉ូ ក្នុងសៀវភៅឈ្មោះ នគរហ្វូណាន ទំព័រ២៨៤ ។

បិតុលា ជា “ព្រះអនុជរបស់ព្រះមាតា មិនបានសោយរាជ្យសម្បត្តិ ក៏ប៉ុន្តែទ្រង់ប្រកបទៅដោយភោគទ្រព្យសក្តិសមជាព្រះរាជាមួយអង្គ” រួចក្រោយមកទ្រង់បានតែងតាំងឲ្យធ្វើជាអភិបាលនៃអនិន្ទ្យបុរៈ (ទីក្រុងសម្បូរសប្បាយ) ។ អភិបាលក្រុងនេះលុបបំបាត់ពន្ធអាករលើសួនច្បារដំណាំ ជាការលុបបំបាត់ដ៏ត្រឹមត្រូវ ដែលជាហេតុធ្វើឲ្យកម្មសិទ្ធិករទាំងឡាយក្លាយទៅជាមាន[២២] ។

[២២] សិលាចារឹកវត្តព្រៃវ័ល្ល និងអង្គជំនឹក កម្រងទី១ ទំព័រ៦០ និង៦៩ ។

# ជំពូកទី៤
# កំណត់សម្គាល់អំពីប្រជាជនដែលមានទំនាក់ទំនងជាមួយកម្ពុជាមុនសតវត្សរ៍ទី៨ ចាម្ប៉ា, អាណ្ណាម-តុងកឹង, ឧបទ្វីបកោះម៉ាឡាកា, ឈាម ឬសៀម, ឥណ្ឌា និងចិន

*ឥឡូវនេះ យើងចូលមកដល់ដើមសតវត្សរ៍ទី៧ នៅពេលដែលអាណាចក្រកម្ពុជាបានកកើតឡើង ហើយភូមិភាគកណ្តាលនៃឥណ្ឌូចិនទាំងមូល ត្រូវស្ថិតនៅក្រោមការត្រួតត្រារបស់រាជវង្សវរ្ម័ន ឬ"អ្នកការពារក្សត្រប្រទេសទាំង១០១" ដូចដែលមានរៀបរាប់នៅក្នុងរឿងព្រេងនិទាន ។ មកដល់ត្រឹមនេះ យើងគួរនាំគ្នាពិនិត្យមើលប្រជាជាតិទាំងឡាយដែលរស់នៅជុំវិញ ហើយដែលអាចនឹងមានឥទ្ធិពលខ្លះៗ មកលើអាណាចក្រនេះម្តង ។*

## ១- នគរចាម្ប៉ា

*ប្រជាជាតិមួយដែលនៅជិតជាងគេ ហើយដែលពួកកម្ពុជៈហិណ្ឌូត្រូវប្រយុទ្ធទប់ទល់មុនគេនោះគឺ ប្រជាជាតិចាម មានកំណើតដើមមកពីម៉ាឡេស៊ី ឬជ្វា ដែលមកតាំងទីលំនៅ នៅលើឆ្នេរសមុទ្រខាងត្បូង និងខាងនិរតីឥណ្ឌូចិន ដោយប្រើកម្លាំង ឬក៏ដោយការយល់ព្រម ឬអត់ឱនពីអ្នករដ្ឋវាសី ។ ពួកកម្ពុជៈបានប្រទះឃើញមានពួកចាមនេះនៅឥណ្ឌូចិនភាគខាងក្រោមរួចទៅហើយ តាំងតែពីពេលដែលគេធ្វើដំណើរមកដល់ម្ល៉េះ ពួកនោះជាម្ចាស់ទឹកដីតូចធំដែលគេគ្រប់គ្រង ព្រមទាំងបានត្រួតត្រាពួកអ្នករដ្ឋវាសី ថែមទៀតផង ។ ពួកចាមនេះ គឺជាពួកម៉ាឡេ ដែលទទួលយកអារ្យធម៌ហិណ្ឌូ ហើយធ្វើដំណើរចេញមកពីកោះស៊ូម៉ាត្រា ឬក៏មកពីកោះជ្វាផងដែរ ។ ចំណែកឯពួកកម្ពុជៈឬខ្មែរ គឺចេញមកពីឥណ្ឌាភាគខាងកើត តាមមើលទៅគឺមកពីកលិង្គៈ នៅលើឆ្នេរកូរ៉ូម៉ង់ដែល ។*

*គេអាចប៉ាន់ប្រមាណបានអំពីការប្រកួតប្រជែង ដែលអាចនឹងកើតមានឡើងតាំងតែពីដំបូង រវាងពួកម៉ាឡេ នៅឥណ្ឌូចិន គឺចាមនេះ ជាមួយនឹងពួកកម្ពុជៈ ដែលមានអភិមានះនឹងសញ្ជាតិដើមរបស់ខ្លួន ហើយនិយាយភាសាមួយដឿនលឿនបន្តិចទៅហើយ ជាពិសេស នៅពេលដែលផលប្រយោជន៍ខាងពាណិជ្ជកម្ម និងអំណាចត្រួតត្រាប្រទាំងប្រទើសគ្នា ។*

*នៅពេលដែលពួកកម្ពុជៈមកដល់ វាហាក់ដូចជាថានគរចាម្ប៉ានេះ គឺជាអាណាចក្រមួយ ដែលពួកចិនហៅថាហ្វូណាន ដែលមានដែនដីចំណុះរបស់ខ្លួនជាច្រើនលាតសន្ធឹងរហូតដល់មាត់សមុទ្រ តាំងពីក្វាងបិញរហូតដល់កំពតហើយដែលក្រោយមកត្រូវធ្លាក់បរាជ័យនៅសតវត្សរ៍ទី១៨ ទើបក្លាយទៅជាប្រទេសអាណ្ណាមវិញ ។*

*ប្រហែលជានៅឆ្នាំ១៣៧នៃគ្រិស្តសករាជ មានមេកោយម្នាក់ក្នុងចំណោមអាណានិគម នៅតាមឆ្នេរសមុទ្រ ដែលពួកចិនឲ្យឈ្មោះថា គុយលាន និងមានទីតាំងស្ថិតនៅខាងលើទូរ៉ានបន្តិច (ប្រហែលជាត្រូវនឹងឈ្មោះស្រូណា នៅក្នុងដែនទីដូលេមេ) បានបង្រួបបង្រួមដែនដីចំណុះទាំងអស់ ឲ្យរួមគ្នាមកជារាជាណាចក្រតែមួយ*

រួចហើយបានវាយដេញកម្ចាត់ពួកចិន-អាណ្ណាមចេញ រើបម្រះខ្លួនរួចពីនឹមត្រួតត្រារបស់នគរចិន ។ គុយលាននោះ បានសម្លាប់ អភិបាល ឬខុបរាជចិនចោល ជាហេតុធ្វើឲ្យជនរួមជាតិរបស់គេ និងបណ្ដាមេរបស់ដែនដីចំណុះឯទៀតៗ មានជំនឿ និងទំនុកចិត្តមកលើគេជាខ្លាំង រួចហើយក៏លើកឲ្យធ្វើជាស្ដេច ។ រាជាណាចក្រម៉ាឡេ ដែលបានចាក់គ្រឹះ នៅឥណ្ឌូចិន មិនដឹងជាតាំងពីពេលណាមក ហើយមានឈ្មោះថា ចាម្ប៉ានោះ បានឧប្បត្តិកឡើងយ៉ាងដូច្នេះ ។

រាជធានីរបស់នគរចាម្ប៉ាមានឈ្មោះតាមចិនហៅថា លីនយី ហើយឈ្មោះ លីនយី នេះ ក៏បានត្រូវពួកអាណ្ណាម និងប្រវត្តិវិទូចិនប្រើសម្រាប់ហៅនគរទាំងមូលផងដែរ ។

តាមមើលទៅ នគរចាម្ប៉ា ឬលីនយី នាពេលនោះលាតសន្ធឹងទៅជើងរហូតដល់ព្រំប្រទល់តុងកឹង និងមកត្បូង រហូតដល់ព្រំប្រទល់កូសាំងស៊ីនសព្វថ្ងៃ ពោលគឺ ត្រូវនឹងទឹកដីអាណ្ណាមបច្ចុប្បន្នទាំងមូល ។ ម្យ៉ាងទៀតនៅពេលនោះ នគរហ្វូណន ដែលដឹកនាំដោយរាជវង្សជ្វា ឬម៉ាឡេ និងស្ថិតនៅក្រោមការត្រួតត្រារបស់អាណានិគមម៉ាឡេដ៏ខ្លាំងពូកែមួយ ប្រហែលជាបានកកើតរួចមុនជាច្រើនសតវត្សរ៍មកហើយ ។ នគរហ្វូណននេះមានរាជធានីនៅនឹងមាត់ពាមនៃទន្លេមេគង្គ[1] ។

តាមរឿងព្រេង ពួកកម្ពុជៈ និងពួកខ្មែរបានវាយបណ្ដេញពួកចាម ឲ្យចាកចេញពីស្រុក ដែលស្ថិតនៅពីខាងលិចជួរភ្នំអាណ្ណាម និងស្រុករបស់ពួកម៉យ, រ៉ូម៉យ ឬម្ល៉យ ទៅនៅស្រុកលាវ ជាកន្លែងដែលពួកគេកសាងនគរចំប៉ាសាក់ឡើង និងទៅនៅផ្នែកអាគ្នេយ៍ត្រង់បិញធន់សព្វថ្ងៃ ហើយបង្កើតបានជារដ្ឋបណ្ឌុរង្គ (ផានរ៉ាង) ។

ទោះជាត្រូវបានបណ្ដេញចេញពីកម្ពុជាយ៉ាងណាក៏ដោយ ប៉ុន្តែជាការពិតណាស់ដែលថា រាជាណាចក្រចាមនៅតាមមាត់សមុទ្រផ្នែកអាគ្នេយ៍ឥណ្ឌូចិនជារាជាណាចក្រមួយខ្លាំងក្លា តាំងតែពីសតវត្សរ៍ទី១នៃគ្រិស្តសករាជមក ។ ពួកនេះពូកែមោះមុតក្នុងការធ្វើសង្គ្រាម ទាំងតាមជើងគោក ទាំងតាមផ្លូវទឹក ។ ប៉ុន្តែពួកនេះអភ័ព្វព្រោះប្រជាជាតិរបស់គេត្រូវបែងចែកជាក្សត្រប្រទេសស្វយ័តចំនួន៥ - ៦ ដូចជានៅឯកម្ពុជាដែរ គ្រាន់តែថារដ្ឋទាំងអស់នោះជានគរសាមន្តរាជ ចំណុះឲ្យព្រះអធិរាជមួយអង្គ ដែលជាបច្ចាញាតិរបស់ព្រះរាជាដែលបានរំដោះពួកគេចេញពីនឹមត្រួតត្រានៃពួកចិន និងអាណ្ណាម ។ ប៉ុន្តែអំណាចរបស់ព្រះអធិរាជនោះខ្សោយមិនខុសពីអំណាចស្ដេចបារាំងកាលពីសម័យមុនយុគកណ្ដាលទេ គ្រាន់តែថាជាគោលការណ៍ គ្មានការប្រកែកប្រណាំងអ្វីពីនគរសាមន្តរាជនោះទេ[2] ។

---

[1] យើងបានឃើញពីខាងលើថា តាមរឿងព្រេង មានស្ដេចចាម៦អង្គ សោយរាជ្យនៅស្រុកខ្មែរ មុនពេលពួកកម្ពុជៈមកដល់ ។

[2] បណ្ឌុរង្គ ឬផានរ៉ាងនេះជារដ្ឋប្រឆាំងតូចមួយ ឬបើហោចណាស់ ក៏ជារដ្ឋមួយដែលមានឯករាជ្យពីចាម្ប៉ា ប្រសើរជាងក្សត្រ

ម្យ៉ាងទៀត ទឹកដីរបស់ក្សត្រប្រទេសទាំងអស់ ពេលនោះប្រហាក់ប្រហែលនឹងទឹកដីបណ្ដាខេត្តរបស់អាណ្ណាមបច្ចុប្បន្នដែរ ហើយទឹកដីទាំងអស់នោះបានដូរឈ្មោះបន្តិចម្ដងៗ ទៅតាមការច្បាំងដណ្ដើម និងការដាក់ជាចំណុះដោយពួកអាណ្ណាម ។ ហេតុការណ៍ដូចគ្នានេះ និងហេតុការណ៍ធ្លាប់កើតមាននៅស្រុកបារាំង ពេលដែលពួកប៉ាគុស នៃក្រុមហ្កាល័រ-រ៉ូម៉ាំង ច្បាំងដណ្ដើមយកបណ្ដាខេត្តនៃអាណាចក្ររូម៉ាំង ក្នុងសតវត្សរ៍ទី១៤ដែរ ។

តាមឯកសារប្រវត្តិសាស្ត្រអាណ្ណាម ពួកចាមជាពួកចោរសមុទ្រ និងដីគោក ដែលបានបញ្ជូនទ័ពទៅធ្វើការដុតបំផ្លាញភូមិនានាតាមមាត់សមុទ្រតុងកឹង និងបណ្ដាខេត្តអាណ្ណាមខាងជើង ជាច្រើនលើកច្រើនសា ។ បើតាមសិលាចារឹកសំស្រ្កឹតរបស់កម្ពុជាវិញថា ពួកកម្ពុជៈចាត់ទុកពួកនេះជាប្រជារាស្ត្រជិតខាង ដែលគេមានទំនាស់ជាមួយម្ដងម្កាល ។ ប៉ុន្តែ ពួកចាមខ្លួនឯងមិនមានបន្សល់ទុកឯកសារអ្វី ដើម្បីការពារខ្លួនឯងផងទេ ។ រីឯពួកអាណ្ណាមវិញ គេខិតខំនិយាយអាក្រក់ពីចាម្ប៉ា ដើម្បីបញ្ជាក់ពីមូលហេតុសមស្រប ដែលធ្វើឲ្យបុព្វបុរសរបស់គេវាយដណ្ដើមយកនគរនេះ ។

ម្យ៉ាងទៀត អាចនិយាយបានថា អំពើចោរកម្ម និងការឈ្លានពានទៅលើអាណ្ណាមនោះ មិនមែនជាសកម្មភាពរបស់ប្រជាជាតិចាមទាំងមូល ឬក៏ជាគំនិតរបស់ព្រះចៅអធិរាជ ដែលសោយរាជ្យនៅឯចាម្ប៉ាបុរៈនោះទេ វាអាចគ្រាន់តែជាសកម្មភាពរបស់ព្រះរាជានៃក្សត្រប្រទេសណាមួយ ក្នុងបណ្ដាក្សត្រប្រទេសរបស់ចាម្ប៉ាប៉ុណ្ណោះ ឬក៏ថា ជាអំពើរបស់ពួកចាមមួយក្រុម ដែលប្រព្រឹត្តឡើងដោយគ្មានការអនុញ្ញាតពីស្ដេចអង្គណាមួយ ដែលចុះទូកតាមតែខ្យល់បក់នាំទៅ ឬក៏នាំគ្នាធ្វើការសង្សឹកនឹងការជេរប្រមាថណាមួយក៏មិនដឹង ។ ក៏ប៉ុន្តែ ការវាយប្រហាររបស់ពួកចាមភាគច្រើន សុទ្ធតែបានត្រូវឯកសារអាណ្ណាមកត់ត្រាថា ជាប្រតិបត្តិការយោធារបស់នគរទាំងមូល តាមការសម្រេចចិត្តរបស់ព្រះរាជា និងទីប្រឹក្សារបស់ព្រះអង្គ និងដឹកនាំបញ្ជាដោយមេទ័ពដែលព្រះរាជាចាត់តាំងច្បាស់លាស់ ។

នៅសម័យនោះ ដែលប្រជាជនមិនសូវស្គាល់គ្នាទៅវិញទៅមក មិនដឹងថា តើមានអ្វីកើតឡើងនៅឯប្រទេសជិតខាង និងមិនមានទម្លាប់ប្រកាសសង្គ្រាមមុនពេលដែលសង្គ្រាមចាប់ផ្ដើមទេ ។ ពួកអាណ្ណាមបានចាត់ទុកថារាល់ការឈ្លានពាន និងការឆក់ប្លន់ដោយស្ដេចចាមណាមួយ ជាអំពើខុសឆ្គងរបស់ប្រជាជាតិទាំងមូល

---

ប្រទេសឯទៀតៗ ។ សិលាចារឹកពោធិក្លោងការ៉ាយ ដែលគេរកឃើញនៅឆ្នាំ១៩០៨ និងមានកាលបរិច្ឆេទនៅមហាសករាជ៩៧២ ត្រូវនឹងគ្រិស្តសករាជ១០៥០ ហាក់ដូចជាជិតទាស់នឹងឯករាជ្យភាពនេះ ។ សិលាចារឹកនោះនិយាយថា អ្នកស្រុកផានរ៉ាងជាមនុស្សស្ពឹក ហើយខិលខូច និងច្រើនតែបះបោរប្រឆាំងនឹងស្ដេចនគរចាម្ប៉ា តែត្រូវបានព្រះបរមេស្វរៈវរមទេវៈដាក់ទោស ដេញវាយរហូតដល់ក្នុងព្រៃភ្នំ ។ បន្ទាប់មក ពួកនោះក៏ប្រែក្លាយខ្លួនជាមនុស្សល្អត្រឹមត្រូវ ហើយស្មោះនឹងស្ដេចនគរចាម្ប៉ាវិញ ។ តែការចុះចូលនោះមិនស្ថិតស្ថេរទេ ។

ជាបំណងរបស់ព្រះរាជា ជាការវាយប្រហាររបស់ប្រជាជាតិមួយទៅលើប្រជាជាតិមួយ តែតាមពិតទៅ នោះគ្រាន់តែជាអំពើរបស់ពួកចោរមួយក្រុម ឬជាការសងសឹកមួយប៉ុណ្ណោះ ។ ពួកអាណ្ណាមអាចនឹងចាត់ទុករឿងរ៉ាវទាំងឡាយដូច្នេះ ក៏ប៉ុន្តែ ខ្ញុំនៅតែចង់រំលឹកដដែលៗថា នគរចាម្ប៉ា បានរលត់បាត់អស់ទៅហើយ ធ្វើម៉េចអាចការពារខ្លួនបាន ហើយបច្ចាញ្ញាតិរបស់ប្រជាជាតិគេដែលត្រូវវាយបំបែកខ្ចាត់ខ្ចាយអស់ទៅហើយនោះ ក៏គ្មានបន្សល់ឯកសារអ្វីការពារខ្លួន ឬបញ្ជាក់ថា សង្គ្រាមដែលខ្លួនប្រកាសឡើងនោះ ជាការឆ្លើយតបទៅនឹងអាណ្ណាមផងទេ ។ ចំណែកពួកអាណ្ណាមវិញដែលមាននៅសល់ដល់សព្វថ្ងៃ គេអាចធ្វើការការពារខ្លួន និងវាយប្រហារទៅលើសត្រូវពីអតីតកាល ដោយគ្មានខ្លាចរអែងថានឹងទទួលការវាយបកវិញឡើយ ។ ដូចនេះ គេត្រូវប្រុងប្រយ័ត្ននៅចំពោះការចោទប្រកាន់នានា ហើយកុំភ្លេចថាទឹកដីចាម្ប៉ាទាំងស្រុងបានត្រូវពួកអាណ្ណាមដណ្តើមដាក់បញ្ចូលមកក្នុងរាជាណាចក្រអាណ្ណាមបាត់ទៅហើយ ។

គេមិនដឹងអ្វីច្រើនប៉ុន្មានទេ នៅពេលដែលនគរចាម្ប៉ាចាប់ផ្តើមកកើតដំបូង ។ ឯកសារប្រវត្តិសាស្ត្រចិនរឿងនិទានរបស់បូជនីយេសក៍ចិន និងស្នាដៃមួយចំនួនផ្សេងទៀត ដែលនិយាយអំពីប្រជាជាតិនេះ មាននិយាយតិចតួចពេក មិនអាចឲ្យយើងរៀបរាប់ព្រឹត្តការណ៍តាមលំដាប់បន្តបន្ទាប់បានទេ ។ មានឯកសារមួយនិយាយថារាជាណាចក្រចាម្ប៉ា បានត្រូវកសាងឡើងប្រហាក់ប្រហែលទៅនឹងរឿងរ៉ាវដែលរៀបរាប់ខាងលើ មានរាជធានីនៅស៊ាងលីនយី ក្នុងអំណាចត្រួតត្រារបស់ យិនណាន គឺក្វាងប៊ិញសព្វថ្ងៃ ហើយថាពួកចាមហៅរាជធានីរបស់គេនោះថា បាលអង់វ៉ុ ឬរាជធានីអង់វ៉ុ នៅចន្លោះខ្សែរយៈទទឹង១៧ និង១៨អង្សា និងចន្លោះរយៈបណ្តោយ ១០៤-១០៥អង្សា ។

សិលាចារឹកដែលគេរកឃើញរហូតមកដល់សព្វថ្ងៃ បានផ្តល់បញ្ជីឈ្មោះរបស់ព្រះរាជាមួយចំនួន ដែលសោយរាជ្យពីសតវត្សរ៍ទី១ដល់សតវត្សរ៍ទី៧ ព្រមទាំងព្រឹត្តិការណ៍មួយចំនួន ដែលមិនសូវស៊ីគ្នាជាមួយឯកសារចិន ប៉ុន្មានទេ ។

យើងពិនិត្យមើលអំពីអ្វីដែលឯកសារទាំងពីរបានប្រាប់ឲ្យដឹង ៖ ព្រះរាជាទីមួយ ដែលសិលាចារឹកថ្វាយព្រះអភិសេកនាមថា ស្រីមារៈ ទ្រង់សោយរាជ្យនៅសតវត្សរ៍ទី២ ឯព្រះរាជាបន្ទាប់ទ្រង់ព្រះនាមថា ភទ្រវរ្ម័នសោយរាជ្យនៅសតវត្សរ៍ទី៤ ។

ស្រីមារៈ ប្រហែលជាឈ្មោះជាភាសាសំស្ក្រឹតរបស់ស្តេចគុយលាន ឬស្តេចដែលសោយរាជ្យបន្តពីព្រះអង្គមិនដឹងថា តើជាអ្នកស្នងរាជ្យទី១ ទី២ ឬទី៣ ដែលយើងមិនបានស្គាល់ឈ្មោះ ។

ឯស្រីភទ្រវរ្ម័នក៏ប្រហែលជាឈ្មោះជាភាសាសំស្ក្រឹតរបស់ស្តេចមួយអង្គ ដែលសោយរាជ្យនៅសតវត្សរ៍ទី៤ ហើយដែលប្រវត្តិវិទូចិនហៅមិនច្បាស់ថាហ្វាន់ហឿន ដែលជាបច្ចាញាតិខាងព្រះមាតារបស់គុយលាន ។

ព្រះរាជបុត្ររបស់ព្រះអង្គព្រះនាមហ្វាន់អ៊ី បានរៀបចំធ្វើកំពែងការពាររាជធានីតាមយោបល់របស់មន្ត្រី

ម្នាក់ ដែលបន្ទាប់មក បានឡើងសោយរាជ្យបន្តព្រះអង្គ ។ ទ្រង់សុគតនៅឆ្នាំ៣៣៦ ។ មន្ត្រីនោះតាមពិត គឺជាខ្ញុំបម្រើម្នាក់ឈ្មោះ វេន មានដើមកំណើតមកពីតុងកឹង ដែលត្រូវព្រះរាជាសន្តោសប្រណីយកជាបុត្រចិញ្ចឹម បានបំបែករដ្ឋទាយាទធម្មានុរូបទាំងអស់ចេញ ហើយពឹងផ្អែកលើមន្ត្រីឯទៀតៗឲ្យប្រកាសខ្លួនជាព្រះរាជាក្រោមព្រះនាមថាហ្វាន់វេន ។ ស្ដេចអង្គនេះសុគតនៅឆ្នាំ៣៤៩ ។ ព្រះរាជាអង្គនេះជាព្រះរាជាចាមដំបូងគេ ដែលលើកទ័ពឆ្លងកាត់ព្រំដែនទៅធ្វើសង្គ្រាមជាមួយតុងកឹង ។ ទ្រង់បានដណ្ដើមយកខែត្រក្វាងណាន ដែលជាស្រុកកំណើត ដាក់បញ្ចូលមកនគរចាម្ប៉ា នៅឆ្នាំ៣៤៧ ។

ឯកសារប្រវត្តិសាស្ត្រចិននិយាយថា ព្រះរាជាដែលសោយរាជ្យបន្តពីហ្វាន់វេន គឺបុត្រព្រះអង្គព្រះនាមថាហ្វាន់ហ្វូ ហើយនៅក្រោមរាជស្ដេចអង្គនេះកងទ័ពចិន-តុងកឹង ដណ្ដើមយកក្វាងណាន់វិញបាន ដោយរុញច្រានឲ្យចាមដកថយទៅនៅឯលីនយីវិញ ។

បន្ទាប់មក គឺព្រះរាជនត្តារបស់ហ្វានហ្វូ ព្រះនាមហ្វានហ៊ូតា ដែលឡើងសោយរាជ្យបន្តពីព្រះអង្គនៅឆ្នាំ៣៩៩ ។ រជ្ជកាលនេះប្រកបទៅដោយភាពវឹកវរ នៅទីបញ្ចប់ព្រះរាជាក៏ត្រូវធ្វើឃាតដោយបុត្រស្ដេចហ្វូណនដែលលោក ប៉េគូប៊ីល ដាក់ឈ្មោះតាមចិនថា តេងកេងឈន់ ។ ឃាតកម្មនេះកើតមាននៅក្រោយឆ្នាំ៤១៣នៃគ្រិស្តសករាជ ។

ព្រះរាជបុត្ររបស់ព្រះបាទហ្វានហ៊ូតា ព្រះនាមថាហ្វានឈាវនង ឡើងសោយរាជ្យបន្តមកហើយមានការលំបាកជាខ្លាំងក្នុងការរៀបចំសណ្ដាប់ធ្នាប់ និងដណ្ដើមយកស្រុកមកវិញ ។ ក្រោយពីសម្រេចតាមគោលបំណងនេះរួច ព្រះរាជាទ្រង់សោយរាជ្យបានប៉ុន្មានឆ្នាំបន្តទៀត រួចក៏សោយទិវង្គតទៅនៅឆ្នាំ៤២១ ។ ព្រះរាជបុត្រព្រះនាម ហ្វានយ៉ាងម៉ាយ បានសោយរាជ្យបន្តមក រួចទ្រង់សុគតនៅឆ្នាំ៤៤៦ ។ ពេលនោះរាជបុត្រព្រះនាម ហ្វានទូ បានឡើងសោយរាជ្យបន្ត ដោយយកព្រះនាមដូចព្រះបិតាដែរ ។

នៅសតវត្សរ៍ទី៥ សិលាចារឹកបាននិយាយអំពីព្រះរាជាមួយព្រះអង្គដែលមានព្រះនាមជាភាសាសំស្ក្រឹតថា គង្គារាជា ឬគង្គេស្វរៈ ។ សិលាចារឹកនិយាយបន្តទៀតថា ព្រះរាជាអង្គនេះបាន «ចាកចោលរាជសម្បត្តិដោយគ្មានព្រះទ័យស្ដាយស្រណោះបន្តិចទេ» ទៅធ្វើបូជនីយេសក៏នៅមាត់ទន្លេគង្គា[៣] ។

ព្រះរាជាមួយអង្គទៀតមានព្រះនាមដែលបញ្ចប់នៅខាងចុងថា ...វដ្ឋាវរ្ម័ន មានន័យថា «ទ្រង់មានអំណាចលើសលប់មហាសាគរ» ។

តាមមើលទៅ ឈ្មោះថា គង្គារាជា និង...វដ្ឋាវរ្ម័ន ប្រហែលជាព្រះនាមជាភាសាសំស្ក្រឹតរបស់ហ្វានហ៊ូតា

[៣] តាមឯកសារឈ្មោះ «កំណត់ត្រាស្ដីអំពីកូសាំងស៊ីន» នៅក្នុង Lettres édifiantes et curieuses, XXXIe année, ១៧៧៤ ។

និងហ៊្វានយ៉ាងម៉ាយ ក៏ប៉ុន្តែគ្មានឯកសារបញ្ជាក់អំពីរឿងនេះទេ ។

សិលាចារឹកដដែលក៏បាននិយាយអំពីព្រះរាជា២ព្រះអង្គទៀតផងដែរ គឺរុទ្រវរ្ម័នទី១ ដែលជាព្រះរាជនត្តាទួត របស់ព្រះបាទ រដ្ឋាវរ្ម័នដែលបានសោយរាជ្យបន្តមក តាមពាក្យសិលាចារឹកថា "ទ្រង់បានទទួលយកអម្រែកដ៏សែនធ្ងន់នៃរាជសម្បត្តិ" ។ ព្រះអង្គជាប់អម្បូរព្រាហ្មណ៍ផង និងក្សត្រិយៈផង ។

ព្រះរាជាមួយអង្គទៀត គឺព្រះបាទសម្ភុវរ្ម័ន ជារាជបុត្ររបស់ព្រះបាទរុទ្រវរ្ម័ន ។

បើតាមឯកសារប្រវត្តិសាស្ត្រចិនវិញ គេនិយាយថានៅសតវត្សរ៍ទី៥ មានព្រះរាជាដូចតទៅនេះ ៖

- ហ៊្វានតាវ សោយរាជ្យស្នងពីព្រះបិតានៅឆ្នាំ៤៤៦ ។
- ហ៊្វានចេនឆេង សោយរាជ្យពីឆ្នាំ៤៥៨ ដល់ ៤៧២ ឬក៏ក្រោយនោះ ។
- ហ៊្វានតាងកេនឈែន ជាជនបរទេស ដ្រែករាជ្យនៅឆ្នាំ៤៩១ ។
- ហ៊្វានឈូ នង ជាបុត្ររបស់ហ៊្វានយ៉ាងម៉ាយ ដែលឡើងសោយរាជ្យនៅឆ្នាំ៤៩២ បន្ទាប់ពីទម្លាក់ស្តេចដ្រែករាជ្យ រួចសុគតនៅឆ្នាំ៤៩៨ ។
- ហ៊្វានវេនសេន ឬវេនគ៊ែន បុត្រស្តេចមុន ។
- ហ៊្វានទៀនខាយ ដែលមានព្រះអភិសេកនាមថាទេវវរ្ម័ន ជាបុត្រស្តេចមុន និងសោយរាជ្យពីឆ្នាំ៥១០ ហើយនៅសោយរាជ្យនៅឡើយនៅឆ្នាំ៥១៤ ។
- ភីតស៊ើយប៉ាម៉ូ (វិជ័យវរ្ម័ន) ជាព្រះអនុជស្តេចមុន ។
- កាវជីចេនខាយ (គុស្រីជ័យវរ្ម័ន ឬវិជ័យវរ្ម័ន ?) សោយរាជ្យឆ្នាំ៥២៦-៥២៧ ។
- កាវជីឡូថូឡូប៉ាម៉ូ (គុស្រីរុទ្រវរ្ម័ន) សោយរាជ្យឆ្នាំ៥៣០-៥៣៤ ។

វាហាក់ដូចជាច្បាស់ណាស់ថារុទ្រវរ្ម័ន និងរដ្ឋាវរ្ម័ន ដែលមាននិយាយនៅក្នុងសិលាចារឹក គឺជាព្រះអភិសេកនាមរបស់ព្រះរាជា២ព្រះអង្គ ដែលសោយរាជ្យនៅសតវត្សរ៍ទី៥ ប៉ុន្តែយើងមិនដឹងកាលបរិច្ឆេទពិតប្រាកដទេ គ្រាន់តែបានស្គាល់ព្រះនាមដែលចិនហៅប៉ុណ្ណោះ ។ ហើយវាក៏ហាក់ដូចជាពិតប្រាកដដែរថា ព្រះរាជា៤ព្រះអង្គតាមឯកសារប្រវត្តិសាស្ត្រចិន ដែលយើងអាចកំណត់ព្រះនាមជាភាសាសំស្ក្រឹតបាន គឺព្រះបាទទេវវរ្ម័ន, វិជ័យវរ្ម័ន, ជ័យវរ្ម័ន និងរុទ្រវរ្ម័ន, មិនមានសិលាចារឹកណាដែលគេរកឃើញនៅចាម្ប៉ានិយាយអំពីព្រះរាជាទាំងនោះទេ ។

ឯកសារប្រវត្តិសាស្ត្រចិនក៏មាននិយាយផងដែរអំពីសង្គ្រាមមួយកើតឡើងនៅក្នុងសតវត្សរ៍ទី៥ រវាងនគរហ្វូណន និងចាម្ប៉ា ។ វាហាក់ដូចជាថា អ្នកដែលបង្កសង្គ្រាមមុនគឺព្រាហ្មណ៍កោណ្ឌញ្ញ (ជ័យវរ្ម័ន) ចិនហៅថាកាវឈាវឡូ ជាព្រះរាជានៃនគរហ្វូណន ដែលមានខ្ញុំឬកូនម្នាក់បះបោរប្រឆាំងនឹងព្រះអង្គ រួចគេចខ្លួនមកប្រកាសខ្លួនជាស្តេចនគរចាម្ប៉ា ។ មូលហេតុ គឺមកពីស្តេចកាវឈាវឡូនេះ ឬក៏នៅក្នុងរាជ្យស្តេចអង្គនេះ ចាមបានធ្វើការ

វាយដណ្ដើមយកជំនួនដែលអធិរាជចិនផ្ញើថ្វាយស្ដេចនគរហ្វូណន ធ្វើឲ្យស្ដេចហ្វូណនបញ្ជូនរាជទូតម្នាក់ នៅឆ្នាំ ៤៨៤ ជាពុទ្ធសាសនិកជន ឲ្យទៅសុំជំនួយពីស្ដេចក្រុងចិន ដែលយល់ព្រមតាមសំណូមពរ ។ គាវឈាវឡូនេះ ជាស្ដេចជ្រែករាជ្យ ម្យ៉ាងទៀតជាខ្មែរផង ។ ប៉ុន្តែ ឯកសារប្រវត្តិសាស្ត្រចិនមិនមានបញ្ជាក់ថា តើស្ដេចនេះ បរាជ័យក្នុងសង្គ្រាមប្រឆាំងនឹងហ្វូណនរួមនឹងចិន ឬយ៉ាងណានោះទេ ។

ទោះជាយ៉ាងណាក៏ដោយ ឯកសារប្រវត្តិសាស្ត្រអាណ្ណាមបានរៀបរាប់ថា នៅឆ្នាំ៣៩០នៃគ្រិស្តសករាជ បណ្ដាខេត្រភាគខាងត្បូងអាណ្ណាម (អាណ្ណាមពេលនោះ គឺតុងកឹង) ត្រូវរងការវាយប្រហារពីពួកចាម ដែលមានព្រះរាជាពេលនោះព្រះនាមតាមការហៅក្រៀវរបស់ពួកអាណ្ណាមថាផាមឡូដាត ឬហ្វានឡូដាត ។ ប៉ុន្តែ ស្ដេចចាមនោះ បានត្រូវវាយបណ្ដេញឲ្យដកថយទៅវិញដោយកងទ័ពចិន ដែលនៅពេលនោះជាម្ចាស់លើ តុងកឹង ។ ពួកចាមក៏បរាជ័យដែរនៅក្នុងការវាយប្រហារបណ្ដាខេត្រខាងត្បូងម្ដងទៀតនៅឆ្នាំ៤២០ ហើយបានត្រូវបង្ខំឲ្យសងការខូចខាតជាច្រើន និងលើកសួយសារអាករទៅឲ្យចិនទៀតផង ។

បើតាមមើលទៅ គឺនៅក្រោមរជ្ជកាលរបស់ស្ដេច ហ្វានយ៉ាងម៉ាយ ដែលសោយរាជ្យបន្តពី ផាមឡូដាត (គឺស្ដេចដែលចិនហៅថា ហ្វានហ៊ូតា) ដែលកងទ័ពចាមធ្វើការឈ្លានពានទៅលើខេត្រញុតណាមរបស់តុងកឹង នៅឆ្នាំ ៤៣៦ ។ ទ័ពចាមឈ្នះអាស្រ័យដោយសារមានដំរី ដែលធ្វើឲ្យទ័ពអាណ្ណាមបាក់បបខ្ចបខ្ចាច ។ ក៏ប៉ុន្តែទ័ពនេះ ត្រូវបរាជ័យវិញ នៅពេលដែលមេទ័ពចិនឈ្មោះ ថានហូឈេ ប្រើកាំជ្រួចដុតចេញរូបសត្វធំៗ ធ្វើឲ្យដំរីភ័យខ្លាចជាខ្លាំង ។ បន្ទាប់មក រាជធានីរបស់នគរចាម្ប៉ាបានត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃអាណ្ណាម នៅឆ្នាំ៤៤៦នៃគ្រិស្តសករាជ ។

ឯកសារប្រវត្តិសាស្ត្រចិនបាននិយាយទៀតថា ស្ដេចហ្វានយ៉ាងម៉ាយបានរត់គេចខ្លួនចេញពីរាជធានី នៅពេលដែលឮថាទ័ពអាណ្ណាមមកជិតដល់ ។ ទ្រង់យាងត្រលប់មកព្រះនគរវិញនៅពេលដែលទ័ពអាណ្ណាមដកចេញផុតអស់ ហើយត្រូវស្រឡាំងកាំងជាខ្លាំងពេលឃើញរាជធានីត្រូវបំផ្លាញខ្ទេចខ្ទី ។ ព្រះអង្គបានធ្លាក់ព្រះកាយប្រឈួនរហូតដល់សោយទិវង្គត ។

ប៉ុន្តែមានបញ្ហាមួយចោទឡើង ៖ ព្រះបាទគង្គារាជា, រដ្ឋាវរ្ម័ន, រុទ្រវរ្ម័ន និងព្រះរាជា៦ព្រះអង្គទៀត បានសោយរាជ្យបន្តបន្ទាប់គ្នាឥតដាច់ នៅសតវត្សរ៍ទី៥ និងទី៦ ។ បើអ៊ីចឹង តើស្ដេចផាមឡូដាត[៤] តាមប្រវត្តិសាស្ត្រអាណ្ណាម និងហ្វានយ៉ាងម៉ាយ តាមឯកសារចិន ដែលសោយរាជ្យបន្តបន្ទាប់គ្នាដែរនោះ ត្រូវសោយរាជ្យនៅឆ្នាំណា? ឬមួយឈ្មោះទាំងពីរនេះ ជាឈ្មោះដែលប្រជាជនហៅតាមភាសាសាមញ្ញ សំដៅយកព្រះបាទ រុទ្រវរ្ម័ន និង

[៤] ពាក្យផាមជាការចម្លងរបស់អាណ្ណាមពីពាក្យចិន ហ្វាន ។ ផាមឡូដាត ត្រូវនឹងឈ្មោះតាមចិនហៅថា ហ្វានហ៊ូតា ។

ព្រះរាជាដែលសោយរាជ្យបន្ត ឬមុនព្រះអង្គ?

សិលាចារឹកចាម ឯកសារប្រវត្តិសាស្ត្រអាណ្ណាម និងឯកសារចិនមានរៀបរាប់អំពីព្រះរាជា ដែលសោយរាជ្យសម្បត្តិបន្តពីព្រះបាទរុទ្រវរ្ម័ន ព្រមទាំងសកម្មភាពខ្លះៗផងដែរ ។

ព្រះរាជាដែលស្នងរាជ្យទី១ គឺព្រះបាទសម្ភុវរ្ម័ន ដែលតាមមើលទៅអាចត្រូវជាព្រះរាជបុត្ររបស់ព្រះបាទរុទ្រវរ្ម័ន ។ សិលាចារឹកមួយនៅមីសឺន បានថ្លែងសសើរព្រះអង្គថា “ទ្រង់មានព្រះកាយពលខ្លាំងក្លាគ្មាននរណាប្រៀបផ្ទឹមបាន មានចរិយាមារយាទល្អប្រសើរ ប្រៀបបានទៅនឹងព្រះអាទិត្យនៃដែនដីដោយជះពន្លឺនៅពេលរាត្រីហើយ ។ ទ្រង់មានភាពក្លាហានមោះមុតតាមរយៈព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ” ។ បើដូច្នេះមែន តើព្រះរាជាអង្គនេះជាស្តេចជ្រែករាជ្យ ហើយមិនមែនជាព្រះរាជបុត្ររបស់ស្តេចអង្គមុនទេ ឬយ៉ាងណា? ព្រោះឃ្លាចុងក្រោយនេះ ហាក់ដូចជាចង់បញ្ជាក់អំពីរឿងនេះ[៥] ។

ព្រះរាជាអង្គនេះប្រហែលជាសោយរាជ្យនៅដើមគ្រិស្តសករាជទី៧ ។ ហើយបើសិនជាព្រះអង្គជាមនុស្សតែមួយជាមួយហ្វានផានឈេ នោះគឺនៅក្នុងរាជ្យរបស់ព្រះអង្គនេះហើយ ដែលចិនបានធ្វើការវាយប្រហារមកលើនគរចាម្ប៉ា ក្នុងរវាងឆ្នាំ៦០៣ ឬ៦០៥ ដោយស្តេចចិន ដែលឯកសារប្រវត្តិសាស្ត្រចាត់ទុកថាជា “ស្តេចលោភលន់ចង់មានចង់បាន” ព្រោះឮថានគរចាម្ប៉ានេះជាប្រទេសអ្នកមានមួយ ក៏មានបំណងវាយយក នេះបើតាមការសិក្សារបស់លោក ប៉េគូបឹល ។ មុនដំបូង ទ័ពចាមទទួលបានជ័យជម្នះខ្លះ ប៉ុន្តែបន្ទាប់មក ត្រូវដកថយឆ្លងព្រំដែនទាំងឥតសណ្តាប់ធ្នាប់ ក្រោមការដេញវាយប្រហាររបស់កងទ័ពចិន និងអាណ្ណាម ដែលដណ្តើមយករាជធានីបាន ហើយវាយកម្ទេចខ្ទេចខ្ទី មុននឹងដកទ័ពថយទៅវិញ[៦] ។ ក៏ប៉ុន្តែ ដោយរវល់តែប្រមូលយកជ័យភណ្ឌខ្លាំងពេក ពួកចិនអាណ្ណាមបានត្រូវរងការវាយបកពីទ័ពចាម ដែលប្រមែប្រមូលគ្នារៀបចំឡើងវិញយ៉ាងឆាប់រហ័ស ។

---

[៥] សូមបញ្ជាក់ថានៅតណ្ហចិន សិទ្ធិរៀមច្បងមិនមានអនុវត្តតឹងរឹងណាស់ណាទេ ទាំងនៅម៉ាឡេស៊ី និងកម្ពុជាសព្វថ្ងៃក៏អ៊ីចឹងដែរ ។

[៦] លោក ប៉េគូបឹល និយាយថារាជធានីលីនយីនេះស្ថិតនៅជិតស្រណូច ដែលខ្ញុំមិនដឹងជានៅត្រង់ណា ។ គាត់និយាយថាគេត្រូវដើរ៧ថ្ងៃពីព្រំដែនមក ទម្រាំមកដល់លីនយី ដូច្នេះ បើគិតថាដើរមួយថ្ងៃបាន៣៥គីឡូម៉ែត្រ រាជធានីនេះត្រូវនៅនឹងមាត់ពាមស៊ីងវ៉េ ។ មានចំណុចសំខាន់មួយដែលលោក ប៉េគូបឹល បានបញ្ជាក់បន្ថែម គឺថាពួកចិនអាណ្ណាមបានយកពី លីនយីទៅនូវមាសចំនួន១៨ដុំធំៗ ដែលដាក់នៅក្នុងបន្ទប់មួយ សម្រាប់ឲ្យស្តេចចាមចូលគោរពបូជាវិញ្ញាណក្ខន្ធបុព្វបុរស ។ គាត់ថាមកពីស្តេចកូសាំងស៊ីន (ចាម្ប៉ា) បានប្រកាន់យកទំនៀមទម្លាប់តាមចិន គឺសំដែងការគោរពបូជាចំពោះព្រះរាជាដែលសុគតទៅ ដោយសង់បន្ទប់ថ្វាយមួយ និងដាក់មាសមួយបន្ទះនៅក្នុងនោះ ។ បន្ទះដុំមាសមានទាំង អស់១៨ ពីព្រោះហ្វានផានឈេជាព្រះរាជាទី១៩នៅចាម្ប៉ានេះ ចាប់តាំងពីគ្យូលានមក ។ ហេតុការណ៍នេះអាចឲ្យយើងកំណត់បាននូវទីតាំងរបស់រាជធានីចាម្ប៉ានៅសតវត្សរ៍ទី៧ និងចំនួនស្តេចដែលសោយរាជ្យរហូតមកដល់ពេលដែលពួកចិនអាណ្ណាមវាយយករាជធានីបាន គឺ១៨អង្គ តាំងពីឆ្នាំ១៣៧ មក ។

បើតាមសិលាចារឹក ព្រះរាជាដែលសោយរាជ្យបន្តពីព្រះបាទសម្ភុវរ្ម័ន គឺព្រះរាជបុត្ររបស់ព្រះអង្គ ព្រះនាមកន្ទារប្បធម្មៈ ដែលសោយរាជ្យចាប់ពីឆ្នាំ៦៣០មក ហើយដែលឯកសារចិនហៅថា ហ្វានឈាវលី ដែល បានបញ្ជូនរាជទូតទៅគាល់ស្តេចស្រុកចិននៅឆ្នាំ៦៣១ ដោយបញ្ជូននូវរបស់របរល្អៗពីក្នុងស្រុកទៅថ្វាយផង ។

ព្រះរាជបុត្ររបស់ព្រះបាទកន្ទារប្បធម្មៈ ឡើងសោយរាជ្យបន្តពីព្រះអង្គ ប៉ុន្តែ យើងមិនបានស្គាល់ព្រះ អភិសេកនាមរបស់ស្តេចនេះទេ ។ ឯកសារប្រវត្តិសាស្ត្រចិន ហៅព្រះរាជាអង្គនេះថា ហ្វានឆេនឡុង ។ ស្តេចអង្គ នេះ បានត្រូវមន្ត្រីមួយរូបធ្វើគុតទាំងពូជ នៅឆ្នាំ៦៨៥ មន្ត្រីនោះចិនហៅឈ្មោះថា ម៉ូហូម៉ានតូគាធូ ដែលប្រហែល គឺជាស្តេចភវេទ្រស្វរវរ្ម័នតាមសិលាចារឹក ដែលត្រូវជាក្មួយរបស់ព្រះរាជាមួយព្រះអង្គ (តើហ្វានឆេនឡុងឬ?) និងត្រូវជាចៅខាងព្រះមាតារបស់ព្រះកន្ទារប្បធម្មៈ គឺព្រះមាតាទ្រង់បានរៀបការជាមួយនឹងព្រាហ្មណ៍ម្នាក់ ។ ស្តេចនេះសោយរាជ្យនៅឆ្នាំ៦៨៥ ។

បន្ទាប់មក ប្រទេសកើតមានការវឹកវរមួយអស់រយៈពេលពីរ-បីឆ្នាំ ។ ឯកសារប្រវត្តិសាស្ត្រចិននិយាយ ថា មានព្រឹត្តិការណ៍មួយចំនួនកើតឡើង ដែលលោក ពែលីយ៉ូ បានសង្ខេបដូចតទៅ ៈ មរណភាពរបស់ស្តេច ហ្វាន ឆេងឡុង ព្រមទាំងរាជវង្សទាំងមូលបានធ្វើឲ្យនគរគ្មានអ្នកស្នងរាជ្យ ។ ប្រជារាស្ត្រចាម ក៏បានឯកភាពគ្នាលើក ព្រាហ្មណ៍ម្នាក់ ដែលត្រូវជា បុត្រសុណិសាររបស់ព្រះបាទហ្វានធូលី ដែលសោយរាជ្យនៅឆ្នាំ៦៣០-៦៣១ ឲ្យឡើងសោយរាជ្យបន្ត បុត្រសុណិសានោះប្រហែលគឺ ម៉ូហូម៉ានតូគាធូ ឬ ភវេទ្រស្វរវរ្ម័ននោះឯង ។ ក៏ប៉ុន្តែនាម៉ឺន សព្វមុខមន្ត្រី ដែលស្ម័គ្រស្មោះនឹងព្រះរាជវង្សមុន ឬក៏ថាមានផលប្រយោជន៍ផ្ទុយនឹងព្រះរាជាថ្មីនេះ មិនយល់ ស្របតាមទេ ក៏នាំគ្នាទម្លាក់ស្តេចនេះចេញពីរាជសម្បត្តិ រួចលើករាជបុត្រីរបស់ព្រះបាទហ្វានធូលី ដែលប្រហែល ជាមហេសីរបស់ព្រាហ្មណ៍ ដែលប្រជារាស្ត្រលើកឲ្យសោយរាជ្យនោះឯងក៏មិនដឹង ឲ្យឡើងសោយរាជ្យវិញ ។ ក៏ប៉ុន្តែ ព្រះមហាក្សត្រិយ៍អង្គនេះ មិនមានសមត្ថភាពនឹងរៀបចំសណ្តាប់ធ្នាប់ក្នុងព្រះនគរបានទេ ។ គេក៏អំពាវនាវ សុំឲ្យ ឈូកូទី ដែលត្រូវជាបុត្រារបស់មាតុច្ឆាមួយអង្គរបស់ព្រះបាទហ្វានធូលី ជាមួយនឹងក្សត្រមួយអង្គ ដែលបានគេចព្រះអង្គទៅនៅកម្ពុជា គឺត្រូវជាបងប្អូនជីដូនមួយជាមួយនឹងព្រះមហាក្សត្រិយ៍ ឲ្យមកសោយរាជ្យ

---

យើងមិនបានស្គាល់ព្រះនាមរបស់ព្រះរាជាទាំង១៨អង្គអស់ទេ ទោះជាព្រះនាមតាមភាសាសាមញ្ញ ឬក៏តាមភាសាសំស្ក្រឹតក្តី ។ ហើយវាហាក់ដូចជាថា គេមិនបានរាប់ឈ្មោះស្តេចជ្រែករាជ្យ ហ្វានតាងកេនឈន់ ផងទេ ដែលសោយរាជ្យនៅឆ្នាំ៤៩១ ។ ម្យ៉ាង ទៀត មានស្តេចយ៉ាងហោចណាស់ក៏៦អង្គដែរ ដែលសោយរាជ្យនៅចន្លោះពីស្តេចគ្យូលាន ដែលសោយរាជ្យនៅពាក់កណ្តាលសត វត្សរ៍ទី២ មកដល់ស្តេចហ្វានហុង ដែលសោយរាជ្យនៅដើមសតវត្សរ៍ទី៤ ។ ដូច្នេះមានស្តេចសោយរាជ្យទាំងអស់ស្មើនឹង១៧ បូក៦ គឺ ២៣អង្គ មិនមែន១៨អង្គទេ ។ លោក ប៉េគូប៊ីល ប្រហែលជាច្រឡំ ដែលគិតថាមានបន្ទះមាស១៨សម្រាប់ស្តេចចាម ចាប់ពី គ្យូលាន មក គឺ១៨នេះ មិនមែនចាប់ពីស្តេចទី១ មកទេ ។

សម្បត្តិវិញ ។ ឈូកូទី ក៏ត្រលប់មកចាម្ប៉ាវិញ ហើយត្រូវបាននាម៉ឺនសព្វមុខមន្ត្រីប្រកាសឲ្យសោយរាជ្យ និងរៀបចំអភិសេកបុត្រីរបស់ ហ្វានធូលី ឲ្យធ្វើជាអគ្គមហេសី (គឺឲ្យព្រះនាងលែងលះជាមួយព្រាហ្មណ៍ចេញ) ។ ព្រះរាជាអង្គនេះ នៅសោយរាជ្យសម្បត្តិនៅឡើយ នៅឆ្នាំ៦៥៣ ពីព្រោះនៅឆ្នាំនោះ ទ្រង់បានបញ្ជូនរាជទូតឲ្យទៅគាល់ស្តេចចិន ។ ខ្ញុំគិតថា ឈូកូទី នេះ ជាឈ្មោះតាមភាសាសាមញ្ញចាម ហើយគឺជាព្រះរាជាដែលសិលាចារឹកហៅថា ប្រកាសធម៌-វិក្រន្តវរ្ម័ន ដែលសោយរាជ្យពីឆ្នាំ៦៥៣ដល់៦៧៩ ។ សិលាចារឹកបានបញ្ជាក់ថា ព្រះអង្គជាព្រះរាជបុត្ររបស់ព្រះជគតធម្មៈ (មិនដឹងដើមកំណើត) ជាមួយនឹងព្រះរាជារបស់កម្ពុជា គឺព្រះស្រីសរវនី (ឦសានវរ្ម័ន) ដែលទ្រង់បានយកជាមហេសីកាលដែលទ្រង់គង់នៅឯភវបុរៈ[៧] ។

នគរចាម្ប៉ាបានកកើតឡើងមុន ក៏ប៉ុន្តែ នៅដើមសតវត្សរ៍ទី៣ រាជាណាចក្រនេះហាក់ដូចជាមានការរីកចម្រើនខ្សោយជាងនគរហ្វូណន បើហោចណាស់ក៏ខាងបច្ចេកទេសធ្វើសង្គ្រាមដែរ ។ យើងបានឃើញហើយថា នគរនេះមិនទាន់មានបន្ទាយការពាររឹងមាំទេ ហើយទីក្រុងទាំងអស់គ្មានរបងការពារ ហាក់ដូចជាបើកចំហឲ្យសត្រូវអឺចឹង ។ ទាល់តែមកដល់ពាក់កណ្ដាលទី១ នៃសតវត្សរ៍ទី៤ ទើបស្តេចហ្វានយីបានចាត់ឲ្យកសាងកំពែងការពាររាជធានីឡើង តាមការផ្ដល់យោបល់ពីទីប្រឹក្សាឈ្មោះ ហ្វានវេន ។

តទៅនេះជាការពិពណ៌នាទីក្រុងឈ្មោះ ក្យូស៊ូ ដែលពួកចាមដណ្ដើមបានពីពួកចិននៅតុងកឹង នៅពាក់កណ្ដាលទី១ នៃសតវត្សរ៍ទី៤ រួចហើយរៀបចំរបងការពារ ៖ កំផែងទីក្រុងក្យូស៊ូ មានគ្រឹះធ្វើអំពីឥដ្ឋជុំវិញប្រវែងទាំងអស់ប្រហែល៣គីឡូម៉ែត្រ និងមានចម្ងាយពីកើតទៅលិច៦៥០ ទ្វេដំហាន ។ គ្រឹះនេះមានកម្ពស់ប្រហែល៦ម៉ែត្រ ។ នៅពីលើគ្រឹះ មានរបងធ្វើអំពីឥដ្ឋកម្ពស់ប្រហែល៣ម៉ែត្រ មានចោះរន្ធបួនជ្រុងសម្រាប់បាញ់ព្រួញចេញផង ។ នៅពីលើរបងឥដ្ឋនោះមានចម្រូង ហើយទាំងអស់នេះសុទ្ធតែមានពន្លា និងរបៀងនៅពីលើកម្ពស់រហូតដល់ទៅ ២១-២៨ម៉ែត្រ ។ ទីក្រុងមានទ្វារ១៣ ។ អគារទាំងអស់បែរមុខទៅទិសខាងត្បូង ។ គេរាប់ឃើញមានផ្ទះទាំងអស់លើសពី២០០០ខ្នង -គឺ៩ដងតិចជាងរាជធានីកម្ពុជា ។ កន្លែងនេះជាទីតាំងយុទ្ធសាស្ត្រមួយសម្រាប់ លិនយី គឺដោយហេតុនេះហើយ បានជាអាវុធយុទ្ធភណ្ឌទាំងអស់របស់នគរលិនយី ដាក់នៅទីនេះ ។ ទីក្រុងនេះ ស្ថិតនៅពីខាងត្បូងខែត្រក្វាងបិញ សព្វថ្ងៃ ។

រាជធានីរបស់នគរចាម្ប៉ានាពេលនោះក៏មានរបងការពារដែរ តែធំជាងក្យូស៊ូមួយភាគបួន ។ មានរបងដូចគ្នាដែរ ក៏ប៉ុន្តែមិនមានទ្វាររហូតដល់ទៅ១៣ទេ គឺមានតែ៤ប៉ុណ្ណោះ ទ្វារសំខាន់គឺទ្វារខាងកើត ។ រាជធានីនេះ មានដៃ

---

[៧] ខ្ញុំមិនញញើតទេនឹងកំណត់ថា រាជធានីភវបុរៈនេះជារាជធានីរបស់ហ្វូណនដែលចិនហៅថាតូមូ ដែលត្រូវបានកសាង និងរៀបចំឡើងវិញដោយព្រាហ្មណ៍កោណ្ឌញ្ញ (ជ័យវរ្ម័ន) ។ ពេលក្រោយមក រាជធានីដូរឈ្មោះទៅជាវ្យាធបុរៈ រួចទៅជាអង្គរបុរីវិញ ។

ទន្លេហ្វាយទាំង២ និងរណ្ដៅ២ដាន់ ព័ទ្ធជុំវិញ ។ ក្នុងរាជធានីមានវិហារ៨ មានប្រជាជនរស់នៅច្រើនណាស់ ក៏ប៉ុន្តែមិនមានតំបន់ជាយក្រុងទេ ។ គឺរាជធានីនេះហើយដែលឧត្តមសេនីយ៍ចិនឈ្មោះ ថាន់ហូឈេ វាយដណ្ដើមយកបាននៅឆ្នាំ៤៤៦ ហើយដុតបំផ្លាញខ្ទេចខ្ទី មុននឹងដកទ័ពចេញទៅវិញ ។

មុនសង្គ្រាមចុងក្រោយនេះ និងបន្ទាប់ពីការដណ្ដើមយកខែត្រយេណាន ជាខែត្រខាងត្បូងរបស់ចិន-អាណ្ណាមបាននៅឆ្នាំ ៣៤៧ ព្រំប្រទល់ខាងជើងរបស់នគរចាម្ប៉ាលាតសន្ធឹងដល់ ហេងឈន់ ឬភ្នំហ្វាងសឺន សព្វថ្ងៃភ្នំនេះកាត់ទទឹងប្រទេសធ្លាក់ចុះរហូតដល់សមុទ្រនៅចន្លោះហាទិញ និងក្វាងបិញ ហើយមានច្រកមួយដែលមានឈ្មោះថា ទ្វារអាណ្ណាម ។ សព្វថ្ងៃទ្វារអាណ្ណាមនេះ គឺជាព្រំប្រទល់រវាងអាណ្ណាមនឹងតុងកឹង[៨] ។

## ២- នគរអាណ្ណាម-តុងកឹង

ពីសតវត្សរ៍ទី១ដល់សតវត្សរ៍ទី១៤នៃគ្រិស្តសករាជ ឈ្មោះ អាណ្ណាម រួមមានប្រទេសដែលយើងហៅសព្វថ្ងៃថា តុងកឹង និងខែត្រខាងជើងបន្តស់របស់អាណ្ណាមបច្ចុប្បន្ន ។ ពួកចិនបានដណ្ដើមយកស្រុកនេះបាននៅឆ្នាំ ១១១ មុនគ្រិស្តសករាជ ហើយបានដាក់ឈ្មោះជាបន្តបន្ទាប់ថា ណាមវៀត, ង៉ានណាម, ណាមយែ និងខ្យាវឈេ (យ៉ាវជី) ក៏ប៉ុន្តែពួកអ្នកស្រុកដើម ក្នុងនោះមានពួកមួង ដែលនៅសេសសល់ដល់សព្វថ្ងៃ ហៅស្រុកនោះថា អូឡាក់ ។ ផ្ដូលេមេ ដាក់ឈ្មោះឲ្យថា អ៊ិនឌីឬស៊ីនដូយ ហៅទន្លេក្រហមថា ដូរីយ៉ា និងហៅទីក្រុងដែលក្រោយមកគឺជាទីក្រុងហាណូយថា អយ្យនគរ ។ ឈ្មោះទាំងអស់នេះមិនត្រូវនឹងឈ្មោះតាមពាក្យអ្នកស្រុកអាយ ឬតាមចិនហៅ ដែលយើងដឹងនោះទេ ។

ឧត្តមសេនីយ៍ចិនដែលត្រួតត្រាស្រុកនេះតាំងពីឆ្នាំ១១១ មុនគ្រិស្តសករាជ រហូតមកដល់ឆ្នាំ៩៦៨ គឺជាង១០០០ឆ្នាំ (ក្រោយពីបានប្រគល់ខែត្រភូគាន, ក្វាងទុង និងក្វាងស៊ីទៅឲ្យចិន) បានបែងចែកទឹកដីនេះ ជាបញ្ញាការដ្ឋាន៣ គឺខ្យាវឈេត្រង់តំបន់ហាណូយ, គាវឈេន ឬគូជៀនត្រង់តំបន់ថាញ់ហ្វា, និងយេណាន ឬញ៉ុតណាម ត្រង់តំបន់ក្វាងបិញ ។

តាមមើលទៅ ពួកតុងកឹង ដែលធ្លាប់ឯករាជកាលពីសម័យរាជាណាចក្រណាមយែ មិនមែនទទួលយកនឹមត្រួតត្រារបស់ចិន ដោយស្រួលៗនោះទេ ។ តាមឯកសារប្រវត្តិសាស្ត្ររបស់គេ ពួកគេបានចាប់កាន់អាវុធប្រឆាំងនឹងចិននៅឆ្នាំ៣៩នៃគ្រិស្តសករាជ រួចហើយពួកគេកាន់អំណាចគ្រប់គ្រងប្រទេសបាន៧០ឆ្នាំ រហូតដល់ធ្លាក់ក្រោមនឹមត្រួតត្រារបស់ចិនម្ដងទៀតនៅឆ្នាំ១០៥ ។ ឯកសារនោះបានឲ្យដឹងថា មាននារីម្នាក់ ដែលស្វាមី

---

[៨] ពួកអារ៉ាប់ហៅនគរចាម្ប៉ាថា សានុ ហើយនិយាយថានៅពីខាងកើតកម្ពុជា ។

នាង ត្រូវអភិបាលខែត្រចិនសម្លាប់ដោយអយុត្តិធម៌ បានបំផុសប្រជាជនឲ្យក្រោកបះបោរឡើង សម្លាប់អភិបាលខែត្រនោះ វាយបំបាក់ទ័ពចិនជាច្រើនលើកច្រើនសា រួចហើយបង្រួបបង្រួមក្រុងទាំងហុកសិបប្រាំ ឲ្យរួបរួមគ្នាមកក្រោមអំណាចរបស់ខ្លួន ។ ក្រោយពីសោយរាជ្យបាន៣ឆ្នាំប្រកបដោយសន្តិភាពរួចមក នារីនោះ ត្រូវបានប្អូនស្រីសម្លាប់នៅក្នុងសង្គ្រាមមួយដែលធ្វើឲ្យទ័ពអាណ្ណាមបរាជ័យ ។

បន្ទាប់ពីព្រឹត្តិការណ៍នេះ អាណ្ណាមត្រូវស្ថិតនៅក្រោមនឹមត្រួតត្រារបស់ចិនចំនួន១៤៤ឆ្នាំ តែបានបះបោរប្រឆាំងម្តងទៀត និងទទួលឯករាជ្យនៅគ្រិស្តសករាជ១៨៥ ។ គឺនៅពេលនោះហើយ ដែលស្តេចរបស់ពួកគេដែលបានចម្រើនធំពេញវ័យ និងសិក្សាទ្រឹស្តីកុងហ្វ៊ុយសឺ (ខុងជឺ) នៅស្រុកចិន បាននាំមកឲ្យគេនូវអក្សរបែបចិត្តានុលេខនា និងសីលធម៌កុងហ្វ៊ុយសឺ ។ ពួកនោះក៏ចាប់បោះបង់អក្សរដើមតាមលំនាំអក្សរហិណ្ឌូចោលព្រមជាមួយនោះ បោះបង់អារ្យធម៌អារ្យាផងដែរ ។ ដោយហេតុនេះ អារ្យធម៌ចិនបានចាក់គ្រឹះនៅអាណ្ណាមហើយប្រទេសនេះ ក៏ត្រូវធ្លាក់ក្រោមនឹមចិនម្តងទៀត នៅឆ្នាំ២២៦ រហូតដល់ឆ្នាំ៥៤៤ ទើបឯករាជវិញ ប៉ុន្តែបានតែ៥៨ឆ្នាំប៉ុណ្ណោះ ។ នៅសតវត្សរ៍ទី៧ ប្រទេសនេះជាស្រុកចំណុះចិន គឺដោយហេតុនោះហើយបានជាគេឃើញមេទ័ពចិនធ្វើចម្បាំងនឹងចាមការពារទឹកដី ក៏ប៉ុន្តែកងទ័ពភាគច្រើនជាជនជាតិអាណ្ណាម ។ ប្រទេសនេះទទួលបានឯករាជ្យម្តងទៀតនៅឆ្នាំ៩៣៩ ប៉ុន្តែបានតែមួយរយៈពេលប៉ុណ្ណោះ ។

នៅក្នុងរជ្ជកាលរបស់ព្រះបាទសូរ្យវរ្ម័នជាព្រះមហាក្សត្ររបស់កម្ពុជា ប្រទេសចិនហៅ តុងកឹង ថាជាដូហូភូ គឺចាត់ទុកដូចជាអាណាខែត្រមួយរបស់ចក្រភពចិន មានរាជធានី និងមានឧបរាជចិនម្នាក់សោយរាជ្យ ។ នៅពេលនោះ អាណាខែត្រដ៏ធំរបស់ណាមវៀត ឬអាណ្ណាមនេះ បែងចែកជា៣បញ្ញាការដ្ឋាន ដែលចែកចេញបន្តជាស្រុកចំនួនដប់បី ឬចូ របស់អាណ្ណាម និងស្រុកចំនួនសែសិបនៅក្រៅរាជាណាចក្រដើម (តាមមើលទៅទំនងជាស្រុកដែលច្បាំងដណ្តើមបានពីក្រៅ) ។

តាមមើលទៅ ពួកខ្មែរហាក់ដូចជាគ្មានទំនាក់ទំនងអ្វីជាផ្លូវការថ្នាក់ជាតិជាមួយពួកអាណ្ណាមទេ នៅដើមគ្រិស្តសករាជ ឬមហាសករាជ ។

## ៣- ទៀបកោះម៉ាឡាកា

ពួកក្រិក និងឡាតាំង បានស្គាល់ទៀបកោះដែលយើងហៅថា ម៉ាឡាកា តាមឈ្មោះថា ឈែសូណៃមាស ក៏ប៉ុន្តែពួកអឺរ៉ុបបានហៅថា ម៉ាឡាកា តាំងពី៤សតវត្សរ៍មកហើយ តាមឈ្មោះទីក្រុងធំដែលមាននៅទីនោះ ។

វាហាក់ដូចជាថា ទៀបកោះនេះមិនមានឈ្មោះតាមភាសាអ្នកស្រុក ឬតាមភាសាហិណ្ឌូ តាំងពីបុរាណកាលមក សម្រាប់ហៅតួទៀបកោះទាំងមូលនោះទេ ។

ពួកចិន និងម៉ាឡេ ដែលជាពួកដើរទូកតាមសមុទ្រ ធ្លាប់បានធ្វើដំណើរមកដល់សមុទ្រខាងត្បូង, ឈូងសមុទ្រ

សៀម និងឈូងសមុទ្របឹងហ្កាល់ ជាញឹកញាប់ បានស្គាល់រដ្ឋផ្សេងៗ នៅលើទ្វីបកោះនេះ ប៉ុន្តែ ក៏គ្មានពាក្យណាសម្រាប់ហៅទឹកដីដ៏វែងនេះ ដែលតភ្ជាប់ទៅនឹងឧបទ្វីបឥណ្ឌូចិនដោយបួរដីតូចចង្អៀត និងវែងនោះទេ ។ តាមមើលទៅ កាលពីមុនប្រហែលជាមានទ្វីបកោះមួយដែលបញ្ចប់ត្រឹមក្រា រួចមានកោះមួយទៀតចាប់ពីត្រឹមក្រានៅខាងជើង រួចលាតសន្ធឹងមកត្បូងរហូតដល់សិង្ហបុរី ។

ប្រសិនបើពួកហិណ្ឌូ បានដាក់ឈ្មោះសំស្ក្រឹតណាមួយឲ្យទីនេះ នោះក៏យើងមិនបានស្គាល់ឈ្មោះនោះដែរ ។ ប៉ុន្តែ ពួកហិណ្ឌូបានដាក់ឈ្មោះឲ្យរាជាណាចក្រផ្សេងៗ ដែលបានកកើតនៅទីនោះ តែដូនកាលយើងក៏នៅតែមានការលំបាកណាស់នឹងកំណត់ថា តើឈ្មោះណាត្រូវនឹងស្រុកណា?

អ្នកស្រុកដែលរស់នៅលើទ្វីបកោះម៉ាឡាកានៅដើមគ្រិស្តសករាជ និងដើមមហាសករាជ គឺពួកមន ខ្មែរ ដែលជាអម្បូរជនជាតិក្លាយចេញពីការច្របល់ចូលគ្នា រវាងពួកមនមកពីរមញ្ញទេសៈ ឬទឹកដីតាវ័យ មកពីគេណាស់សេរីម ពីមែរគុយ និងពីម៉ាតាបាន ជាមួយពួកខ្មែរដែលរស់នៅទីនោះមុនៗ ប៉ុន្តែ ពេលនោះ វាហាក់ដូចជា មានពួកម៉ាឡេ រស់នៅរួចទៅហើយនៅលើចុងខាងត្បូង ដែលជាកន្លែងមានក្រុមឧបនិវេសន៍ហិណ្ឌូតាំងនៅ ហើយក្រុមឧបនិវេសន៍តាំងនោះ បានទទួលស្គាល់អនុត្តរភាពរបស់រាជាណាចក្រកម្ពុជា បើទោះជាថា មិនចំណុះក៏ដោយ[៧] ។

## ៤- កោះម៉ាឡេស៊ី

កោះជ្វា កោះដែលមានឈ្មោះសព្វថ្ងៃថា ស៊ូម៉ាត្រា កោះបាលី កោះប៊័រណេអូ កោះដែលយើងហៅថា សេឡែប បើនិយាយដោយខ្លីថា អាំងស៊ូឡាំងទាំងមូល ទាំងអស់នេះ ជាទឹកដីកោះដែលពួកនាវិកចិន និងហិណ្ឌូបានស្គាល់តាំងពីយូរយារណាស់មកហើយ ។ ដូចជាទ្វីបកោះម៉ាឡាកាដែរ ប្រជុំកោះទាំងអស់នេះហាក់ដូចជាគ្មានឈ្មោះរួមណាមួយសម្រាប់ហៅទេ ។ ពួកហិណ្ឌូហៅកោះទាំងនោះថា សុវណ្ណទ្វីប មានន័យថា កោះមាស ។ នៅសតវត្សរ៍ទី៩-១០ ពួកអារ៉ាប់ និងពែក្ស បានហៅអាណាចក្រមួយថាហ្សាបែគ ដែលព្រះរាជាមានព្រះឋានៈតាមភាសាសំស្ក្រឹតថា មហារាជា ហ្សាបែគ ដែលបានគ្រប់គ្រងលើកោះមួយចំនួន ព្រមទាំងភាគខាងត្បូងរបស់ម៉ាឡាកា មួយចំណែកផងដែរ ។ ក៏ប៉ុន្តែរហូតមកដល់ពេលសព្វថ្ងៃគេនៅមិនទាន់ដឹងថា តើក្រុងហ្សាបែគ និង

---

[៧] នៅលើដែនទីរបស់ផ្តូលេមេ មានឈ្មោះក្រុងជាច្រើន ដែលលោកវរសេនីយ៍ ហ្សេរីនី អះអាងថាអាចកំណត់បាន ៖ នៅលើមាត់សមុទ្រខាងលិចមាន បេរ៉ាបៃត្រូវនឹងមែរគុយ, តាកូឡាត្រូវនឹងតាកូប៉ា, សាបាណា ត្រូវនឹង សាបា ។ នៅលើមាត់សមុទ្រខាងកើតមាន ថារ៉ា ត្រូវនឹង ទ្រីនកាមី, រ៉ាលុងកា ត្រូវនឹង ក្រា ។

អាណាចក្រ របស់វានោះ នៅត្រង់ណាពិតប្រាកដនៅឡើយទេ ។

ពាក្យសំស្ក្រឹតថាជ្វាទ្វីប សំដៅយកតែកោះជ្វាមួយប៉ុណ្ណោះ ដែលចិនហៅមិនច្បាស់ថា ចូប៉ូ តែចូប៉ូនេះជួនកាល ក៏សំដៅយកកោះស៊ូម៉ាត្រា ផងដែរ ។

តាមមើលទៅ កោះដ៏ធំនេះគឺជាទឹកដីរបស់ពួកម៉ាឡេ ហៅថា ស្ថានម៉ាឡាយូ ហើយក៏ជាមាតុភូមិដើមរបស់ពួកនេះ បើហោចណាស់ក៏ខាងប្រវត្តិសាស្ត្រដែរ ។ កោះនេះមានអ្នកស្រុករស់នៅតាំងតែពីមុនគ្រិស្តសករាជមកម្ល៉េះ ។ អ្នកស្រុកទាំងអស់នោះអង់អាចហានក្លា រស់នៅប្រមូលផ្តុំគ្នាជារដ្ឋឯករាជតូចៗ តែចំណុះតិច ឬច្រើនក្រោមអំណាចរបស់រដ្ឋណាមួយ ចាប់ពីសតវត្សរ៍ទី១ដល់ទី១៨ អាស្រ័យទៅតាមកាលៈទេសៈ និងភាពអង់អាចក្លាហានរបស់ស្តេចនៃរដ្ឋនោះ ។

នៅកោះជ្វា អ្នកស្រុកមានដើមកំណើតប្រហាក់ប្រហែលនឹងអ្នកស្រុកស៊ូម៉ាត្រាដែរ តែមិនមែនជាពួកម៉ាឡេ ទេ ។ ហើយកោះនេះក៏មានចែកចេញជារដ្ឋតូចៗ ដែលស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋខ្លាំងណាមួយដូចគ្នា ។

ចំណែកឯកោះដទៃៗទៀត រួមទាំងកោះប៊័រណេអូផង មិនមានអ្វីជាល្បីល្បាញទេ ព្រោះជាជម្រកនៃពួកចោរសមុទ្រដែលគ្មានអារ្យធម៌ មិនស្វាគមន៍ភ្ញៀវ សាហាវព្រៃផ្សៃ និងជួនកាលស៊ីសាច់មនុស្សទៀតផង ។ នៅពេលដែលនៅកោះជ្វា អ្នកស្រុកមានសម្លៀកបំពាក់ដណ្តប់ប្រាណរួចទៅហើយ បើហោចណាស់ ក៏នៅតាមទីក្រុងដែរ អ្នកស្រុកនៅតាមបណ្តាកោះទាំងអស់នេះ នៅតែលែងខ្លួនទទេដោយឥតមានអៀនខ្មាសនៅឡើយ ។

ពួកចិនបានហៅកោះ និងប្រជាជនទាំងអស់នេះ តាមឈ្មោះដែលយើងមិនអាចកំណត់ប្រៀបទៅនឹងស្រុក ឬរាជាណាចក្រណាមួយ ដែលគេស្គាល់តាមឯកសារប្រវត្តិសាស្ត្រម៉ាឡេ ឬជ្វា បានទេ ។ តាមមើលទៅ ចិនហៅកោះទាំងអស់ទៅតាមឈ្មោះរាជាណាចក្រណាដែលត្រួតត្រាគេ ក្នុងពេលនោះ ឬពីមុន ឬក៏តាមឈ្មោះទីផ្សារ ឬទីក្រុងពាណិជ្ជកម្មណា ដែលពួកគេតែងចុះចត ។ ហើយជួនកាល ពួកចិនក៏អាចនឹងយកឈ្មោះរបស់ក្រុងមួយទៅប្រើសម្រាប់ហៅទីក្រុងមួយទើបនឹងកើតថ្មី ឬទើបនឹងបើកធ្វើពាណិជ្ជកម្មជាមួយបរទេស ទាំងអ្នកប្រវត្តិវិទូចិនក៏អាចនឹងច្រឡំឈ្មោះទីក្រុង ជួនកាលច្រឡំរាជាណាចក្រពីរថាតែមួយ ព្រោះមិនបានស្គាល់ភូមិសាស្ត្រសមុទ្រខាងត្បូងច្បាស់ ណាមួយវង្វេងដោយមានកោះច្រើនពេកមិនដឹងមួយណាជាមួយណា ។

តាមការនិទានតៗគ្នា កោះជ្វាបានទទួលយកព្រហ្មញ្ញសាសនានៅដើមមហាសករាជ គឺត្រូវនឹងគ្រិស្តសករាជ៧៨ ដោយព្រាហ្មណ៍ម្នាក់ឈ្មោះ អជិសកៈ ជាស្តេចរដ្ឋហស្តិនបុរៈនៅលើទន្លេគង្គា បានមកបង្កើតជារាជាណាចក្រមួយឈ្មោះថា នុសៈជ្វា ។ គេនៅតែមិនទាន់ដឹងរហូតដល់សព្វថ្ងៃ ថាតើរដ្ឋនោះនៅត្រង់ណា ។

យើងបានឃើញពីខាងលើរួចមកហើយថា ពួកម៉ាឡេបានមកតាំងអាណានិគមនៅលើមាត់សមុទ្រខាងត្បូង និងខាងអាគ្នេយ៍នៃឥណ្ឌូចិន ព្រមទាំងបានបង្កើតនគរចាម្ប៉ារួចមកហើយ ។ យើងនឹងបានឃើញតទៅទៀត

តាមរយៈប្រវត្តិសាស្ត្ររបស់កម្ពុជា និងកំណត់សម្គាល់អំពីនគរចាម្ប៉ា និងអាណ្ណាមថា ប្រជារាស្ត្រម៉ាឡេ និងជ្វា បានធ្វើដំណើរឆ្លងកាត់សមុទ្រ មកចុះចតនៅលើឆ្នេរសមុទ្ររបស់ប្រទេសទាំងបីជាញឹកញាយ ហើយបានទាំងវាយយកកម្ពុជាដាក់ជាចំណុះថែមទៀតផង ។

## ៥- ឈេទូ ឬ សៀម

ប្រទេសដែលចិនហៅថាឈេទូធីទូ -ឈ្មោះនេះមានន័យថា ដីក្រហម ហើយប្រាកដជាមិនមែនជាឈ្មោះតាមភាសាអ្នករដ្ឋវាសីទេ- រួមមានទឹកដីនៃអាងទន្លេមេណាមខាងក្រោម ហើយក៏ប្រហែលជាមានទាំងអាងទន្លេមេណាមខាងលើផងដែរ ។ យើងបានឃើញរួចហើយថា ព្រះបាទហ្វាន់ម៉ាន់ធ្លាប់បានវាយយកនគរឈេទូ នេះដាក់បញ្ចូលមកក្នុងនគរហ្វូណន ហើយទ្រង់បានឆ្លៀតយកឱកាសដែលអាណាចក្ររបស់ព្រះបាទកោណ្ឌញ្ញៈ កំពុងបែកបាក់ ដើម្បីដណ្ដើមយកឯករាជ្យមកវិញ ។

តាមមើលទៅ អ្នកស្រុកឈេទូមិនខុសគ្នាពីប្រជាជនដែលរស់នៅលើទឹកដី ដែលយើងហៅសព្វថ្ងៃថាកម្ពុជាប៉ុន្មានទេ ហើយឆ្នេរខាងឈូងសមុទ្របឹងហ្គាល់របស់រដ្ឋនេះក៏មានក្រុមឧបនិវេសន៍ហិណ្ឌូតាំងនៅ ដូចជានៅតាមឆ្នេរសមុទ្ររបស់ឥណ្ឌូចិនផងដែរ ។ អ្នកស្រុកឈេទូមានអារ្យធម៌ ទំនៀមទម្លាប់ប្រពៃណី និងសាសនា ដូចអ្នកស្រុកហ្វូណន និងចាម្ប៉ា ដែរ ។ នៅក្នុងឯកសាររបស់គេ ពួកចិនតែងប្រៀបធៀបហ្វូណនទៅនឹងឈេទូ ឬចាម្ប៉ា ដោយឥតប្រកាន់ ។ ពីព្រោះថាប្រទេសទាំង៣មានអារ្យធម៌ហិណ្ឌូ និងព្រហ្មញ្ញសាសនាដូចគ្នា ហើយគឺប្រជាជនទាំងបីនេះហើយដែលបានផ្ដល់ឲ្យឥណ្ឌូចិនទាំងមូល លើកលែងតែតុងកឹងចេញនូវចរិតលក្ខណៈ ដែលយើងស្គាល់សព្វថ្ងៃ ។

នៅសតវត្សរ៍ទី៧ ឈេទូ មិនទាន់មានធ្វើសកម្មភាពអ្វីចេញក្រៅពីព្រំដែនរបស់គេនៅឡើយទេ គឺនៅតែក្នុងវង្វង់នៃអាងទន្លេមេណាមប៉ុណ្ណោះ ។ ក៏ប៉ុន្តែ ប្រទេសនេះបានប្រាកដខ្លួនថា ជាសត្រូវមួយរបស់កម្ពុជាស្រេចទៅហើយ ព្រោះគេនេះអាចរើបម្រះខ្លួនរួចពីនឹមត្រួតត្រារបស់ហ្វូណន ដណ្ដើមបានឯករាជ្យ ហើយរក្សាឯករាជ្យនោះបានខុសពីរដ្ឋឯទៀតៗ ដែលឯករាជ្យបានតែមួយរយៈប៉ុណ្ណោះ ។

## ៦- ឥណ្ឌា

ប្រទេសឥណ្ឌាជាប្រភពនៃពួកអ្នកផ្សព្វផ្សាយអារ្យធម៌ ដែលបាននាំយកព្រហ្មញ្ញសាសនាមកកាន់កោះជ្វា និងកន្លែងជាច្រើនទៀតនៃឥណ្ឌូចិន ប្រហែលនៅឆ្នាំ៧៨នៃគ្រិស្តសករាជ ។ គឺជាទឹកដីដ៏ធំមួយ បែងចែកជាក្សត្រប្រទេសជាច្រើនដែលមានការរីកចម្រើនដោយពួកអារ្យៈរួចទៅហើយ ថែមទាំងមានអក្សរសាស្ត្រ មានប្រព័ន្ធទស្សនវិជ្ជាជាច្រើន អភិវឌ្ឍន៍រហូតដល់បរមត្ថវិជ្ជាដ៏សែនអរូបី ។ ប្រទេសឥណ្ឌាធ្លាប់ត្រូវបានពួកអេហ្ស៊ីបពួកអាស៊ីរីយាង ពួកស៊ីត និងប្រជាជាតិជាច្រើន រួមទាំងពួកក្រិចផង ដណ្ដើមយក ពួកឈ្លានពានទាំងអស់នោះ

ភាគច្រើនបានត្រឹមតែដុតបំផ្លាញប៉ុណ្ណោះ តែក៏មានពួកខ្លះកសាងអាណាចក្រនៅលើទឹកដីនេះដែរ ។

ឥណ្ឌាមានព្រហ្មញ្ញសាសនាជាច្រើនពាន់ឆ្នាំរួចមកហើយ បន្ទាប់មកព្រះពុទ្ធសាសនាក៏ចាប់បដិសន្ធិឡើងកាលពីមួយពាន់ឆ្នាំមុន ។ មានស្តេចឥណ្ឌាមួយព្រះអង្គព្រះនាមថា ធម្មសោកៈ សោយរាជ្យកាលពីបីសតវត្សរ៍មុនគ្រិស្តសករាជ បានប្រើប្រាស់ឥទ្ធិពលរបស់ពុទ្ធសាសនា ធ្វើការដណ្តើមយកឥណ្ឌាផ្នែកខាងជើងបានមួយចំណែកធំ ព្រមទាំងបានបញ្ជូនបេសកជនពុទ្ធសាសនិកមកកាន់ឥណ្ឌូចិនមាន ភូមា កម្ពុជា និងចាម្ប៉ា ផងដែរ ។ ព្រះចៅអធិរាជមហាអាឡិចសង់ ឡឺក្រង់ របស់ ម៉ាសេដូនី បានដណ្តើមយករាជាណាចក្រទាំងឡាយនៃឥណ្ឌាភាគខាងជើង រួចហើយបន្សល់ក្រុមខុបនិវេសន៍ក្រិចនៅទីនោះ ។ អាណានិគមទាំងនោះ ក្រោយមកបានក្លាយជារាជាណាចក្រក្រិចហិណ្ឌូផ្សេងៗ តែត្រូវរលុបរលាយទៅវិញដោយការមកដល់នៃជនជាតិថ្មីៗទៀត បន្តុបផ្តើតបានជាវណ្ណៈជាការប្រតិបត្តិសាសនា និងការអប់រំពិសេស ដែលនៅសេសសល់រហូតដល់សព្វថ្ងៃ ។

ឥណ្ឌាមានទឹកដីធំមហិមា និងមានផ្នែកជាច្រើន ដែលមានអារ្យធម៌ជឿនលឿនជាងប្រជាជាតិទាំងឡាយដែលនៅជុំវិញ ជាហេតុធ្វើឲ្យឥណ្ឌាអាចជះឥទ្ធិពលទៅក្រៅបាន តាមព្រំប្រទល់ខាងជើង ខាងត្បូងសាន្ត និងពាយ័ព្យដែលពោរពេញទៅដោយជួរភ្នំខ្ពស់ៗ និងមហាសមុទ្រធំៗ ព័ទ្ធជុំវិញ ។ ឥណ្ឌា បានផ្សាយអារ្យធម៌នៅ អារ៉ាកាន, អាវ៉ា, ព្រាំ, នៅណានឆាវ ឬថៃនៅស្រុកចិន, រួចបានបង្កើតអាណានិគមនៅលើឆ្នេរតេណាស់សេរីម និងមែរគុយ, នៅលើឆ្នេរទាំងអស់របស់ឧបទ្វីបកោះម៉ាឡាកា និងនៅលើឆ្នេររបស់ស្រុក ដែលយើងហៅសព្វថ្ងៃថា សៀម និងកម្ពុជា ។ ពួកអាណ្ណាមក៏ប្រហែលជាធ្លាប់ទទួលអារ្យធម៌ឥណ្ឌាខ្លះៗដែរ មុនទទួលយកអារ្យធម៌ចិន ហើយត្រូវប្រឈមមុខរួមគ្នាជាមួយចិន នៅពេលទៅដល់នគរចាម្ប៉ា ដែលអនុវត្តតាមព្រាហ្មញ្ញសាសនាផ្សេងៗ ៖ រូបបដិមាអាទិទេពព្រហ្មញ្ញសាសនាធំៗ មានដៃច្រើន, នារីមេម៉ាយអង្គុយលើគំនរភ្លើងទាំងរស់ អោបសាកសពប្តីក្នុងដៃដូចជានៅឥណ្ឌាដែរ ។

វាហាក់ដូចជាថា អារ្យធម៌ហិណ្ឌូពេលនោះ មានការជឿនលឿនជាងអារ្យធម៌ចិនបន្តិច ហើយអារ្យធម៌ទាំងពីរនេះ បានប្រជែងគ្នាដណ្តើមយកឥណ្ឌូចិន នៅដើមគ្រិស្តសករាជយើងនេះ ។ ក៏ប៉ុន្តែ មិនមានអារ្យធម៌ណាមួយមានប្រៀបជាងមួយទៀតឡើយ ពោលគឺថា អារ្យធម៌មួយអាចវាតទីយកបានទឹកដីធំ តែមិនអាចធ្វើឲ្យអារ្យធម៌មួយទៀត រលុបបាត់អស់បានទេ ។ ជាក់ស្តែង គឺទឹកដីដែលកាន់កាប់ដោយពួកអាណ្ណាមសព្វថ្ងៃ មានអារ្យធម៌តាមបែបចិនរីឯទឹកដីដែលកាន់កាប់ដោយពួកកម្ពុជា លាវ សៀម សាន និងភូមា មានអារ្យធម៌តាមបែបឥណ្ឌា ។ ចំណុចមួយទៀត គឺគ្មានអារ្យធម៌ណាមួយក្នុងបណ្តាអារ្យធម៌ទាំងពីរ ដែលអាចធ្វើឲ្យមានលក្ខណៈស៊ីវិល័យក្នុងបណ្តាពួកអ្នកស្រុកដើម ដែលមាននៅសល់ពាសពេញឥណ្ឌូចិន ក៏ដូចជានៅឥណ្ឌាខ្លួនឯង ដែលនៅមានអ្នកខ្លះដើរលែងខ្លួនទទេ មិនចេះអានអក្សរ គ្មានច្បាប់ គោរពតាមតែមេភូមិ ចងសម្ព័ន្ធភាពតែជាមួយភូមិស៊ុយតជផគ្នា ហើយជួនកាលទៀត នៅមានចងគំនុំ កាប់សម្លាប់គ្នា សងសឹក និងរបួសស្នាម ដែលកើតមានជាយូរមកហើយ ។

នៅចុងសតវត្សរ៍ទី៧នៃគ្រិស្តសករាជ ប្រទេសឥណ្ឌាមានឥទ្ធិពលយ៉ាងខ្លាំងមកលើឥណ្ឌូចិន ព្រោះថា បណ្ដាក្រុមខុបនិវេសន៍ ដែលនាំយកអារ្យធម៌មកផ្សព្វផ្សាយនៅទីនេះបន្តិចម្ដងៗ គឺក្រុមខុបនិវេសន៍ហិណ្ឌូ ហើយ រាជវង្សស្ដេចដែលសោយរាជ្យនៅទីនេះ សុទ្ធតែជាប់អម្បូរក្សត្រិយ៍ ឬព្រាហ្មណ៍ និងម្យ៉ាងទៀត សាសនាដែលគេ គោរព គឺព្រហ្មញ្ញសាសនា ឬព្រះពុទ្ធសាសនា ។ ពាក្យថា "វរ្ម័ន" មានន័យថា អ្នកការពារដែលព្រះរាជាប្រកាន់ យកនៅពេលឡើងសោយរាជ្យនៅកម្ពុជា ក៏ដូចជានៅចាម្ប៉ា ជាឋានៈដែលស្ដេចហិណ្ឌូខ្លះប្រកាន់យកនៅឥណ្ឌា ភាគខាងត្បូង ។ ច្បាប់ទម្លាប់ ប្រពៃណី ដែលគេអនុវត្ត សុទ្ធតែមានប្រភពចេញមកពីឥណ្ឌា ។ គេគោរពបូជា អាទិទេពរបស់ឥណ្ឌា គេអានសៀវភៅដែលសរសេរនៅឥណ្ឌា ។ ពួកព្រាហ្មណ៍មកតាំងទីលំនៅក្នុងឥណ្ឌូចិនដោយ ស្ម័គ្រចិត្ត ព្រោះអ្នកស្រុកអនុវត្តតាមទ្រឹស្ដីរបស់គេ ហើយលើកកូនក្រមុំឲ្យគេទៀតផង នេះបើតាមអត្ថបទចិនមួយ និយាយ ។

## ៧- ចិន

ទំនាក់ទំនងជាមួយចិន មានការលំបាកយូរ ព្រោះដំណើរតាមសមុទ្រមានគ្រោះថ្នាក់ ជាពិសេស គឺមានការ លំបាកនឹងឆ្លងជ្រោយបណ្ដូរផ្កក្នុងរយៈពេលយូរ នៅពេលដែលមានខ្យល់មូសុងបក់មកពីឦសាន ។ តែទោះជា យ៉ាងណាក្ដី យើងបានឃើញថា ទំនាក់ទំនងនោះមានរួចទៅហើយ តាំងតែពីមុនគ្រិស្តសករាជម្ល៉េះ ជាមួយនគរ ចាម្ប៉ា ក៏ដូចជាជាមួយនគរហ្វូណន ហើយថា ពួកចិនបានស្គាល់ទឹកដីតាមឆ្នេរសមុទ្រឥណ្ឌូចិន និងទៀបកោះ ម៉ាឡាកា បានល្អគួរសម ។

ចិន មានពង្សាវតារ ឯកសារប្រវត្តិសាស្ត្រ និងកំណត់ត្រាភូមិសាស្ត្រ ដែលមានចុះកាលបរិច្ឆេទច្បាស់ លាស់ ហើយការពិពណ៌នារបស់គេ ទោះបីជាចម្លងតៗគ្នាក្ដី ក៏សុទ្ធតែត្រឹមត្រូវ គ្រាន់តែថា សព្វថ្ងៃនេះគេមានការ លំបាកនឹងកំណត់ថា រឿងរ៉ាវណាបានកើតនៅទីកន្លែងណា ព្រោះឈ្មោះដែលចិនហៅនោះខុសពីឈ្មោះ ដែលអ្នក ស្រុកអាយហៅ ម្យ៉ាងទៀត ចិនមិនបានយកចិត្តទុកដាក់នឹងការប្រែប្រួលប្ដូរឈ្មោះស្រុកទេសផ្សេងៗផងទេ ។ ជួនកាល ចិនប្រើពាក្យមួយឃ្លាសម្រាប់ហៅស្រុកមួយនៅសម័យកាលមួយ ដែលអាចនឹងទៅជាមិនត្រឹមត្រូវទេ មួយសតវត្សរ៍ក្រោយមក ។ ជាក់ស្ដែង ចិនហៅនគរហ្វូណន សម័យព្រះនាងលីវយីថាជា "រាជាណាចក្រ នៃ មនុស្សស្រាត" ហើយនៅតែហៅដូច្នេះរហូត ទោះជាអ្នកស្រុកស្លៀកសម្លៀកបំពាក់ ឬក៏បានបិទបាំងកាយខ្លះ ទៅហើយក៏ដោយ ។ ដោយហេតុនេះ ជួនកាលយើងមានការច្រឡំ នៅពេលដែលយើងប្រទះឃើញក្នុងអត្ថបទ នូវ ពាក្យ "រាជាណាចក្រមនុស្សស្រាត" មិនដឹងថាគេចង់និយាយអំពីអ្នកស្រុកហ្វូណន ឬពីប្រជាជនដែលរស់នៅលើ ជួរភ្នំអាណ្ណាម ត្រង់ចន្លោះនគរចាម្ប៉ា និងកម្ពុជា គឺពួកម៉ុយសព្វថ្ងៃនេះ ។ ទោះជាយ៉ាងណាក្ដី យើងមិនគួរតវ៉ានឹង ពួកចិនខ្លាំងពេកទេ ព្រោះថា បើគ្មានឯកសាររបស់ចិនទាំងអស់នោះទេ នោះក៏យើងមិនបានដឹងអ្វីអំពីឥណ្ឌូចិនដែរ

រហូតមកដល់សតវត្សរ៍ទី១៥ ។

ម្យ៉ាងទៀត វាប្រាកដណាស់ថា ចិនមិនមែនជាអធិរាជលើប្រទេសទាំងអស់ ដែលពាណិជ្ជករ និងទូតរបស់គេបានទៅដល់ ឬក៏ត្រួតត្រាលើស្ដេចទាំងអស់ ដែលបញ្ជូនសួយសារអាករឲ្យចិន ហើយចិនផ្ញើជំនូនឲ្យទៅវិញនោះទេ ។ ក៏ប៉ុន្តែ បើតាមឯកសារទាំងឡាយដែលស្ដីអំពីទំនាក់ទំនងរបស់ចិនជាមួយក្សត្រប្រទេស និងរាជាណាចក្រជិតឬឆ្ងាយ អនុត្តរភាពរបស់ចិន បានផ្សព្វផ្សាយចុះទៅត្បូងឆ្ងាយ គ្រប់ទីកន្លែងណាដែលមានដី មានកោះ ឬទៀបកោះ បើទោះជាមិនមានការត្រួតត្រាជាក់ស្ដែងក៏ដោយ ក៏ជាការជះឥទ្ធិពលខាងសីលធម៌ និងអារ្យធម៌ ដែរ[១០] ។ ព្រះចៅអធិរាជចិន និងសេនាបតីទាំងអស់ឆ្លាតវៃណាស់ ក្នុងការប្រើប្រាស់អនុត្តរភាពនេះ ហើយយល់ច្បាស់ថា ការប្រគល់តំណែងអ្វីមួយរបស់ខ្លួន ភាគច្រើនមិនមានន័យអ្វីទេ ជាក់ស្ដែងដូចជាការប្រគល់ឋានៈដល់ស្ដេចកោណ្ឌញ្ញ (ជ័យវរ្ម័ន) ថាជា “ឧត្តមសេនីយ៍ភាគខាងត្បូង ជាស្ដេចនគរហ្វូណន” មិនមាននាំអ្វីប្លែកមកថ្វាយព្រះរាជាអង្គនេះទេ ។ ចិនយល់ច្បាស់ណាស់ថា ពាក្យសរសើររបស់ព្រះរាជាទាំងឡាយ គ្រាន់តែជាពាក្យបញ្ជោរប្រកបដោយផលប្រយោជន៍ប៉ុណ្ណោះ ប៉ុន្តែព្រះរាជានោះ មិនដាក់នគរឲ្យចំណុះចិនឡើយ ។ ម្យ៉ាងទៀត បើទោះជាការប្រឹតក្នុងចិត្តនេះមិនបានទៅដល់ព្រះចៅអធិរាជក៏ដោយ ក៏វាបានជ្រួតជ្រាបក្នុងនយោបាយរបស់ចិន ក្នុងស្រទាប់ឥទ្ធិពលផ្សេងៗ ដែលធ្វើឲ្យប្រជាជនចិនទាំងអស់មានជំនឿថា ពួកគេជណ្ដើមបានសកលលោកទាំងមូល ហើយសកលលោកគោរពបូជាគេដែរ ។

តាមពិត អំណាចខាងសីលធម៌របស់អាណាចក្រចិនដ៏ធំដែលស្ថិតនៅពីខាងជើងឥណ្ឌូចិននេះ បង្កើតបានជាអារ្យធម៌មួយខុសគេ និងធំធេងណាស់ ហើយបើទោះបីជាកន្លែងខ្លះហាក់ដូចជាមានសើៗតែខាងក្រៅ និងជា

---

[១០] គួរកត់សម្គាល់ថា ថ្វីបើចិនមិនមានអំណាចនៅក្នុងសម័យដែលយើងកំពុងសិក្សា ប៉ុន្តែដល់មកសតវត្សរ៍ក្រោយៗមក ចិនមានអំណាចខ្លះទៅលើស្រុកមួយចំនួន ៖ ជាក់ស្ដែងគឺនៅឆ្នាំ១២៩៣ ព្រះចៅអធិរាជគូប៊ីឡាយខាន់បានធ្វើសង្គ្រាមជាមួយកោះជ្វា ដែលបានប្រមាថដល់ទូតចិន ។ នៅឆ្នាំ១២៩៥ ព្រះចៅអធិរាជនេះបានទប់ស្កាត់មិនឲ្យ មានសង្គ្រាមរវាងសៀមនឹងម៉ាឡាយូ ។ នៅឆ្នាំ១៤១១ ចិនធ្វើសង្គ្រាមវាយកោះសិរីលង្កា ចាប់ស្ដេចអល្លង្កោនរៈជាចំណាប់ខ្មាំងយកទៅស្រុកចិន រួចហើយតែងតាំងសមាជិករាជវង្សម្នាក់ឲ្យសោយរាជ្យបន្ត ។ នៅឆ្នាំ១៥៧០ ស្ដេចសៀមបានសំណូមពរចិនឲ្យបួរត្រា ដែលបានប្រគល់ឲ្យស្ដេចថៃតាំងពីឆ្នាំ១៣៧៦ តែបានបាត់ទៅនៅពេលពួកប៉ាកានវាយយករាជធានីអយុធ្យា ។

ហេតុការណ៍ទាំងអស់នេះ រួមទាំងការប្រគល់នូវតំណែងដល់ស្ដេចនគរកញ្ជីនៅឥណ្ឌានៅឆ្នាំ៧២០មួយផង បញ្ជាក់ថា ចិនមិនគ្រប់គ្រងប្រទេសទាំងឡាយណា ដែលទទួលឥទ្ធិពលពីចិន ឬខ្លបខ្លាចការកំហើញ និងកិត្តិគុណរបស់ចិននោះទេ ប៉ុន្តែវាបញ្ជាក់ច្បាស់ថា សកម្មភាពអ្វីមួយរបស់ចិន ជាផ្លូវទូតឬជាផ្លូវទ័ព មានប្រសិទ្ធភាពណាស់ ហើយចិនចេះប្រើកម្លាំងធ្វើសង្គ្រាម ត្រូវពេលដើម្បីឲ្យគេឯងគោរព ។

អភិមានះ ដែលគួរឲ្យអស់សំណើចក្តី ក៏ចិនពិតជាមជ្ឈមណ្ឌលខ្លាំងមួយ ដែលទាក់ទាញក្រសែភ្នែករបស់ព្រះរាជា នៃនគរទាំងឡាយ ដែលរាជទូត ឬពាណិជ្ជករចិន បានទៅដល់ដែរ ។ ចិនមានសំពៅធំៗ ធំជាងសំពៅរបស់ស្រុកឯទៀតៗ ហើយចិនអាចធ្វើនាវាចរកាត់សមុទ្រធំៗ មិនចាញ់ពួកម៉ាឡេទេ ។ ទំនិញល្អៗរបស់ចិនធ្វើឲ្យអ្នកស្រុកស្រលាញ់កោតសរសើរ ។ សម្លៀកបំពាក់ របៀបរបបជាអ្នកមានច្បាប់ទម្លាប់ទាំងអស់នេះ ធ្វើឲ្យចិនមានមោទនភាពក្រៃលែង មោទនភាពដែលចិនចេះប្រើយកចំណេញ និងយកផលប្រយោជន៍ ព្រមជាមួយការចង់ចេះចង់ដឹងចង់ស្គាល់ប្រជាជាតិឆ្ងាយជិត ដែលនាវាគេទៅដល់ផង ។

ការត្រួតត្រារបស់ចិនលើអាណ្ណាម សង្គ្រាមជាមួយនគរចាម្ប៉ា នៅពេលណាដែលពួកចាមឈ្លានពានចូលខែត្រអាណ្ណាម ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ជំនួយជាទ័ពដែលចិនបញ្ជូនចេញទៅជួយស្តេចខាងក្រៅ ដូចជាព្រះបាទកោណ្ឌញ្ញៈ ដែលអំពាវនាវសុំដើម្បីធ្វើចម្បាំងជាមួយស្តេចប្រឆាំង ទាំងអស់នេះមានឥទ្ធិពលលើប្រជារាស្ត្រចិនណាស់ ។

ដូច្នេះ គេមិនត្រូវឆ្ងល់ទេនឹងឃើញថា ចិនហាក់ដូចជាមានវត្តមានគ្រប់ទីកន្លែងនាសម័យនោះ និងឃើញឯកសារប្រវត្តិសាស្ត្រចិន លើករៀបរាប់អំពីរាជទូតជាច្រើន ដែលព្រះចៅអធិរាជទទួលព្រមជាមួយសួយសារអាករផង ដែលផ្ញើទៅផ្ញើមកជាមួយព្រះរាជសារ ព្រះរាជសុន្ទរកថា និងតំណែងផ្សេងៗប្រគល់ជូនស្តេច ដែលគេមិនស្គាល់ រួមទាំងអ្នកដែលអះអាងថា ជាប់ខ្សែលោហិតជាមួយរាជវង្សចិន ហើយទទួលងារចិនអ្វីមួយផង ។

រដ្ឋជិតខាងមួយដែលតែងទទួលឥទ្ធិពលខាងផ្លូវសីលធម៌ និងអារ្យធម៌ពីចិនចាប់តាំងពីសតវត្សរ៍ទី៥ រហូតមក បានទទួលយកជំនឿ ទស្សនវិជ្ជា និងអក្សរចិន ក៏ប៉ុន្តែ បានទាត់ចោលអនុត្តរភាពខាងនយោបាយរបស់ចិន ព្រោះខ្លាចក្លាយខ្លួនជានគរសាមន្តរាជនោះ គឺប្រទេសជប៉ុន ។

# ជំពូកទី៥
# ប្រទេសកម្ពុជា ពីសតវត្សរ៍ទី៧ ដល់ សតវត្សរ៍ទី១០

## វ្រះឈុកិរ៖ វាសវាស័ទ
## *វ៉យធបុរៈ និងសម្ភុបុរៈ*

នៅពេលដែលព្រះបាទជ័យវរ្ម័នសុគតនៅឆ្នាំ៦៦៧ រាជាណាចក្រកម្ពុជាដែលចិននៅតែហៅថា ចេនឡា នៅឡើយ ត្រូវបានបំបែកជាក្សត្រប្រទេស២ ដូចដែលមានកាលពីសតវត្សរ៍ទី៦ មុនពេលដែលព្រះបាទ ស្រីភវវរ្ម័ន បង្រួបបង្រួមមកជារាជាណាចក្រតែមួយ ៖ មួយគឺ ក្សត្រប្រទេសមានឈ្មោះថា វ៉យធបុរៈ ដែលចិនហៅថា លូឆេនឡា មានន័យថា «ចេនឡាទឹក» និងមួយទៀតគឺ ក្សត្រប្រទេសមានឈ្មោះថា សម្ភុបុរៈ ដែលចិនហៅថា ជូឆេនឡា មានន័យថា «ចេនឡាគោក»[១] ។ ក្សត្រប្រទេសទីមួយមានទឹកដីប្រហាក់ប្រហែលត្រូវនឹងកូសាំងស៊ីនសព្វថ្ងៃ រីឯក្សត្រប្រទេសមួយទៀត ត្រូវនឹងកម្ពុជាសព្វថ្ងៃ ហើយលាតសន្ធឹងរហូតដល់ជួរភ្នំដងរែក ។

ចិនហៅចេនឡាគោកម្យ៉ាងទៀតថាវេនតាន (តាមមើលប្រហែលជាវេនឆានទេ) និងហៅថា ប៉ូឡូអ៊ូ ផងដែរ ។ ចិនអះអាងទៀតថា ព្រះរាជាទ្រង់មានព្រះឋានៈជា ស៊ីគ្យូ តែគេមិនដឹងថាពាក្យតាមភាសាសាមញ្ញជាអ្វីពិតប្រាកដទេ ។ ឯកសារចិនបាននិយាយថា មានព្រះរាជា ចេនឡាគោក មួយព្រះអង្គ បានបញ្ជូនរាជទូតទៅចូលគាល់ស្ដេចស្រុកចិននៅឆ្នាំ៧១៧ ក៏ប៉ុន្ដែ ឯកសារនោះមិនបានបញ្ជាក់ព្រះនាមទេ ។ មានព្រះរាជាមួយព្រះអង្គទៀត ដែលគេមិនបានស្គាល់ព្រះនាមដែរ គ្រាន់តែដឹងថា ប្រហែលជាសោយរាជ្យនៅចេនឡាទឹក ក៏បានបញ្ជូនរាជទូតទៅស្រុកចិនដែរ នៅឆ្នាំ៧៥០ ។

បីឆ្នាំក្រោយមក ព្រះរាជបុត្ររបស់ស្ដេចចេនឡាគោកព្រះនាមថាវេនតាន បានចូលគាល់ស្ដេចស្រុកចិនជាមួយនឹងសេនា២៦នាក់ រួចបាននាំទ័ពចិនដែលដឹកនាំដោយឧត្ដមសេនីយ៍ចិនឈ្មោះ ហូលីក្វាង ទៅវាយ

---

[១] កំណត់បង្ហាញមួយផ្ញើមកពីទីក្រុងវ៉េ សរសេរក្នុងឆ្នាំ១៩០៨ ដោយរដ្ឋមន្ត្រីសិក្សាធិការលោក លូស ដែលជាតំណាងជាន់ខ្ពស់របស់អាជ្ញាធរបារាំង (Résident Supérieur) និយាយថា «ពីមុន កម្ពុជាមានឈ្មោះថារាជាណាចក្រចានឡាប់ ឬរាជាណាចក្រ ពួកការ៉-មេន ហើយនិងមានឈ្មោះកម្ពុជាផងដែរ ។ គឺជាស្រុកតូចមួយ ចំណុះឲ្យរាជាណាចក្រមួយទៀតមានឈ្មោះថាភូណាម ។ ស្ដេចចិនព្រះនាម ថៃតុន នៃរាជវង្សយ៉ាង បានដាក់ភូណាមជាអាណានិគមមួយរបស់ចិន ហើយបានបែងចែកនគរនេះជា២ មួយគឺ ធុយចានឡាប នៅខាងត្បូង មានរាជធានីនៅ បាឡាដេបាត, និងមួយទៀតគឺលុកចានឡាបនៅខាងជើង ដែលមានរាជធានីនៅធុយក្វាត ។ ដល់មករាជ វង្សតុង ប្រទេសទាំង២នេះរួមគ្នាមកជាប្រទេសតែមួយ ហើយមានឈ្មោះថា ចានឡាប» ។

លើកលែងតែចំណុចដែលនិយាយថាភូណាមជាអាណានិគមមួយរបស់ចិន ហើយនិងការបែងចែកស្រុកជា ២ចេញ គេឃើញថា កំណត់បង្ហាញនេះត្រូវគ្នាល្អណាស់ជាមួយអ្វីដែលយើងបានឃើញខាងលើ ។

ណានឆាវ ឬថៃ នៅឯយុនណាន នៅឆ្នាំ៧៥៤ ។

នៅឆ្នាំ៧៧១ ឧបរាជ ប៉ូមី (ព្រះមី?) របស់ចេនឡាគោកបានចូលគាល់គោរពស្តេចស្រុកចិន ។ រាជទូតចេនឡាគោកម្នាក់ទៀត ឈ្មោះតាមចិនហៅថា លីទាវគី បានមកដល់ស្រុកចិននៅឆ្នាំ៧៩៩ តាមមើលទៅប្រហែលជាព្រះបាទជ័យវរ្ម័នទី២ បញ្ជូនមក នេះបើតាមរឿងរ៉ាវដែលសិលាចារឹកល្បើកស្រូត នៅខែត្រក្រចេះបានឲ្យយើងដឹង នៅឆ្នាំ៧៨១នៃគ្រិស្តសករាជ ត្រូវនឹងមហាសករាជ៧០៣[២] ។

ប្រាកដណាស់ថា រាជវង្សវ្យាធបុរៈ និងសម្ភុបុរៈ ជាគ្រួសារតែមួយ ជាប់សាច់តាមខ្សែព្រះមាតា ហើយមានទំនាក់ទំនងល្អរវាងគ្នានឹងគ្នា តាំងតែពីពេលដែលបែកគ្នាជាពីរមកម្ល៉េះ ។ ដោយហេតុនេះ ខ្ញុំសន្និដ្ឋានថា ព្រឹត្តិការណ៍ដែលនាំឲ្យប្រទេសទាំង២បែកគ្នា មិនមានអ្វីជាអាក្រក់ណាស់ណាទេ ។ ការបែកគ្នានេះ អាចជាការបែងចែកទឹកដីគ្នាគ្រប់គ្រងដោយមានការយោគយល់គ្នាទៅវិញទៅមករវាងបងប្អូន ហើយបើទោះជាការបែកគ្នានេះ បណ្តាលមកពីអំពើហិង្សាណាមួយក្តី ក៏អំពើហិង្សានោះឆាប់រលត់បាត់ទៅវិញ ព្រោះមិនបាន២៥ឆ្នាំផងក្រោយពីបែកគ្នា ក្សត្រប្រទេសទាំង២បានរៀបចំភ្ជាប់ចំណងអាពាហ៍ពិពាហ៍នឹងគ្នា ។

នេះ គឺគ្រាន់តែជាមតិផ្ទាល់របស់ខ្ញុំប៉ុណ្ណោះ ដែលខ្ញុំមិនអះអាងថា ប្រាកដជាត្រឹមត្រូវទាំងស្រុងនោះទេ ។ ក៏ប៉ុន្តែ សិលាចារឹកព្រះបាទដែលគេបានរកឃើញនៅលើភ្នំដើងព្រៃបានឲ្យគេដឹងថា ព្រះបាទស្រីបុស្ករាក្សៈ ដែលជាប់ខ្សែស្រឡាយជាមួយស្តេចនៃ អនិន្ទិតបុរៈ បានក្លាយជាព្រះរាជានៃសម្ភុបុរៈ ដោយបានបញ្ជាក់ថា «ទ្រង់ម៉ឺងម៉ាត់ខ្លាំងណាស់នៅក្នុងការប្រយុទ្ធ ហើយទ្រង់ត្រូវជាព្រះបិតុលានៃព្រះមាតារបស់ព្រះរាជាដែលបានកសាងព្រះរាជវាំងនៅលើភ្នំមហេន្ទ្រៈ[៣] ។ ទ្រង់ជាបច្ចាញាតិតាមព្រះមាតានៃ«ព្រះមហាក្សត្ររបស់ វ្យាធបុរៈ» ហើយទ្រង់ត្រូវជាព្រះបិតារបស់ ព្រះបាទរាជេន្ទ្រវរ្ម័ន ដែលជា«ឃ្លាំងនៃកុសលទាំងឡាយ» និងដែលបានសោយរាជ្យបន្តពីព្រះអង្គនៅគ្រងរាជបល្ល័ង្កសម្ភុបុរៈ ។ ព្រះបាទរាជេន្ទ្រវរ្ម័ន នេះ ប្រៀបបានទៅនឹង«ពន្លឺត្រចះនៃព្រះច័ន្ទថ្លាយង់» ។ ទ្រង់បានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះនាង នរិបតិន្ទ្រទេវី ជាព្រះវង្សានុវង្សទាយាទរបស់ព្រះអធិរាជានៃវ្យាធបុរៈ ដែលប្រសូតបានព្រះរាជឱរសមួយព្រះអង្គ ព្រះនាមថា មហិបតិវរ្ម័ន មានន័យថា ទ្រង់ជា«យុទ្ធជនឈានមុខគេនៅក្នុងរាល់ការប្រយុទ្ធ» ។ ព្រះមហិបតិវរ្ម័ន ទ្រង់បានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះនាងរាជេន្ទ្រទេវី និងត្រូវជាព្រះបិតា ព្រះនាងឥន្ទ្រទេវី ដែលជាព្រះមាតារបស់ ព្រះបាទយសោវរ្ម័ន ។

---

[២] សូមអាន "កំណត់ចំណាំលើសិលាចារឹកមួយដែលគេទើបរកឃើញនៅកម្ពុជា" ដោយលោក ហ្វ៊ីកសឺដេស ចុះផ្សាយនៅក្នុងព្រឹត្តប័ត្រសាលាបារាំងចុងបូព៌ា ខែកក្កដា-ធ្នូ ឆ្នាំ១៩០៥ ទំព័រ៤១៩ ។

[៣] ព្រះបាទយសោវរ្ម័នបានកសាងព្រះរាជវាំងមួយនៅលើភ្នំគូលែន ដែលមានឈ្មោះថាមហេន្ទ្រៈ ។

ដូច្នេះ ព្រះអង្គម្ចាស់ក្សត្រីយ៍ឥន្ទ្រទេវី ជាបច្ឆាញាតិរបស់រាជវង្សវ្យធបុរៈផង និងសម្ភុបុរៈផង ហើយទ្រង់ក៏ជាបច្ឆាញាតិរបស់ស្តេចអនិន្ទិតបុរៈ ថែមទៀត ។ ព្រះនាងជាប់ខ្សែខាងព្រះមាតាជាមួយនឹង«ព្រាហ្មណ៍អគស្ត្យៈ ដែលចេះចាំគម្ពីរវេទ និងវេទង្គៈ ច្បាស់លាស់ ព្រាហ្មណ៍នោះ មានដើមកំណើតចេញមកពី អារ្យទេសៈ» នៅឥណ្ឌាភាគខាងជើង ជាមួយនឹងព្រះនាង«យសោមទិ ជាព្រះរាជអគ្គមហេសីនៃត្រកូលខ្ពង់ខ្ពស់» ដែលមាន«ព្រះរាជបុត្រមួយព្រះអង្គ ព្រះនាមថា ស្រីនរេន្ទ្រវរ្ម័ន មានន័យថា ជាព្រះរាជាឆ្នើមលើសព្រះរាជាទាំងឡាយ ហើយទ្រង់អស្ចារ្យណាស់នៅក្នុងការប្រយុទ្ធ» ។ ព្រះរាជាដែលជាម្ចាស់នៃពិភពលោកនេះ មានបុត្រីមួយព្រះអង្គ ល្អដូចព្រះនាងលក្ស្មី ព្រះនាមថា ហ្សរេន្ទ្រលក្ស្មី ។ ព្រះរាជបុត្រីនេះ បានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះបាទរាជបតិវរ្ម័ន ជា«សត្រូសិង្ហកំពុងប្រយុទ្ធ» ហើយទ្រង់ប្រសូតបាន ព្រះនាងរាជេន្ទ្រទេវី «ដែលប្រៀបបានទៅនឹងក្សត្រីនៃវង្សអមតៈ មានព្រះកិត្តិនាមល្អឥតខ្ចោះ ផ្សព្វផ្សាយទៅគ្រប់ទិសទាំង៤ ។ គឺនៅក្នុងគភ៌របស់ព្រះនាងរាជេន្ទ្រទេវី ជាគភ៌ដែលផ្តល់កំណើតដល់វង្សស្តេចសិង្ហទាំងឡាយនេះហើយដែលព្រះបាទមហិបតិវរ្ម័ន (ដែលបានបង្រួបបង្រួមទឹកដីកម្ពុជាទាំង២មកក្នុងអំណាចរបស់ព្រះអង្គ) បានផ្តល់កំណើតដល់ព្រះនាងឥន្ទ្រទេវី ដែលល្អឥតខ្ចោះ និងមានកិត្តិនាមមូលបីដូចសមុទ្រទឹកដោះ[៤]» ។

ពង្សាវលីទាំង២ខ្សែ ដែលកំណត់ភាពស្របច្បាប់នៃរាជសម្បត្តិរបស់ព្រះបាទ យសោវរ្ម័ន នៅសតវត្សរ៍ទី៩ បើទោះជាថា មិនគ្រប់គ្រាន់ច្បាស់លាស់យ៉ាងណាក្តី ក៏ជាភស្តុតាងបង្ហាញថា អ្វីដែលខ្ញុំបាននិយាយខាងលើ ថាការបែកបាក់នៃរាជវង្សកម្ពុជានៅពេលដែលព្រះបាទជ័យវរ្ម័នទី១សុគតទៅ មិនមានអ្វីធ្ងន់ធ្ងរ និងស្ថិតស្ថេរនោះទេ ។ រាជវង្សទាំង២ ដែលរំលែកកេរ្តិ៍ដំណែលដ៏ធំធេងចែកគ្នា តែងតែមានរៀបអាពាហ៍ពិពាហ៍បុត្រាបុត្រីទៅវិញទៅមកជារឿយៗ ។

ក៏ប៉ុន្តែ វាក៏អាចនឹងមានករណីដែលកេរ្តិ៍ដំណែលនេះ មិនបានត្រូវគេចែកឲ្យទៅអ្នកត្រូវទទួលស្របច្បាប់ ហើយបែរជាត្រូវធ្លាក់ទៅក្នុងដៃអ្នកដែលបានបំបែករដ្ឋទាយាទនោះចេញក៏មាន ។ អ្វីដែលធ្វើឲ្យខ្ញុំហ៊ាន និយាយដូច្នេះ គឺមកពីមានអង្គម្ចាស់ខ្មែរមួយអង្គ ដែលគេមិនសូវស្គាល់ បានវិលត្រលប់មកពីកោះជ្វាវិញ ហើយសោយរាជ្យនៅលើបល្ល័ង្ករាជ្យវ្យធបុរៈ រួចបានបង្រួបបង្រួមប្រទេសមកជារាជាណាចក្រតែមួយឡើងវិញ ។

នៅពេលនោះ វាហាក់ដូចជាច្បាស់ណាស់ថា ព្រះបាទរាជេន្ទ្រវរ្ម័ន ដែលជាបុត្រារបស់ព្រះបាទ ស្រីបុស្ករាក្សៈ (ជាព្រះរាជាទី១នៃសម្ភុបុរៈ) ជាមួយនឹងព្រះក្សត្រីយ៍រដ្ឋទាយាទនៃព្រះរាជាវ្យធបុរៈ ដែលមិនបានបង្រួបបង្រួមប្រទេសមកជាតែមួយ កំពុងតែសោយរាជ្យនៅឯសម្ភុបុរៈនៅឡើយ ។

[៤] សិលាចារឹកព្រះបាទ, សរសេរដោយលោក បាថ ចុះក្នុងកម្រងក្បាលទី២ ទំព័រ៣៥៦-៣៥៧ និង ៣៦៩-៣៧០ ។

គឺដោយហេតុនោះហើយទើបខ្ញុំគិតថា បណ្ដាអ្នកនិពន្ធទាំងឡាយ ដែលរាប់ព្រះបាទ រាជេន្ទ្រវរ្ម័ន បញ្ចូលក្នុងចំណោមស្ដេចដែលសោយរាជ្យពេលនគរបានត្រូវបង្រួបបង្រួមហើយ ហើយថាព្រះរាជបុត្រ មហិបតិវរ្ម័ន មិនបានសោយរាជ្យនោះ គឺមិនត្រឹមត្រូវទេ ។ គ្មានស្ដេចណាមួយក្នុងចំណោមស្ដេចទាំង២អង្គនេះ បានសោយរាជ្យលើនគរកម្ពុជា ដែលត្រូវបានបង្រួបបង្រួមហើយនោះឡើយ ក៏ប៉ុន្ដែ ស្ដេចទាំង២បានសោយរាជ្យនៅលើរាជាណាចក្រកម្ពុជាដីគោក[៥] ។

បើតាមខ្ញុំយល់ គឺព្រះបាទជ័យវរ្ម័នដែលត្រលប់មកពីកោះជ្វាវិញនោះទេ ដែលជាព្រះរាជាទី១ សោយរាជ្យលើព្រះនគរដែលបង្រួបបង្រួមតែមួយ ។

[៥] ស្លោកទី៣នៃសិលាចារឹកព្រះបាទបាននិយាយថា “ព្រះបាទរាជេន្ទ្រវរ្ម័ន ... ជាស្ដេចសម្ពុបុរៈ” ហើយស្លោកទី៤ប្រាប់ថា មហិបតិ វរ្ម័ន ជាអ្នកសោយរាជ្យបន្ដពីព្រះអង្គ ។

# ជំពូកទី៦
# ប្រទេសកម្ពុជា ឬ ស្រុកខ្មែរ

## ១- ព្រះបាទជ័យវរ្ម័នទី៣ (៨០២-៨៦៩)

គេមិនបានដឹងអំពីដើមកំណើតរបស់ព្រះបាទជ័យវរ្ម័ននេះទេ តែព្រះអង្គបានប្រាកដខ្លួនឡើងជាអ្នកកសាងរាជវង្សមួយថ្មី ឬក៏ថា ទ្រង់ជាអ្នកដែលធ្វើឲ្យរាជវង្សមុនរុងរឿងឡើងវិញ ។ សិលាចារឹកស្តុកកក់ធំ បានហៅព្រះអង្គតាមព្រះមរណនាមថា បរមេស្វរៈ និងគ្រាន់តែបានឲ្យយើងដឹងថា “ព្រះអង្គយាងមកពីកោះជ្វា មកសោយរាជ្យនៅនគរឥន្ទ្របុរៈ (មានន័យថា រាជធានីរបស់ព្រះឥន្ទ្រ)” ។ ខ្ញុំមិនមានញញើតនឹងកំណត់ថា រាជធានីនេះគឺវ្យាធបុរៈ ឬបើពុំនោះទេ គឺរាជធានីដែលមានឈ្មោះជាបន្តបន្ទាប់ថា ភវបុរៈ រួចឦសានបុរៈ ។ ព្រះអង្គ ទ្រង់យាងមកជាមួយនឹងព្រះរាជគ្រូរបស់ព្រះអង្គ គឺ“បណ្ឌិតស្តែងអញសិវៈកៃវល្យៈ” ។

សិលាចារឹកស្តុកកក់ធំបានរៀបរាប់តែប៉ុណ្ណោះ ហើយមិនបាននិយាយថា តើព្រះរាជាអង្គនេះជានរណាមានសិទ្ធិដូចម្តេចខ្លះមកលើរាជបល្ល័ង្កនគរកម្ពុជាទេ ។ តាមពិតទៅ ព្រះអង្គមានសិទ្ធិនេះ តែសិទ្ធិនេះ វាកើតមានឡើងដោយថាហេតុ និងមិនចំពោះ ព្រោះថា ព្រះអង្គត្រូវជាចៅក្មួយរបស់ព្រះបាទស្រីបុស្ករាក្សៈ ដែលជាប់ខ្សែស្រឡាយទៅនឹងរាជវង្សអនិន្ទិតបុរៈ ដែលជាព្រះរាជាទីមួយនៃសម្ភុបុរៈ ក្រោយពេលបែកគ្នារួចមក ។ សិទ្ធិទទួលរាជសម្បត្តិនេះ នឹងទៅជាសិទ្ធិចំពោះបាន លុះត្រាណាតែរាជវង្សជាបុរសទាំងអស់ ដែលជាប់ខ្សែលោហិតជិតនឹងព្រះរាជាកំពុងសោយរាជ្យបានត្រូវបាត់ខ្លួនអស់ ពីព្រោះថា ថ្វីបើព្រះរាជាអាចត្រូវគេលើកឲ្យសោយរាជ្យសម្បត្តិបានក៏ដោយ ក៏ការជ្រើសរើសនោះ អាចប្រព្រឹត្តទៅបានតែលើព្រះអង្គម្ចាស់មួយអង្គនៃរាជវង្សកំពុងសោយរាជ្យ (អនុជ, បិតុលា ឬអនុជជីដូនមួយ) ប៉ុណ្ណោះ ដូចដែលគេធ្លាប់អនុវត្តនៅនគរចាម្ប៉ាពីមុន និងនៅកម្ពុជាសព្វថ្ងៃដែរ ។ គេអាចជ្រើសរើសអនុវង្សម្នាក់បានតែកាលណាគ្មានវង្សស្តេចសោយរាជ្យម្នាក់សោះ ។ តាមមើលទៅ ព្រះបាទជ័យវរ្ម័នទី៣ ទ្រង់ត្រូវជាសមាជិកមួយអង្គនៃអនុវង្សរបស់ព្រះរាជាដែលសោយរាជ្យនៅសម្ភុបុរៈ និងនៅវ្យាធបុរៈ ក្រោយពេលបែកពីគ្នា ។ តើគ្មានអង្គម្ចាស់ណាម្នាក់ទៀតទេឬ នៅក្នុងរាជវង្ស? តាមសិលាចារឹក ព្រះបាទបានបញ្ជាក់ថា ព្រះបាទមហិបតិវរ្ម័នទ្រង់មានបុត្រីមួយព្រះអង្គ គឺព្រះនាងឥន្ទ្រទេវី ដែលត្រូវជាព្រះមាតារបស់ព្រះបាទយសោវរ្ម័ន ក៏ប៉ុន្តែមិនបានបញ្ជាក់ថា តើព្រះអង្គមានរាជបុត្រមួយអង្គដែរឬក៏អត់ទេ? ។ ដូច្នេះ គ្មានរជ្ជទាយាទមួយអង្គណាទេ នៅរាជបល្ល័ង្កកម្ពុជាពេលដែលព្រះបាទជ័យវរ្ម័នយាងមកពីកោះជ្វា ។

ម្យ៉ាងទៀត ប្រសិនបើព្រះបាទជ័យវរ្ម័នទី៣គ្មានសិទ្ធិសោយរាជសម្បត្តិនៅលើរាជបល្ល័ង្កកម្ពុជាតាមរយៈរាជវង្សសម្ភុបុរៈ ឬក៏រាជវង្សវ្យាធបុរៈទេ ព្រះអង្គប្រហែលជាមានសិទ្ធិនេះតាមរយៈខ្សែស្រឡាយមុននោះ គឺថាព្រះរាជបិតា ឬព្រះអយ្យកោរបស់ព្រះអង្គ បានត្រូវគេបំបែកចេញពីរាជបល្ល័ង្ក ក្រោយពេលដែលព្រះបាទ

ជ័យវរ្ម័នទី១សុគតទៅ ដោយទ្រង់ភៀសព្រះកាយទៅនៅឯកោះជ្វា ឬក៏ត្រូវគេនាំយកទៅ ។

យើងមិនបានដឹងច្បាស់ ពីហេតុការណ៍នៃការបាក់បែកនោះកើតឡើងយ៉ាងដូចម្ដេច ហើយថាតើដោយសារព្រឹត្តិការណ៍អ្វីទេដែរ ។ ក៏ប៉ុន្តែយើងដឹងថា នៅសម័យជាមួយគ្នានោះ ពួកម៉ាឡេ និងពួកអ្នកស្រុកកោះ ពូឡូកុងឌ័រ ដែលមានកំណើតដើមជាម៉ាឡេដែរ បានទៅវាយដុតបំផ្លាញតុងកឹង ហើយពួកចិន-អាណ្ណាមត្រូវប្រើទ័ពមួយកងធំ ដើម្បីបណ្ដេញពួកនោះចេញពីបណ្ដាខែត្រដែលគេដណ្ដើមបាន គឺនៅឆ្នាំ៧៦៥ ។ យើងក៏បានដឹងដែរថា នៅឆ្នាំ៧៧៤នៃគ្រិស្តសករាជ ពួកមនុស្ស«ខ្មៅព្រីក និងស្គម» ដែលមើលទៅ គឺពួកម៉ាឡេមកពីកោះជ្វា «បានមកដល់តាមនាវាប្លែកៗ» មកវាយដុតបំផ្លាញនគរចាម្ប៉ា ហើយពួកនេះបានមកម្ដងទៀតនៅឆ្នាំ៧៨៧ ។ បើដូច្នេះ នគរកម្ពុជាក៏ប្រហែលជាត្រូវរងនូវការដុតបំផ្លាញដូចគ្នានេះដែរ ហើយពួកនោះអាចនឹងនៅត្រួតត្រានគរមួយរយៈផង ។ ត្រង់ចំណុចនេះ សិលាចារឹកស្ដុកកក់ធំក៏បាននិយាយផងដែរថា នគរកម្ពុជាស្ថិតនៅក្រោមការត្រួតត្រារបស់ជ្វា នៅក្នុងសតវត្សរ៍ទី៨[១] ។ ព្រឹត្តិការណ៍នេះ អាចជាមូលហេតុដែលធ្វើឲ្យកម្ពុជាបែកបាក់ជាពីរ ហើយពួកម៉ាឡេនៅកោះជ្វាអាចយកនាំសមាជិកខ្លះរបស់រាជវង្សព្រះបាទជ័យវរ្ម័ន ទៅជាមួយផង ។ បើសិនជាដូច្នេះមែន ព្រះបាទជ័យវរ្ម័នទី៣អាចជាសមាជិកម្នាក់នៃរាជវង្សដែលពួកជ្វានាំយកទៅជាឈ្លើយ ហើយពេលនោះព្រះអង្គនៅតូចនៅឡើយ ឬក៏ទ្រង់មិនទាន់ប្រសូត្រផង ក៏មិនដឹង ។

ហេតុដែលរាជាណាចក្រខ្មែរត្រូវបែកជាពីរ ហើយអាចនៅដូច្នេះបាន ក៏ជាការបញ្ជាក់ផងដែរថា ពួកជ្វាមិនបានបន្តធ្វើការវាយលុកចូលជ្រៅ ទៅឆ្ងាយពីមាត់សមុទ្រដែលពួកគេកាន់កាប់នោះទេ គឺឈប់ត្រឹមតែព្រំប្រទល់របស់ចេនឡាទឹកប៉ុណ្ណោះ ។

ម្យ៉ាងទៀត វាហាក់ដូចជាថាសិលាចារឹកព្រះបាទមិនបាននិយាយអំពីវ្យាធបុរៈទេ លើកលែងតែនោះ គឺជាអតីតកាល ។ ព្រោះថា បើសិនជាគេអាចធ្វើបញ្ជីរាយនាមព្រះរាជាដែលសោយរាជ្យនៅសម្ភុបុរៈ ចាប់តាំងពីនគរត្រូវបែកជាពីរ រហូតដល់នគររួបរួមគ្នាមកវិញ គេមិនអាចធ្វើដូចគ្នាបានទេចំពោះវ្យាធបុរៈ ។

តើពួកជ្វាកាន់កាប់វ្យាធបុរៈ ហើយចេនឡាទឹកត្រូវស្ថិតនៅក្រោមការត្រួតត្រារបស់ពួកជ្វា នៅពេលដែលចេនឡាគោក រក្សាបាននូវឯករាជ្យ ឬដូចម្ដេច? បើដូច្នេះមែន គឺហេតុនោះហើយដែលខារខាំងព្រះបាទ រាជេន្ទ្រវរ្ម័ន ជាព្រះរាជាទី២នៅសម្ភុបុរៈ ហើយទ្រង់ក៏ជារជ្ជទាយាទមួយអង្គរបស់វ្យាធបុរៈផងដែរ ដែលមិនឲ្យព្រះអង្គ

---

[១] លោក អែម៉ូនីញេ ជឿថាគេត្រូវបន្ថែមពាក្យ «សីលធម៌» ពីលើពាក្យនៅក្រោមការត្រួតត្រារបស់ជ្វា បានសេចក្ដីថាអាណានិគមរបស់ពួកជ្វានោះ មានត្រឹមតែលើផ្នែកអារម្មណ៍ប៉ុណ្ណោះ ។ តែខ្ញុំជឿថាការត្រួតត្រានោះមានពិតប្រាកដមែន ដូចដែលអត្ថបទបានបែង ។

វាគអំណាចមកលើវយធបុរៈបាន ។ បើទោះជាថា ព្រះអង្គសោយរាជ្យនៅសម្ពុបុរៈហើយឲ្យរាជបុត្ររបស់ព្រះអង្គសោយរាជ្យស្នងនៅវយធបុរៈក៏ដោយ ក៏ព្រះរាជបុត្រនោះ មិនមានអំណាចអ្វីលើសពីព្រះអង្គប៉ុន្មានដែរ ។ បញ្ហាត្រង់នេះមានអាថ៌កំបាំងច្រើន ហើយមានមតិជាច្រើនបានលើកសម្មតិកម្មផ្សេងៗ ប៉ុន្តែខ្ញុំគិតថា សម្មតិកម្មរបស់ខ្ញុំដូចជាសមរម្យច្រើនជាង បើទោះជាសម្មតិកម្មរបស់អ្នកមុនៗនោះ មិនសុទ្ធតែអត់ប្រយោជន៍ក៏ដោយ ។

ខ្ញុំបាននិយាយពីខាងលើរួចមកហើយ ទាក់ទិនទៅនឹងព្រះបាទឥន្ទ្រវរ្ម័នថា ទីតាំងរបស់រាជធានីឥន្ទ្របុរៈស្ថិតនៅត្រង់អង្គរធំសព្វថ្ងៃ (មហានគរ) ដែលមានឈ្មោះជាភាសាសំស្ក្រឹតថា ឥន្ទ្រប្រាស្ថៈ ។ ហើយខ្ញុំសូមបន្ថែមទៀតថា ឈ្មោះឥន្ទ្រប្រាស្ថៈ នេះ ដែលមានន័យដូច ឥន្ទ្របុរៈ ដែរ គ្រាន់តែជាឈ្មោះសម្រាប់បញ្ជាក់អំពីកិត្តិគុណឬក៏ភាពរីកចម្រើនរបស់រាជធានីនោះប៉ុណ្ណោះ ។ ខ្ញុំក៏គិតទៀតថាតើភទ្របុរៈ និងត្បូងសានបុរៈ ជារាជធានីតែមួយឬយ៉ាងណា ដែលចិនហៅថា តូមូ ហើយដែលបានត្រូវកសាងឡើងវិញ ពង្រីកឲ្យធំ និងមានកំផែងការពារផងដោយស្ដេចព្រាហ្មណ៍កោណ្ឌញ្ញៈ ។ តែការប្រៀបដូច្នេះមិនអាចធ្វើទៅបានទេ ព្រោះវាប្រឆាំងគ្នា គឺថា តូមូ ត្រូវនឹងភទ្របុរៈ រីឯត្បូងសានបុរៈ ត្រូវនឹងអង្គរធំ ឬមហានគរ ។ ទោះជាយ៉ាងណាក្ដី នៅពេលណាដែលគេរកឃើញសិលាចារឹកថ្មីៗទៀតនៅអនាគត ឬនៅពេលណាដែលអ្នកប្រាជ្ញភាសាសំស្ក្រឹតអាចអាន និងបកប្រែសិលាចារឹក ដែលយើងរកឃើញរហូតមកដល់សព្វថ្ងៃនេះបាន នោះយើងនឹងដឹងពីការពិត លែងឆ្ងល់ទៀតហើយ ។ ចំពោះមុខនេះយើងគួររង់ចាំពន្លឺដែលខ្វះខាត ហើយពិនិត្យមើលអ្វីដែលយើងអាចដឹងបានអំពីព្រះបាទជ័យវរ្ម័នទី៣ និងអំពីរជ្ជកាលរបស់ព្រះអង្គ ។

ការដែលព្រះបាទជ័យវរ្ម័នទី៣ស្ដាររាជាណាចក្រខ្មែរ ធ្វើឲ្យរុងរឿងដូចអតីតកាលឡើងវិញ ប្រហែលមិនមែនប្រព្រឹត្តទៅដោយគ្មានការប្រយុទ្ធនោះទេ ។ តាមរយៈសិលាចារឹកផ្សេងៗ វាហាក់ដូចជាថាព្រះរាជាថ្មីនេះបានធ្វើចម្បាំងដណ្ដើមយកនគរមកវិញដោយមានព្រះខ័នជាប់នៅព្រះហស្ដ ហើយទ្រង់ត្រូវប្ដូរទីតាំងទៅកន្លែងជាច្រើន ដែលយើងពិបាកនឹងកំណត់ថាកន្លែងណាជាកន្លែងណាណាស់ ។ ហរិហរល័យប្រហែលជានៅដីខែត្របាត់ដំបង ត្រង់កន្លែងដែលគេប្រាប់ខ្ញុំថាមានឈ្មោះថា ហរិហរៈ, អមរេន្ទ្របុរៈ មិនទាន់ដឹងថានៅត្រង់ណា, មហេន្ទ្របព៌ត គឺភ្នំគូលែនសព្វថ្ងៃ នៅពីខាងជើងអង្គរធំ ក្នុងខែត្រព្រហ្មទេព (ព្រហ្មទេវៈ) ។ តាមមើលទៅការផ្លាស់ប្ដូរទីតាំងនេះ អាស្រ័យដោយព្រះរាជាទ្រង់មានកង្វល់ចង់គេចឲ្យឆ្ងាយពីការត្រួតត្រារបស់ពួកជ្វាគឺថាទៅឲ្យឆ្ងាយពីមាត់សមុទ្រ ដែលនាវាសត្រូវអាចមកចុះចតបាន និងម្យ៉ាងទៀត ដោយមានការចាំបាច់ត្រូវតែដូរទីតាំងក្នុងការធ្វើចម្បាំងផង ។ ព្រះអង្គទ្រង់បានបោះបង់មហេន្ទ្រៈចោល រួចយាងត្រលប់មកកាន់ហរិហរល័យវិញ នៅពេលដែលព្រះអង្គមានវ័យចំណាស់ ប្រហែលដោយសារទ្រង់ឈ្វេងយល់ថា រាជធានីមិនត្រូវស្ថិតនៅឆ្ងាយពីបឹងទន្លេសាបពេកទេ ឬក៏ថា ដោយសារព្រះអង្គខ្លាចប៉ះទង្គិចជាមួយទ័ពចាម "ដែលប្រៀបបានទៅនឹងព្រះហស្ដដ៏ខ្លាំងឥតថ្មីមរបស់ព្រះរាជាស្រីក្រន្តវរ្ម័ន ធ្វើការឈ្លានពានចូលរហូតមកដល់ពាក់កណ្ដាលផ្ទៃប្រទេស

កម្ពុជា» ។

បើទោះជាការផ្លាស់ទីកន្លែងញឹកញាប់នេះមានមូលហេតុពិតដូចម្ដេចក៏ដោយ ក៏យើងមើលឃើញថា ព្រះបាទជ័យវរ្ម័នទី៣ ទ្រង់មិនគ្រាន់តែជាព្រះមហាក្សត្រពូកែខាងធ្វើចម្បាំង និងរៀបចំស្រុកទេសប៉ុណ្ណោះទេ ទ្រង់ក៏ជាក្សត្រដែលជឿស៊ប់ក្នុងសាសនា គោរពបូជាអាទិទេពព្រហ្មញ្ញសាសនា ជាពិសេស គឺគោរពព្រះហរិហរៈ ដែលជាការផ្គុំព្រះសិវៈ ជាមួយព្រះវិស្ណុ ក្នុងរាងកាយតែមួយ មានព្រះកេស២ផងដែរ ។ ក្នុងដំណើរផ្លាស់ប្ដូរទីតាំងរបស់ព្រះអង្គ ព្រះអង្គទ្រង់យកតាមជាប់ជាមួយនូវព្រះអាទិទេពមួយអង្គមានឈ្មោះថា «ទេវរាជា» ដែលមានពួកព្រាហ្មណ៍មួយក្រុមតាមថែរក្សា និងរៀបចំពិធីគោរពបូជា ។ ទ្រង់បានតម្កល់ព្រះទេវរាជានេះនៅហរិហរាល័យៈ រួចទ្រង់នាំយកមកតម្កល់នៅមហេន្ទ្រៈ ដោយទ្រង់ចាត់តាំងព្រះរាជគ្រូរបស់ព្រះអង្គ គឺព្រាហ្មណ៍ស្ដែងអញសិវៈកៃវល្យៈ ជាបុរោហិត អមដោយអ្នករៀបចំពិធីមួយក្រុម ។ ចាប់ពីពេលនោះមក ព្រះអង្គទ្រង់បានប្រកាសថា មានតែត្រកូល ស្ដែងអញសិវៈកៃវល្យៈ មួយប៉ុណ្ណោះ ដែលអាចទទួលឋានៈជាបុរោហិត ទទួលបន្ទុកក្នុងការរៀបចំពិធីគោរពបូជាព្រះអាទិទេពជារៀងរហូត ។

ក្រោយពីកសាងប្រាសាទមហេន្ទ្រៈរួច ព្រះអង្គទ្រង់ចាប់កសាងប្រាសាទបឹងមាលាដ៏ឆើតឆាយ ចម្ងាយប្រហែលជា ៣គីឡូម៉ែត្រ ពីភ្នំគូលែន ដែលមានកម្ទេចបាក់បែកនៅសេសសល់ល្អនៅឡើយ នៅលើផ្លូវពីព្រះខ័នទៅអង្គរធំ ល្អទាល់តែអ្នកជំនាន់ក្រោយៗជឿថា សាងសង់ឡើងដោយទេវបុត្រវិស្សុកម្ម ដែលជាវិស្សុករនៅស្ថានព្រះឥន្ទ្រ ។ ការដែលនិយាយដូច្នេះប្រហែលមិនមែនដោយការសន្និសុទ្ធសាធនោះទេ ពីព្រោះថា ពាក្យវិស្សុកម្មនេះ ជាឋានៈដែលគេដាក់ឲ្យមេវិស្សុករក្នុងព្រះរាជវាំង ។

មានអ្នកខ្លះចង់ផ្គូព្រះបាទជ័យវរ្ម័នទី៣នេះ ថាជាព្រះថោង ដែលខ្ញុំបានរៀបរាប់ពីខាងលើដោយលើកហេតុផលថា ព្រះថោងយាងមកពីឥណ្ឌា រីឯព្រះបាទជ័យវរ្ម័នទី៣យាងមកពីកោះជ្វា និងម្យ៉ាងទៀតប្រវត្តិសាស្ត្រតាមសិលាចារឹក និងរឿងនិទាននិយាយថា ស្ដេចទាំងពីរអង្គនេះ ជាអ្នកកសាងរាជប្រាសាទបឹងមាលា ។ ព្រះបាទជ័យវរ្ម័ន បានសាងប្រាសាទនេះ ដើម្បីទ្រង់គង់ប្រថាប់នៅ ឯព្រះថោងសាងប្រាសាទនេះ ដើម្បីថ្វាយដល់រាជបុត្ររបស់ក្សត្រីព្រះអង្គ គឺព្រះកេតុមាលា ដែលចាប់កំណើតឡើងដោយគ្មានបុរសណាមកបៀតបៀនព្រះកាយព្រះនាងទេ តែដោយព្រះនាងយល់សុបិនថា ព្រះឥន្ទ្របានមកអង្អែលផ្ទៃព្រះនាង ។ ការកំណត់ប្រៀបដូច្នេះ គ្មានមូលដ្ឋានទេ[៧] ។

---

[៧] មានរឿងមួយទៀតនិយាយថាព្រះកេតុមាលាមិនមែនជាព្រះរាជនត្តា និងមិនបានសោយរាជ្យបន្តពីព្រះថោង ដោយផ្ទាល់ទេ ។ បន្ទាប់ពីព្រះថោងទៅមាន ៖ បុត្រព្រះអង្គព្រះនាមថា វរៈរាជ ឡើងសោយរាជ្យបន្តនៅឆ្នាំ២១៤ មុនគ្រិស្តសករាជ ត្រូវនឹងពុទ្ធ

ខ្ញុំនិយាយដូច្នេះ មិនមែនមានន័យថា មិនឲ្យជឿរឿងព្រេង ថារឿងព្រេងគ្មានអ្វីជាប្រាកដនោះទេ ។ ដូចខ្ញុំបាននិយាយពីខាងលើរួចមកហើយថា រឿងព្រេងច្រើនតែចាប់កំណើតចេញមកពីហេតុការណ៍ប្រវត្តិសាស្ត្រ ណាមួយ ដែលបង្កប់នៅពីក្នុងការបំផ្លើសបន្ថែម និងអបិយជំនឿ ហេតុការណ៍នោះ គេពិបាកនឹងស្រាយបំភ្លឺណាស់ តែគេអាចស្រាវជ្រាវរកឃើញតាមរយៈការតុបតែងឲ្យកាន់តែល្អនោះឯង ។ ខ្ញុំសូមជូនភស្តុតាងពីរ ៖ ទី១គឺពាក្យ វរ្ម័ន ជាព្រះនាម តាមខ្សែស្រឡាយរបស់ព្រះរាជាទាំងអស់ ចាប់តាំងពីស្តេចកោណ្ឌញ្ញៈ រហូតមកដល់សតវត្សរ៍ទី១៤ តែខ្មែរសព្វថ្ងៃ ភ្លេចស្ទើរអស់បាត់ទៅហើយ ពាក្យនេះមាននៅក្នុងព្រះនាមរបស់ស្តេចចាមប្អូនអង្គក្នុងបណ្តាស្តេចចាមប្រាំមួយអង្គ គឺជ័យវរ្ម័ន, សុរិយាវរ្ម័ន, ធរណិន្ទ្រវរ្ម័ន និងអាទិត្យវរ្ម័ន ។ ចំណុចទី២ គឺព្រះនាមរបស់ព្រះរាជាទី២ ដូចព្រះនាមរបស់ព្រះបាទសុរិយាវរ្ម័ន នៅក្នុងសិលាចារឹកដែរ រីឯព្រះនាមរបស់ព្រះរាជាទី៤ ធរណិន្ទ្រវរ្ម័ន ធ្វើឲ្យគេនឹកទៅដល់ព្រះប្រថវិន្ទ្រវរ្ម័ន នៃសិលាចារឹក ព្រោះធរណី និងប្រថវី មានន័យថា ដីដូចគ្នា ។ ក៏ប៉ុន្តែ ថ្វីបើមានចំណុច ដូចគ្នាដ៏កម្រនៅក្នុងសិលាចារឹកផង និងក្នុងរឿងព្រេងផងយ៉ាងនេះក្តី ក៏យើងមិនអាចអះអាងថា អ្វីទាំងអស់នោះ ប្រាកដជាពិតជាដូច្នេះមែនទាំងអស់នោះទេ ។

សិលាចារឹកស្តុកកក់ធំ មានបែងលម្អិតរឿងមួយចំនួនគួរឲ្យឆ្ងល់ ដែលគួរតែលើកយកមកពិនិត្យ នាពេលនេះ ។ ក្រោយពីបានរៀបចំទុកដាក់ព្រះរាជវង្សឲ្យគង់នៅកន្លែងមួយមានឈ្មោះថា គុទិ នៅពីខាងកើតទន្លេរួចមក ព្រះបាទជ័យវរ្ម័ន ទ្រង់ជ្រើសរើសយកយុវជនចេញពីព្រះរាជវង្ស យកទៅកសាង អមរេន្ទ្របុរៈ ថ្វាយព្រះរាជគ្រូរួចកសាង ភវៈល័យ ដែលព្រះអង្គថ្វាយទៅព្រះរាជគ្រូដែរ រួចទើបទ្រង់កសាង លិង្គ មួយ ។

ក្នុងពេលដែលទ្រង់គង់នៅឯមហេន្ទ្របព៌ត ទ្រង់បានចាត់ឲ្យព្រាហ្មណ៍ហិរយនធម្មៈ ជាព្រាហ្មណ៍មកពីជនបទ

---

សករាជ៣៣១ ពេលដែលព្រះអង្គមានព្រះជន្ម ១៦ព្រះវស្សា ហើយសុគតទៅក្រោយពីសោយរាជ្យបាន ៤០ឆ្នាំ ។ បុត្ររបស់ព្រះវរៈរាជ ព្រះនាមថា ឧទ័យរាជា បានឡើងសោយរាជ្យបន្តពីព្រះបិតាក្នុងព្រះជន្ម ១៦ព្រះវស្សាដែរ ហើយសុគតនៅឆ្នាំ៤១៩ ក្រោយពីសោយរាជ្យបាន ៤៨ឆ្នាំ ។ ព្រះរាជបុត្ររបស់ព្រះឧទ័យរាជា ព្រះនាម សុវណ្ណបទុមរាជា ឡើងសោយរាជ្យបន្តក្នុងព្រះជន្ម ១៦ព្រះវស្សា សុគតនៅឆ្នាំ៤៦៣ ក្រោយពីសោយរាជ្យបាន ៤៨ឆ្នាំដែរ ។ បន្ទាប់មក គឺព្រះអនុជថ្លៃព្រះនាមថា បទេសរាជាធិរាជ ជាកូនអ្នកនេសាទ និងជាស្វាមីព្រះនាងឆាយស ដែលត្រូវជាព្រះអនុជរបស់ព្រះសុវណ្ណ បទុមរាជា ដែលទ្រង់លើកឲ្យធ្វើជាស្តេចគ្រាញ់លើស្រុកមួយ ក្រោយមកត្រូវនាម៉ឺនសព្វមុខមន្ត្រីពេញចិត្តរួចលើកឲ្យសោយរាជ្យសម្បត្តិបន្តបាន ៩១ឆ្នាំ ។ ក្រោយនោះមានប្រជារាស្ត្រម្នាក់ឈ្មោះថា អ្នកវង្ស ជាមនុស្សមានបុណ្យចេស្តា ប៉ះរបស់អ្វីរបស់នោះក្លាយជាមាស ត្រូវបាននាម៉ឺនសព្វមុខមន្ត្រី និងប្រជារាស្ត្រ ជ្រើសរើសឲ្យឡើងសោយរាជ្យ នៅពុទ្ធសករាជ ៥៥៤ (ត្រូវនឹងគ្រិស្តសករាជ ១១) ក្នុងអាយុ ៣៣ឆ្នាំ ។ ប្រពន្ធរបស់អ្នកវង្ស ឈ្មោះ ជូ បានត្រូវអភិសេកជាព្រះអគ្គមហេសីក្រោមព្រះនាមថា ព្រះជូវត្តី ព្រះនាងទ្រង់សុបិនថា ព្រះឥន្ទ្រ មកអង្អែលផ្ទៃ រួចប្រគល់កែវមណីរ័ត្នឲ្យ ទើបព្រះនាងទ្រង់គភ៌ ប្រសូតបានព្រះកេតុមាលា ដែលឡើងសោយរាជ្យបន្តពីព្រះបទេសវង្ស-អាចារ្យ ជាព្រះបិតា នៅពុទ្ធសករាជ ៦០០ ត្រូវនឹងគ្រិស្តសករាជ ៥៧ ។

"ជាអ្នកប្រាជ្ញចេះចាំនូវវិទ្យាសាស្ត្រគ្រប់គ្រាន់" ពិនិត្យសើរើច្បាប់ទាំងឡាយ ដែលបញ្ជាក់អំពី"ភាពចំណុះជារបស់ព្រះអង្គ "ដើម្បីធ្វើឲ្យ កម្រតេង ផែ្ទក្រោមទាំងអស់ (គឺបណ្តាស្តេចត្រាញ់ផ្នែកខាងក្រោមព្រះធរណី) មានច្បាប់សម្រាប់អនុវត្តចំពោះព្រះចក្រវាទិន គឺព្រះអធិរាជជាម្ចាស់ទឹកដី ។ ព័តមានលម្អិតនេះបញ្ជាក់ថា ព្រះបាទជ័យវរ្ម័នទី៣ ទ្រង់ប្រកាសខ្លួនព្រះអង្គ ថាជាព្រះមហារាជ ហើយប្រគល់ដល់ព្រះរាជាឯទៀតក្នុងស្រុកខ្មែរ នូវឋានៈដូចព្រះរាជាវយធបុរៈ ដូចដែលមានចែងនៅក្នុងសិលាចារឹកព្រះបាទ ។

ព្រះបាទជ័យវរ្ម័នទី៣ទ្រង់សុគតនៅឆ្នាំ៨៦៩ ក្រោយពីទ្រង់សោយរាជសម្បត្តិបាន៦៧ឆ្នាំ និងមានព្រះមរណនាមថា បរមេស្វរៈ មានន័យថា "ទ្រង់ជាភ្ញៀវរបស់ស្ថានសួគ៌ឥស្វារៈ" គឺស្ថានរបស់ព្រះសិវៈ ។

ទំនៀមមួយដែលគេប្រទះឃើញមាននៅអាណ្ណាម ក៏ដូចជានៅស្រុកចាម ហើយដែលនៅមានរហូតដល់សព្វថ្ងៃនៅកម្ពុជា គឺថ្វាយព្រះនាមមួយទៀតដល់ព្រះរាជាដែលសុគតទៅ ដទៃពីព្រះនាមពេលដែលទ្រង់នៅមានព្រះជន្ម ព្រះនាមនោះគេច្រើនតែដកយកពីឈ្មោះស្ថានសួគ៌ណាមួយ ដែលគេគិតថា ព្រះអង្គនឹងយាងទៅចាប់កំណើត ។ ព្រះបាទជ័យវរ្ម័ន ទ្រង់មានព្រះមរណនាមថា បរមេស្វរៈ ឯព្រះរាជាដែលសោយរាជ្យបន្តពីព្រះអង្គក៏សុទ្ធតែមានព្រះមរណនាមដែរ ព្រះមរណនាមនោះច្រើនតែបញ្ចប់ដោយពាក្យថា "លោក" ឬ "បទ" ដែលមានន័យថា "ទីកន្លែង" ដូចគ្នា ចំណែកឯព្រះនាមវិញ គឺច្រើនតែយកព្រះនាមរបស់ព្រះអាទិទេពណាមួយតែម្តង ។ ប្រហែលជាចាប់តាំងពីពេលនោះមក នៅពេលដែលព្រះរាជាមួយអង្គទ្រង់សុគតទៅ គេតែងតែសាងសង់រូបបដិមាមួយ ដែលជារូបព្រះអាទិទេពតំណាងព្រះរាជានោះ ពេលទ្រង់យាងទៅកើតនៅស្ថានសួគ៌ ប្រកបដោយលក្ខណៈទាំងឡាយរបស់ព្រះអង្គ ។

## ១- ព្រះបាទជ័យវរ្ម័នទី៤ (៨៦៩-៨៧៧)

ព្រះរាជាដែលសោយរាជ្យបន្តពីព្រះបាទជ័យវរ្ម័នទី៣គឺរាជបុត្ររបស់ព្រះអង្គ ដែលជាស្តេច"មានរស្មីភ្លឺចិញ្ចាចបីដូចជាព្រះអាទិត្យ ប្រកបទៅដោយគុណធម៌វីរភាព ទ្រង់ជាអ្នកបង្កើនភោគទ្រព្យ និងកិត្តិគុណ" (បន្តពីព្រះបិតា) ។ គឺដោយសារគុណសម្បត្តិទាំងអស់នេះហើយ ទើបបានជាទ្រង់មានព្រះនាមមុនពេលឡើងសោយរាជ្យថា ព្រះស្រីជ័យវរធម្មៈ រួចហើយមានព្រះអភិសេកនាមថា ស្រីជ័យវរ្ម័ន ។ ព្រះអង្គជាព្រះចៅអធិរាជដូចជាព្រះបិតាដែរ ហើយ"ព្រះបាទរបស់ព្រះអង្គ ជាន់នៅពីលើព្រះកេសរបស់ព្រះរាជាទាំងឡាយ" ។

ព្រះបាទជ័យវរ្ម័នទី៤ ទ្រង់សោយរាជ្យនៅហរិហរល័យ ជារាជធានីដែលព្រះបិតាសាងសង់ឡើង ហើយដែលទ្រង់យាងត្រលប់មកគង់នៅវិញនៅចុងរជ្ជកាលរបស់ព្រះអង្គ ក្រោយពីទៅគង់នៅឯមហេន្ទ្របុរៈមួយរយៈ ។ ព្រះអង្គគង់នៅជិត"ព្រះទេវរាជា" ដោយមានព្រាហ្មណ៍ស្តែងអញសុខៈស្នាវិន្ទុ ត្រូវជាក្មួយរបស់ស្តែងអញសិវកៃវល្យៈ ជាបុរោហិតរៀបចំពិធីគោរពបូជា ជាមួយព្រាហ្មណ៍មួយក្រុម ។

ព្រះបាទជ័យវរ្ម័នទី៤ បានសុគត នៅឆ្នាំ៨៧៧នៃគ្រិស្តសករាជ ត្រូវនឹងមហាសករាជ៧៩៩ រួចទ្រង់ទទួលព្រះមរណនាមថា វិស្ណុលោក មានន័យថា ការស្នាក់នៅនៃព្រះវិស្ណុ ឬថា ជាភ្ញៀវរបស់ព្រះវិស្ណុ ។

## ១- ព្រះបាទឥន្ទ្រវរ្ម័នទី១ (៨៧៧-៨៨៩)

ព្រះបាទឥន្ទ្រវរ្ម័ន (ព្រះឥន្ទ្រជាអ្នកការពារ) សោយរាជ្យបន្តពីព្រះបាទជ័យវរ្ម័នទី៤ ។ ព្រះអង្គត្រូវជាបងប្អូនឆ្ងាយរបស់ព្រះបាទជ័យវរ្ម័ន ហើយទ្រង់ហាក់ដូចជាមិនមានសិទ្ធិត្រឹមត្រូវលើរាជសម្បត្តិប៉ុន្មានទេ ។ ប្រសិនបើព្រះបាទជ័យវរ្ម័ន មានរាជបុត្រមួយព្រះអង្គ ឬមានព្រះអនុជ ឬក៏បងប្អូនជីដូនមួយនោះ ព្រះបាទឥន្ទ្រវរ្ម័ន គឺជាស្តេចជ្រែករាជ្យ បើពុំនោះទេ ជាព្រះរាជាដែលគេជ្រើសតាំងឡើង ក្នុងចំណោមរាជវង្ស តែសាច់ឆ្ងាយបន្តិច ។

ព្រះអង្គត្រូវជាព្រះរាជនត្តាក្មួយរបស់ព្រះបាទស្រីរុទ្រវរ្ម័ន ដែលត្រូវជាអយ្យកាមីងខាងព្រះមាតារបស់ព្រះបាទជ័យវរ្ម័នទី៤ ។ ព្រះបាទស្រីរុទ្រវរ្ម័ននេះ មានព្រះនាមល្បីថា “ជាអ្នកនិយមការជាក់ស្តែង និងមានវីរភាពឥតប្រៀបផ្ទឹម ។ ទ្រង់គិតតែពីព្រះរុទ្រ ហើយទ្រង់ទទួលបានជ័យជម្នះល្បីល្បាញក្នុងរាល់ការប្រយុទ្ធ” ។ ព្រះបិតារបស់ព្រះអង្គ គឺព្រះព្រឹទ្ធិវិន្ទ្រវរ្ម័ន ដែលសិលាចារឹកលើកប្រៀបប្រដូចទៅនឹង “មហាសាគរ ពោរពេញទៅដោយគុណធម៌” និងទ្រង់“ពូកែល្បីខាងទាញយកផលពីព្រះធរណី” ។ ទាំងអស់នេះ តាមមើលទៅ គឺគ្រាន់តែជាការលើកសរសើរតែប៉ុណ្ណោះ ។ ព្រះព្រឹទ្ធិវិន្ទ្រវរ្ម័ននេះ (ជាបុត្ររបស់ព្រះអនុជក្សត្រី ឬក៏ព្រះបុត្រី) របស់ព្រះបាទរុទ្រវរ្ម័នជាមួយនឹងព្រះនិវិប្បទិន្ទ្រវរ្ម័ន ។ សន្តតិវង្សខ្ទីដូច្នេះ មើលទៅ គឺជាពង្សាវលីរបស់ស្តេចដែលសោយរាជ្យនៅលើក្សត្រប្រទេសមួយតូច អាចថាមិនមែនជាក្សត្រប្រទេសចំណុះទេ ក៏ប៉ុន្តែសោយរាជ្យតៗគ្នា តែដូច្នេះ ពោលគឺជាអង្គម្ចាស់មួយអង្គ ដែលនៅឆ្ងាយពីរាជបល្ល័ង្ក និងជាអនុវង្សៈ មិនមែនជាវង្សៈ[៣]ទេ ។

ព្រះបាទឥន្ទ្រវរ្ម័នទ្រង់ឡើងសោយរាជ្យបន្តពីព្រះបាទជ័យវរ្ម័នទី៤ ប្រហែលដោយសារព្រះបាទជ័យវរ្ម័នទី៤ ទ្រង់សុគតទៅដោយគ្មានបុត្រាមួយអង្គសោះ ហើយគ្មានវង្សមួយអង្គសោះ ចន្លោះពីព្រះបាទជ័យវរ្ម័នមកដល់ព្រះអង្គ ។ រឿងនេះហាក់ដូចជាគ្មានអ្វីប្លែកទេ ព្រោះតាមការពិនិត្យពង្សាវលីសម្ពុបុរៈព្រះមហាក្សត្រីមិនសម្បូររាជបុត្រប៉ុន្មានទេគឺមានតែរាជបុត្រាឬរាជបុត្រីមួយអង្គប៉ុណ្ណោះ ។ តើជាតិសាសន៍ចាប់រេចរឹល ហើយឬយ៉ាងណា ឬក៏ថា បណ្តាក្សត្រាទាំងឡាយឆាប់ប្រឡូកនឹងល្បែងស្នេហាតាំងពីវ័យក្មេងៗ រួចមានមហេសី លុះតែពេលមានវ័យចំណាស់ ដែលចុះខ្សោយណាស់ទៅហើយ ដូចជានៅឥណ្ឌាអ៊ីចឹង ? ម្យ៉ាងទៀត ព្រះរាជានាពេល

---

[៣] ជាវង្សៈបាន គឺព្រះរៀម ឬព្រះអនុជក្សត្រាក្សត្រី, ព្រះបិតុលា ឬមាតុច្ឆា, ព្រះរៀម ឬព្រះអនុជរួមអយ្យកោអយ្យកា, ព្រះបិតាមាតា, ព្រះអយ្យកោអយ្យកា, ព្រះអយ្យកោមា ឬអយ្យកាមីង នៃព្រះរាជា ។

នោះអាចនឹងមានព្រះជាយា និងស្រីស្នំជាច្រើន ដូចនៅកម្ពុជាសព្វថ្ងៃ ក្នុងនោះមានតែព្រះអគ្គមហេសីមួយប៉ុណ្ណោះ ដែលជាព្រះមហាក្សត្រីដែលព្រះរាជបុត្រមានសិទ្ធិអាចឡើងសោយរាជ្យស្នងបាន ដូចដែលជាទម្លាប់រហូតមកដល់ពេលថ្មីៗនេះ នៅប្រទេសលាវ ។ បើទោះជាយ៉ាងណាក្តី ការជ្រើសរើសយកព្រះបាទឥន្ទ្រវរ្ម័នឲ្យឡើងសោយរាជ្យ ហាក់ដូចជាមិនប្រក្រតី ។ ក៏ប៉ុន្តែ មិនមានឯកសារណាបញ្ជាក់ថា ព្រះអង្គឡើងសោយរាជ្យដោយមានការបញ្ចៀសរជ្ជទាយាទពេញសិទ្ធណាមួយចេញ ក៏ទេដែរ ។

មានមនុស្សពីរនាក់ដែលមានតួនាទីសំខាន់យ៉ាងខ្លាំងនៅក្នុងរជ្ជកាលនេះ ហើយប្រហែលជាសំខាន់ ជាពិសេស នៅពេលដែលគេធ្វើការជ្រើសរើសព្រះបាទរុទ្រវរ្ម័ន ឲ្យឡើងសោយរាជ្យ ប្រសិនបើព្រះអង្គឡើងសោយរាជ្យបែបនេះ ។ នោះគឺស្តេងអញស្រីសោមៈ ជាព្រះរាជគ្រូ, និងវិមសិវៈ ដែលជាបព្ពូជជាមួយសិវកៃវល្យៈ ហើយជាសិស្សរួមគ្រូតែមួយជាមួយស្រីសោមៈផង ។ វិមសិវៈ នេះបានត្រូវព្រះរាជាជ្រើសតាំងឲ្យធ្វើជាបុរោហិតរៀបចំពិធីគោរពបូជាផ្សេងៗ ។ អ្នកទាំងពីរនាក់នេះ បានរៀបចំកសាងប្រាសាទមួយថ្វាយព្រះសិវៈ រួចឲ្យធ្វើលិង្គពីរដាក់ក្នុងប្រាសាទនោះ ។ ដោយហេតុនោះហើយ បានជាគេហៅអ្នកទាំងពីរម្នាក់ថាជា កម្រតេងចាស់ ម្នាក់ទៀតថាជា កម្រតេង ក្មេងនៃព្រះសិវស្រមៈ ។ អ្នកជំនាញខាងឥណ្ឌាវិទ្យាជឿថា សិវស្រមៈនោះ គឺប្រាសាទបាយ័ន ។

ព្រះបាទឥន្ទ្រវរ្ម័ន បានចាត់ឲ្យសាងប្រាសាទបាគោធ្វើអំពីថ្ម សង់លិង្គមួយឈ្មោះថា ស្រីឥន្ទ្រេស្វរៈ ហើយនិងរូបបដិមាប្រាំមួយទៀត ក្នុងនោះមានរូបបីព្រះអង្គ មួយដូចព្រះព្រឹទ្ធិវិន្ទ្រវរ្ម័ន ជាព្រះបិតាមួយទៀត ដូចព្រះបាទរុទ្រវរ្ម័ន ជាព្រះអយ្យកោខាងព្រះមាតា និងមួយទៀតដូច ព្រះបាទជ័យវរ្ម័នទី៣ ជាអ្នករៀបចំរាជវង្សឡើងវិញ ។ រីឯព្រះបដិមាបីព្រះអង្គទៀត គឺដូចព្រះមហេសីរបស់ស្តេចទាំងបី គឺព្រះមាតារបស់ព្រះអង្គ ព្រះអយ្យកា ហើយនិងព្រះមហេសីរបស់ព្រះបាទជ័យវរ្ម័នទី៣ ។

ព្រះអង្គបានសាងប្រាសាទបាគងនៅជិតប្រាសាទបាគោ[៤] រួចបានកសាងនៅឯសិវៈបុរៈ ដែលគេមិនដឹងជានៅឯណា នូវ«ប្រាសាទមួយមានពន្លឺភ្លឺចិញ្ចាចចិញ្ចែងប្រៀបបានទៅនឹងរតនវត្ថុ រុំព័ទ្ធទៅដោយវល្លិមានសន្លឹកស្រស់បំព្រង សម្រាប់ការពារព្រះសិវៈ ទប់ទល់នឹងភាពត្រជាក់ និងអាកាសធាតុប្រែប្រួលផ្សេងៗទៀត» ។ នៅជិតប្រាសាទទាំងពីរ«ដែលព្រះអង្គបានសង់ដោយស្នាព្រះហស្តផ្ទាល់ ហើយដែលទ្រង់បានផ្តល់នូវមធ្យោ-

[៤] ប្រវត្តិតាមរឿងនិទាននិយាយថាប្រាសាទទាំង២នេះ រួមជាមួយប្រាសាទទី៣មួយទៀត គឺប្រាសាទលលៃ ដែលបង្កើតបានជាក្រុមប្រាសាទមួយ បានត្រូវកសាងឡើងដោយ ព្រះមហាក្សត្រទី៣របស់កម្ពុជា គឺស្តេចចាមសុរិយាវរ្ម័ន ដែលគោរពថ្វាស្វយម្ភូ ។ ស្វយម្ភូនេះគឺជាជីវិតដែលកើតមានឯង ពោលគឺព្រះព្រហ្ម ក៏ប៉ុន្តែជួនកាលក៏សំដៅចំពោះ ព្រះសិវៈ និងព្រះវិស្ណុផងដែរ ។ បើសិនជាស្វយម្ភូក្នុងរឿងនិទាននេះមិនសំដៅយកព្រះសិវៈទេ នោះគេមិនអាចពន្យល់បានទេ ព្រោះធម្មតា ថ្មនេះសំដៅយកលិង្គនោះឯង ។

បាយផ្គត់ផ្គង់ស្បៀង សេចក្តីសប្បាយ និងការគាប់ចិត្តគ្រប់យ៉ាង ទ្រង់បានចាត់ឲ្យជីកស្រះដ៏ល្អ ដើម្បីបំពេញជូនភ្ញៀវ និងជនដទៃទាំងឡាយ នូវភាពសម្បូរសប្បាយប្រកបទៅដោយវត្ថុចាំបាច់សម្រាប់ការរស់នៅ» ។

ដូចជាព្រះមហាក្សត្រមុនៗដែរ ព្រះបាទឥន្ទ្រវរ្ម័នជាក្សត្រពូកែធ្វើសង្គ្រាម ។ សិលាចារឹកព្រះបាទបានចាត់ទុកព្រះអង្គថា«សមនឹងទទួលការគោរពពីអ្នកទាំងឡាយដែលជាសីហៈ ក្នុងចំណោមមនុស្សជាតិ» ចំណែកឯសិលាចារឹកបាយ័ន់ និយាយថា «ជាសត្វសិង្ហក្នុងបណ្តាព្រះរាជាទាំងឡាយ ព្រះអង្គមិនដែលរាថយពីការប្រយុទ្ធសោះឡើយ ។ ព្រះអង្គប្រកបទៅដោយគុណធម៌ទាំងឡាយដែលព្រះរាជាត្រូវមានរួមទាំង «គុណធម៌ទាំង១០ជាប្រធាន[៥]», គុណសម្បត្តិទាំង៦ ហើយទ្រង់មានអានុភាពទាំង៣ ពីព្រោះថា ព្រះអង្គអាចឈ្នះលើព្រះកាយព្រះអង្គឯងបាន បានការពារដែនដីនេះប្រៀបបានទៅនឹងមនុ ដោយមិនមានអាក់ខានក្នុងកាតព្វកិច្ចរៀបចំពិធីបួងសួង និងដឹងច្បាស់អំពីអ្វីដែលគួរ អ្វីដែលពុំគួរ» ទៀតផង ។

សិលាចារឹកបានបន្តទៀតថា «ប្រហែលជាព្រះដែលបង្កើតលោកនេះ លោកនឿយណាយនឹងការបង្កើតស្តេចច្រើនពេក ទើបលោកបង្កើតព្រះរាជាអង្គនេះមក ឲ្យប្រកបទៅដោយគុណសម្បត្តិគ្រប់គ្រាន់ សម្រាប់លោកទាំងបី ព្រះរាជានេះហើយដែលស្តេចឯទៀតៗទទួលយកបញ្ញារដាក់លើសិរសា» ។

ព្រះបាទឥន្ទ្រវរ្ម័ន សុគតនៅឆ្នាំ៨៨៩នៃគ្រិស្តសករាជ ត្រូវនឹងមហាសករាជ៨១១ ហើយទ្រង់មានព្រះមរណនាមថា ឥស្វរៈលោក ។

## ៥- ព្រះបាទយសោវរ្ម័ន (៨៨៩-៩០៨)

ព្រះបាទយសោវរ្ម័នជាព្រះរាជបុត្ររបស់ព្រះបាទឥន្ទ្រវរ្ម័នទី១ ហើយទ្រង់បានសោយរាជ្យបន្តពីព្រះបិតា នៅឆ្នាំ៨៨៩នៃគ្រិស្តសករាជ ត្រូវនឹងមហាសករាជ៨១១ ។ សិលាចារឹកបាននិយាយអំពីព្រះអង្គថា ជា«ការប្រមូលផ្តុំនៃភាពថ្កុំថ្កើង» ព្រោះព្រះអង្គបានវាតអំណាចត្រួតត្រារបស់កម្ពុជាបានខ្លាំងជាងគេ ។ សិលាចារឹកបានលើកឡើងទៀតថា ព្រះអង្គគួរទទួលបាននូវព្រះនាមបី ៖ ចំពោះអ្នកប្រាជ្ញ ព្រះអង្គជាគ្រូអាចារ្យ ជាសាស្ត្រាចារ្យ, ចំពោះនារីៗ ព្រះអង្គជាបុរសគួរជាទីស្នេហា, ចំពោះព្រះរាជាទាំងឡាយ ព្រះអង្គជាព្រះមហេន្ទ្រៈ គឺព្រះឥន្ទ្រធំ ។ ព្រះអង្គបានចាប់បដិសន្ធិឡើង «ប្រកបទៅដោយសម្ផស្សល្អលើសគេ ពុំមាននរណាម្នាក់ ដែលមាន

---

[៥] នោះគឺគុណធម៌សំខាន់ៗមាន ៖ សប្បុរស, ខន្តី, វិទ្យាសាស្ត្រ, ក្លាហាន, សីលធម៌, វីរភាព, ក្លៀវក្លា, ថាមពល, អានុភាព និងប្រាជ្ញា ។

បើតាមក្បួនច្បាប់ខ្មែរវិញ គុណធម៌សំខាន់ៗខុសពីនេះ ៖ ទាន, កុសល, សប្បុរស, មជ្ឈត្តិកភាព, មនុស្សធម៌, ខន្តី, ភាពត្រូវតាមគន្លង, ត្រាប្រណី, តបកម្ម និងវីរិយៈ ។

ព្រះភ័ក្ត្រស្រស់ល្អស្មើនឹងព្រះអង្គឡើយ ក្រៅតែពីព្រះចន្ទ្រចេញ» ។ «កិត្តិគុណរបស់ព្រះអង្គបរិសុទ្ធ ប្រៀបបាន ទៅនឹងកាំពន្លឺព្រះចន្ទ្រា ដែលគ្របដណ្ដប់ទៅគ្រប់ទិសទីនៃពិភពលោក ហាក់បីដូចជាសមុទ្រទឹកដោះ ហើយដេញ កម្ចាត់អស់នូវភាពអន្ធកាល ដែលរត់គេចដោយខ្លាចរឹងស្លួត ដោយគេជានុភាពរបស់ព្រះអង្គ ។ ទ្រង់ជាព្រះចៅ អធិរាជលើព្រះរាជាទាំងឡាយ ហើយកិត្តិនាមដ៏រុងរឿង, នយោបាយ, សោភ័ណភាព និងសប្បុរសធម៌របស់ ព្រះអង្គបានផ្សព្វផ្សាយទៅគ្រប់ទិសទាំងបួន ប្រៀបបាននឹងទេពធីតាដែលលម្អទៅដោយ ការសន្តោស, ថាមពល, គុណធម៌, ភាពរមទម្យ, កិត្តិគុណ, កុសល និងគតិបណ្ឌិត ។ នៅក្នុងការប្រយុទ្ធ ព្រះអង្គមានព្រះហស្តត្រៀមជានិច្ច នឹងសម្លាប់សត្រូវកោងកាច បីដូចជាទ្រង់បានរៀនសូត្រពី គទព្រឹទ្ធ (ក្រឹស្ន-វិស្ណុ) នូវល្បិចចាប់ហែកទ្រូងរបស់ ហិរន្យកស្សិពុ (មនុស្សសិង្ហ-ជាស្ដេចយក្ស) អ៊ីចឹង ។ ព្រះខ័នរបស់ព្រះអង្គ តែដកចេញហើយ មិនដែលអាក់ខាន នឹងកាប់នោះទេ ហើយកាប់តែមួយព្រះខ័ន អ៊ីៗក៏ដាច់ជាបីកំណាត់ដែរ ទោះជាដែកវែង, មូល, ធំ ឬរឹង យ៉ាងណាក៏ ដោយ គឺហាក់បីដូចជាការដាក់ទោសចំពោះការដែលហ៊ានប្រឆាំងនឹងថ្វីព្រះហស្តរបស់ព្រះអង្គ ។ ព្រះអង្គអាច បាញ់ព្រួញនឹងព្រះហស្តឆ្វេងក៏បាន ព្រះហស្តស្ដាំក៏បាន ហើយតែងតែត្រូវគោលដៅជានិច្ច ។ នៅទីបញ្ចប់ ព្រះ ដែលជាអ្នកបង្កើតលោកឆ្ងល់ហើយសួរខ្លួនឯងថា ចុះហេតុអ្វីក៏អាត្មាអញបង្កើតព្រះរាជានេះមកធ្វើជាគូប្រជែង នឹងខ្លួនឯងដូច្នេះ ព្រះរាជានេះដែលជាប្រជាបតិ (ព្រះបង្កើតលោក) និងជាបរមេស្វរៈ (ឧត្តមរាជា ឬព្រះសិវៈ) មួយទៀត ។

ព្រះបាទយសោវរ្ម័នប្រៀបបានទៅនឹងស្ដេចល្វីទី១៤របស់បារាំង ។ ទ្រង់មានស្ដេងអញវមសិវៈ ដែល ត្រូវជាចៅរបស់សិវកៃវល្យៈ ជាឧបជ្ឈា ជាអ្នករៀបចំពិធីទេវរាជាមុនគេ ។ ព្រះអង្គមានចំណង់ចំណូលចិត្តក្នុង ការសាងសង់ ហើយហាក់ដូចជាមានបំណងដូច្នេះតាមការណែនាំរបស់រាជគ្រូ និងក្រុមគ្រួសាររបស់រាជគ្រូ ។ ព្រះអង្គបានបញ្ជាឲ្យគេកេណ្ឌពួកភគ្គាស្សៈ មានន័យថា អ្នកស៊ីសាច់សត្វ គឺរាស្ត្រសាមញ្ញ (ពួកអ្នករដ្ឋវាសី) សាង សង់ប្រាសាទ, កំពែង, បដិមា, រូបទ្រង់ឲ្យគេចារុំព្រះរាជបញ្ជាដាក់នៅពាសពេញព្រះនគរ ប្រៀបបានទៅនឹងព្រះ អសោកៈមួយអង្គទៀតដូច្នោះដែរ ។ ព្រះអង្គប្រគល់ខ្ញុំជាច្រើនឲ្យវត្តនីមួយៗ ដែលព្រះអង្គបានបង្កើតដីចំនួន មួយរយវ្រះ[៦] ព្រមទាំងទ្រព្យធន និងឧបភោគភណ្ឌធ្វើអំពីមាស សម្រាប់ការរៀបចំពិធីគោរពបូជាផ្សេងៗ ។ ទ្រង់បានចាត់ឲ្យស្ដេងអញសិខៈ ជាសិស្សរបស់ កម្រតេង ចាស់នៃសិវៈស្រមៈ ដែលទ្រង់ឲ្យទទួលបន្ទុកខាងកេណ្ឌ កម្លាំងថ្វាយព្រះរាជា ដើរកសាងសិវលិង្គ និងព្រះបដិមា ដាក់ពាសពេញព្រះនគរ ។ ចំណែកខ្លួនព្រះអង្គ បានកសាង

[៦] គេមិនដឹងថាពាក្យវ្រះនេះមានន័យពិតប្រាកដថាដូចម្ដេចទេ ។ តាមខ្ញុំយល់ នេះគឺជាបរិមាណគ្រាប់ស្រូវមួយបង្ហេច ដែលគេស្ពាយ ពាក់ឆៀងលើស្មា ដើរសាប ឬព្រួស ។ ដី១០០វ្រះ គឺដីដែលត្រូវនឹងគ្រាប់ស្រូវពូជ ១០០បង្ហេចនោះ ។

ផ្ទាល់ព្រះហស្តនូវ «ព្រះបដិមាព្រះសិវៈ និងព្រះជាយាប្អូនអង្គ ជាតំណាងគម្ពីរវេទទាំងបួន ដើម្បីរំលឹកដល់វិញ្ញាណក្ខន្ធព្រះមាតាបិតា ដាក់នៅលើមាត់បឹងឥន្ទ្រទទកៈ» ។ ដោយហេតុនេះ «ភពទាំងពីរ គឺស្ថានក្រោម និងស្ថានលើមានអ្នកការពារប្រកបទៅដោយវីរភាពឥតនរណាប្រៀបផ្ទឹមបាន ៖ នៅលើផែនដី មានព្រះរាជាអបរាជ័យមួយអង្គ គឺព្រះបាទយសោវរ្ម័ននេះ ចំណែកនៅស្ថានសួគ៌ទាំងបីជាន់មានព្រះមហេន្ទ្រ» ។ «នៅក្នុងការប្រយុទ្ធ ពេលក្រឡេកឃើញព្រះរាជានេះ ដែលទ្រង់ប្រកបទៅដោយពន្លឺភ្លឺត្រចះពិបាកនឹងទ្រាំទ្រ បណ្តាសត្រូវកោងកាចទាំងឡាយឱនក្បាលចុះ ប្រៀបបាននឹងផ្កាឈូកបាក់ក ហើយនិយាយថា នេះហើយគឺជាព្រះអាទិត្យ»[៧] ។

រជ្ជកាលរបស់ព្រះអង្គចាប់ផ្តើមឡើងដោយមានការបះបោរប្រឆាំងមួយ ដែលប្រហែលជារៀបចំឡើងដោយសមាជិករាជវង្សានុវង្សរបស់ព្រះបាទជ័យវរ្ម័នទី៤ ដែលត្រូវបានបំបែកចេញពីរាជសម្បត្តិដោយព្រះបាទឥន្ទ្រវរ្ម័នទី១ នៅឆ្នាំ៨៨៩ ក៏ប៉ុន្តែចំណុចត្រង់នេះ គេមិនមានមូលហេតុគ្រប់គ្រាន់នឹងអះអាងទេ ។ ព្រះបាទយសោវរ្ម័ន បានធ្វើការវាយបង្ក្រាបការបះបោរនោះ ហើយបានប្រយុទ្ធដោយលំបាកព្រោះទ័ពព្រះអង្គទន់ដៃ ព្រះអង្គត្រូវសត្រូវព័ទ្ធជុំជិត តែបានសេនាពីរនាក់ការពារជាប់ ប្តូរស្លាប់ជំនួសព្រះអង្គ ។ ក្រោយពីមានជ័យជម្នះលើខ្មាំងសត្រូវរួចហើយ «ដើម្បីជៀសវាងកុំឲ្យមានការបះបោរបែបនេះទៀត ដែលរង់ចាំមើលតែចំណុចខ្សោយរបស់ព្រះរាជាណាចក្រ ហើយប៉ុនប៉ងធ្វើឃាតព្រះរាជា» ព្រះបាទយសោវរ្ម័ន បានបង្កើតកងស៊ើបការណ៍មួយក្រុមរួចហើយបានសម្រេចសាងសង់ «ព្រះរាជធានីរឹងមាំមួយ គ្មានសត្រូវណាដណ្តើមយកបាន» ។

រាជធានីនេះមានឈ្មោះមុនដំបូងដូចជាព្រះនាមរបស់ព្រះអង្គ គឺយសោធបុរៈ, គឺអង្គរធំ ដែលឈ្មោះពិតប្រាកដថា ឥន្ទ្រប្រាស្ថៈ តែសៀវភៅខ្មែរសម័យថ្មីហៅថា ឥន្ទ្របាទ ឬក៏ភាសាសាមញ្ញថា មហានគរ រាជធានីនេះតាមមើលទៅ គឺសាងសង់នៅពីលើ ឬក៏ជិតទីតាំងរបស់រាជធានី ដែលសាងឡើងដោយព្រះបាទត្បិសានវរ្ម័ន នៅដើមសតវត្សរ៍ទី៧នៃគ្រិស្តសករាជ ។ អ្នកខ្លះនិយាយថា ព្រះបាទយសោវរ្ម័ន ហៅរាជធានីនេះថា កម្ពុបុរី តាមឈ្មោះទេវបុព្វបុរសខ្មែរ កម្ពុស្វ័យម្ភុ ដែលព្រះសិវៈ បានប្រគល់ព្រះមហេសី គឺព្រះនាងមេរៈឲ្យ ។

នៅក្នុងរាជធានីនេះ ទ្រង់បានចាត់ឲ្យពូនភ្នំយសោធគិរី គឺប្រាសាទបាពួន ឬ«ភ្នំដែលរលំបាក់បែក» និងឲ្យសង់ប្រាសាទភិមានអាកាស, «ព្រះរាជវាំងសម្បូរទៅដោយខ្យល់» ប្រាសាទនេះសង់រួចនៅក្រោមរជ្ជកាលព្រះរាជាដែលសោយរាជ្យបន្តពីព្រះអង្គ ។ នៅខាងក្រៅរាជធានី ពីខាងកើត ទ្រង់បានចាត់ឲ្យកសាងយសោធរាស្រ្តម «អាវាសរបស់យសោ» ។

ព្រះបាទយសោវរ្ម័ន បានកសាងប្រាសាទលលៃផងដែរ នៅជិតប្រាសាទបាគោ និងបាគង ដើម្បីថ្វាយដល់

---

[៧] សិលាចារឹកព្រះបាទ ក្បាលទី២ ទំព័រ៣៧២-៣៧៦ និងអែម៉ូនីញេ, ប្រទេសកម្ពុជា ក្បាលទី២ ទំព័រ២៦៥-២៦៧ ។

ព្រះវិញ្ញាណក្ខ័ន្ធព្រះបាទឥន្ទ្រវរ្ម័ន ជាព្រះបិតា, ព្រះនាងស្រីឥន្ទ្រទេវី ជាព្រះមាតា, និងព្រះវិញ្ញាណក្ខន្ធរបស់ព្រះបាទមហិបតិវរ្ម័ន និងព្រះនាងរាជេន្ទ្រទេវី ជាព្រះអយ្យកោអយ្យកា ព្រោះថា ព្រះអង្គមានព្រះកិត្តិយសជាពិសេស គឺដោយសារខ្សែព្រះលោហិតខាងព្រះមាតា ។

ព្រះបាទយសោវរ្ម័ន ពេញចិត្តនឹងការធ្វើសង្គ្រាមណាស់ ។ ក្រោយពីមានជ័យជម្នះលើសត្រូវផ្ទៃក្នុង ហើយរៀបចំឲ្យមានក្រុមចារកម្មគ្រប់គ្រងលើពួកនេះរួចមក ព្រះអង្គបានធ្វើការប្រយុទ្ធរុញច្រានទៅលើសត្រូវខាងក្រៅ ធ្វើឲ្យពួកនេះចុះចាញ់ ហើយទ្រង់បានដាក់ស្ដេចបរាជ័យជាច្រើនជាទាសករ ។ ព្រះអង្គក៏មានជ័យជម្នះផងដែរ ក្នុងសង្គ្រាមតាមសមុទ្រ "ទៅលើកងនាវាចររបស់សត្រូវដែលមានសំពៅថ្មីៗពណ៌ស រាប់ពាន់" ដែលព្រះអង្គវាយបាក់បែកអស់ ។

ព្រះបាទយសោវរ្ម័នប្រហែលជាបានធ្វើសង្គ្រាម ហើយមានជ័យជម្នះលើពួកចាមផងដែរ ដែលទ្រង់តាមវាយប្រហាររហូតរាជធានីស្ថិតនៅលើភ្នំវែក ព្រមទាំងបានចាប់ស្ដេចចាមព្រះនាមស្រីជយិន្ទ្រវរ្ម័នជាឈ្លើយរួចលើកឧត្ដមសេនីយ៍ចាមមួយរូបឲ្យឡើងសោយរាជ្យជំនួស ។ ពួកចាមបានប្រមូលគ្នាត្រៀមចាំនៅចន្លោះពីរាជធានីមកព្រំប្រទល់ ដែលមានចំនួនទាំងអស់១២សង្កាត់ ហើយបានធ្វើការវាយមកលើទ័ពព្រះអង្គយ៉ាងខ្លាំង ពេលទ្រង់យាងត្រលប់មកព្រះនគរវិញ ធ្វើឲ្យព្រះអង្គថយដៃ វាយដកថយរហូតទៅដល់ភ្នំត្រៃយការ ។ នៅលើភ្នំនោះ ទ្រង់បានជ្រកនៅក្នុងបន្ទាយមួយដែលមានកំផែងការពាររឹងមាំ រួចទើបចាប់វាយបកទៅលើទ័ពសត្រូវបំផ្លាញសង្កាត់ទាំង១២ មួយម្ដងៗ ។ ព្រះអង្គស្ទើរតែក្ស័យព្រះជន្មម្ដងទៀត នៅក្នុងការប្រយុទ្ធមួយ បើកុំតែបានសេនាការពារបូជាជីវិតការពារព្រះអង្គ ។

ក្រៅពីសង្គ្រាម ព្រះបាទយសោវរ្ម័នជាព្រះរាជាមួយអង្គពូកែខាងការងាររដ្ឋបាលទៀតផង ។ សោយរាជ្យលើនគរមួយដែលមានប្រជាជនរំពើតរំពើង ទ្រង់បានរៀបចំប្រជារាស្ត្រជា៨វណ្ណៈ ដែលក្នុងនោះពួកបច្ចាញាតិរបស់ពួកព្រាហ្មណ៍អន្តោប្រវេសន៍ បានត្រូវបានចែកតាមវណ្ណៈនីមួយៗ ហើយទ្រង់ក៏បានរៀបចំឋានៈរបស់សេនាមន្ត្រីផងដែរ ។ ដោយមានសត្រូវច្រើន ព្រះអង្គបានចងសម្ព័ន្ធមេត្រីជាមួយស្ដេចនគរជិតខាង ហើយបានផ្ដល់ឯកសិទ្ធិដល់ជនបរទេសដែលចូលមកក្នុងព្រះរាជាណាចក្រថែមទៀត ។

ព្រះអង្គគោរពបូជាព្រះសិវៈ ក៏ប៉ុន្តែ មិនប្រកាន់និកាយណាមួយទេ ហើយចេះសន្ដោសប្រណី ពីព្រោះថាទ្រង់មានមន្ត្រីមួយរូប ជាប់ខ្សែព្រះរាជវង្សដែរ ដែលគោរពបូជាព្រះពុទ្ធសាសនា ។ ទ្រង់ចូលចិត្តសិល្បៈ ហើយមានអ្នកប្រាជ្ញបណ្ឌិត នៅជុំវិញព្រះអង្គ ។ ពេលណាព្រះអង្គចេញធ្វើសង្គ្រាម ទ្រង់អនុវត្តតាមទស្សនៈរបស់អ្នកប្រាជ្ញបណ្ឌិតទាំងអស់នោះ ។

ព្រះបាទយសោវរ្ម័ន បានសុគតនៅឆ្នាំ៩០៨នៃគ្រិស្តសករាជ ត្រូវនឹងមហាសករាជ៨៣០ ដោយបានបន្សល់ទុកនូវព្រះកិត្តិនាមថា ជាព្រះចៅអធិរាជលើអស់ព្រះរាជាទាំងឡាយ ជាព្រះរាជាល្អឥតខ្ចោះ ជាព្រះ

អាទិត្យ ។ ព្រះអង្គមានព្រះមរណនាមថា បរមសិវលោក ។

**កំណត់ចំណាំ :** រឿងនិទានខ្មែរមួយដែលខ្ញុំបានរៀបរាប់ពីខាងលើរួចមកហើយ និយាយថា ពួកកម្ពុជាមានកំណើតដើមចេញមកពីរដ្ឋមួយនៅឥណ្ឌា ស្ថិតនៅជិតទីក្រុងដែលី ។ ម្យ៉ាងទៀត គម្ពីរមនវៈធម្មសាស្ត្រៈ បានប្រដៅថា ពួកកម្ពុជៈ ជាប្រជារាស្ត្រមួយក្នុងបណ្តាចំណោមប្រជារាស្ត្របួន ដែលត្រូវគេបណ្តេញចេញពីឥណ្ឌា ព្រោះបានប្រព្រឹត្តបំពានលើច្បាប់ប្រទេស ។ នគរពួកកម្ពុជៈ នេះស្ថិតនៅខាងពាយ័ព្យទីក្រុងដែលី ហើយអាចនឹងលាតសន្ធឹងមកកើតឆ្ងាយពីទីក្រុងដែលី ។ ហេតុការណ៍ដ៏គួរឲ្យចង់ដឹងនេះនឹងគ្មានអ្វីសំខាន់ទេ បើគ្មានហេតុការណ៍មួយទៀត នោះគឺរាជធានីប្រកបទៅដោយកំផែងការពាររឹងមាំដែលកសាងឡើងដោយព្រះបាទយសោវរ្ម័ន មានឈ្មោះថា ឥន្ទ្រប្រាស្ថៈ ដែលគម្ពីរសាស្ត្រាខ្មែរហៅក្លាយថា ជាឥន្ទបត្ថ ។ តែវាមានទីក្រុងមួយមុននឹងទៅដល់ទីក្រុងដែលី ដែលត្រូវគេដុតបំផ្លាញខ្ទេចខ្ទីអស់កាលពី២០០០ឆ្នាំមុន តែមាននៅសេសសល់កម្ទេចកម្ទីនៅឡើយ នៅប្រហែល៥គីឡូម៉ែត្រពីដែលី ដែលមានឈ្មោះថា ឥន្ទ្រប្រាស្ថៈដែរ សព្វថ្ងៃអ្នកស្រុកហៅថា ឥន្ទបត្ត ឬអន្ទបត្ត ។

ហេតុដែលប្រជាជនកម្ពុជាមួយនៅឥណ្ឌូចិន មានឈ្មោះដូចឈ្មោះប្រជាជនកម្ពុជៈ ដែលគេបណ្តេញចេញពីឥណ្ឌា ហើយពួកកម្ពុជាមានរាជធានីមួយឈ្មោះដូចរាជធានីរបស់ពួកកម្ពុជៈ ដែលរៀបរាប់ថា ពួកកម្ពុជាមានកំណើតដើមមកពីឥណ្ឌា គឺជាបញ្ហាមួយដែលគួរឲ្យចាប់អារម្មណ៍ដែរ ។

# ជំពូកទី៧
# កំណត់សម្គាល់អំពីប្រជាជនដែលមានទំនាក់ទំនងជាមួយកម្ពុជា ពីសតវត្សរ៍ទី៨ដល់សតវត្សរ៍ទី១០ : ចាម៉្ប៉ា, អាណ្ណាម-តុងកឹង, ចិន និងឥណ្ឌា

ឥឡូវនេះ អាណាចក្រកម្ពុជាបានត្រូវកសាងឡើងវិញហើយ ដោយមានរាជធានីដ៏ធំមួយ ដែលជា"បន្ទាយប្រកបដោយកំផែងការពាររឹងមាំ គ្មានសត្រូវណាវាយដណ្តើមយកបាន", មានព្រះរាជាជាព្រះចៅអធិរាជត្រួតត្រាលើបណ្តាប្រទេសជិតខាង ហើយវាតទឹកដីហួសពីវៀងច័ន្ទទៅទៀតនៅប្រទេសលាវ, និងមានកិត្តិនាមល្បីរន្ទឺ "ទៅសព្វទិសទីនៃពិភពលោក", នេះបើតាមការរ៉ាយរ៉ាប់របស់សិលាចារឹក ។

តើក្នុងអំឡុងពេលនេះ បណ្តារាជាណាចក្រជិតខាងរបស់កម្ពុជា ដែលយើងបានស្គាល់រួចមកហើយ អាចនឹងមានឥទ្ធិពលតិច ឬច្រើន មកលើកម្ពុជា តាមរបៀបបែបយ៉ាងដូចម្តេចខ្លះ?

## ១- នគរចាម៉្ប៉ា

នៅដើមសតវត្សរ៍ទី៧ ពួកចាមបានគ្រប់គ្រងលើទឹកដីមួយដែលប្រហាក់ប្រហែលត្រូវនឹងអាណ្ណាមសព្វថ្ងៃនេះ ។ ពួកចាមនេះ បានវាយកម្ទេចបណ្តាខេត្រខាងត្បូងរបស់តុងកឹង ដែលនៅជាប់នឹងព្រំដែន, ដណ្តើមបានខេត្រឃីណាន ជាខេត្រចិន-អាណ្ណាម យកមកកាន់កាប់មួយរយៈ តែបានត្រូវទ័ពអាណ្ណាម ដែលដឹកនាំដោយមេបញ្ជាការចិន វាយដេញកម្ចាត់រហូតចូលមកដល់ផ្ទៃក្នុងនគរចាម៉្ប៉ា ហើយបង្ខំឲ្យសងការខូចខាត រួចឲ្យលើកសួយសារអាករទៅថ្វាយទៀត ។ រាជធានីនគរចាម៉្ប៉ា រងការវាយកម្ទេចពីរលើក ក៏ប៉ុន្តែពួកចាមនៅអាចរក្សាទឹកដីបានលើកលែងតែខេត្រឃីណានមួយដែលត្រូវប្រគល់ទៅឲ្យអាណ្ណាមវិញ ។

កាលពីសតវត្សរ៍ទី៥ រាជសម្បត្តិនគរចាម៉្ប៉ាមានព្រះរាជាខ្មែរមួយអង្គសោយរាជ្យ ។ នៅសតវត្សរ៍ទី៧ រាជសម្បត្តិនេះ បានធ្លាក់ទៅក្នុងកណ្តាប់ដៃព្រាហ្មណ៍ម្នាក់ ដែលធ្វើគុតព្រះមហាក្សត្រ បន្ទាប់មកធ្លាក់ទៅក្នុងដៃមហេសីព្រាហ្មណ៍ រួចទៅក្នុងដៃព្រះអង្គម្ចាស់បះបោរមួយអង្គ ដែលក្លាយជាព្រះស្វាមី មហេសីរបស់ព្រាហ្មណ៍ក្បត់នោះ ។ នគរចាម៉្ប៉ាធ្លាប់ជួបប្រទះនឹងបដិវត្តន៍ផ្ទៃក្នុងជាច្រើន ដែលជាហេតុនាំនគរនេះឈានទៅរកការរលត់រលាយ ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក្តី នាសម័យនោះ នគរនេះមិនទាន់បាត់ទឹកដី សូម្បីមួយចំអាមនៅឡើយទេ ។

នៅពាក់កណ្តាលសតវត្សរ៍ទី៨ នគរចាម៉្ប៉ាបានទទួលរងគ្រោះដូចជាតុងកឹង និងកម្ពុជាដែរ ពីការឈ្លានពានរបស់ពួកជន"ស្គមកំព្រឹង ហើយខ្មៅព្រឹក" ដែលធ្វើដំណើរមកពីកោះសូម៉ាត្រា និងកោះពូឡូកុងឌ័រ តាម"នាវាបរទេស" (ឆ្នាំ៧៦៥-៧៧៤ និង៧៨៧ នៃគ្រិស្តសករាជ) ។

អំពើចោរកម្មនេះប្រហែលជាកើតមាននៅក្នុងរជ្ជកាលរបស់ស្តេចចាម ព្រះបាទព្រឹទ្ធិវិន្ទ្រវរ្ម័ន ដែលជា

ព្រះរាជាទី៣ ឬទី៤ សោយរាជ្យបន្តពីព្រះបាទវិក្រន្តវរ្ម័ន នៅពាក់កណ្ដាលទី២នៃសតវត្សរ៍ទី៨ និងនៅក្នុងរជ្ជកាលក្នួយរបស់ព្រះអង្គព្រះនាម ព្រះបាទសត្យវរ្ម័ន ដែលសោយរាជ្យពីឆ្នាំ៧៧៤ ដល់៧៩៤ ។ ពួកចាមបានរុញច្រានពួកឈ្វានពានឲ្យដកថយចេញទៅវិញ ក៏ប៉ុន្តែប្រទេសកម្ពុជាទប់ទល់មិនឈ្នះ ក៏ត្រូវបែកនគរជាពីរដោយសារបរាជ័យនេះ គឺកម្ពុជាទឹក និងកម្ពុជាគោក តាមសម្ដីពួកចិន និងអាណ្ណាម ដូចដែលយើងបានឃើញពីខាងលើរួចមកហើយ ។

មិនយូរប៉ុន្មាន ក្រោយពីបានជៀសផុតពីគ្រោះថ្នាក់រួមរួចមក ពួកចាមបានធ្វើការឈ្លានពានទៅលើខែត្រហ៊ាន់ និងអាយ របស់អាណ្ណាម នៅឆ្នាំ៨០៨ ក្រោមរជ្ជកាលរបស់ព្រះបាទឥន្ទ្រវរ្ម័ន ជាព្រះអនុជរបស់ព្រះបាទសត្យវរ្ម័ន ។ ពួកអាណ្ណាមបានវាយតបតវិញដោយប្រើកម្លាំងទ័ពដ៏ធំ ធ្វើឲ្យពួកចាមបរាជ័យ ហើយយល់ព្រមសងការខូចខាត និងលើកសួយសារអាករថ្វាយស្ដេចអាណ្ណាម ។

ចាប់ពីពេលនោះមក រាជធានីចាស់ គឺលីនយី បានត្រូវបោះបង់ចោល ព្រះរាជាបានយាងមកតាំងព្រះរាជវាំងនៅឯ ឈេន ដែលជាកំពង់ផែសមុទ្រមួយស្ថិតនៅខាងកើតលីនយី វិញ ។ បើតាមពង្សាវតារនិយាយថា នៅក្បែរកំពង់ផែនោះ មានទីក្រុងមួយឈ្មោះហៅថា ឈេនឈីន ទើបបានជាគេហៅនគរចាម្ប៉ាថាជា រាជាណាចក្រឈេនឈីន វិញ ។ គឺពាក្យនេះហើយ ដែលពួកអឺរ៉ុបហៅក្លាយមកជាកូសាំងស៊ីន[១] ។

ព្រះបាទហរិវរ្ម័នដែលសោយរាជ្យបន្តពីព្រះបាទឥន្ទ្រវរ្ម័ននៅឆ្នាំ៨១៣ ហើយដែលនៅគង់លើរាជសម្បត្តិនៅឡើយនៅឆ្នាំ៨១៧ ឬក្រោយនោះ មិនបានបន្តធ្វើសង្គ្រាមទេ ក៏ប៉ុន្តែ ព្រះបាទវិក្រន្តវរ្ម័ន ដែលស្នងរាជ្យបន្តពីព្រះអង្គ បានដឹកនាំទ័ពរាតត្បាតបណ្ដាខែត្ររបស់កម្ពុជា ហើយបានវាយចូលរហូតមកដល់កណ្ដាលផ្ទៃប្រទេស ដែលអាចជាហេតុធ្វើឲ្យព្រះបាទឥន្ទ្រវរ្ម័នទី១ លើករាជធានីពីមហេន្ទ្របព៌ត ទៅតាំងនៅឯហរិហរល័យវិញ ដើម្បីជៀសពីចម្បាំង ។

ក្រោយពីត្រូវវាយបណ្ដេញចេញពីកម្ពុជាម្ដងរួចមក ពួកចាមបានត្រលប់មកវាយប្រហារម្ដងទៀត នៅឆ្នាំ៨៩៨ ក្នុងរាជ្យព្រះបាទយសោវរ្ម័នដែលជារាជបុត្ររបស់ព្រះបាទឥន្ទ្រវរ្ម័ន តែត្រូវបរាជ័យហើយកងទ័ពខ្មែរ

---

[១] សូមអានកំណត់សម្គាល់នៅទំព័រទី៨៥ ។ គេបានឲ្យនិរុត្តិសាស្ត្រមួយទៀតចំពោះឈ្មោះនេះ គឺគេអះអាងថា កូសាំងស៊ីន នេះ ជាការអានរបស់ពួកអឺរ៉ុបនូវពាក្យអាណ្ណាមថា កូជិមថាញ់ មានន័យថា ទឹកដីជិមថាញ់ គឺចាម្ប៉ានេះឯង ។ លោក ប៉េម៉ារីនី បានសរសេរនៅសតវត្សរ៍ទី១៧ថា កូសាំងស៊ីន ក្លាយមកពីពាក្យ ខ្វាវជី មានន័យថា មេជើងកែក ហើយមានអ្នកខ្លះទៀតនិយាយថា ពាក្យនេះជាការហៅមិនត្រូវនូវពាក្យ ឈេនឈីង ដែលចិនប្រើសម្រាប់ហៅផ្នែកខាងត្បូងនៃឧបទ្វីបឥណ្ឌូចិន ។ មានគេនិយាយទៀតថា ពួកព័រទុយហ្គេ ដែលសង្កេតឃើញថា ពួកចាមមានលក្ខណៈដូចពួកហិណ្ឌូនៅឯរដ្ឋកូជិន ហើយឃើញពួកអាណ្ណាមដូចពួកចិន ក៏ហៅអាណ្ណាមភាគខាងត្បូងថា កូសាំងស៊ីនទៅ ។ ក្នុងករណីនេះ កូសាំងស៊ីន គឺឥណ្ឌូចិន ។

បានដេញតាមរហូតដល់រាជធានី រួចដាក់នគរចាម្ប៉ានៅក្រោមការត្រួតត្រារបស់ស្តេចខ្មែរមួយអង្គ ដែលសោយរាជ្យនៅនគរវិជ័យ (គឺក្វាងប៊ិញសព្វថ្ងៃ) ។ ក៏ប៉ុន្តែ នៅពេលដែលព្រះបាទយសោវរ្ម័ន ត្រលប់មកព្រះនគរវិញប្រកបដោយជោគជ័យនោះ ព្រះអង្គ បានត្រូវទ័ពចាម១២សន្ធាត់ ស្កាត់វាយទាល់តែព្រះអង្គត្រូវវាយដកថយទៅវិញដូចដែលបានឃើញខាងលើរួចមកហើយ ។

## ២- អាណ្ណាម-តុងកឹង

នៅដើមសតវត្សរ៍ទី៩ តុងកឹងស្ថិតនៅក្រោមការត្រួតត្រារបស់ចិននៅឡើយ ហើយត្រូវនៅដូច្នេះយូរតទៅទៀត ថ្វីបើមានការបះបោរប្រឆាំងនឹងចិនជាញឹកញយក៏ដោយ ។ នៅដើមសតវត្សរ៍ទី៨ ពួកអាណ្ណាម បានបះបោរទូទាំងប្រទេសប្រឆាំងនឹងពួកចិន ហើយបានប្រកាសលើកស្តេចមួយអង្គដែលប្រហែលជាមានដើមកំណើតហិណ្ឌូ ព្រះនាមហាក់ខេ (ស្តេចខ្មៅ) ឲ្យសោយរាជ្យ ។ ស្តេចខ្មៅនេះ ដោយមានជំនួយពីទ័ពខ្មែរ និងចាម ៣០ម៉ឺននាក់ បានវាយកម្ទេចបន្ទាយចិនមួយ ។ ក៏ប៉ុន្តែក្រោយពីការខិតខំប្រឹងប្រែងប្រកបដោយជោគជ័យ និងសេចក្តីត្រេកអរនេះកន្លងផុតទៅ តុងកឹង ក៏ត្រូវធ្លាក់ចូលក្រោមនឹមត្រួតត្រារបស់ចិនឡើងវិញ នៅគ្រិស្តសករាជ ៧២២ ហើយស្ថិតនៅក្រោមនឹមត្រួតត្រារបស់ពួកអ្នកឈ្នះយ៉ាងតឹងតែងតាំងពីពេលនោះមក ។

នៅដំណាច់សតវត្សរ៍ទី៨ គឺនៅឆ្នាំ៧៦៨ ពួកអាណ្ណាមបានងើបបះបោរម្តងទៀត ហើយបានលើកមេទ័ពឈ្មោះ ភុងហ៊ុង ឲ្យឡើងសោយរាជ្យដែលតែងតែដឹកនាំកម្លាំងវាយទ័ពចិន ដែលឆ្លងចូលមកក្នុងទឹកដី ឲ្យបរាជ័យរាល់លើក ។ ក៏ប៉ុន្តែអត់ពីស្តេចអង្គនេះទៅ បុត្រព្រះអង្គព្រះនាមភុងអាញ់ ដែលឡើងសោយរាជ្យបន្ត មិនមានសេចក្តីក្លាហាននឹងការពារប្រទេសទេ បែរជាប្រគល់ខ្លួនចុះចូលខុបរាជ ដែលចិនបញ្ជូនឲ្យមកសោយរាជ្យបន្តពីភុងហ៊ុង ទៅវិញ ។

រាជធានីរបស់តុងកឹងកាលពីពេលនោះគឺ ហាណូយ ដូចសព្វថ្ងៃដែរ ។ គឺជាបន្ទាយប្រដាប់ទៅដោយគ្រឿងការពារ ដែលមានអ្នកស្រុករស់នៅជុំវិញ មានផ្សារ និងជាពិសេសគឺមានបញ្ជាការកណ្តាលរបស់ចិនផង ។

នៅចុងសតវត្សរ៍ទី៩ ពួកថៃមកពី យុនណាន ដែលចិនហៅថា ណានឆាវ តែអាណ្ណាមហៅថា ណាមឈាវ មានន័យថា "ស្តេចកណ្តាល" បានចូលលុកលុយតុងកឹង ។ នៅក្នុងសង្គ្រាមមួយជាមួយចិន ដែលតែងតែប៉ុនប៉ងបំផ្លិចបំផ្លាញរាជាណាចក្ររបស់គេ ស្ថិតនៅចន្លោះ យុនណាន នឹង ទីបេ ត្រង់ម្តុំ តាលី ពួកណានឆាវនេះ បានវាយឈ្នះទ័ពចិន ដែលមានពលទាហានមួយភាគធំជាពួកអាណ្ណាមតុងកឹង ហើយដណ្តើមបាន យុនណាន ។ ក្រោយមកពួកនេះបានគាំទ្រពួកអ្នកស្រុកភ្នំនៅខាងលើតុងកឹង ដែលតែងតែរងការគាបសង្កត់ពីចៅហ្វាយក្រុងហាណូយ ហើយត្រូវចៅហ្វាយក្រុងនេះ ដេញវាយប្រហាររហូតជិតដល់យុនណាន ។ ពួកអ្នកស្រុកភ្នំនោះប្រហែលជាពួកមួង សព្វថ្ងៃ បាននាំផ្លូវទ័ពណានឆាវ ចុះតាមជ្រលងទន្លេក្រហមមកវាយកម្ទេចតុងកឹង រួចកាន់កាប់ហាណូយបាន ។

រាជធានីហាណូយបានត្រូវវាយកម្ទេច ដុតបំផ្លាញ រួចពួកណាន់ឆាវគ្រប់គ្រងអាណ្ណាមចំនួនដប់ឆ្នាំ ពីឆ្នាំ៨៦០ ដល់៨៧០ ទើបដកថយទៅស្រុកវិញ ហើយត្រូវទ័ពព្រៃដែលចុះចូលជាមួយចិន-អាណ្ណាមស្កាត់វាយប្រហារថែមទៀត ។

យើងនឹងជួបជាមួយពួកណាន់ឆាវ ឬថៃនេះទៀត នៅខាងក្រោយ នៅពេលដែលពួកនេះបង្ហាញខ្លួនមុនដំបូងនៅភូមា រួចនៅភាគខាងជើងទន្លេមេណាម ជាទីដែលពួកគេនឹងកសាងរាជាណាចក្រសៀម ។

តាមមើលទៅ តុងកឹងពេលនោះមិនមានទំនាក់ទំនងអ្វីជាមួយកម្ពុជាទេ ព្រោះស្ថិតនៅឆ្ងាយ ។ ឯកសារប្រវត្តិសាស្ត្រអាណ្ណាមមាននិយាយអំពីពួកខ្មែរជាលើកដំបូង នៅពេលដែល“អធិរាជខ្មៅ“មានដើមកំណើតហិណ្ឌូ ហើយដែលប្រហែលជាខ្មែរ បានដឹកនាំទ័ពខ្មែរ-ចាម ៣០ម៉ឺននាក់ ទៅវាយតុងកឹង ។ ចាប់ពីត្រឹមនោះមកប្រជារាស្ត្រទាំងពីរ ហាក់ដូចជាមិនបានស្គាល់គ្នាទេ [៧] ។

## ៣- ចិន

នៅសតវត្សរ៍ទី៧ ប្រទេសចិនចាប់រីកធំបន្តិចម្តងៗ លាតសន្ធឹងទៅខាងលិច ផ្សាយអារ្យធម៌ទៅជប៉ុន ហើយចាប់ផ្តើមវាយបង្ក្រាបពួកណាន់ឆាវ ឬថៃ ដែលទើបតែរួបរួមគ្នាជារដ្ឋតែមួយ ព្រោះវារំខានដល់ចិនក្នុងការយកទីបេជាចំណុះ ។ ចិនគ្រប់គ្រងលើតុងកឹង ហើយការពារអាណ្ណាមប្រឆាំងនឹងពួកចាម ដោយបែងចែកទឹកដីជាបញ្ញាការដ្ឋាន និងខែត្រខ័ណ្ឌ ដែលមាននៅសេសសល់រហូតដល់សព្វថ្ងៃ ។ ចិនបានធ្វើឲ្យតុងកឹងមានសណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិសុខ ហើយឲ្យប្រទេសនេះទទួលយកអារ្យធម៌ចិន ។ ចិនចង់ធ្វើឲ្យបណ្តាប្រជាជនដែលធ្លាប់បានទទួលការអប់រំផ្សេងៗ ហើយដែលធ្លាប់ទទួលយកអារ្យធម៌ហិណ្ឌូរួចទៅហើយ ដូចជា លាវ, ចាម្ប៉ា និងកម្ពុជា ជាដើម ឲ្យត្រលប់មកទទួលយកអារ្យធម៌ចិនវិញ ។

ឥទ្ធិពលរបស់ចិនមកលើប្រទេសជិតខាងធំធេងណាស់ ។ ក្រោយពេលចិនចាញ់ពួកម៉ុងហ្គោល ហើយមានរាជវង្សថ្មីមួយឡើងសោយរាជ្យ ជាមួយនឹងស្តេច គូប៊ីឡៃខាន់ ឥទ្ធិពលនេះ កាន់តែរីកធំណាស់ទៅទៀតនៅចុងបូព៌ាប្រទេស ។

---

[៧] គទៅនេះ ជាឈ្មោះដែលខ្មែរបានប្រើសម្រាប់ហៅអាណាចក្រអាណ្ណាម ហើយនៅតែបន្តហៅដល់សព្វថ្ងៃ ៖ តុងកឹង = តាំងគ្យៈ, យ៉ាវជី = យួនគាវ, អាណ្ណាម = យួន ។ ពាក្យយួននេះ ធ្វើឲ្យយើងនឹកដល់បញ្ញាការចិននៅខែត្រខាងត្បូងបង្អស់របស់តុងកឹង ឈ្មោះថា យឺណាន ដែលពួកចាមដណ្តើមយកបានហើយកាន់កាប់យ៉ាងយូរ និងឈ្មោះខែត្រយុនណាន របស់ចិនផងដែរ ។

## ៤- ឥណ្ឌា

នៅសតវត្សរ៍ទី៧ ប្រទេសឥណ្ឌា, ដែលពួកខ្មែរសម័យនោះស្គាល់ក្រោមឈ្មោះថា អារ្យទេសៈ ឬកលិង្គ និងជាប្រភពដើមរបស់ពួកជនដែលមកបង្កើតជាអាណានិគម បន្តបានជារាជាណាចក្រកម្ពុជា ហើយបញ្ជូនពួកព្រាហ្មណ៍ពាណិជ្ជករ និងសិប្បករមកផង, កំពុងតែបញ្ចប់បដិវត្តន៍សាសនាមួយ ដែលចាប់ផ្ដើមតាំងតែពីគ្រិស្ដសតវត្សរ៍ទី១មក ។ ដោយមានអារ្យធម៌ព្រហ្មញ្ញសាសនាតាំងតែពីយូរលង់មកម្ល៉េះ ឥណ្ឌាបានប្រែមកកាន់ពុទ្ធ-សាសនាវិញម្ដង នៅសតវត្សរ៍ទី៤មុនគ្រិស្ដសករាជ ក្រោមរជ្ជកាលរបស់ព្រះបាទធម្មសោក ជាស្ដេចសោយរាជ្យនៅបតលីបុត្រ ដែលជាទីក្រុងមួយ មានមុនបតនាសព្វថ្ងៃ ដែលនៅជិតគ្នានោះ ។ ពុទ្ធសាសនា មានការរីកចម្រើន រហូតមកដល់សតវត្សរ៍ទី២មុនគ្រិស្ដសករាជ ។ ស្ដេចអសោកៈ ដែលដើរតួជាស្ដេចកុងស្តង់តាំងផង ជាស្ដេចក្លូវីស ផង បន្ថែមលើនោះ គឺជាមេសាសនាថែមទៀត បានប្ដូរមកកាន់ពុទ្ធសាសនាវិញ ហើយការពារសាសនានេះ ព្រមទាំងបានចាត់តាំងបេសកជនចេញផ្សព្វផ្សាយគ្រប់ទិសទី ។ ព្រះអង្គបានធ្វើឲ្យឥណ្ឌាទាំងមូលប្ដូរមកកាន់ពុទ្ធសាសនាវិញ ក្នុងអំឡុងពេលមិនដល់៣សតវត្សរ៍ផង ក្រោយពីព្រះអង្គសុគតទៅ ។ អំណើះអស់ពីព្រះបាទអសោកៈទៅ ពុទ្ធសាសនានៅបន្តរីកចម្រើនមួយរយៈទៀត តែថមថយបន្តិចម្ដងៗ ។ ពេលនោះ ពួកព្រាហ្មណ៍ដែលនៅមានសេសសល់ កាលបើពិនិត្យឃើញថា ពុទ្ធសាសនិកជនលង់លក់នឹងជីវភាពធម្មតាហើយ ក៏ចាប់ផ្ដើមកៀងគរប្រជាជនឲ្យត្រលប់មកកាន់ជំនឿចាស់វិញ ។ ក្រោមឥទ្ធិពលពួកព្រាហ្មណ៍នេះ ពុទ្ធសាសនា បានប្រែក្លាយមកជាសាសនាមួយស្ងប់ស្ងប់ ហើយវត្តអារាមក៏មិនសូវមានមនុស្សចេញចូល ។ បូជនីយេសក៍ ចិនឈ្មោះ ហ្វាហ៊ាង ដែលបានធ្វើដំណើរមកដល់ឥណ្ឌា នៅសតវត្សរ៍ទី៤ ដើម្បីស្វះស្វែងរកទីកន្លែងដែលព្រះពុទ្ធគង់នៅ វត្តអារាមដែលធ្លាប់មានឈ្មោះល្បី និងរកគម្ពីរផ្សេងៗផង បានបញ្ជាក់ថា ទីកន្លែងដែលគេគោរពបូជាមានការបាក់បែកខ្លះៗហើយ ។ ក្រោយមកទៀត នៅពាក់កណ្ដាលទី១នៃសតវត្សរ៍ទី៧ បូជនីយេសក៍ ចិនម្នាក់ទៀត ឈ្មោះ ហ៊ានសាង ដែលមានជំនឿជឿស៊ប់ក្នុងពុទ្ធសាសនា និងមានចម្ងល់ច្រើនតែឆាប់ជឿ បានមកដល់ឥណ្ឌាដែរ ហើយបានរៀបរាប់ថា មិនគ្រាន់តែប្រទះឃើញកន្លែងសក្ការបូជាជាច្រើន ដែលត្រូវគេបោះបង់ប៉ុណ្ណោះទេ គឺវត្តទាំងឡាយ ដែល ហ្វាហ៊ាង រៀបរាប់ពីមុន ឥឡូវមានវិហារបាក់បែក ហើយត្រូវគេបោះបង់ចោល មានពុទ្ធ-សាសនិកជនតិចតួច មិនដល់ទាំង ១០០ នាក់ផង ដែលកាលពីមុនមានដល់ទៅរាប់ពាន់ឯណោះ ។ នេះហើយជាការអាប់ឱន ចុះនៃពុទ្ធសាសនា ដែលចាប់ផ្ដើមតាំងពីគ្រឹស្ដសករាជទី១មក បានធ្លាក់អាប់ឱនខ្លាំងនៅសតវត្សរ៍ទី៣ ហើយបន្តមកសតវត្សរ៍ក្រោយៗទៀត រួចហើយរឹតតែយ៉ាប់យ៉ឺនស្ដារលែងរួចតែម្ដងនៅសតវត្សរ៍ទី៧ ។ គេចាប់ផ្ដើមភ្លេចទីកន្លែងពិសិដ្ឋ ដែលធ្លាប់គោរពបូជា ហើយដែលធ្លាប់មានមនុស្សច្រើនកុះករ កាលពីសតវត្សរ៍មុនៗ ហើយរឿងរ៉ាវទាក់ទិននឹងប្រទេសជាតិ ក៏បានប្រែក្លាយទៅជារឿងនិទានខ្លះៗទៅហើយដែរ ។ គេចាប់សាងសង់វិហារព្រហ្មញ្ញសាសនា នៅលើទីតាំងវត្តពុទ្ធសាសនា ហើយអ្នកស្រុកក៏ត្រលប់មកគោពបូជាព្រះព្រហ្ម ព្រះសិវៈ

ព្រះវិស្ណុ និងអាទិទេពផ្សេងៗទៀត ដែលបែងភាគចេញពីព្រះទាំងបី ។

នៅពេលដែលសាសនាមហាម៉ាត់មកដល់ ធ្វើឲ្យពុទ្ធសាសនាដែលកំពុងតែត្រដរខ្យល់រលត់រលាយបាត់ទៅ ហើយគំរាមកំហែងមកលើព្រហ្មញ្ញសាសនាដែលទើបតែរើបរស់រានឡើងវិញ នៅកម្ពុជាឯណោះ ក៏ទទួលបាននូវឥទ្ធិពលនៃការចុះឱនថយរបស់ពុទ្ធសាសនា និងការប្រែត្រលប់មកកាន់ទ្រឹស្ដីសាសនាចាស់ ដូចនៅឥណ្ឌាវិញដែរ ។ អាណានិគមហិណ្ឌូភាគច្រើនសុទ្ធជាពួកគោរពព្រាហ្មណ៍ ហើយព្រះរាជាក៏សុទ្ធជាអ្នកគោរពបូជា ថ្វាយស្ដុម្ភ ព្រះសិវៈ ឬព្រះវិស្ណុ ។ ទេវរាជរបស់ព្រះបាទឥន្ទ្រវរ្ម័នអាចជាព្រះព្រហ្មឬព្រះសិវៈ ហើយក៏អាចជាព្រះវិស្ណុ ផងដែរ ព្រោះអាទិទេពនីមួយៗក្នុងបណ្ដាអាទិទេពទាំងបីអាចត្រូវបានចាត់ទុកថាកើតមុន កើតមានដោយខ្លួនឯង ហើយអាទិទេពនីមួយៗក៏តំណាងឲ្យអ្នកទាំងពីរទៀតផងក៏មិនដឹង ។ ក៏ប៉ុន្តែក្នុងចំណោមពួកអ្នកគោរពព្រហ្មញ្ញសាសនា ក៏មានពុទ្ធសាសនិកជនផងដែរ តែមានចំនួនតិចជាង ។ គឺដោយហេតុនេះហើយបានជាការធ្វើអន្តោប្រវេសន៍មកកាន់កម្ពុជាភាគច្រើនជាអ្នកកាន់ព្រហ្មញ្ញសាសនា ឬមួយថាពេលមានដំណើរចាកស្រុកនោះ ពុទ្ធ-សាសនាឱនថយខ្លាំងណាស់ទៅហើយ ឬក៏ថា ពួកអ្នកចេញមកច្រើនមកពីឥណ្ឌាភាគខាងត្បូង ដែលនៅរក្សាការគោរពព្រហ្មញ្ញសាសនា មិនទាន់បានប្រែទៅកាន់ពុទ្ធសាសនាដូចនៅភាគខាងជើងទេ ។ តែអ្វីដែលពិតប្រាកដ គឺថាពេលនោះ នៅឯឥណ្ឌាគេបានរាកចេញពីសាវករបស់ព្រះពុទ្ធហើយ ហើយនៅកម្ពុជាឯនេះវិញ ពុទ្ធសាសនាក៏បានឱនថយហើយដែរ ។

ព្រះបាទយសោវរ្ម័ន ដែលគោរពបូជាទេវរាជរបស់ព្រះអង្គដែលទ្រង់ផ្ទៀងនឹងព្រះសិវៈ និងដែលបានចាត់ឲ្យកសាងវត្ត អាស្រម និងបដិមាព្រះសិវៈ និងព្រះនាងរុទ្រជាព្រះជាយា ជាច្រើន មិនបានធ្វើទុក្ខបុកម្នេញពួកពុទ្ធសាសនិកជនទេ ។ ព្រះអង្គចាត់ទុកពួកនេះស្មើៗគ្នានឹងពួកព្រាហ្មណ៍ដែរ ហើយបានអនុញ្ញាតឲ្យពួកនេះមាន វត្តវិហារ និងបដិមាព្រះពុទ្ធ សម្រាប់គោរពបូជាដូចគ្នា ។

ក៏ប៉ុន្តែកម្ពុជាជាប្រទេសទទួលអារ្យធម៌ពីឥណ្ឌាមក ជាពិសេសគឺពីឥណ្ឌាភាគខាងត្បូង ។ ដោយហេតុនេះជំនឿសាសនា ដែលគេគោរពបូជាក៏ជាសាសនាដែលប្រជាជនកំពុងតែគោរពនៅឥណ្ឌានាសម័យនោះដែរ ពោលគឺ ព្រហ្មញ្ញសាសនា ការគោរពអាទិទេព ។ ដូច្នេះ កម្ពុជាត្រូវស្ថិតនៅជាប្រទេសកាន់ព្រហ្មញ្ញសាសនារហូតដល់អស់ស្ដេចវង្សវរ្ម័ន ។

សរុបសេចក្ដីមក ពុទ្ធសាសនាលែងមាននៅឥណ្ឌាទៀតហើយ គឺបែរជាទៅជ្រកកោននៅឯស្រុកចិន ដែលបានទទួលតាំងពីគ្រិស្តសតវត្សរ៍ទី១មក, នៅកោះសិរីលង្កាដែលបានទទួលតាំងពីសតវត្សរ៍ទី៣មក, នៅឯកោះជ្វា និងបាលីដែលបានទទួលតាំងពីសតវត្សរ៍ទី៥មក និងនៅនេប៉ាល់ ។ ព្រះពុទ្ធសាសនាក៏ទទួលបានជោគជ័យផងដែរនៅទីបេ និងនៅជប៉ុន ក៏ប៉ុន្តែព្រះពុទ្ធសាសនាត្រូវរលាយបាត់ទៅនៅនឹងប្រទេសកំណើត ជាទីកន្លែងដែលព្រះពុទ្ធត្រាស់ដឹងតែម្ដង ។

ការដែលព្រះពុទ្ធសាសនារលត់បាត់ពីប្រទេសឥណ្ឌាគឺជាព្រឹត្តិការណ៍ធំមួយ ប៉ុន្តែខ្ញុំគិតថាវាជារឿងល្អ ព្រោះថាការផ្លាស់ជំនួសសាសនាមួយដែលពោរពេញទៅដោយថាមពលចំពោះជាតិមួយ វាប្រសើរជាងសាសនាមួយដែលមានតែបរមត្ថវិទូ, ទស្សនវិទូដែលទំពែកជ្រុះសក់អស់ដោយសារតែសមាធិ និងមានតែធម៌ទ្រឹស្តីដែលធ្វើឲ្យងងុយងោកងក់ប៉ុណ្ណោះ ។

នៅពេលដែលបដិវត្តន៍សាសនានេះកំពុងតែឈានដល់ចុងបញ្ចប់ទៅហើយ មានបដិវត្តន៍មួយទៀត ដែលប្រកបទៅដោយផលវិបាកជាច្រើន បានកើតមានឡើងយ៉ាងសាហាវនៅឯចុងម្ខាងទៀតនៃពិភពលោក ហើយផ្តើមគំរាមមកលើឥណ្ឌាផងដែរ ។

នៅចុងសតវត្សរ៍ទី៦នៃគ្រិស្តសករាជ គឺ៦០០ឆ្នាំក្រោយព្រះយេស៊ូគ្រិស្ត និង១១០០ឆ្នាំក្រោយព្រះពុទ្ធ មានអ្នកទស្សន៍ទាយដោយផ្អែកលើអធិធម្មជាតិម្នាក់ទៀត បានប្រាកដខ្លួនឡើងនៅប្រទេសអារ៉ាប់ឈ្មោះ មហាម៉ាត់ បានចាប់ផ្តើមផ្សព្វផ្សាយលទ្ធិសាសនាមួយថ្មី ។ ប៉ុន្តែខុសពីព្រះពុទ្ធ និងព្រះយេស៊ូគ្រិស្តដែលស្លូតបូតហើយល្អត្រឹមត្រូវ មហាម៉ាត់ បានផ្សាយសាសនាដោយមានកាន់អាវុធនៅនឹងដៃគួរឲ្យខ្លាច ។ មហាម៉ាត់ ដើរផ្សព្វផ្សាយសាសនាផងធ្វើសង្គ្រាមផង ។ នៅពេលដែល មហាម៉ាត់ ស្លាប់ទៅ សាច់ញាតិ និងញាតិព័ន្ធរបស់គាត់ បានអនុវត្តនយោបាយគាត់បន្តទៀត គឺប្រកាសសង្គ្រាមជាមួយពិភពចាស់ និងជំនឿពីមុនៗ ហើយបន្តគំរាមកំហែងដល់គ្រប់សង្គម ។ ជាជាតិសាសន៍មួយគ្មានអារ្យធម៌ ពួកនេះបានទទួលភាពស៊ីវិល័យត្រឹមតែចេះដើរផ្សព្វផ្សាយបន្តដល់អ្នកដទៃណា ដែលគេបានអូសទាញឲ្យមានជំនឿ ដោយបង្ខំ និងកាប់សម្លាប់អ្នកណាដែលជម្ទះមិនព្រមជឿតាម ។ មានតែពួក អ្នកដែលមិនសប្បាយចិត្ត អ្នកដែលរងនូវការគាបសង្កត់នៃពិភពអេហ្សីប-ក្រិក-រ៉ូម៉ាំង (ពួកអ្នកដែលចេះតែមមៃគិត, ពួកគ្រិស្តសាសនិក, ពួកជ្វីវ, ទាំងអ្នកល្ងង់ខ្លៅទាំងអ្នកប្រាជ្ញ) ដែលប្តូរមកចុះចូលជាមួយជំនឿថ្មីនេះ ។ បណ្តាប្រទេសដែលច្បាំងចាញ់ ក៏ព្រមទទួលយកការត្រួតត្រារបស់អារ៉ាប់ ជាមួយនឹងអាចារ្យ និងអាទិទេពតែមួយរបស់គេ ។ បណ្តាកុលសម្ព័ន្ធដែលច្បាំងចាញ់ បានត្រូវប្រមូលផ្តុំមកក្នុងជំនឿស៊ីប់ប្តូរស្លាប់ប្តូររស់តែមួយ រួចរៀបចំជាកងទ័ពធំមួយ ត្រៀមចាំតែចេញធ្វើសង្គ្រាម ដុតបំផ្លាញ និងកាប់សម្លាប់ប៉ុណ្ណោះ ។ មេដឹកនាំធំៗនៃ ជំនឿនេះក៏ជាអ្នកចម្បាំង បានចេញដឹកនាំទ័ពខ្លះទៅវាយយកអាហ្វ្រិកខាងជើង ខ្លះទៀតមកឥណ្ឌា ធ្វើឲ្យប្រទេសនេះត្រូវរងនូវការដុតបំផ្លាញ និងកាប់សម្លាប់យ៉ាងខ្លាំង ។

ប្រទេសឥណ្ឌាត្រូវរងនូវការគំរាម និងទុក្ខលំបាកយ៉ាងដំណំ ហើយត្រូវបែកបាក់រវាងគ្នាឯងនឹងគ្នាឯងដោយការចុះខ្សោយ ។ ពួកស្តេចច្បាំងគ្នា មិនចេះសាមគ្គីគ្នាប្រឆាំងទប់ទល់នឹងគ្រោះថ្នាក់រួមទេ ហើយនៅបន្តបញ្ចេញកំហឹងដាក់គ្នានៅចំពោះមុខសត្រូវ ដែលអង្គុយមើលរង់ចាំតែអ្នកទាំងពីរអស់ដៃនឹងចាប់សង្គ្រុបបង្ខំឲ្យចុះចូលនឹងសាសនាគេតែម្តង ។

ការដែលពួកអារ៉ាប់កាន់សាសនាមហាម៉ាត់ ធ្វើការវាយដណ្តើមយកពិភពលោកមួយចំណែកធំដូច្នេះ ជា

មហាភ័យដ៏កាចសាហាវមួយចំពោះពិភពចាស់ ព្រោះវាបំបែកអឺរ៉ុបចេញពីអាស៊ី ហើយបង្កើតជាព្រៃមនុស្សមួយបែប ដែលមិនមាននរណាម្នាក់ងាយនឹងធ្វើដំណើរឆ្លងកាត់ដោយមិនមានគ្រោះថ្នាក់ដល់ជីវិតណាស់ ។ ពួកអារ៉ាប់កាត់ផ្ដាច់ផ្លូវដែលតភ្ជាប់ពីអឺរ៉ុបមកកាន់ឥណ្ឌា ពីឥណ្ឌាទៅអឺរ៉ុប ធ្វើឲ្យពួកអឺរ៉ុបលែងស្គាល់ស្រុកចិន ជប៉ុន ឥណ្ឌូចិន និងកោះម៉ាឡេ រហូតដល់សតវត្សរ៍ទី១៤ ឬ១៥ ។ នៅឥណ្ឌា ពួកនេះផ្ដួលរំលំវិហារព្រហ្មញ្ញសាសនា យកសម្ភារមកកសាងវិហារមូស្លីមវិញ ហើយបានបង្កើតអាណាចក្រខ្លាំងក្លាមួយត្រួតត្រាលើឧបទ្វីបទាំងមូល ទាំងមិនអាចបំបាត់អនាធិបតេយ្យ និងផ្ដល់នូវសន្តិភាពឲ្យឧបទ្វីបនេះផងទេ ។

# ជំពូកទី៨
# ប្រទេសកម្ពុជា ពីសតវត្សរ៍ទី១០ ដល់ សតវត្សរ៍ទី១៤

## ១- ព្រះបាទហស៌វរ្ម័នទី១ (៩០៨- ?)

នៅពេលដែលព្រះបាទយសោវរ្ម័ន សុគតទៅនៅឆ្នាំ៩០៨ រាជបុត្ររបស់ព្រះអង្គបានឡើងសោយរាជ្យបន្តក្រោមព្រះអភិសេកនាមថាស្រីហស៌វរ្ម័ន ។ ព្រះស្រីហស៌វរ្ម័នទ្រង់គង់នៅយសោធបុរៈដដែល ក៏ប៉ុន្តែ ប្រហែលជាបានប្តូរឈ្មោះរាជធានីទៅជា ហស៌ធបុរៈ តាមទម្លាប់ ។ ព្រះអង្គបានសម្ពោធប្រាសាទភិមានអាកាស ប្រកបដោយរានហាលខ្ពស់ ដែលចាប់ផ្តើមសាងសង់នៅក្នុងរជ្ជកាលព្រះបិតាព្រះអង្គ ។

គេមិនបានដឹងទេថា ក្សត្រអង្គនេះ សុគតនៅឆ្នាំណាទេ គ្រាន់តែដឹងថា ទ្រង់មានព្រះមរណនាមថា រុទ្រលោក មានន័យថា ទ្រង់ជាភ្ញៀវរបស់ព្រះរុទ្រៈ ។

## ២- ព្រះបាទឦសានវរ្ម័នទី២ (? -៩២៨)

ព្រះរាជាដែលសោយរាជ្យបន្តពីព្រះបាទហស៌វរ្ម័ន គឺព្រះអនុជរបស់ព្រះអង្គ ដែលជាព្រះរាជបុត្ររបស់ព្រះបាទយសោវរ្ម័នដែរ ហើយមានព្រះអភិសេកនាមថា ស្រីឦសានវរ្ម័ន ។ ព្រះអង្គមានព្រាហ្មណ៍បុរោហិតមានឈ្មោះថា ស្តែងអញកុមារៈស្វាមី ដែលអត្ថបទមួយបានលើកសរសើរថា ជា“អ្នកពូកែខាងពិធីបូជា និងធ្លាប់ធ្វើជាបុរោហិតរបស់ព្រះបាទឥន្ទ្រវរ្ម័នទី១ ។

ព្រះបាទឦសានវរ្ម័ន សុគតទៅនៅគ្រិស្តសករាជ៩២៨ ត្រូវនឹងមហាសករាជ៨៥០ ហើយទ្រង់មានព្រះមរណនាមថា ព្រះបរមរុទ្រលោក មានន័យថា ជាភ្ញៀវរបស់ព្រះបរមរុទ្រៈ ។

## ៣- ព្រះបាទជ័យវរ្ម័នទី៤ (៩២៨-៩៤២)

ព្រះរាជាដែលឡើងសោយរាជ្យបន្តពីព្រះបាទឦសានវរ្ម័ននៅឆ្នាំ៩២៨ ប្រហែលដោយដណ្តើមរាជ្យ គឺព្រះបិតុលារបស់ព្រះអង្គ ព្រះនាម ព្រះបាទស្រីជ័យវរ្ម័ន ដែលជាព្រះអនុជរបស់ព្រះបាទយសោវរ្ម័ន ។

មិនដឹងថាដោយមានការបះបោរប្រឆាំងនឹងការឡើងសោយរាជ្យរបស់ព្រះអង្គពីរាជធានីចាស់ ឬក៏ថា ព្រះអង្គ មានមហិច្ឆតាចង់សង់រាជធានីមួយ ដែលល្អជាងរាជធានីដែលព្រះរៀមបានសង់ ព្រះបាទស្រីជ័យវរ្ម័ន បានបោះបង់អង្គរធំ ហើយនាំយកទេវរាជទៅតាំងរាជធានីនៅឯ ដោកគក្សារ[១] ដែលប្រហែលជា អនិន្ទិតបុរៈ (មានន័យ

[១] តាមលោក អែម៉ូនីញេ, គក្សារ ជាឈ្មោះដើមគគីរ ដែលក្លាយមកជាកោះកេរ្តិ៍ ។

ថា រាជធានីនៃពួកព្រានប្រមាញ់) គឺកោះកេរ្តិ៍សព្វថ្ងៃ ស្ថិតនៅក្នុងខេត្តព្រះវិហារ នៅពីខាងជើងខេត្តកំពង់ធំ[២] ។

ហោរារបស់ព្រះអង្គគឺ ស្តេងអញ្ញឦសានមុរទិ ត្រូវជាចៅរបស់វាមសិវៈ និងជាមេគ្រួសារសិវៈកៃវល្យៈ ដែលជាបុរោហិតទីមួយនៃទេវរាជ ។

សិលាចារឹកមួយ[៣] បានលើកពីព្រះអង្គថា ទ្រង់បានធ្វើសង្គ្រាមមានជ័យជម្នះលើពួកចាម ហើយបាន«ធ្វើសង្គ្រាមទៅគ្រប់ទិសទាំងបួន» ។

ព្រះបាទជ័យវរ្ម័ទី៥ សុគតនៅឆ្នាំ៩១២ ហើយទ្រង់មានព្រះមរណនាមថា ព្រះបរមសិវៈបទ ជាភ្ញៀវរបស់ព្រះឧត្តមសិវៈ ។

## ៤- ព្រះបាទហស៍វរ្ម័នទី២ (៩៤២-៩៤៤)

ព្រះរាជបុត្រាប្អូនរបស់ព្រះបាទជ័យវរ្ម័នទី៥ បានឡើងសោយរាជ្យបន្តពីព្រះអង្គនៅជោគគគ៌្យារ ក្រោមព្រះអភិសេកនាមថា ស្រីហស៍វរ្ម័ន ។ ហោរារបស់ព្រះរាជាអង្គនេះ គឺស្តេងអញអត្មសិវៈ ជាអ្នករៀបចំពិធីបូជាថ្វាយព្រះទេវរាជ ។ អត្មៈសិវៈនេះ ជាក្មួយរបស់ឦសានមុរទិ ដែលជាបុរោហិតរបស់ព្រះបិតាព្រះអង្គ ។

សិលាចារឹកព្រះឥន្ទ្រកោសិយ បានលើកសរសើរព្រះរាជាអង្គនេះថា ជាព្រះចៅអធិរាជ ដែល "មាន នខា (ក្រចក) ព្រះបាទភ្លឺរលោងដោយសារប៉ះនឹងមកុដព្រះរាជាទាំងឡាយ នៅលើពិភពលោកនេះ ដែលមកក្រាបបង្គំគាល់" និងថា ព្រះអង្គប្រៀបបានទៅនឹង "ព្រះអាទិត្យនាអរុណោទ័យផង និងព្រះច័ន្ទពេញវង់ឥតថ្មីមផង" ។ គេនិយាយថា គឺជា "ព្រះច័ន្ទនៃរាជវង្សកោណ្ឌញ្ញៈ ជាទីប្រជុំនៃគុណធម៌ទាំងឡាយ"[៤] ។

ក៏ប៉ុន្តែព្រះបាទហស៍វរ្ម័នទី២ទ្រង់សោយរាជ្យមិនទាំងបានពីរឆ្នាំផង ជាហេតុធ្វើឲ្យគេសួរថា តើព្រះអង្គ បានដណ្តើមរាជ្យសម្បត្តិពីព្រះរៀមដែលសោយរាជ្យបន្តពីព្រះអង្គឬយ៉ាងណា ។ បើពុំនោះទេ ប្រសិនបើព្រះអង្គ មិនត្រូវព្រះរៀមធ្វើឃាតទេ តើព្រះអង្គ និងព្រះបិតា ជាបក្សពួកសត្រូវនឹងមហានគរ ហើយព្រះរាជេន្ទ្រវរ្ម័ន ជាព្រះរៀមជាបក្សពួកខាងយសោធរបុរៈ ឬអ្វី?

ព្រះបាទហស៍វរ្ម័នទី២ មានព្រះមរណនាមថា ព្រហ្មលោក ៖ មានន័យថា ជាភ្ញៀវរបស់ព្រះព្រហ្ម ។

---

[២] ក្រុមប្រាសាទកោះកេរ្តិ៍ មានសារសំខាន់ណាស់ដែរ គឺមានប្រាសាទចំនួនប្រហែល ១៥កប់បាត់ក្នុងព្រៃ ។ លោក អែម៉ូនីញេ បានរកឃើញសិលាចារឹកជាង៤០ មាន ១៥០០បន្ទាត់ មានរៀបរាប់ឈ្មោះអ្នកបម្រើជាង ៤០០០នាក់ ដោយមិនទាន់គិតពីខ្ញុំផង ។ សូមអានសៀវភៅរបស់លោក អែម៉ូនីញេ, កម្ពុជា ក្បាលទី១ទំព័រ៣៩៧-៤១១ និងក្បាលទី២ ទំព័រ៣៦៨ ។

[៣] សិលាចារឹកប្រាសាទគុក សូមអានសៀវភៅរបស់លោក អែម៉ូនីញេ ឈ្មោះកម្ពុជា ក្បាលទី២ ទំព័រ៤១៩ ។

[៤] ក្បាលទី១ ទំព័រ៩០ ។

## ៥- ព្រះបាទរាជេន្ទ្រវរ្ម័នទី២ (៩៤៤-៩៦៨)

ព្រះបាទរាជេន្ទ្រវរ្ម័ន ជាព្រះរាជបុត្រាច្បងរបស់ព្រះបាទជ័យវរ្ម័នទី៥ និងត្រូវជាព្រះរៀមរបស់ព្រះរាជាមុន ។ ទ្រង់ប្រកបទៅដោយព្រះសម្ផស្សល្អក្រៃលែង ។ ព្រះអង្គបានឡើងសោយរាជ្យនៅឆ្នាំ៩៤៤ ហើយបាននាំព្រះរាជវង្ស, រាជបរិពារ និងទេវរាជ ព្រមទាំងព្រាហ្មណ៍បុរោហិត ត្រលប់មកគង់នៅនគរស្រីយសោធរបុរៈ (អង្គរធំ) វិញ ដែលត្រូវបោះបង់ចំនួន១៦ឆ្នាំមកហើយ ។ ព្រះអង្គបានធ្វើឲ្យរាជធានីនេះ «ប្រែក្លាយទៅជាល្អសម្បើម និងស្រស់ប្រិមប្រិយ៍ ដោយសង់ផ្ទះធ្វើអំពីមាសចាំងផ្លេក និងសង់វាំងរំលេចទៅដោយត្បូងថ្ម ប្រៀបបានទៅនឹងប្រាសាទរបស់ព្រះមហេន្ទ្រៈសង់នៅលើដី»[៥] ។

នៅក្នុងរជ្ជកាលរបស់ព្រះរាជាអង្គនេះ ដែលមានរយៈពេល២៤ឆ្នាំ មានអភិជនម្នាក់មានគោរម្យងាររជាកម្រតេងឈ្មោះថា នគៈគុលៈ បានសាងសង់ប្រាសាទជាច្រើនឧទ្ទិសដល់ព្រះសិវៈ និងមានរដ្ឋមន្ត្រីម្នាក់ទៀតឈ្មោះថា កវិន្ទ្ររិមត្ថនា ជាអ្នកសម្បូរទ្រព្យសម្បត្តិដូចជាខ្សែក្រវាត់, ថូទឹក, គ្រែស្នែង, ក្រវិល ។ល ។ បានសាងសង់ព្រះបដិមាព្រះពុទ្ធមួយចំនួន ។ ព្រះរាជាផ្ទាល់ បានកសាងប្រាសាទមេបុណ្យនៅចំកណ្ដាលអាងទឹកមួយ រួចសាងបដិមាវិរញ្ចៈមួយ, បដិមាទេវីមួយ, ឥសៈ (សិវៈ) មួយ, សរិង្គិន (វិស្ណុ) មួយ និងលិង្គព្រះសិវៈ មួយ ។

សិលាចារឹកព្រះឥន្ទ្រកោសិយ បានលើកសរសើរព្រះបាទរាជេន្ទ្រវរ្ម័ន ថាជា «ទីគោរពបូជានៃព្រះរាជាទាំងឡាយ ទ្រង់ជាស្ដេចអបរាជ័យ និងតែងតែមានជ័យជម្នះជានិច្ចលើខ្មាំងសត្រូវ ។ ទ្រង់ប្រៀបបានទៅនឹងរតនវត្ថុនៅលើកំពូលមកុដនៃព្រះរាជាទាំងអស់នៅលើផែនដីនេះ ។ ជ័យជម្នះរបស់ព្រះអង្គល្បីរន្ទឺទៅគ្រប់ទិសទី» ។ ទាំងអស់នេះ ហាក់ដូចជាបញ្ជាក់ថា ព្រះបាទរាជេន្ទ្រវរ្ម័ន បានធ្វើសង្គ្រាមជាច្រើន ហើយបានដេញវាយសត្រូវរហូតដល់ក្នុងផ្ទៃប្រទេសគេទៀតផង ។

សិលាចារឹកបាទជុំនៅក្នុងខេត្តសៀមរាបបាននិយាយថា «ព្រះនាងលក្ស្មី ដែលជានារីល្អលើសស្ត្រីទាំងឡាយក្នុងភពទាំងបី ទ្រង់នឿយណាយជាខ្លាំងនឹងការថ្នាក់ថ្នមរបស់ពួកសុរៈ និងអសុរៈ ហើយបែរមកជាប់ចិត្តនឹងព្រះភ័ក្ត្រដ៏ស្រស់ប្រិមប្រិយរបស់ព្រះអង្គ ដើម្បីក្រេបជញ្ជក់យកទឹកដមនៃសម្ផស្សរបស់ទ្រង់វិញ ។ ព្រះនាងពឹងផ្អែកមកលើព្រះវិស្ណុលើដីនេះ ដែលពោរពេញទៅដោយសេចក្ដីក្លាហានកម្រិតកំពូល នៅពេលដែលធូលីហុយទ្រលោមឡើង បានបង្កជាភាពងងឹតសូន្យសុងមួយដូចពេលយប់» ។

«ទ្រង់ជាសត្វសិង្ហក្នុងចំណោមព្រះរាជាទាំងឡាយ និងជាសត្វសិង្ហនៃមនុស្សជាតិ» ។ ទ្រង់បានវាយយកនគរចាម្ប៉ានៅឆ្នាំ៩៦០ គឺនៅក្នុងរជ្ជកាលស្ដេចចាម ព្រះបរមេស្វរវរ្ម័ន ឬក៏ក្នុងរជ្ជកាលព្រះរាជាដែលសោយ

---

[៥] សិលាចារឹកបាទជុំ

រាជ្យបន្ទាប់ តែគេមិនបានស្គាល់ព្រះនាមទេ ។ សិលាចារឹកបក្សីចាំក្រុងបានលើកសរសើរពីព្រះបាទរាជេន្ទ្រវរ្ម័ន ថា "ព្រះអង្គប្រៀបបានទៅនឹងព្រះអគ្គី ដែលដុតពេលរាល់រាជាណាចក្របច្ចាមិត្រ ជាពិសេស គឺនគរចាម្ប៉ា" ។ បន្ថែមពីលើនោះ ឯកសារប្រវត្តិសាស្ត្រចិន បានបញ្ជាក់ថា កម្ពុជាសម័យនោះ ជាមហាអំណាចមួយមានព្រះរាជាចំណុះច្រើនជាង៦០ព្រះអង្គ ។

មានសិលាចារឹកចាមមួយ គឺសិលាចារឹកពោធិនគរ បានរៀបរាប់ថានៅក្នុងសង្គ្រាមជាមួយចាម ពួកខ្មែរដែល "ពោរពេញទៅដោយសេចក្តីលោភលន់ និងបាបធម៌" បានលួចយកទៅនូវព្រះបដិមាព្រះភគវាទិ ធ្វើអំពីមាស "មានពន្លឺត្រចះដូចព្រះច័ន្ទពេញវង់លើវេហាស៍ និងបានលះបង់ព្រះកាយក្នុងការដឹកនាំនគរចាម្ប៉ា ដែលស្តេចស្រីឥន្ទ្រវរ្ម័ន "បានកសាងឡើងក្នុងឆ្នាំ៩១៨ ដាក់ក្នុងព្រះវិហារ ។ សិលាចារឹកនោះបានបន្ថែមទៀតថា "ពួកខ្មែរនោះ ក្រោយមកត្រូវស្លាប់អស់" ក៏ប៉ុន្តែ មិនបានបញ្ជាក់ថា តើស្លាប់ដោយរបៀបណាទេ[៦] ។

នៅសម័យនោះ ឯកសារចិនបានហៅរាជាណាចក្របង្រួបបង្រួមទាំងពីរថា ជាមឡាប់ ប្រហែលដោយយកព្យាង្គដំបូងនៃឈ្មោះរាជធានីចាម្ប៉ា គឺជាមចេន ដាក់ភ្ជាប់នឹងព្យាង្គក្រោយរបស់ឈ្មោះ កម្ពុជា គឺចិនឡាប់ ។ ក៏ប៉ុន្តែ នគរចាម្ប៉ា ប្រហែលជាមិនបាននៅក្រោមការត្រួតត្រារបស់កម្ពុជាយូរទេ ពីព្រោះថា មានស្តេចចាមមួយអង្គបានសាងសង់ព្រះបដិមា ព្រះភគវាទិ ឡើងវិញតែអំឡុងពេលប្រាំឆ្នាំក្រោយដែលពួកខ្មែរលួចយកទៅតែប៉ុណ្ណោះ ។

ព្រះបាទរាជេន្ទ្រវរ្ម័ន[៧] បានសុគតនៅឆ្នាំ៩៦៨នៃគ្រិស្តសករាជ ត្រូវនឹងមហាសករាជ៨៩០ ហើយមានព្រះមរណនាមថា សិវលោក ៖ មានន័យថា ទ្រង់ជាភ្ញៀវរបស់ព្រះសិវៈ ។

## ៦- ព្រះបាទជ័យវរ្ម័នទី៦ (៩៦៨-១០០២)

ព្រះរាជាដែលសោយរាជ្យបន្តពីព្រះបាទរាជេន្ទ្រវរ្ម័ន គឺព្រះរាជបុត្ររបស់ព្រះអង្គ ព្រះបាទស្រីជ័យវរ្ម័នទី៦ ដែលជាព្រះរាជាកែទម្រង់ ឬប្រត្យាស្ថាបនិក និងជាព្រះរាជាពូកែខាងធ្វើសង្គ្រាម តែមានអធ្យាស្រ័យល្អ ។ សិលាចារឹកព្រះឥន្ទ្រកោសិយ បានដំណាលថា "ព្រះអង្គបានរៀបចំឲ្យមានសណ្តាប់ធ្នាប់ល្អក្នុងវណ្ណៈ" ប្រៀបបីដូចជារៀបចំឡើងដោយព្រះព្រហ្មផ្ទាល់ ។ ព្រះអង្គប្រកបទៅដោយទេពកោសល្យ និងមានព្រះហត្ថាកាន់កង

[៦] ព្រះបដិមានេះ បានត្រូវពួកចាមសាងសង់ឡើងវិញ ប្រាំឆ្នាំក្រោយមក នៅឆ្នាំ៩៦៥ ដោយព្រះរាជាចាមព្រះនាមថា ជ័យឥន្ទ្រវរ្ម័ន ។

[៧] លោក អែម៉ូនីញេ បានស្នើថា ព្រះរាជេន្ទ្រវរ្ម័ន នេះគឺជាតួអង្គព្រះបក្សីចាំក្រុងក្នុងរឿងនិទាន ។ ការសន្និដ្ឋាននេះមិនត្រឹមត្រូវទេ ហើយរឹតតែមិនត្រឹមត្រូវណាស់ទៅទៀត ព្រោះថារឿងនេះក៏មានដែរនៅឯស្រុកសៀម គ្រាន់តែមានឈ្មោះផ្សេង និងនៅទីកន្លែងផ្សេងប៉ុណ្ណោះ ។

ចក្រ ។ នៅពេលទ្រង់ចេញដំណើរម្តងៗ សន្ធឹកជើងកងទ័ពរបស់ព្រះអង្គ ធ្វើឲ្យកក្រើកផែនដី និងព្រៃភ្នំទាំងឡាយ ប្រៀបបាននឹងមហាសាគរដែលត្រូវរញ្ជួយដោយព្យុះខ្យល់» ដូច្នោះដែរ ។

ពេលនោះ «សន្ធឹកស្គរលាយឡំជាមួយសំឡេងកងរំពងរបស់គងឃ្មោះធ្វើអំពីស្ពាន់ និងត្រែ ខ្លុយ ស័ង្ខ... ធ្វើឲ្យពួកសត្រូវភ័យបាក់បបខ្លបខ្លាចជាខ្លាំង» ។ សិលាចារឹកក៏បានលើកពីព្រះអង្គដែរថា ទ្រង់បានដុតបំផ្លាញប្រទេសទាំងឡាយណាដែលព្រះអង្គធ្វើសង្គ្រាមជាមួយ ដោយនិយាយថា «អណ្តាតភ្លើងនៃការបូជាដែលកើតឡើងពីប្រតិបត្តិការរបស់ព្រះអង្គ បន្តបានជាផ្សែងធំវែង ប្រៀបបាននឹងទង់ជ័យចម្បាំង ធ្វើឲ្យសត្រូវភ័យខ្លាចហើយរត់គេចចេញបាត់អស់ បើទោះជាអង់អាចយ៉ាងណាក៏ដោយ» ។ ព្រះអង្គគួរឲ្យខ្លាចខ្លាំងណាស់ នៅពេលដែលទ្រង់ខ្ញាល់ ៖ «កាលណាព្រះអង្គគ្រហឹមដូចរាជសីហ៍ពេលមានកំហឹង ព្រះរាជាជាសត្រូវទាំងឡាយរត់គេចចូលព្រៃជ្រៅ ប្រៀបបាននឹងសត្វឈ្លូសដ៏កំសាក ។ នៅពេលដែលព្រះអង្គលើកដាវដ៏មុតថ្លា ប្រឡាក់ទៅដោយឈាមដែលហូរចេញពីសិរសាសត្រូវ គេឃើញព្រះអង្គដូចជាព្រះនាងជ័យជម្នះដ៏ស្រស់ស្អាត ដែលមានព្រះហស្ត និងព្រះបាទក្រហមទៅដោយលម្អងផ្កា» ។

សិលាចារឹកដដែលបាននិយាយថែមទៀតថា «ព្រះហស្តព្រះអង្គដែលប្រៀបបាននឹងស្ពានយុត្តិធម៌ ឆ្លងកាត់មហាសាគរដ៏ស្មោកគ្រោកនៃសតវត្សរ៍ ... មានរាងសណ្ឋានស្រស់ប្រិមប្រិយ» ស្អាតលើសពីព្រះនាងកាមទេព ហើយធ្វើឲ្យពិភពលោកនេះ មានពន្លឺប្រៀបបីដូចព្រះច័ន្ទ្រកំពុងរះ» ។

ដូចជាព្រះរាជាមុនៗ ចាប់តាំងពីព្រះបាទជ័យវរ្ម័នទី៣មក ព្រះបាទជ័យវរ្ម័នទី៦ ក៏មានបុរោហិតសម្រាប់រៀបចំពិធីបូជាថ្វាយព្រះទេវរាជផងដែរ ។ បុរោហិតរបស់ព្រះអង្គគឺ ស្តេងអញអត្ថៈសិវៈ ដែលជាបុរោហិតរបស់ព្រះបាទរាជេន្ទ្រវរ្ម័នជាព្រះវរាជបិតា ។ ទ្រង់ក៏មានរដ្ឋមន្ត្រីមួយរូបជាអ្នកកាន់ពុទ្ធសាសនា ដែលធ្លាប់បានបម្រើព្រះបិតាដែរ ហើយដែលទ្រង់មានទំនុកទុកចិត្តជាខ្លាំង ។ រដ្ឋមន្ត្រីនោះមានឈ្មោះថា គ្រិត្តិបណ្ឌិត បានធ្វើការជួសជុលព្រះពុទ្ធបដិមាដែលត្រូវគេបំផ្លិចបំផ្លាញប្រហែលជាក្នុងសម័យមានវិបត្តិសាសនា ហើយក៏បានសាងសង់ព្រះពុទ្ធបដិមាថ្មីៗជាច្រើន ។ ព្រះរាជា បានប្រគល់ឲ្យមន្ត្រីនេះរៀបចំតុបតែងរាជធានីថែមទៀត ។

ព្រះបាទជ័យវរ្ម័នទី៦ បានជំរុញឲ្យមានការអនុគ្រោះកាន់តែខ្លាំង ។ វាហាក់ដូចជាព្រះអង្គមានបំណងចង់ផ្តល់សិទ្ធិឲ្យពុទ្ធសាសនា និងផ្តល់សន្តិភាពខាងជំនឿដល់ប្រជានុរាស្ត្រ ដោយទាញសាសនាទាំងពីរមកជិតគ្នា ពោលគឺឲ្យព្រាហ្មណ៍បុរោហិតនៃពិធីទេវរាជគោរពព្រះពុទ្ធ ហើយឲ្យពុទ្ធសាសនិកជនគោរពព្រះទេវរាជវិញ ។ ធ្វើយ៉ាងនេះគឺចង់បង្រួបបង្រួមសាសនាទាំងពីរមកតែមួយ ដោយចាត់ទុកព្រះពុទ្ធស្មើនឹងអាទិទេពមួយអង្គនៃព្រហ្មញ្ញសាសនា ហើយបើទោះជាសាសនាទាំងពីរមានទ្រឹស្តីខុសគ្នាខ្លាំងយ៉ាងណាក៏ដោយ គឺឲ្យទាំងព្រាហ្មណ៍ ទាំងប្រជាជន ទៅធ្វើពិធីបូជាព្រះសិវៈ និងព្រះនាងកាលី ទាំងអស់គ្នា រួចហើយនាំគ្នាទៅថ្វាយបង្គំបដិមាព្រះពុទ្ធ ដែលធ្លាប់បានបង្ហាត់បង្រៀនអំពីបរមត្ថវិជ្ជា, សន្តិភាពផ្លូវចិត្ត, ឧបេក្ខាចិត្តចំពោះវត្ថុទាំងឡាយលើលោក និងការលះបង់ចោលនូវការ

សប្បាយគ្រោតគ្រាតនៃដែនដីនេះ ។ គឺជាចេតនារំលាយសាសនាចូលគ្នាដ៏ចម្លែក ប្រហែលដោយស្ថានភាពនយោបាយផ្ទៃក្នុងហើយមើលទៅ ជាពិសេស គឺឥទ្ធិពលកាន់តែកើនឡើងនៃព្រះពុទ្ធសាសនា ក្នុងស្រទាប់អ្នកទីក្រុង ក៏ដូចជាអ្នកស្រែចម្ការ និងរាជបរិពារ ។

ចំណុចមួយទៀតដែលខ្ញុំចង់បញ្ជាក់អំពីរជ្ជកាលនេះ គឺនារីៗ បើហោចណាស់ក៏ម្ចាស់ក្សត្រីយ៍ ហើយក៏អាចមានបុត្រីរបស់ពួកព្រាហ្មណ៍ និងសេនាបតីខ្លះផងដែរ ដែលបានរៀនសូត្រអាចចេះអានសៀវភៅបាន ។ សិលាចារឹកព្រះឥន្ទ្រកោសិយ បានឲ្យដឹងថា មេក្រុមលេខាផ្ទាល់របស់ព្រះបាទជ័យវរ្ម័នទី៦ គឺព្រះនាងប្រាជ្ញា ដែលជាព្រះអគ្គមហេសីមួយអង្គរបស់ព្រះបិតាព្រះអង្គ ។

ព្រះរាជាអង្គនេះទ្រង់សុគតទៅនៅឆ្នាំ១០០២នៃគ្រិស្តសករាជ ត្រូវនឹងមហាសករាជ៩២៤ ។ ទ្រង់មានព្រះមរណនាមថា បរមវីរៈលោក មានន័យថា ជាភៀវរបស់ព្រះបរមអគ្និ ។

## ៧- ព្រះបាទសុរិយាវរ្ម័នទី១ (១០០២-១០៤៩)

ព្រះបាទសុរិយាវរ្ម័នមានព្រះនាមដើមហៅថាវីរជ័យវរ្ម័ន ទ្រង់ជាបច្ចាញាតិឆ្ងាយរបស់ព្រះបាទឥន្ទ្រវរ្ម័ន ដែលសោយរាជ្យពីឆ្នាំ៨៧៧ ដល់៨៨៩ ហើយទ្រង់មានព្រះអគ្គមហេសី គឺព្រះនាងស្រីវីរៈលក្ស្មី ដែលជាប់សាច់ជាមួយព្រះបាទយសោវរ្ម័ន ។ ព្រះអង្គបានឡើងសោយរាជ្យបន្តពីព្រះបាទជ័យវរ្ម័នទី៦ តាំងតែពីឆ្នាំ១០០២ ក៏ប៉ុន្តែ លុះត្រាតែបីឆ្នាំក្រោយមក ទើបបានទទួលការអភិសេក ។ តាមមើលទៅ ព្រះអង្គមិនមែនជារជ្ជទាយាទ ដែលគេបានគ្រោងទុកនោះទេ ប្រហែលជាព្រះអង្គបានបណ្តេញព្រះរាជាមុនពីរាជ្យសម្បត្តិផងក៏មិនដឹង ពីព្រោះសិលាចារឹកព្រះខ័នបាននិយាយថា "ព្រះអង្គបានដណ្តើមយកព្រះនគរពីព្រះរាជាមួយអង្គ ក្នុងចំណោមយុទ្ធជនជាច្រើន" ។ ព្រះអង្គបានទទួលព្រះនាមថា សុរិយាវរ្ម័ន (ព្រះអាទិត្យជាអ្នកការពារ) ហើយសិលាចារឹកព្រះកែវ បានលើកអំពីព្រះអង្គថា "ទ្រង់មានរស្មីភ្លឺចិញ្ចាច ប្រៀបបានទៅនឹងព្រះអាទិត្យនៅលើវេហាស៍ ជាវង្សត្រកូលរបស់ព្រះបាទឥន្ទ្រវរ្ម័ន" ។ ព្រះអង្គសោយរាជ្យបានចំនួន៤៧ឆ្នាំ ។

ព្រះបាទសុរិយាវរ្ម័នកាន់ព្រហ្មញ្ញសាសនា តាមទម្លាប់ដែលមានជាហូរហែរហូតមក ក៏ប៉ុន្តែព្រះអង្គ ដូចជាបានចាប់ចិត្តនឹងទ្រឹស្តីរបស់ព្រះពុទ្ធខ្លាំងណាស់ដែរ ថ្វីបើព្រះអង្គមិនបានបង្ហាញខ្លួនព្រះអង្គថា ជាពុទ្ធសាសនិកជនមួយអង្គក៏ដោយ ។ ទ្រង់បានកសាងបដិមាព្រះសិវៈ និងព្រះវិស្ណុ ក៏ប៉ុន្តែព្រះមរណនាមថា និព្វានបទ ដែលគេថ្វាយដល់ព្រះអង្គពេលក្រោយមក និងការសាងសង់វត្តមួយឧទ្ទិសថ្វាយដល់ព្រះពុទ្ធ បញ្ជាក់ថា ព្រះអង្គបានយកចិត្តទុកដាក់ចំពោះព្រះពុទ្ធសាសនាជាខ្លាំង ។ មិនតែប៉ុណ្ណោះ ព្រះអង្គបានទាំងដាក់រាជបញ្ជាអំពី "សិក្ខាបទពិសិដ្ឋ ដែលជនទាំងអស់ត្រូវប្រតិបត្តិ" ដើម្បីឲ្យទាំងតាបសបុសី, ទាំងស្ថាវីរៈ និងព្រះសង្ឃ ដែលគង់នៅតាមទីសក្ការៈ, វិហារ, វត្តអារាម និងអាស្រមផ្សេងៗ "អនុវត្តនូវតបកម្មដើម្បីផ្សព្វផ្សាយកុសលដល់ព្រះរាជាជាម្ចាស់" ទៀតផង[៨] ។

តាមមើលទៅ ប្រហែលជាមានការធ្វើទុក្ខបុកម្នេញដល់ព្រះពុទ្ធសាសនានៅក្នុងរាជ្យមុនៗ រួចសាសនានេះនៅរងការគំរាមកំហែងនៅឡើយ ហើយពុទ្ធសាសនិកក៏នៅរងអំពើហិង្សានៅឡើយដែរ ព្រោះសិលាចារឹក លពបុរី បានបញ្ជាក់ថែមទៀតថា មានការកាត់ទោសដាក់ទណ្ឌកម្មធ្ងន់ធ្ងរដល់«ជនទាំងឡាយណាដែលចូលទៅក្នុងសមាធិស្ថាន ហើយធ្វើការរំខានដល់តាបស ឬសាសនិក ក្នុងការអនុវត្តន៍កាតព្វកិច្ចរបស់ខ្លួន» ។ គេអាចលើកសំណួរបានថា តើព្រះរាជាអង្គនេះ មានពុទ្ធសាសនិកជននៅជាមួយទេពេលទ្រង់ធ្វើការប្រយុទ្ធដណ្តើមរាជបល្ល័ង្ក ឬក៏ព្រះអង្គធ្វើការតបស្នងសងគុណចំពោះការគាំទ្ររបស់ពួកពុទ្ធសាសនិកជនទាំងនោះ?

ទោះជាយ៉ាងណាក្តី ក៏វាច្បាស់ណាស់ថា មានចេតនាធ្វើឲ្យសាសនាទាំងពីររលាយចូលគ្នាខ្លាំងជាងមុននៅក្រោមរជ្ជកាលនេះ ។ សិលាចារឹកព្រះកែវបានឲ្យដឹងថា ព្រះបាទសុរិយាវរ្ម័នបានរៀបចំឲ្យមានការបែងចែកប្រជាជនជាវណ្ណៈឡើងវិញ ហើយទ្រង់ដាក់ព្រះមុនីសិវៈចរិយាឲ្យដឹកនាំវណ្ណៈព្រាហ្មណ៍ ព្រះមុនីនេះ «រៀបហារ បានប្រតិបត្តិវិន័យតឹងរ៉ឹង និងស្មោះត្រង់នឹងការបេ្តជ្ញា និងគុណធម៌ ហើយធ្លាប់បានត្រូវព្រះរាជាមុនៗ ចាត់ឲ្យគ្រប់គ្រងលើហិមៈស្រិង្គគិរី ពិនិត្យលើគុណសម្បត្តិ និងគុណវិបត្តិ» ។

សិលាចារឹកព្រះកែវ បានលើកអំពីគោរម្យងាររមួយនៅក្បែរព្រះរាជា ដែលយើងមិនដែលដឹងពីមុនមកគឺមុខងារជាជំនួយការមួយបែបហៅថា ស្រីក្សិទ្ធិទ្រកល្បៈ ។ ឋានៈនេះមានរួចទៅហើយមុនស្តេចសុរិយាវរ្ម័នទី១ ព្រោះថា ព្រាហ្មណ៍សិវវិន្ទុ ដែលជា«អ្នកប្រាជ្ញចេះដឹងជ្រៅជ្រះសមនឹងទទួលការគោរពពីបណ្តាអ្នកមានអំណាចទាំងឡាយ និងជាបព្វជិតនៃស្រីកបាលេស្វរៈ ជាចាងហ្វាងនៃតបកម្ម ដែលគ្មានការខុសឆ្គង» បានទទួលឋានៈនេះ តែនៅពេលដែលឪពុកមាខាងម្តាយដែលមានឋានៈនេះ បានទទួលមរណភាពទៅ ។ សិលាចារឹកព្រះឥន្ទកោសិយបាននិយាយថា នៅឆ្នាំ៨៩០នៃគ្រិស្តសករាជ ស្រីធរណិន្ទ្របប្បកល្បៈបានទទួលនូវឋានៈនេះ គឺជាង១០០ឆ្នាំមុនរាជ្យព្រះបាទសុរិយាវរ្ម័ន ។

ឯកសារប្រវត្តិសាស្ត្រចិនបាននិយាយថា នៅឆ្នាំ១០៣០នៃគ្រិស្តសករាជ ស្តេចអង្គនេះបានចងសម្ព័ន្ធមេត្រីជាមួយនគរចាម្ប៉ា ក្នុងរជ្ជកាលស្តេចចាមមួយអង្គដែលយើងមិនបានស្គាល់ព្រះនាម តែសោយរាជ្យ ក្នុងចន្លោះស្តេចជ័យវរ្ម័ន និងជ័យបរមេស្វរវរ្ម័ន ហើយនិងប្រទេសចិន ផងដែរ ។ សម្ព័ន្ធមេត្រីនេះមានរយៈពេល ៦០ឆ្នាំ និងមានគោលបំណងចង់ធ្វើឲ្យមានសន្តិភាពជាមួយនគរចាម្ប៉ា ហើយធានាសន្តិភាពនេះ ដោយមហាអំណាចទីពមួយទៀត ដើម្បីទុកពេលឲ្យព្រះអង្គធ្វើការបង្ក្រាបស្តេចចំណុះទាំងឡាយដែលបះបោរ ជាពិសេសគឺពួកក្សត្រប្រទេសនៅខាងជើងភ្នំដងរែក និងនៅអាងទន្លេមេណាមខាងលើ ដែលមានរាជធានីនៅ លពបុរី

[៨] សិលាចារឹកលពបុរី ។

គឺទ្វារវតី នោះឯង[៩៧] ។ តើនោះមិនមែនជាពួកថៃនៃអាណាចក្រទន្លេមេណាមខាងលើ ដែលចុះមកពីប្រទេសចិនភាគខាងត្បូង ឬមកពីភូមាដែលពួកនេះបានមករស់នៅជាយូរណាស់មកហើយ ហើយបានមកបង្ហាញខ្លួននៅនឹងព្រំប្រទល់នៃអាណាចក្រកម្ពុជាទេ ឬអ្វី?

សិលាចារឹកលង្វែកបានហៅព្រះបាទសុរិយាវរ្ម័នថាជា «ព្រះចៅអធិរាជ និងជាអ្នកទ្រទ្រង់ផែនដី» ដែល «ព្រះអ្នកបង្កើតលោកបានសាងមកឲ្យដូចខ្លួនព្រះអង្គ» ។ «នៅពេលទ្រង់យាងចេញច្បាំងយកជ័យជម្នះលើអស់ស្ដេចដែលខ្លាំងៗទាំងឡាយ សូម្បីតែព្រះអាទិត្យក៏លាក់ខ្លួនបំបាំងកាយដែរ ដោយខ្លាចបារមីរបស់ព្រះអង្គ ។ ភ្លើងផ្សែងដែលហុយចេញពីការបូជារបស់ព្រះអង្គ មិនគ្រាន់តែធ្វើឲ្យផ្ទៃមេឃងងឹតប៉ុណ្ណោះទេ គឺបានបាំងបិទអស់នូវកិត្តិគុណរបស់ព្រះរាជាទាំងឡាយ ដែលធ្លាប់មានឈ្មោះល្បីល្បាញទៀតផង ។ ព្រះអង្គគួរតែទទួលបាននូវកិត្តិគុណរបស់អារុណៈ ... ទ្រង់បានរៀនចេះចាំអំពីទ្រឹស្ដីបទីនិ ទាំងទ្រង់ល្អឥតខ្ចោះ ហើយប្រកបដោយប្រាជ្ញាបារមីដូចជាបណ្ឌិត ... គឺជាព្រះរាជាសាកលដែលប្រៀបបាននឹងអធិរាជនៃអាទិទេពទាំងឡាយ» ។

ព្រះបាទសុរិយាវរ្ម័នទី១ បានកសាងប្រាសាទភ្នំជីសូរនៅក្នុងខេត្តបាទី ហើយក៏បានជួសជុលឡើងវិញនូវប្រាសាទមួយចំនួនទៀតផងដែរ ។

ព្រះអង្គសុគតនៅឆ្នាំ១០៤៩ ហើយមានព្រះមរណនាមថា បរមនិព្វានបទ មានន័យថា ទ្រង់យាងចូលព្រះនិព្វានទាំងស្រុងហើយ ។

## **៨- ព្រះបាទឧទយាទិត្យវរ្ម័នទី១ (១០៤៩-១០៧៩)**

ព្រះរាជាដែលសោយរាជ្យបន្តពីព្រះបាទសុរិយាវរ្ម័នទី១គឺព្រះបាទឧទយាទិត្យវរ្ម័ន ឬឧទយាកៈវរ្ម័ន ដែលត្រូវជាចៅ ឬក្មួយ របស់ព្រះអង្គ ។

ការដែលស្ដេចអង្គនេះឡើងសោយរាជ្យហាក់ដូចជាមិនប្រក្រតី គឺដូចជាឡើងសោយរាជ្យដោយជ័យជម្នះរបស់ក្រុមរាជបរិពារ ដែលមានប្រតិកម្មប្រឆាំងនឹងពុទ្ធសាសនា ។ ស្ដេចអង្គនេះមានព្រះជន្មក្មេងខ្ចីនៅឡើយ ពេលឡើងគ្រងរាជ្យសម្បត្តិ ព្រោះព្រះអង្គនៅបន្តរៀនសូត្រគណិតសាស្ត្រ តារាសាស្ត្រ វេយ្យាករណ៍ ច្បាប់ និងក្រមទាំងឡាយគាក់តែងឡើងសម្រាប់ព្រះរាជា ពីសំណាក់ព្រះរាជគ្រូរបស់ព្រះអង្គឈ្មោះថា ស្រីការៈបណ្ឌិត ។ «ដោយព្រះអង្គចាប់បដិសន្ធិឡើងក្នុងត្រកូលនៃស្ដេចលើពិភពលោក ទ្រង់មានប្រៀបដាច់គេក្នុងការធ្វើឲ្យនារីទាំងឡាយ លង់នឹងសម្ផស្សរបស់ព្រះអង្គ ឲ្យអ្នកចម្បាំងទាំងឡាយចុះចាញ់វីរភាពរបស់ព្រះអង្គ ឲ្យបណ្ឌិតទាំង-

---

[៩៧] សព្វថ្ងៃគឺលវោ ពីមុនគឺលូវ៉ូ, លោវែក, លពបុរី, លវបុរី, នវបុរី ។

ឡាយទទួលស្គាល់គុណធម៌របស់ព្រះអង្គ ឲ្យបណ្ដាប្រជានុរាស្ត្រចំណុះនឹងអំណាចរបស់ព្រះអង្គ និងឲ្យព្រាហ្មណ៍ទាំងឡាយទទួលស្គាល់នូវសប្បុរសធម៌របស់ព្រះអង្គ ។ តាមមើលទៅ ស្ដេចអង្គនេះ គោរពបូជាព្រះសិវៈ ខ្លាំងណាស់ «ព្រោះព្រះអង្គបានចាត់ឲ្យគេលើកភ្នំមាសមួយនៅចំកណ្ដាលរាជធានី រួចឲ្យសាងសង់ប្រាសាទមាសមួយ មានពន្លឺភ្លឺចិញ្ចាចចិញ្ចែង ដាក់សិវៈលិង្គមួយ សម្រាប់រៀបចំពិធីស្រោចទឹកគោរពបូជា» ហើយទ្រង់បានចាត់ឲ្យចន្ទ័ការៈ បណ្ឌិតថែរក្សា ។ ព្រាហ្មណ៍នេះគេច្រើនស្គាល់ថា យ៉ាលីចន្ទ័ការៈ ព្រោះជាតាបសឫសី និងជាបុរោហិតរបស់ព្រះបាទសុរិយាវរ្ម័ន ហើយត្រូវបន្តថែរក្សាលិង្គនេះរហូតដល់រាជ្យស្ដេច ក្រោយមកទៀត ដែលសោយរាជ្យបន្តពីព្រះបាទឧទយាទិត្យវរ្ម័ន គឺព្រះបាទហស៌វរ្ម័នទី៣ ។

ក្នុងរជ្ជកាលស្ដេចអង្គនេះ បណ្ដាអាណាខេត្រខាងត្បូងបានបះបោរឡើង ហើយត្រូវទ័ពរបស់ជនម្នាក់ឈ្មោះថា អារវិន្ទ្រទៈ ដណ្ដើមយកបាន ។ ទ័ពទី១របស់ព្រះរាជាដែលបញ្ជូនទៅបង្ក្រាប ត្រូវបរាជ័យក្រោមដៃ «មេកោយសត្រូវដ៏ហានក្លា» នេះ ។ ក៏ប៉ុន្តែទ័ពមួយកងទៀតដែលដឹកនាំដោយសេនាបតីម្នាក់ គឺខកញ៉ាពិជ័យសង្គ្រាម មានជ័យជម្នះលើអារវិន្ទ្រទៈ ។ ខកញ៉ាពិជ័យសង្គ្រាមនេះជាឧត្ដមសេនីយ៍ដែល «រហ័សរហួនណាស់ក្នុងការរងអាវុធខ្លាំង និងវាយប្រហារតបទៅវិញដោយប្រើដៃទាំងពីរ ជាអ្នកប្រយុទ្ធគ្មានគូប្រៀបផ្ទឹមបាន ជាយុទ្ធជនឆ្នើម ដែលសត្រូវទទួលស្គាល់ថ្វីដៃ ហើយហៅថា ជាព្រះគ្រឹស្នៈ មួយអង្គថ្មី ឬក៏ជាអារុណៈមួយរូបទៀត ជាវីរបុរសគ្មាននរណាស្មើលើលោកនេះ» ។ ក្រោយបរាជ័យ អារវិន្ទ្រទៈ បានគេចខ្លួនទៅនៅឯចាម្ប៉ាបុរៈ រាជធានីរបស់នគរចាម្ប៉ា ។

ប៉ុន្មានឆ្នាំក្រោយមក មានឧត្ដមសេនីយ៍ម្នាក់ឈ្មោះថា កំវ៉ី ដែលមិនសប្បាយចិត្ត ក៏នាំទ័ពរបស់ខ្លួនចេញពីរាជធានី ហើយប្រកាសបះបោរឡើង ។ កំវ៉ី នោះជា «មនុស្សឆ្លាត មានវីរភាព ដែលបានទទួលការសន្ដោសប្រណីពីព្រះរាជា ទ្រង់ប្រទានបុណ្យសក្តិឲ្យ ។ គេមានរាងកាយមាំមួន មានអាវុធគ្រប់គ្រាន់ រហ័ស វាងវៃ អាចធ្វើជាម្ចាស់លើដែនដីទាំងមូលបាន ។ ទ័ពរបស់គេក៏ក្លាហាន និងសម្បូរដោយអាវុធយុទ្ធភណ្ឌ ហ៊ានលះបង់ជីវិត មានចំនួនច្រើនឥតគណនា និងមាននៅគ្រប់ទិសទី» ។

ពេលនោះសេនាបតីពិជ័យសង្គ្រាម បានដឹកនាំទ័ពចេញច្បាំងជាមួយកំវ៉ី ដោយមានឧត្ដមសេនីយ៍ ជាច្រើនចូលរួមនៅក្រោមបញ្ជាផង គឺមានទេវស្រូ, វ៉ុង, វ្លួរ, គាំ, ចេន្តីស្រូ, កម្ភាត់, រញ្ញ, ខ្វញ ។ ពេលលើកទ័ពដេញតាមសត្រូវ សេនាបតីពិជ័យសង្គ្រាមបានឈប់នៅលើខ្នងរាបមួយ ធ្វើពិធីបូជាថ្វាយដល់ព្រះសិវៈ សុំជ័យជម្នះ ។ ពេលនោះ កំវ៉ី បានត្រលប់ក្រោយមកវិញ ហើយការប្រយុទ្ធក៏បានចាប់ផ្ដើមឡើង ។ កំវ៉ី និងពិជ័យសង្គ្រាម «រត់រកគ្នាប្រៀបដូចព្រះរាម និងក្រុងរាពណ៍» រីឯមេកងរបស់ទ័ពទាំងពីរក៏ស្ទុះស្វែងរកគូប្រយុទ្ធរៀងៗខ្លួនផងដែរ ។ ពួកគេប្រកួកប្រកាសហៅគ្នា ជេរប្រទេចផ្ដាសាគ្នា គំរាមគ្នាទៅវិញទៅមក ។ កំវ៉ី បាញ់ព្រួញមួយមកត្រូវចង្ការបស់ ពិជ័យសង្គ្រាម ក៏ប៉ុន្តែពិជ័យសង្គ្រាមគ្មានរួញរា ហើយបានបាញ់ព្រួញបីតែម្ដងសំដៅ កំវ៉ី ព្រួញមួយ

ត្រូវចំក្បាល, មួយចំក និងមួយទៀតចំទ្រូង ។ កំវ៉ី ដួលស្លាប់ភ្លាម ដោយស្រែករោទ៍ទ្រហឹង ធ្វើឲ្យទេវតាទាំងឡាយគ្រេកអរស្មុគមន៍ជាខ្លាំង ។ ពិជ័យសង្គ្រាមក៏ត្រលប់មកកាន់វិហារព្រះសិវៈវិញ ហើយបានថ្វាយទ្រព្យរបស់ខ្លួនទាំងអស់ ដើម្បីជាការតបស្នងសងគុណព្រះអង្គ ។

ក្រោយពី កំវ៉ី ស្លាប់ទៅ នៅមានបះបោរមួយទៀតកើតឡើងនៅក្នុងសរទរដូវបន្ទាប់ មិនដឹងថា ជាការបះបោរថ្មី ឬក៏ទ័ពចាស់របស់ កំវ៉ី បះបោរម្តងទៀត ឬក៏យ៉ាងណាទេ ។ ការបះបោរលើកនេះដឹកនាំដោយបងប្អូនពីរនាក់ គឺសល្យាត់ "ដែលមានកម្លាំងខ្លាំងគ្មានផ្ទឹម ក្លាហាន មានល្បិចច្រើន ហើយពូកែក្នុងការប្រយុទ្ធដោយមោងស័ក" និងប្អូនប្រុសបង្កើត ឈ្មោះ សិទ្ធិករៈ ហើយនិងមេទ័ពម្នាក់ទៀតឈ្មោះថា សាសន្តិភូវនៈ "ដែលមានកម្លាំងគួរឲ្យខ្លាចនៅក្នុងការប្រយុទ្ធ" ។ ពិជ័យសង្គ្រាមបានដឹកនាំទ័ពចេញច្បាំងទៀត ពេលជួបសល្យាត់ក៏ដេរប្រទេចផ្តាសា បបួលចូលច្បាំងគ្នា ។ សល្យាត់ដេរតបវិញ រួចបាញ់ព្រួញស្រោចមកលើពិជ័យសង្គ្រាម ។ ពិជ័យសង្គ្រាមចាប់យកព្រួញមកដាក់លើខ្សែធ្នូ រួចទាញយឺតដោយដៃដ៏មាំទាំងពីរ បាញ់តម្រង់សំដៅសត្រូវ ។ នៅពេលដែលសល្យាត់ត្រូវព្រួញស្លាប់ ទ័ពសត្រូវទាំងអស់ក៏ដកថយរត់បាត់អស់ទៅ[១០] ។ ប៉ុន្តែចលាចលនេះនៅបន្តច្រើនឆ្នាំតទៅទៀត ទម្រាំរលត់បាត់ ហើយពិជ័យសង្គ្រាមក៏ឈប់ដេញតាមទៀតដែរ ។

ដោយពិជ័យសង្គ្រាម បានបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួនបូជាថ្វាយព្រះសិវៈ ក្នុងការធ្វើសង្គ្រាមបង្ក្រាបសត្រូវ ព្រះរាជា បានប្រទានរាជទ្រព្យសងវិញ និងបានប្រទានរង្វាន់ឲ្យជាច្រើន តែពិជ័យសង្គ្រាមបានលះបង់ទ្រព្យទាំងអស់នោះ ក្នុងនាមជាវីរជន ដែល "មានពន្លឺភ្លឺប្រៀបដូចរាហ៊ូ" ។

គឺនៅក្រោមរាជ្យរបស់ព្រះបាទឧទយាទិត្យវរ្ម័ននេះឯង ដែលទ័ពខ្មែរមួយកងក្រោមបញ្ជារបស់មេទ័ពម្នាក់ឈ្មោះថា ស្រីនន្ទៈនវម៌ទេវៈ ច្បាំងចាញ់ទ័ពចាមនៅឯសោមេស្វរៈ ក្រោមរាជ្យស្តេចចាមព្រះនាមស្រីហរិវរ្ម័នទី២ (១០៧៨) ។

## ៩- ព្រះបាទហស៌វរ្ម័នទី៣ (១០៧៩-១០៩០)

រជ្ជកាលរបស់ព្រះបាទឧទយាទិត្យវរ្ម័នពោរពេញទៅដោយភាពវឹកវរ ជាកត្តាបញ្ជាក់ថា មហានគរ ស្ទើរតែគ្មានសន្តិភាពទេ មានសង្គ្រាមក្នុងស្រុក និងការបះបោរប្រឆាំងពីស្តេចត្រាញ់ឬស្តេចចំណុះជាញឹកញាប់ ។ អំណើះអស់ពីព្រះអង្គទៅ ព្រះរាជអនុជរបស់ព្រះអង្គបានឡើងសោយរាជ្យបន្ត មានព្រះនាមថា ហស៌វរ្ម័នទី៣ ។

នៅពេលស្តេចអង្គនេះឡើងសោយរាជ្យ មានកើតភាពវឹកវរម្តងទៀត ក៏ប៉ុន្តែ ព្រះអង្គបានបង្ក្រាបឲ្យរាប

[១០] សិលាចារឹកព្រះងោក សៀវភៅកម្រង ទំព័រ១៦១ ។

អស់ ធ្វើឲ្យស្រុកមានសន្តិសុខឡើងវិញដោយ "ទ្រង់បញ្ជាឲ្យអនុវត្តកាតព្វកិច្ចរបស់វណ្ណៈទាំងបួនយ៉ាងម៉ឺងម៉ាត់" ។

ឯកសារប្រវត្តិសាស្ត្រចិនបានរៀបរាប់ថា ដោយស្តេចអាណ្ណាមព្រះនាមលីញញតុងបានលើកទ័ពមកវាយចិន សម្លាប់ប្រជាជនចិនអស់ជាច្រើននាក់ ព្រះចៅអធិរាជចិនបានអំពាវនាវសុំជំនួយពីព្រះរាជាខ្មែរ និងចាម្ប៉ា ដែលធ្លាប់បានចុះសន្ធិសញ្ញាសម្ព័ន្ធមេត្រីជាមួយគ្នា កាលពីឆ្នាំ១០០០នៃគ្រិស្តសករាជ ។ ស្តេចខ្មែរ និងស្តេចចាម បានកេណ្ឌទ័ពទៅជួយចិនតាមសំណូមពរ ក៏ប៉ុន្តែត្រូវចាញ់អាណ្ណាមទៀត ដែលជាហេតុធ្វើឲ្យចិនត្រូវសុំចរចារកសន្តិភាព ។ រឿងចម្បាំងជាមួយអាណ្ណាមនេះ ថ្វីបើមិនមានសិលាចារឹកខ្មែរឬចាម ឬឯកសារប្រវត្តិសាស្ត្រ អាណ្ណាមណាមួយបានលើកឡើងក៏ដោយ ក៏ប៉ុន្តែប្រហែលជាកើតមានឡើងមែន ពីព្រោះថា ឯកសារប្រវត្តិសាស្ត្រចិន ជាឯកសារដែលហ្មត់ចត់ជាងគេនៅអាស៊ីបុងបូព៌ា ។

ព្រះបាទហស៍វរ្ម័នទី៣ បានសុគតទៅនៅឆ្នាំ១០៩០ ហើយទ្រង់មានព្រះមរណនាមថា សទៈសិវបទ ។

## ១០- ព្រះបាទជ័យវរ្ម័នទី៧ (១០៩០-១១០៩)

ព្រះរាជាដែលសោយរាជ្យបន្តពីព្រះបាទហស៍វរ្ម័នទី៣ គឺព្រះបាទស្រីជ័យវរ្ម័នទី៧ ដែលសោយរាជ្យបាន១៩ឆ្នាំ ចាប់ពីឆ្នាំ១០៩០មក ។

ព្រះអង្គគោរពបូជាព្រះវិស្ណុខ្លាំងណាស់ ហើយទ្រង់ក៏ជាបូជនីយេសក៍ដ៏ស្មោះស្ម័គ្រម្នាក់ផងដែរ ។

សិលាចារឹកវត្តភូ បានរៀបរាប់ថា នៅក្នុងរជ្ជកាលព្រះរាជាមុនៗ មាននារីម្នាក់ឈ្មោះថា ទិលកៈ និងអ្នកប្រាជ្ញគម្ពីរវេទម្នាក់ឈ្មោះថា សុភទ្រៈ ដែលគេហៅក្រៅថា នាមៈសិវយៈ ។

នាងទិលកៈជាបុត្រីរបស់អ្នកប្រាជ្ញម្នាក់នៅក្នុងព្រះរាជវាំង ហើយជីតារបស់នាងជាទស្សនវិទូដ៏ល្បីល្បាញម្នាក់ ។ មាតារបស់នាងជាបុត្រីរបស់កវីម្នាក់ ។ នាងមានសម្ផស្សល្អស្អាត មានចរិយារម្យទម និងមានទេពកោសល្យខ្ពស់ សមនឹងត្រកូលខ្ពង់ខ្ពស់របស់នាង ។ បណ្ដាអ្នកប្រាជ្ញល្បីល្បាញទាំងឡាយ កោតសរសើរល្បិចដ៏ឈ្លាសវៃរបស់នាងក្នុងការជជែកពិភាក្សា ហើយបានដាក់ឈ្មោះឲ្យនាងថា ភគវតីវាគិស្វរី មានន័យថា ទេពកញ្ញាខាងវោហារ ។

នាងទិលកៈនេះ បានត្រូវមាតាបិតារៀបចំទុកដាក់ជាភរិយារបស់អ្នកប្រាជ្ញ សុភទ្រៈ ហើយនាងមានបុត្រម្នាក់ជាមួយស្វាមីនេះ ដែលនាងដាក់ឈ្មោះថា បូជសិវៈ តែអ្នកផងហៅថា សុភទ្រៈ ដូចឪពុកដែរ ។

សុភទ្រៈនេះ ខិតខំរៀនសូត្រទ្រឹស្តីនៃសាសនាព្រះសិវៈខ្លាំងណាស់ ហើយដោយប្រាជ្ញាដ៏ឈ្លាសវៃរបស់ខ្លួន ពូកែដាច់គេក្នុងការប្រមូលអត្ថបទអក្សរសាស្ត្រចាស់ៗយកមកចងក្រងឡើងវិញ ដែលគ្មានបណ្ឌិតណាម្នាក់មានសមត្ថភាពនឹងធ្វើដូចបាន ។ កវីបណ្ឌិតធំៗ កោតសរសើរស្នាដៃដ៏គ្មានដឹមនេះ ។ ថ្ងៃមួយ មានការជជែកពិភាក្សាមួយធំនៅចំពោះព្រះភ័ក្ត្រព្រះបាទជ័យវរ្ម័នទី៧ សុភទ្រៈ បានទទួលជោគជ័យក្នុងការឆ្លើយដោះស្រាយនូវ

សំណួរដ៏លំបាកៗទាំងឡាយ ដែលគូបដិបក្ខរបស់ខ្លួនបើកសៀវភៅចោទសួរឡើង "ដោយសារប្រាជ្ញាដ៏ខ្លាំងក្លាប្រៀបបាននឹងកាំរន្ទះ" ។

ចាប់តាំងពីពេលនោះមក សុភទ្រៈ ត្រូវបានប្រជានុរាស្ត្រទូទាំងព្រះនគរគោរពកោតខ្លាច ហើយត្រូវព្រះរាជាចាត់តាំងឲ្យធ្វើជាអធិការលើអាស្រមភាវនា បូជនីយស្ថានទាំងអស់ និងជាអាជ្ញាកណ្តាលលើរាល់ការពិភាក្សាអំពីផ្លូវធម៌ និងផ្លូវលោក ។ ព្រះរាជាក៏បានប្រទានរយាមាស ខ្សែមាស និងគ្រុណាត់ល្អៗ ។ល។ ឲ្យផងដែរ[១១] ។

សិលាចារឹកសំរោងបានរៀបរាប់ថា នៅក្រោមរាជ្យព្រះបាទជ័យវរ្ម័នទី៧ មានការផ្តួលរំលំបដិមាព្រះនារាយណ៍ ព្រះភគវតី និងសិវលិង្គមួយ រួចមានបញ្ជាឲ្យកសាងបដិមាទាំងអស់នោះឡើងវិញ ។ ដូចយើងបានឃើញពីខាងលើរួចមកហើយថា កាលពីរជ្ជកាលព្រះបាទសុរិយាវរ្ម័នទី១ ក៏មានហេតុការណ៍បែបនេះកើតឡើងដែរ គឺមានការផ្តួលរំលំព្រះពុទ្ធបដិមា ហើយព្រះរាជាមានការលំបាកជាខ្លាំងនឹងការពារកុំឲ្យ "មនុស្សកាចឃោរឃៅ" បៀតបៀនព្រះសង្ឃសូត្រធម៌ ។ ទាំងអស់នេះជាការបញ្ជាក់ថាប្រទេសមានភាពរីករវរខាងសាសនា ជាពិសេសព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនា ។ ខ្ញុំគិតថានោះហើយជាមូលហេតុដែលនាំឲ្យមានការជ្រែករាជ្យ និងសង្គ្រាមផ្ទៃក្នុង ។

ព្រះបាទជ័យវរ្ម័នទី៧ សុគតនៅឆ្នាំ១១០៩ ហើយទ្រង់មានព្រះមរណនាមថា បរមកវីល្យៈ មានន័យថាទ្រង់ជាភ្ញៀវរបស់លោកនៃបរមសុភមង្គល ។

## ១១- ព្រះបាទធរណិន្ទ្រវរ្ម័នទី១ (១១០៩-១១១២)

ព្រះបាទធរណិន្ទ្រវរ្ម័នទី១ ដែលត្រូវជាព្រះរៀមរបស់ព្រះបាទជ័យវរ្ម័នទី៧ បានឡើងសោយរាជ្យបន្ត នៅឆ្នាំ១១០៩នៃគ្រិស្តសករាជ ត្រូវនឹងឆ្នាំ១០៣១នៃមហាសករាជ ។ ព្រះអង្គមិនចង់សោយរាជ្យទេ ហើយបើតាមសិលាចារឹក ទ្រង់បានបដិសេធម្តងរួចមកហើយ នៅពេលដែលព្រះបាទហស៌វរ្ម័នទី៣ ជាព្រះរៀមសោយទិវង្គត ។ ក៏ប៉ុន្តែ ដោយមានការស្នើសុំយ៉ាងទទូចពីប្រជានុរាស្ត្រ ព្រះអង្គ ក៏យល់ព្រម "ទទួលយកនូវបន្ទុកដ៏ធ្ងន់" នេះ ។ ព្រះអង្គបានដឹកនាំព្រះនគរដោយប្រុងប្រយ័ត្ន និងយុត្តិធម៌ខ្លាំងណាស់ ជាពិសេស គឺបានយកព្រះទ័យទុកដាក់ចំពោះសុខុមាលភាពរបស់វណ្ណៈទាំង៧ ដែលមាននៅក្នុងស្រទាប់ប្រជាជននាសម័យនោះ គាប់ជួនជាប្រទេសមានសុខសន្តិភាព ហើយព្រះអង្គក៏មានព្រះជន្មចំណាស់ផង ។

---

[១១] សៀវភៅរបស់លោក អែម៉ូនីញេ មានឈ្មោះថា កម្ពុជា ក្បាលទី២, ទំព័រ១៦៧-១៦៨ តាមការបកប្រែរបស់វេជ្ជបណ្ឌិតកែន ។

ព្រះអង្គជាមិត្តនៃច្បាប់ ក៏ប៉ុន្តែមុននឹងអនុវត្តច្បាប់ ព្រះអង្គសព្វព្រះទ័យឲ្យអ្នកប្រាជ្ញបណ្ឌិត សុភទ្រៈ ដែលចេះចាំអក្សរសិល្បគ្រប់បែប ធ្វើការបកស្រាយពន្យល់សិន[១៧] ។

ព្រាហ្មណ៍ដែលរៀបចំអភិសេកព្រះបាទធរណិន្ទ្រវរ្ម័ន គឺបណ្ឌិតទេវការៈ ជាវីរជនម្នាក់ដែលមានឥទ្ធិពលតាំងតែពីរជ្ជកាលព្រះបាទសុរិយាវរ្ម័ទី១មក ហើយធ្លាប់បានធ្វើការអភិសេកព្រះរាជាពីរព្រះអង្គមុននេះ រួចមកហើយ និងត្រូវរៀបចំការអភិសេកព្រះរាជាដែលត្រូវសោយរាជ្យបន្តគឺព្រះបាទសុរិយាវរ្ម័នទី២ថែមទៀត ។

ព្រះបាទធរណិន្ទ្រវរ្ម័ន បានបោះបង់រាជសម្បត្តិក្រោយពីដឹកនាំប្រទេសបាន៣ឆ្នាំ ។ ព្រះអង្គមានព្រះមរណនាមថា បរនិស្កាលៈបទៈ ។

## ១២- ព្រះបាទសុរិយាវរ្ម័នទី២ (១១១២-១១៦២)

ព្រះរាជាដែលសោយរាជ្យបន្តពីព្រះបាទធរណិន្ទ្រវរ្ម័នទី១ គឺព្រះបាទស្រីសុរិយាវរ្ម័ន ដែលត្រូវជាព្រះនត្តារបស់ព្រះអង្គ ហើយក៏ប្រហែលត្រូវជាចៅរបស់ព្រះបាទជ័យវរ្ម័នទី៧ ផងដែរ ពីព្រោះថា ព្រះបាទធរណិន្ទ្រវរ្ម័នបានយកក្មួយស្រីខ្លួនឯង ជាបុត្រីរបស់ព្រះរៀមព្រះអង្គធ្វើជាព្រះជាយា ។

នៅពេលដែលឡើងគ្រងរាជសម្បត្តិ ព្រះបាទសុរិយាវរ្ម័ន មិនទាន់ពេញវ័យ ហើយមិនទាន់បានបញ្ចប់ការសិក្សានៅឡើយទេ ។ សិលាចារឹកបានលើកពីព្រះអង្គថា «ជាវីរបុរសដែលប្រៀបបានទៅនឹងព្រះអាទិទេពនៃសង្គ្រាម ដែលជាបដិបក្ខដ៏គួរឲ្យភ័យខ្លាចរបស់ព្រះរាជាក្នុងពីររជ្ជកាលមុន» ។ តើព្រះអង្គទទួលរាជ្យសម្បត្តិក្រោយពីព្រះបាទធរណិន្ទ្រវរ្ម័ន សុគតទៅ ឬមួយក៏ដោយការប្រយុទ្ធ? តាមមើលទៅ ព្រះអង្គប្រហែលជាមិនប្រកួតប្រជែងជាមួយព្រះរាជាដែលកំពុងសោយរាជ្យទេ តែត្រូវប្រកួតប្រជែងជាមួយរជ្ជទាយាទមួយអង្គណាផ្សេង ដែលមានសិទ្ធិទទួលរាជសម្បត្តិច្រើនជាងព្រះអង្គ ។

ឯកសារប្រវត្តិសាស្ត្រចិនបាននិយាយថា ចាប់ពីឆ្នាំ១១២៨នៃគ្រិស្តសករាជរហូតមក ចិនមានដាក់តំណាងម្នាក់នៅនឹងរាជវាំងព្រះរាជាកម្ពុជានៅឯឥន្ទបត្ត គឺនគរធំ ។ តាមពិតតំណាងនោះ គឺជារាជទូតចិន ដែលដាក់នៅកម្ពុជាសម្រាប់មួយរយៈកាលតែប៉ុណ្ណោះ មិនមែនជាអ្នកត្រួតពិនិត្យ ជាអធិការ ឬក៏ជាទីប្រឹក្សា ហើយក៏មិនមែនជាអ្នកការពារអ្វីដែរ ។ ឯកសារចិនក៏បានរៀបរាប់ផងដែរថា កម្ពុជានាពេលនោះបានបាត់បង់ភាពថ្កុំថ្កើងពីអតីតកាលអស់ហើយ ក៏ប៉ុន្តែខ្ញុំគិតថា ដូចជាមិនត្រូវ ព្រោះថា គឺសង្គ្រាមនៅពេលមួយឆ្នាំក្រោយ នាដើម

[១៧] សៀវភៅរបស់លោក អែម៉ូនីញេ មានឈ្មោះថា កម្ពុជា ក្បាលទី២ ត្រង់សិលាចារឹកព្រះគោ, ទំព័រ១៦៨ តាមការបកប្រែរបស់វេជ្ជបណ្ឌិត កែន ។

សតវត្សរ៍ទី១១ទេ ដែលធ្វើឲ្យប្រទេសមានឱនភាព ។

តែទោះជាយ៉ាងណាក៏ដោយ ព្រះបាទសុរិយាវរ្ម័ន ត្រូវប្រឈមមុខនឹងការបះបោរនៅក្នុងប្រទេស ហើយនិងសង្គ្រាមជាមួយនគរចាមទៀត ។ ឯកសារចិនបាននិយាយថា នៅឆ្នាំ១១៥៨នៃគ្រិស្តសករាជ ត្រូវនឹងមហាសករាជ១០៧៦ ព្រះរាជាកម្ពុជាបានបង្រួបបង្រួមប្រទេសទាំងពីរ គឺកម្ពុជា និងចាម្ប៉ា មកតែមួយដូចកាលពីក្នុងរជ្ជកាលរបស់ព្រះបាទឥន្ទ្រវរ្ម័ន នាចុងសតវត្សរ៍ទី៩ដែរ ។

សិលាចារឹកពោធិនគររបស់ចាមបានឲ្យដឹងថា នៅក្នុងរជ្ជកាលរបស់ព្រះបាទស្រីជ័យហរិវរ្ម័ន ដែលឡើងសោយរាជសម្បត្តិនៅឆ្នាំ១១៤៥ រហូតដល់ឆ្នាំ១១៧០ ប៉ុន្តែក្រោយនោះផង "នគរចាម្ប៉ាត្រូវរងការវាយប្រហារពីទ័ពកម្ពុជា និងទ័ពវិជ័យ (គឺបិញឌិញ) យ៉ាងខ្លាំង" ។ ទ័ពចាមចាញ់ដៃនៅក្នុងវាលសាក្វាង ហើយទ័ពខ្មែរដណ្តើមបានរាជធានីវិជ័យ ។ ក្រោយពីបានលើកព្រះអនុជថ្លៃព្រះនាមហរិទេវៈ ឲ្យសោយរាជ្យនៅចាម្ប៉ា ក្នុងនាមជាព្រះយុវរាជ ឬឧបរាជ រួចមក ព្រះបាទសុរិយាវរ្ម័ន បានយាងត្រលប់មកកម្ពុជាវិញនៅឆ្នាំ១១៤៥ ។

ដប់បីឆ្នាំក្រោយមក នៅឆ្នាំ១១៥៨ ពួកចាមតាមខែត្របានបះបោរឡើងក្រោមការដឹកនាំរបស់មេគេ ហើយលើកគ្នាមកឡោមព័ទ្ធវាយព្រះយុវរាជ ដែលត្រូវបង្ខាំងឲ្យនៅតែក្នុងរាជធានី ការពារដោយទ័ពខ្មែរ និងចាមមួយចំនួនតូច ។ ពេលទទួលបានដំណឹងនេះ ព្រះបាទសុរិយាវរ្ម័ន បានដឹកនាំទ័ពធ្វើដំណើរកាត់ព្រំដែន ទៅជួយព្រះយុវរាជភ្លាម ។ ទ័ពទាំងពីរព្រួតគ្នាវាយទៅលើពួកបះបោរ ធ្វើឲ្យពួកនេះបរាជ័យនៅនឹងវាលវីរបុរៈ ។

នៅឆ្នាំបន្ទាប់មកទៀត ស្តេចចាមព្រះបាទស្រីជ័យហរិវរ្ម័ន ដែលត្រូវបណ្តេញចេញពីរាជសម្បត្តិកាលពីឆ្នាំ១១៤៥ បានលើកទ័ពមកវាយម្តងទៀត ហើយចាប់ព្រះយុវរាជបានជាឈ្លើយនៅលើវាលមហិ ។ ពេលនេះទ័ពខ្មែរ និងវិជ័យ ត្រូវបង្ខំឲ្យដកថយមកកម្ពុជាវិញ ហើយព្រះបាទស្រីជ័យហរិវរ្ម័ន ក៏ឡើងសោយរាជ្យសម្បត្តិនៅចាម្ប៉ា ជាថ្មី នៅឆ្នាំ១១៤៩ ។

ព្រះបាទសុរិយាវរ្ម័ន បានលើកទ័ពទៅដល់ "កោះដរី និងស្តាន់"ផងដែរ ។ លោកវេជ្ជបណ្ឌិត គែន បានផ្គូ "កោះដរី និងស្តាន់"នេះ ទៅនឹងកោះស្រីលង្កា ក៏ប៉ុន្តែ តាមមើលទៅ ប្រហែលជាមិនមែនទេ[១៣] ។

ព្រះបាទសុរិយាវរ្ម័ន មិនគ្រាន់តែជាស្តេចពូកែខាងចម្បាំងមួយមុខប៉ុណ្ណោះទេ ទ្រង់ក៏ប្រហែលជាអ្នកគ្រប់គ្រងរដ្ឋបាលដ៏ប៉ិនប្រសប និងជាអ្នកច្បាប់ម្នាក់ដែរ ហើយទ្រង់គោរពព្រះសិវៈផង ព្រះវិស្ណុផង និងជាពុទ្ធសាសនិកជនថែមទៀត ពោលគឺទ្រង់ប្រកបទៅដោយលក្ខណសម្បត្តិច្រើនយ៉ាង ។ តាមមើលទៅ ប្រហែលជាព្រះអង្គចេះ

---

[១៣] អ្នកខ្លះយល់ថាពាក្យថាកោះនេះ មើលទៅប្រហែលជាសំដៅយកបន្ទាយដែលមានកំពែងរឹងមាំទេ ។ ខ្ញុំគិតថា នោះគួរតែជាកោះនៅកណ្តាលសមុទ្រ មិនមែនជាកំពូលភ្នំណាមួយ នៅលើខ្ពង់រាបឥណ្ឌូចិននោះទេ ។

ធ្វើការជ្រើសរើសទៅតាមដំណើរបត់បែនរបស់សភាពការនយោបាយ ហើយទើបបានជា ព្រះអង្គ ខិតខំដូចជាព្រះរាជាមុនៗដែរ ដើម្បីធ្វើឲ្យសាសនាទាំងពីរលាយចូលគ្នាតែមួយ ក្នុងស្មារតីឲ្យចេះអត់ឱន យោគយល់គ្នា ធ្វើយ៉ាងណាជៀសវាងកុំឲ្យមានល្អក់កករខាងជំនឿសាសនា និងកុំឲ្យគេចោទព្រះអង្គថា មានលម្អៀងម្ខាងៗ ។

គេបានចាត់ទុកថាព្រះបាទសុរិយាវរ្ម័នជាអ្នកកសាងប្រាសាទដែលយើងហៅសព្វថ្ងៃថាអង្គរវត្ត ឬបើហោចណាស់ ក៏ថា ទ្រង់ជាអ្នកបានបញ្ជាឲ្យគេចាប់សាងសង់ប្រាសាទនេះដែរ ។ យើងនឹងបានឃើញនៅពេលបន្តិចទៀតថា គ្មានឯកសារណាដែលបញ្ជាក់ថា គំនិតនេះត្រឹមត្រូវនោះទេ ហើយនឹងឃើញថា មិនមែនដោយសារគេប្រទះឃើញរូបចម្លាក់របស់ព្រះអង្គ និងព្រះមរណនាមរបស់ព្រះអង្គ (បរមវិស្ណុលោក) នៅលើចម្លាក់រាក់មួយទើបគេអាចចាត់ទុកថាដូច្នេះបាននោះទេ ។ គេត្រូវការឲ្យមានភស្តុតាងផ្សេងក្រៅពីនេះ ដើម្បីបញ្ជាក់ថា ការចាត់ទុកដូច្នេះត្រឹមត្រូវ ។

**កំណត់ចំណាំ** ៖ ខ្ញុំគ្មានបំណងនឹងអះអាងថាព្រះរាជារបស់កម្ពុជាពីរព្រះអង្គក្រោយនេះគឺជាព្រះរាជាទី៨ និងទី៩ ដែលមានចែងនៅក្នុងរាជពង្សាវតាររបស់កម្ពុជាបុរាណ ដែលខ្ញុំមានក្នុងដៃបីច្បាប់ដែរនោះទេ ។ តាមមើលទៅ រាជពង្សាវតារនេះមិនសូវត្រឹមត្រូវប្រាកដប្រជាប៉ុន្មានទេ ហើយខ្ញុំសង្ស័យថា នោះគឺគ្រាន់តែជាកម្រងរឿងនិទាន ដែលមានការពិតត្រឹមតែខ្លះៗប៉ុណ្ណោះ ប៉ុន្តែបានត្រូវគេចងក្រងរៀបចំតាមលំដាប់ពេលវេលាប្រកបទៅដោយស្មារតីប្រុងប្រយ័ត្ន ។ តែខ្ញុំចង់បញ្ជាក់ថា ព្រះបាទធរណិន្ទ្រវរ្ម័នទី២ និងព្រះបាទសុរិយាវរ្ម័នទី២ ដែលសោយរាជ្យបន្តបន្ទាប់គ្នានៅសតវត្សរ៍ទី១២នៅកម្ពុជា ធ្វើឲ្យយើងនឹកឃើញជាពិសេសដល់ព្រះបាទធរណិន្ទ្រា នៅក្នុងរាជពង្សាវតារដែលខ្ញុំមាន ហើយដែលមានច្បាប់មួយនោះ បានបន្ថែមព្រះនាមថា វរ្ម័ន ចុងក្រោយថ្វាយ និងនឹកឃើញដល់ព្រះរាជាមួយព្រះអង្គទៀត គឺព្រះបាទអាទិត្យវរ្ម័ន ។ គេដឹងហើយថានៅក្នុងភាសាខ្មែរ សុរិយា និងអាទិត្យ សំដៅយកព្រះអាទិត្យដូចគ្នា ។

## ១៣- ព្រះបាទធរណិន្ទ្រវរ្ម័នទី២ (១១៦២-១១៦៣)

ព្រះរាជាដែលសោយរាជសម្បត្តិបន្តពីព្រះបាទសុរិយាវរ្ម័នទី២ គឺព្រះរៀម ឬព្រះអនុជជីដូនមួយ របស់ព្រះអង្គមួយអង្គ ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបុត្រីរបស់ព្រះបាទហស៍វរ្ម័នទី៣ ។ ព្រះរាជាអង្គនោះបានឡើងគ្រងរាជបល្ល័ង្កនៅឆ្នាំ១១៦២ ដោយទទួលព្រះអភិសេកនាមថា ព្រះស្រីធរណិន្ទ្រវរ្ម័ន ហើយហាក់ដូចជាសោយរាជសម្បត្តិបានតែប៉ុន្មានខែប៉ុណ្ណោះ ។

## ១៤- ព្រះបាទជ័យវរ្ម័នទី៧ (១១៦២-១២០១)

ព្រះបាទជ័យវរ្ម័ន បានឡើងសោយរាជសម្បត្តិបន្តពីព្រះបាទធរណិន្ទ្រវរ្ម័ន ជាព្រះបិតា នៅឆ្នាំ១១៦២ ។

សិលាចារឹកមួយនៅប្រាសាទអង្គរវត្ត បានរៀបរាប់ថា ព្រះអង្គ បានជ្រើសរើសយកព្រាហ្មណ៍ រិធ្វេសរិធៈ ជាហោរា ហើយបានអភិសេកព្រះអនុជជាព្រះយុវរាជ ដើម្បីឲ្យគេជ្រើសរើសព្រះអនុជនោះ សោយរាជសម្បត្តិបន្តពីព្រះអង្គ ។

នៅក្រោមរជ្ជកាលស្តេចអង្គនេះ សង្គ្រាមជាមួយនគរចាម្ប៉ា បានឆាបឆេះឡើងវិញ ដោយកំហុសរបស់ស្តេចចាម ព្រះបាទស្រីហរិវរ្ម័នទី១ ដែលបានធ្វើការឈ្លានពានបណ្តាខេត្រខាងត្បូងរបស់តុងកឹង, នគរវិជ័យ -បិញឌិញ[១៤] -ដែលជាទីតាំងរាជធានី, នគរផានរ៉ាង ដែលមានស្តេចចាមជ្រែករាជ្យមួយអង្គ ឬក៏ស្តេចស្នងបន្តមួយអង្គសោយរាជ្យ និងវាយកម្ពុជាផងដែរ ដោយចូលរហូតមកដល់ជិតរាជធានីឥន្ទបត្ត ។ ក្រោយពីបានដុតបំផ្លាញរួចហើយ ពួកចាមមិនបានបន្តដំណើរទៅឆ្ងាយពីព្រំប្រទល់ដែនរបស់ខ្លួនទេ តែបានត្រលប់ទៅស្រុកវិញដោយនាំយកទៅជាមួយនូវជ័យភណ្ឌជាច្រើន ។

លោក ហ្គេប៊ឺល នៅក្នុងសៀវភៅរបស់គាត់ឈ្មោះថា កំណត់សម្គាល់ស្តីអំពីកូសាំងស៊ីន បាននិយាយថា ស្តេចខ្មែរពេលនោះសម្ងំធ្វើមិនដឹងមិនឮយូរណាស់ រហូតទាល់តែដល់១៨ឆ្នាំក្រោយមក គឺនៅឆ្នាំ១១៩៧ ទើប "ព្រះអង្គលើកទ័ពមកវាយកម្ទេចកូសាំងស៊ីន (គឺនគរចាម្ប៉ា) ចាប់ស្តេចចាមជាឈ្លើយ បំផ្លិចបំផ្លាញខ្ទេចខ្ទី រួចលើកឧកញ៉ាខ្មែរម្នាក់ឲ្យសោយរាជ្យ មុននឹងដកទ័ពថយមកវិញ ។ សិលាចារឹកតាព្រហ្មបានឲ្យដឹងថា ព្រះអង្គ ក៏បានដោះលែងស្តេចចាមឲ្យមានសិទ្ធិសេរីភាពឡើងវិញផងដែរ ដែលជាហេតុធ្វើឲ្យព្រះរាជាទាំងឡាយ ទៅជាវង្វេងវែងយល់ "នៅពេលដែលឃើញអំពីវិសេសភាពនៃព្រះរាជអាកប្បកិរិយានេះ" ។

សិលាចារឹកចាមនៅមីសឺន និយាយថា ព្រឹត្តការណ៍នេះ កើតឡើងនៅមហាសករាជ១១១២ ត្រូវនឹងគ្រិស្តសករាជ១១៩០ គឺមុនឯកសារខ្មែរ៧ឆ្នាំ ។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបរបស់អត្ថបទសិលាចារឹក ដែលលោក ហ៊ុំណូ ក៏បានបកប្រែ ៖

ស្តេចចាមព្រះនាមជ័យឥន្ទ្រវរ្ម័នអុងវ៉ាំងទូ[១៥] ជាអ្នកបង្កសង្គ្រាម ។ ពេលនោះ មេទ័ពកម្ពុជា គឺជាជនជាតិចាមមួយរូបដែលស្តេចខ្មែរបានយកមកចិញ្ចឹម និងតែងតាំងជាព្រះយុវរាជ (សម្រាប់នគរចាម្ប៉ា) មានឈ្មោះថា ស្រីវិធ្យនន្ទៈ មានកំណើតដើមចេញមកពីទុំប្រូក-វិជ័យ ។ ស្តេចចាមនាំទ័ពចេញមកជួបនឹងទ័ពខ្មែរនៅក្នុងវាលចាក្លាង ហើយត្រូវបរាជ័យ ។ ខ្មែរដណ្តើមយករាជធានីវិជ័យ (គឺបិញឌិញ) បាន រីឯស្តេចចាមត្រូវចាប់បានជាឈ្លើយ

[១៤] ខ្ញុំចាត់ទុក ផានរ៉ាង ថាជារដ្ឋសម្ព័ន្ធមេត្រី ជាជាងខេត្រមួយចំណុះឲ្យចាម្ប៉ា ។

[១៥] លោក ហ៊ឺណូត៍ និយាយថាស្តេចនោះ "ជាស្តេចជ្រែករាជ្យ" ក៏ប៉ុន្តែគ្មានហេតុការណ៍ណាបញ្ជាក់ទេ ហើយអត្ថបទរបស់គាត់ធ្វើឲ្យគេធ្វើការសន្និដ្ឋានបានច្រើនយ៉ាង ។ ឈ្មោះ អុងវ៉ាំងទូ ប្រហែលជាឈ្មោះសាមញ្ញ រីឯជ័យឥន្ទ្រជាឈ្មោះពេលអភិសេក ។

បញ្ជូនមកកម្ពុជា ។

នៅពេលនោះ ឧត្តមសេនីយ៍ខ្មែរ គឺព្រះយុវរាជ ក៏បានលើកព្រះអង្គម្ចាស់ អ៊ិន ដែលត្រូវជាព្រះអនុជថ្លៃរបស់ព្រះរាជាកម្ពុជា ឲ្យឡើងសោយរាជ្យក្រោមព្រះនាមថា សុរិយជ័យវរ្ម័ន រួចហើយខ្លួនឯងសោយរាជ្យនៅឯរាជបុរៈ(ផានរ៉ាង) មានព្រះនាមថា សុរិយាវរ្ម័ន[១៦] ។

ស្តេចនៅវិជ័យ (ប៊ិញឌិញ) ពោលគឺ ព្រះអនុជថ្លៃរបស់ព្រះបាទជ័យវរ្ម័នទី៨ មិនទាន់សោយសុខនឹងរាជសម្បត្តិយូរប៉ុន្មានផង ក៏ត្រូវរាជវង្សចាមមួយអង្គឈ្មោះ រាសូបតិ ដេញកម្ចាត់ចេញពីរាជធានី ហើយឡើងសោយរាជ្យខ្លួនឯងក្រោមឈ្មោះថា ជ័យឥន្ទ្រវរ្ម័ន ។

បន្ទាប់ពីមានព្រឹត្តការណ៍នេះ កងទ័ពខ្មែរត្រូវបង្ខំចិត្តចាកចេញពីនគរចាម្ប៉ា ប៉ុន្តែ ទ័ពមួយកងដែលនៅឯរាជបុរី (ផានរ៉ាង) ជាមួយនឹងស្តេចសុរិយាវរ្ម័ន-វិធ្យនន្ទ ប្រហែលជាមិនបានត្រលប់មកកម្ពុជាវិញទេ ។ កងទ័ពទាំងអស់នោះ បានវិលត្រលប់ទៅចាម្ប៉ាវិញនៅពេលក្រោយមក តែម្តងនេះ ដឹកនាំដោយស្តេចចាម ដែលសោយរាជ្យនៅវិជ័យពីមុន គឺព្រះបាទឥន្ទ្រវរ្ម័នវ៉ាទូ ដែលត្រូវនាំយកមកកម្ពុជាជាឈ្លើយ ប៉ុន្តែត្រូវបានព្រះរាជាកម្ពុជាទុកព្រះទ័យ ហើយចាត់ឲ្យត្រលប់ទៅរំដោះនគរចាម្ប៉ាវិញ ។ ពេលមកដល់នគរចាម្ប៉ា ឥន្ទ្រវរ្ម័នវ៉ាទូ បានអំពាវនាវសុំជំនួយពីស្តេចរាជបុរី ។ ស្តេចរាជបុរីសុរិយាវរ្ម័នបានលើកទ័ពវាយលុកដណ្តើមយកវិជ័យបានមុន ចាប់ស្តេចជ័យឥន្ទ្រវរ្ម័នរាសូបតិធ្វើឃាត រួចហើយប្រកាសខ្លួនឯងជាព្រះរាជា ។

ឥន្ទ្រវរ្ម័នវ៉ាទូខូចចិត្តជាខ្លាំងនឹងការប្រព្រឹត្តរបស់សុរិយាវរ្ម័ន ហើយប្រហែលជាត្រូវកងទ័ពខ្មែរបោះបង់ចោលផង ក៏គេចខ្លួនទៅនៅឯអមរាវតី គឺក្វាងណាមសព្វថ្ងៃ បង្កទ័ព រួចវិលមកវាយវិជ័យដែលស្តេចផានរ៉ាង គង់នៅ ។ វ៉ាទូ ត្រូវសុរិយាវរ្ម័នធ្វើឃាតបាននៅក្នុងការប្រយុទ្ធមួយនៅពេលក្រោយមក ។ ពេលនោះ ព្រះរាជាកម្ពុជាបានយល់អំពីអំពើក្បត់របស់អតីតយុវរាជ ក៏បញ្ជូនទ័ពទៅបង្ក្រាប តែត្រូវបរាជ័យ ។ ទោះជាយ៉ាងណាក្តី ស្តេចសុរិយាវរ្ម័នបានបោះបង់រាជធានីវិជ័យចោល ត្រលប់ទៅសោយរាជ្យនៅឯផានរ៉ាងវិញ ដោយទុករជ្ជទាយាទប្អូនអង្គ នៅសោយរាជ្យបន្តបន្ទាប់គ្នានៅលើរាជបល្ល័ង្កវិជ័យ ។

ឯកសារពង្សាវតារអាណ្ណាមបាននិយាយថា ស្តេចនេះបានបញ្ជូនរាជទូតទៅគាល់ស្តេចអាណ្ណាម លីអាញ់តុង នៅឆ្នាំ១១៩០ ដែលបានច្បាំងមានជ័យជម្នះលើជនក្បត់ម្នាក់ ដែលចង់ធ្វើខ្លួនថា ជារាជបុត្រស្តេច ហើយនិងឧត្តមសេនីយ៍ក្បត់ម្នាក់ ។

---

[១៦] ហេតុការណ៍នេះបញ្ជាក់អ្វីដែលបានអះអាងខាងលើ ៖ ព្រះយុវរាជមិនបានបង្កើតរដ្ឋមួយថ្មីទេ គឺសោយរាជ្យនៅរាជបុរីមួយដែល មានរួចមកហើយ ។

ឯកសារប្រវត្តិសាស្ត្រចិន បានលើកអំពីរាជទូតកម្ពុជាម្នាក់ ដែលនាំសួយសារអាករទៅថ្វាយស្តេចចិននៅឆ្នាំ១២០០ ។

ឆ្លៀតឱកាសដែលចាមឈ្លានពានកម្ពុជា និងការធ្វើសង្គ្រាមអូសបន្លាយមិនចេះចប់ ក្សត្រប្រទេសចំណុះទាំងឡាយនៅខាងជើងស្រុកខ្មែរបានក្រោកទាមទារឯករាជ្យ ផ្តាច់ចំណងទាក់ទងជាមួយមហានគរ ។ ប៉ុន្តែព្រះបាទជ័យវរ្ម័នទី៨ បានលើកទ័ពបង្ក្រាប រហូតទៅដល់ចន្ទនបុរៈ (វៀងច័ន្ទ) , ស្រីធម្មគិរី (ហ្លួងប្រាបាង) ហើយចាប់ស្តេចនគរទាំងពីរឲ្យលើកសួយសារអាករមកថ្វាយ ។ ក្នុងពេលដែលព្រះរាជាកម្ពុជាស្ថិតនៅឆ្ងាយប្រមាណជា ៩០០ គីឡូម៉ែត្រ ពីរាជធានីដូច្នេះ មានទ័ពមជ្ឈិមមួយកងដែលស្ថិតនៅក្រោមបញ្ជារបស់ ព្រះកម្រតេង ជាអភិបាលនគររាជសីមា (កូរ៉ាត់) ឈ្មោះថា អញ្ញរាជេន្ទ្រវរ្ម័ន បានចាប់វាតអំណាចត្រួតត្រាលើរាល់អាណាខេត្រខាងលិច គឺត្រូវនឹងស្រុកសៀម[១៧]សព្វថ្ងៃ ។

តាមមើលទៅអាណាចក្រខ្មែរពេលនោះលាតសន្ធឹងហួសទឹកដីសុខោទ័យទៅទៀត ហើយក្សត្រប្រទេសដ៏ខ្លាំងពូកែមួយនេះក៏នៅចំណុះស្តេចខ្មែរផងដែរ បើហោចណាស់ក៏តាមផ្លូវការដែរ ទោះបីថាមានស្តេចថៃ សោយរាជ្យក៏ដោយ ។ គឺនៅសុខោទ័យនេះឯងដែលគេរកឃើញសិលាចារឹកខ្មែរមួយចំនួន ហើយនិងឯកសារ មានឈ្មោះថា ត្រៃភូមិ ដែលប្រហែលជាគេសរសេរនៅពាក់កណ្តាលទីមួយនៃសតវត្សរ៍ទី១៣ ត្រូវនឹងសតវត្សរ៍ទី១២នៃមហាសករាជ ។ ស្តេចអញ្ញរាជេន្ទ្រវរ្ម័ន ក៏ប្រហែលជាបានដឹកនាំទ័ពរហូតដល់ប្រទេសភូមាទៀតផង ។

ដូចជាព្រះរាជាមុនៗដែរ ព្រះបាទជ័យវរ្ម័នទី៨ មិនគ្រាន់តែជាស្តេចដែលពូកែខាងចម្បាំងប៉ុណ្ណោះទេ ប៉ុន្តែក៏ពូកែខាងការគ្រប់គ្រងប្រទេស និងជាអ្នកច្បាប់ម្នាក់ផងដែរ ។ សិលាចារឹកបានលើកឡើងថា “ព្រះអង្គបានប្រគល់អវយវៈទាំងអស់របស់ព្រះអង្គឲ្យគោព្រៃ” មានន័យថា ព្រះអង្គអនុវត្តនូវយុត្តិធម៌ ។ ទ្រង់យល់ដឹងនិងរំលែកទុក្ខលំបាករបស់ប្រជារាស្ត្រ ហើយបានចាត់ឲ្យកសាងមន្ទីរពេទ្យជាច្រើន នៅតាមទីក្រុង និងវត្តអារាមដែលមានគ្រូពេទ្យពីររូបនៅចាំព្យាបាលជំងឺវណ្ណៈទាំងបួន ជាមួយនឹងគិលានុបដ្ឋាកម្នាក់ គិលានុបដ្ឋាយិកាពីរនាក់ អ្នកកាន់ឃ្លាំងពីរនាក់ អ្នកដាំស្លពីរនាក់ ។ល ។

## ១៥- ព្រះបាទឥន្ទ្រវរ្ម័នទី៣ (១២០១)

ព្រះបាទឥន្ទ្រវរ្ម័នទី៣ ដែលត្រូវបានអភិសេកជាព្រះយុវរាជតាំងតែពីក្នុងរជ្ជកាលមុន បានឡើងសោយ-

---

[១៧] តាមមើលទៅ ទំនាបអាងទន្លេមេណាមខាងក្រោមបានត្រូវចិនហៅថា ឡូហូ ហើយអាងទន្លេមេណាមខាងលើដែលមានពួកសៀម ឬថៃ កាន់កាប់រួចទៅហើយ ចិនហៅថា សៀន ។

រាជ្យបន្តពីព្រះបាទជ័យវរ្ម័នទី៨នៅឆ្នាំ១២០១ ក្រោយពេលដែលកម្ពុជាបានបញ្ជូនរាជទូតទៅស្រុកចិនបន្តិច ។

ឯកសារប្រវត្តិសាស្ត្រចិនបានរៀបរាប់ថា ស្តេចអង្គនេះ បានវាយលុករាតត្បាតទឹកដីជាច្រើន ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ចិន ជាអាទិ៍គឺទឹកដីដែលស្ថិតនៅពីខាងជើងហ្វូងប្រាបាន ហើយស្តេចចិនបានបញ្ជូនទូតមកកម្ពុជានៅឆ្នាំ១២០៦ ដើម្បីសាកសួរមូលហេតុ ហើយស្តេចខ្មែរក៏យល់ព្រមបញ្ឈប់ការវាយប្រហារនោះ ។

ប្រមាណជា១២ឆ្នាំក្រោយមក ព្រះយុវរាជដែលដឹកនាំនគរចាម្ប៉ា ជំនួសព្រះរាជាកម្ពុជា បានឆ្លៀតឱកាសដែលមានសង្គ្រាមផ្ទៃក្នុងធ្វើឲ្យអាណ្ណាមចុះខ្សោយ ក៏រៀបចំទ័ពមួយកងមានចម្រុះខ្មែរចាម ហើយធ្វើការលុកលុយខែត្រង៉េអាន និងវាយទៅលើទ័ពអាណ្ណាមដែលចេញមកទប់ទល់ ។ ប៉ុន្តែពីរឆ្នាំក្រោយពីជោគជ័យនេះ គឺនៅឆ្នាំ១២២០ មិនដឹងជាដោយមូលហេតុអ្វី ស្រាប់តែព្រះយុវរាជបោះបង់នគរចាម្ប៉ាចោល ហើយដឹកនាំទ័ពត្រលប់ចូលមកកម្ពុជាវិញ ។ មកទល់នឹងពេលនោះ នគរចាម្ប៉ា បានស្ថិតនៅក្រោមអាណានិគមរបស់កម្ពុជា ហើយមានរាជវង្ស ខ្មែរសោយរាជ្យអស់ពេល ៣២ឆ្នាំគត់ ។

តាមមើលទៅ ប្រហែលជានៅដើមសតវត្សរ៍ទី១៣នោះ មានកើតការបះបោររបស់ពួកអ្នកស្រុកសៀម ហើយជាពេលដែលស្តេចថៃចាប់ផ្តើមបះបោរទាមទារឯករាជ្យដែរ[១៨] ។

បើទោះជាយ៉ាងណាក្តី នៅចុងសតវត្សរ៍ទី១៣ រាជទូតចិនបានរៀបរាប់ថាស្រុកខ្មែរពេលនោះខ្វះប្រជាជនអាស្រ័យដោយមានសង្គ្រាមមិនចេះចប់មិនចេះហើយជាមួយពួកសៀម ។ បើសិនជារឿងហេតុបានកើតមានដូច្នោះមែន នោះហើយជាមូលហេតុដែលនាំឲ្យបោះបង់នគរចាម្ប៉ាចោល ព្រោះខ្មែរត្រូវប្រមូលផ្តុំកម្លាំងទប់ទល់នឹងពួកសៀមវិញ ។

## ១៦- ព្រះបាទស្រីន្ទ្រវរ្ម័ន

ព្រះរាជាដែលសោយរាជ្យបន្តពីព្រះបាទឥន្ទ្រវរ្ម័នទី២គឺព្រះបាទស្រីន្ទ្រវរ្ម័ន ដែលប្រហែលជាព្រះអង្គគង់នៅ យសោធបុរៈ ដដែល ក៏ប៉ុន្តែគេមិនដឹងថា តើទ្រង់ឡើងសោយរាជ្យនៅឆ្នាំណា និងសុគតនៅឆ្នាំណាទេ ។

---

[១៨] គេប្រហែលជាត្រូវនិយាយឲ្យស្រួលស្តាប់ជាងនេះវិញថា គឺនៅសម័យនោះហើយដែលពួកថៃ បានមករស់នៅពាសពេញទឹកដីសៀមសព្វថ្ងៃ ដែលពីមុនជាទឹកដីរបស់ពួកមនខ្មែរ បានចាប់ផ្តើមបះបោរឡើងក្រោមការដឹកនាំរបស់ស្តេចសុខោទ័យ និងក្សត្រប្រទេសក្បែរខាងមួយចំនួន ។ បើដូច្នោះមែន ទឹកដីទាំងអស់នោះត្រូវបាត់បង់ ផុតពីដៃខ្មែរទៅ ដែលគេចាប់ផ្តើមចាត់ទុកថាជាសត្រូវវិញ ហើយប្រជារាស្ត្រ ត្រូវធ្លាក់ក្នុងអំណាចពួកថៃវិញម្តង ។

## ១៧- ព្រះបាទជ័យវរ្មៈទិបរមេស្វរៈ

ព្រះបាទជ័យវរ្មៈទិបរមេស្វរៈ ដែលសិលាចារឹកខ្លះហៅថា ជ័យវរ្មៈបរមេស្វរៈ បានឡើងសោយរាជ្យបន្តពីព្រះបាទស្រីន្ទ្រវរ្ម័ន ប៉ុន្តែគេមិនបានដឹងពីកាលវេលាទេ ។ ព្រះអង្គបានបង្ក្រាបពួកបះបោរ រួចបានធ្វើសង្គ្រាមជាមួយមហាអំណាចសត្រូវមួយ "ដែលទ្រង់បានដណ្តើមយករាជធានីយ៉ាងស្រួលដូចជាគេដកស្មៅ" ហើយ "ធ្វើឲ្យជ័យជម្នះព្រះអង្គមានរស្មីបីដូចជាបុស្បុកមួយ ដែលគេលើកឡើងនៅចន្លោះសត្រូវសិទ្ធពីរក្បាល" ។

គឺជាស្តេចមួយអង្គដែលមានកុសលល្អ "ប្រសើរជាងទាំងព្រះឥន្ទ្រទៅទៀត ដោយសារទ្រង់បានប្រោះព្រំពិភពលោកឥតឈប់ឈរដោយទឹកភ្លៀងនៃទេពកោសល្យរបស់ព្រះអង្គ ហើយទ្រង់សន្តោសប្រណីតែទៅតាមក្រមច្បាប់ដែលមានចែងនៅក្នុងគម្ពីរសាស្ត្រា និងក្រោយពីបានពិនិត្យហ្មត់ចត់" ប៉ុណ្ណោះ ។

ព្រះអង្គក៏ត្រូវបានគេចាត់ទុកថា ជាព្រះរាជាមួយអង្គដែលប្រកបទៅដោយកិត្តិគុណ ដោយនិយាយថា "ព្រះអង្គឈរ នៅពីលើសិរសានៃព្រះរាជាទាំងឡាយ" ហើយអំណាចរបស់ព្រះអង្គវាតរហូតទៅដល់មាត់សមុទ្រ ។

នេះគឺជាស្តេចចុងក្រោយដែលគេស្គាល់តាមសិលាចារឹក ហើយច្បាស់ណាស់ថាទ្រង់ជាព្រះរាជានៃសម័យកាលអាប់ឱន ជាព្រះរាជាទីចុងបញ្ចប់នៃមហាអាណាចក្រកម្ពុជាព្រហ្មញ្ញនិយម ។ ក៏ប៉ុន្តែ នៅក្នុងរជ្ជកាលរបស់ព្រះអង្គ រាជាណាចក្រខ្មែរនៅមានវិសាលភាពធំធេងនៅឡើយ គឺលាតសន្ធឹងពី អាត្តពឺ នៃនគរចម្ប៉ាពីខាងកើតទៅដល់ឈូងសមុទ្រសៀម និងទៅដល់ភ្នំភួងលួង នៅឯនាយទន្លេសាលូអង់ ពីខាងលិច ទៅដល់ព្រំប្រទល់ស្រុកចិនឆ្ងាយហួសហ្លួងប្រាបាង ហើយនៅខាងជើងរហូតដល់សមុទ្រចិន និងចំណុចកាម៉ង់ នៅខាងត្បូង ។ ទឹកដីអាណាចក្រកម្ពុជាពេលនោះធំណាស់ គឺមានប្រហែលជាមួយលានគីឡូម៉ែត្រក្រឡា ដែលបែងចែកចេញជាក្សត្រប្រទេសស្វយ័តប្រមាណជាម្ភៃ ក្សត្រប្រទេសទាំងនោះ ចំណុះ ឬក៏គ្រាន់តែទទួលស្គាល់អនុត្តរភាពរបស់ព្រះរាជាកម្ពុជាប៉ុណ្ណោះ ប៉ុន្តែរំដើបរំដួលខ្លាំងណាស់ ហើយត្រៀមខ្លួនជាស្រេចនឹងចាប់កាន់អាវុធតស៊ូ ដែលធ្វើឲ្យព្រះរាជាកម្ពុជាត្រូវវាយបង្ក្រាបជារឿយៗ ដើម្បីឃុំគ្រងទុកនៅក្នុងអំណាច ។ នៅសម័យដែលយើងបានឈានមកដល់នោះ វាហាក់ដូចជាថា ពួកក្សត្រប្រទេសទាំងអស់នោះ រង់ចាំតែពេលអាណាចក្រកម្ពុជាមានការបាក់បែកគ្នា នឹងអាលងើបក្រោករកសេរីភាព និងឯករាជ្យប៉ុណ្ណោះ ជាពិសេស គឺពួកសៀម ឬថៃ តែម្តង ដែលកម្រើកមុនគេ ។

## ១៨- ព្រះរាជាដែលគេមិនបានស្គាល់ព្រះនាម (១២៩០?-១៣០០?)

នៅក្រោមរជ្ជកាលរបស់ព្រះរាជាមួយអង្គ ដែលយើងមិនស្គាល់ព្រះនាម អាចនឹងនិយាយថា នៅក្រោមរាជ្យព្រះបាទជ័យវរ្ម័នបរមេស្វរៈ ជាព្រះរាជាដែលគេស្គាល់ក្រោយគេបង្អស់តាមសិលាចារឹក ឬក៏ថា នៅក្រោមរាជ្យរបស់ស្តេចដែលសោយរាជ្យបន្តពីព្រះអង្គ មានរាជទូតចិនមួយរូបមកដល់កម្ពុជា នៅឆ្នាំ១២៩៦ ។ ចិនម្នាក់

ដែលបានមកជាមួយដែរ ប៉ុន្តែមិនមែនជាសមាជិករបស់គណៈប្រតិភូ ឈ្មោះ ឈាវតាក្វាន់ បានសរសេរកំណត់ត្រាដ៏ចម្លែកមួយអំពីកម្ពុជា ដែលគេបានបកប្រែពីរលើកជាភាសាបារាំង[១៩] ។

ឈាវតាក្វាន់ហៅស្រុកខ្មែរថា ឆានឡា ឬឆេនឡា តែបាននិយាយថាគេក៏ហៅថា កានពូឆេ ផងដែរ ជាឈ្មោះដែលត្រូវនឹងពាក្យសំស្ក្រឹត កម្ពុជៈ សព្វថ្ងៃអានថា កម្ពុជា ។

អ្នកនិពន្ធបានធ្វើការរៀបរាប់គ្រួសៗអំពីរាជធានីអង្គរធំ និងថារាជវាំងមានប្រាសាទមាសមួយ មានកំពូលសម្រាប់ព្រះរាជាផ្ទំ ។ ប្រជារាស្ត្រទាំងប្រុសទាំងស្រីបួងសក់ ស្លៀកសំពត់ ព្រះរាជាពាក់មកុដដាំពេជ្រ និងមានព្រះហស្ត និងព្រះបាទលាបពណ៌ក្រហម ហើយកាន់ព្រះខ័នមាសពេលចេញពីព្រះបល្ល័ង្ក ។

ឈាវតាក្វាន់បានរៀបរាប់លម្អិតផងដែរអំពីទំនៀមទម្លាប់របស់អ្នកស្រុក អំពីការប្រសូត្រកូន ពិធីរៀបអាពាហ៍ពិពាហ៍ និងពិធីផ្សេងៗមុនរៀបអាពាហ៍ពិពាហ៍ ។ គាត់បាននិយាយពីពួកឈ្លួងដែលត្រូវបានគេយកមកធ្វើជាខ្ញុំបម្រើៈ ប្រាកដណាស់ថានោះគឺពួកជនដែលរស់នៅខែត្រកំពង់សោម ចន្ទគាប៊ុនរយ៉ង និងស្រុក ដែលស្ថិតនៅពីខាងកើត និងខាងត្បូងខែត្រទាំងអស់នោះ ។ គាត់បានប្រាប់អំពីតម្លៃដែលគេលក់ពួកនោះ និងនិយាយថាពួកនោះត្រូវគេមើលងាយមើលថោកខ្លាំងណាស់ បើឡើងផ្ទះត្រូវលូននឹងជង្គង់ ហើយដាក់ដៃសំពះលើថ្ងាស ។ ជនណាស្រលាញ់ស្រីជង នឹងត្រូវគេមើលងាយមើលថោកដូចពួកនោះដែរ ។

បន្ទាប់មក ឈាវតាក្វាន់ និយាយអំពីច្បាប់ ជំងឺឃ្លង់ ដែលកើតមានច្រើនដោយសារអ្នកស្រុកមានទម្លាប់ងូតទឹកក្រោយពីបានរួមសង្វាសនឹងគ្នារួច ។ មនុស្សស្លាប់គេយកទៅចោលក្នុងព្រៃឬដុត បើជាស្តេចវិញ គេយកសព ឬអដ្ឋិធាតុដាក់ក្នុងចេតិយ ។ ឈាវតាក្វាន់ក៏បានពិពណ៌នាអំពីកសិកម្ម និងពាណិជ្ជកម្ម ផលិតផលកសិកម្ម និងផលព្រៃឈើផងដែរ ។

គាត់បាននិយាយថា កម្ពុជាពេលនោះ មានក្សត្រប្រទេសចំណុះច្រើនជាងកៅសិប ភូមិនីមួយៗមានវត្តមួយ ហើយគេគោរពមេម្នាក់ដែលគាត់ហៅថាម៉ៃស៊ី ។ តាមមើលទៅពាក្យនេះ ប្រហែលជាការហៅមិនត្រូវនូវពាក្យមេ ។

បន្ទាប់មក គាត់និយាយអំពីទ័ពថ្មើរជើងដែលមានខ្លួនទទេ កាន់លំពែង និងខែល ប៉ុន្តែគ្មានធ្នូព្រួញ ហើយគ្មានអាវក្រោះឬមួកក្រាស់ពាក់ទេ ។ ត្រង់នេះហាក់ដូចជាមិនត្រូវ ព្រោះយើងបានឃើញពីខាងលើរួចហើយថា ធ្នូព្រួញបានត្រូវគេប្រើនៅក្នុងការប្រយុទ្ធ ហើយចម្លាក់រាក់នៅប្រាសាទអង្គរវត្ត បានបង្ហាញរូបអ្នក

[១៩] នេះជារឿងមួយគួរឲ្យសង្ស័យណាស់ ពីព្រោះគេត្រូវទទួលស្គាល់ថា មានស្តេចបីព្រះអង្គសោយរាជ្យនៅក្នុងសតវត្សរ៍ទី១៣ ដោយមួយអង្គៗសោយរាជ្យជាមធ្យម ចំនួន៣១ឆ្នាំ ។

ប្រយុទ្ធខ្លះមានពាក់អាវក្រោះ ហើយដៃឆ្វេងមានកាន់ខែលដែរ ។

ឈាវតាក្វាន់បានបញ្ចប់កំណត់ត្រារបស់គាត់ដោយនិយាយថា ព្រះរាជាកម្រនឹងយាងចេញពីរាជវាំងណាស់ ខ្លួនគាត់បានឃើញព្រះរាជាតែបួនប្រាំដងប៉ុណ្ណោះ ហើយវាហាក់ដូចជាព្រះអង្គខ្លាចគេធ្វើឃាត ។ ព្រះកាយរបស់ព្រះរាជាមានពាសក្រោះដែក ។ ពេលយាងទៅណាមកណា ទ្រង់គង់លើគ្រែស្នែងដែលសែងដោយនារីបួននាក់ ហើយជនទាំងអស់ដែលស្ថិតលើផ្លូវត្រូវក្រាបថ្វាសដល់ដី ។ ត្រង់នេះ ឈាវតាក្វាន់ហៅថា សានពាស គឺសំពះ ។

ព្រះរាជាបើកសវនាការមួយថ្ងៃពីរដង ដើម្បីដោះស្រាយកិច្ចការប្រទេស ។ នាម៉ឺន និងប្រជារាស្ត្រ ដែលចូលមកគាល់ស្ដេចអង្គុយផ្ទាល់ដី ។ នៅខាងក្រៅឯណោះ សំឡេងភ្លេងចាប់បន្លឺឡើង គេផ្លុំស័ង្ខ រួចភីលៀង ចាប់បើកវាំងនន ។ ព្រះរាជាលេចព្រះភ័ក្ត្រនៅមាត់បង្អួច ព្រះហស្ដកាន់ព្រះខ័នមាស ។ ពួកអាមាត្យ លើកហត្ថប្រណម ហើយឱនក្បាលដល់ដីរហូតទាល់តែសំឡេងស័ង្ខចប់ ។ ពេលចប់សវនាការ ព្រះរាជាយាងត្រលប់ចូលប្រាសាទវិញ ភីលៀងទាំងពីរទម្លាក់វាំងនន រួចចាកចេញទៅ ។

តទៅនេះគឺជាការពិពណ៌នាអំពីក្បួនព្យុហយាត្រា នៅពេលដែលព្រះរាជាយាងចេញដោយដំរី ។ គេសង្កេតឃើញថា ការពិពណ៌នានេះ ប្រហាក់ប្រហែលនឹងក្បួនព្យុហយាត្រា ដែលគេប្រទះឃើញសព្វថ្ងៃ នៅភ្នំពេញ ឬនៅប្រទេសសៀម ពេលមានបុណ្យទានម្ដងៗដែរ ។ ជាពិសេស គឺសវនាការនៅពេលដែលព្រះរាជាទទួលអគ្គទូត ដូចដែលលោក ឡាលូប៊ែរ, បព្វជិតឈូស៊ី, ជីសូម៉ុង និងជីហ្វ័របាំង បានរៀបរាប់នៅចុងសតវត្សរ៍ ទី១៧ ។

«ពេលព្រះរាជាយាងចេញពីព្រះរាជវាំង ក្បួនដង្ហែចាប់ផ្ដើមដោយកងទ័ពសេះជាដំបូង ។ បន្ទាប់មក គឺក្រុមកាន់ទង់ និងក្រុមភ្លេង ។ ពួកស្រីភីលៀងមានពីបីរយទៅប្រាំរយនាក់ ស្លៀកស្បែកផ្កា សៀតផ្កាក្នុងសក់ កាន់ទៀនធំៗក្នុងដៃ ទៀនទាំងនោះដុតជាប់ជានិច្ច ទោះបីជាពេលថ្ងៃក៏ដោយ ។ បន្ទាប់មកគឺក្រុមភីលៀងកាន់ខបភោគភណ្ឌធ្វើអំពីមាស និងប្រាក់ និងគ្រឿងលម្អផ្សេងៗគ្រប់បែបគ្រប់ម៉ូត មិនដឹងថាសម្រាប់ធ្វើអ្វីខ្លះទេ ។ បន្ទាប់មកទៀត គឺក្រុមនារីកាន់លំពែង និងខែល ដែលជាកងរក្សាព្រះអង្គជាពិសេស ។ បន្ទាប់ពីនោះ គឺក្រុមរទេះចៀម រទេះសេះ តែងលម្អដោយមាស ។ រដ្ឋមន្ត្រី អ្នកអង្គម្ចាស់ សុទ្ធតែជិះដំរី ចេញដំណើរមុនមើលផ្លូវ បាំងក្លស់ពណ៌ក្រហម ។ បន្ទាប់ មកទៀត គឺក្រុមស្រីស្នំរបស់ព្រះរាជា អង្គុយលើគ្រែស្នែង ឬជិះរទេះ ឬដំរី ។

មានក្លស់ជាងមួយរយដែលតុបតែងដោយមាស ។ ក្រោយក្លស់ទាំងនោះ គឺព្រះរាជា គង់ឈរលើដំរី ព្រះហស្ដកាន់ព្រះខ័នមាស ។ សូម្បីតែភ្លុកដំរីក៏សុទ្ធតែលម្អទៅដោយមាសដែរ ។ មានក្លស់ប្រហែលជាម្ភៃដែលតែងលម្អទៅដោយមាស និងមានដងធ្វើអំពីមាស ។ ទ័ពដំរីមានដំរីជាច្រើននៅព័ទ្ធជុំវិញព្រះរាជា ។

# ជំពូកទី៩
# បដិវត្តន៍នៅសតវត្សរ៍ទី១៤

ខ្ញុំបានរៀបរាប់រំលងដោយចេតនានូវព្រឹត្តិការណ៍មួយ ដែលមានសារសំខាន់ណាស់ដែរ ។ ឥឡូវខ្ញុំសូមត្រលប់មករឿងនេះវិញ ។ អ្នកនិពន្ធចិនមិនបានប្រាប់ឲ្យយើងដឹងផងទេថាតើនរណាជាស្តេចសោយរាជ្យនៅកម្ពុជា នៅពេលដែលគាត់មកដល់នៅចុងសតវត្សរ៍ទី១៣ ហើយយើងក៏មិនដឹងថានរណាសោយរាជ្យ នៅពេលនោះដែរ ។ ក៏ប៉ុន្តែគាត់បាននិយាយថា ព្រះរាជាដែលកំពុងសោយរាជ្យនោះ ត្រូវជាបុត្រសុណិសារបស់ព្រះរាជាមុន ។ ព្រះអង្គបានចូលធ្វើទ័ពតាំងពីក្មេង រួចហើយបានរៀបអាពាហ៍ពិពាហ៍ជាមួយបុត្រីស្តេច ។ នៅពេលដែលបុត្រីស្តេចលួចព្រះខ័នរាជ្យពីព្រះបិតាយកមកឲ្យ ព្រះអង្គក៏ឡើងសោយរាជ្យទៅ[១] ។ ព្រះរាជាដែលធ្លាក់ពីរាជសម្បត្តិនោះ មានព្រះរាជបុត្រាមួយអង្គដែរ ប៉ុន្តែដោយគ្មានព្រះខ័នរាជ្យមិនអាចសោយរាជ្យបាន ទ្រង់ក៏កេណ្ឌទ័ពប្រឆាំងនឹងព្រះរៀមថ្លៃ ហើយត្រូវព្រះរាជាចាប់កាត់ម្រាមជើងចេញអស់ ជាហេតុធ្វើឲ្យរឹតតែគ្មានសិទ្ធិសោយរាជ្យណាស់ទៅទៀត រួចហើយត្រូវឃុំខ្លួនក្នុងគុកងងឹត ។ រឿងនេះប្រហាក់ប្រហែលគ្នានឹងរឿងនៅប្រទេសបារាំងសម័យរាជវង្សមេរ៉ូវាំងស៊ីយាង ដែលកាលណាគេកោរសក់ចេញអស់ហើយ មិនអាចសោយរាជ្យបានទេ ។

តើព្រះវង្សទាយាទដែលគេបណ្តេញចេញពីរាជសម្បត្តិ ដោយដកហូតព្រះខ័នរាជ្យនោះ ជានរណា ហើយតើព្រះរាជាដែលជ្រែករាជ្យ និងសោយរាជ្យនៅឡើយនៅឆ្នាំ១២៩៦នោះ ជានរណា? ទាំងអស់នេះ យើងមិនបានដឹងទេ ហើយប្រហែលជាសិលាចារឹកណាមួយដែលគេមិនទាន់រកឃើញ ឬមិនទាន់បានបកស្រាយ នឹងប្រាប់ឲ្យយើងដឹងនៅថ្ងៃក្រោយណាមួយមិនខាន ។

ប៉ុន្តែមានរឿងនិទានមួយដែលលោក ខូដាជឺឡាគ្រេ, មូរ៉ា និងអៃម៉ូនីញេ ប្រមែប្រមូលបាន មានគេនិយាយប្រាប់ខ្ញុំជាញឹកញយ ដែលខ្ញុំគិតថាគួរតែលើកយកមកនិយាយនាពេលនេះ ។ បើសិនជារឿងនេះមិនអាចបំពេញបាននូវចន្លោះខ្វះខាតចាប់ពីព្រះបាទជ័យវរ្ម័នបរមេស្វរៈ ដែលទ្រង់សោយរាជ្យនៅឆ្នាំ១២៤០ មកដល់ព្រះរាជាដែលឈាវតាក្វាន់ ជួបនៅឆ្នាំ១២៩៦ រឿងនេះប្រហែលជាអាចបំពេញចន្លោះខ្វះខាត ចាប់ពីឆ្នាំ១២៩៦ រហូតដល់ឆ្នាំ១៣៤០បាន គឺរហូតដល់ពេលដែលមានរាជពង្សាវតារកម្ពុជាសម័យទំនើប ។

---

[១] ដណ្តើមយកព្រះខ័នរាជ្យបាន ឬស្វេតច្ឆត្របាន បានន័យថាអាចសោយរាជ្យបានហើយ ។ ចំណុចត្រង់ដូចគ្នានឹងនៅប្រទេសឥណ្ឌាដែរ ៖ អ្នកណាអាចដណ្តើមឡើងអង្គុយលើរាជបល្ល័ងបាន គឺក្លាយជាស្តេចហើយ ។

តទៅនេះជាសាច់រឿងដែលធ្វើឲ្យយើងចាប់អារម្មណ៍[២] ៖ មានទឹកជំនន់ដ៏ធំចម្លែកមួយ ដែលគេយល់ថា បណ្ដាលមកពីព្រះរាជាកម្ពុជា បានបញ្ជាឲ្យគេសម្លាប់កូនរបស់ព្រាហ្មណ៍បុរោហិតម្នាក់ ។ ពេលនោះ ស្ដេចនគរអយុធ្យា បានចាត់ឲ្យចេញទូកជាច្រើនមកជួយស្រង់ស្ដេចខ្មែរ ព្រះកែវ និងគម្ពីរព្រះត្រៃបិដក ។ ទឹកជំនន់នោះក៏បានធ្វើឲ្យកងទ័ពចាម ដែលកំពុងតែរាតត្បាតចូលមកក្នុងកម្ពុជា ដកថយទៅស្រុកផាន់រី-ផានរ៉ាង វិញដែរ ។

ព្រះបាទសេនកៈ នៃកម្ពុជាទ្រង់សុគតទៅ ព្រះរាជបុត្រព្រះនាម ព្រះសីហនុរាជ ក៏ឡើងសោយរាជ្យបន្តគាប់ជួនទឹកស្រក ទ្រង់ក៏វិលត្រលប់មកគង់នៅរាជធានីឥន្ទបត្តវិញ[៣] ។ ព្រះរាជាអង្គនេះមានបុត្រីមួយព្រះអង្គ ព្រះនាមបទុម និងបុត្រីមួយព្រះអង្គទៀត ដែលយើងនឹងឃើញថា បានក្លាយជាព្រះអគ្គមហេសីរបស់ព្រះមហាក្សត្រដែលសោយរាជ្យបន្តពីព្រះអង្គ ។

នៅពេលនោះ មានអ្នកចម្ការមួយរូបឈ្មោះថា តាចាយ ដែលឯកសារពង្សាវតារមួយនោះ បានបញ្ជាក់ថា មានកំណើតដើមជាជនជាតិភាគតិចសំរែ ពូកែខាងដាំត្រសក់ផ្អែម ។ គេនាំគ្នាហៅគាត់ថា "នាយត្រសក់ផ្អែម" ដែលតែងតែយកត្រសក់មកថ្វាយព្រះរាជាសោយជាញឹកញយ ធ្វើឲ្យព្រះរាជាសព្វព្រះទ័យ ក៏បញ្ជាឲ្យគាត់ថែរក្សាផលដំណាំត្រសក់របស់គាត់ទាំងអស់ទុកថ្វាយព្រះអង្គ ។ នាយត្រសក់ផ្អែមទូលព្រះរាជាថា មានចោរតែងចូលលួចបេះត្រសក់ពេលយប់ ព្រះរាជាសីហនុរាជ ក៏ប្រទានលំពែងមួយទុកគ្រាន់យាមចម្ការ និងសម្លាប់នរណាដែលហ៊ានចូលមកលួចត្រសក់ លំពែងនោះសព្វថ្ងៃស្ថិតនៅក្នុងរាជវាំងភ្នំពេញ ។

ពេលបន្តិចក្រោយមក ព្រះរាជាចង់ដឹងថា តើតាត្រសក់ផ្អែមយាមកាមថែរក្សាដំណាំដែរឬទេ យប់មួយពេលស្ងាត់ ទ្រង់បានលួចចូលក្នុងចម្ការត្រសក់ ដោយមានតែមហាតលិកពីររូបតាមហែហមប៉ុណ្ណោះ[៤] ។ ប៉ុន្តែ

---

[២] មកដល់ត្រង់នេះ ខ្ញុំសូមជំរាបឲ្យដឹងអំពីការរកឃើញរបស់លោក ហ៊ូប៊ែ ដែលរកឃើញនៅភូមានូវរឿងព្រេងមួយ ដោយគាត់បានចម្លងជាអក្សរឡាតាំងហើយបកប្រែ រួចពិចារណាអំពីចំណុចដូចគ្នារវាងរឿងព្រេងខ្មែរ និងរឿងព្រេងភូមា ។ គាត់ក៏បានធ្វើការដកស្រង់នូវស្នាដៃភូមាមួយមានឈ្មោះថា សុធមនសារិម៉ាងសាមិធម្មាសាធព្រះធំ ។

រឿងនោះដូចគ្នាប្រហាក់ប្រហែលនឹងរឿងចៅត្រសក់ផ្អែម ដែលយើងនឹងនិទានតទៅនេះ ហើយគាត់បានកំណត់កាលបរិច្ឆេទនៅសតវត្សរ៍ទី១០ ចំណែកសេចក្ដីដកស្រង់វិញថា មានតាំងតែពីមុនសម័យព្រះពុទ្ធទៅទៀត ។ នៅក្នុងរឿងទាំងបី ស្ដេចមាននាមថា ស្ដេចពាល ។ ឃើញថា ការរកឃើញនោះ ហាក់ដូចជាធ្វើឲ្យប្រឫកប្របល់ណាស់ដែរ ។

សូមអានអត្ថបទនៅក្នុងព្រឹត្តិបត្រសាលាបារាំងចុងបូព៌ា (Bulletin de l' Ecole Française d' Extrème-Orient) ត្រង់ផ្នែក Les Etudes Indochinoises របស់លោក Hubert ក្បាលទី៥ ឆ្នាំ១៩០៥ទំព័រ១៧៦-១៨៤ ៖ Le Jardinier régicide qui devient roi ។

[៣] រឿងទឹកលិចរាជធានីឥន្ទបត្តនេះ បានស្ថិតជាប់ក្នុងការចងចាំរបស់អ្នកស្រុក មិនមែនថា មានលើកឡើងតែក្នុងរឿងព្រេងខាងលើនេះទេ ។ មានលិខិតមួយបញ្ជាក់ថា រឿងនេះកើតមានតាំងពីមុនទឹកធំនៅអង្គរធំទៅទៀត គឺមុនរឿងតាត្រសក់ផ្អែម ។

[៤] តាមការនិទានផ្ទាល់មាត់មួយ និយាយថាមហាតលិកទាំងពីរនោះជានារី ។

តាត្រសក់ផ្អែមដឹងទាន់ ហើយស្មានថា ព្រះរាជាជាចោរចូលមកលួចត្រសក់ ក៏ចោលលំពែងដែលព្រះរាជាប្រគល់ឲ្យនោះ ទៅត្រូវព្រះរាជាសុគតទៅ[៥] ។

ពេលនោះ នាម៉ឺនសព្វមុខមន្ត្រីប្រជុំគ្នារិះរកមនុស្សម្នាក់ឲ្យសោយរាជ្យ ដើម្បីកុំឲ្យរាជបល្ល័ង្កទំនេរ ដល់មិនដឹងថាត្រូវជ្រើសរើសយកនរណា ក៏សម្រេចលើកតាត្រសក់ផ្អែមឲ្យសោយរាជ្យតែម្តង ដោយថ្វាយព្រះនាមថា ព្រះបាទសម្តេចព្រះបរមមហាបពិត្រធម្មិកមហារាជាធិរាជ ហើយអភិសេកព្រះរាជបុត្រីច័ន្ទវរាវតី ជាព្រះអគ្គមហេសី មានព្រះនាមថា ស្រីចន្ទរាជ ។

ព្រះបាទសម្តេចព្រះបរមមហាបពិត្រធម្មិកមហារាជាធិរាជ មានព្រះរាជបុត្រពីរព្រះអង្គជាមួយព្រះអគ្គមហេសីនេះ គឺព្រះបរមនិព្វានបទ និងព្រះសិទ្ធានរាជា ។ ព្រះអង្គទ្រង់សោយរាជ្យបាន១៧ឆ្នាំ ទើបសុគតទៅក្នុងព្រះជន្ម ៧០ព្រះវស្សា ក្នុងឆ្នាំ១៣៤០ ។ ព្រះរាជបុត្រាច្បងសោយរាជបន្តពីព្រះបិតាបាន ៦ឆ្នាំ ក៏សុគតទៅទៀត ហើយត្រូវបានព្រះអនុជសិទ្ធានរាជាសោយរាជ្យសម្បត្តិបន្តនៅឆ្នាំ១៣៤៧ បើទោះបីថាព្រះអង្គមានព្រះរាជបុត្រាដល់ទៅពីរព្រះអង្គក៏ដោយ ។

រឿងនិទាននេះ បើទោះបីថា ជាការចម្លងយករឿងនិទានភូមា ឬក៏រឿងនិទានឥណ្ឌាដែលមានវ័យចំណាស់ជាង មកធ្វើជារឿងខ្មែរក៏ដោយ ក៏រឿងនេះអាចនឹងមានបង្កប់នូវព្រឹត្តិការណ៍ដ៏អាថ៌កំបាំងមួយ នៅរវាងឆ្នាំ ១៣២០ ឬ១៣២៥ ដែលមានព្រះរាជាមួយអង្គបានត្រូវគេធ្វើឃាត ហើយឃាតករនោះមិនមែនជាអ្នកចាំចម្ការត្រសក់ទេ តែជាមន្ត្រីម្នាក់ដែលមានដើមកំណើតជាជនជាតិភាគតិចសំរ៉ែ[៦] ។ រឿងនេះបំពេញបាននូវចន្លោះដែលគេបានលើកពីខាងលើ សម្រាប់សតវត្សរ៍ទី១៤ បើហោចណាស់ក៏រឿងនេះបានប្រាប់អំពីប្រភពនៃរាជវង្សសព្វថ្ងៃ និងប្រាប់ថា ព្រះរាជាខ្មែរលែងកាន់ព្រហ្មញ្ញសាសនាទៀតហើយ បែរមកកាន់ពុទ្ធសាសនាវិញ ។

គេអាចទទួលស្គាល់ថា ព្រះរាជាមួយអង្គ ដែលធ្លាប់តែហ៊ុំហាបែបព្រះរាជាកម្ពុជានាសតវត្សរ៍ទី១៣

---

[៥] រឿងនិទានដដែលបាននិយាយថា អដ្ឋិធាតុរបស់ព្រះរាជាបានត្រូវព្រះរាជបុត្រីព្រះនាមថា បទុម យកមកតម្កល់ទុកនៅក្នុងប្រាសាទប្រែរូបសព្វថ្ងៃ នៅពីខាងកើតអង្គរធំ ក្បែរទ្វារមរណៈ ។ “ប្រែរូប” ជាចំណែកនៃពិធីមួយដែលខ្ញុំអធិប្បាយនៅក្នុងសៀវភៅ មានឈ្មោះថា “ឈាបនកិច្ច និងពិធីបញ្ចុះសពនៅកម្ពុជា La Crémation et les rites funéraires au Cambodge” ។ ក្នុងពិធីនោះ គេប្រមូលយកផេះដែលសល់ពីការបូជាសពមកសូន្យជារាងមនុស្សដេក រួចហើយទើបគេរើសធាតុទៅតម្កល់ទុក ។

[៦] មានរឿងមួយដែលគេជួបប្រទះនៅសៀមរាប ដែលច្រឡំស្តេចសីហនុរាជថាជាស្តេចពាល ដែលសោយរាជ្យនៅសតវត្សរ៍ទី ១០ បាននិយាយថាប្រាសាទបន្ទាយសំរ៉ែ នៅពីខាងកើតអង្គរធំ សាងសង់ឡើងដោយតាចាយ មានដើមកំណើតជាអ្នកសំរ៉ែ ។ លោក អៃម៉ូនីញេ ក្រោយពីបានពិនិត្យប្រាសាទនេះរួច បាននិយាយថាប្រាសាទនេះគេសង់មុនប្រាសាទអង្គរវត្ត ជាការបញ្ជាក់ថា បើមិនមែនសាងសង់ដោយតាចាយទេ វាអាចជាប្រាសាទសង់ឡើងដោយពួកសំរ៉ែ ដើម្បីបូជាអាទិទេពណាមួយដែលពួកគេគោរព ។

យាងទៅណាមកណាមានសេនាហែហមស្អេកស្កះ បើហោចណាស់ក៏មានស្រីមហាតលិកតាមការពារដែរ ពេលយាងចេញពីព្រះបរមរាជវាំង ទ្រង់ពាក់អាវក្រោះធ្វើអំពីដែកការពារព្រះកាយ អាចនឹងយាងចេញពេលយប់ស្ងាត់ទៅប្រពាតចម្ការត្រសក់ដែលទ្រង់សព្វព្រះទ័យសោយ ដើម្បីពិនិត្យមើលថា តើចៅចាំចម្ការបានយាមកាមការពារត្រសក់មែនដែរឬទេ ។ ក៏ប៉ុន្តែបើគេចង់ទទួលស្គាល់ថា ព្រះរាជាត្រូវគេធ្វើឃាតនោះមិនមែនជាម្ចាស់ចម្ការទេដែលជាឃាតករ វាប្រាកដថា គឺនាម៉ឺនសព្វមុខមន្ត្រីណាម្នាក់ជាឃាតករ គ្រាន់តែថា ឃាតកម្មនេះ គេធ្វើនៅក្នុងចម្ការត្រសក់ នៅចំពោះមុខអ្នកចាំចម្ការ ឬក៏ឃាតករនោះជានាយក្រុមដំណាំក៏មិនដឹង ។

ម្យ៉ាងទៀត បើព្រះរាជាទ្រង់សុគតហើយ ហេតុអ្វីក៏នាម៉ឺនសព្វមុខមន្ត្រីមិនជ្រើសរើសអ្នកសោយរាជ្យស្នងក្នុងក្សត្រិយវង្ស ដែលប្រាកដជាបន្តកាន់ព្រហ្មញ្ញសាសនាតទៅទៀត តែបែរជាជ្រើសរើសប្រជារាស្ត្រ ហើយអាចជាឃាតករផង ដូច្នេះទៅវិញ? ត្រង់នេះបញ្ជាក់ថា វាប្រាកដជាមានការសមគំនិត ឬថា ព្រឹត្តិករណ៍នោះ បានបម្រើឲ្យផលប្រយោជន៍ពួកគេ ឬក៏មកពីថា គេស្ថិតនៅចំពោះមុខក្រុមឃាតករដែលមានអំណាចខ្លាំងជាង ហើយត្រូវតែលើកពួកនោះឲ្យឡើងលើបល្ល័ង្ករាជ្យ មិនអាចនឹងលើកយករឿងឃាតកម្ម ឬរឿងមានសារជាតិជាពួកសំរែ យកមកពិចារណាបានទេ[៧]?

ទាំងស្តេចនរោត្តម ទាំងអ្នកអង្គម្ចាស់ទាំងឡាយ បានទទួលស្គាល់ការពិតនៃប្រភពដើមនេះ ហើយមិនខ្លាចនឹងនិយាយថា រាជវង្សបច្ចុប្បន្នចេញមកពីវង្សតាត្រសក់ផ្អែម ដែលមានដើមកំណើតដើមជាពួកសំរែ បានធ្វើឃាតស្តេច រួចរៀបអភិសេកជាមួយបុត្រីស្តេច ។

រឿងបែបនេះ ភ្ជាប់ជាមួយនឹងលំពែងរាជ្យដែលគេរក្សាទុកនៅក្នុងរាជវាំងសព្វថ្ងៃ ដែលមិនជាល្អប៉ុន្មានសម្រាប់រាជវង្សបច្ចុប្បន្ន ជាភស្តុតាងមួយចំណែកបញ្ជាក់អំពីលក្ខណៈប្រវត្តិសាស្ត្រនៃរឿងនិទាន ទាំងអំពីចរិតលក្ខណៈ ទាំងអំពីការពិត ។

ហើយអ្វីដែលជាការពិតជាក់ស្តែងនោះគឺថា ព្រះរាជាដែលសោយរាជ្យបន្តពីព្រះបាទសីហនុរាជ ជាស្តេច

---

[៧] ទាំងអស់នេះគ្មានអ្វីគួរឲ្យសង្ស័យទេ ។ យើងធ្លាប់បានឃើញពីខាងលើរួចមកហើយថា មានអ្នកដែលដណ្តើមយកព្រះខ័នរាជ្យបាន បានចេញមកបង្ហាញមុខឲ្យប្រជារាស្ត្រ លើកឲ្យសោយរាជ្យ ។ យើងក៏ធ្លាប់បានឃើញដែរថា ពួកព្រាហ្មណ៍បុរោហិតដែលជាអ្នកថែរក្សាទេវរាជ បានឈរមើលគេធ្វើឃាតស្តេចដែលខ្លួនបានរៀបចំអភិសេក រួចហើយទទួលរៀបចំអភិសេកឃាតកឲ្យឡើងសោយរាជ្យបន្តទៀត ។ យើងនឹងបានឃើញក្រោយមកទៀត នៅសតវត្សរ៍ទី១៧ ថាព្រះខ័នរាជ្យនេះបានត្រូវគេយកទៅលាក់ទុកក្នុងរន្ធឈើ រង់ចាំឲ្យព្រះរាជាមួយអង្គយាងមកកាន់យកទៅលើកគ្រវី ដើម្បីឲ្យប្រជារាស្ត្រទទួលស្គាល់ជ្រើសរើសជាស្តេចសោយរាជ្យ ។ នៅកម្ពុជា ព្រះខ័នរាជ្យជាសញ្ញាសម្គាល់រាជានិយម ។ កាលពីសម័យមហានគរ ព្រះរាជាទ្រង់កាន់ព្រះខ័នរាជ្យក្នុងព្រះហស្ត ពេលទ្រង់បង្ហាញព្រះអង្គតាមបង្អួច ។

កាន់ព្រះពុទ្ធសាសនា ។ ការដែលទ្រង់មានព្រះនាមថា ព្រះបាទធម្មិកជាភស្តុតាងស្រាប់ ។ ហើយព្រះនាមរបស់ព្រះរាជបុត្រច្បងថា និព្វានបទ មានន័យថា ទ្រង់បានចូលព្រះនិព្វានហើយនិងព្រះនាមព្រះអនុជថា សិទ្ធាន មានន័យថា ជំនឿសាសនា បញ្ជាក់ថា សុទ្ធតែជាពុទ្ធសាសនិកទាំងអស់គ្នា ។ រាជវង្សថ្មីលែងគោរពបូជាសាសនាមុនលែងបូជាយញ្ញមនុស្សថ្វាយព្រះនាងកាលី នៅក្នុងប្រាសាទមួយនៅឯខាងបូព៌ារាជធានី ដូចដែលគេរៀបរាប់កាលពីសតវត្សរ៍ទី៧ ទៀតហើយ[៨] ។

បើសិនជាដូច្នេះមែន បដិវត្តន៍ដែលបានកើតមានឡើងនេះ ជារឿងសាសនា មិនមែនជារឿងនយោបាយទេ តែក៏បានបម្រើផលប្រយោជន៍ផ្នែកសម្ភារខ្លះ ដែលបង្កប់នៅពីខាងក្នុងទំនាស់នោះដែរ បើទោះជាថា គេមើលមិនឃើញ ក៏ដោយ ។

ក៏ប៉ុន្តែ ដើម្បីឲ្យការផ្លាស់ប្ដូរដ៏ជ្រាលជ្រៅ ដូចដែលយើងបានលើកខាងលើនេះ អាចសម្រេចទៅបានហើយមានការគាំទ្រផងនោះ វាគោងតែព្រះរាជាណាចក្រមានមនុស្សមួយចំនួនធំជាពិសេស នៅរាជធានីឥន្ទបត្តមានមនោសញ្ចេតនាជាមួយព្រះពុទ្ធសាសនាមួយរយៈកាលរួចមកហើយផងដែរ ។ តាមមើលទៅ ប្រហែលជាព្រះពុទ្ធសាសនា បានឈ្នះសាសនាដទៃៗទៀតមែន នៅចុងសតវត្សរ៍ទី១៣នោះ ហើយព្រះសង្ឃ ដែលសុទ្ធជា

---

[៨] តាមរាជពង្សាវតារមួយច្បាប់ទៀតដែលខ្ញុំមាន ព្រះរាជាដែលសោយរាជ្យបន្តពីនាយត្រសក់ផ្អែម ឬតាចាយ មិនមែនជាព្រះរាជបុត្រព្រះនិព្វានបទទេ តែគឺប្អូនដែលមានឈ្មោះថា តាសួស ដែលសោយរាជ្យសម្បត្តិ ៥០ឆ្នាំក្រោម ព្រះនាមថា សម្ដេចព្រះបរមមាយរាជា ។ បន្ទាប់មកមានព្រះរាជាសោយរាជ្យបន្តជាហូរហែដូចតទៅ ៖

- ព្រះស្រីសិរីបុត្រ ជាបុត្រនាយត្រសក់ផ្អែម សោយរាជ្យបាន៣៩ឆ្នាំ
- ព្រះបរមលំពង្សរាជា ជាបុត្រព្រះស្រីសិរីបុត្រ ឡើងសោយរាជ្យនៅក្នុងព្រះជន្ម ១៦ព្រះវស្សា សោយរាជ្យបាន៥៥ឆ្នាំ
- ព្រះបរមរាជឱង្ការ ជាបុត្រព្រះលំពង្សរាជា ឡើងសោយរាជយនៅព្រះជន្ម១៦ព្រះវស្សាដែរ សោយរាជ្យបាន៦០ឆ្នាំ
- ព្រះស្រីសុរិយោពណ៌ ជាបុត្ររបស់ព្រះបរមរាជឱង្ការ ឡើងសោយរាជ្យនៅព្រះជន្ម១៦ឆ្នាំដែរ សោយរាជ្យបានដល់ទៅ ៧៦ឆ្នាំ

ព្រះនិព្វានបទ

- រួចព្រះសិទ្ធានរាជា ជាព្រះរាជបុត្រព្រះអង្គ ។

បើតាមរាជពង្សាវតារនេះ មានស្ដេចដល់ទៅ ៦អង្គដែលសោយរាជ្យនៅចន្លោះចាប់ពីតាត្រសក់ផ្អែម មកដល់ព្រះនិព្វានបទនិងសិទ្ធានរាជា ដែលគេចាត់ទុកថា ជាព្រះរាជបុត្រអស់រយៈពេលរហូតដល់ទៅ ២៧៩ឆ្នាំ ឃើញថា វែងហួសពេក បើទោះជាយកទៅបំពេញចន្លោះតាំងពីព្រះរាជាដែលយើងស្គាល់តាមសិលាចារឹកមក ក៏មិនសមដែរ ។

រាជពង្សាវតារនេះ ប្រហែលជាឯកសារដែលព្រះសង្ឃមួយអង្គបានចម្លងយកទៅបង្ហាញដល់លោក អែម៉ូនីញេ តែមានមុនយូរហើយ គឺតាំងតែពីឆ្នាំ១៨៤៨ គឺមុនពេលដែលលោក អែម៉ូនីញេ មកដល់កម្ពុជាម៉្លេះ ។

បញ្ញវន្តកំពុងតែបង្ហាត់បង្រៀនទ្រឹស្ដីព្រះពុទ្ធដល់សិស្សគណៈជាច្រើន ផ្ទុយពីពួកព្រាហ្មណ៍ ដែលគ្មានសាលាបង្ហាត់បង្រៀន ហើយលាក់គម្ពីរទុកតែក្នុងចំណោមវណ្ណៈរបស់ខ្លួន មិនចែករំលែកដល់អ្នកដទៃ ដូចជានៅប្រទេសឥណ្ឌាដែរ ។

ប្រហែលជាមាននាម៉ឺនមន្ត្រីមួយចំនួនធំ បានទទួលយកព្រះពុទ្ធសាសនារួចហើយ មានតែរាជវង្សានុវង្សប៉ុណ្ណោះ ដែលនៅកាន់ព្រហ្មញ្ញសាសនា ដោយខ្លាចរអាអាទិទេពដែលធ្លាប់កសាងអាណាចក្រ ហើយក៏ប្រហែលដោយមានពួកព្រាហ្មណ៍បណ្ឌិតនៅជុំវិញ ទើបត្រូវតែបូជាមនុស្សម្នាក់ថ្វាយព្រះនាងកាលី ជារៀងរាល់ឆ្នាំ ។ ម្យ៉ាងទៀតដោយពុំទាន់ហ៊ានបោះបង់ការគោរពទេវរាជចោលចេញ ការគោរពនេះ កើតមានឡើងតាំងពីរជ្ជកាលព្រះបាទជ័យវរ្ម័នទី៣ នៅសតវត្សរ៍ទី៩ រហូតមក ។

ជំនឿសាសនារបស់ប្រទេសជាតិទាំងមូល ត្រូវបានកែប្រែបន្តិចម្ដងៗ ជាមួយនឹងពេលវេលា តែរាជវង្សានុវង្ស ដែលធ្លាប់តែអភិរក្សតាមសភាវគតិ ហើយថែមទាំងប្រកាន់ទំនៀមទម្លាប់អាស្រ័យដោយផលប្រយោជន៍ផងនោះ នៅរក្សាជំនឿតាមពីមុន ដែលគោរពអាទិទេពព្រហ្មញ្ញសាសនា គោរពព្រះវិស្ណុ គោរពព្រះសិវៈ និងព្រះនាងកាលី ប៉ុន្តែ ក៏ធូរទូលាយជាមួយព្រះពុទ្ធសាសនាផងដែរ ។

ការរីករាលដាលនៃព្រះពុទ្ធសាសនាទៅក្នុងស្រទាប់ប្រជាជនក្នុងព្រះរាជាណាចក្រ នៅពេលដែលព្រះរាជានៅតែប្រកាន់គោរពសាសនាចាស់ដូច្នេះ អាចនឹងបង្កើតឲ្យមានបរិយាកាសខាងស្មារតី ដែលអាចធ្វើឲ្យមានគ្រោះថ្នាក់ដល់រាជានិយម ធ្វើឲ្យអាណាចក្រត្រូវបែកបាក់ដោយព្រះរាជាមិនបានចាប់អារម្មណ៍ឡើយ ។ ការបដិវត្តន៍មួយ បានចាប់ផ្ដើមរៀបចំកើតឡើងហើយ ប៉ុន្តែ ព្រះរាជាមិនបានចាប់អារម្មណ៍ ដូចជាព្រះចៅអធិរាជរ៉ូម៉ាំង មុនព្រះចៅកុងស្តង់តាំង អឺចឹងដែរ ដែលមិនបានមើលឃើញថា អ្វីដែលកំពុងតែគំរាមកំហែងមកលើអាណាចក្រ ។ ព្រះរាជាប្រហែលជាទ្រង់បានទតឃើញ ហ្វូងមនុស្សដែលលើកគ្នាគាស់រំលើងបដិមាអាទិទេព ព្រហ្មញ្ញសាសនា ឃើញមានអ្នកខ្លះទៀតនាំគ្នាវាយកម្ទេចព្រះពុទ្ធរូប និងឃើញពុទ្ធសាសនិកជនចូលរួមសកម្មភាពផ្សេងៗ បម្រើផលប្រយោជន៍សាសនា ។ ទ្រង់ក៏ប្រហែលជាបានដឹងអំពីទំហំរីករាលដាលនៃពុទ្ធសាសនា ដែលទទួលជោគជ័យរួចទៅហើយនៅក្នុងបណ្ដាខេត្រភាគពាយ័ព្យ ហូរចូលមកក្នុងព្រះរាជាណាចក្រកាន់តែខ្លាំងឡើង ពីមួយថ្ងៃទៅមួយថ្ងៃ ។ បដិវត្តន៍នាពេលនោះ មិនមែនកើតឡើងដោយឯកឯងនោះទេ ប៉ុន្តែវាជាលទ្ធផលនៃភាពល្អក់កករដ៏យូរលង់មួយ ដែលកើតចេញពីទំនាស់ជាច្រើនរវាងសាសនាទាំងពីរ ពីភាពច្របូកច្របល់ ហើយក៏ប្រហែលជាមានការបះបោរគាំទ្រ ឬប្រឆាំងទ្រឹស្ដីសាសនាថ្មីផងដែរ ។ នៅក្នុងស្ថានភាពបែបនេះ ពោលគឺបដិវត្តន៍បានចាក់ឫសនៅក្នុងសតិស្មារតីយូរណាស់មកហើយ ចាំបាច់ត្រូវតែលើកព្រះរាជាដែលកាន់ពុទ្ធសាសនាឲ្យសោយរាជ្យ ដើម្បីបំពេញតាមបំណងរបស់ប្រជាជន ជៀសវាងការមិនសប្បាយចិត្ត ជាពិសេស គឺប្រជាជនទីក្រុង ព្រោះថាអ្នកស្រុកអ្នកស្រែតាមជនបទ ប្រហែលជានៅបន្តគោរពអបិយជំនឿ គោរពអ្នកតា គោរពលិង្គ នៅឡើយទេ ។

កាលណាបើអាចកើតឡើងបាន បដិវត្តន៍ត្រូវតែកើតឡើង ហើយទទួលបាននូវជោគជ័យជាស្ថាពរ ។

នៅពេលនោះ ភាសាសំស្ក្រឹតដែលជាភាសារបស់ពួកព្រាហ្មណ៍ បណ្ឌិត បុរោហិត អាចារ្យព្រហ្មញ្ញសាសនា ជាភាសារបស់ព្រះមហាក្សត្រដែលគោរពព្រះសិវៈ ឬព្រះវិស្ណុ ឬក៏គោរពព្រះទាំងពីរព្រះអង្គតែម្ដង ក្រោមរូបភាពជាព្រះហរិហរៈ បានត្រូវគេបោះបង់ចោលហើយ ហើយជំនួសវិញដោយភាសាបាលី ជាភាសាពិសិដ្ឋរបស់ពុទ្ធសាសនិកជននាសម័យនោះ ដែលបន្ទាប់មកបានក្លាយទៅជាភាសាសម្រាប់អ្នកប្រាជ្ញនៅក្រោម រាជវង្សថ្មី ។

បដិវត្តន៍តោងតែជាបដិវត្តន៍ប្រជាប្រិយ បើហោចណាស់ក៏នៅតាមទីក្រុងដែរ ។ បើដូច្នេះ វាគឺជាបដិវត្តន៍ប្រជាធិបតេយ្យ ហើយដើម្បីឲ្យប្រជារាស្ត្រនៅតែគោរពបូជា ព្រះរាជាក៏តោងតែបោះបង់ចោលនូវទម្លាប់ខ្លះ ជាពិសេស គឺប្រពៃណីដែលប្រជារាស្ត្រមិនចូលចិត្ត ជាក់ស្ដែងដូចជាការកេណ្ឌប្រជាជនដោយពួកព្រះអង្គម្ចាស់ ឬពួកវិស្សុកម្មឲ្យលើកផ្លូវថ្នល់ ឲ្យសង់វិមានធំៗ សង់រាជវាំង ប្រាសាទ បន្ទាយ សម្រាប់លម្អរាជធានី ដូចជាប្រាសាទបាយ័ន ភិមានអាកាស អង្គរវត្ត បឹងមាលា ព្រះខ័ន ឬក៏ប្រាសាទសម្រាប់ការសម្រាករបស់ព្រះរាជា ជាដើម ដែលត្រូវចំណាយមាសប្រាក់ ទុក្ខវេទនា និងទឹកភ្នែករាស្ត្រ ជាច្រើន ។ គឺដោយហេតុនោះហើយ បានជាការសាងសង់ប្រាសាទមួយចំនួន ត្រូវបានគេបោះបង់ចោល ដូចជាប្រាសាទអង្គរវត្ត ដែលគេចាប់សង់តាំងពីសតវត្សរ៍មុនមក តែចម្លាក់ក្បាច់រចនានៅមិនទាន់ចប់សព្វគ្រប់នៅឡើយ គឺនៅដដែលដូចពីមុន ព្រោះក្រោយបដិវត្តន៍ ព្រះពុទ្ធសាសនា បានក្លាយទៅជាសាសនាផ្លូវការ ហើយព្រះរាជាគ្មានមធ្យោបាយខាងសម្ភារ ឬស្មារតីណានឹងបន្តការសាងសង់តទៅទៀតបានឡើយ ។ ម្យ៉ាងទៀត ជំនឿសាសនាក្រោយហាក់ដូចជាមិនរវីរវល់នឹងបង្ហើយអ្វី ដែលជំនឿសាសនាមុនបានចាប់ផ្ដើមនោះទេ រីឯប្រជារាស្ត្រដែលធ្លាប់តែរងនូវការគាបសង្កត់ពីរាជានិយមព្រហ្មញ្ញសាសនា ក៏ហាក់ដូចជាមានសេរីភាពជាងមុន មានសេចក្ដីក្លាហានជាងជាមួយនឹងរាជានិយមថ្មី ជាពិសេស នៅពេលដែលអាណាចក្រទាំងមូលកំពុងតែរងនូវការបាក់បែក ដូចនេះគ្មានផលប្រយោជន៍អ្វីដែលធ្វើឲ្យគេចង់ធ្វើការងារដ៏លំបាកទាំងអស់នោះដែរ ។ គឺដោយបែបនេះហើយដែលការអាប់ឱនចុះនៃអាណាចក្រខ្មែរ បានបណ្ដាលឲ្យមានការអាប់ឱនចុះនៃស្ថាបត្យកម្ម និយាយដោយខ្លីថា ក្រោយពីបដិវត្តន៍ពុទ្ធសាសនា អ្វីៗទាំងអស់ត្រូវបាក់ស្រុតចុះ នៅកម្ពុជា ។

ខាងលើនេះជាការរៀបរាប់អំពីការបាក់បែកនៃអាណាចក្រខ្មែរ បន្ទាប់ពីមានបដិវត្តន៍សាសនាដែលនាំឲ្យគេលើកស្ដេចកាន់ពុទ្ធសាសនា មានព្រះនាម និងព្រះឋានៈតាមវាក្យស័ព្ទពុទ្ធសាសនា ឲ្យសោយរាជ្យលើរាជបល្ល័ង្កស្ដេចព្រហ្មញ្ញសាសនា តែលែងប្រើព្រះនាមថា “វរ្ម័ន - អ្នកការពារ” ទៀតហើយ ។ ខ្ញុំជឿថា គឺចាប់ពីពេលនោះហើយ ដែលមានការបែងចែកទឹកដីដោយស្ដេចត្រាញ់ទាំងឡាយ ដែលធ្លាប់តែចំណុះព្រះរាជាខ្មែរ ។ រាជពង្សាវតាររបស់ប្រទេសទាំងអស់ ដែលទទួលអារ្យធម៌ហិណ្ឌូនៅឥណ្ឌូចិន សុទ្ធតែចាប់ផ្ដើមឡើងក្នុងពេលតែមួយ គឺប្រហែលជាពាក់កណ្ដាលទីមួយនៃសតវត្សរ៍ទី១៤ នៅភូមា សៀម លាវ ម៉ាគាបាន ក៏ដូចជានៅកម្ពុជា ។

នេះក៏ជាភស្តុតាងមួយទៀតដែលបញ្ជាក់ថា ព្រឹត្តិការណ៍ដ៏ធំមួយបានកើតមានឡើងនាពេលនោះ ចំពោះបណ្តារដ្ឋទាំងឡាយដែលធ្លាប់តែចំណុះអាណាចក្រខ្មែរ នោះគឺការបាត់បង់អំណាចរបស់វង្សវរ្ម័ននៅកម្ពុជា ការផ្លាស់ប្តូរសាសនា និងការចុះខ្សោយនៃអំណាចព្រះរាជា បណ្តាលមកពីបដិវត្តន៍ ។ ការរំដើបរំជួលអាចនឹងកើតមានគ្រប់ទិសទី ។ បណ្តារដ្ឋទាំងឡាយដែលធ្លាប់តែចុះចាញ់ ដាក់ខ្លួនជាចំណុះ ហើយយល់ព្រមទទួលស្គាល់អនុត្តរភាពរបស់អាណាចក្រខ្មែរ ពេលនោះប្រហែលជាចាប់ផ្តើមចាប់កាន់អាវុធរើបម្រះទាមទារស្វ័យភាព រួចហើយប្រកាសឯករាជ្យក្នុងពេលតែមួយ ។ ព្រះរាជាកម្ពុជា ដែលអស់អំណាច ហើយគ្មានយន្តការសង្គមអ្វី ដើម្បីកេណ្ឌប្រជារាស្ត្ររាប់ពាន់នាក់ឲ្យធ្វើសំណង់ធំៗ ក៏គ្មានអំណាចណានឹងកេណ្ឌពលរេហ៍ធ្វើសង្គ្រាម "ទៅទិសទាំងបួន" ដូចពីមុនម៉្លោះហើយក៏មិនអាចនឹងចាប់ពួកបះបោរឲ្យចូលមកក្នុងនឹមត្រួតត្រាវិញដូចកាលពីដើមបានដែរ ។ ម្យ៉ាងទៀតរាស្ត្រនៃបណ្តារដ្ឋទាំងអស់នោះ ក៏ប្រហែលជាបានកាន់ព្រះពុទ្ធសាសនាមុនរួចទៅហើយផង ហើយថែមទាំងមានស្តេច[៧] កាន់ព្រះពុទ្ធសាសនា មុនពេលដែលកម្ពុជាបោះបង់ស្តេចកាន់ព្រហ្មញ្ញសាសនាទៅទៀត ជាហេតុបណ្តាលឲ្យរដ្ឋទាំងអស់នោះ រឹតតែមានកម្លាំងខ្លាំងឡើង បើប្រៀបទៅនឹងព្រះចៅអធិរាជដែលខ្សោយស្រាប់ នៅក្នុងប្រទេសខ្លួនឯងនោះ ។

គេមិនអាចពន្យល់តថភាពខាងលើនេះបែបដូចម្តេចបានទៀតទេ គឺថាអ្វីៗទាំងអស់ចំពោះអ្នកស្រុកឥណ្ឌូចិន ហាក់ដូចជាចាប់កើតមានឡើងត្រឹមពាក់កណ្តាលសតវត្សរ៍ទី១៤ ប្រៀបដូចជាការចាប់ផ្តើមសាជាថ្មីឡើងវិញ ។ មុនឆ្នាំ១៣៤០គឺជាយប់ងងឹតឈឹង ក្រោយនោះគឺជាថ្ងៃភ្លឺស្រឡះទែង ។ ហេតុការណ៍ទាំងឡាយពីអតីតកាល ត្រូវកប់លុបបាត់ទៅក្នុងការភ្លេចភ្លាំង ។ គេភ្លេចអស់តាំងពីព្រះនាមស្តេចសោយរាជ្យ ភ្លេចទាំងឈ្មោះរាជធានី ភ្លេចអស់ទាំងព្រឹត្តិការណ៍សំខាន់ៗទាំងឡាយ ។ មានសិលាចារឹកសំស្ក្រឹតជាច្រើនដែលត្រូវបាត់បង់ គ្មាននរណាអាចចេះអានបាន ព្រោះម្យ៉ាងភាសានេះប្រជាជនមិនដែលចេះស្រាប់ផង រីឯអ្នកប្រាជ្ញក៏មិនអាចមើលដាច់ ម៉្លោះហើយក៏ត្រូវទុកចោល ឬលើកគ្រវាត់ចោលទៅក្នុងទន្លេ បឹង បើសិនជាមិនបានកប់ទៅក្នុងដីទេ ។ ប្រវត្តិសាស្ត្រត្រូវបានផ្លាស់ជំនួសវិញដោយរឿងព្រេងនិទានច្រើនរាប់មិនអស់ រឿងភាគច្រើនមិនពិតគួរឲ្យចង់សើច ខ្លះទៀតមានភាពអច្ឆរិយៈហួសហេតុ រឿងកើតឡើងច្រើនប្រទាំងប្រទើសគ្នាពីមួយថ្ងៃទៅមួយថ្ងៃយូរៗទៅ ក្លាយទៅជារឿងនិទានស្រមើស្រមៃ ។ មានរឿងរបស់សៀមដែលគេយកមកធ្វើជារឿងខ្មែរ ដាក់ឈ្មោះទីកន្លែងតាមឈ្មោះក្នុងស្រុកខ្មែរ ហើយរឿងខ្មែរប្រែជារឿងរបស់សៀម មានឈ្មោះទីកន្លែង ត្រូវនឹង

---

[៧] គេបានចាប់រៀនសូត្រព្រះពុទ្ធសាសនាតាំងតែពីដើមសតវត្សរ៍ទី១៣មក នៅឯរាជវាំងស្តេចសុខោទ័យ ។ គម្ពីរត្រៃភូមិមានកំណើតនៅក្នុងពាក់កណ្តាលទី១ នៃសតវត្សរ៍ ទី១៣នោះ ។

ឈ្មោះស្រុកភូមិរបស់សៀម ។

ការអនុវត្តន៍ជំនឿចាស់នៅមានសេសសល់ខ្លះក្នុងស្រទាប់ប្រជាជន ជាពិសេស គឺនៅតាមជនបទស្រុកស្រែ តែចេះតែសាបរលាបទៅៗ ដាក់ស្តែងដូចជា រូបសំណាកអាទិទេពព្រហ្មញ្ញសាសនា នៅមានគេគោរពបូជា ហើយជូនកាលខ្លាចរអាទៀតផង ប៉ុន្តែ អ្នកគោរពបូជាចេះតែតិចទៅៗ ហើយជំនឿនោះ មានអាថ៌កំបាំងកាន់តែខ្លាំងឡើង កាលណាគេឃ្លាតកាន់តែឆ្ងាយពីសតវត្សរ៍ទី១៤ ។ គេស្គាល់ឈ្មោះអាទិទេពដែលរូបនោះតំណាងឲ្យតែបានត្រឹមតែស្គាល់យ៉ាងនោះប៉ុណ្ណោះ ។ កម្ពុជាបុរាណបានកប់លិចបាត់ទៅក្នុងភាពងងឹត រឿងរ៉ាវពីអតីត បានផ្ដិតជាប់ទៅនឹងរាត្រីកាល ហើយប្រជារាស្ត្រខ្មែរក៏ដូចអ្នកស្រុកឥណ្ឌូចិនឯទៀតៗ ដែលទទួលអារ្យធម៌ហិណ្ឌូដែរ គឺត្រូវចាប់ផ្ដើមចេញដំណើរសាជាថ្មី ព្រមគ្នាក្នុងពេលតែមួយ លើមាគ៌ាថ្មីមួយ ដោយជំហានខុសពីមុន ហើយនាំគ្នាកត់ត្រាដំណើរជីវិតរបស់គេពីមួយឆ្នាំទៅមួយឆ្នាំ ខុសពីទម្លាប់មុន ។

ម្យ៉ាងទៀត បើសិនណាជាព្រឹត្តិការណ៍សតវត្សរ៍ទី១៤ មិនបានធ្វើឲ្យពួកគេឯកភាពគ្នាលើការកំណត់ពេលចាប់ផ្ដើមនៃពង្សាវតាររបស់គេទេ តើមានអ្វីទៅដែលធ្វើឲ្យគេឯកភាពគ្នា? ពិតប្រាកដណាស់ថា អ្វីដែលនាំឲ្យគេចាប់ផ្ដើមធ្វើព្រមគ្នានូវអ្វីដែលគេមិនមានទម្លាប់ធ្វើពីមុន នោះគឺការដែលគេបានរួចចាកផុតព្រមគ្នាពីការស្ថិតនៅក្រោមអាណាព្យាបាលតែមួយ នៅពេលដែលកម្ពុជាកំពុងតែមានបដិវត្តន៍ បាត់បង់ប្រជាជនអស់ ដោយសារសង្គ្រាមរ៉ាំរ៉ៃ ហើយបាត់បង់ទឹកដីឆ្ងាយៗ ដែលខ្មែរពិបាកនឹងបញ្ជូនទ័ពទៅការពារ គឺនៅពេលនោះហើយ ដែលគេចាប់មានគំនិតចង់សរសេរកត់ត្រា ចង់និយាយ ព្រោះថា គេមានសេរីភាពហើយ ។

ក្រោយពីទឹកដីមួយចំនួនត្រូវបាត់បង់ទៅ ពេលនោះព្រះរាជាណាចក្រហាក់ដូចជានៅរក្សាបាននូវអាណាខេត្តមួយចំនួននៅខាងត្បូងរាជធានី រួមទាំងអាណាខេត្តជាប់នឹងឈូងសមុទ្រសៀម មានចន្ទគាប៊ុន, បាត់ដំបង, ទឹកដីពីខាងជើងអង្គរធំរហូតដល់កូរ៉ាត់ (នគររាជសីមា) និងនៅលើជួរភ្នំដងរែកលើកលែងតែទឹកដីរាជាណាចក្របាសាក់ចេញ ហើយនិងទៅដល់អាតូពឺផងដែរ ។ ទឹកដីដែលបាត់បង់រួមមានៈ ស្រុកសៀម ដែលជាសត្រូវសាហាវនិងធំជាងគេ, រាជាណាចក្រតូចៗនៅតាមដងទន្លេមេណាមខាងលើ, រាជាណាចក្រវៀងច័ន្ទ, រាជាណាចក្រហ្លួងប្រាបាង ហើយនិងក្សត្រប្រទេសតូចៗប្រហែលជា៤០ នៅលើទឹកដីលាវសព្វថ្ងៃ ។ គួររំលឹកថា ឯកសារប្រវត្តិសាស្ត្រចិនបាននិយាយថា មានស្រុកចំនួន៦០ ដែលស្ថិតនៅក្រោមអនុត្តរភាពរបស់ព្រះរាជាកម្ពុជា ហើយឈាវតាក្វាន់ និយាយថា ចំនួនទាំងអស់គឺ ៩០ ។ ព្រះរាជាណាចក្រកម្ពុជាពេលនោះ នៅជាអាណាចក្រដ៏ធំមួយនៅឡើយ មានរាជធានីជាបន្ទាយ ប្រកបទៅដោយកំពែងការពារដ៏រឹងមាំជាងគេនៅឥណ្ឌូចិន និងជារាជធានីល្អដាច់គេក្នុងចំណោមទីក្រុងធំៗទាំង៣០ ប៉ុន្តែ អំណាចបានចុះខ្សោយ ហើយបើគិតអំពីកម្លាំងទ័ព ដែលខ្វះវិន័យបើប្រៀបទៅនឹងសម័យនៅក្រោមព្រះរាជាវរ្ម័ន, នាម៉ឺនសព្វមុខមន្ត្រី និងឧត្តមសេនីយ៍មិនសូវគោរពកោតខ្លាចព្រះរាជា ។ កម្ពុជាពេលនោះ គ្មានសមត្ថភាពនឹងការពារខ្លួនដូចកាលពី២សតវត្សរ៍មុនទៀតទេ តែត្រូវប្រឈមមុខ

នឹងសង្គ្រាមជាមួយចាម, សៀម ព្រមទាំងក្សត្រប្រទេសចំណុះឯទៀតៗជាញឹកញាប់ រីឯប្រជាជនក៏បះបោរឡើងដែរ ដោយមើលឃើញថា អំណាចរបស់ព្រះរាជាបានចុះខ្សោយហើយ ។

ចាប់ពីពេលដែលមានបដិវត្តន៍នោះមក ការអាប់ឱនចុះមានល្បឿនលឿនគ្មានអ្វីអាចទប់បាន គឺអាប់ឱនចុះទាំងខាងស្ថាបត្យកម្ម ទាំងខាងការគ្រប់គ្រង ។ ពូជសាសន៍ចេះតែហោចទៅៗ ម្យ៉ាងគឺដោយសារក្រុមពួកហិណ្ឌូដែលធ្លាប់តែដឹកនាំបានបាត់បង់ទៅជាមួយនឹងរាជាព្រហ្មញ្ញនិយម ម្យ៉ាងទៀត គឺដោយសារការកាត់រលាយចូលគ្នាជាមួយអ្នករដ្ឋវាសី ។ គេបានសង្កេតឃើញតាំងពីច្រើនសតវត្សរ៍មុនបដិវត្តន៍នោះម៉្លេះ ថាឈ្មោះ ឥស្សរជននិងនាយទាហានជាភាសាសំស្ក្រឹតចេះតែតិចទៅៗ ហើយឈ្មោះអ្នករដ្ឋវាសីតាមភាសាសាមញ្ញចេះតែមានច្រើនឡើងៗ ជាការបញ្ជាក់ថាសមាសភាគហិណ្ឌូចេះតែហោចទៅៗ ហើយធាតុអ្នកស្រុកដើមមានកាន់តែច្រើនឡើងៗ ។ បន្តិចម្តងៗ ខ្មែរលែងនៅជាជាតិធំមួយ មានអារ្យធម៌ហិណ្ឌូដូចពីមុន លែងអភិវឌ្ឍន៍អារ្យធម៌ខ្លួនទៅតាមមាគ៌ាដែលពួកហិណ្ឌូបានត្រួសត្រាយឲ្យនោះទៀតហើយ ។ គេត្រលប់បែរមករកចរិតដើមរបស់គេវិញ គឺស្ថានភាពបុព្វកាលដូចដែលអ្នកស្រុកនៅរក្សាបាននៅឡើយ ។ ពេលនោះ គេមិនអាចទប់ទល់នឹងចរន្តពន្ធុនិស្ស័យ ដែលប្រទាញឲ្យគេតាំងដៃតាំងជើង ហើយធ្លាក់ចូលឱនភាពបានឡើយ ។ ជំនឿសាសនាថ្មីក៏គ្មានថាមពលមិនស្ទាហាប់ធ្វើឲ្យកម្លាំងថយចុះពីមួយសតវត្សរ៍ទៅមួយសតវត្សរ៍ ។ ជាមួយព្រះរាជាវរ្ម័នចុងក្រោយ ថាមពលរបស់កម្ពុជាបានចុះខ្សោយបន្តិចទៅហើយ ប៉ុន្តែ នៅអាចទប់ទល់ជាមួយពួកសៀម ដែល«បោសសម្អាតទីក្រុង ស្អាតដូចគេដកស្មៅ» បាននៅឡើយ ។ ប៉ុន្តែក្រោយមក គេគ្មានសមត្ថភាពនឹងការពារខ្លួនប្រឆាំងនឹងពួកសៀមនោះទៀតទេ ធ្វើសង្គ្រាមម្តងចុះខ្សោយបន្តិច រហូតទាល់តែក្លាយទៅជាអសមត្ថភាពតែម្តង ។ ចាប់ពីក្រោយពេល ដែលសៀមដណ្តើមយកក្រុងលង្វែកបាននៅឆ្នាំ១៥៨៧ វាហាក់ដូចជាថា លែងមានអារ្យធម៌ខ្មែរតទៅទៀតហើយ ។ ពួកសៀមបាននាំយកគម្ពីរ ច្បាប់ និងភោគទ្រព្យផ្សេងៗ របស់ខ្មែរទៅអស់ ហើយចាប់ពីពេលនោះមក សៀមក៏ក្លាយខ្លួនទៅជាប្រទេសមួយមានអារ្យធម៌អារ្យាង ជឿនលឿនជាងគេ នៅឥណ្ឌូចិន ។ ខ្មែរត្រូវចាប់ចម្លងតាមសៀមវិញ នៅពេលណាដែលគេមានលទ្ធភាពងើបក្រោកឈរចម្តងៗ ។

មកដល់ពាក់កណ្តាលសតវត្សរ៍ទី១៤នេះ មុននឹងយើងធ្វើដំណើរបន្តទៅឆ្ងាយទៀត ខ្ញុំគិតថា យើងគួរតែកំណត់កាលបរិច្ឆេទនៃរជ្ជកាលរបស់ក្សត្រ វរ្ម័ន ចុងក្រោយៗនេះសិន ។

ដំបូង គឺព្រះបាទជ័យវរ្ម័នបរមេស្វរៈ ដែលប្រហែលជាទ្រង់សោយរាជ្យនៅពាក់កណ្តាលសតវត្សរ៍ទី១៣ ។

បន្ទាប់មក មានស្តេចដែលសោយរាជ្យតពីព្រះអង្គមក តែយើងមិនស្គាល់ព្រះនាម ហើយអាចជាព្រះរាជាកំពុងសោយរាជ្យ នៅពេលដែលរាជទូតចិនមកធ្វើទស្សនកិច្ចនៅកម្ពុជានៅឆ្នាំ១២៩៦ ។

បន្ទាប់មក គឺរាជបុត្ររបស់ព្រះរាជាខាងលើ ដែលរឿងនិទានមួយថ្វាយព្រះនាមថាអាឡូសរាជ ។

ព្រះអនុជរបស់ព្រះអាឡូសរាជ ព្រះនាមព្រះវរល័ករាជ បានសោយរាជ្យបន្តពីព្រះរៀម ។

បន្ទាប់មកទៀត គឺព្រះសេនករាជ ដែលជាព្រះអនុជពៅរបស់ព្រះអាឡសរាជ និងព្រះវរល័ករាជ ដែលឡើងសោយរាជ្យបន្តពីព្រះរៀម ហើយគឺនៅក្នុងរជ្ជកាលរបស់ស្តេចអង្គនេះហើយដែលមានការធ្វើឃាតកូនព្រាហ្មណ៍ និងមានទឹកជំនន់ ដែលយើងបានឃើញខាងលើរួចមកហើយ ។

ព្រះរាជបុត្ររបស់ព្រះសេនករាជ ព្រះនាមសីហនុរាជ បានឡើងសោយរាជ្យបន្តពីព្រះបិតា ហើយត្រូវធ្វើឃាតដោយតាចាយ ម្ចាស់ចម្ការត្រសក់ផ្អែម នៅក្នុងត្រីមាសទី១នៃសតវត្សរ៍ទី១៤ ។

ទីបញ្ចប់ គឺតាចាយ ដែលឡើងសោយរាជ្យបាន១៧ឆ្នាំ រហូតដល់ឆ្នាំ១៣៤០ ហើយជាស្ថាបនិកនៃរាជវង្សដែលកំពុងសោយរាជ្យសព្វថ្ងៃនៅកម្ពុជា ។

**កំណត់ចំណាំ** ៖ បើសិនជាគេចាត់ទុករឿងនិទានមួយដែលខ្ញុំមាននៅក្នុងដៃជាបានការ ហើយដែលអះអាងថា ព្រះបាទសីហនុរាជត្រូវគេធ្វើឃាតនៅឆ្នាំ១២៩០ នោះមានសម្មតិកម្មថ្មីមួយទៀតបានលេចឡើង ។ ខ្ញុំសូមលើកយក បញ្ហានេះមកជម្រាបជូននាពេលនេះ និងសូមធ្វើការពិភាក្សាទៅតាមការយល់ឃើញរបស់ខ្ញុំ ទាំងញញើតញញើម ដើម្បីទាញអារម្មណ៍របស់អស់លោកអ្នក ចំពោះព្រឹត្តិការណ៍ដ៏ច្របូកច្របល់នៃសម័យកាលប្រវត្តិសាស្ត្រមួយ ដែលយើងសឹងតែមិនដឹងអ្វីទាល់តែសោះ ។

ព្រះបាទជ័យវរ្ម័នទី៧ បានសុគត ឬបាត់ខ្លួនទៅ នៅឆ្នាំ១២០១ ។

ព្រះបាទឥន្ទ្រវរ្ម័ន ជាព្រះរាជបុត្របានសោយរាជ្យបន្តនៅឆ្នាំនោះ ហើយនៅសោយរាជ្យនៅឡើយ នៅឆ្នាំ១២២០ ។

ព្រះរាជបុត្ររបស់ព្រះឥន្ទ្រវរ្ម័ន ព្រះនាមស្រីន្ទ្រវរ្ម័ន បានឡើងសោយរាជ្យបន្តពីព្រះបិតា មិនដឹងថានៅឆ្នាំណាទេ តែក្រោយឆ្នាំ១២២០ ។ ប្រហែលជាស្តេចអង្គនេះឯង ដែលអ្នកខ្លះហៅថា ព្រះសេនកៈ ដែលនៅក្នុងរាជ្យព្រះអង្គមានទឹកជំនន់ធំ ។

ព្រះរាជបុត្ររបស់ព្រះបាទសេនករាជ ព្រះនាមព្រះបាទសីហនុរាជ បានត្រូវ តាចាយ នាយច្បារដំណាំ ធ្វើឃាត នៅឆ្នាំ១២៩០ ។ តាចាយ នោះ ត្រូវគេលើកឲ្យសោយរាជ្យ ហើយរៀបអភិសេកជាមួយបុត្រីស្តេច ។

តែឈាវតាក្វាន់ បានរៀបរាប់ថា ព្រះរាជាដែលសោយរាជ្យនៅឡើយ នៅឆ្នាំ១២៩៦ ជាបុត្រសុណិសារបស់ព្រះរាជាមុន ហើយបានឡើងសោយរាជ្យដោយដណ្តើមពីរជ្ជទាយាទមួយអង្គ ។ បើដូច្នោះ ស្តេចដែលសោយរាជ្យនៅឆ្នាំ១២៩៦ គឺតាចាយ ដែលរឿងនិទានហៅថា នាយត្រសក់ផ្អែម ។

ក្នុងករណីនេះ បដិវត្តន៍សាសនា និងនយោបាយ ដែលលើកព្រះរាជាកាន់ព្រះពុទ្ធសាសនាឲ្យសោយរាជ្យនៅលើរាជបល្ល័ង្កវរ្ម័នព្រហ្មញ្ញនិយម មិនមែនកើតឡើងនៅឆ្នាំ១៣២០នោះទេ គឺនៅប្រហែលជា៣០ឆ្នាំមុន គឺឆ្នាំ១២៩០ ។ អត្ថបទប្រវត្តិសាស្ត្រមួយដែលខ្ញុំមាននៅនឹងដៃនិយាយថា កាលបរិច្ឆេទនៃឃាតកម្មទៅលើស្តេចសីហនុរាជ កើតឡើងនៅក្នុងមហាសករាជ១២១២ ត្រូវនឹងឆ្នាំខាល ទោស័ក ។ ឯកសារនោះនិយាយថា តាចាយ

សោយរាជ្យបាន ១៧ឆ្នាំ ហើយសុគតនៅក្នុងព្រះជន្មាយុ ៧០ព្រះវស្សា គឺត្រូវនឹងឆ្នាំ១៣០៧ ។

ឯកសារមួយទៀត ហៅ តាចាយ ថា ព្រះជ័យ ហើយនិយាយថា គឺប្អូនតាចាយឈ្មោះ តាសួស ដែលឡើងសោយរាជ្យបន្តក្រោមព្រះនាមថា ព្រះមាយរាជា សោយរាជ្យបាន២០ឆ្នាំ ហើយសុគតនៅរវាងឆ្នាំ១៣២៧ ។

បន្ទាប់មក គឺព្រះនិព្វានបទ ជាក្មួយព្រះបរមមាយ និងជាបុត្ររបស់តាចាយ ដែលឡើងសោយរាជ្យបន្ត ហើយរាជពង្សាវតារបានបញ្ជាក់ថា ស្ដេចអង្គនេះ នៅសោយរាជ្យនៅឡើយនៅឆ្នាំ១៣៤០ ។

ហេតុការណ៍ដែល ឈាវតាក្វាន់ លើកឡើងថា ព្រះរាជាដែលសោយរាជ្យនៅឆ្នាំ១២៩៦ ដោយបារម្ភខ្លាចគេធ្វើឃាត បានពាក់អាវក្រោះធ្វើអំពីដែក និងមានកងពលសេនាហែហមណែនណាន់តាន់តាប់ ហាក់ដូចជាគាំទ្រដល់សម្មតិកម្មដែលនិយាយថា ស្ដេចសោយរាជ្យនៅឆ្នាំ១២៩៦នោះ គឺជានាយចាំចម្ការនោះហើយ ព្រោះខ្លាចគេតាមមកធ្វើឃាតវិញ គឺប្រុងប្រយ័ត្នច្រើនជាងស្ដេចដែលសោយរាជ្យតាមច្បាប់ ។

គួរកត់សម្គាល់ថាអ្នកកត់ត្រាចិន ដែលនិយាយថា ស្ដេចសោយរាជ្យនៅឆ្នាំ១២៩៦ បានឡើងសោយរាជ្យតាំងពី៥ឆ្នាំមុនដោយជ្រែករាជ្យ តែមិនបានប្រាប់ថា បានធ្វើគុតស្ដេចមុនផងទេ គ្រាន់តែថា បានទម្លាក់ពីរាជសម្បត្តិប៉ុណ្ណោះ ។

តើគេអាចកាត់ថាធ្វើឃាតបានដែរទេ? រឿងឃាតកម្មនេះអាចកើតមានមែនបាន ព្រោះថាបើពុំនោះមិនមែនរាជបុត្រទេ ដែលត្រូវគេបំបែកចេញពីរាជសម្បត្តិ ។ បើរាជទូតចិននិយាយតែពីរាជបុត្រនោះ បានសេចក្ដីថា គ្មានព្រះបិតាទេ ពោលគឺព្រះបិតាអាចត្រូវគេធ្វើគុតរួចទៅហើយ ។

នៅមានរឿងមួយទៀត ៖ អ្នកនិពន្ធចិននិយាយថា បុត្រីស្ដេចដែលសោយរាជ្យមុនឆ្នាំ១២៩០ បានលួចយកព្រះខ័នរាជ្យមកប្រគល់ឲ្យស្វាមី ទើបស្វាមីនោះឯងប្រកាសតែងតាំងខ្លួនឯងជាស្ដេចសោយរាជ្យទៅ ។ តែអ្នកនិពន្ធចិនមិនបានបញ្ជាក់ទេថា ព្រះនាងបានលួចព្រះខ័នរាជ្យពីព្រះបិតា ។ ដូច្នេះគេអាចសន្និដ្ឋានបានថា ព្រះនាងបានលួចយកព្រះខ័នរាជ្យនៅពេលដែលព្រះបិតាសុគត រួចប្រគល់ឲ្យព្រះស្វាមី ដើម្បីឲ្យព្រះអង្គបានឡើងសោយរាជ្យជំនួសព្រះអនុជ ។

ហើយនៅមានរឿងមួយទៀត ៖ ឈាវតាក្វាន់បានរៀបរាប់ដែរថា ព្រះរាជាដែលសោយរាជ្យនៅឆ្នាំ១២៨៦ បានចាប់យកអាជីពក្នុងកងប្រដាប់អាវុធ តាំងតែពីទ្រង់នៅវ័យក្មេង រួចហើយបានរៀបអាពាហ៍ពិពាហ៍ជាមួយរាជបុត្រីរបស់ព្រះរាជា ចំណែកឯរឿងនិទានបាននិយាយថា មុននឹងឡើងសោយរាជ្យ ទ្រង់ជាប្រធានក្រុមដំណាំ ទទួលបន្ទុកថែរក្សាចម្ការត្រសក់ផ្អែម ។ ចំពោះការអះអាងរបស់អត្ថបទទាំងពីរនេះ ភាពខុសគ្នាប្រហែលស្ថិតនៅត្រង់ពាក្យ «នាយ» សំដៅយក មេ ឬប្រធាន រីឯពាក្យតាវិញ សំដៅយកឋានៈជាមេទ័ព មុននឹងបានមកធ្វើជាប្រធានក្រុមដំណាំក្នុងរាជវាំង ។

ប៉ុន្តែ អ្វីដែលធ្វើឲ្យឆ្ងល់ខ្លាំងបំផុតនោះ គឺត្រង់ដែលថា ជនជាតិដើមសំរ៉ែម្នាក់ អាចមករៀបការជាមួយ

ក្សត្រីមួយអង្គបាន ។ ចំណងមេត្រីភាពបែបនេះសព្វថ្ងៃ គេហៅថា វិសមសម្ពន្ធ គឺការយកប្ដី ឬប្រពន្ធដែលមានឋានៈទាបជាងខ្លួន តែគេមិនបានហាមឃាត់ទាំងស្រុងទេ ។ បើកាលណាម្ចាស់ក្សត្រីមួយអង្គរៀបអាពាហ៍ពិពាហ៍ជាមួយរាស្ត្រ ទោះជារដ្ឋមន្ត្រីក៏ដោយ ព្រះនាងនឹងត្រូវបាត់ព្រះឋានៈជាក្សត្រី ហើយរឿងនោះ គឺវាតែប៉ុណ្ណោះឯង ។ នៅកម្ពុជាសព្វថ្ងៃក៏នៅមានរឿងបែបនេះនៅឡើយដែរ ។ បើយ៉ាងនេះ ករណីដែលព្រះនាងលួចយកព្រះខ័នរាជ្យឲ្យប្ដី គឺគ្រាន់តែដើម្បីស្រោចស្រង់ព្រះឋានៈចាស់ប៉ុណ្ណោះ ឬចង់ឲ្យបានលើសនោះទៀត គឺក្លាយជាព្រះមហាក្សត្រីយ៍ ។

ម្យ៉ាងទៀត រឿងហេតុក៏អាចនឹងកើតបានដែរថា ព្រះនាងបានលួចយកព្រះខ័នរាជ្យទៅឲ្យសហាយ ហើយលុះតែសហាយនោះ បានឡើងសោយរាជ្យក្រោយមក ទើបបានរៀបអាពាហ៍ពិពាហ៍ជាស្វាមីភរិយានឹងគ្នា ប៉ុន្តែឈាវតាក្វាន់ មិនបានរៀបរាប់លម្អិតអស់ទេ ។ ក្នុងករណីនេះ ពួកនាម៉ឺនសព្វមុខមន្ត្រី ក្រោយពីទទួលស្គាល់ឃាតកម្ម និងប្រកាសលើកឃាតកជាស្ដេចរួចហើយត្រូវតែរៀបអភិសេកបុត្រីស្ដេចឲ្យ ដើម្បីផ្សារភ្ជាប់រាជវង្សថ្មីទៅនឹងរាជវង្សវរ្ម័នមុន ធ្វើឲ្យមានឈាមព្រាហ្មណ៍នៅក្នុងវង្សស្ដេចកាន់ពុទ្ធសាសនាដែរ ។

ខ្ញុំសូមសារភាពថា អ្វីដែលបានរៀបរាប់ខាងលើទាំងអស់នេះគ្រាន់តែជាសម្មតិកម្មប៉ុណ្ណោះ ប៉ុន្តែ តើមាននរណាដែលផ្ដល់ពត៌មានប្រសើរជាងនេះទេ ហើយតើនរណាដែលអះអាងថារឿងហេតុបានកើតឡើងខុសពីនេះ? តើមានរឿងយ៉ាងណាចាប់ពីត្រឹមរាជ្យព្រះបាទឥន្ទ្រវរ្ម័នទី៧ ដែលសោយរាជ្យនៅឆ្នាំ១២២០ រហូតមកដល់រាជ្យព្រះបាទនិព្វានបទ ដែលសោយរាជ្យនៅឆ្នាំ១៣៤០ ដែលប្រសើរជាងការសោយរាជ្យបន្តបន្ទាប់គ្នាដូចដែលរឿងព្រេងនិទានប្រាប់?

ទោះជាយ៉ាងណាក្ដី ខ្ញុំគិតថា គេមិនអាចបដិសេធថា គ្មានបដិវត្តន៍ដូចដែលខ្ញុំរៀបរាប់ខាងលើកើតឡើងនោះទេ បដិវត្តន៍នោះកើតមានឡើងនៅឆ្នាំ១២៩០ ឬ១៣២៥ ឬក៏ក្នុងចន្លោះនោះ ។ រឿងនេះ ជារឿងសំខាន់ជាងគេ ។

បើសិនជារឿងនាយចាំចម្ការបានឡើងសោយរាជ្យ មានប្រភពដើមចេញមកពីហិណ្ឌូ ហើយជារឿងដែលកើតមានយូរលង់មុនពេលដែលតាចាយ កើតយ៉ាងណាក្ដី តែគេអាចទទួលស្គាល់បានថា តាចាយ ដែលជាឃាតកសម្លាប់ស្ដេចខ្លួនឯង បានត្រូវគេលើកយករឿងនិទានបុរាណមកបំពាក់ឲ្យ ជាហេតុធ្វើឲ្យតួអង្គទាំងពីរច្រឡំគ្នា ។

# ជំពូកទី១០
# កំណត់សម្គាល់អំពីប្រទេសដែលមានទំនាក់ទំនងជាមួយកម្ពុជា ពីសតវត្សរ៍ទី១០ ដល់ សតវត្សរ៍ទី១៤

## ១- នគរចាម្ប៉ា

នៅសម័យដែលស្តេចវង្សវរ្ម័នអស់អំណាចពីប្រទេសកម្ពុជា ហើយតាចាយ ដែលជានាយក្រុមដំណាំត្រសក់ផ្អែម បានត្រូវគេលើកឲ្យឡើងសោយរាជ្យលើរាជបល្ល័ង្ក នគរចាម្ប៉ា បានបាត់បង់នូវភាពថ្កុំថ្កើងពីអតីតកាលរបស់ខ្លួនអស់ទៅហើយ ។

កាលពីក្នុងសតវត្សរ៍មុនៗ កងទ័ពចាមបានលុកលុយទន្ទ្រានទឹកដីកម្ពុជា និងអាណ្ណាមជាច្រើនដង ប៉ុន្តែត្រូវចាញ់ជានិច្ច បណ្តាលឲ្យមានការដេញតាមវាយរហូតចូលមកដល់ក្នុងប្រទេស ដុតបំផ្លាញខ្ទេចខ្ទី និងធ្វើឲ្យបាត់បង់ទឹកដីជាច្រើនអាណាខែត្រ ។

ជាក់ស្តែងគឺកម្ពុជាបានវាយដុតបំផ្លាញនគរចាម្ប៉ានៅឆ្នាំ៩៦៩ បន្ទាប់មកនៅឆ្នាំ១១៤៥ និងនៅឆ្នាំ១១៥៣ ហើយបានយកនគរចាម្ប៉ា ដាក់ជាខែត្រចំណុះរបស់កម្ពុជា អស់ចំនួន៨ឆ្នាំ ។ កម្ពុជាបានវាយយកនគរចាម្ប៉ាម្តងទៀត នៅឆ្នាំ១១៩០ ហើយបានដាក់ឲ្យព្រះយុវរាជខ្មែរមួយអង្គសោយរាជ្យអស់ពេល ៣០ឆ្នាំ រហូតដល់ឆ្នាំ១២២០ គឺទាល់តែដល់ពេលដែលខ្មែរត្រូវដកទ័ពទៅទប់ទល់ជាមួយនឹងសៀមនៅទិសខាងលិចវិញ ។ ដល់ពេលនោះទើប ស្តេចចាម ជ័យបរមេស្វរវរ្ម័នទី២ អុងអង្សៈរាជា ឡើងសោយរាជ្យនៅវិជ័យ (ប៊ិញឌិញ) ដែលជារាជធានីចាម្ប៉ាខាងជើង ជំនួសព្រះយុវរាជខ្មែរ ។

ចំណែកពួកអាណ្ណាមវិញ ដែលចាមតែងតែលួចវាយឆ្មក់តាមមាត់សមុទ្រ ឬដណ្តើមយកបណ្តាខែត្រ ភាគខាងត្បូងជាញឹកញយនោះ បានវាយនគរចាម្ប៉ា ដុតរាជធានីកម្ទេចខ្ទេចខ្ទីនៅឆ្នាំ១០១៥ ព្រមទាំងចាប់មហាក្សត្រីយ៍ និងស្រីស្នំក្រុមការយកទៅជាមួយផង ។ អាណ្ណាមវាយនគរចាម្ប៉ាម្តងទៀតនៅឆ្នាំ១០៦១ ហើយទាល់តែចាមយល់ព្រមប្រគល់អាណាខែត្រខាងជើងបីឲ្យទើបយល់ព្រមដោះលែងព្រះរាជាចាមមកវិញ ។ ចាម ចាញ់ដៃអាណ្ណាមម្តងទៀត នៅឆ្នាំ១២៤១ តែក្រោយពីបានដឹងថា គូប៊ីឡៃខាន់ បានទម្លាក់រាជវង្សសុង ពីរាជបល្ល័ង្ក ហើយដណ្តើមយកបានប្រទេសចិនទាំងមូលរួចហើយ នៅឆ្នាំ១២៨០ស្តេចចាម ជ័យសិង្ហវរ្ម័នទី២[១] បានសាកល្បងបំបែរគំនិតដណ្តើមយកទឹកដីចាម្ប៉ា ដោយធ្វើជាសុំចុះចូល ។ ក៏ប៉ុន្តែ ស្តេចគូប៊ីឡៃខាន់ បានយល់ព្រមចំពោះ

[១] ចិនហៅថា ប៉ូយាវពូលេឈូ ។

ការចុះចូលនេះ តែក្នុងល័ក្ខខ័ណ្ឌដែលនគរចាម្ប៉ាទទួលស្គាល់អាណានិគម និងយល់ព្រមឲ្យមានក្រុមប្រឹក្សាភិបាលមួយ បង្កើតឡើងដោយ គូប៊ីឡៃខាន់ ខ្លួនឯង ក្រុមប្រឹក្សាភិបាលនោះ មានសមាសភាពជាពួកតាកតារ ។ ពួកចាមបានទទួលយកអាណានិគមនេះ តែបន្ទាប់មកបានបះបោរឡើងនៅឆ្នាំ១២៨២ ដោយចាប់ភ្នាក់ងាររបស់ព្រះចៅអធិរាជឃុំឃាំងទាំងអស់ ។

ពេលនោះ ព្រះចៅអធិរាជគូប៊ីឡៃខាន់ បានបញ្ជូនទ័ពចម្រុះចិន និងតាកតារមួយកងតាមសំពៅមក ឡើងនៅកំពង់ផែឆេនឈីង ហើយវាយដណ្ដើមយករាជធានីលីនយីបាន ។ ព្រះរាជាចាម និងរាជបុត្រព្រះនាមប៉ូទី ដែលបានផ្ដល់យោបល់ថ្វាយព្រះបិតាឲ្យបះបោរប្រឆាំងនឹងចិន បានរត់ភៀសព្រះកាយទៅជ្រកកោនតាមព្រៃភ្នំ ។ ពីជម្រកលាក់ខ្លួននោះ ស្ដេចចាមបានបញ្ជូនតំណាងឲ្យចេញប្រមែប្រមូលទ័ពឡើងវិញ តែបានប្រកាសសុំធ្វើការចរចាជាមួយឧត្ដមសេនីយ៍ចិន ដើម្បីបំភ័ន្តភ្នែក រួចហើយលួចឆ្មក់វាយទៅលើរហូតដល់ទទួលបានជ័យជម្នះ ។ ដោយយល់ឃើញថាខ្លួនមានប្រៀបជាងហើយ ចាមបានស្នើសុំឲ្យចិនពិចារណាករណីខ្លួនឡើងវិញ ក៏ប៉ុន្តែ ចិនមិនព្រម ហើយចាប់បន្តសង្គ្រាមតទៅទៀត រហូតទាល់តែគូប៊ីឡៃខាន់សុគតទៅ ដោយគ្មានបានសងសឹកនឹង ចាមវិញផងទេ[២] ។

នៅឆ្នាំ១៣០០ ចាមបានវាយដណ្ដើមយកអាណាខែត្រ ដែលខ្លួនបានប្រគល់ឲ្យអាណ្ណាមកាលពីឆ្នាំ១០៨១ មកវិញ តែត្រូវអាណ្ណាមវាយបកឲ្យបរាជ័យ ហើយបង្ខំឲ្យប្រគល់ខែត្រអស់ចំនួន២ថែមទៀត ព្រមទាំងលើកបុត្រីថ្វាយស្ដេចអាណ្ណាម ទៀតផង ។ រហូតមកដល់ឆ្នាំ១៣១១ អាណ្ណាមបាននាំយកចាមម្នាក់មកឲ្យសោយរាជ្យនៅនគរចាម្ប៉ា ជំនួសស្ដេចដែលគេបានដកចេញពីរាជបល្ល័ង្ក ។

យូរៗម្ដង ពួកចាមបានវាយឆ្មក់ចូលមកដុតបំផ្លាញកម្ពុជាដែលកំពុងចុះខ្សោយ ខ្សត់ប្រជាជន និងកំពុងតែចុះអាប់ឱនណាស់ទៅហើយ ។ ក៏ប៉ុន្តែរាជាណាចក្រចាម្ប៉ាខ្លួនឯងក៏ទុរន់ទុរាខ្លាំងណាស់ដែរ នៅចាំតែពេលនឹងរលត់រលាយទៅប៉ុណ្ណោះ ។

រវាងនគរចាម្ប៉ា និងស្រុកចិន មានចម្បាំងជាប់ជាប្រចាំ ។ បើទោះជាគ្មានទ័ពចេញច្បាំងប្រឈមមុខគ្នាដោយផ្ទាល់ក្ដី តែមានអរិភាពរ៉ាំរ៉ៃរវាងគ្នា និងគ្នា បណ្ដាលមកពីទំនាស់ក្នុងពាណិជ្ជកម្មតាមសមុទ្រ ។ មានស្ដេចចាមមួយអង្គដែលចិនហៅថា អ៊ីតាតាហា គឺប្រហែលជាស្ដេចស្រីឥន្ទ្រៈ ដែលឯកសារអាណ្ណាមហៅថា ចេបុងញ៉ាបានឡើងសោយរាជ្យនៅឆ្នាំ១៣៧៣ ស្ដេចនោះមិនមានបន្សល់ស្នាដៃអ្វីឲ្យយើងដឹងតាមសិលាចារឹកទេ (ព្រោះជាសម័យចុះអាប់ឱនហើយ) បានឆ្លៀតឱកាសដែលរាជវង្សម៉ុងហ្គោលត្រូវគាស់រំលើង ហើយរាជវង្សមិញ

[២] P.Gaubil, Notice historique sur la Cochinchine, p. 57 du 31e vol, de Lettres édifiantes.

កំពុងរៀបចំកសាងឡើង បានបញ្ជូនរាជទូត និងវត្ថុមានតម្លៃទៅថ្វាយព្រះអធិរាជចិនថ្មី ។ បន្តិចក្រោយមក ស្តេចចាមនោះបានបញ្ជូនឈើប្រណីត ដែលចាប់បានពីសំពៅចោរសមុទ្រចំនួន២០ ទៅថ្វាយព្រះអធិរាជចិនទៀត ជាហេតុធ្វើឲ្យព្រះចៅអធិរាជចិនត្រេកអរជាខ្លាំង ។

ទោះជាយ៉ាងនោះក្តី ពួកចាមតែងមានគំនិតចង់រំដោះយកអាណាខេត្តចំនួន៥ ដែលអាណ្ណាមដណ្តើមយកមកវិញជានិច្ច ព្រោះគេមិនចង់ឲ្យស្រុករលត់រលាយទេ ក៏កើតមានគំនិតចង់ធ្វើសង្គ្រាមសងសឹក ។ ស្តេចស្រុកចិនបានហាមចាមមិនឲ្យធ្វើចម្បាំងជាមួយតុងកឹង គឺឲ្យរក្សាសន្តិភាព ។ ក៏ប៉ុន្តែសន្តិភាពនៅពេលដែលបាត់បង់ទឹកដី គឺប្រៀបបានទៅនឹងការស្លាប់ ។ ផ្ទុយទៅវិញ បើធ្វើសង្គ្រាម គេប្រហែលជាអាចដណ្តើមយកទឹកដីមកវិញ និងអាចកសាងប្រទេសឡើងវិញផង ។ ម្ល៉ោះហើយគេក៏ធ្វើសង្គ្រាម ដែលមិនបាននាំមកនូវផលប្រយោជន៍ផ្ទាល់អ្វីទេ ទោះបីជាព្រះចៅអធិរាជចិនបានហាមប្រាមយ៉ាងណាក៏ដោយ ព្រោះព្រះចៅអធិរាជចិននោះ ក៏មិនបានយល់ពីទឹកចិត្តពួកចាមដែរ ។

នៅក្នុងឆ្នាំ១៣៧៧ ពួកចាមដែលដឹកនាំដោយស្តេចចេបុងញ៉ា បានធ្វើការវាយប្រហារទៅលើទ័ពអាណ្ណាមរហូតដល់ដើងកំដែងចាបានជារាជធានីថ្មីរបស់គេ ដោយកាប់សម្លាប់ស្តេចត្រាន់ឌឹកតុង និងសេនាបតីស្ទើរតែទាំងអស់ ។ ឆ្លៀតឱកាសដែលខ្លួនកំពុងមានប្រៀបនេះ ពួកចាមបានបន្តធ្វើការវាយលុកទៅលើតុងកឹងទៀត តែត្រូវបរាជ័យនៅនឹងកំពង់ដៃដៃអាន និងធានភូ ។ ប៉ុន្មានខែក្រោយមក ជាសំណាងអាក្រក់របស់ពួកចាម ខ្យល់ព្យុះធំមួយបានបក់បោកបំផ្លាញសំពៅអស់ នៅពេលដែលពួកគេប្រុងចេញដំណើរទៅវាយតុងកឹង ម្តងទៀត ។

នៅក្នុងឆ្នាំ១៣៧៨ ចាមបានលើកអនុជរបស់អតីតស្តេចអាណ្ណាម ដែលខ្លួនបានចាប់ទុកជាឈ្លើយ ឲ្យសោយរាជ្យនៅទឹកដីតុងកឹងខាងត្បូង ដោយបានរៀបចំកម្លាំងគាំទ្រវឹងមាំ មានទាំងពួកសេនាហែហម និងពួកចាមក្នុងស្រុកទៀតផង ។ ក៏ប៉ុន្តែទ័ពអាណ្ណាម បានវាយបណ្តេញពួកចាមជាប់រហូតទៅដល់រាជធានីចាម្ប៉ា ។ រាជធានីចាបានក៏ត្រូវធ្លាក់ក្នុងដៃអាណ្ណាមម្តងទៀត ហើយទ័ពអាណ្ណាមបានប្រមូលទ្រព្យសម្បត្តិជាច្រើន យកទៅជាមួយនៅពេលដែលដកចេញទៅវិញ ។

នៅឆ្នាំ១៣៨២ ក្រោយពីរៀបចំប្រទេសសាជាថ្មីរួចហើយ ពួកចាមបានលើកទ័ពទៅវាយង៉េអាននិងថាញ់វ៉ា ដើម្បីជួយគាំទ្រពួកអ្នកស្រុកដែលភាគច្រើនជាចាមកំពុងបះបោរប្រឆាំងនឹងអាណ្ណាម ។ ស្តេចចាមដឹកនាំទ័ពជើងទឹក តែត្រូវបរាជ័យពេលឡើងមកលើគោក ជាហេតុធ្វើឲ្យទ័ពជើងគោកត្រូវបរាជ័យ រត់យកតែប្រាសអាយុរៀងៗខ្លួនដែរ ។ ពួកចាមបានលើកទ័ពមកម្តងទៀត វាយយកថាញ់វ៉ាបាន តែក៏ត្រូវវាយឲ្យបរាជ័យទៀត ហើយសំពៅចាមត្រូវដុតបំផ្លាញខ្ទេចខ្ទីអស់ ។

ត្រលប់មកដល់ស្រុកវិញ ពួកចាមក៏រៀបចំខ្លួនប្រុងចេញធ្វើសង្គ្រាមជាថ្មី ។ ពួកអាណ្ណាមបានចេញទ័ពមកវាយមុន ទាំងតាមជើងគោក ទាំងតាមផ្លូវទឹក ។ ទ័ពផ្លូវទឹកត្រូវខ្យល់ព្យុះបោកកម្ទេច ទុកឱកាសឲ្យស្តេច

ស្រីឥន្ទ្រៈ វាយបំបែកទ័ពជើងគោករបស់អាណ្ណាមក្នុងសមរភូមិចំនួន៦ រួចវាយចូលរាជធានីតុងកឹងបានជោគជ័យ ធ្វើឲ្យស្តេចអាណ្ណាមរត់ភៀសខ្លួនបាត់ទៅ ។ ពួកចាមនៅកាន់កាប់តុងកឹងបានចំនួន៦ខែ ក៏ត្រូវដកថយទៅស្រុកវិញ ព្រោះអស់ស្បៀង ។

ពួកចាមចេញវាយអាណ្ណាមបានឈ្នះម្តងទៀតនៅឆ្នាំ១៣៩០ តែត្រូវបរាជ័យវិញនៅពេល២ឆ្នាំក្រោយមក ហើយព្រះបាទស្រីឥន្ទ្រៈដែលជាព្រះរាជាដ៏មានគុណសម្បត្តិ មិនចេះខ្លៀយហត់ក្នុងសង្គ្រាម បានត្រូវពួកអាណ្ណាមបាញ់កាំភ្លើងត្រូវ ហើយសុគតនៅលើសំពៅនោះទៅ ។ ចាប់ពីពេលនោះមក ចាមត្រូវបាត់បង់ទាំងអ្នកដឹកនាំទាំងថាមពល ។

ក្រោយនោះ មានឧត្តមសេនីយ៍ម្នាក់ឈ្មោះ លីខៃ បានដណ្តើមយកអំណាចនៅចាម្ប៉ា ចំណែកនៅឯអាណ្ណាមវិញ ក៏មានឧត្តមសេនីយម្នាក់ដណ្តើមយករាជសម្បត្តិដែរ ។ ភាពច្របូកច្របល់បណ្តាលមកពីការជ្រែករាជ្យនេះបានធ្វើឲ្យនគរទាំងពីរផ្អាកការធ្វើសង្គ្រាមនឹងគ្នា មួយរយៈសិន ។

សង្គ្រាមចាម្ប៉ា-អាណ្ណាមបានចាប់ផ្តើមឡើងវិញនៅឆ្នាំ១៤០៣ ក្រោយមរណភាពរបស់លីខៃ ក្រោមរជ្ជកាលព្រះរាជាដែលអាណ្ណាមហៅថាបាឌិចខ្មៃ ហើយចិនហៅថាឆេនប៉ាធីខ្មៃ ។ ពេលនេះ គឺពួកអាណ្ណាមជាអ្នកចេញវាយចាម្ប៉ាវិញម្តង ។ ពួកចាមមិនអាចទប់ទល់នឹងទ័ពអាណ្ណាមបានក៏សុំចរចាសន្តិភាព តែត្រូវប្រគល់ដែនដីកូលុយឲ្យ ដែលអាណ្ណាមរៀបចំចេញជាខែត្រថាញ់វ៉ា (ក្វាងណាម) និងទីងា (ក្វាងង៉ាយ) ដោយដាក់នៅក្រោមការត្រួតត្រារបស់មេទ័ពចាមក្បត់ម្នាក់ ។

ពេលនោះ ពួកអាណ្ណាមមានគំនិតចង់បំបាត់នគរចាម្ប៉ា ដែលធ្វើសង្គ្រាមជាមួយពួកគេចំនួន៦សតវត្សរ៍មកហើយ ហើយទោះបីជាបរាជ័យទៅហើយក្តី ក៏នៅតែកាន់អាវុធប្រឆាំងជានិច្ច ។ ស្តេចចាមបានដឹងពីគោលបំណងនេះ ក៏សុំឲ្យព្រះចៅអធិរាជចិនជួយធ្វើអន្តរាគមន៍ ។ ប៉ុន្តែអាណ្ណាមមិនអើពើនឹងអន្តរាគមន៍របស់ចិនទេ ហើយបានឈ្លានពានចូលខែត្រចាលីយ៉ា ដែលពួកចាមដណ្តើមយកបានកាលពីប៉ុន្មានឆ្នាំមុន ។ ស្តេចចាម ឆេនប៉ាធីខ្មៃ ខឹងនឹងអធិរាជចិន ដោយសង្ស័យថា បោះបង់ខ្លួនចោល ហើយក៏តាំងចងសម្ព័ន្ធមេត្រីជាមួយមេបះបោរតុងកឹងម្នាក់ ជាហេតុធ្វើឲ្យព្រះចៅអធិរាជចិនរឹតតែខឹងខ្លាំងឡើង ហើយបោះបង់ស្តេចចាមចោលមែនទែនតែម្តង ។ ពួកអាណ្ណាមក៏តាំងវាយទន្ទ្រានយកនគរចាម្ប៉ា ដែលគ្មានកម្លាំងអ្វីនឹងទប់ទល់ លើកលែងតែរាជធានីចាបានមួយប៉ុណ្ណោះ ដែលមានកំពែងការពាររឹងមាំ ។ ដោយប្រទេសពេលនោះក្រីក្រខ្លាំង ពិបាកនឹងរកស្បៀង ពួកអាណ្ណាមក៏ដកទ័ពថយទៅស្រុកវិញទៅ ។

ប៉ុន្មានឆ្នាំក្រោយមក អាណ្ណាម បានធ្វើសង្គ្រាមជាមួយចិនដែលទាមទារយកខែត្រឡាងសឺង ។ ពេលនោះពួកចាមគួរតែឆ្លៀតឱកាសដែលសត្រូវជាប់រវល់ ដើម្បីកសាងប្រទេសឡើងវិញ ។ ប៉ុន្តែនគរចាម្ប៉ាពេលនោះចុះខ្សោយខ្លាំងណាស់ទៅហើយ អ្វីៗបាក់បែកខ្ទេចខ្ទាំ រាស្ត្រក៏លែងគោរពព្រះរាជា ។ ម្នាក់ៗគិតតែពីប្រយោជន៍

ផ្ទាល់ខ្លួន រាជាណាចក្រទាំងមូលត្រូវបែងចែកក្រោមអំណាចមេកោយផ្សេងៗគ្នា ។ អាណ្ណាមពេលនោះចំណុះស្រុកចិន តែដោយចាមមិនបានជួយចិន ចិនក៏ប្រឆាំងនឹងចាមដែរ ។ ចាមអាចនឹងចងសម្ព័ន្ធភាពជាមួយអាណ្ណាមប្រឆាំងនឹងចិន ហើយអាចទាមទារជាថ្នូរនឹងមេត្រីភាពនោះ ឬជាថ្នូរនឹងការមិនជួយចិន នូវទឹកដីដែលអាណ្ណាមដណ្តើមយក មកវិញបាន ។ ចាមក៏អាចវាយដណ្តើមយកទឹកដីទាំងនោះដោយផ្ទាល់មកវិញបានដែរ ហើយរៀបចំស្រុកឡើងវិញ ក្នុងពេលដែលអាណ្ណាមជាប់ដៃធ្វើសង្គ្រាម១០ឆ្នាំជាមួយចិន ។ ក៏ប៉ុន្តែចាម មិនបានធ្វើអ្វីទាល់តែសោះ គឺនៅទ្រឹងអសកម្មពេញមួយរយៈកាលសង្គ្រាមនោះ និងក្រោយៗមកទៀត ។

ទម្រាំតែចាមនឹកឃើញ ហើយបង្ហាញខ្លួននៅតាមជាយដែនអាណ្ណាមនៅឆ្នាំ១៤៤៤ ក្រោមការដឹកនាំរបស់ស្តេចមួយអង្គដែលអាណ្ណាមហៅថាប៊ីកាយ ឯកសារចិនហៅថាម៉ាហូពេនកៃ អ្វីៗបានហួសអស់ទៅ ហើយ ។ តុងកឹងបានរៀបចំខ្លួនឡើងវិញ ហើយអាណ្ណាមមានសមត្ថភាពគ្រប់គ្រាន់ដើម្បីការពារខ្លួន ។ អាណ្ណាម បានទប់ទល់ជាមួយទ័ពចាមជាប់ ហើយថែមទាំងបានវាយបករហូតមកដល់រាជធានីចាបានទៀត ។ ស្តេចម៉ាហូពេនកៃបានត្រូវចាប់ជាឈ្លើយជាមួយនឹងរាជវង្ស និងបរិពារ ។

ពេលនោះ នាម៉ឺនសព្វមុខមន្ត្រីមិនអល់អែកនឹងទម្លាក់ស្តេចចំណាប់ខ្មាំងនោះចេញទេ ព្រោះវារំខានដល់វាសនាប្រទេសជាតិ ហើយលើករាជវង្សមួយអង្គដែលអាណ្ណាមហៅថា ម៉ាហូគ្វីឡាយ ឯកសារចិនហៅថា ម៉ាហូគៃយឡាយ ត្រូវជាក្មួយស្តេចឆេនប៉ាទីឡៃ ឲ្យឡើងសោយរាជ្យជំនួសវិញ[៣] ។ ជ្រើសតាំងស្តេចថ្មីនេះរួចហើយ ពួកនាម៉ឺនសព្វមុខមន្ត្រីបានស្នើសុំការឯកភាពពីអធិរាជចិន ហើយលែងនឹកនាដល់ស្តេច ដែលអាណ្ណាមចាប់ជាឈ្លើយតទៅទៀត ។

គឺនៅពេលនោះហើយ ដែលពួកអាណ្ណាមធ្វើនយោបាយបំបែកបំបាក់សត្រូវ ដោយដោះលែងស្តេចម៉ាហូពេនកៃ ហើយចាត់កម្លាំងឲ្យជូនទៅដល់ទល់ដែននគរចាម្ប៉ា ។ ពេលយាងទៅដល់រាជធានី ស្តេចម៉ាហូពេនកៃទទួលដំណឹងថា ព្រះរាជាដែលគេជ្រើសតាំងនោះ បានត្រូវគេធ្វើឃាតបាត់ទៅហើយ ហើយជំនួសវិញដោយស្តេចដែលអាណ្ណាមហៅថាគ្វីជូ ។ ស្តេចគ្វីជូនេះដែលយល់ព្រមចរចាជាមួយអាណ្ណាម បានត្រូវគេចាត់ទុកថា បានធ្វើឃាតស្តេច ហើយអ្វីៗហាក់ដូចជានៅត្រឹមនោះ ។

ឯកសារប្រវត្តិសាស្ត្រចិនបានរៀបរាប់បន្ទាប់មកអំពីស្តេចមួយអង្គទៀត ដែលពួកគេដាក់ឈ្មោះថា ម៉ូតូប៉ានឡាយវេ ដែលទ្រង់សុគតនៅឆ្នាំ១៤៦០ ។ ពួកអាណ្ណាមហៅស្តេចនេះថាបានឡាត្រាធៀត ហើយនិយាយថា ស្តេចនេះបានធ្វើឃាតស្តេចគ្វីជូដណ្តើមរាជសម្បត្តិ រួចហើយបានដាក់រាជសម្បត្តិឲ្យទៅព្រះអនុជ

---

[៣] ឯកសារប្រវត្តិសាស្ត្រអាណ្ណាមនិយាយថា គឺពួកអាណ្ណាមដែលបញ្ជាឲ្យជ្រើសតាំងដូច្នេះ ។

ព្រះនាមបានឡាត្រាលួន ចិនហៅថា បានឡាថាត្សូន ។

ព្រះរាជាថ្មីរបស់នគរចាម្ប៉ានេះបានលើកទ័ពទៅវាយខែត្រហ្វាចូវ ជាហេតុធ្វើឲ្យពួកអាណ្ណាមបានលេសវង់ចាំតែឱកាសល្អយូរណាស់មកហើយនោះ ក៏សម្រេចបញ្ចប់រឿង វាយយកនគរចាម្ប៉ាដាក់បញ្ចូលមកក្នុងទឹកដីខ្លួន ។ អាណ្ណាមបញ្ជូនទ័ពថ្មើរជើងចំនួន១៦ម៉ឺននាក់ និងទ័ពជើងទឹក១ម៉ឺនសំពៅ មានគ្នាមិនតិចជាង១០ម៉ឺននាក់ឡើយ ។ ស្តេចចាមភ័យ ក៏ប្រកាសសុំចរចាសន្តិភាព ។ អាណ្ណាមយល់ព្រមចរចា តែមិនឯកភាពលើសំណើរបស់ចាម្ប៉ាទេ ។

ចប់ការចរចានេះ សង្គ្រាមបានចាប់ផ្តើម ហើយអាណ្ណាមឡោមព័ទ្ធបន្ទាយធីណាយភ្លាម ។ ថ្ងៃបន្ទាប់ រាជធានីចាមត្រូវអាណ្ណាមដណ្តើមយកបាន ធ្វើឲ្យមានការដុតបំផ្លាញ និងសម្លាប់រង្គាល ៖ មនុស្ស៤ម៉ឺននាក់បានត្រូវសម្លាប់ និង៣ម៉ឺននាក់ទៀតត្រូវចាប់ជាឈ្លើយ នាំយកទៅកាន់តុងកឹង ។ ព្រះរាជាស្ថិតនៅក្នុងចំណោមចំណាប់ខ្មាំងនឹងគេដែរ តែមានការថែទាំល្អជាង ថ្វីបើមិនព្រមចុះចូល និងមានចរិតកាចសាហាវយ៉ាងណាក្តី ។ ទ្រង់សុគតតាមផ្លូវនៅ ង៉េអាន ហើយស្តេចអាណ្ណាមបានបញ្ជាឲ្យកាត់ព្រះកេសដោតមុខក្បួនសំពៅ ដាក់ក្រោមបដាពណ៌សមួយសរសេរអក្សរថា "ក្បាលស្តេចត្រាលួន ដែលជាប្រភពនៃទុក្ខសោករបស់នគរចាម្ប៉ា" ។

រឿងរាជាណាចក្រពួកអ្នកចម្បាំងបានបញ្ចប់ទៅយ៉ាងដូច្នេះ ។ អាណាខែត្រទាំងអស់ លើកលែងតែរាជាណាចក្រផានរ៉ាង មួយចេញ ដែលមិនកាន់សាសនាមហាម៉ាត់ បានត្រូវអាណ្ណាមដាក់បញ្ចូលជាទឹកដី មានអភិបាលខែត្រជាអាណ្ណាមនៅត្រួតត្រា ។ មានបញ្ញវន្តចាមម្នាក់នៅកម្ពុជាបានប្រាប់ខ្ញុំថា ៖ "ដើម្បីគេចពីនឹមត្រួតត្រារបស់អាណ្ណាម អ្នកស្រុកនាំគ្នារត់ចេញ ខ្លះទៅនៅក្នុងព្រៃភ្នំជាមួយពួកម៉យ ខ្លះឆ្លងទៅកម្ពុជា ខ្លះទៅកោះស៊ូម៉ាត្រា នៅសល់តែពួកស្រីៗ ពួកកំសាក ពួកចាស់ជរា និងកុមារប៉ុណ្ណោះ" ។

តាមពិត ពួកអាណ្ណាមបានទុកឲ្យមេកោយចាមជាច្រើនបន្តតាំងទីលំនៅ នៅភាគខាងត្បូងរាជាណាចក្រជាមួយនឹងខ្ញុំកំដររបស់គេ គឺពួកដែលមិនដែលធ្វើសង្គ្រាមជាមួយអាណ្ណាម ។ ចំណែកពួកអ្នកស្រែចម្ការវិញ គេនៅរស់លើដីរបស់គេ ហើយចាប់ទទួលអារ្យធម៌អាណ្ណាមបន្តិចម្តងៗ ។ ពួកចាមណាដែលនៅរក្សាទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួននៅភាគខាងត្បូង អាណ្ណាមដាក់ឈ្មោះឲ្យថា "ហូយ" ។

យើងនឹងបានឃើញនៅពេលក្រោយ អំពីតួនាទីរបស់ពួកចាមនេះនៅក្នុងប្រវត្តិសាស្ត្ររបស់រាជាណាចក្រអាណ្ណាម ហើយនិងបច្ច័យដែលជួយឲ្យពួកស្តេចកូសាំងស៊ីន គេចផុតពីអនុត្តរភាពស្តេចតុងកឹង ហើយរៀបចំកសាងរាជាណាចក្រអាណ្ណាមទី២ឡើង ។

ចំណែកពួកចាមដែលមិនព្រមសម្របសម្រួលជាមួយអ្នកឈ្នះអាណ្ណាម និងមិនព្រមរស់ក្រោមការត្រួតត្រារបស់អាណ្ណាម ត្រូវគេចាប់ចុះទូកសំពៅបើកក្តោងសំដៅសមុទ្រខាងត្បូង ឆ្លងកាត់ច្រកសិង្ហបុរី សំដៅទៅចំណុចខាងជើងកោះស៊ូម៉ាត្រា ដែលជាស្រុកកំណើតដើមរបស់គេ កសាងរាជាណាចក្រអាឆេ ឬហៅថា អាចេន

ឬអាត់ឈីនន័រ ដែលរដ្ឋនេះមាននៅរហូតដល់សព្វថ្ងៃ ជួនកាលដឹកនាំដោយព្រះរាជាមួយអង្គ ជួនកាលទៀតដឹកនាំដោយក្សត្រីមួយអង្គ ។ នៅក្នុងអាណាចក្រថ្មីនេះ ពួកចាមដែលបានក្លាយខ្លួនជាពួកអាត់ឈីនន័រ នៅតែជាប្រជារាស្ត្រមួយដូចពីមុន គឺរំដើបរំជួល ស្វាហាប់ ចូលចិត្តចម្បាំង ក្លាហាន ធ្វើបដិវត្តន៍ និងចូលចិត្តប្រតិបត្តិការ ។ នៅសតវត្សរ៍ទី១៩ ពួកហុល្លង់ ត្រូវប្រើពេលអស់៣០ឆ្នាំ ដើម្បីដណ្ដើមយកជ័យជម្នះលើពួកនេះបានជាស្ថាពរ ហើយរាជាណាចក្ររបស់ពួកនេះ ទើបតែត្រូវបំផ្លាញបាននៅពេលសព្វថ្ងៃនេះប៉ុណ្ណោះ គឺនៅឆ្នាំ១៩០០[៤] ។

## ២- អាណ្ណាម-តុងកឹង

ក្រោយសង្គ្រាមទាមទារឯករាជ្យពីប្រទេសចិន អាណ្ណាមត្រូវបែងចែកទឹកដីជា ១៣ខេត្ត នៅឆ្នាំ៩៦៨ ទៅតាមអំណាចរបស់មេទ័ពផ្សេងៗ ហើយស្ថិតក្នុងសភាពអនាធិបតេយ្យ ដែលនឹងធ្វើឲ្យប្រទេសនេះធ្លាក់ចូលក្នុងនឹមត្រួតត្រារបស់បរទេសវិញ ក្នុងពេលមិនយូរប៉ុន្មាន ។

ពេលនោះមានអតីតនាយគោបាលម្នាក់ ជាខ្ញុំចៅហ្វាយខេត្តហាងចូវ ក្រោយមកបានមកនៅបម្រើចៅហ្វាយខេត្តបូចាញ់ បានកេណ្ឌទ័ពវាយយកខេត្តបានមួយម្ដងៗ រហូតគ្រប់ទាំង១៣ រួចហើយក៏ប្រកាសខ្លួនជាស្ដេចសោយរាជ្យនៅភូញ៉ូក្វាន ហើយបានដាក់ឈ្មោះនគរថា ដៃគូវៀត ។ ថ្ងៃមួយ ស្ដេចនេះ និងរាជបុត្រច្បងបានត្រូវគេធ្វើឃាតនៅពេលដែលស្រវឹងស្រាខ្លាំង ហើយដួលដេកនៅក្នុងទីធ្លាមុខរាជវាំង ។ ឃាតកត្រូវគេចាប់បាន ហើយត្រូវប្រជារាស្ត្រកាប់ចិញ្ច្រាំសាច់ចែកគ្នាបរិភោគ ។ ហេតុការណ៍នេះបញ្ជាក់ឲ្យយើងដឹងថា ប្រជាជនអាណ្ណាម នៅស៊ីសាច់មនុស្សនៅឡើយ នៅសតវត្សរ៍ទី១០ ហើយថា ពួកនេះជាពួកស៊ីសាច់មនុស្សបើហោច

---

[៤] មានផែនទីឥណ្ឌូចិនមួយ គូរនៅចុងសតវត្សរ៍ទី៧ ដោយលោកឪពុក សេស៊ីត ដែលគេបញ្ជូនឲ្យទៅផ្សព្វផ្សាយគ្រិស្តសាសនានៅប្រទេសសៀមក្នុងឆ្នាំ១៦៨៥ បានបង្ហាញឲ្យយើងឃើញអំពីទឹកដីដែលសេសសល់ពីមហាណាចក្រចាម្ប៉ា ៖ នោះគឺជាទឹកដីមានរាងជាត្រីកោណតូចមួយ មានបាតលាតសន្ធឹងពីព្រំប្រទល់ខាងកើតរបស់កូសាំងស៊ីនបច្ចុប្បន្ន ទៅដល់មាត់ពាមទន្លេសាយហ្គននៅខាងលិច ហើយមានកំពូលនៅខាងជើងឆៀងពាយ័ព្យត្រឹមកម្ពស់បាណាម តែខិតទៅកើតបន្តិច ។ ផែនទីនេះមិនត្រឹមត្រូវទេ ព្រោះថាត្រីកោណចាមត្រូវគូសរហូតទៅដល់គ្របដណ្ដប់បិញធន់ទាំងមូល ។ នៅលើផែនទីនោះ ខ្ញុំមើលឃើញស្គាល់ទឹកដីចាម្ប៉ាពីមុនដែលបានក្លាយទៅជាខេត្តរបស់អាណ្ណាមរួចទៅហើយចាប់ពីខាងត្បូងទៅ គឺ ៖ ដានរ៉ាង (បណ្ឌុរង្គ) គឺបិញធន់សព្វថ្ងៃ, គីញ៉ឹង ឬពូឡូកំបឺ សព្វថ្ងៃជាស្រុកមួយរបស់ខេត្តថាញ់វ៉ា, ញ៉ា ឬគីញ៉ឹន គឺជា មចិម ពោលគឺ ចាម ពិតប្រាកដ សព្វថ្ងៃត្រូវនឹងខេត្តក្វាងណាម ដែលមាន ទូរ៉ាន នៅក្នុងនោះ កន្លែងនេះហើយជាទីកន្លែងដែលនិគមចាមមុនគេបានមកតាំងនៅ តាំងពីមុនគ្រិស្តសករាជម៉្ល៉េះ, ថាញ់វ៉ា, នៅពីឆ្ងាសាននោះគឺក្វាងបិញ ហើយនៅពីខាងជើងគឺក្វាងវិញ ខេត្តខាងត្បូងគេរបស់តុងកឹង ។ ក្នុងផែនទីនោះគេហៅនគរចាម្ប៉ាថា កូសាំងស៊ីន រីឯអាណ្ណាមវិញគេ ហៅថា តុងកឹង ក៏ប៉ុន្តែពួកអាណ្ណាមខ្លួនឯងគេហៅស្រុកទាំង២ថា អាណ្ណាម ខ្មែរហៅថា ស្រុកយួន ។

ណាស់ ក៏ក្នុងការសងសឹកដែរ ។

រាជានិយមទី១ នេះត្រូវរលត់បាត់បង់ទៅជាមួយនឹងបុត្រពៅរបស់ប៊ិញទៀនហ្វង ដែលសោយរាជ្យបាន ៨ខែ ក៏ត្រូវឧត្តមសេនីយ៍ឡេហ៊ាន់ទម្លាក់ពីរាជសម្បត្តិ បង្កើតសន្តតិវង្សឡេខាងដើមឡើង ។ ស្តេចឡេហ៊ាន់ នេះ ជាស្តេចពូកែខាងចម្បាំង ។ ព្រះអង្គបានវាយពួកចិនដែលឈ្លានពានចូលមកអាណ្ណាមក្នុងឆ្នាំ៩៨១ រួចវាយនគរចាម្ប៉ា ដែលបានឃាត់ទុកទូតដែលអាណ្ណាមបញ្ជូនទៅ ដណ្តើមយករាជធានីបាន រួចដុតកម្ទេចចោល ។ សន្តតិវង្ស នេះ ត្រូវរលត់បាត់ទៅនៅឆ្នាំ១០១០ ជាមួយនឹងមរណភាពរបស់បុត្ររបស់ឡេហ៊ាន់មួយរូប ព្រះនាមថា ឡេង៉ាវទ្រី ដែលបានសម្លាប់បងប្អូនអស់៣នាក់ ដើម្បីបំបែកពីរាជសម្បត្តិ មានបងមួយនោះសោយរាជ្យបាន តែ៣ថ្ងៃ ឡេង៉ាវទ្រី នេះ ប្រយុទ្ធអស់៨ខែទើបឡើងសោយរាជ្យបាន ។ ក្រោយពីស្តេចនេះសុគតទៅរាជបុត្ររបស់ព្រះអង្គ បានត្រូវឈ្មោះ លីថៃតូ ដែលជាអ្នកមើលថែរក្សា បំបែកចេញពីរាជសម្បត្តិដែរ ហើយលើកខ្លួនឯងជារាជានុសិទ្ធិមុននឹងកសាងសន្តតិវង្សផ្ទាល់ខ្លួនឡើង ។

សន្តតិវង្សទី៣នេះ គេហៅថា សន្តតិវង្សឡេខាងក្រោយ មានស្តេច៩អង្គសោយរាជ្យនៅអាណ្ណាម បាន ២១៦ឆ្នាំ ពីឆ្នាំ១០១០ ដល់១២២៥ ។

ស្តេចទាំង៩អង្គនោះប្រហែលគង់នៅរាជធានីដៃឡាទាំងអស់គ្នា ដែលក្រោយមកគេហៅថា ថាំងឡុង បន្ទាប់មកហាណូយ ។

ពង្សាវតាររបស់រាជវង្សនេះគឺជាប្រវត្តិរឿងរ៉ាវដ៏វែង ស្តីអំពីការប្រយុទ្ធដណ្តើមរាជបល្ល័ង្ក ការបះបោរជាច្រើន ជួនកាលនៅក្នុងប្រទេស ជួនកាលទៀតនៅជាយដែនក្នុងចំណោមជនជាតិភាគតិច មិនទាន់ស៊ីវិល័យ ដែលទទួលស្គាល់អនុត្តរភាពអាណ្ណាម តែចង់រស់នៅឯករាជនៅលើទឹកដីរបស់ខ្លួន, ពីសង្គ្រាមជាមួយប្រទេសចិន ដែលតែងតែប៉ុនប៉ងយកអាណ្ណាមដាក់ក្រោមនឹមត្រួតត្រារបស់ខ្លួន ឬក៏ឲ្យស្តេចអាណ្ណាមយល់ព្រមចំណុះអធិរាជចិន និងសង្គ្រាមជាមួយនគរចាម្ប៉ា ដែលតែងតែឆ្មក់មកវាយតាមមាត់សមុទ្រ និងតាមជាយដែនមិនឈប់ឈរ ។

ទ័ពចិនច្បាំងចាញ់ហើយត្រូវបានរុញច្រានឲ្យដកថយទៅវិញ ។ ចំណែកឯពួកចាមវិញ ដែលក្លាហាន តែគ្មានវិន័យ ជួនកាលច្បាំងឈ្នះស្ទើរតែធ្វើឲ្យអាណាចក្រអាណ្ណាមរង្គោះរង្គើ ប៉ុន្តែភាគច្រើន គឺត្រូវអាណ្ណាម វាយកាប់សម្លាប់ ធ្វើឲ្យថយដៃជាបន្តបន្ទាប់ និងត្រូវបានបណ្តេញចេញពីអាណាខេត្រខាងជើង ឲ្យដកថយរហូតដល់ក្វាងណាម នៅខាងត្បូងទូរ៉ាន ថែមទៀត ។

ចំពោះពួកវិប្រជាពាក់កណ្តាលស៊ីវិល័យនៅទិសខាងជើង និងខាងពាយ័ព្យវិញ ដែលចុះមកពីខេត្រយុនណាន ហើយមានដើមកំណើតជាពួក ថ ឬថៃ ពោលគឺ កាត់ថៃជាមួយអ្នករដ្ឋវាសី មិនទាន់ស៊ីវិល័យ និងពួកកុលសម្ព័ន្ធដែលរស់នៅតំបន់អាងទន្លេខាងលើ នៅលើខ្ពង់រាបដែលពួកអាណ្ណាមមិនសូវទៅដល់ ពួកនោះបានធ្វើចម្បាំងនឹងគ្នា ជួនកាលឆ្លងទៅវាយចិន ជួនកាលចុះមកវាយអាណ្ណាម ដុតបំផ្លាញភូមិតាមវាលទំនាបខ្ទេចខ្ទីដែលពួកនោះ

ទៅដល់ ។ ត្រូវចិនវាយពីខាងជើង និងអាណ្ណាមវាយពីខាងត្បូង ពួកនេះត្រូវចាញ់ដៃ រួចដកថយ ប៉ុន្តែ មិនយូរប៉ុន្មាន ក៏ត្រលប់វិលមកវិញទៀត ជាច្រើនលើកច្រើនសា ។ ពួកទាំងអស់នេះគ្មានអ្វីទេ ពេលដកថយចេញទៅក៏គ្មានបន្សល់ទុកអ្វីដែរ ទៅដល់ស្រុកកំណើតក៏គ្មានអ្វី តែគេកសាងអ្វីៗឡើងវិញបានតែក្នុងពេលពីរ-បីថ្ងៃប៉ុណ្ណោះ ពួកនេះមិនចេះចាញ់ទេ ។ ពួកអាណ្ណាមក៏ដូចជាពួកចិន មិនអាចរំខានពួកគេបានយូរឡើយ តែពួកគេរំខានសត្រូវរបស់គេបានជានិច្ច បើទោះជាថាការវាយលុករបស់គេនោះមានរយៈពេលខ្លីក៏ដោយ ហើយការវាយប្រហារនោះគ្មានមូលហេតុអ្វីក្រៅតែពីសង្សឹក និងលួចប្លន់ ប៉ុណ្ណោះ ។

មានកុលសម្ព័ន្ធមួយ ឈ្មោះថា កុលសម្ព័ន្ធនុង ម្តងនោះ បានប្រមែប្រមូលកុលសម្ព័ន្ធដែលនៅជិតខាង ក្នុងខែត្រក្វាងនៀន ឲ្យរួបរួមគ្នានៅក្រោមការដឹកនាំរបស់មេតែមួយ ។ សម្ព័ន្ធភាពនេះ ដែលពួកអាណ្ណាម និងចិនដាក់ឈ្មោះថា រាជាណាចក្រនុង មានជីវិតបានប្រហែលជា៣០ឆ្នាំដែរ ។ ក្នុងរយៈកាលនេះ មេដឹកនាំរបស់គេម្នាក់ៗបានប្រកាសខ្លួនជាព្រះចៅអធិរាជ ។ មេម្នាក់មានដើមកំណើតមកពីរាជធានីទ្រឿងសាញ់ ។ ម្នាក់ទៀតមកពីដាយលិច ជាស្រុកស្រែចម្ការ ។ មេទី៣ ដែលបានវាយទន្ទ្រានដល់ខែត្រក្វាងស៊ី និងក្វាងទុង របស់ចិន បានប្រកាសខ្លួនជាព្រះចៅអធិរាជរបស់ដាយណាម ជាមហាអាណាចក្រភាគខាងត្បូង ។ ក៏ប៉ុន្តែ ស្ថិតនៅក្រោមការគាបសង្កត់របស់អាណ្ណាម និងចិន សម្ព័ន្ធភាពរបស់កុលសម្ព័ន្ធពាក់កណ្តាលស៊ីវិល័យនេះត្រូវបរាជ័យ ព្រោះមេដឹកនាំរបស់ពួកគេ ជាមេទ័ពពូកែហានក្លា តែខ្វះការប៉ិនប្រសប់ក្នុងការថែរក្សាជ័យជម្នះដែលដណ្តើមបាន មិនចេះចាត់ចែងមិនចេះធ្វើនយោបាយ បើទោះជាជួនកាលមានការគាំទ្រខ្លះពីស្តេចអាណ្ណាម ដែលស្អប់ចិនក៏ដោយ ជាពិសេសនៅពេលដែលពួកនុងនេះដណ្តើមយកខែត្រក្វាងស៊ី និងក្វាងទុងបាន ។

ស្តេចចុងក្រោយរបស់រាជវង្សឡេជានារី ដែលទទួលអំណាចតពីបិតាកំពុងប្រឈួន ។ ព្រះនាងមានព្រះនាមថា លីជាវហ្វួង ដែលសោយរាជ្យបានប៉ុន្មានខែ ក៏ដាក់រាជសម្បត្តិប្រគល់ឲ្យត្រាន់កាញ់ ជាភីលៀងដែលព្រះនាងបានជ្រើសរើសយកធ្វើជាព្រះស្វាមី ។

ត្រាន់កាញ់ក៏កសាងសន្តតិវង្សទី៤ឡើង គឺសន្តតិវង្សត្រាន់ មានស្តេចចំនួន១៤ អង្គសោយរាជ្យនៅអាណ្ណាម បានចំនួន១៩០ឆ្នាំ ពីឆ្នាំ១២២៥ដល់១៤១៤ ។

សន្តតិវង្សមុនហាក់ដូចជាមិនបានធ្វើឲ្យប្រទេសរីកចម្រើនខាងអារ្យធម៌ប៉ុន្មានទេ តែសេដ្ឋកិច្ចនៅឆ្នាំ១២២៥ ល្អប្រសើរជាង កាលពីឆ្នាំ៩៦៨ ជាពិសេស គឺកងទ័ពមានការរៀបចំល្អ ស្តេចមានរាជវាំងគង់នៅស្រួល ការប្រមូលពន្ធអាករក៏ល្អ និងបានច្រើន ។

ក្រោមសន្តតិវង្សទី៤ ការរីកចម្រើនលឿនជាង ក៏ប៉ុន្តែមានកលខបាយ ការបះបោរ ហើយមានសង្គ្រាមប្រឆាំងនឹងចិនផង និងជាមួយនគរចាម្ប៉ាផង ច្រើនជាងពីមុន ។ ស្តេចត្រាន់កាញ់សោយរាជ្យក្រោមព្រះនាមថា ត្រាន់ថៃតុង ។ ប៉ុន្មានឆ្នាំដំបូងនៃរជ្ជកាលរបស់ស្តេចនេះមានភាពរីកវរជាខ្លាំង ។ ព្រះរាជាមុនដែលបានដាក់រាជ្យ

ថ្វាយរាជបុត្រី មានការរំខានជាខ្លាំងជាមួយបិតុលាម្នាក់របស់ត្រាន់ថៃតុង រហូតទាល់តែទ្រង់សម្រេចព្រះទ័យដឹកថ្នាំសម្លាប់ខ្លួន ។ ព្រះបិតុលារបស់ព្រះរាជាថ្មីនោះក៏យកអតីតព្រះមហាក្សត្រិយានីជាមហេសីទៅ ។ ចំណែកឯព្រះមហាក្សត្រិយានីថ្មី ដែលបានដាក់រាជសម្បត្តិថ្វាយព្រះស្វាមី ក៏ត្រូវបាត់បង់ព្រះរាជតួនាទីដោយសារព្រះអនុជក្សត្រី ដែលមានគភ៌មិនមែនជាមួយព្រះរាជា តែជាមួយបងប្អូនប្រុសរបស់ព្រះរាជាទៅវិញ ។ ព្រះនាងត្រូវគេដកព្រះឋានៈ រួចរៀបការឲ្យឧត្តមសេនីយ៍ម្នាក់ឈ្មោះថា ឡេភូត្រាន់ ។

ព្រះរាជាទីមួយនៃសន្តតិវង្សត្រាន់នេះ ថ្វីបើព្រះអង្គបានក្បត់នឹងព្រះមហេសី តែជាក្សត្រក្លាហានមួយអង្គនៅក្នុងសមរភូមិ ព្រោះទ្រង់បានទទួលជ័យជម្នះលើអធិរាជចិនសម័យពួកម៉ុងហ្គោល និងលើពួកចាម ដ៏សាហាវផងដែរ ។ ទ្រង់ជាព្រះរាជាមួយអង្គដែលចូលចិត្តនឹងព្រះរាជកិច្ច និយមការកែទម្រង់ និងមានការគិតគូរ ចង់ឲ្យប្រជារាស្ត្រមានបាន ។ ព្រះអង្គបានចាត់ឲ្យសាងសង់ទំនប់ ដើម្បីទប់ទឹកទន្លេឲ្យហូរចូលទៅសមុទ្រ កុំឲ្យលិចលង់ប្រជារាស្ត្រ[៥] ។ ទ្រង់ក៏បានរៀបចំឲ្យមានការប្រលងរវាងអ្នកបញ្ញវន្ត ជ្រើសរើសយកតែអ្នកដែលរៀនពូកែដូចនៅប្រទេសចិនដែរ ទោះជាកូនរាស្ត្រប្រជាក៏ដោយ ។

រាជបុត្ររបស់ត្រាន់កាញ់ដែលរៀនសូត្រពីព្រះបិតា បានរុញច្រានការលុកលុយរបស់ចិន ក្រោមការដឹកនាំរបស់ពួកតាកតារ ម៉ាន់ជូ របស់ គូប៊ីឡៃខាន់ ឲ្យបរាជ័យ ក៏ប៉ុន្តែប្រជារាស្ត្រត្រូវរងទុក្ខវេទនា អត់បាយស្លាប់អស់ជាច្រើន ។

ក្រោយមក ពួកចាមបានវាយលុកចូលមកក្នុងប្រទេសរហូតដល់ហាណូយ ព័ទ្ធរាជធានីជាប់ ធ្វើឲ្យព្រះរាជាគេចព្រះកាយចេញ ។ ប៉ុន្តែពួកចាមមិនអាចដណ្តើមយករាជធានីបានទេ ព្រោះមិនចេះផ្គត់ផ្គង់ស្បៀង រស់តាមរបៀបព្រៃ មិនចេះរៀបចំប្រទេស មិនចេះដឹកនាំ ចេះតែដុតបំផ្លាញ ។ ដោយហេតុនេះពួកចាមក៏ត្រូវវាយឲ្យបរាជ័យរួចបណ្តេញចេញពីអាណ្ណាមដោយមេទ័ពអាណ្ណាមម្នាក់ គឺឧត្តមសេនីយ៍ឡេគ្វីលី ។

---

[៥] មានសំណួរមួយ ដែលចោទរហូតមកដល់សព្វថ្ងៃ មិនដឹងថាតើការកសាងទំនប់អមទន្លេបែបនេះផ្តល់ផលល្អ ឬអាក្រក់ ចំពោះតុងកឹង ឬក៏យ៉ាងណាទេ ។ អ្វីដែលជាក់ស្តែងនោះ គឺសព្វថ្ងៃនេះ បាតទន្លេវានៅខ្ពស់ជាងទំនាបដែលនៅសងខាង រីឯទំនប់នោះវិញ បើទោះជាមានការថែរក្សាចាក់ដីបំពេញពីជំនាន់មួយទៅជំនាន់មួយ ដែលជាហេតុធ្វើឲ្យចំណាយអស់ច្រើនយ៉ាងណាក្តី ក៏នៅត្រង់កន្លែងខ្លះទឹកនៅតែចង់ហូរកាត់ដដែល ។ តាមមើលទៅ ស្តេចត្រាន់កាញ់ និងស្តេចដែលសោយរាជ្យបន្តមក ប្រហែលជាបានគិតដល់ផលប្រយោជន៍ផ្ទាល់របស់ប្រជារាស្ត្រនាពេលនោះ មិនបានគិតដល់ផលវិបាកនៃការសង់ទំនប់ទៅអនាគតទេ ។ ម្យ៉ាងទៀត នាសម័យនោះ ប្រហែលជាគេមិនទាន់អាចទស្សន៍ទាយ អំពីអនាគតបានទេ ពោលគឺមិនបានដឹងថាការធ្វើដូច្នេះ នឹងនាំឲ្យមានកករល្បាប់ច្រើន ធ្វើឲ្យបាតទន្លេឆាប់រាក់ ឡើងខ្ពស់ជាងទំនាបនៅសងខាង ទីបញ្ចប់ទន្លេត្រូវស្ថិតនៅក្នុងអាងសិប្បនិមិត្ត ងាយនឹងហៀរចេញមកក្រៅណាស់ ជាពិសេស នៅពេលណាដែលរដ្ឋាភិបាលមិនបានយកចិត្តទុកដាក់ ។

ចុងបញ្ចប់នៃសន្តតិវង្សទី៤នេះមិនជាល្អប៉ុន្មានទេ ។ ក្រោយពីជ័យជម្នះលើពួកចាម ឧត្តមសេនីយ៍ ឡេគ្វីលី បានក្លាយខ្លួនជាមនុស្សមានឥទ្ធិពលយ៉ាងខ្លាំងមកលើព្រះរាជា លើរាជវាំង និងមន្ត្រីសេនាបតីទាំងឡាយ ។ គាត់អាចដកហូតស្ដេចឬដាក់នរណាម្នាក់ឲ្យសោយរាជ្យក៏បាន ពោលគឺ ដឹកនាំប្រទេស និងរាជវាំងជំនួសមុខឲ្យបណ្ដាព្រះរាជាដែលគ្មានបានការទាំងឡាយ ។ ស្ដេចត្រាន់ង៉េតុងស្ដាប់បញ្ជាទាំងអស់របស់ឡេគ្វីលី ហាក់ដូចជាបានដាក់រាជ្យរួចទៅហើយ ។ ស្ដេចត្រាន់ភែដេត្រូវឡេគ្វីលីបញ្ជាឲ្យគេច្របាច់កទាល់តែស្លាប់នៅឆ្នាំ១៣៩០ ។ ស្ដេចត្រាន់ធួនតុង បានឡើងសោយរាជ្យដោយសារឡេគ្វីលីនេះ ។ ឡេគ្វីលីមានសត្រូវជាច្រើន ព្រោះគាត់បានសម្លាប់ឧត្តមសេនីយ៍ច្រើននាក់, សម្លាប់រាជវង្ស និងទីប្រឹក្សាណាដែលមិនចំណុះគាត់ មិនតែប៉ុណ្ណោះ ថែមទាំងដឹកនាំស្ដេចទៀត ជាក់ស្ដែងស្ដេចត្រាន់ធាវដេ ដែលគាត់លើកឲ្យសោយរាជ្យនៅឆ្នាំ១៣៩៩ គឺគ្មានអំណាចអ្វីទាល់តែសោះ ។ ឡេគ្វីលីជាបុគ្គលតែម្នាក់គត់ដែលដឹកនាំប្រទេស ដឹកនាំរាជវាំង ដោយគ្មានខ្លាចរអែងនរណាម្នាក់ទេ ។ គាត់បានប្រកាសខ្លួនថា ជា«ព្រះអយ្យកោនៃព្រះរាជាណាចក្រ» ស្លៀកសម្លៀកបំពាក់ពណ៌លឿង ជាពណ៌ដែលគេប្រើសម្រាប់តែព្រះរាជាប៉ុណ្ណោះ ហើយចេញទៅណាមកណាមានបាំងក្លស់ពណ៌លឿង និងពណ៌មាស១២ជាន់ ។ បន្ទាប់មក ក្រោយពីស្ដេចត្រាន់ធាវដេសោយរាជ្យបាន២ឆ្នាំ ឡេគ្វីលីក៏ដកស្ដេចនេះចេញ ហើយឡើងសោយរាជ្យខ្លួនឯងដោយយកព្រះនាមថាហូគ្វីលី និងបានដូរឈ្មោះនគរទៅជា ដាយងូ វិញ ។

សោយរាជ្យបានមិនបានប៉ុន្មានខែផង មិនដឹងថាដោយហេតុណាយ និងរាជសម្បត្តិ ដែលគ្មានសារសំខាន់ដូចការធ្វើជាមន្ត្រី ឬក៏ដោយមានការគាបសង្កត់ពីសាធារណមតិ ឬក៏មនុស្សមួយក្រុម ដែលឯកសារប្រវត្តិសាស្ត្រមិនបានប្រាប់ឲ្យយើងដឹង ហូគ្វីលីក៏ប្រកាសលើកកូនរបស់ខ្លួនជាវរជ្ជទាយាទ រួចដាក់រាជសម្បត្តិថ្វាយ ហើយប្រកាន់យកតំណែងជាព្រះរាជបិតាវិញ តែនៅតែកាន់អំណាចដដែល ។

ប៉ុន្តែពេលនោះដល់ពេលដែលចិនធ្វើអន្តរាគមន៍ល្មម ។ ចិនលុកលុយនគរដាយងូ កាន់កាប់យ៉ាងតឹងរ៉ឹង ។ អាណ្ណាមបរាជ័យហើយបរាជ័យទៀត ។ ហូគ្វីលី និងព្រះរាជបុត្រដែលកំពុងសោយរាជ្យ ព្រមទាំងរាជបុត្រមួយអង្គទៀត ត្រូវចិនចាប់បានជាឈ្លើយ ដឹកនាំយកទៅស្រុកចិន តែត្រូវធ្វើឃាតអស់នៅតាមផ្លូវ ។

ចាប់ពីពេលនោះមក អាណ្ណាមត្រូវធ្លាក់ក្នុងនឹមត្រួតត្រារបស់ចិនអស់កាលប្រមាណជា ២០ឆ្នាំទៀត ។

## ៣- ស្រុកចិន

នៅដើមសតវត្សរ៍ទី១៣ ទ័ពម៉ុងហ្គោលរបស់ឆេងហ្គីខាន់ (ហ្សង់ហ្ស៊ីខាន់) ដែលទើបតែធ្វើការវាតត្បាតពាសពេញអាស៊ី ទៅដល់ម៉ូស្គូវីភាគខាងត្បូង និងរហូតទៅដល់ប៉ុលការីទៀតផង បានឈ្លានពានចូលមកប្រទេសចិន ដែលត្រូវស្ថិតក្រោមការត្រួតត្រារបស់ពួកម៉ុងហ្គោលនេះ ចាប់ពីឆ្នាំ១២១៨រហូតមក ។ ពួកម៉ុងហ្គោល តាំងរាជធានីនៅប៉េកាំង ។ ប្រទេសចិនពេលនោះមានអំណាចខ្លាំងណាស់ ព្រោះត្រូវដឹកនាំយ៉ាងប៉ិនប្រសប់ និងតឹងរ៉ឹង

បំផុត ដោយសន្តតិវង្សយោរយោមួយ ដែលរស់នៅដោយការបោះតង់កណ្តាលរាជធានីចិន មានទាហានគាកគារ និងម៉ុងហ្គោល យាមកាមយ៉ាងម៉ឺងម៉ាត់ ។

នៅក្នុងរជ្ជកាលរបស់ស្តេចម៉ុងហ្គោលមួយអង្គ គឺគូប៊ីឡៃខាន់ ត្រូវជាចៅរបស់ហ្សង់ហ្គីខាន់ មានជនជាតិវេនីសម្នាក់ ដែលជាមន្ត្រីសំណព្វចិត្តព្រះអធិរាជ បានធ្វើដំណើរមកកាន់ចុងបូព៌ាកាត់នគរចាម្ប៉ាទៅដល់ឥណ្ឌា និងចូលប្រទេសមួយចំនួនទៀត ។ លោក ម៉ាកូប៉ូឡូ ក៏បានបន្សល់ទុកនូវពត៌មានដ៏មានសារសំខាន់ អំពីការស្នាក់នៅរបស់គាត់ ដែលគួរឲ្យចង់ដឹងចង់ឃើញដែរ ។

ពួកម៉ុងហ្គោលទាំងនោះ ក្រោយពីដណ្តើមយកទ្វីបអាស៊ីភាគខាងជើង និងប្រទេសចិនបានយ៉ាងឆាប់រហ័សរួចមក ក៏តាំងចាប់អនុវត្តតាមនយោបាយរបស់ពួកអធិរាជដែលពួកគេបានទម្លាក់ពីអំណាច ។ ពួកគេគាំទ្រសិទ្ធិដែលចិនបានអះអាងថា មានអធិរាជភាពតាំងពីច្រើនសតវត្សរ៍មកហើយលើបណ្តាប្រជាជាតិជិតខាង ហើយក៏តាំងចាប់ផ្តើមបង្ខំឲ្យបណ្តាប្រជាជាតិទាំងនោះ ទទួលស្គាល់អនុត្តរភាពរបស់ខ្លួន ទាំងដោយប្រយោល ទាំងក្នុងការអនុវត្តន៍ជាក់ស្តែង ។ ចំណែកឯបណ្តាប្រជាជាតិទាំងនោះវិញ ដែលធ្លាប់តែគិតថាអាណាចក្រចិនធំ មានអំណាចចិញ្ចាចចិញ្ចែង គេមិនបានប្រកែកប្រឆាំងអ្វីទេ បើទោះជាថាអធិរាជនោះមកពីចម្ងាយ និងថាអធិរាជនោះ មិនដែលលូកដៃចូលក្នុងផ្ទៃក្នុងរបស់គេ ដោយទទួលស្គាល់ទាំងអស់នូវអ្វីៗដែលបានសម្រេចរួចមកហើយ ហើយធ្វើព្រងើយចំពោះរឿងឃាតកម្មលើព្រះរាជា រឿងដណ្តើមរាជសម្បត្តិដ៏អាស្រូវដែលប៉ះពាល់ដល់សុវត្ថិភាព របស់ប្រជារាស្ត្រដែលអធិរាជនោះបានប្រកាសខ្លួនថា ជាអ្នកការពារក៏ដោយ ។ ឥទ្ធិពលរបស់អធិរាជចិនមានសារសំខាន់កាន់តែខ្លាំងថែមទៀត ជាពិសេស នៅពេលណាដែលអធិរាជត្រូវការការទទួលស្គាល់ក្រោយពីគេបានលួចឆក់យកអំណាចបាន ។ ម្ល៉ោះហើយ គ្រប់ព្រះរាជាទាំងអស់តែងតែបញ្ជូនរាជទូត និងវត្ថុអនុស្សាវរីយ៍ផ្សេងៗទៅថ្វាយព្រះចៅអធិរាជចិនជានិច្ច រួចហើយទទួលយកមកវិញនូវការតបស្នងជាវត្ថុ ឬឋានៈតួនាទីមួយ ដែលជួនកាលគួរឲ្យសង្ស័យ ជាក់ស្តែងដូចជា ឋានៈជា «ឧត្តមសេនីយ៍នៃទក្សិណទិសសន្តិភាព» ដែលអធិរាជចិនមួយអង្គ បានថ្វាយដល់ព្រះបាទកោណ្ឌញ្ញៈ ជាដើម ។ អនុត្តរភាព និងអធិរាជភាពនេះ ចិនមានមកតាំងតែពីជាងមួយពាន់ឆ្នាំមុនមក រហូតមកទល់ពេលដែលយើងកំពុងនិយាយនេះ ។ ព្រះបាទកោណ្ឌញ្ញៈសោយរាជ្យនៅសតវត្សរ៍ទី៥ ហើយស្តេចសៀមមួយអង្គ បានទទួលត្រាពីអធិរាជហុងវូរបស់ចិន នៅឆ្នាំ១៣៧៦ ។ ហើយយើងនឹងបានឃើញ ម្តងទៀតថា នៅឆ្នាំ១៥៧០ ស្តេចសៀមមួយអង្គទៀត គឺព្រះណារេត ទ្រង់បានសុំឲ្យអធិរាជចិនប្តូរត្រាថ្មីជាជំនួសត្រាមុន ដែលបានទទួលកាលពីឆ្នាំ១៣៧៦ ដែលបានបាត់បង់ទៅ នៅពេលពួកប៉ាកាន ដុតទីក្រុងអយុធ្យា នៅក្នុងឆ្នាំ១៥៥៥ ។ យើងនឹងបានឃើញភាពចំណុះដោយប្រយោលបែបនេះនៅគុងកឹងផងដែរ នៅពេលដែលបារាំងចាប់ច្បាំងដណ្តើមយក នៅចុងសតវត្សរ៍ទី១៩ ។

នៅសតវត្សរ៍ទី១៣ ពួកអធិរាជម៉ុងហ្គោល ក្នុងនោះមានទាំងគូប៊ីឡៃខាន់ផងដែរ បានចាប់អារម្មណ៍

ជាខ្លាំងចំពោះទឹកដីប្រទេសជិតខាង ជាងបណ្តាអធិរាជចិនទៅទៀត ។ មុនពួកម៉ុងហ្គោលមកដល់ សំពៅចិនមិនដែលចុះទៅក្រោមហួសពីច្រកម៉ាឡាកាទេ បើមានមកដល់កោះជ្វា ឬស៊ូម៉ាត្រា ក៏មានតិចតួចដែរ ។ ក្រោយនោះ សំពៅចិនបានមកកាន់កោះទាំងពីរជាញឹកញាប់ ហើយឆ្លងច្រកម៉ាឡាកា ចូលទៅក្នុងឈូងសមុទ្របឹងហ្កាល់ បន្តទៅធ្វើពាណិជ្ជកម្មនៅតាមឆ្នេរកូរ៉ូម៉ង់ដែល ឬធ្វើការឆក់ប្លន់ក៏មាន ។ ជួនកាលគេប្រទះឃើញសំពៅចិននៅក្នុងសមុទ្រអូម៉ង់ និងឈូងសមុទ្រពែក្ស ទៀតផង ។ លោក ម៉ាកូប៉ូឡូ ប្រហែលជាបានទៅដល់ទីនោះ ក្នុងបេសកកម្មទៅប្រទេសចិន ។ សំពៅចិនក៏មានទំនាក់ទំនងកាន់តែខ្លាំងជាមួយរាជាណាចក្រទាំងឡាយ នៅតណ្ហូចិនផងដែរ ពីព្រោះថា ទំនាក់ទំនងជាមួយលោកខាងក្រៅកាន់តែមានសារសំខាន់ ហើយសំទុះនៃការរាតអំណាចអធិរាជក៏កាន់តែខ្លាំងដែរ ។ គឺនៅក្នុងរជ្ជកាលរបស់អធិរាជគូប៊ីឡៃខាន់នេះឯង ដែលមានរាជទូតចិនមកដល់ស្រុកខ្មែរ ក្នុងនោះមានទាំង ឈាវតាក្វាន់ ផងដែរ ដើម្បីតាមរកពួកដែលប្រឆាំងនឹងរាជានិយមថ្មី ហើយភៀសខ្លួនមកជ្រកកោននៅទីនេះ ។ តាមពិត គូប៊ីឡៃខាន់ មានបំណងចង់រាតអនុត្តរភាពរបស់ចិន ដោយផ្តើមអំណាចដូចជាពួកចិនមុនៗអ៊ីចឹងដែរ រួចហើយលាតសន្ធឹងអនុត្តរភាពនោះទៅឲ្យកាន់តែឆ្ងាយថែមទៀត ។

## ៨- ស្រុកសៀម ឬ ស្រុកថៃ

ចំណែកពួកថៃ សព្វថ្ងៃគេហៅថាសៀម ដែលយើងបានឃើញរួចមកហើយថា បានមកបង្ហាញខ្លួននៅក្នុងអាងទន្លេមេណាមតាំងពីសតវត្សរ៍ទី៩ នៃគ្រិស្តសករាជម្ល៉េះ ពួកនេះចិនហៅថាអៃឡាវ ឬថៃឡាវ[៦] តាំងពីយូរលង់ណាស់មកហើយ គឺប្រហែលជាតាំងពីឆ្នាំ៩០ មុនគ្រិស្តសករាជទៅទៀត ប៉ុន្តែឯកសារប្រវត្តិសាស្ត្រចិន មាននិយាយពីពួកនេះតែពីត្រឹមឆ្នាំ៦២៩មកប៉ុណ្ណោះ នេះបើតាមយើងដឹង ។ ពួកនេះពីមុនរស់នៅកន្លែងមួយដែលចិនហៅថា ណានឆាវ (មានន័យថា ស្តេចនៃស្រុកកណ្តាល) នៅពីខាងលិចយុនណាន ដែលកៀកបំផុតនឹងទីបេ ។

តាមមើលទៅពួកនេះប្រហែលជាមានដើមកំណើតចេញពីនិគមជនហិណ្ឌូដែលចេញពីមគធៈ មកផ្សព្វផ្សាយអារ្យធម៌នៅទីនោះ រួចហើយក៏ត្រូវស្រូបចូលបាត់ទៅក្នុងចំណោមអ្នកស្រុកអាយ ដែលកាត់ទីបេពាក់កណ្តាល ។ គឺដោយហេតុនោះហើយ បានជាពួកគេមានលក្ខណៈជាហិណ្ឌូកាត់ទីបេ ។ សព្វថ្ងៃនេះ ភាសាដែលគេនិយាយនៅតាមស្រុកស្រែរបស់យុនណាន ជាពិសេសខិតទៅខាងលិចបន្តិច និងនៅជុំវិញទីក្រុងតាលី និងបណ្តោយខែត្រជិតខាងនោះ គឺជាភាសាថៃដើម ដែលបានប្រែក្លាយច្រើនហើយ លាយឡំជាមួយភាសាចិន ហើយភាសាថៃនោះ គ្មានពាក្យបាលីទេ ។

[៦] ពួកអាណ្ណាមនៅប្រើពាក្យ អៃឡាវ នេះសម្រាប់ហៅ ពួកលាវ និងពួកសៀមភាគខាងជើង តែសព្វថ្ងៃ ។

ហើយវាហាក់ដូចជាថាអក្សរដែលពួកគេសរសេរពីដំបូងនោះ ក្លាយចេញមកពីអក្សរសំស្ក្រឹតផងដែរ ។

ពួកនេះមានបែកចេញជាក្សត្រប្រទេសចំនួន៦ ឬ៧ ជួនកាលជា៨ ឬ៩ តែរួមគ្នាជាសហព័ន្ធមួយ ។ គឺដោយហេតុនោះហើយ បានជាជួនកាល ចិនហៅពួកនេះថា «ពួកឆាវទាំង៦ ឬទាំង៩» ហើយនេះក៏ជាការបញ្ជាក់ផងដែរថាពួកនេះរស់នៅជាក្រុមអម្បូរស្វយ័តមួយច្បាស់លាស់ នៅខាងនិរតីអាណាចក្រចិន ។ ពួកនេះមានឈ្មោះពិតប្រាកដថា សាយ៉ាម តែពួកប៉ាកាន និងភូមាហៅមិនច្បាស់ថាជាថៃ ឬសាន ហើយដល់ក្រោយៗមក ពួកនេះ ក៏ហៅខ្លួនឯងថាដូច្នេះដែរទៅ[៧] នៅពេលនោះ ។ ប៉ុន្តែ ពួកអ្នកស្រុកដែលរស់នៅត្រង់ទឹកដីភូមាសព្វថ្ងៃ ក៏ហៅទឹកដីរបស់ខ្លួនថា កូសានព្យី មានន័យថា «នគរសានទាំង៧» ឬថា រាជាណាចក្រម៉ា ឬរាជាណាចក្រប៉ុង ផងដែរ កាលពីសតវត្សរ៍ទី៧ ។

នៅក្នុងពាក់កណ្តាលទីមួយនៃសតវត្សរ៍ទី៨ ស្តេចរដ្ឋឆាវថៃដែលស្ថិតនៅខាងត្បូងគេបង្អស់ក្នុងបណ្តារដ្ឋទាំង៦ គឺស្តេចប៉ូឡូកូ ឬស៊ីឡូកូ នៃស្រុកមឿងហ៊ីឆាវ បានឆ្លៀតឱកាសពេលដែលចិនធ្វើសង្គ្រាមជាមួយទីបេ វាយដណ្តើមយកស្រុកឆាវឯទៀតៗដាក់ជាចំណុះ ។ គឺប្រហែលជានៅពេលនោះហើយ ក្រោយពីបានក្លាយខ្លួនជាម្ចាស់លើទឹកដីដ៏ធំមួយរួចហើយ ដែលស្តេចឆាវនោះបានប្រកាន់យកឋានៈជាមហារាជ ដែលគូប៊ីឡៃខាន់ ទទួលស្គាល់ ៥សតវត្សរ៍ក្រោយមក ចំពោះស្តេចឆាវដែលសោយរាជ្យបន្ត ក្រោយពីបានយកនគរឆាវដាក់ជាចំណុះរួចមក ។ អធិរាជឆាវនោះសោយរាជ្យនៅរាជធានីតាលី ម្ល៉ោះហើយនគរនោះក៏ត្រូវគេហៅរត់មាត់ថា រាជាណាចក្រតាលីៗ ដូច្នេះទៅ ប៉ុន្តែពួកចិន និងពួកអ្នកស្រុកជិតខាងមួយចំនួនទៀត នៅតែបន្តហៅថា រាជាណាចក្រណានឆាវៗ ឬរាជាណាចក្រនៃស្តេចទិសខាងត្បូងរៀងមក ។ ពួកអាណ្ណាមហៅពួកនេះថា លុកជាវ មានន័យថា ស្តេច៦ ឬក្សត្រប្រទេស៦ ។ នៅដើមគ្រិស្តសករាជរហូតដល់មុនសតវត្សរ៍ទី៦ ស្រុកនេះមានប្រទេសជិតខាង គឺភូមា និងទីបេពីខាងលិច, ចិនពីខាងជើង និងខាងកើត, តុងកឹង ឬង៉ាំនណាន ពីអាគ្នេយ៍ ហើយនិងមានភ្យូ, ភ្សួរ ឬបៀរម៉ានពីខាងត្បូង ។

នៅដើមពាក់កណ្តាលទី២នៃសតវត្សរ៍ទី៨ គឺនៅក្នុងរជ្ជកាលស្តេចព្រះនាមកាឡូហ៊ុង ជាបុត្ររបស់ស្តេចប៉ូឡូកូ ដែលបានបង្រួបបង្រួមឯកភាពថៃ ហើយបង្កើតបានរាជាណាចក្រតាលីឡើង ពួកចិនដែលមិនសប្បាយចិត្តនឹងឃើញរាជាណាចក្រដ៏រឹងមាំមួយនេះកើតឡើង ជាជាងមានក្សត្រប្រទេស៦ដែលទន់ខ្សោយ ក៏ចាប់បើកការវាយប្រហារមកលើនគរណានឆាវ ឬរាជាណាចក្រតាលី នៅឆ្នាំ៧៥១ ក្នុងគោលបំណងកម្ចាត់ឲ្យបាត់តែម្តង ឬ

---

[៧] នៅក្នុងភាសាភូមា អក្សរ ស របស់ភាសាសំស្ក្រឹតបានត្រូវគេប្តូរទៅជា ធ ដូចជា សក្យមុនី ទៅជា ធគាមុនី, សុទ្ធោទនៈ ទៅជា ធុទ្ធោទនៈ, យសោធរៈ ទៅជា យធោធរៈ, ស្រះវាស្ទិ ទៅជា ធវាទ្ទិ, វេសាឡី ទៅជា វេធាលី ។ល ។

ក៏ដើម្បីរៀបចំសណ្ដាប់ធ្នាប់តាមរបៀបចាស់ឡើងវិញ ។ ក៏ប៉ុន្តែពួកថៃពេលនោះមានអារ្យធម៌ជឿនលឿនបន្តិចហើយ ហើយចេះរៀបចំខ្លួនល្អសម្រាប់ធ្វើចម្បាំង ។ បុរសគ្រប់រូបដែលមានកាយសម្បទាមាំមួន ត្រូវចូលបម្រើកងទ័ព ស្លៀកពាក់ឯកសណ្ឋានដែលព្រះរាជាផ្ដល់ឲ្យ ។ ព្រះរាជាផ្ទាល់ជាអ្នកបញ្ជាលើកងទ័ពសេះ ដែលរៀបចំបានប្រសើរជាងទ័ពចិន ។ ព្រះអង្គក៏មានជង្រុកពេញទៅដោយស្រូវ ហើយនិងមានប្រព័ន្ធពន្ធដារ ដ៏មានប្រសិទ្ធភាពដែលអាចឲ្យធ្វើសង្គ្រាមបានយូរអង្វែង ។ ម្ល៉ោះហើយ ពួកចិនត្រូវពួកថៃវាយឲ្យបរាជ័យ ជាច្រើនលើកនៅឆ្នាំ៧៥៤ ហើយប្រតិបត្តិការរបស់ចិនបានជំរុញឲ្យស្ដេចនគរគាលីខិតទៅរកចំណងមេត្រីភាពជាមួយទីបេ ។ ប៉ុន្តែសម្ព័ន្ធភាពនេះមិនស្ថិតស្ថេរទេ ព្រោះយើងនឹងឃើញនៅពេលក្រោយថា នគរណានឆាវ បានធ្វើសង្គ្រាមជាមួយទីបេនៅឆ្នាំ៧៩៤ ហើយបានជ័យជម្នះ ។

ចិនបានបន្តវាយមកលើណានឆាវជាច្រើនលើកទៀត តែត្រូវបរាជ័យរហូត ហើយបន្ទុំឲ្យវាយដកថយចេញទៅវិញ ។

នគរណានឆាវពេលនោះ មានទំនាក់ទំនងញឹកញាប់ជាមួយនគរដែលយើងហៅសព្វថ្ងៃថា ភូមា ដែលនៅសម័យនោះមានឈ្មោះថា ភាវ ឬភ្យូ ឬភ្យួរ ជាទឹកន្លែងដែលពួកគេដើរឆ្លងកាត់នៅពេលដែលគេធ្វើដំណើរចេញពីឥណ្ឌា សំដៅទៅប្រទេសចិនកាលពីរាប់រយពាន់ឆ្នាំមុន ហើយតាំងពីពេលនោះមក ទំនាក់ទំនងជាមួយគ្នាក្នុងភាពជាអ្នកជិតខាង មិនសូវជាល្អប៉ុន្មានទេ ។ អាចនឹងថាពួកណានឆាវមិនមែនគ្រាន់តែបានដើរឆ្លងកាត់ ភាវ ឬភ្យូ ប៉ុណ្ណោះទេ គឺអាចធ្លាប់តាំងបានតាំងទីលំនៅ នៅត្រង់នេះទៀតផងក៏មិនដឹង មុននឹងត្រូវដេញឲ្យធ្វើដំណើរបន្តទៅមុខទៀតដោយមូលហេតុណាមួយ តាំងពីយូរលង់ណាស់មកនោះ ។ ប៉ុន្តែអ្វីដែលពិតប្រាកដនោះ គឺថា ក្រោយពីបានគេចផុតពីគម្រោងវាយកម្ទេចរបស់ចិនកាលពីឆ្នាំ៧៥៤រួចមក ស្ដេចថៃឈ្មោះ យីមាវស៊ីយុន បានឆ្លងកាត់ព្រំប្រទល់ភាគខាងត្បូងនៅឆ្នាំ៨០០ វាយដណ្ដើមយកអាងទន្លេឥរាវតីខាងលើ រួចហើយចាប់ធ្វើសង្គ្រាមជាមួយស្រុកភាវ គឺប្រទេសភូមាភាគខាងលើបច្ចុប្បន្ន យកដាក់ជាចំណុះ ហើយនិងបានធ្វើសង្គ្រាម ជាមួយប្រទេសទីបេទៀតផង ។

នៅដើមសតវត្សរ៍ទី៩ ក្រោយពីចាញ់ដៃពួកណានឆាវរួចហើយ ពួកភាវបានទទួលស្គាល់អធិរាជភាពរបស់អធិរាជចិន ដើម្បីយកចិនធ្វើជាអាណាព្យាបាលប្រឆាំងនឹងណានឆាវ តែត្រូវស្ដេចពួកនេះ លើកទ័ពមកវាយប្រហារម្ដងទៀតនៅឆ្នាំ៨៣៣ ចាប់មនុស្សបីពាន់នាក់ជាឈ្លើយយកទៅកាន់ឈេតុង សព្វថ្ងៃហៅថា យុនណានសែន ជារាជធានីទី២របស់ពួកគេ ។ មិនតែប៉ុណ្ណោះ ប្រហែលដោយមានការគំរាមពីអ្នកស្រុកជិតខាងរបស់ភូមាផង ដែលចិនហៅថា មីនេន (ប្រហែលជាអាវ៉ាកាន់ ឬអាស្សាមសព្វថ្ងៃ) ស្ដេចរបស់ថៃ ឬគាលី នោះ ក៏បានលើកទ័ពចុះមកវាយបណ្ដាស្រុកតាមមាត់ឈូងសមុទ្របឹងហ្កាល់ នៅឆ្នាំ៨៣៥ ទម្លាក់ស្ដេចចេញពីអំណាចថែមទៀត ។

នៅចុងសតវត្សរ៍ទី៩ ឯកសារប្រវត្តិសាស្ត្រចិន និងអាណ្ណាមបានរាយការណ៍ឲ្យយើងដឹងអំពីពួកណានឆាវវាយកងទ័ពចិនមួយកងដែលចេញមកពីតុងកឹង រួចឆ្លងកាត់ព្រំដែនខាងត្បូងរបស់ស្រុកនេះចូលទៅដល់អាណ្ណាម

ដណ្ដើមយករាជធានីហាណូយបាននៅក្នុងឆ្នាំ៨៦៣ ត្រូវនឹងមហាសករាជ៧៨៥ ។ ក្រោយពីប្រតិបត្តិការដ៏អង់អាចក្លាហានមិនគួរឲ្យជឿនេះ ស្ដេចតាលីប្ដ់ថៃបានវិលត្រលប់មកកាន់ យុនណាន វិញពីរឆ្នាំក្រោយពីបានយកស្រុក ឬកុលសម្ព័ន្ធរបស់ចិននេះ ចំនួន៣៧[៨] ដាក់ជាចំណុះរួចមក ។ គឺនៅពេលនោះហើយ ដែលចិនបានរាប់ ណានឆាវ ចូលក្នុងបណ្ដាគ្រោះថ្នាក់ទាំង៤របស់មហាអាណាចក្រ គ្រោះថ្នាក់បីទៀត មានទីបេ ពួករដ្ឋអ៊ុយហួរ និងពួកទូកដែលចិនហៅថា ទូក្វេ ។

រាជាណាចក្រថៃ ឬតាលី បានរីកចម្រើនដល់កំពូលរហូតដល់ពេលមួយស្រាប់តែត្រូវបែងចែកចេញជារដ្ឋពីរ នៅសតវត្សរ៍ទី១០ មិនដឹងជាមកពីហេតុអ្វី ៖ រដ្ឋមួយនៅខាងលិចមានរាជធានីនៅតាលីដដែល រដ្ឋមួយទៀតនៅខាងកើត ត្រង់ខេត្រយុនណាន ដែលពេលនោះជាសហព័ន្ធនៃកុលសម្ព័ន្ធចំនួន៣៧ ។ ការបែកបាក់គ្នានេះ មិនមានអ្វីជាធ្ងន់ធ្ងរណាស់ណាទេ គ្រាន់តែថាស្ដេចដែលសោយរាជ្យនៅតាលី ដែលពីមុនត្រួតត្រាលើសហព័ន្ធស្រុកទាំង៣៧ ដូចជាត្រួតត្រាលើក្សត្រប្រទេសថៃទាំង៦អឺចឹងដែរ ពេលនេះត្រួតត្រាបានតែទឹកដីចាស់ទាំង៦ប៉ុណ្ណោះ ពោលគឺថា មានការថយចុះអានុភាពបន្តិច ។

វាទំនងថាការបែកបាក់គ្នានេះ បានបន្តជាច្រើនសតវត្សរ៍តមកទៀត ព្រោះយើងឃើញថា នៅឆ្នាំ១២៥៣ មហារាជតាលីត្រូវយល់ព្រមចំណុះពួកម៉ុងហ្គោលរបស់គូប៊ីឡៃខាន់ ដើម្បីសង្គ្រោះប្រទេសកុំឲ្យរលាយបាត់បង់ ។ ដោយហេតុនេះ ស្រុកយុនណានត្រូវត្រលប់មកជាខេត្រមួយរបស់ចិនវិញ រីឯបណ្ដារាជាណាចក្រថៃក៏ត្រូវក្លាយជានគរសាមន្តរាជរបស់ចិនដែរ[៩] ។

ចាប់ពីពេលនោះមក ពួកថៃតែងតែសាកល្បងរើបម្រះទាមទាររកឯករាជ្យជាច្រើនលើកច្រើនសា ក៏ប៉ុន្តែត្រូវចិនបង្ក្រាបគ្រប់ពេល ។ នៅទីបញ្ចប់ ស្ដេចក្រោយគេត្រូវចិនចាប់បានជាឈ្លើយ ហើយនាំយកទៅកាន់រាជធានីណានគីង រួចហើយធ្វើឃាតដោយចាត់ទុកដូចជាក្រុមបះបោរ ។

មុនពេលដែលពួកម៉ុងហ្គោលមកដល់ វាហាក់ដូចជាមានព្រឹត្តការណ៍ធំមួយបានកើតឡើង ពីព្រោះថា គេឃើញមានពួកថៃនេះ ចុះមកតាំងទីលំនៅ នៅភាគខាងជើងស្រុកលាវសព្វថ្ងៃ ត្រង់ហ្លួងប្រាបាង, នៅម៉ង់, នៅ

[៨] តាមមើលទៅ គឺជាផ្នែកទឹកដីដែលណានឆាវបានដណ្ដើមយកមកជាចំណុះ ហើយបានទទួលនូវស្វ័យភាពរបស់គេវិញ ។

[៩] លោកសង្ឃសេស៊ីតមួយអង្គព្រះនាមថាម៉ាធីយ៉ាឆាងបានសរសេររាយលំអិតនៅក្នុងព្រឹត្តបត្ររបស់សាលាបារាំងចុងបូព៌ា ឆ្នាំ១៩០១ ក្បាលទី១ ត្រង់ទំព័រ៣១២ដល់៣២១ ជាអក្សរចិន និងមានបញ្ឈាក់ជាអក្សរឡាតាំងផងដែរ នូវឈ្មោះស្ដេចណានឆាវ ៤៦អង្គដែលសោយរាជ្យពីឆ្នាំ៦២៩ដល់១២៥១ និងឈ្មោះមហារាជតួន១១អង្គ ដែលសោយរាជ្យក្រោយពេល គូប៊ីឡៃខាន់ យកនគរដាក់ជាចំណុះ ចាប់ពីឆ្នាំ១២៦១ដល់១៣៨១ រហូតដល់ពេលដែលស្ដេចចុងក្រោយគេព្រះនាម មិញ ត្រូវបានចិនចាប់ធ្វើជាឈ្លើយនាំយកទៅកាន់ ណានគីង ។

ឈៀងម៉ៃ បន្តបង្កើតបានជារដ្ឋសាន និងរដ្ឋខ្វាំងមួយទៀតនៅអាងទន្លេមេណាមខាងលើ ។ មុនដំបូង ពួកនេះជារដ្ឋសាមន្តរាជរបស់ស្តេចខ្មែរ មានរាជធានីនៅស័ង្គលោក (នៅពាក់កណ្តាលទីពីរនៃសតវត្សរ៍ទី១១) ។ បន្ទាប់មកបានមកសោយរាជ្យនៅសុខោទ័យ[១០] (ចំណែកចុងក្រោយនៃសតវត្សរ៍ទី១១) រួចសោយរាជ្យលើទឹកដីជិតខាងទាំងអស់ ដែលជាទឹកដីរបស់ពួកមនខ្មែរ ឬតាឡាំង ។ គឺចេញពីរាជធានីសុខោទ័យនេះហើយ និងបន្ទាប់មក ពីរាជធានី អយុធ្យា ដែលពួកថៃចាប់បង្កើតបានជាក្សត្រប្រទេសតូចៗមួយចំនួន នៅក្បែរអាងទន្លេមេគង្គខាងលើ ខាងស្តាំ រួចបង្កើតរាជាណាចក្រថៃ ឬសៀម ដែលមានរាជធានីលើកពីអយុធ្យាទៅបាងកក នៅសតវត្សរ៍ទី១៨ ។

នៅពេលដែលតាំងរាជធានីនៅសុខោទ័យ ពួកថៃបានត្រួតត្រារួចទៅហើយទៅលើទឹកដីដែលនៅជុំវិញនោះ ។ គេមិនបានដឹងថាតើរាជាណាចក្រថ្មីនោះមានព្រំប្រទល់រហូតដល់ត្រឹមណានោះទេ ក៏ប៉ុន្តែវាហាក់ដូចជាថាព្រំប្រទល់ខាងកើតមិនបានមកដល់ឈៀងម៉ៃទេ ហើយព្រំប្រទល់ខាងលិចក៏មិនទៅដល់សមុទ្រដែរ ។ ព្រំប្រទល់ខាងជើងប្រហែលជានៅត្រឹមព្រំដែនវវាងសៀម និងភូមាសព្វថ្ងៃ ហើយព្រំប្រទល់ខាងត្បូងប្រហែលជានៅពីលើអយុធ្យាបន្តិច ។

តាមមើលទៅប្រទេសដែលយើងហៅថា សៀមសព្វថ្ងៃ គឺជាទឹកដីរបស់រដ្ឋមនខ្មែរតូចៗពីរ តាំងពីច្រើនសតវត្សរ៍ណាស់មកហើយ ជានគរសាមន្តរាជរបស់កម្ពុជាក្នុងរយៈពេលប្រហែលជាង៦០០ឆ្នាំ តែរដ្ឋនីមួយៗមានស្តេចសោយរាជ្យសព្វៗខ្លួន ។ ឯកសារចិនបានហៅរដ្ឋខាងជើងថា សៀនឡួ មានរាជធានីនៅឡាហុង (ហរិបន្ទុះ សព្វថ្ងៃគឺ លំពូន) និងហៅរដ្ឋខាងត្បូងថា ឡូហ៊ូ ។ ក្រោយមកប្រទេសថៃគឺសៀនឬសៀម បានឯករាជផុតពីកម្ពុជា ក៏ប៉ុន្តែ ឡូហ៊ូ នៅស្ថិតនៅក្រោមការត្រួតត្រានៅឡើយ ។ គឺនៅសម័យនោះហើយដែលលេចព្រះរោងឬរាមាកំហែង ចេញមកជាមេ ឬចៅ នៃទឹកដីសុខោទ័យ[១១] មិនដឹងថាដោយជ្រែករាជ្យ ឬយ៉ាងណាទេ តែទ្រង់ជាអ្នកកសាងសន្តតិវង្ស ស្តេចស្រីសញ្ជនាលយៈសុខោទ័យ ដែលយើងបានស្គាល់ស្តេចមួយចំនួន[១២] ។ ព្រះរោងនេះដែលរឿងនិទានខ្មែរបានចាត់ទុកថា ជាមេកងខាងដឹកជញ្ជូនទឹកបរិសុទ្ធចេញពីល្អាងភ្នំស័ក្តិសិទ្ធិមួយកន្លែង មកកាន់

[១០] ការកាន់កាប់ទឹកដីកាលពីសតវត្សរ៍ទី១៨នោះមិនដូចសព្វថ្ងៃទេ ព្រោះតាមសិលាចារឹកថៃ ស្តេចសុខោទ័យព្រះនាមថាសួថៃត្រូវធ្វើការប្រយុទ្ធទប់ទល់នឹងពួកថៃទាំង៦ នៅភាគខាងជើង ដែលលើកគ្នាមកវាយយករាជធានី ។

[១១] ខ្ញុំបារម្ភខ្លាចតែការផ្គូស្តេចរាមាកំហែងជាមួយនឹងព្រះរោង ដែលអ្នកប្រវត្តិវិទូបស្ចិមប្រទេសកំណត់នេះ មានការខុសឆ្គងទេ ព្រោះថាព្រះរោងអាចគ្រាន់តែជាតួអង្គក្នុង រឿងព្រេងនិទាន ឬក៏ជាវីរបុរសក្នុងសម័យបុរេប្រវត្តិម្នាក់ ដែលគេយកមកដាក់ឲ្យធ្វើជាតួឯកនៃរឿងណាមួយក្រោយមក ។

[១២] មានរឿងនិទានសៀមមួយរៀបរាប់ថាព្រះរោងនេះជាបុត្ររបស់ក្សត្រីនាគមួយអង្គ មានន័យថា កូនអ្នករដ្ឋវាសី ជាមួយនឹងស្តេចហរិបន្ទុនគរ គឺលំពូនសព្វថ្ងៃ ដែលបានជួបនាងនៅក្នុងពេលលេង ។ ស្តេចនោះបានត្រូវព្រះមាតា ដែលជាម្ចាស់ក្សត្រីរដ្ឋទា

រាជធានីឥន្ទបត្ត មួយឆ្នាំម្តង និងជាអ្នកដែលនាំគេឯងធ្វើកញ្ចើល្អីលាបម្រ័ក្សណ៍ ហាក់ដូចជាមានដើមកំណើតនៅឯឡាវហ្ស៊ូទេ ប៉ុន្តែដោយមាន បញ្ហាអ្វីមួយ ក៏គេចខ្លួនទៅនៅឯសៀនទៅ ។ នៅឯសៀននោះ មុនដំបូងគឺជាមេបះបោរ តែក្រោយមកមានឋានៈជាចៅ បន្ទាប់ពីមានជ័យជម្នះលើពួកសៀន និងទ័ពខ្មែរ រួចហើយក៏បានឡើងសោយរាជ្យ ។ រឿងសៀមនិយាយថា ព្រះអង្គជាបុត្រស្តេច បើហោចណាស់ក៏ជាបុត្រចិញ្ចឹមដែរ ហើយទ្រង់បានរៀបអាពាហ៍ពិពាហ៍ជាមួយក្សត្រីយ៍វង្សទាយាទរបស់នគរសុខោទ័យ ម្ល៉ោះហើយក៏ក្លាយព្រះអង្គ ជាព្រះរាជា ព្រោះថាជាស្វាមីរបស់ព្រះក្សត្រីយ៍ ។ អត្ថបទសិលាចារឹកសុខោទ័យបាននិយាយថា បើសិនណាជាការប្រដូច ព្រះរាមាកំហែងទៅនឹងព្រះរោងពិតប្រាកដអ៊ីចឹងមែននោះ ព្រះអង្គគឺជាបុត្រារបស់ព្រះចៅម្នាក់ជាមេទ័ព ជាមេក្រុមបួនដ័រីករាយ និងជាស្តេច ។ ទោះជាយ៉ាងណាក៏ដោយ ព្រះអង្គ គឺជាអ្នកដែលរំដោះប្រទេសឲ្យបានឯករាជ្យ មិនគ្រាន់តែចំពោះនគរសៀន ឬអាងទន្លេមេណាមខាងលើប៉ុណ្ណោះទេ ដែលប្រហែលជាបានឯករាជមុនរួចទៅហើយ នៅពេលដែលព្រះអង្គទទួលព្រះឋានៈជាព្រះចៅ តែជាពិសេស ចំពោះឡាវហ្ស៊ូ ឬអាងទន្លេមេណាម ខាងក្រោម ។ តាមហេតុការណ៍ទាំងអស់នេះ វាហាក់ដូចជាបានបញ្ជាក់រួចទៅហើយថា ព្រះរាមាកំហែង សោយរាជ្យនៅឆ្នាំ១២៩៦ ត្រូវនឹងមហាសករាជ១២១៨ ។

គឺនៅពេលនោះហើយដែលអ្នកកត់ត្រាចិនបានសរសេរថា ប្រទេសកម្ពុជានាឆ្នាំ១២៩៦ បានចុះខ្សោយហើយមានប្រជាជនតិច ក្រោយពីមានសង្គ្រាមជាមួយសៀមរួចមក និងថាអាងទន្លេមេណាមទាំងមូលបានត្រូវបង្រួបបង្រួមមកជារាជាណាចក្រថៃតែមួយ ដែលចិនហៅថាសៀនឡូ និងឡូហ្ស៊ូ គឺហៅតាមរបៀបចិន យកឈ្មោះនគរ ទាំង២ដាក់ភ្ជាប់គ្នាតែម្តង ។ កម្ពុជាពេលនោះ ដោយមានបដិវត្តន៍នយោបាយផង បដិវត្តន៍សន្តតិវង្សផង និងបដិវត្តន៍សាសនាផងដូចដែលខ្ញុំបានរៀបរាប់ខាងលើ មិនមានលទ្ធភាពនឹងចាប់បង្ខំក្សត្រប្រទេសដែលរើបម្រះរក

យាទនៃរាជបល្ល័ង្កសុខោទ័យ បោះបង់ចោល តែត្រូវបានព្រះបិតាទទួលស្គាល់ ហើយយកមកចិញ្ចឹម ដាក់ព្រះនាមថា អារុណកុមារ គឺដោយហេតុនោះហើយទើបទ្រង់អាចឡើងសោយរាជ្យជាព្រះរាជាបាន ហើយមានព្រះនាមក្លាយជាព្រះរោងទៅ ។ ពាក្យរោងនេះ ក្នុងភាសាខ្មែរមកពីពាក្យអារុណ ឬអរុជុន ។ រឿងដដែលនេះបាននិយាយថា ស្តេចអង្គនោះខុះការគួរសមជាមួយនឹងស្តេចសាមន្ត-រាជឡុងគូ ក៏ត្រូវពួកនោះតាមធ្វើបាប រហូតឈឺចិត្ត ក៏លោតទឹកសម្លាប់ខ្លួនទៅ ។

មានរឿងនិទានខ្លះនិយាយថា ព្រះអង្គត្រូវគេធ្វើឃាតនៅក្នុងព្រះរាជវាំង ។

មានរឿងនិទានខ្លះទៀតនិយាយថាគេបានថ្វាយព្រះនាមឲ្យព្រះអង្គថាពញាដាំ (ស្តេចខ្មៅ) ឬពញាហៃ (ស្តេចភ្លើង) និងថាព្រះអង្គ បានដណ្តើមយកខែត្រចន្ទគាប៊ុនពីស្តេចខ្មែរ ហើយបាននាំទ័ពលុកលុយ ម៉ាឡេស៊ី ទៀតផង ។

ពួកម៉ាឡេបានហៅស្តេចអង្គនេះ នៅក្នុងរាជពង្សាវតាររបស់គេថាពញាអាពិ (សូមអាន Hardouin, Légendes historiques siamoises, នៅក្នុង Revue Indochinoise, ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩០៤ ទំព័រទី៤៥ ។

ឯករាជ្យ ឲ្យចូលមកក្នុងនឹមត្រួតត្រារបស់ខ្លួនបានវិញទេ ។ ពេលនោះព្រះពញាខទង[១៣] ដែលសោយរាជ្យនៅចន្លោះនគរទាំង២ ក៏បានសម្រេចបោះបង់រាជធានីចាស់របស់ថៃ មកតាំងនៅលើកោះមួយក្នុងទន្លេមេណាមចម្ងាយប្រហែលជា ៥០០គីឡូម៉ែត្រ នៅខាងត្បូងសុខោទ័យវិញ ។

កោះនេះ ឬបើហោចណាស់ក៏ត្រង់ទីតាំងរាជវាំងថ្មីដែរ មានឈ្មោះថា ណងស្នោ (មានន័យថា វាលស្នោ) ដូច្នេះហើយបានជាខ្មែរហៅស្រុកសៀមពេលនោះថាជារាជាណាចក្រណងស្នោ ឯពួកអឺរ៉ុបក៏ហៅប្រែតាមនោះថា *rayaume du marais des sarnau* ប៉ុន្តែពួកប៉េហ្កាន និងភូមានៅរក្សាឈ្មោះសំស្ក្រឹតថា ទ្វារវតី ។ រាជវាំងថ្មីនេះ នៅពេលដែលកសាងរួច គេដាក់ឈ្មោះឲ្យថា ក្រុងទេពមហានគរស្រីអយុធ្យា[១៤] ។ ចំណែកឯនគរវិញ គេហៅថារាជាណាចក្រអយុធ្យា ឬរាជាណាចក្រសៀម ឬរាជាណាចក្រថៃ រហូតមកដល់ឆ្នាំ១៧៦៣ នៅពេលដែលស្តេចពញាតាក់ បោះបង់អយុធ្យាទៅគង់នៅឯបាងកក (ធនបុរី) វិញ ។

រាជធានីអយុធ្យាស្ថិតនៅចម្ងាយប្រហែលតែ១០០គីឡូម៉ែត្រប៉ុណ្ណោះពីព្រំដែនកម្ពុជា ដែលកាលណោះនៅឯខាងជើងកូរ៉ាត់ (នគររាជ) ។ ដោយចង់ឆាកចេញឲ្យឆ្ងាយពីពួកប៉េហ្កានដែលពួកគេខ្លាចរអា ពួកសៀមបានខិតមកជិតកម្ពុជា ហើយបង្កជាគ្រោះថ្នាក់មួយចំពោះកម្ពុជាដែលកំពុងតែមានឱនភាព ។ គឺចេញពីអយុធ្យានោះឯងដែលខ្មែរបានរៀបចំការពារសត្រូវយ៉ាងរឹងមាំ ដែលទ័ពសៀមចេញមកវាយកម្ពុជាអស់កំឡុង៥សតវត្សរ៍ ។ ការដែលរាជធានីអយុធ្យារបស់ថៃស្ថិតនៅជិតអតីតរាជធានីខ្មែរគឺ ឥន្ទបត្តមហានគរ ជាមូលហេតុ មួយដែលបង្ខំឲ្យព្រះរាជាខ្មែរធ្វើដំណើរចុះមកខាងត្បូង រហូតដល់ស្រីសន្ធរ រួចទៅភ្នំពេញ បន្ទាប់មកលង្វែក ហើយក្រោយមកទៀត ទៅឧត្តុង្គ បើទោះជាព្រឹត្តិការណ៍ផ្ទៃក្នុងតម្រូវឲ្យវិលមកនៅលង្វែកវិញក៏ដោយ ។

## ៨- ស្រុកលាវ ឬ ឆាំយឡាវ

ប្រទេសលាវជាផ្នែកមួយនៅខាងជើងគេបង្អស់នៃនគរហ្វូណន កាលពីជំនាន់ស្តេចកោណ្ឌញ្ញៈ ។ លាវ បានទទួលស្គាល់អធិរាជភាពនៃមហាណាចក្រខ្មែរ ដែលបានចាក់ឫសនៅភាគខាងត្បូងឥណ្ឌូចិន ក៏ប៉ុន្តែគេពិបាកនឹងជឿណាស់ថា ស្តេចហ្វូណន ដែលមានរាជធានីនៅឯតូមូ ក្នុងខេត្តព្រៃកប្បាសសព្វថ្ងៃឯណោះ បានវាតអំណាចពិតប្រាកដមែនទៅលើបណ្តាប្រជារាស្ត្រដែលរស់នៅពីខាងជើងភ្នំដងរែក និងជ្រោះខេមរ៉ាត់ ។

---

[១៣] ព្រះអភិសេកនាមគឺ ស្រីសុរិយាមហាធម្មរាជាធិរាជ តែចិនហៅថាប៉ាឡូឡានមីស៊ុនឡូ (ប៉ាឡូ = ព្រះ, ឡានមី = រាមា, ស៊ុនឡូ = សុរិយា) ។ មានឯកសារខ្លះថ្វាយព្រះនាមថា ព្រះរាមាធិបតី ។ តាមមើលទៅ ខទង ឬខថង ជាឈ្មោះធម្មតា បានជាគេហៅដូច្នេះមកពីអង្រឹងរបស់ព្រះអង្គធ្វើអំពីមាស ។

[១៤] អយុធ្យា ជាឈ្មោះពីមុនរបស់រាជាណាចក្រមួយនៅឥណ្ឌា គឺរាជាណាចក្រអ៊ូដ ។ អ្នកខ្លះថាអយុធ្យាក្លាយមកពីទ្វារវតី ។

ព្រះរាជាណាចក្រកម្ពុជា នៅក្នុងពេលដែលចាប់កសាងឡើងជាដំបូង ក៏ដូចជានៅពេលកសាងឡើងជាលើកទីពីរ មិនដែលមានព្រំប្រទល់ខាងជើងហួសពីខោន ហើយព្រំប្រទល់ខាងត្បូងហួសពីអាត្តូពឺទេ ។

ព្រះរាជាក្រុងកម្ពុជាបានចាប់រាតតឥទ្ធិពលរហូតទៅដល់ខាងជើងរាជាណាចក្រហ្លួងប្រាបាងសព្វថ្ងៃ តែនៅពេលដែលគេបានលើករាជធានីទៅតាំងនៅឯឥន្ទបត្ត លើមាត់បឹងទន្លេសាបប៉ុណ្ណោះ ។ ឥទ្ធិពលជាម្ចាស់ ឬអនុត្តរភាពនេះ ក្រោយមកបានរីកចម្រើនធំឡើង ប៉ុន្តែបានថយចុះទៅវិញបន្ទាប់ពីកើតមានព្រឹត្តិការណ៍ផ្សេងៗ ជាបន្តបន្ទាប់ គឺមានតែឈ្មោះ មិនមានអ្វីជាពិតប្រាកដទេ ។ ព្រះរាជាកម្ពុជាអាចនឹងលើកទ័ពទៅតាមដាក់ទោស ស្តេចនគរសាមន្តរាជ ណាមួយ ដែលបះបោរប្រឆាំងទាមទារឯករាជ្យ ហើយមិនព្រមគោរពតាម, ព្រះអង្គអាចនឹងបង្កការលំបាកដល់ពួកកុលសម្ព័ន្ធសាននៅតាមព្រំដែនយុនណាន ដែលចិនបានយកមកដាក់ជាអាណានិគមនៅសតវត្សរ៍ទី១៣ ជាហេតុធ្វើឲ្យព្រះចៅអធិរាជប៉េកាំងបញ្ជូនរាជទូតមួយទៅកម្ពុជាដើម្បីធ្វើការតវ៉ា ។ ព្រះអង្គអាចទទួលឲ្យស្នាក់នៅក្នុងរាជវាំងរបស់ព្រះអង្គនូវរាជវង្សណាមួយអង្គ ដែលមិនសប្បាយចិត្ត ឬមានកំហុសដូចជាករណីពញាវ៉ាត់ បុត្រពញាកំពង់ ជាស្តេចនៅហ្លួងប្រាបាង ដែលរត់មកសុំជ្រកកោន រួចហើយប្រើអំណាចធ្វើអន្តរាគមន៍ពីលើរាជបល្ល័ង្គ ឲ្យរក្សាសន្តិភាព ឲ្យដោះស្រាយបញ្ហាដោយសម្រួល និងជាពិសេស ទទួលស្គាល់ស្តេចណាជាស្តេចណា ប៉ុន្តែមិនមែនគ្រប់ពេលទេ ។ ព្រះអង្គអាចទទួលស្តេចនគរសាមន្តរាជដែលនៅជិតៗ ឲ្យចូលគាល់ ដើម្បី«ឱនព្រះកេសយកមកជូតធូលីព្រះបាទា» ។ ព្រះអង្គក៏អាចអនុញ្ញាតឲ្យស្តេចនគរសាមន្តរាជទាំងនោះ នាំយកសិលាចារឹកមកកប់នៅក្បែររាជវាំងដូចជាសិលាសាយហ្វុង ដែលនៅតែប៉ុន្មានគីឡូម៉ែត្រប៉ុណ្ណោះពីវៀងច័ន្ទ ។ ប៉ុន្តែព្រះអង្គមិនអនុញ្ញាតឲ្យមានស្តេចណាមួយអង្គ ដែលមានអំណាចជាងស្តេចលាវ បង្ហាញខ្លួនជាម្ចាស់ពីលើទៀតទេ លើកលែងតែព្រះចៅអធិរាជចិនចេញ ដែលធ្លាប់បានទទួលស្គាល់ថា មានអធិរាជភាពលើកម្ពុជា សៀម និងជ្វា រួចមកហើយ ។

តើមុនពេលដែលពួកថៃអាយ-ឡាវមកដល់ ពួកលាវនេះជាអ្នកស្រុកដើម ឬយ៉ាងណា ? ខ្ញុំហាក់ដូចជាមិនជឿទេ ។ បើដូច្នេះ តើពួកនេះមានដើមកំណើតមកពីណា? ពួកនេះមានទំនៀមទម្លាប់ប្រពៃណីដូចខ្មែរច្រើនហើយគឺប្រហែលដោយហេតុនោះហើយ បានជាពួកចិនបានចាត់ទុកពួកលាវនេះថា ជាអ្នកស្រុកហ្វូណន តាំងតែពីមុនគ្រិស្តសករាជម្ល៉េះ ដោយមិនបានបែងចែកអធិបតេយ្យភាពរបស់គេទេ ។ ពិតប្រាកដណាស់ថា ពួកនេះមានលក្ខណៈ ដូចគ្នានឹងពួកខ្មែរដែលជាសម្ព័ន្ធញាតិនឹងអ្នកស្រុករស់នៅអាងទន្លេមេណាមដែរ ។ ពួកនេះដូចជាមិនទាន់កាន់ព្រហ្មញ្ញសាសនា នៅឡើយទេនៅសម័យហ្វូណនទាល់តែដល់ពេលក្រោយយូរមកទើបទទួលយកសាសនានេះ រួចហើយមិនបានប្រែទៅកាន់ពុទ្ធសាសនានៅឡើយទេ មុនសតវត្សរ៍ទី១៤ គឺរហូតដល់ពេលដែល ហ្វាង៉ុម ដណ្តើមយកប្រទេសបាន ។

តើអ្នកស្រុកលាវនោះមានសាច់ឈាមតែមួយ ឬក៏យ៉ាងណា? វាអាចនឹងដូច្នេះ នៅមុនពេលមានពួកអ្នក

ដែលចុះមកពីទីបេ និងអាណាខែត្រខាងត្បូងនៃប្រទេសចិន ជាក្រុមតូចៗ តែទីបញ្ចប់ បានមកដណ្ដើមយកស្រុកទាំងមូល ហើយធ្វើឲ្យអ្នកស្រុកដើមរលាយបាត់ នូវជាតិសាសន៍របស់ខ្លួន ឬក៏មករស់នៅលាយឡំជាមួយអ្នកស្រុកដើម ដោយទទួលយកទំនៀមទម្លាប់ប្រពៃណីមួយចំនួនធំ ។ គឺដោយសារពួកលាវនេះមានឈាមជ័រតែមួយ ដូច្នេះហើយ បានជាគេតែងតែនិយាយថាពួកនេះបែកចេញមកពីបុព្វបុរសតែមួយ ហើយបើទោះជាផលប្រយោជន៍ខាងសម្ភារតម្រូវឲ្យគេបែកគ្នាចេញជាជាតិ៥យ៉ាងណាក្ដី ក៏គេនៅតែមិនភ្លេចថា គេមានប្រភពដើមរួមគ្នាដែរ ។

គេមិនបានដឹងច្បាស់ថាតើនៅពេលណាដែលពួកសាន ឬថៃ ឬសៀម ដែលយើងបានឃើញពីខាងលើរួចមកហើយថា មានដើមកំណើតជាហិណ្ឌូដែរ ចុះពីខាងលិចយុនណានមកកាន់ស្រុកលាវទេ[១៥] ប៉ុន្តែវាប្រាកដណាស់ថា ហេតុការណ៍នេះកើតមានឡើង ក្រោយពេលដែលពួកថៃចូលលុកលុយនគរសាន ។

គួរកត់សម្គាល់ថាពួកថៃមានពីរក្រុម ៖ ក្រុមទី១ គឺពួកដែលរស់ដំបូងនៅក្នុងអាងទន្លេមេណាមខាងលើរួចក្រោយមកបានវាតយកទឹកដីក្នុងអាងទន្លេមេណាមខាងក្រោមទៀត គេហៅថា ពួកថៃធំ, និងក្រុមមួយទៀតដែលមករស់នៅប្រទេសលាវ គេហៅថា ពួកថៃតូច ។ ឯពួកសានក៏មានពីរក្រុមដូចគ្នាដែរ គឺមួយក្រុមមកតាំងទីលំនៅនៅខាងលើអាស្សាម និងមួយក្រុមទៀតនៅខាងកើត បានឆ្លងកាត់ប្រទេសភូមារួចមកតាំងទីលំនៅ នៅត្រង់កន្លែងដែលយើងហៅថា រដ្ឋសានសព្វថ្ងៃ ។

ឯកសារប្រវត្តិសាស្ត្រចិនក៏បាននិយាយថា មានពួកថៃពីរក្រុមដែរ ក៏ប៉ុន្តែមិនបានហៅថាថៃធំ និងថៃតូចទេ តែហៅថាថៃខ្មៅ និងថៃស ។ ការបែងចែកប្រហែលជានឹងត្រឹមត្រូវជាង ប្រសិនបើគេនិយាយថា មានពួកថៃដើម ពោលគឺពួកថៃហិណ្ឌូដែលខ្មៅ និងពួកថៃថ្មី ពោលគឺពួកអ្នកស្រុកដើមដែលរស់នៅយុនណាន ហើយបានក្លាយទៅជាថៃដែរ បន្ទាប់ពីពួកថៃហិណ្ឌូមកដណ្ដើមយកស្រុកបាន ហើយរស់នៅលាយឡំគ្នា បើទោះជាថា ពួកនេះមានជាតិសាសន៍ជាចិន[១៦] មានសម្បុរលឿង ឬស ឬប្រហាក់ប្រហែលនោះក៏ដោយ ។

នៅមានវិប្រជាជាច្រើនទៀតនៅក្នុងប្រទេសលាវ ខិតទៅជិតតុងកឹងបន្តិច ដែលប្រកាន់ថា ខ្លួនជាថៃខ្មៅ

---

[១៥] គឺនៅពេលនោះហើយដែលពួកចិនហៅពួកនេះថា ថៃឡាវ ឬថឡាវ ដើម្បីកុំឲ្យច្រឡំជាមួយពួកថៃដែលនៅយុនណាន ។

[១៦] ពួកថៃដែលបានចុះមកតាំងទីលំនៅៗត្រង់ប្រទេសសៀមជាពួកថៃខ្មៅ ពោលគឺជាពួកដែលចេញមកពីប្រទេសឥណ្ឌា មានកំណើតដើមជាហិណ្ឌូ បានមកដណ្ដើមយកអាណាខែត្រដែលមានពួកចិនស្បែកលឿងរស់នៅដែលគេហៅថាជាពួកថៃស ។ ពួកថៃសនេះ មិនបានចុះមកប្រទេសសៀមតាមពួកថៃខ្មៅទេ ព្រោះគេជាអ្នកចាញ់ ។ គឺដោយហេតុនោះហើយបានជាមានពាក្យដែលហៅពួកថៃ នៅសៀមនោះថា ស្យាម មានន័យថា ខ្មៅ ។

ការបែងចែកអ្នកស្រុកជាខ្មៅ និងសដូច្នេះ គេប្រទះឃើញមានច្រើនណាស់នៅចុងបូព៌ា ដូចជាពួកទីបេតែងហៅពួកហិណ្ឌូថា ឈាហ្គា មានន័យថា ឈាខ្មៅ ឯចិនវិញគេហៅពួកហិណ្ឌូថា ឈាណាក មានន័យថា ឈាស ។

ឬជាថៃស ក៏ប៉ុន្តែការដែលប្រកាន់យ៉ាងនេះ គេសំអាងភាគច្រើនទៅលើពណ៌សម្បុរកបំពាក់ដែលគេស្លៀក ទៅវិញទេ ។ ដូច្នេះ គេមិនត្រូវលើកយករឿងសព្វថ្ងៃនេះមកនិយាយ ដើម្បីដោះស្រាយបញ្ហាដែលយើងកំពុងនិយាយខាងលើនោះទេ ។

ខ្ញុំគិតថា គឺពួកថៃខ្មៅនេះឯង ដែលកាលនោះបានត្រួតត្រាទៅលើពួកថៃស ដល់ត្រូវពួកចិនដេញវាយប្រហារ បានធ្វើដំណើរវិលត្រលប់មកកាន់ប្រទេសភូមាវិញ ជាទីកន្លែងដែលពួកគេធ្លាប់បានដើរកាត់ ឬក៏ធ្លាប់រស់នៅផងក៏មិនដឹងកាលពីច្រើនរយឆ្នាំមុនៗ ហើយក៏គឺពួកថៃខ្មៅនេះឯង ដែលក្រោយពីបានធ្វើដំណើរទៅដល់ស្រុកចិន ហើយបានបន្តដំណើរចុះមកតាំងទីលំនៅ នៅក្នុងអាងទន្លេមេណាមខាងលើ តាំងពីសតវត្សរ៍ទី៩ រហូតដល់សតវត្សរ៍ទី១១ រួចហើយបន្តពង្រាយគ្នាមកក្នុងប្រទេសលាវទៀត ។

ពេលនោះ ពួកកុលសម្ព័ន្ធលាវស្ថិតនៅក្រោមការដឹកនាំរបស់ពួកចៅ ឬឃុន ដែលមិនមែនជាថៃនៅឡើយទេ ហើយខ្ញុំគិតថាប្រទេសលាវបានស្ថិតនៅយ៉ាងដូច្នេះរហូតមក លើកលែងតែនៅឈៀងម៉ៃ និងឈៀងសែន ដែលស្ថិតនៅជិតរាជាណាចក្រសុខោទ័យ ដែលប្រហែលជាមានស្តេចសោយរាជ្យមានដើមកំណើតជាថៃ ហើយបានក្លាយខ្លួនជាសត្រូវរបស់ពួកលាវ ។ ប៉ុន្តែអ្វីដែលប្រាកដ គឺប្រទេសលាវបានស្ថិតនៅជាប្រទេសឯករាជ មិនបានចំណុះថៃទេរហូតមកដល់សព្វថ្ងៃ ហើយនៅពេលដែលពួកកុលសម្ព័ន្ធដែលរស់នៅខាងជើងទន្លេមេណាម នាំគ្នាឆាកទៅចំណុះសុខោទ័យតាំងតែពីសតវត្សរ៍ទី១៣រហូតមក ពួកកុលសម្ព័ន្ធលាវបាននាំគ្នាបែរមករក សុវណ្ណភូន សៀងដុង និង សៀងតុងមឿងស្វា (សព្វថ្ងៃគឺ ហ្លួងប្រាបាង) ឯនេះវិញ ។

ពួកថៃដែលមកដល់ស្រុកលាវមានអារ្យធម៌ជឿនលឿនជាងពួកអ្នកស្រុកអាយ ។ ម្យ៉ាងទៀត ពួកនេះមកដល់មានគ្នាច្រើន ហើយមានពួកថៃធំ (គឺពួកដែលក្រោយមកមានឈ្មោះថា សៀម) នៅពីក្រោយខ្នង ជួយជំរុញ ជួយប្រានពួកគេ ជួយផ្តល់អាវុធ ហើយជួនកាលក៏អាចជួយជាកម្លាំងទ័ពផងដែរ ។ ម្ល៉ោះហើយ ពួកនេះមានប្រៀបលើពួកលាវដែលនៅមិនទាន់ស៊ីវិល័យ ចាប់តាំងពីចុងសតវត្សរ៍ទី១៣មក នៅពេលដែលគេដណ្តើមយកទឹកដីទាំងអស់នៅចន្លោះអាងទន្លេមេណាមខាងលើ និងអាងទន្លេមេគង្គខាងលើ ដណ្តើមបានរាជធានីទី២របស់លាវ ហើយតាំងខ្លួនជាសត្រូវរបស់ហ្លួងប្រាបាង ។ រាជធានីនោះសព្វថ្ងៃគេហៅថាវៀងច័ន្ទ តែកាលនោះ ពួកថៃដាក់ឈ្មោះឲ្យថា ចន្ទះបុរី មានន័យថា ជារាជធានីខ្វិមចន្ទន៍ក្រឹស្នា ។

តាមមើលទៅ ពួកថៃប្រហែលជានៅត្រួតត្រាលើទឹកដីមួយចំនួនធំនៅពីខាងជើង ខាងលិច និងខាងត្បូងរាជធានីនេះនៅឡើយ នៅឆ្នាំ១៣៣៦ នៅពេលដែលវីរបុរសរបស់លាវ គឺហ្វាង៉ុម បានលេចខ្លួនឡើង គឺប្រហែលដោយស្នាដៃព្រះបាទរាមាកំហែង ។

ដូច្នេះ នៅពេលដែលរាជាណាចក្រកម្ពុជាធ្លាក់ចុះអាប់ឱន មានរាជាណាចក្រធំៗពីរកើតឡើងនៅឯប្រទេសលាវ គឺរាជាណាចក្រឡានឆានហូមខាវ ឬស៊ីឡាងសឹងហូមខាវ មានន័យថា "រាជាណាចក្រដំរីរាប់លាន

និងក្លស់ពណ៌ស» ហើយនិងរាជាណាចក្រចន្ទៈបុរី មានន័យថា «រាជាណាចក្រខ្ទឹមចន្ទន៍ក្រឹស្នា» ។ រាជាណាចក្រទី១ នៅជារាជាណាចក្រលាវនៅឡើយ ឯរាជាណាចក្រទី២ បានក្លាយជារាជាណាចក្រថៃទៅហើយ ។

## ៥- ប្រទេសភូមា ឬ ស្រុកមន

ប្រជាជនខ្មែរ បានស្គាល់ប្រទេសដែលយើងហៅសព្វថ្ងៃថា ភូមា ជាច្រើនសតវត្សរ៍ណាស់មកហើយ ក្រោមឈ្មោះថា ស្រុកមន ឬស្រុកបាគូ (ប៉េហ្កាន) ថ្វីបើសិលាចារឹកមិនមាននិយាយអំពីស្រុកនេះក៏ដោយ ។ ដោយកាលពីមុននោះ ស្រុកមន និងស្រុកខ្មែរ មានព្រំប្រទល់ជាប់គ្នា ដែលត្រូវនឹងព្រំប្រទល់រវាងភូមា និងសៀម បច្ចុប្បន្ន វាប្រាកដណាស់ថា ប្រជាជនទាំងពីរពិតជាធ្លាប់មានទំនាក់ទំនងនឹងគ្នា ហើយក៏អាចធ្លាប់ធ្វើចម្បាំងនឹងគ្នាទៀតផងក៏មិនដឹង ត្រឹមមុនសតវត្សរ៍ទី១៨ ។

តាមពិតទៅ មានតែសិលាចារឹកតាព្រហ្មមួយប៉ុណ្ណោះដែលបាននិយាយអំពីខ្ញុំបម្រើជាតិមន ក្រៅពីនោះមិនមានសិលាចារឹកណាលើកឡើងទេ ដែលជាហេតុអាចធ្វើឲ្យគេគិតថាពួកខ្មែរមិនបានយកចិត្តទុកដាក់ចំពោះអ្នកស្រុកដែលរស់នៅឯខាងជើង និងពាយ័ព្យស្រុកសៀម ឬស្រុកសានឡើយ អ្នកស្រុកទាំងអស់នោះចំណុះកម្ពុជា តែខ្មែរដាក់ឈ្មោះឲ្យផ្សេងពីឈ្មោះដែលយើងហៅ ។ ខ្ញុំមិនជឿថា ខ្មែរមិនបានដឹងមិនបានឮអំពីព្រឹត្តិការណ៍ទាំងឡាយដែលកើតមាននៅភូមា (មីយ៉ាន់ម៉ា) ឬបាគូ (ប៉េហ្គូ) មុនពេលដែលកកើតរាជាណាចក្រថៃនោះទេ ។ ខ្មែរប្រាកដជាបានស្គាល់រាជធានីផ្សេងៗរបស់ភូមា ហើយដោយហេតុនោះហើយទើបបានជាគេមានពាក្យជាច្រើនសម្រាប់ហៅអ្នកស្រុកនោះ ។ ឥឡូវនេះ សូមពិនិត្យមើលព្រឹត្តិការណ៍ផ្សេងៗដែលកើតមានឡើង និងការផ្លាស់ប្តូរទីតាំងរាជធានី ដែលជាផលវិបាក ឬក៏ជាមូលហេតុនៃការផ្លាស់ប្តូរនយោបាយធំៗ ។

កាលពីយូរលង់ណាស់មកហើយ គឺតាំងពីសម័យដែលព្រះចៅអធិរាជអាឡិចសង់ឡឺក្រង់ (សតវត្សរ៍ទី៤មុនគ្រិស្តសករាជ) បានធ្វើការវាយប្រហារដណ្តើមយកប្រទេសឥណ្ឌាភាគខាងជើងរួចហើយ ឧត្តមសេនីយ៍ របស់ព្រះអង្គបានបង្កើតរាជាណាចក្រអាំងដូក្រិច មួយនៅលើមាត់ទន្លេគង្គា ពេលនោះមានពួកហិណ្ឌូដែលធ្វើដំណើរមកពីស្រុកកលិង្គឬកលិង្គនៈ បានមកតាំងទីលំនៅ នៅលើមាត់សមុទ្របឹងហ្កាល់ខាងកើត គឺឥណ្ឌូចិននោះឯង ។ ទឹកដីមាត់សមុទ្រត្រង់កន្លែងនោះពេលនោះមានពួកវិប្រជាមិនទាន់ស៊ីវិល័យ ជាអ្នកស្រុកដើមរស់នៅ មានឈ្មោះថា ពិលូ ឬពាលៈ ដែលមាននៅសេសសល់កុលសម្ព័ន្ធខ្លះរហូតដល់សព្វថ្ងៃនៅក្នុងប្រទេសសៀម ។ គេមិនដឹងថាតើពួកអ្នកស្រុកដើមទាំងនោះ បានទទួលពួកហិណ្ឌូយ៉ាងណាទេ ប៉ុន្តែវាហាក់ដូចជាថាពួកគេមិនបានប្រឆាំងទប់ទល់នឹងពួកអ្នកចំណូលថ្មី ដែលមានអារ្យធម៌ព្រហ្មញ្ញសាសនារួចទៅហើយ ហើយថែមទាំងចេះធ្វើសង្គ្រាមទៀតផងទេ ។ ពួកគេអាចនឹងបណ្តោយឲ្យពួកហិណ្ឌូមករស់នៅក្នុងចំណោមពួកគេ ឬមួយក៏គេនាំគ្នាដកខ្លួនថយ ទុកកន្លែងឲ្យតែម្តងក៏ថាបាន ។ បណ្តាក្រុមខបនិវេសន៍ហិណ្ឌូទាំងអស់នោះមិនខុសគ្នាពីអ្វីដែលបានកើតមាននៅឯឥណ្ឌូចិនភាគ

ខាងត្បូង និងអាគ្នេយ៍នោះទេ គឺចាប់ផ្ដើមពីការបង្កើតគ្រឹះស្ថានពាណិជ្ជកម្មតូចៗ រួចបន្តទៅបង្កើតបានជារដ្ឋកម្ពុជា និងចាម្ប៉ាឡើង ។ បណ្ដាក្រុមខបនិវេសន៍ហិណ្ឌូនៅតាមមាត់សមុទ្របឹងហ្គាល់នាពេលនោះប្រហែលជាតាំងនៅត្រង់ទីតាំងក្រុងតាវ័យ, មែរគុយ, តេណាសេរីម និងម៉ាតាបានសព្វថ្ងៃ ដែលពីមុនអ្នកស្រុកដើមដាក់ឈ្មោះឲ្យថា ថាវយ, ម៉ាន់, តាណាវស្រី, ម៉ាតាម៉ា ។ យើងមិនបានដឹងអំពីឈ្មោះពិតប្រាកដរបស់ទីក្រុងទាំងអស់នោះទេ នៅពេលដែលគេកសាងឡើង គ្រាន់តែបានដឹងថា ពួកហិណ្ឌូបានដាក់ឈ្មោះតាមភាសាសំស្ក្រឹតឲ្យថា រមញ្ញទេសៈ មានន័យថា “ស្រុកស្រស់បំព្រង” ទៅតាមទិដ្ឋភាពស្រុកដែលគេបានឃើញ ។

គឺដោយមានឈ្មោះដើមថា រមញ្ញ ដូច្នេះហើយ ទើបបានជាក្រោយមកក្លាយមកជារមន្យៈ រួចមកជា ម៉ានី, មោនី ហើយនៅទីបញ្ចប់មកជាមន ឬមនី ។ បើទោះជាស្រុកនេះមានប្រវត្តិឈ្មោះដោយឡែកយ៉ាងនេះក្ដី តែខ្មែរហៅស្រុកដែលយើងហៅថាភូមានោះថាស្រុកមនដូច្នេះ តាំងពីជាង១០០០ឆ្នាំមុនរហូតមកដល់សព្វថ្ងៃនេះ ។

ស្រុកដែលនៅពីខាងជើងរមញ្ញទេសៈ ដែលពួកមន ឬពាលៈ ឬពិលូ រស់នៅមានឈ្មោះជាភាសាសំស្ក្រឹតដែលពួកបញ្ញវន្តហិណ្ឌូដាក់ឲ្យថា “សុវណ្ណភូមិ” មានន័យថា “ទឹកដីមាស” ប៉ុន្តែតាមមើលទៅពួកអ្នកស្រុក ប្រហែលបានដាក់ឈ្មោះឲ្យផ្សេង តែយើងមិនបានស្គាល់ ។

ពួកអ្នកស្រុកដើមនៅសម័យដែលពួកកលិង្គ ឬកលិង្គនៈ មកបង្កើតអាណាចក្ររមញ្ញទេសៈ ឡើងនោះ គឺពួកការេន ដែលមានការចាត់តាំង មានមេដឹកនាំរួចហើយ ប៉ុន្តែមិនទាន់មានអារ្យធម៌ជឿនលឿនដូចពួក ពិលូ ឬពាលៈ នៅតាមឆ្នេរសមុទ្រតេណាសេរីមនៅឡើយទេ ។ ពួកនេះសព្វថ្ងៃនៅមានរស់នៅរាយប៉ាយពាសពេញប្រទេសភូមាភាគខាងក្រោម ត្រង់ម្ដុំប៉េហ្គូ និងនៅភូមាភាគខាងលើ ត្រង់អវៈ[១៧] ។ ពួកគេរស់តាមភូមិតូចៗនៅជនបទឆ្ងាយពីទីក្រុង មានទំនៀមទម្លាប់ខុសប្លែកពីពួកអ្នកដែលមកត្រួតត្រាពីលើគេ ។ គេមានភាសានិយាយខុសៗគ្នា គឺនៅអវៈ និយាយខុសពីនៅប៉េហ្គូ ក៏ដូចជាភាសាអ្នកប៉េហ្គូខុសពីភាសាពួកភូមា ភាសាពួកការេន ខាងជើងខុសពីពួកការេនខាងត្បូង ។

ពួកនិគមជនកលិង្គដែលមកដល់មុនគេបានពង្រាយខ្លួនទៅទិសខាងជើង រហូតទៅដល់មាត់ពាមទន្លេសាលូអង់ រួចបានកសាងរាជធានីមួយនៅទីនោះ ដាក់ឈ្មោះថា ថាលុន ដែលយើងហៅសព្វថ្ងៃថា តាលិង្គ ។ ការដែលពួកគេមានរាជធានីតាំងនៅឆ្ងាយទៅខាងជើងយ៉ាងនេះ ជាការបញ្ជាក់ថា ពួកគេប្រាកដជាបានរាតអំណាចទៅឆ្ងាយរហូតដល់កន្លែងដែលយើងហៅថា ភូមាខាងក្រោម បច្ចុប្បន្ន ។ ការបង្កើតរាជធានីនេះ ប្រហែលជាកើតមានឡើងនៅដើមគ្រិស្តសករាជ គឺដំណាលគ្នានឹងការបង្កើតរាជធានីតាមូ នៅហ្វូណន ដែរ ។

ក្រោយមក នៅសតវត្សរ៍ទី៦ គេនិយាយថា មានស្ដេចមននៅថាលុន ឬតាលិង្គ មួយអង្គបានទាំរាជបរិពារ

---

[១៧] រាជធានីរបស់ស្រុកដែលចំណុះស្ដេចអវៈ នេះ មានឈ្មោះដំបូងថា មឿងកាំ ។

ធ្វើដំណើរទៅទិសខាងជើង ហើយបានកសាងរាជធានីប៉េហ្គូ នៅក្នុងស្រុកវូកាម ដែលតាមមើលទៅគឺជាទឹកដីមួយកន្លែងរបស់កុលសម្ព័ន្ធការេន ត្រង់ប៉េគូសព្វថ្ងៃ រួចទ្រង់បានដាក់ឈ្មោះឲ្យថា ហង្សាវតី ។ រាជធានីនោះ អ្នកស្រុកឥណ្ឌូចិនក្រោយមកហៅថា ប៉េហ្គូ ឬបាគូ តែពួកអឺរ៉ុបហៅថា ប៉េហ្គាន ។

នៅក្នុងសម័យដែលពួកកលិង្គកសាងរាជធានីថាលុន មានប្រជាជនមួយក្រុមទៀត ចេញមកពីព្រំប្រទល់ទីបេ ឬក៏មកពីទីបេតែម្តងក៏មិនដឹង បានមកដណ្តើមយកទឹកដីដែលយើងសព្វថ្ងៃហៅថាភូមាភាគខាងលើ រួចហើយបានធ្វើដំណើរចុះមកត្បូងបន្តិចម្តងៗ តាមអាងទន្លេឥរាវតីនៃទឹកដីសុវណ្ណភូមិ ។ ពួកអ្នកមកដល់ថ្មីនេះ បានប្រកាន់ខ្លួនថា ជាជាតិសាសន៍ខ្ពង់ខ្ពស់ជាងគេ ហើយបានដាក់ឈ្មោះខ្លួនឯងថា មរម្មៈ ឬម្រម្មៈ ឬម្យម្មៈ ដែលប្រទាំគ្នានឹងពាក្យព្រាហ្មណ៍ដែរ តែពួកអ្នកស្រុកដើមហៅពួកនេះថា កូឡា មានន័យថាបរទេស ។ តាមពិត ពួកនេះមានស្បែកសជាងពួកមនបន្តិចមែន ប៉ុន្តែពួកនេះ បានមកដល់ទឹកដីសុវណ្ណភូមិប្រហែលជា ២សតវត្សរ៍ក្រោយពួកមនប៉ុណ្ណោះ ហើយគ្មានអ្វីជាថ្លៃថ្នូរជាងប៉ុន្មានទេ ព្រោះគេមានដើមកំណើតចេញពីស្រុកមួយ ដែលទទួលអារ្យធម៌មួយចំណែកពីឥណ្ឌា និងមួយចំណែកទៀតពីប្រទេសចិន ។

ដោយមានមោទនភាពនឹងជ័យជម្នះដំបូងៗ និងផាយៗរបស់ខ្លួន ពួកប៊ីរម៉ាន ហាក់ដូចជាបានធ្វើដំណើរចុះមកក្រោមបន្តទៀត រហូតមកដល់ព្រុម ជាភាសាសំស្ក្រឹតគឺស្រីក្សេត្រៈ ហើយបានកសាងរាជធានីទី២ មួយទៀតមានឈ្មោះថា ព្រូ ។ ឈ្មោះនេះក្រោយមកក្លាយមកជា ព្រំ, ជាព្រំមៈ ដែលពួកភូមាហៅថា ព្រហ្មុន ហើយពួកអឺរ៉ុបថា ប្រាក់ម៉ាន, រួចប៊ីរម៉ាន ។ ចំណែកពួកចិនវិញ ដែលមិនអាចអានអក្សរ “រ” បានហៅថា ភ្យូ ឬភាវ រហូតចាប់ពីសតវត្សរ៍ទី៧មកដល់សតវត្សរ៍ទី១២ ។

តើក្រោយពីកសាងរាជធានីទី២នេះរួច ពួកប៊ីរម៉ានបានប៉ះពារជាមួយពួកមន ហើយត្រូវបង្ខំឲ្យធ្វើដំណើរទៅជើងវិញ ឬយ៉ាងដូចម្តេច ? ត្រង់នេះគេមិនបានដឹងដូចម្តេចទេ តែអ្វីដែលប្រាកដនោះគឺថា នៅពេលដែលពួកមន កំពុងដណ្តើមយកទឹកដីភូមាភាគខាងក្រោមនៅសតវត្សរ៍ទី៥ ពួកប៊ីរម៉ានបានកសាងរាជធានីនៅប៉ាកានដែលមានឈ្មោះក្រោយមកថា តាហ្កុង[១៨] រួចបានបោះបង់រាជធានីនោះមកតាំងនៅឯមៀនវិញ ។ គឺដោយមានរាជធានីទី៤នៅមៀននេះឯង ទើបបានជាជួនកាលគេឃើញ ពួកចិនហៅពួកប៊ីរម៉ានថា ពួកមៀនៗ ដូច្នេះ ។

ចំពោះពួកខ្មែរវិញ គេមិនដឹងថាតើចាប់ពីពេលណាមកទេដែលគេហៅពួកប៊ីរម៉ាននេះថា កូឡា និងភូមា ដោយមិនបានដឹងផងទេអំពីអត្ថន័យរបស់ពាក្យទាំងពីរម៉ាត់នេះ ។ ពាក្យកូឡា អាចមកពី “កុឡា” មានន័យថា ថ្លៃថ្នូរ ឬមកពីពាក្យ “កូឡា” មានន័យថា បរទេស ។ ប៉ុន្តែពាក្យនេះ ពួកប៊ីរម៉ានខ្លួនឯងនិយាយថា មិនមែនជាឈ្មោះរបស់ខ្លួនទេ ហើយពួកដែលបានមកធ្វើពាណិជ្ជកម្មនៅតាមមាត់ទន្លេមេគង្គនិយាយថា មានតែពួកខ្មែរ និងលាវប៉ុណ្ណោះ

[១៨] រាជធានីបុរាណនេះសព្វថ្ងៃនៅមាននៅឡើយ តែគ្រាន់តែជាទីក្រុងតូចមួយប៉ុណ្ណោះ ។

ដែលហៅខ្ជួនយ៉ាងនេះ ។ ចំណែកឯពាក្យភូមាវិញ ខ្ញុំគិតថាក្លាយមកពីពាក្យសុវណ្ណភូមិ ៈ គេអាចចាំបាន តែពាក្យខាងចុងថា ភូមី យូរៗទៅក៏ក្លាយទៅជា ភូមា[១៩] ។ តែខ្ញុំបានប្រទះឃើញម្ដងដែលគេសរសេរថាភូមិមាស ។

ពួកបឺរម៉ាននេះមិនមែនមានតែពួកមន ឬប៉េហ្គូ និងពួកកុលសម្ព័ន្ធអ្នកស្រុកដើមជាសត្រូវប៉ុណ្ណោះទេ ។ នៅខាងជើងឆ្ងាយឯណោះមានពួកណាន់ឆាវឬថៃ ដែលមានប្រភពដើមជាពួកហិណ្ឌូដែរ បានមកតាំងទីលំនៅនៅចន្លោះទីបេ និងស្រុកចិនតាំងពីយូរយារណាស់មកហើយ ។ ពួកណាន់ឆាវនេះ ដែលទើបតែរួបរួមគ្នាជារាជាណាចក្រតែមួយ បានវាយប្រហារទៅលើចិនដណ្ដើមយកទឹកដីយុនណាន ហើយកំពុងតែមានកម្លាំងរុលចុះមកទិសខាងត្បូង ។ ពួកណាន់ឆាវ ប្រហែលជាធ្លាប់បានឈ្លានពានស្រុកភូមាជាច្រើនលើកច្រើនសានៅសតវត្សរ៍ទី៨ និងទី៩ ហើយបានយកស្រុកនេះដាក់ជាចំណុះយ៉ាងយូរទៀតផង ។ ពួកចិនហៅក្សត្រប្រទេសថៃនៅយុនណានថា ណាន់ឆាវ តែពួកបឺរម៉ាន ហៅពួកណាន់ឆាវនេះព្រមទាំងពួកចិនផងថា តារ៉ុប, តារ៉ុក ឬតារិក ហើយត្រូវពួកចិន និងពួកថៃយុនណាន ហៅវិញថា មៀនៗ តាមឈ្មោះរាជធានីទី៤របស់គេ ។

តាមមើលទៅ គឺប្រហែលជានៅពេលដែលពួកថៃកំពុងត្រួតត្រាលើទឹកដីភូមាភាគខាងលើនេះឯង ដែលពួកនេះលូកដៃចូលក្នុងបញ្ហាផ្ទៃក្នុងរបស់អ្នកស្រុកនៅក្នុងអាងទន្លេមេណាមខាងលើ ដើម្បីជួយពួកអ្នកស្រុកនេះឲ្យប្រឆាំងនឹងកម្ពុជា រួចហើយក៏ចាប់ផ្ដើមចុះមកតាំងទីលំនៅ នៅក្នុងអាងទន្លេមេណាមនេះ នៅក្នុងសតវត្សរ៍ទី១០ ដោយកសាងរាជធានីហរិបុន្យគ្យៈ (ហរិបុន្យនគរ) គឺលំពូនសព្វថ្ងៃ និងរាជធានីសុខោទ័យ ។ នៅពេលជាមួយគ្នានោះដែរ មានពួកថៃឯទៀតៗចូលមករស់នៅក្នុងទឹកដីលាវ ហើយដណ្ដើមយករាជធានីវៀងច័ន្ទ ។ ស្រុកលាវពេលនោះ ស្ថិតនៅក្រោមការត្រួតត្រារបស់កម្ពុជា ។

នៅខាងត្បូងឯណោះវិញ ការកសាងរាជធានីប៉េហ្គូ ដោយពួកមននៅសតវត្សរ៍ទី៦ ជាការបញ្ជាក់ថាពួកនេះ បានដណ្ដើមយកពាមទន្លេឥរាវតី បានហើយ ហើយបានរុញច្រានពួកបឺរម៉ាន ឲ្យធ្វើដំណើរឡើងទៅទិសខាងជើង ទៅជួបជាមួយពួកណាន់ឆាវ ។

អ្វីដែលពិត គឺពួកបឺរម៉ាននេះ ត្រូវប្រឈមមុខនឹងពួកណាន់ឆាវ ចាប់ពីសតវត្សរ៍បន្ទាប់មក ហើយក៏ត្រូវធ្វើសង្គ្រាមទប់ទល់នឹងពួកប៉េហ្គូនៅខាងត្បូងផងដែរ រហូតដល់ពេលមួយក្រោយមក ដែលពួកណាន់ឆាវឆ្លងកាត់ព្រំដែន ទៅដណ្ដើមយកអាងទន្លេមេណាមខាងលើទាំងមូល ។ ពេលនោះពួកបឺរម៉ាន និងពួកប៉េហ្គូ ច្បាំងគ្នាឥត

---

[១៩] មានសាស្ត្រាខ្មែរមួយបាននិយាយអំពីស្ដេចមួយអង្គ ដែលមានព្រះនាមថា ភូមា តែសាស្ត្រាខ្លះទៀតថា ភូមី មានន័យថា ម្ចាស់ទឹកដី ។ ហេតុការណ៍នេះធ្វើឲ្យខ្ញុំមានចម្ងល់ជាខ្លាំង មិនដឹងថាតើពាក្យនេះមានន័យដូចម្ដេច ឬក៏ក្លាយមកពីពាក្យណាមួយម៉ាត់ ដែលខ្ញុំមិនអាចស្មានបាន ។

ឈប់ឈរ រហូតដល់ពេលពួកអឺរ៉ុបមកដល់ ធ្វើជាអាជ្ញាកណ្តាលបែងចែកទឹកដីទើបស្ងប់ ។

អ្វីដែលគេអាចដឹងបានសម្រាប់រយៈកាលមុនសតវត្សរ៍ទី១១ គឺថា ព្រុម (ស្រីក្សេត្រៈ) ជារាជធានីតាំងពីសតវត្សរ៍ទី៧មក តែគេមិនដឹងថាជារាជធានីរបស់អ្នកណា តើជារបស់ពួកតាលិង្គ (ក្រោយមកក្លាយជាពួកប៉េហ្គូន) ឬជារបស់ពួកម្រម្មៈ (ក្រោយមកក្លាយជាពួកប៊ីរម៉ាន) ។ រឿងនេះថាតិចតួចក៏បាន ប៉ុន្តែក៏ជាចំណុចគួរកត់សម្គាល់មួយដែរ គឺរាជធានីព្រុមមានវត្តមានក្នុងសម័យដែលវង្សវរ្ម័នសោយរាជ្យនៅវយធបុរៈ ដែលមានប្រាសាទបាក់បែកសល់ដល់សព្វថ្ងៃនៅខាងត្បូងបាទី ក្នុងស្រុកព្រៃកប្បាស ។

នៅក្នុងសតវត្សរ៍ទី១១ រាជាណាចក្រប៉េហានបានត្រូវពួកប៊ីរម៉ាន វាយយកដាក់ជាចំណុះ ពួកនេះបានតាំងរាជធានីនៅដាឡា (គឺរ៉ង់ហ្គូន) នៅទីងមាត់ពាមទន្លេឥរាវតី ។ រាជធានីសំខាន់ៗផ្សេងទៀតនាពេលនោះមានម៉ាតាបាន និងបាសាំង ដែលស្ថិតនៅលើដៃទន្លេមួយនៃដីសណ្តឥរាវតី ។

នៅរាជធានីចាស់ គឺប៉ាកាន ឬអរិម្មទនៈ ឯណោះវិញ គេឃើញមានរូបសំណាករបស់ព្រះរាជាប៊ីរម៉ានចំនួន ៥១អង្គ ហើយចាប់តាំងពីពេលដែលពួកនេះចុះមកតាំងទីនៅខាងត្បូងប្រទេសនៅសតវត្សរ៍ទី១៣ គេនិយាយថាមានស្តេចឆ្នើមៗជាច្រើនអង្គ ជាអាទិ គឺព្រះបាទខហ្សាម ឡើងសោយរាជ្យនៅឆ្នាំ១២៥០ រួចត្រូវដើរព្រេចសុគតនៅឆ្នាំ១២៨៣ ។ អស់ពីព្រះអង្គទៅ ព្រះបាទនរស្តបតិ ជារាជបុត្ររបស់ព្រះអង្គជាមួយបុត្រីជាងក្រឡឹងម្នាក់ បានឡើងសោយរាជ្យបន្ត ក្រោយពីរាជបុត្រស្របច្បាប់ព្រះនាមថា សីហៈសុរៈ ត្រូវពួកមន្ត្រីធ្វើគុត ។

ព្រះរាជាអង្គនេះជាយក្សកាលពីជាតិមុន ម្ល៉ោះហើយកាចសាហាវ ឆាប់ខឹង ក្រអឺតក្រទម ល្មោភសុី ប្រមឹក ហើយចូលចិត្តសោយសាច់ ។ រាជពង្សាវតាររៀបរាប់ម្យ៉ាងទៀតថា ទ្រង់ក៏ល្មោភកាមណាស់ដែរ មានមហេសី ៣០០០នាក់ នៅក្នុងព្រះរាជវាំង ក្នុងនោះមានព្រះរាជអគ្គមហេសីទី១មួយអង្គ និងទី២ប្រាំអង្គ ។ ព្រះអង្គបានបញ្ជាឲ្យព្រះរាជបុត្រមួយអង្គចាប់ខ្លួនព្រះរាជបុត្រមួយអង្គទៀត តែព្រះរាជបុត្រទី២នេះ បានរត់គេចខ្លួនរួចហើយក៏បះបោរប្រឆាំងនឹងព្រះអង្គ និងចាប់ព្រះអង្គជាឈ្លើយនៅក្នុងឆ្នាំ១២៨៦ ។ នៅទីបញ្ចប់ ព្រះរាជាក៏ត្រូវព្រះរាជបុត្រនោះដាក់ថ្នាំបំពុលឲ្យសុគតទៅនៅឆ្នាំ១២៨៨ ។

ព្រះរាជបុត្រដែលបះបោរប្រឆាំងនោះគឺព្រះបាទសីហៈសុរា ជាព្រះអង្គម្ចាស់លើរាជធានីព្រុម ក៏ឡើងសោយរាជ្យបន្តមក តែត្រូវសុគតនឹងព្រួញរបស់ព្រះអង្គឯង ក្នុងពេលធ្វើសង្គ្រាមជាមួយព្រះអង្គម្ចាស់នៃរាជធានីដាឡាជាព្រះអនុជ នៅក្នុងឆ្នាំ១២៨៨ ដដែលនោះ ។

ព្រះអនុជមួយអង្គទៀតព្រះនាមថាក្យស្វៈ បានឡើងសោយរាជ្យបន្តមក ។ ព្រះរាជាថ្មីនេះ មានលក្ខណៈសម្បត្តិពិសេស គឺឆ្លាតវៃ គោរពកុសលធម៌ ភក្តីនឹងសាសនា ហើយមានគតិបណ្ឌិត ។ ទ្រង់បានចាត់ទុកប្រជានុរាស្ត្រ និងអ្នកកាន់សាសនាដូចគ្នាជា “សាច់ព្រះកាយផ្ទាល់” ក៏ប៉ុន្តែវាហាក់ដូចជាថា ព្រះអង្គមិនមានទេពកោសល្យក្នុងការធ្វើនយោបាយទេ ពីព្រោះព្រះអង្គគ្មានលទ្ធភាពក្នុងការរក្សាទឹកដីដែលព្រះបិតាបានកសាងទុកមក

បណ្តោយឲ្យរបេះខែត្រអស់មួងមួយៗ ។ ព្រះអង្គបានត្រូវព្រះអនុជ៣អង្គមានដើមកំណើតមកពីនគរសាន ដែលព្រះអង្គបានយកមកនៅក្នុងព្រះរាជវាំង និងព្រះអគ្គមហេសីទី២ដែលជាមនុស្សពិសេសមួយអង្គ តែព្រះអង្គមិនដែលបានសាកសួរយោបល់ក្នុងព្រះរាជកិច្ច ទម្លាក់ពីរាជបល្ល័ង្កនៅក្នុងឆ្នាំ១២៩៨ ចាប់កោរព្រះកេសារួចហើយដាក់ឲ្យបួសនៅក្នុងវត្តអារាមមួយ ។ ព្រះរាជបុត្ររបស់ព្រះអង្គព្រះនាមថា សូនីត បានឡើងសោយរាជ្យបន្តមក ដោយប្រកាន់យកព្រះឋានៈដ៏អធិកអធមដូចព្រះរាជាខ្មែរនៅសតវត្សរ៍ទី១៦ដែរថា សិរិត្រីភវនទិត្យៈបវរធម្មរាជា ។ ព្រះរាជាអង្គនេះ សោយរាជ្យបាន២៧ឆ្នាំ ហើយសុគតនៅឆ្នាំ១៣២៦ ។

បន្ទាប់មក គឺព្រះរាជបុត្រព្រះនាមថា សូមុនីត បានសោយរាជ្យបន្តរហូតដល់ពេលដែលទ្រង់សុគតនៅឆ្នាំ១៣៦៨ ។

នៅក្នុងអំឡុងពេលនេះ ប្រទេសចិនបានលុកលុយប្រទេសភូមាម្តងនៅក្នុងឆ្នាំ១២៧៧ ហើយវាយពួកប៊ីរម៉ាន ឲ្យបរាជ័យយ៉ាងខ្លាំងនៅម៉ុងទី (ណានទៀន) ។ បន្ទាប់មក ពួកចិនបានវាយយកភមោ ក៏ប៉ុន្តែត្រូវដកថយទៅវិញនៅឆ្នាំបន្ទាប់ ក្រោយពីមិនអាចដណ្តើមយកប៉ាកានបាន ។ នេះគឺជាការឈ្លានពានលើកទី១របស់ចិន ។

នៅឆ្នាំ១២៨១ ចិនឈ្លានពានភូមាម្តងទៀត ក្រោយពីទាមទារឲ្យភូមាប្រគល់ដំរីស និងសួយសារអាករផ្សេងៗទៅថ្វាយ ក្នុងនាមជាព្រះចៅអធិរាជ មិនបាន ។ ក្រោយពីដណ្តើមយកភមោបានរួចមក ទ័ពចិនបានវាយយក ង៉សោងក្យាំ “រាជធានីនៅក្បាលទន្លេ” ដែលនៅចម្ងាយតែប៉ុន្មានគីឡូម៉ែត្រប៉ុណ្ណោះខាងទិសអាគ្នេយ៍ ។ នៅពេលនោះ ព្រះបាទនរសូបតិបានចាត់ឲ្យគេធ្វើកំផែងការពាររាជធានីប៉ាកានយ៉ាងរឹងមាំ ប៉ុន្តែដោយនៅតែមិនទុកព្រះទ័យ ទ្រង់ក៏បានភៀសព្រះកាយទៅនៅឯបាសាំង ហើយត្រូវទ័ពចិនដេញតាមរហូតដល់ព្រុម តែមិនហ៊ានតាមទៅឆ្ងាយទេ ។ ការឈ្លានពានលើកទី២របស់ចិននេះ អ្នកស្រុកនៅមានចងចាំនៅឡើយ ។

ការឈ្លានពានរបស់ចិនលើកទី៣កើតមានឡើងនៅក្នុងរាជ្យព្រះបាទសូនីត ដើម្បីលើកព្រះបាទក្យូស្វៈឲ្យឡើងសោយរាជ្យវិញ ។ ក៏ប៉ុន្តែដោយទ្រង់ជាកម្មវត្ថុនៃសង្គ្រាម ព្រះអនុជ៣អង្គរបស់ព្រះអង្គក៏បានធ្វើគុតព្រះអង្គរួចកាត់យកព្រះកេសផ្ញើជូនឧត្តមសេនីយ៍ចិន ព្រមជាមួយនឹងវត្ថុអនុស្សាវរីយ៍ជាច្រើនទៀត ។ មេទ័ពចិនក៏វិលត្រលប់ទៅស្រុកវិញបាត់ទៅ ។ ការលុកលុយរបស់ចិនលើកទី៣នេះមិនបានទៅឆ្ងាយហួសពីម្យិនដាំងរាជធានីរបស់ភូមាភាគខាងជើងទេ ។ ពេលនោះ ប្រហែលជាពួកប៉េហ្គាន បានកសាងអាណាចក្រឡើងវិញនៅខាងត្បូងរួចហើយ ។

នៅសម័យពេលដែលយើងរៀបរាប់មកដល់នេះ មានប្រជាជនពីរជាសត្រូវនឹងគ្នានៅភូមា គឺមួយនៅខាងជើង មួយទៀតនៅខាងត្បូង ប្រជាជនទាំងពីរនេះប៉ះទង្គិចច្បាំងរុញគ្នាទៅវិញទៅមកដណ្តើមទឹកដីសុវណ្ណភូមិ ។ រាល់ពេល អ្នកដែលឈ្នះតែងតែបន្តសង្គ្រាមទៅលើពួកថៃ ដូចៗគ្នា ។ ដូច្នេះ ពួកប៉េហ្គាន និងពួកប៊ីរម៉ាន ដែលជាសត្រូវនឹងគ្នា មានសត្រូវសួពូជរួមគ្នាគឺពួកថៃ ហើយគំនុំរួមនេះឯងបង្កើតបានជាមនោសញ្ចេតនាជាតិរួមមួយ

ដែលធ្វើឲ្យគេរួបរួមគ្នាបាននៅពេលណាមានសន្តិភាពនឹងគ្នា បើហោចណាស់ក៏មួយដងមួយកាលដែរ កាលណាគេមានគោលបំណងរួមគ្នាតែមួយ ជាពិសេសក្នុងការស្តារ និងកសាងប្រទេសឡើងវិញ បើទោះជាថា ទំនាស់បានបន្សល់នូវការខូចខាតជាច្រើន ក៏ដោយ ។ ព្រះរាជាទឹកដីសុវណ្ណភូមិអង្គណាក៏ដោយ មិនថាទ្រង់មានឈោមដ័រជាអ្វីទេ គឺសុទ្ធតែជាសត្រូវនឹងពួកថៃ ឬសៀម ទាំងអស់ ហើយតែងតែធ្វើសង្គ្រាមជាមួយពួកថៃនេះជានិច្ច មិនដែលមានស្តេចអង្គណា ដែលស្រែករត់រកជំនួយពីថៃម្តងណាទេ[២០] ។

## ៥- ប្រទេសម៉ាឡេស៊ី

ពាក្យថា ម៉ាឡេស៊ី ដែលខ្ញុំប្រើនេះ សំដៅយកបណ្តាស្រុកទាំងអស់ដែលមានពួកម៉ាឡេ ឬអ្នកស្រុកដែលស្ថិតនៅក្រោមការត្រួតត្រារបស់ពួកម៉ាឡេរស់នៅ ហើយនៅពេលនេះ ខ្ញុំនឹងលើកតែអំពីឥទ្ធិពលដែលពួកនេះមានមកលើឥណ្ឌូចិនប៉ុណ្ណោះ ។ ទឹកដីម៉ាឡេស៊ីរួមមាន កោះស៊ូម៉ាត្រាដែលជាប្រភពដើមរបស់ពួកម៉ាឡេ, កោះជ្វាជាកោះដែលពួកនេះដណ្តើមបានមុនគេ, កោះតូចៗដែលនៅជុំវិញឧបទ្វីបប៊័រណេអូ ហើយនិងឧបទ្វីបកោះម៉ាឡាកាដែលពួកក្រិច និងឡាតាំងស្គាល់ក្រោមឈ្មោះថា ឈែសូណែសមាស ។ ខ្ញុំមិនបានរាប់បញ្ចូលផងទេនូវពួកចាមដែលជាបច្ចាញាតិរបស់ពួកនេះ ហើយដែលខ្ញុំបានរៀបរាប់ហើយពីខាងលើរួចមកហើយ ។

យើងគ្មានពត៌មានអំពីទឹកដីទាំងអស់នេះកាលពីសម័យបុរាណទេ ។ មានតែពួកចិនប៉ុណ្ណោះ ដែលបានសរសេរពត៌មានខ្លះៗអំពីស្រុកនេះមុនគេ ក្រៅពីនេះយើងស្ទើរតែមិនដឹងអ្វីទាល់តែសោះមុនសតវត្សរ៍ទី១៣ ។ តែពត៌មានរបស់ពួកចិននោះទៀតសោតក៏ចម្លែកខ្លាំងណាស់ដែរ ព្រោះឈ្មោះដែលគេដាក់ឲ្យតាមអក្សរចិនភាគច្រើន មិនអាចកំណត់រកឃើញ មិនដឹងស្រុកណាជាស្រុកណាទេ ។ ការសិក្សាដែលអ្នកប្រាជ្ញមួយចំនួនបានធ្វើ ជាពិសេស លើស្រុកនេះក៏មិនច្បាស់ សម្មតិកម្មដែលពីមុនគេទទួលស្គាល់ថាត្រឹមត្រូវ ឥឡូវនេះបែរជាថាខុសទៅវិញ ។ ខ្ញុំនឹងខិតខំលើកយកមកនិយាយនៅពេលនេះតែអំពីអ្វីដែលប្រាកដប្រជា ដើម្បីបង្ហាញឲ្យឃើញថា ពិភពម៉ាឡេនោះដូចម្តេច ហេតុអ្វីក៏គ្មានអ្វីឲ្យរឹងមាំ អ្នកស្រុកជាពួកចោរសមុទ្រ ប៉ុន្តែមានតួនាទីមួយសំខាន់នៅក្នុងប្រវត្តិសាស្ត្ររបស់ឥណ្ឌូចិន បើនិយាយអំពីឥណ្ឌូចិនត្រូវតែនិយាយអំពីពួកនេះផងដែរ ។

កោះស៊ូម៉ាត្រាមានឈ្មោះដូច្នេះដោយសាររាជធានីដែលមានឈ្មោះ សមុទ្រៈ ។ ពីមុនគេហៅថា កោះជ្វាធំ

[២០] សព្វថ្ងៃនេះ ពួកប៉េហ្គានបានត្រូវគេកម្ទេច បំបាក់ខ្ទេចខ្ទី ឬក៏រលាយចូលជាមួយពួកប៊ីរម៉ានអស់ហើយ អ្នកដែលនៅសល់រស់របៀបជាជនបរទេសនៅលើទឹកដីរបស់ខ្លួន ឬជាក្រុមជនគ្មានសារសំខាន់ លើកលែងតែពួកដែលបានភៀសខ្លួនមកនៅស្រុកសៀមមានប្រមាណជា១០ម៉ឺននាក់ប៉ុណ្ណោះ ។

ឯកោះជ្វាសព្វថ្ងៃជាជ្វាតូច ។ ពួកហិណ្ឌូហៅថាជ្វាទ្វីប ដែលខ្ញុំគិតថាជាឈ្មោះចាស់ជាងគេទាំងអស់ ។ តែអ្នកស្រុកម៉ាឡេខ្លួនឯង និងអ្នកស្រុកជិតខាងបានហៅកោះនេះថា តាណាសម៉ាឡាយូ មានន័យថា ទឹកដីពួកម៉ាឡេ ។ ប្រាកដណាស់ថា កោះទាំងអស់នេះគ្មានឈ្មោះអ្វីឲ្យច្បាស់លាស់ទេកាលពីសម័យបុរេប្រវត្តិ ព្រោះដូចខ្ញុំបានជម្រាបពីខាងលើរួចមកហើយ គេឲ្យឈ្មោះស្រុកមួយទៅតាមតែរាជាណាចក្រដែលបានកកើតឡើងប៉ុណ្ណោះ ។ ជួនកាលវាអាចនឹងថា ការដែលគេហៅថាជ្វាធំ និងជ្វាតូចយ៉ាងនេះ គឺអាស្រ័យទៅតាមឈ្មោះរាជាណាចក្រដែលខ្លាំងជាងគេ អាចវាតអំណាចទៅលើរាជាណាចក្រឯទៀតៗបាន ប៉ុន្តែនិយាយដូច្នេះវាហាក់ដូចជាទូលំទូលាយពេក ។

គេទទួលស្គាល់ថា កោះជ្វាធំ ឬស៊ូម៉ាត្រា ជាស្រុកដើមរបស់ពួកម៉ាឡេ ឬម៉ាឡាយូ ។ គេនិយាយថា ពួកម៉ាឡេ បានចេញពីកោះនេះទៅដណ្ដើមយកកោះជ្វា រួចយកប្រជុំកោះសេឡែប និងឧបទ្វីបម៉ាឡាកា ជាទីដែលគេបានជួបជាមួយវិប្រជាមានជាតិសាសន៍ប្រហាក់ប្រហែលនឹងគេ គឺពួកមន ហើយបន្ទាប់មកបានជួបជាមួយអ្នកស្រុកដើមជាអ្នកសាងនគរហ្វូណន ដែលក្រោយមកក្លាយជាកម្ពុជា និងសៀម ។

ពួកម៉ាឡេបានតាំងទីលំនៅ នៅគ្រប់ទិសទី ហើយបើសិនជាខ្ញុំមិនច្រឡំទេ គឺនៅពេលក្រោយពីការតាំងទីលំនៅនេះរួចហើយ ដែលពួកនេះបានបោះបង់ចោលការគោរពបូជាដុំថ្ម និងជីដូនជីតា បែរមកកាន់ព្រហ្មញ្ញសាសនាវិញ ដែលជាសាសនាមួយគោរពបូជាអាទិទេពតំណាងដោយរូបបដិមា នៅរវាងឆ្នាំ៧០នៃគ្រិស្តសករាជ នៅពេលដែលមានពួកឥណ្ឌាប្រមាណ២ម៉ឺនគ្រួសារមករស់នៅលាយឡំជាមួយនឹងពួកគេ ។ ដោយមានទំនាក់ទំនងជាប់ជាមួយបណ្ដាទឹកដីចំណុះរបស់គេ ពួកជ្វាព្រាហ្មណ៍ទាំងនោះក៏តាំងនាំយកជំនឿថ្មីនេះមកផ្សព្វផ្សាយដែរ ដូចដែលបច្ចាញាតិរបស់គេនឹងធ្វើនៅ១២សតវត្សរ៍ក្រោយមក ពេលផ្សព្វផ្សាយច្បាប់មហាម៉ាត់ ។ តាមមើលទៅពួកម៉ាឡេ ចាប់កាន់ព្រហ្មញ្ញសាសនានៅក្នុងសម័យតែមួយដូចគ្នា ។

ដោយបានរក្សាទំនាក់ទំនងជាប្រចាំជាមួយឥណ្ឌាភាគខាងត្បូង ជាទីកន្លែងដែលព្រហ្មញ្ញសាសនាមានការរីកចម្រើនខ្លាំងជាងភាគខាងជើង ពួកម៉ាឡេមានជំនឿសាសនាមុតមាំណាស់ ។ ជាក់ស្ដែងដូចជានៅនគរចាម្ប៉ា ដែលជាអាណានិគមម៉ាឡេមួយដែរនោះ គេឃើញថាពួកស្ត្រីៗតែងតែលោតចូលក្នុងភ្លើងដែលគេបូជាស្វាមី ដើម្បីសំដែងភក្ដីភាព ព្រមជាមួយនោះក៏មានទម្លាប់មួយទៀតដែលខ្ញុំគិតថាប្រហែលជាមានដើមកំណើតចេញពីពួកម៉ាឡេវិញ គឺសេនាទាំងឡាយសុខចិត្តបូជាខ្លួននៅក្នុងភ្លើងដែលគេដុតមេកោយ ដែលពួកគេធ្លាប់បម្រើ ។

នគរហ្វូណន នគរចាម្ប៉ា ស្រុកសៀម ហើយនិងឧបទ្វីបម៉ាឡាកា ទាំងអស់គ្នានេះមានទំនៀមទម្លាប់មិនសូវខុសគ្នាទេ ។ ឯកសារប្រវត្តិសាស្ត្ររបស់ចិនក៏បានធ្វើការកត់សម្គាល់ឃើញយ៉ាងនេះដែរ ។ ខ្ញុំគិតថា ទម្លាប់ដែលគេប្រើនៅក្នុងរាជវាំងស្ដេច ពិធីការផ្សេងៗ ការរៀបចំចាត់តាំងរាជវាំង ច្បាប់ទម្លាប់សម្រាប់ប្រជារាស្ត្រអនុវត្ត និងការតុបតែងទាំងឡាយ មានការខុសប្លែកពីគ្នាតិចតួចណាស់ ពីព្រោះថារបៀបរបបទាំងអស់នោះគេចម្លងចេញពីឥណ្ឌាទាំងអស់គ្នា ហើយម្នាក់ៗដែលកាន់ព្រហ្មញ្ញសាសនាដូចគ្នា ខិតខំធ្វើគ្រាប់យ៉ាងណាឲ្យបាន

ដូចពួកហិណ្ឌូជាម្ចាស់ដើមនៃសាសនា ។ ដូចដែលគេបានឃើញពីខាងលើរួចមកហើយថា ពាក្យវរ្ម័ន មានន័យថា អ្នកការពារ ដែលគេប្រើភ្ជាប់ទៅនឹងព្រះនាមព្រះរាជានៅហ្វូណន និងក្រោយមកនៅកម្ពុជា មានដើមកំណើតចេញមកពីឥណ្ឌា ប្រើដូច្នេះដោយសន្តតិវង្សបល្លវៈ និងសន្តតិវង្សមួយចំនួនទៀត ហើយព្រះរាជាចាម្ប៉ា ជ្វា និងស៊ូម៉ាត្រា ក៏បានយកពាក្យនេះមកដាក់លម្អព្រះនាមជាភាសាសំស្ក្រឹត ដែលទ្រង់ទទួលយកនៅថ្ងៃអភិសេកដូចគ្នាដែរ ។

ខ្ញុំសង្កេតឃើញថាទៀបកោះម៉ាឡាកាមិនបានអនុវត្តតាមទម្លាប់នេះទេ ហើយព្រះរាជារបស់គេមិនមានព្រះនាមថាវរ្ម័នដែរ ។ ចំណុចត្រង់នេះ គេគួរគិតថា រហូតមកដល់សតវត្សរ៍ទី១៣ មុនពេលដែលទឹកដីរបស់ទៀបកោះ ទាំងមូលធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់រាជាណាចក្រម៉ាឡាកា នៅឆ្នាំ១២៥២ រួចក្រោយមកនៅក្រោមការគ្រប់គ្រងរបស់ពួកសៀម ទៀបកោះនេះគ្រាន់តែជាស្រុកមួយនៅចំណុះនគរហ្វូណនប៉ុណ្ណោះ ហើយតាមធម្មតាស្តេចចំណុះមិនសមនឹងមានឋានៈស្មើ ស្តេចអធិរាជទេ ។ យើងបានស្គាល់ឈ្មោះស្រុកទាំងអស់នេះ ដោយសារពួកចិនដែលហៅខុសពីឈ្មោះដើម ហើយក៏មិនបានបញ្ជាក់អំពីទីតាំងឲ្យបានច្បាស់លាស់ផងដែរ ជាហេតុធ្វើឲ្យមានការលំបាកនឹងកំណត់ទីតាំងឲ្យបានត្រឹមត្រូវណាស់ ។ ពួកចិនរៀបរាប់ថាមានស្រុកមួយ មានឈ្មោះថា ទួនស៊ីយុន នៅចុងសតវត្សរ៍ទី៥ ដឹកនាំដោយគួនលុន (គូឡុង) ម្នាក់ គឺគរុង, ក្រុង មានន័យថា ស្តេច អ្នកស្រុកមានសក់ក្រញាញ់សម្បុរខ្មៅ ។ ស្រុកផានផាន[២១] ពាក្យនេះអាចជាឋានៈរបស់ព្រះរាជា អ្នកអគ្គម្ចាស់ ឬក៏របស់មន្ត្រី ។ ស្រុកឡាងយ៉ាសៀវ (ប្រហែលគឺគេណាស់សេរីម) និយាយភាសាមនដូចផានផានដែរ ភាសានេះមានអម្បូរជាមួយភាសាខ្មែរ[២២] ។ ស្រុកឡូយែ ដែលអ្នកនិពន្ធចិនម្នាក់និយាយថា នៅខណ្ឌពីស្រុកខ្មែរដោយសមុទ្រតូចមួយ (ឈូងសមុទ្រសៀម) តាមមើលទៅគឺ កេដាហ៍ ។ ស្រុកហ្វូឆេ នៅចុងខាងត្បូងនៃទៀបកោះ តែនៅខាងលើកោះសិង្ហបុរី ។

**កោះស៊ូម៉ាត្រា** ៖ នៅសតវត្សរ៍ទី៥ នៃគ្រិស្តសករាជ គេស្គាល់កោះនេះតាមឈ្មោះម៉ាឡេថា គាណាសម៉ាឡាយូ មានន័យថា ទឹកដីពួកម៉ាឡេ ឯឈ្មោះតាមភាសាសំស្ក្រឹតថា ជ្វាទ្វីប ។ នៅពេលក្រោយមក កោះនេះមាន

---

[២១] លោកវរសេនីយ៍ ហេរ្សរីនី គិតថា ទួនស៊ីយុន ប្រហែលជាស្ថិតនៅចន្លោះម៉ាតាបាន និងសុខោទ័យ ហើយថា ផានផាន នៅខាងលើទួនស៊ីយុន ចន្លោះភ្នំតាវ៉យ និងទឹកដីអយុធ្យា ។ ការប៉ាន់ស្មានដូច្នេះអាចត្រឹមត្រូវ ក៏ប៉ុន្តែបើយ៉ាងនេះរាជាណាចក្រទាំង២ និងឡាងយ៉ាសៀវ មិនស្ថិតនៅក្នុងទៀបកោះម៉ាឡាកាទេ ។

[២២] លោក ពែលីយ៉ូ បានពន្យល់ថា ពួកមន និងពួកខ្មែរនេះបានត្រូវបែកគ្នាដោយសារការហូរចុះមកនៃពួកថៃ ដែលធ្វើឲ្យពួកគេដាច់ទំនាក់ទំនងជាមួយគ្នា ។ សូមអានឯកសារ របស់គាត់មានឈ្មោះថា Deux itinéraires de Chine en Inde ដែលចុះនៅក្នុងព្រឹត្តបត្រសាលាបារាំងចុងបូព៌ា ។

ឈ្មោះថា ស្រីភោជៈ ដែលតាមមើលទៅគឺជាឈ្មោះដែលជាគេហៅតាមឈ្មោះរាជាណាចក្រណាមួយ ដែលខ្លាំងពូកែ អាចវាតអំណាចទៅលើនគរជិតខាងបាន ហើយចិនហៅមិនច្បាស់ថាចេលីហ្វូឆេ ។ កោះដ៏ធំនេះមានរដ្ឋទាំងអស់ចំនួន២៩ ។

រដ្ឋដែលធំជាងគេគឺប៉ាលីមបាង ដែលប្រហែលជាមានឈ្មោះថា ស្រីភោជៈ នោះឯង ហើយដែលអ្នកស្រុកក្រៅគិតថា លាតសន្ធឹងលើកោះទាំងមូល ។ រដ្ឋនេះមានតួនាទីសំខាន់ណាស់ កាលពីអតីតកាល[២៣] ។ ស្តេចរបស់នគរនេះបានអះអាងថា គេជាប់ខ្សែស្រឡាយជាមួយព្រះចៅអធិរាជអាឡិចសង់ឡឺក្រង់ ដែលបានទំនាក់ទំនងស្នេហាជា មួយបុត្រីរបស់ស្តេចគឺជាហិណ្ឌីដែលច្បាំងចាញ់ មានរាជបុត្រមួយព្រះអង្គព្រះនាមថាអាស្ហូន ជាព្រះរាជាមួយអង្គមុនគេក្នុងចំណោមព្រះរាជាហិណ្ឌូដែលល្បីល្បាញ ។ ព្រះរាជាដែលល្បីល្បាញជាងគេគឺព្រះបាទស៊ូរែម ។ ស្តេចនេះមានបច្ឆាញាតិមួយអង្គព្រះនាមថាសង់សាពួបា (ឬសេពៃបា) ទ្រង់បានយាងមកគង់នៅសមុទ្រៈ នៅលើភ្នំសាគុនតាងមហាមីរូ ជាភ្នំសក្តិសិទ្ធិរបស់ពួកម៉ាឡេ បន្ទាប់មក បានយាងមកគង់នៅប៉ាលីមបាងវិញ ។ ព្រះអង្គជាមេសន្តតិវង្សនៃរាជាម៉ាឡេទាំងអស់ ដែលសោយរាជ្យនៅប៉ាលីមបាង នៅមេណាងកាបូ ប៉ាហ្គារូយ៉ុង មជប៉ាហីត នៅជ្វា ប៊ិនតាង សិង្ហបុរី ម៉ាឡាកា ហើយបើសិនជាគេជឿតាមរឿងព្រេង ទ្រង់ក៏ជាមេរបស់សន្តតិវង្សចិនមួយថែមទៀត ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះនាងស្រីទេវី ជាបុត្រី របស់ព្រះបាទសង់សាពួបា ។

ស្តេចប៉ាលីមបាងក៏ដូចជាស្តេចម៉ាឡេទាំងឡាយដែរ តែងតែលើករាជវង្សឲ្យសោយរាជ្យនៅនគរនេះ នគរនោះ បើពុំនោះទេលើកក្សត្រីថ្វាយស្តេចនេះ ឬស្តេចនោះ ជានិច្ច ។ ជាក់ស្តែងដូចជាស្តេចមជប៉ាហីត ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះនាងឈន្ទ្រទេវី ជាព្រះអានុជស្តេចស្រុកចិន ហើយមានអាពាហ៍ពិពាហ៍ ជាច្រើនទៀត ដែលរឹតចំណងមេត្រីភាពកើតឡើងហើយនេះ ឲ្យកាន់តែប្រសើរឡើងថែមទៀត ។

មានបច្ឆាញាតិរបស់ស្តេចសង់សាពួបាមួយអង្គ បានកសាងរាជធានីជាច្រើន ។ ព្រះរាជបុត្ររបស់ព្រះអង្គព្រះនាមថា សង់នីឡាអ៊ុតាម៉ា បន្ទាប់ពីសោយរាជ្យនៅបេនតាម បានកសាងរាជធានីសិង្ហបុរៈ នៅឯនគរតា ម៉ាសាក់ ឬធម្មសកៈ ហើយទ្រង់ជាព្រះរាជាទីមួយដែលមានព្រះនាមថា ស្រីត្រីភូវនៈ ។

ពួកចិនដែលបានមកកាន់ប៉ាលីមបាង តាំងពីឆ្នាំ៦៧០ នៃគ្រិស្តសករាជរហូតមក បានចាត់ទុកនគរនេះថាជានគរខ្លាំងពូកែជាងគេទាំងអស់ក្នុងតំបន់នេះ ។ នៅក្នុងឆ្នាំ៧២០ ព្រះរាជាប៉ាលីមបាងមួយអង្គបានយាងកាត់មុខ

---

[២៣] នៅសតវត្សរ៍ទី៦ រដ្ឋនេះមានឈ្មោះថាកណ្ឌរី ហើយនៅសតវត្សរ៍ទី១០ ចិនហៅថាសានហ្វូឡឺ (សំភោជៈ) ។ ពេលធ្លាក់ក្នុងការឈ្លានពានរបស់ពួកជ្វានៅក្នុងឆ្នាំ១៣៩៧ ពួកនេះដាក់ឈ្មោះឲ្យថាគាវក្យង់ (គូកាង) ។ សម័យនោះ ពួកអារ៉ាប់ហៅស្រុកនេះថា ស៊ែបូយ៉ា ។

បូជនីយសក់ចិនឈ្មោះ យីតុ៊ីង ទ្រង់បាំងកូស់ជាច្រើនជាន់ ហើយគង់នៅក្នុងបុស្បុកធ្វើអំពីមាស លើគ្រែធ្វើអំពីមាសដែរ ។ រាជធានីរបស់ព្រះអង្គជារាជធានីរបស់កោះជ្វាធំ ជាទីមជ្ឈមណ្ឌលពាណិជ្ជកម្មជាមួយបរទេសដ៏សំខាន់ ។ តាមមើលទៅកោះស៊ូម៉ាត្រាពេលនោះស្ថិតនៅក្រោមឥទ្ធិពលរបស់ប៉ាលីមបាង ហើយជាសម្បុកមនុស្សដ៏ធំមួយ ដែលជាប្រភពដើមនៃពួកអ្នកដែលបានមកដណ្តើមយកនគរចាម្ប៉ា និងតាំងទីលំនៅដំបូងៗ នៅកម្ពុជា នៅបណ្តាកោះម៉ាឡេស៊ីទាំងឡាយ រួចសាយភាយទៅពេញប្រជុំកោះទាំងមូល និងឧបទ្វីបម៉ាឡាកាដងដែរ ។

***កោះជ្វា*** **:** ពួកឥណ្ឌាហៅកោះជ្វាថា ជ្វាទ្វីប ដែលចិនហៅតាមតែមិនច្បាស់ ទៅជាឆូប៉ូ, ឈូប៉ូ ឬ ទូប៉ូ[២៨] ។ នៅសម័យជាមួយគ្នានឹងប៉ាលីមបាងនោះ មានរដ្ឋមួយដែលត្រួតត្រាលើក្សត្រប្រទេសចំនួន១៨ផ្សេងទៀតនៅលើកោះនោះ គឺរដ្ឋមជប៉ាហីត មកពីឈ្មោះដើមឈើមួយដើមគឺ មជៈ និងផ្លែដែលមានរស់ជាតិល្វីង (ប៉ាហីត) ។ គេមិនដឹងថា រដ្ឋនេះចាប់កកើតឡើងពីពេលណាមកទេ ។

នៅសតវត្សរ៍ទី១៣រដ្ឋនេះមានរាជធានីថ្មី ដែលហាក់ដូចជាមានឈ្មោះថា មជបហីតៈ ស្ថិតនៅលើមាត់ទន្លេកេឌីរី នៅកណ្តាលព្រៃម៉ៃសាក់ដ៏ធំមួយ ។ មានសំណែសសេសសល់របស់រាជធានីនេះសព្វថ្ងៃនៅលើដីជាច្រើនពាន់ម៉ែត្រការ៉េ ដែលជាការបញ្ជាក់ថា គឺជារដ្ឋដ៏ខ្លាំងពូកែមួយ កាលពីសម័យនោះ ។

វាហាក់ដូចជាការពិតដែលថាទីក្រុងនេះមានឈ្មោះថា ជ្វា មុនពេលដែលបានត្រូវកសាងឡើងវិញ ដោយស្តេចវិជ័យ ។ គឺជាទីក្រុងធំជាងគេនៅលើកោះនេះ ជាហេតុធ្វើឲ្យគេហៅកោះទាំងមូលថាជ្វាដូច្នេះដែរ តាំងតែពីមុនពេលដែលបានវាតអំណាចទៅលើក្សត្រប្រទេសឯទៀតៗម្ល៉េះ ។ មានអ្នកខ្លះបានអះអាងថែមទៀតថា កោះនេះពីមុនមានឈ្មោះថា ហូលីង ឬកលិង្គ ដូចឈ្មោះ រដ្ឋកលិង្គ នៅឥណ្ឌាអ៊ីចឹងដែរ ដែលជាការបញ្ជាក់រឹតតែច្បាស់ថែមទៀតថា នេះជាអាណានិគមមួយរបស់ពួកហិណ្ឌូ មកពីកលិង្គ ។ រឿងហេតុអាចកើតមានយ៉ាងនេះមែន តែខ្ញុំគិតថា ពួកអ្នកធ្វើដំណើរតាមនាវាមកដល់កោះជ្វាតោងតែហៅកោះនេះទៅតាមទីក្រុងដែលគេបានចុះចត ហើយកលិង្គ, ជ្វា និងមជបហីតៈ អាចជាកំពង់ផែនាវាបន្តបន្ទាប់ដែលមានពាណិជ្ជកម្មសំខាន់ជាងគេ ។ ដោយហេតុនេះកោះនេះក៏ត្រូវគេហៅថាជ្វាដូច្នេះទៅ ហើយពួកបរទេសហៅ និងសរសេរឈ្មោះទៅតាមអក្សរគេ ពួកហិណ្ឌូហៅថា ហូលីង ឬកលិង្គ ឯពួកចិនហៅថា ឆូប៉ូ ។ល ។ ជាដើម ។

បើទោះជាយ៉ាងណាក្តី គេមិនអាចកំណត់ពេលនៃការកសាងទីក្រុងមជបហីតៈមុនចុងសតវត្សរ៍ទី១២បានទេ ។ ប៉ុន្តែខ្ញុំដូចជាចេះតែនៅចង់កំណត់កាលបរិច្ឆេទនោះទៅពីរសតវត្សរ៍មុន គឺឲ្យត្រូវនឹងសម័យកាលវីរ

[២៨] ខ្មែរយើងហៅថាកោះជ្វា ស្រុកជ្វា នគរជ្វា ។

បុរសស៊ីនបែដ របស់អ្នកនិពន្ធអារ៉ាប់ និងពែក្ស ប៉ុន្តែគ្មានមូលហេតុគ្រប់គ្រាន់ ។

មួយរយឆ្នាំក្រោយមក ព្រះចៅអធិរាជចិនគូប៊ីឡៃខាន់បានបញ្ជូនទ័ពមួយកងឲ្យមកសងសឹកនឹងការប្រមាថរបស់ស្តេចមជបហិតៈមកលើរាជទូតចិន ។ ទ័ពចិនវាយទ័ពជ្វាឈ្នះមុនដំបូងនៅត្រង់ដីសណ្តស៊ូរ៉ាបាយ៉ាក្បែរមាត់ពាមទន្លេកេឌីរី ។ បន្ទាប់មកបានតាមមកវាយរហូតដល់កំផែងរាជធានីមជបហិតៈ ដុតបំផ្លាញស្រុកខ្ទេចខ្ទី តែដណ្តើមយករាជធានីមិនបាន ក៏ត្រលប់ទៅវិញទៅពេល៤ខែក្រោយ ។ ព្រឹត្តិការណ៍នេះកើតឡើងនៅក្នុងឆ្នាំ១២៩៣ ។ ការចាញ់ដៃចិននេះមិនបានធ្វើឲ្យរាជាណាចក្រជ្វាចុះខ្សោយទេ ពីព្រោះយើងឃើញបន្ទាប់មកថាពួកនេះបានចេញមកវាយផ្នែកអាគ្នេយ៍កោះស៊ូម៉ាត្រា ដណ្តើមយករាជាណាចក្រប៉ាសីដាក់ជាចំណុះនៅដើមសតវត្សរ៍ទី១៤ ។

មានការបញ្ជាក់ច្បាស់ថា រហូតដល់មុនចុងសតវត្សរ៍ទី១៤ រដ្ឋមជបហិតៈនេះបានវាតអំណាចទៅលើរាជាណាចក្រចំនួន១៨ ដែលស្ថិតនៅលើកោះក្បែរៗកោះជ្វា ទៅលើរាជាណាចក្រចំនួន៨នៅលើកោះប៊័រណេអូ និងទៅលើរាជាណាចក្រ៣ទៀតនៅទិសខាងកើត នៅក្នុងប្រជុំកោះហ្វីលីពីន ។

ព្រះរាជាជ្វា មិនអាចរក្សារដ្ឋដ៏ច្រើនទាំងអស់នេះនៅក្រោមការត្រួតត្រារបស់ខ្លួនបានយូរប៉ុន្មានទេ ប៉ុន្តែគេឃើញថា នៅសតវត្សរ៍ទី១៤មានព្រះរាជាមួយអង្គបានចាប់ផ្តើមធ្វើសង្គ្រាមជាមួយរាជាណាចក្រប៉ាសីរួចបានវាយកម្ទេចហ្សមប៊ី និងប៉ាលីមបាងពេលធ្វើដំណើរត្រលប់មកវិញ ព្រមទាំងបាននាំយកពួកឈ្លើយសឹកមកដាក់ នៅលើកោះជ្វា ថែមទៀតផង ។

ផប់ផុលនឹងជ័យជម្នះនៅលើកោះស៊ូម៉ាត្រា ព្រះរាជាអង្គនោះក៏ចាប់ផ្តើមធ្វើការវាយដណ្តើមយកក្សត្រប្រទេសទាំង២៩ខាងលើ ព្រមទាំងបានវាយដណ្តើមយកក្សត្រប្រទេសឯករាជ៥ទៀត ដាក់ជាចំណុះ ។ ព្រះអង្គបានកសាងសំពៅ៦០០ មានទ័ព និងអាវុធយុទ្ធភណ្ឌគ្រប់គ្រាន់ ក្រោមការបញ្ជារបស់ឧត្តមសេនីយ៍៣រូប ។ ក្នុងសង្គ្រាមខាងលើ ទ្រង់ប្រមូលបានជ័យភណ្ឌជាច្រើន រហូតដល់ប្រវត្តិវិទូរបស់ប៉ាសី ហ៊ីកាយ៉ុតរ៉ាជា (រ៉ាជាប៉ាសី) និយាយថា មិនអាចគណនាបាន ។

សង្គ្រាមវាតអំណាចនេះ បានធ្វើឲ្យស្តេចមជបហិតៈ មានកិត្តិនាមបោះសំឡេងជាខ្លាំង នៅក្នុងចំណោមព្រះរាជាដទៃទៀត ដែលចាប់បញ្ជូនសួយសារអាករដ៏ច្រើនលើសលប់មកថ្វាយ ហើយមជបហិតៈ ក៏ក្លាយជា «ទីកន្លែងដែលមានមនុស្សម្នាធ្វើដំណើរទៅមកពីស្រុកចំណុះឥតដាច់» ។ រាជធានីមជបហិតៈបានរីកធំ មានប្រជាជនច្រើន សប្បុរសប្បាយ «ឮតែសំឡេងស្គរគងឃ្មោះបន្លឺលាយឡំជាមួយសំឡេងឧបករណ៍តន្ត្រីឯទៀតយ៉ាងពីរោះរងំ» ។ អ្នកប្រវត្តិវិទូបានបន្តទៀតថា«គេឃើញមានល្បែង និងទស្សនីយភាពប្លែកៗជាច្រើន ដូចជាល្ខោនសិល្បសៃយ ល្ខោនតុក្កតា នាដ្យកម្មបាំងមុខ ចម្រៀងជាក្រុម និងក្រុមសៀកដ៏ប៉ិនប្រសប់ ។ មានបុណ្យទាំងយប់ទាំងថ្ងៃ ម្ហូបអាហារក៏មិនខ្វះ មានទេសចរមកពីគ្រប់ទិសទីចូលមកទស្សនា» ។

**ប៉ាសី** ៖ នៅដើមសតវត្សរ៍ទី១២ ទីក្រុងមួយនៅចុងខាងជើងកោះស៊ូម៉ាត្រាមានឈ្មោះថា សាម៉ាឡង់ ។ ទីក្រុងនេះជារាជធានីរបស់រាជាណាចក្រតូចមួយដែលជារដ្ឋចំណុះប៉ាលីមបាង ។ មានព្រះរាជា២អង្គ ជាបងប្អូនដែលបានកសាងទីក្រុងនេះឡើង ព្រះរាជានោះកាន់សាសនាតាមពួកអារ៉ាប់ ប្រហែលដោយសាសនានោះជាសាសនាធ្វើសង្គ្រាមប្រឆាំងពួកក្បត់ និងប្រហែលដោយសារពួកអារ៉ាប់ដែលបានធ្វើដំណើរមកដល់ទីនោះនិយាយតែអំពីចម្បាំងវាតទឹកដី ដែលពួកសាសនិកធ្វើចាប់ពីចុងដែនដីខាងលិច រហូតមកដល់សមុទ្របឹងហ្កាល់ ។ ពួកអ្នកស្រុកក៏បានចូលសាសនាអារ៉ាប់នេះ ដូចជាព្រះរាជាគេដែរ ។ ដូចនេះ រាជាណាចក្រនេះគឺជារាជាណាចក្រទី១ ដែលកាន់សាសនាមហាម៉ាត់ ។

មានមន្ត្រីម្នាក់ឈ្មោះ ម៉ាឡ៉ាស៊ីលូ ដែលត្រូវគេបណ្តេញចេញពីនគរសាម៉ាឡង់ បានមកតាំងទីលំនៅ នៅនឹងភូមិតូចមួយ មានឈ្មោះថា ប៊ូឡូតេឡុង ។ គេនិយាយថាមន្ត្រីនោះបានក្លាយខ្លួនជាមេចោរសមុទ្រដ៏កាចសាហាវ មានទ្រព្យសម្បត្តិហូរហៀរ តែចិត្តទូលាយ ពូកែធ្វើចម្បាំង និងមានល្បិចច្រើន ។ អ្នកស្រុកនៅទីនោះបានលើកមន្ត្រីនោះឲ្យធ្វើជាស្តេច កសាងរាជធានីមួយថ្មាយ និងលើកតម្កើងព្រះរាជាអង្គនេះដូចជាបណ្តាស៊ុលតង់ របស់សាម៉ាឡង់ អ៊ីចឹងដែរ ។ ព្រះអង្គបានប្រកាន់យកព្រះឋានៈជាស៊ុលតង់សុមុទ្រៈនៅឆ្នាំ១២៥០ ។ ព្រះរាជាអង្គនេះបានធ្វើសង្គ្រាមប្រកបទៅដោយជ័យជម្នះជាញឹកញាប់ ជាមួយស៊ុលតង់ សាម៉ាឡង់ ជាហេតុធ្វើឲ្យគេខ្លាចរអាព្រះអង្គគ្រប់គ្នានៅក្នុងតំបន់ ។

គឺនៅពេលនោះហើយដែលទ្រង់បានកសាងរាជធានីប៉ាសីឡើង ចូលកាន់សាសនាអ៊ីស្លាម ហើយបោះបង់ចោលព្រះឋានៈម៉ាឡ៉ាស៊ីលូ ដោយប្រកាន់យកព្រះឋានៈជាមេឡឹកអែលសាឡេសវិញ ។ ទ្រង់បានដាក់ឈ្មោះឲ្យរាជធានីសុមុទ្រៈថា សុមុទ្រៈដាអែលសាឡាំ មានន័យថា "សុមុទ្រៈជាទីសំណាក់សន្តិភាព" ពីព្រោះថា អ្នកស្រុកបានប្តូរចូលកាន់សាសនាអ៊ីស្លាមដោយមិនចាំបាច់មានការបង្ខិតបង្ខំ[២៥] ។ ព្រះអង្គបានរៀបអាពាហ៍ពិពាហ៍ជាមួយបុត្រីព្រះរាជា ពែរឡាក់ ហើយមានរាជបុត្រមួយអង្គគឺ មេឡិកអែលសាហ៊ែ ដែលសោយរាជ្យបន្តពីព្រះអង្គបានប៉ុន្មានឆ្នាំ ក៏សុគតទៅ បន្សល់ទុករាជបុត្រា២អង្គឲ្យនៅជាមួយ ព្រះអយ្យកោមេឡិកអែលសាឡេស មួយគឺមេឡិកអែលម៉ាមូដ មួយទៀតគឺ មេឡិកអែលម៉ង់សួ ។ មេឡិកអែលម៉ាមូដក្រោយមកជាស៊ុលតង់សោយរាជ្យនៅប៉ាសី ឯមេឡិកអែលម៉ង់សួ ជាស៊ុលតង់នៅសុមុទ្រៈ ។

---

[២៥] ឈ្មោះបែបនេះហាក់ដូចជាកាន់តែបញ្ជាក់ថា ការប្តូរចូលកាន់សាសនាអ៊ីស្លាមនៅចុងបូព៌ា នៅបូព៌ា និងនៅបស្ចិមប្រទេស មិនមែនប្រព្រឹត្តទៅដោយការស្ម័គ្រចិត្តនោះទេ ។

រាជាណាចក្រទាំង២មានកិត្តិនាមល្បីសុះសាយទៅគ្រប់ទិសទី ហើយនៅកន្លែងណាក៏ពុតែគេនិយាយអំពីស៊ុលតង់មេឡិកអែលម៉ាមូដ និងមេឡិកអែលម៉ង់សួ ថាមានអំណាចខ្លាំងក្លា សម្បូរសប្បាយដែរ ។ ហេតុការណ៍នេះបានធ្វើឲ្យស្តេចសៀមបញ្ជូនទ័ពតាមជើងទឹកមួយកងធំមកកាន់សុមុទ្រៈ ដើម្បីទាមទារឲ្យលើកសួយសារអាករ ទៅថ្វាយ ដោយប្រកាន់ថាជាប្រទេសចំណុះ ភ្លេចបំពេញកាតព្វកិច្ច ដែលតាមមើលទៅគឺជាសិទ្ធិដែលមានតពីព្រះរាជាកម្ពុជាមក ។ មេឡិកអែលម៉ាមូដទ្រង់ក្រោធនឹងអាកប្បកិរិយារបស់សៀមនេះជាខ្លាំង ហើយបានបញ្ជាឲ្យវាយទៅទ័ពសៀមដែលទើបនឹងចុះដល់ដី រួចឲ្យសាងសង់កំពែងការពាររាជធានី ។ សង្គ្រាមមានរយៈពេលយូរ តែទីបញ្ចប់ម៉ាមូដ ទទួលជ័យជម្នះ សម្លាប់ទ័ពសៀមបានស្ទើរតែទាំងអស់ អ្នកខ្លះត្រូវអ្នកស្រុកសម្លាប់ សេសសល់តិចតួចរត់ឡើងសំពៅត្រលប់ទៅស្រុកវិញ ។

មេត្រីភាពរវាងបងប្អូនទាំង២ល្អណាស់ រហូតដល់ពេលមួយដែលមេឡិកអែលម៉ង់សួ ធ្វើដំណើរទៅកាន់រាជវាំងរបស់បង តែមេឡិកអែលម៉ាមូដមិននៅ ប្រទេះឃើញនារីស្អាតម្នាក់ដើរចេញមក គួរស្រលាញ់ក៏ចាប់យកទៅ ។ ម៉ាមូដខឹងណាស់ ក៏រៀបផែនការសងសឹក ដោយធ្វើជាអញ្ជើញម៉ង់សួឲ្យមកចូលរួមពិធីកាត់ស្បែកអគ្គជាតិបុត្រា រួចចាប់យកទៅបំបរបង់លើកោះឆ្ងាយមួយ ។ ម៉ាមូដបានយកសុមុទ្រៈមកដាក់ជាទឹកដីរបស់ខ្លួន ។ ដល់ក្រោយមក ម៉ាមូដ នឹកឃើញអាណិតប្អូន ស្តាយកំហុស ក៏បញ្ជាឲ្យគេតាមទៅយកប្អូនត្រលប់មកវិញ ប៉ុន្តែ ម៉ង់សួត្រូវស្លាប់តាមផ្លូវ ។ រឿងនេះរឹតតែធ្វើឲ្យ ម៉ាមូដ មានវិប្បដិសារីខ្លាំងឡើងថែមទៀត ទ្រង់ក៏ដាក់រាជសម្បត្តិ ថ្វាយព្រះរាជបុត្រាព្រះនាមថា អាមេដទៅ ។

គឺនៅក្នុងរជ្ជកាលរបស់ស្តេចអាមេដនេះឯង ដែលស្តេចមជបហឹតៈបានបញ្ជូនកងទ័ពមកវាយយក ប៉ាសីហើយដុតបំផ្លាញខ្ទេចខ្ទី ធ្វើឲ្យរដ្ឋនេះរលត់រលាយបាត់ទៅ មិនបានមួយសតវត្សរ៍ផងចាប់ពីពេលកសាងមក នៅឆ្នាំ១២៥០ ។

ប៉ុន្មានឆ្នាំក្រោយមក ពួកចាមនៅឥណ្ឌូចិនដែលត្រូវពួកអាណ្ណាមវាយឲ្យបរាជ័យ បានធ្វើដំណើរមកកាន់ទឹកដីត្រង់នេះ បង្កើតជាមួយពួកម៉ាឡេក្នុងស្រុកបានជារដ្ឋអាចេឡើង ដែលមានអត្ថិភាពរហូតដល់ឆ្នាំ១៩០០ ។

**ម៉ាឡាកា :** *រយៈកាលយូរក្រោយមក ស្តេចមជបហឹតៈបានវាយដណ្តើមយកសិង្ហបុរីដែលសាងនឹឡាអ៊ុតាម៉ា បានកសាងឡើងកាលពីច្រើនសតវត្សរ៍មុន ហើយមានសាហ៍[២៦] អ៊ីស្កង់ឌែរកំពុងតែសោយរាជ្យ ។ តាមពិត*

[២៦] ពាក្យ សាហ៍ នេះជាពាក្យ ពែក្ស ក្លាយមកពីពាក្យសំស្ក្រឹតក្សត្រិយៈ បញ្ជាក់ថា អ្នកដែលធ្វើឲ្យតំបន់នេះបែរទៅកាន់សាសនាអ៊ីស្លាមវិញ គឺពួកពែក្ស ឬពួកម៉ុងហ្គោល មកពីឥណ្ឌា ។

រាជធានី បានត្រូវធ្លាក់ទៅក្នុងដៃសត្រូវដូច្នេះដោយមកពីមានមន្ត្រីក្បត់ គឺបេនដាហារ៉ាសង់រ៉េង់ជូនតាប៉ា ព្រោះខឹងនឹងព្រះរាជាដែលបានសម្លាប់បុត្រីរបស់ខ្លួនជាអគ្គមហេសី យ៉ាងថោកទាបបំផុត ដោយទ្រង់ចោទថា ព្រះជាយាបំបាក់មុខព្រះអង្គ ក៏សងសឹកដោយបើកដៃឲ្យសត្រូវចូលមក ។

អ៊ីស្កង់ឌែរគេចខ្លួនរួច បានភៀសព្រះកាយជាមួយព្រះរាជវង្ស និងសេនាភីលៀងទៅគង់នៅឯម៉ូអារ រួចទៅកូតាប៊ូរូ ទៅសង់ហ្គង់អ៊ូហ្យុង ទីបញ្ចប់ ទៅគង់នៅលើមាត់ទន្លេបង់តាំ ដែលទ្រង់យល់ថាឆ្ងាយផុតពីដៃពួកជ្វា ហើយក៏ចាត់ឲ្យកសាងរាជធានីហ្សាកូឡា ឡើងនៅក្នុងគ្រិស្តសករាជ១៣៧៥ ត្រូវនឹងមហាសករាជ១២៩៧ ។ រាជធានីនេះ ក្រោយមកគឺ ម៉ាឡាកា[២៧] ។

នៅពេលទទួលបានដំណឹងអំពីការកសាងរាជធានីថ្មីនេះ អ្នកស្រុកជាច្រើនដែលភៀសខ្លួនចេញរួចពីសិង្ហបុរីផុតពីការសម្លាប់រង្គាល (មានមនុស្សជាង៤ម៉ឺននាក់ត្រូវគេសម្លាប់) បាននាំគ្នារត់ពាក់ពពូនមករស់នៅ ធ្វើឲ្យកើតជារាជាណាចក្រតូចមួយប្រកបទៅដោយប្រជាជនអង់អាចហានក្លា ព្រោះសុទ្ធជាអ្នកផ្សងព្រេង ជាអ្នកមានកំហឹងឈឺចាប់ ដែលភៀសខ្លួនគេចពីការកាប់សម្លាប់របស់ពួកជ្វា ។ រាជធានីថ្មីនេះមានទីតាំងល្អ គឺស្ថិតនៅលើច្រកដ៏ចង្អៀតនៃសមុទ្រម៉ាឡាកា នៅចំពីមុខកោះរ៉ូប៉ាត់ ។ រាជធានីនេះបន្ទាប់មកបានក្លាយជាទីកន្លែងសម្រាក និងផ្គត់ផ្គង់ស្បៀងសម្រាប់ពួកអ្នកធ្វើរសមុទ្រដែលចេញចូលជាញឹកញាប់ ។

ព្រះរាជាដែលសោយរាជ្យបន្តពីអ៊ីស្កង់ឌែរបន្ទាប់ទីពា គឺកេតជិតបេសា ឡើងសោយរាជ្យនៅឆ្នាំ១២៧៦ បានប្រែចូលកាន់សាសនាអ៊ីស្លាម ហើយដូរឈ្មោះទៅជា ស៊ុលតង់មហាមេដសាហ៍វិញ ។ ពេលនោះអ្នកស្រុកទាំងអស់ ទន្ទេញចាំមាត់នូវរូបមន្តពីរឃ្លា "គ្មានអាទិទេពដទៃទៀតណាក្រៅពីអាទិទេពដែលមានតែមួយគត់ គ្មានអ្នកណាប្រដូច ហើយមហាមេដជាខ្ញុំបម្រើ និងជាអ្នកនាំសាររបស់ព្រះអង្គ" ។ ដោយហេតុនេះម៉ាឡាកាបានស្ថិតនៅជារាជាណាចក្រកាន់សាសនាអ៊ីស្លាមអស់កាលដ៏ខ្លី នៅកណ្តាលរដ្ឋតូចៗជាច្រើនដែលកាន់ព្រហ្មញ្ញសាសនា ។

នៅពេលនោះ សង្គ្រាមបានត្រូវប្រកាសឡើងទៅលើពួកប្រឆាំង ហើយទឹកដីដែលស្ថិតនៅខាងកើតម៉ាឡាកា រហូតដល់សមុទ្រសៀមក៏ត្រូវបានដណ្តើមដាក់ជាចំណុះ រួមមានប៉ាហាង, ត្រេងហ្គានូ, រួចប្រជុំកោះលិង្គៈ និងប្រជុំកោះបេនតាង ដែលពីមុនជាទឹកដីចំណុះស្តេចសិង្ហបុរី បានន័យថាគ្រប់គ្រងដោយបុព្វបុរសរបស់ស៊ុលតង់ម៉ាឡាកា ។

យើងបានឃើញពីខាងលើរួចមកហើយថា ស្តេចសៀមបានទាមទារថាខ្លួនមានសិទ្ធិអធិរាជភាពលើរាជាណាចក្រប៉ាសី នៅខាងជើងកោះស៊ូម៉ាត្រា ដូច្នេះវាច្បាស់ណាស់ថា គេរឹតតែមានសិទ្ធិខ្លាំងណាស់ទៅទៀតមកលើ

---

[២៧] ពាក្យម៉ាឡាកា នេះ ជាឈ្មោះរុក្ខជាតិមួយដើម គឺ emblica officinalis ។

ទៀបកោះម៉ាឡាកា ដែលតាមមើលទៅអនុត្តរភាពនេះបន្តពីអធិរាជភាពរបស់ស្ដេចកម្ពុជាមក ។ ស្ដេចសៀមមួយអង្គដែលប្រវត្តិសាស្ត្ររាជាណាចក្រម៉ាឡាកាហៅថាប៉ូបានីយ៉ា[២៨] ដោយមានបំណងចង់យករាជាណាចក្រថ្មីនេះដាក់ក្រោមការត្រួតត្រា បានបញ្ជូនទ័ពមួយកងឲ្យមកវាយ ក្រោមបញ្ជារបស់រដ្ឋមន្ត្រីខាងសង្គ្រាម ។ តែទ័ពនេះត្រូវស្ដេចម៉ាឡាកាវាយឲ្យបរាជ័យ ហើយទ័ពដែលបញ្ជូនមកលើកទី២ក្រោមបញ្ជារបស់តេដោសៀម ក៏ត្រូវបរាជ័យដែរ ថែមទាំងត្រូវដេញវាយប្រហាររហូតដល់ចុងទៀបកោះ ។ ចាប់ពីពេលនោះមក ស្ដេចសៀមក៏បោះបង់គំនិតចង់បានរាជាណាចក្រនេះដែលចេះការពារខ្លួនបានយ៉ាងពូកែ ហើយគេក៏លែងឃើញមានទ័ពសៀមចូលមកទៀតដែរ ។

នៅដើមសតវត្សរ៍ទី១៤ ស៊ុលតង់ដែលសោយរាជ្យបន្តពីស៊ុលតង់នេះមានឈ្មោះថា ម៉ង់សួសា ទ្រង់បានធ្វើសង្គ្រាមដណ្ដើមយកប៉ាហាងដែលប្រហែលជាបានរើបម្រះរួចពីនឹមត្រួតត្រារបស់ម៉ាឡាកា ហើយដែលកាលនោះស្ថិតនៅក្រោមការដឹកនាំរបស់មហារាជទេវៈសុរិយា ជាសាច់សារលោហិតឬក៏ជាស្ដេចសាមន្តរាជរបស់ស្ដេចសៀម ។ ម៉ង់សួសាបាននាំមហារាជនេះជាឈ្លើយយកមកកាន់ម៉ាឡាកាជាមួយរាជវង្សទាំងអស់ បន្ទាប់មកក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយបុត្រីស្រស់ស្អាតព្រះនាមថា វណាងស្រី ។

អាពាហ៍ពិពាហ៍នេះធ្វើឲ្យសៀម និងម៉ាឡាកាខិតទៅជិតរកគ្នា ព្រោះបន្តិចក្រោយមកស៊ុលតង់ម៉ាឡាកាបានបញ្ជូនរាជទូតមួយទៅកាន់អយុធ្យា ហើយដូចដែលលោក ម៉ារី បាននិយាយអ៊ីចឹង សម្ព័ន្ធមេត្រី និងមិត្តភាពបានកើតមានឡើងរវាងរាជាណាចក្រសៀមដ៏មានអំណាចជាមួយនឹងរដ្ឋតូចម៉ាឡាកា គឺរដ្ឋមួយកាន់ព្រះពុទ្ធសាសនារដ្ឋមួយទៀតកាន់សាសនាអ៊ីស្លាម ។

ប៉ុន្មានឆ្នាំក្រោយមក ស៊ុលតង់បានរៀបអាពាហ៍ពិបាហ៍ជាមួយបុត្រីស្ដេចមជបហឹតៈ ព្រះនាង រ៉ាឌិនហ្គាឡាចន្ទ្រកេរ៉ាណា ហើយបានទទួលជាចំណងដៃនូវរាជាណាចក្រឥន្ទ្រគិរី, សៀងតាង និងប៉ាលឹមបាង ដែលស្ថិតនៅលើកោះស៊ូម៉ាត្រា ឬកោះជ្វាធំ ។ តាមមើលទៅនគរទាំង៤មិនទាន់ប្រែទៅកាន់សាសនាអ៊ីស្លាមនៅឡើយព្រោះថាឈ្មោះ ឥន្ទ្រគិរី ក៏ដូចជាឈ្មោះរបស់នគរព្រះនាងក្សត្រី មិនមែនជាឈ្មោះតាមភាសាអារ៉ាប់ទេ ។

នៅពេលត្រលប់មកកាន់នគរវិញ ស៊ុលតង់ម៉ាឡាកា បានលើកបុត្រីព្រះអង្គឲ្យទៅព្រះរាជាឥន្ទ្រគិរី ធ្វើជាមហេសី ។ គេនិយាយថា សូម្បីតែស្ដេចស្រុកចិនដែលបានអះអាងថាជាប់ខ្សែស្រឡាយជាមួយព្រះចៅអធិរាជអាឡិចសង់ឌ្រឺក្រង់ ក៏ប្រាថ្នាចងសម្ព័ន្ធមេត្រីជាមួយស៊ុលតង់ម៉ាឡាកាដែរ ជាក់ស្ដែងគឺទ្រង់បានលើកព្រះរាជបុត្រីព្រះនាមហុងលីប៉ូថ្វាយ ដែលហែហមទៅដោយរាជទូត និងភីលៀងស្រីប្រុសចំនួន៥០០នាក់ សុទ្ធតែជាកូន អស់

[២៨] តើជាពាក្យ «ពញា» ឬ?

ពួកនាម៉ឺនសព្វមុខមន្ត្រី ពួកនេះក្រោយមកបង្កើតបានជាអាណានិគមចិននៅប៉ូគិតឆៃណា (ភ្នំចិន) ដែលប្រៀបបាន ទៅនឹងភ្នំម៉ុងម៉ាត្រមួយនៅម៉ាឡាកា ។ ដោយព្រះក្សត្រីទ្រង់យល់ព្រមចូលសាសនាអ៊ីស្លាម ស្តេច ស៊ុលតង់ ក៏ទទួលរៀបការធ្វើជាមហេសីទៅ ។

នៅសម័យជាមួយគ្នានោះ សង់អាជី ឬស្តេចប៉ីរណេអូក៏បានចុះសន្ធិសញ្ញាមិត្តភាពជាមួយស៊ុលតង់ម៉ាឡាកាដែរ ដែលបានក្លាយទៅជាមហាអំណាចខ្លាំងក្លាមួយ ។ ទ្រង់បានសម្រេចចិត្តកម្ចាត់មេចោរសមុទ្រដ៏សាហាវម្នាក់ នៅក្នុងសមុទ្រខាងត្បូង គឺស្តេចម៉ង់កាសា ដែលតែងតែរាតត្បាតទឹកដីតាមមាត់សមុទ្រជ្វា សៀមសិង្ហបុរី និងស៊ូម៉ាត្រា ។ ទ្រង់បានបញ្ជូនទ័ពដេញវាយមេចោរសមុទ្រនោះ ហើយបង្ខំឲ្យវាដកថយចេញទៅសម្ងំនៅក្នុងប្រទេសវាវិញ ។

បន្តិចក្រោយមកទៀត ទ្រង់បានធ្វើចម្បាំងជាមួយស៊ុលតង់ប៉ាសី ដែលដណ្តើមរាជសម្បត្តិពីព្រះរៀម និងចាប់ដណ្តើមទឹកដីរដ្ឋផ្សេងៗទៀតរបស់ព្រះអង្គ ។

ស៊ុលតង់ដែលសោយរាជ្យបន្តពីព្រះអង្គគឺ ព្រះរាជបុត្រាព្រះនាមអាឡាអែលឌីនរ៉ាយ៉ាតសាហ៍ ។ ព្រះរាជាអង្គនេះ បានវាយកម្ចាត់ពួកចោរដែលតែងតែមកឆក់ប្លន់ម៉ាឡាកា រួចបានវាយបង្ក្រាបស្តេចហារ៉ូដែលចេះតែមករាតត្បាតមាត់សមុទ្រម៉ាឡាកា ហើយចាប់បង្ខំឲ្យចុះសន្ធិសញ្ញាសន្តិភាពមួយ ។

រាជបុត្ររបស់អាឡាអែលឌីនរ៉ាយ៉ាតសាហ៍ គឺស៊ុលតង់ម៉ាមូដសាហ៍ ជាមនុស្សខិលខូច បានវាយយកស្រុកម៉ង់ជង, ប៉េរ៉ាក់[២៩] និងកាឡង់តង់ដាក់បញ្ចូលមកក្នុងទឹកដី ដែលធ្វើឲ្យមានការភ្ញាក់ផ្អើលជាខ្លាំង ប៉ុន្តែប្រវត្តិវិទូម៉ាឡាកា និយាយថា នេះគឺមកពីកាំភ្លើងដែលទ័ពម៉ាឡាកាមួយចំនួនមានក្នុងដៃ អាវុធទាំងអស់នោះពួកព័រទុយហ្គេដែលទើបមានវត្តមានក្នុងតំបន់បានថ្វាយ ស៊ុលតង់ ជាអនុស្សាវរីយ៍ ។

នៅសម័យនោះប្រពៃណីម៉ាឡាកាបានស្រុតចុះជាខ្លាំង មានបញ្ហាផិតក្បត់ជារឿយៗ ធ្វើឲ្យអ៊ីៗល្អក់កករអស់ ហើយរឿងអស់នេះកើតឡើងមកពីមានគំរូមិនល្អរបស់ព្រះរាជា ព្រះរៀម និងព្រះអនុជ និងសេនាសព្វមុខមន្ត្រី ។ មានរឿងចាប់ពង្រត់ស្ត្រី និងនារីរាល់យប់ ហើយបើកុំតែមាននាយករដ្ឋមន្ត្រីម្នាក់រឹងមាំ គឺបេនដាហារ៉ាស្រីមហារាជា ម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងកិច្ចការនគរ មិនដឹងជាស្រុកពេលនោះក្លាយជាអាក្រក់យ៉ាងណាទេ ព្រោះព្រះរាជាមិនបានយកព្រះទ័យទុកដាក់នឹងដឹកនាំនគរទេ គិតតែពីការសប្បាយ ។ បេនដាហារ៉ានេះ បានរុញច្រានទ័ពព្រះរាជាលីគ័រ ដែលស្តេចសៀមបានបញ្ជូនឲ្យមកវាយប្រហារទីក្រុងប៉ាហាង ឲ្យដកថយទៅវិញ រួចបានចាប់បង្ខំអង្គម្ចាស់សៀមម្នាក់ ដែលបានគេចខ្លួនមកកសាងក្សត្រប្រទេសប៉ាតានី ឲ្យដូរចូលកាន់សាសនាអ៊ីស្លាម ហើយ

[២៩] ជាភាសាខ្មែរ គឺប្រាក់ ។

ដាក់ខ្លួនចំណុះស៊ុលតង់ម៉ាឡាកា ព្រមទាំងប្ដូរឈ្មោះទៅជា ស៊ុលតង់អាមេដសាហ៍ នៃ ប៉ាតានី វិញ ។ បេនដាហារ៉ា នេះ ក៏បានណែនាំឲ្យស្ដេចកេដាហ៍ ដាក់ខ្លួនជាចំណុះ ស៊ុលតង់ម៉ាឡាកា ផងដែរ ។

ដោយរដ្ឋម៉ាឡាកាស្ថិតនៅក្នុងច្រកដ៏ចង្អៀតនៃសមុទ្រ ហើយបានក្លាយទៅជាច្រកចេញចូលនៃសំពៅសមុទ្រ ជាមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏ពិសេសមួយ និងជាទីផ្សារមានសកម្មភាពយ៉ាងសកម្មនោះ ហេតុការណ៍នេះបានទាក់ទាញពួកព័រទុយហ្គេឲ្យមានការចាប់អារម្មណ៍ជាខ្លាំង ។ ពួកនេះមានសំពៅធំៗ ដែលធ្វើដំណើរកាត់សមុទ្រពែក្ស សមុទ្រឥណ្ឌា បឹងហ្គាល់ ទៅដល់ភាគខាងត្បូងស្រុកចិន និងប្រទេសជប៉ុនថែមទៀត ។ ម៉ាឡាកា ពេលនោះ មានប្រជាជន១៩ម៉ឺននាក់ កំពង់ដែលមានសំពៅចូលចតលើកដាក់ទំនិញ ឬផ្គត់ផ្គង់ស្បៀងមុននឹងចាកចេញទៅវិញ មិនតិចជាង២០គ្រឿងទេក្នុង១ថ្ងៃៗ (ទំនិញមានស្ពាន់ឬកាឡាជាដើម) ។ គឺជាទីក្រុងនៃការសប្បាយដែលគេយកប្រាក់ប្រមូលបានមកពីឆ្ងាយ មកចាញវាយបំផ្លាញក្នុងបនល្បែងឬបនស្រី ។ មានសំពៅហិណ្ឌូ ពែក្ស ម៉ាឡេ ជ្វា សៀម ប៉េហ្គាន កម្ពុជា ចាម ចិន មកពីគ្រប់ទិសទី ហើយនាំយកកិត្តិនាមទីក្រុងសប្បាយនេះទៅផ្សព្វផ្សាយគ្រប់ទីកន្លែងវិញ ។ ស្រាប់តែនៅព្រឹកមួយ ពេលព្រះអាទិត្យទើបតែរះ មានកប៉ាល់ហ្វារ៉ង់ហ្គី[៣០] មួយ បានបង្ហាញខ្លួនឡើង នោះគឺជាកប៉ាល់របស់ពួកព័រទុយហ្គេ ដែលធ្វើឲ្យមានការភ្ញាក់ផ្អើលជាខ្លាំង តែបន្ទាប់មក មេបញ្ជាការកប៉ាល់នោះបានត្រូវនាយករដ្ឋមន្ត្រីទទួលយ៉ាងអធិកអធម ។ មេបញ្ជាការកប៉ាល់ទទួលស្គាល់ថា ទីក្រុងនេះ ធំស្អាត ហើយសម្បូរសប្បាយ ។ មេបញ្ជាការកប៉ាល់នោះបានរាយការណ៍ជូនលោកឧត្ដមនាវីព័រទុយហ្គេ លោកអាល់ប៊ុយកែក នៅពេលត្រលប់ទៅដល់កោះហ្គូអាវិញ ។ ដោយយល់ទីក្រុងម៉ាឡាកានេះ ជាច្រកបិទ និងបើកទ្វារទៅកាន់ចុងបូព៌ាប្រទេស លោកឧត្ដមនាវីបានបញ្ជាឲ្យលោក ហ្គុងហ្សាលវេ៍ប៉េរ៉ូរ៉ា ដឹកនាំនាវាចម្បាំង៧គ្រឿងមកវាយដណ្ដើមយកទីក្រុងនេះ ។ ប៉ុន្តែលោក បេនដាហារ៉ាស្រីមហារាជ បានរុញច្រានការឈ្លានពាននោះ ឲ្យដកចេញទៅវិញ ធ្វើឲ្យពួកព័រទុយហ្គេដឹងថា គេមិនអាចដណ្ដើមយក ទីក្រុងនោះបានទេ ដរាបណាមានលោកនាយករដ្ឋមន្ត្រី ។ ប៉ុន្មានឆ្នាំក្រោយមក ពួកគេត្រលប់មកវាយម៉ាឡាកាម្ដងទៀត ក្រោយពីលោក បេនដាហារ៉ា បានត្រូវព្រះរាជាបញ្ជាឲ្យគេសម្លាប់ជាមួយនឹងកូនប្រុសព្រមទាំងកូនប្រសាឈ្មោះ ទួនអាលី ផង នៅពេលដែលព្រះអង្គ បានចាប់បង្ខំយកបុត្រីលោក បេនដាហារ៉ា គឺភរិយារបស់ទួនអាលី ធ្វើជាមហេសី ។ ដោយស្អប់ព្រះរាជា មហេសីនេះបានឲ្យឆ្មបរំលូតកូនចេញរាល់ពេលដែលមានផ្ទៃពោះ ។ ក្រោយមក ដោយយល់ថា រាស្ត្រលែងគាំទ្រព្រះអង្គ

---

[៣០] ពាក្យនេះជាការហៅមិនចំនួវពាក្យហ្វ្រង់ Franc ពោលគឺសំដៅយកពួកអឺរ៉ុប ពីព្រោះចាប់តាំងពីមានសង្គ្រាមដណ្ដើមយកទីក្រុងសេរុយសាឡិម ពីពួកមុលស៊ុយម៉ង់ និងមានការបង្កើតរដ្ឋប៉ាឡេស្ទីន នៅឆ្នាំ១០៩៩មក ពួកអ្នកចុងបូព៌ាប្រទេសស្គាល់ពួកអឺរ៉ុបដូច្នេះ ។

ទៀតហើយ ទ្រង់ក៏បានដាក់រាជសម្បត្តិថ្វាយព្រះរាជបុត្រាទៅ ។

ព្រះរាជបុត្រានេះ ថ្វីបើចូលចិត្តការសប្បាយបន្តិចមែន តែទ្រង់អង់អាចក្លាហានណាស់ ។ ទ្រង់មិនបង្អែបង្អង់ទេ គឺបានបញ្ជាឲ្យកេណ្ឌទ័ព រួចទ្រង់ចូលប្រយុទ្ធប្រៀបដូចរាជសីហ៍ ។ ការប្រយុទ្ធមានរយៈពេល២ថ្ងៃ ទីបញ្ចប់ ពួកព័រទុយហ្គេមានប្រៀបជាង[៣១] ។ ស៊ុលតង់អាហ៍មេដ ត្រូវរបួស បានគេចព្រះកាយមុនដំបូងទៅនៅប៉ាកូ រួចបានយាងឡើងស្ទឹងទៅគង់នៅប៉ាណារីហ្គង់ រួចក្រោយពីព្រះបិតាយាងទៅដល់ បានយាងទៅប៉ាហាង ដែលជានគរសាមន្តរាជមួយ ។ ទៅដល់ទីនោះ ស្តេចទាំង២បានបែកផ្លូវគ្នា ម៉ាមូដបន្តធ្វើដំណើរទៅកាន់កោះប៊ីនតាង ឯ ស៊ុលតង់អាហ៍មេដ ជាមួយនឹងរាជបរិពារ បានកសាងទីក្រុងកូពេហ៍ឡើង ។ ដោយត្រូវនាម៉ឺនសព្វមុខមន្ត្រី ដែលហែហមមិនពេញចិត្តនឹង ស៊ុលតង់ ព្រោះអាកប្បកិរិយាមើលងាយមើលថោករបស់ព្រះអង្គ ព្រះបិតាបានឲ្យគេធ្វើឃាតស៊ុលតង់ចោល ហើយទ្រង់បាននាំរាជបរិពារមួយចំនួនបន្តដំណើរទៅកសាងរាជាណាចក្រហ្សូហ៊រ ។ ជាមួយគ្នានោះ ទ្រង់បានធ្វើការប្រយុទ្ធជាមួយពួកព័រទុយហ្គេបន្តទៀត ។

មួយរយឆ្នាំក្រោយមក គឺពីហ្សូហ៊រ និងរដ្ឋអាចេ នេះឯង ដែលពួកចាមមកពីឥណ្ឌូចិនបង្កើតឡើង ដោយមានកងទ័ពចេញមកវាយបំបាក់អំណាចរបស់ពួកព័រទុយហ្គេនៅម៉ាឡាកា ដណ្តើមអំណាចប្រគល់ឲ្យពួកហុល្លង់វិញ ។

ពួកព័រទុយហ្គេដណ្តើមយកម៉ាឡាកាបាននៅឆ្នាំ១៥១១ ដូច្នេះរាជាណាចក្រនេះមានអាយុបាន១៣៦ឆ្នាំ ។

## ៨- ឥណ្ឌូ និងអ្នកកាន់សាសនាអ៊ីស្លាម

យើងបានឃើញពីខាងលើរួចមកហើយថា ក្រោយពីដណ្តើមយកនគរពែក្សបានហើយ ពួកអារ៉ាប់បានបែងចែកទឹកដីនេះជាច្រើនក្សត្រប្រទេសអ៊ីស្លាម ហើយក្សត្រប្រទេសនីមួយៗបានទាមទារឯករាជ្យពីអធិរាជ នៅបាកដាដ មួយម្តងៗ ។ យើងក៏បានឃើញផងដែរថា ចាប់តាំងពីសតវត្សរ៍ទី៧មក ពួកនេះបានចូលមកដល់ប្រទេសឥណ្ឌូភាគខាងជើង ហើយបានតាំងទីលំនៅ នៅទីនោះ ក្រោយពីបានកម្ចាត់អាណាចក្រស្ស៊ីតចេញ ។

ការលុកលុយរបស់ពួកអារ៉ាប់នេះនៅមានបន្តជាប់មកទៀតនៅក្នុងសតវត្សរ៍ទី៨ ទី៩ និងទី១០ ដែលបានធ្វើឲ្យរដ្ឋស៊ីន រលត់រលាយអស់ទៅ បើទោះជាថាមិនបានកសាងអ្វីក៏ដោយ ។ ក្នុងចន្លោះពេលប៉ុន្មានសតវត្សរ៍នេះ មានតែការបំផ្លិចបំផ្លាញមកលើឥណ្ឌូ ធ្វើឲ្យចុះក្រទៅៗ រីឯពែក្សវិញកាន់តែម្សូរសប្បាយឡើងៗ ។ ទីបញ្ចប់ ការលុកលុយអស់កាល៨ឆ្នាំរបស់ម៉ាមូដខាន់ ជាស្តេចនៃនគរហ្គាសណា ពីឆ្នាំ៩៩២ដល់ឆ្នាំ១០០០ បានបន្សល់ទុក

---

[៣១] នៅក្នុងសង្គ្រាមនេះ ពួកព័រទុយហ្គេ បានទទួលការគាំទ្រពីនាយសំពៅចិន ៥នាក់ ដែលចតសំពៅនៅក្នុងកំពង់ផែ ។

នូវអានុភាពវីរិយ៍ដ៏ល្បីរដូវចត់មិនអាចលុបចេញពីសន្តានចិត្តរបស់ប្រជាជនបានឡើយ ។

បន្ទាប់ពីមានជ័យជម្នះមកលើព្រះរាជានៃមហារាជទាំងឡាយ ដែលជាម្ចាស់លើក្សត្រប្រទេសសាមន្តរាជមួយចំនួន ក្នុងនោះមានក្សត្រប្រទេសដៃល្វី, អាជមែរ, កាណូជ និងកាលិងហ្គុង រួចមកម៉ាមូដក៏ចាប់តាំងទីលំនៅរឹងមាំស៊ប់តែម្តងនៅក្នុងប្រទេស រួចបែងចែកប្រទេសជាស៊ូបាបី និងជាណាបាបី ហើយត្រួតត្រាពួកហិណ្ឌូយ៉ាងតឹងរ៉ឹង ធ្វើឲ្យពួកនេះនៅមានការចងចាំសេសសល់រហូតដល់សព្វថ្ងៃ ។

ម៉ាមូដបានកសាងសន្តតិវង្សមួយ ដែលមានអាយុចំនួន១៥០ឆ្នាំ រហូតដល់ឆ្នាំ១១៥២ ទើបមានស្តេចនគរហ្គូរ មួយអង្គ ដែលបានប្រកាសខ្លួនថា ជាបច្ចាញាតិរបស់ស្តេចពែក្សហ្សូរ៉ាសពីអតីតកាល មកដណ្តើមយកអំណាចបាន ។ ស្តេចហ្គ័រនេះមានព្រះនាមថា កាស៊ីន បានតាំងព្រះរាជធានីនៅឡាហ៊រ ។ ព្រះរាជាដែលសោយរាជ្យបន្តពីព្រះអង្គបានលុកលុយចូលប៉េនហ្សាប រួចបន្ទាប់ពីបានឈ្នះសង្គ្រាមដ៏ធំមួយនៅថានេសារ ហើយបន្តលុកលុយចូល ដៃល្វី, កាណូជ រួចបានបន្តការវាយប្រហារទៅឆ្ងាយហួសពីនោះទៅទៀត ដែលមិនដែលមានកាលពីក្នុងរជ្ជកាលសន្តតិវង្សមុនៗ ។ នៅឥណ្ឌាភាគខាងត្បូងរដ្ឋដែលដណ្តើមបានមានកាណារ៉ា, ប៊ីសណាហ្គារ, រាជាណាចក្រមូលតង់ ។ ចំណែកនៅភាគកណ្តាលវិញ មានរាជាណាចក្របេណារ៉េស ។ ក៏ប៉ុន្តែនៅឆ្នាំ១២១៥ ស្តេចហ្គ័រ បានត្រូវគេធ្វើឃាត អាណាចក្រទាំងមូលក៏ត្រូវបែកខ្ញែក រួចធ្លាក់ក្នុងកណ្តាប់ដៃឧត្តមសេនីយ៍របស់ព្រះចៅអធិរាជចុងក្រោយមានសញ្ជាតិអាហ្វហ្គានីស្ថាន ឬប៉ាតង់ គូទូប ដែលបានប្រកាសខ្លួនជាព្រះចៅអធិរាជនៅរាជធានីដៃល្វី ។

គឺនៅពេលនោះហើយដែលមានលេចពួកតាកតារ-ម៉ុងហ្គោល របស់ ហ្សង់ហ្ស៊ីខាន់ ចេញមក ។ ពួកនេះបានរាតត្បាតពែក្ស, អ៊ីរ៉ង់, ហ្គាសណាដែលកាលនោះគេហៅថាដារ៉ុលម៉ាស្ក ១២២២), កង់ដាហារ រួចបានមកបោះទ័ពនៅពីមុខរាជធានីដៃល្វី ស្រាប់តែមិនដឹងជាដោយហេតុអ្វី ក៏ដកចេញភ្លាមពីឥណ្ឌាដោយនាំយកជ័យភណ្ឌយ៉ាងច្រើនទៅជាមួយផង បែរទៅលុកលុយ ម៉ូស្គូវី និងប្រទេសចិនវិញ ។

អាស្រ័យដោយចិត្តសាវ៉ារបស់ពួកម៉ុងហ្គោលបែបនេះ អាណាចក្រប៉ាតង់ ឬអាហ្វហ្គានីស្ថាន ក៏បានរួចខ្លួនពីការបំផ្លិចបំផ្លាញទៅ ហើយរាជធានីដៃល្វីក៏ដូច្នោះដែរ ។

ចំណែកប្រទេសឥណ្ឌាព្រហ្មញ្ញនិយមវិញ ដោយត្រូវបរាជ័យ ត្រូវគាបសង្កត់ បន្ទុចបន្ទាក់ក្នុងជំនឿសាសនា ក៏ចាប់ប្រគល់ខ្លួនឲ្យពួកអ្នកឈ្នះសង្គ្រាមបន្តិចម្តងៗ ហើយគ្មានគំនិតប្រមែប្រមូលគ្នាប្រឆាំងទប់ទល់នឹងពួកអ្នកឈ្លានពានវិញទេ ។ ចាប់ពីពេលនោះមក គេសង្កេតឃើញថានគរដ៏ធំនេះត្រូវបើកចំហសម្រាប់អ្នកឈ្លានពានបរទេសជានិច្ច ហើយចាញ់គេជានិច្ច ។

ពេលនោះ ពួកមូស្លីម កាន់កាប់ឥណ្ឌាភាគខាងជើង នគរពែក្ស អេហ្ស៊ីប និងប៉ៃកាត ហើយនិងដែយកាតទាំង អស់នៅអាហ្វ្រិកខាងជើង ។ ប្រទេសអេស្ប៉ាញក៏ត្រូវចំណុះពួកនេះដែរ លើកលែងតែអារ៉ាហ្គុង កាស្ទីយ ខាង

ជើង និងកាតាឡូញប៉ុណ្ណោះ ។ ពួកមូស្លីមក៏បានដណ្តើមយកអាស៊ីមីន័រពីអាណាចក្របូព៌ាផងដែរ ហើយរាជធានីកុងស្តង់ទីណូបត្រូវធ្លាក់ខ្លួនភ័យញ័រយ៉ាងខ្លាំង ពេលឃើញពួកនេះបង្ហាញខ្លួននៅក្បែរៗនោះ ។ សង្គ្រាមរំដោះរបស់ពួកហ្វ្រង់ពីឆ្នាំ១០៩៥ដល់ឆ្នាំ១០៩៩ និងការបង្កើតរដ្ឋមួយនៅហ្សេរុយសាឡិម, សង្គ្រាមរំដោះរបស់ក្រុមចម្រុះហ្វ្រង់ អង់គ្លេស និងអាល្លឺម៉ង់ ពីឆ្នាំ១១៤៥ដល់១១៤៩ និងពីឆ្នាំ១១៨៩ដល់១១៩២, សង្គ្រាមរំដោះរបស់ពួកហ្វ្រង់ នៅហ្សេរុយសាឡេម ជាមួយនឹងពួកហុងគ្រី ពី១២១៩ដល់១២២១ ហើយនិងសង្គ្រាមរំដោះ២លើករបស់ហ្វ្រង់ ពីឆ្នាំ១២៤៨ ដល់១២៧០ បានជួយពន្យារពេលមិនឲ្យកុងស្តង់ទីណូបឆាប់ធ្លាក់ចូលក្នុងដៃពួកមូស្លីម ក៏ប៉ុន្តែ ការដណ្តើមយកអាណាចក្របូព៌ាដោយពួកហ្វ្រង់ ដែលលើកមេរបស់ពួកគេម្នាក់ធ្វើជាអធិរាជនៅប៊ីហ្សង់ ក្នុងឆ្នាំ១២០៩ ព្រមជាមួយការកសាងអាណាចក្រឡាតាំងមួយនៅបូព៌ា មិនមែនជាការពង្រឹងរដ្ឋមួយដែលមានទីតាំងនៅមុខគេ និងមានអំណាចខាងស្មារតី សម្រាប់ការពារអឺរ៉ុប និងគ្រិស្តសាសនា ប្រឆាំងទប់ទល់នឹងពួកមូស្លីម នោះទេ ។

នៅពេលដែលព្រឹត្តិការណ៍ធំៗទាំងឡាយប្រព្រឹត្តទៅយ៉ាងដូច្នេះ ដែលធ្វើឲ្យពិភពលោកមួយចំណែកធំ ធ្លាក់ចូលក្នុងកណ្តាប់ដៃពួកអារ៉ាប់ គឺពួកអ្នកកាន់សាសនាអ៊ីស្លាម ហើយតាមរយៈប្រទេសឥណ្ឌា បានតភ្ជាប់ពួកអារ៉ាប់និងពែក្សទៅនឹងចុងបូព៌ាប្រទេស អំណាចរបស់ព្រហ្មញ្ញសាសនានៅឥណ្ឌាបានចាប់ថយចុះជាខ្លាំង ។ នៅតាមទីក្រុង ពួកហិណ្ឌូមួយចំនួនធំដែលភ័យខ្លាច បានប្រែចូលកាន់សាសនាថ្មី ។ វិហារដែលគេបានកសាងឧទ្ទិសថ្វាយព្រះសិវៈ ព្រះវិស្ណុ ក្រឹស្នៈ ។ល។ បានត្រូវគេវាយរំលំចោល ហើយពួកអ្នកឈ្នះបានយកសម្ភារទាំងនោះទៅកសាងវិហារមូស្កេវិញ ។ ចំណែកពួកព្រាហ្មណ៍ដែលនៅបន្តស្មោះគោរពបូជាព្រហ្មញ្ញសាសនា ដែលរងការធ្វើបាបពីពួកអ្នកដែលជឿលើ «ព្រះអាទិទេពតែមួយ គ្មានអ្នកណាប្រៀបផ្ទឹម» ក៏បានរត់គេចចេញពីឥណ្ឌាភាគខាងជើងទៅរកទីកន្លែងណាដែលសុខជាង នៅឯចុងខាងត្បូងរបស់ឧបទ្វីបវិញ ។

ជ័យជម្នះរបស់ពួកហ្វ្រង់ទៅលើពួកអារ៉ាប់ បានល្បីសុះសាយទៅពាសពេញចុងបូព៌ាប្រទេស ធ្វើឲ្យបុព្វបុរសរបស់ពួកហ្វ្រង់នេះ ដែលបានបង្កើតរដ្ឋមួយនៅប៉ាឡេស្ទីន ក្បែរៗនឹងទីកន្លែងដែលជាដើមកំណើតរបស់មហាម៉ាត់ មានកិត្តិនាមតែម្នាក់ឯងតំណាងអឺរ៉ុបទាំងមូល ហើយដែលអ្នកចុងបូព៌ាប្រទេសហៅថា ហ្វារ៉ង់ហ្គី ។ ពេលនោះ នៅលើពិភពលោក គេស្គាល់តែពួកអារ៉ាប់ និងពួកបារាំង ប៉ុណ្ណោះ ។ នៅអាស៊ីគេមិនបានដឹងច្បាស់ទេថាមានប្រជាជនខុសៗគ្នាយ៉ាងណានៅអឺរ៉ុបនោះទេ គេដឹងតែថាមានពួកហ្វារ៉ង់ហ្គីមួយប៉ុណ្ណោះ ដែលខ្មែរហៅថាបារាំង ថាជាប្រជាជនអង់អាចក្លាហាន ដណ្តើមជោគជ័យ និងធ្វើឲ្យពួកអារ៉ាប់ខ្លបខ្លាចបាន ។

ក៏ប៉ុន្តែ នៅឯចុងបូព៌ាប្រទេសឯណោះវិញ នៅពេលដែលទ័ពពែក្សដណ្តើមយកប្រទេសឥណ្ឌាភាគខាងជើងឲ្យប្រែចូលកាន់សាសនាអ៊ីស្លាម និងបង្កើតបានជាមហាណាចក្រម៉ុងហ្គោល ស្មារតីផ្សព្វផ្សាយសាសនារបស់ពួកនេះបានជ្រាបចូលមកដល់ស្រុករបស់ពួកម៉ាឡេ ។ នៅដើមសតវត្សរ៍ទី១៣ មានរាជា២អង្គ ដែលទើបតែបាន

កសាងរដ្ឋសាម៉ាឡង់ បានប្រែចូលកាន់សាសនាថ្មីនេះ ។

រហូតដល់ចុងសតវត្សរ៍ទី១៣ក្បូត្រប្រទេសម៉ាឡេស៊ីរតែទាំងអស់បានកាន់សាសនាអ៊ីស្លាម ហើយក៏មានអ្នកជឿជាច្រើនលាននាក់ទៀតដែរនៅឯស្រុកចិន ។ នៅអាស៊ីប៉ែកអាគ្នេយ៍ កម្ពុជា និងចាម្ប៉ាក៏បោះបង់អាទិទេពចាស់ចោលដែរ ។ ព្រហ្មញ្ញសាសនាបានរលត់បាត់អស់ទៅយ៉ាងឆាប់រហ័ស នៅអាំងស៊ុយឡាំង ហើយមានសេសសល់ជំនឿចាស់តែនៅតាមស្រុកស្រែប៉ុណ្ណោះ ។

នៅគ្រប់ទីកន្លែងដែលអ្នកស្រុកកាន់សាសនាថ្មីនេះ តែងតែមានសង្គ្រាមជានិច្ច សង្គ្រាមនេះនាំឲ្យមានការដូរចូលកាន់សាសនានេះទាំងហ្វូងៗ ។ សាសនានេះជាទីពេញចិត្តរបស់ជាតិសាសន៍ដែលអង់អាចក្លាហានបំផុត ពីព្រោះថាគេបានធ្វើឲ្យដាវរបស់គេប្រឡាក់ទៅដោយឈាមដើម្បីព្រះអាទិទេព ម្យ៉ាងទៀត ពីព្រោះការដណ្ដើមយកឥណ្ឌាដោយពួកអ្នកកាន់សាសនាមហាម៉ាត់បានធ្វើឲ្យរញ្ជួយអាស៊ីទាំងមូល និងពីព្រោះសាសនាថ្មីនេះ សាមញ្ញស្រួល មិនពិបាកនឹងប្រតិបត្តិទេចំពោះអ្នកដែលចូលថ្មី គឺគ្រាន់តែត្រូវទន្ទេញឲ្យចាំថា «មានអាទិទេព តែមួយអង្គគ្មាននរណាប្រដូចបាន ហើយមហាម៉ាត់គឺជាទូតរបស់ព្រះអង្គ» ។ ដើម្បីថ្វាយបង្គំព្រះ គេគ្រាន់តែធ្វើការគោរពដោយបែរមុខទៅទិសខាងលិចតម្រង់ទៅរកទីក្រុងឡាមិច ដែលមានផ្នូររបស់ទូតព្រះតែប៉ុណ្ណោះ ។ បណ្ដាស្ដេចទាំងឡាយបានបោះបង់ព្រះឋានៈពីព្រះរាជាមកជាស៊ុលតង់វិញ បើពុំនោះប្រើពាក្យទាំង២ភ្ជាប់គ្នាតែម្ដង ។ ទ្រង់ឈប់ប្រើអក្សរសំស្ក្រឹត ដែលគេសរសេរពីឆ្វេងទៅស្ដាំទៀតហើយ ហើយបែរមកប្រើអក្សរអារ៉ាប់ ដែលសរសេរពីស្ដាំមកឆ្វេងវិញម្ដង ។ គេទទួលយកគម្ពីរកូរ៉ង់ជាច្បាប់សម្រាប់ពូជអ្នកចម្បាំង ដែលចេញធ្វើសង្គ្រាមរំដោះពិភពលោកទាំងមូលពីដៃពួកក្បត់ ពោលគឺ ពួកអ្នកដែលមិនជឿមហាម៉ាត់ ។

ទោះជាយ៉ាងណាក្ដី នៅពេលដែលសាសនាអ៊ីស្លាមអាចដណ្ដើមបានពួកម៉ាឡេទាំងអស់ សាសនានេះមិនអាចទទួលជោគជ័យមកលើប្រជាជនដែលមានសញ្ជាតិហិណ្ឌូឬឥណ្ឌូចិន បានទេ ។ កម្ពុជា សៀម លាវ ភូមាបានបោះបង់ព្រហ្មញ្ញសាសនាចោល ប៉ុន្តែបានត្រឹមត្រលប់មកកាន់ពុទ្ធសាសនាវិញតែប៉ុណ្ណោះ ។ អាណ្ណាមតុងកឹង ក៏មិនបណ្ដោយខ្លួនឲ្យលង់តាម ហើយនៅរក្សាទស្សនវិជ្ជារបស់កុងហ្វ៊ូយសឺដដែល នៅគោរពជីដូនជីតា និងប្រតិបត្តិពិធីពុទ្ធសាសនាលាយឡំជាមួយសាសនាតាវ ។

យើងនឹងបានឃើញថាមានស្ដេចខ្មែរមួយអង្គនៅក្នុងសតវត្សរ៍ទី១៧ ដែលបានប្រកាន់យកព្រះនាមថាជាអ៊ីប្រាហ៊ីម ហើយដូរចូលកាន់សាសនាមហាម៉ាត់ យកពួកចាម និងម៉ាឡេជាបរិពារ ហើយស្វះស្វែងរកចងសម្ព័ន្ធមេត្រីជាមួយស្ដេចចាម ដែលមើលងាយមើលថោកព្រះអង្គ តែត្រូវសុគតទៅ ដោយមិនបាននាំ ប្រជារាស្ត្រ មន្ត្រី និងរាជវង្ស ឲ្យអនុវត្តតាមព្រះអង្គផងទេ ។ ស្ដេចមួយអង្គនោះ ប្រវត្តិសាស្ត្រខ្មែរ បានដាក់ព្រះនាមឲ្យថាជា «ស្ដេចចេញសាសនា» ឬ«ស្ដេចចូលសាសនាជ្វា» ។

# ក្បាលទី២
# ប្រទេសកម្ពុជាតាមរាជពង្សាវតារ និងឯកសារប្រវត្តិសាស្ត្រផ្សេងទៀត

## ជំពូកទី១
## ប្រទេសកម្ពុជាចាប់ពីឆ្នាំ១៣៥០ រហូតដល់ការបែកបន្ទាយលង្វែក

### ១- ព្រះបាទនិព្វានបទ (១៣៤០-១៣៤៦)

តាចាយ ដែលនាម៉ឺនសព្វមុខមន្ត្រីបានជ្រើសតាំងឲ្យសោយរាជ្យលើរាជបល្ល័ង្កកម្ពុជា និងជាអ្នកកសាងសន្តតិវង្សមហាក្សត្រខ្មែរបច្ចុប្បន្ន បានសុគតទៅនៅក្នុងឆ្នាំ១៣៤០ ។ បើតាមការនិទានតៗគ្នា តាមរឿងព្រេងនិងរាជពង្សាវតារ គឺព្រះរាជបុត្រច្បងរបស់ព្រះអង្គព្រះនាមថាព្រះបាទសម្តេចព្រះបរមនិព្វានបទ[១] ជាមួយព្រះអគ្គមហេសីដែលត្រូវជាព្រះរាជបុត្រីរបស់ព្រះបាទសីហនុរាជ ដែលទ្រង់បានរៀបអាពាហ៍ពិពាហ៍ ដើម្បីឲ្យមានចំណងទាក់ទងជាប់ជាមួយសន្តតិវង្សមុន បានឡើងសោយរាជ្យបន្តពីព្រះអង្គ ។

រាជពង្សាវតារនិយាយថាព្រះបាទនិព្វានបទទ្រង់គង់នៅឯឥន្ទបត្តមហានគរ[២] គឺអង្គរធំសព្វថ្ងៃ ហើយទ្រង់សោយរាជ្យសម្បត្តិដោយសុខសន្តិភាពជាមួយប្រទេសជិតខាង មានស្រុកលាវ សៀម និងអាណ្ណាម ។ យើងអាចបន្ថែមបានទៀតថា ជាមួយនគរចាម្ប៉ាផងដែរ ។

ព្រះអង្គសោយរាជ្យបាន៥ឆ្នាំ ហើយសុគតនៅក្នុងឆ្នាំ១៣៤៦ ។

### ២- ព្រះសិទ្ធានរាជា (១៣៤៦)

ព្រះអនុជរបស់ព្រះបាទនិព្វានបទ ព្រះនាមសម្តេចព្រះសិទ្ធានរាជាបានត្រូវគេជ្រើសរើសឲ្យឡើងសោយរាជ្យសម្បត្តិបន្តពីព្រះអង្គ[៣] ដោយទុកព្រះរាជបុត្រ២អង្គដោយឡែក ក៏ប៉ុន្តែព្រះអនុជនេះបានចូលទិវង្គត ៦ខែក្រោយមក ដោយមិនទាន់ទាំងបានទទួលការអភិសេកផង ។ ការជ្រើសរើសព្រះរាជាបែបនេះប្រហែលជាប្រព្រឹត្តទៅតាមទម្លាប់ ដែលមាននៅសេសសល់រហូតមកដល់សព្វថ្ងៃ គឺច្បាប់ស្នងរាជ្យចាស់បុរាណ ដែលតម្រូវឲ្យព្រះអនុជសោយរាជ្យបន្តពីព្រះរៀម ច្បាប់នេះមានបញ្ហាជាច្រើននៅស្រុកសៀម និងស្រុកភូមា ។

---

[១] តាមមើលទៅព្រះនាមនេះ សមតែជាព្រះមរណនាមទៅវិញទេ ។

[២] មានន័យថា ព្រះរាជធានីរបស់ព្រះឥន្ទ្រ ។

[៣] ឯកសារមួយនោះនិយាយថាទ្រង់សោយរាជ្យបានតែ៤ខែទេ ។

យើងនឹងបានឃើញខាងក្រោមនេះថាព្រះភាគិនេយ្យ ពោលគឺបុត្ររបស់ព្រះរៀម ឡើងសោយរាជ្យបន្តពីព្រះបិតុលា ។ ដោយហេតុនេះខ្ញុំសន្និដ្ឋានថា អ្វីដែលគេចង់បាននោះ គឺព្រះរាជាមួយអង្គជ្រើសរើសចេញពីរាជវង្សជិតបំផុតនឹងព្រះរាជា ដែលមានព្រះជន្មចាស់សមល្មមក្នុងការដឹកនាំ និងគួរឲ្យគេគោរពបាន ។

## ៣- ព្រះស្រីលំពង្សរាជា (១៣៤៧-១៣៥១)

អត់ពីព្រះសិទ្ធានរាជាទៅ សេនាសព្វមុខមន្ត្រី បានជ្រើសរើសព្រះរាជបុត្រច្បងរបស់ព្រះនិព្វានបទអភិសេកឲ្យឡើងសោយរាជ្យបន្តក្រោមព្រះនាមថា ព្រះបាទសម្តេចព្រះរាជឱង្ការព្រះលំពង្សរាជាធិរាជ និងតែងតាំងព្រះរាជបុត្រប្អូនព្រះនាមថា ព្រះសុរិយោទ័យ ឲ្យធ្វើជាឧបរាជ ។ ព្រះរាជា និងព្រះឧបរាជបានចាត់ចែងឲ្យគេរៀបចំពិធីបូជាសពព្រះវររាជបិតា និងព្រះបិតុលា រួចហើយរើសព្រះអដ្ឋិធាតុដាក់ក្នុងកោដ្ឋមាស តម្កល់ទុកក្នុងព្រះចេតិយ ។

នៅសម័យនោះ ប្រទេសសៀមដែលធ្លាប់តែចំណុះខ្មែរពីមុន បានឯករាជហើយ ។ ឯកសាររាជពង្សាវតារបាននិយាយថា ពួកសៀមនេះបានទទួលសេរីភាពនៅក្នុងរាជ្យព្រះបាទបទុមសុរិយោវង្ស ដែលខ្ញុំគិតថា គឺព្រះបាទសុរិយាវរ្ម័នទី២ ដែលសោយរាជ្យក្នុងឆ្នាំ១១៦២ ដោយទ្រង់ជាប់រវល់នឹងគ្រប់គ្រងក្សត្រប្រទេសជាច្រើន នៅភាគខាងជើង ។

នៅពេលដែលព្រះសុរិយោវង្ស ឬសុរិយាវរ្ម័ន សុគតទៅ មានបុរសមានអំណាច និងពូកែឆ្លាតវៃម្នាក់ឈ្មោះថា ពញារោង បានឡើងសោយរាជ្យនៅសុខោទ័យ ហើយបានបង្រួបបង្រួមរដ្ឋសៀមទាំងអស់ ដែលស្ថិតនៅក្នុងអាងទន្លេមេណាម ដាក់មកក្នុងអំណាចរបស់ខ្លួន ធ្វើឲ្យសុខោទ័យក្លាយទៅជារាជាណាចក្រដ៏ខ្លាំងមួយ ។

ម្យ៉ាងទៀត ស្តេចលាវនៅឈៀងរៃ[៤] ក្រោយពីត្រូវវាយឲ្យបរាជ័យដោយស្តេចនគរជិតខាងមួយអង្គ ក៏បាននាំប្រជានុរាស្ត្រចុះមករួមរស់ជាមួយសុខោទ័យ[៥] ហើយបង្រួបបង្រួមបច្ចាញាតិរបស់ពញារោងទាំងអស់មកក្នុងអំណាចរបស់ខ្លួនវិញ និងបានមកតាំងរាជធានីនៅកំផែងពេជ្រ[៦] ដ៏ធំទូលាយ ។ បច្ចាញាតិរបស់ព្រះអង្គបានសោយរាជ្យសម្បត្តិដោយសុខសាន្ត តៗគ្នាដល់ទៅ៤ជំនាន់ ។

---

[៤] សៀងរ៉ៃ គឺសៀងហៃសព្វថ្ងៃ ស្ថិតនៅលើខ្សែរយៈទទឹង១៩អង្សា៥០ក្នុងអឌ្ឍគោលខាងជើង និងខ្សែរយៈបណ្តោយ ៩៧អង្សា ១០ ខាងកើត នៅលើដៃមួយនៃទន្លេមេគង្គ ពីខាងជើងរដ្ឋសាន ។

[៥] នៅលើមាត់ទន្លេមេណាមខាងស្តាំ ត្រង់ខ្សែរយៈទទឹង១៧អង្សាខាងជើង និងខ្សែរយៈបណ្តោយ៩៧អង្សា៣០ខាងកើត ។

[៦] ស្ថិតនៅលើមាត់ទន្លេមេពីងខាងឆ្វេង ចម្ងាយ៤០គីឡូម៉ែត្រពីខាងពាយ័ព្យសុខោទ័យ ។

ក្រោយនោះ មានអ្នកស្រុកម្នាក់ឈ្មោះថា សេនាបូម បានឡើងសោយរាជ្យនៅរដ្ឋលាវមួយជាប់នឹងសុខោទ័យ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍ជាមួយព្រះរាជក្សត្រីរបស់នគរនោះ ។ ទ្រង់បានកសាងរាជធានីក្រុងទេព[៧] រួចបានយកព្រះឋានៈជាព្រះចៅសេរីវិជ័យជាងសែន[៨] ហើយសោយរាជ្យបាន២០ឆ្នាំ ។

រាជបុត្ររបស់ព្រះអង្គព្រះនាមថាខទងដែលសោយរាជ្យបន្តពីព្រះអង្គ បានកសាងរាជធានីនៅណង់ស្នោ ហើយដាក់ឈ្មោះឲ្យថា ក្រុងទេពមហានគរបវរធិរាជវតីស្រីអយុធ្យា ដែលក្រោយមកបានត្រួតត្រាលើនគរតូចធំចំនួន១៦ ។ ក្រោយពីបានកសាងរាជធានីថ្មីនេះរួច ព្រះខទងខ្លួនព្រះអង្គក៏ដូរព្រះឋានៈទៅជាព្រះចៅរាមាធិបតីព្រះចៅក្រុងស្រីអយុធ្យា[៩] វិញ ។

ការតាំងរាជធានីអយុធ្យានៅលើកោះណង់ស្នោ ក្នុងអាងទន្លេមេណាម បានធ្វើឲ្យសៀមមានរាជធានីខិតមកជិតព្រំប្រទល់ដែនខ្មែរ ជាហេតុធ្វើឲ្យជាតិសាសន៍ទាំង២ដែលមានកម្លាំង តែមានផលប្រយោជន៍ផ្សេងៗគ្នា ចាប់មានការប៉ះទង្គិចនឹងគ្នាដោយចៀសមិនរួច ។ ការដែលសៀមកសាងរាជធានីអយុធ្យា នៅកៀកមកក្បែរនឹងរាជធានីឥន្ទបត្តយ៉ាងដូច្នេះ ជាការបញ្ជាក់ច្បាស់ថា ព្រះរាជាណាចក្រកម្ពុជានៅក្នុងសតវត្សរ៍ទី១៤ នោះបានចុះខិនថយទៅហើយ គ្មានសត្រូវណាខ្លបខ្លាចទៀតទេ ព្រោះថាគេមិនខ្លាចរអានឹងមកនៅក្បែរនោះឡើយ ផ្ទុយទៅវិញ ពួកសៀមនេះបានប្រាកដខ្លួនថា អង់អាច និងកាចសាហាវ ។

---

[៧] មានន័យថារាជធានីរបស់ទេវតា តាមមើលទៅប្រហែលគឺមឿងទេពសព្វថ្ងៃ នៅលើមាត់ទន្លេមេង្គនខាងឆ្វេង ។

[៨] ពាក្យខ្មែរថាចៅ សៀម និងលាវថាឆាវ ចិនថាចូបូ សានថាសូបូ អាណ្ណាមថាជាវ ប៊ីរម៉ានថាសាបូ មានន័យថាស្តេច ឬអង្គម្ចាស់ ក្រោយមកគេប្រើសម្រាប់ហៅមន្ត្រីដែលមិនមានជាប់សាច់រាជវង្សផងដែរ ។ គឺចេញពីពាក្យនេះហើយៗរួមផ្សំជាមួយពាក្យដែលប៊ីរម៉ង់ថាអ្ហូ មានន័យថាក្បាល មេឬប្រធាន សៀមថាហ្វូ ខ្មែរថាហ្វា ដែលកើតបានជា ពាក្យថាចៅហ្វ៊ា គឺនាយករដ្ឋមន្ត្រីចៅហ្វាយស្រុក ។ ពាក្យភូមាថា ចាបួ មានន័យថា ស្តេចបរទេសដែលចំណុះ ។ ពាក្យ សាន ថា ចូបូ ឬសូបូ ក្លាយចេញមកពីពាក្យដើមនេះដែរ ។

ពាក្យសៀមថាហ្វូ ប៊ីរម៉ានថាបួ ខ្មែរថាហ្វា លាវថាវ៉ា ប្រើភ្ជាប់ជាមួយពាក្យកែវ មានន័យថាមានតម្លៃ បានជាពាក្យកែវហ្វ៊ាជាឋានៈមួយរបស់រាជវង្សបន្ទាប់ពីឋានៈឧបរាជ ។

[៩] បើតាមការរៀបរាប់នេះ អយុធ្យាដែលជារាជធានីរបស់សៀមពីឆ្នាំ១៣៥០ដល់១៧៦៨ មិនមែនកសាងឡើងដោយស្តេចមកពីសុខោទ័យដែលជាបច្ចាញាតិរបស់ព្រះរោងទេ គឺកសាងដោយស្តេចសៀងសែនមួយអង្គមានដើមកំណើតជារាស្ត្រសាមញ្ញ ដែលបានសោយរាជ្យនៅក្សត្រប្រទេសមួយនៅក្នុងអាងទន្លេមេណាមខាងលើ ។ ក្សត្រប្រទេសនោះមានរាជធានីដំបូងនៅកំដែងពេជ្រ កសាងឡើងដោយស្តេចលាវមួយអង្គ ដែលស្តេចនគរជិតខាងបានបង្ខំឲ្យដកថយគេចព្រះអង្គមកខាងត្បូង ។ ខ្ញុំគិតថាវាគ្មានអ្វីជាប្លែកទេ បើសិនជាថ្ងៃណាមួយគេរកឃើញថា ស្តេចដែលមានជ័យជម្នះនោះគឺជាស្តេចថៃមួយអង្គ មកពីប្រទេសភូមាជាមួយនឹងប្រជារាស្ត្រថៃ ។

សង្គ្រាមដែលធ្លាប់មានតាំងពីច្រើនសតវត្សរ៍ណាស់មកហើយជាមួយពួកមន ដែលរស់នៅត្រង់ទឹកដីសៀមសព្វថ្ងៃនេះមុនពួកសៀមទៅទៀត បានចាប់ផ្ដើមឡើងសាជាថ្មីជាមួយការកសាងរាជធានីអយុធ្យា ដោយព្រះខុទងរបស់ថៃ និងព្រះលំពង្សរាជារបស់ខ្មែរ ។

បើតាមរាជពង្សាវតារខ្មែរដែលខ្ញុំមានក្នុងដៃ នៅក្នុងឆ្នាំ១៣៥២ ស្ដេចសៀមបានសម្រេចពង្រីកទឹកដីដោយដណ្ដើមយកកម្ពុជាដែលព្រងើយកន្តើយមិនព្រមទទួលស្គាល់អធិរាជភាពរបស់ខ្លួន[១០] ។ ស្ដេចសៀមបានរៀបចំទ័ពជា២កង កងទី១មានពលរេហ៍៥ពាន់នាក់ស្ថិតនៅក្រោមបញ្ជារបស់ព្រះរាជនត្តាព្រះនាមថា ស៊ីសាវ៉ាត់ កងទី២ មានពល១ម៉ឺននាក់ស្ថិតនៅក្រោមបញ្ជាការរបស់ព្រះរាជបុត្ររាមាសួន រួចទ្រង់បានបញ្ជាឲ្យធ្វើដំណើរទាំងថ្ងៃទាំងយប់មកវាយយកព្រះរាជាណាចក្រកម្ពុជា ។

ពេលនោះ អាជ្ញាធរខ្មែរនៅតាមជាយដែនមិនបានគិតថាសៀមនឹងចូលមកលុកលុយកម្ពុជាទេ ម៉្លោះហើយមិនបានត្រៀមខ្លួននឹងធ្វើការទប់ទល់ឡើយ ក៏នាំគ្នាដកថយគេចចេញជាមួយគ្រួសារពីមុខទ័ពសៀម តែបានចាត់អ្នកនាំសារឲ្យនាំដំណឹងពីការលុកលុយនេះមកថ្វាយព្រះរាជាដែលគង់នៅឯរាជធានីឥន្ទបត្តបុរី ។ អ្នកនាំសារបានមកដល់មហានគរហើយបានចូលគាល់ព្រះរាជាពេលថ្ងៃត្រង់ ព្រះលំពង្សរាជាបានបញ្ជាឲ្យព្រះអនុជ សុរិយោទ័យជាព្រះឧបរាជកេណ្ឌទ័ព២ម៉ឺននាក់ក្នុងបណ្ដាប្រជារាស្ត្រក្នុង និងជិតៗរាជធានី ហើយចេញរៀបចំតទល់នឹងទ័ពសៀម ។ ចេញព្រះរាជបញ្ជារួច ទ្រង់បានយាងទៅកាន់សាលសវនាការ ជួបជុំនាម៉ឺនសព្វមុខមន្ត្រីរបៀបជាក្រុមប្រឹក្សាសង្គ្រាមមួយ រួចបានលើកសំណួរឡើងថា «ព្រះរាជាណាចក្ររបស់យើងមានសុខសន្តិភាពជាយូរមកហើយ យើងមិនដែលមានហ្វឹកហាត់កងទ័ពទេ ស្រាប់តែឥឡូវពួកសៀមលើកទ័ពមកវាយយើងយ៉ាងនេះ តើអស់លោកយល់ថាដូចម្ដេចដែរ ? » ។

ព្រះឧបរាជបានឆ្លើយតបទៅវិញថា «ទ័ពសៀមប្រាកដជាមានការនឿយហត់ដោយត្រូវធ្វើដំណើរទាំងយប់ទាំងថ្ងៃចាប់ពីទល់ដែនមក ព្រោះចង់មកដល់ឆាប់នឹងអាលវាយយើង ទាំងយើងមិនបានដឹងខ្លួន ។ ពួកនេះប្រមាថមើលងាយខ្មែរ គិតថាយើងមិនចេះធ្វើចម្បាំង ហើយជឿថាយើងមិនចេះការពារខ្លួនទេ ។ ចំណែកទ័ពរបស់យើង ថ្វីបើថាមិនធ្លាប់បានហ្វឹកហ្វឺនមែនពិត តែជាទ័ពថ្មី មិនទាន់អស់កម្លាំង ហើយមានចេតនាចង់ប្រយុទ្ធ» ។ មានបន្ទូលដូច្នេះហើយ ទ្រង់បានសុំការអនុញ្ញាតពីព្រះរាជាចេញដំណើរ ដើម្បីទប់ទល់នឹងទ័ពសៀមឲ្យបានឆ្ងាយពីរាជធានីបន្តិច ត្រង់កន្លែងដែលពួកនេះកំពុងបោះទ័ព ។

---

[១០] រាជពង្សាវតារសៀមនិយាយថា ស្ដេចសៀមបានប្រកាសសង្គ្រាមឡើង ដោយមកពីពួកខម គឺខ្មែរ ព្រហើនបែរខ្នងដាក់មិនព្រមគោរព ។

ព្រះរាជាបានចេញព្រះរាជបញ្ជាតាមសំណើ ព្រះឧបរាជដែលគង់លើដំរី បានយាងចេញដំណើរទាំងយប់នោះ ។ ទ័ពខ្មែរមានចែកចេញជាទ័ពសេះ ទ័ពដំរី និងទ័ពថ្មើរជើង ។ ទ័ពសៀមមិនបានគិតថា ខ្មែរចេញវាយមុនដូច្នេះទេ ក៏ត្រូវបរាជ័យ ហើយព្រះអង្គម្ចាស់ស៊ីសារ៉ាត់ក៏ត្រូវធ្វើគុតនៅលើកដំរីទៅ ។ ចំណែកទ័ពខ្មែរ ដោយរវល់តែសប្បាយរីករាយនឹងជ័យជម្នះ ក៏មិនបានគិតដេញតាមទ័ពរបស់ព្រះរាមាសួន[១១] ដែរគឺ បណ្ដោយទុកឲ្យពួកនេះវិលត្រលប់ទៅវិញបាត់ទៅ ។ ទ័ពខ្មែរត្រលប់ចូលមកកាន់ឥន្ទបត្តវិញប្រមូលបានជ័យភណ្ឌជាច្រើន មានតាំងពីសេះដំរី និងឈើយសឹកផង ។

ក្រោយពីទទួលបានដំណឹងអំពីបរាជ័យ និងមរណភាពរបស់ព្រះរាជនត្តាស៊ីសារ៉ាត់ ស្ដេចសៀមបានបញ្ជាឲ្យកេណ្ឌទ័ពជាច្រើនបន្ថែមទៀត ដោយដាក់ក្រោមបញ្ជារបស់ព្រះអនុជថ្លៃព្រះនាមថាបរមរាជា និងចែកទ័ពជាបីកងស្ថិតនៅក្រោមបញ្ជារបស់រាជបុត្រទាំង៣ (ឬព្រះអនុជ ក៏មិនដឹង) របស់ព្រះរាមាសួន គឺចៅបាសាធ, ចៅបាអាត និងចៅកំបង់ពិសី ។ ទ័ពទាំងអស់នេះចេញដំណើរពីអយុធ្យាមកជួបជាមួយទ័ពរបស់ព្រះរាមាសួនរួចហើយនាំគ្នា បោះជំរំនៅចម្ងាយពីព្រំប្រទល់ដែនសៀមខ្មែរប្រហែលដើរ ពីរ-បីថ្ងៃ ដោយថ្មើរជើង ។

ពេលនោះ ព្រះរាជាកម្ពុជា ដែលយល់ថាបរាជ័យលើកនេះមិនអនុញ្ញាតឲ្យសៀមវិលត្រលប់មកធ្វើសង្គ្រាមវិញទៀតបាន ក៏បញ្ជាឲ្យរំសាយកងទ័ពចេញ និងឈប់ធ្វើកំណែនផ្សេងៗតទៅទៀត ទុកតែទ័ពរក្សាព្រះអង្គប៉ុណ្ណោះ ។ ដល់ពេលសៀមលើកទ័ពចូលមកម្ដងទៀត ទ្រង់បានបញ្ជាឲ្យកេណ្ឌកងទ័ពឡើងវិញដែរ តែព្រះរាជបញ្ជាមុនឲ្យរំសាយទើបតែផ្សព្វផ្សាយចេញមិនទាន់ផុតផង ម្ល៉ោះហើយក៏គ្មានកម្លាំងទប់ទល់នឹងទ័ពសៀម ដ៏ច្រើនលើសលប់ ជាងទ័ពដែលព្រះឧបរាជបានវាយឲ្យបរាជ័យទៅទៀត ។ ទ្រង់បានសម្រេចឲ្យទប់ទល់ តែក្នុងបរិវេណព្រះរាជធានីសិន ទម្រាំចាត់កម្លាំងឲ្យចេញកេណ្ឌទាហានជាថ្មីបាន ។ អ្នកស្រុកដែលរស់នៅជាយរាជធានីឥន្ទបត្តបានរត់ចូលមកជ្រកកោនក្នុងរាជធានី ដែលមានរៀបចំកំពែងដាក់កម្លាំងការពារយ៉ាងរឹងមាំ ។

ព្រះរាជាទ្រង់បានរៀបចំប្រជុំក្រុមប្រឹក្សាសង្គ្រាមនៅក្នុងសាលសវនាការ ហើយប្រកាសប្រាប់អង្គប្រជុំថា ទ័ពសៀមលើកមកលើកនេះច្រើនជាងពីឆ្នាំមុន១០ដង ឯព្រះរាជាណាចក្រគ្មានកម្លាំងទ័ពទេ ។ ក្រោយពីព្រះអង្គ សណ្ដាប់ព្រះយោបល់របស់ព្រះមហាឧបរាជសុរិយោទ័យ និងយោបល់របស់សេនាបតី មន្ត្រី ទ្រង់ក៏ចាត់ព្រះភាគិនេយ្យរបស់ព្រះអង្គ ព្រះស្រីសុរិយោវង្ស ជារាជបុត្ររបស់ព្រះសុគន្ធបទ និងត្រូវជាព្រះរាជនត្តារបស់ព្រះនិព្វានបទ ឲ្យយាងចេញកេណ្ឌកងទ័ពតាមបណ្ដាខេត្រ យកមកជួយរាជធានី ។

បីថ្ងៃក្រោយមក ទ័ពសៀមក៏មកបង្ហាញខ្លួននៅពីមុខរាជធានីឥន្ទបត្តបុរី ហើយចាប់ផ្ដើមធ្វើការវាយ

---

[១១] មានន័យថា "ស្ថានសួគ៌របស់ព្រះរាមា" ឬ "ច្បារដំណាំរបស់ព្រះរាមា" ក្នុងន័យថាស្ថានសួគ៌ដែរ ។

ប្រហារ ។ ព្រះរាមាសួនវាយទ័ពពីខាងជើង ចៅបាសាធនៅពីខាងកើត ចៅបាអាតនៅពីខាងត្បូង និងចៅកំបង់ពិសីនៅពីខាងលិច ។ ទ័ពសៀមបានសាកល្បងវាយជាច្រើនលើក តែឥតប្រយោជន៍ ព្រោះកំពែងរាជធានីរឹងមាំ មានគូទឹកធំ និងជ្រៅព័ទ្ធជុំវិញ ចំណុចត្រង់ណាមានស្ពានសុទ្ធតែមានទាហានការពារម៉ឺងម៉ាត់ និងយាមកាមតាមជញ្ជាំងកំពែងទាំងថ្ងៃទាំងយប់ទៀតផង ។

ពេលនោះព្រះចៅក្រុងកម្ពុជា ដែលពោរពេញទៅដោយសេចក្តីក្លាហាន បានដឹកនាំទ័ពផ្ទាល់ព្រះអង្គ ចេញវាយទ័ពសៀម ។ ការប្រយុទ្ធបង្ហូរឈាមបានប្រព្រឹត្តទៅយ៉ាងសាហាវ ប៉ុន្តែមិនមានទ័ពណាមានជ័យជម្នះលើទ័ពណាទេ ព្រះលំពង្សរាជាក៏យាងចូលមកក្នុងរាជធានីវិញនៅពេលល្ងាច ។

ប៉ុន្មានថ្ងៃក្រោយមក ព្រះរាមាសួនបានចាត់ឲ្យកសាងប្រាង្គខ្ពស់ៗជាច្រើន ប្រហាក់ប្រហែលនឹងកម្ពស់កំពែងអន្គរធំដែរ ដើម្បីងាយស្រួលក្នុងការបាញ់កាំភ្លើង[១៧] ចូលក្នុងរាជធានី និងដើម្បីចៀសវាងការខូចខាត ។

ទ័ពខ្មែរ និងសៀមច្បាំងគ្នារបៀបនេះអស់ពេល៤ខែ ចាប់ពីខែធ្នូ ឆ្នាំ១៣៥២ រហូតដល់ចុងខែមីនា ឆ្នាំ១៣៥៣ តែគ្មាននរណាឈ្នះនរណាទេ ។ ពេលនោះព្រះលំពង្សរាជាបានផ្ញើរាជសារមួយច្បាប់ឲ្យទៅឧត្តម-សេនីយ៍សៀមសួរថា «កម្ពុជាជាមហាណាចក្រមួយធំ ឯសៀមគ្រាន់តែនគរតូចមួយចំណុះកម្ពុជាប៉ុណ្ណោះ ។ សៀមបានឯករាជ្យ យើងក៏មិនចង់រំខាន ព្រោះមិនចង់មានសត្រូវ ។ តើហេតុអ្វីក៏សៀមបញ្ជូនទ័ពមកវាយ កម្ពុជាសូមប្រាប់ឲ្យយើងដឹងអំពីមូលហេតុផង» ។

ឧត្តមសេនីយ៍សៀមឆ្លើយមកវិញថា បើកម្ពុជាយល់ព្រមទទួលស្គាល់អធិរាជភាពរបស់ស្តេចសៀមនោះ គេនឹងដកទ័ពថយទៅវិញទាំងអស់ ។

---

[១៧] កាំភ្លើង=កាំ (គ្រាប់)+ភ្លើង ។ ត្រូវដឹងថាអ្នកចុងបូព៌ាប្រទេសបានស្គាល់ និងប្រើប្រាស់រំសេវជាច្រើនសតវត្សរ៍ណាស់មកហើយ មុនពួកអឺរ៉ុបមានកាំភ្លើងធំតាំងពីសតវត្សរ៍ទី១៤ ហើយខ្មែរបានស្គាល់អាវុធនេះយូរហើយ ។ នៅក្នុងឆ្នាំ១៣៩៨ ពួកតាមែរឡង់ បានប្រើកាំភ្លើងធំនៅក្នុងសង្គ្រាមដណ្តើមទឹកដីរបស់ពួកហិណ្ឌូ ហើយនៅអង្គរធំមានកន្លែងមួយមានឈ្មោះថា «ឃ្លាំងគ្រាប់កាំភ្លើង» ។

លោក វ៉ូស៊ីយុស បានអះអាងថា ចិនមានកាំភ្លើងធំធ្វើអំពីសំរឹទ្ធ និងដែកតាំងពីឆ្នាំ១០៥៥ ហើយចេះធ្វើគ្រាប់បែកតាំងពីឆ្នាំ១២៣២ ដែលអាចសម្លាប់មនុស្សដែលស្ថិតនៅក្នុង រង្វង់១០ម៉ែត្របាន ។

ឈាវតាក្វាន់ បាននិយាយថា នៅក្នុងឆ្នាំ១២៩៥ នៅអង្គរធំមានគេចេះធ្វើកាំជ្រួច និងផាវ កាំជ្រួចខ្លះហោះខ្ពស់អាចឲ្យគេមើលឃើញបានពីចម្ងាយ៤០គីឡូម៉ែត្រ កាំជ្រួចខ្លះទៀតធំ ដូចដុំថ្មហើយផ្ទុះលាន់រំពង ធ្វើឲ្យរញ្ជួយទូទាំងរាជធានី ។

អ្នកនិពន្ធខ្លះបាននិយាយអំពីការប្រើប្រាស់កាំភ្លើងធំដោយសូលីម៉ាន ក្នុងការវាយយកទីក្រុងបែលក្រាដនៅឆ្នាំ១០៧៣ និងដើម្បីការពារទីក្រុងសេវីលនៅឆ្នាំ១២៨៧ ។ ហើយវាប្រាកដណាស់ថា មេរបស់ពួកម័រឈ្មោះថា អ៊ីស្មាអែល បានវាយយកទីក្រុងបេហ្សា របស់អេស្ប៉ាញ នៅក្នុងឆ្នាំ១៣២៥ ដោយសារប្រើកាំភ្លើងដែរ ។

ព្រះរាជាខ្មែរបានឆ្លើយតបទៅវិញថា ទ្រង់សុខចិត្តស្លាប់ជាជាងចុះចូល ដែលនឹងធ្វើឲ្យយើងបាត់បង់អស់នូវកិត្តិនាម ខ្មាសប្រជានុរាស្ត្រ ។ ទ្រង់ក៏យាងចេញត្រួតពលផ្ទាល់ព្រះអង្គ ហើយប្រកាសថា នឹងទប់ទល់រហូតដល់ទីបញ្ចប់ ។ ចំណែកឯទ័ពសៀមវិញ ក៏បានបង្កើនការប្រហារព្រមទាំងបានខិតខំពង្រឹងការការពារផងដែរ ។

រដូវវស្សាមកដល់ មេទ័ពសៀមបានផ្ញើសារទៅថ្វាយស្តេចគេ ទូលថាបើចង់ដណ្តើមយកកម្ពុជា ត្រូវចាប់វាយសង្គ្រុបខ្លាំងឥឡូវនេះ ឲ្យបានមុនពេលដែលទ័ពជំនួយពីខែត្រមកដល់ ។ ស្តេចសៀមឯកភាពនឹងសំណើនេះ ក៏កេណ្ឌទ័ពបន្ថែមហើយ លើកមកផ្ទាល់ព្រះអង្គ រហូតដល់ជើងកំពែងឥន្ទបត្តបុរីតែម្តង នៅចុងរដូវវស្សា ។

ពេលនោះព្រះអង្គម្ចាស់ស្រីសុរិយោវង្ស[១៣] ដែលចេញកេណ្ឌទ័ពអស់ពេល៨ខែហើយ បាននាំទ័ពចូលមកដល់កំពែងរាជធានី ។ ដោយមិនបានរង់ចាំឲ្យទ័ពមកជួបជុំមូលគ្នា ទ្រង់បានដឹកនាំទ័ពមួយកងចូលទៅជិតទ័ពសៀមពេក ដោយមិនដឹងខ្លួន ក៏ត្រូវទ័ពសៀមវាយមកលើក្នុងពេលដែលដកថយផង ធ្វើឲ្យព្រះអង្គបរាជ័យ ទ័ពទាំងឡាយក៏បែកខ្ញែកគ្នាអស់ទៅ ។ ព្រះស្រីសុរិយោវង្សខ្លួនព្រះអង្គបានគេចទៅគង់នៅស្រុកលាវ ក្នុងក្រុងស៊ីសុទ្ធនាគាណាហ៊ុត[១៤] (គឺហ្លួងប្រាបាង ឬវៀងច័ន្ទ?) សព្វថ្ងៃ ប្រហែលដើម្បីបំផុសបំផុលអន្តរាគមន៍ពីខាងត្បូងសានមកវិញ ។

នៅពេលដែលព្រះស្រីសុរិយោវង្សយាងទៅដល់ប្រទេសលាវ ទ័ពឯទៀតៗដែលព្រះអង្គកេណ្ឌបាន បានធ្វើដំណើរមកដល់រាជធានី ហើយទទួលដំណឹងអំពីបរាជ័យ និងការបាត់ខ្លួនរបស់ព្រះអង្គ ធ្វើឲ្យពួកគេអស់សង្ឃឹមជាខ្លាំង ។ ឆ្លៀតឱកាសនោះពួកសៀមក៏បើកការប្រយុទ្ធមកលើ ធ្វើឲ្យទ័ពបែកខ្ញែក រត់ទៅស្រុកវិញអស់ទៅ ។

ឃើញទ័ពខ្មែរបែកខ្ញែកដូច្នេះ ស្តេចសៀមបានបញ្ជាឲ្យបើកការប្រយុទ្ធទៅលើរាជធានី ប៉ុន្តែត្រូវបាត់បង់ទ័ពជាច្រើន និងត្រូវរុញច្រានថយទៅវិញ ។ សៀមនៅបន្តហ៊ុមព័ទ្ធរាជធានីប្រហែលជាមួយឆ្នាំទៀត ប៉ុន្តែនៅតែដណ្តើមមិនបាន គ្រាន់តែប្រមូលបាននូវជ័យភណ្ឌផ្សេងៗតាមខែត្រជិតខាងរាជធានីប៉ុណ្ណោះ ។

ពេលនោះ ព្រះស្រីលំពង្សរាជាធិរាជក៏ធ្លាក់ព្រះអង្គប្រឈួន រហូតដល់សុគតទៅក្នុងឆ្នាំ១៣៥៣ ។ ដូច្នេះព្រះអង្គទ្រង់សោយរាជសម្បត្តិបានបួនឆ្នាំ ក្នុងនោះទ្រង់ចំណាយពេលមួយឆ្នាំដើម្បីធ្វើសង្គ្រាម ។

## ៤- ព្រះឧបរាជស្រីសុរិយោទ័យ (១៣៥៣)

ព្រះឧបរាជស្រីសុរិយោទ័យ ជាព្រះអនុជរបស់ព្រះរាជា ទ្រង់បានរៀបចំទុកដាក់សពព្រះរៀមនៅក្នុងមហាប្រាសាទរង់ចាំឱកាសធ្វើពិធីបូជា រួចចាប់ចាត់ចែងកិច្ចការព្រះនគរ ដោយសម្រេចបន្តធ្វើសង្គ្រាមតទៅទៀត

---

[១៣] ឯកសារខ្លះទៀតនិយាយថា គឺព្រះសុរិយោទ័យទេ ដែលកេណ្ឌទ័ពនេះ ក្រោយមកទ្រង់បានត្រូវលើកឲ្យសោយរាជ្យសម្បត្តិ ។

[១៤] ជួនកាលគេប្រទះឃើញថាគេហៅថា ស៊ីសត្តណាកាហ៊ុត, ស៊ីសត្តណាហ្គាហ៊ុត និងស៊ីសត្តណាខុត្តលាម៉ាចរាត់សាតានី ផងដែរ ។ ឈ្មោះជាភាសាសំស្ក្រឹតគឺ ស្រីសុទ្ធម្មន គិរី សុទ្ធម្មៈនេះគឺជាសាលកាត់ក្តីរបស់ព្រះឥន្ទ្រ ។

ដែលឯកសាររាជពង្សាវតារនិយាយថាគឺជាមហន្តរាយមួយចំពោះព្រះរាជាណាចក្រ ។ រាជពង្សាវតាររៀបរាប់ថា «គេឮសូរតែសំឡេងស្រែកយំរបស់ប្រជារាស្ត្រ ឧត្តមសេនីយ៍ និងមេទ័ពស្លាប់បន្តបន្ទាប់គ្នា សូម្បីតែបក្សាបក្សី ក៏ស្រែកយំស្រណោះរាជធានីដែលខ្មាំងសត្រូវឡោមព័ទ្ធជិតជុំដែរ» ។

ឃើញខ្មែរធ្លាក់ក្នុងក្ដីអស់សង្ឃឹមដូច្នេះ ស្ដេចសៀមបានដាក់បញ្ជាឲ្យចាប់ផ្ដើមការវាយប្រហារម្ដងទៀត «នរណាគេចខ្លួនដកថយក្រោយនឹងត្រូវទទួលទោសប្រហារជីវិត នរណាក្លាហានជ្រៀតចូលក្នុងរាជធានីបាននឹងទទួលបានរង្វាន់» ។

ការប្រយុទ្ធក៏ចាប់ផ្ដើមឡើងយ៉ាងសាហាវឃោរឃៅ ។ ទ័ពសៀមបើកការវាយប្រហារយ៉ាងអង់អាចក្លាហាន ប៉ុន្តែត្រូវទ័ពខ្មែររុញច្រានទម្លាក់ចូលក្នុងគូទឹកវិញអស់ ។ ចុងបញ្ចប់ ទ្វារទិសខាងកើត[១៥] មួយ បានត្រូវសត្រូវវាយបើកបាន ។ ការប្រយុទ្ធបន្តប្រព្រឹត្តទៅយ៉ាងប្ដូរផ្ដាច់នៅលើផ្លូវនៃរាជធានី ហើយព្រះឧបរាជ ដែលដឹកនាំការតស៊ូស្វិតស្វាញនៅមុខកងទ័ពក៏ត្រូវសត្រូវប្រហារបាន ។

មរណភាពរបស់ព្រះឧបរាជរឹតតែធ្វើឲ្យកងទ័ពអស់សង្ឃឹម ទាំងអ្នកដែលធ្លាប់តែក្លាហានក៏គេចខ្លួនអស់ ។ មានតែពួកបារគូព្រាហ្មណ៍ទេ ដែលជាអ្នកថែរក្សាកេតនភណ្ឌរាជានិយមកម្ពុជាតាំងពីបុរាណកាលមក ដោយយល់ថាមិនត្រូវបណ្ដោយឲ្យកេតនភណ្ឌទាំងនោះធ្លាក់ទៅក្នុងដៃសត្រូវទេ ក៏ប្រមែប្រមូលគ្នាជាច្រើនពាន់នាក់ នៅជុំវិញព្រះបរមរាជា, ព្រះធម្មសោករាជ និងព្រាហ្មណ៍បុរោហិតដែលរក្សាព្រះខ័នរាជ្យ, លំពែងរាជ ធ្នូ និងកេតនភណ្ឌឯទៀតៗ បាននាំគ្នាគេចចេញពីរាជធានីជាមួយសេនាសព្វមុខមន្ត្រីមួយចំនួន និងប្រជារាស្ត្រព្រមទាំងគ្រួសារផង ។ ពួកគេវាយសម្រុកទៅលើទ័ពសៀមដែលហ៊ុមព័ទ្ធជុំជិតយ៉ាងអង់អាចក្លាហាន បើកផ្លូវចេញ ត្រូវស្លាប់ បាត់បង់កម្លាំងអស់ជាច្រើន តែអាចរំដោះកេតនភណ្ឌទាំងអស់ដែលជានិមិត្តសញ្ញាជាតិកម្ពុជាបាន ។ នេះគឺជាការប្រយុទ្ធចុងក្រោយ និងជាជ័យជម្នះក្រោយបង្អស់ដែលខ្មែរមានលើទ័ពសៀមនាសម័យនោះ ។

## ៥- ចន្លោះរជ្ជកាលនៃស្ដេចសៀមពាព្រះអង្គ (១៣៥៣-១៣៥៧)

រាជធានីបានធ្លាក់ទៅក្នុងដៃសត្រូវ ហើយស្ដេចសៀមយាងចេញចូលចុះឡើងរបៀបជាអ្នកឈ្នះ ស្ញើចសរសើររាជវាំងដែលសង់ឡើងអំពីថ្ម ប្រកបទៅដោយរូបចម្លាក់ក្បាច់ក្បូររចនា បន្ទប់មួយៗល្អឥតខ្ចោះ ។ ទ្រង់យល់

[១៥] រាជធានីមានគូទឹកធំ និងជ្រៅព័ទ្ធជុំវិញ ពីក្រោមជញ្ជាំងកម្ពស់ជាង១០ម៉ែត្រ ។ មានច្រកចេញចូលជាផ្លូវលំចាក់ដី មានបង្កាន់ដៃជារូបយក្សទ្រនាគរាជមួយ ។ គេការពារច្រក ចេញចូលនេះដោយដាក់ទ័ពនៅលើប្រាង្គខ្ពស់នៅពីលើផ្លូវ និងនៅលើជញ្ជាំងពីខាងឆ្វេង និងខាងស្ដាំ ។ ក៏ប៉ុន្តែគេមិនបានដឹងអំពីការធ្វើស្ពានលើកដាក់បាននោះទេ ម្ល៉ោះហើយ សត្រូវអាចចូលមកដល់ទ្វារ ហើយបុកទម្លុះចូលមកក្នុងបាន ។

ឃើញថា មហានគរល្អមិនចាញ់ស្ថានសួគ៌ពាពជាន់របស់ព្រះឥន្ទ្រប៉ុន្មានទេ ។ នៅពេលដែលទ្រង់យាងចូលទៅក្នុងព្រះបរមរាជវាំង ប្រទះឃើញសពព្រះលំពង្សរាជា ក៏កើតក្តីសង្វេគជាខ្លាំង ទើបទ្រង់ចេញបញ្ជាឲ្យរៀបចំពិធីបូជាថ្វាយឲ្យសក្តិសមនឹងទំនៀមទម្លាប់បុរាណ ។

ក្រោយពិធីបូជាសពនេះ ស្តេចសៀមបានលើកព្រះរាជបុត្រពៅព្រះនាមចៅបាសាធឲ្យសោយរាជ្យលើរាជបល្ល័ង្កកម្ពុជា ហើយបញ្ជាឲ្យព្រះរៀម២អង្គទៀត គឺចៅបាអាត និងចៅកំបង់ពិសី នៅជួយកិច្ចការព្រះអនុជជាមួយនឹងកងទ័ពចំនួន១ម៉ឺននាក់ ដើម្បីការពាររាជធានី[១៦] ។

បន្ទាប់មក ក្រោយពីទ្រង់បានតែងតាំងចៅហ្វាយខែត្រសៀមឲ្យគ្រប់គ្រងខែត្របស្ចិម និងនគររាជសីមា ហើយចែករង្វាន់លើកទឹកចិត្តដល់ពួកអ្នកអង់អាចក្លាហានរួចមក ទ្រង់បានចេញបញ្ជាឲ្យនាំប្រជារាស្ត្រ ដែលរស់នៅក្នុងរាជធានីទាំងអស់ យកទៅស្រុកសៀម លើកលែងតែរាស្ត្រប្រមាណជា១ម៉ឺននាក់[១៧]ប៉ុណ្ណោះ ដោយយកទាំងទ្រព្យសម្បត្តិក្នុងរាជវាំង ជាមាសប្រាក់ ជារបស់មានតម្លៃផ្សេងៗដូចជាកន្ទេលមាស កន្ទេលប្រាក់ សេះ ដំរី រាជរថ ជាដើមទៅជាមួយផង ។

ចៅបាសាធទ្រង់បានតែងតាំងចៅហ្វាយខែត្រសៀម និងខ្មែរឲ្យរៀបចំការដឹកនាំខែត្រឡើងវិញ ហើយឲ្យទៅបង្ក្រាបខែត្រដែលមិនទាន់ទទួលយល់ព្រមចំណុះ ។ ចៅហ្វាយខែត្រទាំងអស់នោះអាចរៀបចំបានតែបណ្តាខែត្រជិតៗរាជធានីប៉ុណ្ណោះ ឯខែត្រឆ្ងាយៗនៅខាងកើត ខាងជើង និងខាងត្បូងមិនព្រមចំណុះទេ ។ ចៅហ្វាយខែត្រទាំងនោះប្រកាសខ្លួនឯករាជ ហើយចាប់ផ្តើមប្រព្រឹត្តអំពើចោរកម្ម និងចម្បាំងរវាងគ្នានឹងគ្នា ធ្វើឲ្យប្រជាជនធ្លាក់ក្នុងទុរភិក្សយ៉ាងធ្ងន់ធ្ងរ ។ ពេលនោះ ព្រះស្រីសុរិយោវង្ស យាងត្រលប់ពីស្រុកលាវមកវិញជាមួយទ័ពមួយកង និងឈ្លើយសឹកប្រមាណ៩ម៉ឺននាក់ ដែលទ្រង់ដណ្តើមបានពីសៀម ពេលកំពុងកៀរពីឥន្ទបត្តទៅកាន់នគររាជ ។ ទ្រង់បានប្រមូលបណ្តាខែត្រដែលមិនចំណុះសៀមមកក្នុងអំណាចរបស់ព្រះអង្គវិញដោយ ឆាប់រហ័ស ។

ព្រះចៅបាសាធសោយទិវង្គតនៅក្នុងឆ្នាំ១៣៥៥ ត្រូវនឹងមហាសករាជ១២៧៧ ចុល្លសករាជ៧១៧ ក្រោយពីទ្រង់សោយរាជ្យបាន៣ឆ្នាំ ។

ព្រះរៀមរបស់ព្រះអង្គ ចៅបាអាត ដែលឡើងសោយរាជ្យបន្តបាន៣ខែ ក៏សុគតទៅទៀត ដោយជំងឺ

---

[១៦] យើងបានឃើញពីខាងលើថារាជពង្សាវតារបាននិយាយថា ព្រះអង្គម្ចាស់ទាំង៣ព្រះអង្គត្រូវជាចៅរបស់ព្រះរាមាសួន មិនមែនជាបុត្រទេ ។ តែខ្ញុំគិតថាប្រហែលជាមានការភ័ន្តច្រឡំនៅទំព័រមុន ដែលត្រូវនិយាយថា “ទ័ពទាំង៣កងបានត្រូវប្រគល់ឲ្យបងប្អូនទាំង៣របស់ព្រះរាមាសួន” មិនមែនឲ្យចៅរបស់ព្រះអង្គទេ ។

[១៧] តាមរាជពង្សាវតារ ចំនួនប្រជាជនពេលនោះមានប្រហែលជា១០ម៉ឺននាក់ ប៉ុណ្ណោះ ។

អាសន្នរោគ ។ ពេលនោះ ព្រះស្រីសុរិយោវង្ស បានដណ្ដើមយកបណ្ដាខែត្រដែលចុះចូលជាមួយសៀមបានមកវិញហើយ ។

ចៅកំបង់ពិសី ជារាជបុត្រច្បងរបស់ស្ដេចសៀម បានឡើងសោយរាជ្យបន្តពីព្រះអនុជ នៅក្នុងឆ្នាំ ១៣៥៧[១៨] ។

មួយខែក្រោយមក ព្រះស្រីសុរិយោវង្សបានលើកទ័ពមកវាយដណ្ដើមយករាជធានីបានវិញ ហើយរាជពង្សាវតារនិយាយថា ទ័ពសៀម៩ភាគ១០បានត្រូវគេកាប់សម្លាប់ ។ ចៅកំបង់ពិសីទ្រង់បានបាត់ខ្លួនក្នុងពេលនោះទៅ ហើយគ្មាននរណាដឹងថា ទ្រង់ក្លាយទៅជាយ៉ាងណានោះទេ ។

ចាប់ពីពេលនោះមក ព្រះរាជាណាចក្របានត្រូវរំដោះ ហើយកសាងឡើងវិញ តែខែត្របស្ទិម[១៩] និងនគររាជសីមា នៅជារបស់សៀមនៅឡើយ ។

## ៦- ព្រះស្រីសុរិយោវង្ស (១៣៥៧-១៣៦៦)

ព្រះស្រីសុរិយោវង្ស ក្រោយពីច្បាំងដណ្ដើមយកបណ្ដាខែត្រដែលឯករាជមិនព្រមចំណុះសៀម និងវាយសៀមឲ្យបរាជ័យរួចមក ក៏ត្រូវបានគេលើកឲ្យសោយរាជសម្បត្តិក្រោមព្រះអភិសេកនាមថា ព្រះបាទសម្ដេចព្រះរាជឱង្ការព្រះស្រីសុរិយោវង្សរាជាធិរាជ[២០] ។ ទ្រង់បានចាត់ចែងចែករង្វាន់ដល់នាយទាហានទៅតាមកិច្ចការដែលបានបំពេញ រួចបានតែងតាំងនាម៉ឺនសព្វមុខមន្ត្រីឲ្យកាន់កិច្ចការព្រះនគរ ។

---

១៨ រាជបុត្រច្បងរបស់ស្ដេចសៀមគឺព្រះខទងរាមា ឬរាមាសួន ដែលយើងបានឃើញដឹកនាំទ័ពសៀមមកវាយខ្មែរ ហើយបានឡើងសោយរាជ្យបន្តពីព្រះបិតានៅក្នុងឆ្នាំ១៣៦៩ ។ តាមមើលទៅព្រះចៅបាសាត ដែលព្រះខទង លើកឲ្យសោយរាជ្យនៅកម្ពុជាជាបុត្រព្រះរាជាទី៤, ចៅបាអាតជារាជបុត្រទី៣ ហើយចៅកំបង់ពិសីជារាជបុត្រទី២ ។

១៩ ខែត្របស្ទិម សព្វថ្ងៃគឺប្រាជីម ស្ថិតនៅលើផ្លូវពីអង្គរធំទៅអយុធ្យា ត្រង់ខ្សែរយៈទទឹង១៤អង្សាខាងជើង និងខ្សែរយៈបណ្ដោយ៩៩អង្សាខាងកើត ។

២០ ទ្រង់ជារាជបុត្ររបស់ព្រះបាទស្រីសុរិយោទ័យជាមួយព្រះរាជអគ្គមហេសី ពេលឡើងសោយរាជ្យ ទ្រង់មានព្រះជន្ម៤៣ព្រះវស្សាហើយ ។ អត្ថបទខាងដើមនិយាយថា ទ្រង់ជារាជបុត្ររបស់ព្រះសុគន្ធបទ និងត្រូវជាចៅរបស់ព្រះនិព្វានបទ, បើសិនជាដូច្នោះមែន ទ្រង់ត្រូវជាចៅក្មួយរបស់ព្រះស្រីសុរិយោទ័យ ពីព្រោះថា ព្រះសុគន្ធបទ ជាបុត្ររបស់ព្រះនិព្វានបទ ហើយព្រះសុរិយោទ័យ ជាបុត្ររបស់ព្រះសិទ្ធានបទ ។ ប៉ុន្តែបើសិនជាព្រះស្រីសុរិយោវង្សមានព្រះជន្ម ៤៣ព្រះវស្សានៅពេលឡើងសោយរាជសម្បត្តិ គេពិបាកនឹងទទួលស្គាល់ថាទ្រង់ត្រូវជាបុត្រមហាខបរាជស្រីសុរិយោទ័យណាស់ ព្រោះទ្រង់ត្រូវជាព្រះអនុជរបស់ព្រះសិទ្ធានដែលសុគតនៅឆ្នាំ១៣៤៦ ហើយខ្លួនព្រះអង្គឯង សុគតនៅក្នុងឆ្នាំ៣៥២ ។ តែរឿងនេះអាចថាពិតបាន បើសិនណាជាទទួលស្គាល់ថា ព្រះសិទ្ធាន និងព្រះលំពង្សរាជា ឡើងសោយរាជ្យមានវ័យចំណាស់ៗទៅហើយ ។

មានរាជពង្សាវតារមួយនោះនិយាយថា ក្នុងរជ្ជកាលរបស់ព្រះរាជាអង្គនេះ ព្រះរាជាណាចក្រកម្ពុជា មានព្រំប្រទល់ខាងកើតដល់ដុងណាយ ត្រូវនឹងខែត្របារាជសព្វថ្ងៃ គឺជាប់នឹងនគរចាម្ប៉ា ហើយព្រំប្រទល់ខាងលិចលាតសន្ធឹងទៅដល់នាងរោងអង្គររាជ នៅអាគ្នេយ៍ខែត្រកូរ៉ាត់សព្វថ្ងៃ ខាងត្បូងទល់នឹងឈូងសមុទ្រសៀម ខាងជើងទៅទល់នឹងស្អាមខ្សាច់គោកខាន់ ពោលគឺ វាលខ្សាច់គោកខាន់ ។

ព្រះរាជវង្សានុវង្សបានត្រូវប្រមែប្រមូលឡើងវិញ ពួកព្រាហ្មណ៍បុរោហិតក៏បាននាំយកកេតនភណ្ឌមកវិញដែរ ព្រះស្រីសុរិយោវង្ស បានតែងតាំងក្មួយព្រះអង្គ បុត្ររបស់ព្រះស្រីសុរិយោទ័យ ដែលសុគតក្នុងសង្គ្រាមជាមួយសៀម ជាឧបរាជ ។

បន្ទាប់មក ទ្រង់បានបញ្ជូនទ័ពមួយកងឲ្យទៅកាន់កាប់ខែត្រនាងរោង នៅពីខាងត្បូងសាននគររាជសីមា យកទីនោះជាព្រំប្រទល់ដែនព្រះនគរខាងជើង ឯខែត្រ២ទៀតដែលស្ដេចសៀមខទង[២១] ឬព្រះចៅរាមាធិបតីដណ្ដើមបាន នៅតែជារបស់សៀមដដែល ។

នាពេលនោះពួកសៀមមានជំនឿលើខ្លួនឯងខ្លាំងណាស់ ហើយមើលទាបមើលថោកខ្មែរដែលខ្លួនបានវាយឲ្យបរាជ័យ ធ្វើឲ្យខ្មែរទ្រាំទ្រការព្រហើននេះដោយលំបាក ។ ដោយហេតុនោះហើយបានជានៅពេលដែលពួកសៀមចូលចាប់ខ្មែរប្រមាណជា១០០នាក់ នៅក្នុងខែត្រជាយដែនជាប់នឹងមាត់សមុទ្រនាំយកទៅស្រុកសៀម ចៅហ្វាយខែត្រនោះ បានសងសឹកដោយចូលចាប់ពួកសៀមហើយនាំយកមកដាក់នៅចុងខែត្រខាងត្បូងវិញ ។ ចៅហ្វាយខែត្រសៀមខឹង បានកេណ្ឌទ័ព២ពាន់នាក់ធ្វើដំណើរមកកាន់ទល់ដែន ។ ពេលទទួលបានដំណឹងនេះ ព្រះរាជាខ្មែរបានចេញបញ្ជាឲ្យកេណ្ឌទ័ព៥ម៉ឺននាក់ពីក្នុងខែត្រទ្រាំង, បាសាក់, ព្រះត្រពាំង, អូរម៉ូល, ក្រមួនស, ទឹកខ្មៅ, ពាម, កំពត និងកំពង់សោម[២២] ចេញទៅទប់ទល់ ។ មេទ័ពធំគឺស្ដេចត្រាញ់ដែលជាចៅហ្វាយខែត្រទ្រាំង ឯមេទ័ពស្រួច គឺចៅហ្វាយខែត្របាសាក់ ។

ទ័ពសៀមត្រូវបរាជ័យតាំងតែពីពេលជួបប្រយុទ្ធជាមួយទ័ពខ្មែរមុនដំបូង ហើយនៅក្នុងការដេញតាម ខ្មែរបានដណ្ដើមយកវាលធំ និងខែត្ររយ៉ង, ចន្ទគាប៊ុន, មង្គលបុរី[២៣] ហើយបាននាំយកឈ្លើយ៨ពាន់គ្រួសារមកកាន់

---

[២១] រាជពង្សាវតារសៀមថែងថាស្ដេចនេះមិនមែនជាប្អូនថ្លៃរបស់ព្រះខទងទេ តែគឺជាបុត្រាទី២ ។

[២២] បាសាក់សព្វថ្ងៃគឺឡុងសៀង, អូរម៉ូលជាចំណែកមួយនៃស្រុកសុកត្រាំង, ក្រមួនសជាចំណែកមួយនៃស្រុកឡុងសៀង, ទឹកខ្មៅជាចំណែកមួយនៃស្រុករ៉ាជយ៉ា, ឯពាម កំពត និងកំពង់សោមស្ថិតនៅមាត់ឈូងសមុទ្រសៀម ។

[២៣] ខែត្រទាំង៣នេះ ស្ថិតនៅលើទឹកដីដែលលាតសន្ធឹងពីមាត់ឈូងសមុទ្របាងកករហូតមកដល់ខែត្របាត់ដំបង និងពីភ្នំដងរែករហូតដល់ឈូងសមុទ្រសៀម ។ តាមមើលទៅ ខែត្រទាំង៣នេះពេលនោះលែងជាទឹកដីកម្ពុជាទៀតហើយ ប្រហែលជាបានផ្ដាច់ចូលទៅសៀមក្នុងសម័យសង្គ្រាមមុន និងនៅពេលដែលស្ដេចសៀមសោយរាជ្យនៅឥន្ទបត្ត ។

កម្ពុជាវិញ ។

ក្រោយជ័យជម្នះនេះ ព្រះរាជាបានចែករង្វាន់ដល់អ្នកដែលមានស្នាដៃ ហើយបានចេញបញ្ជាឲ្យចៅហ្វាយខែត្រទាំងតូចទាំងធំប្រញាប់ប្រញាល់កេណ្ឌទ័ព ហ្វឹកហាត់ឲ្យបានស្ទាត់ជំនាញ និងត្រៀមខ្លួនជានិច្ច ដោយបារម្ភខ្លាចសៀមត្រលប់មកវាយប្រហារទៀត ។

ពេលនោះត្រូវចំពេលដែលស្តេចសៀមវិលត្រលប់មកពីឈៀងម៉ៃវិញ ដោយនាំយកលាវជាច្រើនគ្រួសារមកជាមួយផង ដល់ទទួលដំណឹងអំពីជ័យជម្នះរបស់ទ័ពខ្មែរមកលើទ័ពសៀម ទ្រង់ក៏ចាត់ឲ្យពញាពិជ័យដារ៉ុងដឹកនាំទ័ពនាំមុខចេញលុកលុយកម្ពុជា ឯព្រះអង្គនាំទ័ពធំមកតាមក្រោយ ។ សៀមដណ្តើមយកខែត្រទាំង៤នៅទិសនិរតី ដែលខ្មែរទើបយកបានមកវិញយ៉ាងឆាប់រហ័ស រួចបន្តធ្វើដំណើរចូលមកក្នុងកម្ពុជាទៀត តែត្រូវទ័ពខ្មែរក្រោមការដឹកនាំរបស់ព្រះឧបរាជបានវាយកាត់ត្រឹមស្ពានញែក ។ ការប្រយុទ្ធចាប់ផ្តើមឡើងជាដំបូង រវាងទ័ពព្រះឧបរាជ ជាមួយទ័ពពញាពិជ័យដារ៉ុង ប្រយុទ្ធអស់ពេលជាច្រើនថ្ងៃដោយគ្មានចាញ់ឈ្នះ ស្រាប់តែទ័ពស្តេចសៀមមកដល់ទ្រង់បញ្ជាឲ្យឡោមព័ទ្ធទ័ពខ្មែរ ។ ដោយឃើញទ័ពសៀមរាយចាក់មកចំហៀងដូច្នេះ ហើយដោយខ្លាចត្រូវគេព័ទ្ធជាប់ផង មេទ័ពខ្មែរក៏បញ្ជាឲ្យដកថយ ឆ្លងស្ពានប្រញិបប្រញាប់ រួចចុះសំពៅចេញទៅ ។ ទ័ពជើងទឹកដែលមានសំពៅជាច្រើនកំពុងចតចាំក្នុងស្ទឹងក៏មិនអាចធ្វើអ្វីបាន ក្រៅតែពីហែហមការពារសំពៅឧបរាជចេញទៅប៉ុណ្ណោះ ។ ចៃដន្យអ្វីស្រាប់តែរំសេវផ្ទុះឡើង ធ្វើឲ្យរបួសព្រះឧបរាជ និងសេនាការពារជាច្រើននាក់[២៤] ។ ឆ្លៀតឱកាសដែលទ័ពខ្មែរកំពុងតែច្របូកច្របល់យ៉ាងនេះ សំពៅសៀមក៏ចូលមកដណ្តើមយកសំពៅឧបរាជធ្វើឲ្យទ្រង់សុគតទៅ៣ថ្ងៃក្រោយមក ។

ពេលទទួលបានដំណឹងស្តីពីបរាជ័យនេះ ព្រះស្រីសុរិយោវង្ស បានដឹកនាំទ័ពផ្ទាល់ព្រះអង្គតែម្តង ចេញមករកទ័ពសៀម ដែលទន់ដៃបន្តិចហើយ មិនហ៊ានប្រឈមមុខនឹងព្រះរាជាទេ ក៏វាយដកថយទៅរកកន្លែងសម្រាក ។ ទ័ពខ្មែរបានតាមដេញប្រកិតពីក្រោយ មិនឲ្យទ័ពសៀមសម្រាកបាន ធ្វើឲ្យសៀមរត់បែកខ្ញែកគ្នាចូលទៅស្រុកសៀមវិញទៅ សល់ខ្លះត្រូវចាប់ខ្លួនបានជាឈ្លើយជាមួយអាវុធយុទ្ធភណ្ឌជាច្រើន ។

បន្ទាប់ពីនោះមក ប្រទេសកម្ពុជាស្គាល់សុខសន្តិភាពបានប៉ុន្មានឆ្នាំដែរ ។ ប្រជារាស្ត្ររស់នៅសុខសប្បាយព្រះរាជាណាចក្រក៏មានសុវត្ថិភាពល្អ ។

ព្រះរាជាណាចក្រកម្ពុជាពេលនោះមានព្រំប្រទល់ខាងលិចទល់នឹងខែត្របស្និម ខាងពាយ័ព្យទល់នឹង ឈៀងរ៉ុង និងនគររាជសីមា ខាងជើងទល់នឹងស្ពានខ្សាច់ ខាងឦសានទល់នឹងគោកខាន់ ខាងអាគ្នេយ៍ទល់នឹង បារាជ

---

[២៤] យើងឃើញថាមាននិយាយអំពីរំសេវម្តងទៀតហើយ លើកនេះប្រហែលជានៅរវាងឆ្នាំ១៣៦០ ។

ដុងណាយ ខាងត្បូងទល់នឹងសមុទ្រ ។

ព្រះស្រីសុរិយោវង្ស បានសុគតដោយរោគាពាធនៅក្នុងឆ្នាំ១៣៦៦ក្រោយពីសោយរាជ្យបាន១០ឆ្នាំ ។

## ៧- ព្រះបរមរាមា (១៣៦៦-១៣៧៣)

អស់ពីព្រះស្រីសុរិយោវង្សទៅ រាជវង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រីបានជ្រើសតាំងព្រះរាជបុត្ររបស់ព្រះលំពង្សរាជាព្រះនាមបរមរាមា ដែលត្រូវជាក្មួយរបស់ព្រះរាជា ឲ្យឡើងសោយរាជ្យបន្ត ។

អ្វីដែលគេបានដឹងអំពីព្រះរាជាអង្គនេះ គឺទី១ទ្រង់បានរៀបចំបូជាសពព្រះបិតុលា និងទី២ទ្រង់សុគតដោយរោគាពាធក្រោយពីសោយរាជ្យបាន៧ឆ្នាំ ។

ចំណែកស្ដេចសៀមវិញ បានសុគតទៅនៅក្នុងឆ្នាំ១៣៦៩ ហើយរាជសម្បត្តិត្រូវធ្លាក់ទៅលើព្រះរាជបុត្រច្បង ព្រះរាមាសួន ដែលសោយរាជ្យមិនដល់មួយឆ្នាំផង ក៏ត្រូវព្រះបិតុលាថ្លៃ ព្រះបរមរាជា ដែលជាស្វាមីរបស់ព្រះអនុជក្សត្រីព្រះរាជា ហើយដែលយើងឃើញដឹកនាំទ័ពមកវាយកម្ពុជាពីមុន ទម្លាក់ពីរាជសម្បត្តិទៅ ។

ព្រះរាជាសៀមថ្មីនេះសោយរាជ្យបាន៨ឆ្នាំ ហើយបានធ្វើសង្គ្រាមទៅខាងជើងព្រះនគរ ដណ្ដើមយករាជាណាចក្រតូចៗនៅខាងជើងអយុធ្យា ដែលរក្សាបាននូវឯករាជ្យរហូតមកដល់ពេលនោះមួយម្ដងៗ មានមឿងណាខនដាងខា និងមឿងសេងសាវ នៅក្នុងឆ្នាំ១៣៧២, មឿងកិស្តលោក ក្នុងឆ្នាំ១៣៧៣, មឿងជាកាងរ៉ាយ ក្នុងឆ្នាំ១៣៧៨ ក្រោយពីចម្បាំងដណ្ដើមយកបរាជ័យ២លើក គឺក្នុងឆ្នាំ១៣៧៣ម្ដង និង១៣៧៧ម្ដង, មឿង ទាំងអស់ក្នុងស្រុកលាវពោះខ្មៅ (ហៅដូច្នេះដោយពួកនេះលាបពណ៌ពោះ) ។ សៀមបរាជ័យក្នុងការដណ្ដើមយកឈៀងម៉ៃ ២ដង ប៉ុន្តែបរាជ័យនេះមិនបានធ្វើឲ្យគេបាត់បង់កិត្តិស័ព្ទជាអ្នកចម្បាំងពូកែស៊ិតស្វាញ និងប៉ិនប្រសប់នោះទេ ពីព្រោះថារាជធានីនោះមានកំពែងការពារយ៉ាងរឹងមាំមិនអាចឲ្យសត្រូវវាយចូលបាន ហើយនិងមានទេវតាជួយថែការពារទៀតផង[២៥] ។

## ៨- ព្រះធម្មសោកៈ (១៣៧៣-១៣៩៤)

ព្រះអនុជរបស់ព្រះបរមរាមា គឺព្រះអង្គម្ចាស់ធម្មសោកៈ បានឡើងសោយរាជ្យបន្តពីព្រះរៀមក្រោមព្រះអភិសេកនាមថាព្រះបាទសម្ដេចស្ដេចព្រះរាជឱង្ការព្រះធម្មសោកៈរាជាធិរាជ ។

---

[២៥] ទាល់តែដល់ឆ្នាំ១៣៨៤ទើបឈៀងម៉ៃធ្លាក់ចូលក្នុងអំណាចរបស់សៀម ហើយរហូតទាល់តែដល់ឆ្នាំ១៤៣០ទើបសៀមរៀបចំរាជធានីបានល្អ ក្រោយពីបានជម្លៀសប្រជាជនចេញអស់២ម៉ឺនគ្រួសារ ។

ព្រះរាជាអង្គនេះសោយរាជ្យបាន៩ឆ្នាំ នៅពេលដែលស្តេចសៀមព្រះបរមរាជាសុគតទៅ ហើយព្រះរាជបុត្រព្រះនាមថា ថងឡាំ សោយរាជ្យបន្តបាន៧ថ្ងៃ បន្ទាប់មកត្រូវធ្វើគុតដោយព្រះរាមាសួន ជារាជបុត្ររបស់ព្រះខុទង ដែលត្រូវព្រះ បរមរាជា ដកចេញពីរាជសម្បត្តិនៅក្នុងឆ្នាំ១៣៦៩ បញ្ជូនឲ្យមកគង់នៅខែត្រលព្វបុរីវិញ ជាកន្លែងដែលទ្រង់ជាចៅហ្វាយខែត្រពីមុន ។ ព្រះរាមាសួនសោយរាជ្យបាន៦ឆ្នាំក៏សុគតទៅ ហើយព្រះរាជបុត្រព្រះនាម ព្រះចៅរាមា រាជពង្សាវតារខ្មែរហៅថា ចៅសំភ្យាចាន់ បានឡើងសោយរាជ្យបន្តក្រោមព្រះនាមថា ព្រះចៅបរមរាជា ក្នុងឆ្នាំ១៣៨៨ ។

ព្រះរាជាសៀមនេះមានព្រះទ័យលោភលន់ចង់វាតទឹកដីណាស់ ក៏ចាត់ឲ្យកេណ្ឌទ័ពជាច្រើនដាក់ឲ្យព្រះរាជបុត្រព្រះនាមថាព្រះឥន្ទ្ររាជាកាន់ រួចបានបញ្ជាឲ្យចេញមកវាយដណ្តើមយកព្រះរាជាណាចក្រខេមរាប្តខ្មែរ[២៦] ។

តបទៅនឹងមហិច្ឆតារបស់សៀមនេះ ព្រះរាជាកម្ពុជាបានរៀបចំទ័ពជា៤កង ដាក់ក្រោមបញ្ជារបស់ពញាកែវ, ពញាតី, ចៅពញាយ៉ាត (ចៅពញានេះជាប់សាច់រាជវង្ស) និងចៅហ៊្វាទល្ហៈ[២៧] ជានាយករដ្ឋមន្ត្រី ឲ្យចេញទប់ទល់នឹងទ័ពសៀម ។ រាជពង្សាវតារខ្មែរបានលើកសរសើរជាច្រើនអំពីមេទ័ពទាំង៤ ក៏ប៉ុន្តែមិនបានរៀបរាប់ផងទេ ថាតើកងទ័ពនីមួយៗបានធ្វើអ្វីខ្លះ ។ អ្វីដែលពិតប្រាកដនោះ គឺថាទ័ពសៀមបានចូលមកដល់ជើងជញ្ជាំងរាជធានីឥន្ទបត្ត ដើររុករើរាជធានី ចាប់ចាក់ដីបំពេញគូទឹក ហើយបើកការវាយប្រហារដំបូងៗ សាហាវឃោរឃៅខ្លាំងណាស់ ។ សៀមបើកការវាយប្រហារពង្រួនៗគ្នាក្នុងពេលតែមួយយ៉ាងខ្លាំងក្លា តែការទប់ទល់ពីខាងទ័ពខ្មែរក៏អង់អាចក្លាហានណាស់ដែរ ។ ទ័ពសៀមត្រូវរងរបួសយ៉ាងដំណំដោយដុំថ្ម ដែលប្រជាជនគប់ចេញពីលើជញ្ជាំងថ្មមក ។ ទ័ពសៀមព័ទ្ធរាជធានីអស់ពេល៧ខែ តែធ្វើអ្វីមិនបាន ។ នៅពេលនោះ ស្តេចសៀមធ្វើកលជាចោទទាហាន៦នាក់ថា បានប្រព្រឹត្តខុស ឲ្យគេដាក់ទណ្ឌកម្មដោយវាយនឹងរំពាត់ផ្តៅ ម្នាក់៥០រំពាត់នៅមុខទ័ពខ្មែរ ។ យប់ឡើង គេឃើញសៀមទាំង៦នាក់នោះ ដែលមានគូសសញ្ញាជើងក្អែកលើ ថ្ងាស មកបង្ហាញខ្លួននៅនឹងទ្វារកំផែងរាជធានី និយាយថាស្តេចសៀមអយុត្តិធម៌ ដាក់ទោសគេមិនត្រឹមត្រូវ គេកាច់ខ្នោះលួចរត់ចេញមក ហើយ

---

[២៦] នេះគឺជាលើកទី១ ហើយដែលខ្ញុំប្រទះឃើញគេប្រើពាក្យ ខេមរា នេះ ។

និយាយថាព្រឹត្តិការណ៍នេះកើតឡើងនៅក្នុងឆ្នាំ១៣៨៤ ដូចជាត្រឹមត្រូវល្អណាស់ បើសិនជាគេជឿតាមរាជពង្សាវតារសៀម ពីព្រោះថារាជធានីកម្ពុជាត្រូវសៀមវាយយកបាន ក្នុងឆ្នាំ១៣៨៥ ។ ប៉ុន្តែបើដូច្នេះមែន ព្រឹត្តិការណ៍នេះត្រូវកើតឡើងក្រោមរជ្ជកាលព្រះរាមាសួន មិនមែនក្នុងរជ្ជកាលព្រះចៅច័ន្ទ ជាព្រះរាជបុត្រនោះទេ ។

[២៧] នេះគឺជាលើកទី១ ហើយដែលខ្ញុំជួបជាមួយឋានៈនេះ ដែលយើងនឹងប្រទះឃើញទៀតនៅពេលក្រោយៗ ។ ពាក្យនេះដូចជាមានប្រភពចេញពីភាសាប៉ហ្កាន ។

គេសូមបម្រើខ្មែរដើម្បីសងសឹកនឹងស្ដេចសៀមវិញ ។ គេបាននាំសៀមទាំង៦នាក់នោះ ទៅចូលគាល់ព្រះរាជា ហើយនៅពេលដែលព្រះរាជាកំពុងសណ្ដាប់របាយការណ៍របស់ពួកនោះ មានមន្ត្រីមួយរូបបានចូលមករាយការណ៍ថ្វាយព្រះរាជាថា ពួកសៀមទើបតែលើកដើមឫស្សីមួយដើមនៅចំពីមុខច្រកទ្វារកំផែងខាងលិចដើមឫស្សីនោះ មានដោតក្បាលអ្នកយាមដែលធ្វេសប្រហែសធ្វើឲ្យពួកក្បត់ទាំង ៦នាក់ រត់ចេញរួច ។

ព្រះរាជារឹតតែជឿលើរឿងទាំងអស់នេះថែមទៀត នៅពេលដែលមានទាហានសៀម២នាក់ក្នុងចំណោម ៦នាក់នោះ ស្លាប់ប៉ុន្មានថ្ងៃក្រោយមក[២៨] ។ ទ្រង់ឲ្យរង្វាន់ដល់ពួក៨នាក់ទៀតដែលនៅរស់ រួចបានឲ្យនាម៉ឺនសព្វមុខមន្ត្រីយកចិត្តទុកដាក់ថែមទៀត ។ ពួកនេះបានចូលរួមប្រយុទ្ធក្នុងជួរទ័ពខ្មែរប្រឆាំងនឹងសៀមគ្រប់លើក ហើយបានបង្ហាញស្នាដៃជាច្រើន ធ្វើឲ្យមេកងរបស់ពួកគេជឿទុកចិត្តលើគេជាខ្លាំង ។ ក៏ប៉ុន្តែ រាល់ពេលដែលទ័ពខ្មែររៀបចំចេញធ្វើប្រតិបត្តិការ ពួកនេះតែងតែសរសេរលិខិតផ្ដល់ពត៌មានអំពីថ្ងៃខែ ទីកន្លែង និងម៉ោងពេលប្រតិបត្តិការចងជាប់ជាមួយព្រួញមួយ រួចបាញ់ព្រួញនោះចូលទៅក្នុងជំរំទ័ពសៀមជានិច្ច ។ ថ្ងៃមួយ ការប្រយុទ្ធចាប់ផ្ដើមតាំងពីព្រឹកព្រលឹមរហូតដល់ពេលល្ងាច ធ្វើឲ្យទាហានទាំងសងខាងស្លាប់ ដួលពេញគូទឹកទាំង៤ទិស ស្រាប់តែពួកសៀមទាំង៨នាក់ ដោយមានការជួយឧបត្ថម្ភពីពញាកែវ និងពញាតី ដែលពួកគេបានបញ្ចុះបញ្ចូលឲ្យចូលរួមក្បត់ បើកទ្វារទិសខាងលិចឲ្យខ្មាំងចូល ។ ពួកសៀមទាំង៨នាក់បានត្រូវសម្លាប់នៅនឹងកន្លែង ក៏ប៉ុន្តែអ្វីៗបានកន្លងហួសទៅហើយ ទ័ពសៀមដែលរង់ចាំតែឱកាសនេះយូរណាស់មកហើយ បាននាំគ្នាសម្រុកបុកចូលមកក្នុងរាជធានី ហើយដណ្ដើមបានក្នុងពេលនោះទៅ ។ ព្រះរាជាក៏ត្រូវទ័ពសៀម ធ្វើគុតក្នុងការប្រយុទ្ធនោះដែរ ខ្មែរត្រូវដាក់អាវុធសុំចុះចាញ់នៅក្នុងគ្រិស្តសករាជ១៣៩៤ ត្រូវនឹងមហាសករាជ៣១៦ ចុល្លសករាជ៦៥៩ ។

សៀមចាប់បាននាម៉ឺនសព្វមុខមន្ត្រី និងទ័ពជាឈ្លើយយ៉ាងច្រើន នាំយកទៅកាន់ស្រុកសៀម ប៉ុន្តែមានអ្នកស្រុកមួយចំនួនធំបានគេចខ្លួនរួចជាមួយចៅពញាយ៉ាត និងពួកព្រាហ្មណ៍បុរោហិត ដោយនាំយកព្រះខ័នរាជ្យ លំពែងរាជរបស់ តាចាយ និងកេតនភណ្ឌរបស់រាជានិយមខ្មែរទៅជាមួយផង ។

## ៩- ចន្លោះរជ្ជកាល (១៣៩៤)

ស្ដេចសៀមបានឲ្យគេបោសសម្អាតប្រមូលខ្មោចទាហានដែលស្លាប់យ៉ាងច្រើនក្នុងសង្គ្រាម ចេញពីរាជ

[២៨] ការអធិប្បាយលម្អិតបែបនេះពេកដូចជាធ្វើឲ្យមានការសង្ស័យថារាជពង្សាវតាររៀបរាប់បំភ្លៃ ពីព្រោះថា បើសិនជាសៀម៦នាក់នោះត្រូវស្ដេចសៀមដាក់ទណ្ឌកម្មដើម្បី គ្រាន់តែបន្លំភ្នែកខ្មែរទេ វាមិនសមនឹងធ្ងន់ធ្ងររហូតដល់អាចធ្វើឲ្យមានគ្រោះថ្នាក់បែបនេះឡើយ ។

ធានី ដើម្បីបំបាត់ក្លិនអសោច រួចព្រះអង្គបានលើកព្រះរាជបុត្រព្រះនាមពញាព្រែក[២៩] ឲ្យឡើងសោយរាជសម្បត្តិក្រោមព្រះនាមថា ព្រះឥន្ទ្ររាជា ។

រាជពង្សាវតារខ្មែររៀបរាប់ថា ក្រោយពីរៀបចំពិធីរាជាភិសេករួចបានបន្តិច ស្តេចសៀមបានយាងកាត់មហាប្រាសាទ ទ្រង់នឹកឆ្ងល់ក៏សួរថាហេតុអ្វីក៏ព្រះរាជដំណាក់ដ៏ល្អនេះមានបន្ទប់ច្រើនម្ល៉េះ? ពេលនោះ មន្ត្រីខ្មែរម្នាក់បានទូលថ្វាយថា បន្ទប់ទាំងអស់នោះសម្រាប់ទទួលរាជបុត្ររបស់ស្តេចសាមន្តរាជទាំងឡាយ ដែលត្រូវបញ្ជូនមកកាន់រាជវាំងកម្ពុជា ។

ប្រទះឃើញព្រះគោ ស្តេចសៀមសួរថាតើជាអ្វី? មន្ត្រីខ្មែរចាស់ម្នាក់ដែលចេះចាំអនុស្សាវរីយ៍ពីអតីតកាល បានទូលថ្វាយថា ព្រះបដិមាព្រះគោនេះកសាងឡើងតាំងពីយូរលង់ណាស់មកហើយ ក្នុងសម័យដែលកម្ពុជាជាមហាអំណាច សម្រាប់ដាក់គម្ពីរព្រះត្រៃបិដក ។ គេគោរពបូជាព្រះគោនេះ ហើយចាត់ទុកថា គឺជាព្រះឆ្នួលនៃព្រះរាជាណាចក្រ ។

ស្តេចសៀមពេញចិត្តនឹងចម្លើយទាំងអស់នេះណាស់ ហើយនៅពេលដែលយាងត្រលប់ទៅស្រុកសៀមវិញ ទ្រង់បាននាំយកព្រះគោនោះ និងព្រះពុទ្ធបដិមាជាច្រើនដែលកសាងពីមាស និងប្រាក់ យកទៅជាមួយផង ។ ទ្រង់ក៏បាននាំយកទៅផងដែរនូវអ្នកកាន់សាសនាខ្មែរ ពួកក្បត់ពញាកែវ និងពញាតី និងអ្នកស្រុកជាឈ្លើយសឹកចំនួន៧ម៉ឺននាក់ ។

ចំណែកឯព្រះឥន្ទ្ររាជា ដែលស្តេចសៀមបានលើកឲ្យសោយរាជ្យក្នុងរាជធានីកម្ពុជាវិញ ក្រោយមកបានតាមរកកេតនភណ្ឌរាជានិយមខ្មែរឃើញ ព្រោះថាបើគ្មានវត្ថុទាំងអស់នោះទេ គេមិនអាចសោយរាជសម្បត្តិពេញលក្ខណៈជាព្រះរាជាបានឡើយ ។ ដោយភ័យខ្លាចគេលួចយកទៅវិញ ទ្រង់បានពិចារណាថានឹងបញ្ជូនវត្ថុទាំងអស់នោះទៅទុកនៅឯក្រុងអយុធ្យា ស្រាប់តែផ្គរលាន់រំពងឡើង ហើយភ្លៀងក៏បង្អុរមកយ៉ាងខ្លាំងពេញមួយរាត្រីមុនថ្ងៃដែលត្រូវបញ្ជូនចេញពីរាជធានីឥន្ទបត្ត នេះបើតាមរាជពង្សាវតាររៀបរាប់ ធ្វើឲ្យព្រះឥន្ទ្ររាជា

[២៩] ពាក្យខ្មែរថាពញានេះ ប្រហែលជាក្លាយមកពីពាក្យប៉ើហ្កានថាប៊ីញ៉ា ជាឋានៈរបស់ស្តេចពីបុរាណ ឯពាក្យថាចៅក៏សំដៅយកស្តេច ដែរ ។ ពាក្យចៅពញានេះជាឋានៈរបស់ពួកអ្នកអង្គម្ចាស់ និងព្រះរាជាខ្មែរនៅសតវត្សរ៍ទី១៤ និង១៥ តែបន្ទាប់មកបានប្រើពាក្យនេះ សម្រាប់ហៅតែពួកអ្នកអង្គម្ចាស់ប៉ុណ្ណោះ រួចហើយសម្រាប់តែនាម៉ឺនធំៗ ។ ក្នុងភាសាលាវ គេថា ប៉ាញ៉ា ឬផាញ៉ា ។

គេមិនត្រូវច្រឡំពញាព្រែកនេះ ដែលត្រូវជារាជបុត្ររបស់ស្តេចសៀម ហើយត្រូវគេលើកឲ្យសោយរាជ្យនៅកម្ពុជាក្រោមព្រះនាមថា ព្រះឥន្ទ្ររាជា ជាមួយនឹងបុត្រស្តេចសៀមមួយអង្គទៀតដែលមានឋានៈដូចគ្នាដែរតែធ្វើជាមេទ័ពសៀមទេ ។ ហើយក៏មិនត្រូវច្រឡំជាមួយព្រះឥន្ទ្ររាជាមួយទៀត ដែលត្រូវជាព្រះញាតិរបស់ស្តេចសៀមព្រះភ្យារាម ដែលដណ្តើមរាជសម្បត្តិក្នុងឆ្នាំ ១៤០១ ដែរ ។

មានការភ័ន្តភាំងជាខ្លាំង ហើយទ្រង់ស្រមៃថាមានអតីតព្រះរាជាខ្មែរមួយអង្គមកគង់ពីលើ ហើយព្រមានព្រះអង្គថា នឹងធ្វើបាបព្រះអង្គបើព្រះអង្គបញ្ជូនកេតនភណ្ឌទាំងនោះទៅស្រុកសៀមមែន ។ ព្រះអង្គភ័យខ្លាច ក៏សម្រេចទុកវត្ថុទាំងអស់នៅនឹងឥន្ទបត្តវិញទៅ ។

គេមិនដឹងថាតើព្រះឥន្ទ្ររាជាសោយរាជ្យនៅកម្ពុជាបានប៉ុន្មានឆ្នាំទេ ហើយក៏មិនដឹងថាមានមូលហេតុអ្វីដែលធ្វើឲ្យទ្រង់យាងត្រលប់ទៅស្រុកសៀមវិញ ។ អ្វីដែលគេដឹងគឺថា ព្រះអនុជរបស់ព្រះអង្គភ្យារាមា ដែលឡើងសោយរាជសម្បត្តិបន្តពីព្រះរាមាសួននៅក្នុងឆ្នាំ១៣៧៥ បានត្រូវមន្ត្រីមួយរូបទម្លាក់ពីរាជសម្បត្តិ នៅក្នុងឆ្នាំ១៣៨០ ហើយលើកព្រះឥន្ទ្ររាជាឲ្យសោយរាជ្យលើបល្ល័ង្ករាជសៀមវិញ ចំពេលដែលព្រះរាជាណាចក្រកម្ពុជា កំពុងតែរៀបចំប្រទេស បន្ទាប់ពីទទួលបានឯករាជ្យឡើងវិញដោយស្នាដៃព្រះអង្គម្ចាស់មួយអង្គនៃរាជវង្សានុវង្ស ។

## ១០- ព្រះស្រីសុរិយោវង្ស (១៨០១-១៨១៧)

ផុតពីការត្រួតត្រារបស់សៀម នាម៉ឺនសព្វមុខមន្ត្រីបានលើកព្រះស្រីសុរិយោវង្ស ដែលត្រូវជាព្រះរាជបុត្ររបស់ព្រះសុរិយោទ័យដែលសោយរាជ្យពីឆ្នាំ១៣៥៣ដល់១៣៥៩ ឲ្យឡើងគ្រងរាជបល្ល័ង្កកម្ពុជា នៅពេលដែលព្រះអង្គមានព្រះជន្មាយុ៤៣ព្រះវស្សា ។

រាជពង្សាវតារនិយាយថាទ្រង់សោយរាជ្យបាន១៦ឆ្នាំ ហើយសុគតនៅក្នុងឆ្នាំ១៤១៧ ក្នុងព្រះជន្ម៥៩ព្រះវស្សា ដោយបន្សល់ទុកព្រះរាជបុត្រាមួយអង្គព្រះនាមចៅពញាយ៉ាត មានព្រះជន្ម១៧ព្រះវស្សា ។

## ១១- ព្រះបរមសោកៈ (១៤១៧-១៤២១)

ព្រះរាជាដែលត្រូវគេជ្រើសរើសឲ្យសោយរាជ្យបន្តពីព្រះសុរិយោវង្ស គឺព្រះភាគិនេយ្យរបស់ព្រះអង្គដែលមានព្រះជន្ម២៩ព្រះវស្សា ក្រោមព្រះនាមថាព្រះបរមសោករាជា ។

តាមរាជពង្សាវតារ សៀមបានវាយយកឥន្ទបត្តបុរីម្ដងទៀតក្នុងរជ្ជកាលស្ដេចអង្គនេះ នៅក្នុងឆ្នាំ១៤២០ ហើយព្រះអង្គបានសុគតទៅក្រោយពីសោយរាជ្យបានប្រហែល៣ឆ្នាំ ក្នុងព្រះជន្ម៣២ព្រះវស្សា ។ ការចូលទិវង្គតរបស់ព្រះរាជាជាហេតុបណ្ដាលឲ្យពួកសៀមវាយចូលមកដល់ក្នុងរាជធានី ។

ក៏ប៉ុន្តែរឿងរ៉ាវនេះហាក់ដូចជាច្របូកច្របល់បន្តិច អាចនឹងថាពួកអ្នកដែលសរសេររាជពង្សាវតារមានការច្រឡំកាលវេលារវាងរជ្ជកាល២ គឺរជ្ជកាលស្ដេចធម្មសោកៈ និងបរមសោកៈ ពីព្រោះថាមានរាជពង្សាវតារខ្លះមិនបានទាំងលើកអំពីស្ដេចបរមសោកៈ ឬសុរិយោវង្ស ផងទេ ម្ល៉ោះហើយវាអាចនឹងមានការលំបាកក្នុងការបន្សីកាលវេលា ។ តែទោះជាយ៉ាងណាក្ដី រាជពង្សាវតារទាំងអស់ឯកភាពគ្នាត្រង់ចំណុចដែលថារជ្ជកាលរបស់ស្ដេច

ពញាយ៉ាត បានចាប់ផ្តើមឡើងតាំងពីឆ្នាំ១៤២១[៣០] ។

## ១២- ព្រះស្រីសុរិយោពណ៌ ឬចៅពញាយ៉ាត (១៣៨៤-១៤៣១)

ព្រះចៅពញាយ៉ាត មិនបានធ្លាក់ក្នុងកណ្តាប់ដៃសៀមទេ ទ្រង់បានចេញឃោសនាបញ្ចុះបញ្ចូលនាម៉ឺនមន្ត្រី និងប្រជារាស្ត្រឲ្យប្រឆាំងនឹងសៀមវិញ ។ ទ្រង់កទ័ពបាន រួចបោះជំរំនៅក្នុងបន្ទាយមានរបងការពាររឹងមាំមួយ នៅក្នុងស្រុកស្រីសឈរ (ស្រីសន្ធរ)[៣១] ដែលរឿងនិទាននិយាយថា ជាកន្លែងព្រះបាទបក្សីចាំក្រុងគង់នៅមុនពេលបានឡើងសោយរាជ្យ[៣២] ។ ទ្រង់បានចាត់ឲ្យកសាងរាជធានីតូចមួយ មានរបងការពាររឹងមាំ ហើយមានប្រជារាស្ត្រជាច្រើនមកពីខេត្រផ្សេងៗ ចូលមករួមរស់ក្រោមការគ្រប់គ្រងរបស់ចៅពញាយ៉ាត ក្នុងនោះ មួយចំនួនធំដែលមានបំណងបណ្តេញសៀមចេញពីព្រះនគរ បានស្ម័គ្រចូលបម្រើក្នុងជួរកងទ័ពរបស់ព្រះអង្គ ។

ចៅពញាយ៉ាតមិនចង់ធ្វើសង្គ្រាមប្រឆាំងនឹងទ័ពសៀម និងស្តេចសៀមដែលសោយរាជ្យនៅលើរាជបល្ល័ង្កកម្ពុជាដោយចំហទេ ទ្រង់មានបំណងចង់លួចធ្វើឃាតវិញ ។ ទ្រង់បានចាត់មហាតលិក២នាក់ឲ្យធ្វើការងារនេះ ហើយបានសន្យាឲ្យរង្វាន់ច្រើនដល់អ្នកទាំង២នាក់ ដែលស្ម័គ្រចិត្តធ្វើដំណើរទៅកាន់ឥន្ទបត្តបុរី ជាមួយកម្លាំង ១៥នាក់ទៀត ។ ពួកនេះបានជួបមន្ត្រីសៀមម្នាក់ រួចបានសុំចូលគាល់ស្តេចសៀមដើម្បីសុំបម្រើស្មោះត្រង់អស់មួយជីវិត ។ ពេលនោះស្តេចសៀមគង់នៅក្នុងសួនក្នុងព្រះបរមរាជវាំង មន្ត្រីសៀមក៏នាំអ្នកទាំង ១៧នាក់ ទៅរង់ចាំត្រង់ផ្លូវដែលព្រះរាជាយាងធ្វើដំណើរ រួចឆ្លៀតឱកាសបង្ហាញខ្លួនអ្នកទាំងនោះតែម្តង ។ ស្តេចសៀមនៅឥន្ទបត្តត្រេកអរខ្លាំងណាស់ ដោយមានព្រះបន្ទូលថា តាំងពីទ្រង់បានឡើងជាព្រះចៅក្រុងកម្ពុជា ទើបតែមានអ្នកទាំង ១៧ នាក់នេះទេ ដែលភ្ញាក់រលឹកមកសុំបម្រើព្រះអង្គមុនគេ ម៉្លោះហើយទ្រង់យល់ព្រមទទួល ហើយនឹងឲ្យរង្វាន់ដល់អ្នកទាំងអស់គ្នា ។ ទ្រង់បានបញ្ជាឲ្យគេយកសម្លៀកបំពាក់មកឲ្យ ខ្មែរទាំង១៧នាក់ ស្រាប់តែពួកនេះ ដកយកកាំបិតស្នៀតដែលលាក់ក្នុងគល់ភ្លៅចេញមក ហើយព្រួតគ្នាចាក់ទៅលើព្រះរាជាសំដៅត្រង់ពោះ និងទ្រូងធ្វើឲ្យព្រះអង្គសុគតភ្លាមទៅ ។ ពួកសេនាការពារស្តេចសៀមពេលនោះបាន ចេញមកជួយភ្លាមដែរ ប៉ុន្តែ បានត្រឹមតែកាប់

---

[៣០] មានឯកសារមួយនិយាយថា ស្តេចពញាយ៉ាត ឡើងសោយរាជ្យក្នុងឆ្នាំ១៤៣២ ។ តាមមើលទៅប្រហែលជាឆ្នាំដែលទ្រង់ទទួលព្រះរាជាភិសេកទេ គឺឆ្នាំ១៤២៣ ឬ ១៤៣៣ ។

[៣១] នៅចម្ងាយ៤០គីឡូម៉ែត្រខាងត្បូងសានរាជធានីភ្នំពេញ លើច្រាំងទន្លេមេគង្គខាងឆ្វេង ។

[៣២] រឿងព្រះបាទបក្សីចាំក្រុងនេះជារឿងនិទានសុទ្ធសាធ តែឈ្មោះទីកន្លែងត្រូវទៅនឹងឈ្មោះស្រុកទេសពិតប្រាកដមែន ។ នៅស្រុកសៀមក៏មានរឿងនិទានដូចគ្នានេះដែរ គ្រាន់តែឈ្មោះទីកន្លែងប្តូរទៅជាឈ្មោះស្រុកទេសក្នុងប្រទេសសៀមទៅវិញ ។

សម្លាប់ពួកឃាតកប៉ុណ្ណោះ ឯស្តេចសៀមបានសុគតផុតទៅហើយ[៣៣] ។

ប៉ុន្មានថ្ងៃក្រោយមក ចៅពញាយ៉ាត ដែលចេញដំណើរពីបន្ទាយមករង់ចាំតែដំណឹងនេះ ក៏បានបង្ហាញខ្លួនព្រះអង្គនៅមុខឥន្ទបត្តបុរី ហើយចាប់ផ្តើមបើកការប្រយុទ្ធ ។ ពេលនោះពួកខ្មែរដែលរស់នៅក្នុងរាជធានី ក៏នាំគ្នាចាប់កាន់អាវុធឡើងកាប់សម្លាប់ពួកសៀម រួចបើកទ្វាររាជធានីឲ្យទ័ពចៅពញាយ៉ាតចូល ។ នៅពេលដែលកំពុងតែមានការតាមកាប់សម្លាប់សត្រូវតាមផ្លូវផ្សេងៗនៃព្រះរាជធានី ចៅពញាយ៉ាត បានយាងចូលក្នុងព្រះរាជវាំង ហើយបានជួបនឹងស្រីសៀមស្អាតម្នាក់កំពុងតែយំ ។ ទ្រង់សាកសួរទៅនាងនោះ ដែលក្រាបថ្វាយបង្គំចោលកន្ទុយភ្នែកដៀងមើលព្រះអង្គ រួចទូលថា នាងមានឈ្មោះថា នាងស្រងៀម ជាបុត្រីអកខុន និងត្រូវជាព្រះជាយា របស់ស្តេចសៀមដែលខ្មែរទាំង១៧នាក់ធ្វើគុតនោះ ។ ចៅពញាយ៉ាត ពេញព្រះទ័យនឹងសម្រស់នាង ស្រងៀម ខ្លាំងណាស់ ក៏លើកនាងធ្វើជាស្នំឯក ។

ចៅពញាយ៉ាតបានត្រូវគេលើកឲ្យសោយរាជ្យក្នុងឆ្នាំ១៣៨៤នៃគ្រិស្តសករាជ ក៏ប៉ុន្តែទាល់តែ១២ឆ្នាំក្រោយមក គឺក្នុងឆ្នាំ១៣៩៦ ទើបទ្រង់បានរៀបចំអភិសេកក្រោមព្រះនាមថាព្រះបាទសម្តេចស្តេចព្រះរាជឱង្ការព្រះបរមរាជាធិរាជរាមាធិបតី ព្រះស្រីសុរិយោពណ៌ធម្មិកមហារាជាធិរាជ ព្រះបរមនាថបរមបពិត្រ ។

នៅឆ្នាំ១៣៨៨ នៃគ្រិស្តសករាជ[៣៤] ព្រះរាជាបានប្រជុំព្រះរាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រី និងសេនាបតីទាំងឡាយ រួចទ្រង់មានព្រះបន្ទូលថា «ព្រះរាជាណាចក្រកម្ពុជាយើងមានរាជាណាចក្រសៀមជាសត្រូវ ។ ពី

[៣៣] ស្តេចនេះមិនមែនជាព្រះពញាព្រែក ដែលឡើងសោយរាជ្យនៅកម្ពុជាក្រោមព្រះនាមថា ព្រះឥន្ទ្ររាជាទេ ពីព្រោះព្រះអង្គសោយរាជ្យនៅសៀមតាំងពីឆ្នាំ១៤០១ ។ បើដូច្នេះ តើព្រះអង្គជាស្តេចមួយណា ។ ព្រះសង្ឃរាជខ្មែរប្រាប់ខ្ញុំថា ស្តេចនេះអាចជាស្តេចដែលសោយរាជ្យបន្តពីព្រះឥន្ទ្ររាជា ក៏ប៉ុន្តែបើសិនជាដូច្នោះមែន តើព្រះស្រីសុរិយោវង្ស និងព្រះបរមសោកៈសោយរាជ្យនៅពេលណា ហើយនៅឯណា?

[៣៤] ឯកសារមួយនោះនិយាយច្រើនដងថានៅក្នុងឆ្នាំ១៣១០ នៃមហាសករាជ ត្រូវនឹងចុល្លសករាជ៧៥១ ដែលត្រូវនឹងគ្រិស្តសករាជ១៣៧៤ ឬ១៣៨៨ ឬ១៣៨៩ ។ យើងនឹងបានឃើញនៅខាងក្រោមថា ការចាកចេញពីអង្គរគឺនៅក្នុងចុល្លសករាជ ៧៣៥ ជាឆ្នាំរោងទោស័ក ។ ក៏ប៉ុន្តែឆ្នាំ៧៣៥ នៃចុល្លសករាជដែលត្រូវនឹងគ្រិស្តសករាជ ១៣៧៣ មិនមែនជាឆ្នាំរោងទេ ហើយក៏មិនមែនជាឆ្នាំទោស័កដែរ គឺជាឆ្នាំម្សាញ់បញ្ចស័កទៅវិញទេ ។ ឯមហាសករាជ១៣១០ ដែលត្រូវនឹងគ្រិស្តសករាជ១៣៨៨ ទើបជាឆ្នាំរោងទោស័ក ។ គឺដោយមូលហេតុនេះហើយបានជាខ្ញុំគិតថាកាលបរិច្ឆេទនេះសមជាង ហើយម្យ៉ាងទៀតមានការរៀបរាប់នៅខាងក្រោមពីឆ្នាំចុល្លសករាជ៧៥១ និង៧៥២ (ត្រូវនឹងគ្រិស្តសករាជ១៣៨៩ និង១៣៩០) ។ ចំណុចមួយទៀត គឺគេនិយាយខាងក្រោមថាព្រះអង្គសោយរាជ្យបាន ៤៧ព្រះវស្សា ក្នុងនោះ ១៧ព្រះវស្សានៅមហានគរ ហើយបើយក ១៧ឆ្នាំទៅបូកជាមួយ ឆ្នាំដែលព្រះធម្មសោកៈសុគត១៣៧៣ យើងបាន១៣៩០ គឺខុសគ្នាតែ២ឆ្នាំប៉ុណ្ណោះ ។ ខ្ញុំពិនិត្យឃើញថាមានការមិនសូវសមជាច្រើននៅក្នុងកាលបរិច្ឆេទ តែខ្ញុំអាចបានត្រឹមតែផ្គួផ្គងដូចខាងលើ ហើយសុំឲ្យអ្នកណាដែលមានឯកសារច្រើនជាងជួយកែសម្រួលផងចុះ ។

មុនបណ្ដាអាណាខែត្រភាគខាងលិចមានប្រជាជនច្រើនណាស់ ឥឡូវខែត្រភាគច្រើនត្រូវសៀមយកអស់ហើយ ។ សៀមក៏បានកៀរយកប្រជាជនពីខែត្រផ្សេងៗទៀត ដែលយើងកាន់កាប់ នាំយកទៅជាឈ្លើយថែទៀត យើងពិបាកនឹងទៅរកប្រជាជនពីណាមកដាក់វិញណាស់ ។ បើនឹងចង់ដណ្ដើមយកអាណាខែត្រដែលសៀមយកទៅនោះមកវិញក៏មិនបាន ព្រោះមានការយាមកាមរក្សាម៉ឺងម៉ាត់ណាស់ ណាមួយយើងក៏ពិបាក នឹងធ្វើសង្គ្រាមតទៅទៀតផង ។ ខែត្រជាប់ព្រំដែន មិនអាចឲ្យរើសទ័ពសម្រាប់ទប់ទល់នឹងការលុកលុយរបស់សៀមបានទេ ។ រាជធានីយើងធំ មានរបងការពាររឹងមាំ តែមិនសូវមានប្រជាជន ដូច្នេះមិនគ្រប់គ្រាន់នឹងការពារឡើយ ។ បើសិនណាជាសៀមលើកទ័ពមកវាយម្ដងទៀត ទាំងសាសនិកទាំងពួកព្រាហ្មណ៍នឹងត្រូវវេទនាដូចគ្នា ។

យើងគួរតែចាកចោលរាជធានីនេះដែលយើងមិនអាចការពារបាន ហើយទៅកសាងរាជធានីថ្មីមួយ នៅឯខែត្រស្រីសឈរ (ស្រីសន្ធរ) វិញ ។ បើពួកសៀមមក វាត្រូវឆ្លងកាត់ខែត្រផ្សេងៗដែលវាត្រូវប្រយុទ្ធជាច្រើនកន្លែង អាចទុកពេលឲ្យយើងកេណ្ឌទ័ពទប់ទល់ទាន់មុននឹងបណ្ដោយឲ្យពួកវាចូលមកដល់ដើងរបងរបស់យើង»[៣៥] ។

មានព្រះបន្ទូលរួច ទ្រង់សាកសួរយោបល់នាម៉ឺនសព្វមុខមន្ត្រី ដែលយល់ស្របតាមព្រះរាជតម្រិះដែរ ហើយក៏សម្រេចឲ្យដឹកជញ្ជូនរាជទ្រព្យ រាជបរិពារ និងសេនាបតីទៅកាន់ស្រីសន្ធរ ។ លុះដល់ឆ្នាំ១៣៨៨ ក្រោយពីបានជ្រើសរើសពេលវេលាល្អរួចហើយ ទ្រង់បានយាងចាកចេញពីព្រះរាជវាំងឥន្ទបត្តបុរី តាមព្រះរាជទីនាំងនាវាធំមួយ ហែហមទៅដោយនាវាតូចធំជាច្រើន ក្រោមសំឡេងគងឃ្មោះ និងស្គរលាន់ឮរំពង គួបផ្សំជាមួយសំឡេងហ៊ោកញ្ជ្រៀវរបស់កងទ័ពដើងគោក និងដើងទឹកអឹងកង ដើម្បីធ្វើឲ្យព្រះរាជដំណើរប្រកបទៅដោយជោគជ័យ ។

នាវាព្រះរាជាបានមកចុះចតនៅនឹងទួលបាសាន ហើយភ្លាមៗនោះ គេក៏ចាប់កសាងរាជវាំងហ៊ុមព័ទ្ធទៅដោយកំផែងការពាររឹងមាំ សង់ក្រោលសេះ ក្រោលដំរី និងជម្រកព្រះរាជទីនាំងនាវា ។ ព្រះរាជវាំងបែរមុខទៅរកទន្លេ ។ ព្រះរាជបរិពារសេវកាមាត្យ សង់ផ្ទះជុំវិញព្រះរាជដំណាក់ ត្រង់កន្លែងណាដែលមានទួល ហើយទ្រង់ប្រទាននាមឲ្យព្រះរាជធានីថ្មីថា ក្រុងស្រីសន្ធរបវរធានី ។

រដូវវស្សាមកដល់ ភ្លៀងធ្លាក់ជោកជាំធ្វើឲ្យលិចលង់ទូទាំងព្រះនគរ ព្រះរាជាក៏សម្រេចមកគង់នៅឯចតុម្មុខវិញ គឺរាជធានីភ្នំពេញសព្វថ្ងៃ ត្រង់អាគ្នេយ៍ភ្នំតូចមួយ[៣៦] ។

ព្រះរាជាបានបញ្ជាឲ្យ ខកញ៉ាតេជោ កេណ្ឌកម្លាំងមនុស្សជាច្រើនជីកដីត្រង់កន្លែងមួយ ហើយរែកយកមក

---

[៣៥] យើងបានឃើញពីខាងលើរួចហើយថា ព្រះរាជាបានស្គាល់ និងធ្លាប់បានរស់នៅក្នុងខែត្រនេះមួយរយៈរួចមកហើយ ។

[៣៦] ព្រះសង្ឃព្រះនាមចាន់ ជាបាឡាត់វត្តខណ្ឌលោម បានអះអាងថាគឺតេជោក្រហមកដែលបានពូនកូនភ្នំនេះឡើងនៅក្នុងឆ្នាំ ១៦០៥ រួចហើយបានសង់ចេតិយធំមានរាងជា ពីរ៉ាមីដ ។ ក៏ប៉ុន្តែរាជពង្សាវតារនិយាយថាចេតិយដែលស្ថិតនៅជ្រុងខាងពាយ័ព្យនោះ គឺជាចេតិយដែលដាក់ធាតុស្ដេចចៅពញាយ៉ាត ដែលបានយកចតុម្មុខជារាជធានី ។

ចាក់បំពេញមាត់ទន្លេខាងកើត និងខាងត្បូងភ្នំ ។ កន្លែងដែលគេជីកនោះបានក្លាយទៅជាបឹងមួយ ដែលក្រោយមកគេហៅថា បឹងតេជោ នៅខាងលិចមហាវិថីឌូដាដឺឡាក្រេសពុថ្ងៃ ពីម្ខាងព្រែកជីកខាងនិរតី ។

បន្ទាប់មក ព្រះរាជាបានបញ្ជាឲ្យជីកព្រែកមួយដែលគេហៅថាព្រែកពាមផ្លុង ដើម្បីនាំយកទឹកពីទន្លេ មកប្រើនៅក្នុងរាជធានី ។ ព្រែកនោះ សព្វថ្ងៃនៅមានស្នាមត្រង់កន្លែងដែលមានពាមមួយ តម្រង់ទៅរកស្ពានឆ្នាំ ៨នាក់ ចន្លោះតីរវិថីវៃណេរីល និងតីរវិថីពីកេ ។ គេចាក់បំពេញកន្លែងណាដែលទាប កន្លែងណាមានអូរគេធ្វើស្ពានតូចសម្រាប់ឆ្លងកាត់ ហើយគេកសាងប៉មមួយនៅពីខាងជើងសម្រាប់ការពាររាជធានី ។ រួចគេជីកអូរមួយ ព័ទ្ធជុំវិញប៉មនោះ ដែលគេហៅថាអូរចិនដីដែក ដោយមកពីមានពួកចិនរកស៊ីដែកនៅកន្លែងនោះ ។ អូរនោះសព្វថ្ងៃជាព្រំប្រទល់ខាងត្បូងនៃដីគរុភណ្ឌ តែត្រូវបានគេចាក់បំពេញធ្វើជាផ្លូវអស់ហើយ ។

សំណង់ការពារសត្រូវរួមមានកំពែងព័ទ្ធជុំវិញរាជធានីមួយ ចាប់ផ្តើមពីប៉មខាងជើងសំដៅទៅទិសខាងលិចរួចបត់ទៅត្បូងពីខាងក្រោយបឹងតេជោដែលគេទុកសម្រាប់ធ្វើស្រែ រួចហើយបែរមករកទន្លេវិញ កាត់តាមត្រពាំងអូរ ពោរពេញទៅដោយភក់ដែលប្រឡាយទឹកស្អុយហូរកាត់ ពីខាងក្រោយវត្តធម្មយុត្តិ ធ្លាក់ទៅក្នុងបឹងវែងមួយនៅខាងត្បូងវត្តព្រះពុទ្ធមរកត[៣៧] ។ គេក៏បានលើកកំពែងព័ទ្ធតាមមាត់ទន្លេផងដែរ ដើម្បីបង្ការការវាយប្រហារពីសត្រូវតាមផ្លូវទឹក ។ នៅលើកំពូលភ្នំ ព្រះរាជាបានបញ្ជាឲ្យសង់វត្តមួយ សាលាមួយ នៅតាមជើងភ្នំទ្រង់ឲ្យសាងអាស្រមតូចៗសម្រាប់ពុទ្ធសាសនិកជន ។

អ្នកតាម្ចាស់ទឹកដីឬឃ្លាំងមឿង ដែលមានឈ្មោះថា អ្នកតាប្រាប គេដាក់នៅក្បែរមាត់ពាមព្រែកពាមផ្លុង ។

សង់អ៊ីៗរួចហើយ ព្រះរាជាបានយាងចូលគង់ក្នុងព្រះបរមរាជវាំង ហើយសម្រេចឲ្យគេហៅទន្លេដែលជាប់នឹងរាជធានីនេះថា ទន្លេចតុម្មុខមង្គលសកលកម្ពុជាធិបតី ។

នៅពេលនោះ ប្រទេសមានសន្តិភាពសុខសាន្តបានយូរល្អណាស់ ប្រជារាស្ត្ររីករាយសប្បាយ ពាណិជ្ជកម្មរីកចម្រើន ហើយសាសនិកទទួលបានអំណោយទានជាស្បៀងជារឿយៗ ។ សាសនាចម្រុងចម្រើន សង្គមមានយុត្តិធម៌សមស្របទៅនឹងព្រះទ័យរបស់ព្រះរាជា ។

សត្រូវទាំងឡាយ រួមទាំងពួកចោរលួចចោរប្លន់ផង ខ្លបខ្លាចអំណាចព្រះរាជាខ្លាំងណាស់ ។ មានជនបរទេសជាច្រើនចុះទូកកប៉ាល់ចូលមកកាន់រាជធានី ដែលរីកធំឡើងៗ ។ កិត្តិនាមរបស់រាជធានីល្បីរន្ទឺ ជាហេតុធ្វើឲ្យពួកចិន

[៣៧] តាមមើលទៅរាជធានីចតុម្មុខពេលនោះលាតសន្ធឹងនៅលើមាត់ទន្លេសាបខាងលិច ចាប់ពីស្ពានតាកែវ ឬសត្តយាគដ្ឋាន រហូតដល់ស្ពានឡឺវីស ឬស្ពានភូមិកាតូលិក និងទៅទិសខាងលិចរហូតដល់ស្ពានបាក់ទូកនៅលើផ្លូវទៅកំពត ស្ពាននេះនៅមានឃើញនៅឡើយរហូតដល់ឆ្នាំ១៩០៨ ។

យួន ម៉ាឡេ សៀម ឥណ្ឌា លាវចេញចូលធ្វើពាណិជ្ជកម្ម ឬក៏មកតាំងទីលំនៅតែម្តងក៏មាន ។

ស្តេចសុរិយោពណ៌សោយរាជ្យបាន៤៧ឆ្នាំ បើគិតទាំងរយៈកាល១២ឆ្នាំដែលព្រះអង្គសោយរាជ្យមិនទាន់ទទួលអភិសេកផង ។ ទ្រង់គង់នៅឥន្ទបត្ត១៧ឆ្នាំ ក្នុងនោះ១២ឆ្នាំក្នុងព្រះនាមជារាជានុសិទ្ធិ និង២ឆ្នាំ ជាព្រះរាជា ។ បន្ទាប់ពីឥន្ទបត្ត ទ្រង់បានយាងទៅគង់នៅបាសានក្នុងខែត្រស្រីសន្ធរមិនដល់១ឆ្នាំផង ក៏យាងមកគង់នៅចតុម្មុខបានជិត៣០ឆ្នាំ ។ ក្រោយពីសោយរាជសម្បត្តិបាន៤៧ឆ្នាំ ទ្រង់ក៏ដាក់រាជ្យ ថ្វាយព្រះរាជបុត្រាច្បងព្រះនាមនរាយណ៍រាជា រួចទ្រង់ទទួលយកតំណែងជាព្រះមហាឧបយោរាជបរមបពិត្រ[៣៨] ។

---

[៣៨] ជាភាសាបាលី ៖ ឧវយុវរាជ ។ ឋានៈនេះមាននៅស្រុកលាវ, សៀម និងភូមាដែរ តែនេះគឺជាលើកទី១ ហើយដែលគេប្រទះឃើញក្នុងរាជពង្សាវតារខ្មែរ ។

ឯកសារពង្សាវតារចិនហៅចៅពញាយ៉ាតថាភីងយ៉ា និងថាព្រះអង្គបានបញ្ជូនដំរីជាច្រើនក្បាលជាមួយនឹងផលិតផលពីកម្ពុជាមួយចំនួន ទៅថ្វាយស្តេចក្រុងចិន នៅក្នុងឆ្នាំ១៤១៩ ។ ឯកសារនោះបានលើកពីប្រវត្តិសាស្ត្របរទេសដែលឲ្យដឹងថា រាជទូតកម្ពុជាបានទៅដល់រាជវាំងស្តេចចិន ហើយបានផ្តល់ព័ត៌មានលំអិតអំពីរាជាណាចក្រ ថា “រាជធានីមានទំហំ ៧០លី (២៨គីឡូម៉ែត្រ) ហើយប្រទេសមានវិសាលភាពជាច្រើនពាន់លី (១លីស្មើនឹង៤០០ម៉ែត្រ) ។ នៅក្នុងរាជធានីមានប្រាង្គមួយ និងស្ពានមួយធ្វើអំពីមាស និងមានដំណាក់ស្តេចចំនួន៣០ ។ រៀងរាល់ឆ្នាំព្រះរាជា តែងតែបើកសម័យប្រជុំនៅក្នុងដំណាក់លំហែមួយនៅលើកោះប្រាង្គ១០០ ដែលមានសត្វស្វា ក្ងោក ដំរីស និងរមាស ចូលទទួលចំណីអាហារដែលដាក់ក្នុងស្នូក និងជើងមាស ។ មនុស្សប្រុសស្រីបួងសក់ និងស្លៀកសម្លៀកបំពាក់ខ្លីៗក្រវាត់ខ្សែក្រវាត់ធ្វើអំពីក្រណាត់ ។ គេដាក់ទណ្ឌកម្មដោយកាត់ ច្រមុះ កាត់ដៃជើង ឬសម្លាប់ចោល (សម្លាប់យឺតៗ ឬដោយពិបាក) ទៅតាមស្ថានទម្ងន់នៃទោស ។ ចំពោះពួកចោរ គេដាក់ទោសកាត់ជើងឬកាត់ដៃ” ។ មានចំណុចគួរឲ្យឆ្ងល់មួយ គឺត្រង់ដែលគេនិយាយថា “បើសិនណាជាខ្មែរសម្លាប់ចិន ខ្មែរនោះត្រូវទទួលទោសប្រហារជីវិត តែបើសិនណាជាចិនសម្លាប់ខ្មែរវិញ ចិននោះទទួលទោសត្រឹមតែបង់ប្រាក់ពិន័យប៉ុណ្ណោះ ហើយបើគ្មានប្រាក់បង់ទេ គេលក់” ។

មានពត៌មានលំអិតជាច្រើនទៀត ដែលយើងគួរតែពិនិត្យមើល ព្រោះវាអាចឲ្យយើងដឹងអំពីទំនៀមទម្លាប់ខ្មែរនៅសតវត្សរ៍ទី១៥ ៖ “កាលណាមនុស្សពីរនាក់រៀបអាពាហ៍ពិពាហ៍ជាមួយគ្នា គេនៅតែ២នាក់ក្នុងផ្ទះចំនួន៨ថ្ងៃមិនចេញទៅណាទេ ហើយដុតចង្កៀង ឬទៀនជាប់មិនឲ្យរលត់ឡើយ” ។

“បើមានមនុស្សស្លាប់ គេទុកខ្មោចចោលក្នុងទីរហោឋានឲ្យសត្វហែកស៊ីជាចំណី ។ ប្រុសៗកាន់ទុក្ខដោយកោរសក់ តែស្រីៗគ្រាន់តែកាត់សក់ខាងមុខពីខាងលើថ្ងាសបន្តិចប៉ុណ្ណោះ” ។

“គេសរសេរអក្សរលើស្បែកប្រើស ឬសត្វផ្សេងទៀតដែលគេលាបពណ៌ខ្មៅ” ។

“ខែចន្ទគតិក្រោយគេជាខែទី១នៃឆ្នាំ” ។ ខ្មែរឆ្លាស់ខែនៅខែទី៩ (ចំណុចត្រង់នេះនៅមានរហូតដល់សព្វថ្ងៃ ព្រោះថាខែទុតិយាសាឍ ត្រូវជាខែទី៩នៃឆ្នាំ ឆ្នាំថ្មីចាប់ផ្តើមនៅក្នុងខែមិគសិរ ហើយខែមិគសិរនេះជាខែទី១០នៃឆ្នាំនក្ខត្តយោគ ដែលចាប់ផ្តើមនៅខែចែត្រ) ។

“រាត្រីមានចែកចេញជា ៤យាម” ។

“មានមនុស្សពូកែខាងតារាសាស្ត្រ ចេះទស្សន៍ទាយសូរ្យគ្រាស និងចន្ទគ្រាសបានត្រឹមត្រូវ” ។

## ១៣- ព្រះនារាយណ៍រាមាធិបតី (១៨៣១-១៨៣៦)

ព្រះរាជាអង្គនេះ មានព្រះអភិសេកនាមថា ព្រះបាទសម្តេចព្រះរាជឱង្ការ ព្រះនារាយណ៍រាជាធិរាជរាមាធិបតី ។ គេមិនបានដឹងថា តើព្រះរាជាមុនមានព្រះជន្មរស់នៅបានប៉ុន្មានព្រះវស្សា នៅក្នុងរជ្ជកាលព្រះរាជបុត្រដែលសោយរាជ្យបន្តពីព្រះអង្គទេ គេគ្រាន់តែដឹងថាគេបានបញ្ចុះព្រះអដ្ឋិធាតុរបស់ព្រះអង្គក្នុងចេតិយមួយ នៅលើភ្នំចតុម្មុខ ត្រង់ជ្រុងខាងពាយ័ព្យ ។

តាមមើលទៅ ព្រះអង្គប្រហែលជាមានព្រះជន្មបាន១០ឆ្នាំទៀត ហើយបានគ្រប់គ្រងព្រះរាជាណាចក្ររហូតដល់ពេលទ្រង់សុគតនៅក្នុងឆ្នាំ១៨៣១ ពីព្រោះវាហាក់ដូចជាមានចន្លោះចាប់ពីត្រឹមពេលដែលព្រះអង្គដាក់រាជសម្បត្តិ មកដល់ពេលដែលព្រះនារាយណ៍រាមាធិបតីទទួលការអភិសេក ។

គេនិយាយថាព្រះនារាយណ៍រាមាបានកសាងពីរ៉ាមីដ៥ មួយៗមានកម្ពស់១២០ម៉ែត្រ ក្នុងពេលតែ ៥ខែប៉ុណ្ណោះ ក៏ប៉ុន្តែខ្ញុំមិនដឹងថាតើពីរ៉ាមីដទាំងនោះនៅឯណាទេ មិនមានសំណែសសេសសល់អ្វីបន្តិចឡើយ ។

ព្រះនារាយណ៍សោយរាជ្យបាន៥ឆ្នាំក៏សុគតទៅនៅក្នុងឆ្នាំ១៨៣៦ ។ ទ្រង់មានព្រះរាជបុត្រមួយព្រះអង្គព្រះនាមថា ព្រះស្រីសុរិយោទ័យ ។

## ១៤- ព្រះរាមាធិបតី (១៨៣៦-១៨៦៨)

ព្រះអនុជរបស់ព្រះនារាយណ៍រាមាព្រះនាមស្រីរាជាបានឡើងសោយរាជ្យបន្តពីព្រះរៀមក្នុងព្រះជន្ម១៩ព្រះវស្សា ក្រោមព្រះឋានៈថា សម្តេចព្រះស្រីរាជាធិរាជរាមាធិបតី ។

គ្រាន់តែឡើងគ្រងរាជបល្ល័ង្កភ្លាម ព្រះរាជាអង្គនេះត្រូវប្រយុទ្ធទប់ទល់ជាមួយព្រះភាគិនេយ្យស្រីសុរិយោទ័យជាព្រះរាជបុត្ររបស់ព្រះរៀមដែលបានកេណ្ឌទ័ពប្រឆាំង ដើម្បីទម្លាក់ព្រះអង្គចេញពីរាជសម្បត្តិផង ហើយត្រូវធ្វើចម្បាំងជាមួយពួកសៀមដែលចូលមកដណ្តើមយកខែត្រនគររាជ អង្គរ និងចន្ទគាប៊ុន ផង ។

ព្រះរាជាបានចាត់ឲ្យព្រះអនុជចៅពញាធម្មោរាជា[៣៩] ចេញទៅរៀបចំកម្លាំងទប់ទល់ជាមួយទ័ពស្រួចរបស់សៀមនៅអង្គរធំ រួចហើយបន្ទាប់ពីព្រះអនុជត្រលប់មកចតុម្មុខវិញ ឲ្យយាងទៅកាន់បណ្តាខែត្រខាងត្បូងកេណ្ឌទ័ពឲ្យបាន១២ម៉ឺននាក់ ។ ពេលចៅពញាធម្មោរាជាយាងទៅដល់បាភ្នំ ទ្រង់បានទទួលដំណឹងថា ទ័ពសៀមបានឆ្លងកាត់ព្រំដែនវាយចូលមកហើយ ហើយព្រះរាជា ជាព្រះរៀមបានចេញទ័ពទៅទប់ទល់ប្រយុទ្ធជាមួយសៀម នៅត្រឹមខែត្របាត់ដំបង ។ ពេលនោះព្រះស្រីសុរិយោទ័យក៏ឆ្លៀតឱកាសដណ្តើមយកចតុម្មុខបាន

---

[៣៩] ព្រះរាជបុត្ររបស់ព្រះពញាយ៉ាត ជាមួយអ្នកម្នាងសៀម ។

ហើយបានចូលកាន់កាប់ខែត្រស្ទឹងត្រង់ បារាយណ៍ និងជើងព្រៃផងដែរ[៤០] ។ ក្រោយពីមានការប្រយុទ្ធជាច្រើនលើកច្រើនសា ស្ដេចសៀមក៏ចាប់បានព្រះរាជានឹងព្រះអគ្គម្ចាស់ដែលបះបោរយកទៅស្រុកសៀមទៅ ។

ចៅពញាធម្មោរាជា បានប្រមែប្រមូលទ័ពប្រញាប់ប្រញាល់មកជួយចតុម្មុខ តែត្រូវធ្វើយុទ្ធនាការអស់ពេលមិនតិចជាង៣ឆ្នាំទេ ។ ទីបញ្ចប់ទ័ពសៀម ដែលត្រូវទ័ពខ្មែរលបវាយជាញឹកញយ អស់កម្លាំង និងបាត់បង់ទាហានអស់ជាច្រើន ក៏សម្រេចដកថយឆ្លងដែនទៅស្រុកវិញ ។

ព្រះពញាធម្មោរាជា ដែលពេលនោះកាន់តំណែងជារាជានុសិទ្ធព្រះរាជាណាចក្រ បានរៀបចំចាត់តាំងស្នងការរាជការភ្លាម រួចចាត់អ្នកទាំងនោះឲ្យចុះទៅដឹកនាំបណ្ដាខែត្រទាំងឡាយ ចាប់ពីខែត្រសំរោងទងនៅខាងលិចភ្នំពេញពីខាងក្រោយពញាឮ រហូតទៅដល់ទឹកខ្មៅនៅតាមមាត់សមុទ្រខាងទក្សិណ, និងពីកោះស្លាកែត នៅក្នុងខែត្រល្វាឯម រហូតដល់ពាមមេសរព្រៃនគរ[៤១] និងពាមកញ្ជើ (ជីសណ្ដទន្លេមេគង្គ) ដើម្បីជំនួសចៅហ្វាយខែត្រដែលដឹកនាំទ័ពហែហមទៅ តាមព្រះរាជា ។ បន្ទាប់មក ទ្រង់បានចាត់មន្ត្រីឲ្យទៅទូលព្រះរាជាអំពីអ្វីដែលព្រះអគ្គបានធ្វើ និងការដែលបានរួចខ្លួនមកវិញ ហើយកំពុងតែគង់នៅឯបសិ្ចមបុរី ។

ទទួលបានដំណឹងនេះ ព្រះរាជាបានយាងត្រលប់ចូលមកក្នុងព្រះនគរវិញជាមួយនឹងកងទ័ព និងពួកសៀមដែលទ្រង់បានចាប់យកមកជាឈ្លើយ ។ ពេលយាងមកដល់ខែត្របាត់ដំបង ទ្រង់បានបញ្ជាឲ្យចៅហ្វាយខែត្រ នាំកម្លាំង៥ពាន់នាក់ទៅកាន់ឆាងហ៊ុង[៤២] ដើម្បីត្រៀមទប់ទល់ទ័ពសៀមដែលប្រុងតែនឹងចូលមកម្ដងទៀត ចំណែកខ្លួនព្រះអគ្គ បានបន្តយាងមកគង់នៅក្នុងខែត្រពោធិសាត់ ។ មកដល់ពោធិសាត់ ទ្រង់បានទទួលអ្នកនាំសាររបស់ព្រះ-ធម្មោរាជា ដែលនាំលិខិតមួយច្បាប់មកថ្វាយព្រះអគ្គ ដោយថ្វាយយោបល់ថាសូមឲ្យស្ដេចយាងឡើងទៅខាងជើងដើម្បីកៀងអ្នកអគ្គម្ចាស់ស្រីសុរិយោទ័យដែលគង់នៅទីនោះ ឲ្យយាងចុះមកខាងត្បូងវិញ នឹងអាលធ្វើការប្រយុទ្ធ ។

អនុវត្តតាមយោបល់ព្រះធម្មោរាជា ព្រះរាជាបានយាងទៅកាន់ខែត្រជើងព្រៃ និងបានជួបប្រយុទ្ធជាច្រើនលើក ជាមួយព្រះស្រីសុរិយោទ័យមេក្បត់ ដែលមានកម្លាំងតិចជាង ហើយចេះតែវាយដោះដៃចេញរួចគេចមកគង់នៅក្នុងខែត្រស្រីសន្ធរ បោះបង់បណ្ដាខែត្រដែលកាន់កាប់បានទាំងប៉ុន្មានឲ្យព្រះរាជាវិញ ។

---

[៤០] ខែត្រទាំង៣នេះ ស្ថិតនៅលើច្រាំងទន្លេមេគង្គខាងស្ដាំ ខែត្រទី១ នៅលើច្រាំងទន្លេ ខែត្រ២ទៀតនៅបន្តពីខាងក្រោយតាមលំដាប់លំដោយ ។

[៤១] ខែត្រខាងត្បូងនេះសព្វថ្ងៃគឺ សាយហ្គន គេហៅដំបូងបង្អស់ថា ព្រៃគរ មិនមែនព្រៃនគរទេ ។

[៤២] តាមមើលទៅប្រហែលគឺចង្ហូរថ្ម នៅលើស្ទឹងមង្គលបុរី ចម្ងាយ៤២គីឡូម៉ែត្រខាងលិចបាត់ដំបង ។

នៅពេលដែលទ័ពរបស់ព្រះរាជាឆ្លងទន្លេ រួចមកបោះជំរំនៅត្រង់ ខ្វងមហាសៀក (ទីនេះជាស្រុករបស់ខ្ញុំ) ស្រាប់តែទ័ពព្រះស្រីសុរិយោទ័យមកដល់ ទាំងតាមជើងទឹកទាំងតាមជើងគោក វាយសន្ទ្រុបទៅលើទ័ពហ្លួងនៅត្រើយខាងលិច មិនឲ្យដឹងជាមុន ធ្វើឲ្យទ័ពនោះបរាជ័យទៅ ។ ជ័យជម្នះរបស់ពួកបះបោរនេះ បាននាំមកនូវជ័យជម្នះជាបន្តបន្ទាប់ទៀត ហើយពួកទាហានហ្លួងដែលកេណ្ឌមកពីខែត្រក៏ចាប់ផ្ដើមលួចរត់គេចទៅស្រុកវិញជាហូរហែដែរ ដោយខ្លាចព្រះស្រីសុរិយោទ័យធ្វើបាបគ្រួសារ ។ ការរត់ចោលជួរដ៏សន្ធឹកសន្ធាប់យ៉ាងនេះ រួមផ្សំជាមួយការមកដល់នៃរដូវភ្លៀងផង ធ្វើឲ្យព្រះរាជាត្រូវបង្ខំព្រះទ័យបោះទ័ពនៅក្នុងខែត្រកំពង់សៀម និងស្ទឹងត្រង់ សិនតែខ្លួនព្រះអង្គ ចង់យាងត្រលប់មកចតុម្មុខវិញ ដើម្បីកេណ្ឌទ័ពជាថ្មីច្បាំងជាមួយព្រះភាគិនេយ្យ ។

ក៏ប៉ុន្តែព្រះធម្មោរាជា ដែលយល់ថាសង្គ្រាមនេះនឹងលំបាកហើយអូសបន្លាយពេលវែង ហើយខ្លួនព្រះអង្គអាចឆ្លៀតឱកាសឡើងគង់លើបល្ល័ង្ករាជបាន ទ្រង់បានចាប់ផ្ដើមកេណ្ឌទ័ពក្នុងបណ្ដាខែត្រខាងត្បូង និងខាងលិច ហើយបានផ្ញើសារមួយទៅថ្វាយព្រះរាជា បញ្ចុះបញ្ចូលសុំកុំឲ្យព្រះអង្គលះបង់បណ្ដាខែត្រខាងជើងឲ្យសោះ ព្រោះព្រះស្រីសុយោទ័យអាចនឹងយាងចូលមកកាន់កាប់ភ្លាមនៅពេលល្ងាច បើព្រះរាជាយាងចេញពីព្រឹក ។ តាមពិតគឺព្រះធម្មោរាជាមានបំណងធ្វើយ៉ាងណាឲ្យព្រះរាជារាមាធិបតីឃ្លាតកាន់តែឆ្ងាយពីរាជធានី ។ ប៉ុន្តែព្រះរាជាមិនបានដឹងអំពីបំណងអាក្រក់នេះទេ ទ្រង់ក៏ធ្វើដំណើរយាងត្រលប់ទៅខែត្រពោធិសាត់វិញ តាមមតិព្រះអនុជទៅ ។ ពេលនោះព្រះធម្មោរាជាបានបែងចែកទ័ពជាច្រើនកង មួយកងទ្រង់ឲ្យមកឈរជើងនៅខដុគ្គ មួយកងទៀតទៅឈរនៅត្រង់ពាមស្ទឹងក្រាំងពន្លៃ កងទី៣ទៅឈរនៅខ្សាច់កណ្ដាល និងកងទី៤នៅល្វាឯម ចំពីមុខចតុម្មុខ ។ រួចហើយទ្រង់បានចាត់ឲ្យមានការយាមកាមម៉ឺងម៉ាត់តាមច្រករបៀងផ្សេងៗ ទាំងតាមជើងគោក និងជើងទឹក ជាពិសេសច្រកចេញចូលពីខាងជើង និងខាងកើត ។ ធ្វើយ៉ាងនេះ ទើបទ្រង់អាចការពារខ្លួនព្រះអង្គ ពីព្រះរាជា ជាព្រះរៀមផង និងព្រះស្រីសុរិយោទ័យជាព្រះភាគិនេយ្យផង ។

ទ័ពរបស់ព្រះធម្មោរាជាមានការហ្វឹកហាត់ជារៀងរាល់ថ្ងៃនៅចតុម្មុខ ហើយក៏មានអាវុធយុទ្ធភណ្ឌ សម្បូរបែបទៀតផង ។ រាជធានីមានកំពែងការពាររឹងមាំ មានស្បៀងគ្រប់គ្រាន់ ។ រួចហើយព្រះអង្គបានចាត់បញ្ជូនព្រះជាយាទាំងអស់របស់ព្រះរាជាដែលគង់នៅភ្នំពេញ ហើយដែលបែកពីព្រះរាជាយូរណាស់មកហើយ ឲ្យទៅជួបជុំនឹងព្រះរាជាវិញ ។ ធ្វើដូច្នេះមានន័យថា ទ្រង់បានកាត់ផ្ដាច់ទំនាក់ទំនងជាមួយព្រះរាជាជាស្រេច ហើយក៏ជាសញ្ញាទូលព្រះរាជាថា សូមកុំឲ្យព្រះអង្គមានព្រះទ័យចង់ត្រលប់មកកាន់ចតុម្មុខវិញធ្វើអ្វី ។

ចំណែកឯព្រះខ័នរាជ្យ កេតនភណ្ឌសម្គាល់រាជានិយម ទ្រង់មិនបានផ្ញើថ្វាយព្រះរាជាទេ គឺទ្រង់រក្សាទុកខ្លួនព្រះអង្គឯង ដែលជាហេតុធ្វើឲ្យឃើញយ៉ាងច្បាស់អំពីផែនការក្បត់របស់ព្រះអង្គដែលបានរៀបចំឡើងយ៉ាងល្អតាំងពីយូរយារណាស់មកហើយ រហូតមកដល់ពេលនេះ ។

ព្រះរាជា ក៏ចាប់មិនពេញព្រះទ័យនឹងសារលិខិត និងទូតរបស់ព្រះធម្មោរាជា ហើយទ្រង់មានព្រះបន្ទូលថា

ទ្រង់នឹងកេណ្ឌទ័ពដើម្បីវាយចូលចតុម្មុខបណ្ដេញព្រះអនុជចេញ រួចយាងទៅស្រីសន្ធរធ្វើសង្គ្រាម ជាមួយព្រះភាគិនេយ្យជាបន្តទៀត ។ ក៏ប៉ុន្តែនាម៉ឺនសព្វមុខមន្ត្រីបានថ្វាយយោបល់ថា សូមឲ្យព្រះអង្គគង់នៅស្ងៀមហាក់ដូចជាមិនដឹងអ្វីសិន ដើម្បីកុំឲ្យពួកក្បត់ទាំង២ចងសម្ព័ន្ធមេត្រីជាមួយគ្នាប្រឆាំងនឹងព្រះអង្គ ។

ព្រះរាជាបានយាងមកបោះជំរំនៅបរិបូណ៌ដែលកាលណោះមានឈ្មោះថា អម្រឹតបូរ[៤៣] ដើម្បីឲ្យព្រះអង្គងាយស្រួលក្នុងការត្រួតពិនិត្យបណ្ដាខេត្រខាងលិច រួមមានរលាប្អៀរ ពោធិសាត់ បាត់ដំបង និងនាងរង ដែលនៅជាប់នឹងព្រំដែនសៀម, បណ្ដាខេត្រខាងជើងចាប់ពីកំពង់សៀម ជើងព្រៃ គោកសេះ (បារាយណ៍) ស្ទឹងត្រង់ កំពង់ស្វាយ រហូតទៅដល់គោកខាន់ដែលនៅខាងត្បូងភ្នំដងរែក និងសុរិនអង្គរកដែលនៅភាគខាងជើងភ្នំដងដែរ ។

នៅពេលនោះ ព្រះស្រីសុរិយោទ័យ ក៏ចាត់ឲ្យរៀបចំអភិសេកខ្លួនព្រះអង្គក្រោមព្រះឋានៈជាព្រះបាទសម្ដេចស្ដេចព្រះរាជឱង្ការ ព្រះស្រីសុរិយោទ័យរាជាធិរាជ ព្រះរាជានៃក្រុងស្រីសន្ធរបុរាបុរី ។ ព្រះរាជាណាចក្រស្រីសន្ធរនេះរួមមានបណ្ដាខេត្រដែលស្ដេចបះបោរនេះដណ្ដើមបាន គឺចាប់ពីត្បូងឃ្មុំ ស្រីសន្ធរ បាភ្នំ រហូតទៅដល់បារាជដុងណាយដែលនៅជាប់នឹងរាជាណាចក្រចាម្ប៉ា ពោលគឺទឹកដីទាំងអស់នៅចន្លោះជួរភ្នំអាណ្ណាម និងទន្លេមេគង្គ ចាប់ពីសម្បូរចុះមករហូតទៅដល់មាត់សមុទ្រ លើកលែងតែល្វាឯម និងព្រៃនគរ (សាយហ្គន) ចេញ ដែលស្ថិតនៅក្រោមការត្រួតត្រារបស់ព្រះធម្មោរាជា គឺប្រហាក់ប្រហែលជាទឹកដីកម្ពុជាដែនគោកពីមុន ។

ក្នុងពេលជាមួយគ្នានោះ នៅចតុម្មុខឯណោះវិញ នាម៉ឺនសព្វមុខមន្ត្រីក៏បានសំណូមពរឲ្យព្រះធម្មោរាជាឡើងសោយរាជជំនួសព្រះរៀមជាព្រះរាជាផងដែរ តែព្រះធម្មោរាជាធ្វើជាប្រកែក ហើយមានព្រះបន្ទូលថា ទ្រង់ចង់ដឹកនាំបណ្ដាខេត្រដែលទទួលស្គាល់អំណាចរបស់ព្រះអង្គ ដើម្បីឲ្យប្រជានុរាស្ត្របានសម្បូរសប្បាយជាងមុន ដូច្នេះ ព្រះអង្គមិនចាំបាច់ធ្វើជាព្រះរាជាទេ ។

បណ្ដាខេត្រដែលព្រះធម្មោរាជាគ្រប់គ្រងនាពេលនោះមានៈ នៅខាងលិច ចាប់ពីសំរោងទងរហូតដល់កំពង់សោមនៅលើមាត់សមុទ្រ, នៅខាងកើត និងខាងត្បូង ចាប់ពីកោះស្លាកែតនៅចន្លោះដៃទន្លេមេគង្គទាំង២ ល្វាឯម ព្រៃនគរ (សាយហ្គន) នៅលើមាត់ទន្លេធំ រហូតដល់ពាមកញ្ជើ (ដីសណ្ដទន្លេមេគង្គ) ។

ដូច្នេះព្រះរាជាណាចក្រកម្ពុជាពេលនោះបែកចេញជា៣ក្រោមការត្រួតត្រារបស់ស្ដេច៣អង្គ គឺព្រះរាជាពេញសិទ្ធិស្រីរាមាធិបតីសោយរាជ្យនៅខាងជើងបរិបូណ៌, ស្ដេចបះបោរស្រីសុរិយោទ័យជាព្រះភាគិនេយ្យរបស់ព្រះរាជា សោយរាជ្យនៅខាងកើត និងស្ដេចបះបោរមួយអង្គទៀតគឺព្រះធម្មោរាជា ត្រូវជាព្រះអនុជរបស់

---

[៤៣] អម្រឹតបុរៈ ជាឈ្មោះទីប្រជុំជនមួយនៅលើមាត់ទន្លេសាបខាងស្ដាំ ។ រាជធានីចុងក្រោយរបស់ភូមាមួយដែលសង់ឡើងដោយស្ដេចអាឡុំប្រាក៏មានឈ្មោះដូចគ្នានេះដែរថា អម្របុរៈ ។

ព្រះរាជាសោយរាជ្យនៅខាងត្បូង ។

ក្នុងពេលដំណាលគ្នានោះ នគរចាម្ប៉ា និងអាណ្ណាមកំពុងតែជាប់ធ្វើសង្គ្រាមនឹងគ្នាបន្តមកជាយូរឆ្នាំហើយ ។ ពួកចាមចាញ់ដៃ ពួកអាណ្ណាមបានលើកព្រះអង្គម្ចាស់មហាគ៊ីឡៃ ដែលត្រូវជាព្រះភាគិនេយ្យរបស់ស្ដេចមុន ហើយមានដើមកំណើតចេញពីចាម្ប៉ា ដែលអាណ្ណាមធ្លាប់ដណ្ដើមយកបានរួចមកហើយ ឲ្យឡើងសោយរាជ្យ ។ ព្រះអង្គម្ចាស់ចាមមួយអង្គទៀត ដែលមិនព្រមចុះចូលជាមួយអាណ្ណាម មានព្រះនាមថាពោធិរុង្គក្លាត្រាគ្រុត ឬពោធិភិន្នួស អាណ្ណាមហៅថា គ៊ីដូ បានកេណ្ឌទ័ពជាច្រើនវាយលុកលុយអាណ្ណាម ។ ស្ដេចនេះ ដណ្ដើមបានខែត្រ២ ប៉ុន្តែ ត្រូវដកថយវិញនៅក្នុងឆ្នាំ១៤៤៥ ក្រោមការវាយប្រហារពីស្ដេចអាណ្ណាមឡេញ៉ាញ់តុង[៤៤] ដែលដឹកនាំទ័ពជា ពាកង វាយដណ្ដើមយកទឹកដីមកវិញ និងតាមវាយរហូតដល់មកក្នុងព្រះរាជាណាចក្រថែមទៀត ។ ពេលនោះស្ដេចចាម បានបញ្ជូនសារមកសុំជំនួយពីព្រះស្រីសុរិយោទ័យ តាមរយៈចៅហ្វាយខែត្របារាជដុងណាយ ។ ព្រះស្រីសុរិយោទ័យ មិនបានបញ្ជូនទ័ពទៅជួយចាមទេ ព្រះអង្គមានព្រះបន្ទូលថា ព្រះរាជាណាចក្រកំពុងតែមានសង្គ្រាមដែរ ។ គ្មានជំនួយពីខ្មែរ ស្ដេចចាមក៏ត្រូវបរាជ័យ អាណ្ណាមចាប់បានជាឈ្លើយ ហើយស្រុកចាមក៏ត្រូវបែងចែកជា «រាជាណាចក្រតូចធំ» ស្ថិតនៅក្រោមអំណាចស្ដេចចាមផ្សេងៗដែលស្ថិតក្រោមការត្រួតត្រារបស់វ៉ៃស៊ីដង់អាណ្ណាមម្នាក់ ។

មានពួកចាមជាច្រើននាក់ ជាពិសេសគឺពួកដែលបានតស៊ូប្រយុទ្ធរហូតដល់ដំណាក់កាលចុងក្រោយ រួមមានពួកមន្ត្រី និងសេនាហែហមផង មិនព្រមទទួលយកអាណានិគមរបស់អាណ្ណាមទេ ម្ល៉ោះហើយក៏នាំគ្នារត់មកជ្រកកោននៅកម្ពុជា ។ ខ្លះទៀតគេចខ្លួនទៅរស់នៅជាមួយពួកព្នង មោង រដែ ចារ៉ាយ និងម៉ុយ ។

នៅក្នុងឆ្នាំនោះ ព្រះរាជាទិសខាងជើង ព្រះរាមាធិបតី ដែលគង់នៅឯអម្រឹតបូរ (បរិបូណ៌) ចន្លោះកំពង់ឆ្នាំង និងពោធិសាត់ បានសរសេរលិខិតមួយផ្ញើថ្វាយព្រះអនុជជារាជានុសិទ្ធនៅទិសខាងត្បូង សូមឲ្យផ្ញើព្រះខ័នរាជ្យ អាវក្រោះសម្រាប់ទាហាន សេះ និងដំរី ដែលព្រះអង្គបានប្រមែប្រមូលនៅចតុម្មុខពីមុន មកថ្វាយព្រះអង្គ ។ ព្រះធម្មោរាជា បានប្រកែកមិនព្រមប្រគល់មកឲ្យទេ ដោយទ្រង់មានព្រះបន្ទូលថាកេតនភណ្ឌទាំងអស់ ជារបស់សម្រាប់រាជធានី ប៉ុន្តែទ្រង់យល់ព្រមផ្ញើអាវក្រោះ២០សម្រាប់ៗពលរទេះ ឬខ្ញុំបររទេះ ។ ព្រះរាជា ខ្ញាល់ជាខ្លាំងនឹងចម្លើយរបស់ព្រះអនុជ ហើយក៏ប្រាប់អ្នកនាំសារថាព្រះអនុជបានផ្ញើអាវក្រោះពីសម័យមុន ដែលគេលែងប្រើទៅហើយ ទ្រង់មិនចង់បានទេ ។ រួចហើយបានក៏ឲ្យអ្នកនាំសារនោះទៅសុំយកកេតនភណ្ឌ សាជាថ្មីឡើងវិញ និងបានចាត់មនុស្សដទៃឲ្យទៅចតុម្មុខជួយសុំជាច្រើនដងផងដែរ តែឥតប្រយោជន៍ ។ ព្រះធម្មោរាជា បដិសេធ

[៤៤] មានព្រះនាមមួយទៀតថា បង់គី ។

មិនព្រមប្រគល់ព្រះខ័នរាជ្យ អាវក្រោះ សេះ និងដំរី មកថ្វាយព្រះវៀមទេ ។

នៅគ្រិស្តសករាជ១៨៦៨ ត្រូវនឹងមហាសករាជ១៣៩០ និងចុល្លសករាជ៨៣០ ព្រះធម្មោរាជា ដែលកាលពីប៉ុន្មានឆ្នាំមុនប្រកែកមិនព្រមឡើងសោយរាជ្យ បានឲ្យគេអភិសេកព្រះអង្គក្រោមព្រះនាមថា សម្តេចស្តេចព្រះរាជឱង្ការ ព្រះធម្មោរាជាធិរាជរាមាធិរាជាធិបតី ព្រះរាជានៃកម្ពុជា ។ ពេលនោះទ្រង់មានព្រះជន្ម ២២ ព្រះវស្សា ។ ព្រះមហេសីទី១របស់ព្រះអង្គដែលជាប់សាច់សារលោហិតរាជវង្ស បានត្រូវគេដំឡើងជាព្រះអគ្គមហេសី មានព្រះឋានៈជាសម្តេចព្រះភគវតីទេពធីតារាជទេវី ។ បន្ទាប់មកព្រះរាជាបានកំណត់ឋានៈ និងសញ្ញាសម្គាល់បណ្តាមន្ត្រីព្រះរាជវាំង សមាជិកព្រះរាជវង្សានុវង្ស ហើយបានលើកបណ្តាអ្នកដែលតាមដង្ហែព្រះអង្គ ជាមន្ត្រីទាំងអស់[៤៥] ។

ដំណឹងអំពីការលើកព្រះធម្មោរាជាឲ្យឡើងសោយរាជ្យដូច្នេះ បានធ្វើឲ្យព្រះរាជាស្រីរាមាធិបតី រឹតតែខ្វល់ខ្វាំងឡើង ។ ព្រះអង្គហៀបតែនឹងរៀបចំទ័ពធ្វើដំណើរមកវាយដណ្តើមយកចតុម្មុខ បណ្តេញស្តេចជ្រែករាជ្យចេញទៅហើយ ស្រាប់តែស្តេចបះបោរមួយអង្គទៀតគឺព្រះស្រីសុរិយោទ័យដែលគង់នៅឯស្រីសន្ធរ បានវាយដណ្តើមយកស្រុកស៊ឹងត្រង់បាន នៅដើមរដូវវស្សា ។ ទ័ពដែលកេណ្ឌប្រមូលយកមកវាយស្តេចនៅចតុម្មុខក៏ត្រូវបំបែរឲ្យទៅវាយស្តេចនៅស្រីសន្ធរវិញ ។ មានការជួបប្រយុទ្ធជាច្រើនលើកច្រើនសានៅក្នុងខែត្រស៊ឹងត្រង់ ក៏ប៉ុន្តែគ្មានឈ្នះគ្មានចាញ់ ។ ពេលរដូវសាបព្រោះមកដល់ ទ័ពទាំង២ខាងក៏រំសាយចេញដើម្បីឲ្យពលទាហានទៅធ្វើស្រែចម្ការសិន(១៨៦៩) ។

ព្រះរាជាណាចក្រមានស្តេច៣ព្រះអង្គប្រឆាំងគ្នានៅសោយរាជ្យពាក់ន្ទែងប៉ុន្តែមិនច្បាំងគ្នាទេ ហាក់បីដូចជាបានទទួលស្គាល់ការបែងចែកទឹកដីរវាងគ្នានឹងគ្នា មានសន្តិភាពបណ្តោះអាសន្នចាប់តាំងពីឆ្នាំ១៨៦៧ រហូតដល់ឆ្នាំ១៨៧៣ ទើបចាប់មានការប្រយុទ្ធគ្នាឡើងវិញ ។

នៅឆ្នាំ១៨៧៤ ព្រះរាជាទិសខាងជើង ក្រោយពីរៀបចំកសាងទូកសំពៅបានមួយចំនួន និងប្រមែប្រមូលស្បៀងគ្រប់គ្រាន់ ក៏ចាប់ផ្តើមបើកការវាយប្រហារទៅលើព្រះភាគិនេយ្យជាស្តេចនៅស្រីសន្ធរ ។ ព្រះរាជាស្រីសន្ធរ បានបញ្ចេញកម្លាំងទ័ពសន្ធឹកសន្ធាប់ទប់ទល់តវិញ ទាំងខាងជើងទឹកទាំងខាងជើងគោកធ្វើឲ្យព្រះរាជាទិសខាងជើងមិនអាចធ្វើអ្វីបាន ។ ពេលនោះ ព្រះរាជានៅឯចតុម្មុខក៏បានរៀបចំកម្លាំងទ័ពផងដែរ ត្រៀមខ្វាចក្រែងការប្រយុទ្ធហៀរមកដល់នឹងអាលប្រានចេញ ទោះជាមកពីខាងជើងឬពីខាងកើតក្តី ។

---

[៤៥] រាជពង្សាវតារបាននិយាយថា នៅឆ្នាំនោះមានរញ្ជួយព្រះធរណីអស់រយៈពេល ៥ម៉ោង តាមមើលទៅប្រហែលជាការរញ្ជួយបន្តបន្ទាប់ក្នុងរយៈពេល ៥ម៉ោង ។

អាស្រ័យដោយព្រះរាជាទាំង៣ព្រះអង្គ និងពលរេហ៍ទាំងអស់ត្រូវកាន់អាវុធត្រៀមជាប់ជានិច្ច និងដោយសង្គ្រាមផ្ទៃក្នុងរ៉ូសបន្ទាយជង់នោះ បណ្តាឲ្យប្រទេសមានអនាធិបតេយ្យជាខ្លាំង ។ នៅតាមស្រុកស្រែចម្ការមានកើតចោរ ខ្នញ អំពើលួចឆក់កើនឡើង ធ្វើឲ្យប្រជានុរាស្ត្រដែលត្រូវរងការឆក់ប្លន់ជាប់ជានិច្ច រងទុក្ខវេទនាជាខ្លាំង ។ ម្យ៉ាងទៀត រាជាណាចក្រត្រូវរងការគំរាមពីពួកសៀមថែមទៀត ដែលលូកដៃចូលមកផ្ទៃក្នុង ដោយមានសំណូមពរអន្តរាគមន៍ពីព្រះធម្មោរាជា ដែលបានផ្ញើសារលិខិតមួយច្បាប់ទៅស្តេចសៀម ។

សៀមចូលលុកលុយកម្ពុជានៅដំណាច់រដូវវស្សា ក្នុងខែអស្សុជ ប្រើទ័ពពាម៉ឺននាក់ដឹកនាំដោយចៅពញាម្នាក់ ព្រះស្រីជាតិកម្នាក់ និងដោយព្រះតេជាដែលជារាជទូតរបស់ព្រះធម្មោរាជា មកចុះកប៉ាល់នៅខែត្រកំពត និងពាម (សព្វថ្ងៃគឺហាទៀង) រួចដើរតាមផ្លូវបន្ទាយមាសសំដៅមករកចតុម្មុខ ។ ចំណែកឯស្តេចសៀមវិញ ដែលគ្រងសម្បៀកបំពាក់ចម្បាំង បានយាងលើខ្នងដំរីចេញដំណើរមកបាត់ដំបង ។ ស្តេចសៀមមានទ័ពស្រួចមួយកង ស្ថិតនៅក្រោមបញ្ជាការរបស់ខុកញ៉ាក្រឡាហោម មេទ័ពខាងជើងទឹក, ទ័ពស្ទាបឆ្វេងមួយកង បញ្ជាដោយខុកញ៉ាចក្រីមេទ័ពដីវិប្ចូរដ្ឋមន្ត្រីខាងសង្គ្រាម, ហើយនិងទ័ពស្ទាបស្តាំមួយកងទៀតស្ថិតនៅក្រោមបញ្ជាការរបស់ពញាព្រះឃ្លាំង រដ្ឋមន្ត្រីខាងសេដ្ឋកិច្ច ។

ពេលនោះព្រះធម្មោរាជាបានដឹកនាំទ័ពចេញពីចតុម្មុខ ធ្វើដំណើរឆ្ពោះទៅទិសខាងជើង ។ ទ្រង់បានយាងមកបោះជំរំនៅអម្រឹតរណបុរៈ សង់រាជពន្លាមួយរង់ចាំទទួលស្តេចសៀម ដែលយាងកាត់តាមបាត់ដំបង ពោធិ-សាត់ និងក្រាំង ។

ស្តេចសៀម និងព្រះធម្មោរាជាជួបគ្នានៅបរិបូណ៌នោះ ហើយដោយស្តេចសៀមមានព្រះជន្មតិចជាង ទ្រង់ហៅព្រះធម្មោរាជាថា ព្រះរៀម ឯព្រះធម្មោរាជាហៅស្តេចសៀមថា ព្រះអនុជ ។ ស្តេចទាំង២អង្គពិភាក្សាគ្នា អំពីផែនការប្រយុទ្ធដែលត្រូវអនុវត្ត រួចបានដឹកនាំទ័ពសំដៅទៅឡោមព័ទ្ធវាយខែត្រកំពង់សៀម ដែលជារាជធានីរបស់ព្រះរាជាទិសខាងជើង ។

ព្រះរាជាទិសខាងជើងស្រីរាមាធិបតី ក៏ប្រជុំនាម៉ឺនសព្វមុខមន្ត្រីសាកសួរយោបល់ មន្ត្រីមួយចំនួន ថ្វាយព្រះយោបល់ថា ដោយព្រះអង្គមានទ័ពតិចជាងទ័ពសត្រូវ ណាមួយស្បៀងក៏ខ្វះខាតផង ព្រះអង្គមិនគួរប្រយុទ្ធតបតទេ គួរសាកល្បងសុំចងសម្ព័ន្ធមេត្រីជាមួយព្រះរាជាចតុម្មុខវិញ ។ ក៏ប៉ុន្តែពួកមេទ័ពប្រកែកមិនព្រមឯកភាពជាមួយមតិក្បត់បែបនេះទេ គេប្រកាសថាត្រូវតែធ្វើសង្គ្រាមរហូតអវសានជីវិត ដើម្បីការពារព្រះរាជាណាចក្រប្រឆាំងនឹងពួកសៀម និងពួកខ្មែរក្រុមស្តេចធម្មោរាជា ។ ព្រះស្រីរាមាធិបតីបានយល់ស្របតាមមតិពួកមន្ត្រីដែលមិនចង់ធ្វើសង្គ្រាម ហើយបានសម្រេចថានឹងសុំចុះចាញ់ព្រះអនុជ ជាព្រះរាជាជ្រែករាជ្យនៅចតុម្មុខ ។ ទ្រង់បានចាត់ខុកញ៉ាយោមរាជ រដ្ឋមន្ត្រីយុត្តិធម៌ និងខុកញ៉ាវាំង ជារដ្ឋមន្ត្រីទទួលកិច្ចការព្រះរាជវាំង ឲ្យទៅចរចាពីការសុំចុះចូលរបស់ព្រះអង្គនេះ ។

គេបានឯកភាពគ្នាថា នឹងរៀបចំឲ្យមានការជួបគ្នារវាងស្ដេចទាំង៣អង្គនៅក្នុងខែត្រសំរោងទង ក្នុងជំរំមួយ ដែលគេសង់ព្រះពន្លាជាបន្ទាន់សម្រាប់ព្រះរាជា និងមន្ត្រីរបស់ព្រះអង្គ ដែលយាងមកដោយមិនមានអាវុធជាប់មកជាមួយផងទេ ។ ស្ដេចសៀមបានប្រកាសថា ព្រះអង្គដែលយាងមកកម្ពុជាពេលនេះ គឺដើម្បីជួយរៀបចំសន្តិភាព និងបញ្ចប់សង្គ្រាមរវាងព្រះបិតុលា និងព្រះភាគិនេយ្យ ដែលមានរយៈពេលជាយូរយារណាស់មកហើយ ហើយមិនមានឈ្នះមានចាញ់ ។ រួចទ្រង់មានបន្ទូលទៅកាន់ព្រះរាជាកម្ពុជាថា «ដើម្បីផលប្រយោជន៍ព្រះពុទ្ធសាសនា និងដើម្បីរៀបចំប្រទេសទាំងមូលឲ្យមានសណ្ដាប់ធ្នាប់ឡើងវិញ សូមស្ដេចយាងចេញពីព្រះនគរទៅគង់នៅឯប្រទេសសៀម ហើយសូមប្រគល់ព្រះរាជបុត្ររបស់ព្រះអង្គ ពញាអុង ឲ្យទូលព្រះបង្គំធ្វើជាបុត្រចិញ្ចឹមថែរក្សាតទៅ ។ មន្ត្រីទាំងអស់អាចនឹងតាមព្រះអង្គទៅស្រុកសៀម ឬមិនទៅតាមចិត្តចង់» ។

មានព្រះបន្ទូលចប់ ស្ដេចសៀមដាក់បញ្ជាឲ្យពលសេនាតាមពិនិត្យសកម្មភាពរបស់ព្រះរាជាកម្ពុជាឲ្យជាប់ រួចយាងចូលក្នុងព្រះពន្លាបាត់ទៅ រួចហើយបានចាត់មន្ត្រីម្នាក់ឲ្យទៅយាងព្រះស្រីសុរិយោទ័យមកជួបព្រះអង្គ ។ ស្ដេចដណ្ដើមរាជ្យទិសខាងកើតនេះរីករាយខ្លាំងណាស់ នឹងឃើញព្រះបិតុលាស្រីរាមាធិបតី ជាប់ជាចំណាប់ខ្មាំងរបស់ស្ដេចសៀម ។ ទ្រង់មានព្រះតម្រិះថាព្រះរាជាណាចក្រនឹងត្រូវបែងចែកតែ២ចំណែករវាងខ្លួនព្រះអង្គ និងព្រះបិតុលាធម្មោរាជា ដែលមានព្រះជន្មតិចជាងព្រះអង្គផងនោះ ទ្រង់ក៏យាងមកជួបស្ដេចសៀម ។

ពេលមកដល់ ព្រះស្រីសុរិយោទ័យឃើញព្រះធម្មោរាជា គង់នៅចាំជាមួយស្ដេចសៀមនៅក្នុងព្រះពន្លាជាស្រេច ។ ស្ដេចសៀម ទទួលស្វាគមន៍ព្រះអង្គពីលើព្រះពន្លាមក ដោយមានព្រះបន្ទូលថា ព្រះអង្គបានធ្វើសង្គ្រាមជាមួយព្រះបិតុលាយូរហើយមិនចាញ់មិនឈ្នះ ឥឡូវនេះ ព្រះបិតុលាបានសម្រេចយាងចេញពីព្រះនគរទៅគង់នៅឯស្រុកសៀមហើយ ដូច្នេះវាមិនយុត្តិធម៌ទេបើសិនជាព្រះអង្គនៅគង់ក្នុងប្រទេស ។ បន្ទាប់មក ស្ដេចសៀមបានយាង ព្រះសុរិយោទ័យ ចូលក្នុងបន្ទាយ រង់ចាំពេលចេញដំណើរទៅកាន់ស្រុកសៀម ។

ព្រះស្រីសុរិយោទ័យហៀបតែនឹងធ្វើតាមបញ្ជាស្ដេចសៀមទៅហើយ ស្រាប់តែទាហានរបស់ព្រះអង្គដែលពិនិត្យឃើញថាព្រះអង្គក្លាយជាចំណាប់ខ្មាំងរបស់ស្ដេចសៀម បាននាំគ្នាសម្រុកចូលមកក្នុងបន្ទាយតាមព្រះអង្គ ក៏កើតជាជម្លោះឡើងជាមួយទ័ពសៀមដែលរារាំងផ្លូវ ប៉ុន្តែត្រូវដេញវាយបែកខ្ញែកគ្នាទៅស្រុកវិញអស់ ។

## ១៥- ព្រះធម្មោរាជា (១៤៦៨-១៥០៤)

ព្រះធម្មោរាជា និងព្រះរាជាសៀមបានធ្វើដំណើរជាមួយកងទ័ពមកកាន់លង្វែក ដោយនាំយកព្រះរាជាចំណាប់ខ្មាំងទាំង២អង្គដែលត្រូវយកទៅកាន់អយុធ្យា មកជាមួយផង ។ មកដល់រាជធានីរបស់កម្ពុជាខាងជើងនេះ ស្ដេចទាំង២ បានថ្វាយវត្ថុអនុស្សាវរីយ៍គ្នាទៅវិញទៅមក រួចហើយស្ដេចសៀម ក៏បន្តដំណើរទៅពោធិសាត់

បាត់ដំបង មង្គលបុរី ស្រីសោភ័ណ ស្វាយសិសុផុន សំរោងសិច ព្រះនគរនិងបាត់ដំបងទៅក្រសាត់ដាក់រាជនីព្រះអង្គទៅ[៩៦] ។ បណ្ដាគ្រួសារសៀម ដែលស្ដេចខ្មែរបានកេណ្ឌមកជាមួយពីមុន ក៏នាំគ្នាធ្វើដំណើរតាមទ័ពសៀម ត្រលប់ទៅស្រុកវិញដែរ ។

នៅពេលនោះ ព្រះធម្មោរាជា បានយាងត្រលប់មកកាន់ចតុមុខវិញ រួចហើយទ្រង់បានចេញបញ្ជាឲ្យទ័ពសៀមដែលធ្វើដំណើរមកតាមសមុទ្រ ប្រញិបប្រញាប់ចុះទូកចេញតាមស្ទឹងបន្ទាយមាស និងពាម ត្រលប់ទៅវិញដែរ ។

និយាយពីស្ដេចសៀមវិញ ក្រោយពីឆ្លងផុតព្រំប្រទល់ដែនហើយ បានបញ្ជាឲ្យទ័ពបោះជំរំសម្រាក ៣ថ្ងៃ ។ នៅពេលនោះ ព្រះរាមាធិបតី ដែលប្រកែកពុំព្រមសោយអាហារ និងមិនព្រមស្រង់ទឹកចាប់តាំងពីពេលចេញដំណើរពីលង្វែកមក ក៏ធ្លាក់ខ្លួនប្រឈួនរួចសុគតទៅដោយទុក្ខសោកសង្រេង និងអត់អាហារ ។ ស្ដេចសៀម បានរៀបចំសពព្រះរាជាដាក់ក្នុងមឈូសប្រគល់ឲ្យ ពញាអុង ជារាជបុត្ររបស់ព្រះអង្គ ។ ព្រះពញាអុងនេះ ស្ដេចសៀម បានសុំធ្វើជាបុត្រចិញ្ចឹម រួចថ្វាយព្រះឋានៈជាព្រះសុជានរាជា គឺជាឋានៈរបស់ព្រះរាជបុត្រច្បងរបស់ស្ដេចនៅស្រុកសៀម ។ ក្រោយមក ស្ដេចសៀមបានលើកឲ្យធ្វើជាចៅហ្វាយខែត្រសុវណ្ណលោក និងរៀបអភិសេកបុត្រីរបស់ព្រះអង្គឲ្យជាព្រះជាយា ។

ចំណែកព្រះសុរិយោទ័យវិញ បានសុគតបាត់ទៅ ក្រោយពីយាងទៅដល់អយុធ្យាបាន ១៥ថ្ងៃ ។

អស់អ៊ីនឹងគួរឲ្យបារម្ភទៀត ព្រះធម្មោរាជា បានដឹកនាំកម្ពុជាប្រកបដោយយុត្តិធម៌ ។ ទ្រង់បានដំឡើងឋានៈសេនាដែលស្មោះត្រង់នឹងព្រះអង្គ ឲ្យកាន់មុខងារសំខាន់ៗក្នុងព្រះរាជាណាចក្រ រួចបានចាត់ឲ្យកសាងសាលាឆទានដើម្បីទ្រង់យាងមកចែកអំណោយឲ្យប្រជារាស្ត្រក្រីក្រ ។ នៅឆ្នាំ១៤៩៥ នៃគ្រិស្តសករាជ ទ្រង់បានលើកលែងមិនឲ្យយកពន្ធដារពីប្រជារាស្ត្រចំនួន ៣ឆ្នាំ ។

រាជពង្សាវតារបានលើកអំពីព្រះរាជាអង្គនេះ ថាជាក្សត្រខ្សម្រាប់ព្យាយាម ចូលចិត្តការសិក្សា ហើយទ្រង់ចេះចាំរត់មាត់គម្ពីរព្រះត្រៃបិដកចាប់ពីដើមរហូតដល់ចប់ ។ ព្រះអង្គបានបរិច្ចាគរាជទ្រព្យជាច្រើនដាក់ទានឲ្យប្រជារាស្ត្រ ហើយបានសុំខមាទោសអំពីសំណាក់សាសនិកជន ។ គេនិយាយថាព្រះអង្គថែមទាំងបានអធិប្បាយអំពីព្រះធម្មចក្រកប្បវត្តនសូត្រ ចែកជូនមន្ត្រីសេនាបតីរបស់ព្រះអង្គជាទីសណ្ដាប់ទៀតផង ហើយទ្រង់ឈ្មេងយល់ថា ព្រះអង្គ គឺជាព្រះពោធិសត្វមួយអង្គ ។

គេនិយាយថា ក្រោយពីទ្រង់យល់សុបិនមួយរួចមក ព្រះអង្គបានចាត់ឲ្យកសាងវិហារ និងចេតិយ នៅភ្នំសន្ទុក និងបានចាត់ឲ្យឆ្លាក់ចម្លាក់រាក់រៀបរាប់អំពីព្រះពុទ្ធអង្គគង់ឈរ និងផ្ទំ រូបគ្រុឌ រូបព្រហ្ម និងរូបសិង្ហ នៅលើ

[៩៦] នេះគឺជាផ្លូវពីបាត់ដំបងទៅអយុធ្យាពីមុន ។

ភ្នំនេះផងដែរ ។

ពីរឆ្នាំក្រោយមក គេបាននាំយកព្រះសារីរិកធាតុរបស់ព្រះពុទ្ធ ដែលគេនិយាយថា ព្រះថោងបានទទួលមុនពេលព្រះអង្គយាងចេញពីឥណ្ឌាមកកាន់កម្ពុជា យកមកបញ្ចុះនៅក្នុងព្រះចេតិយនេះ ។ គេបានរៀបចំធ្វើពិធីសម្ពោធព្រះចេតិយនេះចំនួន១៥ថ្ងៃក្នុងដើមខែកត្តិក ឆ្នាំ១៨៨៧[៤៧] ។ ក្នុងពិធីនោះព្រះរាជាបានសាងព្រះផ្នួសមានព្រះនាមថាព្រះមល្លិវ័នបុគ្គលោស្វាមិ ។ នៅពេលលាចាកសិក្ខាបទមកវិញ ទ្រង់បានធ្វើអំណោយដល់វត្តថ្មីនេះនូវភូមិចំនួន២១ ស្រែចំនួន២១ ខ្ញុំប្រុស២១នាក់ ខ្ញុំស្រី២១នាក់ រទេះគោ២១គ្រឿង រទេះក្របី២១គ្រឿង សេះ២១ក្បាល ដំរី២១ក្បាល[៤៨] ឧបករណ៍តន្ត្រីមួយសម្រាប់ ព្រមទាំងពលជាខ្ញុំប្រុសស្រីសម្រាប់ថែទាំ ព្រះវិហារ ព្រះចេតិយ និងចង្កៀងសម្រាប់ដុតបំភ្លឺទៀតផង ។

គេបានរកឃើញអក្សរចារឹកនៅលើសិលាមួយដុំដែលកប់ក្នុងដី មានសេចក្ដីថា ៖ «ទូលបង្គំជាខ្ញុំ សូមប្រកូកប្រកាសដល់អស់បណ្ដាទេវតាទាំងឡាយនៅលើមេឃ ដែលប្រកបទៅដោយកម្លាំងអភិនិហារ សូមអស់លោកធ្វើជាសាក្សីចំពោះការបរិច្ចាគទាំងអស់ ដែលទូលបង្គំជាខ្ញុំបានធ្វើចំពោះព្រះសារីរិកធាតុរបស់ព្រះពុទ្ធអង្គនេះ និងសូមឲ្យកុសលផលបុណ្យបានមកពីទាននេះ ស្ថិតស្ថេរអស់កាល៥ពាន់ឆ្នាំ ទៅហោង»[៤៩] ។

ព្រះរាជាអង្គនេះ បានធ្លាក់ខ្លួនប្រឈួន នៅក្នុងឆ្នាំ១៩០៤ រួចសុគតទៅ ក្នុងព្រះជន្មាយុ ៥៧ព្រះវស្សា ក្រោយពីសោយរាជសម្បត្តិបាន៣៧ឆ្នាំ គ្រប់គ្រងនៅលើព្រះរាជាណាចក្រកម្ពុជាទាំងមូល ។ គេនិយាយថា គេបានយកព្រះអដ្ឋិធាតុរបស់ព្រះអង្គទៅបញ្ចុះនៅក្នុងព្រះចេតិយភ្នំសន្ទុក ក្បែរព្រះសារីរិកធាតុរបស់ព្រះពុទ្ធ ។

---

[៤៧] រាជពង្សាវតារនិយាយថា គេបានយកព្រះសារីរិកធាតុរបស់ព្រះពុទ្ធអង្គ មកតម្កល់នៅក្នុងចេតិយនេះ ដោយដាក់ក្នុងកោដ្ឋមាសមួយ នៅក្នុងប្រាសាទធ្វើអំពីស្ពាន់ក្រហម ប្រាសាទនោះឯងនៅពីលើទម្រធ្វើអំពីឈើខ្លឹមចន្ទន៍ ។ នៅពីលើប្រាសាទមានស្វេតច្ឆ័ត្រមាសមួយ ដែលព្រះរាជាទ្រង់បានប្រគល់មកុដ និងគ្រឿងអលង្ការផ្សេងៗ ឲ្យយកមកធ្វើ ។ នៅជុំវិញប្រាសាទនេះ គេដាក់រូបបដិមាធ្វើអំពីមាស និងប្រាក់ ដែលតំណាងព្រះអរហន្តផ្សេងៗលុតជង្គង់ប្រណម្យបែរទៅរកព្រះសារីរិកធាតុ និងមានរូបបដិមា ខ្លះទៀត ធ្វើអំពីមាសដែរ កាន់ថាសដាក់សម្លៀកបំពាក់ទាំងបីតាមជំនឿ ចំណីអាហារឈ្ងុយឆ្ងាញ់ និងធូបក្រអូប ។ ព្រះមហាក្សត្រិយ៍បានប្រទានគ្រឿងអលង្ការ ឯនា ម៉ឺនសព្វមុខមន្ត្រី ស្រីស្នំ និងរាជវង្សានុវង្សសុទ្ធតែបានបរិច្ចាគទ្រព្យធនទៅតាមសមត្ថភាព ។

ព្រះរាជាមានព្រះបន្ទូលថា ព្រះសារីរិកធាតុរបស់ព្រះពុទ្ធនេះ បានមកពីព្រះថោង ដែលទ្រង់នាំយកពីប្រទេសឥណ្ឌា មកកាន់ព្រះរាជាណាចក្រកម្ពុជា ។

[៤៨] ចំនួន២១នេះគឺជាព្រះជន្មរបស់ព្រះរាជា នៅពេលដែលព្រះអង្គទទួលការអភិសេកជាព្រះរាជានៅរាជធានីចតុម្មុខ ។ ជាធម្មតា នៅពេលដែលព្រះរាជាមួយអង្គសុគតទៅ គេឆ្លាក់រូបសត្វនៅលើកោដ្ឋដែលដាក់ព្រះសពតាមចំនួនព្រះជន្មរបស់ព្រះអង្គ ។

[៤៩] រាជពង្សាវតារបានលើកអំពីការទាក់បានដំរីសមួយនៅក្នុងខែត្រពោធិសាត់ នៅឆ្នាំ១៨៩៤ ។ ដំរីសនោះគេបានអភិសេកដាក់ឈ្មោះថា ព្រះស្វេតមង្គលរាជហប្ទ័យពិជ័យចត្រត្តៈ ។

## ១៦- ព្រះស្រីសុគន្ធបទ (១៥០៤-១៥១២)

ព្រះរាជបុត្រច្បងរបស់ព្រះធម្មោរាជាព្រះនាមថាជន្ធត្តិយរាជា ដែលមានព្រះជន្ម៣២ព្រះវស្សា បានឡើងសោយរាជ្យបន្តពីព្រះបិតា ដោយមានព្រះអភិសេកនាមថា ព្រះបាទសម្តេចស្តេចព្រះរាជឱង្ការព្រះស្រីសុគន្ធបទ ព្រហ្មព្រឹទ្ធរាជាធិរាជរាមាធិបតី ព្រះចៅមហានគរកម្ពុជាធិបតី ។

ការលើកព្រះសុគន្ធបទឲ្យឡើងសោយរាជ្យនេះបានធ្វើឲ្យព្រះអនុជរបស់ព្រះអង្គព្រះនាមព្រះច័ន្ទរាជា មិនសប្បាយព្រះទ័យ ក៏យាងមកគង់នៅឯចតុម្មុខ កេណ្ឌទ័ពបះបោរប្រឆាំងឡើង[៥០] ។ ព្រះច័ន្ទរាជានេះ ទ្រង់ប្រសូតនៅពេលដែលមានចន្ទ្រគ្រាស ដោយហេតុនេះហើយទើបបានជាគេថ្វាយព្រះនាមដូច្នេះ ។

ក្រោយអភិសេកបានបន្តិច ស្តេចសុគន្ធបទបានយាងចាកចោលរាជធានីលង្វែក មកគង់នៅទួលបាសានក្នុងខេត្រស្រីសន្ធរវិញ ជាទីកន្លែងដែលព្រះអយ្យកោរបស់ព្រះអង្គ ចៅពញាយ៉ាត បានជ្រើសរើសជារាជធានីមុននឹងយាងទៅគង់នៅឯចតុម្មុខ ឬភ្នំពេញ ។ រាជពង្សាវតារនិយាយថា ព្រះអង្គសព្វព្រះទ័យនឹងទីតាំងនេះដែលងាយស្រួលក្នុងការការពារ ពីព្រោះស្ថិតនៅចន្លោះបឹងធំមួយនៅខាងកើត និងទន្លេមេគង្គនៅខាងអាគ្នេយ៍ និងព្រៃ ។

នៅពេលនោះ[៥១] មានបុរសម្នាក់ឈ្មោះថា ពិជ័យនាគ និងប្រពន្ធឈ្មោះថា ម៉ែបាន មានដើមកំណើតជាពល

---

[៥០] ព្រះច័ន្ទរាជាទ្រង់ប្រសូត្រនៅក្នុងឆ្នាំ១៤៨៦ ជារាជបុត្រមហេសីទី២មានព្រះនាមថា ព្រះមយោទេពបុប្ផ ។ ទ្រង់បានត្រូវគ្រូសារលោកយមរាជយកទៅចិញ្ចឹមបីបាច់ថែរក្សា តាមមើលទៅប្រហែលដោយសារព្រះមាតានោះ ជាបុត្រីលោកយមរាជ ។ ចំណែកព្រះរៀមជាព្រះរាជាវិញ ទ្រង់មានព្រះជន្មច្រើនជាង១៣ព្រះវស្សា ហើយជារាជបុត្រព្រះមហេសីទី១ ដែលជាព្រះរាជវង្សដែរ ព្រះនាមថាព្រះព្រាកវតីស្រីធីតា ដែលបានរៀបអភិសេកជាមួយព្រះធម្មោរាជា ។ ដោយហេតុនេះ ព្រះរៀមនេះ មានសិទ្ធិពេញលេញនឹងបន្តរាជ្យពីព្រះបិតា ។ យើងមិនដឹងថា ហេតុអ្វីបានជាព្រះច័ន្ទរាជាបះប្រឆាំងទៅវិញ ។

[៥១] នៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាដែលខ្ញុំសូមធ្វើការបកប្រែជូនដូចតទៅនេះ មានចំណុចមួយដែលលើកឡើងដូច្នេះថា : “ឥឡូវនេះយើងសូមនិយាយអំពីប្រវត្តិរបស់ ពិជ័យនាគ ។ រឿងនេះគ្មាននៅក្នុងរាជពង្សាវតារទេ តែមាននៅក្នុងសាវតាររបស់ខេត្រ” ប៉ុណ្ណោះ ។

តាមមើលទៅ គេបានលុបរឿងនេះចេញពីរាជពង្សាវតារតាំងពីយូរណាស់មកហើយ ពីព្រោះគ្មានឯកសារណាមួយ និយាយអំពីរឿងនេះទេ ។ នេះប្រហែលដោយសារព្រះរាជាកម្ពុជាយល់ថា រឿងនេះមិនល្អ ។ តែសម្តេចសង្ឃរាជលោកមិនបានគិតអំពីភាពអាក្រក់ល្អអ្វីទេ លោកបានស្រង់យកមកចុះក្នុងប្រវត្តិសាស្ត្រ ដោយមានការឯកភាពពីសមាជិកគណៈកម្មការរៀបចំ ព្រោះថា រឿងនេះនៅមានគេនិទានតៗគ្នាតែដូច្នេះរួចមកហើយ ។ យើងបានឃើញពីខាងលើរួចមកហើយថា ស្តេចនរោត្តម ដែលរៀបចំបង្កើតគណៈកម្មការនេះឡើង បានយកឯកសារនេះទៅចាក់សោទុក ពីព្រោះតែរឿងត្រង់នេះឯង ដែលព្រះអង្គមានព្រះបន្ទូលថា ធ្វើឲ្យល្អក់កករដល់ប្រវត្តិរបស់ព្រះរាជវង្សានុវង្សកម្ពុជា ។

ព្រះ[៥២] បានយកបុត្រីរបស់ខ្លួនដែលមានរូបរាងស្អាតប្រិមប្រិយ៍ មកថ្វាយព្រះរាជា[៥៣] ។ ព្រះរាជា បានតែងតាំងនាងជាស្នំឯក ពោលគឺជាស្នំឆ្នើមជាងគេបន្ទាប់ពីព្រះមហេសី រួចលើកពិជ័យនាគជាមន្ត្រី ឯម៉ែបាន ត្រូវតែងតាំងជានាគម៉ែបាន និងតែងតាំងប្អូនប្រុសស្នំឯកឈ្មោះ នាយកនជាមហាតលិក ។ ក្រោយមក ពលព្រះនេះ បានទទួលឋានៈជា ខកញ៉ាម៉ឺនស្នេហាចមចិត្ត ។

គ្រួសារនេះដល់ពេលមានទ្រព្យធន បានក្លាយជាទៅជាគ្រួសារមួយមានឥទ្ធិពលនៅក្នុងប្រទេសហើយមានមនុស្សជាច្រើនចូលមករកសុំជ្រកកោន[៥៤] ។ គឺនៅពេលនោះហើយដែលព្រះរាជាសម្រេចព្រះទ័យចង់លស់លាស្នំឯក និងប្អូនប្រុស ឲ្យរួចចាកពីឋានៈជាពលព្រះ ពីព្រោះថាតាមធម្មតា អ្នកណាកើតមកជាពលព្រះ នៅតែជាពលព្រះរហូត បើទោះបីជាមានការលើកតម្កើងដូចម្ដេចក្ដី ។ ទ្រង់បានសាកសួរយោបល់សេនាមន្ត្រីៗ ទូលតបទៅវិញថា គ្រួសារពលព្រះមិនអាចនឹងរួចចាកពីឋានៈនេះបានទេ ពីព្រោះថានៅពេលដែលគេប្រគល់គ្រួសារណាមួយឲ្យទៅជាពលព្រះ គឺគេប្រគល់សម្រាប់រយៈពេល៥ពាន់ឆ្នាំ ទោះជាព្រះរាជាក៏មិនអាចអនុវត្តរំលងច្បាប់នេះចំពោះមនុស្សដែលមិនគោរពសាសនាព្រះពុទ្ធ និងរំលងក្អែកប្រជាជនបានដែរ ។

មួយខែក្រោយមក នៅពេលដែលព្រះរាជាហាក់ដូចជាភ្លេចបំណងចង់លស់លានោះទៅហើយ ស្រាប់តែស្នំឯកធ្លាក់ខ្លួនឈឺ ។ ដោយព្រះរាជាសព្វព្រះទ័យនឹងនាងខ្លាំងពេក ទ្រង់បានបន់ស្រន់ថាសូមឲ្យនាងជាសះស្បើយវិញ ចុះព្រះអង្គនឹងរក្សាឋានៈជាពលព្រះរបស់នាងដោយសង់វត្តមួយ សម្រាប់ឲ្យនាងមកបំពេញកាតព្វកិច្ចចំពោះព្រះពុទ្ធ ជាប្រចាំ ។ ស្នំឯកបានជាពីជំងឺដូចព្រះទ័យមែន ព្រះរាជាទ្រង់បញ្ជាឲ្យសាងសង់វត្តមួយតាមការបន់ស្រន់ដោយបោះសីមានៅគ្រប់ជ្រុងដី ។ រួចហើយទ្រង់ឲ្យបាំងក្រណាត់អមផ្លូវដើរចេញពីព្រះរាជវាំងទៅកាន់វត្តនោះដើម្បីកុំឲ្យគេមើលឃើញស្នំឯកធ្វើដំណើរទៅកាន់វត្តរាល់ថ្ងៃសីល បោចស្មៅជុំវិញព្រះវិហារដូចដែលពួកពលព្រះតែងតែធ្វើ ។ ក្រោយមកទៀតទ្រង់បានឲ្យផ្លាស់ក្រណាត់ ដោយដាំឈើជារបងខ្ពស់ៗវិញ ហើយវត្តនោះ ក៏ត្រូវគេហៅថាជាវត្តព្រៃបាំងរហូតមក ។ ព្រះរាជាមានរាជបុត្រជាមួយស្នំឯកនេះមួយអង្គ ព្រះនាមថា ពញាយស ។

ព្រះរាជាក៏ចង់ដំឡើងឋានៈឲ្យប្អូនប្រុសរបស់ស្នំឯកឡើងជាមន្ត្រីដែរ តែព្រះអង្គខ្លាចមានពាក្យនិន្ទាពីនាម៉ឺនសព្វមុខមន្ត្រី ដែលចងចាំមិនភ្លេចនូវឋានៈជាពលព្រះរបស់គេ ម៉្លោះហើយបានត្រឹមតែដំឡើងឲ្យទៅជា ឃុនហ្លួងព្រះស្ដេចសមហាសេនាធិបតី ដែលមានមន្ត្រី៤រូបនៅក្រោមបញ្ជា ត្រួតត្រាលើពលព្រះទាំងអស់ និងជាអ្នកត្រួត

---

[៥២] ពលព្រះរតនត្រ័យ ។

[៥៣] ទម្លាប់យកកូនស្រីទៅថ្វាយស្ដេចនេះ ពីមុនមាននៅក្នុងប្រទេសចាម្ប៉ា ឥឡូវនេះយើងឃើញថាមានអនុវត្តដែរនៅកម្ពុជា ។

[៥៤] នៅសម័យនោះមានការសាងសង់ ឬជួសជុលជាថ្មីឡើងវិញនូវវត្តជាច្រើន ។ វត្តនាគម៉ែបានត្រូវសាងសង់ឡើងដែរ ដោយទ្រព្យរបស់ម៉ែបាន ។

ពិនិត្យទំនៀមទម្លាប់ប៉ុណ្ណោះ[៥៥] ។ ទ្រង់ក៏ឲ្យទទួលបន្ទុកផងដែរក្នុងការដាក់ទោសពិន័យចំពោះអំពើឆ្គាំឆ្គងទាំងឡាយ មានការមិនគោរពអាចារ្យ អ្នកប្រាជ្ញ និងចាស់ព្រឹទ្ធាចារ្យ ជាដើម ។

បានឡើងជាមន្ត្រីធំម្នាក់ ហើយត្រូវជាប្អូនថ្លៃរបស់ព្រះរាជា និងជាឪពុកមារបស់ព្រះរាជបុត្រផង នាយកន ភ្លេចកំណើតដើមរបស់ខ្លួនជាពលព្រះ ហើយចាប់តាំងមាក់ងាយមន្ត្រីឯទៀតៗ ធ្វើឲ្យមន្ត្រីទាំងនោះនាំគ្នាស្អប់គុំជាខ្លាំង ចង់តែរាយការណ៍ថ្វាយព្រះរាជា ។

ថ្ងៃមួយក្នុងខែចែត្រឆ្នាំ១៥០៨ នៅពេលរាត្រីបន្ទាប់ពីថ្ងៃចូលឆ្នាំទី១ ព្រះរាជាបានយល់សុបិនឃើញថា ព្រះនគរមានកោលាហល ព្រះអង្គ និងពលសេនាទាំងឡាយត្រូវសត្វនាគធំមួយដេញព្រួសពិស និងភ្លើងដាក់ ធ្វើឲ្យឆេះឆាបរាជធានី រួចនាគនោះបានមកឆក់យកស្វេតច្ឆត្រពាំរត់ទៅទិសខាងកើតបាត់ទៅ ។ ព្រះរាជាភិតភ័យតក្កមានឹងសុបិននេះ ទ្រង់ក៏យាងទៅកាន់រោងជ័ន្ទុំដែលមានរាជវង្សានុវង្ស និងមន្ត្រីអ្នកមុខអ្នកការចាំគាល់នៅទីនោះ ។ គេនាំគ្នាថ្វាយព្រះគង្គា ថ្វាយទៀន និងមាលាដល់ព្រះអង្គ ព្រះអង្គក៏ថ្វាយព្រះពរដល់អ្នកទាំងអស់គ្នាឲ្យបានសេចក្តីសុខសប្បាយ ស្រាប់តែទ្រង់បែរព្រះភ័ក្ត្រមើលចំយុនហ្វងកនឃើញមាននាគ២ញីឈ្មោលនៅពីលើក្បាល ។ ឆ្ងល់ណាស់ ទ្រង់ក៏សួរទៅអ្នកដែលនៅជិតព្រះអង្គ តើមានមើលឃើញនាគទាំង២ ដូចព្រះអង្គដែរទេ គេឆ្លើយថា មិនឃើញទេ ជាហេតុធ្វើឲ្យព្រះអង្គរឹតតែព្រួយបារម្ភខ្លាំងឡើងៗ ។ នៅពេលនោះ ចៅហ្វាយខែត្របាត់ដំបង បានទូលព្រះរាជាថា ទឹកជ្រោះភ្នំបាណន់ដែលគេតែងតែត្រងយកមកថ្វាយព្រះរាជាស្រង់នោះ ស្រាប់តែឥឡូវនេះ ប្រែជាមានពណ៌ក្រហមដូចល័ក្ត ។ ព្រះរាជាទ្រង់វិតក្កខ្លាំងណាស់ ពេលយាងចូលក្រឡាបន្ទំ ទ្រង់បានឲ្យគេហៅ ព្រះឥសីផាត មហារាជគ្រូជាមេក្រុមបារគូ និងព្រះហោរាធិបតីចូលគាល់ រួចទ្រង់អធិប្បាយអំពីសុបិនរបស់ព្រះអង្គ និងនាគដែលព្រះអង្គទតឃើញក្នុងសាលប្រជុំ ។ មេក្រុមបារគូ ទូលព្រះរាជាថា កាលពីព្រឹកនោះ លោកបានពិនិត្យឃើញថា ព្រះខ័នរាជ្យមានប្រែះទាំងនៅក្នុងស្រោម ដែលជាប្រផ្នូលមិនល្អទេចំពោះព្រះរាជាណាចក្រ ។ ចំណែកហោរាវិញ បានទូលព្រះអង្គថា បើតាមក្បួនលេខអត្ថៈ សុបិនរបស់ព្រះរាជា និងការទតឃើញនាគរបស់ព្រះអង្គ ជាសញ្ញាបញ្ជាក់ថា នឹងមានមនុស្សកើតឆ្នាំរោងមកដណ្តើមរាជបល្ល័ង្កពីព្រះអង្គ ហើយទៅសោយរាជ្យនៅទិសខាងកើត ។

ព្រះរាជាភិតភ័យខ្លាំងណាស់ ព្រោះយុនហ្វងកនកើតឆ្នាំរោង ហើយការឆ្មើងកន្ទ្រើងរបស់ យុនហ្វងកន

---

[៥៥] ឋានៈនេះពីមុនមកគ្មានទេ ស្តេចបង្កើតឡើងសម្រាប់តែប្អូនថ្លៃប៉ុណ្ណោះ ។ សព្វថ្ងៃឋានៈនេះនៅមាននៅឡើយ តែបានដូរទៅជាខកញ៉ាព្រះស្តេចអធិបតី ជាចាងហ្វាងលើ កិច្ចការព្រះសង្ឃរាជ ទទួលបន្ទុកត្រួតពិនិត្យទំនៀមទម្លាប់សាធារណៈ និងកិច្ចការសាសនាជាពិសេស ។ យើងបានឃើញពីខាងលើរួចមកហើយថា មានព្រះរាជាកម្ពុជា បុរាណ ក៏បានបង្កើតឋានៈមួយប្រហាក់ប្រហែលនេះដែរ ។

កន្លងមក ដែលធ្វើឲ្យនាម៉ឺនសព្វមុខមន្ត្រីខឹងសម្បាស្អប់គ្រប់គ្នា ក៏ជាសញ្ញាមួយបញ្ជាក់ថា អាចនឹងបង្កគ្រោះ ដល់ព្រះអង្គបានមែន ។ ម្ល៉ោះហើយទ្រង់ក៏សម្រេចព្រះទ័យត្រូវតែកម្ចាត់យុនហ្វងកននេះចេញ គឺសម្លាប់នៅថ្ងៃស្អែកពេលទ្រង់ចេញបង់សំណាញ់ ។

ស្នំឯកជាបងនាយកនដែលពួននៅពីខាងក្រោយទ្វារ បានស្ដាប់ឮព្រះឱង្ការរបស់ព្រះរាជាមិនសូវច្បាស់ទេ ហើយក៏មិនយល់ទាំងអស់ដែរ តែកាត់យល់ថា ព្រះរាជាច្បាស់ជារៀបផែនការអ្វីមួយប្រឆាំងនឹងប្អូនហើយ ។ ដល់ស្អែកឡើង នាងបានទៅចូលរួមក្នុងពិធីនេសាទត្រីកំសាន្តរបស់ព្រះរាជាជាមួយនឹងស្រីស្នំឯទៀត និងជំទាវយុនណាង ជាភរិយាមន្ត្រីទាំងឡាយដែរ ដោយនាងគិតបារម្ភពីប្អូនខ្លាំងណាស់ ក៏សរសេរសំបុត្រមួយដាក់បង្កប់នៅក្នុងបាយពំនូត ឲ្យភីលៀងអ៊ុំទូកយកទៅប្រគល់ឲ្យប្អូនប្រុស ។ យុនហ្វងភ្ញាក់ផ្អើលជាខ្លាំងនៅពេលឃើញបងស្រីផ្ញើបាយមួយពំនូតមកឲ្យ ក៏កាត់យល់ថាប្រាកដជាមានអ្វីសំខាន់ហើយ ទើបគេចខ្លួនទៅកំបាំងនឹងគុម្ពោតព្រៃ បើកបាយពំនូតមើល ឃើញលិខិតមួយដែលមានខ្លឹមសារថា ៖ “ប្អូនត្រូវប្រយ័ត្នខ្លួន គេចង់សម្លាប់ប្អូនហើយ ។ បើសិនជា ព្រះរាជាបញ្ជាឲ្យប្អូនលោតចូលទៅក្នុងទឹក ប្អូនមិនត្រូវប្រកែកទេ ត្រូវលោតចូលតាមព្រះរាជបញ្ជា ប៉ុន្តែ ត្រូវហែលគេចខ្លួនចេញឲ្យឆ្ងាយភ្លាមពីកន្លែងនោះ ហើយកុំវិលត្រលប់មកវិញឲ្យសោះ” ។

អានសារលិខិតចប់ យុនហ្វងភាន់ភាំងស្រឡាំងកាំង និងភ័យញ័រខ្លួនចំប្រប់ ក៏លើកលិខិតដាក់លើក្បាលសំពះឡើង ហើយនិយាយទៅកាន់ទេវតាថា “ខ្ញុំម្ចាស់ជាភីលៀងដែលស្មោះត្រង់ និងភក្ដីចំពោះព្រះរាជាខ្លាំងណាស់ ខ្ញុំមិនបានដឹងអ្វីទេ សូមទេវតាទាំងឡាយលោកជួយការពារខ្លួនខ្ញុំផង ខ្ញុំគ្មានអ្នកណាទៀតជួយការពារក្រៅពីព្រះអង្គឡើយ” ។

បន់ស្រន់រួច យុនហ្វង ក៏ត្រលប់មកជួបជុំជាមួយពួកមន្ត្រីវិញ ។

ពិធីនេសាទត្រីកម្សាន្តក៏បានចាប់ផ្ដើម ព្រះរាជាចាប់បង់សំណាញ់ទៅរកកន្លែងដែលគេចង្អុលបង្ហាញថាមានត្រីច្រើន ដែលតាមពិតមានសុទ្ធតែបុសឈើ ធ្វើយ៉ាងណាដើម្បីឲ្យសំណាញ់ជាប់ ។ បន្ទាប់មក អ្វីដែលគេបានគ្រោងទុកក៏បានកើតមានឡើង គឺព្រះរាជាបានបញ្ជាឲ្យយុនហ្វងកន ដែលពូកែហែលទឹក លោតចុះទៅដោះសំណាញ់ ។ កនលោតចូលទៅក្នុងទឹកតាមព្រះរាជបញ្ជា ហើយភ្លាមនោះពួកនាម៉ឺនសព្វមុខមន្ត្រីក៏ចាប់បង់សំណាញ់ទៅលើព្រមៗគ្នា ដើម្បីឲ្យថប់ស្លាប់ក្នុងទឹកតែម្ដង ។ ប៉ុន្តែអតីតពលព្រះ ជាមនុស្សឆ្លាត លោតទឹកភ្លាម ក៏មុជទៅជ្រៅ គេចផុតពីសំណាញ់ទាំងឡាយ រួចហើយបានហែលចេញទៅឆ្ងាយពីទីកន្លែងដែលមានអ្នកចង់សម្លាប់ខ្លួន ។ ហែលឆ្ងាយបន្តិចក៏ទៅដល់កន្លែងរាក់ អាចដើរបានក៏បន្ទឹមតែក្បាលដើម្បីដកដង្ហើម ។ ទីកន្លែងដែលហែលទៅដល់នោះ គឺបឹងទទា នាយកនក៏ពួនសម្ងំលាក់ខ្លួននៅទីនោះទៅ ។

នៅពេលនោះ នៅឯកន្លែងបង់សំណាញ់ឯណោះវិញ គេបានសង្កេតឃើញថាគ្មានសំណាញ់ណាមួយ ដែលលើកមកជាប់ខ្មោចនាយកនឡើយ ។ ព្រះរាជាបានឲ្យគេមុជទឹករាវរក ក៏មិនឃើញខ្មោច ទ្រង់ក៏ព្រះតម្រិះថា “ខ្លា

រួចចេញពីទ្រុងហើយ ថ្ងៃណាមួយវានឹងវិលត្រលប់មកសងគុណយើងវិញជាមិនខាន» ។ ទ្រង់បានចាត់ឲ្យសេនាទាហានតាមរកថែមទៀត តែរកមិនឃើញ ។ នាយកនបានគេចទៅដល់ទីវត្តអារាមមួយ ដែលខ្លួនធ្លាប់បាននៅរៀនសូត្រ ហើយព្រះសង្ឃដែលធ្លាប់ចិញ្ចឹមបីបាច់ និងបង្ហាត់បង្រៀន បានប្រដៅថាឲ្យគេចខ្លួនទៅទិសខាងកើត ទៅរង់ចាំទទួលវាសនារបស់ខ្លួន ។

នាយកនក៏ធ្វើតាមបណ្តាំគ្រូ គេចលាក់ខ្លួនអស់ពេលជាយូរ រហូតដល់ថ្ងៃមួយក៏បានផ្តែផ្តាំឲ្យអ្នកបម្រើយកអាវុធមកឲ្យនៅក្នុងព្រៃដារដែលខ្លួនកំពុងពួន រួចក៏ចេញដំណើរទៅកាន់ខែត្របាភ្នំ ។ នាយកនបានសម្លាប់ចៅហ្វាយខែត្របាភ្នំ នៅចំពោះមុខពួកក្រមការ ដោយលើកហេតុផលថាចៅហ្វាយខែត្របាភ្នំនេះក្បត់ ចូលដៃជាមួយព្រះច័ន្ទរាជា ដែលព្រះរាជាបានចាត់តាំងឲ្យធ្វើជាឧបរាជ សោយរាជ្យនៅចតុម្មុខ តែបានត្រួតត្រាបណ្តាអាណាខែត្រភាគខាងលិចដើម្បីតែផលប្រយោជន៍ផ្ទាល់របស់ខ្លួនព្រះអង្គ ។ បន្ទាប់មក ក៏និយាយទៅកាន់ពួកមន្ត្រីដែលកំពុងតែភិតភ័យថា ខ្លួនមកនេះដើម្បីអនុវត្តបញ្ជារបស់ព្រះរាជា ឲ្យធ្វើឃាតចៅហ្វាយខែត្រ រួចហើយគេណ្ឌទ័ពមួយកងនៅក្នុងខែត្របាភ្នំនេះ ។ ២-៣ថ្ងៃក្រោយមក នាយកនក៏ប្រកាសដំណឹងថា ទ័ពដែលខ្លួនកេណ្ឌនេះ មិនមែនកេណ្ឌថ្វាយព្រះរាជាទេ គឺកេណ្ឌផ្ទាល់ខ្លួន ដើម្បីវាយដណ្តើមយករាជធានីបាសាន ហើយលើកក្លួយរបស់ខ្លួនចៅពញាយស ឲ្យឡើងគ្រងរាជបល្ល័ង្ក ។ គេបាននិយាយថា “អ្នកណាដែលគ្មានបញ្ហាអ្វីជាមួយព្រះរាជា មិនបាច់ចូលមកឡូកឡំទេ អាចធ្វើអ្វីបានតាមតែខ្លួនចង់បម្រើព្រះរាជា ។ ប៉ុន្តែត្រូវដឹងថា នៅពេលដែលខ្ញុំដណ្តើមបានអំណាច ពលព្រះ ទាំងអស់នឹងទទួលបាននូវសេរីភាពជាអ្នកជា ពួកអ្នកជាណាដែលបានបម្រើខ្ញុំនឹងក្លាយទៅជាមន្ត្រី ហើយមន្ត្រីណាដែលបានបម្រើខ្ញុំនឹងឡើងកាន់តែធំទៀត ទៅតាមការងារដែលគេបានធ្វើ» ។

សុន្ទរកថានេះ បានទាក់ទាញមន្ត្រី និងអ្នកស្រុកឲ្យមកចុះចូលជាច្រើន ហើយមិនយូរប៉ុន្មាននាយកនក៏មានកងទ័ពដ៏រឹងមាំមួយនៅក្នុងដៃ ។ នាយកនបានចែកពលទាហានចេញជាច្រើនកង ហើយបញ្ជាឲ្យចេញវាយដណ្តើមយកបណ្តាខែត្រជិតខាង ។

ក្រុមបះបោរទទួលជ័យជម្នះយ៉ាងលឿន រហូតទាល់តែព្រះរាជាភ័យបារម្ភជាខ្លាំង ហើយដោយមានការថ្វាយយោបល់ពីលោកយមរាជរដ្ឋមន្ត្រីខាងយុត្តិធម៌ផង ទ្រង់បានចាត់ឲ្យអញ្ជើញព្រះពិជ័យនាគជាឪពុកនាយកនមកសរសេរអក្សរមួយច្បាប់ ផ្ញើទៅអញ្ជើញកូនឲ្យឆាប់ចុះចូលមកវិញ ។ នាងស្នំឯកក៏បានសរសេរសំបុត្រមួយច្បាប់ទៅដែរ ហើយបានទាំងសន្យាថា ព្រះរាជាយល់ព្រមនឹងលើកនាយកនឲ្យឡើងជាមន្ត្រីជាន់ខ្ពស់ម្នាក់ទៀតផង ។ អានអក្សររបស់ឪពុក និងបងស្រីរួច នាយកននិយាយប្រាប់អ្នកនាំសាររបស់ព្រះរាជាថា ខ្លួននឹងត្រលប់ចូលទៅក្នុងរាជធានីវិញ ប៉ុន្តែសូមរង់ចាំរំសាយកងទ័ព និងបញ្ជូនពួកមេៗឲ្យទៅផ្ទះអស់សិន ។ ពេលពួកអ្នកនាំសារចេញទៅផុត នាយកនបានប្រកាសប្រាប់ប្រជាជនថា ព្រះរាជាបានតែងតាំងខ្លួនឲ្យឡើងជាមេទ័ពដើម្បីវាយកម្ចាត់ចៅពញាច័ន្ទរាជាដែលទើបតែចាប់កាន់អាវុធប្រឆាំងនឹងខ្លួន និងថាបើអ្នកណាសម្លាប់ស្តេចក្បត់នេះបាន ខ្លួននឹងឲ្យ

មាស១០០តម្លឹង ព្រមទាំងលើកឲ្យធ្វើជាមន្ត្រីធំទៀតផង ។ មានមនុស្សជាច្រើនចង់ធ្វើការងារនេះ ហើយក្នុងរយៈពេលមួយដ៏ខ្លី នាយកនមានកម្លាំងដ៏ច្រើននៅជុំវិញខ្លួន ។

ដឹងដំណឹងនេះ ស្នំឯកបានបញ្ជូនភីលៀងម្នាក់មកអង្វរនាយកនឲ្យបោះបង់គំនិតនេះចោលហើយ ត្រលប់ចូលមកក្នុងរាជធានីលង្វែក ដែលព្រះរាជាទើបតែយាងមកគង់នៅវិញជាបន្ទាន់ ស្នំឯកធានាថានឹងសុំឲ្យព្រះរាជាលស់លា ត្រាប្រណីទោសឲ្យ បើពុំនោះទេព្រះរាជានឹងដឹកនាំទ័ពមកចាប់ផ្ចាល់ព្រះអង្គតែម្ដង ពេលនោះបងស្រីមិនអាចជួយបានទេ ។

នាយកនឆ្លើយតបមកវិញថានឹងត្រលប់ចូលមកក្នុងរាជធានីលង្វែកវិញភ្លាម នៅពេលណាដែលទ័ពរំសាយទៅស្រុកភូមិវិញអស់ ខ្លួនអាចនឹងមកចូលគាល់ព្រះរាជានៅខែក្រោយ បងស្រីមិនបាច់ព្រួយបារម្ភទេ ពីព្រោះខ្លួនគ្មានបំណងបះបោរប្រឆាំងនឹងព្រះរាជាឡើយ ។ ព្រះរាជាជឿ ទ្រង់ក៏ឲ្យរង់ចាំរហូតដល់ផុតកំណត់ មិនមានធ្វើអ្វីទាំងអស់ ។ ឆ្លៀតឱកាសនោះនាយកនបានខិតខំពង្រីកកម្លាំងទ័ពរបស់ខ្លួន ហ្វឹកហាត់ទាហានឲ្យបំបះបំបោរ ខែត្រផ្សេងៗទៀត បញ្ចុះបញ្ចូលប្រជាជនថាកេណ្ឌទ័ពនេះគឺដើម្បីទប់ទល់នឹងស្ដេចក្បត់ដែលដណ្ដើមបែងចែកទឹកដីជារាជាណាចក្រមួយទៀត មានរាជធានីនៅចតុម្មុខ ។ ពាក្យនេះអ្នកស្រុកខ្សឹបខ្សៀវតៗគ្នាពីមាត់មួយទៅមាត់មួយ ពាសពេញព្រះនគរ ហើយមិនមានធ្វើឲ្យអ្នកណាម្នាក់ពិភាល់ឡើយ ។ ស្ដេចពញាច័ន្ទខ្លួន ព្រះអង្គក៏ជឿថា ព្រះរាជា និងនាយកន ឃុបឃិតគ្នាប្រឆាំងនឹងខ្លួនព្រះអង្គដែរ ទំនាក់ទំនងដែលប្រព្រឹត្តទៅតាមរយៈស្នំឯកខ្លួន ព្រះអង្គគឺជាកម្មវត្ថុនៃការឃុបឃិតនេះ ។ ព្រះអង្គមានការភិតភ័យណាស់ ក៏លួចគេចចេញពីចតុម្មុខ ធ្វើដំណើរកាត់ខែត្រពោធិសាត់ យាងទៅសុំជ្រកកោនជាមួយស្ដេចសៀមទៅ នៅក្នុងឆ្នាំ១៥០៨ ដែលកាលនោះ ព្រះអង្គមានព្រះជន្ម ២៣ព្រះវស្សា ។

នៅពេលដែលពញាច័ន្ទរាជាគេចព្រះកាយទៅគង់នៅឯស្រុកសៀម ហើយព្រះរាជាកំពុងតែរង់ចាំការចុះចូលរបស់នាយកននៅឯលង្វែក នាយកនក៏ប្រជុំទីប្រឹក្សារបស់ខ្លួនដោយនិយាយថា «ពីមុន ខ្ញុំខ្លាចតែមនុស្សម្នាក់ប៉ុណ្ណោះ គឺចៅពញាច័ន្ទរាជានេះឯង ។ ឥឡូវព្រះអង្គរត់ទៅនៅស្រុកសៀមហើយ ខ្ញុំគ្មានអ្វីនឹងភ័យបារម្ភទៀតទេ ដូច្នេះ បើសិនជាយើងចង់ យើងអាចដណ្ដើមយកព្រះរាជាណាចក្របាន» ។ ពួកនាម៉ឺនសព្វមុខមន្ត្រីទះដៃអបអរនឹងសម្ដីនេះ នាយកនក៏កោះប្រមូលកងទ័ព ហើយបែងចែកចេញជា៤កង : កងទ័ពស្រួច កងស្លាបខាងស្ដាំ កងស្លាបខាងឆ្វេង និងកងទ័ពក្រោយ រួចហើយកាន់ទ័ព១ម៉ឺននាក់ផ្សេងទៀតចេញទៅបោះជំរំនៅក្បែរខែត្រស្រីសន្ធរ ។

គឺរហូតទាល់តែដល់ពេលនោះ ទើបព្រះរាជាប្រគល់ទ័ព៣ពាន់នាក់ឲ្យចៅពញាយោធាសង្គ្រាមជាមេទ័ពស្រួច និងខុកញ៉ាចក្រី ជាវដ្ឋមន្ត្រីខាងសង្គ្រាម និងជាមេអគ្គបញ្ជាការ ចេញទៅពិនិត្យមើល និងទប់ទល់ទ័ពនាយកនសិន រង់ចាំទ័ពដែលកេណ្ឌថ្មីបាន និងដាក់ក្រោមបញ្ជាការរបស់ចៅពញាច័ន្ទរាជា មកដល់ ។ ពេលនោះ មន្ត្រីម្នាក់

ទូលព្រះអង្គថា ពញាច័ន្ទរាជា បានបាត់ខ្លួនពីចតុម្មុខ២ថ្ងៃហើយ ហើយកំពុងតែធ្វើដំណើរទៅស្រុកសៀមជាមួយមនុស្ស៩នាក់ទៀត ។ ព្រះរាជាព្រួយព្រះទ័យណាស់នឹងដំណឹងនេះ និងមានព្រះបន្ទូលតែមួយអង្គឯងថា "ឱព្រះអនុជអើយ ព្រះអង្គមិនគួរបោះបង់ចោលព្រះរៀមនៅក្នុងកាលៈទេសៈបែបនេះសោះ" ។ បន្ទាប់មក ទ្រង់ក៏យាងចូលក្រឡាព្រះបន្ទំទាំងអស់សង្ឃឹម ។

ពេលនោះ ទ័ពព្រះរាជាក៏ចេញដំណើរទៅ ព្រឹកមួយទ័ពស្រួចបានមកជួបជាមួយទ័ពដែលនាយកនដឹកនាំ ។ នាយកនជិះដំរីដ៏ល្អមួយ បាំងក្លស់នៅកណ្ដាលចំណោមកងទ័ព ។ ចៅពញាយោធាសង្គ្រាមឃើញដូច្នោះ ក៏ចូលទៅជិត ហើយនិយាយថា "ឯងមិនគួរធ្វើបែបនេះតបទៅនឹងការសន្ដោសប្រណីដែលព្រះរាជាមានចំពោះឯងនៅឯព្រះបរមរាជវាំងទេ ព្រះអង្គសព្វព្រះទ័យនឹងឯងខ្លាំងណាស់" ។ ឮសម្ដីនេះ នាយកន បរដំរីមកមុខកងទ័ព ស្រែកសួរថា តើព្រះរាជាចាត់ពញាសង្គ្រាមមកដើម្បីដោះស្រាយរឿងរ៉ាវជាមួយខ្លួនឬអ្វី រួចហើយក៏យិតធ្នូបាញ់ចំបំពង់កពញាសង្គ្រាម ដួលស្លាប់នឹងជើងដំរីទៅ ដោយមិនរង់ចាំចម្លើយអ្វីឡើយ ។ ឃើញដូច្នេះ ពលទាហាន របស់ព្រះរាជាក៏វាយដកថយ រត់មកជួបជាមួយកងទ័ពដែលដឹកនាំដោយខុនញ៉ាចក្រី ធ្វើឲ្យពួកនេះបាក់រត់តាមដែររហូតទាល់តែដល់គោកខាន់ ទើបរៀបចំសណ្ដាប់ធ្នាប់បានវិញ សម្រាកបោះជំរំ រួចហើយត្រៀមបិទផ្លូវ មិនឲ្យទ័ពបះបោរដែលដេញតាមមកធ្វើដំណើរបន្តទៅមុខ ។

ខុនញ៉ាចក្រី បានសរសេរសារលិខិតរាយការណ៍អំពីបរាជ័យនេះថ្វាយព្រះរាជា ហើយស្នើសុំទ័ពជំនួយ ។ ទទួលដំណឹងនេះ ព្រះរាជាក៏កោះប្រជុំសេនាបតីភ្លាម ។ លោក យមរាជ រាយការណ៍ថា ឥឡូវនេះ នាយកនកំពុងតែដឹកនាំទ័ពអបរាជ័យធ្វើដំណើរជិតមកហើយ កំណែនទាហាននៅតាមបណ្ដាខេត្តភាគខាងជើងមិនទាន់បាននៅឡើយទេ ហើយនៅសល់ទ័ពតែ១ម៉ឺននាក់ប៉ុណ្ណោះនៅក្នុងរាជធានី ទ័ពទាំងនោះជាប់រវល់ក្នុងការយាមកាមត្រួតពិនិត្យចរាចរ និងយាមទ្វារកំផែង ។ លោក យមរាជ ក៏ថ្វាយយោបល់ សូមឲ្យព្រះរាជាដកថយជាមួយរាជបរិពារទៅគង់នៅឯចតុម្មុខ ដើម្បីងាយស្រួលក្នុងការកេណ្ឌទ័ពតាមបណ្ដាខេត្តខាងត្បូង កាលណាបានច្រើនហើយសឹមត្រលប់មកទប់ទល់នឹងសត្រូវវិញ ។ រួចលោកនិយាយបន្តថា ៖ "ក្នុងរយៈពេលនោះ ខ្លួនទូលព្រះបង្គំ និងលោកចក្រី នឹងស្ថិតនៅពីខាងក្រោយ វាយទប់កុំឲ្យនាយកនចាប់ព្រះអង្គ និងរាជបរិពារបាន" ។

លោកពិជ័យនាគ ជាឪពុកនាយកន ខឹងនឹងកូនខ្លាំងណាស់ បានស្នើសុំទ័ពព្រះរាជា១ពាន់នាក់ដើម្បីចេញទៅច្បាំងជាមួយកូន ហើយបានទូលព្រះរាជាថានឹងថ្វាយខ្លួន ក្រុមគ្រួសារ និងញាតិកាទាំងអស់ ចំពោះព្រះរាជា និងតាមបម្រើព្រះអង្គគ្រប់ទិសទី ។ "បើសិនទូលព្រះបង្គំជាខ្ញុំបែរជាក្បត់ទៅនៅជាមួយកូនវិញ សូមឲ្យទូលព្រះបង្គំស្លាប់នឹងមុខអាវុធយ៉ាងវេទនាខ្លោចផ្សា ហើយសូមព្រះអង្គចាត់ឲ្យគេកាប់សម្លាប់គ្រួសារ និងញាតិកាទាំងអស់ចោលចុះ" ។ ព្រះរាជាជឿសម្ដីពិជ័យនាគ ក៏ប្រទានទ័ព១ពាន់នាក់ឲ្យ រួចចេញរាជបញ្ជាឲ្យបណ្ដាប្រជានុរាស្ត្រទាំងអស់ចូលមកនៅក្នុងរាជធានីលង្វែក ដែលមានទាហានការពារ២ម៉ឺន៥ពាន់នាក់ ចំណែកព្រះអង្គ និងបរិពារក៏ចុះ

ទូកមកកាន់ចតុម្មុខមុន ។

ខកញ៉ារាយមរាជ និងខកញ៉ាចក្រីរង់ចាំទ័ពកំណែនថ្មីមកជួយមិនចេះឃើញមកសោះ ណាមួយនាយកននាំទ័ព៥ម៉ឺននាក់មកដល់ហើយ ក៏វាយដកថយសំដៅទៅកាន់ចតុម្មុខដែរ ។ នាយកនតាមវាយប្រកិតៗ សម្លាប់ខកញ៉ាចក្រីបាន ធ្វើឲ្យកងទ័ពបាក់បែករត់ខ្ចាត់ខ្ចាយ រួចដេញតាមវាយរហូតទៅដល់ទ្វាររាជធានី ។ មកដល់ត្រង់នេះ ទ័ពនាយកនជួបប្រទះទ័ព១ពាន់នាក់របស់ឪពុកខ្លួន នាយកនក៏បញ្ជាថា "ចូរដេញតាមហើយកាប់សម្លាប់ឲ្យអស់ ទុកតែឪពុករបស់យើងបានហើយ" ។ ពិជ័យនាគបានតស៊ូប្រយុទ្ធយ៉ាងខ្លាំងក្លា ប៉ុន្តែមានគ្នាតិចពេក មិនអាចទប់ទល់នឹងទ័ពមួយកងធំបាន ក៏បញ្ជាឲ្យវាយដកថយ គេចចេញតាមផ្លូវធំសំដៅទៅកាន់ចតុម្មុខ ដោយនៅសល់ទ័ពតែ ៥រយនាក់ប៉ុណ្ណោះ ។ រត់មកដល់វត្តព្រះសុគន្ធបទ ជួបសម្តេចសង្ឃ ក៏នាំគ្នាចូលទៅតាំងទីនៅកន្លែងនោះប្តេជ្ញាថា នឹងតស៊ូប្រយុទ្ធរហូតដល់អវសានជីវិត ។

ទ័ពពួកក្បត់ឡោមព័ទ្ធវត្តដែលបានក្លាយទៅជាបន្ទាយមួយដ៏ជិតទាំងអស់ រួចហើយក៏ចាប់ធ្វើការវាយប្រហារ ។ ការប្រយុទ្ធសាហាវណាស់ ធ្វើឲ្យស្លាប់មនុស្សទាំងសងខាង តែមិនមានអ្នកណាឈ្នះអ្នកណាចាញ់ទេ ។ ដោយមើល ឃើញភាពគួរឲ្យអាណោចអាធ័មរបស់ទ័ពទាំង២កង ដែលកាប់សម្លាប់គ្នាដូច្នេះ ព្រះសុគន្ធបទលោកក៏និមន្តមកនៅកណ្តាល ហើយមានពុទ្ធដីកាអង្វរសូមឲ្យទាំងសងខាងដាក់អាវុធចុះ ។ ព្រះអង្គបានហៅនាយកនឲ្យមកសុំទោសឪពុក រួចមានពុទ្ធដីកាទៅកាន់ពិជ័យនាគថា កូនរបស់លោកបានត្រូវវាសនាកំណត់ឲ្យមកសោយរាជ្យនៅកម្ពុជាមិនអាចប្រឆាំងបានទេ ត្រូវតែទទួលតាមយ៉ាងនេះ ។ ពិជ័យនាគឆ្លើយទៅវិញថា បើធ្វើយ៉ាងនេះប្រៀបបាននឹងធ្វើឲ្យគេកាប់សម្លាប់ក្រុមគ្រួសារញាតិការបស់ទូលព្រះបង្គំហើយ រួចហើយក៏ដកដាវប្រុងចង់កាប់សម្លាប់កូន ប៉ុន្តែ បានត្រូវកងការពារចាប់ដាប់ ហើយយកទៅឃុំទុកនៅក្នុងវត្តនោះទៅ ។

នៅក្នុងទីឃុំឃាំង ព្រះសុគន្ធបទបាននិយាយពន្យល់ជាច្រើន រហូតទល់តែពិជ័យនាគយល់ព្រមស្តាប់តាម ទើបលោកហៅឪពុក និងកូនឲ្យឡើងលើគំនរអាវុធមួយកម្ពស់មួយជំហរមនុស្ស ស្បថស្បែនៅចំពោះមុខមហាជនថានឹងស្រុះស្រួលជានានឹងគ្នាវិញ ។ ពេលនោះ ព្រះសុគន្ធបទ ក៏ចាក់ទឹកមន្តស្រោចស្រពឲ្យអ្នកទាំង២ ។

ចប់ពិធីស្បថស្បែ នាយកនបញ្ជាឲ្យយកអាវុធចេញពីគំនរ ទៅកសាងផ្លូវចូលវត្ត ។ គឺដោយហេតុនោះហើយទើបបានជាវត្តនោះបានត្រូវគេហៅថា វត្តព្រះថ្កល់ៗរហូតមក[៥៦] ។

ស្តេចកនពេលនោះ បានបន្តជ្រើសរើសកងទ័ពនៅក្នុងខេត្រខាងកើតដែលចុះចូលនឹងខ្លួន ។ រើសបាន

[៥៦] ភូមិថ្កល់នេះស្ថិតនៅពីខាងទិសពាយ័ព្យភ្នំពេញ ចម្ងាយប្រហែល៨គីឡូម៉ែត្រ ។ គេមានសង់វិហារកាតូលិកមួយនៅកន្លែងនេះនៅសតវត្សទី១៧ ។

ហើយបែកកម្លាំងជាពីរ រួចក៏ដឹកនាំមួយក្រុមមកតាំងនៅចំពីមុខចតុមុខ ។

ដឹងដំណឹងនេះ ព្រះរាជាបានបញ្ជាឲ្យចេញទ័ពមកទប់ទល់ ប្រយុទ្ធគ្នា៣យប់៣ថ្ងៃមិនឈ្នះមិនចាញ់ ។ ដល់យប់ថ្ងៃទី៣ នាយកនបានចាត់ឲ្យទាហានមួយក្រុមធ្វើដំណើរវាងពីខាងលិច ចូលមកនៅពីខាងត្បូងទ័ពព្រះរាជា ។ ដល់ស្អែកឡើង ទ័ពនាយកនចាប់វាយទ័ពព្រះរាជាពីខាងមុខផង និងពីខាងក្រោយផង ធ្វើឲ្យទ័ពនោះថយដៃ វាយដកថយតាមផ្លូវទៅទិសខាងជើង រត់គេចរហូតទៅដល់លង្វែក ។

ពេលនោះព្រះរាជាបាននាំរាជបរិពារគេចព្រះអង្គទៅគង់នៅឯខែត្រសន្ធុក លើមាត់ស្ទឹងសែនត្រង់កន្លែងមួយជិតកំពង់ធំសព្វថ្ងៃ ។ ព្រះអង្គបានចេញបញ្ជាពីទីនោះឲ្យនាម៉ឺនសព្វមុខមន្ត្រីចេញកេណ្ឌប្រមូលទ័ព ។

ទទួលបានជ័យជម្នះលើកងទ័ពព្រះរាជា ដែលខ្លួនបានវាយបំបាក់ឲ្យរត់ដកថយទៅទិសខាងជើងអស់ហើយ នាយកន បានចូលគ្រប់គ្រងរាជធានីចតុម្មុខ រួចក៏ចាប់ចាត់តាំងចៅហ្វាយខែត្រ នាម៉ឺនតូចធំ ហើយបញ្ជូនអ្នកដែលស្មោះត្រង់ឲ្យទៅបញ្ចុះបញ្ចូលបណ្ដាអាណាខែត្រខាងលិច និងខាងត្បូងឲ្យចុះចូលនឹងខ្លួន ។ បណ្ដាខែត្រទាំងនោះមាន ចតុម្មុខ សំរោងទង បាទី ទ្រាំង បន្ទាយមាស ពាម កំពត កំពង់សោម បាសាក់ (ត្រាវិញ) ព្រះត្រពាំង ក្រមួនស អូម៉ាល់ ទឹកខ្មៅ ពាមមេសរ ព្រៃនគរ (សាយហ្គន) និងបារាជដុងណាយ គឺភាគខាងត្បូងកម្ពុជាទាំងអស់ ចាប់តាំងពីភ្នំពេញរហូតដល់មាត់សមុទ្រសៀម និងទៅដល់ព្រំប្រទល់នគរចាម្ប៉ា ។ អ្នកស្រុកទទួលអបអររាក់ទាក់ទទួលនាយកន ជាស្ដេច ព្រោះជាអ្នកមានបុណ្យ មានឫទ្ធិចេស្ដាបារមី ។ គេចាប់និយាយ រឿងរ៉ាវផ្សេងៗពីនាយកនដូចជាថានាយកនកើតចេញពីផ្ទៃម្ដាយមក ធ្លាក់ទៅក្នុងទឹកទាំងនៅក្នុងសុក ក៏ត្រូវ ត្រីពោលេប ហើយបានត្រូវព្រះសង្ឃមួយអង្គស្រង់យកទៅចិញ្ចឹមបីបាច់ថែរក្សាក្រោយពីវះយកចេញពីពោះត្រីមក ។ នៅពេលដែលស្ដេចបង់សំណាញ់ពីលើ មាននាគមកជួយនាំហែលទឹកគេចខ្លួន រួចហើយសត្វព្រាបទំពីលើក្បាលហាក់បីដូចជាទំលើមែកឈើ ជួយលាក់កុំឲ្យទាហានស្ដេចឃើញ ហើយជ័យជម្នះទាំងអស់ដែលនាយកនបានទទួលនេះ គឺអាស្រ័យដោយកុសលដែលបានសាងពីជាតិមុន[៥៧] ។

នៅក្នុងខែមិគសិរឆ្នាំ១៥១០ នាយកនបានបញ្ជូនកងទ័ព៥ម៉ឺននាក់ ទៅហ៊ុំព័ទ្ធលង្វែកដែលបានក្លាយជារាជធានីឡើងវិញ ឯខ្លួនឯងបានត្រលប់ទៅរាជវាំងនៅទួលបាសានក្នុងខែត្រស្រីសន្ធរ ។ ប៉ុន្មានថ្ងៃក្រោយមកមេទ័ពខាងទន្លេក្នុង (ទន្លេសាប) បានពើបប្រយុទ្ធជាមួយទ័ពព្រះរាជាពេញមួយថ្ងៃ គ្មានឈ្នះគ្មានចាញ់ ទ័ពព្រះរាជាក៏មិនដកថយទៅណាដែរ ។

មេទ័ពម្នាក់ទៀតដែលបញ្ជាកងទ័ពខាងទន្លេធំ បានរៀបចំលើកប៉មការពារ រង់ចាំទ័ពដែលជ្រើសរើសថ្មី

[៥៧] គេថាព្រះសង្ឃបានដាក់ឈ្មោះឲ្យថា កែវ ក៏ប៉ុន្តែឪពុកម្ដាយហៅថា កន ។

បញ្ជូនមកដល់ បើពុំនោះគឺបញ្ជាមិនឲ្យចេញដំណើរទេ ។ ពេលនោះចៅហ្វាយខែត្រកំពង់សៀម និងស្ទឹងត្រង់ មិនព្រមទទួលស្គាល់អំណាចនាយកនទេ តែដល់មើលឃើញថា ទ័ពនាយកនរាតត្បាតពេញនគរ ធ្វើឲ្យអ្នកស្រុក មានការខ្វល់ខ្វាយជាខ្លាំង ក៏បានផ្ញើសារទៅសុំជំនួយពីព្រះរាជា ។ ព្រះរាជាក៏បញ្ជូនទ័ពមកឲ្យចំនួន៨ពាន់នាក់ បញ្ជាដោយចៅពញាយសរាជាជាព្រះរាជបុត្រ ជាហេតុធ្វើឲ្យកងរក្សាព្រះអង្គកាន់តែចុះខ្សោយថែមទៀត ក្នុងការប្រយុទ្ធតទល់ជាមួយទ័ពទន្លេក្នុង ។

ឆ្លៀតឱកាសទ័ពព្រះរាជាថយកម្លាំងនេះ មេទ័ពក្រុមបះបោរក៏ចាប់បើកការវាយប្រហារមកលើទ័ពព្រះរាជា ដោយប្រយុទ្ធពេញ៤យប់ ៤ថ្ងៃ ហើយបង្ខំឲ្យទ័ពព្រះរាជាដកថយរហូតទៅដល់អម្រឹតបុរៈ គឺបរិបូណ៌ ។ ដំណឹងនេះ លេចឮទៅដល់ចៅពញាយសរាជាដែលកំពុងតែដឹកនាំទ័ពទៅកាន់ខែត្រកំពង់សៀម ចៅពញាយសរាជា ក៏នាំទ័ពវិលត្រលប់មកក្រោយវិញដើម្បីជួយព្រះបិតា ។ ដឹងថាចៅពញាយសរាជាត្រលប់មកវិញ ព្រះរាជាបានប្រកាសប្រាប់កងពលឲ្យដឹង រួចទ្រង់បញ្ជាឲ្យវាយបកមកលើទ័ពពួកក្បត់វិញ ស្របពេលដែលទ័ពរាជបុត្រមកដល់ដែរ ។ ទ័ពព្រះរាជាទាំង២កងរួមកម្លាំងវាយព្រមៗគ្នាទៅលើពួកក្បត់ សម្លាប់ពួកនេះអស់១ពាន់នាក់ភ្លាមៗ ។ មេទ័ពសត្រូវអស់សង្ឃឹម ក៏នាំទ័ពសេសសល់រត់គេចមកភ្នំពេញវិញ ។

រហូតដល់ពេលនោះ វាហាក់ដូចជាអ្វីៗត្រូវកាត់ផ្តាច់ នាយកន ដូចជាអស់បុណ្យហើយ ព្រោះទាហាន និងអ្នកគាំទ្រ ក៏ចាប់ធ្លៀយណាយអស់សង្ឃឹម ។

ព្រះរាជា បានប្រគល់ឲ្យចៅហ្វាយខែត្រពោធិសាត់ ទៅបោះទ័ពនៅក្នុងខែត្ររលាប្អៀរ នៅពីខាងជើងលង្វែក ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យព្រះនគរ រួចឲ្យចៅពញាយសរាជាដឹកនាំទ័ព៥ពាន់នាក់ ទៅគ្រប់គ្រងបណ្តាខែត្រខាងជើងដែលចុះចូលជាមួយនាយកនពីមុនមក ចំណែកព្រះអង្គយាងទៅគង់នៅឯខែត្រសន្ទុកវិញ ។

ចៅពញាយសរាជាបានដណ្តើមយកខែត្រខាងជើងមកវិញ រួមទាំងកំពង់សៀម ស្ទឹងត្រង់ គោកសេះ និងជើងព្រៃជង[៥៨] ដោយរៀបចំចាត់តាំងចៅហ្វាយខែត្រដែលស្មោះត្រង់ដឹកនាំរួចហើយ ទ្រង់ក៏យាងទៅតាមព្រះបិតានៅឯសន្ទុក ។

នៅពេលនោះ នាយកនមានទ័ពសរុបប្រមាណ១០ម៉ឺននាក់នៅបាសាន រង់ចាំតែបញ្ជានឹងអាលចេញដំណើរ ក៏ប៉ុន្តែនាយកននៅស្ទាក់ស្ទើរ មិនទាន់ហ៊ានសម្រេចយ៉ាងណានៅឡើយ ។ នាយកន បានចាត់ឲ្យគេរៀបចំធ្វើពិធីប្រក់ព្រំពល រួចហើយបានប្រកាន់យកឋានៈជាមហាឧបរាជមានឈ្មោះថា ព្រះស្រីជេដ្ឋាធិរាជ ជាឋានៈសម្រាប់អ្នកចាត់ចែងកិច្ចការសង្គ្រាម ហើយមិនហ៊ានទទួលយកឋានៈជាស្តេចដូចដែលគេហៅជាទូទៅរួចមកហើយនោះទេ ។ កន បានឲ្យគេធ្វើទង់ពណ៌ក្រហមមានជរជាយ និងរូបនាគក្បាល៧នៅកណ្តាលចែកឲ្យកងទ័ព និងឲ្យគេធ្វើ

[៥៨] គឺបណ្តាខែត្រទាំងអស់នៅចន្លោះទន្លេសាបពីខាងលិច និងទន្លេមេគង្គពីខាងកើត ត្រឹមខែត្រលង្វែក ដែលស្ថិតនៅលើត្រើយខាង

ស្មុតច្ចត្រមួយសម្រាប់ខ្លួនឯង ។ នាយកនបានឲ្យពិជ័យនាគជាឪពុក ធ្វើជាមេបញ្ជាការលើកទ័ពការពារបន្ទាយបាសាន រួចក៏ដឹកនាំទ័ពធ្វើដំណើរចេញទៅកាន់ខេត្តកំពង់សៀម ។ ពុដំណើរនេះ ពួកមន្ត្រីៗក៏រត់គេចទៅជ្រកកោនជាមួយព្រះរាជា ។

ស្ដេចកនក៏សរសេរលិខិតមួយច្បាប់ ចាត់ឲ្យមន្ត្រីរបស់ខ្លួនជាច្រើនរូបនាំយកទៅថ្វាយព្រះរាជាដែរ ។ មុននឹងទទួលអ្នកនាំសារទាំងអស់នោះ ព្រះរាជាបានឲ្យគេនាំយកក្រុមគ្រួសារពិជ័យនាគទាំងអស់មកទុកមួយកន្លែងហាក់បីដូចជាទ្រង់ប្រុងតែនឹងឲ្យគេធ្វើទណ្ឌកម្មអ្វីចឹង ។ សារលិខិតមានខ្លឹមសារដូចតទៅ ៖ «ទូលព្រះបង្គំឃុនហ្លួងព្រះស្ដេចធិបតី សូមទូលថ្វាយព្រះរាជាទ្រង់ព្រះសណ្ដាប់ថា រហូតមកដល់ពេលនេះ ទូលព្រះបង្គំគ្មានបំណងអ្វីក្រៅតែអំពីការពារជីវិតទូលព្រះបង្គំដែលត្រូវរងការគំរាមកំហែងនោះទេ ហើយមិនដែលមានគំនិតចង់ដណ្ដើមយកព្រះរាជាណាចក្រពីព្រះអង្គម្ដងណាឡើយ ។ ទូលព្រះបង្គំមានបំណងតែមួយគត់គឺតាមបម្រើព្រះអង្គដូចពីមុនប៉ុន្តែទូលព្រះបង្គំខ្លាចតែព្រះអង្គមិនព្រមលើកទោសគ្រាប្រណី ។ អាស្រ័យហេតុនេះ ទូលព្រះបង្គំ សំណូមពរសូមឲ្យព្រះអង្គ ព្រះមេត្តាដោះលែងម្ដាយ និងសាច់សារលោហិតទូលព្រះបង្គំទាំងអស់ ដើម្បីឲ្យទូលព្រះបង្គំ បានឃើញមុខឡើងវិញ និងដើម្បីជាការបញ្ជាក់ផងដែរថា ព្រះអង្គទ្រង់យល់ព្រមលើកលែងទោស ហើយអាចឲ្យទូលព្រះបង្គំជឿទុកចិត្តបាន ។ កាលណាក្រុមគ្រួសារទូលព្រះបង្គំបានត្រលប់មករស់នៅជិតទូលព្រះបង្គំវិញហើយ ទូលព្រះបង្គំនឹងរំសាយកងទ័ព ឲ្យពួកគេវិលត្រលប់ទៅស្រុកវិញ» ។

ព្រះរាជាបានសរសេរព្រះសារលិខិតមួយឆ្លើយតបទៅវិញថា បើសិនជា នាយកន នៅស្មោះត្រង់មែន នាយកន ត្រូវតែចូលខ្លួនមកថ្វាយបង្គំគាល់ព្រះរាជា មិនចាំបាច់សុំឲ្យប្រគល់ចំណាប់ខ្មាំងទៅឲ្យនោះឡើយ ព្រោះនេះមិនមែនជាទម្លាប់ធ្វើដូច្នេះទេ ។ បើសិនជា នាយកន សារភាពចុះចូល នោះនឹងទទួលបាននូវការលស់លាគ្រាប្រណី ប៉ុន្តែបើសិនជាមិនព្រមចូលខ្លួនមកទេ ម្ដាយ ក្រុមគ្រួសារ និងញាតិកាទាំងអស់ នឹងត្រូវទទួលទារុណកម្មមិនខាន ។

ស្ដេចកនបានបញ្ជូនសំបុត្រនេះទៅឲ្យឪពុកមើល ធ្វើឲ្យពិជ័យនាគមានការព្រួយបារម្ភយ៉ាងខ្លាំង ក៏សម្រេចចិត្តថាត្រូវតែរារាំងនាយកនកុំឲ្យបន្តសង្គ្រាម ហើយត្រូវតែចូលសារភាព ។ គាត់រត់ទៅកាន់ពន្ធនាវិញយ៉ាងលឿន ហើយនៅពេលដែលឆ្លងផុតមាត់ទ្វារ គាត់ក៏រអិលជើងដួលជង់នឹងដាវមួយដែលដាក់គងលើទម្រមួយបណ្ដាលឲ្យរបួសជាខ្លាំង រហូតដល់ដួលលើដី សន្លប់បាត់បង់ស្មារតី ។ ពួកពលសេនាបាននាំគ្នាលើកគាត់ឡើង ហើយរាយការណ៍ជូននាយកន នាយកន ក៏ប្រញាប់ប្រញាល់រត់មក តែឪពុកបានស្លាប់បាត់ទៅហើយ នៅពេលមកដល់ ។

---

ស្ដាំទន្លេសាប ។ គោកសេះមិនមែន ជាខេត្តទេ ជាចំណែកមួយនៃខេត្តជើងព្រៃ ។

ពេលនោះ ក៏មានលេចព្ពាក្យចចាមអារ៉ាមថា នាយកនបានអារកសម្លាប់ឪពុក នៅពេលឈ្លោះជជែកគ្នា ។

ដើម្បីទុកពេលធ្វើបុណ្យឲ្យឪពុក នាយកន បានបញ្ជាឲ្យដកទ័ពចេញទៅវិញ ។ ព្រះរាជាក៏ចាត់ឲ្យខុកញ៉ាតេជោ ចូលមកកាន់កាប់ខេត្រកំពង់សៀមវិញ រួចហើយឲ្យឆ្លងទន្លេទៅកាន់កាប់ខេត្រត្បូងឃ្មុំថែមទៀត ។ ទ្រង់បានចាត់ឲ្យខុកញ៉ាក្រឡាហោម រដ្ឋមន្ត្រីខាងជើងទឹក ចេញទៅវាយដណ្តើមយកលង្វែក និងចតុម្មុខមកវិញផងដែរ ។ ប៉ុន្មានថ្ងៃក្រោយមក ចៅពញាសួគ៌ាលោក[៥៩] ចៅហ្វាយខេត្រពោធិសាត់ បាននាំទ័ព មួយចំនួនមកជួយក្រឡាហោម វាយយកចតុម្មុខ (ភ្នំពេញ) បាន ។

ទទួលបានដំណឹងថាភ្នំពេញត្រូវរងការគំរាម នាយកនដែលពេលនោះមានទ័ព១២ម៉ឺននាក់ក្នុងដៃ បានប្រគល់ទ័ព១ម៉ឺននាក់ឲ្យឪពុកមាឈ្មោះ កៅ ដែលត្រូវជាប្អូនប្រុសរបស់ ម៉ែបាន និងមានងារជាចៅពញាទល្ហៈ ឲ្យចេញទៅរង់ចាំទប់ទ័ពព្រះរាជាដែលដឹកនាំដោយចៅពញាសួគ៌ាលោកនៅនឹងទន្លេក្នុង (គឺទន្លេសាប) ។ រួចបានចាត់ឲ្យមន្ត្រីម្នាក់ ដែលខ្លួនបានដំឡើងឲ្យទៅជាខុកញ៉ាក្រឡាហោម ដឹកនាំទ័ព១ម៉ឺននាក់ទៀត ចេញទៅស្កាត់ផ្លូវចៅពញាតេជោ ។ ចំណែកខ្លួនឯង នៅសល់ទ័ព១០ម៉ឺននាក់ ចេញទៅតតាំងជាមួយទ័ពដែលដឹកនាំដោយខុកញ៉ាក្រឡាហោម របស់ព្រះរាជា ។

ទ័ពរបស់ព្រះរាជាទទួលបរាជ័យនៅក្នុងសមរភូមិជាច្រើន រួចហើយក៏នាំគ្នារត់គេចមកសន្ទុក ជាកន្លែងដែលព្រះរាជាគង់នៅ ដោយយកលេសថាមកសុំជំនួយបន្ថែម ។

មានការចេញកេណ្ឌទ័ពជាថ្មីទៀតនៅក្នុងខេត្រស្ទឹងត្រង់ គោកខាន់ សុរិនជន្កា[៦០] រំដួលស្នំ ខាចចុងកាល់ បាត្រាង ដង្កែទំនប់ មន្គលបុរី ឫស្សីសាញ ទឹកឈូ បាត់ដំបង ពោធិសាត់ ក្រគរ ខ្លាញ ក្រាំង និងបរិបូណ៌[៦១] ក៏ប៉ុន្តែទាំង១៦ខេត្រនេះ បានត្រឹមតែ៥ម៉ឺននាក់ប៉ុណ្ណោះ ព្រោះប្រជារាស្ត្រមិនចង់ធ្វើសង្គ្រាម ក៏នាំគ្នារត់គេចចូលព្រៃ

---

[៥៩] យើងបានឃើញពីខាងលើរួចមកហើយថាមានព្រះរាជាមួយអង្គព្រះនាមថា និព្វានបទ មានន័យថាទ្រង់ជាភ្ញៀវស្ថាននិព្វាន, មានព្រះរាជាមួយព្រះអង្គទៀតព្រះនាមថា សុគន្ធបទ មានន័យថាទ្រង់ជាភ្ញៀវរបស់ស្ថានសួគ៌ ។ ឥឡូវនេះ យើងឃើញមានចៅហ្វាយខេត្រម្នាក់មានឈ្មោះថា សួគ៌ាលោក ដែលមានន័យដូចគ្នាដែរ ហើយយើងនឹងឃើញនៅខាងក្រោយទៀតថា មានចៅហ្វាយខេត្រម្នាក់ទៀត មានឈ្មោះថា ពិស្ណុលោក មានន័យថា ជាភ្ញៀវរបស់ព្រះវិស្ណុ ។ ឈ្មោះទាំងអស់នេះ ធ្វើឲ្យយើងនឹកឃើញដល់ ព្រះមរណនាមនៅកម្ពុជាសម័យបុរាណ គឺឈ្មោះដែលគេថ្វាយដល់ព្រះរាជា ក្រោយពីទ្រង់សុគតទៅ ។ ជារឿងមួយគួរឲ្យឆ្ងល់ថាហេតុអ្វី បានជាដល់មកកម្ពុជាសម័យថ្មី គេយកឈ្មោះបែបនេះមកដាក់ឲ្យមនុស្សរស់ទៅវិញ ។

[៦០] តាមឈ្មោះដែលរៀបរាប់នេះ យើងឃើញថា នៅដើមសតវត្សរ៍ទី១៦ ទឹកដីនៅខាងជើងភ្នំដងរែក ចន្លោះខេត្រខុប៊ុន និងកូរ៉ាត់ នៅជារបស់ខ្មែរនៅឡើយ ។

[៦១] បណ្តាខេត្រទាំងអស់នេះស្ថិតនៅខាងជើង និងខាងកើតបឹងធំ និងទន្លេសាប រួមមានខេត្របាត់ដំបងទាំងមូល និងទឹកដីដ៏ធំមួយនៅខាងជើងភ្នំដងរែក ។ បរិបូណ៌ពេលនោះមានឈ្មោះថា អម្រឹតបុរៈ ។

អស់ ។ ពេលនោះទ័ពស្តេចកនបានមកដល់លើមាត់ស្ទឹងសែន នៅសល់តែប៉ុន្មានគីឡូម៉ែត្រប៉ុណ្ណោះពីសន្ទុក ។ ស្តេចកនអាចនឹងចាប់ផ្តើការប្រយុទ្ធទៅលើកងទ័ពរបស់ព្រះរាជា ហើយទទួលជោគជ័យបាន ប៉ុន្តែគេចង់លួចធ្វើគុតព្រះរាជាផង ក៏ចាត់ឲ្យនាគម៉ឺនសួរេនចូលគាល់ព្រះរាជារួចធ្វើគុតព្រះអង្គទៅ ស្តេចកនសន្យាថា នឹងលើកឲ្យធ្វើជាខុកញ៉ាយោមរាជ ។ នាគម៉ឺនសួរេននេះត្រូវជាកូនចៅពញាយោធាសង្គ្រាម ដែលស្តេចកន បានបាញ់ព្រួញសម្លាប់នៅនឹងដើងដំរី ។ មានគេនិយាយប្រាប់ថាព្រះរាជាបានប្រើឪពុកខ្លួនឲ្យទៅតទល់ជាមួយនឹងស្តេចកនដោយប្រគល់ទ័ពឲ្យតែមួយចំនួនតូចប៉ុណ្ណោះ ពីព្រោះព្រះរាជាចង់ឲ្យគាត់ស្លាប់ដូច្នេះ ម្ល៉ោះហើយ ខ្លួនមានចិត្តស្អប់ព្រះរាជា ក៏ចុះចូលជាមួយពួកបះបោរទៅ ។ ស្តេចកនពូកែរើសមនុស្សណាស់ ពីព្រោះថា នាគម៉ឺនសួរេន នេះ ជាមនុស្សឆ្លាតវៃ រហ័សរហួន មានសមត្ថភាពធ្វើអ្វីៗបានសម្រេចគ្រប់យ៉ាង ។

ដល់ស្អែកឡើង ស្តេចកនធ្វើជាខឹង បានចេញបញ្ជាឲ្យចាប់នាគម៉ឺនសួរេនមកវាយ៣០រំពាត់ ។ គេនាំអ្នកទោសយកមកដាក់នៅចន្លោះកងទ័ពទាំង២ ហៀបតែនឹងធ្វើទារុណកម្មទៅហើយ ស្រាប់តែសេនារបស់ នាគម៉ឺនប្រមាណជា២០០នាក់ស្ទុះចូលមកដណ្តើមយកពីដៃទាហាន រួចនាំយកមកចុះចូលជាមួយទ័ពខាងព្រះរាជាវិញ ។ ចៅពញាតេជោជាអ្នកទទួលពួកនេះ ហើយក្រោយពីបានសាកសួរពត៌មានរួចហើយ ក៏នាំនាគម៉ឺនសួរេន ចូលគាល់ព្រះរាជាដែលគង់នៅឯវាំងស្ទឹងសែន លើស្ទឹងកំពង់ធំ ។ នាគម៉ឺនសួរេនទូលព្រះរាជាថា ខ្លួនបានរៀបចំផែនការក្បត់ ប្រឆាំងនឹងស្តេចកន តែត្រូវស្តេចកនដឹង ក៏ដាក់ទោសឲ្យគេវាយខ្លួននឹងរំពាត់ផ្តៅឲ្យស្លាប់ តែបានពលទាហានរបស់ខ្លួន២០០នាក់ជួយទាន់ ។ បន្ទាប់មកនាគម៉ឺននេះក៏ធ្វើជាយំយែករំអួយថា មិនដឹងជាក្រុមគ្រួសាររបស់ខ្លួនដែលកំពុងតែរស់នៅក្នុងបន្ទាយស្តេចកន ត្រូវគេវាយធ្វើបាបយ៉ាងណាទេ ។ ព្រះរាជាដែលជឿសម្តីទាំងអស់របស់នាគម៉ឺនសួរេន បានលើកលែងទោសចំពោះការដែលនាគម៉ឺននេះក្បត់ព្រះអង្គទៅបម្រើស្តេចកន រួចក៏តែងតាំងឲ្យទទួលឋានៈដូចដែលព្រះអង្គបានប្រគល់ពីមុន ។

នៅពេលនោះ ស្តេចកនក៏ចាប់បើកការវាយប្រហារមកលើទ័ពរបស់តេជោ ។ ប្រយុទ្ធគ្នាពេញមួយថ្ងៃមិនឈ្នះមិនចាញ់ តែទាហានស្លាប់ទាំងសងខាងពាសពេញដី ហើយទ័ពព្រះរាជាហាក់ដូចជាចង់ឈប់ប្រយុទ្ធតទៅទៀត ។ ខុកញ៉ាតេជោភ័យបារម្ភចំពោះសុវត្ថិភាពរបស់ព្រះរាជា ក៏ចេញបញ្ជាឲ្យរៀបចំព្រះទីនាំងនាវានាំព្រះរាជាយកមកគង់នៅឯខែត្រពោធិសាត់វិញ ដែលនៅទីនោះគេអាចរើសទ័ពបានជាថ្មី ។ ម្ល៉ោះហើយក៏វាយដកថយចេញ លះបង់ទឹកដីដ៏ធំឲ្យខ្មាំងសត្រូវ ប៉ុន្តែដើម្បីសង្គ្រោះព្រះរាជា ដែលជាមូលហេតុតែមួយគត់ក្នុងការប្រឆាំងនឹងជនក្បត់ ។ ប៉ុន្តែតើជួយព្រះរាជាដូចម្តេចបានទៅ បើឥឡូវមាននាគម៉ឺនសួរេនដែលបន្ទំខ្លួនចូលមកដើម្បីលួចធ្វើគុតព្រះអង្គទៅហើយ ។ ព្រឹកឡើង នៅពេលដែលព្រះរាជាតើនពីក្រឡាបន្ទំ ហើយកំពុងហៅហោរាឲ្យមកទស្សន៍ទាយអំពីព្រះសុបិនពីយប់កន្លងទៅ នាគម៉ឺនសួរេន និងពលទាំង២០០នាក់បានសម្រុកចូលទៅក្នុងដំណាក់ព្រះអង្គដោយស្រែកថាខ្លួនមានកិច្ចការសំខាន់ដើម្បីទូលថ្វាយព្រះរាជា ហើយសម្លាប់ហោរាដែលចង់ឃាត់

ដំណើររបស់ខ្លួន រួចហើយធ្វើគុតព្រះរាជា សុគតទៅ ។ ឧក្រិដ្ឋកម្មនេះកើតឡើងនៅថ្ងៃ១៥កើត ខែជេស្ឋ ឆ្នាំវក គ្រិស្តសករាជ១៥១២ ត្រូវនឹងមហាសករាជ១៤៣៤ ចុល្លសករាជ៨៧៤ ។ រហូតដល់ពេលនោះព្រះបាទស្រីសុគន្ធបទ សោយរាជសម្បត្តិបាន៨ឆ្នាំ គិតទាំងរយៈកាល៣ឆ្នាំនៃសង្គ្រាមស៊ីវិលផង ។ ព្រះអង្គឡើងសោយរាជ្យក្នុងព្រះជន្ម ៣២ព្រះវស្សា ហើយត្រូវគេធ្វើឃាតក្នុងព្រះជន្ម ៤០ព្រះវស្សា ។

មានការប្រយុទ្ធកើតឡើងបន្ទាប់ពីព្រះរាជាត្រូវគេធ្វើឃាតនេះ រវាងទាហានទាំង២០០នាក់របស់នាគម៉ឺនសួរេន និងកងរក្សាព្រះអង្គ ។ ចៅពញាយស រាជបុត្ររបស់ព្រះរាជា និងត្រូវជាក្មួយរបស់ស្តេចកន បាននាំទាហានមួយក្រុមតូចរត់មកដល់ក្រោយពីបានឮសំឡេងប្រយុទ្ធ កាប់សម្លាប់ពួកក្បត់ ២០នាក់ ហើយចាប់នាគម៉ឺនសួរេន បាន ។ ទ្រង់បានបញ្ជាឲ្យនាំនាគម៉ឺនសួរេននេះយកទៅកាត់ក្បាលនៅពីមុខព្រះរាជវាំង ។

ក្នុងពេលនោះដែរ ការប្រយុទ្ធរវាងទ័ពស្តេចកនដែលលួចឈ្លបចូលទៅមុខក្នុងពេលយប់ ជាមួយនឹងទ័ពព្រះរាជាដែលចាប់វាយដកថយទៅដែរ ។ ចៅពញាយសរាជា ដោយពិនិត្យឃើញថាទ័ពបះបោរមានចំនួនច្រើនលើសលប់លើទ័ពរបស់ខកញ៉ាគេដោររួមជាមួយទ័ពព្រះអង្គ ហើយគិតថាមិនអាចតតាំងបាន ក៏ឡើងទូកចុះតាមស្ទឹងសែន ដើម្បីគេចព្រះអង្គទៅស្រុកសៀម ។

ពួកបារគូក៏គេចខ្លួនដែរ ដោយនាំយកទៅផងនូវព្រះខ័នរាជ្យ ព្រះអាទិទេពទាំង៥ព្រះអង្គដែលជាតំណាងសុភមង្គលព្រះរាជាណាចក្រ ធ្នូ ព្រួញ និងលំពែងរាជ្យ ។ ធ្វើដំណើរបានពាក់កណ្តាលផ្លូវ បារគូជាមេព្រាហ្មណ៍បុរោហិត គិតឃើញថា នគរសៀមជាសត្រូវរបស់ព្រះរាជាណាចក្រកម្ពុជា បើសិនជាយកកេតនភណ្ឌទាំងអស់នេះទៅមុខជាសៀមមិនឲ្យយកត្រលប់មកវិញទេ ។ បារគូ និងអ្នកបម្រើ ក៏នាំគ្នាឡើងគោកលើច្រាំងស្ទឹងខាងឆ្វេងវិញ រួចធ្វើដំណើរកាត់ព្រះរាជាណាចក្រ មកដល់ខេត្របាទី ទើបយកកេតនភណ្ឌទាំងអស់ ដាក់លាក់ទុកក្នុងរូងដើមចំបក់មួយដើម ។

ទៅដល់ស្រុកសៀម ចៅពញាយសរាជាបានចូលទៅរស់នៅជាមួយព្រះពញាច័ន្ទរាជាជាព្រះបិតុលាដែលបានគេចព្រះអង្គពីចតុម្មុខមក កាលពីជាង២ឆ្នាំមុន ។

## ១៧- ស្តេចកន ស្តេចជ្រែករាជ្យ (១៤៩៨-១៥០៥)

ក្រោយពីវាយបំបែកទ័ពទាំង២កងរបស់ព្រះរាជារួចហើយ ហើយចៅពញាយសរាជាគេចខ្លួនបាត់ទៅ ស្តេចកនគិតថា មានតែខ្លួនម្នាក់ប៉ុណ្ណោះ ដែលនៅជាម្ចាស់ព្រះរាជាណាចក្រកម្ពុជា ហើយក៏ត្រលប់មកនៅឯស្រីសន្ធរវិញ ។ ស្តេចកនបានចាត់ឲ្យចៅហ៊្វាកែវ ជាឪពុកមា ចេញបង្ក្រាបអាណាខេត្រដែលមិនទាន់ទទួលស្គាល់អំណាចរបស់ខ្លួន ថ្វីបើមានខ្លះមិនប្រឆាំងនឹងខ្លួនក៏ដោយ ។ មិនយូរប៉ុន្មានបណ្តាអាណាខេត្រទាំងអស់ទូទាំងប្រទេសមានចៅហ្វាយ និងនាម៉ឺនត្រួតត្រា ដែលតែងតាំងដោយស្តេចកន ។ ប៉ុន្តែស្តេចកនគ្មានព្រះខ័នរាជ្យ

ដែលជានិមិត្តសញ្ញារាជានិយមទេ ក៏បានផ្សព្វផ្សាយថានឹងឲ្យរង្វាន់ជាមាស៥០០តម្លឹង (ប្រហែល ១៨គីឡូក្រាម) ដល់ជនណា ដែលរកព្រះខ័នរាជ្យឃើញយកមកប្រគល់ឲ្យខ្លួន។ ស្តេចកនក៏បានឲ្យគេធ្វើព្រះខ័នរាជ្យមួយទៀត ដែលខ្លួនកាន់ នៅពេលបង្ហាញខ្លួន នៅមុខសាធារណជន។

ដោយប្រើប្រាស់ព្រះខ័នរាជ្យក្លែងក្លាយនេះ ស្តេចកនបានចាត់ឲ្យគេរៀបចំអភិសេកខ្លួនជាព្រះរាជានៃព្រះរាជាណាចក្រកម្ពុជា ក្រោមព្រះនាមថាសម្តេចព្រះស្រីជេដ្ឋាធិរាជរាមាធិបតី ជាព្រះរាជាសោយរាជសម្បត្តិនៅក្រុងស្រីសន្ធរបវរបាសាន។

ស្តេចកនបានលើកឪពុកមាឈ្មោះ កែវ ជាប្អូនរបស់ម្តាយ ឲ្យឡើងជាទីចៅហ្វ៉ា គឺរដ្ឋមន្ត្រីទី១ ត្រួតត្រាលើសមាជិករាជវង្ស និងពលព្រះស្រីរតនត្រៃទាំងអស់។ អនុលោមទៅតាមទម្លាប់នៅក្នុងព្រះរាជាណាចក្រ ស្តេចកនបានលើកលែងឲ្យប្រជានុរាស្ត្រទាំងអស់រួចពន្ធចំនួន១ឆ្នាំ នៅក្នុងឱកាសអភិសេកខ្លួននេះ ហើយរាជពង្សាវតារនិយាយថាប្រជារាស្ត្រពេលនោះបានសុខសប្បាយខ្លាំងណាស់។

បន្ទាប់មក ស្តេចកនបានសម្រេចចិត្តផ្លាស់រាជធានីឲ្យរាជាណាចក្រដែលខ្លួនដណ្តើមបាន ដោយជ្រើសរើសកន្លែងមួយ ស្ថិតនៅលើព្រំប្រទល់ខេត្តត្បូងឃ្មុំ និងបាភ្នំ ត្រង់កន្លែងមួយមានឈ្មោះថា ស្រឡប់ ហើយមកគង់នៅចាប់ពីឆ្នាំ១៥១៨រហូតមក។ គេត្រូវប្រើពេលអស់២ឆ្នាំដើម្បីសាងសង់រាជវាំង កំផែងរាជធានី ប៉មសម្រាប់ការពារ ដំណាក់រាជមន្ទីរ និងត្រឡែងកែង រោងរបាំ សួនច្បារ។ ហើយដោយរាជធានីខ្វះខាតទឹក ស្តេចកនបានចាត់ខុកញ៉ាវៀង វាំង លំពាង និងស្នល់ ឲ្យជីកស្រះទឹកធំមួយរាងការ៉េ ហើយជ្រុងមួយៗមានឈ្មោះតាមអ្នកទាំងបួន។ ស្រះទឹកនេះនៅមានរហូតដល់សព្វថ្ងៃ។

និយាយអំពីរាជធានីថ្មី គេបានដាក់ឈ្មោះឲ្យថា ក្រុងស្រឡប់ព្រៃនគរបុរះរាជធានី[៦២] ។ បីឆ្នាំក្រោយមករាជធានីនេះមានមនុស្សរស់នៅច្រើនរាជធានីមុន២ដង ហើយមានជនបរទេសចេញចូលជាច្រើន។ ព្រះរាជាណាចក្រ មានសុខសន្តិភាពដូចពីមុនឡើងវិញ ហើយប្រជានុរាស្ត្របានសុខសម្បូរសប្បាយក្រោមរាជ្យស្តេចកននេះ ជាងស្តេចមុនៗទាំងអស់។

ស្តេចកន ជាព្រះរាជាកម្ពុជាមុនគេដែលបានចាត់ឲ្យបោះពុម្ពប្រាក់សម្រាប់ចាយវាយ ជាប្រាក់ស្ពឹងធ្វើពី

---

[៦២] រាជធានីនេះស្ថិតនៅចម្ងាយប្រហែលជា ២២គីឡូម៉ែត្រ ពីខាងកើតទីតាំងខេត្តព្រៃវែងសព្វថ្ងៃ នៅចំកណ្តាលខ្ពង់រាបខ្ពស់មួយព័ទ្ធជុំវិញទៅដោយទំនប់ មានប្រវែងជ្រុងមួយៗ ប្រហែល២ពាន់ម៉ែត្រ លើជ្រុងនីមួយៗមានច្រកចេញចូល៣ ៖ ច្រកមាស ត្រាច និងគ្នោត កល់ពីខាងជើង, ចង្អែក លាងជីលែង និងអន្ទុកពីខាងកើត, រាម ចចាតខាំ និងទំនប់ តាជីពីខាងត្បូង, ចិនកែ ពោធិធំ និងធ្នូកពីខាងលិច។ បន្ទាយព្រៃនគរនេះ លោក អែម៉ូនីញេ បានហៅថាជា "រាជធានីរបស់កម្ពុជាពីបុរាណ" តែតាមពិត នេះគឺជាបន្ទាយរបស់ស្តេចកនទេ។

មាសមានរូបនាគម្ខាង ។

ពេលនោះ នៅអយុធ្យាឯណោះវិញ ព្រះអង្គម្ចាស់ច័ន្ទ និងព្រះអង្គម្ចាស់យសមានការធុញថប់ជាខ្លាំង បានស្នើសុំស្តេចសៀមត្រលប់មកកម្ពុជាវិញ តែមិនបាន ។ ស្តេចសៀមខ្វល់រហូតដល់ថាឈប់លែងឲ្យអ្នកទាំង២ ចូលគាល់ ។ ព្រះអង្គម្ចាស់ច័ន្ទ ដែលមករស់នៅអយុធ្យានេះចំនួន៨ឆ្នាំ ពេលនោះមានព្រះជន្ម៣០ ព្រះវស្សាហើយ ទ្រង់ព្រះតម្រិះរិះរកវិធីធ្វើយ៉ាងណាឲ្យស្តេចសៀមសព្វព្រះទ័យឡើងវិញ ។ ទ្រង់បានចេញទៅទាក់បានដំរីសមួយយកមកថ្វាយស្តេចសៀម ស្តេចសៀមក៏ចាប់រាក់ទាក់ទទួលអ្នកទាំង២ឡើងវិញ ។ ដំរីសនោះ គេដាក់ឈ្មោះឲ្យថា ព្រះគជេន្ទ្រណារឿនខត្តម មានន័យថា «ដំរីល្អ» ។

ថ្ងៃមួយ ព្រះអង្គម្ចាស់ច័ន្ទបានស្នើសុំការអនុញ្ញាតពីស្តេចសៀម វិលត្រលប់ចូលមកស្រុកខ្មែរវិញ ដើម្បីកម្ចាត់ស្តេចកន ។ ស្តេចសៀមឆ្លើយថា សូមឲ្យរង់ចាំបន្តិច ពេលណាឱកាសល្អមកដល់ ទ្រង់នឹងចាត់ឲ្យគេហែហមព្រះអង្គទៅកាន់ស្រុកខ្មែរ ។

ព្រះអង្គម្ចាស់ច័ន្ទមិនសប្បាយចិត្ត និងចម្លើយនេះទេ ទ្រង់បានសម្រេចព្រះទ័យថា ត្រូវតែត្រលប់មកកម្ពុជាវិញភ្លាម ដោយមិនបាច់រង់ចាំការអនុញ្ញាតពីស្តេចសៀមទៀតឡើយ ។ ទ្រង់បានចាត់ខ្ញុំបម្រើរបស់ព្រះអង្គឲ្យចេញទៅបំផុសបំផុលបក្សពួកដែលព្រះអង្គមាននៅក្នុងខេត្រនាងរង នាងពាក ចុងកាល់ ទំនប់ទន្លេ ទឹកជួស មង្គលបុរី នគររាជ និងបាត់ដំបង ឲ្យអ្នកទាំងអស់នោះដើរនិយាយប្រាប់គេឯងថា ពួកគេរៀបចំនាំគ្នាចេញទៅទាក់ដំរីមួយ មានសម្បុរសដូចសំឡី ។ អ្នកបម្រើព្រះអង្គម្ចាស់ច័ន្ទបានផ្សព្វផ្សាយដំណឹងដំរីសនេះបានយ៉ាងលឿនរហូតទាល់តែពួកចៅមឿង ចៅបាន ចៅហ្វាយស្រុក និងមេភូមិទាំងឡាយជឿ ហើយនាំគ្នារាយការណ៍ថ្វាយព្រះរាជាអំពីរឿងដំរីសខុសធម្មតានេះ ។ ស្តេចសៀមមានបំណងចង់បានដំរីសនោះខ្លាំងណាស់ ដល់ពេលបើកអង្គប្រជុំ ទ្រង់ក៏សាកសួរថា តើមាននរណាស្ម័គ្រចិត្តចេញទៅទាក់ដំរីនោះ យកមកថ្វាយព្រះអង្គដែរឬទេ? ចៅពញាច័ន្ទរាជ ដែលបានចូលរួមប្រជុំនឹងគេដែរ ហើយដែលធ្លាប់ទាក់បានព្រះគជេន្ទ្រណារឿនខត្តម ថ្វាយម្តងរួចមកហើយ បានសុំខ្លួនចេញទៅទាក់យកមកថ្វាយម្តងទៀត ក៏ប៉ុន្តែបានស្នើសុំទាហាន៥០០នាក់ ដំរី៥០ ព្រមទាំងអាវុធយុទ្ធភណ្ឌចាំបាច់ផ្សេងៗសម្រាប់ការទាក់ដំរីនេះ និងព្រះរាជបញ្ជាពិសេសឲ្យពលសេនាទាំងអស់ ស្តាប់បង្គាប់ព្រះអង្គ មិនអាចប្រកែកបាន ។ ស្តេចសៀមយល់ព្រមតាមគ្រប់ល័ក្ខខ័ណ្ឌនៃសំណើនេះ រួចថ្វាយដាវរាជបញ្ជាមួយឲ្យផង (ឆ្នាំ១៥១៥) ។

ចៅពញាច័ន្ទរាជាក៏ធ្វើដំណើរចេញមកកម្ពុជាជាមួយព្រះភាគិនេយ្យពញាយសរាជា ខ្ញុំបម្រើទាំងអស់ និងពលទាហាន៥០០នាក់ដែលស្តេចសៀមថ្វាយឲ្យមកតាម ។ ធ្វើដំណើរ៧ថ្ងៃ មកដល់ព្រំប្រទល់ដែន ទ្រង់ឆ្លងចូលមកក្នុងកម្ពុជា ឲ្យពលទាហានបោះជំរំសម្រាក រួចទ្រង់សរសេរលិខិតមួយទៅថ្វាយដំណឹងដល់ស្តេចសៀមថា ព្រះអង្គបានធ្វើដំណើរមកដល់ព្រំប្រទល់ដែនហើយ ហើយព្រះអង្គនឹងបន្តដំណើរចូលទៅក្នុងព្រះរាជាណាចក្រ

តទៅទៀត ។ ពេលទទួលសារលិខិតនេះ អ្នកអង្គម្ចាស់ពញាអុងរាជា ជារាជបុត្ររបស់ព្រះស្រីរាមាធិបតី ដែលស្តេចសៀមបានសុំទុកជាកូនហើយលើកឲ្យធ្វើជាចៅហ្វាយខែត្រសុវណ្ណលោក[៦៣] ក៏នៅក្នុងសវនាការនោះដែរ ។ ពញាអុងនេះបានប្រកែកមិនព្រមត្រលប់មកកម្ពុជាវិញតាមការបបួលពីពញាច័ន្ទរាជា ជាបងប្អូនជីដូនមួយទេ ព្រោះបានធ្វើជាចៅហ្វាយខែត្រសុវណ្ណលោកនោះ វាសុខស្រួលទៅហើយ ។ ពេលស្តេចសៀមសួរអំពីខ្លឹមសារសារលិខិត ទ្រង់ក៏ទូលតបទៅវិញថាអ្នកអង្គម្ចាស់ច័ន្ទជាមនុស្សមានមោទនភាព ឆ្លាតវៃ សកម្ម មិនចង់បាត់បង់នូវសិទ្ធិអំណាចរបស់ខ្លួនទេ គាមមើលទៅព្រះអង្គយាងទៅដល់ព្រំប្រទល់ដែន ដើម្បីដណ្តើមយកព្រះរាជាណាចក្រកម្ពុជាពីស្តេចកន ដែលជ្រែករាជ្យមកវិញ ។

ពេលនោះស្តេចសៀមបានចាត់ពលទាហានសេះ៣០ឲ្យចេញទៅតាមពញាច័ន្ទ ដើម្បីបញ្ចុះបញ្ចូលឲ្យលះបង់គំនិតនេះហើយ ត្រលប់មកអយុធ្យាវិញ ឬបើពុំនោះទេក៏ត្រូវបញ្ជូនទាហាន ៥០០នាក់ដែលព្រះអង្គប្រគល់ឲ្យដើម្បីតាមទាក់ដីរីសទៅវិញដែរ ។

ពេលនោះចៅពញាច័ន្ទបានធ្វើដំណើរឆ្លងកាត់ព្រំដែន ហើយបានអូសទាញអ្នកស្ម័គ្រចិត្តតាមហែហមព្រះអង្គបាន៨០០នាក់ ចំណែកឯខ្ញុំបម្រើរបស់ព្រះអង្គបានកេណ្ឌគ្នាបាន២ពាន់នាក់ថែមទៀត ។ ជាមួយនឹងគ្នាចំនួន ៣ពាន់នាក់នេះ ហើយនិងទ័ពសៀម៥រយនាក់ផង ទ្រង់បានធ្វើដំណើរយាងមកដល់ខែត្រនគរសៀមរាប (អង្គរធំ)[៦៤] ហើយដណ្តើមយកទីក្រុងនេះបាន ។ គឺនៅទីនោះហើយ ដែលអ្នកនាំសាររបស់ស្តេចសៀមបាន តាមមកទាន់ ហើយដោយយល់ថាមិនអាចយាងព្រះអង្គត្រលប់ទៅស្រុកសៀមវិញបាន ក៏សាកល្បងបញ្ចុះបញ្ចូលទ័ពសៀមទាំង៥០០នាក់ឲ្យត្រលប់ទៅវិញ ។ ពេលនោះអ្នកអង្គម្ចាស់ច័ន្ទក៏ដកយកព្រះសែង (ដាវ) អាជ្ញាសឹក ចេញមកគ្រវីនៅពីមុខពួកសៀម ហើយមានបន្ទូលថា “នេះជាសញ្ញានៃអំណាចរបស់យើង ដែលស្តេចរបស់ពួកឯង ទ្រង់បានប្រទានឲ្យ ។ បើពួកឯងមិនគោរពតាមយើងទេ យើងនឹងកម្ទេចពួកឯងទាំងអស់នៅទីនេះ” ។ ទ័ពសៀម ខ្លាចទ័ពទើបរើសថ្មី៣ពាន់នាក់ ដែលនៅឈរព័ទ្ធជុំវិញជុំជិត ក៏លុតជង្គង់ចុះសុំការប្រោសប្រណី ។

អ្នកអង្គម្ចាស់ច័ន្ទទ្រង់អាណិតដល់ទ័ពសៀមទាំងនោះ ក៏មានបន្ទូលទៅកាន់ថា “អ្នកឯងវិលត្រលប់ទៅស្រុកសៀមវិញចុះ ហើយសូមទូលថ្វាយព្រះរាជាផងថា យើងសូមថ្លែងអំណរគុណព្រះអង្គ ដែលបានចិញ្ចឹមបីបាច់ថែរក្សាយើងអស់កាល៩ឆ្នាំ រួចទ្រង់បានឲ្យទ័ព៥រយនាក់ជូនយើងរហូតមកដល់ទីនេះ ។ យើងមិនអាចថ្លែងអំណរ

---

៦៣ ខែត្រនេះស្ថិតនៅលើទន្លេមេណាម ចម្ងាយប្រហែល ៣០គីឡូម៉ែត្រ ពីខាងជើងសុខោទ័យ ។

៦៤ នេះគឺជាលើកទី១ ហើយដែលយើងប្រទះឃើញពាក្យសៀមរាប ប្រើភ្ជាប់ជាមួយពាក្យនគរ ដើម្បីហៅខែត្រអង្គរ ។ តើពាក្យនេះមានកំណើតមុនរាជ្យស្តេចកន ឬក៏ក្រោយ? ខ្ញុំគិតថាពាក្យនេះកើតមាននៅពេលក្រោយមកទេ ក៏ប៉ុន្តែពួកអ្នកសរសេរប្រវត្តិសាស្ត្រនៅសតវត្សរ៍ទី១៩មិនបានគិតល្អិតល្អន់ ប្រើពាក្យនេះ ដូចដែលខ្លួនហៅនៅសម័យក្រោយនោះអ៊ីចឹងដែរ ។

គុណដល់ព្រះអង្គនៅពេលនេះបាន ពីព្រោះយើងនៅក្រ យើងគ្មានអ្វីនឹងថ្វាយដល់ព្រះអង្គជាការតបស្នងសងគុណទេ ។ តែសូមព្រះរាជាកុំបីខ្វល់នឹងយើងធ្វើអ្វី សូមព្រះអង្គទ្រង់មេត្តាត្រាប្រណីលើកលែងទោសឲ្យយើងផងកាលណាយើងទទួលបានជ័យជម្នះ ហើយបានឡើងសោយរាជ្យ យើងនឹងចាត់បញ្ជូនសួយសារអាករទៅថ្វាយដើម្បីជាការតបស្នងសងគុណនឹងគុណូបការៈដែលព្រះអង្គមានចំពោះយើង ក្នុងពេលដែលយើងរស់នៅក្នុងរាជធានីរបស់ព្រះអង្គ» ។

ពួកសៀមត្រលប់ចូលទៅស្រុកសៀមវិញទៅ ឯពញាច័ន្ទ ក៏បន្តព្រះរាជដំណើរចូលមកក្នុងកម្ពុជាជាបន្តទៀត ។ មកដល់ខែត្របាត់ដំបង ពញាមនោមេត្រី ជាចៅហ្វាយខែត្រនេះ បានមកទទួលព្រះអង្គជាមួយនឹងទ័ព ១ម៉ឺននាក់ ដែលខ្លួនប្រគល់ថ្វាយព្រះអង្គ ។

ចៅពញាសួគ៌ាលោក ចៅហ្វាយខែត្រពោធិសាត់ ដែលមិនអបអរនឹងការយាងមកដល់របស់ពញាច័ន្ទ បានសរសេរសំបុត្រផ្ញើទៅប្រាប់ដំណឹងដល់ស្ដេចកន ហើយបានកេណ្ឌទ័ព៤ម៉ឺននាក់ដើម្បីទប់ទល់ ព្រមទាំងបានរៀបចំកំផែងការពារខែត្រទៀតផង ។ ទ័ពអ្នកអង្គម្ចាស់ច័ន្ទបានពើបប្រយុទ្ធនឹងទ័ពចៅហ្វាយខែត្រនេះម្ដង ក៏ប៉ុន្តែ ពេលនោះមានជនប្រឆាំងម្នាក់ឈ្មោះ តាមឿង ដែលប្រមូលក្រុមគ្រួសារ និងមិត្តភក្តិបាន១៥០នាក់ទាំងអស់គ្នាសុទ្ធតែបម្រើនៅក្នុងជួរទ័ពខែត្រ បានឆ្លៀតឱកាសដែលចៅហ្វាយខែត្រនៅតែឯង ក៏នាំគ្នាវាយប្រហារ ហើយសម្លាប់ចៅហ្វាយខែត្រនោះទៅ ។ ចប់ឃាតកម្មនេះ តាមឿងបាននិយាយបញ្ចុះបញ្ចូលប្រជាជនក្នុងខែត្រ ឲ្យចុះចូល រួបរួមគ្នា តាមដង្ហែអ្នកអង្គម្ចាស់ច័ន្ទ ដែលជាប់ពូជជាមួយរាជវង្សស្ដេចកម្ពុជាពីមុន ដែលស្ដេចកន មានកំណើត ដើមជាទាសករ បានទម្លាក់ចេញពីអំណាច ។ ពេលនោះប្រជាជនទាំងអស់ក៏នាំគ្នាបើកទ្វារទីក្រុង ហើយទះដៃអបអរសាទរអ្នកអង្គម្ចាស់ច័ន្ទ ដែលយាងចូលមកក្នុងទីក្រុងជាមួយនឹងកងទ័ពទាំងអស់ ។ អ្នកអង្គម្ចាស់ ក៏តែងតាំងតាមឿង ឲ្យធ្វើជាចៅហ្វាយខែត្រពោធិសាត់ ហើយទ្រព្យសម្បត្តិទាំងអស់របស់ចៅហ្វាយខែត្រមុន ក៏ត្រូវបានគេយកមកចែករំលែកឲ្យកងទ័ព ។ កូនប្រុសតាមឿងទាំង៤នាក់បានត្រូវតែងតាំងឲ្យដឹកនាំទ័ពជួរមុខមានគ្នា ៨ពាន់នាក់ ហើយទទួលភារកិច្ចទៅវាយដណ្ដើមយកខែត្រក្រគរ ខ្លុង និងក្រាំង ។

នាពេលនោះ ស្ដេចកន ក្រោយពីងូតទឹកពេលថ្ងៃត្រង់រួច បានចេញដើរប្រពាតសួនច្បារជាមួយមេនំមេនាង រួចបាននាំនាងម្នាក់មកក្នុងព្រះរាជដំណាក់ផ្ទុំក្រសាលជាមួយស្ដាប់ភ្លេង និងចម្រៀង ។ ពេលផ្ទុំលង់លក់ទៅទ្រង់សុបិនឃើញថាព្រះរាជវាំងត្រូវភ្លើងឆេះ ទោះជាព្រះអង្គខំរត់គេចយ៉ាងណាក៏មិនផុត ហើយព្រះអង្គ ត្រូវភ្លើងឆេះសុសខ្លួន ។ ភ្ញាក់ពីដំណេកឡើង ស្ដេចកនបានហៅហោរាមកទស្សន៍ទាយ ហើយបានសម្លាប់ហោរាម្នាក់ដោយកំហឹង ព្រោះទស្សន៍ទាយឲ្យមិនល្អ រួចក៏យាងចេញពីព្រះរាជដំណាក់ទៅ ។ ពេលនោះខុកញ៉ាលំពាង នាយច្បារដំណាំ បានទូលដំណឹងអំពីការមកដល់នៃអ្នកនាំសំបុត្ររបស់ចៅហ្វាយខែត្រពោធិសាត់ ។ ស្ដេច កនភ្ញាក់ខ្លួនព្រើតតែមិនឲ្យខាតពេលយូរ បានចេញបញ្ជាឲ្យខុកញ៉ាចក្រីចេញកេណ្ឌទ័ពភ្លាម ដេម្បីទៅទប់ទល់នឹងអ្នកអង្គម្ចាស់ច័ន្ទ ។

ខកញ៉ាចក្រីបានទូលស្តេចកនថា សូមទ្រង់កុំបារម្ភថ្វី ព្រោះថាបើទូលព្រះបង្គំមិនអាចឃាត់ខ្លាបាន ហោចណាស់ក៏ទូលព្រះបង្គំនឹងធ្វើឲ្យវារបួសជាទម្ងន់ដែរ ។ ស្តេចកនពេញចិត្តនឹងសម្តីនេះណាស់ ទ្រង់គិតថា នេះជាប្រផ្នូលល្អ ទើបទ្រង់ប្រទានកូនលំពែងមានចង្កំមាសមួយឲ្យ ។

ខកញ៉ាចក្រីចេញដំណើរទៅកាន់លង្វែកភ្លាមជ្រើសរើសទាហានមួយកង រីឯចៅហ៊្វាកៅ ត្រូវជាមា ស្តេចកន និងជាមេបញ្ជាការធំ ក៏ចេញទៅកំពង់សៀមដែរ កេណ្ឌទ័ពមួយកងទៀត ដើម្បីធ្វើសកម្មភាពរួមគ្នា ។ ស្តេចកនបានប្រទានព្រះសែងអាជ្ញាសឹកឲ្យ ព្រមទាំងថ្វាយមាសមួយថាស សញ្ញាសម្គាល់ឋានៈ និងស្គរជ័យ៤ ។ ពេលប្រមូលទ័ពបាន ចៅហ៊្វាកៅ បានប្រគល់ទ័ពមួយចំនួនឲ្យទៅខកញ៉ាតេជោ ដឹកនាំទៅប្រឈមមុខជាមួយ ទ័ពអ្នកអង្គម្ចាស់ច័ន្ទ ដែលកំពុងតែធ្វើដំណើរមក ។

នៅពេលនោះ ពញាចក្រីប្រមូលទ័ពបាន៤ម៉ឺននាក់នៅក្នុងខែត្រលង្វែក និងខែត្រជិតខាង ហើយបានចេញបញ្ជាឲ្យចៅពញាខទ័យធិរាជចៅហ្វាយខែត្រសំរោងទង និងខកញ៉ារាជាមេត្រីចៅហ្វាយខែត្រចតុម្មុខ រួមគ្នាបង្កើតជាកងទ័ពខាងឆ្វេង ឲ្យពញាវង្សាមេត្រីរៀបចំកងទ័ពខាងស្តាំជាមួយទាហានរើសបានមកពីខែត្របាទី និងឲ្យពញាវិរានុកូល កាន់ទ័ពខាងក្រោយ ទាំងអស់គ្នាដឹកនាំទ័ពទៅកាន់ខែត្រក្រាំង ជាទីកន្លែងដែលអ្នកអង្គម្ចាស់ច័ន្ទគង់នៅ ។

ការប្រយុទ្ធកើតមានឡើងដំបូងរវាងទ័ពតាមឿងជាមួយទ័ពលោកចក្រីរបស់ស្តេចកន ។ ថ្វីបើទ័ពរបស់គាត់មានកម្លាំងតិចជាងទ័ពរបស់សត្រូវក៏ដោយ តែតាមឿងមានទំនុកចិត្តមុតមាំទៅលើទាហានរបស់គាត់ ដែលសុទ្ធតែជាអ្នកស្ម័គ្រចិត្ត ក៏សម្រេចចិត្តប្រយុទ្ធ ។ ការប្រយុទ្ធចាប់ផ្តើមជាដំបូងរវាងទ័ព២ពាន់នាក់ របស់កូនច្បងរបស់ តាមឿង ជាមួយនឹងទ័ពចៅហ្វាយខែត្រសំរោងទង ដែលត្រូវសម្លាប់បានភ្លាម ប៉ុន្តែទ័ពរបស់កូនតាមឿង ត្រូវវាយដកថយទៅរកទ័ពរបស់ឪពុកវិញដែរ ។ ដោយយល់ឃើញថានេះជាជ័យជម្នះមួយ ព្រោះថាចៅហ្វាយ ខែត្រសំរោងទងបានស្លាប់ទៅហើយ ក៏នាំទ័ពចូលទៅក្នុងខែត្រពោធិសាត់វិញ ។ ទ័ពរបស់ចៅហ្វាយខែត្រសំរោងទងរត់ត្រលប់ទៅក្រោយវិញជួបជាមួយទ័ពរបស់ពញាចក្រីក៏នៅជាមួយគ្នានោះទៅ ។ ពញាចក្រី ហៀបតែនឹងបញ្ជាឲ្យទ័ពទាំងអស់ចេញដំណើរដេញតាមទ័ពសត្រូវដែលខ្លួនគិតថាកំពុងតែរត់គេចទៅហើយនោះ ទទួលមានគេប្រាប់ដំណឹងថា ទ័ព៩ម៉ឺននាក់របស់ស្តេចកនបានធ្វើដំណើរមកជិតដល់ជំរំខ្លួនហើយ ក៏ឈប់រង់ចាំសិន ។

មកដល់ភ្លាម ស្តាប់របាយការណ៍រួច ស្តេចកនក៏បែងចែកទ័ពចេញជាច្រើនកងតូចៗ រួចបញ្ជាឲ្យចេញដំណើរដេញតាមទ័ពអ្នកអង្គម្ចាស់ច័ន្ទភ្លាម និងថាឲ្យឡោមព័ទ្ធក្រុងពោធិសាត់ឲ្យជាប់ បើសត្រូវមិនព្រមចុះចូល ទេ ។ ទ័ពស្តេចកនឡោមព័ទ្ធពោធិសាត់ចាប់ពីថ្ងៃខានស្អែកឡើង ហើយទាហានរបស់ស្តេចកនចូលរហូតមកដល់ជើងកំផែងទីក្រុង ស្រែកដេរដៀលត្មះអ្នកស្រុក ។ ការប្រយុទ្ធជាទូទៅក៏ចាប់ផ្តើមឡើង ក៏ប៉ុន្តែអ្នកស្រុកមោះមុតការពារទីក្រុងបានយ៉ាងល្អ ក្រោមបញ្ជារបស់អ្នកអង្គម្ចាស់ច័ន្ទ ធ្វើឲ្យពួកទាហានស្តេចកនត្រូវដកថយចេញឆ្ងាយ

ពីកំផែងបន្តិច ដើម្បីកុំឲ្យរងរបួសដោយសារផ្លែព្រួញ និងដុំថ្មដែលគប់មកពីលើកំពូលកំផែង ។

ស្តេចកន មានទ័ពពេលនោះសរុបទាំងអស់១០ម៉ឺននាក់ ឯអ្នកអង្គម្ចាស់ច័ន្ទមានតែ២ម៉ឺននាក់ប៉ុណ្ណោះ ក៏ប៉ុន្តែ ព្រះអង្គមិនរួញរាឡើយ ។ ទ្រង់បានបែងចែកទ័ពជា២កង កងទី១មាន៩ពាន់នាក់ប្រគល់ឲ្យពញាសួគ៌ាលោកចៅហ្វាយខែត្រពោធិសាត់កាន់ ចំណែកព្រះអង្គកាន់ទ័ព១ម៉ឺននាក់ ពញាមហាសេនាចៅហ្វាយខែត្របរិបូណ៌កាន់ទ័ព ២ពាន់នាក់ដឹកនាំមុខជាទ័ពស្រួច ឯអ្នកអង្គម្ចាស់យសរាជា និងខុកញ៉ាវាំងជាភីលៀងកាន់ទ័ព៣ពាន់នាក់នៅការពារទីក្រុង ។ បែងចែករួច ទ័ពស្រួចចេញដំណើរនៅពេលយប់មកដល់ បន្ទាប់មកកងទី១របស់ពញាសួគ៌ាលោក ចេញវាយទៅលើកងទ័ពរបស់ពញាចក្រី រួចកងទ័ពរបស់អ្នកអង្គម្ចាស់ច័ន្ទចេញវាយទៅលើកងទ័ពស្តេចកន ។ មានរឿងនិទានដែលនិយាយអំពីមូលហេតុធ្វើឲ្យទ័ពស្តេចកនបាក់ចាញ់ គឺមានពួកខ្មោចដែលងើបចេញពីផ្នូរមកស្រែកហ៊ោបន្ទាច ។ តែអ្វីដែលប្រាកដ គឺទ័ពអ្នកអង្គម្ចាស់ច័ន្ទបានបើកការវាយប្រហារទៅលើទ័ព ពួកក្បត់ដោយមិនបានឲ្យដឹងមុន ធ្វើឲ្យពួកនេះបាត់ម្ចាស់ការ រត់បែកខ្ញែកគ្នាមិនដឹងទិសតំបន់ ។ ពញាចក្រី ត្រូវគេសម្លាប់បាន ហើយកាត់ក្បាលយកទៅថ្វាយអ្នកអង្គម្ចាស់ច័ន្ទ អង្គម្ចាស់ច័ន្ទបានបញ្ជាឲ្យយកទៅដោតនឹងបង្គោលរបង ។ ទ័ពឈ្នះប្រមូលបានជ័យភណ្ឌជាច្រើន ។

អ្នកអង្គម្ចាស់ច័ន្ទ បានដឹកនាំទ័ពបន្តដំណើរទៅដល់ក្រគរ ហើយបានបញ្ជាឲ្យសង់បន្ទាយ រើសទ័ពបន្ថែម និងប្រមូលស្បៀងសម្រាប់ផ្គត់ផ្គង់ទ័ព ។ រួចហើយទ្រង់យាងបន្តទៅក្រាំង រហូតដល់ខ្ទង ប៉ុន្តែមិនបានជួបនឹងពួកខ្មាំងទេ ។ ព្រះអង្គបញ្ជាឲ្យសង់បន្ទាយ រើសទ័ពបន្ថែម និងប្រមូលស្បៀងដូចនៅក្រគរទៀត រួចហើយទ្រង់បន្តដំណើរទៅកាន់ខែត្រអម្រិតបុរៈ នៅពេលដែលចៅហ្វាយខែត្រនេះ ជាបក្សពួកស្តេចកនមិនអាចកេណ្ឌទ័ពទប់ទល់នឹងអ្នកអង្គម្ចាស់ច័ន្ទបាន ក៏រត់គេចខ្លួនបាត់ទៅ ។ អ្នកស្រុកបាននាំគ្នាមកអបអរសាទររាក់ទាក់ទទួលអ្នកអង្គម្ចាស់ច័ន្ទ ដោយនាំយកតង្វាយជាច្រើនមកថ្វាយផង រួចនាំគ្នាកសាងបន្ទាយរឹងមាំមួយថ្វាយ ដោយប្រគល់ឲ្យចៅហ្វាយខែត្រម្នាក់ដែលទ្រង់ទើបចាត់តាំងថ្មីនៅរក្សាការពារ ។

មកដល់វាលស្រាបអន្លាម អ្នកអង្គម្ចាស់ច័ន្ទ បានជួបជាមួយទ័ពរបស់ចៅហ៊្វាទល្ហៈ ដែលបាក់ចាញ់ដៃរត់ពីពោធិសាត់មក កំពុងប្រមែប្រមូលគ្នា ។ ទ្រង់បើកការវាយប្រហារទៅលើ ធ្វើឲ្យពួកនេះបាក់បែករត់ខ្ចាត់ខ្ចាយម្តងទៀត ហើយព្រះអង្គដេញតាម សម្លាប់បានចៅហ៊្វាទល្ហៈដោយផ្ទាល់ដៃព្រះអង្គ ។ បន្ទាប់ពីជ័យជម្នះថ្មីនេះ កងទ័ពបន្តដំណើរទៅមុខទៀត ហើយបានមកបោះជំរំសម្រាកនៅខាងកើតរលាប្អៀរ ។ ពេលនោះចៅហ្វាយខែត្រដែលស្តេចកនតែងតាំងគេចរត់បាត់ទៅ ទ្រង់ក៏ជ្រើសរើសមេទ័ពម្នាក់ឲ្យឡើងជំនួសវិញ ។

ពេលនោះ ជ័យជម្នះបានលេចចេញជារូបរាងបន្តិចហើយចំពោះអ្នកអង្គម្ចាស់ច័ន្ទ ធ្វើឲ្យអ្នកស្រុកប្រែមានទំនុកចិត្តមកលើព្រះអង្គវិញ ក៏នាំគ្នាមកស្វាគមន៍ព្រះអង្គច្រើនកុះករ ។ អ្នកស្រុកលង្វែកមកមុនគេ បន្ទាប់មកគឺអ្នកស្រុកជិតខាង នាំយកតង្វាយផ្សេងៗមកជាមួយ ឯពួកប្រុសៗស្ម័គ្រចូលទ័ពបម្រើព្រះអង្គ ។

និយាយពីស្តេចកនវិញ ទ្រង់បានចាត់បញ្ជូនភ្នាក់ងារឲ្យចុះតាមខេត្តនានា ជំរុញឲ្យចៅហ្វាយខេត្តនីមួយៗ ខិតខំប្រឹងប្រែងឡើងក្នុងការជ្រើសរើសទ័ព ។ ការងារនេះបាននាំមកនូវកងទ័ពថ្មីសម្រាប់ស្តេចកនចំនួន ១៧ម៉ឺននាក់ ដែលទ្រង់បែងចែកចេញជា២កង ស្ថិតនៅក្រោមបញ្ជាការរបស់ព្រះអង្គផ្ទាល់ ។ ទ្រង់ប្រគល់រាជធានី ស្រីសន្ធរ ឲ្យបុត្រាព្រះអង្គ និងចៅហ៊្វាំងការពារ រួចក៏ចេញដំណើរមកកាន់ចតុម្មុខ មកបោះជំរំនៅក្រាំងពន្លៃ[៦៥] ។

នៅក្រាំងពន្លៃនោះ ស្តេចកន បានបញ្ជាឲ្យលោក យមរាជ ដឹកនាំទ័ព២ម៉ឺន ៥ពាន់នាក់ មកវាយដណ្តើមយកលង្វែកវិញ ។ ទទួលបានដំណឹងនេះ អ្នកអង្គម្ចាស់ច័ន្ទ បានដឹកនាំទ័ព៤ម៉ឺននាក់មកជួយ ។ ទ្រង់បញ្ជាឲ្យទ័ពលង្វែកចេញវាយមុន ហើយឲ្យធ្វើជាចាញ់ដៃរត់គេចដើម្បីឲ្យសត្រូវដេញតាម រហូតមកដល់កន្លែងមួយដែលព្រះអង្គនៅត្រៀមរង់ចាំ សឹមបែរវាយបកសង្គ្រុបទាំងអស់គ្នាវិញ ។ ប្រតិបត្តិការនេះធ្វើឲ្យទ័ពសត្រូវខាតបង់មេទ័ពអស់ ១១នាក់ និងទាហានប្រហែលជា៥ពាន់នាក់ ហើយអ្នកនៅសល់ធ្លាក់ខ្លួនជាចំណាប់ខ្មាំងរបស់ទ័ពអ្នកអង្គម្ចាស់ច័ន្ទ ។ គេកាត់ក្បាលមេទ័ពទាំង១១នាក់ រួចចាត់ឲ្យមេទ័ពនៅរស់៥នាក់ទៀត ដែលគេកាត់ស្លឹកត្រចៀក នាំយកក្បាលទាំងនោះទៅថ្វាយស្តេចកន ជាមួយនឹងពាក្យផ្តាំផ្ញើថា «បើទ្រង់មានទាហានច្រើនហើយ ចង់បន្តការប្រយុទ្ធ សូមឲ្យឆាប់ចូលមក ។ ក៏ប៉ុន្តែបើសិនជាចង់ផ្អាកសង្គ្រាម ព្រោះថា ជិតដល់រដូវវស្សាហើយ ណាមួយជិតចូលឆ្នាំផង ទុកពេលឲ្យអ្នកស្រុកត្រៀមរៀបចំធ្វើស្រែចម្ការ ត្រូវលើកឡើងតាមតែចិត្តចង់ទៅចុះ» ។

មេទ័ពស្តេចកនទាំង៥នាក់ចេញដំណើរផុត អ្នកអង្គម្ចាស់ច័ន្ទ ក៏នាំទ័ពត្រលប់មករលាប្អៀរវិញ តែទ្រង់បានចាត់សេនាឆ្លាតវៃម្នាក់ឲ្យតាមពិនិត្យមើលសភាពទ័ពសត្រូវបន្តទៀត ។

ស្តេចកនទទួលយល់ព្រមតាមសំណើរបស់អ្នកអង្គម្ចាស់ច័ន្ទ ហើយបានសរសេរសារលិខិតមួយឆ្លើយតបមកវិញ ដោយមានបោះត្រាផង រួចចាត់មន្ត្រី៣នាក់ឲ្យនាំយកសារលិខិតនោះទៅឲ្យគូសត្រូវ ជាមួយនឹងសំពត់សូត្រ ចាក់ជរផ្កាមាស២០ដុំ សំពត់សូត្រពំលេចពណ៌ផ្សេងៗ២០ដុំ និងកម្រាលព្រំ២ផង ។

លិខិតនោះមានខ្លឹមសារដូចតទៅ ៖ «យើង សម្តេចព្រះស្រីជេដ្ឋាធិរាជរាមាធិបតីបរមបពិត្រ ស្តេចក្រុងកម្ពុជាធិបតីសិរីសោធនបវរឥន្ទបត្ត យើងដែលប្រជានុរាស្ត្រ និងរាជវង្សានុវង្សបានស្នើសុំឲ្យឡើងសោយរាជ្យលើរាជបល្ល័ង្កក្រុងស្រឡប់ពិជ័យនគរខាងកើត សូមទូលថ្វាយព្រះអនុជាធិរាជចៅពញាច័ន្ទរាជាទ្រង់ជ្រាបថា យើងរីករាយណាស់នឹងឃើញអ្នកដឹកនាំទ័ពមកប្រយុទ្ធជាមួយនឹងយើង ប៉ុន្តែដោយរដូវវស្សាជិតចូលមកដល់ហើយ យើងត្រូវទុកពេលឲ្យអ្នកស្រុកបង្កបង្កើនផលសិន ដូច្នេះសូមផ្អាកកិច្ចប្រតិបត្តិការសង្គ្រាមមួយអន្លើក្នុងរដូវនេះ ។ យើងយល់ព្រមតាមសំណើរបស់អ្នក តែមានលក្ខ័ណ្ឌថាយើងទាំងសងខាងមិនត្រូវឆ្លៀតឱកាសនេះ ដើម្បីលួចដណ្តើមយកអាណាខេត្តរបស់ម្ខាងទៀត បីដូចជាចោរខ្មោញនោះទេ ។ ការប្រយុទ្ធនឹងចាប់ផ្តើមឡើងវិញ

[៦៥] ជាស្ទឹងមួយនៅលើច្រាំងខាងស្តាំទន្លេសាប ហូរចាក់មកក្នុងទន្លេនេះនៅត្រង់ខាងលើកំពង់ហ្លួងបន្តិច ។

តែពេលណាមានការប្រកាសសង្គ្រាមពិប្រាកដ ។ ធ្វើយ៉ាងនេះទើបត្រឹមត្រូវ សមជាស្តេចផែនដី» ។

អ្នកអង្គម្ចាស់ច័ន្ទទ្រង់ខ្វល់ខ្វាំងណាស់នឹង ស្តេចកន ជាអតីតខ្ញុំម្នាក់ ដែលហៅព្រះអង្គថាអនុជដូច្នេះ ។ ទ្រង់ក៏មានព្រះបន្ទូលទៅកាន់អ្នកនាំសាររបស់ស្តេចកនថា ៖ «យើងទទួលយល់ព្រមតាមលក្ខណ្ឌរបស់ នាយកន ប៉ុន្តែ អ្នកត្រូវប្រាប់ទៅគេវិញថា យើងមិនពេញចិត្តនឹងឲ្យមនុស្សដែលមានដើមកំណើតឆ្ងាយដាច់ស្រឡះពីយើង មកចាត់ទុកយើងជាអនុជនោះទេ» រួចហើយទ្រង់ចែករង្វាន់ជាមាស និងប្រាក់ខ្លះដែលព្រះអង្គបានយកពីស្រុកសៀមមកឲ្យអ្នកទាំងនោះ រួចក៏ដេញឲ្យត្រលប់ទៅវិញ ។

ពេលនោះ កងទ័ពរបស់អ្នកអង្គម្ចាស់ច័ន្ទមិនពេញចិត្តនឹងការផ្អាកការប្រយុទ្ធទេ ។ ពួកមេទ័ពនាំគ្នានិយាយថា «តើធ្វើសង្គ្រាមដូចម្តេច ពេលដែលយើងកំពុងតែមានជោគជ័យ ព្រះអង្គបែរទៅជាផ្អាកប្រតិបត្តិការ ទុកឲ្យសត្រូវនៅរក្សាកាន់កាប់អាណាខែត្រមួយចំនួន ដែលយើងអាចនឹងដណ្តើមយកបានទៅវិញ» ។ ពួកគេនាំគ្នាចូលគាល់អ្នកអង្គម្ចាស់ច័ន្ទ ហើយទូលព្រះអង្គថា «នាយកនមានខែត្រច្រើនជាងយើង១០ដង បើចាប់រើសទ័ពនៅក្នុងបណ្តាខែត្រចំណុះទាំងអស់នោះ ចាប់ពីមាត់សមុទ្រនៅខាងត្បូង ទៅដល់ស្រុកលាវនៅខាងជើង រហូតទៅដល់ព្រំប្រទល់ជាមួយនគរចាម្ប៉ា នឹងបានទាហានដល់ទៅរាប់រយពាន់នាក់ ។ ចំណែកខាងយើងវិញ យើងមានខែត្រតែ ៦-៧ ប៉ុណ្ណោះ ។ ព្រះអង្គជ្រាបស្រាប់ហើយ ថាយើងបានជ្រើសរើសទ័ពច្រើនណាស់ ពីក្នុងខែត្រទាំង៦-៧នេះ ដែលធ្លាប់រងគ្រោះជាដំណំដោយសារសង្គ្រាម ហើយខែត្របាត់ដំបងបានខាតបង់ប្រជាជន ជាច្រើនដោយសារសៀមកៀរយកទៅ» ។ អ្នកអង្គម្ចាស់ច័ន្ទ មានព្រះបន្ទូលតបទៅវិញថា កងទ័ពរបស់យើងនឿយហត់ខ្លាំងណាស់ទៅហើយមិនអាចបន្តការប្រយុទ្ធតទៅទៀតក្នុងពេលនេះបានទេ ព្រះអង្គចង់រើសទ័ពបន្ថែមទៀតសិន ។ ព្រះអង្គចរចាជាមួយស្តេចកនដូច្នេះ ពីព្រោះព្រះអង្គមិនចង់ប្រយុទ្ធជាមួយទ័ពមកពីខែត្រកំពង់ស្វាយ ដែលមានពាក់សុទ្ធតែអាវក្រោះដែកដែលទ័ពយើងគ្មាន ណាមួយទ័ពសត្រូវមានការចាត់តាំងច្បាស់លាស់ជាទ័ពព្រះរាជា មានកូស់ ទង់ជ័យ និងភ្លេងភ្លាត់ល្អជាងទ័ពយើង ។ ព្រះអង្គជារាជវង្ស បានជានិយាយរួចទៅហើយ មិនអាចលេបសម្តីវិញបានទេ ។

មានព្រះបន្ទូលរួច អ្នកអង្គម្ចាស់ច័ន្ទ ធ្វើការណែនាំដល់ចៅហ្វាយខែត្រទាំងអស់ដែលប្រមូលបានមកវិញ រួចទ្រង់ដឹកនាំទ័ពចូលទៅក្រុងបរិបូណ៌ទៅ ។ ចំណែកឯស្តេចកនវិញ ទ្រង់ក៏បានវិលត្រលប់ទៅកាន់ ស្រីសន្ធរ ជារាជធានីរាជាណាចក្រខាងកើត ហើយគង់នៅស្ងប់សៀមដែរ ។

មុននឹងមានការផ្អាកការប្រយុទ្ធគ្នានេះ ពេលទទួលដំណឹងថាចៅហ្វាយខែត្រកំពង់ស្វាយរៀបចំចេញដំណើរមកវាយយកក្រគរ ទ្រង់បានដឹកនាំទ័ពចេញវាយប្រហារមុន សម្លាប់ចៅហ្វាយខែត្រនោះបាន ព្រមទាំងដណ្តើមយកបានខែត្រសន្ទុក ស្ទឹងត្រង់ កំពង់សៀម បារាយណ៍ ជើងព្រៃ[៦៦] និងខែត្រមួយចំនួនទៀត រួចបាន

[៦៦] យើងបានឃើញពីខាងលើរួចមកហើយថា បណ្តាខែត្រទាំងអស់នេះស្ថិតនៅចន្លោះទន្លេសាប និងទន្លេមេគង្គ មានរយៈទទឹងជា

ប្រគល់ឲ្យនាយទាហានរបស់ព្រះអង្គគ្រប់គ្រងកាន់កាប់ ។ ប្រតិបត្តិការនេះកើតមានឡើងក្នុងពេលកំពុងចរចាគ្នាម្ល៉ោះហើយ ស្តេចកន បានចោទប្រកាន់ថាគឺជាការបំពានលើកិច្ចសន្យា ។ ប៉ុន្តែអ្នកអង្គម្ចាស់ច័ន្ទ អះអាងថា រឿងវាកើតមានក្នុងអំឡុងពេលកំពុងចរចា មុនមានកិច្ចព្រមព្រៀង ដូច្នេះមិនខុសទេ ។

## ១៨- ព្រះច័ន្ទរាជា (១៥១៦-១៥៥៥)

នៅក្នុងពេលដែលមានការផ្អាកការប្រយុទ្ធគ្នានោះ នាយទាហានទាំងឡាយរួមជាមួយព្រះរាជវង្សានុវង្សផង បានឯកភាពគ្នាស្នើសុំឲ្យអ្នកអង្គម្ចាស់ច័ន្ទឡើងសោយរាជ្យជាព្រះរាជានៃព្រះរាជាណាចក្រកម្ពុជា ។ ព្រះអង្គបានយល់ព្រមទទួលតាម ក៏ប៉ុន្តែទ្រង់បានសម្រេចព្រះទ័យថាទ្រង់នឹងទទួលយកការអភិសេកលុះណាតែទ្រង់ដណ្តើមបានជ័យជម្នះលើនាយកនក្បត់រួចសិន ។ គេបានរៀបចំសង់ព្រះពន្លាផ្សេងៗសម្រាប់ធ្វើការប្រកាសតែងតាំងព្រះរាជានេះ រួមមានព្រះរាជបល្ល័ង្កបាំងទៅដោយក្ងស់រួត៥ជាន់ ព្រះអង្គបានឲ្យសង់៥ជាន់សិន (មិនទាន់ទទួលយកក្ងស់៩ជាន់ភ្លាមទេ) , គ្រឿងប្រដាប់បំពាក់ឲ្យសេះដែលអូសព្រះរាជរថ, គ្រឿងប្រដាប់បំពាក់ឲ្យដំរីពេលយាងចេញធ្វើសង្គ្រាម, គ្រឿងប្រដាប់បំពាក់ឲ្យសេះចម្បាំង និងគ្រឿងប្រដាប់លម្អព្រះរាជទីនាំងនាវា ។

អ្នកអង្គម្ចាស់ច័ន្ទ បានឡើងគង់លើរាជបល្ល័ង្កបាំងដោយក្ងស់នៅក្នុងគ្រិស្តសករាជ១៥១៦ ត្រូវនឹងមហាសករាជ១៤៣៨, ចុល្លសករាជ៨៧៨ គឺថ្ងៃច័ន្ទ ១៥រោជ ខែផល្គុន ឆ្នាំជូត អដ្ឋស័ក ដោយទ្រង់ទទួលព្រះឋានៈជាព្រះរាជាមិនទាន់អភិសេក ថាសម្តេចព្រះបរមនាថច័ន្ទរាជាធិរាជ ស្រីជ័យចេស្តា មហាក្រសត្រ អង្គម្ចាស់ក្រុងកម្ពុជា ។ នៅក្នុងពេលប្រកាសនោះ ពួកព្រាហ្មណ៍បុរោហិតបានផ្លុំស័ង្ខ និងមានការប្រគំភ្លេងគងរំពងហើយមានប្រជារាស្ត្រធ្វើដំណើរពីគ្រប់ខេត្រខ័ណ្ឌមូលមីរ មកសំដែងការអបអរសាទរ ។

ព្រះរាជាបានតែងតាំងរដ្ឋមន្ត្រី សេនាបតី ព្រះសង្ឃរាជនៃព្រះវិហារពុទ្ធសាសនាទាំង៧ នាយក្រុម ព្រះរាជវង្សានុវង្ស២អង្គ ព្រះឥសីផាត ជាមេក្រុមបារគូទទួលបន្ទុកថែរក្សាអាវុធស័ក្តិសិទ្ធិ និងរៀបចំពិធីតាមព្រហ្មញ្ញសាសនាផ្សេងៗ នាម៉ឺនតូចធំ អាស្រ័យទៅតាមគុណូបការៈដែលពួកគេបានបំពេញកន្លងមក ។ គេបាននិយាយថាព្រះរាជាក៏បានចាត់ឲ្យគេសាងសង់វត្តមួយ នៅនឹងកន្លែងដែលគេលើកឲ្យព្រះអង្គសោយរាជ្យនោះ ។ គឺនៅពេលនោះហើយ ដែលទីរួមខេត្រអម្រិតបុរៈ បានដូរឈ្មោះមកជា បរិបូណ៌ វិញ រហូតមកដល់សព្វថ្ងៃនេះ[៦៧] ។

---

មួយនឹងលផ្នែកដែរ ។ នេះគឺជាចំណុចខាងត្បូងបំផុត នៃទឹកដីដែលយើងហៅពីមុនថា មធ្យទេសៈ មានន័យថា ស្រុកកណ្តាលប្រទេស ។

[៦៧] គេហៅដូច្នេះមកពីទីនោះដីស្រែមានជីជាតិខ្លាំងណាស់ ក្រោយពីព្រះរាជាបានបញ្ជាឲ្យទាហានបង្វែរផ្លូវទឹកស្ទឹងឲ្យហូរកាត់ដោយលើកទំនប់មួយ ។

ក្នុងអំឡុងពេលនោះ ស្តេចកនបានរៀបចំជ្រើសរើសកងទ័ពនៅតាមបណ្តាខេត្ត ដែលស្ថិតនៅក្រោមអំណាចរបស់ព្រះអង្គ ហើយបានប្រមូលយកមកដាក់នៅស្រីសន្ធរ នៅចុងឆ្នាំ១៥១៦ ។

ភាពប្រទូសរ៉ាយរវាងគ្នានឹងគ្នាចាប់កើតមានឡើងវិញជាដំបូង ដោយសារទ័ពពួកបះបោរនៅសំរោងទងបានចេញមកកេណ្ឌប្រជាជនប្រមាណជា១០០គ្រួសារនៅក្នុងខេត្តលង្វែក ។ ពេលទទួលបានដំណឹងនេះព្រះពញាច័ន្ទរាជា បានបញ្ជាឲ្យខកញ៉ាចក្រីដឹកនាំទ័ព១ម៉ឺននាក់ ទៅប្រដៅពួកនោះ ។ ខកញ៉ាចក្រីបានវាយពួកនេះឲ្យបរាជ័យ រួចដេញតាមវាយរហូតទៅខាងត្បូង ដណ្តើមបានខេត្តបាទី ព្រៃកប្បាស ទ្រាំង រួចទើបវិលត្រលប់មកចតុម្មុខវិញ ។

ចូលមកក្នុងឆ្នាំ១៥១៧ មានការប្រយុទ្ធជាច្រើន ក៏ប៉ុន្តែការប្រយុទ្ធទាំងអស់នោះមិនបានធ្វើឲ្យមានការប្រែប្រួលអ្វីដល់ស្ថានភាពរបស់គូប្រឆាំងទាំង២ប៉ុន្មានទេ ។ ការប្រយុទ្ធបានត្រូវបញ្ឈប់ទាំងស្រុងនៅដើមឆ្នាំថ្មីរួចបានចាប់ផ្តើមវិញយ៉ាងខ្លាំងក្លានៅពេលចប់រដូវវស្សា ។ ទ័ពព្រះរាជាបានទទួលជោគជ័យជាស្ថាពរលើទ័ពស្តេចកននៅក្នុងខែមាឃធំ ជាខែទី៣នៃឆ្នាំ ហើយមិនគ្រាន់តែដណ្តើមយកបានខេត្តទ្រាំងប៉ុណ្ណោះទេ គឺថែមទាំងដណ្តើមយកបានខេត្តកំពត និងកំពង់សោមទៀតផង ។ ប៉ុន្តែការដណ្តើមយកខេត្តបាសាក់ និងព្រះត្រពាំង ត្រូវបរាជ័យ ។

គឺនៅពេលនោះឯងដែលស្តេចកនលើកគម្រោងការលួចធ្វើឃាតព្រះច័ន្ទរាជា ដូចដែលខ្លួនធ្លាប់បានធ្វើចំពោះព្រះរាជាមុនរួចមកហើយ ។ ស្តេចកនបានជ្រើសរើសទាហានស្ម័គ្រចិត្ត១០០នាក់ ដោយទ្រង់បានសន្យាថានឹងលើកពួកគេឲ្យធ្វើជាចៅហ្វាយខេត្តលើខេត្តណាដែលដណ្តើមយកបានពីព្រះរាជា នៅពេលណាដែលពួកគេសម្លាប់ព្រះអង្គបាន ។ ពួកទាហានទាំងនោះបានធ្វើជានាំគ្នារត់មកសុំជ្រកកោនជាមួយកងទ័ពព្រះរាជា ហាក់បីដូចជាគេក្បត់នឹងមេគេមុនអ៊ីចឹង ។ ព្រះច័ន្ទរាជា ទទួលយកពួកនោះដោយបីតិសោមនស្ស និងមានការទុកចិត្តជាខ្លាំងហើយបានឲ្យដាក់បញ្ចូលពួកនោះទៅក្នុងកងរក្សាព្រះអង្គ ។ ថ្ងៃមួយព្រះរាជាបានចុះស្រង់ទឹកក្នុងស្ទឹងបរិបូណ៌ដោយបានហៅឲ្យទាហានទាំងអស់ចុះងូតទឹកជាមួយព្រះអង្គដែរ ។ ពលទាហានទាំងអស់បានអនុវត្តតាមព្រះរាជបញ្ជាលើកលែងតែពួកចុះចូលថ្មី១០០នាក់មិនបានចុះងូតនឹងគេទេ ព្រោះមានកាំបិតស្នៀតលាក់ទុកនៅនឹងភ្លៅក៏មានការរំដើបរំជួលក្នុងចិត្តជាខ្លាំង ។ ព្រះរាជាដែលពិនិត្យមើលឃើញហេតុការណ៍នេះ ក៏បញ្ជាឲ្យពួកនោះស្រាតសម្លៀកបំពាក់ចេញ ។ ពួកនោះគិតថាផែនការរបស់ពួកគេនឹងត្រូវបរាជ័យ បើសិនណាជាគេមិនចាប់អនុវត្តភ្លាមទេ ក៏នាំគ្នាខិតមកជិតព្រះរាជាគិតថា នឹងចាប់ធ្វើការវាយប្រហារមកលើព្រះអង្គភ្លាមតែម្តង ។ ព្រះរាជាក៏ចាប់ផ្តើមលែងទុកចិត្តលើពួកនោះ បានរៀបចំប្រុងប្រៀបការពារខ្លួនព្រះអង្គ ដោយស្រែកហៅកងការពារឲ្យចូលមកជួយ រួចទ្រង់រត់ទៅយកដាវដែលព្រះអង្គព្យួរនៅនឹងដើមឈើមួយ ។ ទ្រង់បានលើកអាវុធត្រៀមការពារខ្លួនព្រះអង្គ រួចកាប់ទាំងដាវជាប់នៅក្នុងស្រោមទៅលើជនក្បត់ម្នាក់ដែលចូលមកជិតព្រះអង្គជាងគេ ។ ព្រះរាជ

កាយវិការនេះ បានធ្វើឲ្យវាអាក់សកម្មភាពបន្តិចដែរ ព្រមជាមួយពេលដែលស្រោមដាវត្រូវរបូតចេញទៅ ។ អាក្សត់នោះ ពេលពិនិត្យឃើញថាមានតែខ្លួនម្នាក់ឯងនៅចំពោះមុខព្រះរាជា មិនបានចាប់អារម្មណ៍ថា ពួកខ្លួនឯទៀត កំពុងតែជាប់ដៃជាមួយកងរក្សាព្រះអង្គទេ ក៏កើតមានការតក់ស្លុតជាខ្លាំង ហើយបើកមាត់ស្រែកហៅគ្នាឲ្យចូលមកជួយ រួចក៏ត្រូវព្រះរាជាចាក់មួយដាវចូលក្នុងមាត់ស្លាប់ទៅ ។ ក្នុងពួកក្បត់១០០នាក់នោះ មាន១០នាក់ដែលត្រូវបានគេសម្លាប់នៅនឹងកន្លែង ៨នាក់ត្រូវចាប់បានទាំងរស់ សេសសល់ប៉ុន្មានបានគេចរត់រួចទៅរកទ័ពស្តេចកនវិញ ។ ចំណែកខាងទ័ពព្រះរាជា មានទាហាន១៥នាក់រងរបួស និងស្លាប់ម្នាក់ ។ ខ្មាំងដែលចាប់រស់ទាំង៨នាក់បានត្រូវគេសម្លាប់ដោយកាត់ក្បាល ។

នៅចុងឆ្នាំនោះ ព្រះរាជាបានលើកស្នំឯកជាព្រះជាយា ហើយក៏បានប្រគល់ឋានៈផ្សេងៗ ទៅឲ្យពួកមេនំមេនាង ទៅតាមឋានៈរបស់គេផងដែរ ។

នៅខែមិគសិរឆ្នាំ១៥១៩ ស្តេចកនដែលអ្នកប្រវត្តិវិទូខ្មែរហៅថាជាព្រះរាជានៃព្រះរាជាណាចក្រទិសខាងកើត បានមកបង្ហាញខ្លួនព្រះអង្គនៅក្នុងខែត្រកំពង់សៀម ជាមួយកងទ័ព៨ម៉ឺននាក់ ដែលមកទាំងតាមផ្លូវគោកផង និងផ្លូវទឹកផង ។ ព្រះច័ន្ទរាជា បានបញ្ជូនព្រះរាជបរិពារទាំងអស់ឲ្យទៅនៅឯរាជវាំង ខែត្រពោធិសាត់ រួចព្រះអង្គដឹកនាំទ័ពមានចំនួនប្រហាក់ប្រហែលគ្នាឆ្លងទន្លេ ចេញទៅធ្វើសង្គ្រាមនៅភូមិភាគបូព៌ាតែម្តង ។ ដោយមានការយឺតយ៉ាវបន្តិចក្នុងការឆ្លងទន្លេ ខែត្រកំពង់សៀមបានធ្លាក់ចូលទៅក្នុងដៃរបស់ ស្តេចកន មួយថ្ងៃមុនព្រះអង្គយាងទៅដល់ ក៏ប៉ុន្តែព្រះអង្គមិនមានញញើតទេ ទ្រង់បានបន្តដំណើរចូលទៅបើកការវាយប្រហារលើទ័ព ស្តេចកន ធ្វើឲ្យពួកនេះបរាជ័យទាំងស្រុង រកតែរត់ចុះទូកទៅវិញក៏មិនទាន់ផង ។ ព្រះអង្គចាប់បានទាហានខ្មាំងជាច្រើននាក់ជាឈ្លើយ ។ ប៉ុន្មានថ្ងៃបន្ទាប់មក ស្តេចកនបានបញ្ជូនទ័ពមួយកងទៀត ឲ្យមកវាយដណ្តើមយកកំពង់សៀមវិញ ក៏ត្រូវបរាជ័យទៀត ប៉ុន្តែនៅអាចរក្សាទីតាំងបាននៅឡើយ ។

ក្រោយពីបរាជ័យផ្ទួនៗនេះមក ស្តេចកន បានសម្រេចចិត្តថាត្រូវធ្វើការចរចាជាមួយចៅពញាច័ន្ទរាជាវិញ ទើបទ្រង់សរសេររាជសារមួយ ឲ្យនាម៉ឺនម្នាក់នាំយកមកថ្វាយព្រះច័ន្ទរាជា ។ នាម៉ឺននោះបានមកចុះទូកនៅត្រង់ខាងក្រោមកំពង់សៀមបន្តិច ជួបនឹងពួកទាហានកំពុងដើរយាមល្បាត ក៏ត្រូវពួកនោះចាប់យកមកថ្វាយព្រះរាជា ។ ព្រះអង្គខ្ញាល់នឹងទាហានរបស់ព្រះអង្គណាស់ ដែលអនុវត្តផ្ទុយនឹងច្បាប់សង្គ្រាម ធ្វើទុក្ខធ្វើទោសទូតរបស់សត្រូវ បណ្តាលឲ្យធ្លាក់សារនោះជាមួយនឹងក្លងមាស ទៅក្នុងទឹកស្ទឹងបាត់ ។ ទ្រង់បានឲ្យគេធ្វើទារុណកម្មនាយទាហានដែលប្រព្រឹត្តខុសដោយវាយ២៥រំពាត់ផ្តៅ រួចដាក់ឃ្នាងក ។ បន្ទាប់មក ព្រះអង្គបានបញ្ជាឲ្យអ្នកនាំសាររបស់ ស្តេចកន សូត្រសេចក្តីសំបុត្រដែលខ្លួនបានទន្ទេញចាំរត់មាត់ថ្វាយព្រះអង្គសណ្តាប់ ។

ក្នុងសេចក្តីនៃសារលិខិតនោះ ស្តេចកនប្រកាសស្នើសុំសន្តិភាពជាមួយព្រះអង្គច័ន្ទរាជា ដោយបែងចែកទឹកដីគ្នា ដែលម្នាក់ៗមានធំសមគួរណាស់ទៅហើយ ។ ព្រះរាជាបានឆ្លើយតបទៅអ្នកនាំសារវិញថា ព្រះរាជាណាចក្រ

ទាំងមូលជាគេ្គីងណែល ដែលបុព្វបុរសព្រះអង្គបានបន្សល់ទុកមកឲ្យព្រះអង្គ ដែលជាបច្ចាញាតិរបស់ព្រះរាជាពីបុរាណតរៀងមក ហើយខ្លួនព្រះអង្គនេះទៀតសោតក៏ជាម្ចាស់របស់ស្តេចកនជាចោរក្បត់ ហើយបែរជាចង់មកសុំចែកទឹកដីជាមួយព្រះអង្គទៅវិញ ។ ព្រះអង្គមានព្រះបន្ទូលបន្ថែមប្រាប់ទៅអ្នកនាំសារនោះថា “បើសិនជាចៅហ្វាយរបស់អ្នកឯងចង់បញ្ឈប់សង្គ្រាម ត្រូវឲ្យគេដកថយចេញទៅ នោះយើងក៏នឹងដកថយចេញដែរ” ។

ស្តេចកន នៅពេលទទួលចម្លើយនេះ ទ្រង់មានព្រះបន្ទូលថា កាលពីចរចាគ្នាលើកមុន ចៅពញាច័ន្ទរាជាបានប្រព្រឹត្តបំពានដណ្តើមយកអាណាខែត្រខាងលិចអស់មួយចំនួនដូច្នេះមិនអាចទុកចិត្តបានទេ ។ ទ្រង់បានរៀបចំដាក់ពង្រាយកងទ័ពតាមព្រំប្រទល់ខែត្រដែលទ្រង់ចង់រក្សាទុក រួចហើយក៏យាងត្រលប់ចូលទៅក្នុងរាជវាំងនៅឯក្រុងស្រឡប់ព្រៃនគរវិញទៅ ។ ចំណែក ព្រះច័ន្ទរាជា វិញ បានយាងត្រលប់មកបរិបូណ៌ រួចយាងបង្ហួសទៅពោធិសាត់ ជាទីកន្លែងដែលព្រះរាជបរិពារទាំងអស់ស្ថិតនៅក្នុងអំឡុងពេលនៃការប្រយុទ្ធ ។ ទ្រង់បានចាត់ឲ្យគេសាងសង់ដំណាក់មួយប្រក់ស្បូវ មានសាលសវនាការនៅខាងក្នុងផង និងនៅខាងក្រៅផង ។

ពេលនោះជាពេលចូលឆ្នាំថ្មី រាជវាំងទាំង២ គឺខាងលិច និងខាងកើត បានរៀបចំពិធីបុណ្យចូលឆ្នាំដូចគ្នា ។ ពេលនោះខុកញ៉ាចក្រីខាងព្រះច័ន្ទរាជាមានគំនិតចង់លួចធ្វើឃាតស្តេចកន ក៏ជ្រើសរើសបានទាហាន ៤នាក់ ស្ម័គ្រចិត្តចូលទៅក្រុងស្រឡប់ព្រៃនគរ ដើម្បីលួចធ្វើឃាតស្តេចកន ។ ប្រតិបត្តិការនេះបរាជ័យ ទាហាន ២នាក់ត្រូវគេចាប់សម្លាប់ចោល ។ រឿងនេះដឹងដល់ព្រះរាជា ទ្រង់ខ្វល់ជាខ្លាំង ។ ព្រះអង្គបានព្រមានខុកញ៉ាចក្រី ដែលប្រព្រឹត្តថោកទាបដូច្នេះ ហើយបានចាត់ទុកខុកញ៉ានោះថាជា “ចោរសង្គ្រាម” ។

ចាប់ពីពេលនោះមក ទ័ពព្រះរាជាកើនចំនួនរាល់ខែ ។ ពេលចូលឆ្នាំថ្មីម្តងៗ គេឃើញទ័ពព្រះអង្គមាននាយទាហានថ្មីៗរហូត ។ ចំនួនដំរីក៏កើនឡើងដែរ ព្រោះពេលចេញទាក់ម្តងៗ ដែលជួនកាលព្រះរាជាយាងចូលរួមដោយផ្ទាល់ព្រះអង្គ គេទាក់បានដំរីពី២០ ទៅ៣០ក្បាលយកមកផ្សាំងបង្រៀនសម្រាប់ចេញធ្វើសង្គ្រាម ។ ទ្រង់បានតែងតាំងអ្នកណាដែលធ្លាប់បានបួសរៀននៅក្នុងវត្តអារាមហើយបានប្រលងជាប់ ឲ្យធ្វើជាក្រមស្រុក, ជាក្រមការស្រុក និងជាសុភា (ចៅក្រម) ។

នៅក្នុងឆ្នាំ១៥២៧ ព្រះអង្គបានចាត់ឲ្យពួកសង្គ្រាយ គឺពួកអ្នកថែរក្សាទំនៀមទម្លាប់ ប្រមូលពួកអ្នកធ្លាប់បានបួសរៀនទាំងអស់ដែលត្រូវចូលបម្រើក្នុងកិច្ចការរាជការ ឲ្យមកជួបជុំគ្នានៅបរិបូណ៌ ធ្វើការប្រលងប្រជែងអំពីចំណេះភាសាបាលី និងការបកប្រែ ។ អ្នកណាដែលបានប្រលងជាប់នៅពេលនោះត្រូវបានព្រះអង្គចាត់តាំងឲ្យទទួលធ្វើការងារសាធារណៈភ្លាម សមស្របទៅតាមសមត្ថភាពរបស់គេម្នាក់ៗ ។ មានបង្កើតក្រុមល្ខោន មានតួស្រីប្រុសពូកែល្បីខាងច្រៀងរាំ ដើម្បីធ្វើឲ្យរាជវាំងមានពន្លឺរស្មីដូចកាលពីអតីតកាល ។

និយាយអំពីស្តេចកនវិញ កាន់តែងប់ងុលនឹងការសប្បាយ ភ្លេចអស់ផលប្រយោជន៍ប្រទេសដែលព្រះអង្គដឹកនាំ ព្រមទាំងកិច្ចការយុត្តិធម៌ផង ។ ព្រះអាកប្បកិរិយានេះបានធ្វើឲ្យមន្ត្រីជាច្រើនដែលធ្លាប់តែដើរតាមព្រះអង្គ

មានការខកចិត្តជាខ្លាំង ម្យ៉ាងទៀតក្រមព្រហ្មទណ្ឌថ្មីដែលទ្រង់បានឲ្យកែប្រែដើម្បីទាក់ទាញចិត្ត ប្រជារាស្ត្រក៏មានការប៉ះពាល់ដល់ពួកមន្ត្រី និងអ្នកស្មោះត្រង់ល្អដែរ ។ ចៅក្រមកាត់សេចក្ដីបានតែត្រឹមឲ្យបង់ពិន័យ ហើយសំណងនៃការខូចខាតបានត្រឹមតែ ១ភាគ៣នៃច្បាប់ពីមុនប៉ុណ្ណោះ ។

ព្រះច័ន្ទរាជា បានប្រមាថស្ដេចកន ដោយមានព្រះបន្ទូលថា “នាយកនជាមនុស្សទុច្ចរិត ម៉្លោះហើយតែងអនុគ្រោះឲ្យជនទុច្ចរិតដូចគ្នា” ។ ដើម្បីរៀបចំសណ្ដាប់ធ្នាប់ឡើងវិញ និងដាក់ទោសដល់ពួកចោរ ដែលមានចំនួនកាន់តែច្រើនឡើងៗក្នុងពេលស្រុកកំពុងវឹកវរ ទ្រង់បានសម្រេចឲ្យគេបង្កើនពន្ធដារមួយភាគបីឡើងវិញ ។

នៅសម័យនោះ នៅខែត្រស្រីសន្ធរមានមន្ត្រីថ្នាក់ទាបម្នាក់ឈ្មោះ ចៅហ្លួងឥន្ទកុមារ បានយកក្មួយស្រីម្នាក់មកចិញ្ចឹមទុកដូចជាកូនបង្កើត ។ ពេលក្មួយស្រីនោះធំចម្រើនពេញវ័យហើយ គាត់ក៏រៀបចំទុកដាក់នាងធ្វើជាភរិយាបុរសម្នាក់ឈ្មោះ កំពេជ្រ សមស្រមតាមទំនៀមទម្លាប់ប្រពៃណីព្រះរាជាណាចក្រ ។ ការបាន ១ឆ្នាំ នាយកំពេជ្រនេះប្រទូស្ដប្រពន្ធខ្លួនជាមួយនឹងខ្ញុំស្រីអ្នកបម្រើរបស់ប្រពន្ធខ្លួនម្នាក់ រួចក៏នាំខ្ញុំស្រីនោះរត់ទៅ ។ ចៅហ្លួង ឥន្ទកុមារ ជាឪពុកក្មេកបានដេញតាមចាប់នាយកំពេជ្រ រហូតមកដល់កំពង់លង្វែក ប៉ុន្តែមិនបាននាំយកទៅព្រះរាជាណាចក្រខាងកើតវិញដើម្បីធ្វើការជំនុំជម្រះទេ បែរជានាំចូលមកជួបចៅហ្វាយខែត្រលាវៀរ ដាក់បណ្ដឹងឲ្យរកយុត្តិធម៌ឲ្យវិញ ។ ពេលសវនាការ នាយកំពេជ្រឆ្លើយថា ឪពុកមាក្មេកនេះតាមមកចាប់ខ្លួនមិនមែន ដើម្បីនាំឲ្យទៅជួបជុំជាមួយភរិយាវិញទេ ប៉ុន្តែដើម្បីឃាត់ឃាំងមិនឲ្យខ្លួន ដែលមកដល់ព្រះរាជាណាចក្រខាងលិចទៅហើយ បានចូលបម្រើព្រះច័ន្ទរាជា ។ ក្រោយពីបានស្ដាប់ចម្លើយនេះហើយ ចៅក្រមក៏ជឿ ហើយកាត់សេចក្ដីឲ្យចៅហ្លួង ឥន្ទកុមារ ចាញ់ក្ដីទៅ ។ ចៅហ្លួងមិនសុខចិត្ត ក៏ប្ដឹងឡើងឧទ្ធរណ៍ ចៅក្រមបានបញ្ជូនសំណុំរឿងទាំងអស់ទៅសាលាឧទ្ធរណ៍ទៀត ។ ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ ចៅក្រមសាលាឧទ្ធរណ៍មិនដឹងជាកាត់សេចក្ដីយ៉ាងណាក៏យកសំណុំរឿងនេះទៅទូលព្រះរាជា ។ ព្រះរាជាពិនិត្យមើលសំណុំរឿងយ៉ាងល្អិតល្អន់ រួចមានព្រះបន្ទូលថា នាយកំពេជ្រមិនគ្រាន់តែមានកំហុសបោះបង់ចោលភរិយាប៉ុណ្ណោះទេ តែនៅមានកំហុសដោយបានលួចយកខ្ញុំបម្រើរបស់ភរិយាខ្លួនថែមទៀត ដូច្នេះត្រូវទទួលទោសតាមកំហុសក្រោយនេះ ។ ពេលនោះ ពួកចៅក្រមបានប្រកែកមិនព្រមប្រកាសសាលក្រមតាមយោបល់ព្រះរាជាទេ ព្រោះថាខ្ញុំនោះជាខ្ញុំរបស់ប្រពន្ធ ហើយតាំងពីបុរាណកាលមក គេមិនដែលទទួលស្គាល់ថាប្ដីលួចទ្រព្យប្រពន្ធ ឬប្រពន្ធលួចទ្រព្យរបស់ប្ដីនោះទេ ។ ព្រះរាជា មានព្រះបន្ទូលតបទៅវិញថា “ពីមុនមកវាអ៊ីចឹងមែន តែឥឡូវនេះ វាមិនអ៊ីចឹងតទៅទៀតទេ” រួចព្រះអង្គក៏សម្រេចសេចក្ដីថា “នាយកំពេជ្រនេះមិនគ្រាន់តែមិនស្មោះត្រង់នឹងភរិយា បានបោះបង់នាងចោលធ្វើឲ្យនាងធ្លាក់ក្នុងភាពអាមាសជាស្រីមេម៉ាយប៉ុណ្ណោះទេ ថែមទាំងលួចយកខ្ញុំបម្រើរបស់ភរិយាម្នាក់ ធ្វើឲ្យនាងបាត់បង់ខាតទ្រព្យអស់ថែមទៀត ដូច្នេះនាយកំពេជ្រត្រូវទទួលទណ្ឌកម្មដែលមានឈ្មោះថា ទោសានុទោស ។ ទណ្ឌកម្មនេះ តម្រូវឲ្យគេបណ្ដើរនាយកំពេជ្រតាមផ្លូវក្នុងរាជធានីចំនួន ៣ថ្ងៃ លើក្បាលមានទូលកញ្ជើភ្នែកខ្មោច រួចហើយត្រូវវាយ ១០០

រំពាត់ខ្សែតី ។ បន្ទាប់មក ទ្រង់បានចេញព្រះរាជបញ្ញាឲ្យប្រគល់ខ្ញុំស្រីនោះទៅឲ្យនាងជាភរិយាវិញ រួចឲ្យប្រកាសផ្ដាច់សន្ទាសពីគ្នាតទៅ ។ ការសម្រេចក្ដីនោះ ក៏ត្រូវគេយកមកអនុវត្តតាមរហូតមក ចំពោះរឿងក្ដីប្រហាក់ប្រហែលគ្នា ។

ប៉ុន្មានឆ្នាំក្រោយមក ព្រះរាជាបានចេញព្រះរាជបញ្ញាឲ្យពាណិជ្ជករទាំងឡាយប្រើប្រាស់សម្រាប់ការទិញដូររបស់ផ្សេងៗតែជាមួយប្រាក់កាក់ដែលព្រះអង្គឲ្យបោះពុម្ព មានឈ្មោះថា ហាលបីវាប៉ុណ្ណោះ ដើម្បីទុកជាអនុស្សាវរីយ៍រំលឹកដល់មេដោះ ដែលបានបីបាច់ថែរក្សាព្រះអង្គ ។

នៅសម័យពេលនោះ អ្នកស្រុកហៅព្រះច័ន្ទរាជាថា ព្រះរាជាទិសខាងលិច ហើយហៅស្ដេចកនថា ព្រះរាជាទិសខាងកើតតែដូច្នេះរត់មាត់ទៅហើយ ប៉ុន្តែព្រះច័ន្ទរាជា បានចេញព្រះរាជបញ្ញាមួយហាមមិនឲ្យហៅស្ដេចកនដូច្នេះទេ បើពុំនោះទេនឹងត្រូវទទួលទោសដល់ជីវិត ។ ទ្រង់មានព្រះបន្ទូលថា «បើសិនជាយើងច្បាំងចាញ់ ហើយត្រូវស្លាប់ក្នុងការប្រយុទ្ធ ពេលនោះទើបប្រជានុរាស្ត្រអាចហៅវាថាជាព្រះរាជាជាអង្គម្ចាស់ជីវិតតម្កល់លើត្បូងបាន ប៉ុន្តែចំពោះមុខនេះត្រូវហៅវាតាមឋានៈដែលព្រះបាទស្រីសុគន្ធបទបានដាក់ឲ្យ មុនពេលមានការបះបោរគឺឃុនហ្លួងព្រះស្ដេចកន ។ តែបើសិនជាវាច្បាំងចាញ់ត្រូវសម្លាប់បានទៅវិញនោះ ឋានៈតែមួយដែលសមស្របចំពោះវាគឺពាក្យថា អាក្បត់» ។

នៅក្នុងឆ្នាំនោះដែរ ព្រះរាជាទ្រង់បានឲ្យដឹកនាំទំនិញជាច្រើនសំពៅទៅកាន់នគរជ្វាម៉ាឡាយូ ដើម្បីលក់ រួចហើយទិញកាំភ្លើងធំ១រយដើម និងកាំភ្លើងដៃ (កាំភ្លើងវែង) ១ពាន់ដើមយកមកវិញ ។ ស្ដេចកន ក៏បានបញ្ជូនសំពៅ ២គ្រឿងយកទំនិញទៅលក់ដែរ ហើយនាំយកមកវិញនូវកាំភ្លើងធំ១៥០ដើម និងកាំភ្លើងដៃ ៣ពាន់ដើម ក៏ប៉ុន្តែសំពៅទាំង២នោះបានជួបព្យុះ ក៏លើកកាំភ្លើងទាំងអស់នោះបោះចោលទៅក្នុងទឹកទៅ សំពៅទី១ បោះកាំភ្លើងចោលនៅពាមកញ្ជរ សំពៅទី២ដែលតូចជាង បោះចោលនៅពាម ។ សំពៅតូចក្រោយនេះបានត្រូវទាហានរក្សាមូលដ្ឋានចាប់បាន ឯកាំភ្លើងធំ៥០ដើម និងកាំភ្លើងដៃ១ពាន់ដើមបានត្រូវគេបញ្ជូនទៅកាន់បរិបូណ៌ ។ សំពៅរបស់ ព្រះច័ន្ទរាជាវិលត្រលប់មកកាន់កម្ពុជាវិញមានផ្ទុកកាំភ្លើងពេញ មិនមានខូតខាតបាត់បង់អ្វីទេ ។

ទទួលបានកាំភ្លើងធំ១៥០ដើម និងកាំភ្លើងដៃ២ពាន់ដើមបន្ថែមដូច្នេះ ព្រះច័ន្ទរាជា បានជ្រើសរើសទាហានបន្ថែមចំនួន២០ម៉ឺននាក់ទៀត ។ ទ្រង់ចាត់តាំងឧកញ៉ាមនោមេត្រី និងឧកញ៉ារាជាមេត្រីឲ្យធ្វើជាមេបញ្ជាការទ័ពឆ្វេងស្ដាំ រួចបានលើកព្រះភាគិនេយ្យពញាយសរាជាឲ្យធ្វើជាអគ្គសេនាប្រមុខលើកងទ័ពទាំងមូលកាន់ទ័ព ៥ម៉ឺននាក់ ដើម្បីចេញទៅធ្វើសង្គ្រាមនៅព្រៃវែង ។

ទ័ព៥ម៉ឺននាក់ទៀតទ្រង់ដាក់ក្រោមបញ្ជាឧកញ៉ាសួគ៌ាលោក ជាបុត្រារបស់ តាមឿង ។ ឧកញ៉ាឧទ័យធិរាជកាន់ទ័ពស្រួច ឧកញ៉ាពេជ្រតេជោ និងសហការីកាន់ទ័ពឆ្វេងស្ដាំ ។ ទ័ពនេះត្រូវធ្វើដំណើរកាត់ខែត្រកំពង់សៀម ទៅបោះទីតាំងនៅខាងមុខរាជធានីសំរោងព្រៃនគរ ដើម្បីរារាំងកុំឲ្យទ័ពចៅហ៊្វាកៅឆ្លងមកជួយស្ដេចកនជាក្នួយបាន ។

ព្រះរាជាកាន់ទ័ពធំ មានគ្នា១០ម៉ឺននាក់ ។ ទ័ពស្រួចមានទាហាន២ម៉ឺននាក់ ស្ថិតនៅក្រោមបញ្ជាការរបស់ ឧកញ៉ាចក្រី បុត្រច្បងរបស់តាមឿង ចេញដំណើរមុន ។ ឧកញ៉ាយោមរាជបញ្ជាទ័ពស្លាបឆ្វេង ឧកញ៉ាក្រឡាហោម បញ្ជាទ័ពស្លាបខាងស្តាំ ម្នាក់ៗចំនួន១ម៉ឺននាក់ ហើយសម្តេចចៅពញាបញ្ជាទ័ពខាងក្រោយចំនួន ១ម៉ឺននាក់ដែរ ។ ចំណែកឯសម្តេចចៅហ៊្វា ត្រូវព្រះអង្គចាត់ឲ្យកាន់ទ័ពនៅក្នុងរាជធានី នៅការពារព្រះរាជវាំង ។

ធ្វើដំណើរមកដល់ខត្តគ្គ ទ័ពព្រះរាជាឈប់សម្រាកជាលើកដំបូង ហើយទ្រង់យាងឡើងលើភ្នំព្រះរាជទ្រព្យ បន់ស្រន់អស់បណ្តាទេវតាដែលថែរក្សាព្រះរាជាណាចក្រ សូមឲ្យលោកជួយព្រះអង្គទទួលនូវជ័យជម្នះ រួចទ្រង់យាងតាមទូកសារាយណ៍អណ្តែតដែលព្រះសង្ឃរាជថ្វាយ ទៅពោធិសាត់ ។ នៅពេលត្រលប់មកពីពោធិសាត់វិញ ទ្រង់បានបញ្ជាឲ្យទ័ពទាំង ៨កង ចេញដំណើរទៅកាន់រាជវាំងស្តេចកន ។

និយាយពីស្តេចកនវិញ ដែលមានជំនឿជឿជាក់ក្នុងខ្លួនថា ព្រះច័ន្ទរាជា មិនហ៊ានលើកទ័ពមកវាយព្រះអង្គ ក៏គិតតែពីសប្បាយ ដោយគិតថា មានសុវត្ថិភាពហើយ ។ ដល់ទទួលរបាយការណ៍ថា ទ័ពព្រះរាជាចូលមកជិតដល់ហើយ ក៏ភ្ញាក់ខ្លួនព្រើត ភិតភ័យខ្លាំងណាស់ ចេញបញ្ជាមិនដឹងខុសមិនដឹងត្រូវ ប្រមូលទ័ពបានតែ ១ម៉ឺននាក់ប៉ុណ្ណោះ ។ ទ្រង់ក៏សម្រេចរត់ចោលរាជធានីបាសាន ដោយចាប់បង្ខំឲ្យប្រជារាស្ត្រទៅតាមព្រះអង្គផង ។ ពេលរត់នោះ ក៏មកជួបជាមួយទ័ពរបស់ឧកញ៉ាសួគ៌ាលោក ប្រយុទ្ធគ្នាពេញ១ថ្ងៃ រកតែដកដៃគេចក៏មិនរួច ។ នៅពេលនោះ ទ័ពរបស់ឧកញ៉ាចក្រី និងឧកញ៉ាតេជោ ដែលខិតខំធ្វើដំណើរឥតឈប់ឈរ ព្រោះចង់វាយស្តេចកន បានមកដល់ល្មម ព័ទ្ធទ័ពស្តេចកនជាប់ពីខាងក្រោយ និងពីខាងចំហៀង ទ័ពឧកញ៉ាសួគ៌ាលោកនៅពីខាងមុខ ក៏ព្រួតគ្នាវាយយ៉ាងពេញទំហឹង ។ ចៅហ៊្វាកៅជាឪពុកមាស្តេចកន ពេលបានទទួលដំណឹងអំពីការមកដល់សំរោងព្រៃនគររបស់កងទ័ពព្រះរាជាផង និងដំណឹងអំពីគ្រោះថ្នាក់ដែលស្តេចកនកំពុងជួបប្រទះផង ក៏នាំទ័ព៥ម៉ឺននាក់ ឡើងទៅទិសខាងជើង ដែលគ្មានទ័ពព្រះរាជា ដើម្បីទៅផ្សារភ្ជាប់ជាមួយទ័ពស្តេចកន ដែលកំពុងតែទប់ទល់ស៊ិតស្វាញនៅឡើយ នៅកណ្តាលកងទ័ពរបស់ព្រះរាជា ប៉ុន្តែបានត្រូវទ័ពរបស់ឧកញ៉ាតេជោ ដែលដឹងអំពីល្បិចនេះជាមុន តាមវាយបំបែកពីក្រោយជាប់ ។

ស្តេចកនមិនបានដឹងថាឪពុកមាមកជួយទេ ប៉ុន្តែដល់ឃើញទ័ពឧកញ៉ាតេជោធ្វើចលនា ក៏កាត់យល់ថាទ័ពនេះមានគេវាយមកលើហើយ ក៏បែរកម្លាំងវាយទៅខាងនោះ ហើយបើកផ្លូវចេញរួច តែត្រូវមកជួបជាមួយទ័ពរបស់សម្តេចចៅពញា និងទ័ពរបស់ឧកញ៉ាមហាមន្ត្រី ដែលកំពុងតែលាក់ខ្លួនរង់ចាំនៅក្នុងព្រៃលំបង់ ក្នុងនោះមានទាហាន២៥០នាក់ក្រោមបញ្ជាការរបស់ព្រះសួឡាត់មានកាំភ្លើងកាន់នៅដៃ ។ មានទ័ព ៥ពាន់នាក់ទៀតនៅក្រោមបញ្ជាការរបស់ឧកញ៉ាមហាទេព ឈរជើងនៅលើភ្នំពាមជាំង មានកាន់កាំភ្លើង ធ្នូ និងស្នា ។ ពេលនោះ ទ័ពពួកបះបោរទាំង១ម៉ឺននាក់បានត្រូវសម្លាប់ រងរបួស ឬក៏ត្រូវចាប់ខ្លួនបាន បើពុំនោះទេ ត្រូវរត់ខ្ចាត់ខ្ចាយ អ្នកនៅសល់ខ្លះហែលឆ្លងទន្លេតូច រត់ទៅតាមផ្លូវសរព្រះច័ន្ទសំដៅទៅរកទ័ពនៅសំរោងព្រៃនគរ ។ ព្រះច័ន្ទរាជា

ទ្រង់រង់ចាំពួកបាក់ទ័ពនេះនៅក្នុងវាលសរព្រះច័ន្ទនោះឯង ។ ពេលនោះទ័ពស្រួចរបស់ព្រះអង្គ ប៉ះជាមួយសត្រូវមុនគេ ហើយមេទ័ពស្រួចសម្តេចចៅពញាបានត្រូវឪពុកមារបស់ស្តេចកនបបួលឲ្យចូលមកប្រយុទ្ធគ្នាហើយសម្លាប់បាន ប៉ុន្តែទ័ពចៅហ៊្វាកៅបានត្រូវទ័ពព្រះរាជាពាកង់ទៀតដេញតាមប្រកិត ក៏វាយដកខ្លួនថយ រហូតបានទៅជួបជាមួយនឹងទ័ពស្តេចកន ។

បានជួបជុំគ្នាមា និងក្មួយ ស្តេចកន និងចៅហ៊្វាកៅគិតថាពួកគេមានកម្លាំងខ្លាំងល្មមហើយ ក៏នាំគ្នាធ្វើដំណើរតាមផ្លូវទៅព្រៃលំបង់ ។ ទៅដល់ទីនោះក៏ជួបជាមួយទ័ពខុកញ៉ាមហាមន្ត្រី១ម៉ឺននាក់ ដែលដាច់ខាតរារាំងផ្លូវពួកគេមិនឲ្យទៅមុខ ធ្វើឲ្យស្តេចកនដែលត្រូវវាយប្រហារជាច្រើនលើកច្រើនសាររួចមកហើយ ធ្លាក់ខ្លួនអស់សង្ឃឹមហើយស្រែកយំ ។ ចៅហ៊្វាកៅជាមាឃើញដូច្នេះក៏និយាយលួងលោម រួចចាប់ក្មួយដាក់លើខ្នងសេះពីខាងក្រោយបម្រុងនាំគេចចេញពីសមរភូមិទៅ ដោយនិយាយថា “គ្មានអ្វីខាតបង់ទេកាលណាយើងនៅរស់” ។ ពេលនោះ ពួកទាហានរបស់ព្រះសូឡាត់២៥០នាក់ក៏ចាប់បាញ់កាំភ្លើងសំដៅមកលើ ធ្វើឲ្យទាហានពួកក្បត់ស្លាប់អស់ជាច្រើន ។ ក៏ប៉ុន្តែចៅហ៊្វាកៅនៅតែស្រែកកម្លាទាហានឲ្យបន្តការប្រយុទ្ធ ទាំងស្តេចកនក៏មានទឹកចិត្តឡើងវិញដែរ ។ ពួកគេ នៅសល់ទាហានប្រហែលតែ៥ពាន់នាក់ប៉ុណ្ណោះ ក៏ប៉ុន្តែជាមួយទាហានប៉ុននេះ គេអាចទប់ទល់ ហើយគេចខ្លួនរួចពីការវាយសង្គ្រុបឥតបង្អង់ដៃពីគ្រប់ទិសទីរបស់ទ័ព ខុកញ៉ាមហាមន្ត្រី ១ម៉ឺននាក់ ។ ពួកគេគេចខ្លួនទៅដល់ច្រក នៅចន្លោះភ្នំពាមជាំង និងភ្នំពានជញ្ជាំង ដោយអស់កម្លាំងនឿយហត់ខ្លាំងពេក មិនអាចបន្តដំណើរទៅមុខទៀតបាន ក៏នាំគ្នាឈប់សម្រាកដាំបាយហូបសិន ។ ប៉ុន្តែខុកញ៉ាមហាទេពដែលបោះទ័ពនៅលើកំពូលភ្នំមិនបានទុកពេលឲ្យទេ ក៏ចាប់ប្រមៀលដុំថ្មធំម្ភាក់មកលើ ហើយបាញ់កាំភ្លើង ព្រួញធ្នូស្នាមកលើថែមទៀត ។ នៅពេលស្ងប់ទៅស្តេចកន និងឪពុកមាមាននៅសល់ទាហានមិនដល់៥រយនាក់ផង អ្នកឯទៀតស្លាប់ ឬក៏រត់បែកខ្ញែកអស់ទៅ ។ ប៉ុន្តែ ពួកគេនៅតែអាចរត់គេចខ្លួនរួចយ៉ាងលឿន រហូតទាល់តែទ័ពព្រះរាជាមើលមិនទាន់ មិនហ៊ានដេញតាម ។

ពេលនោះ ព្រះច័ន្ទរាជា បានចេញបញ្ជាឲ្យខុកញ៉ាយមរាជ ខុកញ៉ាវាំង ខុកញ៉ាក្រឡាហោម និងខុកញ៉ាចក្រីនាំទាហានទៅបោះទ័ពនៅពីមុខរាជធានីសំរោងព្រៃនគរ ជាកន្លែងដែលនាយកន និងឪពុកមារត់ទៅពួនលាក់ខ្លួនសម្ងំនៅ ទ័ពទាំងអស់ស្ថិតនៅក្រោមបញ្ជារបស់សម្តេចចៅពញាយសរាជា ជាព្រះអគ្គមេបញ្ជាការ ។ ទ័ពព្រះរាជាឡោមព័ទ្ធរាជធានីនេះជាប់៣ខែ ប៉ុន្តែមិនអាចដណ្តើមយកបន្ទាយរឹងមាំដែលនៅលើកំពូលភ្នំបានទេ ។ ពេលនោះ ខុកញ៉ាចក្រីខាងទ័ពព្រះរាជា ក៏មានគំនិតចាប់សង់កំពែងឲ្យបានខ្ពស់ស្មើនឹងកំពែងរាជធានី រួចដាក់ទ័ពកាំភ្លើងបាញ់ចូលទៅក្នុងអស់ពេល ៥ថ្ងៃ នៅតែមិនបានផល ។ ប៉ុន្តែ ព្រះរាជាបានប្រកាសឲ្យដឹងថា ព្រះអង្គនឹងមិនឲ្យដកថយការហ៊ុមព័ទ្ធនេះទេ ឲ្យបន្តរហូតទាល់តែទទួលបានជ័យជម្នះ ហើយនៅពេលនោះ មនុស្សទាំងអស់ ដែលព្រះអង្គឃើញនៅក្នុងរាជធានីនឹងត្រូវដាក់ឲ្យទៅជាខ្ញុំទាំងអស់ ។ ព្រោះដូច្នេះ ពួកទាហាននៅក្នុងកងទ័ពព្រះរាជា ដែលមានបងប្អូនរស់នៅក្នុងរាជធានីនោះ ក៏ផ្សព្វផ្សាយដំណឹងនេះបន្តៗគ្នា ហើយបាននិយាយបន្ថែមថា ស្តេចសៀមនឹងបញ្ជូន

ទ័ពមកជួយព្រះច័ន្ទរាជា ជាហេតុធ្វើឲ្យរឹតតែជ្រួលច្របល់ខ្លាំងឡើងថែមទៀត ។

យប់មួយព្រះរាជាបានបញ្ជាឲ្យគេដុតស្មៅដែលនៅជាប់នឹងអាចម៍បំណះ ភ្លឺព្រោងព្រាតជុំវិញរាជធានី ធ្វើឲ្យអ្នកដែលរស់នៅខាងក្នុងជឿថាទ័ពសៀមបានមកដល់ហើយ ភ្លើងទាំងអស់នោះជាភ្លើងដែលពួកគេដុតបំភ្លឺ ។ ពេលនោះប្រជាជនចាប់ភិតភ័យជាខ្លាំង ក៏នាំគ្នាបើកទ្វាររាជធានីរត់ចេញមកក្រៅ ដើម្បីគេចឲ្យផុតពីការកាប់សម្លាប់ និងការធ្លាក់ខ្លួនជាខ្ញុំប្រសិនបើត្រូវគេចាប់បាន ។ ទាហានស្តេចកនក៏រត់ចេញមកដែរទាំងរញ៉េរញ៉ៃគ្មានសណ្តាប់ធ្នាប់ នាំគ្នាសម្រុកចេញទៅក្រៅខ្សែឡោមព័ទ្ធ តែត្រូវទ័ពព្រះរាជាដែលនៅត្រៀមចាំកាប់សម្លាប់អស់ជាច្រើន ។ ដល់ឃើញដូច្នេះ ពួកអ្នកស្រុកក៏ចូលដៃចូលជើងជាមួយទ័ពព្រះរាជា ជួយកាប់សម្លាប់ពលទាហាន និងឧត្តមសេនីយ៍ក្បត់ដែលរត់មិនរួច ស្លាប់អស់គ្មានសល់ ។ ចៅហ៊្វាកៅ ឪពុកមារបស់ស្តេចកន បានត្រូវខកញ៉ាចក្រីកាប់នឹងដាវស្លាប់នៅមាត់ទ្វាររាជធានី ។ ចំណែកស្តេចកនវិញ ត្រូវខកញ៉ាវាំង រកឃើញកំពុងអង្គុយកណ្តាលចំណោមស្រីៗនៅក្នុងដំណាក់ ក៏ចោលលំពែងធ្វើឲ្យរបួស រួចចាប់ចង ដាក់ឲ្យគេយាមកាមយ៉ាងហ្មត់ចត់ ។ ស្អែកឡើងព្រះច័ន្ទរាជាទ្រង់បានបញ្ជាឲ្យគេសម្លាប់ស្តេចកនចោល និងឲ្យដាក់បក្សពួកទាំងអស់ជាខ្ញុំ របស់ព្រះរាជាណាចក្រ ។

ប៉ុន្មានថ្ងៃក្រោយមក ព្រះរាជាបានចាត់តាំងឲ្យព្រះសូទ្បាត់ត្រួតត្រាលើខែត្រត្បូងឃ្មុំ និងមើលខុសត្រូវបន្ទាយ ចំណែកព្រះអង្គក៏ឡើងគង់លើទូកសារាយណ៍អណ្តែត យាងទៅកាន់រាជធានីបរិបូណ៌វិញ ។ យោលទៅតាមការស្នើសុំរបស់ព្រះសង្ឃរាជ ដែលបានថ្វាយទូកនេះដល់ព្រះអង្គ ព្រះអង្គទ្រង់បានចាត់ឲ្យកសាងវត្តមួយនៅក្នុងព្រៃផ្ទុយដេករួចហើយឲ្យយកទូកនោះទៅឆ្លាក់ជាព្រះពុទ្ធរូបមួយអង្គធំ និងព្រះពុទ្ធរូបតូចៗជាច្រើនទៀតតាមដែលអាចធ្វើបាន ។ មួយឆ្នាំក្រោយមក គឺនៅក្នុងឆ្នាំ១៥០៦ វត្តនោះមានឈ្មោះថា ព្រះពុទ្ធលាយល័ក្ខ[៦៨] ឯព្រះចៅអធិការ បានទទួលឋានៈជា ព្រះឥន្ទទេពចក្រ ។

ទីក្រុងពោធិសាត់បានដូរឈ្មោះទៅជា បន្ទាយមានជ័យ ហើយបានក្លាយជារាជធានីរបស់ព្រះរាជាណា-ចក្រអស់មួយរយៈ ។

មួយឆ្នាំមកទៀត ចៅពញាយសរាជា ជាបុត្ររបស់ស្នំឯក និងត្រូវជាក្មួយស្តេចកន បានសុគតទៅក្នុងព្រះជន្មាយុ ១៨ព្រះវស្សា ។ សពរបស់ព្រះអង្គបានត្រូវគេធ្វើពិធីបូជាជាមួយសពព្រះបិតា ព្រះសុគន្ធបទដែរ ។

ក្នុងមួយរយៈពេលមានសង្គ្រាមនេះរហូតដល់ឆ្នាំ១៥២៥ ស្តេចសៀមហាក់ដូចជាមិនបានយកចិត្តទុកដាក់ចំពោះព្រឹត្តិការណ៍ទាំងឡាយ ដែលកើតមាននៅកម្ពុជាទេ ប៉ុន្តែគេបានចាត់ទុកព្រះរាជាណាចក្រកម្ពុជាថា

---

[៦៨] វត្តនេះមាននៅរហូតដល់សព្វថ្ងៃ ហើយមានទាំងចម្លាក់រាក់ និងព្រះបដិមាល្អៗ ថែមទៀតផង ។

នៅចំណុះអធិរាជភាពរបស់គេ ហើយយោលទៅតាមទម្លាប់បុរាណដែលមានរវាងនគរអធិរាជ និងនគរសាមន្តរាជ ស្តេចសៀមបានស្នើឲ្យព្រះច័ន្ទរាជាយកដំរីសដ៏ល្អមួយដែលព្រះអង្គមាននៅក្នុងក្រោលទៅថ្វាយ ។ ព្រះច័ន្ទរាជាមិនយល់ព្រមបង្ហាញឲ្យឃើញថាព្រះអង្គចំណុះស្តេចសៀមទេ ហើយមិនបានផ្ញើដំរីសតាមសំណើឡើយ ។ ស្តេចសៀម បានចាត់ទុកការប្រកែកមិនព្រមថ្វាយដំរីសឲ្យនេះ ថាជាការមិនបានបំពេញកាតព្វកិច្ចក្នុងភាពជានគរចំណុះ ហើយដោយទ្រង់គិតថា ព្រះរាជាណាចក្រកម្ពុជាធ្លាក់ចុះដុនដាបដោយសង្គ្រាមរវាងគ្នាឯងនិងគ្នាឯងខ្លាំងណាស់ទៅហើយ ទ្រង់ក៏ដឹកនាំទ័ពឆ្លងកាត់ព្រំប្រទល់ដែនចូលមកឈ្លានពានខែត្រអង្គរ ។ ព្រះរាជាចាត់ឲ្យកេណ្ឌទ័ពជាប្រញាប់ ទ័ពនោះពោរពេញទៅដោយសេចក្តីក្លាហាន រួចទ្រង់បានដឹកនាំផ្ទាល់ព្រះអង្គ ចេញទៅវាយទ័ពស្តេចសៀមឲ្យបរាជ័យ ចាប់បានឈ្លើយ ១ម៉ឺននាក់នាំយកមកពោធិសាត់[៦៩] ។

នៅឆ្នាំ១៥២៨ ប្រហែលជា៤ឆ្នាំក្រោយពីបរាជ័យរបស់ទ័ពសៀមរួចមក ព្រះច័ន្ទរាជា មានព្រះតម្រិះថារាជធានីពោធិសាត់នេះស្ថិតនៅជិតព្រំប្រទល់ដែនខ្លាំងណាស់ ទ័ពសត្រូវងាយនឹងបើកការវាយប្រហារមកលើបានយ៉ាងស្រួល បើសិនជាគេដើរស្រូតតែបន្តិច ទ្រង់ក៏សម្រេចផ្ទេររាជធានីមកតាំងនៅខាងត្បូងបន្តិចត្រង់លង្វែក ។ គឺនៅលង្វែកនេះឯង ដែលព្រះអង្គទទួលព្រះពិធីរាជាភិសេកឡើងសោយរាជ្យនៅក្នុងឆ្នាំ១៥២៩ នៅពេលដែលព្រះអង្គមានព្រះជន្មាយុ ៥៣ព្រះវស្សា ។

ថ្ងៃមួយ ពេលយាងប្រពាតព្រៃ ព្រះរាជាបានប្រទះឃើញដុំថ្មមួយដុំដែលត្រូវមែកគគីរមួយដើមដុះព័ទ្ធស៊ើរជុំជិត ទ្រង់ក៏បញ្ជាឲ្យគេកាប់យកមែកគគីរនោះទៅឆ្លាក់ជាព្រះពុទ្ធរូប៤ព្រះអង្គទល់ខ្នងគ្នា បែរព្រះភ័ក្តទៅរកទិសទាំង៤ ឯដុំថ្មទ្រង់ឲ្យឆ្លាក់ធ្វើជាទម្រ ។ រួចទ្រង់បានបញ្ជាឲ្យសង់វត្តមួយនៅលង្វែក ដាក់ព្រះពុទ្ធរូបនេះ នៅក្នុងព្រះវិហារមណ្ឌប[៧០] សម្រាប់ឲ្យពុទ្ធសាសនិកគោរពបូជា នៅក្នុងឆ្នាំ១៥៣០នៃគ្រិស្តសករាជ ត្រូវនឹងមហាសករាជ ១៤៥២ ចុល្លសករាជ៨៩២ ។

គេនិយាយថា ព្រះច័ន្ទរាជា បានកសាងវត្តមួយនៅខត្តុងដែលមានព្រះពុទ្ធរូបធំមួយអង្គ និងកសាងវិហារតូចជាងគេនៅលើភ្នំព្រះរាជទ្រព្យដែលមានព្រះពុទ្ធរូបនិព្វានមួយអង្គ ព្រមទាំងឲ្យជីកស្រះទឹកពាជង គឺស្រះធម្មកេរ្តិ៍នៅខាងជើងភ្នំ ស្រះដើមពោធិនៅខាងលិច និងត្រពាំងសរីទ្ធនៅខាងជើងដែរ ។ ទ្រង់ក៏បានបញ្ជាឲ្យគេបោះចម្រូងយ៉ាងមាំ រួចចាក់ដីជាច្រើនបិទកន្លែងមួយដែលទឹកហូរចេញពីក្នុងដីមកបង្កើតបានជាត្រពាំងមួយហៅថា ត្រពាំង

[៦៩] ខ្ញុំជឿថា គឺនៅក្នុងឱកាសនោះឯងដែលភូមិនៅលើស្ទឹងអង្គរទទួលឈ្មោះថា សៀមរាប ។

[៧០] សព្វថ្ងៃគេហៅថា វត្តត្រឡែងកែង ស្ថិតនៅត្រង់ពាក់កណ្តាលជ្រុងខាងកើតរាជធានី នៅមាត់បឹងធំមួយ ។ ព្រះពុទ្ធរូបព្រះភក្ត្រ ៤ បាត់ទៅហើយ នៅសល់តែទម្រថ្ម មានស្នាមព្រះបាទ៨ប៉ុណ្ណោះ ព្រះបាទនីមួយៗប្រវែងប្រហែល ១ម៉ែត្រ ៤០សង់ទីម៉ែត្រ ។

ផ្សារដែក[៧១] ។ រួចទ្រង់បានឲ្យគេត្រួសរានព្រៃនៅជុំវិញភ្នំយកដីធ្វើស្រែប្រមូលផល ផ្គត់ផ្គង់ជីវភាពព្រះសង្ឃដែលគង់នៅក្នុងវត្ត ព្រោះថា វត្តនោះនៅឆ្ងាយពីភូមិអ្នកស្រុក និងបានប្រគល់ពលព្រះជាច្រើនដាក់នៅក្រោមបញ្ជាការមេម្នាក់ ដើម្បីឲ្យធ្វើស្រែទាំងអស់នោះ ។ ព្រះសង្ឃរាជវត្តនោះ មានព្រះឋានៈជា ព្រះមហាធាតុថេរ ។

ពេលនោះ សង្គ្រាមស៊ីវិលបានផ្ទុះឡើង នៅឯស្រុកសៀម ក្នុងឆ្នាំ១៥២៩ ។

ទទួលបានដំណឹងនេះ ព្រះច័ន្ទរាជា បានកោះប្រជុំរាជវង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រីនៃព្រះរាជាណាចក្រ រួចទ្រង់មានព្រះបន្ទូលថា ៖ «ពួកសៀមបានចូលមកលុកលុយព្រះរាជាណាចក្រកម្ពុជាយើង២ដងរួចមកហើយ ហើយរាល់ពេលដែលចេញទៅវិញ គេបានកៀរយកអ្នកស្រុករបស់យើងទៅជាមួយផង ។ ដោយសារហេតុនេះហើយ បានជាព្រះបិតារបស់យើងត្រូវបង្ខំចិត្តបោះបង់ចោលឥន្ទបត្តបុរី ដកថយមកគង់នៅចតុម្មុខវិញ ។ ឥឡូវស្រុកសៀមមានវិបល្លាស ដោយយុនវរវង្សាធិរាជបានធ្វើឃាតព្រះរាជាដណ្តើមរាជសម្បត្តិ យើងត្រូវតែឆ្លៀតយកឱកាស» ។ មានព្រះបន្ទូលរួច ព្រះរាជាបានបញ្ជាឲ្យព្រះអនុជរបស់ព្រះអង្គ យាងទៅខែត្របាភ្នំកេណ្ឌទ័ពឲ្យបាន១២ម៉ឺននាក់ ហើយឲ្យកេណ្ឌសេះដំរី និងរទេះសាលីផង ដែលចាំបាច់សម្រាប់ត្រៀមធ្វើសង្គ្រាម ។ ពីរបីថ្ងៃក្រោយមក ទ្រង់បានចាត់លោក ចៅហ៊្វាទល្ហៈ គឺនាយករដ្ឋមន្ត្រី ឲ្យកាន់ទ័ពស្រួច ឯព្រះអង្គ កាន់ទ័ពមួយកងទៀត យាងទៅជាមួយដែរ តាមផ្លូវពីចតុម្មុខទៅពោធិសាត់ និងបាត់ដំបង ។

ទ័ពស្រួចរបស់ចៅហ៊្វាទល្ហៈទទួលបានជ័យជម្នះរហូត លើទ័ពអាជ្ញាធរខែត្ររបស់សៀម តាំងពីដំបូង រហូតដល់ព្រំប្រទល់ខែត្របសិ្ចម ធ្វើឲ្យពួកមន្ត្រីសៀមរត់គេចខ្លួនបាត់អស់ ហើយខ្មែរយើងចាប់បានសៀម ៤ពាន់នាក់ជាឈ្លើយ ។

មកដល់បសិ្ចមបុរី ពលទាហានអស់កម្លាំងខ្លាំងណាស់ទៅហើយ ក៏សម្រាករង់ចាំទ័ពព្រះរាជាស្រីរាមាធិបតីយាងមកដល់ ។

ពេលទ័ពព្រះរាជាមកដល់ លោក ចៅហ៊្វាទល្ហៈ ក៏នាំចៅហ្វាយខែត្រ និងមន្ត្រីសៀមដែលចាប់បានយកមកថ្វាយព្រះរាជាក្រាម ។ ពួកនោះបានទូលព្រះរាជាថា គេបានរៀបចំសណ្តាប់ធ្នាប់នៅអយុធ្យាឡើងវិញហើយ ដោយជនក្បត់ដណ្តើមរាជបល្ល័ង្ក និងប្រពន្ធឈ្មោះ សោមាស៊ីសូដាច័ន្ទ បានត្រូវ យុនគួនទេព និងមន្ត្រីជាច្រើននាក់ទៀតចាប់បានហើយសម្លាប់ចោល ។ ឥឡូវនេះ គេបានលើកព្រះរានរាជា ត្រូវជាព្រះបិតុលាព្រះរាជា ដែលសោយទិវង្គតទៅឲ្យឡើងសោយរាជ្យ ទ្រង់ព្រះនាមថាព្រះចៅមហាចក្រពត្រារាជាធិរាជ ព្រះរាជានៃប្រទេសសៀម ។ ព្រះច័ន្ទរាជា ខ្លាចក្រែងពួកមន្ត្រីទាំងអស់នោះនិយាយកុហក ទ្រង់ក៏បញ្ជាឲ្យទ័ពសេះរបស់ព្រះអង្គ ធ្វើ

---

[៧១] មុនពេលដែលរាជធានីត្រូវផ្លាស់មកនៅភ្នំពេញ ពួកកួយតែងយកដែកដែលពួកគេចំរាញ់ចេញពីរ៉ែភ្នំដែកមកលក់នៅកន្លែងនេះ ។

ដំណើរទៅអយុធ្យាមុន ដើម្បីស៊ើបសួរពត៌មាន ។ ចំណែកឯកងទ័ពព្រះរាជា នៅតែបន្តដំណើរទៅមុខ ដោយច្បាំងវាយយកទឹកដីសៀមជាបន្តបន្ទាប់ និងចាប់បានឈ្លើយសឹកជាច្រើនយកមក ថ្វាយព្រះរាជា ។

នៅពេលដែលកងទ័ពបោះជំរំរង់ចាំដំណឹងពីរាជធានីសៀម និងពីព្រឹត្តិការណ៍ដែលបានកើតឡើង ស្តេចនគរប៉ៃហ្កាន នៅពេលដែលបានទទួលដំណឹងអំពីបដិវត្តន៍នៅអយុធ្យា ក៏បានកេណ្ឌទ័ព ៣ម៉ឺននាក់ រួចធ្វើដំណើរមក ប្រុងវាយយករាជធានីសៀមនេះ ដូចជាព្រះរាជាកម្ពុជាដែរ ។ តែដល់ទ្រង់ជ្រាបថាទ័ពខ្មែរបានមកបោះជំរំនៅពីខាងត្បូងអយុធ្យាជិតបង្កើយ ហើយមានទាហានដល់ទៅ១២ម៉ឺននាក់ ច្រើនលើសលប់ទ័ពប៉ៃហ្កាន ព្រះអង្គមិនអាចដណ្តើមយកជ័យជម្នះបាន ទ្រង់ក៏បញ្ជាទ័ពឲ្យដកថយទៅក្រោយវិញ ។

នៅឆ្នាំ១៥៣១ ចៅពញាអុង ជាបុត្ររបស់ព្រះស្រីរាជាដែលសុគតទៅដោយត្រូវធ្លាក់ខ្លួនជាចំណាប់ខ្មាំងរបស់សៀម ហើយដែលស្តេចសៀមបានសុំយកមកធ្វើជាកូនចិញ្ចឹម និងលើកឲ្យធ្វើជាចៅហ្វាយខែត្រសុវណ្ណលោក ទ្រង់មានព្រះជន្ម៥៤ព្រះវស្សាហើយ ។ ដោយចង់ឲ្យស្តេចខ្មែរលើកសួយសារអាករទៅថ្វាយស្តេចសៀម បានប្រគល់ទ័ព ៩ម៉ឺននាក់ ឲ្យចៅពញាអុង ចូលមកលុកលុយរាតត្បាតកម្ពុជាពីខាងជើង ហើយឲ្យទ័ពជើងទឹក ៥ម៉ឺននាក់ទៀត ចូលមកតាមមាត់សមុទ្រ ។

ព្រះច័ន្ទរាជា បានចាត់ឲ្យលោកក្រឡាហោម រដ្ឋមន្ត្រីខាងទ័ពជើងទឹក ចេញមកប្រយុទ្ធជាមួយទ័ពជើងទឹកសៀម ឯព្រះអង្គដឹកនាំទ័ពជើងគោកទៅជួបជាមួយទ័ពពញាអុង ។ ការប្រយុទ្ធផ្តើមឡើងនៅជិតពោធិសាត់ ហើយចៅពញាអុងបានត្រូវព្រួញស្លាប់នៅលើក្បាលដំរី មេទ័ពសៀមជាច្រើនត្រូវប្រហារ ធ្វើឲ្យទ័ពសៀមបាក់បែកខ្ចាត់ខ្ចាយអស់ទៅ ។ ក្នុងពេលជាមួយគ្នានោះទ័ពជើងទឹកសៀមដែលដឹកនាំដោយភ្យាតេជវង្សាក៏បានត្រូវវាយឲ្យបរាជ័យ រួចឡើងទូកចេញទៅវិញ អស់ដែរ ។ រាជពង្សាវតារមិនបានប្រាប់ឲ្យដឹងថា សៀមចុះទូកនៅឯណាទេ ក៏ប៉ុន្តែគេអាចស្មានបានថា នៅក្នុងខែត្រពាម គឺហាទៀង សព្វថ្ងៃ ។

ព្រះច័ន្ទរាជា បានចាត់ឲ្យគេសង់វត្តមួយដើម្បីរំលឹកដល់ជ័យជម្នះរបស់ព្រះអង្គនេះ ហើយឲ្យយកមាសប្រាក់ដែលប្រមូលបានពីសត្រូវទៅរំលាយធ្វើជាព្រះពុទ្ធរូបជាច្រើនអង្គ ដាក់នៅក្នុងវត្តនេះ ។ ព្រះអដ្ឋិធាតុរបស់ចៅពញាអុង ទ្រង់ឲ្យដាក់នៅក្នុងចេតិយមួយ ដែលសង់នៅក្នុងបរិវេណវត្តនេះ ។ វត្តនេះមានឈ្មោះថា វត្តពោធិមានបុណ្យ ដោយមកពីមានដើមពោធិ១ដើមដែលមានស្លឹកខ្ចីល្អក់ នៅពេលដែលព្រះរាជាយាងកាត់ទៅធ្វើសង្គ្រាម ។ ព្រះគ្រូចៅអធិការវត្តនេះមានព្រះឋានៈជាព្រះពោធិវង្ស ។

នៅក្នុងឆ្នាំ១៥៣៩ ជនម្នាក់ឈ្មោះថា ក្រឡាពាសសួស[៧២] បានរកឃើញព្រះខ័នរាជ្យរបស់អតីតមហា

---

[៧២] គួររំលឹកថា ព្រះឥសីផាត មានខ្ញុំបម្រើម្នាក់ឈ្មោះថា សួស ក៏ប៉ុន្តែរាជពង្សាវតារនិយាយថា សួសនេះ មិនមែនជា សួស ដែលតាមបម្រើព្រះឥសី ពីមុននោះទេ ។

ក្សត្រវង្ស ដែលព្រាហ្មណ៍ព្រះឥសីផាតបានយកទៅលាក់នៅខែត្របាទីក្នុងរជ្ជកាលព្រះសុគន្ធបទ ជាមួយនឹងលំពែងរបស់តាចាយ ហើយនិងកេតនភណ្ឌផ្សេងៗទៀតនៅក្នុងរន្ធដើមចំបក់មួយដើម ។ គេបាននាំយកវត្ថុទាំងអស់នោះមករាជធានីលង្វែកវិញ ។

ព្រះមហារាជានៃព្រះរាជាណាចក្រកម្ពុជានេះ ទទួលបានជ័យជម្នះជានិច្ច ក្លាហានហើយឈ្លាសវៃ ទ្រង់សុគតទៅនៅក្នុងឆ្នាំ១៥៥៥នៃគ្រិស្តសករាជ ត្រូវនឹងមហាសករាជ១៤៧៧ ចុល្លសករាជ៩១៧ ។ ពេលនោះព្រះអង្គមានព្រះជន្មាយុ៧៩ព្រះវស្សា ហើយសោយរាជ្យក្នុងរយៈពេលលើសពី៥៥ឆ្នាំ[៧៣] ។

គឺដោយបែបនេះហើយដែលធ្វើឲ្យគេភ្លេចអស់រឿងរ៉ាវស្តេចកន ដែលបានសោយរាជ្យអស់១៦-១៧ឆ្នាំដែរ ។ រាជពង្សាវតារខ្មែរ ក្រោយពីលើកសរសើរខ្លះដល់ជនក្បត់នេះ ក៏បែរមកលើកសរសើរព្រះរាជា ដែលទទួលបានជ័យជម្នះម្តង ។ ក៏ប៉ុន្តែវាហាក់ដូចជាថាព្រះច័ន្ទរាជានេះជាស្តេចត្រឹមត្រូវហើយល្អមែន ។ ទ្រង់មានជំនឿខ្លាំងលើព្រះពុទ្ធសាសនា ហើយសព្វព្រះទ័យក្នុងការធ្វើទាន កសាងវត្ត និងព្រះពុទ្ធរូបជាច្រើន ។ ដោយហេតុនោះហើយបានជាព្រះអង្គត្រូវប្រជារាស្ត្រពេលនោះស្រឡាញ់ខ្លាំងណាស់ រហូតដល់ភ្លេចអស់សម័យសុខសប្បាយ ក្រោមរាជ្យស្តេចកន ។

គេបាននាំយកព្រះខ័នរាជ្យ និងកេតនភណ្ឌសម្គាល់រាជានិយមផ្សេងៗទៀត ដែលគេរកឃើញនៅក្នុងរន្ធដើមចំបក់នៅក្នុងខែត្របាទី ដែលព្រះឥសីផាត យកទៅលាក់ទុកមកថ្វាយព្រះអង្គវិញ ។ វត្ថុទាំងអស់នេះគេអាចមើលឃើញនៅក្នុងហោព្រះនៃព្រះរាជវាំងស្តេចស៊ីសុវត្ថិ នៅភ្នំពេញសព្វថ្ងៃ ។

## ១៩- ព្រះបរមឥន្ទរាជាទី១ (១៥៥៦-១៥៦៧)

ព្រះរាជាដែលសោយរាជ្យបន្តពីព្រះច័ន្ទរាជា គឺរាជបុត្ររបស់ព្រះអង្គព្រះនាមថា ព្រះបរមរាជា មានព្រះជន្មាយុ៤៦ព្រះវស្សា ដែលព្រះអង្គបានលើកជាអ្នកស្នងរាជ្យតាំងតែពីប៉ុន្មានឆ្នាំមុនម៉្លេះ ។ ព្រះរាជាអង្គនេះបានត្រូវអភិសេកក្រោមព្រះនាមថា ព្រះបាទសម្តេចព្រះបរមឥន្ទរាជាធិរាជរាមាធិបតី បរមបពិត្រ ។ ព្រះមហេសីទី១ ព្រះនាម អ្នកម្នាង មាលី បានត្រូវលើកជាព្រះអគ្គមហេសី ក្រោមឋានន្តរៈជា សម្តេចព្រះភគវតីស្រីរតន៍ នៅក្នុងឆ្នាំ១៥៥៦ ។

មួយឆ្នាំក្រោយព្រះរាជពិធីអភិសេករួចមក ព្រះរាជា បានសម្រេចព្រះទ័យ ឆ្លៀតយកឱកាសសៀមចាញ់

---

[៧៣] មានរឿងដំណាលថា ព្រះអង្គមានព្រះរាជបុត្រីមួយអង្គ ដែលបានក្លាយទៅជាព្រះមហាក្សត្រីរបស់ព្រះរាជាណាចក្រលាវ ក្រោយពីទ្រង់បានរៀបអាពាហ៍ពិពាហ៍ ជាមួយស្តេចលាវនៅវៀងច័ន្ទ ។

ដៃពួកប៉េហ្កាន ដែលវាយយករាជធានីបាន ដើម្បីដណ្តើមយកបណ្តាអាណាខែត្រខ្មែរ ដែលសៀមយកទៅ មកវិញ ។ ទ្រង់បានឲ្យកេណ្ឌទ័ព ២ម៉ឺននាក់ បែងចែកជា ២កង ដាក់ក្រោមបញ្ជាឧត្តមសេនីយ៍ ២នាក់ គឺឧកញ៉ាមហាសេនា និងឧកញ៉ាយោធាសង្គ្រាម ហើយបញ្ជាឲ្យទៅដណ្តើមយកខែត្រចកជើងសៅ (សាស្តូងសៅ-សព្វថ្ងៃគឺប៉ូទ្រីយូ) និងខែត្រនាងរង ដែលនៅជិតគ្នានោះមកវិញ ។

ក្នុងពេលជាមួយគ្នានោះ ទ័ពជើងទឹកដែលប្រមូលផ្តុំគ្នានៅខែត្រពាម (ហាទៀង) បានចុះទូកទៅកាន់មាត់សមុទ្រ ខែត្របន្ទាយប៉ុន និងរយ៉ង ស្ថិតនៅខាងត្បូងខែត្រទាំង២ខាងលើ ។

ខែត្រទាំង៤នេះ បានត្រូវដណ្តើមយកមកវិញ ដោយដុតបំផ្លាញខ្ទេចខ្ទី ហើយដាក់ឲ្យទ័ពខ្មែរមួយចំណែកនៅកាន់កាប់ថែរក្សា ។ ទ័ពខ្មែរបាននាំឈ្លើយសឹកចំនួន៧ម៉ឺននាក់ មានប្រុសស្រី និងកុមារផង យកមកបំពេញអាណាខែត្រភាគកណ្តាល ដែលសៀមបានកៀរប្រជាជនយកទៅអស់ពីមុន ។ តាមការនិយាយតៗគ្នាមកថា សង្គ្រាមពេលនោះសាហាវណាស់ ចៅហ្វាយខែត្រសៀមទាំង៤នាក់ច្បាំងការពាររហូតដល់ស្លាប់ខ្លួនក្នុងសមរភូមិ ហើយខ្មែរយើង ក៏មានខាតបង់មេទ័ពមិនតិចដែរទេ ។

នៅក្នុងឆ្នាំ១៥៦០ ព្រះរាជាកម្ពុជា បានយាងមកគង់នៅក្នុងខែត្រអង្គរ (សៀមរាប) ក្រោយពីទ្រង់បានរៀបចំកងទ័ពសាជាថ្មីរួចមក ដើម្បីបន្តការប្រយុទ្ធដណ្តើមយកទឹកដីតទៅទៀត ។ ព្រះអង្គយាងមកគង់នៅត្រង់ភូមិកំពង់ក្រសាំង ដើម្បីឲ្យបានជិតបន្តិច ងាយស្រួលនឹងធ្វើប្រតិបត្តិការ រួចទ្រង់នាំទ័ព២ម៉ឺននាក់ ចូលទៅលុកលុយខែត្រនគររាជ (កូរ៉ាត់) ដែលសៀមបានផ្តាច់ចេញពីព្រះរាជាណាចក្រ ដណ្តើមយកមកវិញ ។

រាជពង្សាវតារបាននិយាយថា នៅក្នុងឆ្នាំ១៥៦០ដដែលនោះ ស្តេចនគរលាវ ព្រះចៅក្រុងស៊ីសត្តនាក-នៈហ៊ុត ដែលសោយរាជ្យនៅវៀងច័ន្ទ បានបញ្ជូនដំរីចម្បាំងធំមួយកម្ពស់៨ហត្ថ មកឲ្យព្រះចៅក្រុងកម្ពុជា ដែលកំពុងគង់នៅបាសាន ជាទីប្រជុំជនដ៏ធំមួយ ដើម្បីឲ្យទ្រង់ជ្រើសរើសរកដំរីយកមកជល់គ្នា តាមតែព្រះទ័យ ដោយភ្នាល់ដាក់ព្រះរាជាណាចក្រទាំង២ ។ ការភ្នាល់គ្នារបៀបនេះ កើតមានញឹកញយណាស់នៅសម័យនោះ ហើយគឺជាទម្លាប់មួយនៅក្នុងបណ្តាប្រទេសនៅចុងបូព៌ា ក៏ប៉ុន្តែការភ្នាល់គ្នាដាក់ប្រទេសដោយជល់សត្វបែបនេះ ជាបញ្ហាមួយគួរឲ្យបារម្ភ ។ ទោះជាយ៉ាងណាក៏ដោយ រាជពង្សាវតារបាននិយាយថាព្រះរាជាកម្ពុជា បានយល់ព្រមតាមសំណើរបស់ព្រះរាជាលាវ ហើយបានឲ្យយកដំរីមួយក្បាលកម្ពស់៧ហត្ថ ពីលង្វែកមកជល់ជាមួយដំរីលាវ ។ ដំរីលាវជល់ចាញ់ ព្រះរាជាចាប់ដំរីនោះ និងមនុស្ស១ពាន់នាក់ ដែលហែហមមកទុកឲ្យតែមន្ត្រីលាវ ២នាក់ និងមនុស្ស១០នាក់ ត្រលប់ទៅស្រុកវិញប៉ុណ្ណោះ ។ មានឯកសារមួយនោះនិយាយថាព្រះរាជាទ្រង់ចាប់ទុកតែដំរីទេ ឯមន្ត្រី និងមនុស្ស១ពាន់នាក់ ព្រមទាំងទ្រមាក់ផង ទ្រង់ឲ្យត្រលប់ទៅវិញ ។

ដោយទ្រង់ខ្វល់នឹងបរាជ័យក្នុងការជល់ដំរី ហើយប្រហែលដោយព្រះរាជាកម្ពុជាចាប់យកដំរីផង - នេះជាការបញ្ជាក់ថា កម្មវត្ថុនៃការភ្នាល់ពេលនោះមិនមែនទឹកដីព្រះនគរទេ - ដល់ដើមឆ្នាំក្រោយមក ព្រះរាជាក្រុង

ស៊ីសត្តនាគនៈហ៊ុត (វៀងច័ន្ទ) បានចាត់ឲ្យមហាឧបរាជនាំទ័ព៩ម៉ឺននាក់ ចុះទូកតាមទន្លេមកវាយកម្ពុជា ឯព្រះរាជាបានយាងមកតាមផ្លូវគោក ជាមួយទ័ព៧ម៉ឺននាក់ ។

ទ័ពមហាឧបរាជ បានមកជួបប្រយុទ្ធជាមួយទ័ពព្រះសត្ថា រាជបុត្ររបស់ព្រះរាជាកម្ពុជា ហើយត្រូវវាយឲ្យបរាជ័យ នៅព្រែកប្រសព្វ ក្នុងខេត្តស្រីសន្ធរ ថ្វីបើព្រះសត្ថាមានទ័ពតែ២ម៉ឺននាក់ប៉ុណ្ណោះក្តី ។ ចំណែកឯទ័ពរបស់ព្រះរាជាលាវ ដែលចុះមករហូតដល់ភ្នំសន្ទុកក្នុងដីកំពង់ស្វាយ ក៏ត្រូវទ័ពខ្មែរ២កងវាយឲ្យបរាជ័យដែរ គឺទ័ពមួយកង ជាទ័ពរបស់អ្នកអគ្គម្ចាស់ ស្រីសុរិយោពណ៌ ដែលទ្រង់កេណ្ឌនៅក្នុងខេត្តនគរវត្ត និងកំពង់ស្វាយ, និងទ័ពមួយកងទៀតជាទ័ពរបស់ព្រះរាជា ដែលកេណ្ឌមកពីខេត្តសំរោងទង រលាប្អៀរ និងពោធិសាត់ ។ ទ័ពខ្មែរប្រមូលបានដ័យភណ្ឌ និងចាប់ឈ្លើយបានជាច្រើន ។ ឈ្លើយទាំងអស់នោះបានត្រូវនាំយកមកដាក់នៅខេត្តបារាយណ៍ និងជើងព្រៃ ក្រោមការត្រួតត្រារបស់មន្ត្រីលាវម្នាក់ឈ្មោះថា សែនខាងហ៊ុវភាសា (សៀមថា ខាងយួរ) ។ ក្នុងសង្គ្រាមនោះ មានពួកលាវជាច្រើនដែលរត់ចោលជួរ បានត្រូវអ្នកស្រុកសម្លាប់ ។ ព្រះរាជា និងមហាឧបរាជលាវ ក៏វិលត្រលប់ទៅនគរវិញទៅ ។

សង្គ្រាមជាមួយលាវមិនទាន់ចប់សព្វគ្រប់ផង ពួកសៀមក៏តាំងចាប់ផ្តើមចូលលុកលុយខេត្ត៤ ដែលព្រះរាជាកម្ពុជាដណ្តើមយកក្នុងចន្លោះឆ្នាំ១៥៥៧ដល់១៥៦០ ដោយបណ្តេញចៅហ្វាយខេត្ត និងទ័ពខ្មែរចេញអស់ ។ ព្រះរាជាខ្មែរ បាននាំទ័ព៧ម៉ឺននាក់ យាងទៅដណ្តើមយកខេត្តចន្ទគាប៊ុនមកវិញ រួចបន្តទៅដណ្តើមយកខេត្តសុធនរាជ ពេជ្របុរី ច័ន្ទបុរី និងសុខនរាជធានី[៧៨] ថែមទៀត ។ ចៅហ្វាយខេត្តសៀម បានត្រូវសម្លាប់នៅក្នុងពេលប្រយុទ្ធ ។ ក៏ប៉ុន្តែដល់មកឆ្នាំក្រោយ ទ័ពដែលនៅការពារខេត្តទាំងអស់នោះ បានត្រូវទ័ពសៀមដេញឲ្យរត់ខ្ចាត់ខ្ចាយអស់ ។

សង្គ្រាមនៅបន្តមកជាច្រើនឆ្នាំទៀត រហូតដល់ស្តេចសៀមស្នើសុំឲ្យមានសន្តិភាព ដែលព្រះរាជាខ្មែរ បានយល់ព្រមនៅក្នុងឆ្នាំ១៥៦៤ ។

នៅឆ្នាំ១៥៦៦ ស្តេចលាវបានកេណ្ឌទ័ព២ម៉ឺននាក់ ឲ្យមហាឧបរាជនាំចុះទូកប្រណាំងមកវាយកម្ពុជាម្តងទៀត ។ ព្រះរាជាកម្ពុជា បាននាំទ័ព៩ម៉ឺននាក់ទៅកាត់ទ័ពលាវ ជួបគ្នានៅលើកោះចៅរាម ទល់មុខនឹងរកាកោងចម្ងាយ៣៨គមពីខាងជើងភ្នំពេញ ហើយវាយពួកនោះឲ្យបរាជ័យនៅត្រង់នោះ ។ ទូកពួកលាវ បានត្រូវបំផ្លាញខ្ទេចខ្ទី ពួកលាវណាដែលគេចខ្លួនរួចពីការកាប់សម្លាប់រង្គាល ត្រូវដើរជាក្រុមតូចៗត្រលប់ទៅវិញ តែត្រូវអ្នកស្រុកតាមដេញវាយតទៅទៀត ។

---

[៧៨] ឈ្មោះខេត្តទាំងអស់នេះជាភាសាសៀមគឺ ភេតសាបុរី ភេតចប៊ុន ភេតចបុរី និងច័ន្ទគាប៊ុន ។

ព្រះបរមឥន្ទរាជា បានសុគតទៅនៅក្នុងឆ្នាំបន្ទាប់ គឺឆ្នាំ១៥៦៧ ក្នុងព្រះជន្មាយុ៥៦ព្រះវស្សា ក្រោយពីទ្រង់សោយរាជសម្បត្តិបាន២ឆ្នាំ ។ ព្រះរាជបុត្រារបស់ព្រះអង្គ ព្រះជ័យចេស្ដា ទើបនឹងចុះសន្ធិសញ្ញាជាមួយសៀម ដែលកំណត់ព្រំប្រទល់ទឹកដីព្រះរាជាណាចក្រទាំង២ដោយបោះបង្គោលចំណាំ បង្គោលមួយបោះនៅត្រង់វត្តស្រះកេត ។

## ២០- ព្រះបរមឥន្ទរាជាទី២ (១៥៦៧-១៥៧៥)

ព្រះសត្ថា ជារាជបុត្រារបស់ព្រះបរមឥន្ទរាជា បានត្រូវនាម៉ឺនសព្វមុខមន្ត្រី និងព្រះរាជវង្សានុវង្ស ជ្រើសរើសឲ្យឡើងសោយរាជសម្បត្តិបន្តពីព្រះរាជវរបិតា ក្រោមព្រះនាមថា ព្រះបាទសម្តេចព្រះបរមឥន្ទរាជាធិរាជរាមាធិបតីបរមបពិត្រ ព្រះរាជានៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះជនាយុ២៥ព្រះវស្សា[៧៥] ។ ព្រះមហេសីទី១របស់ព្រះអង្គ អ្នកម្នាងពៅ បានត្រូវអភិសេកឲ្យឡើងជាព្រះមហាក្សត្រី មានព្រះនាមថា សម្តេចព្រះភគវតីស្រីចក្រពោធិរាជ ។ ព្រះអនុជរបស់ព្រះអង្គ ព្រះស្រីសុពណ៌ ព្រះជន្មាយុ១៩ព្រះវស្សា បានត្រូវតែងតាំងឲ្យធ្វើជាព្រះឧបរាជ ។

ក្រោយពិធីរាជាភិសេកព្រះរាជាកម្ពុជាបានប៉ុន្មានខែ មានដំណឹងលេចឮឡើងថា ស្តេចនគរហង្សាវតី ឬប៉េហ្គាន ប៉ាគូ (បារគូ) បានចូលលុកលុយព្រះរាជាណាចក្រសៀម មកដល់រាជធានីអយុធ្យា ជាមួយទ័ពមួយកងធំ ។ ដោយផ្អែកលើសន្ធិសញ្ញាដែលបានចុះហត្ថលេខាជាមួយគ្នា កាលពីឆ្នាំកន្លងទៅជាមួយព្រះរាជាខ្មែរ ដែលទើបនឹងសុគតទៅ ស្តេចសៀមបានផ្ញើរាជទូតមកសុំជំនួយពីព្រះរាជាក្មេង ដែលទើបតែឡើងសោយរាជ្យ ។ ព្រះរាជាអាចនឹងមិនគោរពសន្ធិសញ្ញដែលព្រះបិតាបានចុះហត្ថលេខា ក៏ប៉ុន្តែ ព្រះអង្គបានសម្រេចបញ្ជូនទ័ព២ម៉ឺននាក់ ទៅជួយក្រុងអយុធ្យា ។ ទ័ពប៉េហ្គាន ក៏ចាញ់ ហើយត្រូវវិលត្រលប់ទៅនគរវិញ ។

នៅពេលដែលទ័ពសៀម និងទ័ពខ្មែរវិលត្រលប់មកពីសង្គ្រាមវិញប្រកបដោយជោគជ័យ ហើយបោះជំរំសម្រាកនៅជិតគ្នាត្រង់ដើមពោធិដើងបី ស្តេចសៀមព្រះនរេនសូរ (ព្រះណារេត) បានសង្កេតឃើញថា មហាឧបរាជខ្មែរដែលអង្គុយនៅមុខព្រះអង្គ មិនបានក្រាបបង្គំដូចជានាម៉ឺនសព្វមុខមន្ត្រីឯទៀតទេ ។ ទ្រង់ បានមានព្រះបន្ទូលធ្វើការកត់សម្គាល់លើបញ្ហានេះជាសាធារណៈ នៅចំពោះសេនាបតីទាំងឡាយ ។ ពេលនោះ ព្រះមហាឧបរាជ មានបន្ទូលតបទៅវិញថា «ទូលបង្គំមកនេះក្នុងនាមព្រះរាជាកម្ពុជា ហើយក៏ជាអគ្គមេបញ្ជាការលើកងទ័ពខ្មែរទាំងមូល ដែលព្រះរាជាបានប្រគល់ឲ្យនាំមកផងដែរ ។ ម្យ៉ាងទៀត ទូលព្រះបង្គំជារាជវង្ស ហើយជាមហាឧបរាជទៀតផង ទូលព្រះបង្គំគួរតែត្រូវបានព្រះរាជាសៀមឲ្យតម្លៃ ហើយទទួលស្គាល់ ចាត់ទុកក្នុងឋានៈជាមេ

[៧៥] ព្រះអង្គទ្រង់ប្រសូត្រនៅក្នុងឆ្នាំ១៥៤៣ ជាបុត្ររបស់អ្នកម្នាងមាលី ។

បញ្ជាការកងទ័ព ដូចជាព្រះអង្គដែរ» ។ ស្តេចសៀមនៅស្ងៀមមិនតបតអ្វីទេ ក៏ប៉ុន្តែដើម្បីបង្ហាញឲ្យឃើញថា ព្រះអង្គជាមេតែម្នាក់គត់នៅទីនេះ ទ្រង់បានបញ្ជាឲ្យគេនាំយកឈ្លើយសឹកម្នាក់ ដែលព្រះមហាឧបរាជខ្មែរចាប់បានយកមកកាត់ក្បាល រួចឲ្យយកទៅដោតលើចុងឫស្សីនៅនឹងមុខសំពៅព្រះមហាឧបរាជ ។ ព្រះមហាឧបរាជខ្ញាល់ខ្ញាំងណាស់ ក៏ចេញសំពៅត្រលប់មកកម្ពុជាវិញភ្លាម ។ ពេលយាងមកដល់លង្វែកវិញ ព្រះអង្គបានរាយការណ៍អំពីការប្រមាថរបស់ស្តេចសៀមថ្វាយព្រះរាជា ព្រមទាំងបានសំណូមពរឲ្យលុបសន្ធិសញ្ញា ដែលបានចុះហត្ថលេខានៅអយុធ្យាចោល នៅពេលចប់រដូវវស្សាខាងមុខ ។

ដល់ពេលពួកប៉េហ្គានចូលមកលុកលុយស្រុកសៀមម្តងទៀត ពួកមេទ័ពខ្មែរបានទទួលការអនុញ្ញាតពីព្រះរាជា ឲ្យចេញទៅធ្វើសង្គ្រាមជាមួយសៀម ជួយស្តេចនគរហង្សាវតីដណ្តើមយកស្រុកសៀម ។ ពលទាហាន១ម៉ឺននាក់ ដែលស្ថិតនៅក្រោមបញ្ជាការរបស់លោក ចៅហ៊្វាទល្ហៈ បានចេញដំណើរទៅតាមផ្លូវលំពែងហ្វាយ ទៅវាយដណ្តើមយកខែត្របស្ចិមបុរី និងនគរនាយក ប៉ុន្តែទ័ពនេះធ្វើដំណើរទៅមុខលឿនពេក ក៏ដាច់នៅតែឯង ។ ពេលបានជួបជាមួយទ័ពសៀម២កង ដឹកនាំដោយពញា ស៊ីសាយណារ៉ុង និងពញា ស៊ីរាជតេជោ ទ័ពនីមួយៗ មានគ្នា១ម៉ឺននាក់ ចៅហ៊្វាទល្ហៈ ត្រូវវាយឲ្យដកថយចូលមកក្នុងកម្ពុជាវិញ ។

នៅឆ្នាំ១៥៧៥[៧៦] ដើម្បីធានាថារាជសម្បត្តិស្ថិតនៅក្នុងដៃព្រះរាជបុត្ររបស់ព្រះអង្គ ព្រះរាជា បានលើកព្រះអនុជឧបរាជ ឲ្យឡើងទៅជាទីឧភយោរាជ ដើម្បីឲ្យទ្រង់បាត់បង់សិទ្ធិជាអ្នកស្នងរាជ្យ ពីព្រោះថា តាមធម្មតាព្រះអនុជដែលជាឧបរាជ តែងតែឡើងសោយរាជ្យបន្តពីព្រះរៀមជានិច្ច រួចហើយព្រះអង្គ បានលើកព្រះរាជបុត្របួនព្រះនាមចៅពញាតន់ ដែលទើបតែមានព្រះជន្ម៦ព្រះវស្សា ប៉ុណ្ណោះ ឲ្យធ្វើជាឧបរាជវិញ ។ បន្ទាប់មក ព្រះអង្គក៏ដាក់រាជសម្បត្តិឲ្យព្រះរាជបុត្រច្បងព្រះនាមថា ព្រះជ័យជេដ្ឋា ដែលទើបតែមានព្រះជន្ម ១០ ព្រះវស្សាប៉ុណ្ណោះ ។

## ២១- ព្រះជ័យជេដ្ឋាទី១ (១៥៧៦-១៥៨៧)

ព្រះជ័យជេដ្ឋា បានទទួលព្រះរាជពិធីរាជាភិសេកនៅក្នុងឆ្នាំ១៥៧០ ក្រោមព្រះនាមថា ព្រះជ័យជេដ្ឋាធិរាជ បរមបពិត្រ ប៉ុន្តែកិច្ចការគ្រប់គ្រងព្រះនគរស្ថិតនៅលើព្រះបិតានៅឡើយ ។

---

[៧៦] លោក កាបាតុង បាននិយាយថា កាលបរិច្ឆេទនេះមិនត្រឹមត្រូវ ។ តែខ្ញុំគិតថាមិនខុសទេ ពីព្រោះ ព្រះជ័យជេដ្ឋា ទ្រង់ប្រសូត្រនៅក្នុងឆ្នាំ១៥៦៤ ហើយពញា តន់ ប្រសូត្រនៅក្នុងឆ្នាំ១៥៦៨ ។ បើសិនជា ព្រះសត្ថា លើករាជបុត្រទាំង២ មួយឲ្យឡើងសោយរាជ្យក្នុងព្រះជន្ម១០ឆ្នាំ មួយឲ្យធ្វើជាឧបរាជក្នុងព្រះជន្ម៦ឆ្នាំ ពេលនោះវាត្រូវនឹងឆ្នាំ១៥៧៥ នេះឯង លើកលែងតែឆ្នាំកំណើតនោះវាខុស ។

ការដែលព្រះរាជាដាក់រាជសម្បត្តិ ហើយលើកព្រះរាជបុត្រជ័យជេដ្ឋាឲ្យឡើងសោយរាជសម្បត្តិ យ៉ាងនេះបានធ្វើឲ្យព្រះឧភយោរាជ និងនាម៉ឺនសព្វមុខមន្ត្រីជាច្រើនមានការអាក់អន់ស្រពន់ចិត្តជាខ្លាំង ពីព្រោះ បើតាមទំនៀមពីបុរាណ គឺពួកគេនេះឯង ដែលជាអ្នកមានសិទ្ធិក្នុងការជ្រើសតាំងព្រះរាជា ។ ពួកគេមិនហ៊ាន ប្រឆាំងតវ៉ាដោយចំហទេ ក៏ប៉ុន្តែបានចាប់ព្រងើយកន្តើយ មិនយកចិត្តទុកដាក់ដល់កិច្ចការរាជការ ចាប់តាំងតែពីពេលនោះមកជាហេតុធ្វើឲ្យកើតមានអនាធិបតេយ្យទូទាំងប្រទេស ហើយព្រះរាជាដាក់រាជ្យត្រូវបង្ខំព្រះទ័យលះបង់ខេត្តច័ន្ទបុរី និងនគររាជសីមា ដែលទើបតែដណ្តើមបាន ឲ្យទៅសៀមវិញ ។

ព្រះរាជាក្រុងអយុធ្យា នៅពេលដែលទទួលដំណឹងថា ព្រះរាជាណាចក្រកម្ពុជា កើតមានការច្របូកច្របល់ហើយ នាម៉ឺនសព្វមុខមន្ត្រីមិនស្ដាប់បញ្ជារបស់ព្រះរាជា រដ្ឋមន្ត្រីទាំងឡាយក៏ក្លាយទៅជាអសកម្ម ក៏ចាត់ឲ្យកេណ្ឌទ័ព១០ម៉ឺននាក់ សេះ១៨៥០ក្បាល ដំរី៨០០ក្បាល នាំមកវាយកម្ពុជា ។ ទ័ពស្រួច មានពល៥ពាន់នាក់បញ្ជាដោយឧត្តមសេនីយ៍ខ្លាំងពូកែម្នាក់ឈ្មោះថា ព្រះរាជានូ ។

តបតទៅនឹងទ័ពសៀមនេះ ព្រះរាជានុសិទ្ធិ បានរៀបចំទ័ព ៣ម៉ឺន៥ពាន់នាក់ នៅក្នុងខេត្តបាត់ដំបង ក្នុងនោះមានទ័ព១ម៉ឺននាក់កេណ្ឌមកពីខេត្តបារាយណ៍ និងជើងព្រៃ និង១ម៉ឺននាក់ទៀតជាទ័ព ដែលចៅហ្វាយខេត្តពញាសួគ៌ាលោកជ្រើសរើសបានក្នុងខេត្តពោធិសាត់ ។ ពញាតេជោ ចៅហ្វាយខេត្តកំពង់ស្វាយ មានទ័ព ៣ម៉ឺននាក់នៅនឹងអតីតរាជធានី, ទ័ព២ម៉ឺននាក់ជ្រើសរើសនៅក្នុងខេត្តកំពង់ស្វាយ និងទ័ព ១ម៉ឺននាក់ទៀត ជ្រើសរើសនៅនឹងអង្គរវត្ត[៧៧] ។ ឯព្រះឧភយោរាជ កាន់ទ័ពដែលជ្រើសរើសមកពីរលាប្អៀរ ២ម៉ឺននាក់ និងមកពីបរិបូណ៌១ម៉ឺននាក់ ។

ព្រះរាជាជ័យជេដ្ឋា បានយាងទៅកាន់ខេត្តសំរោងទង បាទី និងខេត្តនៅខាងត្បូងភ្នំពេញ ដើម្បីជ្រើសរើសទ័ពដែរ ។

នៅពេលដែលខ្មែរកំពុងតែជ្រើសរើស និងរៀបចំទ័ពដូច្នេះ ស្ដេចសៀមបានចូលមកដណ្តើមយកខេត្តពោធិសាត់បាន រួចហួសមកបោះជំរំនៅពីមុខបរិបូណ៌ ឡោមព័ទ្ធទ័ពព្រះឧភយោរាជជាប់ ហើយបន្តមក វាយយកលង្វែកទៀត ។ សៀមព័ទ្ធទីក្រុងលង្វែកនេះ៣ខែ ទើបព្រះរាជាជ័យជេដ្ឋា ពញាអន ហើយនិងមន្ត្រី ១០នាក់ទៀតដែលចេញទៅជ្រើសរើសទ័ពនៅក្នុងបណ្តាខេត្តខាងត្បូង ខាងកើត និងខាងជើង នាំទ័ពមកដល់ ក៏វាយសង្គ្រុបទៅលើទ័ពសៀមឲ្យបរាជ័យ ដកថយទៅស្រុកវិញទៅ ។ សង្គ្រាមនេះ បានកេណ្ឌមនុស្សដែលមានកាយសម្បទាល្អស្ទើរតែអស់រលីងពីក្នុងព្រះរាជាណាចក្រ ខ្លះឲ្យចូលធ្វើទាហាន ខ្លះទៀតឲ្យបររទេះដឹកស្បៀង មានតែតិចតួច

[៧៧] ខេត្តនេះជួនកាលគេហៅថាអង្គរ ជួនកាលថានគរសៀមរាបថា អង្គរវត្ត និងជួនកាលទៀតហៅថា សៀមរាប ។

ប៉ុណ្ណោះដែលគេចរត់ចូលពួនក្នុងព្រៃ ។ ចប់សង្គ្រាម ប្រទេសជួបប្រទះនឹងគ្រោះទុរ្ភិក្សយ៉ាងខ្លាំង ហើយថែមទាំងមានកើតជំងឺអាសន្នរោគទៀតផង ។

ប្រទេសពេលនោះជួបគ្រោះចង្រៃកាន់តែខ្លាំងថែមទៀត ដោយព្រះរាជាដាក់រាជ្យបានធ្លាក់ខ្លួន ទៅជាឆ្កួតហើយរករឿងតែជាមួយព្រះពុទ្ធរូប ។ នៅលង្វែក ព្រះអង្គបានបញ្ជាឲ្យគេយកព្រះពុទ្ធរូបជាច្រើនព្រះអង្គបោះចូលទៅក្នុងទឹក ។ មានព្រះសង្ឃសៀម២អង្គ ព្រះនាមទិក្ខណៈបញ្ញោ និងសុរៈបញ្ញោ បានមើលជំងឺព្រះរាជាឲ្យសះជាមកវិញ ក៏ប៉ុន្តែប្រជានុរាស្ត្របានចោទព្រះសង្ឃទាំង២អង្គនោះ ថាជាអ្នកធ្វើអំពើឲ្យព្រះរាជាឆ្កួត និងធ្វើឲ្យព្រះនគរកើតវិបល្លាស ក៏នាំគ្នាបណ្តេញព្រះសង្ឃទាំង២អង្គនោះទៅវិញ ។

ប្រជារាស្ត្រកើតមានការព្រួយបារម្ភច្របូកច្របល់ជាខ្លាំង ហើយវិបត្តផ្លូវស្មារតីធ្វើឲ្យគេគិតថានឹងកើតមានភយន្តរាយជាមិនខាន ។ យ៉ាងណាមិញ គេនិយាយថា ទឹកជ្រោះស័ក្តិសិទ្ធិនៅភ្នំបាណន់ក្នុងខេត្របាត់ដំបងរីងខះ លែងហូរ អាងដែលធ្លាប់តែទទួលទឹកជ្រោះនោះពេញៗស្រាប់តែបែរជារីងស្ងួតអស់ ។ ព្រះខ័នរាជ្យរបស់អតីតក្សត្រវង្សវរ្ម័នដែលគេបានរកឃើញនៅក្នុងរន្ធដើមចំបក់ នៅក្នុងខេត្របាទីហើយនាំយកមកលង្វែកវិញចេញច្រែះ ពួកបារគូដែលថែរក្សាដុសខាត់យ៉ាងណាក៏មិនជ្រះ ហើយមានឈាមហូរចេញពីដើមទ្រូងប្រេះស្រាំរបស់ព្រះពុទ្ធរូបមួយអង្គនៅវិហារស្នួគ៌ ។ និមិត្តសញ្ញាទាំងអស់នេះបញ្ជាក់ថាស្រុកកើតទុរ្ភិក្ស មានជំងឺអាសន្នរោគធ្វើឲ្យមនុស្សស្លាប់អស់ស្ងាត់ស្រុក ហើយប្រជារាស្ត្រកើតមានកំហឹងឈឺ ចាប់កាន់តែខ្លាំងឡើងៗ ធ្វើឲ្យបាក់ទឹកចិត្តនិងស្មារតីអស់រលីង ។

នៅពេលនោះ នៅក្នុងរាជធានីមានពួកអេស្ប៉ាញ៉ុល និងព័រទុយហ្គេ[៧៨] ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះសត្ថា ។ ព្រះរាជាការពារ ហើយទុកចិត្តពួកនោះណាស់ រហូតទាល់តែទ្រង់ប្រទានប្អូនស្រីជីដូនមួយ មួយអង្គឲ្យជនព័រទុយហ្គេ ឈ្មោះ ឌីយ៉ូ ហ្គោបែឡូសូ ធ្វើជាភរិយា ។ ពួកនាម៉ឺនសព្វមុខមន្ត្រី មិនពេញចិត្តនឹងពួកនេះទេ ព្រោះគេខ្លាចពួកនេះ ប្រើឥទ្ធិពលមកលើព្រះរាជា ណាមួយពួកនេះជាពួកស្បែកសផង ។

[៧៨] ពួកអឺរ៉ុបដែលមកកាន់កម្ពុជាមុនគេ គឺពួកសាសនទូតលីការដូសូ និងចាវម៉ាដេរ៉ូ មកដល់ក្នុងឆ្នាំ១៥៥៣ ។ បន្ទាប់មក គឺអ្នកផ្សព្វផ្សាយសាសនាដូមីនីកាំងសញ្ជាតិអេស្ប៉ាញ៉ុលឈ្មោះ ហ្គាស្ប៉ាដាគ្រូស បានមកដល់ក្នុងឆ្នាំ១៥៦០ ។ លោកឪពុក ជនហ្គុងសាឡេសដឺម៉េងដូហ្សូ បាននិយាយនៅក្នុងលិខិតមួយដែលគេបោះពុម្ពនៅទីក្រុងរ៉ូមក្នុងឆ្នាំ១៥៨៥ ថា មានអ្នកផ្សព្វផ្សាយសាសនា ដូមីនីកាំងសញ្ជាតិព័រទុយហ្គេមួយរូបឈ្មោះបងប្រុសស៊ីលវើស មានឥទ្ធិពលមកលើរាជវាំងស្តេចកម្ពុជាសម័យនោះខ្លាំងណាស់ ។ តាមពិតបេសកកម្មផ្សព្វផសាយសាសនាកាតូលិកមកក្នុងកម្ពុជា មាននៅឆ្នាំ១៥៨១ទេ ក៏ប៉ុន្តែអាចនឹងមានពួកអឺរ៉ុបខ្លះបានមកដល់មុន ដូចដែលលោកកាបាតុងបាននិយាយថា មកពីម៉ាឡាកា ឬមកពីស្រុកសៀម មុនពេលដែលពួក “អ្នករុករកដែលគោរពបូជាសាសនា” មកដល់ ។

បានជាព្រះរាជាស្រឡាញ់ និងគាំទ្រ ព្រោះពួកនេះដឹងរឿងរ៉ាវកិច្ចការព្រះនគរច្រើន ជាពិសេសគឺដឹងថា ស្ដេចសៀម ដែលបរាជ័យក្នុងការវាយយកកម្ពុជាម្ដងហើយនៅឆ្នាំ១៥៨១ ហើយនឹងរៀបចំប្រុងធ្វើសង្គ្រាមសាជាថ្មី ហើយថាសង្គ្រាមលើកនេះធំជាងលើកមុន ម្យ៉ាងទៀតពួកនេះ មានគំនិតចង់ដាក់ព្រះរាជាណាចក្រកម្ពុជា នៅក្រោមអាណាព្យាបាលរបស់នគរអេស្ប៉ាញ ដែលទើបតែដណ្ដើមយកព័រទុយហ្គាល់បាន នៅក្នុងឆ្នាំ១៥៧៨ ពួកព័រទុយហ្គេទាំងអស់នោះ បានថ្វាយយោបល់ដល់ព្រះរាជា ឲ្យព្រះអង្គចាត់ ឌីយ៉ូហ្គោបែឡូសូ ធ្វើដំណើរទៅទីក្រុងម៉ានីល ជាមួយពួកអេស្ប៉ាញ៉ុលឈ្មោះ ប្លាវ៉ូជីហៃណាន់ ហ្គុងសាឡេស, អង់តូនីញ៉ូម៉ាសាដូ និងប៉ង់តាឡេអុងការនៃរ៉ូ ដើម្បីសុំជំនួយពីអភិបាលប្រទេសហ្វីលីពីន មកទប់ទល់ជាមួយនឹងពួកសៀម ដែលប៉ុនប៉ងវាយព្រះរាជាណាចក្រ (១៥៩០) ។ ព្រះរាជសារលិខិតដែលព្រះរាជាកម្ពុជា បានប្រគល់ឲ្យពួកនោះកាន់យកទៅ មានខ្លឹមសារអួតអាងថា ព្រះរាជាណាចក្រកម្ពុជាជាមហាអំណាចមួយ ព្រះរាជាសព្វព្រះទ័យនឹងសាសនាកាតូលិកណាស់ សូមឲ្យលោកអភិបាល ហ្គោម៉េពេរ៉េដាសម៉ារីញ៉ា បញ្ជូនព្រះសង្ឃកាតូលិកមួយចំនួន ដើម្បីផ្សព្វផ្សាយសាសនាដល់អ្នកស្រុក និងសុំឲ្យផ្ដល់ទាហានមកជាមួយឲ្យបានច្រើនផង ដើម្បីជួយការពារ ។ រាជទូតរបស់ព្រះសត្ថា បានទៅដល់ទីក្រុងម៉ានីល នៅក្នុងឆ្នាំ១៥៩០ ក៏ប៉ុន្តែ មិនបានអ្វីយកមកវិញទេ ពីព្រោះអភិបាលហ្វីលីពីន កំពុងរៀបចំចេញធ្វើប្រតិបត្តិការវាយយកប្រជុំកោះម៉ូលុក ប្រតិបត្តិការដែលធ្វើឲ្យអភិបាលនោះ និងពលទាហានស្លាប់បាត់បង់អស់[៧៩] ។ ពួកឌីយ៉ូហ្គោបែឡូសូ កំពុងតែនៅហ្វីលីពីននៅឡើយទេ ដល់មកឆ្នាំ១៥៩៣ នៅពេលដែលស្ដេចសៀម ព្រះណារេត ហៅស្ដេចខ្មៅ បានដឹកនាំទ័ព១០ម៉ឺននាក់ មានដំរី៨រយ សេះ១ពាន់៥រយ ចែកចេញជាច្រើនកង ដឹកនាំដោយឧត្តមសេនីយ៍ដ៏អង់អាច មកវាយយកកម្ពុជា ។

តើព័ត៌មានស្ដីអំពីអរិភាពនេះ បានផ្សព្វផ្សាយទៅដល់ទីក្រុងម៉ានីល ហើយជំរុញឲ្យអភិបាលក្រុងនេះសម្រេចចិត្តផ្ដល់ជំនួយឲ្យកម្ពុជា ដែលមិនបានផ្ដល់ភ្លាមៗតាមការសន្យា ឬដូចម្ដេច? គេមិនបានដឹងថា ការពិតយ៉ាងណាទេ ក៏ប៉ុន្តែគេដឹងថា ឌីយ៉ូហ្គោបែឡូសូ បានទទួលលិខិតរបស់លោកអភិបាលក្រុងម៉ានីល មួយច្បាប់ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៥៩៣ ទូលព្រះរាជាកម្ពុជាថា ខ្លួនសូមធ្វើជាអាជ្ញាកណ្ដាលនៅក្នុងជម្លោះជាមួយស្រុកសៀម ។ នៅពេលដែលឌីយ៉ូហ្គោបែឡូសូ និងមិត្តភក្តិរបស់គេត្រលប់មកដល់កម្ពុជាវិញ រាជធានីលង្វែក បានធ្លាក់ទៅក្នុងកណ្ដាប់ដៃសៀមជាច្រើនសប្ដាហ៍រួចទៅហើយ ។

---

[៧៩] លោកអភិបាលស្រុកហ្វីលីពីន ហ្គោម៉េពេរ៉េដាសម៉ារីញ៉ា បានដឹកនាំប្រតិបត្តិការនោះដោយផ្ទាល់ ក៏ប៉ុន្តែ ត្រូវពួកចិនដែលគេចាប់បង្ខំឲ្យមកចែវទូកឲ្យបះបោរប្រឆាំងឡើងនៅកណ្ដាលសមុទ្រ ដោយកាប់សម្លាប់ទាំងលោកអភិបាល នាយទាហាន និងពួកអេស្ប៉ាញ៉ុលចោលអស់ រួចហើយនាំយកសំពៅមកចូលចតនៅអាណ្ណាមវិញ ។

តើមានហេតុការណ៍អ្វីកើតឡើងខ្លះ? តទៅនេះ គឺជារឿងរ៉ាវដែលឯកសារកម្ពុជា ដែលខ្ញុំមានបានរៀបរាប់ ។

មុនដំបូង ទ័ពសៀមដណ្ដើមយកខែត្រគូរ៉ាត់ រួចហើយនៅសម្រាកនៅទីនោះចំនួនពីរបីថ្ងៃ រើសទ័ពនៅទីនោះបាន១ម៉ឺននាក់ ថែមទៀត ។ បន្ទាប់មក គេចេញដំណើរតាមផ្លូវស្ពានទិព្វ មកដើរលើស្ពានធ្វើអំពីថ្មមួយ ឆ្លងស្ទឹងឈ្មោះថា ស្ពានត្រែង រួចចូលមកដល់អង្គរវត្ត (សៀមរាប) ទើបចុះសំពៅចំនួន២៥០ ឆ្លងបឹងទន្លេសាប មកដណ្ដើមយកខែត្រកំពង់ស្វាយ ។ មានទ័ពជើងទឹក២រយសំពៅទៀត ដែលគេកេណ្ឌនៅក្នុងខែត្រនគរស្រីធម្មរាជ ពាតឆ្លោង សាអាងខ្លា និងឆាយា ផ្ទុកពលទាហាន២ម៉ឺននាក់ បានមកឡើងនៅខែត្របាសាក់ (សព្វថ្ងៃគឺមណ្ឌលសុកត្រាំង នៅកូសាំងស៊ីន) ។ ទ័ពមួយកងទៀតមានពួកចាម ប្រហែល (ជាពួកម៉ាឡេ ទេ ទើបសម) ១ម៉ឺននាក់ ក្រោមបញ្ជារបស់ឧត្តមសេនីយ៍សៀមឈ្មោះ ពញារាជវង្សា ចុះសំពៅ១៥០ មកដណ្ដើមយកខែត្របន្ទាយមាស ។ ទ័ពទាំងអស់នេះចាប់ធ្វើសកម្មភាពព្រមៗគ្នា នៅក្នុងខែធ្នូ ។

ព្រះរាជាជាក់រាជ្យ បានសម្រេចចេញទប់ទល់ជាមួយទ័ពសៀម ដែលដឹកនាំដោយព្រះណារេត ហើយបានចាត់ឲ្យព្រះឧភយោរាជ យាងទៅតាំងទ័ព នៅអមរាទិ (បរិបូណ៌) ដែលមានកំពែងដី[៨០] មាំទាំគ្រាន់បើ ។ ពញាអន និងពញាជិនចាន់តុក ដឹកនាំទ័ពទៅកាន់ខែត្របន្ទាយមាស ឯព្រះរាជាជ័យជេដ្ឋាយាងទៅបាភ្នំ បំបះបំបោរប្រជាជនប្រឆាំងនឹងសត្រូវ ។ ពញាបវរនាយកទៅតាំងទ័ពនៅក្នុងខែត្របាត់ដំបង ។

មួយចំណែកទៀត លោកក្រឡាហោមដឹកនាំទ័ពជើងទឹកមួយកង នៅរក្សាដែនទន្លេធំខាងកើត ហើយលោកវិបុលរាជ នៅរក្សាដែនទន្លេធំខាងលិច ។ កងទី១មានទូក២៥០ កេណ្ឌមកពីបណ្ដាខែត្រខាងត្បូង ឯកងទី២ មានទូក ២០០ កេណ្ឌមកពីខែត្រនគរស្រីធម្មរាជ ពាតឆ្លោង សាអាងខ្លា និងឆាយាដែរ ។ លើសពីនោះ នៅមានរទេះដឹកស្បៀងទ័ពចំនួន ២ពាន់គ្រឿង ថែមទៀត ។ គេនិយាយថាទ័ពជើងទឹក ពួកអុំទូក និងពួកបររទេះ មានគ្នាទាំងអស់ ២ម៉ឺននាក់ ។

ប៉ុន្តែ បើទោះជាខិតខំប្រឹងពង្រាយទ័ពយ៉ាងនេះក្ដី ក៏ទ័ពខ្មែរត្រូវទទួលបរាជ័យនៅគ្រប់សមរភូមិ ។ ឧត្តមសេនីយ៍ ជិនចិនតុក បានត្រូវខ្មាំងសម្លាប់បាននៅបន្ទាយមាស ហើយជំនួសដោយអ្នកអង្គម្ចាស់អន ។ តែត្រង់ចំណុចនេះ ទ័ពសត្រូវបានត្រូវរុញច្រានឲ្យថយក្រោយរហូតដល់ខែត្រស្រីសន្ធរ នៅលើទន្លេធំ នៅពីខាងត្បូងភ្នំពេញ ។ ឯខែត្រទ្រាំង បាសាក់ បន្ទាយមាស និងគយកំពង់ក្របី សៀមដណ្ដើមយកបាន ។ នៅខាងជើងឯណោះវិញ សៀមដណ្ដើមយកបានខែត្របាត់ដំបង និងអង្គរវត្ត ហើយឡោមព័ទ្ធអមរាទិ (បរិបូណ៌) ដែល

[៨០] នោះគឺជាកំពែងរបស់រាជធានីចាស់ ដែលគេបានបោះបង់ចោលនៅក្នុងឆ្នាំ១៥២៦ ។

មានព្រះឧភយោរាជគង់នៅ ។ ព្រះឧភយោរាជ មិនចង់បោះបង់ទីតាំងនេះឲ្យសត្រូវទេ ប៉ុន្តែដល់បានទទួលដំណឹងថា ព្រះរាជា និងព្រះរាជបរិពារ បានគេចខ្លួនចេញពីរាជធានីហើយ ទ្រង់ក៏វាយបើកផ្លូវឆ្លងកាត់ទ័ពសៀមចេញទៅជួយលង្វែក ។ ទ្រង់មានព្រះតម្រិះថា បើចង់ឈ្នះ គឺត្រូវឈ្នះនៅក្នុងរាជធានី ព្រោះរាជធានីជាស្នូលនៃការទប់ទល់ទូទាំងប្រទេស ។ ទ្រង់បានយាងចូលមកគង់នៅក្នុងរាជធានី រៀបចំពង្រឹងកិច្ចការពារយ៉ាងម៉ឺងម៉ាត់ និងប៉ិនប្រសប់ ។ ទ័ពសៀមដេញតាមព្រះអង្គប្រកិតៗ រួចបោះទ័ពនៅពីមុខរាជធានីលង្វែក ។ ប៉ុន្តែដោយព្រះរាជា និងរាជបរិពារគេចចេញបាត់ទៅ ហើយអ្នកស្រុកក៏ទៅជាអស់សង្ឃឹម គិតតែព្រួយនឹងការវាយលុករបស់សត្រូវ បានធ្វើឲ្យកិច្ចការពារជាប់គាំង ហើយនៅទីបញ្ចប់ ក៏ព្រលែងរាជធានីឲ្យសត្រូវតែម្តង នៅចុងឆ្នាំ១៥៩៣ ។ ព្រះឧភយោរាជ និងគ្រួសារត្រូវសៀមចាប់បាន នាំយកទៅស្រុកគេជាមួយប្រជាជនរាជធានី និងទីជិតខាងចំនួន ៩ ម៉ឺននាក់[៨១] ។

[៨១] រាជពង្សាវតារខ្មែរ រាជពង្សាវតារសៀម និងការដំណាលតៗគ្នាព្រមទាំងរឿងនិទានទាំងឡាយស្តីអំពីការបាត់បង់បន្ទាយលង្វែក បានឯកភាពគ្នាកំណត់កាលបរិច្ឆេទនៃព្រឹត្តិការណ៍នេះក្នុងឆ្នាំ១៥៨៣ ។ ក៏ប៉ុន្តែ លោក អៃម៉ូនីញេ បានរកឃើញអក្សរចារឹកលើឈើមួយ នៅអន្លក់ ក្នុងខេត្តព្រៃកប្បាស ដែលនិយាយថា ហេតុការណ៍នេះកើតឡើងនៅក្នុងឆ្នាំកុរ ចុល្លសករាជ៩៤៩ ពុទ្ធសករាជ ២១២៩ ដែលត្រូវនឹងគ្រិស្តសករាជ១៥៨៧ ទៅវិញ ។ យើងពិបាកនឹងបដិសេធកាលបរិច្ឆេទដែលមានការបញ្ជាក់ច្បាស់លាស់បែបនេះណាស់ ក៏ប៉ុន្តែយើងក៏ពិបាកនឹងបដិសេធកាលបរិច្ឆេទដែលរាជពង្សាវតារសៀម និងរាជពង្សាវតារខ្មែរបានកំណត់ឲ្យដែរ ។ ចំណែកឯលោកហ្វ្រង់ស៊ីហ្គានីញេវិញ គាត់កំណត់យកឆ្នាំ១៥៨៥ ដោយមិនបានបញ្ជាក់អំពីមូលហេតុទេ ក៏ប៉ុន្តែបាននិយាយដែរថា ឯកសារអឺរ៉ុបកំណត់យកឆ្នាំ១៥៩៣ ។ នៅឆ្នាំ១៩០៩ លោក កាបាតុង បានលើកអំពីឯកសារអេស្ប៉ាញ៉ុលមួយ ដែលគេបោះពុម្ពផ្សាយតាំងពីឆ្នាំ១៦០៤ នៅវ៉ាឡាដូលីដ ហើយដែលមានរៀបរាប់អំពីព្រឹត្តិការណ៍ ដែលកើតឡើងនៅកម្ពុជា ក៏បានទទួលស្គាល់ថា បន្ទាយលង្វែកធ្លាក់ទៅក្នុងដៃសៀមនៅក្នុងឆ្នាំ១៥៩៣ នេះដែរ ។

ដូច្នេះ យើងឃើញថាមានកាលបរិច្ឆេទបី គឺឆ្នាំ១៥៨៣, ១៥៨៧ និង១៥៩៣ ដែលសុទ្ធតែសំអាងទៅលើឯកសារពិសេសៗ កាលបរិច្ឆេទទី១សំអាងទៅលើរាជពង្សាវតារខ្មែរ និងសៀម កាលបរិច្ឆេទទី២សំអាងទៅលើចារឹកលើឈើមួយ និងកាលបរិច្ឆេទទី៣សំអាងទៅលើឯកសារអឺរ៉ុប ។ បើពិនិត្យឲ្យដិតដល់ទៅ រាជពង្សាវតារខ្មែរ និងរាជពង្សាវតារសៀម អាចនឹងមានការខុសឆ្គង ដោយមកពីឯកសារនេះ គេចម្លងតៗគ្នាជាច្រើនលើកច្រើនសា ។ ទី១ ការខុសឆ្គងនោះអាចនឹងបណ្តាលមកពីឯកសារដើមមិនត្រឹមត្រូវខ្លួនឯង តែក៏អាចមកពីអ្នកចម្លងដែលមិនប៉ិនប្រសប់ មិនបានយល់ច្បាស់អំពីសករាជទាំងបីដែលគេនិយមប្រើព្រមៗគ្នា ឬក៏គិតតែប្រទាញឲ្យសករាជទាំងបីត្រូវគ្នា ភ្លេចគិតដល់ព្រឹត្តិការណ៍ពិត ។ ទី២ ឈ្មោះ និងស័ក ឆ្នាំនីមួយៗ ជាកត្តាសម្រាប់បញ្ជាក់ដើម្បីកុំឲ្យគេច្រឡំឆ្នាំណាជាឆ្នាំណា ក៏ប៉ុន្តែជួនកាលវាទៅជាមូលហេតុធ្វើឲ្យមានការច្រឡំទៅវិញ ក៏មាន ។ ចំណែកឯចារឹកនៅលើឈើនៅអន្លក់ គ្មានចំណុចត្រង់ណាដែលបញ្ជាក់ថា ឯកសារនេះគេសរសេរនៅក្នុងឆ្នាំណា តើឯកសារនេះកើតឡើងក្នុងពេលបែកលង្វែក ឬយ៉ាងណាដែរទេ ។ តែខ្ញុំគិតថា គេគ្មានមូលហេតុអ្វីម៉ឺងម៉ាត់ ដើម្បីបដិសេធកាលបរិច្ឆេទដែលលោក កាបាតុង ដកស្រង់ចេញពីឯកសារអេស្ប៉ាញ៉ុលណាស់ ។ ដូច្នេះគេត្រូវកំណត់យកការបែកបន្ទាយលង្វែកត្រឹមឆ្នាំ១៥៩៣ ។

ប្រហែលគឺនៅពេលនោះហើយ ដែលឌីយ៉ឺហ្គោបែឡូសូ និងមិត្តភក្តិរបស់គេធ្វើដំណើរត្រលប់មកដល់កម្ពុជាវិញ ទទួលដំណឹងថាសៀមដណ្តើមយករាជធានីលង្វែកបានហើយ ហើយព្រះសត្ថា និងព្រះរាជា ជាព្រះរាជបុត្របានភៀសព្រះកាយទៅគង់នៅឯស្រីសន្ធរ ឬក៏បានយាងទៅដល់ស្ទឹងត្រែងផងក៏មិនដឹង ដែលជាទឹកដីកម្ពុជាដែរ នៅជំនាន់នោះ ។

ប្រទេសកម្ពុជាពេលនោះ បានធ្លាក់ចូលក្នុងភាពវិនាសហិនហោចជាខ្លាំង បន្ទាប់ពីសៀមដណ្តើមយកបានរាជធានីលង្វែក ព្រះរាជាភៀសព្រះកាយបាត់ ហើយពួកសៀមគ្រប់គ្រងដឹកនាំប្រទេសយ៉ាងតឹងរ៉ឹងបំផុត ។ គេរុករើកកាយរាជធានី រួចដុតខ្ទេចខ្ទី ។ ប្រជាជនត្រូវគេកៀរទាំងហ្វូងៗ យកទៅដាក់នៅទីកន្លែងផ្សេងៗ ក្នុងទឹកដីសៀម ហើយមានមនុស្សស្លាប់ជាច្រើនតាមផ្លូវ ពេលធ្វើដំណើរទៅ ។ ទ្រព្យសម្បត្តិផ្សេងៗ សាស្ត្រារាជពង្សាវតារ និងគម្ពីរច្បាប់បានត្រូវគេបំផ្លាញចោល ឬត្រូវព្រះណារេតនាំយកទៅកាន់រាជធានីអយុធ្យា ។ មហាណាចក្រកម្ពុជា ដែលធ្លាប់តែរុងរឿង បានធ្លាក់ចុះអាប់ឱនដោយសារតែខ្សោះអស់ប្រជាជន ។ ភាពខ្សោះអស់ប្រជាជននេះ បេសកជនចិនលោក ឈាវតាក្វាន់ បានសង្កេតឃើញតាំងតែពីសតវត្សរ៍ទី១៣មកម៉្លេះ ក្នុងឆ្នាំ១២៩៦ ហើយលោកបាននិយាយទៀតថា គឺជាផលវិបាកនៃសង្គ្រាមដែលសៀមបង្កឡើង ធ្វើឲ្យកម្ពុជាចុះខ្សោយ ដោយកាត់បន្ថយនូវមធ្យោបាយ ដែលព្រះរាជាខ្មែរប្រើប្រាស់ដើម្បីការពារខ្លួន ថ្វីបើប្រទេសនេះនៅតែមានអត្ថិភាពប្រកបដោយវិសាលភាព និងគោលជំហររឹងមាំក៏ដោយ ។ គឺជាមហានគរ ដែលនៅមានកិត្តិនាមល្បីល្បាញរន្ទឺពាសពេញបូព៌ាប្រទេស តែបាត់បង់ការគាំទ្រដល់អនុត្តរភាព និងមានតែការទទួលស្គាល់ពីបណ្តាក្សត្រប្រទេសតូចៗ នៅស្រុកលាវប៉ុណ្ណោះ ។

ភាពរីករវដែលធ្វើឲ្យកម្ពុជានៅឯកោ, ការប្រកួតប្រជែងដណ្តើមអំណាចគ្នា, សង្គ្រាមដែលកម្ពុជាត្រូវតែធ្វើជាមួយសៀម និងនគរសាមន្តរាជ, ការធ្លាក់ចុះនៃសន្តតិវង្សវរ្ម័នកាន់ព្រហ្មញ្ញសាសនា នៅដើមសតវត្សរ៍ទី១៤ ហើយជំនួសវិញដោយសន្តតិវង្សកាន់ព្រះពុទ្ធសាសនា ដែលនាំឲ្យមានបដិវត្តន៍សាសនានយោបាយ និងប្រជាធិបតេយ្យ ទាំងអស់នេះបានធ្វើឲ្យព្រះរាជាណាចក្រចុះខ្សោយ ដោយព្រះរាជាត្រូវបាត់បង់អំណាចបន្តិចម្តងៗ ។ ព្រឹត្តិការណ៍ទាំងអស់នេះ បានធ្វើឲ្យពួកលាវរើបម្រះទាមទារសេរីភាព ហើយចុះមកនៅកាន់តែជិតឡើងៗរហូតមកដល់ល្បាក់ខោន តាំងតែពីសតវត្សរ៍ទី១៤ ដែលជាហេតុធ្វើឲ្យអនុត្តរភាពខ្មែរកាន់តែចុះខ្សោយជាបន្តបន្ទាប់ ។ ភាពអាប់ឱនកាន់តែធ្ងន់ឡើងថែមទៀត នៅពេលដែលពួកសៀមកៀរប្រជាជនទាំងហ្វូងៗ ជាឈ្លើយយកទៅស្រុកគេ ។

ការបោះបង់ចោលរាជធានីនគរធំ នៅសតវត្សរ៍ទី១៤ ហើយព្រះរាជាមកគង់នៅបាសាន រួចមកនៅចតុម្មុខ (ភ្នំពេញ) គង់ក្នុងវាំងឈើប្រក់ស្លឹកមិនមែនប្រក់ក្បឿង នេះជាភស្តុតាងបញ្ជាក់ច្បាស់ អំពីភាពចុះអាប់ឱនដែលមិនអាចកំបាំងពីភ្នែកពួកអ្នកដែលបានឃើញបានដឹង ដែលយើងត្រូវតែលើកយកមកនិយាយនៅពេល

នេះ ។ យើងបានឃើញពីខាងលើរួចមកហើយ ថាប្រជាជនកម្ពុជាពេលនោះ ជឿថាមានលេចសញ្ញាមិនល្អរួចទៅហើយ នៅក្នុងសកម្មភាពផ្សេងៗរបស់ជនខក្រិដ្ឋ ដែលធ្វើឲ្យពួកគេមានការភិតភ័យ ហើយព្រួយបារម្ភថា ពួកគេនឹងទទួលរងនូវមហន្តរាយដ៏ធ្ងន់ធ្ងរជាមិនខាន ។ តើមហន្តរាយដ៏ធំ ដែលមកគំរាមកំហែងពួកគេនោះជាអ្វី? ហើយតើអ្វីទៅជាមូលហេតុនៃទុក្ខព្រួយ ដែលធ្វើឲ្យពួកគេវង្វេងវង្វាន់ ក្លាយទៅជាប្រជាជនមួយ លែងទុកចិត្តលើខ្លួនឯងហើយចោទប្រកាន់ទៅលើសាសនាទាំង២ថា បានទម្លាក់វាសនាមិនល្អឲ្យព្រះរាជា ដាក់បណ្តាសាឲ្យកើតជំងឺអាសន្នរោគ ជំងឺឃ្លង់ នៅទូទាំងព្រះនគរ មិនតែប៉ុណ្ណោះបានទាំងឲ្យពួកសៀមដណ្តើមយករាជធានីបាន ក្រោយពីឡោមព័ទ្ធជាប់ជាច្រើនឆ្នាំ ។ ទុក្ខព្រួយក្រហល់ក្រហាយរបស់ប្រជាជននេះ គឺជាសញ្ញាមួយទៀត បញ្ជាក់អំពីការអាប់ឱន ការភ័យខ្លាច និងការចុះខ្សោយ ។

ក៏ប៉ុន្តែដោយប្រជាជនកម្ពុជានាសម័យនោះ ក៏ដូចជាសម័យព្រះរាជាវង្សវរ្ម័នដែរ ជាជាតិសាសន៍មួយក្លាហាន ជាពូជអ្នកចម្បាំង ត្រៀមខ្លួនជានិច្ចនឹងធ្វើសង្គ្រាម, ដោយគេមានមេបញ្ជាការជាឧត្តមសេនីយ៍ដ៏ប៉ិនប្រសប់, ដោយគេធ្លាប់បានរុញច្រានពួកចាមឲ្យដកថយចេញទៅវិញ មិនតិចជាង២០ដង ធ្លាប់វាយក្សត្រនគរចំណុះឲ្យបរាជ័យលើសពី១០០ដង ធ្លាប់បានចេញធ្វើសង្គ្រាមទៅក្រៅទឹកដីជាង ១០ដង ធ្លាប់វាយពួកសៀមឲ្យបរាជ័យ២០ដងក្នុងពេលជាង៤សតវត្សរ៍, ដោយអ្នកស្រុកទៅជាមានការប្រុងប្រយ័ត្នខ្លួនជានិច្ច ព្រោះតែការចូលលុកលុយមកពីទិសពាយ័ព្យ និងខត្តររបស់ទ័ពសៀម និងលាវ, ដោយអ្នកស្រុកមានស្មារតីជាអ្នកចម្បាំង ទាំងព្រះរាជាដាក់រាជ្យទាំងព្រះរាជាតែងតាំងថ្មី ដែលនៅក្មេងមិនទាន់សមល្មមក្នុងការដឹកនាំ ទាំងពួកឧត្តមសេនីយ៍រដ្ឋមន្ត្រី នាម៉ឺនសព្វមុខមន្ត្រីទាំងអស់ មានទំនុកចិត្តហើយ បានលះបង់អស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីបម្រើជាតិ ។ គេសម្រេចជ្រើសរើសទ័ពបានយ៉ាងរហ័ស ប្រឆាំងនឹងទ័ពសៀម បាន៤កងនៅក្នុងឆ្នាំ១៥៨២ វាយបំបែកការឡោមព័ទ្ធរាជធានីលង្វែកក្នុងឆ្នាំ១៥៨៣ ថែមទាំងបានរុញច្រានពួកសៀមរហូតដល់ទល់ដែនទៀតផងជាហេតុធ្វើឲ្យគេមានសង្ឃឹមថា អាស្រ័យដោយវិធានការដ៏ប៉ិនប្រសប់ ទប់ទល់ប្រឆាំងនឹងផែនការវាយប្រហារហ្មត់ចត់របស់សត្រូវ កម្ពុជានឹងអាចបណ្តេញសត្រូវឈ្លានពានស្ងួពូជ បានយ៉ាងហោចណាស់ម្តងទៀតដែរនៅក្នុងឆ្នាំ១៥៩៣ ។

ក៏ប៉ុន្តែការពិតបែរជាផ្ទុយស្រឡះ គឺទ័ពខ្មែរបានត្រូវវាយឲ្យបរាជ័យនៅលើគ្រប់សមរភូមិ ហើយសៀមដណ្តើមយករាជធានីលង្វែកបាន ។ ព្រះឧភយោរាជ និងគ្រួសារត្រូវសៀមចាប់បានជាឈ្លើយ ចំណែកឯព្រះរាជាដាក់រាជ្យ និងព្រះរាជាក្មេងវិញ ត្រូវគេចព្រះកាយទៅគង់នៅឯខាងជើងបំផុតនៃព្រះរាជាណាចក្រដើម្បីកុំឲ្យសៀមចាប់បានហើយនាំយកទៅស្រុកសៀម ដូចជាព្រះរាជាមុនមួយអង្គ គឺព្រះបាទស្រីរាជា នៅក្នុងឆ្នាំ១៤៧៣ ។ ដល់ពេលនេះ មិនគ្រាន់តែជាការអាប់ឱនចុះប៉ុណ្ណោះទេ គឺជាមរណភាព ជាចុងបញ្ចប់នៃព្រះរាជាណាចក្រមួយតែម្តង ។ ប្រជាជនបាត់ម្ចាស់ការភ្លេចអស់អ្វីៗ មិនដឹងថាខ្លួនជានរណា ។ គេត្រូវបាត់បង់អស់នូវ

តម្លៃរបស់ខ្លួន បាត់បង់ទាំងអានុភាព និងថាមពល ហើយគ្មានសល់អ្វីបន្តិចឡើយ ។

ក្រោយពីវិបត្តិដ៏ធំធេងនេះ នៅពេលដែលមានរាជវង្សឆ្ងាយមួយអង្គ គឺព្រះរាមាជើងព្រៃ ដែលជាសត្រូវរបស់ព្រះរាជាដាក់រាជ្យព្រោះទំនាស់ដណ្តើមព្រះជាយាគ្នា ហើយក៏ជាសត្រូវរបស់ព្រះរាជាថ្មីផងដែរ ក្រោយពីបានពិនិត្យឃើញថាអ្វីៗរលំរលាយដល់ដីអស់ហើយ ទាំងរាជវង្សទាំងរាជបរិពារ និងមន្ត្រីធំៗក៏បាត់បង់អស់ពីព្រះរាជាណាចក្រ រាជធានីត្រូវត្រួតត្រាដោយឧត្តមសេនីយ៍សៀមម្នាក់ ក្រោយពីព្រះអង្គបានបណ្តេញទ័ពសៀម និងឧត្តមសេនីយ៍ជាតំណាងស្តេចសៀមចេញពីលង្វែកនៅក្នុងឆ្នាំ១៥៩៤ផុតទៅ គ្មានសល់អ្វីទៀតទេនៅក្នុងព្រះរាជាណាចក្រ ៖ ចិត្តគំនិតចាស់ត្រូវរលុបបាត់អស់ មនុស្សម្នាក្លាយទៅជាទន់ជ្រាយ កំសាក នរណាក៏ដូចជានរណា មានតែក្តីអស់សង្ឃឹម ។

បន្ទាប់មក ក្រោយពីព្រះរាជាដាក់រាជ្យសោយទិវង្គតទៅ ព្រះរាជាថ្មីក៏សុគតបាត់ទៅដែរ ក្រោយពីពួកអេស្ប៉ាញ៉ុល និងព័រទុយហ្គេធ្វើគុតព្រះរាមាជើងព្រៃនៅស្រីសន្ធរ ក្នុងឆ្នាំ១៥៩៥ រួចហើយពួកចាម និងម៉ាឡេធ្វើគុតពញាតន់ក្នុងឆ្នាំ១៥៩៦ ប្រទេសកម្ពុជាមានព្រះរាជា១៣ព្រះអង្គ សោយរាជ្យក្នុងពេលតែ១សតវត្សរ៍ ហើយនៅចងចាំឥតភ្លេចអនុស្សាវរីយ៍នៃមហាវិនាសកម្មកន្លងមក ក៏ប៉ុន្តែគេគ្មានសេចក្តីក្លាហាននឹងធ្វើការសងសឹកតបតនឹងពួកសៀមវិញទេ ។ សៀវភៅក្បួនខ្នាតច្បាប់ គម្ពីរសាស្ត្រា បានត្រូវគេលួចយកទៅបាត់ ឬដុតបំផ្លាញខ្ទេចខ្ទី ។

នៅក្នុងគ្រិស្តសករាជ១៦៩២ ដើម្បីបានចេះដឹងអំពីទំនៀមទម្លាប់ពីបុរាណ ដែលគេភ្លេចបាត់អស់ទៅ ហើយតាមការណែនាំរបស់ព្រះមាតុច្ឆាមួយព្រះអង្គ ព្រះបាទជ័យជេដ្ឋាត្រូវធ្វើសំណើសុំគម្ពីរសាស្ត្រា ក្រាំងច្បាប់រដ្ឋប្បវេណី និងច្បាប់សាសនាសរសេរដោយដៃ ទៅប្រទេសសៀម ដែលបានលួចយកទៅពីមុន ។

នៅក្នុងការចងចាំរបស់ប្រជាជនខ្មែរ ការបាត់បង់រាជធានីលង្វែកគឺជាដំណាក់កាលអាក្រក់មួយ ដែលពីមុននោះ ព្រះរាជាណាចក្រមានទឹកដីធំ ហើយសម្បូរសប្បាយ ប្រជារាស្ត្របានសុខក្សេមក្សាន្ត ប្រទេសខ្លាំងពូកែ ។ តាមពិត កម្ពុជាបានធ្លាក់ចុះឱនថយតាំងពីមុននោះយូរយារមកហើយ បើពុំនោះទេ ការគ្រាន់តែបាត់បង់ កម្មេចកម្មី និងត្រួតត្រាលង្វែកក្នុងពេល២-៣ឆ្នាំប៉ុណ្ណោះ នឹងមិនអាចធ្វើឲ្យប្រទេសត្រូវរលាយបាត់បង់ ខ្សោះកម្លាំង ហើយប្រជាជនធ្លាក់ចូលក្នុងដំណើរថយក្រោយដូច្នេះទេ ។ ចាប់ពីពេលបាត់បង់លង្វែកមក កម្ពុជាត្រូវបាត់ឈ្មោះពីចុងបូព៌ា ហាក់បីដូចជារលត់រលាយបាត់ពីលើពិភពលោកនេះទៅ លែងមាននរណាស្គាល់ទៀតហើយ ។ នៅពេលដែល ពួកអឺរ៉ុបបានមកដល់កាលពី១សតវត្សរ៍មុននេះ ដោយចុះចតនៅនឹងឆ្នេរសមុទ្រប្រទេសឥណ្ឌា ត្រង់អរ៉ា អារ៉ាកាន់ មែរគុយ តេណាស់សេរីម ម៉ាតាបាន មកដល់ភូមា ប៉េហ្គូ ជូរ ម៉ាឡាកា រហូតមកដល់ស្រុកសៀម ហើយឆ្ងាយរហូតដល់ តុងកឹង អាណ្ណាម កូសាំងស៊ីន ពួកនោះមិនបានដឹងអំពីអត្ថិភាពរបស់ព្រះរាជាណាចក្រកម្ពុជាទេ ។ រាជទូត របស់ស្តេចល្វីទី១៤ គឺពួកលោកឪពុកសេស៊ីតទាំង៦នាក់ បានដឹងអំពីប្រទេសកម្ពុជា

នៅឯរាជវាំងអយុធ្យា នៅឆ្នាំ១៦៩៥ ពេលដែលពួកគាត់បានជួបអ្នកអន្តម្នាស់ខ្មែរមួយអន្ត ដែលហាក់បីដូចជាយាងមកពីប្រទេសឆ្ងាយដាច់សង្វែងមួយ គ្មានអារ្យធម៌ ហើយចំណុះស្រុកសៀម ។

# ជំពូកទី២
# អំពីប្រទេសដែលមានទំនាក់ទំនងជាមួយកម្ពុជា
# នៅសតវត្សរ៍ទី១៤, ១៥ និង១៦

មកដល់ពេលដែលសៀមវាយយកបន្ទាយលង្វែកបាននេះ ពោលគឺនៅចុងសតវត្សរ៍ទី១៦ យើងគួរពិនិត្យមើល អំពីស្ថានភាពនយោបាយរបស់បណ្ដាប្រទេស ដែលមានទំនាក់ទំនងជាមួយកម្ពុជាបន្តិច ។

## ១- *ប្រទេសលាវ*

នៅពេលដែលមហាអាណាចក្រកម្ពុជាត្រូវបាក់បែកទៅ វាហាក់ដូចជាថាបណ្ដាក្សត្រប្រទេសលាវតូចៗ នៅខាងជើងភ្នំដងរែក ដែលកន្លងមក ធ្លាប់ទទួលស្គាល់អនុត្តរភាពរបស់ព្រះរាជាខ្មែរដោយបង្ខំចិត្ត បានទទួលនូវសេរីភាពពេញលេញ ហើយត្រូវធ្លាក់ចូលទៅក្នុងអំណាច និងការដឹកនាំដ៏តឹងរ៉ឹងថ្មីមួយពីស្ដេចក្នុងស្រុកដែលទើបតែងណ្ដើមអំណាចបាន ។ ប្រហែលជាមានក្សត្រប្រទេសជាច្រើន ដែលត្រូវធ្លាក់ទៅក្នុងការដឹកនាំរបស់ពួកថៅថៃតាំងតែពីពេលនោះមកម៉្លេះ ពីព្រោះមានរឿងដំណាលថាមានពួកវិប្រជាលាវខ្លះ បានគេចខ្លួនចេញពីពួកអ្នកដណ្ដើមអំណាចថ្មី ហើយរត់ទៅរស់នៅឆ្ងាយក្នុងព្រៃភ្នំក្រំថ្ម ដើម្បីឲ្យបានស្ងប់ស្ងាត់ហើយមានសុវត្ថិភាពជាង ។

ពួកលាវហាក់ដូចជាបានផ្ដាច់ខ្លួនផុតស្រឡះពីកម្ពុជាហើយ តាំងតែពីដើមសតវត្សរ៍ទី១៤ នៅពេលដែលមានអង្គម្ចាស់លាវមួយអង្គ[១] ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយបុត្រីស្ដេចកម្ពុជា បានដឹកនាំទ័ពចម្រុះលាវ ខ្មែរ ទៅវាយដណ្ដើមយកស្រុកលាវមកគ្រប់គ្រងវិញ ។ អ្នកអង្គម្ចាស់នោះមានព្រះនាមថា ផាំង ទ្រង់ប្រសូតក្នុងរវាងឆ្នាំ១៣១៦ គេហៅថាចៅហ៊្វាផាំង ហ៊្វាផាំង ឬហ្វាផាំង[២] មានព្រះជន្ម២១ព្រះវស្សា ។ ព្រះអង្គបានដណ្ដើមយកបានទឹកដីលាវទាំងមូល ហើយបានរក្សាក្សត្រប្រទេស ដែលមានពីមុនមកទាំងអស់ទុកនៅដដែលគ្រាន់តែទ្រង់បានតែងតាំងមេដឹកនាំថ្មី រួចហើយបែងចែកចេញជាស្រុករដ្ឋបាលផ្សេងៗ និងរៀបចំឲ្យមានច្បាប់ទម្លាប់ឡើងប៉ុណ្ណោះ ។ ទ្រង់ក៏បានដណ្ដើមយកនគរឡានឆាង ជាស្រុកកំណើតរបស់ព្រះបិតា មកវិញផងដែរ ។ ឈ្មោះរបស់

[១] ទ្រង់ត្រូវជាព្រះនត្តារបស់ ភ្យាកំផុង ស្ដេចហ្លួងប្រាបាង ជាបុត្ររបស់ ភ្យាវត្ត ដែលបានលួចពគ្រត់ព្រះជាយាមួយអង្គរបស់ព្រះបិតា ហើយគេចព្រះអង្គមកគង់នៅឯស្រុកខ្មែរ ។ មានឯកសារមួយនោះនិយាយថាភ្យាវត្តបានប៉ុនប៉ងដណ្ដើមរាជសម្បត្តិពីព្រះបិតា ភ្យាកំផុង ។

[២] ត្រង់នេះ យើងឃើញថាពាក្យហ៊្វា ឬហ្វាមានន័យថាអ្នកអង្គម្ចាស់ ចំណែកឯសមាសពាក្យចៅហ៊្វា ដូចទៅនឹងពាក្យចៅពញាដែរមានន័យថា អ្នកអង្គម្ចាស់ជាធំ ។ ភាសាភូមា ឬប៉េហ្កាន ហៅថា ចៅភ៉ា ដែលពួកអង់គ្លេសសរសេរថា ចុលភ៉ា និងចូភ៉ា ។

ព្រះរាជាណាចក្រនេះក្លាយចេញពីឈ្មោះភូមិ២ គឺសៀងដុង និងសៀងតុង[៣] ដែលមាននៅរហូតដល់សព្វថ្ងៃជាឈ្មោះសង្កាត់២ នៃរាជធានីហ្លួងប្រាបាង ដែលពីមុនឆ្នាំ១៥០១មានឈ្មោះថា វ៉ាត់សា តាវ៉ានី ស៊ីសុតាណាជាឈ្មោះដែលគេហៅ កោះដូរ ពីមុនៗ អ្នកស្រុកមានសញ្ជាតិជាឡាវ ឬថៃ ។

នៅពេលត្រលប់មកពីវាយយកហ្លួងប្រាបាងដាក់ជាចំណុះរួចហើយ ហ្វ៊ាង៉ោមបានជួបជាមួយពួកខាខាវ ពួកនេះដូចជាពួកថៃកាលពីប៉ុន្មានសតវត្សរ៍មុនដែរ បានចាកចេញពីស្រុកដើមរបស់ខ្លួនមករស់នៅក្នុងខ្ពង់រាបខ្ពស់ៗ និងក្នុងព្រៃភ្នំ ។ ពួកនេះខស្សរាហ៍ច្បាំងគ្នាណាស់ ហ្វ៊ាង៉ោមបានយល់ព្រមទទួលយកពួកនេះដាក់ក្រោមអាណាព្យាបាល តែបានបង្ខំឲ្យឈប់ច្បាំងគ្នាចំនួន៥ថ្ងៃក្នុង១សប្តាហ៍ ហើយឲ្យឈប់លួចគោក្របីគ្នាក្នុងពេលច្បាំងដើម្បីជៀសវាងកុំឲ្យមានសង្គ្រាមតទៅទៀត ។

មានម្តងនោះ ទ្រង់បានយាងចេញពីហ្លួងប្រាបាង ទៅវាយយកវៀងច័ន្ទ ដែលមិនព្រមទទួលស្គាល់អំណាចរបស់ព្រះអង្គ មកដាក់ជាចំណុះ ។ វៀងច័ន្ទពេលនោះគេហៅថាណាខនថៃ មានន័យថា រាជធានីពួកថៃ[៤] ។ ទ្រង់បានជួបជាមួយកងទ័ពប្រឆាំងពេលយាងទៅជិតដល់ ហើយបានវាយឲ្យបរាជ័យយ៉ាងងាយ រួចយាងចូលទៅក្នុងរាជធានី ស្ទើរតែគ្មានការខូចខាតកម្លាំងអ្វីបន្តិចសោះ ។

គេនិយាយថា នៅពេលដែលពួកថៃនៅក្នុងអាងទន្លេមេណាមកាន់ដើងវៀងច័ន្ទ ទ្រង់បានសម្រេចព្រះទ័យចេញធ្វើសង្គ្រាមជាមួយ ដោយបានដឹកនាំទ័ពទៅដល់ព្រំប្រទល់ដែនទៅហើយ ស្រាប់តែព្រះរាជាសុខោទ័យបញ្ជូនទូតមកសុំសន្តិភាព និងចងស្ពានមេត្រីដោយលើករាជបុត្រីព្រះនាមថានាងកែវយុផាជាមហេសីទី២ ។ ទ្រង់បានយល់ព្រមតាមសំណើ ក៏ប៉ុន្តែបានឲ្យសុខោទ័យបញ្ជូនសួយសារអាករទៅថ្វាយមានចំនួនច្រើនលើសលប់ជារៀងរាល់ឆ្នាំ ។

អនុលោមទៅតាមសំណូមពររបស់នាម៉ឺនសព្វមុខមន្ត្រីក្នុងព្រះរាជាណាចក្រ ង៉ោម បានយល់ព្រមឲ្យគេអភិសេកជាព្រះរាជាលាវនៅក្នុងឆ្នាំ១៣៥៣? នៅក្នុងបរិវេណវត្តបាសាក់ ដែលមានសេសសល់សំណល់បាក់បែករហូតមកដល់សព្វថ្ងៃ ។ នៅក្នុងឱកាសនោះ ទ្រង់បានថ្លែងព្រះរាជឱង្ការអំពីគោលការណ៍យុត្តិធម៌ ដែលគួរឲ្យកត់សម្គាល់ ទៅកាន់នាម៉ឺនទាំងឡាយ នៅចំពោះមុខពលរេហ៍ និងប្រជារាស្ត្រថា “នាយចៅហ្វាយមិនត្រូវវាយធ្វើបាប ឬកាប់សម្លាប់ខ្ញុំកំដរទេ ។ មេកោយដែលរងនូវការប្រមាថ ទោះជាមកលើរូបខ្លួនផ្ទាល់ក្តី មកលើក្រុមគ្រួសារខ្លួនក្តី មិនត្រូវកាត់សេចក្តីដោយខ្លួនឯងទេ ត្រូវប្រគល់រឿងនោះឲ្យចៅក្រមកាត់វិញ ។ ជនល្មើសត្រូវកាត់

[៣] សៀង ខ្មែរថា ឈៀង, ស៊ី មកពីពាក្យបាលីថា សិរី សំស្ក្រឹតថា ស្រី ។

[៤] ឈ្មោះ ពិសិដ្ឋ គឺស្រីច័ន្ទនគរ មានន័យថា រាជធានីនៃដើមចន្ទន៍ក្រឹស្នាដ៍មានសិរី ។

ទោសត្រឹមត្រូវទៅតាមកំហុសដែលគេបានប្រព្រឹត្ត ហើយទណ្ឌិតត្រូវដោះលែងឲ្យមានសេរីភាពវិញ នៅថ្ងៃដែលទណ្ឌកម្មត្រូវបញ្ចប់ ។ ខែត្រនីមួយៗត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពទូទៅថ្វាយព្រះរាជា ហើយចៅហ្វាយខែត្រត្រូវចូលមកគាល់ព្រះរាជានៅហ្លួងប្រាបាង៣ឆ្នាំម្តង ដោយនាំយកពន្ធអាករមកជាមួយផង ។ ត្រូវចេញដំណើរនៅខែទី១ដើមឆ្នាំ ដើម្បីឲ្យបានទៅដល់មឿងស្វា (ហ្លួងប្រាបាង) នៅខែទី៣ ។ មិនត្រូវដាក់ប្រជារាស្ត្រឲ្យទៅជាទាសករទេ ។ មិនត្រូវសម្លាប់ឃាតករទេ ព្រោះវានឹងធ្វើឲ្យមានស្លាប់កាន់តែច្រើន ការសម្លាប់មនុស្សម្នាក់ទៀត គឺជាកំហុស ។ មេទ័ពមិនត្រូវទទួលសំណូកពីជនណាដែលមិនចង់ចេញធ្វើសង្គ្រាមទេ បើពុំនោះនឹងត្រូវទម្លាក់បុណ្យសក្តិឲ្យមករស់នៅជាប្រជាជនធម្មតា» ។

បើសិនជារាជពង្សាវតារលាវមិននិយាយបំផ្លើសទេ ព្រះចៅហ៊្វាងោមនេះ ដែលត្រូវជាព្រះរាជបុត្រសុណិសា របស់ព្រះរាជាកម្ពុជា ជាមហារាជាខ្លាំងពូកែមួយអង្គ ដែលបានបង្រួបបង្រួមក្សត្រប្រទេសលាវទាំងអស់ ដាក់មកក្នុងអំណាចរបស់ព្រះអង្គតែក្នុងរយៈពេល ២ ទៅ ៣ឆ្នាំ ប៉ុណ្ណោះ ក្សត្រប្រទេសទាំងអស់នោះពីមុន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះរាជាឥន្ទបត្ត ហើយទើបតែរំដោះខ្លួនចេញរួច ។

អ្នកម្នាងកែវ មហេសីរបស់ព្រះអង្គ ជាពុទ្ធសាសនិកដ៏ជ្រះថ្លាម្នាក់ ។ «ព្រះនាងទ្រង់មានព្រះទ័យអាម៉ាស់ខ្លាំងណាស់ដែលពិនិត្យឃើញថា ប្រជាជនលាវមិនបានអនុវត្តតាមព្រះពុទ្ធោវាទ មិនគោរពច្បាប់ ពួកទាហាន និងមេបញ្ជាការឃោរឃៅ ធ្វើអ្វីៗតាមតែអំពើចិត្ត តែមិនដែលទទួលទោសកំហុសសោះ» ។ ព្រះនាង បានយាងទៅជួបព្រះរាជាជាព្រះស្វាមី រួចទូលព្រះអង្គថា «នៅស្រុកលាវនេះ អ្នកខ្លាំងប្រើអំណាចលើអ្នកទន់ខ្សោយ ប្រៀបបីដូចថា នេះជាច្បាប់ធម្មជាតិ ។ ការធ្វើបែបនេះមិនល្អទេ ហើយទូលព្រះបង្គំជាខ្ញុំម្ចាស់មិនអាចទ្រាំមើល ដូច្នេះតទៅទៀតបានទេ ទូលព្រះបង្គំសូមការអនុញ្ញាតពីព្រះអង្គ វិលត្រលប់ទៅនគរព្រះបិតាខ្ញុំម្ចាស់វិញហើយ» ។ ឮព្រះបន្ទូលមហេសីបែបនេះ ព្រះរាជា បានមានបន្ទូលលួងលោមព្រះនាង ហើយសន្យាថា ទ្រង់នឹងរៀបចំឲ្យគេគោរពព្រះពុទ្ធសាសនានៅក្នុងព្រះរាជាណាចក្ររបស់ព្រះអង្គ រួចបានចាត់រាជទូតទៅឥន្ទបត្ត សុំឲ្យព្រះបិតាក្មេកបញ្ជូនគម្ពីរពុទ្ធសាសនា និងព្រះសង្ឃមកផង ដើម្បីបង្ហាត់បង្ហាញសាសនាថ្មីនេះដល់ប្រជាជន ។

ព្រះរាជាឥន្ទបត្ត បានចាត់បញ្ជូនព្រះសង្ឃ៨អង្គជាមួយនឹងគម្ពីរផ្សេងៗ និងព្រះពុទ្ធរូបមួយអង្គ មានព្រះនាមថាព្រះបាង[៥] ដែលយកមកពីស្រីលង្កា កសាងឡើងពីគ្រឿងអលង្ការរំលាយបញ្ចូលគ្នា ដែលនារីៗស្រុកនោះបរិច្ចាគទៅកាន់ស្រុកលាវ ។ ព្រះពុទ្ធរូបនេះ ព្រះរាជាកម្ពុជាបានទទួលពីព្រះរាជាស្រីលង្កាជាមិត្តភក្តិ ។

---

[៥] គេនិយាយថា ឈ្មោះរាជធានីហ្លួងប្រាបាង ក្លាយមកពីព្រះនាមព្រះពុទ្ធរូបនេះឯង ដែលព្រះរាជាកម្ពុជាទ្រង់បានធ្វើអំណោយឲ្យទៅព្រះរាជាលាវ ។

ព្រះពុទ្ធសាសនា ត្រូវបានផ្សព្វផ្សាយចូលទៅក្នុងប្រទេសលាវយ៉ាងនេះឯង ។

ហ្វាងៅម មានព្រះជន្ម ២១ ព្រះវស្សា នៅពេលដែលព្រះអង្គយាងចេញពីឥន្ទបត្តនគរមក ។ ទ្រង់មានព្រះជន្ម ២៦[៦] ព្រះវស្សា នៅពេលដែលទ្រង់ទទួលការអភិសេកមានព្រះនាមថា ភ្យាឡាក់សាតាវ៉ានីស៊ីសុតនៈកនៈហ៊ុត ហើយមានព្រះជន្ម៤០ ព្រះវស្សា នៅពេលដែលទ្រង់បាត់បង់ព្រះអគ្គមហេសីនាងកែវ ដែលជាបុត្រីព្រះរាជាកម្ពុជា ។

មរណភាពរបស់ព្រះមហាក្សត្រី ជាសញ្ញាបញ្ជាក់អំពីការបាក់ស្រុតចុះនៃព្រះរាជាណាចក្រ ។ គេនិយាយថា ព្រះមហេសីបាននាំយកទៅជាមួយនូវថាមពល និងគុណធម៌របស់ព្រះរាជា ។ ទ្រង់បានលះបង់កិច្ចការព្រះនគរឲ្យទៅអ្នកដែលជិតស្និទ្ធនឹងព្រះអង្គ ហើយទ្រង់ក្លាយទៅជាតឹងតែងចំពោះអ្នកឯទៀត ធ្វើឲ្យកើតមានការមិនសប្បាយចិត្តកាន់តែខ្លាំងឡើងៗ ប្រជារាស្ត្ររងទុក្ខវេទនា នៅទីបញ្ចប់ក៏សម្រេចដេញព្រះអង្គចេញពីរាជបល្ល័ង្កទៅ ។ ព្រះរាជាបាត់បង់រាជសម្បត្តិនេះ ដែលពីមុនទ្រង់អង់អាចក្លាហាន អាចដណ្ដើមយកស្រុកលាវទាំងមូល មកដាក់ក្រោមអំណាចបាន ក៏ត្រូវភៀសខ្លួនព្រះអង្គទៅគង់នៅ ថាតណាម ឬមឿងណាម រស់នៅទីនោះបានប៉ុន្មានឆ្នាំទៀត ហើយសុគតទៅនៅក្នុងឆ្នាំ១៣៦០ ក្នុងព្រះជន្មាយុ៤៤ព្រះវស្សា[៧] ។ ដូចជាព្រះរាជាវង្សនឯទៀតៗដែរ ទ្រង់បានទទួលព្រះមរណនាមថា ភ្យាហ្វាភ្យាណាន់[៨] ។

ព្រះរាជបុត្រាច្បងរបស់ព្រះអង្គព្រះនាមថាហ្វួនរុម បានត្រូវគណៈរដ្ឋមន្ត្រី (សេនាមាត្យា) និងសម្ដេច ព្រះសង្ឃរាជ ជ្រើសតាំងឲ្យឡើងសោយរាជសម្បត្តិបន្តពីព្រះអង្គ ។

វត្តព្រះពុទ្ធសាសនាដំបូងគេដែលព្រះសង្ឃខ្មែរ និមន្តមកពីឥន្ទបត្ត បានកសាងឡើងនៅវៀងច័ន្ទ តាំងពីរជ្ជកាលមុនម្ល៉េះ មានឈ្មោះថា វត្តព្រះកែវ ពីព្រោះគេបានយកថ្មកែវ ដែលបានពី ឥន្ទបត្ត មកបញ្ចុះត្រង់ផ្ចិតព្រះពុទ្ធបដិមាដែលតាំងនៅលើបល្ល័ង្ក ។ ព្រះរាជាបានផ្ដល់សិទ្ធិជ្រកកោនដល់វត្តនេះ បានសេចក្ដីថា វត្តនេះអាចទទួលរាល់ពិរុទ្ធជនណាដែលបានប្រព្រឹត្តបទល្មើស ហើយរត់មកចូលក្នុងវត្តនេះ ឲ្យស្នាក់នៅចាកផុតទុក្ខទោស

---

[៦] ឯកសារមួយទៀតនិយាយថា ទ្រង់មានព្រះជន្ម៣៧ព្រះវស្សា ។

[៧] ឯកសារមួយទៀតថា នៅក្នុងឆ្នាំ១៣៧៤ ក្នុងព្រះជន្មាយុ ៥៩ព្រះវស្សា ។

[៨] តាមមើលទៅព្រះនាមនេះប្រហែលត្រូវជា ព្រះចៅហ្វាព្រះនរិន្ទ ទេ ។

មានព្រះពុទ្ធរូបមួយអង្គ មានរូបរាងដូចស្ដេចនរោត្តម បានត្រូវគេធ្វើពិធីអភិសេកឡើងនៅភ្នំពេញ ក្នុងខែកុម្ភៈ ឆ្នាំ១៩០៩ នៅពេលដែលគេបញ្ចុះអដ្ឋិធាតុរបស់ព្រះអង្គ ទៅក្នុងព្រះចេតិយមួយ សង់ឡើងនៅក្នុងបរិវេណវត្តព្រះកែវមរកត ហើយព្រះអង្គទ្រង់ទទួលព្រះមរណនាមថា ព្រះអង្គម្ចាស់សុវណ្ណកោដ្ឋ ។ យើងឃើញថាទំនៀមទម្លាប់នេះ គេនៅតែថែរក្សាតរៀងរហូតមកនៅកម្ពុជា ។

បាន[៩] ។ បន្ទាប់មក ព្រះរាជា និងព្រះមហេសី បានយកស្លាបព្រាមាសដួសទឹកមន្តចាក់ទៅលើដី ដើម្បីឲ្យព្រះនាងធរណីធ្វើជាសាក្សីលើការបញ្ចុះសីមាវត្តនេះ និងព្រះពុទ្ធបដិមា ផងដែរ ។

ព្រះរាជាហ្វូនរុម សោយរាជ្យបានយូរណាស់ ហើយទ្រង់សុគតទៅនៅក្នុងឆ្នាំ១៨០៦ ក្នុងព្រះជន្មាយុ ៧៩ព្រះវស្សា ។

ព្រះរាជបុត្រាច្បងរបស់ព្រះចៅហ្វូនរុម ព្រះនាមឡាំកំដែង បានឡើងសោយរាជសម្បត្តិបន្ត ហើយសុគតទៅក្នុងព្រះជន្មាយុ៦៤ព្រះវស្សា ។ ចៅព្រហ្មកុមារបានឡើងសោយរាជ្យបន្ត (១៨២៥) ហើយត្រូវព្រះនាងកែវពិម្ពារ ជាព្រះមាតា និងជាព្រះមហេសី (មហាទេវី) របស់ព្រះរាជាមុនធ្វើគុត ៣ឆ្នាំក្រោយមក ក្នុងឆ្នាំ១៨២៨ រួចលើកព្រះរាជនត្តា ចៅកាយប៊ុណ្ណាបាន ឲ្យឡើងគ្រងរាជបល្ល័ង្កវិញ ។

ព្រះមហាទេវីនេះបានឲ្យគេធ្វើគុតព្រះរាជាអង្គនេះ និងព្រះរាជាបន្តបន្ទាប់៣ព្រះអង្គថែមទៀត ក្រោយពីលើកឲ្យសោយរាជ្យរួច ។ នៅទីបញ្ចប់ ព្រះនាងបានយកបុត្រារបស់បិតាចិញ្ចឹមជាស្វាមី ហើយលើកស្វាមីនេះឲ្យសោយរាជសម្បត្តិ ។ ប៉ុន្តែពេលនោះប្រជារាស្ត្រលែងទប់ចិត្តបានទៀតហើយ ក៏នាំគ្នាបះបោរឡើង សម្លាប់ទាំងព្រះមហាទេវី ដែលមានព្រះជន្ម៩៥ព្រះវស្សា និងព្រះស្វាមីក្មេងផងដែរ[១០] ។

មានឯកសារមួយនិយាយថាពេលនោះគឺគ្រិស្តសករាជ១៨២៨ ត្រូវនឹងមហាសករាជ១៣៥០ ចុល្លសករាជ ៧៩០ ។

បន្ទាប់ពីនោះ នគរត្រូវគ្មានស្តេចសោយរាជ្យអស់រយៈពេល៣ឆ្នាំ រហូតដល់ពេលដែលក្សាផុង[១១] ឬប៉ាន ខាវប៉ាសាក់ ដែលព្រះមហាទេវីធ្លាប់បានលើកឲ្យឡើងសោយរាជ្យដែរតែប្រកែក ព្រោះខ្លាចត្រូវព្រះនាងធ្វើឃាត បានយល់ព្រមឡើងគ្រងរាជបល្ល័ង្កវិញ ក្នុងឆ្នាំ១៨៣៨ ហើយទទួលព្រះអភិសេកនាមថា ព្រះចៅសញ្ជៈចក្កប៉ាទីប៉ែនពៅ ។

នៅក្នុងរជ្ជកាលស្តេចអង្គនេះ ក្សាសាយមួយដែលជាព្រះចៅរបស់វៀងច័ន្ទ មានបំណងចង់បំបែកខ្លួន ក៏ត្រូវព្រះអង្គចាត់ឲ្យគេសម្លាប់ រួចលើកអ្នកអង្គម្ចាស់ភឿកចៅផាក់ដេង ព្រះជន្មាយុ៣៥ព្រះវស្សា ឲ្យកាន់អំណាច

---

[៩] ដល់មកឆ្នាំ១៨៩១ គេបានពង្រីកបុព្វសិទ្ធិនេះទៅឲ្យវត្តមនុរាម និងបស្សរាម ផងដែរ ។

[១០] ដំណើររឿងរ៉ាវនេះ ដូចគ្នាបេះបិទទៅនឹងរឿងសៀមនៅសតវត្សរ៍ទី១៦ ដែលព្រះមាតាស៊ីសុដាច័ន្ទបានឲ្យគេធ្វើគុតព្រះរាជបុត្រដែលជាព្រះរាជា ដើម្បីលើកសហាយឲ្យឡើងគ្រងរាជបល្ល័ង្ក តែត្រូវសហាយនោះធ្វើឃាតវិញ នៅពេលក្រោយមក ។

មានរឿងដូចៗគ្នាច្រើនណាស់នៅក្នុងប្រវត្តិសាស្ត្រឥណ្ឌូចិន ជាក់ស្តែងដូចជារឿងនាយត្រសក់ផ្អែមសម្លាប់ស្តេចនៅកម្ពុជា នៅស្រុកសៀមក៏មានប្រហាក់ប្រហែលគ្នាដែរ ។ រឿងស្តេចក្រុងចន្ទ្រផងក៏ដូចគ្នា គ្រាន់តែថាតួអង្គជាស្តេចសៀមមិនមែនស្តេចខ្មែរទេ ។

[១១] ផុងក្នុងភាសាលាវត្រូវនឹងពាក្យវង្សក្នុងភាសាខ្មែរ ។ ក្សាផុង គឺ ព្រះវង្ស បានន័យថា ជាព្រះរាជវង្ស ។

ជំនួសវិញ ។ ពេលនោះអំណាចរបស់ព្រះអង្គរាតនៅលើទន្លេមេគង្គ ចាប់ពីណាមហុងនៅខាងត្បូង រហូតទៅដល់ព្រំប្រទល់មឿងសាយនៅខាងជើង ។

នៅពេលនោះ ព្រះរាជាមានដំរីមួយក្បាល កម្ពស់៩ហត្ថ មានសម្បុរគ្នោត ។ ដើម្បីបង្ហាញថា ព្រះអង្គមានអធិរាជភាពមកលើនគរលាវ ស្តេចអាណ្ណាមបានទាមទារឲ្យយកដំរីនោះទៅថ្វាយព្រះអង្គ[១២] ។ ព្រះចក្កប៉ាទី ប្រកែកមិនព្រមប្រគល់ដំរីឲ្យទេ ដើម្បីបង្ហាញថាទ្រង់មិនទទួលស្គាល់ថាលាវជានគរសាមន្តរាជរបស់អាណ្ណាមឡើយ ។ ស្តេចអាណ្ណាមក៏បញ្ជូនទ័ពឲ្យមកដាក់ទណ្ឌកម្មស្តេចលាវ ដោយចាត់ទុកថាជាស្តេចបះបោរ តែទ័ពនោះត្រូវវាយឲ្យបរាជ័យមិនឆ្ងាយប៉ុន្មានពីហ្លួងប្រាបាង ក្នុងសមរភូមិជាច្រើននៅពួនមឿង ក្នុងឆ្នាំ១៤៧៩ ។ លោក ម៉ារីនីនិយាយថា បរាជ័យរបស់ទ័ពអាណ្ណាម គឺបណ្តាលមកពីមានជំងឺឆ្លងមួយ ដោយសារពួកលាវបំពុលទឹក ។

នៅពេលនោះ ព្រះរាជាទ្រង់បានដាក់រាជសម្បត្តិថ្វាយព្រះរាជបុត្រា ចៅឡាសែនខៃ ដែលឡើងសោយរាជ្យក្រោមព្រះនាមថាព្រះចៅទុនឡាឡាសេនខៃ នៅក្នុងឆ្នាំ១៤៩១ នៃគ្រិស្តសករាជ ។ ហើយចៅវិសុនកុមារ នៃវៀងច័ន្ទ បានត្រូវលើកឲ្យធ្វើជាចៅនៅហ្លួងប្រាបាងវិញ រួចហើយឲ្យឡើងជាសែនសឿងតាមសំណូមពររបស់ព្រះសង្ឃ ឋានៈនេះស្មើនឹងឋានៈមហាឧបរាជនៅកម្ពុជា ។

មួយឆ្នាំក្រោយពីដាក់រាជសម្បត្តិមក[១៣] ព្រះរាជាសុគតទៅក្នុងព្រះជន្មាយុ ៨១ព្រះវស្សា ។ ពេលនោះស្តេចអយុធ្យាបានផ្ញើមឈូសមួយ មានលាបម្រ័ក្សណ៍ និងស្រោបមាស ហើយនិងក្រណាត់សូត្រ ៥០០ហត្ថសម្រាប់រុំព្រះសព[១៤] សមស្របទៅតាមទំនៀមហិណ្ឌូបុរាណ ។ ហេតុការណ៍នេះ នាំឲ្យមានសន្តិភាពដ៏យូរអង្វែងរវាងព្រះរាជាណាចក្រថៃ និងព្រះរាជាណាចក្រលាវ នៅពេលក្រោយមក ។

ព្រះចៅទុនឡាឡាសែនខាយ បានសុគតនៅក្នុងឆ្នាំ១៥០១ ។ ព្រះរាជបុត្រារបស់ព្រះអង្គព្រះនាមថាព្រះចៅជិពូ ព្រះជន្ម២៥ព្រះវស្សា មានព្រះនេត្រខ្វាក់ម្ខាង ប៉ុន្តែព្រះកាយស្រស់ល្អណាស់ បានឡើងសោយរាជ្យបន្តបាន៣ឆ្នាំ ក៏សុគតទៅទៀត ។

អ្នកអង្គម្ចាស់វិសួនជាមហាឧបរាជនៅហ្លួងប្រាបាង បានឡើងសោយរាជ្យបន្តក្នុងឆ្នាំបន្ទាប់មក ។ ទ្រង់

---

[១២] យើងនឹងបានឃើញនៅខាងក្រោយ ថាស្តេចសៀមមួយអង្គក៏ចង់ប្រើសិទ្ធិដូចគ្នានេះដែរ តែព្រះរាជាខ្មែរប្រកែក ។

[១៣] មានឯកសារមួយទៀតនិយាយថា១៩ឆ្នាំ ហើយបានបន្ថែមថាទ្រង់ឡើងសោយរាជ្យក្នុងឆ្នាំ១៥០១ រួចត្រូវគេដណ្តើមយករាជសម្បត្តិបន្ទាប់ពីសោយរាជ្យបាន ៣ឆ្នាំ ។

[១៤] សិទ្ធិរបស់ប្រទេសអធិរាជក្នុងការទាមទារយកដំរីសដែលប្រទេសសាមន្តរាជមាន គឺជាសិទ្ធិផ្តាច់ការ ប៉ុន្តែច្រើនតែជួបនឹងការប្រកែក ។ ក៏ប៉ុន្តែការបញ្ជូនមឈូសស្រោបមាស និងក្រណាត់សូត្រមួយចំនួនសម្រាប់រុំសពព្រះរាជាចំណុះ គឺជាកាតព្វកិច្ចមួយរបស់ប្រទេសអធិរាជ ដែលបញ្ជាក់អំពីអធិរាជភាព ដូចការទាមទារដំរីផងដែរ ។

សោយរាជ្យបាន៣០ឆ្នាំ រួចបានសុគតនៅក្នុងព្រះជន្មាយុ ៧៧ព្រះវស្សា ប្រហែលក្នុងឆ្នាំ១៥៣០ ។

ព្រះចៅពោធិសារាជ្យ ព្រះជន្ម១៧ព្រះវស្សា ក៏ឡើងសោយរាជ្យបន្តពីព្រះបិតា ។ ប្រហែលគឺព្រះរាជាអង្គនេះហើយ ដែលបានប្តូររាជធានីលាវមកវៀងច័ន្ទវិញ ដោយដូរឈ្មោះទៅជា ស៊ីសុតានាខណាហ៊ុតស៊ី (ឡានសាង ឬឡានឆាន) ហោមខាវ[១៥] ជាឈ្មោះដែលគេដាក់ឲ្យហ្លួងប្រាបាងពីមុន ។

មកដល់ពេលនេះ សង្គ្រាមបានផ្ទុះឡើងរវាងស្តេចអយុធ្យា និងស្តេចលាវ ដោយមានអ្នកអង្គម្ចាស់សៀមមួយអង្គរត់មកជ្រកកោននៅក្នុងរាជវាំងវៀងច័ន្ទ ហើយព្រះរាជាលាវមិនព្រមបញ្ជូនទៅថ្វាយស្តេចសៀមវិញ ។ នៅក្នុងសង្គ្រាមនោះ ស្តេចសៀម ភ្យាអាទិត្យ ត្រូវរងរបួសដោយគ្រាប់កាំភ្លើង រួចហើយក៏ត្រលប់ទៅសុគតនៅឯស្រុកសៀមវិញ ។ រាជពង្សាវតារសៀមមិនបាននិយាយអំពីសង្គ្រាមនេះទេ ហើយក៏ មិនមានរៀបរាប់អំពីស្តេចសៀមណា ដែលត្រូវសុគតដោយសារធ្វើសង្គ្រាមជាមួយលាវដែរ[១៦] ។

គេនិយាយថែមទៀតថា នៅសម័យនោះ ប្រទេសលាវជាប្រទេសមួយសម្បូរសប្បាយ (ស្តេចចៅ) នៃ (បណ្តាស្រុកមឿង) ចំណុះទាំងឡាយ តែងតែលើកសួយសារអាករមកថ្វាយព្រះរាជា ឥតមានអាក់ខានឡើយ ។

ដប់ឆ្នាំក្រោយពីធ្វើសង្គ្រាមជាមួយសៀមរួចមក ចៅពោធិសា បានយាងទៅកាន់ឈៀងម៉ៃ ដែលមានព្រះរាជា ព្រះរាជបុត្រាទាំង២របស់ព្រះអង្គ និងនាយករដ្ឋមន្ត្រីដែលកាន់អំណាចបន្តពីព្រះរាជា ត្រូវគេធ្វើឃាតអស់ ។ ព្រះចៅពោធិសា បានយករាជាណាចក្រនោះដាក់មកក្នុងអំណាចព្រះអង្គ រួចប្រគល់ទៅឲ្យព្រះ រាជបុត្រាច្បង ដែលជាឧបរាជគ្រប់គ្រង ដោយថ្វាយព្រះនាមថា ព្រះអ៊ូវ៉ាញ[១៧] ។

---

[១៥] ព្រះរាជាណាចក្រសម្បូរសប្បាយ សម្បូរទៅដោយសិរពស់ និងដំរីស្វេតច្ឆត្រស ។ ឡានឆាង ជាពាក្យចិន មានន័យថា ដំរីរាប់លាន ។

មានឯកសារមួយនិយាយថា ការប្តូរទីតាំងរាជធានីនេះកើតមានឡើងនៅក្នុងឆ្នាំ១៥៦៥ ក្រោមរជ្ជកាលស្តេច សេតាក់ ជាបុត្រស្តេចពោធិសា ឡើងសោយរាជ្យបន្តក្នុងឆ្នាំ១៥៤៨ ។

[១៦] មានស្តេចសៀមមួយអង្គដែលត្រូវសុគតនៅក្នុងចម្បាំងមួយ ប៉ុន្តែចម្បាំងនោះមិនមែនធ្វើជាមួយនឹងពួកលាវទេ គឺធ្វើជាមួយនឹង ពួកប៉េហ្គូនទៅវិញ ។ ព្រះអនុជរបស់ព្រះរាជា ព្រះនាមថា ឯកទសរុទ្ធ បានឡើងសោយរាជ្យបន្តបាន ៦ឆ្នាំ ។ សម័យនោះ សៀម គ្មានសង្គ្រាមជាមួយនឹងលាវទេ ។ ម្យ៉ាងទៀត គ្មានស្តេចសៀមណាដែលមានព្រះនាមថា ភ្យាអាទិត្យ នោះដែរ ។ អ្នកសរសេរពង្សាវតារលាវប្រហែលជាមិនបានបញ្ឆាក់រកការពិតទេ ព្រោះសូម្បីតែឈ្មោះស្តេចក៏មិនត្រឹមត្រូវផង បើដូច្នេះ អាចនិយាយថាគាត់មិនបានដឹងអំពីរឿងរ៉ាវដែលកើតនៅក្រៅស្រុកលាវច្បាស់ឡើយ ទាំងការបោះបង់អង្គរធំនៅក្នុងសតវត្សរ៍ទី១៤ ហើយនិងការបែករាជធានីលង្វែកនៅចុងសតវត្សរ៍ទី១៦ ។

[១៧] ត្រង់នេះក៏គ្មានរៀបរាប់នៅក្នុងរាជពង្សាវតារសៀមដែរ ណាមួយឈៀងម៉ៃនេះជារាជធានីដ៏ល្អមួយ ដែលសៀមខ្លួនឯង មានការលំបាកខ្លាំងណាស់នឹងដណ្តើមយកមកដាក់ក្នុងអំណាច ។ យើងបានឃើញរួចមកហើយថា ស្តេចសៀមបានវាយឈៀងម៉ៃ

ព្រះចៅពោធិសាសោយរាជ្យជាច្រើនឆ្នាំបន្តមកទៀត រួចត្រូវសុគតដោយធ្លាក់ពីលើកដំរី នៅក្នុងពេលដែលទ្រង់ចង់បង្ហាញថ្វីព្រះហស្តដល់ស្តេចបរទេសមួយអង្គ ដោយជិះដំរីផ្សាំងហ្វឹងដំរីដែលទើបតែទាក់បាន ។

ព្រះចៅសេតាក់ជាព្រះរាជបុត្រាបានឡើងសោយរាជ្យបន្តពីព្រះអង្គនៅក្នុងឆ្នាំ១៥៤៨ ។ ក្នុងរជ្ជកាលនេះ ព្រះរាជាត្រូវចេញបង្ក្រាបការបះបោរមួយរបស់ពួកថាញ់ងូ ដែលបានលើកចៅមេឃូជាស្តេច រួចមិនបានប៉ុន្មានផង ក៏មានចិត្តចង់ដណ្តើមយកឈៀងម៉ៃ ។ លោក ឪពុកហ្សង់ម៉ារីឡឺរីយ៉ា និយាយថា ជ័យជម្នះនេះបានមកពីការបំពុលទឹកដូចមុនដែរ ។

ចៅសេតាក់ បានយាងមកគង់នៅរាជធានីវៀងច័ន្ទ ។ ស្តេចសៀមបានបញ្ជូនបុត្រីមួយអង្គមកថ្វាយ ដើម្បីឲ្យទ្រង់ទទួលយកជាព្រះជាយា ប៉ុន្តែចៅសេតាក់បានបញ្ជូនព្រះនាងត្រលប់ទៅវិញ ដោយមិនពេញព្រះទ័យ ។ ស្តេចសៀម ក៏បញ្ជូនព្រះរាជបុត្រីច្បងមកថ្វាយម្តងទៀត ចៅសេតាក់ពេញចិត្ត ក៏ព្រមទទួល ។

បួនឆ្នាំក្រោយមក ស្តេចសៀម មហាចក្រពត្ររាជាធិរាជបានស្នើសុំជំនួយពីស្តេចលាវទប់ទល់នឹងស្តេចប៉េហ្គូ ដែលលើកទ័ពចូលមកឈ្លានពាន ដោយស្តេចសៀមប្រកែកពុំព្រមបញ្ជូនដំរីស៧ក្បាលទៅថ្វាយ ។ ចៅសេតាក់ បានកេណ្ឌទ័ពភ្លាម រួចចេញវាយពួកប៉េហ្គាន បង្ខំឲ្យដកថយចេញពីអយុធ្យាទៅកាន់ស្រុកវិញទៅ រាជពង្សាវតារសៀមនិយាយថានៅក្នុងឆ្នាំ១៥៤៤ ។ បានប៉ុន្មានឆ្នាំក្រោយមក ពួកប៉េហ្គានបានលើកគ្នាមកវាយម្តងទៀត ធ្វើឲ្យស្តេចសៀមព្រះមហិន្ទ្រាធិរាជ ដែលជាបុត្ររបស់ព្រះមហាចក្រពត្ររាជាធិរាជបរាជ័យ រត់គេចចេញពីរាជធានីទៅ នៅក្នុងឆ្នាំ១៥៥៥[១៨] ។

ចៅហ៊្វាម៉ង់តា ស្តេចប៉េហ្គាន វាយយកអយុធ្យាបាន ដុតកម្ទេចខ្ទេចខ្ទី រួចហើយមានបំណងចង់បន្តមកវាយយកវៀងច័ន្ទទៀត តែវាយយកមិនបាន ហើយបានចាប់យកឧបរាជជាឈ្លើយ នាំយកទៅកាន់រាជធានីអវ៉ារបស់ពួកគេបាត់ទៅ ។

ព្រះចៅសេតាក់ទ្រង់សុគតដោយជំងឺឆ្លងមួយ ដែលធ្វើឲ្យកងពលរបស់ព្រះអង្គជាច្រើនស្លាប់ជាមួយគ្នាផងដែរ នៅពេលដែលយាងត្រលប់មកពីធ្វើចម្បាំងវិញ ។

---

ជាច្រើនលើកច្រើនសា នៅក្នុងឆ្នាំ១៣៨០ រួច១៣៨៣ បន្ទាប់មក១៣៨៤, ១៤២៨ ដណ្តើម កាន់កាប់រាជធានីនេះបាន នៅក្នុងឆ្នាំ១៤៣០ ហើយរហូតទាល់តែដល់ឆ្នាំ១៥២៦ ទើបចាត់ទុកថាយកមកដាក់បញ្ចូលក្នុងព្រះរាជាណាចក្របាន ។ បើតាមព្រឹត្តិការណ៍នេះ ការដែលនិយាយថា លាវយកបានឈៀងម៉ៃមកគ្រប់គ្រង គឺពិតជាស្តេចសៀមមិនឯកភាពប៉ុន្មានទេ ណាមួយស្តេច សេតាក់បានប្រកែកពុំព្រមទទួលយករាជបុត្រីដែលបានបញ្ជូនមកថ្វាយជាព្រះជាយាផងទេ ព្រោះមិនស្រលាញ់ ទាល់តែបញ្ជូនមួយអង្គទៀតមកថ្វាយទើបយល់ព្រមទទួល ។

[១៨] សៀមចោទថា មានមន្ត្រីក្បត់ម្នាក់ជាអ្នកធ្វើឲ្យរាជធានីធ្លាក់ទៅក្នុងដៃសត្រូវ ។

ក្បាអាសែន ដែលប្រហែលគឺជាខបរាជនៅពេលនោះ បានដណ្តើមយករាជបល្ល័ង្កនៅក្នុងឆ្នាំ១៥៧២ ។ ស្តេចប៉េហ្កាន ព្រះនាមថាចៅហ៊្វាអេម៉ាឡេ បាននាំទ័ពចូលមកវាយយករាជធានីវៀងច័ន្ទបានម្តងទៀត រួចហើយបានលើកខបរាជ មិនដឹងថាគឺខបរាជរបស់ក្បាអាសែន (ឬជាខបរាជដែលគេបានចាប់យកទៅអវ៉ា ពីមុន) ឲ្យឡើងគ្រងរាជបល្ល័ង្កវិញ ។

មួយឆ្នាំក្រោយមក មានមេទ័ពភូមា៤រូបបានចេញមកធ្វើសង្គ្រាមនៅលាវ ប្រឆាំងនឹងពួកប៉េហ្កាន ជំនួសណូមឿង ដែលត្រូវជាបុត្ររបស់សេតាក់ ។

ពេលនោះមានជនកំហូចម្នាក់បះបោរឡើងនៅអាតូពឺ ហើយបានប្រកាសខ្លួនថាជាព្រះចៅសេតាក់ ។ ស្តេចលាវ ដែលពួកប៉េហ្កាន បានលើកឲ្យឡើងសោយរាជ្យ បានបញ្ជូនទ័ពឲ្យទៅវាយប្រហារ ហើយត្រូវសុគតនៅក្នុងឆ្នាំ១៥៧៩ ។

ក្បាអាសែន បានត្រលប់មកសោយរាជសម្បត្តិវិញនៅក្នុងឆ្នាំ១៥៨០ ហើយសុគតនៅក្នុងឆ្នាំ១៥៨២ ។ (រដ្ឋមន្ត្រីទាំង ៤ចតុស្តម្ភ) បានជ្រើសតាំងចៅណូមឿង ជារាជបុត្ររបស់ចៅសេតាក់ ឲ្យឡើងសោយរាជសម្បត្តិនៅក្នុងឆ្នាំ១៥៨៤ ក៏ប៉ុន្តែមិនបានប៉ុន្មានផង ចៅណូមឿងត្រូវរត់គេចភៀសខ្លួនជាមួយចៅឈៀងម៉ៃ ក្រោមការគាបសង្កត់ពីពួកប៉េហ្កាន ។ នៅពេលនោះ ចៅហ៊្វា ជាស្តេចរបស់ប៉េហ្កាន បានឡើងសោយរាជ្យលើរាជបល្ល័ង្កលាវនៅក្នុងឆ្នាំ១៥៩០ ។

ស្តេចនេះសោយរាជ្យបាន៩ឆ្នាំ រហូតដល់ឆ្នាំ១៥៩៩ អ្នកស្រុកវៀងច័ន្ទក៏បះបោរឡើង បណ្តេញស្តេចបរទេសនេះចេញពីស្រុកទៅបាត់ ។ អ្នកដែលឡើងគ្រងរាជបល្ល័ង្កបន្តមកជាកុមារពនេចរម្នាក់ ឈ្មោះថា ព្រះថានីមានអាយុទើបតែបាន ១៨ឆ្នាំប៉ុណ្ណោះ ។

ពួកលាវនិយាយថា ស្តេចក្មេងនេះ ជាប់អម្បូរបុព្វបុរសដែលជាស្តេចថៃតាំងតែពី១ពាន់ឆ្នាំមុនម្ល៉េះ ។ បុព្វបុរសនេះជាស្តេចលាវទី១ ដែលបានត្រូវគេលើកឲ្យសោយរាជ្យបន្តពីប្រភេទសាធារណរដ្ឋមួយបែប ក្រោយពីគេបានបណ្តេញពួកចិនចេញទៅ នៅសតវត្សរ៍ទី៦ នៃគ្រិស្តសករាជ ។ សាធារណរដ្ឋបែបនេះមិនអាចបន្តមានអត្ថិភាពបាន ដោយសារពួកអ្នកដឹកនាំមិនស្រុះស្រួលគ្នាក្នុងការជ្រើសរើសមេម្នាក់ក្នុងចំណោមគ្នាឯង ក៏សម្រេចជ្រើសរើសយកស្តេចចេញពីរាជវង្សថៃមកវិញ ។

នៅសតវត្សរ៍ទី១៧ ស្តេចលាវមានអំណាចផ្តាច់ការទាំងខាងអាណាចក្រ និងពុទ្ធចក្រ ។ ដីធ្លីទាំងអស់ នៅក្នុងព្រះរាជាណាចក្រ ព្រមទាំងទ្រព្យសម្បត្តិទាំងឡាយរបស់ប្រជារាស្ត្រ ជារបស់ព្រះរាជា ដូចជានៅប្រទេសឥណ្ឌាដែរ ។ សម័យនោះមិនទាន់មានស្រទាប់អភិជននៅឡើយទេ មុខងារ និងឋានៈផ្សេងៗអាស្រ័យទៅតាមតែព្រះទ័យរបស់ព្រះរាជា ព្រោះព្រះអង្គជាអ្នកបង្កើតមន្ត្រី ។ អ្វីៗដែលព្រះរាជា បានប្រទានឲ្យនរណាម្នាក់នឹងត្រូវត្រលប់មកជារបស់ព្រះរាជាវិញ នៅពេលដែលអ្នកនោះស្លាប់ទៅ ដូចជានៅកម្ពុជា ឥណ្ឌាសម័យពួកម៉ុងហ្គោល

និងនៅប្រទេសជាច្រើនទៀតនៅអាស៊ីដែរ ។

មានមន្ត្រីធំ៨នាក់ជួយក្នុងកិច្ចការគ្រប់គ្រងព្រះរាជាណាចក្រ ៖ សែនមឿង គឺឧបរាជ ដែលលោកវ៉ាន់វ្លូស្ហូ ហៅថា គេវីនីញ៉ាកំប៉ាន ឬគេវីនីញ៉ាសែន[១៩] ហើយដែលយើងបានឃើញពីខាងលើរួចមកហើយ គឺមានឋានៈជាចៅ ។ សែនមឿង ទទួលបន្ទុកកិច្ចការព្រះនគរមួយចំណែក ជួយព្រះរាជានៅក្នុងការគ្រប់គ្រងព្រះរាជាណាចក្រ ហើយធ្វើការកោះប្រជុំនាម៉ឺនសព្វមុខមន្ត្រី នៅពេលដែលព្រះរាជាសុគតទៅ ដើម្បីជ្រើសរើសព្រះរាជាមួយអង្គទៀត ។ ក្នុងពេលរង់ចាំលទ្ធផលនៃការជ្រើសរើសព្រះរាជាថ្មីនេះ សែនមឿង ដឹកនាំប្រទេសហើយមានអំណាចបី ដូចជាព្រះរាជាដែរ ។ ពួកហុល្លង់បានបញ្ជាក់ថា សិទ្ធិទាំងអស់នេះរបស់ សែនមឿង មានពិតមែន ហើយបាន និយាយបន្ថែមអំពីបែបបទបន្តរាជ្យថា «នៅក្នុងសតវត្សរ៍ទី១៧ សិទ្ធិឡើងសោយរាជ្យបន្តនេះ អនុវត្តបានតែចំពោះរាជបុត្រ ដែលប្រសូត្រចេញពីព្រះមហេសីមានខាន់ស្លា» ប៉ុណ្ណោះ ។

ហើយ ដោយព្រះរាជាណាចក្រត្រូវបែងចែកចេញជាខេត្រធំៗ (មឿង) ៧ បើសិនណាប្រទេសសុខសប្បាយជាធម្មតា មានមន្ត្រីធំៗ៧នាក់ទៀត មានអំណាចមិនចាញ់មហាឧបរាជប៉ុន្មានទេ ដែលគ្រប់គ្រងលើមឿងនីមួយៗនោះតាមរយៈអនុសេនីយ៍របស់ខ្លួន ប៉ុន្តែខ្លួនឯងរស់នៅក្នុងរាជធានីជាមួយនឹងព្រះរាជា ។ មន្ត្រីធំៗទាំងអស់នេះប្រៀបបានទៅនឹងពួកកំណាន់ខេត្រនៅកម្ពុជា ដែលមានឋានៈជារដ្ឋមន្ត្រី ធ្វើការនៅអមព្រះរាជាហើយចាប់ពីពេលមិនយូរប៉ុន្មាន ទទួលខុសត្រូវលើខេត្រមួយ ដែលមានចៅហ្វាយស្រុកត្រួតត្រាផ្សេង ចៅហ្វាយស្រុកនោះ បានត្រូវព្រះរាជាតែងតាំងឡើងតាមតែសំណូមពររបស់កំណាន់ខេត្រ ដោយទ្រង់មិនបានត្រួតពិនិត្យពីលើទៀតទេ ។ មន្ត្រីធំប្រចាំមឿងទាំង៧នាក់នេះ ជាទីប្រឹក្សារបស់ព្រះរាជា[២០] ។

នៅពីក្រោមមន្ត្រីធំៗទាំង៨រូបនេះ មានមន្ត្រីតូចធំជាច្រើនទៀត ដែលចំណុះឲ្យលោកមន្ត្រីធំម្នាក់ៗម្ល៉ោះហើយគោរពប្រណិប័តន៍មន្ត្រីធំនោះ ។

---

[១៩] វីនីញ៉ា គឺពញា ។ គេ ប្រហែលត្រូវនឹងពាក្យខ្មែរថា ទេព, ទេវៈ ។ ចំណែកឯពាក្យសែន ប្រហែលមកពីពាក្យថាសេនា ។ កំប៉ាន ប្រហែលត្រូវនឹងពាក្យថា កំពែង ។

[២០] ការរៀបចំការគ្រប់គ្រងប្រទេសបែបនេះ មិនមែនមាននៅក្នុងព្រះរាជាណាចក្រវៀងច័ន្ទតែមួយនោះទេ ។ នៅកម្ពុជា គេឃើញមានពួកកំណាន់ខេត្រ ដែលជារដ្ឋមន្ត្រី ហើយគេឃើញមានប្រហែលៗគ្នាដែរនៅក្នុងពួកស៊ីបសាងប៉ាណា ដែលមានមន្ត្រី ៤នាក់ ជាចៅហ្វាយលើស្រុកសំខាន់ៗទាំង៤, ហើយនិងស៊ីបសាងកាណាដែលជាចៅហ្វាយលើស្រុកទាំង១២ ។ នៅសៀងតុង ការគ្រប់គ្រងមានរូបភាពធំធេងជាងបន្តិច ដោយមានក្រុមប្រឹក្សាមួយនៅជាប់ជាមួយនឹងព្រះរាជា មានសមាជិកដល់ទៅ៣២នាក់ ដែលជ្រើសតាំងឡើងដោយព្រះរាជា ជាតំណាងស្រុកទាំង៣២នៅក្នុងព្រះរាជាណាចក្រ ។ មើលទៅ កាលពីមុនមានការរៀបចំអំណាចបែបនេះនៅទូទាំងឥណ្ឌូចិន ។

ខេត្តនីមួយៗក្នុងបណ្តាខេត្តទាំង៧មានទ័ពជើងគោក ទ័ពសេះ និងមេទ័ពផ្ទាល់របស់ខ្លួន ដែលស្តាប់បញ្ជារបស់លោកឧត្តមមន្ត្រីប្រចាំខេត្ត ដែលនៅជាប់ជាមួយព្រះរាជា បើសិនជាប្រទេសមានសុខសន្តិភាពធម្មតា ។ ពេលមានសឹកសង្គ្រាម ទ័ពទាំងអស់នោះអាចនឹងស្តាប់បញ្ជារបស់មហាឧបរាជវិញក៏មាន ។ ទ័ពទាំងអស់ទទួលការផ្គត់ផ្គង់ផ្ទាល់ពីខេត្តដើមរបស់ខ្លួន ។

រាជវាំងរបស់ព្រះរាជាល្អណាស់ មានភីលៀងជាច្រើននាក់ ។ ព្រះរាជាមានព្រះជាយារាប់រយនាក់ ព្រះជាយាទាំងនោះ មានស្ត្រីបម្រើរាប់ពាន់នាក់ ។ គេស្គាល់ឋានៈមន្ត្រីទៅតាមទ្រព្យសម្បត្តិ ដែលមានទៅតាម ទំហំប្រអប់ដាក់ស្លាម្លូ ទៅតាមសញ្ញាសម្គាល់ផ្សេងៗ ធ្វើអំពីមាសឬប្រាក់ដែលពាក់ និងទៅតាមសម្រស់យានជំនិះ ដែលគេជិះដូចជា នៅកម្ពុជា ឬនៅសៀមអ៊ីចឹងដែរ ។ មានតែមហាឧបរាជទេ ដែលមានសិទ្ធិជិះដំរីដូចជាព្រះរាជា នៅក្នុងក្បួនហែព្រះអង្គ ។ មន្ត្រីឯទៀតៗ ហែជិះគ្រែស្នែងតូចធំទៅតាមឋានៈរបស់ខ្លួន លម្អទៅដោយព្រំពណ៌មាស ។

ព្រះរាជាកម្រនឹងបង្ហាញព្រះភ័ក្ត្រជាសាធារណៈណាស់ ទ្រង់យាងចេញជួបប្រជាជនតែ២ដងប៉ុណ្ណោះ ក្នុងមួយឆ្នាំៗ ប៉ុន្តែ ចន្លោះពេលរវាងពេលទាំង២នេះ មានតែ១ថ្ងៃប៉ុណ្ណោះ ដូចជាព្រះរាជាវៀន ស្តេចប៉េហ្គាន ឬស្តេចសៀមដែរ[២១] ។ នៅពេលនោះ ទ្រង់គ្រងព្រះភូស្ត្រាប៉ាក់មាសគង់លើដំរី នៅលើព្រះកេសមានកំណាត់បូរមាសព័ទ្ធជុំវិញ ដើម្បីចងសក់ដែលវែងអន្លាយ ព្រះកាណ៌មានពាក់ទំហូធំៗ ដែលធ្វើឲ្យត្របកត្រចៀកយារវែងដល់ស្មា ។ ទ្រង់យាងទៅកាន់ប្រាសាទដើម្បីថ្វាយតង្វាយដល់សាសនិកជន[២២] ។ នៅពីខាងមុខព្រះរាជាមាននាម៉ឺនសព្វមុខមន្ត្រីដើរហែតាមឋានៈរៀងៗខ្លួន និងតន្ត្រីករជាច្រើន ។

នៅក្នុងឆ្នាំ១៦៤២ លោក ហេ្សរ៉ាវ៉ាន់វូស្ទូហ្វ ដែលធ្វើដំណើរចេញពីកម្ពុជាទៅកាន់វៀងច័ន្ទដែលគាត់ហៅថា «វៀងច័ន្ទនៃប្រទេសលូវែន» បានទៅដល់ទីនោះនៅថ្ងៃទី៨ ខែវិច្ឆិកា ហើយបាននិយាយបញ្ជាក់ថាមានពលទាហាន ៣០០នាក់ ដៃកាន់លំពែង ឬកាំភ្លើង ដើរពីខាងមុខព្រះរាជា ។ បន្ទាប់មក គឺទ័ពដំរីមានអ្នកជិះកាន់អាវុធគ្រប់ដៃ រួចហើយគឺទ័ពភ្លេងចំនួន២០០នាក់ នៅចុងបញ្ចប់គឺស្រីស្នំរបស់ព្រះរាជាជិះលើដំរី១៦ក្បាល ។ ព្រះរាជាមានព្រះជន្ម២៣ព្រះវស្សា ទ្រង់សោយរាជសម្បត្តិ៣ឆ្នាំរួចមកហើយ (១៦៤២) បន្តពីព្រះរៀមដែលសុគតទៅក្រោយពីសោយរាជ្យបាន១០ឆ្នាំ តែគ្មានបុត្រស្នង ។ ព្រះរាជាទ្រង់ប្រកបទៅដោយធម៌ខ្លាំងណាស់ និងមានមន្ត្រីជាទីប្រឹក្សាដ៏ប៉ិនប្រសប់ ហៅថាពួកទេវីនីញ៉ា ។ ដំរីព្រះរាជា ជាដំរីដែលធំ និងល្អជាងគេ មានពាក់កម្រាលព្រំដ៏ធំហៀរដល់ដី រំលេចទៅដោយគ្រឿងអលង្ការជាច្រើន លោក ហ្សង់ម៉ារីឡឺរីយ៉ា និយាយពន្ទើសថា (លម្អទៅដោយ

---

[២១] សូមអានទំនាក់ទំនងការទូតរបស់ស្តេចល្វី ទី១៤ ជាមួយស្តេចសៀម និងអានកំណត់ត្រារបស់ ជាវតាក្កាន់ ស្តីអំពីកម្ពុជា ។

[២២] នៅកម្ពុជា គឺបុណ្យកឋិន ។

ទ្រព្យសម្បត្តិទាំងអស់របស់ព្រះរាជាណាចក្រ) ។ នៅថ្ងៃដែលព្រះរាជាយាងចេញក្រៅ នារីៗមិនត្រូវចេញពីផ្ទះទេ ប៉ុន្តែអាចមើលព្រះរាជាធ្វើដំណើរពីមាត់បង្អួចបាន ។ ព្រះសង្ឃត្រូវនិមន្តមកទទួលព្រះរាជាឲ្យបានឆ្ងាយបន្តិចពីវត្ត ។

ទូតបរទេស តែងទទួលបាននូវការទទួលរាក់ទាក់ខ្លាំងណាស់ ហើយព្រះរាជាសព្វព្រះទ័យចង់ឲ្យពួកនេះ ចូលរួមទស្សនាល្បែងកើតចេញពីការផ្សាំងដំរីក្មេងៗ ទើបតែទាក់បាន ដែលគេរៀបចំឡើងដើម្បីឲ្យប្រជារាស្ត្រ និងសេវកាមាត្យបានសប្បាយ[២៣] ទស្សនារបាំរបស់ពួកស្រីភីលៀង និងទស្សនាការបាញ់កាំជ្រួច ។ ព្រះរាជាទទួលពួករាជទូត បរទេសនៅក្នុងបន្ទប់មួយធំ ដោយទ្រង់គង់នៅលើបល្ល័ង្កយ៉ាងខ្ពស់ ព្រះព័ស្ត្រស្អាតៗ និងធ្វើទំនាក់ទំនងជាមួយបណ្តារាជទូតទាំងនោះ តាមរយៈនាយករដ្ឋមន្ត្រីរបស់ព្រះអង្គ ទ្រង់មិននិយាយតទល់ផ្ទាល់តែម្តងទេ ដូចជានៅស្រុកសៀម កម្ពុជា ប៉េហ្គូ និងអាវ៉ាកាន់ ដែរ ដែលព្រះរាជាទ្រង់បង្ហាញព្រះអង្គតែតាមមាត់បង្អួចតែប៉ុណ្ណោះ[២៤] ។

លោក ហេរ្វ៉ាវ៉ាន់វូសូហ្វ បានរៀបរាប់ថា សារលិខិតដែលឧត្តមសេនីយ៍របស់ក្រុមហ៊ុនគាត់ នៅបាតាវីយ៉ា ឲ្យគាត់កាន់មកបានត្រូវមន្ត្រីធំដែលគាត់ហៅថា ទេវីនីញ៉ា ទទួលយក ដាក់លើជើងពានមាស មានបាំងក្លស់មាសយ៉ាងខ្ពស់ កម្ពស់ស្មើនឹងដងក្តោងរបស់សំពៅធំមានអ្នកអុំ៤០នាក់ ដែលគេបញ្ជូនឲ្យទៅទទួលគាត់នៅចម្ងាយប្រហែលជាងមួយគីឡូម៉ែត្រពីរាជធានី ។ ការនាំសារតាំងមកថ្វាយព្រះរាជាប្រព្រឹត្តទៅបែបនេះ ។ ពិធីអធិកអធមដូចគ្នានេះ មានរៀបរាប់ឡើងដែរ ដោយសមាជិករាជទូតដែលស្តេចល្វីទី១៤ បានបញ្ជូនទៅគាល់ស្តេចស្រុកសៀម ហើយមានរៀបរាប់ប្រហាក់ប្រហែលគ្នាដោយវរសេនីយ៍ត្រី ស៊ីម និងអនុសេនីយ៍ឯក ហ៊ីរ៉ាមកុក ជាទូតដែលក្រុមហ៊ុនអង់គ្លេសនៅឥណ្ឌា បញ្ជូនទៅភូមានៅក្នុងឆ្នាំ១៧៩៥ និង១៧៩៦ ។

លោកឪពុក ម៉ារីនី បាននិយាយថា នៅពេលដែលទ័ពអវ៉ាគ្រប់គ្រងខែត្រមួយរបស់លាវ ដែលមិនចង់លើកសួយសារអាករទៅឲ្យនៅក្នុងសតវត្សរ៍ទី១៦ ស្តេចអវ៉ាបានចូលលុកលុយស្រុកលាវ ដណ្តើមយករាជធានីបាន រួចនាំប្រជាជនជាច្រើនយកទៅជាមួយ ។ ហេតុការណ៍នេះ មិនមានរៀបរាប់នៅក្នុងរឿងដែលខ្ញុំបានលើកខាងលើ

---

[២៣] យើងបានឃើញពីខាងលើហើយថា ល្បែងនេះមិនមែនសុទ្ធតែគ្មានគ្រោះថ្នាក់នោះទេ ព្រោះព្រះពោធិសារាជ បានសុគតក្នុងពិធីនេះក្នុងឆ្នាំ១៥៤៨ នៅមុខបណ្តាទូត ដែលទ្រង់ចង់ធ្វើឲ្យសប្បាយ ។

[២៤] នៅសម័យដំណាលគ្នានោះ ពួកស្តេចម៉ុងហ្គោលដែលសោយរាជ្យនៅរាជធានីដែល្ហី ឬអាក្រា បានទទួលពួករាជទូតនៅក្នុងបន្ទប់ដ៏ស្អាតមួយ ហៅថា ឌីវ៉ាន់តអាំ ហើយទ្រង់បង្ហាញខ្លួននៅក្នុងឡូស៊ីយ៉ាមួយ ដាក់នៅលើតុធ្វើអំពីថ្មើមថ្មធំមួយ ដែលមានបណ្តារដ្ឋមន្ត្រីទាំងឡាយអង្គុយជុំវិញ ។ ទ្រង់មិនទទួលយកសារតាំងដោយផ្ទាល់ព្រះហស្តទេ វីសៀរ របស់ព្រះអង្គជាអ្នកទទួល ក៏ប៉ុន្តែ ទ្រង់មានព្រះបន្ទូលទៅកាន់ពួកទូតទាំងនោះ សាកសួរសំណួរផ្សេងៗ ហើយពួកទូតទាំងនោះអាចសាកសួរសំណួរមកព្រះអង្គវិញបាន ។ ស្តេចពែក្ស ក៏រៀបចំការទទួលរាជទូតបរទេសបែបដូចគ្នានេះដែរ ។

ទេ ហើយក៏មិនមាននៅក្នុងរឿងជាបន្តទៅទៀតដែរ ។ ពួកលាវដែលជាប់ជាឈ្លើយនៅប៉ោហ្គូ មិនសប្បាយចិត្តនឹងពួកអ្នកត្រួតត្រាលើខ្លួនទេ ថ្ងៃមួយក៏ចាប់កាន់អាវុធបះបោរឡើង ។ ប៉ុន្តែពួកគេមិនបានវាយដណ្តើមយក ប៉ោហ្គូទេ ទោះបីថាពេលនោះជាការងាយណាស់ក៏ដោយ គឺគ្រាន់តែវាយសត្រូវឲ្យបរាជ័យ រួចនាំគ្នាវិលត្រលប់មកស្រុកវិញ វាយពួកសត្រូវនៅនឹងស្រុកលាវ បណ្តេញឲ្យពួកនោះវិលត្រលប់ទៅស្រុកវិញប៉ុណ្ណោះ ។ មកដល់វៀងច័ន្ទដែលទ័ពប៉ោហ្គូត្រួតត្រាអស់ពេលប៉ុន្មានឆ្នាំមកហើយ ពួកលាវទាំងអស់នោះ ក៏ដាក់អាវុធទទួលស្គាល់អំណាចរបស់ស្តេចគេវិញ ។ ព្រឹត្តិការណ៍សំខាន់ទាំងអស់នេះកើតមានឡើង នៅដើមសតវត្សរ៍ទី១៧ ឬចុងសតវត្សរ៍ទី១៦ ។ លោកឪពុក ម៉ារីនី បាននិយាយបន្ថែមថា នៅពេលនោះស្តេចអវ៉ា ប្រុងនឹងលើកទ័ពមកវាយលុកស្រុកលាវម្តងទៀត ក៏ប៉ុន្តែផែនការនេះត្រូវបញ្ចប់ទៅដោយព្រះអង្គត្រូវសុគត ។

ស្តេចអវ៉ាដែលសោយបន្តបានប្រកាន់យកគោលនយោបាយផ្សេង ដោយទ្រង់គ្រាន់តែចង់ឲ្យស្តេចលាវលើកសួយសារអាករមកថ្វាយរៀងរាល់ឆ្នាំ និងបញ្ជូនដំរីល្អមួយក្បាលមកថ្វាយប៉ុណ្ណោះ ។ ព្រះរាជាលាវបានចាត់ទុកសំណើនេះថា ជាការប្រមាថមួយ ដែលនឹងនាំឲ្យលាវក្លាយខ្លួនទៅជានគរចំណុះស្តេចអវ៉ា ទ្រង់ក្រោធជាខ្លាំង ហើយបានឲ្យឃាត់ទូតប៉ោហ្គានដែលនាំសារមកទុកនៅនឹងវៀងច័ន្ទ រួចបានឲ្យកងទ័ពរបស់ព្រះអង្គដកហូតយកអាវុធយុទ្ធភណ្ឌទាំងអស់ ដែលស្តេចអវ៉ា មុនបានយកមកគរទុកនៅនឹងទល់ដែន ។

លោកឪពុក ម៉ារីនី និងពួកពាណិជ្ជករហុល្លង់បានរៀបរាប់ទៀតថា នៅសតវត្សរ៍ទី១៧ គេបានធ្វើដំណើរពីកម្ពុជា និងសៀម មកកាន់រាជធានីវៀងច័ន្ទរបស់លាវ ដើម្បីរៀនធម៌ព្រះពុទ្ធ និងស្តាប់ធម៌ទេសនា[២៥] ។

ពាណិជ្ជកម្មមិនសូវជាមានការអភិវឌ្ឍន៍ប៉ុន្មានទេ ក៏ប៉ុន្តែមានការដូរញដូរជាទៀងទាត់ ប្រកបដោយភាពងាយស្រួល និងសុវត្ថិភាពដែលមិនគួរជឿ ៖ ពួកលាវធ្វើដំណើរទៅស្រុកសៀមតាមរទេះ ហើយត្អូញត្អែរថា មិនត្រូវបានសៀមទទួលរាក់ទាក់ទេ ព្រោះគេចាត់ទុកថា លាវជាមនុស្សព្រៃគ្មានអារ្យធម៌ដូចគេ ។ ពួកចិនមក២ឆ្នាំម្តង ដើម្បីដូរញដូរទំនិញនៅក្នុងទីក្រុងមួយស្ថិតនៅលើដែនទន្លេមេគង្គខាងស្តាំមានឈ្មោះថា មេកុក និងនៅសៀងហៃ ដែលពួកហុល្លង់ហៅថា មឿងហ្វាក់ ។ ចំណែកឯពួកសៀមវិញ មានមកច្រើនរាល់តែឆ្នាំ ដោយយកក្រណាត់ឆ្នូតៗមកដោះដូរយកមាសទៅវិញ ក្រណាត់នោះអ្នកស្រុកចូលចិត្តណាស់ ជាពិសេស ស្រីៗ ។ មានធ្វើពាណិជ្ជកម្មជាមួយកម្ពុជាផងដែរ តាមពួកហុល្លង់និយាយថាចៀសមិនរួច ហើយកម្ពុជាទិញយកវត្ថុធាតុដើមទៅជាច្រើន

[២៥] ច្បាប់ស្តីពីបរាជិករបស់បព្វជិតដែលត្រូវអាបត្តិ ហើយបណ្តេញចេញពីវត្តអារាម ដែលគេអនុវត្តនៅកម្ពុជាសព្វថ្ងៃ ដែលខ្ញុំបានសរសេរនៅក្នុងសៀវភៅ "ច្បាប់ក្រមកម្ពុជា" ត្រង់ជំពូក "ច្បាប់ទំនៀមពីបុរាណ" បានត្រូវរៀបរៀងឡើងតាំងពីសតវត្សរ៍ទី១៧ ដោយគណៈកម្មការសាសនាមួយ ក្នុងនោះមានព្រះសង្ឃលាវ២អង្គដែលគេនិមន្តមកពីឡាន ឈៀង ឬវៀងច័ន្ទ ចូលរួមដែរ ។

ជាពិសេស គឺកប្បាស ។

ពួកហុល្លង់និយាយថាអ្នកស្រុកអាតូពឺ ដែលធ្វើរ៉ែមាសនៅក្នុងស៊ឹង បានបង់ពន្ធជាមាសតែម្តង គឺមាស (ហ្នត់ដូចម្សៅ) ព្រោះគេយកមាសបានរហូតដល់ទៅ២ហាប គឺ១២០គីឡូក្រាមក្នុងមួយឆ្នាំៗ ។

ព្រះរាជាណាចក្រលាវពេលនោះ មានទំនាក់ទំនងជាមួយបរទេសជាច្រើន មិននៅឯកោទេ គឺតែងទទួលរាជទូតរបស់ស្តេចប្រទេសជិតខាង មានអវ៉ា ជាដើម ដែលមានទំនាក់ទំនងមិនសូវជាល្អប៉ុន្មានទេជាមួយលាវ ចាប់ពីសង្គ្រាមចុងក្រោយនៅដើមសតវត្សរ៍ទី១៧មក, ជាមួយតុងកឹង ថ្វីបើពួកអាណ្ណាមធ្លាប់បានធ្វើសង្គ្រាមជាមួយស្តេចវៀងច័ន្ទ បណ្តាលឲ្យលាវស្លាប់អស់ជាច្រើនក្តី[២៦], ជាមួយសៀមដែលតែងតែស្រមៃចង់យកលាវដាក់ជាចំណុះ ប៉ុន្តែចំពោះមុខត្រូវចងស្ពានមេត្រីដើម្បីយកកម្លាំងប្រឆាំងនឹងពួលប៉េហ្កាន និងភូមាសិន ដែលព្រួតគ្នាវាយមកលើ[២៧], ហើយជាមួយកម្ពុជា ដែលលាវរក្សាចំណងទាក់ទងខាងពាណិជ្ជកម្ម និងសាសនាជាប់ជាប្រចាំ បើទោះជាមានការផុលរមាស់ខ្លះតាំងពីពាន់ឆ្នាំមុនមកក៏ដោយ នៅពេលដែលលោក ហ្សេវ៉ាវ៉ាន់វូស្ទូហ្វ ត្រូវបានខបរាជវៀងច័ន្ទ ចាត់តាំងឲ្យផ្សារភ្ជាប់ចំណងមេត្រីភាពរវាងស្តេចទាំង២ឡើងវិញ ពីព្រោះថា បុព្វបុរសរបស់គេបានស្បថស្បែជាមួយគ្នានៅលើកោះ សាសែនហំ ថា នឹងចងចំណងមេត្រីភាពនឹងគ្នាជារៀងរហូតតដល់កូនចៅ ។

ប្រទេសលាវពេលនោះជារាជាណាចក្រមហាអំណាចមួយ ថ្វីបើប្រទេសនេះគ្មានច្រកចេញទៅសមុទ្រក៏ដោយ ។ ព្រំប្រទល់ខាងជើងទល់នឹងយុនណាន រីឯព្រំប្រទល់ខាងត្បូង ពួកហុល្លង់នៃបេសកកម្មវ៉ាន់វូស្ទូហ្វបានបញ្ជាក់ថា "បាសាក់ជាព្រំដែនចុងផុតរបស់ប្រទេសលូវែន" ។ គួរបញ្ជាក់ថាទឹកដីទាំងអស់ដែលនៅខាងក្រោមបាសាក់ ឬចំប៉ាសាក់ ជាទឹកដីរបស់កម្ពុជាទេ[២៨] ។

ពួកលាវបានរើបម្រះចេញពីការគ្រប់គ្រងរបស់ចិននៅសតវត្សរ៍ទី៦ រួចហើយបានបង្កបង្កើតជាក្សត្រប្រទេសតូចៗជាច្រើននៅខាងជើងវៀងច័ន្ទ ដែលទទួលស្គាល់អធិរាជភាពរបស់ស្តេចកម្ពុជា តែនៅរក្សាបានឯករាជ្យរបស់ខ្លួន ។ គឺជាចក្រភពមួយធំ ស្ថិតនៅក្រោមការត្រួតត្រារបស់រាជាធិបតេយ្យមួយ ដែលមានព្រះ

---

[២៦] ទូតអាណ្ណាមបានមកដល់វៀងច័ន្ទនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៦៤២ តែមិនបានការទទួលរាក់ទាក់ទេ ហើយត្រូវវិលត្រលប់ទៅវិញ ជាបន្ទាន់ ។

[២៧] រាជទូតសៀមដែលមកដល់វៀងច័ន្ទថ្ងៃទី២ ខែឧសភា ឆ្នាំ១៦៤២ មិនបានស្វាគមន៍ការទទួលរាក់ទាក់ទេ ហើយបានត្រូវស្តេចលាវបញ្ជាមិនឲ្យទៅវិញទៀតបើគ្មានការអនុញ្ញាតពីព្រះអង្គ ហើយទ្រង់បានឲ្យប៉ូលិសតាមដានជាប់ ។ ពួកហុល្លង់និយាយថា រាជទូតលាវ ក៏មិនបានទទួលការស្វាគមន៍រាក់ទាក់ដែរនៅស្រុកសៀម អ្នកទាំង២នាក់នេះចេះតែប្រណែនគ្នា ។

[២៨] ក្នុងករណីនេះ នៅពេលដែលព្រះរាជាលង្វែកត្រូវបានគេបណ្តេញចេញពីរាជធានីទៅ ហើយយាងទៅគង់នៅឯស៊ឹងត្រែង គឺព្រះអង្គស្ថិតនៅក្នុងទឹកដីកម្ពុជានៅឡើយ មិនមែននៅក្នុងទឹកដីលាវទេ ។

រាជាសោយរាជ្យតៗគ្នាអស់ពេលជាច្រើនសតវត្សរ៍ តែយើងមិនបានស្គាល់អស់ ។ គេមិនត្រូវភ្លេចទេថា បាសាក់ ដែលជាខែត្រមួយរបស់លាវកាលពីសតវត្សរ៍ទី១៦ និង១៧ បានក្លាយទៅជារាជាណាចក្រមួយចំណុះសៀម ក្រោយពីពួកសៀមវាយដណ្តើមយករាជធានីវៀងច័ន្ទបាន ហើយដុតបំផ្លាញខ្ទេចខ្ទីនៅក្នុងឆ្នាំ១៨២៨ ។ នៅពេលនោះ ហ្លួងប្រាបាងដែលជារាជធានីរបស់លាវមុនវៀងច័ន្ទកាលពីមុនសតវត្សរ៍ទី១៦ ក៏បានប្រែក្លាយទៅជារាជាណាចក្រមួយផ្សេងទៀត ហើយក៏ប្រហែលជាមានរដ្ឋតូចៗច្រើនទៀត ដែលបានទាមទារយកឯករាជ្យផងដែរ ដោយរំលឹកពីអតីតកាលយូរលង់មកហើយ ហើយដែលមើលទៅគឺមាននៅតាមទីក្រុងដែលមានក្សត្រ (ចៅ) គ្រប់គ្រងស្នងពូជតៗគ្នា រៀងរហូតមក ។

នៅសតវត្សរ៍ទី១៧ ព្រះរាជាណាចក្រលាវមានព្រះរាជាមួយអង្គសោយរាជ្យ ដែលជាប់សាច់សារលោហិតជាមួយព្រះរាជាលាវពីមុន ឬក៏ជាប់សាច់សារលោហិតថៃ ។ ព្រះរាជាណាចក្រនេះរួមមានក្សត្រប្រទេសទាំងឡាយ ដែលទើបតែបានរួចផុតពីអនុត្តរភាពរបស់ខ្មែរ បន្ទាប់ពីកើតមានព្រឹត្តិការណ៍ដែលនាំឲ្យមានការផ្លាស់ប្តូររាជវង្ស និងសាសនានៅកម្ពុជា ។ ប្រជាជនគឺពួកលាវ មានលាយថៃខ្លះ តែគឺជារាជាណាចក្រមួយឯករាជ្យ ។

ហេតុការណ៍ដូចគ្នាបានកើតមានឡើងនៅនគរចាម្ប៉ា (អាណ្ណាមសព្វថ្ងៃ) ។ នៅពេលដែលពួកអាណ្ណាមដណ្តើមយកទឹកដីបាន ហើយចូលមកតាំងទីលំនៅរស់នៅ ប្រជាជនចាមមួយចំនួនមិនបានរត់ចោលស្រុកទេ ។ ពេលនោះព្រះរាជាណាចក្រចាស់ ត្រូវបានរៀបចំឡើងវិញ ដោយមានស្តេចជាអង្គម្ចាស់អាណ្ណាមម្នាក់ ដែលជាឧបរាជនៅតុងកឹងពីមុន តែបន្ទាប់មកបានផ្តាច់ខ្លួនឯករាជពីតុងកឹង ដោយមានការគាំទ្រពីពួកចាមដែលធ្លាប់តែរស់មានសេរីភាពយ៉ាងនេះ ។

មានចំណុចមួយទៀតដែលត្រូវកត់សម្គាល់អំពីហេតុការណ៍ខាងលើ គឺថាគ្រឹះនៃជាតិសាសន៍លាវ ប៉ុន្តែពួកថៃដែលមកដល់ក្រោយអាចធ្វើឲ្យលាវទទួលយកនូវភាសា អារ្យធម៌ កាយសម្បទា និងចរិតលក្ខណៈរបស់ខ្លួនបាន ។

ប្រទេសលាវមានទីតាំងនៅជាប់នឹងកម្ពុជា ហើយទទួលបានឯករាជ្យតាំងពីសតវត្សរ៍ទី១៣ ប៉ុន្តែរក្សាបាននូវទំនាក់ទំនងល្អជាមួយប្រទេសជិតខាង ។ ប្រទេសលាវនាសម័យនោះគឺជារដ្ឋដ៏សំខាន់មួយ មានទឹកដីធំធេង និងមានអារ្យធម៌ត្រចះត្រចង់ ។ ខ្ញុំសូមផ្តល់ការយល់ដឹងខ្លះអំពីប្រទេសជិតខាងរបស់កម្ពុជាដោយបញ្ឈរក់ពីការលូតលាស់របស់គេយ៉ាងដូច្នេះ មុននឹងជម្រាបជូនអំពីនគរចាម្ប៉ា ដែលលែងជាមហាអំណាចមួយទៀតហើយ ។

## ២- នគរចាម្ប៉ា

ពួកចាម ដែលជាសត្រូវស្លូពូជរបស់ពួកអាណ្ណាម ជួនកាលបានចងសម្ព័ន្ធមេត្រីភាពជាមួយខ្មែរ តែជួនកាលទៀត ជាសត្រូវនឹងខ្មែរ ។ ពួកចាមនេះធ្លាប់បានចូលលុកលុយអាណាខែត្ររបស់អាណ្ណាម និងកម្ពុជា ជាញឹក

ញយ ហើយបានបើកកិច្ចប្រតិបត្តិការឆក់ប្លន់តាមឆ្នេរសមុទ្រឥតឈប់ឈរ ក្រោយពីបណ្តាខេត្តខាងជើងចំនួន៥ របស់គេ បានត្រូវផ្តាច់ទៅឲ្យអាណ្ណាម ។ ពួកចាមនេះលែងមានអត្ថិភាពទៀតហើយ នៅចុងសតវត្សរ៍ទី១៦ ។ ពួកនេះ បានផ្លាស់ប្តូរចូលកាន់សាសនាមហាម៉ាត់វិញនៅសតវត្សរ៍ទី១៨ តាមរយៈអ្នកផ្សព្វផ្សាយសាសនា មកពីកោះជ្វាតាំងពី២រយឆ្នាំមុន ។ ពួកចាមទើបតែបានបាត់បង់ខេត្តមួយចំនួន ក្នុងនោះមានទីក្រុងវ៉េ ដែលមានជៀមចាមជារាជធានីរបស់ខ្លួនតាំងនៅ និង ថាញ់ហ៊្វា ដែលមានទូរ៉ាននៅក្នុងនោះផង ។

ចាមបានវាយមកលើឆ្នេរសមុទ្រអាណ្ណាមម្តងនៅក្នុងឆ្នាំ១៣៦១ វាយទីរួមខេត្តឡាមបិញនៅក្នុងឆ្នាំ ១៣៦៥ វាយឲ្យទ័ពអាណ្ណាមបរាជ័យ ប៉ុន្តែនៅទីបំផុតក៏ត្រូវពួកអាណ្ណាមរុញច្រានឲ្យដកថយទៅវិញ មិនតែប៉ុណ្ណោះ ត្រូវអាណ្ណាមតាមវាយរហូតដល់ស្រុកទៀតផង នៅក្នុងឆ្នាំ១៣៦៦ និង១៣៦៧ ។

នៅក្នុងឆ្នាំ១៣៧១ ចាមបានចូលវាយដុតបំផ្លាញទីក្រុងដៃអាន ដែលស្ថិតនៅលើមាត់ពាមស៊ុងវ៉េ តាមការញុះញង់របស់ព្រះមាតាស្តេចជ្រែករាជ្យអាណ្ណាមម្នាក់ ។ ដល់មកឆ្នាំ១៣៧៣ ចាមបានចូលលុកដល់ទីក្រុងវ៉េ ក៏ប៉ុន្តែត្រូវវាយឲ្យបរាជ័យ ហើយពួកអាណ្ណាមបានដេញតាមកាប់សម្លាប់រហូតមកដល់រាជធានីចាបានតែម្តង ។ នាវាចម្បាំងរបស់ចាម បានត្រូវបំផ្លាញដោយខ្យល់ព្យុះមួយនៅក្នុងឆ្នាំ១៣៧៧ ។

ដោយបានប្រកាសជាស្តេចអាណ្ណាម នូវអ្នកអគ្គម្ចាស់អាណ្ណាមជាឈ្លើយម្នាក់ ដែលបានរៀបការជាមួយក្សត្រីចាមមួយអង្គជាភរិយា ហើយតាំងនៅង៉េអាន ដែលកាលពីដើមជាខេត្តមួយរបស់ចាម ពួកអាណ្ណាមបានតាមមកវាយជាច្រើនលើកច្រើនសា រួចវាយចូលដល់ក្នុងរាជធានីង៉េអានក្នុងឆ្នាំ១៣៨២ ធ្វើឲ្យព្រះរាជានោះសុគតទៅនៅក្នុងការប្រយុទ្ធតាមជើងទឹក ។ ទ័ពអាណ្ណាមបានវាយទ័ពចាមឲ្យបរាជ័យទៀតទាំងតាមផ្លូវគោក ទាំងតាមផ្លូវទឹក នៅក្នុងឆ្នាំ១៣៨៣ និង១៣៨៤ ។ មកដល់ឆ្នាំ១៣៨៥ ពួកចាមបានចូលមកវាយម្តងទៀត វាយចូលដល់មកមាត់ទ្វាររាជធានីហាណូយតែម្តង ហើយលុកលុយរាតត្បាតពាសពេញអាណាខេត្តតុងកឹងភាគខាងត្បូង អស់រយៈពេល ៦ខែ ។ ក្រោយពីត្រូវវាយឲ្យដកថយទៅ ពួកចាមនេះបានត្រលប់មកវាយខេត្តថាញ់ហ៊្វាម្តងទៀត នៅក្នុងឆ្នាំ១៣៩០ តែត្រូវអាណ្ណាមវាយបណ្តេញចេញវិញ ធ្វើឲ្យស្លាប់អស់ស្តេចចាមមួយអង្គថែមទៀត ។ ចាម ក៏លើកឧត្តមសេនីយ៍ដែលជួយសង្គ្រោះកងទ័ពខ្លួនឲ្យរួចពីស្លាប់ធ្វើជាស្តេច ។

ក្នុងឆ្នាំ១៣៩៣ ពួកចាមបានវាយទៅលើទ័ពអាណ្ណាម ដែលចេញមកស៊ើបការណ៍នៅនឹងទល់ដែន ។

មានកើតភាពច្របូកច្របល់ខ្លះ ជាមួយស្តេចដែលឡើងសោយរាជ្យបន្តពីឧត្តមសេនីយ៍មេទ័ព ធ្វើឲ្យពួកអាណ្ណាម ឆ្លៀតឱកាសលើកទ័ពចូលមកវាយនៅក្នុងឆ្នាំ១៤០៣ ក៏ប៉ុន្តែ ទ័ពអាណ្ណាមត្រូវបរាជ័យទៀត ។ ក្នុងឆ្នាំ ១៤០៤ អាណ្ណាមបានវាយចូលជាថ្មី ហើយឡោមព័ទ្ធរាជធានីចាបានជាប់ បំផ្លិចបំផ្លាញខ្ទេចខ្ទី តែមិនអាចដណ្តើមយកបាន ក៏ដកថយចេញទៅវិញអស់ទៅ ។

ដោយពួកចាមនៅតែបន្តវាយមកលើឆ្នេរសមុទ្រអាណ្ណាម និងបើកកិច្ចប្រតិបត្តិការចេញមកក្រៅទឹកដី

*របស់ខ្លួនឥតឈប់ឈរ ព្រោះមានការគាំទ្រពីប្រជាជនចាម ដែលរស់នៅក្នុងខែត្រដែលធ្លាក់ចូលក្នុងការគ្រប់គ្រងរបស់អាណ្ណាម នៅទីបញ្ចប់ស្តេចអាណ្ណាម ឡៀញ៉ាន់តុង បានសម្រេចបំផ្លាញពួកនេះឲ្យដាច់ពូជតែម្តង ។*

## ៣- អាណ្ណាម-តុងកឹង

*អាណ្ណាម បានរើបម្រះខ្លួនចេញពីនឹមត្រួតត្រារបស់ចិន នៅក្នុងឆ្នាំ១៤២៨ នៅពេលដែលសន្តតិវង្សមិញទើបតែផ្តួលរំលំដណ្តើមអំណាចបានពីពួកតាកតារម៉ុងហ្គោល នៅឯរាជធានីប៉េកាំង ។ កន្លងមក អាណ្ណាមបានទទួលរងនូវការគាបសង្កត់ខ្លាំងណាស់ ព្រោះត្រូវកងទ័ពចិនរុករានបំផ្លិចបំផ្លាញផង ត្រូវពួកមន្ត្រីបែងចែកអំណាចគ្នាផងមិនតែប៉ុណ្ណោះត្រូវពួកពាណិជ្ជករចិនដែលមកតាមកងទ័ពកេងប្រវ័ញ្ចផង ។ ក្រោយពីបានធ្វើការប្រយុទ្ធប្រឆាំងនឹងចិនមិនបានជោគជ័យរួចមក ពួកអ្នកបះបោរប្រឆាំងនឹងចិន បានលើករាជវង្ស២នាក់ផ្សេងៗគ្នាឲ្យឡើងសោយរាជ្យ ម្នាក់គឺជាបុត្រាពៅរបស់ស្តេចត្រាន់ង៉េតុងដែលជាព្រះរាជាទី៨នៃសន្តតិវង្សត្រាន់ មានឈ្មោះថា ង៉ុយ (យ៉ាឌិញ) ត្រូវក្រុមគាំទ្រប្រកាសលើកជាស្តេចនៅក្នុងឆ្នាំ១៤០៧ ម្នាក់ទៀតឈ្មោះ ត្រាន់គ្វីខាង (ទ្រៀងក្វាងដេ) ត្រូវជាក្មួយរបស់ង៉ុយ និងជាចៅរបស់ត្រាន់ង៉េតុង បានត្រូវបក្សពួកប្រកាសលើកជាស្តេចនៅក្នុងឆ្នាំ១៤១០ ។ ក្រោយមកត្រាន់គ្វីខាងបានត្រូវគេចាប់ប្រគល់ឲ្យចិន ហើយក៏ធ្វើអត្តឃាតនៅតាមផ្លូវធ្វើដំណើរទៅស្រុកចិន ។*

*រឿងជ្រើសតាំងស្តេចទាំង២អង្គនេះជារឿងវាសនាប្រទេសជាតិទាំងមូល ក៏ប៉ុន្តែតាំងតែពីពេលដែលគេបានចូលដៃចូលជើងគាំទ្រពួកជ្រែករាជ្យថត្វីលី និងហូហានធឿង មក ប្រជាជនប្រែហាក់ដូចជាសោះអង្គើយជាមួយនឹងរាជវង្សត្រាន់ បើទោះបីថា ពួកហូ ត្រូវបាត់បង់អស់ទៅហើយក្តី ។*

*ការជិះជាន់គាបសង្កត់ ការរៀបចំបែងចែកដីភូមិជាថ្មី និងរាជបញ្ញារឆ្នាំ១៤១៤ ដែលតម្រូវឲ្យបុរសៗអាណ្ណាមទុកសក់វែងដូចចិន[២៩] ហើយហាមឃាត់នារីៗមិនឲ្យសាក់ខ្លួន និងឲ្យស្លៀកតែសម្លៀកបំពាក់ខ្លីៗ មានដៃវែង បាននាំឲ្យមានការបះបោរប្រឆាំងនឹងអាជ្ញាធរចិនឡើង ។ នៅសម័យនោះ វាហាក់ដូចជាថាមេទ័ពចិន ដែលជាអភិបាលលើអាណ្ណាម ចង់ឆ្លៀតយកឱកាសដែលប្រជាជនមិនសប្បាយចិត្តដើម្បីទាញយកផលប្រយោជន៍ផ្ទាល់ខ្លួនហើយវាយយកអាណ្ណាមទាំងមូលតែម្តង ក្រោយពីបញ្ជូនកងទ័ពចិនឲ្យត្រលប់ទៅវិញរួចហើយ ។ គំនិតក្បត់នេះ បើសិនជាមានមែន បានត្រូវបែកការណ៍ ហើយមេទ័ពចិនក៏ត្រូវគេកោះហៅឲ្យវិលត្រលប់ទៅវិញ ។*

*អ្វីដែលមេទ័ពចិននោះធ្វើមិនបានសម្រេច បានត្រូវអ្នកដទៃធ្វើបានសម្រេច នៅពេលដែលគ្មានរូបគាត់ ។*

---

[២៩] *ប្រជាជនអាណ្ណាមនៅទុកសក់វែងប៉ប្រះស្មា ធ្លាក់មកលើខ្នង រហូតមកដល់សតវត្សទី១៧ ។*

មានមន្ត្រីធំរបស់រាជវាំងមុនម្នាក់ មានឈ្មោះថា ឡេឡឺយ ឬឡេលី ដែលមិនដែលចុះចូលជាមួយនរណា បានប្រមែប្រមូលពួកអ្នកដែលប្រឆាំងនឹងការគ្រប់គ្រងរបស់ចិនមកជាក្រុមតែមួយ រួចចាប់បើកការវាយឆ្មក់ទៅលើពួកចិននៅក្នុងឆ្នាំ១៤១៧ ធ្វើឲ្យពួកនេះមានការភ្ញាក់ផ្អើល និងបាត់បង់កងពលអស់ជាច្រើន ។ ឡេឡឺយ វាយចិន ដួនឈ្នះដួនចាញ់ ។ គ្រួសាររបស់គាត់ត្រូវចិនចាប់បាន ហើយអារកសម្លាប់ទាំងអស់ ធ្វើឲ្យគាត់អស់សង្ឃឹម ទន់ដៃទន់ជើងអស់មួយរយៈ ប៉ុន្តែបន្ទាប់មកគាត់ក៏មានសេចក្ដីក្លាហានឡើងវិញ ចាប់ធ្វើការប្រយុទ្ធ ពោរពេញទៅដោយកំហឹងឈឺចាប់ ពោរពេញទៅដោយភាពសាហាវ ធ្វើឲ្យសត្រូវបរាជ័យ តែក្រោយមកគាត់ ក៏ត្រូវបរាជ័យវិញម្ដង ។ សង្គ្រាមរំដោះស្រុកនេះមានរយៈពេល១០ឆ្នាំ នៅទីបញ្ចប់ឡេឡឺយក៏រុញច្រានទ័ព ចិនឲ្យចាកចេញពីទឹកដីអាណ្ណាមបាន ធ្វើឲ្យស្រុកទទួលបានសេរីភាពនៅក្នុងឆ្នាំ១៤២៨ ។ ឡេឡឺយ ក៏ឡើងសោយរាជ្យ បង្កើតបានជាសន្តតិវង្ស ឡេ ថ្មី ដែលមានស្ដេច ២៥អង្គ សោយរាជ្យអស់កាល៣៦៤ឆ្នាំ ពី១៤២៨ ដល់១៧៩១ ។

ឡេឡឺយទទួលរាជាអភិសេកនៅរាជធានីដុងដូ ដែលមានឈ្មោះម្យ៉ាងទៀតថា កេជឺយ ទ្រង់បានប្ដូរឈ្មោះឲ្យហៅថា ដុងគីញ វិញ មានន័យថា រាជធានីទិសបូព៌ា រាជធានីនេះក្រោយមកគឺហាណូយនោះឯង ហើយទ្រង់បានប្ដូរព្រះនាមថាឡេធួនធាន ។ ដោយបញ្ជាក់ថា សន្តតិវង្សត្រាន់ មិនមានរាជបុត្រស្នងត្រកូលតទៅទៀត ទ្រង់បានសំណូមពរឲ្យព្រះចៅអធិរាជចិនទទួលស្គាល់ព្រះអង្គ ថាជាស្ដេចរបស់អាណ្ណាម ។

ក្រោយពីបានឡើងសោយរាជ្យរួចមក ឡេធួនធានបានចាប់ផ្ដើមធ្វើសង្គ្រាមជាមួយកុលសម្ព័ន្ធព្រៃភ្នំមួយចំនួននៅភាគខាងជើង វាយពួកនោះឲ្យបរាជ័យ រួចហើយទ្រង់ចាប់រៀបចំប្រទេសឡើងវិញតាមគំរូរបស់ចិនដោយធ្វើការកែទម្រង់ខ្លះដែលពួកចិនធ្លាប់បានដឹកនាំធ្វើដែរ តែសម្រេចបានតែបន្តិចបន្តួចប៉ុណ្ណោះ ។ ទ្រង់បានបញ្ចុះឋានៈរាជបុត្រមួយអង្គ ដែលបានប្រព្រឹត្តខុសឆ្គង មិនត្រឹមត្រូវតាមគន្លងធម៌ ។

ព្រះរាជាដែលសោយរាជ្យបន្តបន្ទាប់ពីស្ដេច ឡេធួនធាន បានយកតម្រាប់តាមព្រះអង្គ គឺធ្វើសង្គ្រាមជាមួយពួកចាម ដែលតែងតែចាប់កាន់អាវុធលួចឆ្មក់ចូលវាយតាមមាត់សមុទ្រ ថ្វីបើបានបញ្ជូនរាជទូតមកគោរពព្រះអង្គរួចហើយក្ដី ។ មួយចំណែកទៀត បណ្ដាខេត្រនៅភាគខាងត្បូងត្រូវធ្វើការប្រយុទ្ធទប់ទល់នឹងរដ្ឋតូចៗ មិនទាន់ស៊ីវិល័យចំនួន១០ ដែលនៅព័ទ្ធជុំវិញអាណ្ណាម ហើយតែងតែត្រូវរុញច្រានចូលមកក្នុងព្រះរាជាណាចក្រ បង្កវិនាសកម្មផ្សេងៗ មិនដឹងដោយមូលហេតុអ្វី ប្រវត្តិសាស្ត្រក៏មិនបានកត់ត្រាអំពីមូលហេតុនេះដែរ ។

នៅក្រោមរជ្ជកាលស្ដេចឡេ ប្រទេសមានរបៀបរបបត្រឹមត្រូវ អាណាខេត្រមានសណ្ដាប់ធ្នាប់ ហើយការណែនាំពីថ្នាក់កណ្ដាលបានត្រូវផ្សព្វផ្សាយចេញ ។ គេជីកព្រែកបង្ហូរទឹក ដីទំនេរបានត្រូវគាស់រានរួចហើយប្រគល់ទៅឲ្យកសិករ ។ មានសំពៅជំនួញបរទេសមកពីចិន ម៉ាឡេ ចេញចូលកំពង់ផែកាន់តែច្រើនឡើងៗ ពីមួយថ្ងៃទៅមួយថ្ងៃ ។ ជ័យជម្នះទៅលើពួកចាម បានអនុញ្ញាតឲ្យអាណ្ណាម ស្រូបយកបណ្ដាខេត្រនៃរាជាណាចក្រសត្រូវមួយម្ដងៗ ស្ទើរតែទាំងអស់ ។

អាណ្ណាមបានក្លាយទៅជាជាតិធំមួយដែលប្រទេសជិតខាងបាក់បបខ្លបខ្លាច មានកងទ័ពពូកែក្លាហានអាចធានាបាននូវអនាគតល្អ ស្រាប់តែមិនបាន១០០ឆ្នាំផងក្រោយពីការកសាងសន្តតិវង្សរួចមក នៅក្នុងរជ្ជកាលព្រះរាជាទី៧ អ្វីៗត្រូវរលាយបាត់អស់ទៅវិញ ដោយសារតែស្តេចនោះអាក្រក់ ។ ប្រជាជនបានបះបោរឡើងដឹកនាំដោយឧត្តមសេនីយ៍ម្នាក់ ហើយដណ្តើមយករាជធានីបាន ធ្វើឲ្យព្រះរាជានោះឈឺចិត្ត ផឹកថ្នាំសម្លាប់ខ្លួនឯងទៅ នៅក្នុងឆ្នាំ១៥០៩ ។

ឧត្តមសេនីយ៍អ៊ូអ៊ីងនោះក៏ប្រកាសខ្លួនឯងជាស្តេច ក៏ប៉ុន្តែមិនបានទទួលការគាំទ្រពីប្រជាជនទូទាំងប្រទេសទេ ។ ចាប់ពីឆ្នាំ១៥១០ដល់១៥១៦ មានការបះបោរ៧លើកបន្តបន្ទាប់គ្នា នៅទីបញ្ចប់ឧត្តមសេនីយ៍អ៊ូអ៊ីងក៏ត្រូវមេបះបោរម្នាក់ សម្លាប់បាន នៅក្នុងឆ្នាំ១៥១៧ ។

ស្តេចដែលឡើងគ្រងរាជបល្ល័ង្កថ្មីសោយរាជ្យមិនបានស្រួលប៉ុន្មានទេ ព្រោះមានការបះបោរប្រឆាំងជាច្រើន ដែលត្រូវជម្នះ ។ នៅទីបញ្ចប់ទ្រង់អាចបង្ក្រាបការបះបោរទាំងអស់ឲ្យរាបទាបបាន ប៉ុន្តែព្រះរាជាដែលឡើងសោយរាជ្យបន្តពីព្រះអង្គត្រូវប្រឈមមុខនឹងការបះបោរឡើងវិញ ហើយត្រូវបង្ខំចិត្តរត់គេចចេញពីរាជធានី ។ នៅពេលដែលយាងត្រលប់ចូលមកក្នុងរាជធានីវិញនៅក្នុងឆ្នាំ១៥១៧ ទ្រង់ត្រូវទទួលរងនូវការគំរាមកំហែងពីពួកមេទ័ព ដែលលែងគោរពស្តាប់បញ្ជាព្រះអង្គទៅហើយ ។ នៅទីបញ្ចប់មានមេទ័ពម្នាក់ឈ្មោះ ម៉ាក់ដាំងដុង ដែលព្រះរាជាឡើងជាវតុងទុកព្រះទ័យជាងគេ អាចវាយបង្ក្រាបមេទ័ពឯទៀតៗដែលប្រកាសថា ខ្លួននៅតែស្មោះត្រង់នឹងព្រះរាជាជានិច្ចនោះ ឲ្យដកថយចេញពីរាជធានីហាណូយទៅ ។ ជាការតបស្នងសងគុណព្រះរាជាបានប្រគល់នូវឋានៈដ៏ខ្ពង់ខ្ពស់បំផុត និងអំណាចទាំងអស់ឲ្យទៅ ម៉ាក់ដាំងដុង ដែលបានក្លាយខ្លួនទៅជាម្ចាស់លើព្រះរាជាណាចក្រទាំងមូល និងលើព្រះរាជាទៀតផង ។ ក្រោយពីទ្រង់បានប្រគល់អ្វីៗឲ្យទៅម៉ាក់ដាំងដុងរួចហើយ ព្រះរាជាបានចាប់មានការភ័យបារម្ភនឹងមហិច្ឆតារបស់មេទ័ពនេះ រួចចាប់នឹកខ្លាច ក៏រត់គេចចេញពីរាជធានីទៅ នៅក្នុងឆ្នាំ១៥២២ ។ ម៉ាក់ដាំងដុង ក៏ដេញតាម ហើយចាប់ព្រះអង្គបាននៅក្នុងឆ្នាំ១៥២៣ និងនាំត្រលប់មកហាណូយវិញ បញ្ជាឲ្យគេឃុំខ្លួនព្រះអង្គ រួចលើករជ្ជទាយាទឡេគួងហ្វាងឲ្យឡើងសោយរាជ្យវិញ ។ តាមពិត គឺម៉ាក់ដាំងដុងនេះឯង ដែលដឹកនាំប្រទេសជាតិ និងចេញបញ្ជាផ្សេងៗព្រមទាំងអនុវត្តសិទ្ធិអំណាចទាំងអស់ជំនួសព្រះរាជា ។ ក៏ប៉ុន្តែ ដូចជាហ្វូគីលីដែលយើងបានឃើញពីខាងលើរួចមកហើយដែរ ម៉ាក់ដាំងដុង មិនទាន់ហ៊ានប្រកាសលើកខ្លួនជាស្តេចភ្លាមទេ ។ ទាល់តែបានបញ្ជាឲ្យគេប្រហារជីវិត ធ្វើឃាតស្តេចមុននៅក្នុងគុករួច ទើប ម៉ាក់ដាំងដុង ចូលទៅជួបស្តេចក្មេងឡេគួងហ្វាង បង្ខំឲ្យចុះហត្ថលេខាដាក់រាជសម្បត្តិឲ្យខ្លួន ។ ម៉ាក់ដាំងដុង បង្កើតបានជាសន្តតិវង្សមួយថ្មី មានស្តេច៤អង្គដឹកនាំព្រះរាជាណាចក្រអាណ្ណាមបាន២០ឆ្នាំ ហើយបានបន្តការលំបាកដល់ចក្រពត្រ្តចិនតាមរយៈការទាមទារផ្សេងៗគ្មានឈប់ឈរ និងតាមរយៈបក្សពួករបស់ខ្លួន រហូតទាល់តែបាត់អំណាចទៅ នៅក្នុងឆ្នាំ១៥៩២ ។

នៅពេលនោះមានឧត្តមសេនីយ៍ម្នាក់ ឈ្មោះថា ង្វៀងគីម បានងើបឡើងដើម្បីលើកបច្ចាញាតិមួយអង្គរបស់សន្តតិវង្សឡេ ឲ្យឡើងសោយរាជ្យវិញ ។ ង្វៀងគីម បានទៅជួបរជ្ជទាយាទនោះនៅ ថាញ់វ៉ា ដែលកាលនោះគេហៅថា តៃគិញ កេណ្ឌទ័ពរួចប្រកាសលើកព្រះអង្គជាស្ដេច ទើបយាងព្រះអង្គមកកាន់រាជធានីហាណូយ ហើយបណ្ដេញស្ដេច ម៉ាក់ ចុងក្រោយចេញទៅ ។

ង្វៀងគីមបានទទួលឋានៈជាជួ មានន័យថាជាមន្ត្រីធំ ជាមេដឹកនាំរដ្ឋាភិបាល ។ គាត់មានអំណាចខ្លាំង ដូចជា ហូគ្វីលី និងម៉ាក់ដាំងដុង នៅមុនពេលដែលដណ្ដើមរាជបល្ល័ង្កអ៊ីចឹងដែរ ។ ចាប់ពីត្រឹមគាត់នេះទៅ អ្នកដែលស្នងត្រកូលង្វៀង និងជិញតទៅ មិនគ្រាន់តែដឹកនាំព្រះរាជាណាចក្រប៉ុណ្ណោះទេ គឺដឹកនាំទាំងព្រះរាជា ថែមទៀត ។ តែអំណាចដ៏ខ្ពង់ខ្ពស់បែបនេះ ដែលមានឡើងនៅក្រោមស្ដេចមិនបានការ មានវត្តមានដើម្បីគ្រាន់តែជាតំណាងអំណាចព្រះរាជា សម្រាប់ការគោរពបូជាប៉ុណ្ណោះ ប៉ុន្តែអំណាចពិតប្រាកដស្ថិតនៅក្នុងដៃរបស់ ជួ ទៅវិញទេ អំណាចបែបនេះជួបប្រទះការច្រណែនឈ្នានីសជាច្រើន ហើយមានសត្រូវប្រឆាំងប្ដូរផ្ដាច់ ។ ថ្វីបើគេមិនអាចធ្វើការវាយប្រហារប្រឆាំងចំពោះមុខបាន ព្រោះគាត់មានអំណាចធំណាស់ ក៏ប៉ុន្តែង្វៀងគីមបានត្រូវគេដាក់ថ្នាំបំពុលដល់ស្លាប់ នៅក្នុងឆ្នាំ១៥៤៦ ។ កូនប្រសាររបស់ ង្វៀងគីម បានឡើងកាន់អំណាចបន្តពីឪពុកក្មេក ដោយទទួលឋានៈជា ជួ ហើយបានបន្តធ្វើការប្រយុទ្ធប្រឆាំងនឹងពួកម៉ាក់ ដែលបានបង្កើតជាក្សត្រប្រទេសមួយនៅតំបន់ កាវបាង ត្រង់កន្លែងដែលកាលពីមុនពួកនុងបានបង្កើតរាជាណាចក្រតូចមួយ ។ ទឹកដីត្រង់នេះ មិនធ្លាប់ចំណុះប្រទេសណាទេ ឯប្រជាជនដែលមិនមែនជាពួកអាណ្ណាម បានរក្សាខ្ជាប់នូវអនុស្សាវរីយ៍រាជាណាចក្រពីអតីតកាល ហើយធ្លាប់បានយកក្វាងស៊ី និងក្វាងតុងដាក់ជាចំណុះផង ។ គេទទួលយកការត្រួតត្រារបស់ស្ដេចអាណ្ណាម សោយរាជ្យនៅហាណូយដោយលំបាក ហើយចូលចិត្តមានមេដឹកនាំដោយឡែក ។ ពួកម៉ាក់ បានមកតាំងអំណាចនៅទីនេះ ចាប់ពីឆ្នាំ១៥៩២ រហូតដល់ឆ្នាំ១៦៦០ ដោយសង្ឃឹមក្នុងចិត្តថា នឹងអាចដណ្ដើមយកព្រះរាជាណាចក្រទាំងមូលបានមកវិញ ពីដៃស្ដេចឡេ ក្រោមការដឹកនាំគ្រប់គ្រងរបស់ពួកជួ ។

នៅពេលដែល ត្រាញ់គៀម ជាកូនប្រសាររបស់ ង្វៀងគីម បានប្រកាន់យកឋានៈជា ជួ នៅហាណូយ ការប្រកាន់យកឋានៈនេះ ហាក់ដូចជាមិនសូវស្របច្បាប់ កូនរបស់ ង្វៀងគីម ឈ្មោះថា ង្វៀងហួង ក៏បានប្រកាន់យកតំណែងជា ជួ នេះដែរ ដោយសំអាងថាទទួលកេរ្តិ៍តពីឪពុក តែក៏មិនត្រឹមត្រូវដែរព្រោះមិនមានការតែងតាំងពីស្ដេច ។ ង្វៀងហួង មិនសប្បាយចិត្តទេ ព្រោះពីមុនឪពុកខ្លួនជា ជួ តែម្នាក់ឯង ឥឡូវមាន ជួ ដល់ទៅ២នាក់ ក៏ធ្វើការទាមទារទៅព្រះរាជា ដែលយល់ព្រមលើកង្វៀងហួងឲ្យទៅជាវឿង មានន័យថា ជាអ្នកអង្គម្ចាស់ ដែលជាឋានៈខ្ពស់ជាងបងថ្លៃ ។

ពេលនោះ ស្ដេចនៅហាណូយជាស្ដេចមិនបានការ អំណាចពិតប្រាកដស្ថិតនៅក្នុងដៃពួកជួ ត្រកូលជិញ ដែលជាអ្នកដឹកនាំព្រះរាជាណាចក្រពិតប្រាកដ និងដឹកនាំព្រះរាជាផង ។ ពួកជួ ត្រកូលវឿង ឬង្វៀង មានការ

ប្រណែនជាខ្លាំង ដល់មិនអាចដឹកនាំបាននៅតុងកឹង ក៏បែរមកមើលទឹកដីចាម្ប៉ា ដែលអាណ្ណាមទើបតែដណ្ដើមយកបានវិញម្ដង ។ ពួកនេះបានចែកអំណាចគ្នានៅទីនោះ រួចហើយក៏ប្រកាសសង្គ្រាមប្រឆាំងនឹងពួកជិញ ដែលកាន់អំណាចនៅឯតុងកឹង ។ ដោយហេតុនេះ នគរចាម្ប៉ា បានត្រូវរៀបរយឡើងវិញ ក្រោមរាជវង្សដែលមិនមែនជាចាម ពោលគឺ ជាអាណ្ណាម ក៏ប៉ុន្តែបន្ទាប់មកបែរមកវាយអាណ្ណាមវិញ ។ ប្រជាជននគរចាម្ប៉ាពេលនោះ រួមមានពួកចាម ដែលមិនព្រមរត់ចោលស្រុក ហើយសុខចិត្តទ្រាំរស់នៅបង្កបង្កើនផលលើដីស្រែចម្ការរបស់ខ្លួន និងពួកអាណ្ណាម ដែលទើបចូលមករស់នៅលើទឹកដីនៅទំនេរ ដែលម្ចាស់បានរត់គេចចោលស្រុកព្រោះមិនចង់ចំណុះពួកឈ្លានពាន ។ ប្រជាជនទាំង២ប្រភេទនេះបានស្រុះស្រួលរួបរួមគ្នាជុំវិញមេដឹកនាំថ្មី ដើម្បីធ្វើការប្រយុទ្ធតទល់នឹងស្ដេចនៅហាណូយ ។

## ៤- ប្រទេសឥណ្ឌា

អំណើះអស់ពីហ្សង់ហ្ស៊ីខាន់ទៅ មានអ្នកស្នងត្រកូលតាមខ្សែខាងស្ត្រីជាប្រពន្ធម្នាក់ ឈ្មោះថា ទីមួរឡេង (តាមែរឡង់) ប្រមូលកេណ្ឌបានកងទ័ពចម្រុះជាតិសាសន៍មួយធំ ក្នុងនោះភាគច្រើនជាពួកតាកតារ ម៉ុងហ្គោល និងទៀរក៍ បានវាយដណ្ដើមយកបាននគរពែក្សទាំងមូលរហូតដល់ទន្លេអឺហ្វ្រាត ទឹកដីកៀរឌីស្ដាន ហ្សកហ្ស៊ី និងអាមេនីផង ។ អ្នកដឹកនាំថ្មីនេះបានចាប់វាយយកប្រទេសឥណ្ឌានៅក្នុងឆ្នាំ១៣៩៨ ដឹកនាំទ័ពឆ្លងភ្នំ កាន់កាប់ទីក្រុងដែលបានឆ្លងកាត់ ចុះទូកសំពៅឆ្លងស្ទឹងទន្លេ ហើយចាប់ប្រជាជនជាឈ្លើយបាន១០ម៉ឺននាក់នាំយកទៅអារកសម្លាប់ចោលនៅមុខរាជធានីដែលី ដោយខ្លាចពួកនេះបះបោរប្រឆាំងក្នុងពេលប្រយុទ្ធ រត់ទៅចូលដៃចូលជើងជាមួយសត្រូវ ។ ដណ្ដើមយកដែលីបានហើយ តាមែរឡង់បានចូលលុកលុយបឹងហ្គាល់ថែមទៀត រួចទើបនាំទ័ពត្រ-លប់ចូលនគរវិញ ដោយនាំយកជ័យភណ្ឌមកជាច្រើន ស្កប់ស្កល់នឹងបានវាតទឹកដីឆ្ងាយជាងអធិរាជអាឡិចហ្សង់ទៅទៀត ។ ពួកហិណ្ឌូនៅចងចាំថា តាមែរឡង់ នេះ ប្រៀបបានដូចជាយក្ស ហើយបានដាក់ឈ្មោះឲ្យថា ជាស្ដេចបំផ្លិចបំផ្លាញ ។

បន្ទាប់ពីតាមែរឡង់ មហាមេដប៉ាតង់ដែលជាតម្រួតរនៅដែលីបានឡើងសោយរាជ្យ រួចសុគតទៅនៅក្នុងឆ្នាំ១៤១៣ ។ មានសន្តតិវង្សថ្មីមួយទៀតដណ្ដើមយកអំណាចបាន គឺពួកក្សៀសែយ៉ាត់ ដែលរក្សាអំណាចបានរហូតដល់ឆ្នាំ១៤៥១ ។ សន្តតិវង្សប៉ាតង់បានរក្សាអំណាចនៅឡូឌីបាន៦០ឆ្នាំ បន្ទាប់ពីនោះមក ប្រទេសឥណ្ឌាភាគខាងជើង ត្រូវធ្លាក់នៅក្រោមនឹមត្រួតត្រារបស់ពួកម៉ុងហ្គោល ដែលក្រោយមកបានវាតអំណាចស្ទើរពាសពេញឥណ្ឌាទាំងមូល ចាប់បង្ខំឲ្យឥណ្ឌាភាគខាងត្បូងទទួលស្គាល់អធិរាជភាពរបស់ខ្លួន ។ នៅទីបញ្ចប់ ក្រោយពីបានសាបព្រោះអារ្យធម៌ដ៏ល្អត្រចះត្រចង់រួចមក សន្តតិវង្សម៉ុងហ្គោលក៏រលត់រលាយបាត់ទៅ ក្រោមឥទ្ធិពលនៃការរំលោភបំពានគ្រប់បែបយ៉ាង រួមមានការប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗ ការបះបោរ ការបែកបាក់គ្រួសារ ការកាប់

សម្លាប់ ឪពុកខ្លួនឯងដណ្តើមអំណាច ។ល ។ ដែលជាហេតុធ្វើឲ្យពួកអង់គ្លេសចូលមកដណ្តើមកាន់កាប់បាន ហើយដើរតួជាអ្នកការពាររាជវង្សរហូតមកដល់សព្វថ្ងៃ ។

នៅសតវត្សរ៍ទី១៦ ស្តេចអាក់បាសោយរាជ្យនៅរាជធានីដែលី ។ ទ្រង់បានរៀបចំចក្រភពរបស់ព្រះអង្គប្រកបទៅដោយយុត្តិធម៌ គ្រប់គ្រងដោយគតិបណ្ឌិត អ្នកផងមើលមកឃើញថាទ្រង់ជាស្តេចត្រឹមត្រូវ មានសន្តានចិត្តទូលាយ ចូលចិត្តអំពើល្អ ស្អាត ហើយតែងតែគិតដល់ប្រជារាស្ត្រដែលទ្រង់ដឹកនាំជានិច្ច ។ ទ្រង់បានឲ្យគេសង់ផ្លូវស្អាតល្អ មានដាំដើមឈើមានផ្លែនៅសងខាងសម្រាប់ផ្តល់ម្លប់ដល់អ្នកដំណើរ ទ្រង់បានឲ្យគេជីកព្រែកប្រឡាយដើម្បីបង្ហូរយកទឹកពីទន្លេគង្គាទៅស្រោចស្រពស្រែចម្ការ ទ្រង់បានឲ្យគេជីកស្រះទឹកធំដើម្បីតម្កល់ទឹកទុកបង្ការការរាំងស្ងួត និងជីកស្រះតូចៗសម្រាប់ការប្រើប្រាស់តាមភូមិនីមួយៗ ។ ស្តេចម៉ុងហ្គោលនោះ-ដែលជាស្តេចល្បីល្បាញជាងគេ ពីព្រោះព្រះអង្គទ្រង់ជាស្តេចពូកែធ្វើសង្គ្រាមពង្រីកទឹកដីផង តែទ្រង់ក៏ពូកែខាងក្បួនច្បាប់ជាទស្សនវិទូប្រកបទៅដោយការសន្តោសប្រណីផងដែរ ដែលជាប្រការមិនសូវមានសម្រាប់ស្តេចកាន់សាសនាមហាម៉ាត់ ហើយក៏កម្រណាស់ដែរសម្រាប់ស្តេចកាន់គ្រិស្តសាសនា- ព្រះអង្គបានសុគតទៅនៅក្នុងឆ្នាំ១៦០៥ ។ បន្ទាប់ពីនោះមក មានកើតស្តេចល្អបែបនេះមួយអង្គទៀតនៅឯអាក្រា រាជធានីដែលទ្រង់បានបង្កើតឡើង នៅក្នុងរាជវាំងសង់អំពីថ្មើមថ្មពណ៌សយកមកពី ជយបុរៈ នៅកណ្តាលបន្ទាយពណ៌ក្រហម ដែលស្ថិតនៅលើមាត់ទន្លេជមនា ។ ទ្រង់បានវាយយករាជាពូតនៈ, បីងហ្កាល់, គូហ្សារ៉ាទី, សិនដ្ឋ, កាស្មៀរ និងកង់ដាហា ដាក់ជាចំណុះ ។ បើទោះបីថាព្រះអង្គបានបង្ហូរឈាម និងទឹកភ្នែករបស់អ្នកស្រុកយ៉ាងណាក្តី ក៏មានអ្នកស្រុកជាច្រើនដែលព្រះអង្គធ្លាប់វាយឲ្យបរាជ័យរួចដាក់មកក្នុងការត្រួតត្រារបស់ព្រះអង្គ និងពលទាហាន ដែលព្រះអង្គធ្លាប់ដឹកនាំទៅធ្វើការកាប់សម្លាប់រង្គាល និងដុតបំផ្លាញខ្ទេចខ្ទី នាំគ្នាយំសោកស្តាយព្រះអង្គគ្រប់គ្នា ។

នៅសតវត្សរ៍ទី១៦ ប្រទេសឥណ្ឌាគ្មានទំនាក់ទំនងអ្វីជាប់លាប់ជាមួយឥណ្ឌូចិនទេ ខុសពីពេលមុនដែលមាននិគមជនឥណ្ឌានៅពាសពេញ ហើយគឺឥណ្ឌានេះឯងដែលបាននាំអារ្យធម៌មកឲ្យឥណ្ឌូចិន ។ ជាពិសេសគឺ កម្ពុជាដែលក្រោយពីទទួលបាននូវអារ្យធម៌អារ្យាងពីឥណ្ឌាហើយ បានជំរុញអារ្យធម៌នេះឲ្យឡើងដល់កំពូលខ្ពស់បំផុតដល់មកពេលនេះ កម្ពុជាបានបោះបង់ព្រហ្មញ្ញសាសនាដែលនៅបន្តរីកលូតលាស់នៅឥណ្ឌាទាំងភាគខាងជើង ទាំងភាគខាងត្បូងនៅឡើយ ហើយផ្តាច់ចំណងទាក់ទងទាំងអស់ជាមួយ ដេកង់ ជាគ្រូបាអាចារ្យ ដែលធ្លាប់បានបង្ហាត់បង្រៀនភាសាសំស្ក្រឹត និងផ្តល់ទម្រង់អក្សរឲ្យ ។ ពេលនោះពួកបច្ចាញាតិរបស់និគមជនឥណ្ឌា បានរលាយប្របល់ចូលសព្វសាច់ជាមួយពួកអ្នករដ្ឋវាសីអស់ហើយ ។ ហើយដោយគ្មានទំនាក់ទំនងជាមួយឥណ្ឌា ដែលត្រលប់ទៅកាន់ព្រហ្មញ្ញសាសនាវិញ និងគ្មានទំនាក់ទំនងជាមួយកោះជ្វា ដែលបានប្រែទៅកាន់សាសនាអ៊ីស្លាមនោះ ប្រទេសកម្ពុជាបានក្លាយទៅជាប្រទេសមួយឯកោ ដូចជារដ្ឋតូចៗឯទៀតនៅឥណ្ឌូចិន ដែលបានទទួលអារ្យធម៌អារ្យាងដែរ ព្រោះថា គេមានច្រកសម្រាប់មើលឃើញលោកខាងក្រៅតែតាមរយៈកោះសិរីលង្កាមួយប៉ុណ្ណោះ

ជាទីកន្លែងដែលព្រះពុទ្ធសាសនាបោះទីតាំងរឹកលូតលាស់ខ្លាំងមែនទែនទៅហើយ ។

សង្គ្រាមឈ្លោះប្រកែកគ្នាដណ្តើមដីធ្លី និងប្រជាជន ដែលកើតមានឥតដាច់នៅឥណ្ឌូចិន ពីសតវត្សរ៍ទី១៣ រហូតដល់សតវត្សរ៍ទី១៧ មិនអនុញ្ញាតឲ្យគេថែរក្សា ហើយអភិវឌ្ឍន៍ចំណង់ចំណូលចិត្តខាងអក្សរសាស្ត្រ វិទ្យាសាស្ត្រ និងសិល្បៈ បានដូចកាលពីពេលដែលគេមានចំណងទាក់ទងជាមួយនឹងឥណ្ឌាទេ ។ ទាំងឥណ្ឌូចិន ទាំងកម្ពុជាដែលធ្លាប់ជាជាតិសាសន៍ដ៏ធំមួយ គឺលែងមានទំនាក់ទំនងជាមួយប្រទេសឥណ្ឌា ដែលជាគ្រូបង្ហាត់បង្ហាញទៀតហើយ ។ ដោយហេតុនេះ ប្រទេសកម្ពុជាដែលកាន់ព្រះពុទ្ធសាសនាត្រូវចុះអាប់ឱនទៅៗ ខាងប្រាជ្ញា ស្មារតី ។

## ៥- ពួកអឺរ៉ុប

មានព្រឹត្តិការណ៍ដ៏ធំមួយដែលគេអាចចាត់ទុកបានថាជាព្រឹត្តិការណ៍ដ៏ធំធេង គឺធំជាងការបាក់ស្រុតចុះនៃអាណាចក្រកម្ពុជា ឬក៏ការរលត់រលាយនៃព្រះរាជាណាចក្រចាម្ប៉ាទៅទៀត ព្រោះវាមានឥទ្ធិពលដែលមិនដែលមានដោយផ្ទាល់ ឬដោយប្រយោល មកលើបណ្តារដ្ឋទាំងឡាយនៅឥណ្ឌា អាំងស៊ូឡាំង ឥណ្ឌូចិន និងចុងបូព៌ាប្រទេសផងដែរ ដោយជះផលវិបាកមកលើនយោបាយប្រចាំថ្ងៃរបស់រដ្ឋទាំងនោះ ក៏ដូចជាមកលើផលប្រ-យោជន៍ ខាងជាតិសាសន៍ និងអារ្យធម៌នោះ គឺការធ្វើដំណើរមកដល់របស់ពួកអឺរ៉ុប ដែលអង់អាចក្លាហាន ហ៊ានធ្វើឲ្យអ្វីៗប្រែក្រឡាស់ច្របូកច្របល់អស់ ហើយក្តាប់អ្វីៗទាំងអស់បន្តិចម្តងៗ ។

ចាប់តាំងពីពេលដែលមានសង្គ្រាមធំៗបង្កឡើងដោយពួកម៉ុងហ្គោល និងតាកតាររបស់ហ្សង់ហ្ស៊ីខាន់រួចមក នៅឯចុងបូព៌ាប្រទេស ជាពិសេស គឺនៅស្រុកចិន គេធ្លាប់ប្រទះឃើញមានពួកអ្នកបស្ចិមប្រទេសធ្វើដំណើរផ្សងព្រេងមកដល់ចុងខាងកើតបំផុតនៃដែនដីនេះដែរ តែពួកនេះមកជាចំនួនតិចតួច មិនដែលមកជាក្រុមទេម្ល៉ោះហើយ ច្រើនតែនាំផលប្រយោជន៍មកឲ្យស្តេចក្នុងស្រុកដែលពួកគេមកដល់ មិនដែលនាំយកការភ័យខ្លាចមកឲ្យទេ ។ អ្នកទាំងអស់នោះរួមមានទាំងអ្នកធ្វើដំណើរផ្សងព្រេងចាប់តាំងពីសតវត្សរ៍ទី១២មក ដូចជាជនជាតិវេនីសឈ្មោះ ម៉ាកូប៉ូឡូ, លោកសង្ឃកាតូលិកហ្វ្រង់ស៊ីស្កាំង ឈ្មោះ អូដរិចដឺព័រដឺណូន, ជនជាតិអ៊ីតាលីឈ្មោះ នីកូឡូឌីកុងទី, ជនជាតិរុស្ស៊ីឈ្មោះ អាថាណាក់នីគីទីន, ជនជាតិហ្សេន័រឈ្មោះ ហ៊ីយេរ៉ូនីម៉ូឌីសង់តូស្តេហ្វាណូជាដើម ដែលមកហើយបានសរសេរកំណត់ត្រាផ្សេងៗ ឬបាននិយាយរឿងរ៉ាវប្រាប់គេឯង ។ នៅមានអ្នកផ្សងព្រេងជាច្រើនទៀតដែលគេមិនបានដឹង ព្រោះមិនមានសរសេរអ្វីទុក ។

ពួកអឺរ៉ុបដ៏ហានក្លាទាំងអស់នោះបានមកដល់ប្រទេសឥណ្ឌាដោយធ្វើដំណើរឆ្លងកាត់ប៉ាឡេស្ទីន និងពែក្សឬក៏មកតាមប៉ាឡេស្ទីន រួចឆ្លងកាត់សមុទ្រក្រហម ឬមកដល់ស្រុកចិនតាមកុងស្តង់ទីណូប ពែក្សឬម៉ូស្គូវី តាកតារីឬម៉ុងហ្គោលី ។

ការធ្វើដំណើរដ៏វែងឆ្ងាយពីអឺរ៉ុបមកចុងបូព៌ាពេលនោះជួបប្រទះការលំបាក និងគ្រោះថ្នាក់ជាច្រើន គឺ

ដោយហេតុនោះហើយបានជាមិនសូវមានអ្នកណាចង់មក ។

កំប៉ុន្តែ ៦ឆ្នាំក្រោយពីលោក គ្រីស្តូហ្វកូឡុម បានរកឃើញទ្វីបអាមេរិក (១៤៩២) ដែលគេជឿថាជាមាត់សមុទ្រខាងកើតរបស់ប្រទេសឥណ្ឌា គឺនៅពេលដែលជនជាតិព័រទុយហ្គាល់ម្នាក់ឈ្មោះ វ៉ាស្កូដឺហ្គាម៉ា បានរកឃើញផ្លូវថ្មីមួយទៀតសម្រាប់ធ្វើដំណើរមកកាន់ឥណ្ឌានៅក្នុងឆ្នាំ១៤៩៨ ផ្លូវនោះគឺធ្វើដំណើរតាមសមុទ្រព័ទ្ធជុំវិញទ្វីបអាហ្វ្រិកឆ្លងកាត់ជ្រោយខ្យល់ព្យុះ (សព្វថ្ងៃគេហៅថាជ្រោយនៃសេចក្តីសង្ឃឹម) រួចមកចុះចតនៅនឹងកាលីគុតនាមាត់ឆ្នេរម៉ាឡាបា សករាជថ្មីមួយបានចាប់ផ្តើមឡើងសម្រាប់ពិភពលោក ។ ជាតិសាសន៍ផ្សេងៗ ដែលមិនធ្លាប់ដែលស្គាល់គ្នាពីមុនមក បានចាប់ផ្តើមជួបគ្នាយ៉ាងគំហុក ជាមួយនឹងផលប្រយោជន៍ គុណភាព ចំណង់ចំណូលចិត្តខាងនយោបាយ សាសនា និងគំនិតកេងប្រវ័ញ្ចពាណិជ្ជកម្មប្លែកៗពីគ្នា ។

គេប្រទះឃើញមានពួកព័រទុយហ្គាល់ ហុល្លង់ អង់គ្លេស បារាំង និងដាណឺម៉ាកកាន់តែច្រើនឡើងៗ នៅតាមមាត់សមុទ្រឥណ្ឌា ទៀបកោះម៉ាឡាកា កោះជ្វា ប័រណេអូ អារ៉ាកាន់ ភូមា សៀម រហូតដល់មាត់សមុទ្រប្រទេសជប៉ុន និងចិន ដែលមានទំនាក់ទំនងជាមួយពួកអ្នកស្រុកអាយកាន់តែខ្លាំងឡើងៗ ។

ពួកអ្នកមកពីអឺរ៉ុបទាំងនោះបានមកជួបគ្នានៅចុងបូព៌ា ធ្វើសង្គ្រាមនឹងគ្នា និងជាមួយស្តេចស្រុកអាយផងដែរ ។ ជួនកាល មានពួកទាហានដែលរត់ចោលជួរ ឬក៏ពួកនាវិកដែលត្រូវចាប់បានហើយដោះលែងទៅវិញ បានផ្លាស់ប្តូរបម្រើការងារពីប្រទេសមួយទៅឲ្យប្រទេសមួយទៀត ឬក៏ស្ម័គ្រចូលខ្លួនបម្រើស្តេចស្រុកអាយ ហើយបង្ហាត់បង្ហាញឲ្យចេះប្រើសិល្បៈសង្គ្រាមរបស់លោកខាងលិច ។ អ្នកផ្សព្វផ្សាយសាសនាកាតូលិក ដែលមកដល់ចុងបូព៌ាដោយខ្លួនឯងតាមផ្លូវគោក ឬដែលប្រទេសនីមួយៗនាំយកមកតាមកប៉ាល់ ដើម្បីបម្រើផលប្រយោជន៍សមាគមសាសនារបស់គេ ក៏សកម្មក្នុងការផ្សព្វផ្សាយសាសនា មិនចាញ់ពួកទាហាន ឬពួកឈ្មួញប៉ុន្មានដែរទេ ។ ពួកនោះអង់អាចក្លាហាន ចូលលុកជ្រៅទៅក្នុងរាជាណាចក្រនីមួយៗ ហើយរៀបដើងព្រួលជួយដល់ការឈ្លានពានយករាជាណាចក្រនោះដាក់ជាចំណុះ ។ ប៉ុន្តែពួកអឺរ៉ុបដែលមានការប្រថុយប្រថានជាងគេ គឺពួកអ្នកដែលរត់ចោលជួរ ជាពិសេសគឺពួកអ្នកផ្សងព្រេងព័រទុយហ្គាល់ និងអេស្ប៉ាញ៉ុល ដែលធ្វើដំណើរគ្មានទិសដៅ ជួនកាលតែឯកឯង ជួនកាលជាក្រុម ។

នាពេលនោះកំពង់ផែដែលធំជាងគេនៅឥណ្ឌូចិនគឺកំពង់ផែតេណាស់សេរីម ដែលបម្រើផលប្រយោជន៍ជាពិសេសឲ្យប្រទេសសៀម ដោយបើកទ្វារបែរទៅរកឈូងសមុទ្របឹងហ្កាល់ ។ ក្រោយពី វ៉ាស្កូដឺហ្គាម៉ា ធ្វើដំណើរព័ទ្ធជុំវិញទ្វីបអាហ្វ្រិក ឆ្លងកាត់ជ្រោយខ្យល់ព្យុះ រួចមកចុះចតនៅកាលីគុតលើឆ្នេរសមុទ្រម៉ាឡាបា មិនទាន់ទាំងបាន៣ខែផង ស្រាប់តែពួកព័រទុយហ្គាល់មកតាំងទីលំនៅ នៅពាសពេញតេណាស់សេរីម ។ ហេតុការណ៍ទាំងអស់នេះ លោក អាមេរីហ្គោវេស្ពូស៊ី បានរៀបរាប់នៅក្នុងឆ្នាំ១៥០១ ហើយយើងនៅមានរបាយការណ៍ជាច្រើនទៀតដែលបញ្ជាក់ថា កំពង់ផែតេណាស់សេរីមនេះ មានពួកអឺរ៉ុបមកចូលចតច្រើនជាងគេ ដូចជារបាយ

ការណ៍របស់ជនជាតិរ៉ូម៉ាំងឈ្មោះ លូដូវីកូដឺវ៉ាថេម៉ា ក្នុងឆ្នាំ១៥០៣ និងរបាយការណ៍របស់ជនជាតិព័រទុយហ្គេ ឈ្មោះ ទ្រឹស្តង់ដឺអាគូញ៉ា ក្នុងឆ្នាំ១៥០៦ ជាដើម ។ ៣ឆ្នាំក្រោយមកមានជនជាតិព័រទុយហ្គេម្នាក់ទៀត ឈ្មោះ ឌីយេហ្គោឡូប៉េសេគៀរ៉ា បានធ្វើដំណើរផ្សងព្រេងនៅក្នុងសមុទ្រម៉ាឡាកា មកដល់រាជាណាចក្រអ៊ីស្លាម ម៉ាឡាកា កាត់ពីមុខសិង្ហបុរី រួចចូលមកក្នុងឈូងសមុទ្រសៀម ។ បន្ទាប់ពីនោះគឺលោក អាល់ប៊ុយកែក ដែលយល់ច្បាស់អំពី សារសំខាន់ខាងផ្នែកពាណិជ្ជកម្ម និងយុទ្ធសាស្ត្ររបស់ម៉ាឡាកា ក៏តាំងចាប់ផ្តើមសង្គ្រាមដណ្តើមយកមុនគេនៅក្នុងឆ្នាំ ១៥០៩ ទីបញ្ចប់ក៏ដណ្តើមយកបានមែន នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៥១១ ។

លោក អាល់ប៊ុយកែក នេះ ជាឧបរាជស្តេចព័រទុយហ្គេ ប្រចាំនៅចុងបូព៌ា កាលនោះគេហៅថា “ប្រទេស ឥណ្ឌាខាងកើត” ។ គាត់បានបញ្ជូនអនុសេនីយ៍ឯករបស់គាត់ម្នាក់ ឈ្មោះ ឌុយអាតហ្វែរណង់ដែស ឲ្យធ្វើដំណើរទៅ ស្រុកសៀម ឡើងតាមទន្លេមេណាមរហូតដល់អយុធ្យា មុនពេលដែលរាជធានីត្រូវភ្លើងឆេះ (រាជពង្សាវតារ សៀម និងការនិទានតៗគ្នាមកនិយាយថា ខូចខាតអស់ផ្ទះ១០ម៉ឺនខ្នង[៣០]) ក្នុងរាជ្យព្រះបាទជ័យរាជាធិរាជ ។ អនុ សេនីយ៍នោះវិលត្រលប់មកវិញតាមជើងគោក ដោយនាំយករាជទូតដែលព្រះរាជាបញ្ជូនឲ្យមកជួបស្តេចឧបរាជ ប្រទេសឥណ្ឌាខាងកើតផង ធ្វើដំណើរតាមផ្លូវដែលសៀមតែងចុះមកវាយរាជាណាចក្រ ម៉ាឡាកា រហូតទៅដល់ តេណាស់សេរីម ។

នៅក្នុងឆ្នាំ១៥១៧ មានអនុសេនីយ៍របស់ឧបរាជប្រទេសឥណ្ឌាខាងកើតម្នាក់ទៀត ឈ្មោះថា ហ្វែរណា អូប៉េរេដឺអង់ដ្រាត បានមកដល់កូសាំងស៊ីន (គឺអាណ្ណាមសព្វថ្ងៃ) ។ ជនជាតិវេនីសឈ្មោះ ម៉ាកូប៉ូឡូ ក៏ធ្លាប់បាន មកដល់ទីនេះដែរកាលពីសតវត្សរ៍ទី១៤ កាលនោះគឺជាប្រទេសចាម្ប៉ា ក្រោយពួកអារ៉ាប់ដែលហៅទីនោះថា ហ្សែនហ្វ ។

នៅក្នុងឆ្នាំ១៥៣៩ លោក ហ្វែរណង់ដេម៉ង់ដេពីនតូ បានធ្វើដំណើរជុំវិញកោះជ្វា ស៊ុយម៉ាត្រា បាតា ទៀប-កោះម៉ាឡាកា ហើយបានចុះទស្សនាលីហ្គ័រ និងប៉ាតានី ។ គាត់បានចេញពីទីនោះនៅក្នុងខែឧសភា ឆ្នាំ១៥៤០ ជាមួយនឹង អង់តូនីញ៉ូដាហ្វារីយ៉ា ទៅពិនិត្យមើលឆ្នេរសមុទ្រភាគខាងត្បូងប្រទេសចាម្ប៉ា ។ គាត់បានមកចុះចតនៅ ពូឡូកុងឌ័រ ដែលគាត់កំណត់ថានៅ៨,២០ អង្សាពីខាងជើងខ្សែបន្ទាត់ ត្រឹមកម្ពស់មាត់ពាមទន្លេកម្ពុជា ។ គាត់បាន (បន្តឡើងតាមទន្លេនេះចម្ងាយ៦គារ៉ុត ប្រហែលជា២៤គម) មកដល់កោះមួយ ដែលគាត់ហៅថា កាំបូហ្សា ត្រង់ កន្លែងមួយដែលមានឈ្មោះថា ប្រាឡាពីសាន តែខ្ញុំមិនដឹងថាជាកន្លែងណាសព្វថ្ងៃ ។ គាត់ថា គាត់បានទៅ

[៣០] តួលេខនេះហាក់ដូចជាច្រើនហួសពេក ពេលនោះអយុធ្យាមានប្រជាជនប្រហែលត្រឹមតែ ៤០០ ទៅ ៥០០ពាន់ គ្រួសារ ប៉ុណ្ណោះ ។ ខ្ញុំគិតថាប្រហែលជា ១ម៉ឺនខ្នងផ្ទះទេ ។

ដល់ស្ទឹងមួយដែលខ័ណ្ឌចែកកម្ពុជាពីចាម្ប៉ា រួចហើយបានបន្តដំណើរតាមឆ្នេរសមុទ្រចាម្ប៉ាទៅដល់ស្ទឹងមួយទៀត ដែលគាត់ហៅថា ទូបាសូយ នៅចម្ងាយ១៧គាវុត (ប្រហែល៦៨គម) ពីព្រំប្រទល់ដែនកម្ពុជា គឺនៅក្នុង បិញធន់ ។ គាត់បានបន្តដំណើរទៅទិសខាងជើងទៀត ហើយបានទៅដល់ជ្រោយមួយដែលគាត់និយាយថា អ្នកស្រុកហៅថា ទីណាកូរើ[៣១] ហើយដែលពួកព័រទុយហ្គេស្គាល់ច្បាស់ហើយដាក់ឈ្មោះឲ្យថា វ៉ារែឡា ។ ក្រោយនោះបន្តិច លោក អង់តូនីញ៉ូដាហ្វ៉ែរីយ៉ា បានទៅដល់កោះហៃណាំ ហើយបានប្រយុទ្ធជាមួយកប៉ាល់ ចម្បាំងរបស់ចិន ។ នៅទីបញ្ចប់ ក្រោយពីបានធ្វើដំណើរផ្សងព្រេងដ៏គ្មានខ្លាចស្លាប់ចំនួន២០ដង គាត់ក៏ត្រូវគេចាប់បានជាមួយ នឹងបក្សពួកនៅណាន់គិន ហើយនាំយកទៅប៉េកាំង រួចនាំមកក្វាងស៊ីវិញ ។

ពីរឆ្នាំក្រោយមក ក្រោយពីបានសិក្សានូវអ្វីដែលពួកគេឃើញនៅស្រុកចិន និងបណ្ដាស្រុកដែលបានឆ្លងកាត់ អង់តូនីញ៉ូដាហ្វ៉ែរីយ៉ា និងម៉ង់ដេពីនតូ និងបក្សពួកមួយចំនួនទៀត បានទទួលនូវសេរីភាពឡើងវិញ ហើយមកជួបជុំគ្នានៅឯ ម៉ាតាបាន ដែលមានចៅពញាមួយអង្គសោយរាជ្យ ចំពេលដែលពួកភូមាវាយចូលដុតបំផ្លាញខ្ទេចខ្ទី[៣២] ។

យូរបន្តិចក្រោយមក គេប្រទះឃើញ ម៉ង់ដេពីនតូ នៅឯជប៉ុនឯណោះ ។

ដូច្នេះ យើងឃើញថា ពួកព័រទុយហ្គេ បានគ្រប់គ្រងលើទីផ្សារទាំងអស់នៅចុងបូព៌ាប្រទេស ។ សំពៅ ព័រ-ទុយហ្គេ ធ្វើដំណើរទៅមកក្នុងសមុទ្រ ចាប់ពីជ្រោយខ្យល់ព្យុះ ឬជ្រោយនៃសេចក្ដីសង្ឃឹមរហូតដល់កោះនៃប្រទេសជប៉ុន ។ ពួកគេស្គាល់ប្រទេសទាំងអស់នៅក្នុងតំបន់នេះ ពីត្រឹមពាក់កណ្ដាលសតវត្សរ៍ទី១៦មក ។ ពួកព័រ-ទុយហ្គេ ដែលបានមកដល់ប្រទេសកម្ពុជាមាន លោកឪពុក ហ្គាស្ប៉ាដែឡាគ្រុយ នៅក្នុងឆ្នាំ១៥៥០ លោកឪពុក លូអ៊ីសគ័រដូហ្សូ និងជន់ម៉ាដែរ៉ា នៅក្នុងឆ្នាំ១៥៥៣ អ្នកទាំងអស់នេះធ្វើដំណើរកពី ហ្គូអា មកក្នុងរាជ្យព្រះរាមាច័ន្ទរាជា រួចមានលោកឪពុក ឡូប៉េ និងអាហ្សេវ៉ាដូ ក្នុងឆ្នាំ១៥៥៨ ។ ក្រោយពីអវត្តមានអស់ពេលប៉ុន្មានខែ អ្នកទី១ បានវិលត្រលប់មកវិញនៅក្នុងឆ្នាំ១៥៦០ ក្នុងរជ្ជកាលព្រះបរមឥន្ទ្ររាជាដែលសោយរាជ្យនៅលង្វែក ។ ពួកសាសនទូតកាតូលិកព័រទុយហ្គេ ដែលមកកាន់កម្ពុជានេះមិនមែនមកតែម្នាក់ឯងទេ តែងតែមានពួកពាណិជ្ជករ ពួកអ្នកដើរកប៉ាល់ ពួកអ្នកផ្សងព្រេង និងពួកអ្នករត់ចោលជួរមកជាមួយជានិច្ច ហើយពួកនេះមិនខ្លាចនឹងធ្វើអ្វីៗទេ ដើម្បីរស់ ។ មានអ្នកខ្លះបេះកសាងបាននូវស្ថានភាពដ៏សំខាន់ ដណ្ដើមបានតួនាទីនៅក្នុងនយោបាយ ហើយប្រែក្លាយទៅជាមន្ត្រីធំទៀត ។ យើងនឹងបានឃើញនៅខាងក្រោមនេះនូវតួនាទីដ៏សំខាន់របស់ លូអ៊ីសបេឡូសូ នៅ

---

[៣១] តាមមើលទៅ គឺជាពាក្យម៉ាឡេថា តាណាហ៍ ប្រែថា ដីពួកកូរើ ។

[៣២] មហាក្សត្រីដែលត្រូវជាបុត្រីរបស់ស្ដេច ប៉េហ្គូ បានត្រូវភូមាចាប់បាន ជាមួយនឹងរាជបុត្រទាំង៤អង្គ ។

កម្ពុជាក្នុងឆ្នាំ១៥៩៤ ពេលមានការធ្វើឃាតស្តេចរាមាជើងព្រៃ ដើម្បីលើករជ្ជទាយាទរបស់ស្តេចមុនឲ្យឡើងសោយរាជ្យវិញ ដែលបន្ទាប់មកបានធ្វើឲ្យបក្សពួកគាត់ទទួលបាននូវបុណ្យសក្តិធំ ក្នុងនោះមានពួកអេស្ប៉ាញ៉ុលឈ្មោះ ហ្គុនសាលេស និងផ្ញារ៉ូកាស្តីឡូ និងជនព័រទុយហ្គេឈ្មោះ ដុនឌីយ៉ូហ្គោ ជាដើម ។

ស្ថានភាពរបស់ពួកព័រទុយហ្គេនៅចុងបូព៌ាប្រទេសកាន់តែរឹងមាំឡើងៗរាល់ថ្ងៃ ហើយដើម្បីរក្សាបាននូវស្ថានភាពនេះ គេត្រូវប្រយុទ្ធតទល់នឹងពួកអឺរ៉ុបផ្សេងៗទៀត ដែលបានបើកនាវាកាត់ជ្រោយនៃសេចក្តីសង្ឃឹមដែរ ហើយចូលមកឈ្លោះដណ្តើមយកអាណាចក្រមហាសមុទ្រ និងទីផ្សារធំៗនៅចុងបូព៌ាប្រទេសនេះ ។ ពួកព័រទុយហ្គេ មិនបានទទួលស្វាគមន៍ការមកដល់របស់លោកឪពុក ដឺឡាម៉ុត ជាសាសនទូតសញ្ជាតិបារាំងទេ ជាពិសេស គឺពួកដូមីនីកាំង អេស្ប៉ាញ៉ុល ២នាក់ គឺលោកឪពុក ម៉ាល់ខូអាត និង ដឺឡាបាស៊ីដ ដែលត្រូវបានបណ្តេញចេញមិនឲ្យចូល ។ លោកឪពុក ដឺឡាបាស៊ីដ បានត្រូវគេសម្លាប់ចោលនៅពេលដែលចុះចតក្នុងទឹកដីកម្ពុជា ហើយមរណភាពនោះមិនមែនជា "ទុក្ករភាពនៃជំនឿខ្លួនឯងទីមួយ" ដូចដែលគេថានោះទេ ប៉ុន្តែគឺជាអ្នករងគ្រោះ ដោយសារការដែលពួកព័រទុយហ្គេស្អប់ខ្ពើមពួកអេស្ប៉ាញ៉ុល ជាពិសេស គឺពួកដូមីនីកាំង ដែលជាចៅក្រមក្នុងសាលាកាត់ក្តីកាតូលិកនៅប្រទេសអេស្ប៉ាញនេះតែម្តង ។

ពួកព័រទុយហ្គេស្អប់ពួកហុល្លង់ជាងគេ ។ នៅក្នុងឆ្នាំ១៦០១ ពួកព័រទុយហ្គេបានកាប់សម្លាប់វគ្គាលក្រុមនាវិកហុល្លង់របស់កប៉ាល់ឈ្មោះ ហាកឡឹម និងលែយដឺ ដែលស្តេចខ្មែរបានស្វាគមន៍ទទួលយ៉ាងត្រឹមត្រូវ ដោយមានការចូលដៃចូលជើងពីពួកមូស្លីមម៉ាឡេ ដែលរបររកស៊ីលក់ដូររបស់គេ ត្រូវបានរំខានដោយពួកហុល្លង់ដែលទើបនឹងមកដល់នេះ ។

ពួកហុល្លង់ត្រូវពួកព័រទុយហ្គេស្អប់ជាងគេបំផុត ព្រោះត្រូវជាសម្ព័ន្ធមិត្តរបស់ពួកអង់គ្លេសផង បានបើកការវាយប្រយុទ្ធមកវិញនៅគ្រប់ទីកន្លែង ធ្វើឲ្យពួកព័រទុយហ្គេប្រយុទ្ធតបតយ៉ាងសាហាវជាទីបំផុត ព្រោះគ្មាននរណាគាំទ្រ ។ ប្រទេសអេស្ប៉ាញក៏ក្បត់ហើយបានដណ្តើមយកប្រទេសព័រទុយហ្គេដាក់ជាចំណុះ ម្យ៉ាងទៀត ពួកអេស្ប៉ាញនេះ កំពុងសប្បាយរីករាយនឹងការរកឃើញទ្វីបអាមេរិក ហើយនាវាអេស្ប៉ាញត្រលប់មកពីអាមេរិកវិញ ដឹកមាសមកជាច្រើន ធ្វើឲ្យគេក៏ចាប់ព្រងើយកន្តើយបោះបង់ទីតាំងនៅឥណ្ឌាខាងកើតចោល ។ ក្រោយមកការបាត់បង់វិន័យ បានធ្វើឲ្យពួកព័រទុយហ្គេបែកខ្ញែកគ្នា ទៅរស់នៅជាមួយពួកអ្នកស្រុកដើមក្នុងនាមជាអ្នកស៊ីឈ្នួលធ្វើសង្គ្រាមឲ្យស្តេច ។ មានពួកនេះជាង១ពាន់នាក់នៅការពារស្តេចភូមាក្នុងឆ្នាំ១៥៤៨, ៣៦០នាក់នៅជាមួយស្តេចសៀមក្នុងឆ្នាំ១៥៥០ ។ និយាយដោយខ្លី នៅទីណាដែលស្តេចស្រុកអាយមានលុយ គឺមានវត្តមានពួកអ្នកស៊ីឈ្នួលធ្វើសង្គ្រាមព័រទុយហ្គេហើយ ។

ក៏ប៉ុន្តែមិនមែនតែពួកព័រទុយហ្គេនេះទេ ដែលបោះបង់ផលប្រយោជន៍ប្រទេសជាតិរបស់ខ្លួន ទៅបម្រើស្តេចស្រុកអាយ ។ មានពួកអឺរ៉ុបផ្សេងៗទៀតជាច្រើននាក់ដែរបានធ្វើដូច្នេះ ជាថ្នូរនឹងផលប្រយោជន៍ ដែលជូន

កាល មានវិសាលភាពធំធេង ។ ហេតុការណ៍នេះបាននាំឲ្យកើតមានការប៉ះទង្គិច ការប្រណែនពីពួកមន្ត្រី អំពើហិង្សាពីពួកអឺរ៉ុប ដែលយល់ថា ខ្លួនចំណាយពេលឥតប្រយោជន៍ ត្រូវគេបោកបញ្ឆោត មើលងាយមើលថោក រួចមានការបំពានអំណាចរបស់ព្រះរាជា ការបះបោររបស់អ្នកស្រុក ការទាមទារសំណងខូចខាត នៅទីបញ្ចប់គឺ កើតមានសង្គ្រាមរវាងពួកអឺរ៉ុប និងអ្នកស្រុកអាយឡើង ពួកនេះគ្មានអាវុធអ្វីគ្រប់គ្រាន់ដូចពួកអឺរ៉ុបទេ ។ យើងនឹងបានឃើញនៅខាងក្រោមនេះ នូវសង្គ្រាមមួយនៅភ្នំពេញរវាងពួកហុល្លង់ ជាមួយនឹងទ័ពរបស់ព្រះរាជា ។

ក្រុមហ៊ុនពាណិជ្ជកម្មរបស់អឺរ៉ុប បានបំពេញតួនាទីសំខាន់មួយនៅចុងបូព៌ាប្រទេស នោះគឺការធ្វើឲ្យអាណាចក្រធំៗបែកបាក់ទៅជារដ្ឋតូចៗ ។ ចំពោះបញ្ហានេះ មុនដំបូងមានតែពួកព័រទុយហ្គេម្នាក់ប៉ុណ្ណោះ នៅដើមសតវត្សរ៍ទី១៧ ។ ឧបរាជអាល់ប៊ុយកែក បានដណ្ដើមយកសូស កោះទីស៊ុយ៉ារីន (កោះភូមិ៣០) ហ្គូអា និងរាជធានីក្នុងឆ្នាំ១៥១០ ដែលអនុញ្ញាតឲ្យគេអាចធ្វើពាណិជ្ជកម្មនៅតាមមាត់ឆ្នេរសមុទ្រទាំងអស់ ។ រួចគាត់បានវាយដណ្ដើមយកទីក្រុងម៉ាឡាកា ដែលជាហេតុធ្វើឲ្យស្ដេចទាំងឡាយនៅកោះជ្វា ស៊ូម៉ាត្រា និងឥណ្ឌូចិន នាំគ្នារត់មករកគាត់ ។ គាត់បានវាយយកទីក្រុងអារមូហ្ស៍នៅលើឆ្នេរសមុទ្រពែក្ស ដែលធ្វើឲ្យគាត់មានសិទ្ធិផ្ដាច់មុខលើចរាចរនៅក្នុងឈូងសមុទ្រពែក្ស និងនៅក្នុងសមុទ្រអារ៉ាប់ ។ ក្រោយមក គាត់បានវាយយកកោះឌីយូ នៅលើឆ្នេរគូសេរ៉ាទី ហើយបានបោះដៃទៅត្រួតត្រាឆ្នេរសមុទ្រហិណ្ឌូខាងលិច ។ នៅពេលនោះពួកព័រទុយហ្គេ មានទីភ្នាក់ងារពាណិជ្ជកម្ម ឬភោគនិគមពាសពេញ ចាប់ពីនគរពែក្សរហូតដល់ចុងខាងត្បូងប្រទេសឥណ្ឌា ទៅដល់ជ្រោយកូម៉ូរ៉ាំង ក្នុងនោះរួមមានបារ៉ាជី, ស៊ូរ៉ាត់, ក្រុមកោះបាសែម ដែលមានផងដែរនូវបុមបៃ និងសាល់សែតដែលទិញយកពីគុហ្សឺរ៉ាត, អ៊ីរ័ន័រ, កាណាអ៊ីរ័, កាលីគូតជាដៃដែល វ៉ាស្កូដឺហ្គាម៉ា បានចុះចតមុនដំបូង, កូសាំង, គូឡាន ។ នៅលើឆ្នេរកូរ៉ូម៉ង់ដែល ពួកព័រទុយហ្គេមានណាហ្គាប៉ាតាណាម គឺជាភូមិមួយ ដែលគេបានកែប្រែឲ្យទៅជាទីក្រុង ប្រកបដោយរបងការពាររឹងមាំ សានតូម ដែលជា ម៉ាដ្រាស សព្វថ្ងៃ, ហើយនិងឆ្នេររបស់សិរីលង្កាផងដែរ ។ ពួកព័រទុយហ្គេពេលនោះ គឺជាស្ដេចនៅពាសពេញអាស៊ី ក៏ប៉ុន្តែស្ដេចទាំងនោះមានសត្រូវជាច្រើន ដែលជាអ្នកមក ពីអឺរ៉ុបដូចគ្នា ។ ពួកសាសនទូតរបស់ព័រទុយហ្គេ បានបញ្ចុះបញ្ចូលអ្នកស្រុកឲ្យប្រែមកកាន់សាសនាកាតូលិកនៅច្រើនកន្លែងកន្លែងខ្លះឆ្ងាយៗពីទីតាំងរបស់គេ ជាក់ស្ដែងគឺគេប្រទះឃើញមាន រហូតដល់សព្វថ្ងៃនូវសំណង់បាក់បែកនៃវិហារកាតូលិក ដែលគេបានសាងសង់ ។ កិច្ចប្រតិបត្តិការរបស់ព័រទុយហ្គេ មិនមែនមាននៅត្រឹមតែពែក្ស និងឥណ្ឌាប៉ុណ្ណោះទេ ។ ចាប់តាំងពីសតវត្សរ៍ទី១៦មក ពួកនេះបានទៅដល់កោះទាំងឡាយរបស់ជប៉ុន, ឆ្នេរសមុទ្រចិន, ជ្វា, ស៊ូម៉ាត្រា, ហៃណាំ, ឥណ្ឌូចិន, ម៉ាតាបាន, តេណាសេរីម, ភូមា, សៀម និងកម្ពុជា ផងដែរ ។ គេឃើញមានពួកព័រទុយហ្គេធ្វើដំណើរទៅដល់ឈៀងម៉ៃថែមទៀត ។ គិតត្រឹមឆ្នាំ១៦០០ ពួកនេះត្រួតត្រាលើពាណិជ្ជកម្មទាំងអស់រវាងចុងបូព៌ាប្រទេសជាមួយអឺរ៉ុប ជាម្ចាស់លើទីក្រុងប្រកបទៅដោយរបង និងកម្លាំងការពាររឹងមាំ ចំនួន៣០ ដែលធ្វើឲ្យស្ដេចហិណ្ឌូ និងឥណ្ឌូណេស៊ី បាក់បបខ្លបខ្លាចជាខ្លាំង ធ្វើឲ្យគេក្លាយទៅជាមានអំណាចជាអ្នកមាន ហើយ

នាំយកភាពសម្បូរសប្បាយទៅឲ្យប្រទេសគេ ។

នៅពេលនោះ ចាប់ផ្ដើមមានការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មអឺរ៉ុបផ្សេងៗទៀតជាច្រើន គឺក្រុមហ៊ុនរបស់អង់គ្លេសនៅក្នុងឆ្នាំ១៦០១, ហុល្លង់ក្នុងឆ្នាំ១៦០២, បារាំងក្នុងឆ្នាំ១៦០៤, ដាណឺម៉ាកក្នុងឆ្នាំ១៦១២ និងមានពួកអឺរ៉ុបផ្សេងទៀត បានធ្វើដំណើរមកដល់ទឹកន្លែងណា ដែលពួកព័រទុយហ្គេបានមកដល់ និងទៅដល់ស្រុកខ្លះទៀត ដែលព័រទុយហ្គេមិនដែលទៅដល់ទៀតផង ។ យើងនឹងពិនិត្យមើលហេតុការណ៍នេះជាបន្តទៅទៀត នៅក្នុងសតវត្សរ៍ទី១៧ ។

# ជំពូកទី៣
# ពីការបែកបាក់បន្ទាយលង្វែកនៅក្នុងឆ្នាំ១៥៨៥ រហូតមកដល់សព្វថ្ងៃនេះ

## ១- ព្រះបាទរាមាជើងព្រៃ (១៥៩៤-១៥៩៥)

យើងបានឃើញរួចហើយពីខាងលើ ថាព្រះរាជាកម្ពុជា ព្រះបរមឥន្ទរាជា (ព្រះសត្ថា) បានភៀសព្រះអង្គចេញពីបន្ទាយលង្វែក តាំងតែពីមុនពេលដែលសៀមវាយលុកចូលមក ដោយទុកឲ្យព្រះឧភយោរាជ[១] ស្រីសុរិយោពណ៌ ដែលទើបវាយសៀមឈ្នះនៅអម្រិតបូរ (បរិបូណ៌) នៅការពាររាជធានី ។ ទ្រង់បានយាងជាមួយនឹងព្រះរាជវង្សទាំងអស់កាត់ទៅរកព្រះរាជបុត្រច្បង ព្រះជ័យជេដ្ឋា ដែលរងការគាបសង្កត់ពីទ័ពសៀមមកពីទិសខាងត្បូង ហើយបានវាយដកថយទៅកាន់ស្រីសឈរ[២] ជាមួយនឹងព្រះអនុជចៅពញាតន់ និងពួកអឺរ៉ុប២នាក់ផង ។

គង់នៅស្រីសឈរបានបន្តិច ព្រះរាជវង្សានុវង្សយល់ឃើញថា សុវត្ថិភាពនៅទីនេះមិនល្អ ក៏នាំគ្នាធ្វើដំណើរទៅស្ទឹងត្រែង[៣] ។ ទឹកន្លែងត្រង់នេះ ប្រហែលមិនមែនជាទឹកដីរបស់លាវទេមើលទៅនាសម័យនោះ ប៉ុន្តែក៏ប្រហែលជាគ្មានទំនាក់ទំនងអ្វីធំដុំជាមួយកម្ពុជាដែរ ព្រោះនៅឆ្ងាយ គឺនៅពីខាងជើងជួរសម្បុកសម្បូរ និងព្រះតាពាង (ប៉ាតាង) ទៅទៀត ម្យ៉ាងទៀត អ្នកស្រុកភាគច្រើនជាជនជាតិលាវផង[៤] ។

រាជពង្សាវតារបានលើកមូលហេតុផ្សេងចំពោះការធ្វើដំណើរទៅស្ទឹងត្រែងនេះ ដោយលើកឡើងថា

---

[១] ពាក្យនេះមានប្រភពចេញពីភាសាសំស្ក្រឹត ប្រើសម្រាប់សម្គាល់រាជវង្សដែលមិនអាចទទួលរាជសម្បត្តិបាន បើទោះបីជាព្រះរាជបុត្រា ឬនត្តា របស់ស្តេចគ្រងរាជ្យក៏ដោយ ។ និយាយឲ្យខ្លីគឺថា ឋានៈនេះគេប្រើសម្រាប់ធ្វើឲ្យរាជវង្សមួយអង្គឃ្លាតឆ្ងាយចេញពីរាជសម្បត្តិ ។

[២] ឈ្មោះនេះបានប្រែមកជាស្រីសន្ធរ តាំងពីយូរយារណាស់មកហើយ ហើយដែលពួកអេស្ប៉ាញ៉ុល និងព័រទុយហ្គេ ហៅថា ស៊ីស្ទរ ឬស៊ីស្ទ័រ នៅក្នុងសតវត្សរ៍ទី១៧ ។ គឺជារាជធានីរបស់កម្ពុជានាសម័យនោះ ហើយជាមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏សំខាន់មួយ មានប្រជាជន ៩ម៉ឺននាក់ ។ ពាក្យស៊ីស្ទ័រក្លាយមកពីស្រីសន្ធរ ហើយកាលពីពេលនោះគេមានស្រុក៣ គឺស៊ីធរឆ្វេង ស៊ីធរស្តាំ និងស៊ីធរកណ្តាល នៅខាងកើតខែត្រខ្សាច់កណ្តាល ។ ទីក្រុងនេះស្ថិតនៅខាងត្បូងបឹងស៊ីធរ ខាងកើតបឹងតាគង់ និងនៅខាងជើងព្រែកមួយដែលហូរកាត់ផ្លូវទៅល្វាឯម ដែលស្ថិតនៅចំពីមុខចតុមុខ ឬភ្នំពេញ ។ ចម្ងាយត្រង់ពីស៊ីធរ មកភ្នំពេញ គឺ៣០គីឡូម៉ែត្រ ។

[៣] ត្រង់នេះ គឺដូចដែលលោកកាបាតុងបានរៀបរាប់អ៊ីចឹង ព្រះរាជាមិនបានភៀសព្រះអង្គទៅរាជវាំងស្តេចលាវ គឺវៀងច័ន្ទ នោះទេ ។

[៤] ជនជាតិហុល្លង់ឈ្មោះហ្សេរ៉ារ៉ាន់វូស្ទូវ ដែលធ្វើដំណើរឡើងតាមទន្លេមេគង្គទៅដល់វៀងច័ន្ទនៅក្នុងឆ្នាំ១៦៤១-១៦៤២ បានរៀបរាប់ថា ព្រំដែនកម្ពុជាពេលនោះនៅខ្ពស់ណាស់ គឺរហូតដល់ចន្លោះខោន និងបាសាក់ ។

មានព្រះវង្សមួយអង្គព្រះនាមថាព្រះរាមាជើងព្រៃ[៥] មានបំណងដណ្តើមយកមហាក្សត្រីយ៍ព្រះភគវតីស្រីចក្រពត្តិ ជាព្រះជាយាទី១របស់ព្រះសត្ថា ធ្វើឲ្យស្តេចអង្គនេះភ័យបារម្ភចំពោះព្រះក្សត្រីយ៍ ក៏នាំគ្នារត់ភៀសព្រះកាយទៅស្ទឹងត្រែងទៅ ដើម្បីបានគេចផុតពីគោលបំណងអាក្រក់របស់ព្រះរាមាជើងព្រៃផង និងបានគេចផុតពីទ័ពសៀម ដែលធ្វើដំណើរមកដល់ទន្លេមេគង្គរួចទៅហើយផង ។

ពេលនោះ ព្រះទេវីក្សត្រីយ៍ ជាព្រះមាតុច្ឆារបស់ព្រះរាជា មិនបានយាងទៅតាមព្រះរាជាទេ តែបានភៀសព្រះកាយចេញពីស្រីសន្ធរទៅគង់នៅឯភ្នំពាមជាំង ជាមួយរាជបុត្រារបស់ព្រះសត្ថា គឺចៅពញាតន់ និងចៅពញាយោម[៦] ហើយនិងនាម៉ឺនដែលស្មោះត្រង់មួយចំនួន ។ ចំណែកឯឪយឺហ្គោបែឡូសូ និងមិត្តភក្តិរបស់គេវិញ ដែលទើបតែត្រលប់មកពីម៉ានីល ប្រហែលជាបានធ្វើដំណើរទៅតាមព្រះឧភយោរាជ និងព្រះរាជានៅឯស្ទឹង-ត្រែង ហើយទាល់តែដល់ពេលក្រោយយូរណាស់ គឺពេលដែលទ័ពឆ្នក់កម្ពុជាដែលមិនទាន់មានការរៀបរយត្រឹមត្រូវ បើកការវាយប្រហារទៅលើទ័ពសៀមដែលចង់ពង្រីកអំណាចមកទិសខាងកើត និងខាងត្បូង ទើបពួកនេះត្រលប់ចុះមកវិញដើម្បីចូលរួមជាមួយ ។ បេឡូសូ ត្រូវសៀមចាប់បាននៅក្នុងការប្រយុទ្ធមួយនៅក្នុងឆ្នាំ ១៥៩៤ ។ ចំណែកឯប្លាវូហ៊្ស, អង់តូនីញ៉ូម៉ាសាដូ និងប៉ង់តាលេអុងការណៃរ៉ូ ត្រូវចាប់ខ្លួនបានពេលក្រោយបន្តិចនៅក្នុងការប្រយុទ្ធតាមនាវា ។

ព្រះឧភយោរាជព្រះសត្ថា និងព្រះរាជាជ័យជេដ្ឋា បានសុគតនៅក្នុងឆ្នាំ១៥៩៤ នៅឯស្ទឹងត្រែង ព្រះសត្ថាពេលនោះ មានព្រះជន្មាយុ៤១ព្រះវស្សា ទ្រង់បានសោយរាជ្យប្តីដឹកនាំប្រទេសបាន១៧ឆ្នាំ ឯព្រះជ័យជេដ្ឋាមានព្រះជន្មាយុ ៣០ ព្រះវស្សា ទ្រង់បានសោយរាជ្យ ក៏ប៉ុន្តែមិនបានដឹកនាំប្រទេសទេអស់ពេល ១០ឆ្នាំ[៧] ។

[៥] ជើងព្រៃជាឈ្មោះខេត្តមួយរបស់កម្ពុជា ស្ថិតនៅលើច្រាំងខាងស្តាំរបស់ទន្លេមេគង្គ ចន្លោះខេត្តស្ទឹងត្រង់ និងខេត្តអន្លង់រាជ ។

[៦] ចៅពញាតន់ ទ្រង់ប្រសូត្រនៅក្នុងឆ្នាំ១៥៦៨ ឯចៅពញាយោម ដែលជាបុត្ររបស់ព្រះសត្ថា ជាមួយអ្នកម្នាងលាវមួយអង្គប្រសូត្រនៅក្នុងឆ្នាំ១៥៧៣ ។ ដូច្នេះពេលនោះ ពញាតន់ មានព្រះជន្ម ២៦ព្រះវស្សាហើយ ហើយពញាយោម មានព្រះជន្ម ២១ព្រះវស្សា ។ ក៏ប៉ុន្តែរាជពង្សាវតារ និងការនិទានតៗគ្នានិយាយថា ពញាតន់ ទើបតែមានព្រះជន្ម ១៦ព្រះវស្សាទេ ហើយពញាយោម មានព្រះជន្ម ១១ព្រះវស្សា ។

[៧] កន្លែងនេះមានការច្របូកច្របល់ជាខ្លាំង ប្រហែលដោយមកពីខ្ញុំគិតថាពត៌មានដែលបានពីឯកសារអេស្បាញ៉ុលផ្តល់ថ្ងៃខែ និងហេតុការណ៍ច្បាស់លាស់ជាង និងម្យ៉ាងទៀត ខ្ញុំកំណត់យកឆ្នាំ១៥៩៣ ជាឆ្នាំដែលសៀមដណ្តើមយករាជធានីលង្វែកបាន ។ រាជ-ពង្សាវតារបានកំណត់ថាព្រះសត្ថាទ្រង់ប្រសូត្រនៅក្នុងឆ្នាំ១៥៤៣ ហើយព្រះជ័យជេដ្ឋាប្រសូត្រ នៅក្នុងឆ្នាំ១៥៦៤ រួចហើយថាស្តេចទាំង២អង្គ បានសុគតទៅនៅស្ទឹងត្រែងក្នុងឆ្នាំ១៥៨៥ បានសេចក្តីថា នៅពេលដែលព្រះសត្ថា មានព្រះជន្មាយុ ៤២ព្រះវស្សា ហើយព្រះជ័យ ជេដ្ឋាមានព្រះជន្មាយុ២០ ព្រះវស្សា ។ ប៉ុន្តែបើយើងគិតថាសៀមវាយយកលង្វែកបាននៅឆ្នាំ១៥៩៣ ហើយស្តេចទាំង២អង្គ សុគតនៅក្នុងឆ្នាំ១៥៩៤ នោះស្តេចទាំង២នឹងត្រូវមាន ព្រះជន្មាយុ៥១ឆ្នាំ និង៣០ឆ្នាំ ។ ហើយរាជពង្សាវតារបានលើក

បើតាមការនិទានតៗគ្នានៅសម្បូរ ព្រះអដ្ឋិធាតុរបស់ស្តេចទាំង២អង្គ បានត្រូវគេនាំយកមកបញ្ចុះនៅក្នុងចេតិយមួយ នៅក្នុងបរិវេណវត្តសម្បូរ ។ សម្បូរពេលនោះ គឺជាទីក្រុងធំមួយ ។

ដោយពិនិត្យឃើញថានគរគ្មានស្តេច ហើយពញាតន់ក៏គ្មានសមត្ថភាពនឹងឈ្នោះដណ្តើមរាជសម្បត្តិបាន[៨] ព្រះវង្សារាមាជើងព្រៃដែលមានព្រះជន្ម៥០ព្រះវស្សាទៅហើយ បានចាប់ផ្តើមដណ្តើមយកអំណាច ។ ទ្រង់បានចាប់ផ្តើមរជ្ជកាលរបស់ព្រះអង្គដោយបង្ហាញឲ្យឃើញនូវភាពមោះមុតឥតខ្លាចស្លាប់ គឺទ្រង់បានកេណ្ឌទ័ពដោយស្ងាត់កំបាំង រួចវាយចូលរាជធានីភ្លាមគ្មានឲ្យនរណាដឹងទាន់ សម្លាប់ឧត្តមសេនីយ៍ក្យាមហាមន្ត្រីសៀម ដែលគ្រប់គ្រងនៅទីនោះជាមួយនឹងពលរេហ៍សៀម២ម៉ឺននាក់ ។ បន្ទាប់មក ប្រហែលដោយខ្លាចពួកសៀមវិលត្រលប់មកវិញ ណាមួយរាជធានីស្ថិតនៅជិតព្រំប្រទល់ខេត្របាត់ដំបង និងអង្គរ ជាទីដែលសៀម បានដាក់ទ័ពប្រមូលផ្តុំផងព្រះរាជាក៏យាងមកគង់នៅឯស្រីសន្ធរវិញ ហាក់បីដូចថាព្រះអង្គជាព្រះរាជាពេញសិទ្ធិ មានបរិពារហែហម និងសេវាបម្រើផ្សេងៗសម្រាប់ព្រះរាជវាំង ។

នៅពេលបានទទួលពត៌មានស្តីពីមរណភាពរបស់ស្តេចទាំងពីរអង្គដែលជាអ្នកគាំពាររបស់ខ្លួន បេឡូសូ ដែលនៅជាប់ក្នុងទីឃុំឃាំងរបស់សៀម មានការអស់សង្ឃឹមជាខ្លាំង ថានឹងលែងអាចវិលត្រលប់មកជាន់ដីកម្ពុជាវិញជារៀងរហូតហើយ ក៏យល់ព្រមបំពេញបេសកកម្មឲ្យស្តេចសៀម ដោយធ្វើដំណើរទៅហ្វីលីពីនស្នើសុំឲ្យអភិបាលក្រុងម៉ានីល ចងមេត្រីភាពរវាងអេស្ប៉ាញ និងស្រុកសៀម ។ ពេលទៅដល់ ម៉ានីល, បេឡូសូ បានជួបជាមួយ

បន្ថែមទៀតថាស្តេចឪពុកសោយរាជ្យបាន១៧ឆ្នាំ ស្តេចកូនសោយរាជ្យបាន១០ឆ្នាំ ។ ឃើញថាកាលបរិច្ឆេទ ដែលផ្តល់ឲ្យដោយរាជពង្សាវតារឆ្លើយគ្នាល្អណាស់ ហើយពត៌មានរបស់ឯកសារអេស្ប៉ាញ៉ុលមិនត្រឹមត្រូវទេ ។ បើដូច្នេះ តើយើងត្រូវទាត់ពត៌មានឯកសារអេស្ប៉ាញ៉ុលចោល ហើយនិយាយថា លោកឪពុក សង់អង់តូនីញ៉ូ ច្រឡំពេលវេលាដល់ទៅ១០ឆ្នាំឬ? ឬមួយក៏ថា កំហុសមកពីពួកអ្នកដែលចម្លងរាជពង្សាវតារទៅវិញទេ ដែលបានខិតខំកែសម្រួលកាលបរិច្ឆេទឲ្យសមស្របទៅតាមគ្នា ដើម្បីកុំឲ្យគេមើលទៅមិនត្រូវ? ខ្ញុំគិតថាសម្មតិកម្មក្រោយនេះ អាចនឹងចាត់ទុកថាមានពិតប្រាកដបាន ពីព្រោះថាចំពោះហេតុការណ៍ខ្លះ យើងជាជនជាតិអឺរ៉ុបមានការស្ទុះស្ទាញនឹងសម្រេច ខ្មែរមិនញញើតនឹងធ្វើការកែសម្រួលតម្រឹមទេ ដរាបណាគេគ្មានការទទួលខុសត្រូវផ្ទាល់ ឬមិនមានការដាក់ទណ្ឌកម្មជាក់ស្តែង គឺអ្នកដែលកែសម្រួលប្រវត្តិសាស្ត្រមិនដែលមានទោសទេនៅកម្ពុជា ។ បើទោះជាយ៉ាងណាក្តី យើងត្រូវរង់ចាំដល់ពេលដែលមានឯកសារផ្សេងៗទៀត ដើម្បីកាត់សេចក្តីលើរឿងនេះ ជាពិសេស ឯកសារមកពីម៉ានីល ដែលគេបានប្រកាសថា ជិតនឹងផ្សព្វផ្សាយហើយ ។

[៨] ចំណុចត្រង់នេះ បើសិនណាជាពញាតន់មានព្រះជន្ម២៦ព្រះវស្សាដូចដែលរាជពង្សាវតារបានលើកមែនពីព្រោះថាទ្រង់ប្រសូត្រនៅក្នុងឆ្នាំ១៥៦៨ ហើយលង្វែកត្រូវសៀម វាយយកបាននៅ១៥៩៣ រួចព្រះជ័យជេដ្ឋាសុគតនៅក្នុងឆ្នាំ១៥៩៤ ព្រះអង្គមានវ័យសមល្មមអាចនឹងទាមទារយកអំណាចពីស្តេចជ្រែករាជ្យបាន ដោយបង្កបក្សពួកមួយក្រុម ។ ក៏ប៉ុន្តែប្រហែលជាព្រះអង្គមាន ព្រះជន្មតែ១៦ព្រះវស្សាទេ ទើបបានជាមិនអាចកេណ្ឌគ្នាឲ្យគាំទ្រ ព្រោះនៅវ័យក្មេងពេក មិនទាន់អាចសម្រេចកិច្ចការធំៗបាន ។

មិត្តភក្តិរបស់គាត់ ដែលទើបតែទៅដល់ដែរ ក្រោយពីបានចាប់ពួកទាហានដែលស្តេចសៀមប្រគល់ភារកិច្ចឲ្យថែរក្សាពួកគេ បោះចូលទៅក្នុងទឹកសមុទ្រ ឬចងដាក់ច្រវាក់ ដោយមានការឃុបឃិតពីក្រុមអ្នកដើរសំពៅចិន រួចក៏បើកសំពៅរត់ទៅ ។ បេឡូសូក៏ចាប់ប្រែចិត្តវិញ មិនបានធ្វើកិច្ចការដើម្បីគាំទ្រឲ្យមានចំណងមេត្រីភាពជាមួយសៀមទេ តែបែរជាទៅសំណូមពរឲ្យជួយគាត់មកកម្ពុជាវិញ តែមិនមែនគាំទ្រព្រះរាមាជើងព្រៃដែលខ្លួនចាត់ទុកថា ជាស្តេចជ្រែករាជ្យ ហើយដែលប្រហែលជានឹងមិនស្វាគមន៍ខ្លួនផងនោះទេ តែគឺដើម្បីជួយដល់រជ្ជទាយាទរបស់ព្រះមហាក្សត្រដែលសុគតទៅនៅឯស្រីសន្ធរវិញ ។ ដោយមានការគាំទ្រពីពួកដូមីនីកាំង និងពួកអូហ្គូស្តាំង នៅម៉ានីល ដែលមានបំណងចង់ឲ្យអេស្ប៉ាញដណ្តើមយកកម្ពុជា ដើម្បីខ្លួនបានប្រែក្លាយប្រទេសនេះឲ្យកាន់សាសនាកាតូលិកវិញ រួចហើយពង្រីកឥទ្ធិពលរបស់ខ្លួន ។ ទីបំផុតបេឡូសូក៏និយាយបញ្ចុះបញ្ចូលលោកអភិបាលល៉ឺប៉េរ៉េ-ដាសម៉ារីញ៉ា ដែលជាកូនរបស់សពលោក ហ្គោមេប៉េរ៉េដាសម៉ារីញ៉ា បានសម្រេចដោយទទួលបានទ័ពអេស្ប៉ា-ញ៉ុល ១២០នាក់ និងកប៉ាល់ ៣គ្រឿង ស្ថិតនៅក្រោមបញ្ជារបស់អនុសេនីយ៍ឯក ជន និងដេវ៉ែរហ្គាលីណាតូ មានដើមកំណើតមកពីឡាសប៉ាល់ម៉ាស (កោះកាណារី) ហើយនិងពួកដូមីនីកាំង៣នាក់ ក្នុងនោះមានលោកឪពុកអាឡុងសូដឺមីណេ អាយុប្រហែល៧០ឆ្នាំ និងលោកឪពុក ឌីយ៉ឺហ្គោអាឌូអាត ដែលជាមនុស្សអង់អាចក្លាហានផងដែរ ។ កប៉ាល់ទាំង៣ ចេញដំណើរពីម៉ានីល នៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៥៩៦ ។ មានតែកប៉ាល់២ទេ ដែលបានធ្វើដំណើរមកដល់កម្ពុជា គឺកប៉ាល់ដែលបញ្ជាដោយបេឡូសូ និងប្លាសរូហ៊ុំ ចំណែកកប៉ាល់១ទៀត ដែលបញ្ជាដោយហ្គ្រេហ្គ័រដឺវ៉ាហ្គាស វង្វេងផ្លូវ ឬមកដល់ក្រោយក៏មិនដឹង ។

មកដល់កម្ពុជា បេឡូសូចតកប៉ាល់នៅបាភ្នំ (ខែត្របារាជ) ។ គឺនៅទីនោះឯង ដែល បេឡូសូ បានទទួលដំណឹងថា ព្រះរាមាជើងព្រៃដណ្តើមយករាជសម្បត្តិបាន ហើយយាងមកគង់នៅស៊ីស្ព័រ (ស្រីសន្ធរ) ។ បេឡូសូ គិតថា ត្រូវចុះចូលនឹងព្រះរាជាថ្មីនេះ ហើយបានបញ្ជូនពត៌មានស្តីពីការមកដល់របស់ខ្លួនទៅថ្វាយព្រះរាមាជើងព្រៃ ។ ដើម្បីលើកជើង បេឡូសូ ព្រះរាមាជើងព្រៃ បានបញ្ជូនទៅវិញនូវលិខិតតែងតាំង បេឡូសូ ជាអភិបាលខែត្រ និងលិខិតអនុញ្ញាតឲ្យ ប្លាសរូហ៊ុំ មានសិទ្ធិធ្វើដំណើរទៅទីណាក៏បាននៅក្នុងព្រះរាជាណាចក្រ រួចទ្រង់រង់ចាំស្តាប់ដំណឹងឆ្លើយតបពីមិត្តរបស់អតីតព្រះមហាក្សត្រទាំងព្រះទ័យព្រួយបារម្ភទៅវិញ ។ បេឡូសូ និងប្លាសរូហ៊ុំ បានធ្វើដំណើរឡើងតាមទន្លេមេគង្គ មកដល់ភ្នំពេញដែលកាលនោះគេហៅថាចតុមុខ ។ បើតាមឯកសាររបស់ពួកអេ-ស្ប៉ាញ៉ុល និងព័រទុយហ្គេ ថា ចតុមុខនាពេលនោះ ជាមជ្ឈមណ្ឌលពាណិជ្ជកម្មធំមួយ មានជនជាតិចិនរស់នៅចំនួន៣ពាន់នាក់ ។ ពេលនោះមានជម្លោះមួយបានផ្ទុះឡើងរវាងពួកចិននឹងពួកអឺរ៉ុប ។ ដោយមានការគាំទ្រពីពួកជប៉ុនដែលកាន់គ្រិស្តសាសនាចំនួន២០នាក់ ពួកអឺរ៉ុបបានបើកការវាយប្រហារទៅលើពួកចិន ហើយសម្លាប់ពួកនេះអស់៣រយនាក់ រួចរឹបអូសយកសំពៅចិនទាំងអស់ព្រមទាំងទំនិញផង ។ ច្រើនថ្ងៃក្រោយមក បេឡូសូ និងប្លាសរូហ៊ុំ បានបញ្ជូនសំណើទៅសុំចូលគាល់ព្រះរាជា មិនមែនដើម្បីរាយការណ៍ថ្វាយអំពីព្រឹត្តិការណ៍វាយប្រហារនោះទេ

តែគឺដើម្បីថ្វាយសត្វលាមួយក្បាល និងជំនូនមួយចំនួន ដែលអភិបាលក្រុងម៉ានីល បានបន្ទុកបន្ទាក់ឲ្យខ្លួននាំយកមកថ្វាយ ។ ប៉ុន្តែព្រះរាជាបានបដិសេធមិនព្រមទទួលទេ ដរាបណាពួកអឺរ៉ុបមិនទាន់ប្រគល់សំពៅ និងទំនិញទៅឲ្យពួកចិនវិញ ។

ឆ្លើយតបទៅនឹងព្រះរាជតរិយាបថនេះ បេឡូសូ និងប្លាសរូហ៍ស្ស បានសម្រេចចាត់ចែងសភាពការណ៍ឲ្យបានលឿន ។ គេនាំគ្នាធ្វើដំណើរចេញពីភ្នំពេញទៅកាន់ស្រីសន្ធរ ជាមួយនឹង ដូមីនីកាំងឌីយ៉ឺហ្គោអាឌូអាត និងកម្លាំងមោះមុតដាច់ខាតចំនួន៣៨នាក់[៩] ។ ចេញដំណើរពីក្បាលព្រលប់ ដើរចម្ងាយ៣០គីឡូម៉ែត្រ ពួកនេះបានមកដល់រាជធានីនៅប្រហែលជាម៉ោង២ទៀបភ្លឺ ហើយបានចាប់បើកការវាយប្រហារទៅលើព្រះរាជវាំងមុនថ្ងៃរះ ។ ព្រះរាមាជើងព្រៃ បានត្រូវពួកនេះធ្វើឃាត នៅពេលដែលទ្រង់កំពុងរៀបចំភៀសខ្លួនចេញជាមួយស្រីស្នំ និងសេនាការពារ ចំណែកឯពួកនាម៉ឺនសព្វមុខមន្ត្រី និងរាជបរិពារ ដែលមានតែលំពែង និងធ្នូស្នាជាអាវុធ បានត្រូវបាញ់សម្លាប់អស់ជាច្រើន (ព្រឹត្តិការណ៍នេះកើតឡើងនៅក្នុងខែឧសភា ឆ្នាំ១៥៩៦)[១០] ។ ប្រតិបត្តិការនេះ ទទួលបានជោគជ័យទាំងស្រុង ក៏ប៉ុន្តែពួកអ្នកផ្សងព្រេងបានត្រូវអ្នកស្រុកចោមរោមវាយបកវិញ ក្រោយពីបានពិនិត្យឃើញថាពួកនេះមានចំនួនតិចជាង ដោយបង្ខំឲ្យពួកគេដកថយមកកាន់ភ្នំពេញវិញទាំងលំបាក ជាទីដែលគេចតកប៉ាល់ទុក ។ បើកុំតែមេទ័ពខ្មែរត្រូវរបួសដោយលំពែងធ្លាយពោះស្លាប់ កុំអីពួកនេះពិបាកនឹងគេចខ្លួនរួចណាស់ ។ គាប់ជួនពេលនោះ ហ្គាលីណាតូ និងពលទាហានរបស់គេ បានធ្វើដំណើរពីបារាជមកដល់ល្វែម ធ្វើឲ្យសភាពការណ៍នៅភ្នំពេញល្អប្រសើរឡើងវិញ ។ ក៏ប៉ុន្តែមិនបានប៉ុន្មានថ្ងៃផង ក្រោយពីបានបើកការប្រជុំក្រុមប្រឹក្សាសង្គ្រាមមួយរួចមក ហើយពិនិត្យឃើញថា ពួកខ្មែរអាចនឹងបើកការប្រយុទ្ធបកម្តងទៀតធ្វើឲ្យមានការលំបាកក្នុងការទប់ទល់ ហ្គាលីណាតូ បានសម្រេចលើកយុថ្កាបើកកប៉ាល់ចេញពីភ្នំពេញ ចុះតាមទន្លេមេគង្គ ធ្វើដំណើរទៅកាន់តុងកឹងវិញ ក្នុងគោលបំណងទៅទាមទារយកកប៉ាល់មួយគ្រឿង ដែលពួកចិនបាននាំយកទៅ ក្រោយពីបានធ្វើឃាតលោកអភិបាលក្រុងម៉ានីល និងក្រុមនាវិក រួចមក ។ ទៅដល់តុងកឹង បែឡូសូ និងប្លារូហ៍ស្ស ដែលនៅតែមានគំនិតមិនចង់បោះបង់គម្រោងការរបស់ខ្លួននៅកម្ពុជានោះ បាននាំគ្នាដើរបែកចេញពីជនរួមជាតិគេ ឆ្លងកាត់ជួរភ្នំអាណ្ណាម ស្រុករបស់អ្នកព្រៃខា ចូលមកស្រុកលាវ រួចត្រលប់មកកម្ពុជាវិញ ។ មកដល់ស្ទឹងត្រែងពួកគេបានបញ្ចុះបញ្ចូលអ្នកអង្គម្ចាស់តន់ថាឱកាសដណ្តើមយករាជសម្បត្តិមកដល់ហើយ ហើយយាងព្រះអង្គឲ្យធ្វើដំណើរមកជាមួយ

---

[៩] រាជពង្សាវតារនិយាយថាតែ១០នាក់ទេ ។

[១០] រាជពង្សាវតារបានអះអាងថា ព្រះរាមាជើងព្រៃ បានចេញបញ្ជាឲ្យកាប់សម្លាប់ពួកអឺរ៉ុបមុន ជាហេតុធ្វើឲ្យពួកនេះបើកការវាយប្រហារមុនពេលអនុវត្តព្រះរាជបញ្ជា ។ ប៉ុន្តែកំណត់ត្រាមួយជាភាសាអេស្ប៉ាញ៉ុលដែលលោកកាបាតុងទើបតែរកឃើញ មិនបាននិយាយដូច្នេះទេ ។

គេ ។ ពេលធ្វើដំណើរមកដល់ស្រីសន្ធរ ពួកនាម៉ឺនសព្វមុខមន្ត្រីដែលកំពុងតែនឿយណាយនឹងអនាធិបតេយ្យ បណ្តាលមកពីមរណភាពរបស់ព្រះរាមាជើងព្រៃផង ពីព្រោះថាកម្ពុជាពេលនោះ មិនមែនគ្រាន់តែគ្មានស្តេចសោយរាជ្យប៉ុណ្ណោះទេ គឺខ្វះទាំងអ្នកឡើងស្នងរាជ្យបន្តថែមទៀត ក៏សម្រេចនាំគ្នាលើកចៅពញាតន់ ឲ្យឡើងគ្រងរាជបល្ល័ង្ក នៅថ្ងៃទី១៤ ខែខសភា ឆ្នាំ១៥៩៦ ទៅ ។

## ២- ព្រះបរមរាជា ឬ ចៅពញាតន់ (១៥៩៦-១៥៩៧)

ចៅពញាតន់ពេលនោះមានព្រះជន្មាយុ ១៨ព្រះវស្សា[១១] ។ នាម៉ឺនសព្វមុខមន្ត្រីបានជ្រើសតាំងព្រះអង្គ ជាមហាក្សត្រនៅថ្ងៃទី១៤ ខែខសភា ឆ្នាំ១៥៩៦ ដោយថ្វាយព្រះនាមថាសម្តេចព្រះបរមរាជា ។

ក្រោយពីបានឡើងសោយរាជ្យ ព្រះបរមរាជា បានសព្វព្រះរាជហឫទ័យតបស្នងសងគុណដល់ បែឡូសូ និងថ្វារូហ័្ស ភ្លាម ដោយទ្រង់លើកអ្នកទី១ឲ្យធ្វើជាស្តេចត្រាញ់នៅលើដីបាភ្នំ និងអ្នកទី២ឲ្យធ្វើជាស្តេចត្រាញ់នៅលើដីទ្រាំង ។ តាមមើលទៅ ប្រជាជនប្រហែលជាមិនសូវពេញចិត្តប៉ុន្មានទេ នឹងការតែងតាំង ពួកអ្នកផ្សងព្រេងទាំង២ ឲ្យក្លាយទៅជាអភិបាលខេត្រដ៏មានអំណាចនៅក្នុងព្រះរាជាណាចក្រនេះហើយមានមន្ត្រីជាច្រើននាក់ដែលមិនសប្បាយចិត្ត ។ ដោយហេតុនេះ ព្រះរាជាដែលគង់នៅក្រោមស្វេតច្ឆត្រ មិនសូវជាស្រួលប៉ុន្មានទេ ។ បែឡូសូ និងថ្វារូហ័្ស យល់ហេតុការណ៍នេះច្បាស់ណាស់ ក៏តាំងស្វះស្វែងរកជំនួយពីខាងក្រៅ ។ បែឡូសូ បានសុំជំនួយពីពួកព័រទុយហ្គេ នៅម៉ាឡាកា ឯថ្វារូហ័្ស ទៅសុំជំនួយពីពួកអេស្បាញ៉ុលនៅឯហ្វីលីពីន ។ អភិបាល ក្រុងម៉ានីលបានប្រគល់ទាហាន ២០០នាក់ ឲ្យជិះកប៉ាល់៣គ្រឿងចេញមក ក៏ប៉ុន្តែគ្មានកប៉ាល់ណាមួយបានមកដល់កម្ពុជាទេ ហើយមានតែកប៉ាល់១ប៉ុណ្ណោះដែលបានត្រលប់ទៅដល់ហ្វីលីពីនវិញ ។ ដូច្នេះ បែឡូសូ និងថ្វារូហ័្ស មិនអាចពឹងផ្អែកអ្នកណាបានក្រៅតែពីពឹងលើខ្លួនឯងឡើយ ។

នៅពេលនោះ ពួកចាម និងម៉ាឡេ ដែលព្រះរាជាខ្មែរមុនៗអនុញ្ញាតឲ្យរស់នៅប្រមូលផ្តុំគ្នានៅក្នុងខេត្រត្បូងឃ្មុំ បើទោះបីថាពួកនេះជាជនបរទេសហើយកាន់សាសនាមហាម៉ាត់ក៏ដោយ បាននាំគ្នាបះបោរឡើង ។ ពួកនេះបានពិនិត្យមើលឃើញថាព្រះរាជាណាចក្រចុះទន់ខ្សោយ ក៏មានបំណងចង់កាន់អាវុធឡើងទាមទារឯករាជ្យក្រោមការដឹកនាំរបស់មេ២នាក់ គឺចាមឈ្មោះ ពោធិរតន៍ ដែលប្រហែលជាជាប់ខ្សែស្រឡាយនឹងរាជវង្សចាមពី

[១១] បើសិនជាគេគិតថា ព្រះអង្គប្រសូត្រនៅក្នុងឆ្នាំ១៥៦៨នោះ ព្រះអង្គមានព្រះជន្ម២៨ព្រះវស្សា ក៏ប៉ុន្តែលោក កាបាតុង និយាយថាព្រះអង្គមានព្រះជន្ម១៨ព្រះវស្សានេះ ឯងមិនដឹងថាលោកផ្អែកទៅលើឯកសារអេស្បាញ៉ុល ឬក៏ឯកសាររាជពង្សាវតារខ្មែរ?

មុន និងជនម៉ាឡេឈ្មោះ ល័ក្សណៈ[១២] ដែលពង្រត់ម្ចាស់ក្សត្រី១អង្គ ដែលខ្លួនធ្លាប់ស្រឡាញ់ ប្រហែលជាក្សត្រីយ៍ដែលធ្លាប់រៀបអាពាហ៍ពិពាហ៍ជាមួយ បែឡូសូ ហើយទ្រង់មានគំនុំស្អប់ពួកអឺរ៉ុប ជំរុញឲ្យល័ក្សណៈធ្វើការសងសឹកថា ៗ បែឡូសូ និងប្លាវូហ៍្ស បានកេណ្ឌទ័ពនៅក្នុងអាណាខែត្រទឹកដីរបស់ខ្លួន រួចចេញច្បាំងវាយកម្ទេចពួកចាម និងម៉ាឡេ បះបោរបរាជ័យអស់ទៅ ។ ពេលមកដល់រាជធានីស្រីសន្ធរ ព្រះបរមរាជាចៅពញាតន់ បានចាត់ឲ្យអ្នកទាំង២បន្តដំណើរទៅកាន់ភ្នំពេញ ដើម្បីជួយរៀបចំសណ្ដាប់ធ្នាប់ ដែលល្អក់កករដោយជម្លោះរវាងពួកជប៉ុន និងអេស្ប៉ាញ៉ុល ២កប៉ាល់ ដែលទើបតែមកដល់ ដោយដឹកអាវុធយុទ្ធភណ្ឌមកផ្គត់ផ្គង់កប៉ាល់ ៣មុន ដែលនៅម៉ានីល គេមិនដឹងថាបាត់ដំណឹងទៅហើយទេ ។ ក៏ប៉ុន្តែ បែឡូសូ និងប្លាវូហ៍្ស មកដល់យឺតពេល ពួកជប៉ុនបានសម្លាប់ពួកអេស្ប៉ាញ៉ុលអស់ជាច្រើន ។ បន្ទាប់មក ពួកជប៉ុនបានរួមដៃជាមួយនឹងពួកម៉ាឡេ ព្រួតគ្នាវាយមកលើទ័ពដ៏តិចតួចរបស់ បែឡូសូ និងប្លាវូហ៍្ស ហើយសម្លាប់អ្នកទាំង២បាន ក្រោយពីការប្រយុទ្ធដ៏អង់អាចក្លាហានរួចមក ។

ព្រះបរមរាជាចៅពញាតន់ ក្រោយពីបានជ្រាបពីដំណឹងនេះ បានបញ្ជាទ័ពផ្ទាល់ខ្លួនព្រះអង្គចេញពីស្រីសន្ធរមកវាយពួកម៉ាឡេដែលស្ថិតនៅក្រោមបញ្ជាការរបស់ល័ក្សណៈ និងពួកចាមដែលស្ដាប់តាមបញ្ជារបស់ពោធិរតន៍ ។ ក៏ប៉ុន្តែដោយវាសនាអាក្រក់ ព្រះរាជាត្រូវបានសត្រូវធ្វើឃាតនៅក្នុងការប្រយុទ្ធដំបូង នៅក្នុងឆ្នាំ១៥៩៧ទៅ[១៣] ។

## ៣- ព្រះបរមរាជាទី២ ឬ ពញាអន (១៥៩៧-១៥៩៩)

ព្រះរាជាដែលនាម៉ឺនសព្វមុខមន្ត្រី និងព្រះរាជវង្សានុវង្ស បានជ្រើសរើសឲ្យឡើងសោយរាជ្យបន្តពីចៅពញាតន់ គឺព្រះបិតុលារបស់ព្រះអង្គមួយអង្គ ព្រះនាមថា ពញាអន ។ ទ្រង់មានព្រះអភិសេកនាមថា សម្ដេចព្រះបរមរាជាបរមបពិត្រ ។

និយាយអំពីពួកចាម និងម៉ាឡេវិញ ក្រោយពីទទួលជ័យជម្នះលើចៅពញាតន់រួចហើយ បានដណ្ដើមយកខែត្រ២ដាក់ជាចំណុះ ហើយក៏តាំងរៀបចំការគ្រប់គ្រងឡើងវិញសាជាថ្មី ។ ក៏ប៉ុន្តែពួកអ្នកស្រុកមិនព្រមស្ដាប់បញ្ជាពួកនេះទេ ព្រោះថាជាជនបរទេសមិនចេះនិយាយខ្មែរ ម្ល៉ោះហើយម្នាក់ៗគ្មាននរណាចង់ធ្វើជាមន្ត្រី ឬក៏ជាទាហានបម្រើឡើយ ។ ទោះជាយ៉ាងណាក្ដី ពួកនេះនៅតែអាចជ្រើសរើសទ័ពបានពីក្នុងចំណោមពួកចាម និងម៉ាឡេ មកពីគ្រប់ទិសទីក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងចង់មកជួយពួកអ្នកកាន់សាសនាដូចគ្នាដែរ ។

---

[១២] ពាក្យនេះក្នុងភាសាម៉ាឡេ គឺជាឋានៈរបស់ឧត្ដមនាវី ។ ជននេះមានដើមកំណើតនៅឯ ហ្សូហ៍រ ។
[១៣] បើតាមរាជពង្សាវតារដែលខ្ញុំមាន ទ្រង់បានត្រូវចាមម្នាក់ធ្វើឃាត ។

ប៉ុន្តែស្ថានភាពរបស់ពួកនេះបានស្រុតចុះជារៀងរាល់ថ្ងៃ ។

ព្រះរាជាដែលទើបនឹងឡើងសោយរាជ្យថ្មី បានបើកការវាយប្រហារមកលើពួកនេះយ៉ាងអង់អាចក្លាហាន នៅលើសមរភូមិជាច្រើន ។ នៅទីបញ្ចប់ ទ្រង់ទទួលបាននូវជ័យជម្នះ ។ មេកោយរបស់ពួកនេះត្រូវចាប់បាន ហើយសម្លាប់ចោលជាមួយនឹងកូនចៅបះបោរមួយចំនួន ចំណែកអ្នកដែលដោយរោយតាមគេបានត្រូវលើកលែងទោស ។

ការបះបោររបស់ពួកបរទេសទើបតែស្ងប់បាត់ទៅមិនទាន់ទាំងបានប៉ុន្មានផង ក៏លេចមានការបះបោរមួយទៀត ដឹកនាំដោយអ្នកស្រុកអាយម្នាក់ឈ្មោះថា នាយកែវ មានដើមកំណើតចេញមកពីខែត្រតាកែវ នៅក្បែរ ចតុម្មុខ (ភ្នំពេញ) ដែលបានប្រកាសខ្លួនថាជាស្តេចកែវព្រះភ្លើង ។ ជននេះជាមនុស្សចេះដឹងម្នាក់ ហើយអាចកៀងគរគេឯងឲ្យចុះចូលដើរតាម បន្តបានជាទ័ពមួយកង ។ ព្រះរាជាពញាអន បានដឹកនាំទ័ពមកវាយស្តេចកែវព្រះភ្លើងនេះ ២ដង ក៏ប៉ុន្តែមិនអាចធ្វើអ្វីបាន ។

ក្រោយពីប្រតិបត្តិការលើកទី២ ព្រះរាជាដែលមានចរិតច្រឡើសបើសបន្តិចដែរ បានជួបនឹងនារីម្នាក់ឈ្មោះ ទាវ នៅពេលទ្រង់យាងវិលត្រលប់ទៅស្រីសន្ធរវិញ ក៏ចាប់ចិត្តស្រលាញ់ចង់បាននាងមកធ្វើជាស្នំ ។ ប៉ុន្តែនាងទាវ ដែលស្ម័គ្រស្មោះជាមួយ ពញាថី ជាស្វាមី បានប្រកែកមិនយល់ព្រមស្រលាញ់ព្រះអង្គវិញទេ ជាហេតុធ្វើឲ្យព្រះរាជាខ្វាល់ ហើយបញ្ជាឲ្យគេចាប់នាងចងដាក់ច្រវាក់ ។ ហេតុការណ៍នេះបានធ្វើឲ្យ ពញាថី ខឹងសម្បានឹងព្រះរាជាជាខ្លាំង ក៏រត់មកចុះចូលជាមួយស្តេចកែវព្រះភ្លើង ហើយរៀបផែនការធ្វើគុតព្រះរាជា ប៉ុន្មានខែក្រោយមក នៅក្នុងការស្កាត់លួចវាយប្រហារមួយ ក្នុង១៥៩៨ ។

នាសម័យនោះ មានពួកអឺរ៉ុបជាច្រើននាក់ ជាពិសេសគឺពួកព័រទុយហ្គេ និងអេស្ប៉ាញ៉ុល សុទ្ធតែមានឥទ្ធិពលជាខ្លាំងមកលើរាជវាំងកម្ពុជា ។ ពួកនេះមានរបររកស៊ីរីកចម្រើនល្អណាស់ បង្កើតបានជាការរំខានដល់ពួក ចិន,ចាម និងម៉ាឡេ ដែលរកស៊ីធ្វើពាណិជ្ជកម្មដែរ ម្ល៉ោះហើយ ក៏នាំគ្នាខិតខំធ្វើយ៉ាងណាឲ្យពួកនេះធ្លាក់ចូលក្នុងភាពអាប់យស ។ ក្រោយពីមរណភាពរបស់ បែឡូសូ និងប្លាវូហ្ស៍ នៅក្នុងឆ្នាំ១៥៩៧រួចមក ឥទ្ធិពលរបស់ពួកព័រទុយហ្គេ និងអេស្ប៉ាញ៉ុលក៏ធ្លាក់ចុះ ហើយពួកនេះត្រូវបង្ខំចិត្តចាកចេញពីកម្ពុជា វិលត្រលប់ទៅហ្វីលីពីនវិញ ។

ប៉ុន្តែការបណ្តេញកាត់កាលនេះមិនមានអាយុកាលយូរប៉ុន្មានទេ ពីព្រោះថា ប៉ុន្មានឆ្នាំក្រោយនោះបន្តិច គេប្រទះឃើញពួកសេស៊ុីត និងកាតូលិកនិកាយផ្សេងៗទៀតជាច្រើននៅកម្ពុជា រួចមាននិគមព័រទុយហ្គេមួយ ដែលបានគេចចេញផុតពីការសម្លាប់រង្គាលរបស់ពួកម៉ាកាសា តាមការអុចអាលពីពួកហុល្លង់ ដែលជាសត្រូវរបស់ពួកគេពួកព័រទុយហ្គេនេះ និងបព្វជិតសាសនាកាតូលិករបស់គេបានមកតាំងទីលំនៅមុនដំបូងនៅភ្នំពេញ ដែលគេហៅថាកូលំប៉េ រួចបន្ទាប់មកបានទៅតាំងទីលំនៅ នៅឯពញាឮ ដែលគេហៅថា ពីញ៉ាលូ ។ មានពួកជប៉ុនមួយចំនួន ដែលត្រូវគេធ្វើបាបនៅឯប្រទេសជប៉ុនដោយសារការកាន់សាសនាកាតូលិក បានមកចូលរួមជាមួយពួកព័រទុយហ្គេនេះដែរ

ហើយបានមកតាំងនៅលើដងទន្លេក្បែរភ្នំពេញ ត្រង់កន្លែងមួយដែលពួកអឺរ៉ុបហៅតាមឈ្មោះរបស់គេថា ចូវដុក ។

## ៤- ព្រះរាជានុសិទ្ធិ ចៅពញាយោម (១៥៩៩-១៦០០)

ព្រះអង្គម្ចាស់យោម ជាព្រះរាជបុត្រាទីពីររបស់ព្រះសត្ថា ពេលនោះទើបតែមានព្រះជន្មាយុ ១៥ ព្រះវស្សាប៉ុណ្ណោះ[១៤] ។ ទ្រង់ត្រូវទទួលបន្ទុកដឹកនាំគ្រប់គ្រងប្រទេសជាតិ ដោយទទួលព្រះឋានៈជាសម្តេចព្រះកែវហ៊្វា[១៥] គឺថា ទ្រង់មានអំណាចដូចជាព្រះរាជា ក៏ប៉ុន្តែមិនមែនជាស្តេចទេ ។ ពេលនោះនាម៉ឺនសព្វមុខមន្ត្រី មិនចង់លើកចៅពញាយោម ឲ្យឡើងសោយរាជ្យទេ គេស្រលាញ់ព្រះស្រីសុរិយោពណ៌ជាង ដែលព្រះបរមឥន្ទរាជា (ព្រះសត្ថា) បានលើកឲ្យធ្វើជាឧបរាជ រួចជាឧភយោរាជ ហើយត្រូវសៀមចាប់យកទៅជាឈ្លើយ តាំងតែពីពេលក្រុងលង្វែកត្រូវបែកបាក់ម៉្លេះ ។

ចៅពញាយោម ក្នុងព្រះឋានៈជាព្រះរាជានុសិទ្ធិ ទ្រង់គង់នៅឯរាជធានីស្រីសន្ធរ ហើយបានចាប់បន្តធ្វើសង្គ្រាមជាមួយស្តេចកែវព្រះភ្លើង ។ ទីបញ្ចប់ទ្រង់ចាប់ស្តេចកែវព្រះភ្លើងបាន ហើយបានបញ្ជាឲ្យគេសម្លាប់ចោលទៅ ។

ចៅពញាយោមមានព្រះទ័យស្រាល ហើយក៏ខិលខូចមិនចាញ់ពញាអនប៉ុន្មានដែរ ។ ទ្រង់សព្វព្រះទ័យនឹងការបរបាញ់សត្វ និងការសប្បាយផ្សេងៗណាស់ ហើយមិនខ្វាចនឹងចាប់ប្រពន្ធ ឬកូនក្រមុំប្រជាជនទេ កាលណាទ្រង់សព្វព្រះទ័យ ហើយមិនសូវយកព្រះទ័យទុកដាក់នឹងកិច្ចការព្រះនគរឡើយ ។ ម៉្លោះហើយក៏កើតមានអំពើឧក្រិដ្ឋពាសពេញប្រទេស បណ្តាចៅហ្វាយខែត្រក៏មិនបានយកចិត្តទុកដាក់ ហើយក៏មិនដែលទទួលទោសពៃរ៍អ្វីដែរ ។ មានការចាប់ពង្រត់អ្នកស្រុកដែលនៅឆ្ងាយពីទីប្រជុំជនយកពីកន្លែងមួយទៅលក់ជាខ្ញុំ នៅកន្លែងមួយទៀត គឺលក់ទៅវិញទៅមកចុះឡើងជាច្រើនលើកច្រើនសា ។

សម្តេចព្រះទេវីក្សត្រីយ៍ ជាព្រះអយ្យការបស់ចៅពញាយោមដែលគង់នៅឯចតុម្មុខ និងនាម៉ឺនសព្វមុខមន្ត្រីទាំងអស់ នៅពេលដែលសង្កេតឃើញថាប្រជារាស្ត្ររងទុក្ខខ្លោចផ្សាហើយមិនសប្បាយចិត្តនឹង ចៅពញាយោមដូច្នេះ ក៏បានចាត់គ្នាឲ្យទៅគាល់ស្តេចសៀម សុំឲ្យបញ្ជូនព្រះឧភយារាជស្រីសុរិយោពណ៌[១៦] និងព្រះរាជ

[១៤] បើគេឯកភាពគ្នាថារាជធានីលង្វែកបែកបាក់នៅក្នុងឆ្នាំ១៥៩៣ ហើយពញាយោម ប្រសូត្រនៅក្នុងឆ្នាំ១៥៧២ នោះ ព្រះអង្គត្រូវមានព្រះជន្ម ២៥ ព្រះវស្សាហើយ ។

[១៥] ពាក្យ "កែវហ៊្វា" ក្នុងភាសាភូមា គឺជាឋានៈជាព្រះរាជា ។

[១៦] តើពាក្យ "ពណ៌" ក្លាយមកពី "វង្ស" ឬយ៉ាងណា? រាជពង្សាវតារនិយាយថាទ្រង់ប្រសូត្រនៅក្នុងឆ្នាំ១៥៤៨ តែបើសិនជាក្នុងមូលហេតុដូចដែលបានរៀបរាប់ខាងលើ គេត្រូវគិតថា ១៥៥៨វិញ ។

បុត្រទាំងអស់មកវិញ ។

ស្តេចសៀមពេលនោះ បានទទួលយកសំណូមពរតែមួយចំណែកទេ គឺបានអនុញ្ញាតឲ្យវិលត្រលប់មកកម្ពុជាវិញតែព្រះស្រីសុរិយោពណ៌ និងព្រះរាជបុត្រាប្អូនព្រះនាមព្រះឧទ័យប៉ុណ្ណោះ ចំណែកឯព្រះជ័យចេស្តាជាព្រះរាជបុត្រាច្បង ទុកឲ្យនៅនឹងស្រុកសៀមសិន ។

ព្រះរាជានុសិទ្ធិពញាយោម នៅពេលដែលបានទទួលដំណឹងថា ព្រះស្រីសុរិយោពណ៌ យាងមកដល់ ស្លាកែត[១៧] ហើយ ទ្រង់បានទប់ព្រះទ័យមិនឲ្យមានរឱសហ៊ានអ្វីទេ ហើយបាននាំនាម៉ឺនសព្វមុខមន្ត្រីជាច្រើនទៅគាល់រួចបានបង្វែរអំណាចជាផ្លូវការថ្វាយនៅក្នុងឆ្នាំ១៦០០ ។

## ៥- ព្រះស្រីសុរិយោពណ៌ (១៦០០-១៦១៨)

ព្រះឧបយុវរាជ បានឡើងគង់លើរាជបល្ល័ង្កនៅក្នុងឆ្នាំ១៦០០ ដោយទទួលព្រះនាមថា ព្រះបាទសម្តេចស្តេចព្រះរាជឱង្ការព្រះស្រីសុរិយោពណ៌ទេវតារាជាបរមរាជាធិរាជរាមា ។ ពេលនោះទ្រង់មានព្រះជន្មា ៤៦ព្រះវស្សាហើយ ។ មហេសីរបស់ព្រះអង្គបានឡើងទៅជាព្រះអគ្គមហេសី ហើយមានព្រះឋានៈជាសម្តេចព្រះភគវតីស្រីសុជាតិ ។ ព្រះឧទ័យជាព្រះរាជបុត្រា ដែលទើបតែមានព្រះជន្មាយុ១៣ព្រះវស្សា បានឡើងជាព្រះមហាឧបរាជ រីឯព្រះរាជានុសិទ្ធិចៅពញាយោម នៅរក្សាព្រះឋានៈជា ព្រះកែវហ្វ៊ា ដដែល ។

ចៅពញាយោមបានសំដែងឲ្យឃើញតាមរយៈការនាំនាម៉ឺនសព្វមុខមន្ត្រី ទៅចូលគាល់ព្រះឧបយុវរាជនៅឯស្លាកែតថា ព្រះអង្គស្វាគមន៍អបអរការយាងមកដល់របស់ព្រះរាជា ដែលព្រះអយ្យកាព្រះអង្គបានជ្រើសរើសឡើង តែក្នុងព្រះទ័យរបស់រាជានុសិទ្ធិ វិញ បានសន្សំទុកនូវគម្រោងការដ៏សែនខក្រិដ្ឋជាច្រើន ។

បន្ទាប់ពីបានឡើងសោយរាជសម្បត្តិភ្លាម ព្រះរាជាស្រីសុរិយោពណ៌បានចាត់ឲ្យឧកញ៉ាតេជោព្រះអង្គដែលអ្នកស្រុកហៅថាតេជោក្រហម-ក ហើយនិងឧកញ៉ាយមរាជមឿង ដឹកនាំទ័ពទៅបង្ក្រាបអ្នកស្រុកកំពង់ស្វាយ ស្រីសន្ធរ នគរវត្ត ត្បូងឃ្មុំ និងបាភ្នំ ដែលកន្លងមកបះបោរមិនព្រមទទួលស្គាល់អំណាចរបស់ព្រះកែវហ្វ៊ា ។ យុទ្ធនាការនេះមិនជាយូរប៉ុន្មានទេ ពីព្រោះខែត្រទាំងអស់នោះ មិនបានប្រឆាំងទប់ទល់នឹងទ័ពរបស់ព្រះរាជាឡើយ ហើយឆាប់នាំគ្នាមកសារភាពចុះចូលជាបន្ទាន់ ។

ក្រោយមកទៀត តេជោព្រះអង្គ បានទទួលព្រះរាជបញ្ជាឲ្យទៅបង្ក្រាបជនបះបោរម្នាក់ឈ្មោះថា អ្នកព្រះរៀម ហៅ កូម៉ែល ដែលកំពុងតែកទ័ពនៅក្នុងខែត្រទ្រាំងប្រកបដោយជោគជ័យ ។ គេនិយាយថា ជននេះបានប្រើប្រាស់សីលធ្មប់បំពុលទឹកត្រពាំង និងទឹកអណ្តូងទាំងអស់ដែលស្ថិតនៅតាមផ្លូវដែលទ័ពព្រះរាជាធ្វើដំណើរទៅ

[១៧] នៅជិតកំពត លើផ្លូវពីកំពង់ក្នុងទៅកំពង់ត្រាច ត្រង់កន្លែងដែលពួកវៀតណាមកសាងប៉មមួយនៅក្នុងឆ្នាំ១៨៤០ ។

ធ្វើឲ្យទាហានពុលស្លាប់អស់ជាច្រើន ។

ពេលនោះស្តេចសៀម បានយល់ព្រមបញ្ជូនព្រះជ័យចេស្តា ឲ្យវិលត្រលប់មកកម្ពុជាវិញ តាមសំណូមពររបស់ព្រះរាជាកម្ពុជាជាព្រះបិតា ។ ក្នុងព្រះរាជដំណើរយាងត្រលប់មកវិញនេះ ព្រះជ័យចេស្តាបានបង្ក្រាបធ្វើឲ្យបណ្តាខេត្រដែលនៅតាមផ្លូវមានសន្តិភាពឡើងវិញ មានខេត្រនាងរង បាត់ដំបង ពោធិសាត់ កំពត រហូតដល់កោះស្លាកែត រួចទ្រង់យាងកាត់ទៅជួបជាមួយតេជោព្រះអង្គដែលទើបតែដាក់គាំងទ័ពនៅពីមុខបន្ទាយខ្មាំង នៅទ្រាំង ។ ក្រោយពីបានជួបជាមួយកងទ័ព ហើយទទួលពត៌មានអំពីយុទ្ធសាស្ត្របំពុលទឹករបស់ កូម៉ែល ព្រះជ័យចេស្តា បានចេញបញ្ជាហាមមិនឲ្យទាហានផឹកទឹកត្រពាំងដែលនៅតាមដងផ្លូវទេ រួចបានចាត់ឲ្យកេណ្ឌអ្នកស្រុកទៅដងទឹកពីទីឆ្ងាយ ដាក់បំពង់រាប់ពាន់សែន យកមកឲ្យទាហានផឹកវិញ ។

យប់មួយ នៅពេលដែលពួកខ្មាំងនៅក្នុងបន្ទាយទ្រាំងមិនបានគិតដល់ថា នឹងមានការប្រយុទ្ធ តេជោព្រះអង្គ និងយមរាជមឿងបានប្រមូលទាហាន ដែលមានកាំភ្លើងកាន់នៅដៃ វាយលុកចូលទៅក្នុងបន្ទាយ ហើយបាញ់សម្លាប់ពួកខ្មាំងទាំងអស់ រួមទាំងកូម៉ែល និងពួកឆ្មបផង ។

ចប់សង្គ្រាម ព្រះរាជាណាចក្របានសុខសន្តិភាពហើយ ព្រះស្រីសុរិយោពណ៌ បានលើកតេជោព្រះអង្គឲ្យធ្វើជាចៅហ្វាយខេត្រសំរោងទង ។

រយៈកាលបន្តិចក្រោយមក តេជោព្រះអង្គបានទទួលមរណភាពទៅដោយជរាភាព ។ ពេលនោះព្រះរាជាបានលើកខ្ញុំបម្រើរបស់តេជោព្រះអង្គម្នាក់ឈ្មោះ យ៉ត[១៨] មានដើមកំណើតជាជនជាតិព្នង ឲ្យឡើងធ្វើជាចៅហ្វាយខេត្របន្ត ពីព្រោះខ្ញុំនេះតែងតែដើរតាមនាយចៅហ្វាយទៅគ្រប់សមរភូមិប្រយុទ្ធ និងរៀនសូត្រចេះដឹងពីចិត្តគំនិត និងល្បិចប្រយុទ្ធផ្សេងៗរបស់ចៅហ្វាយនាយ ហើយបានបង្ហាញឲ្យឃើញថាមានប្រាជ្ញាឈ្លាសវៃជាច្រើនលើកច្រើនសា ។ នាយយ៉តនេះបានចាប់បន្តធ្វើការបង្ក្រាបឲ្យស្រុកមានសុខសន្តិភាព ប្រកបដោយជោគជ័យ ដែលត្រូវអាក់ខានមួយរយៈ ដោយមរណភាពរបស់តេជោព្រះអង្គ ។

គឺនៅពេលនោះហើយដែលព្រះរាជា បានសម្រេចប្តូរព្រះរាជវាំងពីកោះស្លាកែត ដោយនាំព្រះរាជបរិពាររាជវង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រីមកគង់នៅឯលង្វាឯម[១៩] ដែលស្ថិតនៅចំពីមុខភ្នំពេញវិញ ។ ទ្រង់បានលើក

[១៨] និទានស្តីអំពីរឿងនេះនិយាយថា តេជោព្រះអង្គបានបញ្ជាឲ្យទ្រមាក់ដីរបស់គាត់រៀបចំគំនរឱស ហើយដុតគាត់ទាំងរស់ ដើម្បីបំពេញការសប្បាយរបស់ភរិយាគាត់ ។ និទាននោះនិយាយទៀតថា គាត់ជាស្តេចត្រាញ់នៅដីកំពង់ស្វាយ មិនមែននៅសំរោងទងទេ ហើយបាននិយាយបន្ថែមទៀតថា ព្នងយ៉ាតនេះបន្ទាប់មកបានយកប្រពន្ធរបស់តេជោព្រះអង្គធ្វើជាភរិយា ។

[១៩] រាជធានីនេះព្រះរាជា បានឲ្យកសាងឡើងនៅក្នុងព្រៃល្វាផ្អែម ក្រោយមកបានក្លាយទៅជាទីក្រុងសំខាន់មួយ ដែលពួកព័រទុយហ្គេ និងអេស្បាញ៉ុល ហៅថា ឡូអ៊ីម ។

ព្រះអគ្គមហេសីសម្តេចព្រះភគវតីស្រីសុជាតិឲ្យឡើងជាព្រះមហាក្សត្រីយ៍ ។ ខែត្រស្រីសឈរក៏ត្រូវបែងចែកជា ២គឺ មួយផ្នែកខាងលើនៅរក្សាឈ្មោះថា ស្រីសឈរ ដដែល ឯមួយផ្នែកខាងក្រោមមានឈ្មោះថា ល្វាឯម នៅក្នុងឆ្នាំ១៦០៤ ។

ហើយនៅពេលនោះដែរដែលព្រះរាជា ដែលទ្រង់គ្រងតែអាវផាយពណ៌លឿងតាមរបៀបសៀម និងបាន សម្រេចឲ្យនាម៉ឺនសព្វមុខមន្ត្រី តាំងពីពួកមហាតលិក និងនាយពលឡើងទៅ បោះបង់សម្លៀកបំពាក់របៀបលផ្នែក ដែលបង់កក្រមាវែងចេញ ហើយឲ្យស្លៀកពាក់ដូចព្រះអង្គវិញ ។ ទាំងការនិយាយស្តី ក៏ទ្រង់ឲ្យដូរ គឺឲ្យហៅព្រះអង្គ ថាព្រះស្រីសុរិយោពណ៌សម្តេចមនាថវិញ ។ ស្ត្រីៗដែលមានឋានៈខ្ពស់ត្រូវឆ្លើយនឹងព្រះរាជាថាព្រះពរ ឆ្លើយនឹង ព្រះមហាក្សត្រីយ៍ថាព្រះម៉ែហើយឆ្លើយនឹងពួកអ្នកអង្គម្ចាស់ថា ព្រះបាទម្ចាស់ ។

នៅពេលនោះ អតីតរាជានុសិទ្ធិព្រះកែវហ្វ៊ាយោមមិនអាចលាក់កំបាំងគំនិតដែលចង់ដណ្តើមយកអំ ណាចតទៅទៀតបានទេ ទ្រង់បានគេចខ្លួនទៅគង់នៅក្នុងខែត្រស្ទោង ចន្លោះខែត្រជីក្រែង និងខែត្រកំពង់ស្វាយ នៅក្នុងឆ្នាំ១៦១១ ហើយចាប់កេណ្ឌកងទ័ព ។ ព្រះស្រីសុរិយោពណ៌ បានលើកទ័ពទៅវាយកែវហ្វ៊ា យោម ចាប់ខ្លួនបាន ហើយបានបញ្ជាឲ្យគេធ្វើឃាតចោលទៅ ។

ពួកសៀម ដែលតាមដានសភាពការណ៍នៅកម្ពុជាជាប់ នៅពេលដែលទទួលពត៌មានស្តីអំពីការបំបែក ខ្លួនរបស់ពញាយោម ក៏បញ្ជូនទ័ពមួយកងចូលមកដល់ក្នុងខែត្រពោធិសាត់ ដោយយកលេសថាមកជួយព្រះ រាជាកម្ពុជា ។ ព្រះស្រីសុរិយោពណ៌ បានដឹកនាំទ័ពទៅជួបជាមួយទ័ពសៀម ពួកនេះក៏ចាប់បើកការវាយប្រហារ មកលើព្រះរាជា តែត្រូវព្រះរាជារុញច្រានឲ្យដកថយទៅប្រទល់ដែនវិញទៅ ។ ព្រះរាជាបានយាងទៅកាន់ស្វា- កែតនៅក្នុងខែត្រកំពត ជាទីដែលព្រះអង្គគង់នៅ តាំងពីពេលយាងត្រលប់ពីស្រុកសៀមម្ល៉េះ ។

នៅក្នុងឆ្នាំ១៦០១ ព្រះសុរិយោពណ៌ បានកសាងវត្តសម្បុក ប្រទានដី កាត់ឫសសីមា រួចទ្រង់បញ្ជា ចៅហ្វាយខែត្រឲ្យរៀបចំទទួលទូតមកពីទិសខាងត្បូង... 

ព្រះស្រីសុរិយោពណ៌គ្រងរាជសម្បត្តិបាន១៣ឆ្នាំហើយ ប៉ុន្តែមិនទាន់ទទួលព្រះរាជាភិសេកនៅឡើយ ។ ព្រះរាជាភិសេកនេះបានប្រព្រឹត្តទៅនៅក្នុងខែធ្នូ ឆ្នាំ១៦១៣[២០] ព្រះរាជាទ្រង់កាន់ព្រះខ័នរាជ្យ គង់នៅក្រោម ស្វេតច្ឆត្រ ហើយទទួលព្រះនាមថា ព្រះបាទសម្តេចព្រះបរមរាជាធិរាជរាមធិបតីព្រះស្រីសុរិយោពណ៌ ។

[២០] កាលបរិច្ឆេទនេះ មានកំណត់ហេតុមួយបញ្ជាក់ច្បាស់អំពីព្រះរាជពិធីអភិសេក ព្រះស្រីសុរិយោពណ៌ ។

## ៦- ព្រះជ័យជេដ្ឋា ឬ ជ័យចេស្តាទី២ (១៦១៨-១៦២២)

ប្រាំឆ្នាំក្រោយមក គឺនៅក្នុងឆ្នាំ១៦១៨ ដោយនៀយណាយនឹងគ្រប់គ្រងប្រទេសជាតិណាមួយមានអាពាធផង ព្រះស្រីសុរិយោពណ៌បានផ្តល់ដំណឹងដល់ព្រះជ័យជេដ្ឋាជាព្រះរាជបុត្រាច្បងរបស់ព្រះអង្គ ដែលសៀមទុកឲ្យនៅនឹងស្រុកគេនៅឡើយ ថាព្រះអង្គមានបំណងចង់ដាក់រាជសម្បត្តិថ្វាយ ។ ព្រះជ័យជេដ្ឋា ក៏សុំការអនុញ្ញាតពីព្រះរាជាអយុធ្យា ធ្វើដំណើរមកកម្ពុជាវិញ ដោយមានទ័ពសៀមហែហមមកជាមួយផង និងពួកខ្មែរ ដែលនៅបម្រើព្រះអង្គហើយដែលមានបំណងចង់មកតាមដែរ ។ មកដល់បរិបូណ៌ ទ្រង់បានបញ្ជាឲ្យទ័ពសៀមវិលត្រលប់ទៅវិញ រួចក៏យាងកាត់មករកល្វាឯម ។ ពេលនោះទ្រង់មានព្រះជន្ម៤០ព្រះវស្សាហើយ ។

ព្រះស្រីសុរិយោពណ៌ក៏លើកព្រះជ័យជេដ្ឋាឲ្យឡើងគ្រងរាជបល្ល័ង្ក មានព្រះនាមថាព្រះបាទសម្តេចព្រះរាជឱង្ការព្រះជ័យជេដ្ឋាធិរាជរាមាធិបតីបរមបពិត្រ ។ ព្រះឧទ័យជាព្រះអនុជ ដែលមានព្រះជន្ម៣៩ព្រះវស្សាបានទទួលព្រះឋានៈជាព្រះមហាឧបរាជ ។

មួយឆ្នាំក្រោយមកព្រះស្រីសុរិយោពណ៌បានសោយទិវង្គតទៅ នៅក្នុងព្រះជន្ម៦៨ព្រះវស្សា ។ ព្រះជ័យជេដ្ឋា និងព្រះឧទ័យបានរៀបចំព្រះរាជពិធីបូជាព្រះសពព្រះវររាជបិតា រួចហើយបានយកព្រះអដ្ឋិធាតុទៅបញ្ចុះនៅក្នុងចេតិយមួយសង់នៅលើភ្នំព្រះរាជទ្រព្យ នៅក្បែរឧត្តុង្គ ភ្នំនោះក៏ដូរឈ្មោះទៅជាត្រៃត្រឹង្សចាប់ពីពេលនោះរហូតមក ។

នៅរវាងឆ្នាំ១៦២០ ព្រះរាជាជ័យជេដ្ឋា បានធ្វើដំណើរបូជនីយេសក៍មកកាន់ភ្នំត្រៃត្រឹង្ស ទ្រង់ចាប់ព្រះទ័យជាខ្លាំងនឹងស្រុកឧត្តុង្គ ក៏បញ្ជាឲ្យសង់រាជវាំងមួយនៅពីខាងជើងស្រះកែវ រួចបានចេញបញ្ជាឲ្យដូរឈ្មោះរាជធានីដែលនៅក្បែរព្រះរាជវាំងនោះថាជា ឧត្តុង្គមានជ័យ វិញ ។ នៅឆ្នាំ១៦២២ ទ្រង់បានឲ្យជីកស្រះមួយទៀតនៅពីខាងក្រោយស្រះកែវនោះ ។ គឺនៅក្នុងឱកាសនោះឯងដែលទ្រង់បានចេញបញ្ជាឲ្យ នាម៉ឺនសព្វមុខមន្ត្រីហៅព្រះអង្គថា សម្តេចព្រះនរាយណ៍មនាថ ។

នៅក្នុងឆ្នាំ១៦២៣ ទ័ពសៀមពីរកងបានចូលមកលុកលុយព្រះរាជាណាចក្រកម្ពុជា មួយកងចូលមកពីទិសខាងជើង ដឹកនាំដោយព្រះរាជបុត្រស្តេចសៀម និងមួយកងទៀតដឹកនាំដោយឧត្តមសេនីយ៍ក្យាថៃណាំ ចូលមកក្នុងខែត្របន្ទាយមាសពីទិសខាងត្បូង ។ ព្រះជ័យជេដ្ឋា បានដឹកនាំទ័ពចេញទៅវាយទ័ពសៀម នៅទិសខាងជើងឲ្យបរាជ័យនៅបរិបូណ៌ ត្រង់ភ្នំចង្កង់[២១] ឯព្រះឧទ័យ បានដឹកនាំទ័ពចេញវាយសៀមឲ្យបរាជ័យនៅបន្ទាយមាស បន្ទំ

[២១] មានទ័ពសៀមជាច្រើនត្រូវចាប់បានជាឈ្លើយនៅក្នុងការប្រយុទ្ធមួយនៅជើងភ្នំចង្កង ប្រហែលជា៥០គីឡូម៉ែត្រ ពីខាងជើងទន្លេសាប ជាហេតុធ្វើឲ្យគេហៅថា សៀមចង្កង់ៗ ដូច្នេះរហូតមក ។

ឲ្យចុះទូកចេញទៅវិញទៅ ។ មួយឆ្នាំក្រោយមក ទ័ពសៀមចុះសំពៅវិលត្រលប់មកម្តងទៀត ក៏ប៉ុន្តែត្រូវព្យុះ បក់បោកបន្ទំឲ្យត្រលប់ចូលទៅក្នុងទន្លេមេណាមវិញដើម្បីជៀសវាងការខូចខាត ជាហេតុធ្វើឲ្យស្តេចសៀម ព្រះចៅប្រាសាទថោង បោះបង់យុទ្ធនាការនេះចោល ។ ដើម្បីរំលឹកដល់ជ័យជម្នះនេះ ហើយដើម្បីសំដែងការដឹងគុណដល់ព្រះរតនត្រ័យផង ព្រះរាជាបានចេញបញ្ជាឲ្យកសាងប្រាង្គមួយនៅលើកំពូលភ្នំ ព្រះរាជទ្រព្យពីលើចេតិយដែលដាក់អដ្ឋិធាតុព្រះបិតាព្រះអង្គ ។

ឡើងគ្រងរាជបល្ល័ង្កមិនបានប៉ុន្មានផង ព្រះជ័យជេដ្ឋា បានទទួលយកក្សត្រីអាណ្ណាមមួយអង្គដែលព្រះរាជាអាណ្ណាមបានបញ្ជូនមកថ្វាយ ធ្វើជាព្រះជាយា ហើយបានលើកព្រះក្សត្រីនោះឡើងជាសម្តេចភគវតីព្រះស្រីវក្សត្រីយ៍ ។

ព្រះក្សត្រីយ៍នេះមានសម្ផស្សល្អខ្លាំងណាស់ ហើយចេះធ្វើឲ្យព្រះរាជាស្រលាញ់ និងស្តាប់បង្គាប់ ។ គេបានចាត់ទុកថា ទំនាក់ទំនងរវាងព្រះរាជាអាណ្ណាមជាមួយព្រះរាជាកម្ពុជា បានចាប់ផ្តើមកើនឡើងពីត្រឹមពេលដែលក្សត្រីយរូបនេះយាងមកដល់រាជវាំងកម្ពុជា ។

នៅក្នុងឆ្នាំ១៦២៣ មានទូតអាណ្ណាមមួយក្រុម បាននាំយកជំនូនល្អៗមកថ្វាយព្រះរាជាជ័យជេដ្ឋា ជាព្រះរាជបុត្រសុណិសាររបស់ព្រះរាជាអាណ្ណាម ហើយស្នើសុំព្រះរាជានុញ្ញាតឲ្យប្រជាជនអាណ្ណាមចូលមករស់នៅចុងខាងត្បូងនៃព្រះរាជាណាចក្រ ហើយសុំព្រះរាជានុញ្ញាតបង្កើតទីស្នាក់ការគយមួយកន្លែងនៅព្រៃនគរ (សាយហ្គន)[២២] ដើម្បីគាំទ្រដល់កិច្ចការទាំងអស់នេះ ។ ព្រះរាជាអាចនឹងលំបាកក្នុងការប្រកែកមិនយល់ព្រមតាមសំណើ ហើយព្រះរាជក្សត្រីយ៍ក៏ប្រហែលជាបានទទូចឲ្យព្រះរាជាបំពេញតាមបំណងរបស់ព្រះបិតាផងដែរ នៅទីបញ្ចប់ព្រះរាជា ក៏យល់ព្រមផ្តល់ការអនុញ្ញាតតាមការស្នើសុំទាំង២ ។ គឺដោយបែបនេះហើយដែលពួកយួនចូលមករស់នៅក្នុងស្រុកខ្មែរ ហើយចាប់ផ្តើមទន្ទ្រានដណ្តើមយកទឹកដីដែលយើងហៅសព្វថ្ងៃថា កូសាំងស៊ីន ។

នៅសម័យនោះ តាមការរៀបរាប់ផ្សេងៗដែលប្រហែលជាគេនិយាយបំផ្លើសច្រើន បានដំណាលពីអ្នកស្រុកអាត្តូពឺ រើសបានមាសនៅនឹងបាតស្ទឹងពេលទឹកស្រក ព្រះរាជាក៏យាងទៅកាន់ទីកន្លែងនោះ[២៣] ។ ពាណិជ្ជករជាតិហុល្លង់ លោក ហេរ្វ៉ាវ៉ាន់វូស្ទូវ បានសរសេរពីរឿងនេះនៅក្នុងឆ្នាំ១៦៤២ថា ៖

[២២] ខែត្រចុងខាងត្បូងរបស់កម្ពុជានេះ និយាយឲ្យចំថាកន្លែងដែលជាទីតាំងរបស់ទីក្រុងសាយហ្គុង និងច្រឹឡឹងសព្វថ្ងៃ មិនមានឈ្មោះថា ព្រៃនគរទេ តែមានឈ្មោះថា ព្រៃគរ ឯពាក្យវៀតណាមថា សាយហ្គន មានន័យថាព្រៃគរ ដូច្នេះឯង ។

[២៣] ហេតុការណ៍ជាភស្តុតាងមួយទៀតបញ្ជាក់ថា នៅក្នុងសតវត្សរ៍ទី១៧ ស្ទឹងត្រែង និងអាត្តូពឺ ជាទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា ហើយព្រះរាជាក្រោយបន្តស់របស់លង្វែក ព្រះជ័យជេដ្ឋា ពេលភៀសព្រះអង្គទៅស្ទឹងត្រែង ទ្រង់គង់នៅក្នុងទឹកដីកម្ពុជា មិនមែនចូលទៅស្រុកលាវទេ ។

"នៅត្រង់ទីកន្លែងនោះ (បឹតហ្សុង-បាចុង-ស៊ឺងត្រែង) មានស្ទឹងមួយហូរចុះពីទិសខាងកើតមក ។ បើឡើងតាមស្ទឹងនេះទៅ ចម្ងាយ៣០ម៉ៃល៍ មានកន្លែងមួយឈ្មោះថា ណាមម៉យ មានពួកលូវ៉ែន (លាវ) រស់នៅ និងមានខ្មែរខ្លះដែររស់នៅទីនោះដែរ" ។

"កាលពី២០ឆ្នាំមុន ព្រះរាជាកម្ពុជា បានយាងតាមទូកមកដល់កន្លែងដែលអ្នកស្រុករើសបានមាស នៅ២០ម៉ៃល៍ពីខាងលើណាមម៉យ ជាមួយទ័ពជប៉ុន ចិន ម៉ាឡេ និងខ្មែរចំនួន៣០០នាក់ ។ ក៏ប៉ុន្តែទឹកមិនស្អាត ធ្វើឲ្យមនុស្សស្លាប់អស់ជាច្រើន នៅសល់មិនដល់៥០នាក់ផងទេ ដែលអាចវិលត្រលប់ពីបេសកកម្មនេះវិញ ។ ទោះជាយ៉ាងណាក្តី ពួកលូវ៉ែនបានអះអាងថាមានរ៉ែមាសជាច្រើន តែអ្នកស្រុកមិនបានទាញយកផលទេ ដោយមិនចេះធ្វើជំនួញ" ។

ព្រះជ័យជេដ្ឋា បានសុគតទៅនៅក្នុងឆ្នាំ១៦២៨ ក្នុងព្រះជន្មាយុ៥៨ព្រះវស្សា ក្រោយពីទ្រង់ឡើងសោយរាជ្យបាន ១០ឆ្នាំ ។

## ៧- រយៈកាលចន្លោះរាជសម្បត្តិ (១៦២៨-១៦២៩)

ព្រះឧទ័យជាព្រះអនុជ នៅពេលនោះ មានព្រះជន្មាយុ៤៨ព្រះវស្សាហើយ ។ ព្រះអង្គបានធ្វើជាឧបរាជតាំងពីឆ្នាំ១៦១៨មក ទ្រង់ក៏ចាប់កាន់កិច្ចការព្រះនគរជាបន្តក្នុងព្រះឋានៈជាព្រះឧបយុវរាជ មានព្រះនាមថាព្រះធម្មនាថយោមរាជធម្ម ។

ព្រះឧទ័យកាន់កាប់អំណាចរហូតដល់ឆ្នាំ១៦២៩ ដល់ពេលដែលព្រះរាជបុត្រច្បងរបស់ព្រះជ័យជេដ្ឋា ព្រះនាមថាចៅពញាសួរ ដែលបានសាងព្រះផ្នួសតាំងតែពីមុនពេលព្រះបិតាទ្រង់សុគត បានលាចាកព្រះផ្នួសមកវិញ ពេលនោះទ្រង់មានព្រះជន្ម២៦ព្រះវស្សាហើយ ។ ព្រះឧទ័យជាព្រះរាជានុសិទ្ធិ ដែលបានទទួលព្រះឋានៈមួយ ដែលធម្មតាមិនអនុញ្ញាតឲ្យព្រះអង្គទទួលរាជសម្បត្តិបានទេ ទ្រង់ក៏សម្រេចរៀបចំអភិសេកព្រះភាគិនេយ្យឲ្យឡើងសោយរាជសម្បត្តិឡើង ។

## ៨- ព្រះស្រីធម្មរាជាទី១-ចៅពញាសួរ (១៦២៩-១៦៣០)

ព្រះរាជពិធីអភិសេកចៅពញាសួរបានប្រព្រឹត្តទៅក្នុងឆ្នាំ១៦២៩ ហើយទទួលព្រះនាមថា ព្រះបាទសម្តេចស្តេចព្រះរាជឱង្ការព្រះស្រីធម្មរាជាធិរាជរាមាធិបតី ។ រាជពង្សាវតារជួនកាលហៅព្រះអង្គថា ព្រះស្រីធម្មរាជា ជួនកាលទៀតហៅព្រះអង្គថាព្រះរាជសម្ភារ ។

ព្រះរាជាវ័យក្មេងនេះ មិនចង់កាន់អំណាចទេ ម៉្លោះហើយ ទ្រង់បានប្រគល់កិច្ចការព្រះនគរទាំងអស់ឲ្យព្រះបិតុលាចាត់ចែង ចំណែកខ្លួនព្រះអង្គ បានយាងទៅគង់នៅឯកោះឃ្លោក សព្វថ្ងៃហៅថា ខ្សាច់កណ្តាល គិតគូរ

អំពីអក្សរសាស្ត្រវិញ ។ គឺជាក្សត្រមួយអង្គពូកែខាងរឿងសាសនា និងអក្សរសាស្ត្រ ហើយគេនិយាយថា ព្រះអង្គបាននិពន្ធកាព្យឃ្លោង និងរឿងរ៉ាវប្រវត្តិសាស្ត្រជាច្រើន ប៉ុន្តែមិនឃើញមានសេសសល់អ្វីរហូតមកដល់យើងទេ ។ ទ្រង់បានឲ្យជួរពិធីការដែលព្រះរាជាមុនៗ បានប្តូរជាច្រើនលើកច្រើនសាមកហើយ ដោយឲ្យអ្នកទាំងពួងហៅព្រះអង្គថា ព្រះរាជសម្ភារបារមីពិសេស និងឲ្យហៅអតីតព្រះរាជានុសិទ្ធិថា ព្រះភូវនាថ ។

ទ្រង់បានឯកភាពជាមួយព្រះជ័យជេដ្ឋា លះបង់ភាពជាបព្វជិតនៅឆ្នាំបន្ទាប់ ដើម្បីដឹកនាំទ័ពទៅវាយលុកខែត្រកូរ៉ាត់ ក្នុងព្រះរាជបំណងដណ្តើមយកពីសៀមមកវិញ ។ ក៏ប៉ុន្តែ ត្រូវបរាជ័យ មិនអាចឈរជើងបាន ក៏ដកទ័ពមកវិញ ដោយនាំយកឈ្លើយជាច្រើនមកជាមួយផង ។ ពេលយាងត្រលប់មកដល់អង្គរវត្តវិញ ព្រះឧបយុវរាជបានយាងទាំងគ្រួសារកាត់ទៅជួបនឹងព្រះអង្គ ធ្វើព្រះអង្គបានជួបជាមួយព្រះសុជាតិក្សត្រី ជាព្រះមហេសីរបស់ព្រះបិតុលាព្រះអង្គ ដែលគេបានផ្គូផ្គងជាមួយព្រះអង្គពីមុន តែត្រូវព្រះបិតុលារៀបអាពាហ៍ពិពាហ៍ ជាមហេសី ក្នុងពេលដែលព្រះអង្គកំពុងបំពេញបព្វជ្ជា ។ ទ្រង់ក៏ចាប់ផ្តើមស្រលាញ់ព្រះនាងដោយបានសុំណាត់ជួបជាមួយព្រះនាងនៅមុខនាគ ហើយក៏ស្រលាញ់គ្នាទៅ ។

ពេលយាងត្រលប់មកឧត្តុង្គវិញ ព្រះឧភយោរាជក៏ប្រឈួន ការថែធ្មួនក៏មិនដិតដល់ ទំនាក់ទំនងស្នេហារវាងព្រះរាជា និងព្រះក្សត្រីអង្គវតីចេះតែបន្តទៅ ។ រាជពង្សាវតារមួយនិយាយថា អ្នកទាំង២សន្យឹមថា បានជួបគ្នានៅពេលដែលព្រះឧភយោរាជសុគត ក៏ប៉ុន្តែផ្ទុយទៅវិញ ព្រះរាជានុសិទ្ធិ បែរជាជាសះស្បើយ ធ្វើឲ្យអ្នកទាំង២មានការភិតភ័យជាខ្លាំង ខ្លាចត្រូវគេវែកមុខរាយការណ៍ថ្វាយព្រះបិតុលា ព្រោះនរណាក៏ដឹងដែរថា ព្រះអង្គស្រលាញ់គ្នា ។ ភ័យពេក ព្រះអង្គវតី បានលួចរត់ចេញពីរាជវាំងរបស់ព្រះឧភយោរាជ ទៅគង់នៅព្រះរាជាវាំងរបស់ព្រះរាជាជាមួយសហាយវិញ ។

ព្រឹត្តិការណ៍ក្នុងរាជវង្សនេះ បានបង្កឲ្យកើតមានរឿងអាស្រូវជាខ្លាំង ៖ មនុស្សជាច្រើនបន្ទោសថា ព្រះឧភយោរាជបានដណ្តើមយកគូស្នេហារបស់ព្រះវជ្ជទាយាទ, អ្នកខ្លះទៀតបន្ទោសព្រះរាជាដែលបានដណ្តើមយកព្រះជាយារបស់ព្រះឧភយោរាជ ដែលខិតខំដឹកនាំប្រទេសជាតិក្នុងនាមជាព្រះយោមរាជធំ រួចហើយបានប្រគល់រាជសម្បត្តិមកឲ្យថែរក្សាវិញ, ហើយមានអ្នកខ្លះទៀតកាន់ជើងព្រះអង្គវតីដែលសព្វព្រះទ័យនឹងព្រះរាជាក្មេងដែលជាគូសង្សារចាស់ ជាជាងស្រលាញ់ព្រះស្វាមីចាស់ ដែលគ្រាន់តែជាឧភយោរាជប៉ុណ្ណោះ ។ ព្រះឧភយោរាជ និងព្រះរាជាក៏ចាប់តាំងកេណ្ឌទ័ពតែសព្វៗខ្លួន ហើយសង្គ្រាមបង្ហូរឈាមតែគ្រួសារឯងក៏បានផ្ទុះឡើង ។ ប៉ុន្តែតាំងពីការប្រយុទ្ធគ្នាដំបូងម្ល៉េះ ទ័ពព្រះរាជាត្រូវបរាជ័យ ហើយមេទ័ពរបស់ព្រះរាជា ៤នាក់ ដែលសុទ្ធជាជនជាតិចិនក៏ត្រូវគេសម្លាប់បាន ។ ព្រះរាជា និងព្រះអង្គវតី ក៏នាំគ្នាគេចខ្លួនទៅកាន់ខែត្រកញ្ជរ តែត្រូវទ័ពព្រះឧភយោរាជមួយកងតាមទាន់ ហើយធ្វើឃាតនឹងកាំភ្លើងសុគតទៅ ។

ព្រះស្រីធម្មោរាជាសោយរាជ្យបាន១ឆ្នាំ ហើយក៏សុគតទៅក្នុងព្រះជន្មាយុ២៩ព្រះវស្សា[២៤] ។

## ៩- ព្រះអង្គទងរាមាធិបតី- ចៅពញានូ (១៦៣០-១៦៤០)

ព្រះរាជាដែលឡើងសោយរាជ្យបន្តពីព្រះអង្គសូរ គឺចៅពញានូ ដែលទទួលការអភិសេកក្រោមព្រះនាមថា ព្រះបាទសម្តេចព្រះរាជឱង្ការព្រះអង្គទងរាជាធិរាជរាមាធិបតីបរមបពិត្រ នៅក្នុងព្រះជន្មាយុ២៣ព្រះវស្សា ។ រាជពង្សាវតារនិយាយថាទ្រង់សោយរាជ្យបាន៥ឆ្នាំ ក៏ប៉ុន្តែការគណនាបង្ហាញថាទ្រង់សោយរាជ្យបាន ៩ឆ្នាំយ៉ាងតិច ។ ទ្រង់បានបង្ក្រាបការបះបោរមួយរបស់អ្នកស្រុករលាំងទ្រុល ដឹកនាំដោយជនហិណ្ឌូម្នាក់ ដែលត្រូវចាប់ខ្លួនបាន រួចហើយទ្រង់បានបញ្ជាឲ្យគេកាត់ក្បាលសម្លាប់ចោល ។

ព្រះរាមាធិបតីទ្រង់បានផ្លាស់ប្តូររូបមន្តពិធីការដែលកំណត់ឡើងដោយព្រះធម្មោរាជា ដោយទ្រង់ឲ្យអ្នកផងហៅព្រះអង្គថា ព្រះករុណាពិសេសព្រះអង្គរាជ ។ ទ្រង់សោយរាជ្យសម្បត្តិនៅរាជធានីឧត្តុង្គ ។

ព្រះរាមាធិបតីបានចូលទិវង្គត នៅក្នុងខែមិថុនា ឆ្នាំ១៦៤០[២៥] ។

## ១០- ព្រះបទុមរាជាទី១- ព្រះអង្គនន់ (១៦៤១)

តាមការបង្ហាញពីព្រះឧភយោរាជព្រះឧទ័យ អតីតព្រះយោមរាជធំ នាម៉ឺនសព្វមុខមន្ត្រីបានលើកព្រះរាជបុត្រាច្បងរបស់ព្រះអង្គ ដែលមានព្រះជន្មាយុ២៤ព្រះវស្សាហើយ ឲ្យឡើងសោយរាជ្យបន្ត ក្រោមព្រះនាមថា ព្រះបាទសម្តេចស្តេចព្រះរាជឱង្ការព្រះបទុមរាជាធិរាជរាមាធិបតី ។ បើតាមសម្តីរបស់លោក ហ្យេរ៉ាវ៉ាន់វូស្ទូវ ព្រះរាជាអង្គនេះត្រឹមត្រូវ ស្លូត ហើយមានព្រះរាជអាកប្បកិរិយាល្អ ។ តាមមើលទៅ គឺប្រហែលដោយទ្រង់បានការពារពួកហុល្លង់ ដែលបានកសាងអគារពាណិជ្ជកម្មមួយ នៅខាងក្រោមពញាឮបន្តិច[២៦] ។

ក្រោយពេលទ្រង់ឡើងសោយរាជ្យបានបន្តិច មានកើតជំងឺមួយធំនៅក្នុងខែកក្កដា ឆ្នាំ១៦៤០ ធ្វើឲ្យស្លាប់ប្រជាជនកម្ពុជាអស់ជាច្រើន ។ ជំងឺនេះ បានធ្វើឲ្យមេអគារពាណិជ្ជកម្មហុល្លង់នៅកម្ពុជាឈ្មោះ វ៉ាន់ខែរហាហ្គិន ស្លាប់ក្នុងពេលតែ ២៤ម៉ោងប៉ុណ្ណោះ ។

---

[២៤] ឯកសារខ្លះនិយាយថា ទ្រង់សោយរាជ្យបាន ៨ឆ្នាំ ហើយសុគតក្នុងជន្មាយុ ៣៧ ព្រះវស្សា ។

[២៥] កាលបរិច្ឆេទនេះ បានមកពីឯកសារមួយសរសេរដោយជនជាតិហុល្លង់ម្នាក់ ឯកសារនោះមានឈ្មោះថា Récit succinct de ce qui s'est passé de curieux aux Indes Orientales, dans le Royaume du Cambodge ។ បើតាមរាជពង្សាវតារ ថាទ្រង់សុគតនៅក្នុងឆ្នាំ ១៦៦៤ ។

[២៦] ឯកសារខាងលើបានលើកពីព្រះអង្គថា "ទ្រង់ស្លូតបូត ហើយមាព្រះភ័ក្ត្រស្រស់ល្អ" ហើយថា "ទ្រង់ចូលចិត្តពួកហុល្លង់" ។

ព្រះបទុមរាជាសោយរាជសម្បត្តិនៅឧត្តុង្គបានប្រហែល១ឆ្នាំ ស្រាប់តែចៅពញាច័ន្ទ ជាព្រះរាជបុត្រាទី៣របស់ព្រះជ័យជេដ្ឋាជាមួយម៉មលាវឈ្មោះថា នាងអ្នកបុស្បា ហើយត្រូវជាព្រះអនុជរបស់ព្រះអង្គទងចៅពញានូ មិនសប្បាយព្រះទ័យនឹងព្រះឧភយោរាជព្រះឧទ័យ ដែលដកហូតរាជបល្ល័ង្កពីព្រះអង្គយកទៅឲ្យព្រះអង្គនន់វិញ ក៏បានលើកផែនការក្បត់ ហើយបានលួចធ្វើឃាតព្រះឧទ័យព្រមទាំង រាជវង្សានុវង្សជាច្រើនអង្គទៀត នៅក្នុងពិធីកំសាន្តមួយ នៅក្នុងថ្ងៃទី៥ ខែមករា ឆ្នាំ១៦៤២ ដោយមានការជួយគាំទ្រពីពួកម៉ាឡេ និងចាមដែលទ្រង់បានសន្យាថា នឹងផ្តល់ផលប្រយោជន៍ឲ្យជាក្រោយ[២៧] ។

រួចចៅពញាច័ន្ទ បានបញ្ជូនទ័ព ៥កង ឲ្យចេញទៅជួបជាមួយព្រះរាជាអង្គនន់ ដែលកំពុងតែប្រពាតការបរបាញ់សត្វនៅចម្ងាយប្រហែល៦០លីយីពីរាជធានី នៅក្នុងខែត្រមួយនៅមាត់សមុទ្រ ហើយដែលមានមហាតលិកការពារតែ៦០នាក់ប៉ុណ្ណោះ ។ ព្រះអង្គត្រូវទ័ពទាំង៥កងព័ទ្ធវាយប្រហារ រួចចាប់នាំខ្លួនមកកាន់រាជធានីឧត្តុង្គ ។

បន្ទាប់ពីឃាតកម្មមកលើព្រះឧទ័យ មានរាជកុមារ ៣អង្គ បានភៀសខ្លួនរួចពីការកាប់សម្លាប់រង្គាល ។ គឺរាជបុត្ររបស់ព្រះរាជា និងត្រូវជាព្រះរាជនត្តារបស់ព្រះឧទ័យ ។ រាជកុមារទាំង៣អង្គបានគេចចូលទៅជ្រកកោននៅក្នុងវត្តមួយ ម្ល៉ោះហើយក៏ទទួលបាននូវសិទ្ធិជ្រកកោន ដែលនៅសម័យនោះ គ្មាននរណារំលោភបានទេ នៅក្នុងតណ្ហចិនទាំងមូល ។ ចៅពញាច័ន្ទធ្វើហាក់ដូចជាបានបំភ្លេចកុមារទាំងនោះហើយ ប៉ុន្តែបានតាមដានរហូត ។ រហូតដល់ពេលដែលមានប្រជាជន១ម៉ឺន២ពាន់នាក់ ខឹងសម្បា ហើយកាន់អាវុធឡើង ធ្វើឲ្យកុមារទាំង៣ រត់ចេញពី

---

[២៧] ឯកសាររបស់ពួកហុល្លង់ខាងលើបានឲ្យដឹងថា ព្រះឧភយោរាជព្រះឧទ័យ បានត្រូវធ្វើឃាតនាល្ងាចមួយ នៅពេលដែលទ្រង់កំពុងតែក្រសាលបៀចិនជាមួយអ្នកអង្គម្ចាស់ច័ន្ទ ហើយនិងមន្ត្រីធំៗផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រ ។ ពេលព្រះអង្គកំពុងតែក្រសាល នោះ មហាតលិករបស់ព្រះអង្គដែលបានចូលដៃចូលជើងជាពួកក្បត់ បានលូនចូលមកជិតព្រះអង្គពីខាងក្រោយ ហាក់ដូចជាចង់មកចូលទូលព្រះអង្គអំពីបញ្ហាអ្វីមួយ ដូចដែលធ្លាប់តែធ្វើដូច្នេះជាធម្មតា រួចហើយក៏ដកកាំបិតស្នៀតចាក់សម្លាប់ព្រះអង្គតែម្តង ។ ភ្លាមនោះពួកដៃជើងឯទៀតៗក៏ស្ទុះក្រោកឡើង ពន្ទត់ភ្លើង វាយសំពងទៅលើអ្នកទាំងអស់ដែលនៅទីនោះ រួចហើយក៏ដុតវាំងចោលតែម្តងទៅ ។ ភ្លើងឆេះឡើងនេះ ជាសញ្ញាប្រាប់ដល់ពួកក្បត់ឯទៀតៗ ឲ្យសំរុកចូលទៅក្នុងគេហដ្ឋានរបស់ពួកមន្ត្រីដែលស្មោះត្រង់នឹងព្រះឧភយោរាជ ហើយដុតចោលទាំងអស់ដែរ ។ មានមន្ត្រីខ្លះដែលដឹងខ្លួនទាន់ បានឆ្លៀតឱកាសកំពុងច្របូកច្របល់រត់គេចខ្លួនទៅកាន់ស្រុកស្រែចម្ការបាន ក៏ប៉ុន្តែបន្ទាប់មកត្រូវចាប់ខ្លួននាំយកមករាជធានីវិញ ហើយទទួលការវាយដំធ្វើបាបតតគ្រាប្រណីមិនគួរនឹងមើល រួចហើយក៏ត្រូវសម្លាប់ចោលទៅ ។ ទារុណកម្មចំពោះមន្ត្រីទាំងអស់នោះសាហាវព្រៃផ្សៃណាស់ ៖ គេយកឈើដោតទំលាយពោះ ខ្លះយកកំប៉ះគូទ រួចប្រើកាំបិតចុងស្រួចឆ្កៀលសាច់ឆ្អឹងខ្នងតាំងពីក្រោមរហូតដល់ ក-ដៃទាំង២ គេចងភ្ជាប់ទៅនឹងបង្គោលចងខ្វែងជើងក្អែក ជើងជាន់លើក្តារ១បន្ទះ ហើយគេទុកចោលហាលថ្ងៃនៅលើផ្លូវសាធារណៈ ទុកឲ្យអ្នកស្រុកដើរមកដេរប្រទេចផ្តាសា រហូតដល់ស្លាប់ក្នុង២ ឬ៣ថ្ងៃ ។ ឯកសារមួយដែលខ្ញុំមាននៅក្នុងដៃនិយាយថា ចេតិយជាច្រើន ដែលគេសង់នៅជុំវិញភ្នំផ្នែកខាងក្រោម គឺសម្រាប់ដាក់អដ្ឋិធាតុរបស់មន្ត្រីទាំងអស់នោះឯង ដែលត្រូវសម្លាប់ដោយបញ្ជាពញាច័ន្ទ ។

វត្តរួចចាប់កុមារបងទាំង២មកប្រគល់ឲ្យពញាច័ន្ទ ។ រាជកុមារពៅបាន ត្រូវព្រះវររាជមាតាជួយសង្គ្រោះ យកទៅចិញ្ចឹមបីបាច់ថែរក្សា មិនព្រមប្រគល់ឲ្យពញាច័ន្ទទេ ។ ប៉ុន្មានឆ្នាំក្រោយមក ព្រះរាជាបានលើកព្រះរាជកុមារនេះឲ្យឡើងធ្វើជាមហាឧបរាជ ។

ឯកសាររបស់ពួកហុល្លង់បានរៀបរាប់ថា រាជកុមារទាំង២បានរងនូវការធ្វើទារុណកម្មអាក្រក់ខ្លាំងណាស់ មុននឹងត្រូវគេសម្លាប់ ។ គេយកព្រះអង្គទៅដាក់គុក ហើយឲ្យសោយតែសាច់ដែលគេកាត់ចេញពីខ្លួនព្រះអង្គ ។ តែរាជកុមារទាំង២មានសេចក្ដីក្លាហាន ខុសប្លែកពីកុមារទាំងឡាយ ។ នៅពេលដែលទ្រង់ត្រូវគេសម្លាប់ដោយចងភ្ជាប់ទៅនឹងដើមចេក ទ្រង់បានសំណូមពរហើយពិនិត្យបញ្ជាក់ថា គេបានសំលៀងកាំបិតដែលត្រូវយកមកកាប់ខ្លួនព្រះអង្គជា២កំណាត់នោះមុតល្អហើយ ។ ការធ្វើឃាតរាជកុមារទាំង២បានធ្វើឲ្យប្រជារាស្ត្រមានការភិតភ័យជាខ្លាំង ហើយគ្មាននរណាម្នាក់ហ៊ានចេញមុខមកជួយឡើយ ។

តាមពិតទៅ អ្នកអង្គម្ចាស់ច័ន្ទ ទ្រង់ដឹកនាំប្រទេសក្នុងព្រះនាមព្រះរៀមរបស់ព្រះអង្គ ហើយអ្វីៗសុទ្ធតែធ្វើទៅតាមបញ្ជារបស់ព្រះរៀមទាំងអស់ ។ ប៉ុន្តែដោយប្រជារាស្ត្រស្អប់ព្រះអង្គ តែស្រលាញ់ព្រះរៀមម៉្លោះហើយទ្រង់ក៏សម្រេចចិត្តកម្ចាត់ព្រះរៀមចេញ ។ ពួកហុល្លង់និយាយថា ទ្រង់បានរៀបចំធ្វើឲ្យព្រះអនុជថ្ងៃរបស់ព្រះរាជា ចោទប្រកាន់ព្រះរាជាថាបានចែចង់ព្រះជាយារបស់ព្រះអង្គ រួចហើយទ្រង់បានចេញបញ្ជាឲ្យគេកាត់-កព្រះរាជាទៅ ។ បន្ទាប់មក អ្នកអង្គម្ចាស់ច័ន្ទបានបញ្ជាឲ្យគេសម្លាប់ព្រះអនុជថ្ងៃនោះចោលទៀត ដោយចោទថាបានធ្វើការចោទប្រកាន់មិនត្រឹមត្រូវទៅលើព្រះរាជា ។ រឿងកំប្លែងទាំងអស់នោះ មានគោលបំណងជាពិសេសគឺដើម្បីរក្សារាជសម្បត្តិទុកខ្លួនឯង ។

## ១១- ព្រះបទុមរាជាទី២ ពញាច័ន្ទ -ស្ដេចចូលសាសនាជ្វា (១៦៤២-១៦៥៩)

ក្រោយពីបានអនុវត្តអំពើឧក្រិដ្ឋខាងលើរួចហើយ អ្នកអង្គម្ចាស់ច័ន្ទ ដែលមានព្រះជន្ម២៦ព្រះវស្សាបានឲ្យគេរៀបចំពិធីអភិសេកព្រះអង្គ ក្រោមព្រះនាមថា ព្រះបាទសម្ដេចព្រះបទុមរាជាធិរាជរាមាធិបតី ។ អ្នកអង្គម្ចាស់ឯម រាជបុត្រារបស់ព្រះឧទ័យ ដែលព្រះវររាជមាតាបានជួយសង្គ្រោះ ត្រូវបានលើកឲ្យឡើងឋានៈជាព្រះកែវហ្វ៉ា ។ ពួកហុល្លង់និយាយថាចៅពញាច័ន្ទនេះ មានកិត្តិនាមល្បីខាងមានចិត្តអាក្រក់ និងកាចសាហាវ ហើយព្រះរាជាទាំងអស់ រួមទាំងព្រះរាជាមុនៗផង ខ្លាចរអាគ្រប់គ្នា នៅពេលទតឃើញនូវអត្តចរិតឃោរឃៅរបស់ព្រះអង្គនាថ្ងៃមួយ[២៨] ។

---

[២៨] ចៅពញាច័ន្ទ មានព្រះមាតាជាជនជាតិលាវ ។

ចាប់តាំងតែពីពេលដែលបានឡើងគ្រងរាជបល្ល័ង្ក ទ្រង់បានចេញព្រះរាជបញ្ញាមួយបញ្ជាក់អំពីព្រះឋានៈរបស់ព្រះរាជវង្សានុវង្សទាំងអស់ជាភាសាបាលី ហើយទ្រង់បានសម្រេចឲ្យឆ្លើយនឹងព្រះរាជាថា ព្រះករុណាពិសេស ហើយឆ្លើយនឹងសមាជិកព្រះរាជវង្សថាព្រះបាទម្ចាស់ ។

នៅសម័យនោះ ពួកហុល្លង់បានបើកអគារពាណិជ្ជកម្មរបស់គេនៅកម្ពុជាបាន២-៣ឆ្នាំហើយ ។ ពួកនោះបានជួបជាមួយពួកព័រទុយហ្គេដែលមានវត្តមានតាំងតែពីឆ្នាំ១៥៥៣មកម្ល៉េះ ហើយថែមទាំងបានបំពេញភារកិច្ចធំៗថ្វាយដល់រាជវង្សថែមទៀតផង ដូចដែលយើងបានឃើញរួចមកហើយ នៅចុងសតវត្សរ៍មុន ។ ពួកព័រទុយហ្គេមានអគារពាណិជ្ជកម្មនៅកំពង់ហ្លួង ឯពួកហុល្លង់មានអគារនៅពញាឮ ។ ពួកជាតិសាសន៍នេះទាំង២មានការប្រកួតប្រជែងខាងពាណិជ្ជកម្មស្រួចស្រាល់ខ្លាំងណាស់ ដូច្នេះហើយការស្អប់គ្នាទៅវិញទៅមកក៏ខ្លាំងណាស់ដែរ ។ គេបានចាប់ផ្ដើមដណ្ដើមទីតាំងគ្នាទៅវិញទៅមករួចមកហើយ នៅក្នុងចុងបូព៌ាទាំងមូល ហើយគេក៏តាំងចាប់ផ្ដើមជេរគ្នាទៅវិញទៅមក ដណ្ដើមគាប់គួរជាមួយព្រះរាជាកម្ពុជា សំដៅបំផ្លាញគ្នាទៅវិញទៅមកដែរ ។

នៅក្នុងឆ្នាំ១៦៣៦ ពួកអ្នកស្រុកបានចូលយកទំនិញរបស់កប៉ាល់ឈ្មោះ ន័រវីក ដែលលិចនៅក្បែរមាត់សមុទ្រកម្ពុជា ពួកហុល្លង់ក៏ប្ដឹងរកយុត្តិធម៌[២៩] ។ ពេលនោះព្រះរាជា ដែលពិភាល់ថាពួកនេះជាចារកម្មរបស់ពួកសៀម បានឆ្លើយតបទៅវិញថាព្រះអង្គមានសិទ្ធិ និងទទួលយករាល់របស់របរផ្សេងៗ ដែលបានមកពីការលិចលង់របស់កប៉ាល់បរទេស ។ ពួកហុល្លង់ឆ្លើយថាពួកគេមិនមែនជាជនបរទេសទៀតទេ ព្រោះគេ បានមកតាំងទីលំនៅនៅក្នុងព្រះរាជាណាចក្រកម្ពុជារួចទៅហើយ ។ ទឡ្ហីករណ៍នេះមិនត្រឹមត្រូវទេ ពីព្រោះថា នៅឯអឺរ៉ុប គេសន្មត់ថារាល់កប៉ាល់របស់ប្រទេសមួយ ដែលលិចនៅលើឆ្នេរសមុទ្ររបស់ប្រទេសមួយទៀត គេតែងតែចាត់ទុកជាកប៉ាល់បរទេសហើយ ។ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៦៣៨ លោកឧត្ដមសេនីយ៍ វ៉ាន់ឌីយ៉ឺម៉ិន ដែលឈរជើងនៅឯបាតាវីយ៉ា បានបញ្ជូនឈ្មោះ ប៉ូលគ្រុក ឲ្យធ្វើដំណើរមកកាន់រាជវាំងឧត្តុង្គ ដើម្បីធ្វើការដោះស្រាយ ។ ពេលនោះពួកព័រទុយហ្គេ ដែលបានសម្លាប់ពួកហុល្លង់អស់២នាក់កាលពីមួយឆ្នាំមុន បានសម្រេចចិត្តថា នឹងធ្វើឲ្យបេសកកម្មនេះបរាជ័យ ។ រឿងរ៉ាវនេះបានអូសបន្លាយពេលជាង៣ឆ្នាំមកហើយ ដោយលោកឧត្ដមសេនីយ៍ នៃក្រុមហ៊ុនពាណិជ្ជកម្មហុល្លង់ នឹកគិតស្មានថា ខ្លួននេះបានត្រូវព្រះរាជា និងព្រះមហាឧបរាជចាត់ទុកដូចជាបងប្អូនរួចទៅហើយ តែស្ដេចទាំង២អង្គនេះ បានប្រកែកមិនយល់ព្រមទទួលលិខិតរបស់គាត់ទេ ហើយទទួលមានព្រឹត្តិការណ៍ចៅពញាច័ន្ទ និងពួកអ៊ីស្លាមធ្វើឃាតព្រះរាជា ព្រះឧភយោរាជជាមួយនឹងមន្ត្រីអ្នកមុខអ្នកការនៅក្នុងព្រះរាជាណាចក្រកាលពីថ្ងៃទី៥ ខែមករា ឆ្នាំ១៦៤២ ពួកហុល្លង់ក៏ចាប់ផ្ដើមគិតរកដំណោះស្រាយសាជាថ្មី ។

---

[២៩] ពួកខ្មែរបានដណ្ដើមយកទំនិញអស់ពីកប៉ាល់ ក្នុងនោះមានទាំងស្ពាន់មកពីជប៉ុនចំនួន៥០០ហាប និងកាំភ្លើងធំ១៣ដើមផង ។

ព្រះរាជាថ្មីបានផ្ញើព្រះរាជសារលិខិតមួយច្បាប់ទៅឲ្យឧត្តមសេនីយ៍[៣០] ក្រុមហ៊ុនហុល្លង់ដែលឈរជើង នៅឯកោះជ្វា បញ្ជាក់ថាព្រះអង្គមានបំណងចង់រក្សាទំនាក់ទំនងល្អជាមួយគ្នា ។ លោកឧត្តមសេនីយ៍ នៅពេលបានដឹងថា បេសកជនរបស់គាត់មិនទាន់បានចូលគាល់ព្រះរាជានៅឡើយទេ ផ្ទុយពីពួកអេស្ប៉ាញ និងព័រទុយហ្គេ បែរជាទទួលបាននូវការប្រោសប្រណីជាច្រើន មិនតែប៉ុណ្ណោះព្រះរាជាបានទាំងបញ្ជូនដំរី២ក្បាលទៅជូនលោកអភិបាលក្រុងម៉ានីលថែមទៀតផងនោះ ក៏ចាត់តាំងឲ្យលោក គ័រណឺក្លែក ជាមេខាងផ្នែកពាណិជ្ជកម្ម ធ្វើដំណើរតាមកប៉ាល់ ២គ្រឿងមកកម្ពុជានៅក្នុងខែឧសភា ឆ្នាំ១៦៤២ ។ លោកគ័រណឺក្លែកមានភារកិច្ចមកទូលសរសើរព្រះរាជា ដែលទទួលបានជ័យជម្នះលើពួកខ្មាំងសត្រូវ ដែលកន្លងមកបានធ្វើឲ្យព្រះអង្គបាត់បង់អស់នូវសិទ្ធិស្របច្បាប់ទាំងឡាយ ហើយទ្រង់បានកម្ទេចចោលពួកស្ដេចជ្រែករាជ្យទាំងអស់ ។ គាត់ក៏មានភារកិច្ចត្រូវរាយការណ៍ថ្វាយព្រះរាជា សូមឲ្យព្រះអង្គប្រុងប្រយ័ត្ននឹងល្បិចកលរបស់ពួកព័រទុយហ្គេ ដែលកន្លងមកបានលួចបំពុល ព្រះរាជា ប៉ីរណេអូ និងនាម៉ឺនសព្វមុខមន្ត្រីមួយចំនួន និងសូមឲ្យព្រះអង្គរក្សាទំនាក់ទំនងល្អជាមួយពួកហុល្លង់ ដែលជានិច្ចជាកាលជាមិត្តដ៏ល្អសម្រាប់ព្រះរាជាដែលទទួលរាក់ទាក់ពួកគេ ។

នៅពេលដែលការចរចាខាងលើកំពុងតែប្រព្រឹត្តទៅ នៅក្នុងឆ្នាំដដែលនោះ ព្រះរាជាដែលបានទទួលយកនារីម៉ាឡេម្នាក់ជាព្រះជាយា ។ ប្រហែលជាដើម្បីបំពេញព្រះទ័យព្រះជាយានេះផង ហើយក៏ប្រហែល ដើម្បីលើកទឹកចិត្តពួកម៉ាឡេ និងចាមដែលបានជួយឲ្យព្រះអង្គដណ្ដើមយករាជបល្ល័ង្កមកវិញបានផង ទ្រង់បានប្ដូរចូលសាសនាមហាម៉ាត់វិញ ដោយឲ្យគេកាត់ស្បែក ហើយទ្រង់ប្រកាសប្ដូរព្រះនាមថា អ៊ីប្រាហ៊ីមវិញ ។ លោក ហេរ្វ៉េវ៉ាន់វូសូហ្វ បាននិយាយថា ព្រះរាជាទ្រង់បានផ្ដល់ផលប្រយោជន៍ជាច្រើនដល់ពួកម៉ាឡេ និងចាម ។ ហេតុការណ៍នេះ បានធ្វើឲ្យប្រជាជនមិនសប្បាយចិត្តទេ គេបានហៅព្រះរាជាថាជាស្ដេចចេញសាសនា និងជាស្ដេចចូលសាសនាជ្វា ។

ពួកម៉ាឡេ និងចាមដែលកាន់សាសនាមហាម៉ាត់ទាំងអស់នេះច្រើនតែជាពាណិជ្ជករ ម្ល៉ោះហើយ គឺជាសត្រូវនឹងពួកអឺរ៉ុប ដែលជាដៃគូប្រកួតប្រជែង ។ ដល់ពេលបានក្លាយជាអ្នកជិតស្និទ្ធនឹងព្រះរាជា ពួកនេះក៏ប្រែក្លាយទៅជាកាចសាហាវ ។ ដោយខ្លាចអាការវាយប្រហាររបស់ពួកនេះ និងដោយពួកព័រទុយហ្គេចេះតែផ្សព្វផ្សាយពាក្យមិនល្អពីខ្លួនផង ពួកហុល្លង់ក៏សម្រេចចិត្តដកថយចេញពីកម្ពុជា ដែលមិនមែនជាទីសុខសាន្តសម្រាប់ខ្លួនទេ ។ បេសកជនរបស់ឧត្តមសេនីយ៍បាតាវីយ៉ាបានចាកចេញពីកម្ពុជា ហើយនាយអគារពាណិជ្ជកម្មហុល្លង់នៅកម្ពុជា ក៏ត្រូវគេ

---

[៣០] ឧត្តមសេនីយ៍របស់ក្រុមហ៊ុនហុល្លង់នៅចុងបូព៌ា (Compagnie hollandaise des Indes - Orientales) ដែលនៅបាតាវីយ៉ា ហើយដឹកនាំគ្រប់គ្រងរាល់អគារពាណិជ្ជកម្មហុល្លង់ទាំងអស់ គឺជាមេដឹកនាំពាណិជ្ជកម្ម មិនមែនជាមេទ័ពទេ ។

បញ្ជាឲ្យដកចេញទៅវិញដែរ ដរាបណារាជរដ្ឋាភិបាលកម្ពុជាមិនបានបំពេញសេចក្ដីត្រូវការរបស់ខ្លួននោះ ។

តើមានអ្វីកើតឡើងក្រោយពីពួកហុល្លង់ចាកចេញផុតទៅ? យើងបានដឹងអំពីអ្វីៗដែលកើតមានជាបន្តមកទៀតតែដោយសារឯកសារពួកហុល្លង់ប៉ុណ្ណោះ ។ ពួកហុល្លង់មិនបានប្រាប់ឲ្យដឹងពិតប្រាកដថាតើអ្នកណាដែលជាមេភ្លើងទេ ក៏ប៉ុន្តែពួកគេបានសរសេរថា ក្រោមការញុះញង់របស់ពួកព័រទុយហ្គេ និងពួកម៉ាឡេ និងដោយមានការថ្វាយយោបល់ពីឧកញ៉ាពីរស្នេហ៍ដុល (?) ព្រះរាជាបានចេញបញ្ជាឲ្យកាប់សម្លាប់ពួកហុល្លង់ រឹបយកម្ទេចអគារ និងដណ្ដើមយកកប៉ាល់ហុល្លង់ឈ្មោះ ន័រវីក និងសំពៅឈ្មោះ វីវីកផង ។ ព្រះរាជបញ្ជានេះ ត្រូវបានគេអនុវត្តតាមនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៦៤៤ លើកលែងតែកប៉ាល់ន័រស៊ីកមួយចេញ ដែលគេមិនអាចចាប់បាន ។ ក៏ប៉ុន្តែ ចៃដន្យអាក្រក់នេះ បានធ្លាក់ទៅលើកប៉ាល់ឈ្មោះ អូវ៉ែហ្វេ ដែលទើបតែមកដល់ពីកោះហ្វ័រម៉ូហ្សា (តៃវ៉ាន់)[៣១] ទៅវិញ ដោយគ្មានបានដឹងរឿងរ៉ាវដែលកើតមាននៅកំពង់ហ្លួងទេ ។ អ្នកដើរកប៉ាល់នេះ បានត្រូវពួកជប៉ុន ដែលមានគ្នាប្រហែលជា ១០នាក់ បន្ទំឲ្យចុះមកដីហើយសម្លាប់អស់មួយចំនួន មួយចំនួនទៀតត្រូវចាប់ជាឈ្លើយ ។

ពេលទទួលបាននូវដំណឹងនេះ ពួកហុល្លង់នៅបាតាវីយ៉ាបានសម្រេចចិត្តធ្វើការសងសឹកវិញ ដោយបញ្ជូនកប៉ាល់៥គ្រឿងមកកម្ពុជា និងទូកសំប៉ានជាច្រើន ដឹកនាំទាហាន១៦០នាក់ និងនាវិក២៤០នាក់ ។ គេនឹងធ្វើការសងសឹកដោយការបង្ហូរឈាមប្រសិនបើព្រះរាជាអ៊ីព្រាហ៊ីម មិនព្រមប្រគល់ចំណាប់ខ្មាំងមកឲ្យវិញ ហើយមិនធ្វើឲ្យមានទំនាក់ទំនងដូចកាលពីមុនឆ្នាំ១៦៤០ទេ ។ ក្រុមហ៊ុនពាណិជ្ជកម្មហុល្លង់ទើបតែបានផ្ញើការសរសើរមកថ្វាយព្រះរាជា ស្រាប់តែត្រូវធ្វើសង្គ្រាមមួយទៅវិញ ក៏ប៉ុន្តែពួកគេចង់បានសន្តិភាព ។ កប៉ាល់ទាំងអស់បានចេញដំណើរនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៦៤៤ ឡើងមកតាមទន្លេបាសាក់ ហើយបានមកបោះយុថ្កានៅទីងពាមទន្លេសាបពីខាងលើភ្នំពេញ-ចតុម្មុខបន្តិច គឺប្រហែលជាចម្ងាយ១៦គីឡូម៉ែត្រ ពីអគារពាណិជ្ជកម្មហុល្លង់ ។

នៅពេលដែលកិច្ចចរចាចាប់ផ្ដើមឡើងនៅថ្ងៃទី៧ ខែកក្កដា ពួកមន្ត្រីខាងកម្ពុជាបានសំណូមពរឲ្យពន្យារពេល ៧ថ្ងៃ ដោយហេតុថាព្រះមាតារបស់ព្រះរាជាទើបនឹងសុគត ។ ដោយពិនិត្យឃើញថាគ្មានអ្វីប្លែក គួរឲ្យសង្ស័យនៅតាមមាត់ទន្លេ មេបញ្ជាការហុល្លង់ក៏យល់ព្រមតាមសំណើ ហើយថែមទាំងបានសំដែងការចូលរួមមរណទុក្ខ ដោយការបាញ់កាំភ្លើងធំគោរពទៀតផង ។

កប៉ាល់ហុល្លង់នៅក្នុងទឹករហូតដល់៦ខែ តែនៅមិនទាន់មានលទ្ធផលអ្វីបន្តិចសោះ ។ ដល់ថ្ងៃទី២០ ខែមករា

[៣១] កោះហ្វ័រម៉ូស ចិនហៅថា តៃវ៉ាន់ អ្នកស្រុកអាយហៅថា ប៉េកាន ។ ពួកហុល្លង់កាន់កាប់កោះនេះបាននៅក្នុងឆ្នាំ១៦៣៤ ក៏ប៉ុន្តែដល់មកឆ្នាំ១៦៦១ មានចោរសមុទ្រឈ្មោះ កុកស៊ីងហ្គា ដែលជាដៃជើងរបស់រាជវង្សមិញដណ្ដើមយកវិញ ក្រោយពីបានកាន់កាប់មួយរយៈ ។ មានបន្ទាយសំខាន់២ គឺតៃវ៉ាន់ ឬហ្វៃយូវ៉ាន់ និងហ្គាឡង់ដាំង ។ ឈ្មោះដែលពួកហុល្លង់ហៅថា កុកស៊ីងហ្គា តាមមើលទៅប្រហែលគឺ បេវឌិញ ។

ឆ្នាំ១៦៤៥ មេបញ្ជាការហុល្លង់ក៏សម្រេចចិត្តនាំគ្នាចេញកប៉ាល់ធ្វើដំណើរបន្តទៅកាន់លវ៉ែក ។ ទៅជិតដល់កំពង់ហ្លួងទៅហើយ ស្រាប់តែមានលេចឮដំណឹងថាគេកំពុងប្រមូលឫស្សីមកករនៅភ្នំពេញ ជាមួយនឹងអាវុធយុទ្ធភណ្ឌផ្សេងៗទៀត ។ មេបញ្ជាការក៏បញ្ជាឲ្យធ្វើដំណើរចុះមកវិញ តែត្រូវទូកតូចៗជាច្រើនស្កាត់វាយនៅពាក់កណ្ដាលផ្លូវ ។ កប៉ាល់ហុល្លង់បានវាយរុញច្រានទូកទាំងអស់នោះចេញបាន តែត្រូវរងការបាញ់ឥតដាច់ពីលើគោកថែមទៀត ។ យប់មកដល់ កប៉ាល់បានបោះយុថ្កាសម្រាកសិន ។ ដល់ពេលព្រឹកស្អែកឡើង គេពិនិត្យឃើញមានស្ពានមួយប្រវែង១២០ម៉ែត្រ ទទឹង៦ម៉ែត្រនៅកាត់ទទឹងទន្លេ និងមានកាំភ្លើងធំ៨ដើមរៀបតម្រៀបគ្នានៅលើច្រាំងទន្លេខាងលិច ឯខាងកើតទន្លេវិញមានប៉មមួយកំពុងសង់ឡើងមិនទាន់រួច ។ មេបញ្ជាការហុល្លង់បានសម្រេចថាត្រូវតែវាយបើកផ្លូវចេញ ហើយការប្រយុទ្ធក៏ចាប់ផ្ដើមឡើង ។ មេបញ្ជាការនោះបានត្រូវគ្រាប់ដាច់ក្បាលបាត់តាំងតែពីចាប់ផ្ដើមប្រយុទ្ធភ្លាមម៉្លេះ ហើយខាងហុល្លង់បានបាត់បង់កម្លាំងអស់១២០នាក់ ក៏ប៉ុន្តែកប៉ាល់បានឆ្លងផុតចូលទៅក្នុងទន្លេធំ ខាងក្រោមភ្នំពេញ នៅវេលាម៉ោង៤រសៀល ហើយបោះយុថ្កាសម្រាកនៅទីនោះទៅ ។ ឯកសារហុល្លង់និយាយថា នៅក្នុងការប្រយុទ្ធគ្នានោះ ខាងខ្មែរបានខូចខាតកម្លាំងរហូតដល់ទៅ១ពាន់នាក់ ។

ដោយមិនអាចទប់ទល់នឹងការវាយប្រហារតទៅទៀត កប៉ាល់ហុល្លង់ ក៏ធ្វើដំណើរចុះតាមទន្លេបន្តទៅទៀត ហើយទៅដល់ផានរ៉ាំងនៅថ្ងៃទី១២ ខែកក្កដា ។ ស្ដេចនគរចាម្ប៉ាដែលសេសសល់ពីការវាតទីរបស់ពួកអាណ្ណាមនៅពេលនោះ បានទទួលស្វាគមន៍ពួកហុល្លង់ ហើយអនុញ្ញាតឲ្យពួកនេះធ្វើពាណិជ្ជកម្មនៅតាមកំពង់ផែរបស់គេ ក៏ប៉ុន្តែបានហាមប្រាមមិនឲ្យវាយពួកព័រទុយហ្គេ នៅក្នុងទឹកដីគេទេ ។ ស្ដេចនគរចាម្ប៉ានោះបានប្រកាសថា អាកប្បកិរិយារបស់ស្ដេចច័ន្ទអុីប្រាហុីមគឺជាអំពើក្បត់ តែព្រះអង្គបានផ្ដាច់ចំណងទាក់ទងជាមួយតាំងតែពីពេលដែលពញាច័ន្ទបានធ្វើឃាតព្រះឧភយោរាជទទ័យ និងព្រះអង្គនន់ ដែលជាមិត្តភក្តិមកម៉្លេះ ។ ក្នុងពេលនោះមាននាវាហុល្លង់មួយគ្រឿងទៀត ឈ្មោះ អេទ័លប៉ូលែរ ចេញមិនទាន់ផុតពីទន្លេបាសាក់នៅឡើយ ហើយកំពុងតែរងការវាយប្រហារពីទ័ពជើងទឹកកម្ពុជា ដែលដឹកនាំដោយព្រះរាជាផ្ទាល់ព្រះអង្គ និងពួកព័រទុយហ្គេ ម៉ាឡេ និងជប៉ុន ជាអ្នកបញ្ជាផង ។ នាវានោះអាចទ្រាំទ្រការវាយប្រហារនោះបានយ៉ាងល្អ ហើយចុះផុតចូលទៅក្នុងលំហសមុទ្រ ឯនាវាកម្ពុជាក៏លែងហ៊ានដេញតាមទៀតដែរ ។

បាតាវីយ៉ាបានស្នើសុំជំនួយអន្តរាគមន៍ពីស្ដេចសៀមៗ បានបញ្ជូននាវា១០គ្រឿងមក ក៏ប៉ុន្តែនៅពេលមកដល់មាត់ពាមទន្លេមេគង្គមិនឃើញកងនាវាហុល្លង់ នាវាសៀមទាំងអស់នោះក៏ត្រលប់ទៅវិញអស់ទៅ នៅក្នុងខែកញ្ញា ឆ្នាំ១៦៤៥ ។ ប៉ុន្មានខែក្រោយមក ព្រះរាជាកម្ពុជា បានយល់ព្រមប្រទានសន្តិភាព ដោយទ្រង់បានបញ្ជូនរាជទូតទៅកាន់បាតាវីយ៉ា នៅក្នុងខែឧសភា ឆ្នាំ១៦៤៦ ។ មកខែមេសា ឆ្នាំ១៦៤៧ ទ្រង់បានដោះលែងពួកឈ្លើយសឹកដែលទ្រង់បានចាប់ពីកប៉ាល់អូរ៉ែនហ្សេ ក៏ប៉ុន្តែបញ្ហាលំបាកនៅតែមានបន្តទៅទៀត រហូតដល់ខែកក្កដា ឆ្នាំ១៦៥២ នៅពេលដែលពួកហុល្លង់បានសំណូមពរឲ្យព្រះរាជាបញ្ជូនរាជទូតទៅចរចាសម្រេចថា

លើកចុងក្រោយ ។

នៅខែកក្កដា ឆ្នាំ១៦៥៣ ឧត្តមសេនីយ៍បាតាវីយ៉ាបានជូនដំណឹងទៅព្រះរាជាកម្ពុជាវិញថាពួកហុល្លង់មិនអាចមកបោះទីតាំងនៅលើទឹកដីកម្ពុជាជាមួយនឹងសត្រូវរបស់ខ្លួនបានទេ លើកលែងតែព្រះអង្គបណ្តេញពួកនោះចេញសិន ។ តាមពិតពួកហុល្លង់ពេលនោះកំពុងតែមានសង្គ្រាមជាមួយពួកអង់គ្លេស ដែលទើបតែបានធ្វើឃាតស្តេចរបស់គេ ។ ព្រះរាជាបានច្រានសំណើនោះ ហើយការចរចាបានបន្តរហូតដល់ខែកក្កដា ឆ្នាំ១៦៥៦ ទើបមានចុះសន្ធិសញ្ញាមួយដែលមិនមានចោទប្រកាន់ទោសកំហុសអ្វីដល់ព្រះរាជាអ៊ីប្រាហ៊ីម ឡើយ ឯពួកហុល្លង់ក៏មិនបានទទួលនូវការសងសឹកអ្វីដែរ តែបានទទួលផលប្រយោជន៍ខាងពាណិជ្ជកម្មខ្លះ ដែលពួកគេមិនអាចថែរក្សាការពារបាន[៣២] ។

មកដល់ពេលនេះ គឺក្នុងឆ្នាំ១៦៥៨ ព្រះរាជាអ៊ីប្រាហ៊ីមសោយរាជ្យបាន១៨ឆ្នាំហើយ ។ ពេលនោះមានបុត្រា២អង្គរបស់អតីតព្រះឧភយោរាជព្រះឧទ័យដែលពញាច័ន្ទ-ព្រះអ៊ីប្រាហ៊ីមបានធ្វើឃាត គឺពញាសូរ (ពញាសូរនេះ ក្រោយមកបានឡើងសោយរាជ្យមានព្រះនាមថាព្រះបទុមរាជា) មានព្រះជន្ម២៦ព្រះវស្សា និងព្រះអង្គតន់មានព្រះជន្ម១៨ព្រះវស្សា បានចាប់កាន់អាវុធបះបោរប្រឆាំងនឹងព្រះរាជាឡើង ។ ពេលនោះ ព្រះរៀមរបស់ក្សត្រាទាំង២ គឺព្រះអង្គឯម ដែលបានរួចរស់រានមានជីវិត ដោយត្រូវព្រះវររាជមាតាយកមកចិញ្ចឹមបីបាច់ថែរក្សា ហើយមានឋានៈជាព្រះកែវហ្វ៉ាមិនបានចូលដៃចូលជើងជាមួយទេ តែបែរជាកាន់ជើងខាងព្រះរាជាទៅវិញ ។

ពញាសូរ និងព្រះអង្គតន់បានត្រូវទ័ពព្រះរាជាវាយឲ្យបរាជ័យ ក៏រត់ទៅជ្រកកោននឹងព្រះមហេសីមេម៉ាយមានសញ្ជាតិអាណ្ណាមរបស់ព្រះជ័យជេដ្ឋា ដែលណែនាំឲ្យក្សត្រទាំង២រត់ទៅសុំជំនួយពីស្តេចអាណ្ណាម ។ ពេលនោះ មានប្រជាជនអាណ្ណាមជាច្រើនដែលជាជនអនាថា ជនរត់ចោលជួរ ជនមានទោសដែលត្រូវបណ្តេញចេញពីស្រុក និងជនផ្សេងៗទៀត ចូលមករស់នៅលាយឡំជាមួយអ្នកស្រុកដើមនៅក្នុងខេត្របារាជ និងដុងណាយ ។ ពេលឃើញក្សត្រខ្មែរទាំង២អង្គរត់មករកជំនួយដូច្នេះ ស្តេចអាណ្ណាម គិតថាឱកាសល្អមកដល់ ហើយក្នុងការដណ្តើមយកប្រទេសនេះ ។ អ្នកប្រវត្តិវិទូអាណ្ណាមឈ្មោះ ទ្រឿង វិញគីបានសរសេរថា ប្រទេសកម្ពុជា មានទន្លេ

---

[៣២] មានសង្គ្រាមមួយកើតឡើងនៅក្នុងឆ្នាំ១៦៥៨-៥៩ ។ ពេលនោះផ្ទះពាណិជ្ជកម្មរបស់ហុល្លង់ បានត្រូវពួកអាណ្ណាមដុតបំផ្លាញខ្ទេចខ្ទី ហើយមានពួកហុល្លង់ជាច្រើននាក់ បានត្រូវចាប់ខ្លួន និងសម្លាប់ចោល ។ អ្នកដែលគេចខ្លួនរួចបានរត់ទៅស្រុកស្រែ រួចបន្តដំណើរទៅស្រុកសៀម ទើបឆ្លងទៅបាតាវីយ៉ាបានជាមួយនឹងមេរបស់គេម្នាក់ ឈ្មោះថា ពីយែរយែទីញ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៦៥៩ ។

មានចុះសន្ធិសញ្ញាមួយទៀត នៅក្នុងថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៦៦៥ ជាមួយនឹងព្រះរាជាបទុមរាជា ។ ពីយែឃីទីញបានទទួលការអនុញ្ញាតឲ្យតាំងអគារពាណិជ្ជកម្មនៅលវែក ក៏ប៉ុន្តែពួកហុល្លង់នៅតែមិនអាចស្តារស្ថានភាពរបស់គេនៅកម្ពុជាបាន បើទោះបីជាពួកព័រទុយហ្គេ ម៉ាឡេ និងចាម លែងបានទទួលនូវការប្រោសប្រណីទៀតហើយក៏ដោយ ។

ធំៗ មានដៃច្រើន ដីស្រែក៏មានជីជាតិល្អ គួរឲ្យចង់បានណាស់ ។ ព្រះរាជាអាណ្ណាមក៏យល់ព្រមផ្តល់ជំនួយដល់ក្សត្រទាំង២[៣៣] ហើយបានបញ្ជូនទ័ព២ពាន់នាក់ដឹកនាំដោយឧត្តមសេនីយ៍ ជាផងឲ្យមកជួយ ។ សង្គ្រាមក៏ចាប់ផ្តើមឡើង ហើយព្រះអង្គឯម បុត្រាទី៣របស់ព្រះឧភយោរាជ ដែលចូលដៃចូលជើងជាមួយនឹងឃាតកសម្លាប់ព្រះបិតា ក៏ត្រូវសុគតទៅនៅក្នុងការប្រយុទ្ធមួយតាមជើងទឹកនៅបារាជ ។ រីឯព្រះរាជាវិញ ត្រូវពួកអាណ្ណាមចាប់បានជាមួយនឹងសេនាអាមាត្យ ហើយដាក់ក្នុងទ្រុងដែក នាំយកទៅកាន់ខែត្រក្វាងបិញ នៅជាប់នឹងព្រំដែនតុងកឹង ។ ទ្រង់បានសុគតនៅទីនោះនៅក្នុងឆ្នាំ១៦៥៩ ក្នុងព្រះជន្មាយុ ៤០ព្រះវស្សា ។ បើគិតទៅ ព្រះអង្គសោយរាជ្យបានប្រហែលជា ១៨ឆ្នាំ ។

ពួកអាណ្ណាមបានអះអាងថា អ្នកទោសដែលគេចាប់បានក្នុងសង្គ្រាមនោះបានត្រូវគេដោះលែងមកកម្ពុជាវិញតែនៅក្រោយពេលដែលគេបានចុះសន្ធិសញ្ញាសន្តិភាពមួយ ដែលបញ្ជាក់ច្បាស់ថាប្រទេសកម្ពុជានឹងនាំយកសួយសារអាករទៅថ្វាយស្តេចអាណ្ណាមជាទៀតទាត់ ហើយពួកប្រជាជនអាណ្ណាមដែលចូលមករស់នៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា នឹងទទួលបាននូវសិទ្ធិកម្មសិទ្ធិលើដីដែលខ្លួនកាន់កាប់ ហើយនឹងត្រូវចាត់ទុកដូចជាអ្នករដ្ឋវាសី ប៉ុណ្ណោះ ។

ការជ្រៀតជ្រែករបស់ពួកអាណ្ណាមចូលមកក្នុងរឿងរ៉ាវរបស់កម្ពុជា តាមរយៈមហាក្សត្រីមានដើមកំណើតជាអាណ្ណាមនេះ គឺជាសេចក្តីផ្តើមនៃការខុសឆ្គងដ៏វែងអន្លាយ ដែលនឹងនាំមកនូវការបាត់បង់ទឹកដីបន្តិចម្តងៗ មិនខុសពីការលុកលុយរាតត្បាតពីសំណាក់ពួកសៀមប៉ុន្មានទេ ។ ហេតុការណ៍នេះបានបញ្ចេញឲ្យឃើញនូវអ្វីដែលអាចនឹងកើតមានភ្លាមៗតែម្តង ៖ ក្រោយពីទទួលជ័យជម្នះហើយម្ចាស់ការលើសភាពការណ៍បានហើយ ឧត្តមសេនីយ៍អាណ្ណាមក៏ចាប់សាកល្បងកម្មេចក្សត្រាខ្មែរទាំង២អង្គ ជាបក្សពួកភ្លាមដែរ ។ ក៏ប៉ុន្តែ ដោយមិនអាចធ្វើអ្វីបាននៅចំពោះមុខប្រទេសទាំងមូល ណាមួយត្រូវបរាជ័យនៅក្នុងការប្រយុទ្ធជាមួយទ័ពរបស់ព្រះអង្គខ្លះផង ឧត្តមសេនីយ៍អាណ្ណាមនោះត្រូវបង្ខំចិត្តវាយដកថយ រត់ចេញពីកម្ពុជាទៅវិញ នៅក្នុងឆ្នាំ១៦៥៩ ដោយនាំយកទៅជាមួយនូវជ័យភណ្ឌជាច្រើនទៅផង ។

នៅក្នុងឆ្នាំបន្ទាប់មក ពួកសៀមដែលតែងតែគិតថាកម្ពុជាជាចំណីដ៏ឆ្ងាញ់ពិសាររបស់ខ្លួនទៅអនាគត បានបញ្ជូនរាជទូតមួយទៅកាន់រាជវាំងកែចូនៅហាណូយ សុំចងសម្ព័ន្ធមេត្រីភាពប្រឆាំងនឹងពួកវៀងនៅខាងត្បូង

---

[៣៣] រាជពង្សាវតារអាណ្ណាមបាននិយាយថា ក្សត្រាទាំង២អង្គ បានទូលថ្វាយព្រះរាជាអាណ្ណាមថា ក្សត្រាទាំង២ សុខចិត្តលះបង់រាជសម្បត្តិថ្វាយព្រះអង្គ ឲ្យតែព្រះអង្គជួយសងសឹកនឹងព្រះអង្គច័ន្ទ ដែលបានធ្វើឃាតបិតាក្សត្រាទាំង២ ។ អ្នកប្រវត្តវិទូខ្មែរមិនឯកភាពនឹងសំដីនេះទេ ហើយមានព្រះសង្ឃចាស់មួយអង្គមានសង្ឃដីកាថា សូម្បីតែព្រះរាជាដែលកំពុងតែសោយរាជសម្បត្តិក៏មិនអាចបេះតែលើកស្រុកប្រគល់ឲ្យនរណាបានតាមចិត្តនោះទេ ។

(ក្រុងវើ) ដែលទីបតែរើបម្រះរួចពីនឹមត្រួតត្រារបស់ពួកអាណ្ណាមខាងជើង ហើយបានបង្ហាញឲ្យឃើញតាមរយៈអន្តរាគមន៍លើកទី១ខាងលើថា ចង់វាកមករកដណ្តើមយកកម្ពុជាដែរ ។

## ១២- ព្រះបទុមរាជាទី៣-ពញាសូរ (១៦៥៩-១៦៧២)

ព្រះបទុមរាជពញាសូរ ជារាជបុត្រាច្បងរបស់ព្រះឧភយោរាជ ដែលស្តេចចូលសាសនាជ្វាបានធ្វើឃាត ។ ទ្រង់បានសុំជំនួយពីអាណ្ណាម តែត្រូវពួកនេះប្រុងនឹងកម្ទេចចោលទៅវិញ ។ នាម៉ឺនសព្វមុខមន្ត្រីបានលើកព្រះអង្គឲ្យទទួលការងារដឹកនាំព្រះនគរ ។ ពេលនោះព្រះអង្គមានព្រះជន្ម២៨ព្រះវស្សាហើយ[៣៤] ។

នៅពេលនោះពួកចាម និងម៉ាឡេ នៅក្នុងខែត្រត្បូងឃ្មុំ ដែលធ្លាប់បានបះបោរម្តងរួចមកហើយនៅក្នុងឆ្នាំ១៥៩៩ មិនសប្បាយចិត្តនឹងភាពក្រឡាប់ចាក់ក្រោយពីព្រះរាជាអ៊ីប្រាហ៊ីមបានត្រូវធ្វើឃាតដែលធ្វើឲ្យបាត់បង់ផលប្រយោជន៍ខ្លួនអស់ ក៏បះបោរឡើងម្តងទៀត ក្នុងរវាងឆ្នាំ១៦៦០ ។ ព្រះរាជាបានដឹកនាំទ័ពផ្ទាល់ព្រះអង្គចេញទៅបង្ក្រាបពួកនេះ ឲ្យបរាជ័យ រត់គេចកាត់ខែត្រកំពង់ស្វាយរហូតទៅដល់ខែត្រអង្គរ តែត្រូវទ័ពព្រះរាជាតាមដេញវាយប្រហាររហូត ហើយតម្រូវចុះអនុសញ្ញាមួយបង្ខំឲ្យពួកមេៗរបស់ពួកនោះភៀសខ្លួនទៅរស់នៅឯស្រុកសៀមទៅ ។

រាជបុត្រាទាំងអស់របស់ព្រះរាជាចោលសាសនា គឺព្រះអង្គនី ព្រះអង្គឧទ័យ និងព្រះអង្គអំ ក៏បាននាំគ្នាធ្វើដំណើរទៅរស់នៅឯស្រុកសៀមដែរ ជាមួយនឹងស្រីស្នំក្រមការទាំងអស់របស់រាជវាំងមុន មានទាំងព្រះសង្ឃផងសរុបទាំងអស់ ២,២២៤នាក់ ។

ដោយត្រូវធ្វើឲ្យធូរស្រាលពីសត្រូវ -មានពួកចាម ម៉ាឡេ និងរាជបុត្ររបស់អតីតព្រះមហាក្សត្រ និងបក្សពួក ព្រះបទុមរាជាពញាសូរក៏ចាប់កាន់ព្រះខ័នរាជ្យឡើងគង់លើបល្ល័ង្ករាជ ទទួលព្រះរាជាភិសេកនៅក្នុងឆ្នាំ១៦៦២ ក្រោមព្រះនាមថា ព្រះបាទសម្តេចស្តេចព្រះរាជឱង្ការបរមរាជាធិរាជរាមាធិបតីបរមបពិត្រ ។

នៅក្នុងឆ្នាំ១៦៦១ ទ្រង់បានលើកព្រះអនុជ គឺព្រះអង្គតន់ ឲ្យឡើងជាឧភយោរាជ ប្រហែលដើម្បីបំបែកព្រះអនុជចេញឲ្យឆ្ងាយពីរាជបល្ល័ង្កឲ្យហើយ ហើយទ្រង់បានទទួលព្រះនាងអង្គឡី ជាបងប្អូនជីដូនមួយ ធ្វើជាព្រះអគ្គមហេសី មានព្រះនាមថា សម្តេចព្រះភគវតីព្រះបមក្សត្រីយ៍ ។

នៅក្នុងខែកក្កដា ឆ្នាំ១៦៦១នោះ មានជនបារាំងម្នាក់ឈ្មោះ លុីសឺវ្រីយ បានធ្វើដំណើរពីស្រុកសៀមមក

[៣៤] មានឯកសារមួយនិយាយថា ព្រះអង្គជាព្រះរាជបុត្រារបស់មហេសីមួយអង្គព្រះនាមថា នាងសួស ហើយទ្រង់ប្រសូត្រនៅក្នុងឆ្នាំ១៦២៨ ។ ឯកសារមួយទៀតថាទ្រង់ ប្រសូត្រនៅក្នុងឆ្នាំ១៦៣១ ចំណែកឯកសារដែលខ្ញុំមានថាប្រសូត្រឆ្នាំ១៦២១ និងមានព្រះជន្ម ៣៨ព្រះវស្សា នៅពេលទ្រង់ឡើងសោយរាជ្យ ។

តាំងទីនៅត្រង់បាសាក់ ក្បែរស្វាយរៀង ក្នុងនាមជាសាសនទូតរបស់ក្រុមនិកាយផ្សព្វផ្សាយជំនឿ ហើយបាន បង្កើតនិគមកាតូលិកអាណ្ណាមមួយនៅទីនោះ បានមួយរយៈ ។ បីឆ្នាំក្រោយមក លុីសីវ្រឹយ បានផ្ញើរសំបុត្រនៅក្នុង សារលិខិតមួយផ្ញើទៅស្រុកបារាំង ថាគាត់មិនអាចបញ្ចុះបញ្ចូលឲ្យអ្នកស្រុកអាយណាម្នាក់ប្ដូរមកកាន់សាសនា កាតូលិកបានទេ ។ នៅពេលដែលគាត់មកពញាញ្ញប៉ុន្មានឆ្នាំក្រោយមកទៀត គាត់បានឃើញថា នៅទីនេះមានអ្នក កាន់សាសនាកាតូលិកប្រហែល៤០០នាក់ ក្នុងនោះមានចម្រុះពួកចិន ព័រទុយហ្គេ និងអាណ្ណាម ដែលគាត់ហៅថា ជាពួកកូសាំងស៊ីន ។

នៅឆ្នាំ១៦៧១ ព្រះស្រីជ័យជេដ្ឋា ជារាជបុត្រារបស់ព្រះបទុមវង្សរាជាដែលត្រូវព្រះរាជាចោល សាសនាធ្វើឃាត ហើយក៏ត្រូវជាព្រះភាគិនេយ្យរបស់ព្រះរាជា និងជាព្រះរាជបុត្រាថ្លៃរបស់ព្រះរាជាផងដែរ បានក្បត់នឹងព្រះរាជា ហើយនាំឲ្យពួកបេសកជនធ្វើឃាតព្រះរាជាចោលទៅ ។

ព្រះឧភយោរាជគន់ និងព្រះអង្គនូក៏រត់គេចខ្លួនទៅកូសាំងស៊ីន សុំជំនួយពីពួកអាណ្ណាម ដូចដែលព្រះ ឧភយោរាជ និងព្រះរាជាទើបសុគតធ្លាប់បានធ្វើរួចម្ដងមកហើយក្នុងឆ្នាំ១៦៥៨ ។

## ១៣- ព្រះបាទជ័យជេដ្ឋាទី៣-ធម្មោសុរិយោវង្ស (១៦៧២-១៦៧៣)

ស្ដេចនេះជារាជបុត្ររបស់ព្រះអង្គនន់ និងត្រូវជាព្រះរាជនត្តារបស់ព្រះឧភយោរាជឧទ័យ ដែលបានត្រូវ គេធ្វើឃាតនៅឧត្ដុង្គកាលពីឆ្នាំ១៦៤២ ។ ព្រះអង្គទើបតែបានឃុបឃិតធ្វើឃាតព្រះរាជាមុនរួចដែរ រួចហើយ បានចាប់កាន់អំណាចភ្លាម និងបានឲ្យគេរៀបចំអភិសេកព្រះអង្គក្រោមព្រះនាមថា ព្រះធម្មោសុរិយោវង្សរាជា ធិរាជបរមបពិត្រ ។ ពេលនោះព្រះអង្គមានព្រះជន្មាយុ៣៣ព្រះវស្សាហើយ ។ ព្រះអង្គបានចាប់បង្ខំព្រះអគ្គ មហេសីរបស់ព្រះរាជាដែលទ្រង់បានធ្វើឃាត គឺសម្ដេចព្រះភគវតីព្រះចមក្សត្រីយ៍ ឲ្យទទួលធ្វើជាព្រះអគ្គមហេសី របស់ព្រះអង្គដែរ ប៉ុន្ដែព្រះចមក្សត្រីយ៍ បានធ្វើការសងសឹកនឹងព្រះអង្គវិញ ដោយនាំពួកម៉ាឡេជាកូនចៅដែល ធ្លាប់គាំទ្រព្រះរាជាអុីប្រាហុីម ឲ្យមកធ្វើឃាតព្រះរាជា ៥ខែក្រោយពីអភិសេករួច ។ តែឃាតកម្មនេះមិនបាន ប្រគល់រាជសម្បត្តិទៅឲ្យព្រះរាជវង្សរបស់ព្រះរាជាចោលសាសនាវិញទេ ។

## ១៤- អ្នកអង្គជ័យ (១៦៧៣-១៦៧៤)

ព្រះកែវហ៊្វាអ្នកអង្គជ័យ ជារាជនត្តារបស់ព្រះឧទ័យយោមរាជធំ និងជារាជបុត្រារបស់ព្រះរាជាបទុម រាជាអង្គសូរ[៣៥] ដែលមានព្រះជន្មាយុ២១ព្រះវស្សាហើយ បានត្រូវនាម៉ឺនសព្វមុខមន្ត្រីលើកឲ្យឡើងកាន់អំណាច

[៣៥] ព្រះរាជាអង្គនេះបានត្រូវព្រះរាជាមុន គឺព្រះជ័យជេដ្ឋា ធ្វើឃាតនៅក្នុងឆ្នាំ១៦៧២ ។

ក្រោមព្រះនាមថា សម្តេចព្រះកែវហ្វ៊ា គឺថាជាព្រះរាជាដែលមិនបានទទួលការអភិសេក ។

នៅឆ្នាំបន្ទាប់មក ព្រះឧភយោរាជអង្គតន់ និងព្រះអង្គនន់ ដែលបានរត់ភៀសព្រះកាយទៅជ្រកកោននឹងពួកអាណ្ណាមក្រោយព្រឹត្តិការណ៍មានឃាតកម្មទៅលើព្រះរាជាបទុមរាជា បានចូលលុកលុយប្រទេសពីខាងត្បូងមកនិយាយថាមិនមែនមកដណ្តើមអំណាចអ្វីទេ គ្រាន់តែចង់សងសឹកនឹងព្រះរាជា ដែលបើតាមពិតទៅ គ្មានមូលហេតុអ្វីនឹងមកសងសឹកសោះ ពីព្រោះថាអ្នកអង្គជ័យនេះមិនមែនជារាជវង្សខាងព្រះរាជាអ៊ីប្រាហ៊ីមឯណា ។ ព្រះឧភយោរាជ បាននាំទ័ពអាណ្ណាមយ៉ាងធំមកជាមួយ ហើយធ្វើសង្គ្រាមពេញ១ឆ្នាំ ។ ព្រះរាជាបានដឹកនាំទ័ពចេញប្រយុទ្ធនឹងទ័ពព្រះឧភយោរាជ ហើយត្រូវសុគតនៅមុខកងទ័ពនោះទៅ[៣៦] ។ ទ្រង់បានសោយរាជ្យមិនបាន៣ឆ្នាំផងទេ ។

ពេលនោះ ព្រះឧភយោរាជអង្គតន់ ដែលមានព្រះជន្ម៩១ព្រះវស្សាហើយ បានអាពាធហើយសុគតទៅដែរ ។ ដូច្នេះនៅសល់តែព្រះអង្គនន់មួយអង្គឯងប៉ុណ្ណោះ ។

## ១៥- រយៈកាលចន្លោះរាជ្យ-ព្រះឧភយោរាជអង្គនន់ (១៦៧៤-១៦៧៥)

ស្តេចនេះជាបុត្រារបស់ព្រះអង្គឯម ដែលបានគាំទ្រព្រះរាជាចោលសាសនាប្រឆាំងនឹងព្រះអនុជទាំង២ ដែលបានរត់ទៅសុំជំនួយពីស្តេចកូសាំងស៊ីន ។ ទ្រង់បាននាំព្រះរាជវង្សមកគង់នៅឯរាជធានីឧត្តុង្គវិញ ហើយក៏ចាប់កាន់កាប់អំណាចក្នុងព្រះនាមថា សម្តេចបទុមរាជាឧភយោរាជ គឺទ្រង់មិនគ្រងរាជ្យទេ ។ មានឯកសារខ្លះនិយាយថា ទ្រង់មានព្រះឋានៈជាសម្តេចព្រះកែវហ្វ៊ា ។ ការដែលទ្រង់ប្រកាន់យកព្រះឋានៈជា ព្រះឧភយោរាជនេះ គឺដើម្បីឲ្យស្របទៅនឹងព្រះរាជបន្ទូលដែលទ្រង់បានប្រកាសពីមុនមកថា ទ្រង់មិនមែនមកប្រយុទ្ធដើម្បីរាជបល្ល័ង្កនោះទេ គឺដើម្បីតែការសងសឹកប៉ុណ្ណោះ ។

ព្រះអង្គនន់កាន់អំណាចមិនបានទាំង៥ខែផង ព្រះអង្គសូរដែលត្រូវជារាជបុត្ររបស់ព្រះបទុមរាជា ដែលសុគតទៅ ហើយត្រូវជាព្រះអនុជរបស់សពអ្នកអង្គជ័យ ដែលពេលនោះមានព្រះជន្ម១៨ព្រះវស្សាហើយ បានប្រមែប្រមូលកងទ័ពប្រឆាំងនឹងព្រះឧភយោរាជអង្គនន់ ។ ព្រះអង្គសូរបានទទួលជោគជ័យល្អបន្តរ ធ្វើឲ្យព្រះឧភយោរាជទ្រាំមិនបានក៏រត់គេចខ្លួនទៅនៅឯកូសាំងស៊ីន ក្បែរភ្នំដឹកា (ត្រង់ព្រំប្រទល់ដែនកម្ពុជា-អាណ្ណាមបច្ចុប្បន្ន) នៅប្រាំតម្លឹង ។ បន្តិចក្រោយមករាជវង្សានុវង្សរបស់ព្រះអង្គ ក្នុងនោះមានស្រីស្នំម្នាក់ដែលមានដើមកំណើតជាចិន បាននាំគ្នារត់មករស់នៅជាមួយព្រះអង្គដែរ ។

---

[៣៦] មានឯកសារមួយទៀតនិយាយថាទ្រង់ត្រូវបរាជ័យ ក៏ភៀសព្រះអង្គទៅគង់នៅឯស្រុកប្រាំដំឡឹង ក្នុងខែត្រសំរោងទង ហើយសុគតនៅទីនោះដោយសារជំងឺ ។

## ១៦- ព្រះជ័យជេដ្ឋាទី៤-ព្រះអគ្គសូរ រជ្ជកាលទី១ (១៦៧៥-១៦៨៨)

ព្រះអគ្គសូរពេលនោះ មានព្រះជន្ម១៩ព្រះវស្សាហើយ ។ កាលពីឆ្នាំកន្លងទៅ ទ្រង់បានទាមទារយកអំណាចដែលព្រះអគ្គត្រូវទទួលបន្តពីព្រះអគ្គជ័យជាព្រះរៀម ដែលបានសុគតនៅក្នុងការប្រយុទ្ធជាមួយនឹងព្រះអគ្គតន់ និងព្រះអគ្គនន់ ។ នៅពេលដែលព្រះអគ្គនន់រត់ភៀសព្រះកាយទៅនៅឯកូសាំងស៊ីន ព្រះអគ្គសូរក៏ចូលកាន់អំណាចនៅក្នុងឆ្នាំ១៦៧៥ ហើយបានឲ្យគេអភិសេកព្រះអគ្គនៅរាជធានីឧត្តុង្គក្រោមព្រះនាមថា សម្ដេចព្រះជ័យជេដ្ឋាបរមសុរិន្ទ្រធិរាជ ។ ទ្រង់បានលើកអ្នកព្រះអគ្គនន់ ជាបងប្អូនជីដូនមួយឲ្យឡើងជាព្រះឧភយោរាជ ។

នៅក្នុងឆ្នាំបន្ទាប់ ព្រះរាជាបានយាងមកគង់នៅទ្រនំជ្រីងក្នុងខែត្រសំរោងទង ហើយបានបញ្ជាឲ្យគេសង់រាជវាំងមួយថ្វាយ ។

នៅសម័យនោះ ប្រហែលជាក្នុងរវាងឆ្នាំ១៦៨០ មានឧត្តមសេនីយ៍ចិនម្នាក់ខាងរាជវង្សមិញឈ្មោះថា ឌួងង៉ានឌីច ក្រោយពីច្បាំងចាញ់កងទ័ពរបស់ខាងហ៊ី -អ្នកកសាងសន្តតិវង្សថាញ់- បាននាំទ័ពដែលនៅសល់ចុះសំពៅ២០០ ធ្វើដំណើរមកអាណ្ណាម ។ ប៉ុន្តែខ្យល់ព្យុះបក់បោកលិចសំពៅអស់ សល់តែសំពៅ៥០ និងទ័ព៣ពាន់នាក់ប៉ុណ្ណោះដែលអាចឡើងគោកបាន ក៏នាំគ្នាមកសុំចុះចូលនឹងស្ដេចអាណ្ណាមនៅនឹងទូរ៉ានតែម្ដង ហើយសំណូមពរសុំដីធ្លីដើម្បីរស់នៅ ។ ស្ដេចអាណ្ណាមមិនចង់រក្សាពួកបរទេស៣ពាន់នាក់នេះឲ្យនៅជិតខ្លួនព្រះអង្គទេ ក៏បញ្ជូនឲ្យមករស់នៅក្នុងកម្ពុជាវិញ ដោយថ្វាយដំណឹងដល់ ព្រះជ័យជេដ្ឋា បានជ្រាបផងដែរ គឺឲ្យនៅខែត្របារាជ និងដុងណាយ ដែលមានពួកអន្តោប្រវេសន៍អាណ្ណាមចូលមករស់នៅច្រើនបន្តរួចទៅហើយ ហើយបានចាត់ទុកថា នេះគឺជាទឹកដីដែលខ្លួនដណ្ដើមបាន ។ ឧត្តមសេនីយ៍ឌួងង៉ានឌីច មិនសប្បាយចិត្តនឹងទឹកដីដែលគេបានធ្វើសម្បទានឲ្យរស់នៅទេ ក៏នាំទ័ពពាក់កណ្ដាលទៅរស់នៅឯមីថវិញ ទុកឲ្យមេបញ្ជាការរងឈ្មោះ ត្រាន់ រស់នៅនឹងបារាជ ជាមួយនឹងទ័ពពាក់កណ្ដាលទៀត ។

ពួកចិនទាំងអស់នេះត្រូវរ៉ូវគ្នាជាមួយនឹងពួកអាណ្ណាមណាស់ ព្រោះជាអ្នកមកពីក្រៅដូចគ្នា ប៉ុន្តែមិនសូវត្រូវគ្នាជាមួយពួកខ្មែរទេ ជាពិសេសជាមួយអាជ្ញាធរខ្មែរដែលគ្រប់គ្រងទឹកដីក្នុងនាមព្រះរាជាកម្ពុជា ។ ម្យ៉ាងទៀតពួកនេះចូលចិត្តបង្កចលាចលយ៉ាងខ្លាំង មិនចូលចិត្តធ្វើការងារ ហើយមិនចង់គោរពច្បាប់ទម្លាប់របស់ព្រះរាជាណាចក្រលើសពីពួកអាណ្ណាមទៅទៀត ។ គេរស់នៅជាកង មិនមែនជាអ្នកស្រុកសមទៅតាមអត្ថន័យរបស់ពាក្យនេះទេ ហើយហាក់ដូចជាចូលចិត្តនឹងការធ្វើសង្គ្រាមជាជាងរស់នៅក្នុងសន្តិភាពដូចនៅកម្ពុជានេះ ។

គឺដោយហេតុនេះហើយបានជានៅពេលដែលព្រះអគ្គនន់ធ្លាក់ចេញពីអំណាច ទ្រង់បានសម្រេចព្រះទ័យចាប់ផ្ដើមធ្វើការប្រយុទ្ធតបតទៅនឹងព្រះអគ្គសូរឡើងវិញនៅក្នុងឆ្នាំ១៦៨២ បើទោះបីថាព្រះអគ្គសូរ ធ្លាប់បានលើកទ្រង់ឲ្យឡើងជាទីឧភយោរាជហើយក៏ដោយ ក៏ព្រះអគ្គនន់បានមកទាក់ទងនឹងពួកចិនខាងលើនេះ ដែលមានមេកងឈ្មោះថា បាងកន ឲ្យធ្វើជាស្នូលនៃកងទ័ពមួយដ៏រឹងមាំដែរ ។ ព្រះអគ្គបានទទួលយកពួកចាម ដែលកំពុងតែ

រត់គេចខ្លួនពីស្រុកទេសមក ឲ្យចូលក្នុងកងទ័ពរបស់ព្រះអង្គថែមទៀត ។ បន្ទាប់មកទ្រង់ក៏ចាប់វាយដណ្តើមយកខែត្របាសាក់ ព្រះត្រពាំង ភ្នំពេញ និងឧត្តុង្គ ។

ព្រះជ័យជេដ្ឋាព្រះអង្គសូរ ពេលនោះមិនបានគិតថានឹងមានកើតសង្គ្រាមដូច្នោះទេ ម្ល៉ោះហើយគ្មានប្រុងប្រៀបអ្វីនឹងទប់ទល់ឡើយ ។ នៅពេលដែលកងទ័ពរបស់ព្រះអង្គនន់ធ្វើដំណើរចេញពីភ្នំពេញ ដែលកាលនោះមានឈ្មោះថា ចតុម្មុខមក ទ្រង់ក៏ភៀសព្រះកាយទៅគង់នៅឯទូនំជ្រីងក្នុងខែត្រសំរោងទង ដែលទ្រង់បានចាត់ឲ្យគេសង់ព្រះរាជដំណាក់មួយថ្វាយពីមុនរួចហើយ ។ បន្តិចក្រោយមកទើបទ្រង់យាងចេញពីទូនំជ្រីងមកវិញជាមួយនឹងទ័ពមួយកងដែលទ្រង់កេណ្ឌបានពីបណ្តាខែត្រនៅតំបន់នោះ រួមជាមួយទ័ពជំនួយរបស់សៀមមួយកង ដែលស្តេចសៀមបានបញ្ជូនឲ្យមកជួយ ។ ទ័ពរបស់ព្រះអង្គបានវាយទ័ពព្រះឧភយោរាជឲ្យបរាជ័យ ពួកចិនរត់ចោលអស់ ព្រះឧភយោរាជក៏គេចខ្លួនព្រះអង្គទៅគង់នៅឯកោះគេង (គឺកោះគូឡាវយាងសព្វថ្ងៃ) ហើយលាក់ខ្លួននៅទីនោះទៅ នៅឆ្នាំ១៦៨៤ ។

ព្រះរាជាក៏យាងត្រលប់ពីទូនំជ្រីង មកគង់នៅឧត្តុង្គវិញ (ឆ្នាំ១៦៨៥) ។ ក្នុងពេលនោះ ព្រះឧភយោរាជក៏បានយាងមកគង់នៅក្នុងខែត្រស្រីសន្ធរ ហើយបានឲ្យគេសង់បន្ទាយការពារមួយនៅទីនោះ ។

នៅក្នុងឆ្នាំបន្ទាប់មកទៀត ព្រះឧភយោរាជ បានទទួលទ័ពសៀមមួយកងពីព្រះរាជាអយុធ្យា ដែលតែងតែចង់ដុតភ្លើងសង្គ្រាមស៊ីវិលឲ្យឆេះរោលរាលនៅកម្ពុជា ទ័ពនោះមកតាមជើងគោកផង និងតាមជើងទឹកផង ។ ទ្រង់បានប្រមូលទ័ពចិន និងទ័ពខ្មែររបស់ព្រះអង្គបញ្ចូលជាមួយគ្នា រួចបានចាប់បើកការប្រយុទ្ធជាថ្មី វាយសម្រុកមកដល់ភ្នំពេញនៅដើមឆ្នាំ១៦៨៤ ។ ព្រះរាជាជ័យជេដ្ឋាអង្គសូរបានដឹកនាំទ័ពចេញទៅប្រយុទ្ធ ទប់ទល់ វាយទ័ពព្រះឧភយោរាជឲ្យបរាជ័យ បង្ខំឲ្យព្រះឧភយោរាជដកថយទៅស្រីសន្ធរដែលរាជពង្សាវតារ ២ច្បាប់នៅតែហៅស្រីសឈរតាមឈ្មោះដើមដដែល ។ ក្រោយបរាជ័យនេះ ព្រះឧភយោរាជអង្គនន់ បានបញ្ជូនរាជទូតទៅសុំជំនួយបន្ថែមពីស្តេចសៀម ។ គឺរាជទូតរបស់ព្រះអង្គនន់នេះឯង ដែលពួករាជទូតរបស់ស្តេច លូី ទី១៤ បានជួបនៅអយុធ្យាក្នុងឆ្នាំ១៦៨៥ ហើយនិយាយថាមានតែព្រះភាគិនេយ្យរបស់ព្រះឧភយោរាជមួយអង្គទេក្នុងចំណោមពួកបរទេសទាំងអស់ ដែលមានសិទ្ធិទទួលព្រះរាជសង្ហាមាស ។ លោក ដឺសូម៉ុង បាននិយាយថា រជ្ជទាយាទកម្ពុជាមួយអង្គដែលបានភៀសព្រះអង្គមកគង់នៅស្រុកសៀម បានសំណូមពរស្តេចសៀមឲ្យជួយព្រះអង្គបានគង់លើរាជបល្ល័ង្កវិញ ហើយលោកបានបន្ថែមទៀតថា សៀមបានធ្វើអន្តរាគមន៍រួចមកហើយកាលពីពេលថ្មីៗនេះ ។

នៅក្នុងឆ្នាំ១៦៨៧ ព្រះរាជាជ័យជេដ្ឋាអង្គសូរ បានជាសះស្បើយពីជំងឺអុតធំដែលស្ទើរតែធ្វើឲ្យព្រះអង្គក្ស័យព្រះជន្ម ។ ទ្រង់បានដាក់រាជសម្បត្តិថ្វាយព្រះមាតា ដើម្បីយាងសាងផ្នួស៧ថ្ងៃ លាបំណន់ដែលបានបន់ស្រន់នៅពេលទ្រង់អាពាធ ។

នៅឆ្នាំ១៦៨៨ សម្តេចចៅពញាកន និងចិនម្នាក់ឈ្មោះថា គាងចុងស៊ា ឯកសារមួយទៀតថាឈ្មោះ កាន

ចុងអ៊ា មានបំណងទម្លាក់ព្រះរាជាពីរាជបល្ល័ង្ក ក៏នាំគ្នាទៅស្រីសន្ធរសុំទ័ព និងអាវុធយុទ្ធភណ្ឌពីព្រះឧភយោរាជ រួចនាំគ្នាមកឈរជើងនៅភ្នំពេញ ។ ពួកនេះហៀបតែនឹងចេញដំណើរទៅឧត្តុង្គទៅហើយ ស្រាប់តែទ័ពព្រះរាជាមកដល់មុន ហើយបើកការប្រយុទ្ធមកលើ ធ្វើឲ្យពួកនេះភ្ញាក់ខ្លួនភ័យរត់គេចអស់ទៅដោយចោលអាវុធ និងសំពៅ ២ គ្រឿងនៅលើសមរភូមិ ។ ក្មួយស្រីម្នាក់របស់សម្ដេចពញាកនឈ្មោះ អ្នកអង្គអី ដែលនៅក្នុងសំពៅមួយ ក៏ត្រូវព្រះរាជាចាប់បានជាឈ្លើយ ហើយទទួលយកធ្វើជាព្រះជាយាប៉ុន្មានខែក្រោយមក ។

នៅក្នុងឆ្នាំនោះ ក្រោយពីទ្រង់កាន់អំណាចអស់ពេល ១៨ឆ្នាំ ព្រះរាជាក៏បង្គាប់ឲ្យគេរៀបចំអភិសេកព្រះអង្គក្រោមព្រះនាមថា សម្ដេចព្រះជ័យជេដ្ឋាបរមោសុរិន្ទរាជាធិរាជរាមា ។

ហើយនៅក្នុងឆ្នាំដដែល ព្រះឧភយោរាជអង្គនន់ ក្រោយពីមិនបានទទួលជំនួយអ្វីពីពួកសៀម ព្រះអង្គក៏យាងទៅកាន់កូសាំងស៊ីន (អតីតនគរចាម្ប៉ា) ដើម្បីសុំជំនួយពីស្ដេចហ៊ានវៀង[៣៧] បានទ័ព៣២ម៉ឺននាក់បញ្ជាដោយឧត្ដមសេនីយ៍អាណ្ណាមឈ្មោះ អុងផានយួន និងអុងធុមម្ង ។ ទ្រង់បានដឹកនាំទ័ពនេះរហូតមកដល់រាជធានីឧត្តុង្គ ។

ទ័ពអាណ្ណាមរបស់ព្រះឧភយោរាជវាយដណ្ដើមយករាជធានីបាន រួចហើយបានកៀរអ្នកស្រុកកំពង់ហ្លួង និងបន្ទាយលើយកមកដាក់នៅជ្រោយចង្វាពីមុខភ្នំពេញ ។ សម្ដេចព្រះទាវជាព្រះមាតុច្ឆារបស់ព្រះរាជា ព្រះជន្ម ១៥ ព្រះវស្សា ក៏ស្ថិតនៅក្នុងចំណោមអ្នកស្រុកទាំងនោះដែរ ។ ចំណែកឯព្រះរាជាជ័យជេដ្ឋា បានគេចព្រះអង្គទៅឯស្រុកប្រាំតម្លឹង រួចហើយបានចាត់ឲ្យចៅពញាភក្ដីសង្គ្រាមស្ទួសតាមមករកព្រះមាតុច្ឆាយកទៅវិញ ។ ទ្រង់បានប្រទានចិញ្ចៀនមួយវង់ដើម្បីឲ្យសម្ដេចព្រះទាវជឿទុកចិត្ត រួចហើយចៅពញាភក្ដី ក៏ចេញដំណើរមកជាមួយអ្នកបម្រើម្នាក់ឈ្មោះ អាគោ នៅថ្ងៃអាទិត្យពេញបូណ៌ខែផល្គុណ (ចុងខែកុម្ភៈ) ។ មកដល់ស្ទឹងខកញ៉ាហ្លួង ពេលព្រលប់ ចៅពញាភក្ដី ក៏ហែលទឹកឆ្លងកាត់ទៅជ្រោយចង្វា ចូលគាល់ព្រះក្សត្រីបង្ហាញព្រះទម្រង់ ហើយយាងព្រះនាងមកភ្លាមតែម្ដង ។ ចៅពញាភក្ដីដាក់ព្រះក្សត្រីនៅលើស្មា រួចហែលទឹកឆ្លងទន្លេមកវិញ ឯអាគោក៏ហែលចម្លងភីលៀងព្រះនាងមកដែរ ។ ហែលមកដល់ត្រើយម្ខាង ចៅពញាភក្ដីធ្វើអង្រឹងសែងព្រះក្សត្រី រួចចេញដំណើរបន្តទៀតដោយមិនឲ្យនរណាឃើញទាន់ ។ មកដល់ទំនប់ព្រះទេព រួចមកដល់លំហាច ជាកន្លែងដែលព្រះរាជាទ្រង់រង់ចាំព្រះមាតុច្ឆា និងសេនាអង់អាចក្លាហាន ជាមួយនឹងសេនាហែហមមួយកង និងដំរីជាច្រើន ។ ព្រះក្សត្រីយាងគង់លើដំរីមួយក្បាលរហូតមកដល់ប្រាំតម្លឹង ។

ពេលទ្រង់ជ្រាបអំពីការបាត់ខ្លួនរបស់សម្ដេចទាវ ព្រះឧភយោរាជអង្គនន់បានចាត់ឲ្យទ័ពអាណ្ណាម ៥ពាន់នាក់ធ្វើដំណើរដេញតាម ។ ទ័ពអាណ្ណាមមកជួបជាមួយទ័ពរបស់ព្រះរាជា ដែលដឹកនាំដោយចៅពញាភក្ដីសង្គ្រាម

---

[៣៧] ស្ដេចអាណ្ណាមនេះ សុគតនៅក្នុងឆ្នាំ១៦៨៨ ។

នៅត្រង់វាលហុង ក៏ត្រូវទ័ពព្រះរាជាវាយឲ្យបរាជ័យរត់ត្រលប់ទៅជ្រោយចង្វារវិញ ។ ឃើញទ័ពអាណ្ណាមបាក់រត់គ្មានសណ្ដាប់ធ្នាប់ដូច្នេះ ទ័ពព្រះរាជាក៏ដេញតាមវាយរហូត រួចឆ្លងក្បូនឡើងវាយយកបានបន្ទាយជ្រោយចង្វារ ។

ពេលនោះទ័ពអាណ្ណាមភិតភ័យខ្លាំងណាស់ បែកបាក់ខ្ចាត់ខ្ចាយ រត់នាំមេកោយរបស់គេ និងព្រះឧភយោរាជ យកទៅដល់កូសាំងស៊ីនវិញដោយលំបាក ។ អ្នកស្រុកខត្តុង្គ និងកំពង់លែងក៏វិលត្រលប់ពីជ្រោយចង្វារមកទីលំនៅរៀងៗខ្លួនវិញ ។

ពេលនោះសម្ដេចទាវក្សត្រីបានស្នើសុំព្រះរាជាឲ្យយាងជាមួយព្រះនាង សាដានត្រលប់តាមផ្លូវ ដែលព្រះនាងរត់គេចជាមួយចៅពញាភក្ដី ដើម្បីពិនិត្យមើលទីកន្លែងដែលព្រះអង្គបានឈប់សម្រាកលាក់ខ្លួន រួចទ្រង់បានឲ្យគេសង់វត្តអារាមទុកជាអនុស្សាវរីយ៍ ។ វត្តទី១គឺវត្តកានឡាល សង់នៅលើទួលប្រាំតម្លឹង ជាទីកន្លែងដែលព្រះរាជាបាននាំព្រះនាងទៅដល់ក្រោយពីគេចព្រះអង្គរួចមក ។

ដោយយាងបន្តមកទៀត ឈប់មើលគ្រប់ទីកន្លែងដែលបានឈប់សម្រាក រហូតមកដល់ព្រៃពួន ជាទីកន្លែងដែលព្រះក្សត្រីត្រូវពួនលាក់ខ្លួន កុំឲ្យពួកអ្នកដែលតាមមករកព្រះនាងឃើញ ។ ព្រះរាជា ក្រោយពីព្រះសណ្ដាប់ដំណើររឿង ឃើញថាព្រះនាងគេចផុតពីគ្រោះថ្នាក់ដោយអព្ភូតហេតុ ទ្រង់ក៏បញ្ជាឲ្យកសាងវត្តមួយនៅទីនោះ ។ ទ្រង់បានលើកចៅពញាភុកឲ្យឡើងជាទីឧកញ៉ាធម្មា រួចប្រគល់ភារកិច្ចឲ្យសាងសង់វត្តនេះ និងជីកស្រះទឹកធំមួយផង ។

នៅពេលនោះ មានលេចពាក្យចចាមអារាមមិនល្អចំពោះព្រះរាជា និងព្រះក្សត្រី ពាសពេញព្រះរាជាណាចក្រ ដោយចោទថា ហេតុតែព្រះរាជាយកព្រះទ័យទុកដាក់នឹងព្រះមាតុច្ឆាក្មេងយ៉ាងនេះ ពីព្រោះព្រះនាងបានសហាយស្មន់ជាមួយព្រះរាជា ។ ព្រះក្សត្រី ដែលកំពុងតែគ្រងព្រះពស្ត្រាតាមរបៀបអ្នកស្រុក ទ្រង់ខ្ញាល់ខ្លាំងណាស់ ហើយបានដេរប្រទេចផ្ដាសាតបតទៅអ្នកដែលបាននិយាយប្រហារព្រះនាងវិញថា ៖ «អ្នកណាក៏ដោយ ទោះជាមន្ត្រីថ្នាក់ណាក៏ដោយ ឬក៏ជាប្រជារាស្ត្រក៏ដោយ ដែលបានសង្ស័យមកលើរូបខ្ញុំ និយាយមិនល្អពីអតីតកាលរបស់ខ្ញុំ សូមឲ្យអ្នកទាំងអស់នោះស្លាប់ទៅហើយធ្លាក់ចុះនរកដ៏សែនជ្រៅ កុំឲ្យព្រះពុទ្ធលោកប្រោសបាន» ។

## - រយៈកាលចន្លោះរាជ្យ (១៦៨៨)

វត្តព្រៃពួនកសាងរួចក៏រៀបចំពិធីបញ្ចុះសីមា ពិធីនោះបានធ្វើឲ្យព្រះរាជាទ្រង់នឹកឃើញកាលគ្រងចីវរ ៧ថ្ងៃក្រោមម្លប់ព្រះរតនត្រ័យ ទ្រង់ក៏សម្រេចព្រះទ័យបោះបង់រាជសម្បត្តិសាងព្រះផ្នួសម្ដងទៀត ។ ព្រះអង្គបានដាក់រាជសម្បត្តិថ្វាយចៅពញាយ៉ង ត្រូវជាចៅក្មួយ ព្រះជន្ម២២ព្រះវស្សា ដែលបួសជាភិក្ខុ ឯព្រះក្សត្រីក៏បួសជាដូនជី ក្នុងវត្តព្រៃពួននោះដែរ ។

ក្សត្រទាំង២អង្គគង់នៅក្នុងវត្តនេះប្រហែលជា៣ខែ រហូតដល់ចេញវស្សា ទើបចាកលាសិក្ខាបទមកវិញ ។ ព្រះរាជាបានយកអំណាចមកកាន់ជាថ្មី ឯព្រះក្សត្រីបានឡើងជាព្រះក្សត្រីឯកនៅក្នុងព្រះរាជវាំង ។

## ១៨- ព្រះជ័យជេដ្ឋា រជ្ជកាលទី២ (១៦៨៨)

ក្រោយពីលាចាកសិក្ខាបទ ព្រះរាជា និងព្រះវររាជមាតុច្ឆាបានចេញព្រះរាជបញ្ជាឲ្យគេកសាងវត្តថ្មីមួយទៀត នៅក្នុងខែត្រសំរោងទង ត្រង់កន្លែងដែលពេលកំពុងរត់គេចពីសត្រូវ ស្នំព្រះនាងឈ្មោះ នាងអំ បានថ្វាយផ្កាដល់ព្រះនាងនៅក្រោមម្លប់ដើមជ្រៃ ។ វត្តនោះមានឈ្មោះថា វត្តអូជ្រៃ ។

នៅទីបញ្ចប់ ព្រះរាជាបានឲ្យគេសង់វត្តមួយទៀតនៅគោកចំបក់ ត្រង់កន្លែងមួយដែលអ្វីៗទាំងអស់ នៅជុំវិញព្រះរាជាកំពុងតែរំជើបរំជួល អ្នកទាំងអស់គ្នាកំពុងតែភ័យខ្លាច ព្រះរាជាទតឃើញមេគោមួយក្បាលបំបៅកូនធ្វើវាហី ជាហេតុធ្វើឲ្យព្រះអង្គមានសេចក្ដីក្លាហានឡើងវិញ ។ វត្តនោះមានឈ្មោះថា វត្តមេគោបំបៅកូន ។

បន្ទាប់មក ព្រះរាជាបានឲ្យគេសង់ដំណាក់មួយនៅក្បែរវត្តចុងក្រោយនេះ រួចហើយទ្រង់ក៏ចាប់រៀបចំរចនាសម្ព័ន្ធរដ្ឋបាលរបស់ព្រះរាជាណាចក្រឡើងវិញ ប្រទានរង្វាន់ដល់អ្នកទាំងឡាយណាដែលធ្លាប់តាមដង្ហែព្រះអង្គដោយស្មោះស្ម័គ្រ ។ ទ្រង់បានចាត់តាំងចតុស្ដម្ភ គឺឧកញ៉ាយោមរាជ ឧកញ៉ាវាំង ឧកញ៉ាក្រឡាហោម និងឧកញ៉ាចក្រីឡើងវិញ បន្ទាប់មកមានរាជតេជោ និងមហាតលិកឆ្វេងស្ដាំគឺមហាទេព និងមហាមន្ត្រី ។

ព្រះរាជាក៏បានចាត់តាំងផងដែរ នូវមន្ត្រី៩រូបសម្រាប់តាមបម្រើសម្ដេចព្រះទាវជាព្រះមាតុច្ឆា ក្នុងនោះមានឈ្មោះ សួស ជាអ្នកបានជួយសង្គ្រោះព្រះក្សត្រី ដែលមានឋានៈជាក្រឡាពាស ហើយដំឡើងឲ្យទៅជាថ្នាក់សម្ដេចចៅពញា ទទួលបានភូមិ៩ រួមទាំងខ្ញុំ និងអ្នកស្រុក ដែលរស់នៅក្នុងភូមិនោះទាំងអស់[៣៨] ជាកម្មសិទ្ធិ ។

មន្ត្រី២រូប គឺអ្នក អ៊ីម ដែលបានចាប់កាន់អាវុធមុនគេ និងចៅដៃលី ដែលបានបង្កការលំបាកជាច្រើន ដល់ព្រះរាជាណាចក្រ ត្រូវដាក់ទោសប្រហារជីវិតបង់ ម្នាក់ដោយជ្រមុជក្នុងទឹកស្រះ ម្នាក់ទៀតជ្រមុជក្នុងទឹកព្រែក ។

បន្ទាប់ពីផ្ដល់យុត្តិធម៌រួច ព្រះរាជាបានយាងត្រលប់វិលមកគង់នៅឯឧត្តុង្គ ជាព្រះរាជធានីវិញ ។

ពេលនោះនៅឯខែត្រស្រីសន្ធរមានរាជវង្ស២អង្គ គឺព្រះអង្គអ្នកច័ន្ទ និងព្រះអង្គអ្នកអុក ដែលជាមិត្តភក្ដិរបស់អតីតព្រះឧភយោរាជ បានដឹកនាំអ្នកស្រុកឲ្យបះបោរឡើង ហើយនាំគ្នាធ្វើដំណើរទៅកាន់ខែត្រព្រៃវែង ជាទីកន្លែងដែលពួកកាន់សាសនាកាតូលិករស់នៅ ពួកនេះពីមុនដឹកនាំដោយលោកឪពុក សឺវ្រឺយ ។ ព្រះរាជាបានបញ្ជាឲ្យសម្ដេចព្រះស្រឡៅដឹកនាំទ័ពទៅបង្ក្រាបពួកនោះ ចាប់រាជវង្សទាំង២ បានហើយធ្វើឃាតចោលនៅនឹងជ្រោយបន្ទៀរួចទ្រង់បានបែងចែកភូមិទាំង៩ជាកម្មសិទ្ធិរបស់រាជវង្សទាំង២ឲ្យទៅសម្ដេចពញាស្រឡៅ និងរាជវង្សផ្សេងៗទៀត[៣៩] ។

---

[៣៨] ភូមិទាំង៩នោះមាននៅរហូតដល់សព្វថ្ងៃ នៅខាងលិចភ្នំពេញ ពីក្រោយបឹង ។ ម្យ៉ាងទៀត ចៅពញាសួស មានសល់កូនចៅរស់នៅដល់សព្វថ្ងៃនេះដែរ ។

[៣៩] ការលើកអំពីភូមិចំនួន៩ជាកម្មសិទ្ធិរបស់រាជវង្សមួយអង្គនេះ ក៏ដូចជាការបញ្ជាក់ខាងលើអំពីចៅពញាសួសទទួលបានភូមិ៩ ដែរហាក់ដូចជាបង្ហាញឲ្យឃើញថា នៅសម័យនោះ ព្រះរាជាប្រទានរង្វាន់ដល់អ្នកដែលតាមបម្រើព្រះអង្គដោយប្រគល់ភូមិមួយចំនួនឲ្យ ។

ការបះបោរខាងលើនេះមានរយៈពេលប្រហែលជា៣ខែ ។ ក្រោយព្រឹត្តិការណ៍នេះ ព្រះរាជាបានយាងចេញពីរាជធានីឧត្តុង្គ មកគង់នៅឯកំពង់ក្របសាំង ត្រង់ទួលព្រះស្រីវិញ ។ នៅទួលក្របសាំងនេះព្រះអង្គបានចាត់តាំងគណៈរដ្ឋមន្ត្រី ដោយរាប់បញ្ចូលទាំងបុរោហិត, ចៅក្រមជាន់ខ្ពស់, ចៅហ្វាយឃ្លាំងទាំង៤ និងចៅហ្វាយស្រុកទាំង១០ថ្នាក់ ។ គឺនៅក្នុងភូមិទួលក្របសាំងនេះឯងដែលអាគោ ខ្ញុំរបស់ពញាភក្តីសង្គ្រាមបានរៀបអាពាហ៍ពិពាហ៍ជាមួយនាងអំ ភីលៀងដែលបានថ្វាយផ្កាមួយទងដល់ព្រះទាវ ហើយត្រូវបានលើកឲ្យធ្វើជាចៅហ្វាយខែត្រគោកសេះឡើង[៤០] ។

មានបញ្ហាមួយធំជាងបញ្ហាអាពាហ៍ពិពាហ៍នោះទៅទៀត ដែលធ្វើឲ្យគណៈរដ្ឋមន្ត្រីឈឺក្បាល គឺបញ្ហាផ្លាស់ប្តូររាជធានី ។ ក្រោយពីបានសាកសួរទីប្រឹក្សា ហោរា និងព្រះសង្ឃរាជរួចមក គេសម្រេចថារាជធានីទួលក្របសាំងនេះ មានប្រជាជនច្រើន ចង្អៀតណាស់ គួរដូររាជធានីទៅដាក់នៅឯបឹងក្បិនវិញ ។

ការផ្លាស់ប្តូររាជធានីនេះប្រព្រឹត្តទៅនៅឆ្នាំបន្ទាប់ ហើយរាជធានីថ្មីមានឈ្មោះថា ដំណាក់ ។

មានការបះបោរមួយទៀតកើតឡើងធ្វើឲ្យសភាពការណ៍ក្នុងព្រះរាជាណាចក្រភាគខាងត្បូងល្អក់កករបន្តិច ។ នោះគឺការបះបោររបស់ពួកចិននៅមីថ ក្រោមការអុជអាលរបស់ឈ្មោះ ហ៊ុញតាំ ជាជំនួយការម្នាក់របស់ឧត្តមសេនីយ៍ដួងង៉ាន់ឌីច ។ ពួកបះបោរបានសម្លាប់ដួងង៉ាន់ឌីច រួចហើយលើកហ៊ុញតាំឲ្យធ្វើមេ និងប្រកាសទឹកដីមុំនោះជាក្សត្រប្រទេសមួយឯករាជ ។ ពួកបះបោរបានស្លដែកចាក់ធ្វើកាំភ្លើងធំ និងកេណ្ឌបានទូកក្តារបានជាច្រើន ។ គេបិទផ្លូវចរាចរ បង្កើតគយយាមល្បាត ហើយឃាត់ពួកខ្មែរឲ្យបង់ប្រាក់លោះ ។

ព្រះរាជាកម្ពុជាយល់យល់ថា ពួកចិននេះនឹងមកវាយប្រហារព្រះរាជាណាចក្រនៅថ្ងៃណាមួយជាមិនខានទើបទ្រង់បញ្ជាឲ្យគេសង់កំពែងការពារនៅភ្នំពេញ នៅបាក់ណាម និងនៅគោបឹច រួចហើយបានឲ្យគេធ្វើផ្លូស់បិទទន្លេនៅត្រង់បាណាម ដោយចងក្បូននឹងច្រវាក់មាំៗ ។

ព្រះឧភយោរាជអង្គនន់ ពេលនោះទ្រង់គង់នៅឯព្រៃនគរ ។ ទ្រង់មានពិភាល់ខ្លាំងណាស់នឹងការបះបោររបស់ពួកចិននេះ ដែលគ្មានសម្ព័ន្ធភាពអ្វីជាមួយព្រះអង្គទេ ក៏សំណូមពរសុំជំនួយពីពួកអាណ្ណាម ។ ពេលនោះ ពួកអាណ្ណាម ប្រុងប្រៀបតែនឹងប្រកាសសង្គ្រាមជាមួយកម្ពុជាទៅហើយ បានហៅហ៊ុញតាំឲ្យមកចុះចូលនឹងខ្លួនរួចឲ្យដឹកទ័ពដើរមុខ ។ ហ៊ុញតាំពេលនោះរីករាយណាស់នឹងបានត្រូវគេទទួលស្គាល់ ចាត់ទុកដូចជាស្តេច ក៏ចាប់ចេញដំណើរ ហើយធ្លាក់ចូលក្នុងអន្ទាក់របស់ពួកអាណ្ណាម ដែលមានទូកសំពៅច្រើនលើសលប់ព័ទ្ធជិតជុំ ។ ហ៊ុញតាំ ក៏ត្រូវពួកអាណ្ណាមចាប់បាន រួចសម្លាប់ចោលទៅ ឯបន្ទាយទាំងឡាយក៏ត្រូវគេបំផ្លាញចោលគ្មានសល់ ។ អាណានិគមចិននៅមីថក៏ត្រូវបានគេប្រគល់ឲ្យអុងប៉ាងចិននៅបារាជឈ្មោះ ត្រាន់ កាន់កាប់គ្រប់គ្រងវិញ ។

[៤០] មឿងគោកសេះនេះនៅក្នុងខែត្របារាយណ៍ ដោយមានវត្តបារាយណ៍នៅចំកណ្តាល ។

ទ័ពអាណ្ណាម ក្រោយពីបានកម្ទេចទ័ពពួកបះបោរចិននៅ មីថ រួចហើយ មិនបានឈប់នៅសៀមទេ ។ គេបានបន្តដំណើរមកវាយដណ្ដើមយកភ្នំពេញទៀត រហូតទាល់តែបាន ។

ព្រះរាជាកម្ពុជាបានភៀសព្រះកាយមកគង់នៅឯកំពង់ហ្លួង លើច្រាំងខាងស្ដាំទន្លេសាប ត្រឹមឧត្តុង្គ រួចទ្រង់បានផ្ញើទូតមកសុំចរចាសន្តិភាព ។ ប៉ុន្មានថ្ងៃក្រោយមកសន្ធិសញ្ញាសន្តិភាពរវាងកម្ពុជា និងអាណ្ណាម ក៏បានត្រូវចុះហត្ថលេខាជាថ្មី ដោយកំណត់ឲ្យកម្ពុជាលើកសួយសារអាករថ្វាយព្រះរាជាអាណ្ណាម ជារៀងរាល់ឆ្នាំ ។

មានការនិទានតៗគ្នាថា ក្បួនច្បាប់ផ្សេងៗរបស់ព្រះរាជាណាចក្របានត្រូវខ្ចាត់ខ្ចាយរប៉ាត់រប៉ាយបាត់អស់ជាមួយនឹងការបាក់បែកលង្វែកកាលពីឆ្នាំ១៥៩៣ ធ្វើឲ្យពួកចៅក្រមមានការលំបាកណាស់ក្នុងការកាត់សេចក្ដី ព្រោះគ្មានអ្វីជាសំអាង កាត់សេចក្ដីទៅតាមតែការចងចាំប៉ុណ្ណោះ ។ ព្រះរាជាមុនៗបានបញ្ជាឲ្យខិតខំប្រមែប្រមូលក្បួនច្បាប់ទាំងអស់ ពីតាមបណ្ដាខេត្ត និងវត្តអារាម ឡើងវិញដែរ ហើយគេប្រមូលបានមកវិញជាច្រើន ក៏ប៉ុន្តែក្បួនច្បាប់ទាំងអស់នោះមិនត្រូវគ្នាទេ មួយចំនួនប្រែខុសច្បាប់ដើមដោយការចម្លងតៗគ្នាមក ។ ដោយពិនិត្យឃើញដូច្នេះ ព្រះរាជាបានចេញបញ្ជាឲ្យប្រមូលក្បួនច្បាប់ទាំងអស់យកមកសិក្សាប្រៀបធៀបគ្នាមើល ហើយបើចាំបាច់ទ្រង់ឲ្យធ្វើវិសោធនកម្ម ។ ទ្រង់បានបន្ទុកបណ្ដាក់ឲ្យអ្នកប្រាជ្ញបណ្ឌិត៦រូបធ្វើការសើរើពិនិត្យច្បាប់ទាំង១២ក្បាលឡើងវិញ ។ ពួកអ្នកប្រាជ្ញបណ្ឌិតបានធ្វើការងារនេះសម្រេចក្នុងរយៈពេល៥ឆ្នាំ រួចហើយព្រះជ័យជេដ្ឋាក៏ប្រកាសឲ្យប្រើ ។

មានសេសសល់ច្បាប់នេះរហូតមកដល់សព្វថ្ងៃចំនួន២ច្បាប់ ដែលមានភស្តុតាងបញ្ជាក់អំពីការសើរើពិនិត្យឡើងវិញនេះ គឺក្រមចោររៀបរៀងតាំងពីឆ្នាំ៩៨៣នៃចុល្លសករាជ ត្រូវនឹងគ្រិស្តសករាជ១៦២១ និងក្រមសុភាធិបតី រៀបរៀងពីឆ្នាំ៩៨០នៃចុល្លសករាជ ត្រូវនឹងគ្រិស្តសករាជ១៦១៨ ។ ច្បាប់ផ្សេងៗទៀត ដែលមើលទៅប្រហែលជារៀបរៀងឡើងក្នុងសម័យកាលនោះដែរ ប៉ុន្តែមិនមានបញ្ជាក់ឈ្មោះព្រះរាជា ឬកាលបរិច្ឆេទច្បាស់លាស់ គឺប្រហែលជាត្រូវបានគេសើរើពិនិត្យឡើងវិញជាច្រើនដង[៤១] ។

ក្រមចោរមានសេចក្ដីបញ្ជាក់ឲ្យឃើញច្បាស់អំពីព្រះរាជបញ្ជាឲ្យសើរើពិនិត្យឡើងវិញ ៖ «ព្រះរាជាជ័យជេដ្ឋាដែលសោយរាជ្យនៅរាជធានីឧត្តុង្គ មានព្រះទ័យសន្ដោសត្រាប្រណីដល់រាស្ត្ររបស់ព្រះអង្គ ។ ព្រះអង្គឈ្វេងយល់ថាទណ្ឌកម្មដែលដាក់ទៅលើពួកឧក្រិដ្ឋថ្នាក់លេខ១នោះ មានសភាពធ្ងន់ធ្ងរ ព្រៃផ្សៃខ្លាំងពេកណាស់ ទ្រង់មានព្រះទ័យចង់ឲ្យលុបចេញវិញ ។ ដោយហេតុនេះ ទ្រង់បានបញ្ជាឲ្យយកទណ្ឌកម្មដែលបានកំណត់ឲ្យដាក់លើឧក្រិដ្ឋកម្មថ្នាក់លេខ២ មកដាក់លើឧក្រិដ្ឋកម្មថ្នាក់លេខ១ ហើយយកទណ្ឌកម្មសម្រាប់ឧក្រិដ្ឋកម្មថ្នាក់លេខ៣ មកដាក់លើឧក្រិដ្ឋកម្មថ្នាក់លេខ២វិញ ។ល ។» សេចក្ដីត្រង់នេះមានន័យថា លុបបំបាត់ទណ្ឌកម្មប្រហារជីវិតបង់ ។ យើងបានឃើញពី

[៤១] ដូចជាក្រមស្រុក ជាប្រភេទច្បាប់រដ្ឋធម្មនុញ្ញមួយបែប ដែលគេច្រើនហៅថា ក្រមស្រុកជ័យជេដ្ឋា ។

ខាងលើរួចមកហើយថាមានស្តេចលាវមួយអង្គ គឺ ហ្វាងោម ក៏បានបញ្ជាឲ្យលុបទណ្ឌកម្មនេះចោលដែរ ដោយទ្រង់ពន្យល់ថាគេមិនត្រូវសម្លាប់មនុស្សដែលបានសម្លាប់គេនោះទេ ព្រោះវានឹងធ្វើឲ្យមានមរណភាពមួយថែមទៀត ។

ក្រោយមក មានច្បាប់មួយទៀតបានកែច្បាប់ព្រះជ័យជេដ្ឋា ដោយប្រែដាក់ឲ្យមានទោសប្រហារជីវិតឡើងវិញ ។ ច្បាប់នោះរៀបរៀងឡើងនៅក្នុងឆ្នាំ១៦៦០ ។ ខ្ញុំជឿថាច្បាប់ឆ្នាំ១៦២១មិនត្រូវបានគេគោរពតាមប៉ុន្មានទេ បើយ៉ាងហោចណាស់ក៏ក្នុងការអនុវត្តន៍ដែរ ។ ជាក់ស្តែងគឺមានរឿងរ៉ាវទាក់ទងទៅនឹង សម្តេចព្រះទាវក្សត្រីដែលមានលើកឡើងនៅក្នុងច្បាប់ទំនៀមពីបុរាណ ក្នុងនោះមាននិយាយអំពីករណីមនុស្សជាច្រើន ដែលត្រូវប្រហារជីវិតដោយកាត់ក្បាល[៤៧] ។

ទោះជាយ៉ាងណាក្តី ប្រហែលជា៧០ឆ្នាំក្រោយមក គឺនៅក្នុងឆ្នាំ១៦៩០ ព្រះជ័យជេដ្ឋាដែលយើងកំពុងតែសិក្សានេះ ទ្រង់បានបញ្ជាឲ្យគេពិនិត្យច្បាប់ឆ្នាំ១៦២១ទាំង១២ច្បាប់ឡើងវិញ រួចបានប្រទាននាមឲ្យថា ច្បាប់ព្រះជ័យជេដ្ឋា ប៉ុន្តែឲ្យដាក់កាលបរិច្ឆេទត្រឹមឆ្នាំ១៦៧៥ ជាឆ្នាំដែលព្រះអង្គឡើងសោយរាជ្យ ។

នៅក្នុងឆ្នាំ១៦៨១ គឺ១ឆ្នាំបន្ទាប់ពីច្បាប់ទាំងឡាយបានត្រូវប្រកាសឲ្យប្រើរួចហើយ ព្រះឧភយោរាជអង្គនន់បានយាងត្រលប់ចូលមកក្នុងស្រុកខ្មែរវិញ ហើយក៏សុគតទៅនៅស្រីសន្ធរ ។ ពេលនោះព្រះអង្គមានព្រះជន្ម៣៧ព្រះវស្សា និងកាន់អំណាចបាន១ឆ្នាំ ហើយការបះបោររបស់ព្រះអង្គមានរយៈពេលពី១៥ទៅ១៦ឆ្នាំ ។ ពេលនោះព្រះរាជាទ្រង់គង់នៅឯបឹងក្សិន ។ មិនយូរប៉ុន្មានក្រោយមក ទ្រង់បានយាងត្រលប់មកគង់នៅឯឧត្តុង្គវិញ ។

រាជពង្សាវតារបានរៀបរាប់ថា នៅក្នុងឆ្នាំ១៦៩២ ព្រះរាជវង្សានុវង្សរបស់ព្រះរាជានគរចាម្ប៉ាបាននាំគ្នាយាងមកដល់ព្រះរាជាណាចក្រកម្ពុជា ដោយមានទាំងសេនាហែហម៥ពាន់នាក់មកជាមួយផង ដើម្បីសុំជ្រកកោនជាមួយព្រះរាជាកម្ពុជា ។ ព្រះជ័យជេដ្ឋា បានប្រទានដីធ្លី និងអនុញ្ញាតឲ្យពួកនោះរស់នៅជិតលង្វែក ។

មួយឆ្នាំបន្ទាប់មកទៀត ច្បាប់អយ្យកោទាក់ទិនទៅនឹងស្ថានសម្រាលទោស បានត្រូវប្រកាសឲ្យប្រើ ។ ហើយច្បាប់មន្ទីររដ្ឋបាល គឺច្បាប់ទាក់ទងនឹង "កងរក្សាព្រះអង្គ" ដែលមិនមែនជាច្បាប់យើងមានសព្វថ្ងៃ តែជាច្បាប់មួយចាស់ជាង ដែលគេបានធ្វើវិសោធនកម្មជាច្បាប់ថ្មីនេះ ក៏ត្រូវបានប្រកាសឲ្យប្រើផងដែរ ។ តាមច្បាប់នេះ អ្នកស្រុកមិនត្រូវចងត្រដោកគោទេនៅពេលបររទេះកាត់រាជធានី មិនត្រូវបាំងឆ័ត្រពេលជិះរទេះ មិនត្រូវក្រៀវគោ មិនត្រូវកាប់សម្លាប់គោយកសាច់បរិភោគទេ រទេះក៏មិនឲ្យលាបពណ៌ឆើតៗ ចន្ទោលរទេះមិនឲ្យដាក់ចង្កិំពណ៌មាសដែរ ។

---

[៤៧] ខ្ញុំសូមលើករឿងមួយ គឺនៅក្នុងពេលដែលលោកសូម៉ុង ជារាជទូតរបស់ស្តេចល្វីទី១៤ អញ្ជើញមកដល់រាជវាំងសៀម នៅក្នុងឆ្នាំ១៦៩៥ ទោសប្រហារជីវិតមានអនុវត្តតែចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋចំពោះព្រះរាជាប៉ុណ្ណោះ ។ ហើយច្បាប់សៀមពេលនោះមិនសូវខុសពីច្បាប់ខ្មែរប៉ុន្មានទេ ។

បីឆ្នាំម្ដងអ្នកស្រុកត្រូវបង់ពន្ធរទេះ និងគោចំនួនស្មើនឹង១ភាគ១០ ហើយព្រះរាជាបានសម្រេចថា គោណាដែលមានសម្បុរពព្រុសដូចរោមលលកត្រូវដកហូតទុកជាព្រះរាជទ្រព្យ ។

នៅក្នុងឆ្នាំ១៦៩៥ ព្រះរាជាដែលមានព្រះជន្ម៣០ព្រះវស្សា ហើយសោយរាជសម្បត្តិតាំងពីទ្រង់មានព្រះជន្ម២០ព្រះវស្សាម៉្លេះ បានដាក់រាជថ្វាយដល់ព្រះភាគិនេយ្យ ព្រះឧទ័យ ដែលមានព្រះជន្ម២២ព្រះវស្សា[៨៣] ។

## ១៩- ព្រះនរាយរាមាធិបតី-ព្រះឧទ័យ ចៅពញាយ៉ង (១៦៩៥-១៦៩៦)

ព្រះរាជាអង្គនេះទ្រង់បានទទួលការអភិសេកនៅក្នុងឆ្នាំ១៦៩៥ ក្នុងព្រះជន្ម២៣ព្រះវស្សា ក្រោមព្រះនាមថា ព្រះបាទសម្ដេចស្ដេចព្រះរាជឱង្ការព្រះនរាយរាមាធិបតីព្រះឧទ័យរាជាបរមបពិត្រ ។ ព្រះអង្គបានយកព្រះមាតុច្ឆា ជាបុត្រីរបស់ព្រះបាទសម្ដេចព្រះបរមរាជាធិរាជជាអគ្គមហេសី ។ ទ្រង់សោយរាជ្យបាន១០ខែ រួចក៏សុគតនៅក្នុងឆ្នាំ១៦៩៦ ។

## ២០- ព្រះជ័យជេដ្ឋា-រជ្ជកាលទី៣ (១៦៩៦-១៦៩៩)

ព្រះបាទជ័យជេដ្ឋា ក្រោយពីបានសាងព្រះផ្នួសជាលើកទី៣ អស់រយៈកាល៥ថ្ងៃរួចហើយ ក៏លាចាកសិក្ខាបទ ហើយមកទទួលយកព្រះអគ្គមហេសី រៀបចំព្រះរាជពិធីអភិសេក ឡើងគង់លើរាជសម្បត្តិជាលើកទី២ ដោយមានព្រះនាមខុសពីមុនបន្តិចបន្តួច ។

នៅឆ្នាំ១៦៩៩ មានមន្ត្រីម្នាក់ឈ្មោះថា ឧកញ៉ានរិន្ទឯម ត្រូវជាកូនលោកពញាសេនា ម៉េង បានលើកគម្រោងផែនការក្បត់ មិនមែនគ្រាន់តែដើម្បីទម្លាក់ព្រះរាជាពីរាជបល្ល័ង្កប៉ុណ្ណោះទេ គឺប៉ុនប៉ងគាស់រំលើងរាជវង្សទាំងមូលតែម្ដង ។ ជនក្បត់នេះបានធ្វើដំណើរទៅកាន់កូសាំងស៊ីន សុំបានទ័ពអាណ្ណាម២ម៉ឺននាក់ ក៏រៀបចំជា ២កងធ្វើដំណើរឡើងមកតាមដៃទន្លេទាំង២ ។ ព្រះរាជាជ័យជេដ្ឋា ត្រូវបង្ខំព្រះទ័យរត់គេចព្រះអង្គទៅគង់នៅឯខេត្រពោធិសាត់ ដើម្បីកេណ្ឌទ័ព ។ ទ័ពអាណ្ណាមរបស់ឧកញ៉ានរិន្ទឯមបានរៀបចំដេញតាមព្រះរាជា ដែលធ្វើដំណើរយឺតៗមកដល់កំពង់ឆ្នាំង ក៏តាំងជុតបំផ្លាញខ្ទេចខ្ទី ។

ពេលនោះ ព្រះស្រីធម្មរាជាជាព្រះរាជបុត្រារបស់ព្រះរាជា និងអ្នកអង្គម្ចាស់ឯម ត្រូវជារាជបុត្រារបស់អតីតព្រះឧភយោរាជក្បត់ ដែលទើបតែត្រលប់មកពីអាណ្ណាមពីឆ្នាំមុន បានដឹកនាំទ័ពមួយកងម្នាក់ ចេញពីខេត្រពោធិសាត់មក មួយកងមកតាមផ្លូវគោក មួយកងទៀតចុះតាមទន្លេសាប មកចោមវាយទៅលើទ័ពអាណ្ណាម ធ្វើឲ្យពួកនោះរត់ចោលឧកញ៉ានរិន្ទឯម ដកថយទៅខាងត្បូងសាយហួនដល់ខេត្របៀនហ៊ា និងបារាជ ដែលស្ដេចកូសាំងស៊ីន

[៨៣] រាជពង្សាវតារបាននិយាយថា ព្រះជ័យជេដ្ឋា ទ្រង់មានដំរីញីពណ៌ស មួយក្បាល ។

ទើបតែប្រគល់ថ្វាយមកឲ្យព្រះរាជាកម្ពុជាវិញ ។ មុននេះ ខែត្រទាំង២ ស្ថិតនៅក្នុងការគ្រប់គ្រងរបស់ពួកអាណ្ណាម ។

គេអាចនឹងចោទសំណួរបានថា តើព្រះឧភយោរាជអង្គនន់ឬ ដែលសុគតទៅនៅក្នុងឆ្នាំ១៦៩១ ជាអ្នកបានប្រគល់ខែត្រទាំង២នេះទៅថ្វាយស្តេចអាណ្ណាម ឬមួយក៏ខុកញ៉ានរិន្ទឯមទេដែលជាអ្នកប្រគល់ខែត្រទាំង២ នេះជាថ្នូរនឹងកងទ័ពដែលខ្លួនបានសុំ ។ មានឯកសារខ្លះបាននិយាយថែមទៀតថា ដើម្បីទប់ទល់កុំឲ្យទាហានរត់ចោលកងទ័ព ស្តេចអាណ្ណាមបានអនុញ្ញាតឲ្យឧត្តមសេនីយ៍របស់ព្រះអង្គនៅគ្រប់គ្រងខែត្រទាំង២ឲ្យបាន ។ ក៏ប៉ុន្តែអ្វីដែលប្រាកដនោះ គឺថាកងទ័ពអាណ្ណាមបានសម្លាប់ខុកញ៉ានរិន្ទឯមចោល មុនពេលដែលកងទ័ពនេះចាប់បន្តដំណើរមកភាគខាងត្បូងបន្តិច ។

នៅឆ្នាំបន្ទាប់ ទឹកដីខែត្រទាំង២នោះក៏ត្រូវគេបែងចែកជាស្រុកខ័ណ្ឌតូចៗ គ្រប់គ្រងដោយនាម៉ឺនអាណ្ណាមចំណុះឲ្យឧត្តមសេនីយ៍ដែលដឹកនាំទ័ពមកជួយខុកញ៉ានរិន្ទឯមនោះឯង ។ ពួកឧត្តមសេនីយ៍ទាំងនោះនៅនឹងបន្ទាយសាយហ្គន ហើយមានអំណាចទាំងខាងស៊ីវិល ទាំងខាងកងទ័ព ។ ទឹកដីខែត្រទាំង២នេះបានក្លាយទៅជារបស់អាណ្ណាមចាប់តាំងតែពីពេលនោះរហូតមក ។

នៅដំណាច់ឆ្នាំ ក្រោយពីទ្រង់សោយរាជ្យជាលើកទី៣បាន៤ឆ្នាំ ព្រះរាជាជ័យជេដ្ឋាបានដាក់រាជសម្បត្តិថ្វាយអ្នកអង្គម្ចាស់ឯម ដែលព្រះអង្គបានលើកឲ្យឡើងជាព្រះកែវហ្វ៉ាតាំងតែពីពេលត្រលប់ពីអាណ្ណាមមកវិញ ហើយដែលព្រះអង្គបានរៀបអភិសេកបុត្រីរបស់ព្រះអង្គមួយអង្គថ្វាយ ពីព្រោះថាព្រះកែវហ្វ៉ា បានបង្ហាញឲ្យឃើញថ្វីដៃរួចមកហើយ ក្នុងការប្រយុទ្ធជាមួយទ័ពអាណ្ណាមរបស់ខុកញ៉ានរិន្ទឯម ។

## ២១- ព្រះកែវហ្វ៉ាបរមបពិត្រអង្គឯម (១៧០០-១៧០១)

អ្នកអង្គម្ចាស់ឯមពេលនោះទ្រង់មានព្រះជន្ម២៥-២៦ព្រះវស្សាហើយ ។ ព្រះអង្គត្រូវជាបុត្រារបស់ព្រះឧភយោរាជអង្គនន់ជាមួយស្រីចិនម្នាក់ ។ ព្រះអង្គត្រូវបានលើកឲ្យឡើងជាព្រះបាទសម្តេចព្រះកែវហ្វ៉ាបរមបពិត្រនៅក្នុងគ្រិស្តសករាជ១៧០០ ត្រូវនឹងមហាសករាជ១៦២២ ចុល្លសករាជ១០៦២ ។ ព្រះអង្គបានយាងទៅគង់នៅឯខែត្រពោធិសាត់ ។

ចំណែកឯព្រះរាជាដាក់រាជ្យវិញ បានចំណាយពេលវេលារបស់ព្រះអង្គត្រួតពិនិត្យការជួសជុលវត្តព្រះពោធិមានបុណ្យ ដែលព្រះច័ន្ទរាជា បានឲ្យកសាងឡើងកាលពីឆ្នាំ១៥៣៤ ក្រោយពីទ្រង់មានជ័យជម្នះលើពួកសៀម ។ ទ្រង់បានចំណាយព្រះរាជទ្រព្យផ្ទាល់នៅក្នុងការជួសជុលនេះ ។ នៅពេលដែលការជួសជុលនេះចប់សព្វគ្រប់រួចហើយ ព្រះអង្គទ្រង់បានយាងចូលសាងព្រះផ្នួសម្តងទៀត ក៏ប៉ុន្តែបានតែ៣ថ្ងៃ ព្រះអង្គក៏លះបង់សិក្ខាបទមកទទួលយករាជសម្បត្តិវិញជាលើកទី៤ រាជពង្សាវតារនិយាយថាតាមសំណូមពររបស់ព្រះកែវហ្វ៉ា ជាហេតុបង្ហាញឲ្យឃើញថា ទ្រង់ជាស្តេចដ៏មានអំណាចពិតប្រាកដមែន ។

## ២២- ព្រះជ័យជេដ្ឋា-រជ្ជកាលទី៤ (១៧០១-១៧០២)

ព្រះបាទជ័យជេដ្ឋា បានឡើងសោយរាជ្យជាលើកទី៤ នៅក្នុងព្រះជន្មាយុ៤៥ព្រះវស្សា ។

ទើបឡើងគ្រងរាជបល្ល័ង្កមិនទាន់បានប៉ុន្មានផង ព្រះអង្គត្រូវប្រយុទ្ធប្រឈមមុខនឹងជនបះបោរម្នាក់ឈ្មោះថា ភីរែនគីម ជាកូនរបស់មន្ត្រីព្រះរាជវាំងម្នាក់ ។ ជនក្បត់នេះដែលបានទទួលទ័ពជំនួយពីស្ដេចអាណ្ណាម ក៏ដឹកនាំឡើងតាមផ្លូវទឹករហូតមកដល់ត្រើមខត្តុង្គ ។ ពេលទ័ពសត្រូវមកជិតដល់ហើយ ព្រះរាជាក៏នាំព្រះរាជវង្ស និងសេនាមន្ត្រីទាំងអស់ គេចព្រះអង្គទៅគង់នៅឯខែត្រពោធិសាត់ ។ ភីរែនគីមបានដឹកនាំទ័ពដេញតាម ក៏ប៉ុន្តែព្រះរាជាទ្រង់មានឱកាសអាចកេណ្ឌបានទ័ពមួយកងតូចទាន់ ហើយបានបើកការវាយប្រហារបកមកលើទ័ពក្បត់វិញ វាយឲ្យពួកនេះ បរាជ័យបែកបាក់គ្នាអស់ទៅ ឯភីរែនគីមត្រូវចាប់ខ្លួនបាន ។

ឆ្នាំបន្ទាប់មក ព្រះជ័យជេដ្ឋា បានដាក់រាជសម្បត្តិម្ដងទៀត ក៏ប៉ុន្តែម្ដងនេះថ្វាយដល់ព្រះរាជបុត្រាច្បងព្រះនាម ស្រីធម្មោរាជា ដែលមានព្រះជន្ម១២ព្រះវស្សា ។ រួចហើយព្រះអង្គក៏យាងចូលសាងព្រះផ្នួសម្ដងទៀត ចំនួន៣ថ្ងៃ ។

## ២៣-ព្រះធម្មោរាជាទី៤ (១៧០២-១៧០៤)

ដោយព្រះរាជាថ្មីមានព្រះជន្មតិចពេក គេក៏បង្អង់មិនទាន់រៀបចំព្រះរាជពិធីអភិសេកទេ ហើយព្រះបិតានៅបន្តចាត់ចែងកិច្ចការព្រះរាជាណាចក្រ ហាក់បីដូចជាទ្រង់មិនដាក់រាជ្យនៅឡើយ ។

នៅក្នុងឆ្នាំបន្ទាប់ មានជនសំរ៉ែម្នាក់ ដែលទៅរស់នៅឯស្រុកកូឡា (ភូមា) អស់ពេលប៉ុន្មានឆ្នាំ បានត្រលប់មកវិញ ។ ពួកកុលសម្ព័ន្ធសំរ៉ែនេះធ្លាប់មានបុព្វបុរសឡើងធ្វើជាព្រះរាជាកម្ពុជាហើយបង្កើតបានជាសន្តតិវង្សថ្មីមួយ គឺតាជីប្តុតាត្រសក់ផ្អែម ។ ជនសំរ៉ែនោះហាក់ដូចជាមិនសូវជាទេ ក៏ប៉ុន្តែគេមានលក្ខណៈសម្បត្តិសមល្មមនឹងធ្វើឲ្យប្រជាជនជឿថាគេជាអ្នកមានបុណ្យ ដែលត្រូវមកសោយរាជ្យនៅកម្ពុជានេះ ។ មានប្រជាជនជាច្រើនជឿហើយដើរតាម ធ្វើឲ្យស្រុកទេសជ្រួលច្របល់ជាខ្លាំង ។ នាម៉ឺនសព្វមុខមន្ត្រី បានចាត់ទ័ពមួយកងឲ្យចុះមកចាប់ជនសំរ៉ែនេះ ក៏ប៉ុន្តែជននោះបានគេចខ្លួនបាត់ទៅ ហើយព្រះរាជាណាចក្រក៏ត្រលប់មានសណ្ដាប់ធ្នាប់ល្អឡើងវិញ ។

នៅឆ្នាំ១៧០៣ ព្រះរាជធានីដែលផ្ទេរទៅតាំងនៅឯពោធិសាត់តាំងពីឆ្នាំ១៦៩៩មក បានប្ដូរមកតាំងនៅទីងខត្តុង្គវិញ ។

នៅឆ្នាំបន្ទាប់មកទៀត ព្រះស្រីធម្មោរាជាបានដាក់រាជសម្បត្តិថ្វាយដល់ព្រះបិតាវិញ ក្រោយពីសោយរាជ្យបាន២ឆ្នាំ ។

## ២៤- ព្រះជ័យជេដ្ឋា-រជ្ជកាលទី៥ (១៧០៤-១៧០៦)

ព្រះជ័យជេដ្ឋាបានឡើងគ្រងរាជបល្ល័ង្កម្ដងទៀត ជាលើកទី៥ ។ ពេលនេះព្រះអង្គមានព្រះជន្ម៤៩

ព្រះវស្សាហើយ ។ រាជពង្សាវតារមិនឃើញមាននិយាយថា តើព្រះអង្គឲ្យគេរៀបចំព្រះរាជពិធីអភិសេកថ្វាយដែរ ឬអត់ទេ ។

នៅពេលនោះគឺឆ្នាំ១៧០៥ មានព្រះរាជវង្សានុវង្សលាវជាមួយនឹងប្រជាជន ៥ពាន់នាក់ ដែលត្រូវបណ្តេញចេញពីរាជធានីវៀងច័ន្ទ បាននាំគ្នារត់មកសុំជ្រកកោន និងសុំរស់នៅនៅកម្ពុជា ។ រាជវង្សនេះសោយរាជសម្បត្តិនៅលើរាជបល្ល័ង្កលាវជាច្រើនឆ្នាំមកហើយ មុនដំបូងសោយរាជ្យនៅហ្លួងប្រាបាង រួចមកនៅឯវៀងច័ន្ទ ។ ព្រះរាជាលាវដែលលោក ហ្សេរ៉ាវ៉ាន់វូស្សូវ បានជួបនៅក្នុងឆ្នាំ១៦៤១ក្រោយពីទ្រង់សោយរាជ្យបាន ៣ឆ្នាំហើយ ប៉ុន្តែមិនបានឲ្យដឹងព្រះនាមទេ គឺព្រះអង្គម្ចាស់សុរិយា ព្រះនាមពេញគឺថាវសុរិយាវង្សធម្មិកៈ រាជាបរមបពិត្រធិរាជ ។ ព្រះរាជាអង្គនេះបានសុគតទៅនៅក្នុងឆ្នាំ១៥៩៥ ដោយបន្សល់ទុកនូវព្រះរាជនត្តា ដែលនៅតូចៗនៅឡើយ ។

មានមន្ត្រីម្នាក់ក្នុងចំណោមមន្ត្រីរបស់ព្រះអង្គ បានរៀបអាពាហ៍ពិពាហ៍ជាមួយនាងគាម៉ង់ ជាបុត្រីមួយអង្គរបស់ព្រះរាជាសុរិយា បំបែកព្រះរាជនត្តាតូចៗទាំងនោះចេញពីរាជបល្ល័ង្ក ហើយក៏ឡើងសោយរាជ្យខ្លួនឯង ។ ពេលនោះមានមន្ត្រីម្នាក់ទៀត អាចជាព្រះឧភយោរាជ ឬក៏ជាពញាសែន បានងើបប្រឆាំងឡើងវាយដណ្តើមបានជ័យជម្នះ ហើយបង្ខំឲ្យមន្ត្រីក្បត់នោះធ្វើអត្តឃាត រួចក៏ឡើងសោយរាជ្យបន្តមកទៀតដោយមានព្រះនាមថា ភ្យានន់អធិរាជ ។

មានព្រះភាគិនេយ្យរបស់ព្រះរាជាសុរិយាមួយអង្គ ជាបុត្ររបស់ព្រះរៀមមួយអង្គទៀត ដែលភៀសព្រះអង្គទៅគង់នៅឯក្រុងវ៉េ បានវិលត្រលប់មកវិញជាមួយនឹងទ័ពមួយកង ហើយប្រកាសសង្គ្រាមជាមួយ ភ្យានន់ ។ ព្រះរាជាភ្យានន់អធិរាជ ដែលប្រហែលជារាជវង្សមួយអង្គរបស់ព្រះរាជាសុរិយាដែរ បានត្រូវសុគតនៅក្នុងការប្រយុទ្ធនោះ ហើយប្រាជ័យអុងវ៉េ ដែលទទួលបានជ័យជម្នះ ក៏ឡើងសោយរាជ្យនៅវៀងច័ន្ទ រីឯ ថាវ (ឬចៅ) នង ដែលជាអនុជមួយអង្គ ក៏យាងទៅសោយរាជ្យនៅហ្លួងប្រាបាង ។ ដល់មកឆ្នាំ១៦០៥ មានបុត្រាមួយអង្គរបស់ព្រះរាជាសុរិយា បានមកដេញថាវនងចេញ ហើយឡើងសោយរាជ្យនៅហ្លួងប្រាបាងនោះទៅ ។ ចាប់ពីពេលនោះមក ប្រទេសលាវដែលមានឯកភាពអស់កាលជាយូរណាស់មកហើយ ក៏ត្រូវបែងចែកជារាជាណាចក្រពីរ ដែលមានព្រះរាជាជាបងប្អូនជីដូនមួយនឹងគ្នា គឺជាព្រះភាគិនេយ្យ និងជាបុត្ររបស់ព្រះសុរិយាទាំងអស់គ្នា ហើយត្រូវជាបច្ឆាញាតិរបស់ព្រះរាជាហ្សាន៉ោម ។

តាមមើលទៅ គឺរាជវង្សរបស់ព្រះឧបរាជភ្យាណាកន ដែលបានរត់គេចមកសុំជ្រកកោននៅកម្ពុជា ។

នៅក្នុងឆ្នាំ១៧០៦ ព្រះរាជាជ័យជេដ្ឋា ដែលនឿយណាយនឹងអំណាចក្រោយពីសោយរាជ្យបាន ២ឆ្នាំ ក៏ដាក់រាជសម្បត្តិម្តងទៀតជាលើកទី៥ ថ្វាយដល់ព្រះស្រីធម្មោរាជាជាព្រះរាជបុត្រា ដែលទ្រង់បានលើកឲ្យសោយរាជ្យម្តងរួចមកហើយ នៅក្នុងឆ្នាំ១៧០២ តែបានដាក់រាជ្យថ្វាយព្រះបិតាវិញនៅក្នុងឆ្នាំ១៧០៤ ។

## ២៥- ព្រះធម្មោរាជាទី៤-រជ្ជកាលទី២ (១៧០៦-១៧១០)

ព្រះរាជាអង្គនេះមិនបានទទួលព្រះរាជពិធីអភិសេកទេកាលពីទ្រង់សោយរាជ្យលើកមុន ព្រោះនៅក្មេងពេក គឺទើបតែមានព្រះជន្មាយុ១២ព្រះវស្សាប៉ុណ្ណោះ ។ ទ្រង់បានដាក់រាជសម្បត្តិនៅក្នុងឆ្នាំ១៧០៤ ។ នៅពេលដែលព្រះអង្គឡើងគ្រងរាជបល្ល័ង្កសាជាថ្មីនេះ ទ្រង់មានព្រះជន្ម១៧ព្រះវស្សាហើយ ហើយបានត្រូវអភិសេកក្រោមព្រះនាមថា ព្រះស្រីធម្មោរាជាធិរាជរាមាធិបតីបរមបពិត្រ ជាព្រះរាជាស្នង ឯព្រះបិតារបស់ព្រះអង្គវិញ បានទទួលយកព្រះឋានៈជាព្រះឧភយោរាជ គឺជាឋានៈដែលគេតែងតែប្រគល់ថ្វាយដល់ព្រះរាជា ដែលមិនចង់ទទួលយករាជសម្បត្តិ ឬក៏ត្រូវគេបំបែកពីរាជសម្បត្តិ ។

និយាយពីពួកលាវដែលនាំគ្នាមកកម្ពុជាតាមស្តេចរបស់ខ្លួនវិញ បានត្រូវព្រះរាជាអនុញ្ញាតឲ្យទៅរស់នៅក្នុងខែត្របាទី ជាមួយពួកលាវមួយក្រុមមុន ដែលកាលពីឆ្នាំ១៥៦១ក្រុមនេះគេឲ្យនៅឯបារាយណ៍ តែបន្ទាប់មកបានឲ្យមករស់នៅទីនេះដែរក្រោយពីមានបះបោរម្តងរួចមក ។ ភូមិដែលពួកលាវនេះរស់នៅ គេដាក់ឈ្មោះឲ្យថាភូមិបារាយណ៍ក្បាតដុំ មានន័យថា ភូមិពួកអ្នកបះបោរនៅបារាយណ៍ ។ ដោយមានការជួយគាំទ្រពីបណ្តាជនរួមជាតិគេ ពួកអ្នកមកដល់ថ្មីបានបង្កការលំបាកដល់អាជ្ញាធរមូលដ្ឋានម្តងនៅក្នុងឆ្នាំ១៧០៨ ។ ព្រះរាជាបានចាត់ឲ្យមន្ត្រី២នាក់មកនាំពួកនេះទៅរស់នៅឯកោះរាពណ៍វិញ តែពួកនេះមិនព្រម ហើយក៏ប្រមែប្រមូលគ្នាបះបោរជាចំហឡើង ។ ព្រះរាជាក៏ចាត់ឲ្យកងទ័ពចេញមកបង្រ្កាប ជាហេតុធ្វើឲ្យពួកលាវនេះបំបែកគ្នាជា៣កង គឺកងទី១រត់ចូលព្រៃ កងទី២រត់ទៅកូសាំងស៊ីន រីឯកងទី៣រត់ទៅរកព្រះកែវហ៊្វាអង្គឯម ដែលត្រូវជាព្រះភាគិនេយ្យរបស់ព្រះជ័យជេដ្ឋាផង និងត្រូវជាបុត្រសុណិសាព្រះអង្គផង ។ ព្រះកែវហ៊្វានេះបានដកព្រះកាយឆ្ងាយពីរាជវាំងប្រកបទៅដោយចរិតប្រឆាំង តាំងតែពីពេលដែលទ្រង់បានដាក់រាជសម្បត្តិថ្វាយព្រះបិតាក្មេកវិញ នៅក្នុងឆ្នាំ១៧០១ ។ គេបារម្ភព្រះកែវហ៊្វានេះធ្វើតម្រាប់តាមព្រះបិតាព្រះអង្គដែរ គឺព្រះឧភយោរាជអង្គនន់ ។

តាមពិតទៅ ព្រះកែវហ៊្វាទ្រង់រង់ចាំតែឱកាសនឹងចាប់កាន់អាវុធប្រឆាំងប៉ុណ្ណោះ ។ ព្រឹត្តិការណ៍បះបោររបស់ពួកលាវនេះជាឱកាសល្អហើយ ទ្រង់ក៏ប្រកាសខ្លួនព្រះអង្គជាអ្នកការពារពួកនោះ ហើយបានហៅមេធំរបស់ពួកគេឈ្មោះ សុកុណាបាទ ឲ្យត្រលប់មកពីកូសាំងស៊ីនមកវិញ ។ សុកុណាបាទត្រលប់កម្ពុជាជាមួយនឹងទ័ពអាណ្ណាម ២ម៉ឺននាក់ ដែលគេបានកេណ្ឌជាមួយអាជ្ញាធរមូលដ្ឋានដែលរួមគំនិតជាមួយព្រះកែវហ៊្វា ។ ក្នុងពេលជាមួយគ្នានោះ ព្រះកែវហ៊្វា កេណ្ឌបានទ័ពក្លួយ និងសំរ៉ែ១ម៉ឺននាក់ដែរ ។ ព្រះកែវហ៊្វាដឹកនាំទ័ពធ្វើដំណើរឆ្ពោះទៅកាន់រាជធានីឧត្តុង្គ រីឯសុកុណាបាទចាប់វាយយកអាណាខែត្រខាងកើត ។ ទ័ពទាំង២ធ្វើសកម្មភាព លឿនរហ័សណាស់ ទាល់តែព្រះរាជា និងព្រះអនុជអង្គទងដែលមានព្រះជន្ម១៨ព្រះវស្សាហើយ ត្រូវព័ទ្ធជាប់នៅក្នុងបន្ទាយឧត្តុង្គ ។ ព្រះរាជាទប់ទល់ជាមួយទ័ពសត្រូវអស់ពេល៣ខែ ទ្រាំលែងបានទើបទ្រង់វាយបើកខ្សែត្រៀមរត់គេច ចេញនាពេលយប់មួយសំដៅទៅស្រុកសៀម ដោយនាំយកព្រះរាជបុត្រារបស់ព្រះរាជាមួយអង្គ ដែលប្រសូត្រនៅក្នុងឆ្នាំ១៧០៦ ទៅជាមួយផង ។

## ២៦- ព្រះកែវហ៊្វាអង្គឯម-រជ្ជកាលទី២ (១៧១០-១៧២២)

ព្រះកែវហ៊្វាអង្គឯម បានសោយរាជ្យម្តងនៅក្នុងឆ្នាំ១៧០០ ។ ក្រោយពីបានបណ្តេញព្រះរាជាស្នងឲ្យរត់គេចព្រះអង្គទៅស្រុកសៀមរួចមក ទ្រង់ក៏ចាប់កាន់កិច្ចការព្រះរាជាណាចក្រ ប៉ុន្តែមិនទាន់ហ៊ានឲ្យគេអភិសេកព្រះអង្គជាស្តេចនៅឡើយទេ ។ ព្រះអង្គរង់ចាំអស់ពេល៤ឆ្នាំ គឺរហូតដល់មកឆ្នាំ១៧០៤ ទើបត្រូវបានអភិសេកឲ្យឡើងគ្រងរាជបល្ល័ង្កក្រោមព្រះនាមថា ព្រះបាទសម្តេចព្រះកែវហ៊្វាបរមបពិត្រ ដែលទ្រង់ធ្លាប់បានទទួលរួចមកហើយ នៅក្នុងឆ្នាំ១៧០០-១៧០១ ។ ពេលនោះព្រះអង្គមានព្រះជន្ម៣៤ព្រះវស្សាហើយ ។

នៅឆ្នាំបន្ទាប់មក ស្តេចស្រុកសៀមបានបញ្ជូនទ័ព១ម៉ឺន៥ពាន់នាក់ជាមួយនឹងរាជទូតផង មកកាន់ ស្រុកខ្មែរ ដើម្បីសុំឲ្យព្រះកែវហ៊្វាជ្រែករាជ្យលះបង់រាជបល្ល័ង្កថ្វាយទៅព្រះស្រីធម្មោរាជាវិញ ។ អតីតព្រះរាជានេះបានឈប់សំចតនៅក្នុងខែត្របាត់ដំបង ជាមួយនឹងព្រះអនុជអង្គទង និងព្រះបុត្រាអង្គឯម ជាមួយនឹងកងទ័ពដែលបញ្ជាដោយចៅពញាពលទេព និងចៅពញារាជាសោភាវតី ។ ព្រះរាជាថ្មីកែវហ៊្វាអង្គឯម បដិសេធមិនយល់ព្រមទទួលយកសំណើខុសពីធម្មតានេះទេ ហើយក៏មិនព្រមអនុញ្ញាតឲ្យក្សត្រាទាំង៣អង្គស្នាក់នៅក្នុងព្រះរាជាណាចក្រដែរ ព្រោះវត្តមានរបស់ក្សត្រទាំង៣អង្គអាចនាំឲ្យមានភាពល្អក់កករបាន ។

នៅក្នុងឆ្នាំ១៧១៥ នៅពេលដែលព្រះជ័យជេដ្ឋាឧភយោរាជ យាងសាងព្រះផ្នួសជាលើកទី៥ ចំនួនមួយសប្តាហ៍ ព្រះកែវហ៊្វាអង្គឯមបានដាក់រាជសម្បត្តិថ្វាយព្រះអគ្គមហេសី ជាបុត្រីដែលព្រះជ័យជេដ្ឋា បានលើកថ្វាយព្រះអង្គកាលពីពេលដែលទ្រង់យាងត្រលប់ពីអាណ្ណាមមកវិញ ក្រោមព្រះនាមថា ព្រះមហាក្សត្រី រួចទ្រង់ក៏យាងចូលសាងព្រះផ្នួស ។ សាងផ្នួសបាន៣ថ្ងៃ ព្រះកែវហ៊្វាអង្គឯមក៏លាចាកសិក្ខាបទ រួចចាប់កាន់អំណាចឡើងវិញ ។

នៅចុងឆ្នាំ១៧១៦ ព្រះអង្គទង ជាព្រះអនុជរបស់ព្រះរាជាស្រីធម្មោរាជាដែលធ្លាក់ពីរាជសម្បត្តិ បានចេញមុខដឹកនាំអ្នកស្រុកពោធិសាត់ដែលបះបោរឡើងប្រឆាំងនឹងព្រះរាជាព្រះកែវហ៊្វា ។ ព្រះកែវហ៊្វា ពេលនោះគ្មានកងទ័ពទេ ណាមួយប្រជានុរាស្ត្រក៏មិនពេញចិត្តនឹងព្រះអង្គផងដែរ ព្រោះទ្រង់ចូលចិត្តតែការសប្បាយ ។ បើទោះជាថាប្រទេសកម្ពុជានាសម័យនោះមិនទាន់ធ្លាក់ចុះទន់ខ្សោយដូចសព្វថ្ងៃក៏ដោយ ក៏ប៉ុន្តែគេមិនអាចធ្វើឲ្យប្រជារាស្ត្រដើរតាមទាំងមិនសប្បាយចិត្តបានដែរ ។ ម៉្លោះហើយ ដោយដឹងច្បាស់ថា ប្រជារាស្ត្រមិនគាំទ្រព្រះអង្គ ព្រះកែវហ៊្វា មិនបានរៀបចំកេណ្ឌទ័ពក្នុងចំណោមប្រជារាស្ត្រខ្មែរទេ ទ្រង់បែរទៅរកពួកអាណ្ណាម ដែលជាឈ្លើយសឹកនៅក្នុងកម្ពុជាវិញ ។ ទ័ពអាណ្ណាមនេះ ក្រោយពីបានទទួលការរៀបចំរួចហើយ ក៏ចេញទៅវាយប្រយុទ្ធប្រឆាំងនឹងព្រះអង្គទង ធ្វើឲ្យព្រះអង្គរងរបួសនៅក្នុងសមរភូមិដំបូង ហើយបង្ខំឲ្យព្រះអង្គវាយដកថយទៅក្រោយវិញ ។ ពួកអ្នកស្រុកពោធិសាត់ដែលអស់សង្ឃឹមក៏បំបែកគ្នា វិលត្រលប់ទៅស្រុកភូមិវិញអស់ដែរ ។

ព្រះអង្គទង ថ្វីបើត្រូវរងរបួស ប៉ុន្តែព្រះអង្គមិនអស់សង្ឃឹមទេ ។ ទ្រង់បានភៀសព្រះកាយទៅគង់នៅឯបុស្សីសាញ់ ដើម្បីព្យាបាលរបួស ។ ដល់មកឆ្នាំ១៧២២ ស្តេចសៀមបានឲ្យទ័ព១ម៉ឺននាក់ជូនដំណើរ ព្រះស្រី

ធម្មោរាជា យាងឆ្លងកាត់ព្រំដែនចូលមកកម្ពុជាតាមជើងគោកជាមួយនឹងព្រះបុត្រាអង្គឯម និងទ័ព៥ពាន់នាក់ទៀត ឡើងសំពៅតាមជើងទឹកមកចុះនៅពាម (ហាទៀង) ។ ព្រះអង្គទងបានយាងកាត់ទៅរកទ័ពជើងគោករបស់ព្រះរៀមនៅទីនោះ ។

ពាម ឬហាទៀង ដែលជាទីប្រជុំជនរបស់ខែត្រខម ឬមឿងខម ពេលនោះស្ថិតនៅក្រោមការត្រួតត្រាអស់ពេលប៉ុន្មានឆ្នាំរួចមកហើយដោយមេចោរសមុទ្រជាតិចិនម្នាក់ ដែលជាអតីតបក្សពួករបស់សន្តតិវង្សមិញ ។ ចិននោះមានឈ្មោះថា ម៉ាក់គូ[៨៨] កាលនៅឯភ្នំពេញធ្វើជាមេបនល្បែងស៊ីសង ។ នៅពេលក្លាយជាអ្នកមាន ចិននេះ

---

[៨៨] ម៉ាក់គូ កើតនៅក្នុងភូមិឡេក្វាត សង្កាត់ហៃគឿង ស្រុកឡុយចៅ ខែត្រកង់តុង ។ គាត់ស្លាប់នៅហាទៀង នៅក្នុងឆ្នាំ១៧៣៦ ក្នុងអាយុ៧៨ឆ្នាំ ។ កូនប្រុសគាត់ឈ្មោះ ម៉ាក់តុងបានឡើងកាន់អំណាចតពីគាត់ មានឋានៈជាបេសកជនរបស់ព្រះចៅអធិរាជចិន ហើយមានសិទ្ធិបោះពុម្ពកាក់ស័ង្កសី ។ គេនិយាយថាម៉ាក់តុងនេះបានកសាងផ្លូវជាច្រើនដែលយើងបានជួសជុលឡើងវិញ ហើយក៏បានជីកព្រែកជីកប្រឡាយច្រើនផងដែរ តែអ្នកក្រោយៗ មិនបានថែរក្សាឲ្យល្អទេ ។ គាត់បានឲ្យគេសាងសង់ផ្សារមួយ ហើយបានចាត់ឲ្យពង្រឹងប្រព័ន្ធការពារទីក្រុង ដែលឪពុករបស់គាត់បានសង់ឡើងនៅត្រង់ច្រកចូលកំពង់ផែ ។ គាត់ល្បីល្បាញពូកែ ខាងការការពារទីក្រុងប្រឆាំងនឹងមេចោរសមុទ្រ ជាតិចិនឈ្មោះ ហួកញាន នៅក្នុងឆ្នាំ១៧៧០ និងប្រឆាំងអ្នកផ្សងព្រេងចិនម្នាក់ទៀត ឈ្មោះត្រាន់ថាយ ដែលត្រូវរ៉ូវគ្នាជាមួយបងប្អូនជីដូនមួយគាត់២នាក់ ហើយប្រឆាំងនឹង ខុកញ៉ាខែ និងជនជាតិម៉ាឡេឈ្មោះ លីម៉ាលូ ដែលបានដឹកនាំកម្លាំង១ពាន់នាក់ មកវាយប្រហារលើគាត់ ។ មានតែពួកសៀមទេ ដែលអាចដណ្តើមយកហាទៀងបាននៅក្នុងឆ្នាំ១៧៧២ ក្រោយពីឡោមព័ទ្ធអស់ពេល៣ថ្ងៃ ។ ប៉ុន្តែម៉ាក់តុងបានទទួលអំណាចគ្រប់គ្រងលើហាទៀងវិញនៅឆ្នាំ១៧៧៥ ក្រោយពីបានចុះសន្ធិសញ្ញាមួយជាមួយសៀម ។ នៅចុងឆ្នាំ១៧៧៩ នៅពេលដែលគាត់ធ្វើដំណើរទៅកាន់រាជធានីបាងកក ចូលគាល់ស្តេចសៀម ម៉ាក់តុង បានត្រូវស្តេចសៀមឃាត់មិនឲ្យវិលត្រលប់មកហាទៀងវិញទេ ។ ស្តេចសៀមបានឲ្យគេកាត់កកូនច្បងគាត់ជាមួយនឹងរាជវង្សអាណ្ណាមម្នាក់ដែលបានធ្វើដំណើរទៅជាមួយគ្នា និងបរិពារហែហម៥០នាក់ទៀត ។ ម៉ាក់តុង ត្រូវគេធ្វើទារុណកម្មយ៉ាងខ្លាំង ។ ដោយទ្រាំមើលទារុណកម្មនោះមិនបាន ជនជាតិសៀមម្នាក់ ក៏បានលួចប្រគល់ថ្នាំពុលឲ្យគាត់ផឹកសម្លាប់ខ្លួនទៅនៅក្នុងឆ្នាំ១៧៨១ ហើយបានជួយជីវិតកូនគាត់៣នាក់ និងចៅគាត់៤នាក់ ។ ក្នុងពេលដែល ម៉ាក់តុង ជាប់ឃុំឃាំងនៅឯស្រុកសៀម កូនគាត់ឈ្មោះ ម៉ាក់ទឹសាញ បានឡើងកាន់អំណាចតពីគាត់នៅឯហាទៀង ហើយបានក្លាយខ្លួនជាអ្នកគាំទ្រស្តេចយ៉ាឡុង យ៉ាងដាច់ខាតម្នាក់ ដែលកំពុងតស៊ូដណ្តើមអំណាចពីពួកតៃសឺននៅអាណ្ណាម ។ នៅពេលដែល ម៉ាក់ទឹសាញ ស្លាប់នៅក្នុងឆ្នាំ១៧៩០ ប្អូនប្រុសរបស់គាត់ឈ្មោះ ម៉ាក់កុងប៊ិញ បានឡើងកាន់អំណាចបន្ត ។ គឺម៉ាក់កុងប៊ិញនេះឯង ដែលបានទទួលសព ម៉ាក់តុង ពីស្តេចសៀម ដែលផ្ញើមកឲ្យនៅក្នុងឆ្នាំ ដដែលនោះ ។ ម៉ាក់កុងប៊ិញ បានរៀបចំបញ្ចុះសពជីតានៅលើភ្នំប៊ិញសឺន ។ គាត់ស្លាប់នៅក្នុងឆ្នាំ១៨០៩ ដោយបន្សល់ទុកតែកូនតូចៗ មិនអាចកាន់អំណាចបន្តពីគាត់បាន ។ ក៏ប៉ុន្តែដល់មកឆ្នាំ១៨១៦ មានកូនប្រុសគាត់ម្នាក់ឈ្មោះ ម៉ាក់ឌិន បានឡើងធ្វើជាអ្នកគ្រប់គ្រងក្រុងហាទៀង រួចជាចៅហ្វាយក្រុងនៅក្នុងឆ្នាំ១៨១៨ ។ ដូចជាគ្មានអ្នកស្នងត្រកូលនេះ រស់នៅរហូតមកដល់សព្វថ្ងៃទេ ក៏ប៉ុន្តែគេនិយាយថា នៅមានត្រកូលនេះនៅឡើយនៅក្នុងឆ្នាំ១៨៦៧ នៅពេលដែលពួកបារាំងចូលកាន់កាប់ហាទៀង ពួកនោះបានរត់គេចខ្លួនទៅកាន់ទីក្រុងវេទៅ ។

កើតគំនិតចង់ធ្វើឲ្យជីវិតខ្លួនកាន់តែប្រសើរ និងថ្កុំថ្កើងឡើង ក៏ទៅតាំងទីលំនៅឯពាម ប្រមែប្រមូលពួកចោរសមុទ្រចិន និងអាណ្ណាមជាច្រើននាក់ ព្រមទាំងពួកអាវ៉ាសែផ្សេងៗ ដែលវង់ចាំតែពេលបម្រើចៅហ្វាយខ្លាំងពូកែម្នាក់ឲ្យមក រស់នៅជាមួយខ្លួន ។ ម៉ាក់គូបានដណ្តើមយកទីប្រជុំជនធំៗចំនួន៧ដាក់មកក្នុងអំណាចរបស់ខ្លួន ៖ ទី១គឺពាម[៤៥] ដែលក្រោយមកមានឈ្មោះថា ហាទៀង, កោះភូកុកដែលខ្មែរហៅថាកោះត្រល់, ស្រែលួងកែដែលខ្មែរហៅថា ស្រែអំបិល នៅក្នុងខេត្រកំពង់សោម, វៀងធំ (កំពង់សោម), ក្រមួនស, កានវត (កំពត) និងកាម៉ៅនៅភាគខាងត្បូង ដែលកាលពីមុនមានមានឈ្មោះថា ទឹកខ្មៅ ។

ការប្រមូលបានទីប្រជុំជនទាំង៧ដាក់មកក្នុងអំណាចរបស់ខ្លួន មានន័យថាអតីតមេចោរសមុទ្រនេះបានបង្កើតបានក្សត្រប្រទេសមួយនៅលើទឹកដីកម្ពុជា ។ ដើម្បីធានាអនាគតរបស់ខ្លួន ម៉ាក់គូបានបញ្ជូនទូតទៅចូលគាល់ស្តេចអាណ្ណាម ទូលថាទឹកដីអាណាខេត្រភាគអាគ្នេយ៍នេះខ្លួនសូមលើកថ្វាយស្តេចអាណ្ណាម ហើយសុំការអនុញ្ញាតគ្រប់គ្រងជំនួស ។ ស្តេចអាណ្ណាមបានចាត់តាំងលើកម៉ាក់គូជាអភិបាល ហើយជាឧត្តមសេនីយ៍លើទឹកដីមាត់ឈូងសមុទ្រសៀមទាំងមូល (១៧១៥) បើទោះបីថាម៉ាក់គូនេះគ្មានសិទ្ធិអ្វីបន្តិចបន្តួចលើទឹកដីទាំងអស់នោះក៏ដោយ ព្រោះថាទ័ពរបស់គេមិនដែលវាយដណ្តើមបានម្តងណាទេ ហើយក៏គ្មានការធ្វើសម្បទានឲ្យ ឬក៏មានការប្រទូសរ៉ាយអ្វីដែរ ។

គឺដោយបែបនេះហើយដែលម៉ាក់គូបានក្លាយខ្លួនទៅជាមន្ត្រីដ៏មហិមាម្នាក់ តែក៏ជាមេចោរសមុទ្រដ៏សាហាវម្នាក់សម្រាប់រាជវាំងអាណ្ណាមក៏ដូចជារាជវាំងកម្ពុជា ផងដែរ ។

នៅពេលដែលពួកសៀមចង់ដឹកនាំទ័ពមកចុះនៅហាទៀង ដើម្បីបន្តដំណើរឡើងទៅវាយអ្នកអង្គឯមពួកនេះបានមកជួបឧបសគ្គមួយ គឺម៉ាក់គូនេះឯង ដែលគាំទ្រស្តេចកំពុងសោយរាជ្យ ហើយបានកេណ្ឌទ័ពចេញពីពួកមនុស្សយង់ឃ្នងចម្រុះជាតិសាសន៍ ត្រៀមប្រយុទ្ធរួចជាស្រេច ។ ម៉ាក់គូបានវាយទ័ពជើងទឹកសៀម ដែលដឹកនាំដោយពញាកាសា និងតេជោ ឲ្យបរាជ័យស្ទើរតែទាំងស្រុង ។ តែទ័ពសៀមខាងជើងគោក ទទួលបានលទ្ធផលល្អអាចរុញច្រានទ័ពអាណ្ណាមរបស់ព្រះកែវហ្វ៊ាអង្គឯមឲ្យដកថយមកត្រឹមពោធិសាត់ និងមកដល់ឧត្តុង្គ ក្រោយពីច្បាំងគ្នាអស់ពេល១ឆ្នាំ ។

ដោយពិនិត្យឃើញថាមិនអាចបន្តទ្រាំទ្របានទេ ព្រះកែវហ្វ៊ាអង្គឯមបានសាកសួរយោបល់សេនាមន្ត្រីដែលតាមហែហម រួចក៏ចាត់បញ្ជូនរាជទូតឲ្យទៅចរចាជាមួយឧត្តមសេនីយ៍សៀម ពញាចក្រី ថាព្រះអង្គយល់ព្រមដាក់កម្ពុជាជាចំណុះសៀម ហើយនឹងលើកសួយសារអាករជាផ្កាមាសផ្កាប្រាក់ទៅថ្វាយរៀងរាល់ឆ្នាំប្រសិនណាបើសៀមទុកឲ្យព្រះអង្គកាន់អំណាចដដែល ហើយនាំយកអ្នកអង្គម្ចាស់ខ្មែរដែលនៅជាមួយទ័ពសៀមទៅអយុធ្យាវិញ ជាពិសេស គឺអតីតព្រះរាជាខ្មែរដែលទ័ពសៀមចង់យកមកឲ្យសោយរាជ្យនៅកម្ពុជាវិញ ។

[៤៥] ពាម នេះ ជាឈ្មោះទីប្រជុំជនរបស់ខេត្រខម ឬមឿងខម ។ ពួកអាណ្ណាមហៅថា ភួនថាញ់ ។

មេទ័ពសៀមបានយល់ព្រមតាមបណ្ដាល័ក្ខខ័ណ្ឌទាំងអស់នេះ ហើយក៏នាំទ័ពត្រលប់ទៅអយុធ្យាវិញ ដោយនាំយកអ្នកអង្គមាស់ និងអតីតស្ដេចខ្មែរទៅផង ។

ប្រជារាស្ត្រ និងនាម៉ឺនមួយចំនួនដែលមិនគាំទ្រព្រះកែវហ្វាមានការខឹងសម្បាជាខ្លាំង ហើយតាមការជំណាលតៗគ្នាមកបាននិយាយថា គេនាំគ្នាហៅព្រះកែវហ៊្វាអង្គឯមថាជាស្ដេចសៀម ។ ដោយទ្រាំនឹងពាក្យអាស្រូវនេះមិនបាន ព្រះកែវហ៊្វាក៏ដាក់រាជសម្បត្តិថ្វាយព្រះរាជបុត្ររបស់ព្រះអង្គ គឺអ្នកអង្គជ័យ ។ នៅពេលនោះព្រះអង្គមានព្រះជន្ម៤២ព្រះវស្សាហើយ ហើយទ្រង់សោយរាជសម្បត្តិបាន៦ឆ្នាំ ។

## ២៧- អ្នកអង្គជ័យ-ព្រះសត្ថា (១៧២២-១៧២៩)

អ្នកអង្គជ័យមានព្រះជន្មាយុ២០ព្រះវស្សាហើយ នៅពេលដែលទ្រង់ឡើងសោយរាជ្យ ។ ក្រោយពីព្រះបិតាដាក់រាជសម្បត្តិថ្វាយបាន២ខែ ព្រះអង្គបានត្រូវអភិសេកនៅឧត្ដុង្គក្រោមព្រះនាមថា ព្រះសត្ថា និងមានព្រះឋានៈជាព្រះរាជាស្នង ។ ទ្រង់បានយកព្រះមាតុច្ឆាសម្ដេចព្រះស្រីសុជាតា បុត្រីរបស់ព្រះជ័យជេដ្ឋាជាព្រះអគ្គមហេសី ។

រជ្ជកាលរបស់ព្រះអង្គ បានចាប់ផ្ដើមឡើងជាមួយនឹងការវាយពួកក្លឹង ឬពួកហិណ្ឌូរបស់នាងភាក់ ឲ្យបរាជ័យ ។

ក្នុងរជ្ជកាលនេះ ព្រះអយ្យកោជ័យជេដ្ឋា ដែលបានសោយរាជ្យ ហើយដាក់រាជ្យជាច្រើនលើកច្រើនគ្រាដើម្បីសាងព្រះផ្នួស មានព្រះជន្ម៦៥ព្រះវស្សា ហើយមានព្រះឋានៈជាព្រះឧភយោរាជ ។ ព្រះអង្គធ្លាក់ព្រះកាយប្រឈួន ហើយសុគតទៅនៅក្នុងឆ្នាំ១៧២៥ ។

នៅឆ្នាំ១៧២៩ មិនដឹងជាឡើយណាយនឹងរាជកិច្ច ឬក៏ដោយមានការផ្ដល់យោបល់ពីព្រះបិតាព្រះកែវហ៊្វាអង្គឯម ព្រះសត្ថាបានដាក់រាជសម្បត្តិថ្វាយព្រះបិតាវិញ ក្រោយពីគ្រងរាជបល្ល័ង្កបាន៨ឆ្នាំ ។

## ២៨- ព្រះកែវហ៊្វាបរមបពិត្រ-កែវហ៊្វាអង្គឯម រជ្ជកាលទី២ (១៧២៩-១៧៣០)

ព្រះកែវហ៊្វាអង្គឯមបានសោយរាជសម្បត្តិឡើងវិញ ហើយបានទទួលព្រះរាជាភិសេកក្រោមព្រះនាមថា សម្ដេចស្ដេចព្រះរាជឱង្ការព្រះជ័យជេដ្ឋាធិរាជរាមាសូរកំពូលលោកិយ៍ត្រៃភាវនា ។ ប៉ុន្ដែ បានតែ៧ខែ ប្រជារាស្ត្រក៏បះបោរប្រឆាំងនឹងព្រះអង្គ ធ្វើឲ្យព្រះអង្គដាក់រាជសម្បត្តិថ្វាយ ព្រះរាជបុត្រព្រះសត្ថា ម្ដងទៀត ។

## ២៩- ព្រះអង្គជ័យ ហៅ ព្រះសត្ថា រជ្ជកាលទី២ (១៧៣០-១៧៣៦)

ព្រះសត្ថា បានត្រូវអភិសេកជាលើកទី២នៅដើមឆ្នាំ១៧៣០ ក្រោមព្រះនាមថាព្រះបាទសម្ដេច ស្ដេច

ព្រះរាជឱង្ការព្រះបរមោ្មរាជាធិរាជរាមាធិបតី ។ ពេលនោះទ្រង់មានព្រះជន្ម២៧ព្រះវស្សាហើយ ។ ព្រះបិតារបស់ព្រះអង្គដែលបានដាក់រាជសម្បត្តិថ្វាយព្រះអង្គ បានទទួលព្រះឋានៈជាព្រះឧភយោរាជ ។

នៅក្នុងឆ្នាំបន្ទាប់ មានជនភៀសខ្លួនលាវម្នាក់ រស់នៅភូមិព្រះសូត្រក្នុងខែត្របាភ្នំ ដែលឡប់សតិ បានប្រកាសខ្លួនថា ជាអ្នកមានបុណ្យ ហើយទទួលភារកិច្ចឲ្យចុះមកសម្លាប់ផ្តាច់ពូជពួកអាណ្ណាមចេញពីកម្ពុជា ។ មានប្រជាជនជាច្រើនជឿជាក់លើជននេះ ហើយដើរតាមនៅភាគខាងត្បូងនៃព្រះរាជាណាចក្រ រហូតទៅដល់ភាគខាងម្ខាងទៀតនៃទល់ដែន ។ ពួកនេះបាននាំគ្នាឆ្លងចូលទៅក្នុងកូសាំងស៊ីន ហើយចាប់កាប់សម្លាប់រាល់ជនអាណ្ណាមណាដែលគេជួបប្រទះ ។ ពេលនោះឧត្តមសេនីយ៍ដែលគ្រប់គ្រងនៅសាយហ្គនបានបញ្ជូនទ័ពមួយកងតូច ឲ្យមកបង្ក្រាបពួកនេះ ហើយដេញតាមរហូតដល់ឆ្លងផុតទល់ដែន ។ ពេលមកដល់ស្រុក ដោយមានជំនឿងប់ងុលលើជនលាវពួកនេះ ក៏ចាប់តាំងធ្វើការកាប់សម្លាប់ជាបន្តទៀត ។ ព្រះរាជាបានចាត់ស្នងការព្រះរាជាណាចក្រឲ្យទៅបង្ក្រាប ហើយពួកនេះក៏បែកខ្ញែកគ្នាអស់ទៅ ។ ស្តេចអាណ្ណាម នៅពេលដែលបានជ្រាបអំពីហេតុការណ៍កាប់សម្លាប់រង្គាលនេះ ក៏បញ្ជូនកងទ័ពមកវាយកម្ពុជា ដោយមិនបានគិតថា ព្រះរាជាកម្ពុជា បានធ្វើអន្តរាគមន៍រួចទៅហើយទេ ។ ដោយមិនអាចទប់ទល់នឹងទ័ពអាណ្ណាមបាន ព្រះសត្ថាក៏ភៀសព្រះកាយទៅគង់នៅឯពាមស្រែង ក្នុងខែត្រសន្ទុក ។ ទ្រង់បានកេណ្ឌទ័ពប្រញាប់ប្រញាប់ រួចដឹកនាំមកកាន់ភ្នំពេញ ជាទីកន្លែងដែលពួកអាណ្ណាម ទើបធ្វើដំណើរមកដល់ ។ ព្រះអង្គបានវាយទ័ពអាណ្ណាមឲ្យបរាជ័យ រត់បែកខ្ញែកគ្នាត្រឡប់ទៅកូសាំងស៊ីនវិញ តាមដៃទន្លេទាំង២ ។

ទទួលបានពត៌មានស្តីពីបរាជ័យនេះ ស្តេចអាណ្ណាមបានចេញបញ្ជាឲ្យកេណ្ឌទ័ពមួយកងធំជាងមុន ចេញដំណើរមកវាយកម្ពុជាទៀត ។

នៅពេលដែលទ័ពអាណ្ណាមមកដល់ភ្នំពេញ ព្រះរាជាដែលទើបតែយាងត្រលប់ជាមួយរាជវង្សានុវង្សមកគង់នៅឧត្តុង្គ បានភៀសព្រះអង្គម្តងទៀត ទៅគង់នៅឯពាមក្របៅ ក្នុងខែត្រសន្ទុក ។ ទ្រង់ជ្រើសរើសទ័ពនៅទីនោះ រួចដឹកនាំមកវាយពួកអាណ្ណាម ធ្វើឲ្យពួកនេះបរាជ័យម្តងទៀត ហើយបង្ខំឲ្យដកថយទៅខែត្រមីថ និងវិញឡុងអស់ទៅ ។ ខែត្រទាំង២នេះជាទឹកដីរបស់កម្ពុជាទេ ក៏ប៉ុន្តែពួកអាណ្ណាមកាន់កាប់ ហើយដាក់បញ្ចូលជាផ្លូវការជាមួយខែត្រ៣ទៀត ដែលគេវាយយកបានពីមុន ។

នៅពេលនោះ ដោយពិនិត្យឃើញថាឧត្តុង្គស្ថិតនៅជិតភ្នំពេញពេក ព្រះរាជាក៏សម្រេចព្រះទ័យចាកចោលរាជធានីនេះ ដោយនាំរាជបរិពារទៅគង់នៅឯលង្វែកវិញ ឆ្ងាយទៅខាងជើងបន្តិច ដែលព្រះរាជាមុនៗ បានបោះបង់ចោលកាលពីសតវត្សរ៍មុន ។ ដោយហេតុនេះហើយបានជារាជធានីខ្មែររំកិលខិតទៅខាងជើងទៀត ព្រោះខ្លាចអាណ្ណាម ផ្ទុយខុសពីពេលមុនដែលរំកិលខិតមកខាងត្បូង ដោយខ្លាចសៀម ។

នៅក្នុងឆ្នាំ១៧៣៦ ព្រះរាជាព្រះសត្ថា បានដាក់រាជសម្បត្តិដើម្បីសាងផ្នួស៣ថ្ងៃ រួចទើបលាចាកសិក្ខាបទមកគង់លើរាជបល្ល័ង្ក កាន់អំណាចឡើងវិញ ។

នៅក្នុងឆ្នាំដដែលនោះ ព្រះរាជាមានមន្ទិលសង្ស័យថាព្រះអគ្គមហេសីស្រីសុជាតា ជាបុត្រីរបស់ព្រះជ័យជេដ្ឋា ក្បត់នឹងព្រះអង្គ ឃុបឃិតជាមួយអ្នកអង្គសូរប្ញសម្ដេចព្រះឧទ័យ, អ្នកអង្គស្ងួន ហៅ ព្រះស្រីជ័យជេដ្ឋា, និងចៅពញាច័ន្ទហៅបទុមរាជា ជាបុត្រាមួយអង្គរបស់ព្រះអង្គទង និងបុត្រារបស់អតីតព្រះរាជាស្រីបទុមរាជា ដែលសុទ្ធតែត្រូវជាបងប្អូនជីទួតមួយរបស់ព្រះអង្គ ចង់ទម្លាក់ព្រះអង្គពីអំណាច ឬក៏ចង់ធ្វើឃាតព្រះអង្គ ។ នៅឆ្នាំបន្ទាប់មកទៀត ដោយសន្ស៊ំព្រះទ័យចង់សងសឹកនឹងពួកនេះ ព្រះរាជាបានយាងមកគង់នៅឯភ្នំពេញ រួចហើយក៏រៀបចំវិធានការចាប់ខ្លួន និងកាប់សម្លាប់ព្រះមហេសី និងបក្សពួកទាំងអស់ ។

ក្សត្រាទាំង៣ព្រះអង្គ ពេលដឹងខ្លួនថាព្រះរាជាប្រុងនឹងធ្វើបាបហើយ ក៏គេចខ្លួនចេញពីរាជធានី ហើយប្រមែប្រមូលកងទ័ពដើម្បីប្រយុទ្ធប្រឆាំងនឹងព្រះរាជាវិញ ។ ការប្រយុទ្ធស៊ីសាច់ហុតឈាមសាហាវខ្លាំងណាស់អស់រយៈពេលជាច្រើនខែ ។ នៅទីបញ្ចប់ ព្រះរាជាសត្ថា និងព្រះអនុជអ្នកអង្គឯមត្រូវរត់ភៀសព្រះកាយទៅកូសាំងស៊ីន នៅក្នុងឆ្នាំ១៧៣៧ ។ បងប្អូនព្រះស្រីជ័យជេដ្ឋា និងបទុមរាជាបានដេញតាមប្រកិតពីក្រោយ រួចហើយព្រះស្រីជ័យជេដ្ឋាក៏បោះទ័ពនៅនឹងបាភ្នំលើត្រើយខាងកើតទន្លេ ព្រះបទុមរាជាបោះទ័ពនៅលើត្រើយខាងលិច ហើយរៀបចំវិធានការទប់ទល់កុំឲ្យព្រះរាជាព្រះសត្ថាវិលត្រលប់មកវាយយកកម្ពុជាវិញ បើទោះជាព្រះអង្គមានទ័ពអាណ្ណាមជួយក្ដី ។ នៅពេលនោះ អ្នកអង្គម្ចាស់ឯម ដែលព្រះធម្មោរាជាជាបិតាបានប្រទានព្រះនាមរបស់ព្រះអង្គថ្វាយ -នៅសម័យនោះ ការប្រទានព្រះនាមផ្ទាល់ថ្វាយមានន័យថាទ្រង់បានផ្ទេររាល់សិទ្ធិទាំងឡាយថ្វាយ- បានវាយចូលលុកលុយខែត្រអង្គរ ជាមួយនឹងកងទ័ពដែលគេណ្ឌបាននៅកូរ៉ាត់ អស់ពេលច្រើនឆ្នាំមកហើយ ។ ជាមួយគ្នានោះ ស្ដេចសៀមបានប្រគល់ទ័ព២ពាន់នាក់ឲ្យអ្នកអង្គទងជាព្រះបិតុលា ចេញតាមពីក្រោយដើម្បីជួយ និងបានឲ្យព្រះធម្មោរាជដឹកនាំទ័ព៣ពាន់នាក់ឡើងទូកមកចុះនៅឯកំពត ។

នៅពេលដែលទ័ពអ្នកអង្គម្ចាស់ឯម និងទ័ពព្រះអង្គទងចុះមកជិតដល់លង្វែក នៅសល់ប្រហែលជា ៥០គីឡូម៉ែត្រ ព្រះមហាក្សត្រីស្រីសុជាតាបានកោះប្រជុំរាជវង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រីពិគ្រោះយោបល់ រួចហើយព្រះនាងក៏សម្រេចនាំគ្នាមកជួបក្សត្រទាំង២អង្គនៅខត្តុង្គ ។ ក្រោយពីជួបគ្នាបន្តិចនៅលើទន្លេសាប គេបានសម្រេចថា ត្រូវមកជួបជុំគ្នា ដោះស្រាយបញ្ហានៅឯភ្នំពេញ ។ ក្សត្រាទាំង២យាងចូលមកក្នុងរាជធានីជាមួយនឹងកងទ័ពទាំងអស់ ហើយគេបានស្រុះស្រួលឯកភាពគ្នាថាលើកព្រះធម្មោរាជាឲ្យគ្រងរាជបល្ល័ង្កឡើងវិញ ។ ប៉ុន្តែព្រះធម្មោរាជាទើបតែបានថ្វាយព្រះនាមរបស់ព្រះអង្គថ្វាយដល់ព្រះរាជបុត្រា ព្រះធម្មោរាជាអង្គឯម ម្ល៉ោះហើយទ្រង់ប្រកែកមិនព្រមទទួលយករាជសម្បត្តិទេ សូមឲ្យថ្វាយទៅព្រះរាជបុត្រាទៅចុះ ។ ក៏ប៉ុន្តែរាជវង្សានុវង្សមិនព្រម ពីព្រោះថា មានតែព្រះអង្គទេដែលការបរបាគ្នាអាចទទួលយកបាន ដូច្នេះព្រះអង្គត្រូវតែលះបង់ការផ្ទេរព្រះនាមថ្វាយព្រះរាជបុត្រសិន ។

ដោយមិនសូវសព្វព្រះរាជហឫទ័យប៉ុន្មាន ព្រះធម្មោរាជាបានសម្រេចព្រះទ័យគង់នៅខែត្រទ្រាំង រហូត

ដល់ឆ្នាំ១៧៣៨ ទាល់តែដល់ពេលដែលមានការចាំបាច់នៅភ្នំពេញ ដែលបានក្លាយជាមជ្ឈមណ្ឌលរបស់ព្រះរាជាណាចក្រ ទើបព្រះរាជវង្សានុវង្សទៅយាងព្រះអង្គឲ្យវិលត្រលប់មកកាន់រាជធានីលង្វែកវិញ[៩៦] ។

## ៣០- ព្រះធម្មរាជា-រជ្ជកាលទី៣ (១៧៣៨-១៧៤៧)

ព្រះធម្មរាជាអង្គសូរទ្រង់មានព្រះជន្ម៤៨ព្រះវស្សា នៅពេលដែលទ្រង់ត្រូវបានអភិសេកជាលើកទី៣ ។ ពេលអភិសេកលើកនេះទ្រង់មានព្រះនាមថា ព្រះបាទសម្តេចព្រះរាជឱង្ការព្រះជ័យជេដ្ឋាធិរាជរាមាធិបតីបរមបពិត្រ ។ ទ្រង់ត្រូវជាព្រះរាជបុត្រារបស់ព្រះរាជាជ័យជេដ្ឋា ដែលទ្រង់បានដាក់រាជសម្បត្តិថ្វាយព្រះអង្គ ។ ទ្រង់សោយរាជ្យម្តងបានមួយឆ្នាំនៅក្នុងឆ្នាំ១៧០២-១៧០៣ រួចបានដាក់រាជសម្បត្តិថ្វាយព្រះបិតាវិញ ។ បន្ទាប់មក ក្រោយពីសោយរាជ្យបាន២ឆ្នាំ ព្រះបិតាព្រះអង្គក៏ដាក់រាជសម្បត្តិថ្វាយព្រះអង្គទៀត ហើយសោយរាជ្យពីឆ្នាំ១៧០៦ ដល់១៧១៤ ក៏ត្រូវព្រះកែវហ៊្វាអង្គឯមបណ្តេញចេញពីរាជបល្ល័ង្ក ។ ឥឡូវនេះ ក្រោយពី២៣ឆ្នាំកន្លងផុតទៅទ្រង់បានឡើងគ្រងរាជបល្ល័ង្កកម្ពុជាជាថ្មីម្តងទៀត ។

អ្នកអង្គម្ចាស់អង្គទង ត្រូវជាបុត្រារបស់ព្រះទ័យ ដែលយាងពីចន្ទគាប៊ុន មកចុះចតនៅកំពត មានព្រះជន្ម៤៧ព្រះវស្សា ហើយបានត្រូវលើកឲ្យឡើងជាទីឧភយោរាជ ។ ព្រះទ័យជាបុត្រាបានត្រូវលើកឲ្យឡើងជាព្រះឧបរាជ ។ ព្រះអគ្គមហេសីទ្រង់ទទួលព្រះឋានៈជាសម្តេចព្រះជាតិក្សត្រី ។ ចំណែកឯព្រះធម្មរាជាអង្គឯមជាព្រះរាជបុត្រាមួយអង្គទៀត ដែលមានព្រះជន្ម២៩ព្រះវស្សា បានទទួលព្រះឋានៈជាព្រះកែវហ៊្វា ហើយបានរៀបអាពាហ៍ពិពាហ៍ជាមួយម្ចាស់ក្សត្រីអ្នកអង្គមី ជាបុត្រីរបស់នាងអង្គសូរដែលសុគតទៅនៅពេលប្រសូត្របុត្រ ។

រាជពង្សាវតារបានលើកឡើងថា នៅពេលនោះទន្លេមេគង្គមានជំនន់មួយធំខុសប្លែកពីរៀងរាល់ឆ្នាំ ហើយនិងមានការឈ្លោះប្រកែកប្រយុទ្ធគ្នារវាងពួកខ្មែរ និងពួកអាណ្ណាមនៅក្នុងខែត្របាសាក់ (សុកទ្រាំង) ។ ពួកអាណ្ណាម ត្រូវបានវាយឲ្យបរាជ័យ ក៏នាំគ្នាដកថយទៅនៅលើកោះហុងពាមមីសា ក្នុងទន្លេមេគង្គ ហើយបានយកទីនោះរស់នៅរៀបចំហាក់បីដូចជាម្ចាស់កម្មសិទ្ធិតែម្តង ។

ពីរឆ្នាំក្រោយពីម៉ាក់គូទទួលមរណភាពបាត់ទៅក្នុងអាយុ៧៨ឆ្នាំ ឆ្នាំ១៧៣៨ ព្រះរាជាកម្ពុជាធម្មរាជាបានឆ្លៀតឱកាសដែលមានជម្លោះមួយកើតឡើងរវាងពួកខ្មែរជាមួយនឹងបក្សពួករបស់ម៉ាក់គុង ជាកូនរបស់ម៉ាក់គូ ដែលឡើងកាន់អំណាចតពីឪពុក បានមានបំណងចង់ដណ្តើមយកហាទៀងមកវិញ ។ ក៏ប៉ុន្តែហាទៀង មានកម្លាំងការពារយ៉ាងរឹងមាំ និងប៉ិនប្រសប់ ធ្វើឲ្យខាងកម្ពុជាខាតបង់កម្លាំងអស់ជាច្រើន ក៏ដកថយមកវិញ ។

[៩៦] គេនិយាយថា នៅពេលនោះរាជវាំងកម្ពុជា មានដំរីសមួយក្បាល ។

នៅឆ្នាំ១៧៤៧ ព្រះរាជាបានអាពាធ ហើយសុគតទៅ នៅក្នុងព្រះជន្ម៥៧ព្រះវស្សា ។ ព្រះអង្គសោយរាជ្យ ៣ដង បាន១២ឆ្នាំ ហើយមានរយៈពេលយូរជាងគេនៅក្នុងរជ្ជកាលចុងក្រោយ គឺបាន១០ឆ្នាំ ។

## ៣១- ព្រះធម្មោរាជាទី៥-អង្គឯម (១៧៤៧)

ព្រះកែវហ៊្វាអង្គឯម ដែលព្រះធម្មោរាជាជាព្រះបិតាបានលះបង់ព្រះនាម និងសិទ្ធិទាំងអស់ថ្វាយកាលពីឆ្នាំ១៧៣៣ បានឡើងសោយរាជ្យបន្តក្នុងព្រះជន្ម៤២ព្រះវស្សា ។ ការដែលព្រះបិតាលះបង់ព្រះនាម និងសិទ្ធិអំណាចថ្វាយកាលពីពេលមុននេះបានធ្វើឲ្យនាម៉ឺនសព្វមុខមន្ត្រីជ្រើសតាំងព្រះអង្គឡើង ។ ព្រះអនុជរបស់ព្រះអង្គព្រះនាមថាអង្គហ៊ីង ដែលព្រះបិតាបានថ្វាយព្រះនាមថា ស្រីសុរិយោពណ៌នៅក្នុងឱកាសធ្វើពិធីកោរជុក បានបះបោរឡើងដណ្តើមរាជសម្បត្តិ ទាំងព្រះអង្គទើបតែមានព្រះជន្មមិនទាន់គ្រប់ ១៦ព្រះវស្សាផង[៤៧] ។ ទ្រង់បានធ្វើឃាតព្រះរាជា ហើយចង់ឡើងសោយរាជ្យជំនួស ក៏ប៉ុន្តែនាម៉ឺនសព្វមុខមន្ត្រីមិនព្រម ហើយបានលើកព្រះឧភយោរាជ អ្នកអង្គតន់ ហៅថា ព្រះអង្គទង ឲ្យឡើងកាន់អំណាចវិញ ។

## ៣២- រាមាធិបតី-ព្រះអង្គទង (១៧៤៧-១៧៤៩)

ក្សត្រអង្គនេះមានព្រះជន្ម៥៦ព្រះវស្សា និងមានព្រះឋានៈជាព្រះឧភយោរាជអស់កាល ១០ឆ្នាំមកហើយ ។ គេបានលើកឲ្យទ្រង់ឡើងកាន់អំណាច ក៏ប៉ុន្តែមិនមែនលើកឲ្យឡើងគ្រងរាជបល្ល័ង្កទេ គឺទុកឲ្យតែព្រះអង្គចាត់ចែងរាជកិច្ចក្នុងឋានៈជាព្រះឧភយោរាជប៉ុណ្ណោះ ។

នៅឆ្នាំ១៧៤៨ ពួកក្សត្រាដែលភៀសព្រះកាយទៅគង់នៅកូសាំងស៊ីនកាលពី១០ឆ្នាំមុន ជាមួយព្រះសត្ថា បានចាប់ដឹកនាំទ័ពអាណ្ណាមចូលលុកលុយកម្ពុជា ។ ពួកគេបានវាយចៅហ្វាយខែត្របាសាក់ លោកឧកញ៉ានរេន្ទគុក ដែលដឹកនាំទ័ពមួយកងតូចដែលកេណ្ឌបានទាំងប្រញិបប្រញាប់ទៅទប់ទល់ ហើយត្រូវបង្ខំឲ្យដកថយមកកាន់កោះហុងពាមមេសវិញ ។ រួចហើយកងទ័ពរបស់ព្រះអង្គបានធ្វើដំណើរឆ្ពោះមកខាងជើង និងមកជិតដល់ឧត្តុង្គ ។ មកដល់ទីនោះ គេជួបជាមួយទ័ពរបស់លោកនាយករដ្ឋមន្ត្រី ចៅហ៊្វាឯក ក៏វាយទ័ពនោះឲ្យបែកខ្ញែក

[៤៧] ក្សត្រាកម្ពុជា ច្រើនតែបានទទួលឈ្មោះពាដងនៅក្នុង១ជីវិត ៖ គឺទទួលឈ្មោះម្តងនៅពេលដែលគេរៀបចំពិធីកោរសក់ព្រៃពីកំណើត, ម្តងទៀតនៅក្នុងឱកាសកោរជុក ដែលជាពិធីរៀបចំថ្វាយពេលពេញវ័យ ហើយម្តងទៀតនៅពេលដែលរៀបចំពិធីអភិសេកជាស្តេច ជាឧបរាជ ឬក៏ជាព្រះឧភយោរាជ ។ ព្រះអង្គអាច និងមានព្រះនាមទី៤ មួយទៀតនៅពេលដែលទ្រង់សុគត ។ មុនពេលទទួលព្រះនាមក្នុងពិធីកោរជុក ព្រះក្សត្រាអង្គនេះមានព្រះនាមថា អង្គហ៊ីង ។ ទ្រង់ជាបុត្រារបស់ព្រះធម្មោរាជា ជាមួយនឹងអ្នកម្នាងសៀមម្នាក់ឈ្មោះ អ្នកម្នាងរ័ត្ន (១៧៣០) ហើយទ្រង់មានព្រះអនុជរួមមាតាមួយអង្គទៀតព្រះនាមថា ព្រះអង្គដួង ។

ខ្វាត់ខ្វាយអស់ទៅ ។ ព្រះរាជាអង្គទង ព្រះឧបរាជព្រះឧទ័យជារាជបុត្រា ព្រះស្រីជ័យជេដ្ឋា (អ្នកអង្គស្ងួន) ជាបងប្អូនជីដូនមួយ និងត្រូវជាបុត្រារបស់ព្រះស្រីបទុមរាជា និងជាព្រះអនុជរបស់ព្រះធម្មោរាជាដែលព្រះសុរិយោពណ៌ បានធ្វើឃាត ក៏នាំគ្នារត់ទៅស្រុកសៀមសុំជំនួយ ។

អតីតព្រះមហាក្សត្របរមរាជា និងព្រះអនុជអ្នកអង្គឯមក៏ឡើងជាម្ចាស់ស្រុក ហើយបានយាងមកគង់នៅឧត្តុង្គ នៅក្នុងរាជវាំងរបស់ព្រះឧភយោរាជ ដែលស្ថិតនៅពីខាងលិចបឹងប៉ាម៉ា ។ ព្រះអង្គមិនអាចបញ្ឈរទៅលើកងទ័ពអាណ្ណាមបានទេ ក៏បណ្ដោយឲ្យពួកនោះដឹកនាំប្រទេស ធ្វើបាបប្រជារាស្ត្រ នាំឲ្យរាស្ត្រក្ដៅក្រហាយខឹងសម្បាកាន់តែខ្លាំងឡើងៗរាល់ថ្ងៃ ។

លោក ក្រឡាហោមអុក និងចៅហ្វាយខែត្រពោធិសាត់លោកឧកញ៉ាសួគ៌ាលោក អ៊ុក ក្រោយពីបានជូនដំណើរព្រះឧភយោរាជឆ្លងកាត់ទល់ដែនរួចហើយ ក៏ត្រលប់មកពោធិសាត់វិញ រៀបចំជ្រើសរើសកងទ័ព ។ ពួកឧត្តមសេនីយ៍អាណ្ណាមក៏ដឹកនាំទ័ពធ្វើដំណើរសំដៅមកកាន់ខែត្រពោធិសាត់ ។ ក្នុងជាមួយគ្នានោះ ព្រះអង្គ ហ៊ីងស្រីសុរិយោពណ៌ក៏បានដឹកនាំទ័ពខ្មែរមួយកង តាមដើងទឹកមកដែរ ។ មេដឹកនាំទ័ពក្រោយនេះបានត្រូវស្លាប់ នៅពេលក្រោយបន្តិចមក តែទ័ពអាណ្ណាមបានធ្វើដំណើរមកដល់វាលស្រាបអង្កាម (រលាប្អៀរ) ហើយបោះទីតាំងនៅកន្លែងនោះតែម្ដង ។ ពេលនោះលោកក្រឡាហោមក៏លើកទ័ពមកដល់ វាយប្រហារទៅលើទ័ពអាណ្ណាម ដែលដឹកនាំដោយអ្នកអង្គអេងឲ្យបរាជ័យទាំងស្រុង ហើយរត់គេចខ្លួនកាត់មុខឧត្តុង្គ មិនហ៊ានចូលក្នុងក្រុងទេ ។ អ្នកអង្គឯម និងអតីតព្រះរាជាធម្មោរាជាក៏រួសរាន់នាំគ្រួសាររត់តាមពួកអាណ្ណាម វិលត្រលប់ទៅកូសាំងស៊ីនវិញដែរ ។ អ្នកអង្គឯម យាងមកដល់កំពង់ឆ្នាំងមិនបានប៉ុន្មានផង ក៏សុគតទៅ (១៧៤៨) ។ ចំណែកឯអតីតព្រះរាជាធម្មោរាជ បានយាងទៅដល់អាណ្ណាម ប៉ុន្តែដោយនឿយហត់ជាខ្លាំង ក៏សុគតទៅក្នុងឆ្នាំនោះដែរ ក្នុងជន្មាយុ ៤៣ព្រះវស្សា ។

លោកក្រឡាហោម អុក និងចៅហ្វាយខែត្រពោធិសាត់ក៏ចាត់ចែងរៀបចំស្រុកទេសឡើងវិញ ផ្លាស់ប្ដូរចៅហ្វាយខែត្រណាដែលគ្មានសមត្ថភាព គេចវេះមិនបានទប់ទល់ជាមួយសត្រូវ រួចបានស្នើសុំស្ដេចសៀមឲ្យបញ្ជូនព្រះស្រីជ័យជេដ្ឋាអង្គស្ងួន ដែលត្រូវជាបុត្រារបស់ព្រះរាជាស្រីបទុមរាជា ដែលអង់អាចក្លាហានជាង ឲ្យមកទទួលរាជសម្បត្តិនៅកម្ពុជា គឺមិនបានសុំឲ្យបញ្ជូនព្រះរាជាអង្គទងឬព្រះឧភយោរាជឧទ័យ ដែលអស់សេចក្ដីក្លាហានទៅហើយនោះទេ ។ ស្ដេចសៀមបានយល់ព្រមតាមសំណើនេះ ហើយក៏បញ្ជូនព្រះស្រីជ័យជេដ្ឋា ឲ្យវិលត្រលប់មកវិញជាមួយមន្ត្រីសៀមជាច្រើននាក់ សម្រាប់ធ្វើជាទីប្រឹក្សាជួយព្រះអង្គ ។

## ៣៣- ព្រះជ័យជេដ្ឋាទី៥ អង្គស្ងួន (១៧៤៩-១៧៥៥)

ព្រះជ័យជេដ្ឋា ពេលនោះមានព្រះជន្ម៤២ព្រះវស្សាហើយ ។ ព្រះអង្គជាព្រះរាជបុត្រារបស់ព្រះបាទធម្មោរាជា ដែលព្រះសុរិយោពណ៌អង្គហ៊ីងបានធ្វើគុត ។ ព្រះអង្គត្រូវបានអភិសេកឲ្យឡើងសោយរាជ្យក្រោម

ព្រះនាមថា  ព្រះបាទសម្តេចស្តេចព្រះរាជឱង្ការព្រះស្រីជ័យជេដ្ឋាធិរាជបរមបពិត្រ ។

ព្រះអង្គទទួលស្គាល់គុណូបការៈរបស់ចៅហ្វាយខែត្រពោធិសាត់ ដែលបានស៊ូប្តូរនឹងព្រះអង្គនៅក្នុងពេលមានសង្គ្រាម ម្ល៉ោះហើយព្រះអង្គក៏តែងតាំងឲ្យធ្វើជាចៅហ៊្វា គឺនាយករដ្ឋមន្ត្រី ។ ការលើកតម្កើងចៅហ្វាយខែត្រពោធិសាត់នេះ បានធ្វើឲ្យនាម៉ឺនមន្ត្រីចាស់ៗកើតការច្រណែន ក៏ឃុបឃិតគ្នាធ្វើយ៉ាងណាបំបែកលោក ចៅហ៊្វា ចេញពីព្រះទ័យព្រះរាជា ។ ពួកមន្ត្រីទាំងអស់នោះចាក់រុកថា លោក ចៅហ៊្វា ក្បត់ មានបំណងចង់ដណ្តើមយករាជសម្បត្តិ រហូតដល់ព្រះរាជាជឿ ហើយបានចាត់ឲ្យជនម៉ាឡេម្នាក់ ឈ្មោះថា ប៉ូឡឹម៉ែន លួចធ្វើឃាតលោក ចៅហ៊្វា ចោល ។ លោក ចៅហ៊្វាអុក ដឹងរឿងនេះ ក៏គេចខ្លួនទៅនៅឯស្រុកសៀមទៅ ហើយព្រះរាជាក៏លើកខកញ៉ាចក្រីពូ ឲ្យឡើងជំនួសវិញ ។

នៅឆ្នាំ១៧៥១ ពួកអ្នកអង្គម្ចាស់ដែលភៀសព្រះកាយទៅគង់នៅឯស្រុកសៀមតាំងពីឆ្នាំ១៧៤៨ បានទទួលការអនុញ្ញាតពីព្រះរាជាសៀមឲ្យវិលត្រលប់មកស្រុកវិញ ហើយបានមកតាំងព្រះរាជដំណាក់នៅពាមចាស់ក្នុងស្រុកពោធិមេបា ។ ព្រះឧបរាជឧទ័យ ដែលប្រហែលជាមិនគាំទ្រផែនការរបស់ព្រះបិតារបស់ព្រះអង្គ ក្នុងការទម្លាក់ព្រះរាជាស្រីជ័យជេដ្ឋាពីរាជសម្បត្តិ បានយាងចូលសាងព្រះផ្នួសនៅអង្គរវត្ត ។ ចំណែកព្រះអង្គទង ដែលគេបង្ខំឲ្យទទួលតួនាទីជាព្រះឧភយោរាជ បន្ទាប់ពីការជ្រើសរើសព្រះមហាក្សត្រថ្មីឲ្យគ្រងរាជបល្ល័ង្កហើយនោះ បានយាងទៅគង់នៅក្នុងខែត្រក្រង ស្ថិតនៅតាមមាត់ប្រាំងទន្លេខាងស្តាំភាគខាងត្បូងបំផុតនៃបឹងទន្លេសាប ។

ក្នុងពេលជាមួយគ្នានោះ មានមន្ត្រីម្នាក់ឈ្មោះថា ក្បេត្រឯក ដែលភៀសខ្លួនទៅនៅស្រុកសៀម បានរៀបចំផែនការទម្លាក់ព្រះស្រីជ័យជេដ្ឋាចេញពីរាជបល្ល័ង្ក ដើម្បីលើកអ្នកអង្គម្ចាស់តន់ បុត្រារបស់ព្រះឧបរាជដែលយាងចូលសាងព្រះផ្នួសនៅអង្គរវត្ត ឲ្យឡើងសោយរាជ្យវិញ ។ មន្ត្រីនោះបានបញ្ជូនកូនប្រុសរបស់ខ្លួនឲ្យទៅកេណ្ឌទ័ពក្នុងចំណោមអ្នកស្រុកដែលរស់នៅឯភ្នំខ្លោល ។ ទៅដល់ភ្នំខ្លោល កូនមន្ត្រីនោះបានជួបជាមួយមនុស្សឡប់សតិម្នាក់ឈ្មោះ សួស ដែលអ្នកស្រុកគោរពស្រលាញ់ ជឿថាជាមនុស្សមានបុណ្យមានកម្លាំងមហិមា ហើយនាំគ្នាហៅថា សីលសួស ។ ផែនការក្បត់នេះបានធ្វើឲ្យរំខានដល់ព្រះឧភយោរាជជាខ្លាំង ព្រះអង្គក៏រៀបចំអន្ទាក់ចាប់ ក្បេត្រឯក បាន រួចហើយក៏សម្លាប់ចោលទៅ ។ ពេលនោះសីលសួសមានទ័ព៣ពាន់នាក់ បានប្រកាសខ្លួនឡើងជាព្រះអង្គយ៉ង ជាឈ្មោះអ្នកអង្គម្ចាស់មួយអង្គដែលសុគតយូរណាស់មកហើយ ហើយបានលើកជនខ្ទិនខ្ទង់ម្នាក់ជាស្តេច ដាក់ឈ្មោះថា ព្រះបាទអង្គុលីរាជ ។ ព្រះឧភយោរាជបានកេណ្ឌកម្លាំង រួចហើយយាងទៅកាន់ភូមិក្បាលក្របី នៅខាងលិចឧត្តុង្គ ជាទីកន្លែងដែលកូនរបស់ក្បេត្រឯក និងសីលសួសរស់នៅ ដោយមានព្រះកែវហ៊្វា និងព្រះអង្គអាត ទៅជាមួយផង ។ មនុស្សទាំង២នាក់នេះ ត្រូវគេចាប់បាន ហើយសម្លាប់ចោលទៅ ។ បន្ទាប់មកព្រះឧភយោរាជបាននាំទ័ពទៅវាយស្តេចអង្គុលីរាជទៀត ។ ទ្រង់បានវាយបំបែកទ័ពរបស់ស្តេចនេះ រួចចាប់ស្តេចអង្គុលីរាជយកទៅសម្លាប់ចោលនៅឯកំរែងភ្នំស្រង់ នៅក្នុងខែត្រក្រង ។

ប្រហែលនៅចុងឆ្នាំ១៧៥៣ ព្រះឧភយោរាជបានយាងមកគង់នៅឧត្តុង្គវិញ ដើម្បីឲ្យបានជិតព្រះរាជា

ជាព្រះភាគិនេយ្យ ។ នៅឆ្នាំបន្ទាប់មកទៀត បុត្រារបស់ព្រះអង្គគឺអ្នកអង្គសួរ ហៅព្រះឧបរាជឧទ័យ បានសោយទិវង្គតនៅក្នុងវត្តអង្គរវត្ត ។ ពេលនោះព្រះអង្គមានព្រះជន្ម៤០ព្រះវស្សា ។ បុត្រារបស់ព្រះអង្គ បានប្រកាន់យកនាមព្រះបិតាថា ព្រះឧទ័យ ដើម្បីជាការបញ្ជាក់ថាព្រះអង្គទ្រង់ឡើងស្នងបន្តពីព្រះបិតា ។ ប៉ុន្តែឋានៈជាព្រះឧបរាជបានត្រូវធ្លាក់ទៅលើព្រះអង្គហ៊ីងស្រីសុរិយោពណ៌ ដែលត្រូវជាបុត្រារបស់អតីតព្រះរាជាព្រះជ័យជេដ្ឋា ហើយជាឃាតករព្រះរាជាធម្មោរាជារអង្គឯមនៅឆ្នាំ១៧៤៧ ។

ព្រះរាជាជ័យជេដ្ឋាបានសុគតនៅក្នុងឆ្នាំ១៧៥៥ ក្នុងព្រះជន្មាយុ៨៦ព្រះវស្សា ក្រោយពីទ្រង់សោយរាជសម្បត្តិបាន៧ឆ្នាំ ។

## ៣៤- ព្រះរាមាធិបតី-អង្គទង (១៧៥៦-១៧៥៧)

ព្រះឧភយោរាជ ដែលធ្លាប់សោយរាជ្យបានមួយឆ្នាំម្តងរួចមកហើយកាលពីឆ្នាំ១៧៤៨-១៧៤៩ បានត្រូវពួកបារគូ និងនាម៉ឺនសព្វមុខមន្ត្រីលើកឲ្យឡើងសោយរាជ្យម្តងទៀតនៅដើមឆ្នាំ១៧៥៦ នៅពេលដែលទ្រង់មានព្រះជន្មាយុ៥៧ព្រះវស្សា ។ ព្រះអង្គមានព្រះឋានៈជាអ្នកគ្រងរាជ្យ ឬរាជានុសិទ្ធិ ។

នៅក្នុងឆ្នាំនោះដែរ ក្រោយពីមានជម្លោះតូចតាចមួយ ព្រះឧបរាជសុរិយោពណ៌បានមានបំណងធ្វើឃាតព្រះឧទ័យ (អង្គតន់) ក៏ប៉ុន្តែព្រះអង្គតន់បានភៀសព្រះកាយទៅដល់ពាម-ហាទៀង ដែលកូនម្នាក់របស់អតីតមេចោរសមុទ្រម៉ាក់គូ គឺម៉ាក់តុង[៤៨] កំពុងត្រួតត្រាកន្លែងនោះបម្រើឲ្យផលប្រយោជន៍ស្តេចអាណ្ណាម ។ ម៉ាក់គូបានព្រួតដៃជាមួយទ័ពខ្មែរមួយកង វាយប្រហារទៅលើទ័ពជើងទឹកសៀមមួយកង ដែលមានបំណងឡើងគោក នៅពាមនេះឲ្យបរាជ័យនៅក្នុងឆ្នាំ១៧២២ ហើយគាត់បានស្លាប់នៅក្នុងឆ្នាំ១៧៣៧ ។ ព្រះអង្គតន់បានព្រមព្រៀងគ្នានឹងម៉ាក់តុង ដើម្បីទម្លាក់ព្រះអង្គទងចេញពីរាជបល្ល័ង្ក ។ នៅពេលដែល ម៉ាក់តុង បញ្ជូនបេសកជនទៅ បញ្ចុះបញ្ចូលអ្នកស្រុកនៅក្នុងខែត្រទ្រាំង បន្ទាយមាស បាទី និងព្រៃកប្បាស ព្រះអង្គតន់បានយាងទៅកាន់ខែត្រត្រាំវិញ ក្នុងចំណោមប្រជាជន ដែលស្ថិតនៅក្រោមអំណាចអាជ្ញាធរអាណ្ណាម តាំងពីប៉ុន្មានឆ្នាំមកហើយ ។ ទ្រង់កេណ្ឌទ័ពបានយ៉ាងឆាប់រហ័ស ហើយរៀបចំចេញជា៣កង ដោយដាក់នៅក្រោមបញ្ជាការមន្ត្រីខ្មែរដែលស្មោះនឹងព្រះអង្គ៣នាក់ រួចឲ្យចេញដំណើរមកកាន់ឧត្តុង្គតាមផ្លូវផ្សេងៗគ្នា ។ ម៉ាក់តុងដឹកនាំទ័ពជាពួកចោរប្លន់មួយកង ធ្វើដំណើរពីខាងក្រោយទ័ពខ្មែរទាំង៣កង ។ ទ័ពព្រះឧទ័យរាជាទទួលបានទ័ពជំនួយមួយនៅក្រសាំង នៅខាងជើងជិតមាត់ជ្រូក (ចូវដុក) ។ មកដល់ភ្នំពេញ មេទ័ពទាំង៣បានវាយទ័ពព្រះឧបរាជស្រីសុរិយោពណ៌ ឲ្យបរាជ័យនៅក្នុងសមរភូមិ

---

[៤៨] ពួកអាណ្ណាមហៅថា ម៉ាក់ធានទឺ ខ្មែរហៅថា ព្រះសុទត្ត ។

មួយ ព្រះស្រីសុរិយោពណ៌ បានរត់ភៀសព្រះកាយបាត់ទៅ ។ ព្រះខទ័យ បានចាត់កម្លាំងឲ្យដេញតាម ចាប់ព្រះស្រីសុរិយោពណ៌បាននៅខែត្រព្រៃក្តី ក្នុងដីកំពង់ស្វាយ ហើយធ្វើឃាតចោលទៅ ។ ព្រះអនុជរបស់ព្រះឧបរាជ គឺព្រះកែវហ៊្វាអង្គដួង ដែលយាងចូលសាងព្រះផ្នួសព្រោះមិនចង់មានបញ្ហាជាមួយព្រះខទ័យ បានត្រូវគេបង្ខំឲ្យលាចាកសិក្ខាបទ[៤៩] រួចហើយត្រូវគេធ្វើឃាតដែរ នៅពេលយាងចេញផុតពីបរិវេណវត្តស្បឹង ។

ក្រោយពីធ្វើឃាតស្តេចទាំង២អង្គរួច ព្រះខទ័យ បានយាងចូលគាល់ព្រះរាជាអង្គទងជាព្រះអយ្យកោ ដោយឥតអៀនខ្មាស ហើយសុំការអនុញ្ញាតនាំយកព្រះរាជវង្សានុវង្ស និងបរិពារមករស់នៅខាងជើងវត្តព្រះចេតិយថ្មី ។ ព្រះរាជាទ្រង់បានអនុញ្ញាតតាមសំណើ ដោយមិនអាចធ្វើអ្វីបាន ព្រោះព្រះខទ័យមានទ័ពរឹងមាំ ។

ពីរខែក្រោយមក នៅពេលដែលពួកទាហានមួយចំនួនធំវិលត្រលប់ទៅស្រុកកំណើតវិញហើយ ព្រះខទ័យ ទទួលដំណឹងថា មហេសីមេម៉ាយរបស់ព្រះឧបរាជស្រីសុរិយោពណ៌ បានរៀបចំផែនការប្រឆាំងនឹងព្រះអង្គ ដោយមានមន្ត្រីធំៗជាច្រើនចូលរួមផង ហើយពួកគេកំពុងប្រុងប្រៀបបើកការវាយប្រហារមកលើព្រះអង្គហើយ ។ ដោយភ័យខ្លាចចំពោះការវាយប្រហារនេះ ព្រះអង្គបាននាំព្រះរាជវង្ស និងសេនាអាមាត្យ យាងចេញពីឧត្តុង្គ មកគង់នៅឯជ្រោយចង្វា ចំពីមុខភ្នំពេញវិញ រួចហើយបានចាត់តាំងមន្ត្រី និងមេទ័ពមួយចំនួនឲ្យចេញកេណ្ឌទ័ពសាជាថ្មី ។

ពេលពិនិត្យឃើញថាព្រះខទ័យធ្វើខ្លួនជាស្តេច ហើយប្រុងប្រៀបវាយប្រហារទៅលើព្រះមហេសីមេម៉ាយរបស់ព្រះឧបរាជដូច្នេះ ព្រះរាជាអង្គទងក៏មានសេចក្តីក្លាហានឡើងវិញ ហើយកេណ្ឌទ័ពមួយកងវាយទៅលើពួកបះបោរ ។ ប៉ុន្តែទ័ពនេះបរាជ័យ ព្រះរាជាក៏គេចខ្លួនចេញពីរាជធានីឧត្តុង្គ ទៅគង់នៅឯខែត្រពោធិសាត់ ដោយនាំយកក្សត្រាក្សត្រី មានអ្នកអង្គម្ចាស់អង្គទង អង្គនន់ ព្រះរាមា និងសេនាអាមាត្យទាំងអស់ ទៅជាមួយផង ។ ព្រះអង្គបានសុគតនៅទីនោះ ក្រោយពីយាងទៅដល់បានបន្តិច ក្នុងព្រះជន្មាយុ ៦៥ ព្រះវស្សា ។ សរុបទៅ ព្រះអង្គបានសោយរាជសម្បត្តិ ៣ឆ្នាំ ក្នុងចន្លោះពេលមួយដែលមានរយៈ ៧០ឆ្នាំ ។

មិនយូរប៉ុន្មានក្រោយមក ព្រះខទ័យបានឲ្យគេធ្វើឃាតព្រះមហេសីមេម៉ាយ របស់ព្រះឧបរាជ និងព្រះបុត្រាច្បងរបស់អង្គទង ដែលព្រះនាងមានជាមួយព្រះធម្មោរាជាជាព្រះស្វាមីមុន ក្រោយពីបាននាំយកពីបវេលជាភូមិមួយនៅខាងកើតព្រៃឫស្សីសាញ់មកវិញ ។ ទ្រង់បានដកចៅហ្វាយខែត្រកំពង់ស្វាយ ចេញពីតំណែង ដែលទទួលអ្នកអង្គម្ចាស់អង្គនន់រាមា និងអង្គជ័យឲ្យស្នាក់នៅ ហើយដាក់អ្នកជិតរបស់ព្រះអង្គដែលចាប់អ្នកអង្គម្ចាស់

---

[៤៩] ការគ្រងចីវរលឿងអាចធ្វើឲ្យគេចផុតពីការចាប់ទោសពៃរ៍បាន ។ គេនឹងជួបរឿងដូចគ្នានៅស្រុកសៀម នៅពេលដែលស្តេចជ្រែករាជ្យ ក្បាទន ត្រូវធ្វើឃាត ។

ទាំង២ ដាក់ក្នុងទ្រុងថ្វាយព្រះអង្គ ជំនួសវិញ ។ នៅក្នុងពេលកំពុងធ្វើដំណើរ មន្ត្រីម្នាក់របស់ព្រះឧទ័យ គឺពញាច័ន្ទ បានកាប់បំបាក់ទ្រុង រំដោះយកព្រះអង្គននរាមា រត់គេចទៅស្រុកសៀម ។ នៅសល់តែព្រះអង្គជ័យប៉ុណ្ណោះ ដែលព្រះអង្គទង បានឲ្យគេសម្លាប់ចោលនៅខត្តុគ្គ ។

ដើម្បីរំងាប់ការតវ៉ារបស់ពួកអាណ្ណាម ដែលចោទថាព្រះអង្គបានចូលទៅក្នុងទឹកដីកូសាំងស៊ីន រហូតដល់ខែត្រវិញឡុង ជ្រើសរើសទ័ពធ្វើសង្គ្រាមប្រឆាំងនឹងព្រះរាជាមុន ព្រះឧទ័យបានប្រគល់ទៅឲ្យអាណ្ណាម នូវទឹកដី២កន្លែង គឺដីតាំងពីឡុងដែលក្រោយមកគឺខែត្រអាងយ៉ាង និងមួយកន្លែងទៀត ដែលក្រោយមក គេបង្កើតបានជាស្រុក២ គឺចាន់ដន និងស៊ុយឡាប់ ហើយភ្ជាប់ទៅក្នុងខែត្រវិញឡុង (១៧៥៧) ។

## ៣៥- ព្រះស្រីសុរិយោពណ៌-ព្រះឧទ័យ (១៧៥៨-១៧៧៥)

ក្រោយពីទ្រង់បានប្រព្រឹត្តអំពើឧក្រិដ្ឋផ្សេងៗដូចដែលបានរៀបរាប់ខាងលើរួចហើយ អ្នកអង្គតន់ ហៅថាព្រះឧទ័យ ជាបុត្ររបស់ព្រះឧបរាជព្រះឧទ័យ ដែលសុគតទៅនៅអន្តរវត្តកាលពីឆ្នាំ១៧៥៣ និងត្រូវជាព្រះនត្តារបស់ព្រះរាជាអង្គទង និងជាកូនចិញ្ចឹមរបស់ម៉ាក់គុង បានឡើងសោយរាជ្យនៅក្នុងព្រះជន្ម២០ព្រះវស្សា ក្រោមព្រះនាមថា ព្រះបាទសម្តេចស្តេចព្រះរាជឱង្ការព្រះនរាយណ៍រាជាធិរាជរាមាធិបតីព្រះស្រីសុរិយោពណ៌បរមសុរេន្ទ ។

ព្រះចៅអាណ្ណាមបានប្រកាសទទួលស្គាល់ស្តេចកម្ពុជានេះភ្លាម ។ ស្តេចនេះមិនគ្រាន់តែជាជនឧក្រិដ្ឋចំពោះរាជវង្សានុវង្សប៉ុណ្ណោះទេ ក៏ប៉ុន្តែបានក្បត់ប្រទេសជាតិថែមទៀត ។ ទ្រង់បានប្រគល់ទឹកដីខែត្រពីរ ដែលគេហៅសព្វថ្ងៃថាសុកត្រាំង និងត្រាវិញ ទៅឲ្យពួកអាណ្ណាម ។ គឺដោយបែបនេះហើយដែលរដ្ឋាភិបាលក្រុងវ៉េ បានឆ្លៀតយកឱកាសដែលប្រទេសកម្ពុជាជួបប្រទះនឹងការលំបាក ដណ្តើមយកទឹកដីកូសាំងស៊ីនដាក់បញ្ចូលមកក្នុងការគ្រប់គ្រងរបស់ខ្លួនបន្តិចម្តងៗ ។ ហើយពួកអាណ្ណាមនេះលោភលន់មិនចេះស្កប់ស្កល់ទេ ។ រៀបចំខែត្រទាំង២មិនទាន់ទាំងបានស្រួលបួលផង ពួកនេះក៏ចាប់តាំងកសាងបន្ទាយនៅសាដែក (ផ្សារដែក) នៅកូឡាវយាង (កោះគេង) និងនៅចូវដុក (មាត់ជ្រូក) ថែមទៀត ។

ប៉ុន្តែរាជពង្សាវតារខ្មែរបានលើកឡើងថា ព្រះរាជាឧទ័យជាស្តេចល្អ មានព្រះទ័យទូលាយ ហើយចូលចិត្តដាក់ទាន ។ ទ្រង់បានបរិច្ចាគព្រះរាជទ្រព្យជាច្រើនដាក់ទានដល់ស្មូមយាចក និងបូជាថ្វាយព្រះពុទ្ធ និងពុទ្ធសាសនិក ដើម្បីសន្សំបុណ្យជៀសវាងអកុសលកម្មទាំង៥យ៉ាង និងបាបកម្មទាំង១៤បែប ។ មានទុគ៌តជនជាច្រើនកាត់ពីទីឆ្ងាយៗ មកទទួលទានពីព្រះអង្គ ។ នេះគឺជាការវិនិច្ឆ័យអំពីអត្ថប្រយោជន៍ផ្សេងៗដែលគេអាចឆ្លៀតទាញយកបានពីព្រះអង្គ ។

ព្រះអង្គសព្វព្រះទ័យនឹងផ្តល់ដំបូន្មាន យោលបល់ល្អៗដល់នាម៉ឺនមន្ត្រី និងជំរុញឲ្យពួកនោះធ្វើទាន ជៀស

វ៉ាងបាបកម្ម ។ ទ្រង់ឈ្វេងយល់ថាព្រះអង្គគឺជាពោធិសត្វមួយអង្គដែលត្រូវចុះមកជួយសង្គ្រោះសត្វលោក ថ្ងៃណាមួយ ព្រះអង្គនឹងនាំអ្នកទាំងអស់នោះជាច្រើនរយពាន់ឡើងជិះលើសំពៅមាសមួយឆ្លងកាត់មហាសមុទ្រ បើទោះជាមានព្យុះបក់បោកយ៉ាងណាក្តី ។

នៅឆ្នាំ១៧៦៣ ពេលដែលសភាពការណ៍ក្នុងប្រទេសស្ងប់ស្ងាត់ល្អហើយ ព្រះឧទ័យបានប្រគល់ការដឹកនាំប្រទេសឲ្យមន្ត្រីធំៗទទួល រួចហើយទ្រង់យាងគ្រងស្បង់ពណ៌លឿង សាងព្រះផ្នួស៣ខែ ទើបលាចាកសិក្ខាបទ មកគង់លើរាជបល្ល័ង្កវិញ ។

នៅក្នុងឆ្នាំ១៧៦៥ ព្រះរាជាបានលើកព្រះមហេសីអ្នកម្នាងមាលិន្ទបុប្ផាវតី ឲ្យឡើងជាសម្តេចព្រះភគវតី រួចហើយបានកែសម្រួលពិធីការដោយឲ្យមន្ត្រីទាំងឡាយឆ្លើយនឹងព្រះមហាក្សត្រីថា ព្រះករុណាពិសេស ចំណែកឯភរិយាមន្ត្រីទាំងនោះវិញ ទ្រង់ឲ្យហៅព្រះមហាក្សត្រីថា ព្រះម៉ែ ។

២ឆ្នាំក្រោយមក ស្តេចភូមា[៥០] ដែលធ្វើសង្គ្រាមជាមួយស្តេចសៀមតាំងពីខែមករា ឆ្នាំ១៧៦៥ ក្រោយពីបានដណ្តើមយកតាវ៉យ មែរគុយ ហើយនិងតេណាស់សេរីមរួចមក បានដណ្តើមយកអយុធ្យាទៀត ក្រោយពីហ៊ុមព័ទ្ធជាប់អស់រយៈពេល២ខែ រួចដុតកម្ទេចខ្ទេចខ្ទី (ថ្ងៃទី២៨ ខែមេសា ឆ្នាំ១៧៦៧) ។ ពេលនោះមានអ្នកអង្គម្ចាស់សៀមមួយអង្គ ដែលរាជពង្សាវតារខ្មែរហៅថាព្រះចៅឡេសាង បានរត់គេចទៅឡើងគោកនៅហាទៀងដោយទទួលការថែទាំពីព្រះសង្ឃកាតូលិកឈ្មោះ ពីញ៉ូ រួចហើយបានមកស្នើសុំជ្រកកោននៅរាជវាំងឧត្តុង្គ[៥១] ។

ក្រោយពីរាជធានីសៀមធ្លាក់ចូលក្នុងដៃសត្រូវរួចមក មានកើតជំងឺប៉េស្ត និងអាសន្នរោគ ព្រមទាំងមានចោរលួចចោរប្លន់ពាសពេញប្រទេស ។ ពេលនោះមានកូនកាត់ចិនក្នុងសហគមន៍ហៃហុងម្នាក់ឈ្មោះថា ភ្យាតាក ឬចៅពញាតាក ជាចៅហ្វាយខែត្រមួយនៅទិសខាងជើង ដែលមានទ័ព១ពាន់នាក់ បានវាយពួកភូមាឲ្យបរាជ័យជាច្រើនលើកច្រើនសា ។ ដោយរាជធានីអយុធ្យាបានត្រូវបំផ្លាញខ្ទេចខ្ទីអស់ ហើយព្រះរាជាក៏ត្រូវបានគេធ្វើគុតទៀតធ្វើឲ្យរាជបល្ល័ង្កនៅទំនេរ ភ្យាតាកក៏ប្រកាសខ្លួនឡើងជាព្រះរាជាសៀម នៅឯបាងផ្លាសយ ។ ភ្យាតាក ដែលធ្វើដំណើរមកដល់រយ៉ង បានត្រូវប្រជាជនអបអរទទួល ចាត់ទុកថាជាអ្នករំដោះ ហើយនាំគ្នាចូលបម្រើកងទ័ព ធ្វើឲ្យចំនួនកើនឡើងដល់ ២ពាន់នាក់ ។ ពេលនោះចៅហ្វាយខែត្រចន្ទគាប៊ុនមិនព្រមចំណុះ ទទួលស្គាល់អំណាចរបស់ភ្យាតាក ទេ, ភ្យាតាក ក៏វាយលុកដណ្តើមយកខែត្រចន្ទគាប៊ុន រួចហើយក៏ដឹកនាំទ័ពដែលមានចំនួនកាន់តែច្រើនឡើងទៅវាយពួកភូមាទៀត ។ ភ្យាតាកវាយឈ្នះពួកភូមានៅសមរភូមិជាច្រើន ហើយបានរុញច្រានពួកនេះឲ្យដក

[៥០] នោះគឺព្រះរាជាទី៣នៃសន្តតិវង្សអាឡោងផ្រា ដែលបានឡើងសោយរាជ្យលើរាជបល្ល័ង្កអាំងវ៉ាក្រោយពីបដិវត្តន៍ឆ្នាំ១៧៥៤ ។

[៥១] អ្នកអង្គម្ចាស់នេះ បានសុគតកម្ពុជាក្នុងឆ្នាំ១៧៧១ ។ រាជពង្សាវតារអាណ្ណាមហៅព្រះអង្គថាចៅស៊ីសាង ។ ចំណែកបព្វជិត ពីញ៉ូវិញ ក្រោយមកបានទទួលឋានៈជា អេវ៉ឺកអាដ្រង់ ។

ថយចេញពីព្រះរាជាណាចក្រទៅ ។ ជ័យជម្នះទាំងអស់នេះ បានធ្វើឲ្យភ្យាតាកក្លាយទៅជាមនុស្សអស្ចារ្យជាងគេនៅក្នុងស្រុកសៀម ប្រជារាស្ត្រទាំងអស់ទទួលស្គាល់ក្នុងឋានៈជាមេដឹកនាំ ។ ភ្យាតាក បានមកតាំងរាជវាំងនៅបាងកក ប្ដូរឈ្មោះដាក់ថា ធាណាបុរី វិញ ត្រង់កន្លែងដែលព្រះនរាយណ៍បានធ្វើសម្បទានប្រគល់ឲ្យប្រទេសបារាំងពីមុន ដែលនៅជាកម្មសិទ្ធិរបស់ពួកបារាំងនៅឡើយ ថ្វីបើបារាំងមិនបានមកតាំងទីនៅក៏ដោយ ។

ភ្យាតាក ចង់ឲ្យព្រះរាជាខ្មែរទទួលស្គាល់អធិរាជភាពរបស់សៀម ហើយចាត់ទុកកម្ពុជាជានគរសាមន្តរាជមួយ ដូចដែលស្ដេចសៀមមុនៗតែងតែគិតអ៊ីចឹងដែរ ក៏ចាត់បញ្ជូនរាជទូតឲ្យនាំសារមកថ្វាយ មានអត្ថន័យថា «សូមឲ្យព្រះរាជាកម្ពុជារក្សាទុកនូវប្រពៃណីដែលធ្លាប់មានតាំងតែពីមុន កុំបីគិតដល់ការផ្លាស់ប្ដូរដែលកើតមានឡើងអាស្រ័យដោយព្រឹត្តិការណ៍ធំៗប៉ះពាល់ដល់ព្រះរាជាណាចក្រសៀមនោះ» ហើយថាព្រះរាជាកម្ពុជាត្រូវលើកសួយសារអាករទៅថ្វាយ ដូចដែលព្រះរាជាមុនៗធ្លាប់បានអនុវត្តកន្លងមក ។ រាជពង្សាវតារក៏មាននិយាយផងដែរថា ព្រះអង្គបានទាមទារឲ្យខ្មែរបញ្ជូនអ្នកអង្គម្ចាស់សៀមមួយអង្គ ដែលរត់មកជ្រកកោននៅក្នុងរាជវាំងឧត្តុង្គទៅវិញទៀតផង ។

ពេលនោះព្រះរាជាកម្ពុជា ព្រះឧទ័យសុរិយោពណ៌ ដែលធ្លាប់តែជាស្ដេចបះបោរមួយអង្គ ហើយដែលបានឡើងសោយរាជ្យដោយសារតែការចងសម្ព័ន្ធមេត្រីជាមួយអាណ្ណាម រួចបានប្រគល់ខែត្រ២ឲ្យ និងធ្លាប់បានធ្វើឃាតរាជវង្សជាច្រើនអង្គដើម្បីកុំឲ្យមករារាំងការឡើងគ្រងរាជបល្ល័ង្ករបស់ព្រះអង្គ គឺជាសត្រូវនឹងអតីតព្រះរាជាណាចក្រសៀមដែលតែងតែទំនុកបម្រុង ជំរុញឲ្យមានស្ដេចប្រឆាំងនឹងស្រុកខ្មែរឥតដាច់ ទ្រង់មិនទទួលស្គាល់ថារាស្ត្រសាមញ្ញម្នាក់អាចឡើងសោយរាជ្យលើរាជបល្ល័ង្កសៀមបានទេ ទោះបីថាជននោះបានជួយសង្គ្រោះរំដោះប្រទេសពីការត្រួតត្រារបស់សត្រូវក៏ដោយ ។ ទ្រង់បានចាត់ទុកភ្យាតាកថាមិនមានឋានៈស្មើ នឹងព្រះអង្គទេ ។ ព្រះអង្គបានតបព្រះរាជសារទៅវិញថា «ទ្រង់មិនអាចចរចាស្មើភាពគ្នាជាមួយមនុស្សម្នាក់ ដែលកើតចេញពីពាណិជ្ជ-ករចិនម្នាក់ជាមួយនឹងស្រីសៀមសាមញ្ញម្នាក់បានទេ បើទោះជាថាជននោះមានសមត្ថភាពផ្ទាល់ខ្លួនដូចម្ដេចក្ដី» ។

ទទួលបានរាជសារនេះ ភ្យាតាក ប្រឡោតខឹងយ៉ាងខ្លាំង ហើយបានប្ដេជ្ញាថានឹងទម្លាក់ព្រះរាជាកម្ពុជានេះចេញពីរាជបល្ល័ង្កឲ្យបាន ។ ដើម្បីសម្រេចបំណងនេះ ទ្រង់បានចាប់ផ្ដើមបំផុសបំផុលរកស្ដេចប្រឆាំងមួយអង្គ ហើយបានជ្រើសរើសយកអ្នកអង្គម្ចាស់អង្គនន់រាមា ដែលបានរត់ភៀសព្រះកាយមកគង់នៅស្រុកសៀម ជាមួយមន្ត្រីម្នាក់ដែលធ្លាប់កាប់បំបាក់ទ្រុងរំដោះព្រះអង្គមក ។ ភ្យាតាកបានឲ្យទ័ពសៀមមួយកងជូនព្រះអង្គនន់រាមាធ្វើដំណើរមកកាន់ឧត្តុង្គកាត់តាមផ្លូវនគរវត្ត ដើម្បីស្នើប្រគល់ឲ្យនាម៉ឺនសព្វមុខមន្ត្រីនៅក្នុងព្រះរាជាណាចក្រដែលមិនសូវជាពេញចិត្តនឹងព្រះឧទ័យស្រីសុរិយោពណ៌ប៉ុន្មាននោះ សម្រេច ។ ពេលធ្វើដំណើរមកដល់អង្គរវត្តកងទ័ពនេះបោះជំរំសម្រាក រង់ចាំការប្រយុទ្ធ ។ ព្រះរាជាកម្ពុជាពេលនោះ បានចាត់ឲ្យកេណ្ឌទ័ពមួយកង ដាក់នៅក្រោមបញ្ជាការរបស់លោកក្រឡាហោម ប៉ាង ។ ក្រឡាហោមប៉ាងបានត្រូវគេប្រហារបាន នៅក្នុងការប្រយុទ្ធ

ដំបូង ក៏ប៉ុន្តែកងទ័ពខ្មែរដែលមិនមានការតក់ស្លុតព្រោះបាត់បង់មេកោយនោះ បានបន្តការប្រយុទ្ធរហូតទាល់តែទទួលបានជ័យជម្នះលើទ័ពសៀម ធ្វើឲ្យពួកនេះបែកបាក់រត់ខ្ចាត់ខ្ចាយទៅស្រុកវិញអស់ នៅក្នុងឆ្នាំ១៧៦៩[៥២] ។

នៅពេលនោះ ម៉ាក់គុងដែលខ្មែរយើងហៅថា ព្រះសុទត្ត ចៅហ្វាយខែត្រហាទៀង ដែលទទួលដំណឹងពីការវាយប្រហារនេះពីស្ដេចអាណ្ណាម បានសម្រេចចិត្តធ្វើអន្តរាគមន៍ជួយព្រះរាជាកម្ពុជា ។ គាត់បានកេណ្ឌទ័ពខ្មែរមួយកងចេញពីខែត្រទ្រាំង និងបន្ទាយមាស រួចបានដឹកនាំទាំងតាមជើងគោក និងតាមជើងទឹកទៅវាយលុក អាណាខែត្រមាត់សមុទ្ររបស់សៀម ។ នៅពេលកដល់ចន្ទគាប៊ុន ទ័ពម៉ាក់គុងបានជួបប្រយុទ្ធជាមួយទ័ពសៀមមួយកងដែលកំពុងនៅរង់ចាំ ទ័ពសៀមនោះបានវាយឲ្យម៉ាក់គុងបរាជ័យ រត់ចោលទូកក្ដារ និងសម្ភារមួយចំនួន ចូលទៅហាទៀងវិញ ។

ស្ដេចសៀមបានយាងត្រលប់មកបាងកកវិញ ហើយបានរៀបចំនាវាមួយកង រួចនាំទ័ពឡើងជិះសំពៅជាមួយព្រះអង្គម្ចាស់អង្គនន់រាមា ចេញដំណើរសំដៅមកហាទៀង វាយដណ្ដើមយកខែត្រនេះបាន និងចាប់ក្រុមគ្រួសារម៉ាក់គុង មួយចំនួនជាចំណាប់ខ្មាំង ឯម៉ាក់គុងបានរត់គេចខ្លួនបាត់ទៅ ។ ក្នុងពេលជាមួយគ្នានោះ កងទ័ពជើងគោកសៀមមួយកង ដែលនៅក្រោមបញ្ជាការរបស់យមរាជសៀមម្នាក់ បានឆ្លងកាត់ព្រំដែនខ្មែរភាគខាងជើងធ្វើដំណើរកាត់នគរវត្តបាត់ដំបង និងពោធិសាត់សំដៅមករករាជធានីឧត្ដុង្គ ។ ភ្យាតាក និងអ្នកអង្គនន់រាមា ក៏បានមកដល់ភ្នំពេញដែរ ដោយធ្វើដំណើរពីហាទៀងមកមិនដល់៦ថ្ងៃផង ព្រោះគ្មានជួបទ័ពទប់ទល់បន្តិចណាសោះ ។

ដោយខ្លាចសៀមចាប់បាន ព្រះរាជាកម្ពុជាបាននាំព្រះរាជវង្សានុវង្ស និងបរិពារគេចចេញពីឧត្ដុង្គមកចុះនាវានៅកំពង់ហ្លួង ហើយធ្វើដំណើរទៅកាន់ត្រឡុងខ្ទះបាក់អញ្ចៀន ឲ្យលោក យមរាជ ដឹកនាំទ័ពនាំមុខ ប្រយុទ្ធយ៉ាងអង់អាចជាមួយទ័ពសៀម ។ ពួកអ្នកស្រុកដែលខ្លាចសៀមក៏រត់តាមព្រះរាជាទៅដែរ អ្នកខ្លះទៅដល់មាត់ក្រសះ និងអន្លង់ឫស្សី ខ្លះទៀតទៅដល់ត្រឡុងខ្ទះបាក់អញ្ចៀនដែរ ។

នៅពេលដែលព្រះរាជាកំពុងតែរត់គេចទៅនោះ ទ័ពភ្យាតាក និងអ្នកអង្គនន់រាមាបានធ្វើដំណើរតាមមាត់ទន្លេប្រាបឈាម ចាប់ស្រីៗ និងយករបស់របរអ្នកស្រុកដែលរត់ទៅមាត់ក្រសះអស់ទៅ ។

នៅពេលនោះហើយដែលពួកអាណ្ណាមចាប់ផ្ដើមធ្វើអន្តរាគមន៍[៥៣] ដោយកេណ្ឌទ័ពមួយកង មកជួបគ្នាជាមួយនឹងទ័ពលោក យមរាជ នៅពាមបញ្ជូសពាស ។ ទ័ពអាណ្ណាម និងខ្មែរ បានទទួលជ័យជម្នះលើទ័ពសៀម រួចបាន

---

[៥២] តាមរាជពង្សាវតារបាននិយាយថា នៅក្នុងឆ្នាំនោះមានផ្កាយដុះកន្ទុយមួយល្អណាស់ លេចឡើងនៅក្នុងដើមខែកញ្ញា ចេញពីទិសខាងកើត ហើយបន្តសំដៅទៅទិសនិរតី ។

[៥៣] រាជពង្សាវតារខ្មែរនិយាយថា ស្ដេចអាណ្ណាមពេលនោះមានព្រះនាមថា យ៉ាឡុង ។ តាមពិតស្ដេចនោះមានព្រះនាមថា ហ៊ុវៀង អភិសេកនាមគឺ ង្វៀងភុកធន់ ។ គឺជាបុត្រារបស់ស្រីស្នំម្នាក់ ។ ព្រះអង្គសោយរាជ្យបាន១៣ឆ្នាំ ពីឆ្នាំ១៧៥៦ ដល់១៧៧៨ ។

មកដេញ ភ្យាតាក និងអ្នកអង្គនន់ ចេញពីភ្នំពេញ ឲ្យធ្វើដំណើរទៅហាទៀងវិញ រួចទ័ពសៀម និងភ្យាតាក ក៏ចុះទូកទៅស្រុកសៀមវិញអស់ទៅ ។ ឯអ្នកអង្គនន់ ទ្រង់គង់នៅទីងហាទៀងនេះជាមួយទ័ពសៀម៥រយនាក់ ប៉ុន្តែបន្ទាប់មក បានទៅគង់នៅឯកំពតវិញ ដោយមិនអាចការពារហាទៀងទប់ទល់នឹងម៉ាក់គុងបាន ។ ទៅដល់កំពត ទ្រង់បានបន្តជ្រើសរើសទ័ពបន្ថែមទៀតពីខែត្រជិតខាង ។

នៅភាគខាងជើងទ័ពសៀមច្បាំងចេះតែចាញ់ជាញឹកញាយ ។ ដល់ទទួលដំណឹងថា ភ្យាតាក ចុះទូកជាមួយកងទ័ពចេញពីហាទៀងទៅវិញ ក៏យល់ថាខ្លួនកំពុងតែស្ថិតនៅក្នុងគ្រោះមហន្តរាយហើយ បានបោះបង់ការប្រយុទ្ធវិលត្រលប់ទៅស្រុកវិញដែរ ដោយនាំយកទៅជាមួយនូវឈ្លើយសឹក១ម៉ឺននាក់ ដែលគេបានប្រមូលផ្តុំនៅពោធិ៍-សាត់ ។ គេនិយាយថា មានអ្នកស្រុកជាច្រើនត្រូវស្លាប់ដោយអត់អាហារតាមផ្លូវ ។

នៅពេលអស់ទ័ពសៀមហើយ ទ័ពលោក យមរាជ ក៏បែកចេញពីទ័ពអាណ្ណាម ហើយធ្វើដំណើរទៅរកទ័ពអ្នកអង្គនន់រាមា ជួបគ្នានៅទីងពាមរកា ក៏វាយឲ្យបរាជ័យទៅ (១៧៧១) ។

នៅចុងឆ្នាំ១៧៧១ ព្រះរាជា បានយាងមកគង់ជាបណ្តោះអាសន្ននៅមាត់កណ្តុរ ស្ថិតនៅលើទន្លេសាបចម្ងាយ ១០គីឡូម៉ែត្រពីភ្នំពេញ ។ ទ្រង់បានទទួលយករ៉េស៊ីដង់អាណ្ណាមម្នាក់ ហៅ បាវហូ មកនៅទីងព្រះរាជវាំង ។ ធ្វើយ៉ាងនេះ មានន័យថា ព្រះអង្គ បានដាក់ព្រះរាជាណាចក្រនៅក្រោមអាណាព្យាបាលរបស់អាណ្ណាមហើយ ។ បន្ទាប់មកព្រះរាជាបានយាងមកគង់នៅទីងពាក់ព្រ័ត្រ[៥៤] រួចបានចាត់រាជទូតទៅបាងកក ចរចាសន្តិភាពជាមួយភ្យាតាក ដោយលែងចាត់ស្តេចសៀមថ្មីនេះថារាស្ត្រសាមញ្ញមកជ្រែករាជសម្បត្តិ ដូចកាលពីប៉ុន្មានឆ្នាំមុនទៀតហើយ ។ ភ្យាតាកមិនព្រមទទួលរាជទូតទាំងអស់នោះទេ ក៏បានឲ្យគេចាប់ឃុំទុក រួចផ្ញើរាជសារមួយមកថ្វាយព្រះរាជាកម្ពុជា និយាយថាការចចាអាចនឹងមានទៅបានលុះណាតែទ្រង់បញ្ជូនព្រះមាតា និងរាជវង្សានុវង្ស ទាំងអស់ ឲ្យទៅគង់នៅឯស្រុកសៀមសិន ។ ចំណែកឯម៉ាក់គុងវិញ គេក៏ចាប់ចរចាជាមួយស្តេចសៀម ហើយហាក់ដូចជាបានបោះបង់ការគាំទ្រស្តេចខ្មែរដែរ ហើយបានទទួលការអនុញ្ញាតពីភ្យាតាក ឲ្យក្រុមគ្រួសារដែលស្តេចសៀមចាប់ទុកជាចំណាប់ខ្មាំងនៅឯបាងកកនោះ វិលត្រលប់ទៅហាទៀងវិញ ។ ដើម្បីជាថ្នូរ ម៉ាក់គុង បានយល់ព្រមប្រគល់អ្នកអង្គម្ចាស់សៀមមួយអង្គដែលភៀសខ្លួនមកគង់នៅរាជវាំងកម្ពុជា ហើយដែលព្រះរាជាកម្ពុជាប្រកែកមិនព្រមប្រគល់ឲ្យទៅ ភ្យាតាក ។ ភ្យាតាកក៏នាំយកអ្នកអង្គម្ចាស់សៀមនោះ ទៅបាងកកវិញរួចធ្វើឃាតចោលទៅ ។

នៅក្នុងឆ្នាំ១៧៧៤ ព្រះរាជាកម្ពុជាបានយាងចេញពីរាជដំណាក់ពាក់ព្រ័ត្រ មកគង់នៅឯកោះចិន ជាកោះ

---

[៥៤] ភូមិនេះនៅជិតខត្តុង្គ ត្រង់កន្លែងមួយមាននៅរហូតដល់សព្វថ្ងៃ សម្រាប់ទុកស្បែកគោក្របីដែលបារគូ វះទុកធ្វើជាព្រ័ត្រនៅក្នុងព្រះរាជពិធីអុំទូក នាថ្ងៃពេញបូណ៌មី ខែតុលា ។

មួយនៅក្នុងទន្លេសាប ស្ថិតនៅចំពីមុខកំពង់ហ្លួង មិនទាន់ហ៊ានយាងត្រលប់ចូលរាជធានីវិញទេ ដោយខ្លាចព្រះអង្គម្ចាស់អង្គនន់រាមា ដែលកំពុងតែឃោសនារើសទ័ពនៅក្នុងអាណាខេត្រខាងលិច ចាប់ព្រះអង្គបាន ។

អនាធិបតេយ្យមានគ្រប់ទីកន្លែង នគរទាំងមូលវិលត្រលប់មករកភាពព្រៃផ្សៃឡើងវិញ ។ មានខេត្រជាច្រើនដែលមិនគោរពព្រះរាជា តែក៏មិនស្តាប់បញ្ជារបស់ស្តេចបះបោរដែរ ។ ចៅហ្វាយខេត្រប្រមូលពន្ធបាន តែមិនបានយកមកបង់ជូនរាជការទេ ឯអ្នកប្រមូលពន្ធត្រូវប្រជារាស្ត្រដេញមិនឲ្យចូលក្នុងភូមិ ។ នៅកន្លែងខ្លះប្រជាជនត្រូវគេបង្ខំឲ្យបង់ពន្ធឲ្យភាគីទាំង២ ។ រាស្ត្ររងទុក្ខវេទនា ជំងឺអាសន្នរោគរាតត្បាត ហើយជំងឺអុតបានធ្វើឲ្យអ្នកស្រុកស្លាប់អស់ជាច្រើន ។

រាជពង្សាវតារបាននិយាយថា នៅទីបញ្ចប់ ដោយទ្រង់មានមេត្តាករុណាដល់ប្រជានុរាស្ត្រខ្លាំងពេក ព្រះរាជាក៏សុខព្រះទ័យលះបង់រាជសម្បត្តិថ្វាយដល់ព្រះអង្គនន់រាមា ជាគូប្រណាំងប្រជែង និងជាសត្រូវផង នៅក្នុងឆ្នាំ១៧៧៥ ។ ទ្រង់សោយរាជ្យបាន១៧ឆ្នាំ ហើយរជ្ជកាលរបស់ព្រះអង្គមានតែទុក្ខវេទនា ។

## ៣៦- ព្រះអង្គរាមរាជា-អង្គនន់ (១៧៧៥-១៧៧៩)

ព្រះអង្គរាមរាជាជាព្រះរាជបុត្រារបស់ព្រះស្រីជ័យជេដ្ឋា និងជាព្រះរាជនត្តារបស់ព្រះធម្មោរាជាទី១ ។ ព្រះអង្គមានព្រះជន្ម៣៦ព្រះវស្សាហើយនៅពេលដែលទ្រង់ទទួលព្រះរាជាភិសេកក្រោមព្រះនាមថា ព្រះបាទសម្តេចស្តេចព្រះរាជឱង្ការព្រះរៀមរាជាធិរាជបរមបពិត្រ ។ ព្រះរាជាមុនដែលដាក់រាជ្យ បានទទួលព្រះឋានៈជាព្រះឧភយោរាជ ឯព្រះអង្គថន ជាព្រះអនុជរបស់ព្រះអង្គរាមរាជា បានទទួលព្រះឋានៈជាព្រះឧបរាជធំ ។

ដោយមានការព្រួយបារម្ភខ្លាចពួកអាណ្ណាម ដែលប្រឆាំងនឹងការឡើងសោយរាជ្យរបស់ព្រះអង្គ ធ្វើការវាយប្រហារមកលើ ព្រះរាជាបានចេញព្រះរាជបញ្ជាឲ្យធ្វើកាំភ្លើងធំ កាំភ្លើងតូច រំសេវ គ្រាប់កាំភ្លើងធំ គ្រាប់កាំភ្លើងតូច ហើយបានឲ្យសង់បន្ទាយការពាររឹងមាំ២ មួយនៅភ្នំពេញ មួយទៀតនៅមុខកំពូល ។ ក៏ប៉ុន្តែចៅហ្វាយក្រុងសាយហ្គន និងស្តេចយ៉ាឡុង (ង្វៀងភុកធន់) ដែលសោយរាជ្យនៅរាជធានីវេពេលនោះ មានការរវល់នឹងរឿងផ្សេងទៅវិញ ។ នោះគឺពួកអ្នកភ្នំខាងកើត ឬតៃសឺន នៅនឹងតៃភូ បានបះបោរឡើងក្រោមការ ដឹកនាំរបស់បងប្អូន២នាក់ឈ្មោះ ឌុកអុងថាញ់ និងឌុកអុងឯម[៥៥] ហើយធ្វើការគំរាមកំហែងមកលើរាជធានីវេ ក្នុងឆ្នាំ១៧៧៥ ។ ចំណែកនៅកូសាំងស៊ីនខាងក្រោមវិញ មានការបះបោរមួយកើតឡើង ធ្វើឲ្យចៅហ្វាយ ខេត្រអាណ្ណាម ឈ្មោះ ចាសចេ មានការលំបាកនឹងបង្ក្រាបយ៉ាងខ្លាំង ។ ម្ល៉ោះហើយ ពួកនេះមិនបានបើកការវាយប្រហារមកលើកម្ពុជាទេ ផ្ទុយទៅវិញ

---

[៥៥] ពួកអាណ្ណាមដាក់ឈ្មោះគេថា ង្វៀងវ៉ាន់ញ៉ាក់ និងង្វៀងវ៉ាន់ហ្វេុធុង ។

គេបានសំណូមពរឲ្យកម្ពុជាជួយទៅវិញ ។ ក៏ប៉ុន្តែព្រះរាជាកម្ពុជាបានប្រកែក មិនចង់មានទំនាក់ទំនងជាមួយពួកអាណ្ណាម ដែលធ្លាប់តែវាយប្រហារមកលើព្រះអង្គ មុនពេលដែលទ្រង់បានឡើងសោយរាជ្យឡើយ ។

ចៅហ្វាយក្រុងសាយហ្គុនមិនបានអង្វរករអ្វីទៀតទេ ប៉ុន្តែនៅពេលដែលបង្ក្រាបការបះបោររួច គេក៏បែរមករកធ្វើសង្គ្រាមសងសឹកនឹងកម្ពុជាតែម្តង ។ គាត់បានដឹកនាំទ័ពឡើងតាមទន្លេ រហូតមកដល់ភ្នំពេញ ដោយគ្មានជួបប្រទះការទប់ទល់អ្វីឡើយ ។ ប៉ុន្តែមកដល់ភ្នំពេញ មានទ័ពខ្មែរមួយកងកំពុងតែរង់ចាំជាស្រេច ។ មានការប្រយុទ្ធគ្នាចំនួន២០ លើកនៅជុំវិញរាជធានី ពួកអាណ្ណាមត្រូវបរាជ័យស្ទើរតែរាល់លើក ។ នៅពេលដែលច្បាំងទៅបាត់បង់កម្លាំងអស់ច្រើនពេក ហើយការផ្គត់ផ្គង់ស្បៀងក៏លំបាក ព្រោះអ្នកស្រុកបះបោរប្រឆាំងគ្រប់ទិសទី ជាពិសេសពីខាងក្រោយ ពួកអាណ្ណាមក៏បែរខ្នងរត់ត្រលប់ទៅកូសាំងស៊ីនវិញទៅ នៅចុងឆ្នាំ១៧៧៦ ។

ព្រះរាជាបានដឹកនាំទ័ពដេញតាមរហូតដល់ហួសព្រំដែន ដណ្តើមយកបានខែត្រវិញឡុង និងមីថមកវិញ ។ គេនិយាយថា ទ្រង់បានបំផុសបំផុលពួកអ្នកស្រុកកូសាំងស៊ីន ដែលមានកំហឹងនឹងពួកអាណ្ណាមស្រាប់ ឲ្យកាប់សម្លាប់ពួកអាណ្ណាមឲ្យអស់ពីទឹកដី ក៏ប៉ុន្តែបានព្រះឧភយោរាជ និងព្រះឧបរាជធំឃាត់ ។

នៅក្នុងឆ្នាំ១៧៧៧ វិបុលរាជស្រី ដែលជាជំនួយការរបស់លោកក្រឡាហោម រដ្ឋមន្ត្រីខាងទ័ពជើងទឹក ដោយយល់ឃើញថា ព្រះឧបរាជអង្គធំជាមនុស្សតែម្នាក់គត់ដែលអាចទាមទារយករាជបល្ល័ង្កបាន ក៏សុំការអនុញ្ញាតចូលគាល់ ហើយថ្វាយយោបល់ឲ្យទ្រង់យល់ព្រមធ្វើគុតព្រះរាជាជាព្រះរៀម ដើម្បីដណ្តើមរាជសម្បត្តិ ។ ព្រះឧបរាជធំ បានប្រានចោលមតិនេះ ក៏ប៉ុន្តែទ្រង់មិននិយាយស្តីអ្វីទេ ព្រោះថាតាមពិតទៅទ្រង់ក៏ចង់បានរាជបល្ល័ង្កបន្តពីព្រះរៀមដែរ ។ វិបុលរាជស្រីភ័យខ្លួន ខ្លាចព្រះឧបរាជធំចោទប្រកាន់ ក៏ទៅចូលគាល់ព្រះរាជាទូលបង្កាច់ថាព្រះឧបរាជធំក្បត់បានចាត់ឲ្យខ្លួនមកធ្វើគុតព្រះរាជា ។ ព្រះរាជាទ្រង់ជឿសម្តីវិបុលរាជស្រី ហើយបានផ្តុកផ្តាក់ឲ្យជននេះធ្វើគុតព្រះឧបរាជវិញ នៅពេលដែលទ្រង់ក្រសាលបាស្កាជាមួយ ហើយញាក់ភ្នែកធ្វើសញ្ញា ។ ព្រះរាជាបានបបួលព្រះឧបរាជធំលេងបាស្កានៅនឹងរានហាលដំណាក់ខត្តុគ្គ តែទ្រង់មិនបានឲ្យសញ្ញាសោះ ។ ស្អែកឡើង ទ្រង់ក្រសាលទៀត តែនៅតែមិនផ្តល់សញ្ញាដដែល ធ្វើឲ្យវិបុលរាជស្រី មានការអស់សង្ឃឹមជាខ្លាំងបារម្ភខ្លាចតែព្រះរាជាបានពិភាក្សាសាកសួរព្រះអនុជដឹងរឿងរ៉ាវសព្វគ្រប់ទេដឹង ព្រោះថាព្រះឧបរាជ នឹងធឹងខ្លាំងណាស់ ហាក់ដូចជាគ្មានអារម្មណ៍ប្រូបូកប្រូបល់អ្វីបន្តិចសោះឡើយ ។ វិបុលរាជស្រី បានចូលគាល់ព្រះរាជាម្តងទៀត ហើយទូលព្រះអង្គ អះអាងថាព្រះអនុជបានរៀបចំអាវុធយុទ្ធភណ្ឌទុកនៅក្នុងព្រះរាជដំណាក់ អំពើក្បត់នៅតែពេលនឹងផ្ទុះឡើងប៉ុណ្ណោះ ព្រះរាជាត្រូវចាត់ការឲ្យរហ័ស ទើបទប់ស្កាត់ទាន់សភាពការណ៍ ។ ព្រះរាជាចាប់មានការភិតភ័យជាខ្លាំង ហើយបានសន្យាថា ទ្រង់នឹងធ្វើសញ្ញាឲ្យ នៅក្នុងពេលលេងបាស្កាល្ងាចនេះ ។ ពេលលេងបាស្កាម្តងទៀត ទ្រង់នៅតែមិនបានឲ្យសញ្ញាដដែល ព្រោះខ្លាចចាញ់បញ្ឆោតវិបុលរាជ ។ ប៉ុន្តែនៅពេលដែលទ្រង់ងាកព្រះភ័ក្ត្រមើលទៅវិបុលរាជ ជននេះចាត់ទុកថា នោះជាសញ្ញាដែលព្រះរាជាឲ្យហើយក៏ដកកាំបិតស្នៀត

ចាក់មកលើចង្កេះឆ្វេងរបស់ព្រះឧបរាជ ធ្វើឲ្យព្រះឧបរាជស្រែកយ៉ាងខ្លាំង ហើយដួលទៅអោបជើងព្រះរាជា ។ ព្រះរាជារំភើបខ្លាំងណាស់ ក៏ឱនចាប់បីព្រះអនុជឡើង បបោសអង្អែល និងព្រះកន្សែងសោកាជាខ្លាំង ធ្វើឲ្យព្រះឧបរាជយល់ថា ព្រះរៀមចាញ់បោកគេហើយ ។ ព្រះឧបរាជក៏រៀបរាប់ថ្វាយ ព្រះរៀមអំពីរឿងដែលវិបុលរាជស្រី បានទៅបញ្ចុះបញ្ចូលព្រះអង្គ ព្រះអង្គបានប្រកែក ប៉ុន្តែព្រះអង្គនៅសៀម មិនបានទូលរឿងនេះថ្វាយ ហើយទ្រង់ថាសុំទោសចំពោះការដែលមិនបានរាយការណ៍ថ្វាយនេះ ។ ព្រះរាជាក៏ចេញបញ្ជារភ្លាម ឲ្យគេចាប់វិបុលរាជស្រី ប្រគល់ឲ្យចៅក្រមដាក់ទោសទៅតាមច្បាប់ នៅក្នុងខែធ្នូ ឆ្នាំ១៧៧៧ ។

វិបុលរាជស្រីនេះបានប្រព្រឹត្តខុសឆ្គងម្តងរួចមកហើយ កាលពីមួយ ឬពីរឆ្នាំមុន ហើយត្រូវបានព្រះរាជាប្រោសប្រណីលើកទោសឲ្យ ។ ជននេះបានស្រលាញ់ស្នំម្នាក់ ដែលព្រះរាជាសព្វព្រះទ័យ ទើបតែលើកធ្វើជាស្នំឯកនៅក្នុងព្រះរាជវាំង ។ ដោយត្រូវធ្វើឲ្យភ្ញាក់ផ្អើលពេលទតឃើញវិបុលរាជនេះនៅលើទែនសយនា ស្នំឯកនៅពេលដែលទ្រង់ទើបតែយាងចេញបានបន្តិច ដើម្បីទៅបំពេញកិច្ចការសំខាន់មួយ ជននេះបានស្ទុះទៅកញ្ឆក់យកដាវមួយមកកាន់គំរាមព្រះរាជាដើម្បីបើកផ្លូវរត់ចេញ ។ ពួកអ្នកយាមឃើញដូច្នេះ ស្រឡាំងកាំង មិនដឹងថាមានរឿងហេតុអ្វីកើតឡើងនៅក្នុងព្រះរាជដំណាក់ ក៏បណ្តោយឲ្យវិបុលរាជរត់ចេញទៅ ។ ប៉ុន្តែ ដល់ដឹងរឿងរ៉ាវសព្វគ្រប់ពួកអ្នកយាមនោះក៏នាំគ្នាដេញតាម ហើយបាញ់ព្រួញត្រូវវិបុលរាជត្រង់ឆ្អឹងជំនីរ ដួលដេកនឹងដី ។ ប៉ុន្តែព្រះរាជាទ្រង់បានលើកទោសកំហុសឲ្យទៀត ។ វិបុលរាជមកទូលព្រះរាជាបន្តុចព្រះឧបរាជថា មានបំណងចង់ធ្វើឃាតព្រះរាជា ដោយទូលថាដើម្បីសងគុណព្រះអង្គ ដែលបានលើកលែងទោសឲ្យពីមុននោះឯង ។ ទោសកំហុសលើកនេះជាក់ស្តែងខ្លាំងណាស់ ក៏ប៉ុន្តែគេគិតថាព្រះរាជា ដែលធ្លាប់លើកទោសកំហុសឲ្យវិបុលរាជម្តងមកហើយទ្រង់សព្វព្រះទ័យនឹងជននេះខ្លាំងណាស់ ណាមួយទ្រង់បានជឿទៅលើសម្តីបងប្អូន របស់វិបុលរាជទាំង៤នាក់គឺ តេជោទែន ចៅហ្វាយស្រុកកំពង់ស្វាយ, ពាង ចៅហ្វាយស្រុកបារាយណ៍, សូរ ចៅហ្វាយស្រុកព្រៃក្តី, និងមូ ចៅហ្វាយស្រុកទ្រាំង, ថាព្រះឧបរាជធំពិតជាបានរៀបផែនការក្បត់ព្រះអង្គមែន ហើយបានស្នើសុំឲ្យព្រះអង្គលើកលែងទោសឲ្យម្តងទៀត ។ ព្រះឧភយោរាជ ក្រោយពីបានជ្រាបអំពីឧក្រិដ្ឋកម្មនេះ ហើយដោយកំពុងតែប្រឈួនស្រាប់ ទ្រង់មានព្រះទ័យរំជើបរំជួលខ្លាំងណាស់ ណាមួយទ្រង់បារម្ភចំពោះខ្លួនព្រះអង្គផង ទើបថ្វាយព្រះយោបល់ដល់ព្រះរាជាថា ត្រូវដាក់ទោសវិបុលរាជស្រីឲ្យធ្ងន់ជាទីបំផុត ។ ប៉ុន្តែព្រះឧភយោរាជ បានសុគតប៉ុន្មានថ្ងៃក្រោយមក ក្នុងព្រះជន្ម ៣៨ព្រះវស្សា គេនិយាយថា ទ្រង់ក៏ត្រូវគេលួចធ្វើឃាត ដូចជាព្រះអនុជអ៊ីចឹងដែរ ។ ខ្ញុំបានស្គាល់តាចាស់ម្នាក់ ដែលជីតារបស់គាត់មានជាប់ពាក់ព័ន្ធនឹងរឿងនេះ បាននិយាយថា គាត់ធ្លាប់ឮឪពុកគាត់ ប្រាប់ថាព្រះឧភយោរាជត្រូវសុគតដោយគេធ្វើឃាតចាក់នឹងដាវធ្លុះព្រះកាយ ។

ពេលនោះមន្ត្រីទាំងឡាយមិនបានគិតដល់រឿងអ្វីវែងឆ្ងាយទេ ក៏សម្រេចកាត់ទោសសម្លាប់វិបុលរាជស្រីចោលទៅ ។

ការកាត់ទោសប្រហារវិបុលរាជស្រីនេះ បានធ្វើឲ្យម្ដាយឈ្មោះ ជិទាវឡាង មានកំហឹងជាខ្លាំង ហើយសម្រេចចិត្តធ្វើការសងសឹកវិញ ប៉ុន្តែមិនមែនសងសឹកនឹងពួកចៅក្រមទេ គឺសងសឹកនឹងព្រះរាជាតែម្ដង ព្រោះគឺព្រះរាជានេះឯងដែលបានឲ្យសញ្ញាឲ្យសម្លាប់ព្រះឧបរាជក្សត់ ហើយបែរមកចាប់កំហុសអ្នកទទួលរាជបញ្ជាទៅវិញ ។ ជិទាវឡាងបានទៅសុំយកសពវិបុលរាជស្រីមកធ្វើបុណ្យយ៉ាងអធិកអធម រួចហើយបញ្ចុះបញ្ចូលកូនគាត់ទាំង៤នាក់ទៀត ឲ្យនាំគ្នាបះបោរឡើងប្រឆាំងនឹងព្រះរាជា ។ ក៏ប៉ុន្តែចៅហ្វាយខេត្រទាំងអស់នោះ ថ្វីបើគោរពម្ដាយ នឹកអាណិតពេលឃើញទឹកភ្នែកគាត់ហូរធ្លាក់មក និងឃើញគាត់បញ្ចេញកំហឹងទៅលើព្រះរាជាក៏ដោយ ក៏ពួកគេមិនចង់ធ្វើតាមគាត់ដែរ ។ រឿងរ៉ាវហាក់ដូចជាស្ងប់ទៅវិញ ទទួលពេលបុណ្យភ្ជុំបិណ្ឌចូលមកដល់ ។ ជិទាវឡាងបានអញ្ជើញទៅវត្ត យកចង្ហាន់ទៅប្រគេនលោកឧទ្ទិសកុសលជូនដល់មាតាបិតាជីដូនជីតាដូចធម្មតា រួចហើយគាត់បានហៅកូនទាំង៤ទៅផ្ទះ ដើម្បីបំពេញពិធីក្នុងគ្រួសារបន្ថែមទៀត ។ ទៅដល់ផ្ទះ គាត់យកអដ្ឋិធាតុរបស់វិបុលរាជស្រី ដែលដាក់ក្នុងកោដិមាសមកបង្ហាញ ហើយនិយាយថាធាតុរបស់បងកូនទាំងអស់គ្នានេះកំពុងតែដង្ហោយហៅឲ្យកូនសងសឹកជួស ដូច្នេះកូនត្រូវតែប្រមែប្រមូលមិត្តភក្តិ បក្សពួក ញាតិមិត្តទាំងឡាយ បង្កើតជាទ័ពមួយជាប្រញាប់ ដើម្បីសងសឹកនឹងព្រះរាជា ។ ចៅហ្វាយខេត្រទាំង៤ស្រាប់តែប្រឡោតខឹងតាមការញុះញង់របស់លោកជិទាវជាម្ដាយ ក៏សន្យាថានឹងសងសឹកព្រះរាជាវិញ រួចវិលត្រលប់ទៅកាន់ខេត្ររៀងៗខ្លួន ក្នុងចិត្តនឹកគិតតែអំពីរៀបចំផែនការសងសឹកប៉ុណ្ណោះ ។

នៅឆ្នាំបន្ទាប់ ស្ដេចសៀម ក្បាតាកបានចងសម្ព័ន្ធមេត្រីភាពជាមួយព្រះរាជាកម្ពុជា ហើយបានរៀបចំផែនការទៅវាយស្ដេចលាវដែលសោយរាជ្យនៅវៀងច័ន្ទ ដោយសុំជំនួយពីទ័ពខ្មែរ១ម៉ឺននាក់ ។ សម្ព័ន្ធមេត្រីភាពជាមួយសៀម ដើម្បីវាយលាវដែលកម្ពុជាមិនដែលមានផលប្រយោជន៍អ្វីបន្តិចសោះនោះ បានធ្វើឲ្យព្រះរាជាអស់ប្រជាប្រិយភាព ។ នៅក្នុងខេត្រកំពង់ស្វាយដែលទ័ពត្រូវដើរកាត់ គឺមួយកងបានសំដៅទៅរកចំប៉ាសាក់ និងមួយកងទៀតសំដៅទៅរកទន្លេមេគង្គ គេបានកេណ្ឌស្រីៗឲ្យបុកស្រូវដែលប្រមូលបានពីអ្នកស្រុក ធ្វើអង្ករឲ្យកងទ័ព ធ្វើឲ្យអ្នកស្រុកខឹងសម្បាបះបោរឡើង ។ ពេលទៅដល់ស្រុកលាវ មានទាហានមួយចំនួនដែលគេរើសចេញពីខេត្រកំពង់ស្វាយនេះ បានរត់ចោលជួរត្រលប់មកវិញ ហើយពួននៅក្នុងព្រៃ ។ ព្រះរាជាបានបញ្ជូនមនុស្សឲ្យតាមដើររកពួកដែលរត់ចោលជួរទាំងអស់នោះ ដើម្បីចាប់យកមកដាក់ទោស ក៏ប៉ុន្តែបេសកជនទាំងនោះ បានត្រូវអ្នកស្រុកព្រួតគ្នាចាប់កាប់សម្លាប់ចោលអស់ ។ តេជោទែន ជាស្ដេចត្រាញ់ដែនដីកំពង់ស្វាយ មិនបានរាយការណ៍អំពីសភាពការណ៍នេះថ្វាយព្រះរាជាទេ ចំណែកឯបងប្អូនគាត់២នាក់ទៀត គឺសែនខាងហ៊ុំពាង ចៅហ្វាយខេត្របារាយណ៍ និងមន្ត្រីស្នេហាសួរ ចៅហ្វាយខេត្រព្រៃក្ដី ក៏មិនបានធ្វើអ្វីដែរ ដើម្បីចាប់ចងពួកទាហានរត់ចោលជួរ និងទប់ទល់កុំឲ្យការបះបោររីករាលដាលថែមទៀត ។ ចៅហ្វាយខេត្រទាំង៣នាក់នេះបានត្រូវគេកោះហៅឲ្យមកចូលគាល់ព្រះរាជានៅបន្ទាយពេជ្រ រួចហើយកាត់ទោសប្រហារជីវិត ។ ក៏ប៉ុន្តែទោសរបស់ ពាង ចៅហ្វាយខេត្របារាយណ៍

បានត្រូវព្រះរាជាសម្រាលមកត្រឹមបញ្ចុះឋានៈ និងវាយ៥០រំពាត់ ឯស្តេចត្រាញ់ទែនត្រូវដកដំណែងចេញ ។

អតីតស្តេចត្រាញ់តេជោទែនបានវិលត្រលប់មកក្នុងខេត្តរបស់ខ្លួនវិញជាមួយនឹងប្អូនប្រុសពាង ហើយក៏តាំងប្រកាសបះបោរប្រឆាំងនឹងព្រះរាជាចាប់ពីឆ្នាំបន្ទាប់មក គឺឆ្នាំ១៧៧៩ ។ ដើម្បីឆ្លើយតបទៅនឹងសកម្មភាពទាំងអស់នេះ ព្រះរាជាបានចាត់ឲ្យបងប្រុសរបស់អ្នកទាំង២ គឺខុកញ៉ាមូ ចៅហ្វាយខេត្តទ្រាំង ដែលកាលពីមុនជាស្តេចត្រាញ់ដែនដីកំពង់ស្វាយ ជាអ្នកចាប់អ្នកអង្គម្ចាស់អង្គនន់រាមា និងអង្គជ័យដាក់ទ្រុងដែកក្នុងឆ្នាំ១៧៥៧ ឲ្យចេញមកបង្ក្រាប ។ ឈ្មោះ មូ នេះ ជាមនុស្សសកម្ម នឹងនរមិនឆេវឆាវ ក៏ប៉ុន្តែនៅក្នុងព្រះរាជវាំងមិនសូវមានគេចូលចិត្តទេ ព្រោះជាមនុស្សលោភលន់ បើចង់បានអ្វីហើយ គាត់ហ៊ានធ្វើអ្វីៗទាំងអស់ឲ្យតែបានដូចបំណង ។

មូដឹកនាំទ័ពមកដល់កំពង់ធំ ជួបទ័ពបះបោររបស់ប្អូនទាំង២ ក៏ឈប់ចរចាគ្នាសិន ។ នៅទីបញ្ចប់ គាត់ក៏ជឿតាមសម្តីប្អូន ហើយយល់ព្រមចូលដៃជាមួយ ធ្វើសង្គ្រាមប្រឆាំងនឹងព្រះរាជាវិញ ។ ទាំង៣នាក់បងប្អូន មូ ពាង និងទែន ក៏នាំទ័ពមកកាន់បន្ទាយពាមសែន ដែលវិបុលរាជសួសដកចេញទៅបាត់ ។

ជនក្បត់នេះមានបក្សពួកនៅឯខេត្តបាសាក់ និងព្រះត្រពាំង (ត្រាវិញ) ដែលពួកអាណ្ណាមទើបតែដណ្តើមយកដាក់ជាទឹកដីរបស់គេ ក៏ចាត់តាំងភ្នាក់ងារទៅជ្រើសរើសកងទ័ពក្នុងចំណោមពួកខ្មែរនៅទីនោះ ឲ្យឡើងមកវាយយកបន្ទាយពេជ្រ ដែលនៅចម្ងាយតែប៉ុន្មានគីឡូម៉ែត្រប៉ុណ្ណោះពីឧត្តុង្គ ។ ទ័ពបះបោរក៏លើកមកដណ្តើមយកបន្ទាយនេះបាន ហើយចាប់អ្នកអង្គម្ចាស់អង្គអេង ជាបុត្រារបស់ព្រះឧភយោរាជឧទ័យសុរិយោពណ៌ ដែលសុគតទៅកាលពីខែធ្នូ ឆ្នាំ១៧៧៧ ហើយដែលទើបតែមានព្រះជន្ម៦ព្រះវស្សាប៉ុណ្ណោះ ។ រួចហើយជនក្បត់នេះបានចាប់បុត្រា ៤អង្គទៀតរបស់ព្រះរាជានុសិទ្ធិឲ្យគេសម្លាប់ចោល ទើបចាកចេញទៅវិញ ដោយនាំយកព្រះរាជទ្រព្យទាំងអស់ទៅជាមួយផង ក្រោយពីបានបញ្ជាឲ្យដុតព្រះរាជមន្ទីរចោលរួចហើយ ។

អ្នកស្រុកត្រូវរត់ចោលផ្ទះសម្បែង ព្រោះពួកអាណ្ណាមដែលពួកបះបោរបានហៅមក ដេញពីក្រោយតាមធ្វើបាប និងដណ្តើមយកទ្រព្យសម្បត្តិ ។ គម្ពីរសាស្ត្រាក្បួនច្បាប់ផ្សេងៗដែលមាននៅតាមវត្តអារាម បានត្រូវពួកនេះ បោះគ្រវាត់ចោលទៅក្នុងទឹក អណ្តែតពាសពេញទន្លេ ធ្វើឲ្យប្រជាជនទាំងមូលអស់សង្ឃឹមយ៉ាងខ្លាំង ។ រាជពង្សាវតាររៀបរាប់ថាមាននារីៗជាច្រើននាក់ស្រែកយំ នៅពេលដែលឃើញក្បួនច្បាប់ជំនឿសាសនានេះបានត្រូវគេបំផ្លិចបំផ្លាញ ឲ្យខូចខាតបាត់បង់យ៉ាងនេះ ។

នៅពេលនោះព្រះរាជាទ្រង់កំពុងតែគង់នៅឯកំពង់ធំ ។ ពេលទ្រង់បានទទួលពត៌មានស្តីពីអំពើឃោរឃៅទាំងនេះ ហើយឃើញវិបុលរាជសួសបង្ហាញខ្លួនក្បែរៗរាជធានី ព្រះអង្គក៏យាងត្រលប់មកវិញ ហើយបានជួបប្រយុទ្ធជាមួយទ័ពពួកបះបោរនៅកំពង់ឆ្នាំង ។ ដោយមិនអាចវាយយកជ័យជម្នះបាននៅព្រែកបូពាងណាមួយទ្រង់បារម្ភខ្លាចវិបុលរាជ ដែលនៅកំពង់ពេជ្រលើកគ្នាមកព្រួតវាយថែមទៀតនោះ ព្រះអង្គក៏ភៀសព្រះកាយចេញពីសមរភូមិ ថយទៅជ្រកព្រះកាយនៅភ្នំកំរៀង ក្នុងខេត្តក្រង ។

គេនិយាយថា នៅទីនោះ ព្រះរាជាទ្រង់ទាល់ព្រះតម្រិះមិនដឹងថាតើត្រូវធ្វើយ៉ាងណាទេ ស្រាប់តែលេចលោក ធុតង្គ មួយអង្គឈ្មោះថា សីលមាស ចេញមកទូលសុំអនុញ្ញាតដឹកនាំទ័ព ហើយធានាថានឹងដណ្តើមយកជ័យជម្នះមកថ្វាយ ។ ព្រះរាជាដែលកំពុងតែអស់សង្ឃឹមទៅហើយ ក៏យល់ព្រមតាម ។ ប៉ុន្តែសីលមាសក៏មិនមានសំណាងល្អជាងព្រះរាជាប៉ុន្មានដែរ គាត់បានចេញប្រយុទ្ធ តែមិនបានជោគជ័យសោះ ។ នៅពេលនោះ មូ បានទទួលពត៌មានច្បាស់ថាព្រះរាជាទ្រង់គង់នៅឆ្ងាយពីកងពលរេហ៍និង មានតែសេនាបន្តិចបន្តួចប៉ុណ្ណោះនៅការពារ ហើយដាច់ស្បៀង គ្មានគ្រឿងសាស្ត្រាវុធផង ក៏នាំទ័ពចូលរហូតមកដល់កន្លែងដែលព្រះអង្គគង់នៅ ចាប់ព្រះអង្គនាំយកទៅដល់បឹងខ្យង[៥៦] នៅខាងត្បូងខត្តុគ្គ រួចចាប់ជ្រមុជក្នុងទឹក សម្លាប់ព្រះអង្គទៅ នៅក្នុងខែសីហា ឆ្នាំ១៧៧៩ ត្រូវនឹងមហាសករាជ១៧០១ (ចុល្លសករាជ១១៤១) ។

ព្រះអង្គរាមរាជា សោយរាជ្យបាន ៤ឆ្នាំ ។ ពេលនោះ ទ្រង់មានព្រះជន្ម ៣៩ព្រះវស្សា ។

## ៣៧- រយៈកាលចន្លោះរាជ្យ (១៧៧៩)

មូ ដណ្តើមអំណាចបាន រួចបានប្រកាសខ្លួនជាចៅហ៊្វា គឺថ្នាក់ជានាយករដ្ឋមន្ត្រី ។ គាត់បានលើកឧកញ៉ាអធិវង្សាប៉ុក ឪពុកចិញ្ចឹមរបស់អ្នកអង្គម្ចាស់អង្គអេង ឲ្យឡើងធ្វើជាឧកញ៉ាវាំង ឯព្រះអង្គអេងផ្ទាល់ជាព្រះមហាឧបរាជ ។ វិបុលរាជសួសបានឡើងជាឧកញ៉ាក្រឡាហោម គឺរដ្ឋមន្ត្រីទ័ពជើងទឹក ។ ពាង ប្អូនរបស់គាត់ គាត់ឲ្យឡើងជាឧកញ៉ាចក្រី គឺរដ្ឋមន្ត្រីខាងសង្គ្រាម ។ ក៏ប៉ុន្តែប្រជារាស្ត្រ និងនាម៉ឺនសព្វមុខមន្ត្រីចង់ឲ្យមានស្តេចសោយរាជ្យមួយអង្គ ។

ថ្វីបើមានឧទាហរណ៍ហូរហែមកពីខាងប្រទេសភូមា ដែលអាឡោងផ្រាបានដណ្តើមយករាជបល្ល័ង្ក នៅក្នុងឆ្នាំ១៧៥៣ និងពីប្រទេសសៀម ដែលភ្យាតាកបានប្រកាសខ្លួនជាព្រះរាជាក្នុងឆ្នាំ១៧៦៧ក៏ដោយ ក៏ប៉ុន្តែចៅហ៊្វាមូ មិនបានអនុវត្តតាម ឬក៏មានមហិច្ឆតាខ្ពស់ដល់ម្លឹងពេកទេ ។ គាត់បានរៀបចំឲ្យធ្វើការជ្រើសរើសរកព្រះរាជាមួយអង្គ ចេញពីក្នុងព្រះរាជវង្សានុវង្ស ទៅតាមបំណងរបស់ប្រជារាស្ត្រ និងប្រពៃណីពីបុរាណ ។

## ៣៦- ព្រះអង្គអេង (១៧៧៩-១៧៩៦)

នាម៉ឺនសព្វមុខមន្ត្រី និងចៅហ៊្វាមូបានឯកភាពគ្នាជ្រើសតាំងអ្នកអង្គម្ចាស់អង្គអេង ដែលត្រូវជាបុត្ររបស់ព្រះឧភយោរាជស្រីសុរិយោពណ៌ (ព្រះឧទ័យ) ដែលសុគតនៅឆ្នាំ១៧៧៧ ឲ្យឡើងគ្រងរាជសម្បត្តិទាំងព្រះអង្គ

---

[៥៦] ឯកសារខ្លះនិយាយថា នៅបឹងប្រមា នៅចំពីខាងមុខព្រះរាជវាំង ។

ទើបតែមានព្រះជន្មាយុ៦ព្រះវស្សាប៉ុណ្ណោះ ។ ធ្វើយ៉ាងនេះ ចៅហ៊្វាមូ គាត់អាចគេចផុតពីការទិតៀនរបស់សាធារណមតិ ក៏ប៉ុន្តែគាត់នៅរក្សាអំណាចបានដដែល ។

ជនណាធ្វើការរំខាន ចៅហ៊្វាមូបណ្តេញជននោះចេញ ក្នុងនោះរួមមានទាំងឧកញ៉ាបែន ដែលជាឧកញ៉ាយោមរាជ របស់ព្រះបិតាព្រះរាជាផងដែរ ។ ក្រោយមក ចៅហ៊្វាមូបានបញ្ជូនឧកញ៉ាបែនទៅឲ្យស្តេចសៀមភ្យាតាក តាមរយៈការស្នើសុំរបស់អ្នកអង្គម្ចាស់អង្គកែវខ្ជង ដើម្បីធ្វើទណ្ឌកម្មតបទៅនឹងការដែលបែនបានប្រយុទ្ធតទល់នឹងព្រះអង្គ ពេលព្រះអង្គដឹកនាំទ័ពចូលមកក្នុងកម្ពុជា ។

ភ្យាតាត នៅពេលដែលពិនិត្យឃើញថាការគ្រប់គ្រងប្រទេសកម្ពុជាចុះទន់ខ្សោយបែបនេះ ក៏គិតថា ខ្លួនអាចដណ្តើមយកស្រុកនេះបាន ហើយក៏រៀបចំទ័ពជាពាកង មួយកងៗមានគ្នា៧ពាន់នាក់ រួចឲ្យចេញដំណើរមកវាយយកបន្ទាយពេជ្រនៅជិតឧត្តុង្គ នគរវត្ត និងកំពង់ស្វាយ ។ ចៅហ៊្វាមូមិនព្រងើយកន្តើយទេ គាត់បានចេញបញ្ជាឲ្យកេណ្ឌទ័ពជាច្រើននៅតាមបណ្តាខេត្រដែលទទួលការគំរាមកំហែងភ្លាម ។ គាត់ដឹងថា ការប្រយុទ្ធនឹងបុកសំដៅមករករាជធានី ដែលជាចំណុចសំខាន់នៃសង្គ្រាម ដូច្នេះ ត្រូវរៀបចំការពារទីតាំងរបស់រដ្ឋាភិបាលឲ្យបានរឹងមាំ ទើបគាត់ចេញបញ្ជាប្រមូលកម្លាំងទ័ពទាំងអស់ក្នុងព្រះនគរឲ្យមកឈរជើងនៅជុំវិញឧត្តុង្គ នៅត្រង់កំពង់ហ្លួង ពាមជំនីក និងកំពង់រទេះ ហើយចាត់ឲ្យកសាងបន្ទាយការពារយ៉ាងរឹងមាំ នៅទីទាំងនោះ ។ គាត់ប្តេជ្ញាថានឹងតស៊ូប្រយុទ្ធរហូតដង្ហើមចុងក្រោយបង្អស់ ។ គាត់បានចាត់មនុស្សនាំបញ្ជាទៅឲ្យអ្នក ស្រុកក្រចេះ សម្បុក និងសម្បូរនៅលើទន្លេមេគង្គ ឲ្យប្រមូលទូកយកមកទុកនៅកៀនស្វាយ[៥៧] រង់ចាំទទួលបញ្ជា រួចហើយបានបញ្ជូនតំណាងទៅសុំជំនួយពីកូសាំងស៊ីនភាគខាងក្រោម ។ អាណ្ណាមបានបញ្ជូនទ័ពមួយកងតូច ដឹកនាំដោយឧត្តមសេនីយ៍ឈ្មោះ អុងជរម៉ា មកបោះទ័ពនៅនឹងជ្រោយចង្វា ចំពីមុខភ្នំពេញ ។

ចំណែកយុវក្សត្រព្រះអង្គអេង ត្រូវគេយកមកដាក់នៅជ្រោយចង្វា ឲ្យឆ្ងាយផុតពីការលបវាយឆ្មក់ ដែលអាចនឹងកើតមានឡើង ហើយផ្ទុកផ្តាក់ឲ្យក្រឡាហោមសួស អតីតវិបុលរាជនៅការពារ ។

ទ័ពខ្មែរដែលដឹកនាំដោយពញាតេជោទែនបានត្រូវទ័ពសៀមវាយឲ្យបរាជ័យនៅកំពង់ស្វាយ ។ ទ័ពសៀមដែលឈ្នះនោះបានបន្តធ្វើដំណើរមកកាន់រាជធានីឧត្តុង្គ ទទួលលេចឮដំណឹងថាស្តេចសៀម ភ្យាតាកធ្លាក់ខ្លួនឆ្កួត ហើយត្រូវពួកអ្នកប្រឆាំង ដែលដឹកនាំដោយពញាសានចាប់បាន ក្រោយពីការប្រយុទ្ធអស់៣ម៉ោង ដែលមានការគាំទ្រពីពួកកាន់សាសនាកាតូលិកផង រួចបានត្រូវគេបំបួសជាព្រះសង្ឃតាមសំណូមពរ និងឲ្យគង់នៅក្នុងវត្តមួយដោយមានទាហានយាមការពារយ៉ាងហ្មត់ចត់ ។

---

[៥៧] នៅក្នុងខេត្រកៀនស្វាយ ខាងត្បូងភ្នំពេញ នៅលើទន្លេមេគង្គខាងក្រោម ។

មេទ័ពសៀម២នាក់ក្នុងចំណោមមេទ័ពទាំង៣នាក់ដែលជាមេបញ្ជាការប្រយុទ្ធនៅកម្ពុជា ពេលបានទទួលពត៌មានខាងលើពីចៅហ្វាយខេត្រកូរ៉ាត់ ក៏ស្រុះស្រួលគ្នាហើយយល់ព្រមបោះបង់សង្គ្រាម ហើយដឹកនាំទ័ពប្រញាប់ប្រញាប់វិលត្រលប់ទៅបាងកកវិញភ្លាម ។ ពេលទៅដល់រាជធានីដែលមានប្រជារាស្ត្រកំពុងតែបះបោរធ្វើបដិវត្តន៍ ពួកមេទ័ពទាំងនោះក៏ដណ្តើមយកអំណាច ប៉ុន្តែមិនមែនធ្វើតាមរបៀបចៅហ៊្វាមូទេ គឺធ្វើតាម ភ្យាតាកនិងអាឡោងជ្រា ៖ ពញាមហាក្រសាសែក នាយករដ្ឋមន្ត្រី ដែលតាំងខ្លួនជាព្រះមហាក្សត្រសៀម (ព្រះចៅវាំងហ្លួង) តែម្តង ។ សាសី ប្អូនប្រុសរបស់ក្រសាសែក ដែលមានឋានៈត្រឹមតែជាឧត្តមសេនីយ៍ បានឡើងជាឧបរាជ (ព្រះចៅវាំងណា) ។ ឯក្មួយប្រុសរបស់គាត់ឈ្មោះ ម៉ាឡាក់ ត្រូវបានឲ្យឡើងជាកែវហ៊្វា ។ ចំណែកពួកអ្នកធ្វើបដិវត្តន៍ផ្សេងទៀត រួមទាំងពញាសានផង គេកាប់សម្លាប់ចោលដោយលាក់លៀម នៅខែមីនា ឆ្នាំ១៧៨២ ។ មួយខែក្រោយមក ព្រះរាជាថ្មីបានបញ្ជាឲ្យយកភ្យាតាកចេញពីវត្ត មកធ្វើឃាតជាមួយនឹងបុត្រទាំងអស់ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៧៨២ ដោយយកលេសថា ភ្យាតាកអាចនឹងបំផុសការបះបោរឡើងវិញបាន ។

នៅពេលដែលហេតុការណ៍ទាំងអស់នេះ កើតមានឡើងនៅឯស្រុកសៀម នៅស្រុកអាណ្ណាមឯណោះវិញ ក៏កើតមានព្រឹត្តិការណ៍ដែលមិនជាស្រាលប៉ុន្មានដែរទេ ។ ពួកតៃសឺន ដែលយើងបានឃើញពីខាងលើរួចមក ហើយថាបានងើបបះបោរនៅកូសាំងស៊ីន បានលបលួចចូលមកក្នុងទឹកដីកម្ពុជា ដើម្បីរៀបចំកម្លាំងឡើងវិញ ។ ស្តេចអាណ្ណាមឈ្មោះ យ៉ាឡុង[៥៨] (ង្វៀងភុកអាញ់) ដែលគង់នៅសាយហ្គនតាំងពីឆ្នាំ១៧៧៧មក បានផ្តល់ដំណឹងនេះឲ្យរដ្ឋាភិបាលខ្មែរ ដោយសុំឲ្យជួយបណ្តេញពួកនេះចេញទៅវិញ ។ មេដឹកនាំកម្ពុជា គឺចៅហ៊្វាមូ និងសួស បានចាត់ឲ្យក្រឡាហោមពោធិដឹកនាំទ័ពមួយកងតូច ទៅវាយពួកតៃសឺន នៅវាលពោធិយ៍ងបណ្តេញចេញពីកម្ពុជា ។ ប៉ុន្តែ លោកក្រឡាហោមបរាជ័យ ត្រូវពួកបះបោរអាណ្ណាមសម្លាប់បាន ឯកងទ័ពក៏រត់បែក ខ្ញែកគ្នាអស់ ។ ពួកតៃសឺន បានវិលត្រលប់ចូលទៅក្នុងកូសាំងស៊ីនវិញ ដណ្តើមយកសាយហ្គនបាននៅក្នុងខែកុម្ភៈ ឆ្នាំ១៧៨១ ធ្វើឲ្យស្តេចយ៉ាឡុង រត់ភៀសព្រះកាយទៅជ្រកកោននៅឯស្រុកសៀម សុំការការពារពីព្រះយុវៈចូឡាលោក[៥៩] ។

មិនយូរប៉ុន្មានក្រោយមក មេទ័ពអាណ្ណាមឈ្មោះ អុងជរម៉ា បានស្នើសុំការអនុញ្ញាតពីរដ្ឋាភិបាលកម្ពុជាធ្វើដំណើរឆ្លងកាត់ទៅស្រុកសៀមជាមួយមន្ត្រីមួយចំនួន ដើម្បីនាំយកស្តេចយ៉ាឡុងមកវិញ ។ ចៅហ៊្វាមូ និងសួសបានឯកភាពផ្តល់ការអនុញ្ញាតឲ្យ ហើយថែមទាំងបានផ្តល់កម្លាំងការពារជូនទៅទៀតផង ។ ក៏ប៉ុន្តែនៅពេលធ្វើ

---

[៥៨] ស្តេចនេះឡើងសោយរាជ្យនៅក្នុងឆ្នាំ១៧៧៩ បន្តពីង្វៀងភុកតាន់ចាញ ដែលទទួលរាជសម្បត្តិបន្តពីង្វៀងភុកធន់ ដែលដាក់រាជ្យថ្វាយ កាលពី១ឆ្នាំមុន ។

[៥៩] លោក ប៉ាឡឺហ្គ័រ ហៅព្រះអង្គថា ព្រះពុទ្ធិចៅហ្លួង បាននិយាយថា ទ្រង់សោយរាជ្យបាន ២៩ឆ្នាំ គឺពីឆ្នាំ១៧៦៦ដល់១៨១១ ។

ដំណើរមកដល់ខែត្របាត់ដំបង ពួកកម្លាំងការពារបានសម្លាប់អុងជរម៉ា និងបក្សពួកចោល រួចចែករបស់របរគ្នាវិលត្រលប់មកស្រុកវិញអស់ទៅ ។ ឧក្រិដ្ឋកម្មនេះមិនត្រូវបានគេរកខុសរកត្រូវដាក់ទណ្ឌកម្មទេ ។ នៅកូសាំងស៊ីន គេគិតថា គឺរដ្ឋាភិបាលកម្ពុជា ដែលបញ្ជាឲ្យពួកកងការពារប្រព្រឹត្តបទល្មើសនេះ បើពុំនោះទេ គឺពួកនេះត្រូវរ៉ូវជាមួយពួកតៃសឺន ។ តែរឿងនេះបានបញ្ចប់បែបនោះទៅ ។

ទ័ពសៀមបានវិលត្រលប់ទៅបាងកកវិញហើយ ឯទ័ពអាណ្ណាមក៏បានឆ្លងព្រំដែនទៅវិញដែរ ព្រះរាជាក្មេងក៏យាងត្រលប់ចូលមកក្នុងរាជធានីឧត្តុង្គវិញ នៅក្នុងឆ្នាំដដែលនោះ ។ ទ័ពដែលគេបានកេណ្ឌបានយ៉ាងច្រើនក៏ត្រូវរំសាយឲ្យវិលត្រលប់ទៅស្រុកវិញ មិនទាន់បានប៉ុន្មានផង ស្រាប់តែចៅហ៊្វាមូ និងឧកញ៉ាសួស កើតមានទំនាស់នឹងគ្នា គឺនៅក្នុងខែមិថុនា ឆ្នាំ១៧៨២ ។ មុនដំបូង សួស មិនសប្បាយចិត្តទាល់តែសោះ បានចាប់នឹកគិតសោកស្ដាយចំពោះអំពើចូលដៃចូលជើងជាមួយនឹងចៅហ៊្វាមូ ក៏សរសេរលិខិតមួយផ្ញើទៅឲ្យបែន ដែលនៅជាប់ជាឈ្លើយរបស់សៀម ដោយបបួលឲ្យវិលត្រលប់មកកម្ពុជាវិញ ។ គេមិនដឹងថា បែនធ្វើយ៉ាងណាទេ ទើបបានជាសៀមយល់ព្រមដោះលែងឲ្យវិលមកវិញ ពេលធ្វើដំណើរមកដល់បាត់ដំបងបាន ជួបជាមួយសួសដែលរង់ចាំនៅទីនោះ ។ អ្នកទាំងពីរបានបំផុសអ្នកស្រុកខែត្របាត់ដំបងឲ្យបះបោរឡើង ជ្រើសរើសបានទ័ពមួយកងធំ រួចនាំគ្នាមកវាយយករាជធានីឧត្តុង្គបាន ។ ចៅហ៊្វាមូ ត្រូវគេបាញ់ព្រួញចំត្រង់ចំហៀងខ្លួនខាងស្ដាំ ហើយបានត្រូវខ្មែរមកពីសុកត្រាំង ដែលមានតៃសឺនជាមេកោយ វាយបន្ថែមសម្លាប់ចោលតែម្ដង ។ ចក្រីពាង ប្អូនរបស់ចៅហ៊្វាមូ ក៏ត្រូវគេសម្លាប់ដែរ ។

នៅពេលទទួលដំណឹងថាកូនទាំង២ចុងក្រោយរបស់គាត់ គឺចៅហ៊្វាមូ និងចក្រីពាង ត្រូវគេសម្លាប់អស់ហើយ លោកជំទាវ ឡាង ជាម្ដាយ បានប្រកូកប្រកាសហៅរកមិត្តភក្តិទាំងអស់របស់កូនគាត់ រួមទាំងអ្នកដែលធ្លាប់បានទទួលផលពីខ្លួនគាត់ផង ឲ្យចូលរួមជួយគាត់ធ្វើការឃោសនាប្រឆាំងឡើង ។ គាត់ជិះដំរីដឹកនាំទ័ពប្រយុទ្ធយ៉ាងអង់អាចក្លាហាន លើសពីមនុស្សប្រុសទៅទៀត ។ ក៏ប៉ុន្តែជំទាវឡាងត្រូវគេចាប់ខ្លួនបានជាមួយនឹងមេទ័ពមួយចំនួននៅក្នុងការប្រយុទ្ធស៊ីសាច់ហុតឈាមមួយនៅឧត្តុង្គ ។ ពេលនោះបែនបានឡើងជាអ្នកដឹកនាំប្រទេស ហើយគាត់គ្មានការសន្ដោសប្រណីទាល់តែសោះចំពោះពួកអ្នកប្រឆាំងនឹងគាត់ ។ បែនបានឲ្យគេខ្នុះច្រមុះជំទាវឡាង និងបក្សពួក រួចធ្វើទារុណកម្មពួកនេះ ចាត់ទុកដូចជាសត្វក្របី គឺឲ្យវារនឹងជង្គង់រាល់ថ្ងៃទៅកាន់ទីវាលណាដែលនៅជិត ហើយធ្វើហាក់ដូចជាស៊ីស្មៅអ៊ីចឹង ។ គេឲ្យចំណីជាបាយតែមួយពំនូតប៉ុណ្ណោះ ហើយនៅពេលណាដែលពួកនេះស្គមវារលែងរួច ទើបគេកាត់ក្បាលសម្លាប់ចោល ។

ក្រោយពេលដណ្ដើមយកអំណាចបានហើយ បែនបានប្រកាសខ្លួនជាចៅហ៊្វា គឺនាយករដ្ឋមន្ត្រី រួចហើយ

---

[៦០] អរដូន ជាឆាររបស់ស្ដេចត្រាញ់ ដែលជាចៅហ្វាយខែត្រជីត្បូងឃ្មុំ ។

ក៏បែរមកប្រឆាំងនឹងសួសជា ដៃគូក្បត់របស់គាត់វិញ ហើយឲ្យគេសម្លាប់ចោលទៅ នៅពេលដែល សួស ត្រូវរ៉ូវគ្នាជាមួយលោក អរជូន[៦០] ចៅហ្វាយខេត្រត្បូងឃ្មុំ ប្រុងកេណ្ឌទ័ពប្រឆាំងនឹងគាត់ នៅក្នុងឆ្នាំ១៧៩០ ។ អ្នកដែលសម្លាប់ សួស គឺកូនប្រសាររបស់គាត់ មាសកៃសឺន[៦១] ដែលគាត់បានសម្លាប់ឪពុកកាលពីមុន រួចហើយបានលើកកូនស្រីឲ្យដើម្បីកុំឲ្យចងចិត្តខឹងនឹងគាត់ ។ សម្លាប់ឪពុកក្មេករួចហើយ មាស សម្លាប់ប្រពន្ធដែលបានស្តីបន្ទោសឲ្យខ្លួនចោលទៀត ដោយនិយាយថា ដើម្បីសងសឹកជួសឪពុក ។

ពេលដឹងថាសួសត្រូវគេសម្លាប់ហើយ លោក អរជូន ក៏ដឹកនាំទ័ពដែលមានចាមមួយចំនួនធំ ធ្វើដំណើរមកកាន់ភ្នំពេញ ហើយចាត់ឲ្យជនម៉ាឡេឈ្មោះ ទួនសេត ដែលកាន់ទ័ពស្រួច ចេញវាយប្រហារទៅលើចៅហ៊្វាបែន ។ ចៅហ៊្វាបែន និងខុកញ៉ាក្រឡាហោមប៉ុកបានរត់គេចខ្លួនទៅកាន់ខេត្របាត់ដំបង រួចទៅស្រុកសៀម ដោយនាំយកយុវក្សត្រព្រះអង្គអេង ព្រះមាតុច្ឆា២អង្គ និងព្រះរៀមក្សត្រី៣អង្គទៅជាមួយផង ។ ស្តេចសៀមទទួលសាទរក្រុមអ្នកភៀសខ្លួនខ្មែរ ហើយព្រះឧបរាជ ឬចៅវាំងណាក៏ទទួលយកព្រះក្សត្រីទាំង៣អង្គ ជាព្រះជាយាតែម្តង ។ ស្តេចសៀមបានលើកចៅហ៊្វាបែនជាហ្លួ មឿង (ចៅហ្វាយខេត្រ) បាត់ដំបង នៅក្នុងឆ្នាំ១៧៩១ មានងារជាចៅពញាអភ័យធីបែសវិសេសសង្រ្គាមរាម ។ល ។ ដែលជាងាររបស់ស្តេចត្រាញ់ខេត្របាត់ដំបង កាលនៅជាទឹកដីកម្ពុជានៅឡើយ ។

នៅក្នុងឆ្នាំ១៧៩៤ ចៅហ៊្វាបែន បានរៀបចំពិធីអភិសេកព្រះរាជា អង្គអេង ដែលមានព្រះជន្ម ២០ ព្រះវស្សាហើយ នៅបាងកក ដោយថ្វាយព្រះនាមថាព្រះបាទសម្តេចស្តេចព្រះរាជឱង្ការព្រះនរាយណ៍រាជាធិរាជ ។ ការដែលរៀបចំអភិសេកព្រះរាជាកម្ពុជានៅឯរាជធានីបាងកករបស់សៀម ដោយស្តេចសៀមដូច្នេះ ជាការបញ្ជាក់ថា កម្ពុជាទទួលស្គាល់ថាខ្លួនជានគរចំណុះ ហើយទទួលការគ្រប់គ្រងរបស់សៀម ។ គឺក្នុងនាមជាអ្នកការពារនេះឯង ដែលពេលក្រោយមកស្តេចសៀមបានរៀបចំឲ្យទ័ពសៀមមួយកង មានចៅហ៊្វាបែនជាមេបញ្ជាការជូនដំណើរព្រះរាជាមកកាន់ឧត្តុង្គ ។

ពេលទទួលបានដំណឹងថាចៅហ៊្វាបែនធ្វើដំណើរមកដល់ខេត្របាត់ដំបងហើយ លោកយមរាជ កុយ បានដឹកនាំទ័ពមួយកងតូចទៅទប់ទល់ តែត្រូវបរាជ័យហើយស្លាប់នៅក្នុងការប្រយុទ្ធនោះទៅ ។ ឃើញផ្លូវចូលទៅឧត្តុង្គស្រឡះហើយ ចៅហ៊្វាបែនក៏ប្រញាប់រួសរាន់ដឹកនាំទ័ពចូលទៅ ជួបជាមួយទ័ពអាណ្ណាមពួកតៃសឺន ដែល

[៦១] តាមមើលទៅកៃសឺនមាសនេះគឺជាឈ្មោះមាស ដែលមានដើមកំណើតនៅសុកត្រាំង ជាប់នឹងព្រំដែនរបស់អាណ្ណាម នៅកូសាំង-ស៊ីនខាងក្រោម ហើយបានចូលដៃចូលជើងជាមួយពួកតៃសឺន តែខ្មែរយើងហៅថា កៃសឺនៗ ទៅវិញ ដោយហេតុនោះហើយ ទើបបានជាមានឈ្មោះថា កៃសឺនមាសៗ ដូច្នេះទៅ ។ តាមការនិទានតៗគ្នានៅកម្ពុជា ក៏ដូចជានៅឯសុកត្រាំង មាសនេះជាមនុស្សស្វាហាប់ ក្លាហានមិនចេះខ្លាច ហើយសាហាវ ។

ឡើងមកជួយពួកខ្មែរតាមការស្នើសុំ មានអុងជរម៉ា និងអុងធុងបិញជាមេបញ្ជាការ ។ ចៅហ៊្វាបែនបានវាយទ័ពអាណ្ណាមនោះ បង្ខំឲ្យដកថយចេញទៅកូសាំងស៊ីនវិញ ។ ពេលនោះមាននៅសល់តែមេទ័ពអាណ្ណាមម្នាក់ប៉ុណ្ណោះនៅកម្ពុជា ចំណែកនៅបាសាក់-សុកត្រាំង គឺអុងចុកស៊ីម ។

ក្រោយពីដណ្ដើមបានជ័យជម្នះលើពួកខ្មែរដែលជាសត្រូវ និងសម្ព័ន្ធមិត្រអាណ្ណាមរួចហើយ ចៅហ៊្វាបែនបានចាត់ឲ្យលោកចក្រី កែប និងលោកយមរាជ កាន ដែលតែងតាំងថ្មី ដឹកនាំទ័ពជើងទឹកទៅមាត់ជ្រូក (ចូវដុក) វាយដណ្ដើមយកទឹកដីមួយចំនួនមកវិញ ។ ចក្រីកែបបានជួបប្រយុទ្ធជាមួយទ័ពរបស់ អុងចុកស៊ីម នៅព្រែកផ្លាង ហើយវាយបង្ខំឲ្យអុងចុកស៊ីមរត់ចូលទៅសាយហ្គន តាមមេទ័ព៣នាក់មុនទៅ ។

ពេលនោះពួកតៃសឺន នៅកូសាំងស៊ីនមិនទាន់មានលទ្ធភាពធ្វើការសងសឹកមកលើកម្ពុជា បាននៅឡើយទេ ព្រោះពួកគេទើបតែប្រយុទ្ធស៊ីសាច់ហុតឈាមជាមួយស្ដេចយ៉ាឡុង ដណ្ដើមយកបានរាជធានីវេ ស្រុកនៅរំដើបរំជួលនៅឡើយ គេនៅត្រូវប្រយុទ្ធជាមួយទ័ពព្រះរាជាដែលនៅសេសសល់ ហើយត្រូវបន្តបង្ក្រាបភូមិស្រុកដែលមិនព្រមចំណុះថែមទៀត ។ ចំណែកស្ដេចយ៉ាឡុងវិញ បានរត់ទៅស្រុកសៀមសុំជំនួយ ហើយត្រូវភៀសព្រះកាយពីក្រុងបាងកកមកគង់នៅឯកោះត្រល់ (កោះភូកុក) នៅក្នុងឈូងសមុទ្រសៀម នៅទន្ទឹមនឹងហាទៀង និងកំពត ។ ពេលជ្រើសរើសបានទ័ពថ្មី និងប្រមូលបានបក្សពួកជាច្រើន ទ្រង់ចាប់ផ្ដើមលុកលុយយកខេត្រទឹកខ្មៅ (កាម៉ៅ) និងត្រានយ៉ាង (រ៉ាចយ៉ា) ដាក់មកក្នុងអំណាចព្រះអង្គ ។ ប្រតិបត្តិការនេះបានធ្វើឲ្យព្រះអង្គស្ដារបាននូវព្រះកិត្តិនាមឡើងវិញ ទ្រង់ក៏យាងមកកាន់រាជធានីខត្តុង្គសុំជំនួយពីចៅហ៊្វាបែន ដើម្បីបណ្ដេញពួកតៃសឺនចេញពីសាយហ្គន ធ្វើឲ្យព្រះអង្គបានត្រួតត្រាលើកូសាំងស៊ីនភាគខាងត្បូងទាំងមូល ។

ចៅហ៊្វាបែនបានរៀបចំទ័ពមួយកងតូច ដាក់ភ្ជាប់ជាមួយទ័ពអាណ្ណាមរបស់ស្ដេចយ៉ាឡុង ហើយចេញដំណើរទៅសាយហ្គន ជាមួយលោកចក្រី និងលោកយមរាជ ។ ទ័ពសម្ព័ន្ធមិត្របានវាយពួកតៃសឺនឲ្យបរាជ័យ ហើយមេរបស់គេគឺអុងចុកស៊ីមក៏ត្រូវសម្លាប់បាន ។ ស្ដេចយ៉ាឡុង បានយាងត្រលប់ទៅរាជធានីវេវិញ ឯទ័ពកម្ពុជាក៏ត្រលប់មកកាន់រាជធានីខត្តុង្គពុជ័យវិញដែរ នៅក្នុងឆ្នាំ១៧៩២ ។

នៅពេលទ័ពខ្មែរត្រលប់មកពីសង្គ្រាមនៅកូសាំងស៊ីនបានបន្តិច ស្ដេចសៀម ក្នុងនាមជាស្ដេចមានអធិរាជភាពលើកម្ពុជា បានសុំឲ្យចៅហ៊្វាបែនប្រគល់កម្លាំង១ម៉ឺននាក់ ទៅជួយជីកព្រែកស្រះកេតនៅឯបាងកក នៅក្នុងសង្កាត់សមសែន មានន័យថា ត្រួសារ ១សែន ។ ចៅហ៊្វាបែនគោរពតាមបញ្ជានេះ ហើយបានធ្វើឲ្យគាត់មានសត្រូវជាច្រើននៅកម្ពុជា ។

គឺនៅពេលនោះឯងដែលស្ដេចសៀមបញ្ជូនព្រះអង្គអេង ដែលគេបានរៀបចំពិធីអភិសេកថ្វាយនៅឯបាងកក ឲ្យមកខត្តុង្គវិញ គឺរង់ចាំរហូតដល់ពេលនេះទើបគេឲ្យទ្រង់មានសិទ្ធិគ្រប់គ្រងព្រះរាជាណាចក្រ ។ ព្រះរាជកាយវិការដំបូងរបស់ព្រះអង្គគឺការលើកលោកក្រឡាហោមឲ្យឡើងជា ចៅហ៊្វាទល្ហៈ និងការប្រគល់ត្រាទៅឲ្យមន្ត្រី

ដែលចៅហ្វាបែនបានតែងតាំង ស្របទៅតាមទំនៀមទម្លាប់ពីបុរាណ ។ រួចហើយទ្រង់បានជម្រាបទៅចៅហ្វាបែនថា ព្រះរាជាសៀមចង់ឲ្យគាត់ទៅនៅចាត់ចែងគ្រប់គ្រងខេត្តបាត់ដំបងរបស់គាត់វិញ ។ ការលើកព្រះអង្គអេងដែលមានព្រះជន្ម២១ព្រះវស្សា ឲ្យឡើងគ្រងរាជសម្បត្តិវិញដូច្នេះ វាសមស្របទៅនឹងបំណងរបស់ប្រជារាស្ត្រខត្តុង្គដែលនឿយណាយនឹងការខ្វះស្តេចសោយរាជ្យយូរមកហើយ ព្រោះលោក អរជូន ស្តេចត្រាញ់ដីត្បូងឃ្មុំ មិនអាចធ្វើឲ្យគេគោរពបាន មិនចេះដឹកនាំចាត់ចែងការងារ ។ ចៅហ្វាបែន ក្រោយពីបានទទួលការអនុញ្ញាតពីព្រះរាជារួចហើយ ក៏ដឹកនាំទ័ពសៀមត្រលប់ទៅបាត់ដំបងវិញ ជាទីដែលយើងបានឃើញរួចមកហើយថា គាត់បានទទួលការតែងតាំងពីស្តេចសៀមជាចៅហ្វាយខេត្ត ។ ចាប់តាំងពីពេលនោះរហូតមកដល់ឆ្នាំ១៩០៧ ដីនោះ រួមទាំងខេត្តអង្គរផង ដែលគេបានភ្ជាប់ទៅនឹងបាត់ដំបង នៅក្រោមការត្រួតត្រារបស់ចៅហ្វាបែន ដែលចំណុះហើយទទួលបញ្ជាពីស្តេចសៀម បានក្លាយទៅជាទឹកដីរបស់លោកម្ចាស់ គឺចៅហ្វា បែន នេះឯង គ្មានទំនាក់ទំនងរដ្ឋបាលអ្វីជាមួយនឹងព្រះរាជាកម្ពុជាទេ ។ ចំណែកឯបណ្តាខេត្តដែលស្ថិតនៅពីខាងជើងបាត់ដំបងវិញ មានមង្គលបុរី សិរីសោភ័ណ និងគូរ៉ាត គេមិនចាំបាច់ សង្ស័យអ្វីឡើយ ពួកសៀមបានយកដាក់ធ្វើជាទឹកដីរបស់គេយ៉ាងស្ងៀមស្ងាត់ នៅក្នុងឆ្នាំ១៧៩៥ ។

គេអាចនឹងងាយយល់អំពីសកម្មភាពរបស់សៀម ហើយទទួលស្គាល់វិធីសាស្ត្រដែលគេបានប្រើណាស់ ដើម្បីធ្វើឲ្យទឹកដីដ៏ធំ និងមានសារសំខាន់ជាយុទ្ធសាស្ត្រខាងផ្នែកយោធានេះ បានត្រូវផ្តាច់ចេញពីកម្ពុជា ដោយមិនដឹងខ្លួន ។ ចៅហ្វាបែនជាមនុស្សក្បត់ប្រាកដណាស់ ព្រោះបានដឹងហើយថាខ្លួនមានតួនាទីខ្ពង់ខ្ពស់មួយ តែបែរជាកាត់យកទឹកដីមួយចំណែកធំចេញពីព្រះរាជាណាចក្រយកមកគ្រប់គ្រង ក្រោមគោរមងារសៀមជាហ្លួងមឿងប្រៀបបានទៅនឹងព្រះរាជាណាចក្រតូចមួយស្ថិតនៅចន្លោះកម្ពុជានឹងសៀមទៅវិញ ។ ក្រោយពីបានរៀបចំឲ្យមានព្រះរាជាគង់លើរាជបល្ល័ង្កវិញរួចហើយ គាត់បានរក្សាទ័ពដែលបានជួយគាំទ្រដល់ការងារនេះទុកនៅក្នុងខេត្តរបស់គាត់សិន ដោយគាត់ថាដើម្បីបង្ការសម្រាប់ជួយព្រះរាជាបើសិនណាជាព្រះអង្គទទួលការគំរាមកំហែង ។ ដោយទ័ពនោះជាទ័ពបរទេស តែមានគាត់ជាមេបញ្ជាការ ត្រង់នេះមានន័យច្បាស់ណាស់ថាគាត់គឺជាចៅហ្វាយខេត្តខ្មែរ ប៉ុន្តែគាត់ស្ថិតនៅក្រោមបញ្ជាការរបស់ស្តេចសៀម ឯទឹកដីដែលគាត់រស់នៅជាទឹកដីខ្មែរ ។ ប៉ុន្តែអ្វីៗនៅស្ងៀមស្ងាត់ គ្មាននរណាបានគិតដល់ទេ ។ នៅពេលក្រោយៗមក ចៅហ្វាបែនគោរពតាមតែបញ្ជាមកពីបាងកក មិនទទួលបញ្ជាពីខត្តុង្គទេ និងឡើងចុះចេញចូលរាជវាំងទាំង២ ក៏ប៉ុន្តែលើកតង្វាយទៅថ្វាយតែស្តេចសៀម មិនមែនក្នុងនាមជាចៅហ្វាយខេត្តទេ គឺក្នុងនាមជាមេទ័ពសៀម ។ ចំណែកចំណូលផ្សេងៗនៅក្នុងខេត្តគាត់រក្សាទុកដើម្បីចិញ្ចឹមទាហានដែលនៅជាមួយគាត់ ក៏ប៉ុន្តែបានថ្វាយជូនទៅស្តេចសៀមដដែល ដែលរឹតតែបញ្ជាក់ឲ្យឃើញអំពីភាពចំណុះរបស់គាត់ ។ កូនៗរបស់គាត់បានបន្តដំណែងពីគាត់ ហើយក៏បានបន្តនយោបាយនេះរហូតមក ។ ការកាត់យកទឹកដីកម្ពុជាដាក់ជាចំណុះសៀម បានប្រព្រឹត្តទៅបែបនេះបន្តិចម្តងៗទៅតាម

កាលៈទេសៈ ដោយគ្មានអ្នកណាចាប់អារម្មណ៍ទាល់តែសោះ ដំបូងឡើយដឹកនាំដោយអ្នកដែលមានបំណងច្បាស់លាស់ រួចបន្តដោយកូនចៅរបស់គាត់ ។ ហេតុការណ៍នេះបានស្ថិតស្ថេរគង់វង្សនៅរហូតមកដល់សព្វថ្ងៃនេះ ដោយគ្មានការចុះអនុសញ្ញាអ្វីមួយជាលាយល័ក្ខអក្សរ ឬជាពាក្យសម្ដីសោះទេ មានតែការចងចាំតៗគ្នាមកប៉ុណ្ណោះ ។ តាមពិតទៅ កម្ពុជានៅក្នុងសតវត្សរ៍ទី១៩គ្មានកម្លាំងអ្វីនឹងធ្វើការទាមទារយកទឹកដីមកវិញឡើយ តែការកាត់យកទឹកដីទៅដោយពួកសៀមនេះបានត្រូវគេទទួលស្គាល់ក្នុងចិត្តគំនិតទៅហើយ តាំងតែពីមុនពេលដែលមានសន្ធិសញ្ញាបារាំងសៀមនៅក្នុងឆ្នាំ១៨៦៧ ទៅទៀត ។ សន្ធិសញ្ញានេះគ្មានតម្លៃអ្វីសោះ ព្រោះគេនាំគ្នាចុះហត្ថលេខាដោយមិនបានសួរយោបល់ព្រះរាជាកម្ពុជាផងទេ ព្រះអង្គក៏បានប្រកែកមិនទទួលស្គាល់ថែមទៀត ។ ក៏ប៉ុន្តែវានៅតែមានតម្លៃរហូត ដោយមកពីប្រទេសបារាំងដែលគ្មានពត៌មានច្បាស់លាស់ បានចុះហត្ថលេខា ។

នៅឆ្នាំបន្ទាប់មកទៀត ក្នុងពេលដែលគេកំពុងតែរវល់កសាងរាជវាំងដើម្បីព្រះរាជាថ្មីនៅពីខាងកើតវត្តវាំងក្ដារ ព្រះបាទអង្គអេងបានបញ្ជូនសំណើទៅស្នើសុំស្ដេចសៀម សូមឲ្យបញ្ជូនព្រះមាតុច្ឆាមួយអង្គក្នុងចំណោមព្រះមាតុច្ឆាទាំង២អង្គ គឺសម្ដេចព្រះភគវតី មហេសីទាំង៣អង្គ និងរាជបុត្រទាំង៤អង្គ ព្រមទាំងសេនាភីលៀងផងមកកម្ពុជាវិញ ។ ព្រះរាជាសៀមបានបញ្ជូនអ្នកទាំងអស់នោះមក នៅក្នុងរវាងខែឧសភា ឆ្នាំ១៧៩៥ ។

ព្រះបាទអង្គអេង បានចេញព្រះរាជបញ្ញាជាច្រើន ដែលគួរតែលើកយកមករៀបរាប់ ។ ព្រះរាជបញ្ញាមួយនោះទាក់ទងទៅនឹងពួកមហាតលិក មហាទេព និងមហាមន្ត្រី ដែលមានត្រារំលេចទៅដោយភ្ញីផ្កាមួយរង្វង់ត្រូវបាំងក្លស់២ជាន់ធ្វើអំពីសូត្រពណ៌ក្រហម ពាក់អាវផាយពណ៌ផ្កាកូលាប និងមានកាន់ថង់រងផង[៦២] ពេលចូលមកក្នុងព្រះរាជវាំង ។ មន្ត្រីដែលមានសក្តិ ៨-៩ហ៊ូពាន់[៦៣] អាចពាក់អាវផាយពណ៌បៃតង ហើយបាំងក្លស់សូត្រមួយជាន់ពណ៌បៃតងដែរ ។ អ្នកដែលមានសក្តិ៦-៧ហ៊ូពាន់មានអាវផាយ និងក្លស់ពណ៌ស្វាយ ។ ឯអ្នកមានសក្តិ៤-៥ហ៊ូពាន់ វិញ អាចមានត្រឹមតែអាវផាយពណ៌ខៀវប៉ុណ្ណោះ ។ ព្រះរាជបញ្ញានោះក៏បាន បញ្ជាក់ផងដែរថា ភរិយារបស់មន្ត្រីមានសក្តិ ៩-១០ហ៊ូពាន់ ត្រូវមានឋានៈជា ឃុនណាង[៦៤] ។

នៅឆ្នាំបន្ទាប់មក ព្រះរាជាអង្គអេងទ្រង់ប្រឈួនរួចសុគតទៅ នៅក្នុងព្រះជន្ម២៦ព្រះវស្សា ។ ទ្រង់សោយរាជ្យសរុបទាំងអស់បាន២០ឆ្នាំ ចែកចេញជា២រជ្ជកាល ដែលចន្លោះពីគ្នា៣ឆ្នាំ ។ រាជពង្សាវតារក៏ដូចជាការនិទានតៗគ្នា មិនបានកត់សម្គាល់ឃើញមានអ្វីដែលជាស្នាដៃពិសេសរបស់ព្រះរាជាអង្គនេះទេ និងគ្មានការសាងសង់អ្វី

---

[៦២] ប្រអប់ស្លាធ្វើអំពីឈើ ស្រោបដោយក្រណាត់ ។

[៦៣] ពាក្យ «ហ៊ូពាន់» នេះ សម្គាល់ឋានន្តរសក្តិមន្ត្រី មកពីពាក្យសៀម២ម៉ាត់ គឺៈ ហ៊ូ ឬហួ = មេកោយ, ពាន់ = ១ពាន់ ។ ដូច្នេះពាក្យនេះមានន័យថា មេកោយកាន់ពល១ពាន់នាក់ ។

[៦៤] គឺ ឃុន = មេ, និង ណាង = នាង ។

ជាផលប្រយោជន៍ដល់សាសនាដែរ ។ ទ្រង់មិនបានធ្វើអ្វីជាដុំកំភួនទេ ព្រោះពេញមួយជីវិតរបស់ព្រះអង្គត្រូវដឹកនាំដោយជនបរទេស ឬក៏មន្ត្រីដែលព្រះអង្គមិនបានតែងតាំងឡើង តែគេបានដាក់មកឲ្យព្រះអង្គទទួលយក ។ គេអាចនិយាយបានថា ព្រះអង្គក្បត់ជាតិ ព្រោះវាហាក់ដូចជាទ្រង់បានដោះដូររាជសម្បត្តិជាមួយនឹងទឹកដីបាត់ដំបង និងអង្គរ ។

## ៣៩- រយៈកាលចន្លោះរាជ្យ១០ឆ្នាំ (១៧៩៦-១៨០៦)

ចៅហ៊្វាប៉ុក នាយករដ្ឋមន្ត្រី បានដឹកនាំកិច្ចការព្រះរាជាណាចក្រដោយមិនបានខិតខំប្រឹងប្រែងជ្រើសរើសព្រះរាជាថ្មីមួយអង្គណាទេ ។ ព្រះរាជវង្សានុវង្សពេលនោះស្ទើរតែរលត់បាត់ផុតពូជអស់ទៅហើយ នៅសល់តែរាជបុត្រារបស់ព្រះអង្គអេង ដែលនៅតូចៗនៅឡើយ ។ ចៅហ៊្វាបែនដែលសុខស្រួលទៅហើយ នៅក្នុងជីវិតរបស់គាត់ ក៏នៅស្ងៀមមិនបានខ្វល់ខ្វាយនឹងអ្វីបន្តិចសោះ ។ ចំណែកស្តេចសៀម ដែលតែងតែប្រកាសខ្លួនថា ជាអ្នកការពាររដ្ឋទាយាទ និងនាម៉ឺនសព្វមុខមន្ត្រី ដែលហាក់ដូចជាមានការភ័យខ្លាចចំពោះការទិតៀនអំពីការគ្រប់គ្រងគួរឲ្យអៀនខ្មាសនេះ ម៉្លោះហើយក៏នៅស្ងៀមដែរទៅ ។ រីឯប្រជាជនទៀតសោត ក៏ហាក់ដូចជាបាត់បង់អស់នូវសេចក្តីក្លាហាន មិនចង់ធ្វើសង្គ្រាម ចង់បានសន្តិភាពវិញម្តង សមនឹងពេលដែលគេទុកឲ្យរស់ទៅតាមតែសម្មាអាជីវៈ ។ ពួកចៅហ្វាយខែត្រកាន់តែឯករាជឡើងៗ ដោយមកពីគ្មានការដឹកនាំ ហើយពេញចិត្តណាស់នឹងសភាពការណ៍បែបនេះ ប្រមូលពន្ធបានរក្សាទុកបង់មកឲ្យនាយករដ្ឋមន្ត្រីតែអ្វីដែលខ្លួនចង់បង់ ជួនកាលមិនទាំងបង់ឲ្យទៀតក៏មាន ។ និយាយដោយខ្លីគឺ ព្រះរាជាណាចក្រពេលនោះកំពុងតែរលួយពុកផុយ បាត់បង់ទៅៗដោយខ្សោះអស់កម្លាំងអ្នកណាចង់ធ្វើយ៉ាងណាក៏បាន ។ ប្រសិនបើកម្ពុជាមិនត្រូវអាណ្តាមចូលមកកាន់កាប់លុកលុយរាតត្បាតវាយដណ្តើមយក រួចកាត់យកដីកូសាំងស៊ីនដាក់ជារបស់គេទេ ពោលគឺថា បើសិនណាជាស្រុកខ្មែរគ្មានពួកអ្នកឈ្លានពានមកពីទិសខាងត្បូង មានតែសត្រូវសៀមតែមួយគត់នោះ ប្រហែលជាសៀមកាត់យកប្រទេសទាំងមូលដាក់ទៅក្នុងស្រុកគេបាត់ទៅហើយ នៅចុងសតវត្សរ៍ទី១៨ ហើយវាសនាកម្ពុជាក៏ដូចជាវាសនាប្រជាជនខ្មែរទាំងមូលក៏ត្រូវចប់បាត់ទៅហើយដែរ ។ ក៏ប៉ុន្តែ អាចនិយាយថាយើងមានសំណាងដែរ ដែលមានសត្រូវ២នាក់នៅសងខាងដែលស្រេកឃ្លានសង្គ្រឹតចង់បានទឹកដីយើងដូចគ្នា ម៉្លោះហើយ ក៏តាមដានត្រួតពិនិត្យ គ្នាទៅវិញទៅមក ។ សត្រូវទាំង២នេះខ្លាចរអាគ្នាទៅវិញទៅមក ចំណែកចំណីដែលស្ថិតនៅកណ្តាលវិញ ភ័យញ័រចំប្រប់ រង់ចាំតែឲ្យអ្នកណាដែលមកមុនហើយលេបបាត់ ។ ប៉ុន្តែសត្រូវម្នាក់ៗស្ទាក់ស្ទើរមិនទាន់ហ៊ានលូកដៃមកប៉ះចំណីនោះទេ ដោយខ្លាចធ្វើឲ្យម្ខាងទៀតភ្ញាក់ដឹងខ្លួន ។ ស្ថានភាពបែបនេះបានរក្សាកម្ពុជា រហូតដល់ពេលដែលពួកបារាំងមកដល់ ជួយប្រទេសនេះកុំឲ្យស្លាប់ មិនតែប៉ុណ្ណោះ បានជួយដាស់ប្រជាជនឲ្យភ្ញាក់ក្រោកឡើងវិញធានាបាននូវឯករាជជាតិ ជួយការពារព្រះរាជា ជួយផ្តល់កម្លាំងឲ្យប្រទេសទាំងមូល ផ្តល់សុភមង្គល ដោយការធានាបាននូវសុខ

សន្តិភាព ពាណិជ្ជកម្ម រួចបន្ទាប់មក ផ្តល់ឲ្យនូវរាជរដ្ឋាភិបាលអចិន្ត្រៃយ៍មួយ សុចរិត មាននាម៉ឺនមន្ត្រីធ្វើការទទួលបាននូវប្រាក់បៀវត្សទៀងទាត់ ម្ល៉ោះហើយមិនបានទិញមុខតំណែងរបស់ខ្លួនទេ ។

ពួកបារាំងទើបតែបានប្រគល់មកឲ្យប្រជាជនខ្មែរវិញនូវទឹកដីដែលសៀមបានកាត់យក តាំងពីមាត់សមុទ្ររហូតទៅដល់ភ្នំដងរែក ទឹកដីទាំងនោះសៀមមិនដែលបានសន្យាថានឹងប្រគល់មកឲ្យខ្មែរវិញម្តងណាទេ តែបានយល់ព្រមប្រគល់ឲ្យបារាំង ។ ដោយហេតុនេះ អតីតកម្ពុជានៃសតវត្សរ៍ទី១៧ អាចរស់រានមានជីវិតឡើងវិញ មានស្តេចសោយរាជ្យ ដោយមានអ្នកចាំជួយការពារខ្លាំងក្លាដែលមិនដែលនឹកគិតចង់លុបបំបាត់ព្រះរាជាណាចក្រនេះទេ ផ្ទុយទៅវិញ មានតែចង់ឲ្យប្រជារាស្ត្រខ្មែររស់នៅមានសេរីភាព នៅក្នុងស្រុកមួយដែលមានការគ្រប់គ្រងល្អ មានអារ្យធម៌ ហើយគ្មានសង្គ្រាមមករំខាន ។

ព្រះរាជាសៀមបានទាមទារឲ្យគេយកសពព្រះអង្គអេងទៅបូជានៅអយុធ្យា ។ ក៏ប៉ុន្តែនៅពេលដែលគេដឹកព្រះសពមកដល់ខែត្រមង្គលបុរី ស្រាប់តែមានបញ្ជាមកថាត្រូវដឹកព្រះសពយកទៅឧត្តុង្គវិញ[៦៥] ហើយឆាប់បញ្ជូនទ័ពទៅជួយវាយពួកភូមា ដែលចូលមកលុកលុយស្រុកសៀម ។ លោកចក្រីកែប បានដឹកនាំទ័ព ៥ពាន់នាក់ចេញទៅភ្លាម ហើយគេនិយាយថា ទ័ពខ្មែរនេះពូកែអស្ចារ្យ បានវាយពួកភូមាឲ្យបរាជ័យ រួចទើបវិលត្រលប់មកកម្ពុជាវិញ ពោរពេញទៅដោយជ័យជម្នះ ។

ទ័ពនេះមកដល់ មិនទាន់រំសាយចេញទេ ស្រាប់តែព្រះរាជាអយុធ្យាផ្ញើបញ្ជាមកចៅហ៊្វាប៉ុក ឲ្យបញ្ជូនទៅជួយស្តេចយ៉ាឡុង ដែលបានស្រែកសុំជំនួយ ។ ទ័ពនោះក៏ចេញដំណើរទៅ ក្រោមបញ្ជាការរបស់ឧកញ៉ា វាំងឡាង ។ ក៏ប៉ុន្តែ ការដែលរដ្ឋាភិបាលមួយគោរពស្តាប់តាមបញ្ជារបស់ស្តេចបរទេស ប្រៀបបានទៅនឹងហ្វូងទាសករបែបនេះ បានធ្វើឲ្យកើតការក្តៅក្រហាយ និងអាម៉ាស់ជាខ្លាំង ក្នុងចំណោមប្រជាជន ។ ម្ល៉ោះហើយកងទ័ពនោះមិនបានទៅណាឆ្ងាយ គឺបានធ្វើដំណើរមកដល់ត្រឹមរំដួល ក៏បែកខ្ញែកគ្នាអស់ទៅ ព្រោះទាហានម្នាក់ៗវិលត្រលប់ទៅរកគ្រួសាររបស់គេ ។ ចៅហ៊្វាប៉ុកបានចេញបញ្ជាឲ្យគេតាមចាប់ទាហានដែលរត់ចោលជួរទាំងអស់នោះយកមកវិញ ហើយធ្វើទោសសម្លាប់ចោល ។ មានទាហានជាច្រើនដែលត្រូវគេអារកសម្លាប់ សេសសល់ប៉ុន្មានគេបញ្ជូនទៅរាជធានីវេ ។ ប្រជាជនរឹតតែមានទោមនស្សខ្លាំងឡើងៗ ។ នៅទីបញ្ចប់ ស្តេចយ៉ាឡុង ទទួលបានជ័យជម្នះលើពួកតៃសឺន ដណ្តើមយកអំណាចបានមកវិញ រួចហើយបានបញ្ជូនកាំភ្លើងធំ ២ដើម មានរំលេចដោយរូបមករ

---

[៦៥] តាមមើលទៅប្រហែលជាគេយកមកបន្ទាយពេជ្រទេ ។ ទោះជាយ៉ាងណាក្តី សពព្រះរាជាបានត្រូវគេបូជានៅពេលដែលទ័ពនាំត្រលប់មកវិញ នៅក្នុងឆ្នាំ១៧២៨ រួចហើយគេបានយកព្រះអដ្ឋិធាតុព្រមទាំងរូបចម្លាក់២ធ្វើអំពីលង្ហិន ទៅបញ្ចុះនៅក្នុងចេតិយមួយដែលគេបានសង់ឡើងពីខាងកើតចេតិយធំ នៅលើខ្នងភ្នំព្រះរាជទ្រព្យក្បែរឧត្តុង្គ ។ ពិធីបុណ្យបូជាព្រះសពនេះមានរយៈកាលពេញមួយឆ្នាំ ។

មកកម្ពុជា កាំភ្លើងនេះបានត្រូវមេទ័ពអាណ្ណាមអុងហ៊ួយកទៅ ក្រោយពីគាត់បានធ្វើឃាតព្រះរាមរាជារួច ។

កងទ័ពខ្មែរដែលទៅច្បាំងនៅអាណ្ណាមនោះល្បីល្បាញខ្លាំងណាស់ រហូតទាល់តែមេទ័ព គឺឧកញ៉ាក្រឡាហោមព្រហ្ម ទៅជាក្រអឺតក្រទម គិតថាខ្លួនបានជួយស្ដេចយ៉ាឡុងឲ្យឡើងគ្រងរាជបល្ល័ង្កវិញបាន ហើយក៏ចាប់មើលងាយមើលថោកចៅហ៊្វាប៉ុក មិនមកចូលរួមប្រជុំគណៈរដ្ឋមន្ត្រីទេ ។ ចៅហ៊្វាប៉ុកបានឲ្យគេចាប់ខ្លួនក្រឡាហោមព្រហ្ម បញ្ជូនទៅថ្វាយស្ដេចសៀមដើម្បីដាក់ទោសទណ្ឌ ។ ព្រះរាជាបាងកកទុកព្រហ្មទុក រួចបានឲ្យហ្លួងពេជ្រណាពិចិត្រមឿងមកជំនួសវិញ ហើយបានទាំងបញ្ជូនអ្នកអង្គម្ចាស់អង្គច័ន្ទមកដែរ ដើម្បីគ្រប់គ្រងប្រទេសជាតិ ។

នៅឆ្នាំ១៨០៥ ក្រោយពីស្ដេចអាណ្ណាមបានបញ្ជូនក្រណាត់សូត្រ៦៨ដុំមកថ្វាយ ព្រះអង្គច័ន្ទ បានយាងនាំយកកំណាត់ទាំងអស់នោះមកបាងកកជាមួយចៅហ៊្វាប៉ុក ដើម្បីចូលគាល់ស្ដេចសៀម ។ ចៅហ៊្វាប៉ុក ក៏ស្លាប់នៅឯបាងកកនោះទៅ ក្នុងអាយុ៦៥ឆ្នាំ ។ គាត់បានថែរក្សារាជបុត្ររបស់ព្រះអង្គអេង និងជារាជានុសិទ្ធ ព្រះរាជាណាចក្រកម្ពុជាអស់ពេល១១ឆ្នាំ ។

## ៤០- ព្រះអង្គច័ន្ទ (១៨០៦-១៨៣៤)

នៅឆ្នាំ១៨០៦ ព្រះអង្គច័ន្ទជារាជបុត្រាច្បងរបស់ព្រះអង្គអេងមានព្រះជន្ម១៥ព្រះវស្សាហើយ ។ ស្ដេចសៀមបានសម្រេចអភិសេកព្រះអង្គឲ្យឡើងគ្រងរាជ្យ ដោយថ្វាយព្រះនាមថាព្រះបាទសម្ដេចព្រះរាជឱង្ការ ព្រះឧទ័យរាជាធិរាជរាមាធិបតីព្រះស្រីសុរិយោពណ៌ ។ នេះគឺជាលើកទី២ហើយ ដែលស្ដេចសៀមបង្ហាញឲ្យឃើញអំពីអធិរាជភាពរបស់គេមកលើកម្ពុជា ។

ព្រះរាជាណាចក្រកម្ពុជាពេលនោះរងនូវការបាក់បែកប្រេះស្រាំខ្លាំងណាស់ មិនប្រកែកប្រណាំងអ្វីទេ យល់ព្រមទទួលព្រះរាជាតាមតែហេតុការណ៍វិវត្ត ។ ពេលនោះចៅហ៊្វាបែនបានធ្វើកិច្ចការមួយដែលនាំគាត់ឲ្យអាចវិលត្រលប់មកកាន់កម្ពុជាវិញបាន ។ គឺគាត់បាននាំយកបុត្រីរបស់គាត់ម្នាក់មកថ្វាយព្រះរាជាអង្គច័ន្ទ ។ ព្រះរាជាប្រហែលជាមិនហ៊ានប្រកែកទេ ទើបទ្រង់យល់ព្រមទទួលយកធ្វើជាមហេសីទៅ ។

នៅពេលនោះស្ដេចអាណ្ណាមក៏ចាប់ប្រឆាំងជំទាស់ ហើយបានបញ្ជូនទ័ពមួយកងមកកាន់ភ្នំពេញ ។ ស្ដេចអាណ្ណាមទទួលយល់ព្រមថាឲ្យសៀមរៀបចំពិធីអភិសេកព្រះរាជាកម្ពុជានៅឯបាងកកចុះ ក៏ប៉ុន្តែបើព្រះរាជាកម្ពុជាយល់ព្រមចំណុះស្ដេចសៀម ព្រះអង្គក៏ត្រូវចំណុះស្ដេចអាណ្ណាមដែរ ហើយត្រូវលើកសួយសារអាករទៅថ្វាយជាទៀងទាត់ ក្នុងនោះមានដំរីឈ្មោលកម្ពស់៥ហត្ថ២ក្បាល ថែរមាស២ ក្អុកដំរីពាគូ ក្រវាញ ក្រមួនឃ្មុំ ម្រ័ក្សណ៍ ។ល ។

ពេលនោះពួកនាម៉ឺនសព្វមុខមន្ត្រីរបស់ព្រះរាជាមិនហ៊ានប្រកែកនឹងសំណើដ៏ប្រមាថនេះទេ មិនដឹងថា

តើកម្ពុជាគួរចំណុះសៀមផង និងចំណុះអាណ្ណាមផង ឬក៏យ៉ាងណា គឺមានអធិរាជ២ដែលនឹងប្រកាប់ប្រចាក់គ្នាដើម្បីមូលហេតុនគរចំណុះ វាល្អជាជាងមានអធិរាជតែមួយ ដែលនឹងលេបត្របាក់យកទឹកដីអស់តែម្តង ។ ម្ល៉ោះហើយពួកគេក៏យល់ព្រមតាម ធ្វើឲ្យទ័ពអាណ្ណាមវិលត្រលប់ទៅសាយហ្គនវិញទៅ តែបានទុកមេទ័ព២នាក់ឲ្យនៅការពារភ្នំពេញ ។ តាមរយៈសន្ធិសញ្ញានេះ ពួកសៀម និងអាណ្ណាមបានមកប្រឈមជួបមុខគ្នានៅកម្ពុជា ហើយនេះមិនមែនដោយសារកាលៈទេសៈចៃដន្យអ្វីទេ គឺដោយមានគោលការណ៍ច្បាស់លាស់ ប្រឆាំងគ្នា តែទទួលស្គាល់ទាំងអស់គ្នា ។ សង្គ្រាមនឹងកើតមានយូរអង្វែង ប៉ុន្តែគឺដើម្បីឲ្យព្រះរាជាណាចក្ររស់រានមានជីវិត ។

ការដែលព្រះរាជាអង្គច័ន្ទ ទទួលស្គាល់អធិរាជភាពរបស់អាណ្ណាម មិនបានធ្វើឲ្យរាជវាំងបាងកក សប្បាយចិត្តប៉ុន្មានទេ ហើយចាប់ពីពេលនោះមកទំនាក់ទំនងល្អ ដែលធ្លាប់តែមានរវាងស្តេចសៀមជាមួយព្រះរាជាឧត្តុង្គក៏ចាប់ផ្តើមប្រេះឆាដែរ ។

និយាយពីស្តេចយ៉ាឡុងវិញ ដើម្បីបញ្ជាក់ឲ្យរឹតតែឃើញច្បាស់អំពីអធិរាជភាពរបស់ព្រះអង្គ ទ្រង់បានស្រមើស្រមៃឃើញរហូតដល់ឲ្យធ្វើត្រារាជបូនជ្រុងស្មើមួយអំពីមាសយ៉ាងធ្ងន់ ផ្ញើមកថ្វាយព្រះអង្គច័ន្ទ (តាមធម្មតា ត្រាខ្មែរមានរាងមូល) ។ ព្រះរាជាកម្ពុជាបានទទួលយកត្រានោះ ហើយពោលសរសើរថា សព្វព្រះរាជហឫទ័យខ្លាំងណាស់ ក៏ប៉ុន្តែទ្រង់មិនដែលបានប្រើវាម្តងណាឡើយ ។

មរណភាពរបស់ចៅហ្វាបែន ស្តេចត្រាញ់ដែនដីបាត់ដំបង រួចបន្តមកទៀតមរណភាពរបស់ស្តេចសៀមនៅក្នុងឆ្នាំ១៨១១ ហើយនិងការលើកបុត្រាព្រះនាមថាភេនឌិនខ្លាងឲ្យឡើងសោយរាជ្យបន្ត មិនបានធ្វើឲ្យស្ថានការណ៍ធូរស្បើយទេ ។ សៀមមិនយល់ព្រមឲ្យកម្ពុជាមានអធិរាជ២ដូច្នេះទេ កម្ពុជាត្រូវចំណុះតែសៀមមួយ គត់ព្រោះថាមានតែសៀមទេដែលបានអភិសេកស្តេចខ្មែរ ។ ការបញ្ជូនអ្នកអង្គម្ចាស់ស្ងួន និងអ្នកអង្គម្ចាស់ឯម ជាព្រះអនុជរបស់ព្រះរាជា ទៅរាជវាំងសៀមជាមួយនឹងក្រឡាហោមមឿងដែលជាជនជាតិសៀមស្រាប់ ហើយនិងចក្រីបែនផង ដើម្បីទៅចូលរួមក្នុងព្រះរាជពិធីឈាបនកិច្ចស្តេចសៀម នៅក្នុងខែមេសា ឆ្នាំ១៨១០ គឺជាការសំដែងឲ្យឃើញអំពីការគោរពក្នុងនាមជានគរចំណុះ បានធ្វើឲ្យកំហឹងរបស់សៀមធូរស្បើយបន្តិច ក៏ប៉ុន្តែមិនបានធ្វើឲ្យវារលត់បាត់ទេ ។ ដើម្បីបង្ហាញឲ្យឃើញនូវសិទ្ធិអធិរាជរបស់ខ្លួនក្នុងការតែងតាំងព្រះរាជា និងរាជវង្សានុវង្ស ស្តេចសៀមបានប្រកាសតែងតាំងយ៉ាងឱឡារិកឲ្យអ្នកអង្គម្ចាស់ទាំង២អង្គ ឡើងជាទីឧភយោរាជ និងជាឧបរាជ ដោយមិនបានសាកសួរយោបល់ព្រះរាជាកម្ពុជាផងទេ ។

នៅសម័យនោះ គេដោះមឿង ចៅហ្វាយខែត្រដីកំពង់ស្វាយ មានបំណងចង់បំផុសអ្នកស្រុកក្នុងខែត្រឲ្យបះបោរប្រឆាំងនឹងព្រះរាជាឡើង ។ នៅបាត់ដំបងឯណោះវិញ ចៅហ្វាយខែត្រថ្មីដែលបានយកឈ្មោះថា បែន ដូចជាឪពុកខ្លួនដែរ បានចាប់ផ្តើមកសាងកំពែងការពារទីក្រុង ។ និយាយពីក្រឡាហោមមឿង និងឧកញ៉ាចក្រី បែន នៅពេលវិលត្រលប់មកដល់រាជធានីឧត្តុង្គវិញក៏ត្រូវចោទថាជាភ្នាក់ងាររបស់សៀម និងបានឃុបឃិតឲ្យ

សៀមតែងតាំងអ្នកអង្គម្ចាស់ទាំង២អង្គ ។ សភាពការណ៍ពេលនោះបានបង្ហាញថាពិតជាមានការរួមគំនិតក្បត់មែន ហើយគំរាមកំហែងមកលើព្រះរាជា ។ ប៉ុន្តែព្រះបាទអង្គច័ន្ទមិនបានប្រហែសបន្តិចណាទេ ទ្រង់បានចេញព្រះរាជបញ្ជាឲ្យឃាត់ខ្លួនលោកក្រឡាហោម និងលោកចក្រី ដែលស្ថិតនៅក្នុងដៃព្រះអង្គស្រាប់ រួចឲ្យគេសម្លាប់ចោល ។បន្ទាប់មក ទ្រង់បានតែងតាំងខុកញ៉ាវង្សាអគ្គរាជឲ្យឡើងធ្វើជាចៅហ្វាយខែត្រកំពង់ស្វាយ រួចបញ្ជូនទៅកាន់ទីនោះ ហើយឲ្យចាប់គេដោះមឿង ។ ប៉ុន្តែមន្ត្រីម្នាក់នេះឆ្លាតនៅពេលបានដឹងថា បក្សពួករបស់ខ្លួនទាំង២នាក់បានត្រូវគេធ្វើឃាតទៅហើយ និងបំផុសបំផុលប្រជាជនក្នុងខែត្រ ឲ្យបះបោរមិនបានសម្រេច គាត់ក៏គេចខ្លួនរត់ទៅជ្រកកោននៅឯស្រុកសៀមទៅ ។ នៅបាត់ដំបងឯណោះវិញ ចៅហ្វាយខែត្រថ្មីរឹតតែខិតខំពង្រឹងការការពារបន្ថែមទៀត ។

ស្តេចសៀមកាន់ជើងពួកបះបោរ ហើយបានបញ្ជូនទ័ពមួយកងមកបាត់ដំបង ។ ការដែលសៀមធ្វើដូច្នេះនាំឲ្យគេមានជំនឿថា ការរួមគំនិតក្បត់បានចាប់ផ្តើមឡើងនៅឯបាងកកមែន ដោយមានការគាំទ្រពីស្តេចសៀមផង ។ ព្រះរាជាកម្ពុជាបានកេណ្ឌទ័ពជាប្រញាប់ រួចបានចាត់ឲ្យយកមួយកងទៅបោះទីតាំងនៅនឹងពាមសែនត្រង់មាត់ពាមស្ទឹងកំពង់ធំ និងកំពង់ស្វាយ ។ ទ័ពមួយកងទៀត ទ្រង់ឲ្យទៅនៅកំពង់ឆ្នាំង ឯកងទី៣ ទ្រង់ឲ្យទៅបោះទីតាំងនៅស្ទឹងពាក់កន្តិល ។ ក្នុងពេលជាមួយគ្នានោះ ព្រះអង្គច័ន្ទទ្រង់បានចាត់មន្ត្រី ២នាក់ ឲ្យទៅសុំជំនួយពីស្តេចអាណ្ណាម ។

ស្តេចយ៉ាឡុង គ្រេកអរណាស់នឹងបានចូលមកធ្វើអន្តរាគមន៍ម្តងទៀតនៅកម្ពុជា ហើយបានចាត់បញ្ជូនទ័ពអាណ្ណាមមួយកងពីសាយហ្គនមក ដែលដឹកនាំដោយឧត្តមសេនីយ៍៥នាក់ ។ ទ័ពអាណ្ណាមនេះធ្វើដំណើរតាមទន្លេឡើងមកយ៉ាងរួសរាន់ មកដល់ភ្នំពេញមិនបានឈប់ទេ ក៏បន្តដំណើរទៅបោះទីតាំងចាប់ពីត្រឹមព្រែកមានលាភ (ពីមុនហៅថាព្រែកពាក់ព្រ័ត្រ) នៅលើកោះជ្រោយចង្វារ រហូតដល់កោះចិន ចំពីមុខកំពង់ហ្លួង រួចហើយក៏នាំគ្នាសម្រាកដោយស្ងៀមស្ងាត់ រង់ចាំតែបញ្ជានឹងអាលចេញប្រយុទ្ធ តែមិនសូវជាចង់ប៉ុន្មានទេ ។ គ្មានទ័ពណាបានមកវាយទៅលើទ័ពអាណ្ណាមនេះទេ រហូតដល់ពេលដែលទ័ពសៀមត្រូវបានគេវាយឲ្យបរាជ័យ ហើយរត់ទៅកាន់ស្រុកសៀមវិញអស់ទៅ ទ័ពជំនួយរបស់អាណ្ណាមនេះក៏ដកថយចេញទៅវិញដែរ ដោយគ្មានបានបាញ់កាំភ្លើងមួយគ្រាប់ណាសោះទេ ។

ដោយសព្វព្រះទ័យខ្លាំងណាស់ និងជ័យជម្នះលើកនេះ ព្រះអង្គច័ន្ទ និងព្រះអនុជទាំង៣អង្គ បានយាងចូលសាងព្រះផ្នួសនៅវត្តភ្នំព្រះរាជទ្រព្យ នៅជិតឧត្តុង្គ បានប៉ុន្មានសប្តាហ៍ ទ្រង់ក៏លាព្រះផ្នួសចាកសិក្ខាបទមកវិញ ។

រាជពង្សាវតារបានរៀបរាប់ថា នៅសម័យនោះ នាវាព័រទុយហ្គេមានបង្គោលក្តោង៣ បានមកចូលចតនៅនឹងកំពង់ពោធិតូច (កំពង់ហ្លួង) ហើយមន្ត្រីម្នាក់ដែលកាន់សាសនាកាតូលិកបានទិញរបស់របរមកពីអឺរ៉ុប ពីនាយកប៉ាល់ យកទៅថ្វាយព្រះរាជា ដោយដោះដូរជាមួយផលិតផលរបស់កម្ពុជា (ខែមេសា ឆ្នាំ១៨១១) ។

រាជពង្សាវតារក៏បានកត់សម្គាល់អំពីព្រឹត្តិការណ៍មួយចំនួនទៀតផងដែរ មានការបះបោររបស់មនុស្សម្នាក់មានឈ្មោះថា សីលជ័យ ដែលត្រូវគេដាក់ទោសសម្លាប់បង់, ការបកប្រែសៀវភៅដកស្រង់អត្ថបទគម្ពីរព្រះត្រៃបិដកមកជាភាសាសាមញ្ញ ដោយគណៈកម្មការចៅអធិការវត្ត ដែលប្រមូលផ្តុំគ្នាធ្វើការនៅវត្តភ្នំព្រះរាជទ្រព្យ, ការចូលទិវង្គតរបស់អ្នកអង្គម្ចាស់ព្រះអង្គកែវខ្លួង ដែលមានព្រះជន្ម៨២ព្រះវស្សា, ហើយនិងការឃើញមានផ្កាយដុះកន្ទុយលេចចេញនៅទិសខាងលិច[៦៦] ។

ខ្យល់ព្យុះដែលប្រមូលផ្តុំគ្នាបន្តិចម្តងៗមកនៅពីលើស្រុកខ្មែរ បានផ្ទុះខ្លាំងឡើងនៅពេលដែលព្រះរាជា អង្គច័ន្ទ ប្រព្រឹត្តកំហុសឆ្គងមួយ ។ បញ្ហាបានកើតឡើងរវាងព្រះអង្គជាមួយនឹងព្រះអង្គស្ងួន ដែលស្តេចសៀមថ្មីបានតែងតាំងជាទីឧភយោរាជ ។ ដោយមានការភ័យខ្លាច ព្រះអង្គស្ងួនបានរត់ភៀសព្រះកាយទៅគង់នៅពោធិសាត់ជាមួយព្រះរាជវង្សានុវង្ស និងភីលៀងសេនាទាំងអស់ ដែលនៅចម្ងាយតែ ៥០គីឡូម៉ែត្រប៉ុណ្ណោះពីដីបាត់-ដំបង ។ ព្រះរាជាបានបញ្ជូនព្រះសង្ឃ២អង្គ រួចមន្ត្រី៤នាក់ទៀត ឲ្យទៅយាងព្រះអង្គត្រលប់មកបន្ទាយពេជ្រវិញ ប៉ុន្តែព្រះអង្គស្ងួនមិនយល់ព្រមត្រលប់ទៅវិញទេ ។ មិនតែប៉ុណ្ណោះ ទ្រង់បានចាប់មន្ត្រីទាំង៤នាក់នោះទុកធ្វើជាចំណាប់ខ្មាំងថែមទៀត រួចចាប់ប្រមែប្រមូលទ័ព និងអាវុធយុទ្ធភណ្ឌ ទាមទារឲ្យព្រះរាជាប្រគល់បណ្តាខេត្តក្រុងក្រគរ និងខ្លុងថ្វាយ ។

ព្រះរាជាអង្គច័ន្ទ មានព្រះតម្រិះថា ព្រះឧភយោរាជបានត្រូវស្តេចសៀមតែងតាំងឡើង ស្តេចសៀមនឹងគាំទ្រព្រះឧភយោរាជ រួមទាំងប្រជារាស្ត្រខែត្រពោធិសាត់ ដែលធ្លាប់អបអរសាទរព្រះអង្គផង ។ ឆ្លើយតបទៅនឹងសភាពការណ៍នេះ ព្រះអង្គច័ន្ទ បានស្នើសុំជំនួយពីស្តេចយ៉ាឡុង ។ ឧត្តមសេនីយ៍អាណ្ណាមឈ្មោះ អុងជរអ៊ីងឌិញលឿង ដែលបញ្ជារនៅសាយហ្គន ហើយជាតំណាងស្តេចយ៉ាឡុងប្រចាំនៅកូសាំងស៊ីន បានបញ្ជូនទ័ព៥រយនាក់ឲ្យមកឈរជើងនៅនឹងកោះចិន នៅក្នុងទន្លេសាប ទល់មុខនឹងកំពង់ហ្លួង ។ កម្លាំងទ័ពប៉ុននេះ មិនគ្រប់គ្រាន់ទេ អាចប្រៀបបានត្រឹមកងនគរបាល ដែលគេប្រើសម្រាប់តែទប់ទល់កុំឲ្យមានការលួចពង្រត់ព្រះរាជាប៉ុណ្ណោះ ។ ក៏ប៉ុន្តែ

---

[៦៦] ផ្កាយដុះកន្ទុយនេះមានឈ្មោះថា ហាឡី គេមើលឃើញគ្រប់គ្នានៅលើសកលលោក ។ នៅស្រុកបារាំង ផ្កាយដុះកន្ទុយនេះបានធ្វើ ឲ្យគេដាក់ឈ្មោះស្រាទំពាំងបាយជូរ ដែលផលិតនៅក្នុងឆ្នាំ១៨១១ ថាជា ស្រាផ្កាយដុះកន្ទុយ ។ ផ្កាយដុះកន្ទុយដដែលនេះបានបង្ហាញខ្លួនម្តងទៀតនៅក្នុងឆ្នាំ១៩១០ មានពណ៌ស្អាតល្អណាស់ ហើយបានធ្វើឲ្យមានការរំជើបរំជួលក្នុងបណ្តាអ្នកតារាសាស្ត្រទាំងឡាយនាសម័យនោះ ព្រោះគេមានជំនឿថាពិភពលោកអាចនឹងត្រូវបញ្ចប់នៅក្នុងឆ្នាំនោះ ។ គេបានឃើញផ្កាយដុះកន្ទុយនេះលើកដំបូងនៅក្នុងឆ្នាំ១៤៥៦ នៅពេលដែលពួកមូស្លីមចូលកាន់កាប់ទីក្រុងបែលក្រាដ ។ ការលេចចេញនូវផ្កាយដុះកន្ទុយនេះនៅពេលនោះបានធ្វើឲ្យទ័ពទាំងសងខាង មានការភិតភ័យ ហើយសម្តេចប៉ាបកាលីសទី៣បានសម្រេចថា ចាប់ពីពេលនោះមក គេត្រូវសូត្រធម៌អង់ហ្សេលុសរាល់ថ្ងៃ នៅពេលថ្ងៃត្រង់ ។

បើទោះជាយ៉ាងនេះក្តី ក៏ព្រះរាជាកម្ពុជាបានរៀបចំទទួលស្វាគមន៍ ទ័ពនេះយ៉ាងសមរម្យ បង្ហាញឲ្យឃើញថា នៅពេលដែលមានការគំរាមកំហែងពីពួកបះបោរ ព្រះអង្គសព្វព្រះទ័យនឹងហៅរកព្រះរាជាអាណ្ណាមឲ្យមកជួយ ជាជាងរត់ទៅរកស្តេចសៀម ហើយទ្រង់ទុកចិត្តអាណ្ណាម ជាងទុកចិត្តសៀម ។

ស្តេចសៀមបានសម្រេចចិត្តធ្វើអន្តរាគមន៍ម្តង ។ ទ្រង់បានបញ្ជូនទ័ព២កង មួយកងៗមានគ្នា ៥ពាន់នាក់ ដែលមួយកងដឹកនាំដោយលោកយមរាជ មួយកងទៀតដឹកនាំដោយពុហុល្វាទេព ។ ព្រះរាជាកម្ពុជា បានបញ្ចេញទ័ព២កងតូចទប់ទល់ មួយកងៗមានគ្នា១ពាន់នាក់ ហើយនិងទ័ពជើងទឹកមួយកងដែលដឹកនាំ ដោយស្តេចត្រាញ់ខែត្របាភ្នំ ។ ក៏ប៉ុន្តែទ័ពតូចៗទាំងអស់នេះមិនអាចទប់ទល់ជាមួយនឹងទ័ពសត្រូវដែលច្រើនជាង៥ដងបានឡើយ ម៉្លោះហើយក៏នាំគ្នាដកថយ មិនហ៊ានប្រយុទ្ធទេ ។ នៅពេលដែលព្រះរាជាទទួលបានដំណឹងថា ព្រះឧភយោរាជ កំពុងដឹកនាំទ័ពខ្មែរ៣ពាន់នាក់ និងទ័ពសៀម២ពាន់នាក់ ធ្វើដំណើរមកកាន់រាជធានីឧត្តុង្គ ទ្រង់ក៏ភៀសព្រះកាយចេញពីរាជធានីទៅជាមួយនឹងព្រះរាជវង្សានុវង្ស ក្រោមកិច្ចការពាររបស់ទ័ពអាណ្ណាម ទៅគង់នៅឯកោះដីនៅក្នុងទន្លេមេគង្គ នៅខាងក្រោមភ្នំពេញបន្តិច ។

នៅពេលដែលព្រះរាជាកំពុងតែយាងចុះតាមទន្លេ ទ័ពរបស់ព្រះអង្គបានបើកការវាយប្រហារទៅលើទ័ពសៀមនៅកំពង់ឆ្នាំង តែត្រូវបរាជ័យ ក៏រត់ចុះទៅទិសខាងត្បូង ដោយនាំប្រជាជនយកទៅផង ដើម្បីកុំឲ្យសៀមកៀរ ។ ពេលទទួលបាននូវពត៌មានស្តីអំពីបរាជ័យនេះ ព្រះឧបរាជអង្គឯម និងអ្នកអង្គម្ចាស់អង្គឌួង បាននាំគ្នាបោះបង់ព្រះរាជាជាព្រះរៀម ហើយរត់ត្រលប់ក្រោយមកកាន់ឧត្តុង្គវិញ ដែលទ័ពសៀមកំពុងតែកាន់កាប់ ។ ការបោះបង់ចោលដោយព្រះអនុជទាំង២ បានធ្វើឲ្យព្រះរាជាអង្គច័ន្ទអស់សង្ឃឹមជាខ្លាំង ទើបបណ្តោយខ្លួនព្រះអង្គតាមតែពួកអាណ្ណាម ដែលបន្ទាប់មកបាននាំព្រះអង្គទៅកាន់សាយហ្គន ។

ពេលនេះ ព្រះរាជាណាចក្រត្រូវគ្មានអ្នកដឹកនាំម្តងទៀតហើយ ព្រោះព្រះរាជាគង់នៅឯស្រុកអាណ្ណាម ចំណែកឯអ្នកអង្គម្ចាស់បះបោរមួយអង្គគឺព្រះឧភយោរាជ ក៏មិនទាន់ហ៊ានចាប់កាន់អំណាចនៅឡើយដែរ ហើយគង់នៅឯពោធិសាត់ឯណោះ ។ ព្រះឧបរាជអង្គឯម និងព្រះអង្គឌួងក៏រៀបចំរដ្ឋាភិបាលបណ្តោះអាសន្នមួយឡើង ដែលមានពាក់កណ្តាលជាខ្មែរ និងពាក់កណ្តាលទៀតជាសៀម រួចហើយបាននាំគ្នាយាងទៅបាងកកនៅក្នុងខែកក្កដា ឆ្នាំ១៨១១ ដើម្បីសុំយោបល់ឯកភាពពីស្តេចសៀម ។

បន្តិចក្រោយមកព្រះរាជាអង្គច័ន្ទមានសេចក្តីក្លាហានឡើងវិញ បានដឹកនាំទ័ព២ម៉ឺននាក់ចូលមកក្នុងរាជធានីឧត្តុង្គ ក្នុងនោះមានទ័ពអាណ្ណាម៥ពាន់នាក់ និងទ័ពខ្មែរដែលគាំទ្រតាមដង្ហែព្រះអង្គ ។ ប្រជារាស្ត្រទាំងអស់ស្វាគមន៍អបអរទទួលព្រះអង្គ ហើយព្រះរាជាបានយាងចូលក្នុងព្រះរាជវាំងនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៨១៣ ។ ទ័ពសៀមមានការភ្ញាក់ផ្អើលជាខ្លាំងនឹងការយាងត្រលប់មកវិញយ៉ាងរហ័សរបស់ព្រះរាជាបែបនេះណាមួយបានឮសំឡេងប្រជាជនទះដៃអបអរសាទរអឺងកងផង អ្នកស្រុកស្រែចម្ការក៏ដកដៃចេញពីខ្លួនអស់ទៅផង ឯនាម៉ឺនសព្វ

មុខមន្ត្រីក៏បាននាំគ្នាធ្វើដំណើរទៅកាន់រាជធានីខត្តុក្ត ដើម្បីចូលគាល់ព្រះរាជាផង ទ័ពសៀមទាំងនោះគិតថា នគរទាំងមូលនឹងបះបោរប្រឆាំងនឹងខ្លួនជាមិនខាន ម្ល៉ោះហើយក៏ប្រញាប់ប្រញាប់ ឆាប់នាំគ្នាធ្វើដំណើរទៅកាន់ព្រំដែនជាបន្ទាន់ ។ ប៉ុន្មានខែក្រោយមក ព្រះឧភយោរាជអង្គស្ងួនសុគតនៅបាងកកនោះ ។ សៀមបានបញ្ជូនព្រះអដ្ឋិធាតុរបស់ព្រះអង្គ មកថ្វាយព្រះអង្គច័ន្ទនៅក្នុងឆ្នាំ១៨២៤ ។

ការដែលពួកអាណ្ណាម បានជួយលើកព្រះអង្គច័ន្ទ ឲ្យយាងមកគង់លើរាជសម្បត្តិវិញ នៅពេលនេះហាក់ដូចជាបានប្រព្រឹត្តទៅដោយគ្មានការបង្ហូរឈាមសោះឡើយ អ្វីៗហាក់ដូចជាវិលត្រលប់មករកភាពស្ងប់ស្ងាត់វិញ ហើយស្រាប់តែចៅហ្វាយខែត្រកំពង់ស្វាយឈ្មោះ ម៉េង ដែលជាអ្នកចូលរួមសមគំនិតជាមួយនឹងព្រះអង្គឯម និងព្រះអង្គឌួង បានចាប់ផ្តើមបំផុសបំផុលអ្នកស្រុកឲ្យបះបោរឡើង ដើម្បីទាក់ទាញឲ្យមានអន្តរាគមន៍ពីសៀមសាជាថ្មី និងឲ្យគាត់ទទួលបានសិទ្ធិអំណាចដូចមិត្តចាស់របស់គាត់នៅឯបាត់ដំបង គឺបែនកាលពីមុនអ៊ីចឹង ។ ម៉េងបានបញ្ចុះបញ្ចូលប្អូនគាត់ដែលជាចៅហ្វាយខែត្របារាយណ៍ឲ្យដើរតាមគាត់ រួចចាប់ផ្តើមជ្រើសរើសទ័ព ស្រាប់តែព្រះរាជាបានចាត់ទ័ពមួយកងតូចឲ្យទៅកំពង់ស្វាយ ដើម្បីទប់កុំឲ្យការបះបោររីករាលដាល ។ ម៉េង និងប្អូនប្រុសមិនអាចទប់ទល់នឹងទ័ពព្រះរាជា ព្រោះមិនទាន់រើសទ័ពបាន ក៏នាំគ្នារត់ទៅជ្រកកោននៅក្នុងខែត្រទន្លេរពៅ[៦៧] ។ បន្តិចក្រោយមក ដោយភ័យខ្លាចអ្នកស្រុកចាប់យកមកប្រគល់ឲ្យព្រះរាជា អ្នកទាំង២ បាននាំគ្នារត់ឆ្លងទៅនៅឯខោនវិញ ។ ទឹកដីខោននេះ ខ្មែរមិនដែលប្រគល់ឲ្យទៅលាវម្តងណាទេ ក៏ប៉ុន្តែ បានគោរពស្តាប់បញ្ជារបស់ចៅនៅបាសាក់[៦៨] តាំងតែពី៧៥ឆ្នាំមុនមកម៉្លេះ ។

ម៉េងបានចេញដំណើរបន្តពីនោះទៅកាន់បាងកក ហើយបានញុះញង់ឲ្យស្តេចសៀមដណ្តើមយកដីកំពង់ស្វាយ ។ សៀមបានរៀបចំប្រតិបត្តិការមួយ វាយដណ្តើមយកកំពង់ស្វាយ និងបន្ទាយការពារ ដែលចៅហ្វាយខែត្របានបោះបង់ដោយកំសាក ក៏ប៉ុន្តែពួកសៀមត្រូវបង្ខំចិត្តបោះបង់ចោលទៅវិញ ក្រោយពីមានការខូចខាតច្រើនពេក ។

នៅក្នុងឆ្នាំ១៨១៤ ទ័ពសៀមបានលេចមុខនៅកូរ៉ាត់ រួចហើយបានដណ្តើមយកទឹកដីទាំងអស់ ដែលស្ថិតនៅចន្លោះខែត្រព្រហ្មទេព និងភ្នំដងរែក ហើយក៏បានយកខែត្រម្លូព្រៃ និងទន្លេរពៅផងដែរ ដែលស្ថិតនៅក្នុង

---

[៦៧] ខែត្រនេះសព្វថ្ងៃជាទឹកដីរបស់កម្ពុជាវិញហើយ ហើយស្ថិតនៅលើត្រើយទន្លេមេគង្គខាងឆ្វេង នៅខាងជើងខែត្រម្លូព្រៃ និងខាងត្បូងខែត្រគង់របស់លាវ ។

[៦៨] ចាប់តាំងពីឆ្នាំ១៧១៥មក ដីបាសាក់នៅចំណុះវៀងច័ន្ទនៅឡើយ ក៏ប៉ុន្តែបានពង្រីកឯករាជភាពល្អគ្រាន់បើហើយ ។ ពេលនោះហ្លួងប្រាបាងបានផ្តាច់ខ្លួនចេញផុតពីការគ្រប់គ្រងរបស់វៀងច័ន្ទដែរ ។ សៀមមិនបានជំទាស់ទេ នៅពេលដែលស្តេចបាសាក់ប្រកាសខ្លួនជាព្រះរាជា ។

ដីកំពង់ស្វាយ ក៏ប៉ុន្តែនៅឆ្ងាយពីរាជធានីខត្តុក្កខ្លាំងពេក ជាហេតុធ្វើឲ្យព្រះរាជាមិនសូវបានយកព្រះទ័យទុកដាក់ ។ ដណ្ដើមយកទឹកដីទាំងអស់នោះបានដោយស្រួលរួចហើយ ទ័ពសៀមបានឆ្លងទន្លេទៅដណ្ដើមយកស្ទឹងត្រែង ដាក់បញ្ចូលទៅក្នុងព្រះរាជាណាចក្រសៀម ថែមទៀត[៦៩] ។ គឺនៅស្ទឹងត្រែងនេះឯងដែលព្រះរាជាលង្វែកមួយអង្គ បានរត់មកជ្រកកោន នៅចុងសតវត្សរ៍ទី១៦ ក្រោយពីសៀមចូលលុកលុយ ។

ព្រះរាជាកម្ពុជាពេលនោះមិនបានប្រកែកតវ៉ាប្រឆាំងអ្វីទេ បណ្ដោយឲ្យសៀមធ្វើតាមតែចិត្តចង់ ម៉្លោះហើយ កម្ពុជាក៏ត្រូវកាត់ផ្ដាច់លែងមានព្រំប្រទល់ដែនជាប់ជាមួយប្រទេសលាវទៀតហើយ ព្រោះមានទឹកដី ដែលក្លាយទៅជារបស់សៀមនៅចន្លោះកណ្ដាល ។ នៅក្នុងឆ្នាំ១៨១៥កម្ពុជា និងសៀមបានចុះសន្ធិសញ្ញាសន្តិភាពមួយ ក៏ប៉ុន្តែគេមិនបាននិយាយអំពីទឹកដីដែលសៀមទើបតែយកទៅនេះទេ ។ ទឹកដីនេះបានក្លាយទៅជារបស់សៀម ក៏ប៉ុន្តែបើគេគិតតាមផ្លូវទូតវិញ គ្មានលក្ខណៈអ្វីឲ្យច្បាស់លាស់ទេ ដូចតែដីបាត់ដំបង និងអង្គរ ដែលយើងបានឃើញពីខាងលើរួចមកហើយ ។

គឺនៅសម័យនោះឯង ដែលគេបានជីកព្រែកជីកវិញ តេរាជពង្សាវតារកម្ពុជានិយាយថានៅក្នុងឆ្នាំ១៨១៥, រាជពង្សាវតារអាណ្ណាមនិយាយថាក្នុងឆ្នាំ១៨១៦ តែសៀវភៅមួយមានឈ្មោះថា «យ៉ាឌិញអុងជី» = ប្រវត្តិដីកូសាំងស៊ីនថា នៅក្នុងឆ្នាំ១៨២០[៧០] ។ ព្រែកនេះគេជីកចេញពីស្ទឹងវិញតេ តម្រង់ទៅរកដៃសមុទ្រហាទៀង ។ កម្លាំងចូលរួមមានទាំងអស់១ម៉ឺននាក់ គឺអាណ្ណាម៥ពាន់នាក់ និងខ្មែរ៥ពាន់នាក់ ជីកព្រែកប្រវែងទាំងអស់ ៥៣ គីឡូម៉ែត្រ ទទឹង ៣៣ម៉ែត្រ ជម្រៅ ២ម៉ែត្រ៦០ ។ ពលកម្នាក់ៗទទួលបានប្រាក់៧ហ្វ្រង់ និងអង្ករ ៣០ គីឡូក្រាម ក្នុង១ខែៗ ។ មានវិស្វករអាណ្ណាម៣នាក់ដឹកនាំការងារនេះ ក៏ប៉ុន្តែពួកពលករមានមេកោយផ្ទាល់ ជាជាតិសាសន៍រៀងៗខ្លួន ។ ស្ដេចនគរទាំង២ គឺស្ដេចយ៉ាឡុង និងព្រះបាទអង្គច័ន្ទ បានឯកភាពគ្នាឲ្យគេជីកព្រែកនេះឡើង ដែលតភ្ជាប់ទន្លេមេគង្គទៅនឹងឈូងសមុទ្រសៀម ក៏ប៉ុន្តែប្រជាជនខ្មែរបានចាត់ទុកកំណែននេះថា ជាការជិះជាន់មួយ ហើយនិងជាការអន់ខ្សោយរបស់ព្រះរាជាកម្ពុជានៅចំពោះមុខស្ដេចអាណ្ណាម ព្រោះជីកព្រែកនៅក្នុងទឹកដីខ្មែរ ។ អ្នកស្រុកនៅក្នុងខេត្រពាម, បន្ទាយមាស, ទ្រាំង និងព្រែកប្បាស នៅចងចាំអំពីកំណែននេះនៅឡើយ បើទោះបីថាកម្រៃដែលគេបានទទួលនៅពេលនោះសមរម្យហើយក៏ដោយ ០,២៣ហ្វ្រង់ (សម្រាប់អង្ករ១ថ្ងៃ) ។ នៅពេលដែលអាជ្ញាធរបារាំងស្នើសុំពលករឲ្យចូលរួមជួយលើកផ្លូវជាតិ ដោយបើកកម្រៃឲ្យច្រើនជាង៤ដង គេតែងតែព្

[៦៩] ខេត្រស្ទឹងត្រែងបានក្លាយទៅជាខេត្រលាវ-បារាំងនៅក្នុងឆ្នាំ១៨៩៤ ក្រោយពេលដែលត្រើយខាងឆ្វេងរបស់ទន្លេមេគង្គ បានត្រូវកាត់បញ្ចូលមក ។ បារាំងបានបង្វិលមកឲ្យកម្ពុជាវិញហើយ នៅក្នុងឆ្នាំ១៩០៤ ។

[៧០] គេចាប់ផ្ដើមជីកនៅក្នុងឆ្នាំ១៨១៥-១៨១៦ ក្នុងខែមិគសិរ ហើយជីកចប់នៅក្នុងខែមករា ។

អ្នកស្រុកត្អូញត្អែរពីសម័យជីកព្រែកនោះ ដែលត្រូវគេបង្ខំឲ្យធ្វើការពេញមួយរដូវ "ជីកព្រែកឲ្យយួន" ។

អ្វីដែលធ្វើឲ្យខ្មែររឹតតែខឹងខ្លាំងឡើងថែមទៀតនោះ គឺនៅក្រោយពេលជីកព្រែកនេះរួច ពួកអាណ្ណាម បានកាត់យកដីទាំងអស់ដែលស្ថិតនៅខាងត្បូងព្រែក ចាត់ទុកព្រែកនោះថាជាព្រំដែននគរទាំង២ ។ មិនតែប៉ុណ្ណោះ អាណ្ណាមបានបង្កើតប៉ុស្តិ៍គយនៅលើត្រើយខាងស្តាំទន្លេមេគង្គ ត្រង់កន្លែងច្រកចូលទៅក្នុងព្រែក នៅកោះក្តាក និងនៅពាមជរ ថែមទៀត ។

នៅពេលដែលខ្មែរ និងអាណ្ណាមកំពុងតែព្រួតដៃគ្នាជីកព្រែកវិញគេខាងនិរតីប្រទេស នៅខាងជើងប្រទេស ឯណោះវិញមានពួកបះបោរ១ក្រុម បានលេចមុខឡើងនៅក្នុងខេត្រកំពង់ស្វាយ ។

ខកញ៉ាតេជោ ចៅហ្វាយខេត្រកំពង់ស្វាយបានរួសរាន់កេណ្ឌទ័ពបានមួយកងតូច ដើម្បីទប់ទល់នឹងពួកបះបោរ ក៏ប៉ុន្តែមិនអាចទប់បាន ក៏វាយដកថយមកវិញ ក្រោយពីជំនួយការរបស់ចៅហ្វាយខេត្រត្រូវសត្រូវសម្លាប់បាន ។ ខកញ៉ាតេជោបានដឹកនាំទ័ពគេចទៅកំពង់លែង នៅក្នុងខែមីនា ឆ្នាំ១៨១៦ ជាមួយនឹងចៅហ្វាយខេត្រព្រៃក្តី ជាខេត្រតូចមួយនៅលើស្ទឹងសែន ។ ព្រះរាជាខ្វល់ជាខ្លាំងនឹងខកញ៉ាតេជោ ដែលមិនបំពេញភារកិច្ចឲ្យបានត្រឹមត្រូវ ទ្រង់ក៏ដាក់ខកញ៉ានរិន្ទសេនាម៉ាជំនួសវិញ ។ ខកញ៉ានរិន្ទសេនាបានកេណ្ឌទ័ពមួយកងភ្លាម ហើយបានវាយទៅលើពួកបះបោរ ធ្វើឲ្យពួកនោះបរាជ័យនៅក្នុងខែឧសភា ឆ្នាំ១៨១៦ ។

ព្រះរាជាកម្ពុជាពេលនោះទ្រង់ហាក់ដូចជាបានខិតខំប្រឹងប្រែង ធ្វើយ៉ាងណាឲ្យមានភាពស្មើគ្នារវាងប្រទេសជាអ្នកការពារទាំង២ ។ យ៉ាងណាមិញ ទ្រង់បានចាត់បញ្ជូនឲ្យទៅតាមកំពត និងតាមសំពៅ នូវសាច់ប្រាក់ចំនួន ២០០ឆ្នាំង ទៅថ្វាយស្តេចសៀម ហើយក៏បានចាត់មន្ត្រី២រូបឲ្យនាំក្រមួន ២ហាប, ក្រវាញ ១ហាប, ម្រ័ក្សណ៍ ១ហាប, ស្ពាន់ធ័រ ១ហាប, ដង្កោ ១ហាប, ភ្លុកដំរី ២ហាប និងស្នែងខ្ទី ២គូ ទៅថ្វាយស្តេចអាណ្ណាមដែរ ។

នៅក្នុងអំឡុងឆ្នាំ១៨១៦នោះដែរ មានរឿងធំមួយកើតឡើង គឺកូនចៅម្នាក់របស់ពួកព័រទុយហ្គេ ដែលមករស់នៅកម្ពុជាកាលពីប៉ុន្មានសតវត្សរ៍មុន បានទទួលការប្រោសប្រណីពីព្រះរាជា ដែលតែងតាំងឲ្យឡើង ជាខកញ៉ាក្រឡាហោម គឺរដ្ឋមន្ត្រីទ័ពជើងទឹក ។ ជននោះមាននាមត្រកូលថាម៉ុងតេរ៉ូ ហើយមានឈ្មោះផ្ទាល់ខ្លួនថា បែន និងមានឋានៈជាព្រះរាជពិភេក គឺគ្រូពេទ្យសម្រាប់ព្រះរាជា ។ ជននេះជាកូនកាត់ទេ ក៏ប៉ុន្តែគេចាត់ទុកគាត់ថា ជាជនអឺរ៉ុប ។ ព្រះរាជាបានចាត់ទុកគាត់ថាជាអ្នកបម្រើស្មោះត្រង់ម្នាក់ ក៏ប៉ុន្តែពួកសហសេវិកទាំងឡាយ ស្អប់គាត់ដោយព្រោះតែគាត់ជាប់ខ្សែស្រឡាយអឺរ៉ុប ហើយគាត់ឆ្លាតវាងវៃជាងគេ ម្ល៉ោះហើយក៏រករឿងចោទប្រកាន់គាត់ថាគៃបន្លំ សាហាវ មានបទឧក្រិដ្ឋ១០យ៉ាង ។ ព្រះរាជាបានសម្រេចឲ្យគេនាំយកគាត់ទៅតុលាការ ។ តុលាការបានរកទៅឃើញថា គាត់មានកំហុសដោយសារគាត់បានយកប្រាក់ពីអ្នកដែលគាត់បានរកបុណ្យសក្តិឲ្យ បានលាក់ខ្ញុំរបស់គេដែលរត់មកជ្រកកោននឹងគាត់ ផ្ទុយទៅនឹងច្បាប់ព្រះនគរដែលកំណត់ថា ត្រូវតែប្រគល់ទៅឲ្យម្ចាស់ដើមវិញ បើពុំនោះទេម្ចាស់ថ្មីត្រូវទិញខ្ញុំនោះពីម្ចាស់ដើម បានប្រព្រឹត្តកាមគុណជាមួយប្រពន្ធ ប្តុសហាយរបស់អ្នកដទៃ

ដែលគាត់បានទាក់ទាញឲ្យមកផ្ទះគាត់ ជួនកាលគាត់យករហូតតែម្ដង និងកាត់សេចក្ដីទៅតាមតែលាភសក្ការៈដែលបានទទួល ។ បែនម៉ុងតេរ៉ូ បានសារភាពទទួលស្គាល់កំហុសរបស់ខ្លួន ក៏ប៉ុន្តែដល់ស្អែកឡើង គាត់គេចខ្លួនបាត់ ។ គេបានតាមចាប់គាត់មកវិញ ហើយព្រះរាជាបានសម្រេចកាត់ទោសគាត់ឲ្យគេសម្លាប់ដោយកាត់ក្បាល ។ ចំណែកកូនប្រុសរបស់គាត់ដែលបានរៀបចំការរត់គេចរបស់គាត់ ព្រះរាជាបានលើកលែងទោសកំហុសឲ្យ ដោយទ្រង់គិតថាគ្នាប្រព្រឹត្តដូច្នេះក៏ដោយសារតែ ដើម្បីតបស្នងសងគុណឪពុកប៉ុណ្ណោះ ។

ព្រះអង្គច័ន្ទមានព្រះរាជបំណងចង់ឲ្យការផ្ដល់យុត្តិធម៌របស់ព្រះអង្គត្រូវបានអនុវត្តពេញលេញ ម្ល៉ោះហើយ ទ្រង់បានដាក់ទណ្ឌកម្មលើអ្នកដែលបានចូលដៃចូលជើងជាមួយ បែនម៉ុងតេរ៉ូ ទាំងអស់ ទោះបីជាអ្នកទាំងអស់នោះជាអ្នកនៅក្រោមបញ្ជារបស់បែនក៏ដោយ ។ ក្រឡាបញ្ជីរ័ត្ន និងក្រឡាបញ្ជីនូត្រូវវាយ៥០រំពាត់រួចហើយ ត្រូវចាត់ទុកជាខ្ញុំរាជការដូចជាពួកអ្នកថែទាំសេះអ៊ីចឹង ។ អ្នករួមគំនិតឯទៀតៗត្រូវដាក់ទណ្ឌកម្មផ្សេងៗ រួមទាំងមន្ត្រីអ្នកយាមគុកផង ដែលបានធ្វើឲ្យអ្នកទោសរត់រួច ។ ពួករាជការណាដែលបានទិញបុណ្យសក្តិ ត្រូវបញ្ចុះឋានៈ ទម្លាក់ឲ្យមកជារាស្ត្រសាមញ្ញ ហើយទ្រព្យសម្បត្តិទាំងអស់ត្រូវរឹបអូស[៧១] ។

នៅក្នុងឆ្នាំ១៨១៧ រាជការបានកំណត់យកពន្ធស្រូវ ៥ថាំងលើស្រូវ៥០ថាំង ដំបូង រួចបានសម្រេចថាតទៅអនាគត ពន្ធនេះនឹងត្រូវគិតរហូតដល់ចំនួនកូនចៅ និងខ្ញុំកំដរ ដែលស្ថិតនៅក្នុងបន្ទុកគ្រួសារថែមទៀត ។ ម្ល៉ោះហើយ ព្រះរាជាបានចេញព្រះរាជបញ្ជាឲ្យគេធ្វើសម្រង់ចំនួនប្រជាជន មានរៀបរាប់អំពីឈ្មោះមេគ្រួសារ ប្រពន្ធ កូន ចៅ និងខ្ញុំកំដរ ដោយបញ្ជាក់ច្បាស់អំពីភេទ និងអាយុផងដែរ ។

នៅក្នុងឆ្នាំនោះ ក្រោយពីមានភាពរាំងស្ងួតខ្លាំងរួចមក មានទឹកជំនន់មួយយ៉ាងធំប្លែកពីសព្វដង ធ្វើឲ្យផលស្រូវថយចុះ ម្យ៉ាងដោយសារប្រជាជនមិនអាចភ្ជួររាស់ដីបានទាន់ពេល ម្យ៉ាងទៀតដោយសារសំណាបសន្ទូង ត្រូវទឹកលិចបាត់អស់ ។ ផ្ទះជាច្រើនត្រូវទឹកជំនន់ហូរនាំយកទៅបាត់ សត្វពាហណៈក៏លង់ទឹកស្លាប់ច្រើន សត្វធាតុរត់ទៅជ្រកនៅឯដីខ្ពង់រាបខ្ពស់ៗអស់ ។ អ្នកស្រុកត្រូវនាំគ្រួសារ និងគោក្របីទៅរកទីខ្ពស់ដែរ ។ ពេលនោះ មានការចាប់ជិះរត់មនុស្ស និងលួចគោក្របីជាច្រើន ។ បន្ទាយល្វាឯម ដែលពួកអាណ្ណាមបានសាងសង់ឡើង ត្រូវបំផ្លាញខ្ទេចអស់ ហើយទឹកលិចព្រះរាជវាំងកម្ពស់២ហត្ថកន្លះ ។ ទុរ្ភិក្សរាលដាលពាសពេញនគរ ព្រោះស្រូវលិចទឹកខូចគ្មានសល់ ស្រូវ ១ថាំង តម្លៃ ៥ បាត គឺប្រហែលជា ៤៧ក្រាមប្រាក់សុទ្ធ ស្មើនឹង ១០ហ្វ្រង់ ។ មានកើតចោរដើរកាប់សម្លាប់លួចប្លន់ជាច្រើន ណាមួយមានអាសន្នរោគ ជំងឺសត្វ និងអុត ពាសពេញប្រទេសទៀតផង ។

នៅដំណាច់ឆ្នាំ មេទ័ពអាណ្ណាមត្រូវផ្លាស់ចេញ ព្រះរាជាបានជូនដំណើររហូតទៅដល់សាយហ្គន ដើម្បីបាន

[៧១] មានកូនចៅរបស់ បែនម៉ុងតេរ៉ូ ម្នាក់ ឈ្មោះថា កុលដឺម៉ុងតេរ៉ូ ដែលបានស្លាប់នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩០៨ ក្នុងឋានៈជាអគ្គមហាសេនា គឺនាយករដ្ឋមន្ត្រី ។

ចូលសំដែងការគួរសមចំពោះលោកសេនាប្រមុខដែលឈរជើងនៅទីនោះផង ។ ប៉ុន្មានខែក្រោយមក បន្ទាប់ពីបានសំដែងការគោរពក្នុងឋានៈជានគរចំណុះដល់អាណ្ណាមរួចហើយ ព្រះរាជាបានចាត់មន្ត្រីជាន់ខ្ពស់ ២នាក់ឲ្យចុះសំពៅតាមកំពតទៅចូលរួមព្រះរាជពិធីបូជាសពព្រះឧបរាជសៀម ។ នេះជាការសំដែងឲ្យឃើញនូវការទទួលស្គាល់ភាពជាចំណុះស្តេចបាងកក ។

នៅឆ្នាំ១៨១៨ អ្នកកាន់សីលម្នាក់នៅបាភ្នំ ឈ្មោះថា កែ កើតជំងឺឡប់សតិហើយប្រកាសថាខ្លួនជាអ្នកមានបុណ្យ បានកេណ្ឌទ័ពសម្លាប់ខុកញ៉ោតេដោម៉ុនជាចៅហ្វាយខែត្រចោល ហើយទាក់ទាញមន្ត្រី៣នាក់ ដែលមិនសប្បាយចិត្តឲ្យចូលដៃជាមួយ ចាប់ផ្តើមកាប់សម្លាប់ពួកអាណ្ណាមយ៉ាងរន្ធាល ។ ដើម្បីការពារជនរួមជាតិរបស់គេ មេទ័ព អាណ្ណាម២នាក់គឺអុងតាក្វាន (ឡេវ៉ាន់យៀត) និងអុងចាន់ដូវ បានដឹកនាំទ័ព៥ពាន់នាក់ មកបោះទីតាំងនៅកោះសូទិន ក្នុងខែត្រកំពង់ចាម ។ ពេលនោះព្រះរាជាកម្ពុជាបានបញ្ជូនចៅហ្វ៊ាទួនផា ឲ្យដឹកនាំទ័ព ២ពាន់នាក់ទៅវាយពួកបះបោរដែរ ។ ទ័ពទាំង២កងបានបើកការវាយប្រហារទៅលើទ័ពបះបោរ ដែលមានចំនួនតិចជាង មិនអាចទប់ទល់បាន ហើយឡោមព័ទ្ធចាប់ កែ សម្លាប់ចោលទៅ ។ ពួកមន្ត្រី៣រូបដែលមិនសប្បាយចិត្ត ហើយចូលដៃចូលជើងជាមួយពួកក្បត់ ត្រូវចាប់បានជាឈ្លើយ ហើយបញ្ជូនទៅឲ្យមេទ័ពអាណ្ណាមនៅឯបេនញែ (សាយហ្គន) ។ ក្រោយពីសាកសួរចម្លើយរួច មេទ័ពអាណ្ណាមក៏បញ្ជូនអ្នកទាំង៣នាក់មកថ្វាយព្រះរាជាកម្ពុជាវិញ ។ ព្រះអង្គបានចេញព្រះរាជបញ្ជាឲ្យសម្លាប់ចោលទៅ ។

ដប់ឆ្នាំក្រោយមក គឺនៅក្នុងឆ្នាំ១៨២៩ ស្តេចសៀមបានបញ្ជូនចៅឃុនបឌិន[៧២] ឲ្យទៅធ្វើសង្គ្រាមជាមួយស្តេចលាវ ដណ្តើមយករាជធានីវៀងច័ន្ទបាន ។ ចៅឃុនបឌិនចាប់ស្តេចលាវបានជាឈ្លើយ ហើយនាំយកមកបាងកក ដាក់ឲ្យប្រជាជនស្តីដេវរួចធ្វើឃាតចោលទៅ ។ សៀមដុតបំផ្លាញរាជធានីវៀងច័ន្ទខ្ទេចខ្ទី ហើយបានកៀរអ្នកស្រុកយកមកដាក់នៅលើត្រើយទន្លេមេគង្គខាងស្តាំ រួចបែងចែកឲ្យទៅរស់នៅតាមខែត្រផ្សេងៗ ។ គេត្រូវរង់ចាំរហូតដល់ពេលដែលពួកបារាំងបានមកត្រួតត្រាលើប្រទេសលាវ ទើបរាជធានីនេះត្រូវបានគេកែលម្អ កាប់ព្រៃឈើចេញ យកធ្វើជារាជធានីរបស់លាវឡើងវិញ ។ សព្វថ្ងៃនេះមានវ៉េស៊ីជង់ធំបារាំងម្នាក់រស់នៅទីនោះ ។

ក្រោយពីបានធ្វើសង្គ្រាមបំផ្លិចបំផ្លាញលាវ គម្ពីរក្បួនច្បាប់ និងអារ្យធម៌របស់ប្រជាជនលាវ ឲ្យវិលធ្លាក់ចូលទៅក្នុងសភាពព្រៃផ្សៃដូចកាលពី ៦-៧សតវត្សរ៍មុនរួចមក ព្រះរាជាបាងកកបានចូលមកលុកលុយកម្ពុជាតាមសំណើរបស់ចៅហ្វាយខែត្រពោធិសាត់ ដែលទើបតែនាំអ្នកស្រុករបស់ខ្លួនចំនួន ២ភាគ៣ ទៅរស់នៅឯស្រុក

---

[៧២] ចៅឃុនបឌិន នេះ ស្លាប់នៅបាងកកក្នុងអាយុ៧៧ឆ្នាំ នៅក្នុងឆ្នាំ១៨៤៧ ឬ១៨៤៨ ។ អ្នកខ្លះគិតថា គាត់នេះមានសញ្ជាតិបារាំង ក៏ប៉ុន្តែតាមពិត គាត់ជាជនជាតិសៀមទេ ។

សៀម ដោយមិនទាំងបានប្រកាសសង្គ្រាមផងទេ ។ សៀមធ្វើយ៉ាងនេះ គឺដើម្បីកុំឲ្យអាណ្ណាមមានអធិរាជភាពមកលើកម្ពុជាខ្លាំងពេក ។

ការពើបប្រយុទ្ធដំបូងបានផ្ទុះឡើងនៅកំពង់ឆ្នាំង ពេលដែលពួកសៀមបានទៅដល់ក្រោយពីឆ្លងកាត់បាត់ដំបង និងពោធិសាត់រួច ។ ពេលនោះព្រះរាជាកម្ពុជាមិនទាន់កេណ្ឌទ័ពបាននៅឡើយ ។ ទ័ពខ្មែរត្រូវបរាជ័យ ហើយមេទ័ពលោកឧកញ៉ាចក្រីភិតភ័យជាខ្លាំង រត់រហូតទៅដល់ខែត្រព្រៃកប្បាស នៅខាងត្បូងឯណោះ ។

ព្រះរាជាដែលគង់នៅភ្នំពេញ បាននាំព្រះរាជវង្សានុវង្ស រត់គេចព្រះអង្គទៅនៅឯលង់ហោ (វិញឡុង) ។ មួយថ្ងៃបន្ទាប់ពីព្រះរាជាយាងចេញដំណើរផុត ទ័ពសៀម៤កងចូលមកដល់ខត្តក្ន រួចបន្តដំណើរមកដល់ភ្នំពេញប៉ុន្មានថ្ងៃក្រោយមក ជាមួយនឹងព្រះអនុជរបស់ព្រះរាជាទាំង២អង្គ គឺព្រះឧបរាជអង្គឯម និងព្រះអង្គឌួង ។ ទ័ពទាំង៤កងនេះបញ្ជាដោយអគ្គបញ្ជាការចៅឃុនបឌិន ជាវីរបុរសដែលទើបតែបានវាយកម្ទេចរាជធានីវៀងច័ន្ទ និងអតីតចៅហ្វាយខែត្រពោធិសាត់ឈ្មោះ កា ។ មកដល់ភ្នំពេញបានប៉ុន្មានថ្ងៃ ពួកនេះបានបន្តដំណើរទៅវាយយកចូវដុក នៅនឹងមាត់ពាមព្រែកវិញតេ ដើម្បីធានារក្សាឲ្យបានទំនាក់ទំនងជាមួយឈូងសមុទ្រសៀម ដែលមានទ័ពមួយកងត្រូវចេញដំណើរមក ។ ទ័ពជើងទឹកនេះបានមកចុះចតនៅហាទៀង វាយដណ្តើមយកទីក្រុងនេះបានដោយគ្មានការប្រយុទ្ធហើយទុកទ័ពមួយកងឲ្យនៅថែរក្សា រួចក៏បន្តដំណើរទៅជួបជាមួយបឌិន នៅឯចូវដុក ។ ចៅឃុនបឌិន ក៏សម្រេចធ្វើដំណើរចុះទៅវិញឡុងដែលព្រះរាជាគង់នៅ ហើយវាយយកបាននៅក្នុងខែធ្នូ ឆ្នាំ១៨៣១ ។

នៅពេលនោះ នៅតាមបណ្តាខែត្រភាគខាងកើតវិញ លោកចក្រី ឡុង និងលោកយមរាជ ហ៊ូ បានរៀបចំទ័ពបំពាក់អាវុធយ៉ាងរហ័ស រួចវាយកងទ័ពសៀមមួយកងឲ្យបរាជ័យនៅក្នុងខែត្រព្រៃវែង ។ ក្រុមអ្នកក្លាហានខ្មែរផ្សេងៗទៀត បានប្រមែប្រមូលគ្នីគ្នា រៀបចំជាកងទ័ពដែរ ហើយវាយឆ្មក់មកលើទ័ពសៀម ដែលដើរពាសពេញប្រទេសរាល់ថ្ងៃ ។ មេទ័ពសៀមទទួលបានដំណឹងនេះជាហូរហែ ក៏សម្រេចចិត្តធ្វើការប្រយុទ្ធដោយគ្មានអែអង់ ។ ការដណ្តើមយកវិញឡុងបានជាជ័យជម្នះដ៏អស្ចារ្យមួយ ធ្វើឲ្យអ្នកស្រុកខ្លាចរអាលែងហ៊ានបះបោរប្រឆាំង និងទទួលស្គាល់សៀមថា ជាអ្នកមករំដោះទៅវិញ ។ ក៏ប៉ុន្តែជាគ្រោះចង្រៃ ទ័ពជើកទឹករបស់បឌិនបានត្រូវវាយឲ្យបរាជ័យ ហើយបំផ្លិចអស់ទាំងស្រុង រហូតដល់មេទ័ពសៀមនេះគ្មានសល់កម្លាំង នឹងបន្តការប្រយុទ្ធទប់ទល់ពួកអាណ្ណាម ដែលមកដល់តាមជើងគោកផង និងជើងទឹកផង ហើយខ្លាំងក្លាព្រោះមានវិន័យ និងរៀបចំដោយនាយទាហានបារាំងដែលទើបតែចូលបម្រើស្តេចយ៉ាឡុង មានជាអាទិលោកវរសេនីយ៍ទោ ឡូវ៉ង់បារីស៊ី ។ ចៅឃុនបឌិនបានវិលត្រលប់ចូលទៅស្រុកសៀមវិញ ក្រោយពីបានដុតកម្ទេចភ្នំពេញចោល ព្រោះអ្នកស្រុកមិនព្រមទៅតាម ។ ចំណែកទ័ពដែលសេសសល់ បាននាំគ្នាទៅចុះសំពៅនៅហាទៀង កំពត រួចត្រលប់ទៅបាងកក តាមសមុទ្រអស់ទៅ ។

ព្រះឧបរាជអង្គឯម និងអ្នកអង្គម្ចាស់អង្គឌួង ដែលគង់នៅឯភ្នំពេញ ក៏យាងចុះទូកចេញដំណើរទៅតាមទ័ព

សៀមដែរ ហើយមិនបានឈប់សម្រាកនៅនឹងខត្តុង្គទេ ព្រោះអ្នកស្រុកមិនអបអរស្វាគមន៍ ដូច្នេះទ្រង់ក៏ធ្វើដំណើរ រហូតមកដល់បាត់ដំបង ។ តាមផ្លូវ ទ្រង់បានចាប់បង្ខំទុកទាំងអស់ដែលបានជួប និងអ្នកស្រុក ដែលរស់នៅតាមមាត់ប្រាំងទន្លេ ឲ្យចូលរួមដំណើរទៅជាមួយ ។ ក៏ប៉ុន្តែនៅពេលពួកអ្នកស្រុក មានចំនួនកាន់តែច្រើនឡើងៗ ពួកនោះក៏នាំគ្នាបះបោរឡើង រើបម្រះវិលត្រលប់មកភូមិស្រុកវិញអស់ ។

ពេលអស់ទ័ពសៀម អាណ្ណាមបានក្លាយជាម្ចាស់កម្ពុជាម្តងទៀត ។ ស្តេចអាណ្ណាមបានបញ្ជូនទ័ព ១ម៉ឺន ៥ពាន់នាក់មកកម្ពុជា ហើយដើម្បីបង្ហាញឲ្យឃើញពីឆន្ទៈយុត្តិធម៌របស់ព្រះអង្គ ព្រះអង្គបានយកប្រាក់ចំនួន ១៨១ណែនមកថ្វាយព្រះរាជាកម្ពុជា ជាសំណងថ្លៃដំរីចំនួន៨៨ក្បាលដែលមេទ័ពអាណ្ណាមម្នាក់បានចាប់យកទៅ ដោយមិនមានព្រះរាជបញ្ជាផងទេ ។ តាមពិតទៅតម្លៃសំណងនេះមិនជាច្រើនប៉ុន្មានទេគឺតែ១៣០ ហ្វ្រង់សម្រាប់ដំរីមួយក្បាលប៉ុណ្ណោះ ។ ក៏ប៉ុន្តែស្តេចអាណ្ណាមធ្វើយ៉ាងនេះគឺចង់បង្ហាញឲ្យឃើញថា ទ្រង់មិនរំលោភបំពានទេ ហើយជានយោបាយ ផងដែរ ។ បន្ទាប់មក ស្តេចអាណ្ណាមបានធ្វើគ្រាប់តាមព្រះចៅអធិរាជចិន និងពួកម៉ុងហ្គោល ដោយទ្រង់បានផ្ញើសម្លៀកបំពាក់បែបអាណ្ណាម មានរួមទាំងមួកផង មកថ្វាយព្រះរាជាកម្ពុជាជាជំនូន ។ ថ្ងៃស្អែកឡើង ព្រះរាជាកម្ពុជាបានគ្រងព្រះពស្ត្រានេះយាងចូលមកភ្នំពេញ ធ្វើឲ្យនាម៉ឺនសព្វមុខមន្ត្រីមួយចំនួនមានការអាម៉ាសជាខ្លាំង ។ ក៏ប៉ុន្តែក៏នៅមាននាម៉ឺនខ្លះដែលស្លៀកពាក់តាមព្រះអង្គដែរ ដើម្បីអែបអបផង និងដោយភ័យខ្លាចផង ព្រោះពួកគេក៏បានទទួលសម្លៀកបំពាក់នេះពីស្តេចអាណ្ណាមដូចគ្នា ។ ម្តងនេះ គេឃើញច្បាស់ថា ពួកអាណ្ណាមមានប្រៀបខ្លាំងជាងពួកសៀមប្រាកដណាស់ ។

ក្រោយពីបានលើកព្រះរាជាកម្ពុជាឲ្យឡើងគ្រងរាជបល្ល័ង្កវិញរួចហើយ ពួកអាណ្ណាមក៏នាំគ្នាដកថយចេញទៅកូសាំងស៊ីនវិញអស់ទៅ ដោយមានជំនឿជឿជាក់ថា ម្តងនេះពួកសៀមលែងហ៊ានមកតវ៉ាដណ្តើមសិទ្ធិត្រួតត្រាលើស្រុកខ្មែរទៀតហើយ ព្រោះថាពួកគេបានវាយសៀមឲ្យបរាជ័យ និងបានលើកព្រះរាជា ដែលសៀមទម្លាក់ពីរាជសម្បត្តិឲ្យឡើងសោយរាជ្យវិញ ។

ក៏ប៉ុន្តែមានមូលហេតុមួយផ្សេងទៀត ដែលបង្ខំស្តេចអាណ្ណាមមិញម៉ាងឲ្យហៅទ័ពត្រលប់ទៅកូសាំងស៊ីនវិញ គឺដើម្បីវាយបង្ក្រាបពួកបះបោរ ដែលចង់បំបែកកូសាំងស៊ីនចេញពីអាណ្ណាម ។ ពួកនោះបានគ្រប់គ្រងលើសាយហ្គន ហើយថែមទាំងបានស្រែកហៅរកជំនួយពីសៀម ទៀតផង ។ ទ័ពសៀមបានចូលលុកលុយកម្ពុជាហើយបង្ខំឲ្យព្រះរាជាគេចព្រះអង្គទៅគង់នៅឯវិញឡុងម្តងទៀត ។

ពេលនោះស្តេចអាណ្ណាមបានកោះហៅមេទ័ពដែលនៅប្រចាំការនៅភ្នំពេញ ឈ្មោះ អុងបាវហូ ដែលទ្រង់សង្ស័យថាបានចូលដៃចូលជើងជាមួយមេរបស់ពួកបះបោរឈ្មោះ អុងគាម៉ា ឲ្យវិលត្រលប់ទៅរាជធានីវៃវិញ ។ ក៏ប៉ុន្តែអុងបាវហូមិនបានគោរពតាមព្រះរាជបញ្ជានេះទេ បែរជារត់គេចខ្លួនទៅស្រុកសៀមទៅវិញ ។ ស្តេចអាណ្ណាមបានផ្លាស់ អុងជួយ ឲ្យមកជំនួស អុងបាវហូ ។

ទ័ពស្តេចអាណ្ណាមបានវាយដណ្តើមយកសាយហ្គុនបានមកវិញ ក្រោយពីបានឡោមព័ទ្ធអស់ពេល ៨ខែ និងធ្វើការប្រយុទ្ធជាច្រើនលើកច្រើនសា ។ ចៅហ្វាយក្រុងឈ្មោះ អុងផូវខ្វៃ ត្រូវគេសម្លាប់បាន ធ្វើឲ្យគ្នាគាត់ឈ្មោះ អុងដុងដុក (ចៅហ្វាយស្រុកមាត់ជ្រូកចូវដុក) រត់គេចចូលមកក្នុងកម្ពុជា ។ ព្រះរាជាបានឲ្យគាត់ទៅពួននៅឯពាមជីកង នៅត្រើយទន្លេធំខាងឆ្វេង ក្រោមកំពង់ចាមបន្តិច ។

នៅឆ្នាំបន្ទាប់ ពេលដែលព្រះរាជាអង្គច័ន្ទសុគតដោយរោគរាកមួលនៅលើព្រះទីនាំងនាវា ដែលចតនៅកោះពោធិព្រះបាទ ពួកអាណ្ណាមគិតឃើញថា ព្រះរាជាណាចក្រកម្ពុជាពេលនេះច្បាស់ជាត្រូវធ្លាក់ក្នុងដៃស្តេចមិញម៉ាង[៧៣] ដែលបានឡើងសោយរាជ្យបន្តពីស្តេចយ៉ាឡុងតាំងតែពីឆ្នាំ១៨១១មក មែនទែនហើយ ។ គោរពតាមបញ្ជារបស់ស្តេចមិញម៉ាង អុងខាំម៉ាងបានកោះប្រជុំនាម៉ឺនសព្វមុខមន្ត្រី រដ្ឋមន្ត្រី ព្រះសង្ឃរាជ និងពួកបារគូផង ដើម្បីធ្វើការជ្រើសរើសព្រះរាជាថ្មីមួយព្រះអង្គ ។ ការជ្រើសរើសព្រះរាជាថ្មីនេះ គេមិនបានឲ្យដំណឹងទៅស្តេចសៀម ជ្រាបផងទេ ។

ព្រះបាទអង្គច័ន្ទ គ្មានព្រះរាជបុត្រាទេ បុត្រាមួយព្រះអង្គដែលប្រសូត្រនៅឯខត្តុង្គបានសុគតទៅតែប៉ុន្មានម៉ោងប៉ុណ្ណោះក្រោយពីប្រសូត្ររួច ។ និយាយអំពីព្រះអនុជរបស់ព្រះអង្គ មានព្រះឧបរាជអង្គឯម អ្នកអង្គម្ចាស់អង្គឌួង និងអង្គស្ងួនវិញ ពួកអាណ្ណាមមិនយល់ព្រមឲ្យឡើងសោយរាជ្យទេ ព្រោះអ្នកទាំង ២ខាងដើម បានប្រយុទ្ធប្រឆាំងនឹងព្រះរាជា ចូលដៃជាមួយសៀម និងទៅរស់នៅស្រុកសៀម ។ ដូច្នេះ គ្មានអ្នកស្នងរាជ្យជាបុរសទេ ។ ក្រុមប្រឹក្សាមិនយល់ព្រមប្រគល់ព្រះរាជបល្ល័ង្កទៅឲ្យព្រះរាជបុត្រីច្បងរបស់ ព្រះអង្គច័ន្ទព្រះនាមបែនឡើយ ព្រោះព្រះនាងត្រូវជាចៅរបស់ចៅហ៊្វាបែន ដែលបានលើកកូនស្រីថ្វាយព្រះរាជា ក្រោយពីបានប្រគល់ដីបាត់ដំបងឲ្យទៅសៀមរួច ណាមួយព្រះនាងប្រឆាំងនឹងអាណ្ណាមខ្លាំងណាស់ទៀត ។ គេបានឯកភាពគ្នាលើកព្រះអង្គម្ចាស់ក្សត្រីអង្គម៉ីឲ្យឡើងសោយរាជ្យវិញ ។

## ៨១- ព្រះក្សត្រីអង្គម៉ី (១៨៣៨-១៨៤១)

ព្រះក្សត្រីអង្គម៉ី[៧៤] ជាបុត្រីរបស់ព្រះរាជាអង្គច័ន្ទជាមួយព្រះជាយាលំដាប់ទី៣ មានឈ្មោះថា អ្នកម្នាងក្រចាន់ ពេលនោះទ្រង់មានព្រះជន្ម២១ព្រះវស្សាហើយ ។ ព្រះអនុជក្សត្រីរបស់ព្រះនាង ព្រះនាមថាព្រះអង្គម្ចាស់ពៅ ត្រូវបានលើកឲ្យឡើងធ្វើជាព្រះឧបរាជ ដែលតាំងតែពីពេលណាមកមិនដែលមាននារីទទួលនូវឋានៈនេះទេ ។ ព្រះក្សត្រីស្ងួន ដែលតូចជាងគេ បានគង់នៅជាមួយព្រះរៀមទាំង២អង្គ ហើយទទួលឋានៈជាព្រះកែវហ៊្វា ។

---

[៧៣] ស្តេចនេះមានព្រះជន្ម៤៨ឆ្នាំ ហើយបានសោយរាជ្យ១៨ឆ្នាំហើយ ។

[៧៤] ពួកអាណ្ណាមថ្វាយព្រះឋានៈថា បាកុងជួ មានន័យថា ព្រះក្សត្រីជាម្ចាស់ជីវិត តែខ្មែរយើងសរសេរ បាគុនចាវ ទៅវិញ ។

ប្រជាជនហាក់ដូចជាមិនមានការភ្ញាក់ផ្អើលអ្វីទេ ចំពោះការដែលគេជ្រើសរើសព្រះក្សត្រីមួយអង្គ ឲ្យឡើងគង់លើរាជបល្ល័ង្កដូច្នេះ ពីព្រោះថាថ្វីបើកន្លងមកគេមិនដែលឃើញមានព្រះមហាក្សត្រីសោយរាជសម្បត្តិក៏ដោយ ក៏ប៉ុន្តែគេធ្លាប់ប្រទះឃើញព្រះរាជាដាក់រាជសម្បត្តិថ្វាយព្រះអគ្គមហេសី ឬព្រះមាតាជាញឹកញយដែរ ដើម្បីទ្រង់អាចយាងចូលសាងព្រះផ្នួសបាន ។ ម្ល៉ោះហើយប្រជាជនហាក់ដូចជាត្រូវបង្ខឹកបង្ហាត់ឲ្យចេះទទួលយកសភាពការណ៍នេះ ជាបណ្តើរៗមកហើយ ។ ក៏ប៉ុន្តែមានអ្នកខ្លះបានអះអាងប្រកបទៅដោយមូលហេតុត្រឹមត្រូវថា ការជ្រើសរើសយកក្សត្រីមួយអង្គឲ្យឡើងសោយរាជ្យដូច្នេះត្រូវចាត់ទុកជាមោឃៈ ពីព្រោះថា បើតាមទំនៀមពីបុរាណដែលកន្លងមកគ្មាននរណាម្នាក់ ចាប់អារម្មណ៍ដល់ គឺថាប្រសិនណាបើគ្មានរជ្ជទាយាទជាបុរស ដើម្បីបន្តវេនពីព្រះរាជាទេ រដ្ឋមន្ត្រី និងអ្នកមុខអ្នកការទាំងអស់ត្រូវជ្រើសរើសព្រះរាជាចេញពីក្នុងចំណោមមេក្រុមបារគូ ។ អ្នកខ្លះទៀតនិយាយថា ទំនៀមពីបុរាណនោះមិនមែននិយាយថា "គ្មានរជ្ជទាយាទបុរស" នោះទេ តែថា "ក្នុងករណីដែលគ្មានរាជវង្សានុវង្សបន្តវេន" តែម្តង ។ ឥឡូវនេះ គេនៅមានសល់អ្នកអង្គម្ចាស់ក្នុងរាជវង្សានុវង្សនៅឡើយ ដូច្នេះមិនអាចនិយាយថាគ្មានរាជវង្សានុវង្សបន្តវេនបានទេ ។ ពួកមន្ត្រីធំៗមួយចំនួនបានប្រជុំគ្នាជាសម្ងាត់នៅលើកំពូលភ្នំព្រះរាជទ្រព្យ ពិភាក្សារឿងនេះ ហើយមានមន្ត្រីម្នាក់ហ៊ានរហូតដល់និយាយថា «បើគេរើសក្សត្រាមួយអង្គមិនបានទេការជ្រើសតាំងនេះត្រូវចាត់ទុកជាមោឃៈ ។ បើសិនជារើសបានក្សត្រាមួយអង្គ ក៏ប៉ុន្តែប្រជារាស្ត្រនិងព្រះរាជាសៀមមិនទទួលស្គាល់ នោះយើងនឹងមានសង្គ្រាម ។ ប៉ុន្តែបើសិនណាជាគេរើសបានក្សត្រីមួយអង្គ ហើយបើសិនជាស្តេចសៀមមិនធ្វើអន្តរាគមន៍ទេ នោះវាសនាស្រុកខ្មែរនឹងត្រូវចប់ ព្រោះច្បាស់ជាអាណ្ណាមកាត់បញ្ចូលធ្វើជាទឹកដីរបស់គេ ជាសម្រេចតែម្តង» ។ ព្រះសង្ឃមួយអង្គបានស្នើឡើងថា យើងគួរនាំគ្នាធ្វើដំណើរទៅស្រុកសៀម ។ ក៏ប៉ុន្តែ អ្នកដែលមានគំនិតទាំងអស់នេះ មិនបានត្រូវគេអញ្ជើញឲ្យចូលរួមក្នុងការជ្រើសរើសព្រះរាជាផងទេ ។ ចំណែកឯប្រជាជនវិញ គេអស់កម្លាំងនឿយណាយនឹងសង្គ្រាម និងចង់បានសន្តិភាពណាស់ តែមិនបានគិតដល់ថា ព្រះមហាក្សត្រីនឹងគ្មានឥទ្ធិពល ហើយក៏មិនបានដឹងថាមេទ័ពអាណ្ណាម អុងទ្រួនគុន ដែលនៅពីខាងក្រោយព្រះនាង មានអំណាចខ្លាំងណាស់ អាចនឹងបញ្ជាលើរាល់រដ្ឋមន្ត្រីបាន ។ ដោយពិនិត្យឃើញថា ព្រះមហាក្សត្រីទន់ខ្សោយ ហើយចំណុះអាណ្ណាមខ្លាំងពេក មានពាក្យចចាមអារ៉ាមលេចឡើងក្នុងចំណោមបក្សពួកអ្នកអង្គម្ចាស់ និងសៀម សាយភាយទៅដល់ក្នុងស្រទាប់ប្រជាជនថា ព្រះនាងបានសហាយជាមួយមេទ័ពអាណ្ណាម ។ រឿងនេះមិនពិតទេ ក៏ប៉ុន្តែការនិយាយបង្ខូចព្រះកិត្តិនាមបានរីករាលសាយភាយទប់លែងបាន រហូតទាល់តែព្រះមហាក្សត្រីធ្លាក់ខ្លួនទៅជាមនុស្សឆ្កួត[៧៥] ។

---

[៧៥] ព្រះនាងសុគតនៅខត្តុង្គ នៅរវាងឆ្នាំ១៨៧៨ ។

ឥឡូវនេះអ្វីៗបានសំដែងចេញឲ្យឃើញច្បាស់ណាស់ថា អាណ្ណាមប្រុងប្រៀបនឹងយកកម្ពុជាធ្វើជាទឹកដីរបស់គេមែនទែនហើយ ហើយការដែលគេរៀបចំព្រះមហាក្សត្រីអង្គមី ឲ្យឡើងគ្រងរាជបល្ល័ង្កនេះ គឺគ្រាន់តែដើម្បីទម្លាប់ប្រជាជនឲ្យស៊ាំនឹងភាពគ្មានស្តេចសោយរាជ្យ ឲ្យបំភ្លេចព្រះរាជវង្សានុវង្សចោលប៉ុណ្ណោះ បើទោះជាថា កន្លងមកប្រជារាស្ត្រធ្លាប់បានធ្វើពលីកម្មជាច្រើន ដើម្បីរាជបល្ល័ង្កក៏ដោយ ។

តាមព្រះរាជក្រឹត្យមួយរបស់ស្តេចអាណ្ណាម ព្រះរាជាណាចក្រកម្ពុជាត្រូវគ្រប់គ្រងដោយមន្ត្រីអាណ្ណាម ៣នាក់ គឺទ្រឿងមិញយ៉ាង ផាមវ៉ាន់ឌាន និងត្រាន់វ៉ាន់ណាង ដែលមកនៅដឹកនាំប្រទេសដោយមានជំនួយពីរដ្ឋមន្ត្រី និងចៅហ្វាយខែត្រខ្មែរជាច្រើននាក់ ។

រាជធានីភ្នំពេញពេលនោះគេដូរឲ្យហៅថាត្រានតាយឬត្រានណាំយ៉ាងវិញ (ភ្នំ=ណាំ, ពេញ=យ៉ាង) ។

វ៉េស៊ីដង់អាណ្ណាមពេលនោះនឹកគិតថាគេមានអំណាចខ្លាំងណាស់ ហើយបានបង្ខំឲ្យមន្ត្រីទាំងអស់ ស្លៀកសម្លៀកបំពាក់តាមរបៀបអាណ្ណាម[៧៦] ឲ្យបួងសក់ និងផ្តល់ឋានៈឲ្យតាមរបៀបអាណ្ណាម ហើយបានដាក់មេអាណ្ណាមម្នាក់នៅជាប់នឹងចៅហ្វាយខែត្រកម្ពុជា ដើម្បីត្រួតពិនិត្យលើរាល់សកម្មភាពផង និងដឹកនាំការងាររដ្ឋបាលផង ។

មិនតែប៉ុណ្ណោះ អាណ្ណាមមានបំណងចង់ធ្វើឲ្យព្រះរាជាណាចក្រខ្មែរបាត់បង់អស់នូវធាតុដើមរបស់ខ្លួនដោយបានប្តូរឈ្មោះស្រុកទេសទាំងអស់ថែមទៀត ។ យោងតាមសំណើរបស់ពួកអ្នកដែលនៅជាប់នឹងចៅហ្វាយខែត្រខ្មែរ ព្រះរាជាអាណ្ណាមបានសម្រេចប្តូរឈ្មោះខែត្រ ដោយបន្ថយចំនួនពី៥៦មកនៅត្រឹម៣៣ វិញ ហើយបានបង្កើតស្រុក២សម្រាប់ទឹកដីដែលមានពួកអ្នកស្រុកព្រៃរស់នៅ រួចឲ្យហៅតាមឈ្មោះ អាណ្ណាម ទាំងអស់ ។

ឈ្មោះខែត្រទាំង៣៣នោះមាន ណាមយ៉ាង ឬត្រានតាយ សម្រាប់ភ្នំពេញ, ក្រៅពីនេះជាឈ្មោះខែត្រថ្មីដែលគេបានបង្រួមឲ្យតិច ដែលខ្ញុំមិនដឹងថាឈ្មោះណាត្រូវនឹងខែត្រចាស់ណាមួយទេ ៖ ថានធូ, តាំងន, ទុយឡាប់, បាណាម (បាក់ណាម) , បាឡាយ (បារាយណ៍) , បិញធាន (កោះអញ្ចៀន) , ខាបាត, ឡាវេន (ព្រៃវែង) , ហៃដុង, គិមទ្រឿង, ចាវដុង, កាអាវ, វ៉ាងវ៉ាន, ហាបិញ, ដុងឡយ, សានភូ (ប្រហែលគឺសម្បូរ) , សានបុក (សម្បុក) , តាំវូ, ខាយបៀន, ហៃតាយ, ខាស៊ុម (កោះសូទិន) , ថេឡាប់, តាំកាយ, ឡូវៀត (លង្វែក) , ឡុងទន (សំរោងទង) , ក្វាងបៀន, ហួយឺ, ចានតាយ, អ៊ុយឺ, ចានថាញ់, ម៉ាត់លួត, អ៊ិមអាន ។

៦ស្រុកសម្រាប់អ្នកស្រុកព្រៃ២នោះគឺ កាញ់ចេ (ក្រចេះ) និងកាន់យើ (កញ្ជរ) ។

មានមន្ត្រីទាំងអស់១០៧រូបដែលទទួលបន្ទុកការងាររដ្ឋបាលស៊ីវិល និងខាងកងទ័ព ។ គឺមាន ៖ ទួងក្វាន ឬសេនាប្រមុខ១រូប, ថាមតាន់ ឬអ្នកមានភារៈចាត់ចែង និងថែរក្សាទ្រព្យកងទ័ព១រូប, ដេដុក ឬអគ្គមេបញ្ជាការ ១

[៧៦] ឋានៈនោះមាន អុងចាញ់, អុងផ, ដូយ, កាយឡាង, ថុន, ទ្រឿង, ត្រាំ ។ល ។

រូប, ហ៊ាបតាន់ ឬវរសេនីយ៍ឯក១រូប, ឡាញ់ប៊ិញ ឬវរសេនីយ៍ត្រី២រូប, ផឡាញ់ប៊ិញ ឬជំនួយការវរសេនីយ៍ត្រី ២រូប, ប៊ិញប៊ីដាវ ឬឆ្មាំកងទ័ព១រូប, លឿងប៊ីដាវ ឬឆ្មាំខាងកស្តុភារ១រូប, វៀនង៉ុយឡាង ឬនាយការិយាល័យក្រសួង២រូប, ជូស៊ូ ឬនាយរងការិយាល័យក្រសួង៣រូប, បាតវូ ឬផ្នែកខាងរបៀប៤រូប, បាតដាម ឬលេខាធិការថ្នាក់ទី៨ចំនួន៨រូប, គួនដាម ឬលេខាថ្នាក់ទី៩ចំនួន៨រូប, ថឡាយ ឬនាយទោផ្គត់ផ្គង់ស្បៀង៦០រូប, ហួនដាវ ឬសាស្ត្រាចារ្យ១២រូប, ហើយនិងយ៉ាវថ ឬគ្រូបង្រៀន ។

ទ្រឿងមិនយ៉ាងបានទទួលការចាត់តាំងឲ្យធ្វើជាទួងក្វាននៅភ្នំពេញ ឯឡេដៃគឿងគឺជាថាមតាន់ ។ មានជានភូស៊ូ ម្នាក់ ស្ថិតនៅក្រោមការត្រួតត្រារបស់អ្នកទាំង២ មានភារកិច្ចត្រួតពិនិត្យសេវាស៊ីវិល និងយោធានៅក្នុងភូ (ខែត្រ) ៣ គឺហាយតាយ, ហាយដុង និងសានទិញ ។

ទ័ពអាណ្ណាមនៅកម្ពុជាក៏បានត្រូវគេរៀបចំឡើងវិញដែរ ដោយបែងចែកជា ២៥កងពល និងមានកងពលពិសេសមួយ ទទួលបន្ទុកថែរក្សាពង្រាប និងបង្ក្រាត់ដីរីចម្បាំង ។

យើងនឹងវិលត្រលប់មកមើលការរៀបចំនេះនៅពេលក្រោយ ។ កម្ពុជាទាំងមូលបានត្រូវអាណ្ណាម បែងចែកចេញជា៨ភូ (ខែត្រ) មានទាំងអស់១៨ហ្វៀន (មណ្ឌលរដ្ឋបាល) គឺ :

- ភូត្រាន់តាយ, ភ្នំពេញ, មានហ្វៀន ២គឺ ថៃអាន និងលូអាន
- ភូញាហ្វា មានហ្វៀន ២ដែរគឺ ធឿងដុង និងដុងញួង
- ភូណាមនិញ មានហ្វៀន ៣គឺ ណាមធិញ, ណាមថៃ និងភូណាម
- ភូវ៉ូកុង មានហ្វៀន ៣ដែរគឺ ប៊ិញដុង, គីតូ និងដុងធុយ

**ភូទាំង៤នេះ ត្រួតត្រាដោយ ទួងក្វាន និងថាមតាន់ ។**

- ភូហាយតាយ មានហ្វៀន ២គឺ ហាយប៊ិញ និងថានដុង
- ភូហាប៊ិញ មានហ្វៀន ២ដែរគឺ ដុងហា និងភូឡាយ

**ភូទាំង២នេះ ត្រួតត្រាដោយ ជានភូស៊ូ ។**

- ភូសានទិញ មានហ្វៀន ២គឺ ក្រុឡាំ និងសានដុង
- ភូមីឡាម មានហ្វៀន ២ដែរគឺ មីឡាម និងដាវឡាម

**ភូទាំង២នេះ ត្រួតត្រាដោយ ជានភូស៊ូ នៅសានទិញ ។**

ចំណែកឯកងពលទាហានទាំង៥ មួយៗមាន៥កងវរសេនាធំ ដោយមិនមានគិតដល់កងអនុសេនាធំកម្ពុជាផងទេ មាន : កងពលកណ្តាល មាន២៦៩៦នាក់, កងពលបើកផ្លូវ មាន២១១៦នាក់, កងពលស្លាបខាងឆ្វេងមាន២៥៣០នាក់, កងពលស្លាបខាងស្តាំមាន២២០០នាក់, និងកងពលបិទគូទមាន២២៥៥នាក់ សរុបទាំងអស់ត្រូវជា ១១.៧៩៦នាក់ ។

រៀបចំដូច្នេះរួចហើយ ស្តេចអាណ្ណាម បានចាត់តាំង ឡេវ៉ាន់ឌុក ឲ្យធ្វើជាធិញលុករាជអធិការរបស់ព្រះរាជាប្រចាំកម្ពុជា ។

ពួកអាណ្ណាមបានហៅព្រះក្សត្រីអង្គម៉ីថាង៉ុកវ៉ាន ហើយថ្វាយព្រះឋានៈជាភាសាអាណ្ណាម ថាមីឡាម ក្វានជួ (ព្រះមហាក្សត្រីនៃភូមិឡាម) ។ ព្រះរៀមរបស់ព្រះនាង ព្រះក្សត្រីបែន ទទួលឋានៈថាលូអានក្វាន (ក្សត្រីទី២នៃលូអាន) , ព្រះអនុជក្សត្រីមួយអង្គទទួលឋានៈជាថាវដុងក្វានក្វាន និងមួយអង្គទៀតជា តាប់និញក្វានក្វាន ។

មានការងារមួយដែលមានប្រយោជន៍ ក៏ប៉ុន្តែបានធ្វើឲ្យអ្នកស្រុកខឹងសម្បាជាខ្លាំង គឺកំណែនឲ្យធ្វើផ្លូវយុទ្ធសាស្ត្រមួយដោយគ្មានផ្តល់កម្រៃ តភ្ជាប់ពីភ្នំពេញទៅស្ពានយមរាជ បច្ចុប្បន្ននៅលើផ្លូវទៅកំពត (ប្រហែលជា ៨គីឡូម៉ែត្រពីភ្នំពេញ) រួចបន្តទៅទ្រាំង និងបន្ទាយមាស និងការបង្កើតឲ្យមានក្រុមរត់សំបុត្របន្តគ្នា ប្រចាំតាមសាលានីមួយៗ ដែលមានគ្នា៣០នាក់ផ្លាស់ប្តូរវេនគ្នា ជ្រើសរើសចេញពីអ្នកស្រុករស់នៅក្នុងភូមិជិតៗ ។ ផ្លូវនេះដែលក្រោយមកគឺផ្លូវពីភ្នំពេញទៅកំពត ខ្មែរហៅថាផ្លូវអាណ្ណាម[៧៧] ។

នៅសម័យនោះ គឺក្នុងឆ្នាំ១៨៣៥ នៅឯកំពង់សោម មានបងប្អូន២នាក់ ដែលមានឋានៈជាឧកញ៉ា គឺឧកញ៉ាជ័យ និងឧកញ៉ាជូ បានប្រកែកមិនព្រមគោរពតាមបញ្ជារបស់អាណ្ណាមទេ ហើយចាប់ផ្តើមកាន់អាវុធប្រឆាំងឡើង ។ ទាំង២នាក់បងប្អូនធ្វើការប្រយុទ្ធអស់កាលយ៉ាងយូរតែមិនអាចបង្ក្រាបទ័ពចម្រុះអាណ្ណាម-ខ្មែរបានហៀបតែនឹងត្រូវគេចាប់បានទៅហើយ ក៏នាំគ្នារត់គេចឆ្លងព្រំដែនទៅជ្រកកោននៅឯបាងកកបាត់ទៅ ។

នៅឆ្នាំ១៨៣៦ នៅខេត្តកំពង់ស្វាយឯណោះវិញ តេជោរាមដែលបះបោរប្រឆាំងនឹងរបបថ្មី បានត្រូវគេចាប់យកមកភ្នំពេញ ហើយអុងទួងគុនចេញបញ្ជាឲ្យគេសម្លាប់ចោលទៅ ។ គេបានលើកស្នងអី ជំនួយការរបស់តេជោរាម ឲ្យឡើងកាន់អំណាចបន្តពីគាត់ ។ មុនដំបូងស្នងអីបានបំពេញការងារល្អណាស់ ក៏ប៉ុន្តែ ដល់មកឆ្នាំ១៨៣៧ ស្រាប់តែឈ្មោះនេះបានចាប់រើស៊ីដង់អាណ្ណាមសម្លាប់ចោល ហើយចាប់កេណ្ឌទ័ព ។ ស្នងអី ធ្វើសកម្មភាពបានប៉ុន្មានសប្តាហ៍ ក៏រត់គេចខ្លួនដោយនាំយកអ្នកស្រុកស្ទោង និងដីក្រែងមួយចំនួនធំផង ទៅនៅឯទន្លេរពៅ ដែលស្ថិតនៅក្រោមការត្រួតត្រារបស់សៀមនៅឡើយ ។ ពួកអាណ្ណាមបានសម្លាប់ប្រជាជនខេត្តកំពង់ស្វាយអស់ជាច្រើន ដែលគេចោទថាបានគាំទ្រ ស្នងអី ។ អ្នកស្រុកមួយចំនួនទៀត គេនាំយកទៅអាណ្ណាម ។

ព្រឹត្តិការណ៍ទាំងអស់នេះ រួមទាំងការបះបោរ និងការប្រឆាំងអាណ្ណាមផង បានធ្វើឲ្យប្រជាជនកម្ពុជា មានការព្រួយបារម្ភជាខ្លាំង ។ គេក៏ចាប់តាំងនាំគ្នាងាកបែរទៅរកខេត្តបាត់ដំបង ដីខ្មែរពីមុន តែឥឡូវបានក្លាយទៅជា

---

[៧៧] ផ្លូវនេះសង់ចេញពីភ្នំត្រង់ក្បែរផ្ទះលោកគ្រូពេទ្យធំ ។ មានមួយចំណែក គេហៅថា ផ្លូវប៉េត្រូល ។

របស់សៀមហើយ ដែលមានរាជវង្ស២អង្គកំពុងរស់នៅ គឺព្រះអង្គឯម និងព្រះអង្គឌួង[៧៨] ។ ស្តេចសៀម បានអនុញ្ញាតឲ្យព្រះអង្គឯមគង់នៅនឹងបាត់ដំបង ឯព្រះអង្គឌួងឲ្យគង់នៅមង្គលបុរី ។ ក្សត្រទាំង២អង្គ បានឃ្លាតឆ្ងាយពីរាជបល្ល័ង្កហើយ ដោយត្រូវអាណ្ណាមបំបែក បណ្តេញកាត់កាលចោល និងនៅជាមួយសៀម ក៏ស្តេចសៀមមិនបានផ្គត់ផ្គង់ឲ្យល្អណាស់ណាដែរ ព្រោះមានគេប្រណែននិន្ទា ។ ក៏ប៉ុន្តែព្រះអង្គ នៅតែជាសេចក្តីសង្ឃឹមចុងក្រោយរបស់ប្រទេសជាតិដដែល ។ ទម្លាប់ជាប្រពៃណីមួយបាននិទានតៗគ្នាថា «កាលណាទឹកហូរចុះពីខាងជើងមកខាងត្បូង កាត់ពីមុខកំពង់ហ្លួង ទឹកនោះបានប្រាប់អ្នកស្រុកថា ព្រះអង្គម្ចាស់ទាំងឡាយមានព្រះកាយពលល្អទេ ព្រះមហេសីទាំងអស់របស់ព្រះអង្គបានប្រសូត្រព្រះរាជបុត្រាថ្វាយព្រះអង្គ ហើយអ្នកស្រុកនិយាយថា ព្រះអាទិត្យនៅតែរះឯជើងមេឃរៀងរាល់ថ្ងៃ មិនទាន់រលត់បាត់នៅឡើយ» ។

នៅពេលដែលហៀបនឹងរលត់ទៅហើយ ប្រជាជនខ្មែរដ៏កម្សត់នៅតែនឹកដល់ព្រះរាជវង្សានុវង្សនៅឡើយ បើទោះបីថារាជវង្សានុវង្សនោះបានដឹកនាំគេអស់កាលជាច្រើនសតវត្សរ៍ ឲ្យធ្វើសង្គ្រាមកាប់សម្លាប់តែគ្នាឯង ឬប្រឆាំងនឹងបរទេស, ឲ្យគាំទ្រសមាជិករាជវង្សដណ្តើមអំណាច ដណ្តើមរាជបល្ល័ង្កគ្នា, កាត់យកខែត្រផ្សេងៗទៅកាន់កាប់ ក៏ប៉ុន្តែមិនចេះគ្រប់គ្រង, ហើយមិនដែលបាននឹកគិតដល់សុខទុក្ខរបស់ប្រជាជនដ៏កម្សត់បន្តិចណាក៏ដោយ ។ ទោះជាយ៉ាងណាក្តី ប្រជាជននៅមានសេចក្តីសង្ឃឹមតែលើរាជវង្សមួយនេះប៉ុណ្ណោះ ព្រោះថាគ្មានអ្នកមានបុណ្យណាម្នាក់ចេញមុខមកជួយ ដូចជានៅស្រុកចិន, អាណ្ណាម, ភូមា, សៀម ដើម្បីបំផុសអ្នកស្រុកឲ្យនាំគ្នាបះបោរឡើងវាយប្រហារទៅលើពួកសត្រូវរបស់ព្រះរាជាណាចក្រ ហើយបណ្តេញចេញ ដណ្តើមយករាជបល្ល័ង្កមកវិញ រួចឡើងអង្គុយលើរាជបល្ល័ង្កនោះ ក្រោមស្នូរទះដៃអបអរសាទរពីប្រជាជនទាល់តែសោះ ។ ចៅហ៊ាបែន និងចៅហ៊ាមូប្រហែលជាអាចបំពេញនូវតួនាទីជាវីរជននេះបាន ក៏ប៉ុន្តែ អ្នកទាំង២នាក់នេះមិនមែនជាអ្នកមានបុណ្យទេ ហើយក៏គ្មានឆន្ទៈខ្ពស់នឹងបំពេញភារកិច្ចនេះដែរ មិនតែប៉ុណ្ណោះ ថែមទាំងបានក្បត់ជាតិជាបន្តបន្ទាប់ទៅទៀត កាត់ផ្តាច់យកទឹកដីមាតុភូមិទៅឲ្យសៀមទៅវិញ ។ ម្ល៉ោះហើយ ប្រជាជនដែលហាក់បីដូចជាត្រូវសណ្តំទៅហើយ បានភ្ញាក់ខ្លួន... 

---

[៧៨] ព្រះអង្គឌួងមានបុត្រា៣ព្រះអង្គ និងបុត្រីមួយព្រះអង្គ ពីឆ្នាំ១៨៣៨ដល់១៨៤៤ ៖ មានព្រះរាជឱរសមួយព្រះអង្គបានប្រសូត្រ ពីអ្នកម្នាងប៉ែន ជាមហេសីទី៣ នៅក្នុងខែមាឃ ឆ្នាំ១៨៣៨ ទ្រង់ទទួលព្រះនាមថា ប្រឡឹង រួចថា អង្គវតី គឺព្រះបាទនរោត្តម ។ នៅក្នុងឆ្នាំ១៨៣៩ ទ្រង់មានបុត្រីមួយអង្គ គឺអ្នកអង្គម្ចាស់ចង្កុលណី ។ ដល់មកឆ្នាំ១៨៤០ អ្នកម្នាងពៅប្រសូត្របានបុត្រាមួយអង្គ ដែលក្រោយមកមានឋានៈជាព្រះកែវហ្វា រួចជាព្រះឧបរាជ ហើយជាព្រះរាជាស៊ីសុវត្ថិ ក្រោយពីព្រះនរោត្តមសុគតទៅ ។ នៅក្នុងឆ្នាំ១៨៤១ អ្នកម្នាងខាំប្រសូត្របានបុត្រាមួយអង្គ គឺព្រះអង្គមាស់វត្ថា ឬស៊ីវត្ថា ដែលក្រោយមកបានបះបោរប្រឆាំងនឹងព្រះវរៀម ។

មេទ័ពអាណ្ណាម អុងទួងគុន បានយល់ច្បាស់ណាស់ថាកម្ពុជានៅមានថាមពលដែលកំពុងតែក្រាបសម្ងំ ហើយអាចនឹងងើបក្រោកឡើងបះបោរប្រឆាំងនឹងការត្រួតត្រារបស់យួន លើរាជវង្សានុវង្សនេះឯង ។ គាត់បានប្តេជ្ញាថានឹងកម្ចាត់កម្ចាយក្សត្រទាំង២អង្គនេះចេញ ដោយធ្វើយ៉ាងណាបំបែកបំបាក់ពីគ្នាសិន ព្រោះកន្លងមកក្សត្រទាំង២អង្គសាមគ្គីគ្នាស្និតល្អួតណាស់ រួចសឹមឆ្លៀតយកឱកាសដែលលេចចេញពីព្រឹត្តិការណ៍នេះ ដើម្បីបំផ្លិចបំផ្លាញចោលតែម្តង ។

អុងទួងគុនបានចាត់ឲ្យជនអាណ្ណាមម្នាក់ក្លែងខ្លួនធ្វើជាខ្មែរ ដោយដាក់ឈ្មោះថា ភគវ៉ា នាំលិខិតមួយទៅថ្វាយព្រះឧបរាជអង្គឯម ទូលថាអាណ្ណាមមកកម្ពុជានេះក្នុងគោលបំណងដើម្បីជួយធ្វើឲ្យមានសន្តិភាព ។ ការដែលលើកព្រះមហាក្សត្រីអង្គមីឲ្យឡើងសោយរាជ្យនេះ ក៏ព្រោះតែថាព្រះនាងគ្រាន់តែជាព្រះមហាក្សត្រីបណ្តោះអាសន្នប៉ុណ្ណោះ រង់ចាំតែពេលដែលមានក្សត្រាខ្មែរមួយអង្គចង់វិលត្រលប់មកសោយរាជ្យវិញ អាណ្ណាមនឹងជួយជ្រោមជ្រែង ។ ក៏ប៉ុន្តែព្រះឧបរាជមានគូប្រជែងមួយ គឺព្រះអង្គឌួង ជាអនុជរបស់ព្រះអង្គ ដែលរៀបចំផែនការក្បត់នឹងព្រះអង្គរួចទៅហើយ ។

ព្រះឧបរាជ គិតថាភ័ព្វសំណាងព្រះអង្គបានមកដល់ហើយៗ ជឿសម្តីអាណ្ណាមថា ព្រះអនុជជាគូប្រជែងរបស់ព្រះអង្គ ទ្រង់ក៏បានចារព្រះសារលិខិតមួយច្បាប់ទៅថ្វាយស្តេចសៀមថា ព្រះអនុជកំពុងតែធ្វើចលនាប្រឆាំងនឹងផលប្រយោជន៍សៀមនៅស្រុកខ្មែរ ។ ស្តេចសៀមបានចាត់មន្ត្រី២នាក់ឲ្យមកយាងព្រះអង្គឌួង ទៅបាងកកភ្លាម ហើយហាមផ្តាច់មិនឲ្យយាងមកមង្គលបុរី វិញទេ ។

ដោយកម្ចាត់ព្រះអនុជឲ្យបាត់ពីមុខពីមាត់រួចហើយ ព្រះឧបរាជបានយាងទៅគង់នៅពោធិសាត់ជាមួយព្រះរាជវង្ស ព្រះរាជបុត្រាបុត្រីរបស់ព្រះអង្គឌួង ដែលទ្រង់រក្សាទុកជាចំណាប់ខ្មាំង និងមន្ត្រីខ្មែរជាច្រើនទៀតនៅបាត់ដំបងដែលទ្រង់មិនអាចទុកចោលបាន ។ មេទ័ពអាណ្ណាមដែលបញ្ជានៅទីនោះបានចាប់ខ្លួនអ្នកទាំងអស់នោះ ហើយបញ្ជូនមកភ្នំពេញ ។ ព្រះឧបរាជអង្គឯម មិនយល់ថាហេតុអ្វីក៏មានរឿងដូច្នេះទេ តែចំពោះខ្លួនព្រះអង្គ មេទ័ពអាណ្ណាមទទួលរាក់ទាក់បំផុត ម្ល៉ោះហើយទ្រង់ក៏យាងមកភ្នំពេញជាមួយនឹងគេឯង មានកងការពារជូនដំណើរហាក់បីដូចជាមានកិត្តិយសណាស់ ។ ពេលយាងមកដល់ភ្នំពេញ អុងទួងគុនបានទទួលស្វាគមន៍ ព្រះអង្គគ្រឹកគគ្រេង ទាំងប្រជាជនក៏ទះដៃអបអរសាទរ ព្រោះមើលឃើញថាព្រះអង្គនេះហើយជាអ្នកមករំដោះគេ ។ ការដែលប្រជាជនអបអរសារទទួលព្រះឧបរាជខ្លាំងហួសហេតុពេកបានធ្វើឲ្យអុងទួងគុនអន់ចិត្ត ដល់យប់ឡើងក៏ចាប់ព្រះអង្គដាក់ក្នុងទ្រុងដែក ហើយបញ្ជូនទៅកាន់រាជធានីវ៉ៃនៅថ្ងៃស្អែកឡើង (១៨៤០) ។

ចំពោះមន្ត្រីមកពីខែត្របាត់ដំបង មានមួយចំនួនធំត្រូវគេសម្លាប់ចោលភ្លាមដោយមិនចាំបាច់កាត់ទោស នៅសល់ខ្លះគេបញ្ជូនទៅវ៉ៃដែរ ហើយឃុំទុកនៅទីនោះ ។

ចំណែកនៅបាងកកឯណោះវិញ ព្រះអង្គឌួងដែលព្រះរៀមចោទប្រកាន់ថាក្បត់ បានត្រូវសៀមឃាត់ខ្លួន

ដាក់ប្រវាក់ទុកនៅក្នុងព្រះបរមរាជវាំងដែរ ។

នៅពេលដែលស្ថានការណ៍នៅកម្ពុជាកំពុងតែអាក្រក់ទៅៗ វៀតណាមក៏មិនចេះស្កប់ស្កល់នឹងចំណង់របស់គេដែរ ។ គេចង់ឲ្យខ្មែរប្តូរសាសនាកាន់តាមគេវិញ ម្ល៉ោះហើយគេបណ្តេញលោកសង្ឃចេញពីវត្តអារាមបញ្ជាឲ្យកាប់ដើមពោធិ គាស់រំលើងព្រះពុទ្ធបដិមា និងឲ្យវាយកម្ទេចចេតិយចោល ។ លើសពីនោះទៅទៀត គេចង់ឲ្យស្រុកនេះគ្មានអ្វីជាតំណាង ដោយបានឲ្យរដ្ឋមន្ត្រីរបស់ព្រះមហាក្សត្រី ធ្វើដំណើរទៅសាយហ្គន តែបានភរថាឲ្យទៅវេ៉ ក្នុងនោះមានលោកចៅហ្វ៊ា ឡុង សម្តេចចៅពញាហ៊ូ និងលោកក្រឡាហោម គិញ ដោយយកលេសថា ស្តេចអាណ្ណាម ចង់ជួបប្រមូលគ្នាជាមួយនឹងព្រះឧបរាជដែលទើបតែយាងទៅដល់ ។ ប៉ុន្មានថ្ងៃបន្ទាប់មក គេបានបញ្ជូនព្រះមហាក្សត្រី ព្រះអនុជអង្គពៅជាព្រះឧបរាជ និងព្រះអនុជអង្គស្ងួន ទៅសាយហ្គនទៀត ។ ព្រះរៀមក្សត្រីអង្គបែនជាចៅរបស់ចៅហ៊្វា បែន ដែលបានប្រគល់ខែត្របាត់ដំបង ទៅឲ្យសៀមកាលពីមុន ពេលនេះទ្រង់មានព្រះជន្ម៣២ព្រះវស្សាហើយ (១៨៤១) បានត្រូវគេនាំយកទៅ លង់ហោ (វិញឡុង) ។ គេបាននិយាយថា ព្រះក្សត្រីអង្គនេះ នឹងត្រូវដោះស្រាយខុសពីព្រះអនុជទាំងអស់ ព្រោះទ្រង់មានព្រះមាតាជាបុត្រីរបស់ចៅហ៊្វាបែន ដែលបានគេចព្រះអង្គ ទៅនៅឯបាត់ដំបង ហើយទ្រង់មានព្រះបិតុលាម្នាក់ជាសត្រូវស្ងាប់រស់របស់អាណ្ណាម ។ ទៅដល់វិញឡុង គេឃុំព្រះនាងទុកសិន បន្ទាប់មក គេយកព្រះនាងចេញពីទីឃុំឃាំង ទៅជ្រមុជទឹកទន្លេសម្លាប់ចោលដោយមិនដឹងជា មានរឿងអ្វី (១៨៤២) ។

ការដែលអាណ្ណាមធ្វើទាំងប៉ុន្មាននេះ ប្រជាជនបានឃើញ និងដឹងឮទាំងអស់ ធ្វើឲ្យគាត់អាចកាត់ស្មានបានថា បើព្រះរាជវាំងអាណ្ណាមបន្តធ្វើអ៊ីតទៅទៀតនោះគឺ មិនយូរមិនឆាប់គេនឹងយកព្រះរាជាណាចក្រកម្ពុជា ដាក់បញ្ចូលទៅក្នុងទឹកដីកូសាំងស៊ីនជាមិនខាន ។ អាណ្ណាមបានរៀបចំអនុវត្តវិធានការ២ ដែលមានសារសំខាន់គ្រាន់បើដែរ ហើយដែលរាល់ប្រជាជនស៊ីវិល័យតែងតែធ្វើ គឺការធ្វើសម្រង់ស្ថិតិប្រជាជន និងការចុះបញ្ជីសុរិយោដីអចលនទ្រព្យ ដូចដែលគេបានធ្វើរួចហើយនៅអាណ្ណាម ។ ក៏ប៉ុន្តែប្រជាជនយល់ថា នេះគឺជាសកម្មភាពដំបូងនៃការកាត់យកទឹកដីហើយៗមានកំហឹងកាន់តែខ្លាំងឡើងៗ ។ ពេលនោះពួកអ្នកដែលស្រលាញ់សៀម គឺបក្សពួករបស់ព្រះឧបរាជអង្គឯម និងអ្នកអង្គម្ចាស់អង្គឌួង បានលួចចុះទៅបំផុសប្រជាជនតាមស្រុកស្រែចម្ការឲ្យបះបោរឡើង ហើយចាប់ផ្តើមកាប់សម្លាប់ជនអាណ្ណាមឥតរើសមុខ ។ ការកាប់សម្លាប់នេះ បានរីករាលដាលរហូតមកដល់ភ្នំពេញ ដែលទ័ពអាណ្ណាមបាននាំគ្នារត់មកជ្រកនៅទាំងកងៗ តែក៏ត្រូវគេលួចសម្លាប់នៅពេលយប់ដែរ ។ ក្នុងរយៈពេលតែ៨ថ្ងៃប៉ុណ្ណោះ កម្ពុជាទាំងមូលសឹងតែគ្មានវត្តមានអាណ្ណាមតទៅទៀត លើកលែងតែនៅតាមទីប្រជុំជនធំៗ ដែលគេមិននឹកស្មានថាប្រជាជនខ្មែរពេលនោះ អាចធ្វើដូច្នេះបានសោះ ។

ប្រជាជនបានបះបោរជាទូទៅ ហើយពួកមន្ត្រីធំៗបានលួចប្រជុំគ្នាជាសម្ងាត់ និងបានសម្រេចថា ត្រូវហៅរកសៀម ឲ្យមកជួយកម្ពុជាម្តងទៀត ។ គេនាំគ្នាបង្កើតគណៈកម្មការរដ្ឋាភិបាលបណ្តោះអាសន្នមួយ រួចបានចាត់

តាំងមន្ត្រីធំ២រូប គឺឧកញ៉ាវិបុលឡុង ជាអនុរដ្ឋមន្ត្រីខាងទ័ពជើងទឹក និងឧកញ៉ាសួគ៌ាលោក មួក ចៅហ្វាយខេត្រពោធិសាត់ ឲ្យនាំយកញត្តិមួយទៅបាងកក សុំអន្តរាគមន៍របស់សៀម និងការលើកព្រះអង្គឌួង ឲ្យឡើងសោយរាជ្យលើរាជបល្ល័ង្កកម្ពុជា តាមចំណង់ចំណូលចិត្តរបស់ប្រជារាស្ត្រ ។

ស្ដេចសៀមបានឯកភាពតាមការស្នើសុំទាំង២ រួចបានចាត់តាំងចៅឃុនបឌិនឲ្យកេណ្ឌទ័ព មករៀបចំលើករាជវង្សកម្ពុជាឲ្យសោយរាជ្យឡើងវិញ ។

ប៉ុន្មានសប្ដាហ៍ក្រោយមក មេទ័ពអាណ្ណាមទាំង៣នាក់ដែលឈរជើងនៅពោធិសាត់បានត្រូវវាយឲ្យបរាជ័យ ហើយបាននាំគ្នារើសម្ភារដកថយចេញ ដោយបោះបង់បន្ទាយពោធិសាត់ទុកឲ្យទ័ពសៀម ។ ចៅឃុនបឌិនបានដឹកនាំទ័បបន្តដំណើរចូលមកក្នុងផ្ទៃប្រទេស ក្រោមស្នូរទះដៃអបអរសាទរពីប្រជាជនដែលបាននាំគ្នាងើបក្រោកឈរឡើង ជួយគាំទ្រវាយប្រហារទៅលើកងទ័ពសត្រូវ ដែលរត់គេចពាសពេញប្រទេស ។

ពេលនោះព្រះចៅអធិរាជអាណ្ណាមបានបញ្ជូនទ័ពជំនួយមួយកង មកជាមួយព្រះឧបរាជអង្គឯម, រាជបុត្រា របស់ព្រះអង្គព្រះនាមថា អង្គភីម និងព្រះក្សត្រីទាំង៣អង្គដែលជាបុត្រីរបស់ស្ដេចអង្គច័ន្ទ ដោយសង្ឃឹមថានឹងធ្វើឲ្យមានការបែកបាក់គ្នារវាងខ្មែរនិងខ្មែរ ។ ក៏ប៉ុន្តែក្រោយពីមានអាវុធកាន់នៅក្នុងដៃ ក្រុមនេះ បានបែរទៅប្រឆាំងនឹងពួកអាណ្ណាមដែលជិះជាន់ពួកគេអស់ពេល៧ឆ្នាំមកហើយ រួចក៏នាំគ្នារត់ទៅចុះចូលជាមួយទ័ពសៀមវិញ ភ្លេចអស់អំពើឃោរឃៅរបស់សៀមកាលពីពេលមុន ។

ទ័ពសៀមវាយរុញច្រានទ័ពអាណ្ណាម ដែលដយថយទៅជាក្រុមតូចៗ ដោយដេញតាមរហូតទៅជិតដល់ចូវដុក ។ នៅទីនោះ មានមេទ័ពអាណ្ណាមជាច្រើន ក្នុងនោះរួមមានទាំងមេទ័ពប្រចាំខេត្រពោធិសាត់ទាំង៣នាក់ផងបាននាំគ្នាផឹកថ្នាំសម្លាប់ខ្លួន ដើម្បីជៀសវាងការទទួលទណ្ឌកម្មពីព្រះចៅអធិរាជ ។

## ៤២- ព្រះបាទអង្គឌួង (១៨៤១-១៨៥៩)

នៅពេលនោះ នៅរាជធានីឧត្ដុង្គឯណោះវិញ ប្រជាជនកំពុងតែនាំគ្នារាក់ទាក់ស្វាគមន៍មេទ័ពសៀម ចៅឃុនបឌិន និងព្រះអង្គឌួង ដែលបានចាប់ផ្ដើមដឹកនាំកិច្ចការប្រទេសជាតិហើយ ។ ព្រះអង្គបានចេញព្រះរាជបញ្ជាទៅគ្រប់ខេត្រខ័ណ្ឌ តែងតាំងចៅហ្វាយខេត្រ ឬទទួលស្គាល់អំណាចរបស់ពួកមេដឹកនាំបះបោរ រួចបានយាងមកគង់នៅក្នុងព្រះរាជវាំងមួយធ្វើអំពីឈើនៅឃ្លាំងស្វឹក ជិតពញាឮ ដែលប្រជារាស្ត្របាននាំគ្នាសង់ថ្វាយ ក្នុងពេលតែប៉ុន្មានសប្ដាហ៍ប៉ុណ្ណោះ ។

ចំណែកពួកអាណ្ណាមវិញ បានប្រមូលកម្លាំងទ័ព និងភស្តុភារជាច្រើននៅក្នុងព្រែកដឹកហាទៀង ធ្វើឲ្យចៅឃុនបឌិន មានការព្រួយបារម្ភជាខ្លាំង ព្រោះបានរំសាយទ័ពទៅវិញខ្លះទៅហើយ ហើយបើនៅទាំងអស់ ក៏ទ័ពនោះតិចមិនអាចប្រៀបទៅនឹងទ័ពអាណ្ណាមបានទេ ។ ស្រាប់តែលេចកប៉ាល់ទឹកសៀមមួយកង មកចុះចតនៅនឹងកំពត

ដោយមានដឹកទ័ពជំនួយមានសៀម ខ្មែរ ម៉ាឡេ និងពួកអ៊ីរ៉ុបមកផង ។ ចៅឃុនបឌិនប្រុងថា នឹងចេញទ័ពទៅតភ្ជាប់ជាមួយទ័ពជំនួយនោះ ទទួលមានដំណឹងលេចឮថាពួកនោះត្រូវអាណ្ណាមវាយប្រហារ ហើយបាននាំគ្នាចុះទូកចេញទៅ ស្រុកសៀមវិញទៅហើយ ។ បរាជ័យនេះបានធ្វើឲ្យចៅឃុនបឌិនរឹតតែមានការលំបាកថែមទៀត ព្រោះទើបតែបរាជ័យនៅក្នុងការប្រយុទ្ធតាមជើងទឹកមួយនៅលើចូវដុកដែរ ក្រោយការប៉ះប្រយុទ្ធគ្នាអស់ពេល ២ថ្ងៃ ។

ពេលនោះ ព្រះអង្គឌួង បានយាងមកគង់នៅឯខែត្រទ្រាំងវិញ ជាមួយទ័ពខ្មែរមួយកង ។ ទ័ពអាណ្ណាម ដែលទើបតែវាយប្រហារទៅលើទ័ពសៀម ហើយបង្ខំឲ្យចុះទូកចេញទៅស្រុកវិញ បានបែរមកវាយទ័ពព្រះអង្គម្ដងដោយជួបប្រយុទ្ធគ្នាស៊ីសាច់ហុតឈាមនៅជើងកញ្ចុំ (១៨៤១) ។

ព្រះអង្គឌួង បានយាងត្រលប់មកឧត្ដុង្គវិញ ទាំងក្ដីអស់សង្ឃឹម ។ ក៏ប៉ុន្តែបឌិនបានប្ដេជ្ញានៅតតាំង ហើយបានចាត់ឲ្យគេសង់របាំងការពារនៅទន្លេធំ លើដៃទន្លេចូវដុក និងដៃទន្លេតូចៗ១០កន្លែងទៀត សម្រាប់ទប់បង្អាក់ដំណើររុលទៅមុខរបស់ពួកអាណ្ណាម ថ្វីបើរបាំងខ្លះតូចក៏ដោយ ។

ទ័ពសត្រូវទាំងសងខាង បានបោះទីតាំងនៅលើទឹកដីដែលគេដណ្ដើមយកបាន ហើយលួចចេញវាយគ្នាមួយដងមួយកាល ជួនកាលនៅពេលយប់ ធ្វើឲ្យមានការខូចខាតហិនហោចជាខ្លាំង ។ សៀម និងអាណ្ណាមច្បាំងគ្នានៅលើទឹកដីកម្ពុជា ម្ល៉ោះហើយគេមិនប្រញាប់ប្រញាល់នឹងដណ្ដើមយកជ័យជម្នះពីគ្នាទៅវិញទៅមកទេ ។ ម្នាក់ៗគិតតែដណ្ដើមយកអាណាខែត្រកម្ពុជាមួយចំនួនដាក់ចូលទៅក្នុងទឹកដីរបស់ខ្លួន បែងទឹកដីខ្មែរចែកគ្នា ម្ល៉ោះហើយខិតខំធ្វើម៉េចកាន់កាប់ទឹកដីឲ្យបានច្រើន តាមតែអាចធ្វើទៅបាន ។ អ្នកទាំង២មានកង្វល់តែមួយដូចគ្នា គឺកាន់កាប់ភ្នំពេញចតុម្មុខឲ្យបាន ព្រោះជាបេះដូង និងជាចំណុចយុទ្ធសាស្ត្ររបស់ប្រទេស ។ បើសិនជាមិនគិតពីចតុម្មុខនេះទេ គេប្រហែលជាបានចុះសន្ធិសញ្ញាសន្តិភាពរួចបាត់ទៅហើយ ហើយកម្ពុជាទាំងមូល ក៏នឹងត្រូវបែងចែករវាងសៀម និងអាណ្ណាមអស់ទៅហើយដែរ ។

ដូច្នេះ ភ្នំពេញ ដែល២០ឆ្នាំក្រោយមក ជារាជធានីរបស់កម្ពុជាក្រោមកិច្ចការពាររបស់បារាំង គឺជាឧបសគ្គមួយ ដែលបើដើរជំពប់ទៅនឹងមានកើតសង្គ្រាម ឬមួយសន្តិភាព ។ ទ័ពអាណ្ណាមយល់អំពីបញ្ហានេះច្បាស់ណាស់ ក៏ប៉ុន្តែដោយប្រជាជនទូទាំងប្រទេសបានងើបប្រឆាំងហើយ ហើយរដ្ឋាភិបាលអាចនឹងត្រូវគេដណ្ដើមយកអុងទួងគុន បានសម្រេចចិត្តដកស្នាក់ការពីភ្នំពេញទៅដាក់នៅឯចូវដុកវិញ ។ ចៅឃុនបឌិនបានឱកាសក៏ចូលមកកាន់កាប់រាជធានីដែលអាណ្ណាមបោះបង់ចោល រួចបានបញ្ជាឲ្យគេសង់វាំងមួយនៅកំពង់វៀងភ័ក្រ្ត ត្រង់កន្លែងដែលមានសាលាឃុំតាំងពីឆ្នាំ១៨៨៥មក សព្វថ្ងៃជាទីតាំងរោងចក្រទឹកកកនៅខាងជើងវត្តឧណ្ណាលោម ។

ពេលនោះពួកអាណ្ណាមបានដោះលែងព្រះអង្គឯមឲ្យមានសេរីភាព និងចាត់ទុកព្រះអង្គជាស្ដេចមួយអង្គឡើងវិញ ហើយនាំព្រះអង្គមកភ្នំពេញ រួចនាំទៅចូវដុកជាមួយនៅពេលដែលពួកគេដកថយទៅ ក្នុងក្ដីសង្ឃឹមថានឹងឲ្យព្រះអង្គប្រឆាំងនឹងព្រះអង្គឌួងដែលរាស្ត្រស្រលាញ់ចូលចិត្ត និងឲ្យព្រះអង្គ និងអ្នកដែលគាំទ្រព្រះអង្គបន្តធ្វើ

សង្គ្រាមជាមួយនឹងសៀមតទៅទៀត ។ ដើម្បីលាក់បាំងគោលបំណងអាក្រក់របស់ខ្លួន កុំឲ្យប្រជាជនមើលឃើញ ពួកអាណ្ណាមបានរៀបអាពាហ៍ពិពាហ៍ព្រះឧបរាជអង្គឯម ជាមួយអ្នកអង្គពៅ ដែលគេបានលើកឲ្យធ្វើជាឧបរាជដែរ រួចហើយរៀបអាពាហ៍ពិពាហ៍អ្នកអង្គម្ចាស់អង្គភឹម បុត្រារបស់ព្រះអង្គឯម ជាមួយព្រះក្សត្រីអង្គស្ងួន ដែលក្រោយមកបានក្លាយទៅជាមហេសីមួយអង្គរបស់ព្រះអង្គឌួង ក្រោយពីព្រះអង្គភឹមសុគតទៅ ។ ការរៀបចំទុកដាក់នេះល្អណាស់ ក៏ប៉ុន្តែមិនបានប៉ុន្មានផង ព្រះឧបរាជអង្គឯម[៧៩] ដែលប្រជាជនមិនដែលចូលចិត្តបន្តិចណាសោះតាំងតែពីយូរណាស់មកហើយ បានសុគតទៅនៅក្នុងឆ្នាំ១៨១៣ ហើយអ៊ីៗក៏ត្រូវបញ្ចប់ទៅដែរ ទុកឲ្យព្រះអង្គឌួងនៅទាមទារព្រះរាជបល្ល័ង្កតែមួយព្រះអង្គឯង ។

អត់ពីព្រះអង្គឯមទៅ ពួកអាណ្ណាមគិតថាត្រូវតែបង្ខំសភាពការណ៍ឲ្យបានឆាប់រហ័ស បើពុំនោះទេ ត្រូវធ្វើការបរបា ។ ពួកគេចាប់វាយបន្ទាយពាមមានជ័យ (បាណាម)[៨០] ដណ្តើមយកបាននៅក្នុងខែសីហា រួចហើយបានឡើងតាមទន្លេតូចមកវាយទៅលើបន្ទាយដែក ដែលព្រះរាជាកំពុងតែគង់នៅដោយគ្មានដឹងថា ពាមមានជ័យ ត្រូវអាណ្ណាមដណ្តើមយកបានទៅវិញទេ ។ ប្រយុទ្ធគ្នាអស់ពេល៣ថ្ងៃ ព្រះរាជាបានវាយដកថយជាមួយចៅឃុនបឌិនទៅភ្នំពេញវិញ ជាមួយនឹងទ័ពសៀមដែលសេសសល់ រួចគេបន្តទៅកាន់ឧត្តុង្គ ដោយបោះបង់ចោលទឹកដីមួយចំណែកធំ រួមទាំងចតុម្មុខផង ឲ្យទៅសត្រូវ ។

ឧត្តុង្គត្រូវបានរៀបចំកំផែងការពារ ក៏ប៉ុន្តែគេហាក់ដូចជាអស់សង្ឃឹមថានឹងអាចឈ្នះបានទៀតហើយណាមួយ ចៅឃុនបឌិន ដែលធ្លាប់តែមានឈ្មោះល្បីល្បាញដោយសារតែធ្លាប់ដុតបំផ្លាញរាជធានីវៀងច័ន្ទខ្ទេចខ្ទីក៏លែងមានទំនុកចិត្តលើអ៊ីៗទៀតដែរ ។ ជាថ្មីម្តងទៀតនេះ ប្រជាជនលែងមានសង្ឃឹមលើនរណាម្នាក់ទៀតហើយ ស្រាប់តែលេចដំណឹងថាទ័ពរប៉ាត់រប៉ាយ ដែលដឹកនាំដោយពួកអ្នកស្រុកដណ្តើមបានជ័យជម្នះទៅលើទ័ពអាណ្ណាមមួយកងធំនៅជិតលង្វែក ដោយសម្លាប់មេទ័ពសត្រូវបាន ហើយធ្វើឲ្យទ័ពសត្រូវនេះបាក់បែកខ្ចាត់ខ្ចាយ ។ មេទ័ពសត្រូវ ម្នាក់ទៀតត្រូវចាប់បាន ឯទ័ពដែលរត់ខ្ចាត់ខ្ចាយនោះ ត្រូវអ្នកស្រុកនាំគ្នាដេញចាប់កាប់សម្លាប់យ៉ាងរង្គាល ។

ពេលនោះបរិយាកាសសប្បាយរីករាយកើតមានពាសពេញព្រះរាជាណាចក្រ អ្នកដែលបាក់ស្មារតីក៏ចាប់មានសេចក្តីក្លាហានឡើងវិញ ។ គេនាំគ្នាចាប់កាន់អាវុធម្តងទៀត ហើយនៅទីណាដែលគេប្រទះឃើញ កងទ័ពអាណ្ណាមកំពុងតែរត់បែកខ្ញែក ប្រជាជនក៏ប្រមូលគ្នា លើកនរណាម្នាក់ឲ្យធ្វើជាមេ រួចតាមវាយពួកអាណ្ណាម

[៧៩] ទ្រង់មានព្រះជន្ម៥១ព្រះវស្សា នៅពេលដែលសុគតនោះ ។

[៨០] ស្ថិតនៅលើត្រើយទន្លេមេគង្គខាងឆ្វេង ចម្ងាយប្រហែល ៧០គីឡូម៉ែត្រ ខាងលើភ្នំពេញ ។

ដោយឥតញញើតដៃ ។ ក៏ប៉ុន្តែក្នុងចំណោមមេទ័ពដែលប្រជាជនបានលើកឲ្យធ្វើជាមេ ដោយមិនបានព្រាងទុកជាមុននេះ មានខ្លះជាមេចោរ ដែលបានជ្រើសរើសគ្នីគ្នាគេក្នុងបំណងធ្វើការឆក់ប្លន់ផងដែរ ។ ព្រះអង្គឌួង បានចេញបញ្ជាឲ្យចាប់មេទ័ពបែបនេះ២នាក់ ដែលមិនព្រមចូលខ្លួនមកបង្ហាញមុខនៅក្នុងព្រះបរមរាជវាំង ម្នាក់មានរហស្សនាមថា ចក្រីនង ម្នាក់ទៀតគេហៅថាក្រឡាហោមមួក ។ ព្រះអង្គបានកាត់ទោសឲ្យគេសម្លាប់ចក្រីនងចោលទៅ ក៏ប៉ុន្តែទ្រង់បានលើកលែងទោសឲ្យក្រឡាហោមមួក ហើយបានចាត់តាំងឲ្យទៅនៅការពារខែត្របាភ្នំ និងបន្ទាយពាមក្បាល (១៨៤៨) ។ រួចហើយព្រះរាជាបានយាងត្រលប់ចូលមកភ្នំពេញវិញ ។

នៅក្នុងឆ្នាំបន្ទាប់ ព្រះអង្គឌួងបានទទួលដំណឹងថាមន្ត្រីរបស់ព្រះអង្គម្នាក់ គឺចក្រីមី (ឬមឿន) បានដឹកនាំចលនាក្បត់មួយប្រឆាំងនឹងព្រះអង្គ ។ ទ្រង់បានចេញព្រះរាជបញ្ជាឲ្យចាប់មេក្បត់ធំៗ៧នាក់សម្លាប់ចោល អ្នកឯទៀតៗ ដែលនាំគ្នារត់គេចភៀសខ្លួនទៅ ចូវដុក ទៅជ្រកកោនជាមួយពួកអាណ្ណាម ហើយទ្រង់បានឲ្យរឹបអូសយកទ្រព្យសម្បត្តិទាំងអស់ ។

ក្នុងរយៈពេលដែលអាណ្ណាមត្រួតត្រាកម្ពុជាជាង៧ឆ្នាំនេះ គេបានសង់បន្ទាយរឹងមាំ -ប៉មច្រើនជាង ៥០កន្លែង គឺមានតាំងពីសម្បូររហូតដល់កូសាំងស៊ីន ពីស្រែអំបិល- កំពង់សោម ដែលគេបានសង់ប៉មមួយនៅលើភ្នំវត្តផុង រហូតទៅដល់ហាទៀង ដោយកាត់តាមកំពតដែលសព្វថ្ងៃមានសេសសល់បង្គោលទូរគមនាគមន៍មួយ និងស្លាកែត នៅតាមផ្លូវទៅហាទៀង ដែលគេអាចមើលឃើញលេណដ្ឋានមួយនៅឡើយ ។ បន្ទាយទាំងអស់នេះសុទ្ធតែត្រូវពួកអ្នកស្រុកវាយទៅលើ ធ្វើឲ្យទ័ពអាណ្ណាមដែលនៅខាងក្នុងភ័យញាប់ញ័ររត់គេចចេញអស់ ។

ពេលនោះព្រះអង្គឌួង និងចៅឃុនបឌិន ដោយពិនិត្យឃើញថាគ្មានអ្វីនឹងបន្តធ្វើសង្គ្រាមតទៅទៀតហើយ ដោយទ្រង់បាក់ទឹកចិត្តអស់កម្លាំងផង ក៏បានស្នើសុំចរចាសន្តិភាពជាមួយអាណ្ណាម ដែលមានអគ្គបញ្ជាការដ្ឋាននៅកំពង់ហ្លួង ។ មេទ័ពអាណ្ណាមមិនព្រមទទួលសំបុត្រដែលផ្ញើទៅឲ្យទេហើយបានដឹកនាំទ័ពធ្វើដំណើរមកកាន់ខេត្តគ្គ ។ ទ័ពខ្មែរ និងសៀមពេលនោះ បានពង្រឹងការទប់ទល់យ៉ាងស្វិតស្វាញ រហូតទាល់តែអាចបំផ្លាញរាល់ការវាយប្រហាររបស់ពួកអាណ្ណាមបាន ។ នៅពេលវាយប្រហារទៅ ពិនិត្យឃើញថាមិនអាចដណ្តើមយកជ័យជម្នះលើពួកខ្មែរ ដែលមានថាមពល និងយុទ្ធវិធីខ្ពង់ខ្ពស់បាន ពួកអាណ្ណាមដែលទើបតែប្រកែកមិនយល់ព្រមចរចាសន្តិភាព បានចាប់ផ្តើមស្នើសុំចរចាខ្លួនឯងម្តង ។ ព្រះរាជាអង្គឌួង និងចៅឃុនបឌិនបានបញ្ជូនសារលិខិតរបស់អាណ្ណាមទៅវិញ ដោយមិនមានឆ្លើយតបទេ ។ មេទ័ពអាណ្ណាមបានទទូចសុំចរចាទៀត ។ ព្រះអង្គឌួង បានឆ្លើយតបថា ព្រះអង្គនឹងជឿថា អាណ្ណាមមានបំណងចង់ចរចាពិតប្រាកដមែន តែលុះណាអាណ្ណាមយល់ព្រមបញ្ជូនព្រះរាជវង្សានុវង្សទាំងអស់ ព្រមទាំងនាម៉ឺនមន្ត្រីហើយនិងប្រជាជនខ្មែរណា ដែលអាណ្ណាមចាប់ទុកនៅសាយហ្គន ឬនៅឯរាជធានីវ៉េត្រឡប់មកវិញ ។ ក៏ប៉ុន្តែមេទ័ពអាណ្ណាមបានទូលតបមកព្រះអង្គថា ខ្លួនគ្មានអំណាចអ្វីគ្រប់គ្រាន់នឹងសម្រេចលើកិច្ចការទាំងអស់នោះបានទេ ខ្លួនគ្រាន់តែជាមេទ័ពម្នាក់ប៉ុណ្ណោះ ។ ព្រះរាជាបានយល់ព្រមធ្វើការចរចាសន្ធិសញ្ញា

សន្តិភាពជាមួយមេទ័ពអាណ្ណាម ហើយបានណាត់ជួបគ្នានៅក្នុងភូមិពពៃ បើសិនជាបន្ទាប់ពីនោះទៅស្តេចអាណ្ណាមយល់ព្រមតាមសន្ធិសញ្ញានោះដែរ ។

កិច្ចប្រជុំនោះបានប្រព្រឹត្តទៅនៅក្នុងខែធ្នូ ឆ្នាំ១៨៤៥ ដោយមានការចូលរួមអំពីចៅឃុនបឌិន និងឧត្តមសេនីយ៍អាណ្ណាមផង ។ ការចរចាបានឯកភាពគ្នាថា នឹងលើកព្រះអង្គឌួងឲ្យឡើងសោយរាជ្យជាព្រះរាជាកម្ពុជា ដោយមានការយល់ព្រមពីរដ្ឋាភិបាលសៀម និងអាណ្ណាមទាំងអស់គ្នា រួចហើយអាណ្ណាមនឹងបញ្ជូនព្រះរាជវង្សានុវង្សខ្មែរ ដែលគេបានឃាត់ទុកឲ្យវិលត្រលប់មកវិញ ជាថ្នូរនឹងឈ្លើយសឹកអាណ្ណាមទាំងនាយទាហាន និងកូនទាហាន ដែលខ្មែរចាប់បាន ។ រួចហើយគេក៏បំបែកគ្នាទៅ ។

ប៉ុន្មានសប្តាហ៍ក្រោយមក សន្ធិសញ្ញានេះបានទទួលសច្ចាប័នពីរដ្ឋាភិបាលសៀម និងអាណ្ណាម ហើយគេបានធ្វើការផ្លាស់ប្តូរឈ្លើយសឹកគ្នាទៅវិញទៅមកនៅក្នុងខែមិថុនា ឆ្នាំ១៨៤៦ ។ អាណ្ណាមបានបង្វិលព្រះខ័នរាជ្យមកភ្នំពេញថ្វាយទៅព្រះអង្គឌួង ដែលបានយកទៅរក្សាទុកនៅក្នុងដំណាក់ពិសេសមួយនៅឧត្តុង្គ ។

សិលាចារឹកមួយនៅក្នុងវត្តបារាយណ៍បាននិយាយថា "ព្រះបាទអង្គឌួងមិនបានដេញតាមកម្ចាត់កម្ចាយសត្រូវរបស់ព្រះអង្គឲ្យរលត់រលាយទាំងអស់ទេ ហើយក៏មិនយកគុណធម៌ អំណាចវិទ្យាសាស្ត្រ និងភាពល្អឥតខ្ចោះរបស់ព្រះអង្គ មកគ្របសង្កត់លើពួកនេះដែរ" ។ ព្រះអង្គបានទទួល ព្រះរាជាភិសេកនៅចុងឆ្នាំ១៨៤៧ នៅចំពោះមុខតំណាងម្នាក់ពីរាជវាំងវេ៉ គឺអុងខាំម៉ាង និងតំណាង២នាក់របស់ស្តេចសៀម គឺចៅភ្យាពេជ្រពិជ័យ និងបារគូម្នាក់មកពីបាងកក ។

មានចំណុចមួយចំនួនដែលគួរតែលើកយកមកនិយាយ ដើម្បីឲ្យឃើញនូវរបស្សូបាយដែលនគរទាំងពីរបានប្រើសម្រាប់ព្រឹត្តិការណ៍ដ៏ឱឡារិកនេះដែរ ។ ស្តេចអាណ្ណាមបានផ្ញើជាជំនូនសម្រាប់ការលើកឲ្យសោយរាជ្យនេះ នូវត្រារាង៤ជ្រុងមួយធ្វើអំពីមាស និងព្រះឋានៈថាការវមេនក្លុកវឿង (មានន័យថាព្រះរាជាកម្ពុជា) ។ ស្តេចសៀមបានបញ្ជូនមកឲ្យវិញនូវគ្រឿងឥស្សរិយយសសម្រាប់រាជបល្ល័ង្កកម្ពុជា ដែលគេបានយកទៅបាងកកកាលពីមុន រួចហើយបានសុំឲ្យព្រះអង្គឌួងអនុម័តយល់ព្រម តាមរយៈសន្ធិសញ្ញាសម្ងាត់មួយដែលចៅហ្វាយខែត្រកំពង់ស្វាយបានថ្វាយ គឺប្រគល់ទឹកដីមូលព្រៃ ទន្លេរពៅ និងទឹកដីឯទៀតៗដែលខ្មែរបានយកតាំងតែពី៣០ឆ្នាំមុនមកម្ល៉េះ ។ ព្រះរាជាបានមានព្រះបន្ទូលថា "យើងមិនយល់ព្រមប្រគល់ដីសូម្បីតែបន្តិច ទៅឲ្យពួកសៀមទេ ។ ក៏ប៉ុន្តែដោយពួកគេខ្លាំងជាង ឲ្យគេរក្សាទុកដីដែលគេបានយករួចទៅហើយ មួយរយៈទៀតសិនចុះ" ។ ចៅហ្វាយខែត្រកំពង់ស្វាយបាននាំពាក្យទៅប្រាប់ស្តេចសៀមវិញ ហើយបានចេញលិខិតមួយច្បាប់ ចុះហត្ថលេខា និងបោះត្រាខ្លួនឯង បញ្ជាក់ថាបានយល់ព្រមប្រគល់ដីដែលសៀមស្នើសុំ ក្នុងនាមព្រះរាជាកម្ពុជា ។ ខែត្រទាំង២នេះ ស្តេចសៀមបានយល់ព្រមបង្វិលមកឲ្យបារាំងតាមរយៈសន្ធិសញ្ញារវាងរដ្ឋាភិបាលបារាំង និងសៀមឆ្នាំ១៩០៤ រួចហើយបានដាក់បញ្ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាវិញនៅក្នុងឆ្នាំបន្ទាប់ ។

នៅទីបញ្ចប់ សង្គ្រាមអស់រយៈពេល៨ឆ្នាំ ដែលធ្វើឲ្យប្រជារាស្ត្ររងទុក្ខវេទនាខ្លោចផ្សាជាខ្លាំង បានធ្វើឲ្យសៀម ទទួលបានត្រលប់មកវិញនូវសិទ្ធិអធិរាជភាពមកលើកម្ពុជា ដែលគេបានបាត់បង់ទៅកាលពីឆ្នាំ១៨៣៣ និងបាន ធ្វើឲ្យកម្ពុជា ដែលមានអធិរាជត្រួតត្រាតែមួយអស់ពេលប៉ុន្មានឆ្នាំមកហើយ ហើយស្ទើរតែត្រូវអាណ្ណាមស្រូប យកបាត់ទៅ ត្រលប់មកមានអធិរាជត្រួតត្រា២សាជាថ្មីឡើងវិញ ដូចដែលមានកាលពីមុនកាលបរិច្ឆេទនេះ[៨១] ។

ក្រោយពីមានសន្ធិសញ្ញាសន្តិភាពរួចហើយ គេបានវាយកម្ទេចកំពែងការពារភ្នំពេញចោល ចំណែកដុំឥដ្ឋ និងសម្ភារផ្សេងៗដែលសេសសល់ពីកំពែងនេះ ត្រូវបានយកទៅធ្វើការសាងសង់នៅឧត្តុង្គ រួមមានវត្តវាំងចាស់ ព្រះពុទ្ធនិព្វាន ព្រះវិហារសមណៈ ប្រាង្គក្រាំងពន្លៃ សាលាគោ ជាដើម ។ គេបាននាំគ្នាលើកព្រះពុទ្ធរូប ដែលពួក អាណ្ណាមបានរុញផ្តួលទៅដី និងតុបតែងលម្អឡើងវិញ ។

ព្រះរាជា បានចេញព្រះរាជបញ្ជាឲ្យគេសាងសង់ព្រះរាជវាំងមួយថ្វាយព្រះអង្គនៅឧត្តុង្គ ។

គឺចាប់ពីមានសន្ធិសញ្ញានោះឯង ដែលប្រជាជនកម្ពុជាចាប់ផ្តើមធ្វើដំណើរចាកចេញពីបណ្តាអាណាខែត្រ នៅកូសាំងស៊ីន ដែលពួកយួនបានដណ្តើមយកពីមុន ដោយបោះបង់ដីស្រែចម្ការទុកឲ្យពួកអាណ្ណាម ពីព្រោះពួកនេះ ចេះតែចាក់រុករករឿងឈ្លោះ យប់ឡើងចេញដើរលួចឆក់ បង្កការលំបាកមិនឲ្យខ្មែររស់នៅបានសុខស្រួល ។ គ្មាន យុត្តិធម៌ចំពោះម្ចាស់ដីទេ ៖ តុលាការទទួលស្គាល់រាល់ការបំពានដណ្តើមយកដីដោយជនអាណ្ណាមម្នាក់កាលណាជន នោះបង្ហាញឲ្យឃើញថាគេជាអ្នកសាបព្រោះលើដីនៅពេលចុងក្រោយនេះ ដោយមិនគិតទេថាតើគេបានជួលដី នោះ ឬមួយក៏គេបានលួចសាបព្រោះមិនឲ្យម្ចាស់ដីដឹង បើទោះជាថាម្ចាស់ដីជាខ្មែរនោះបានភ្ជួររាស់រួចហើយ យួនមក លួចសាបក៏ដោយ ។ ដីដែលគេទុកទំនេរ កាលបើមានជនអាណ្ណាមណាម្នាក់មកកាន់កាប់តុលាការសម្រេចថា ម្ចាស់ ដើមបានបោះបង់ចោលហើយ ។ ភាពអយុត្តិធម៌នេះបានបណ្តាលឲ្យមានការសង្កត់សង្កិនគួរឲ្យភ័យខ្លាចកើតមាន ឡើង ។ មានការលួចដុត ការកាប់សម្លាប់ ការកាយភ្លឺស្រែទម្លាយ ការលែងសត្វពាហណៈ ឲ្យស៊ីបំផ្លាញភោគផល ជាដើម ដែលបន្ទាប់មកបានត្រូវចៅក្រមអាណ្ណាមដាក់ទណ្ឌកម្មជាទម្ងន់ ។ បើសិនជាគេរកជនប្រព្រឹត្តល្មើសមិន ឃើញទេ គេប្រគល់ឲ្យភូមិទាំងមូលទទួលខុសត្រូវ ។ គេចាប់មេភូមិ ចាប់ចាស់ទុំ និងកសិករសាមញ្ញ ឲ្យសងសំណង យ៉ាងធ្ងន់ធ្ងរ ឬវាយនឹងដំបងផ្តៅស្វិតរហូតដល់ស្លាប់ ។ ជួនកាលទៀត មានកើតជាការប្រយុទ្ធរវាងពួកយួន ជាមួយពួកខ្មែរទាំងហ្វូងៗ ជាហេតុធ្វើឲ្យខ្មែរមិនអាចទ្រាំបាន ក៏នាំគ្នារត់ បោះបង់ដីចោលទុកឲ្យយួន ហើយមករក

[៨១] សៀមបានទាក់ទាញយកអ្នកអង្គម្ចាស់អង្គភីម បុត្រារបស់ព្រះអង្គឯម ដែលបានប្រយុទ្ធប្រឆាំងនឹងសៀមនៅក្នុងជួរកងទ័ព អាណ្ណាមឲ្យយាងទៅបាងកក ហើយក៏រក្សាទុកនៅទីនោះទៅ ។ ធ្វើដូច្នេះ គេអាចមានមធ្យោបាយមួយនៅក្នុងដៃរបស់គេ ដើម្បីញាក់ កម្ពុជាជាបន្តទៅទៀត ។ ក៏ប៉ុន្តែចៃដន្យអាក្រក់ ក្សត្រាអង្គនេះបានធ្លាក់អាពាធ ហើយសុគតទៅនៅក្នុងឆ្នាំ១៨៤៨ ។

ជ្រកកោននៅឯកម្ពុជាវិញ ។ ពួកអាណ្ណាមបានប្តូរឈ្មោះភូមិស្រុក ដែលពួកគេបានមកតាំងនៅ រហូតទាល់តែគេភ្លេចឈ្មោះដើមជាខ្មែររបស់ភូមិស្រុកនោះអស់ ។ បើសិនជាឈ្មោះនោះមានអត្ថន័យអាចឲ្យគេបកប្រែបាន គេនឹងបកប្រែឈ្មោះ កម្ពុជា នោះ ជាហេតុធ្វើឲ្យបាត់ឈ្មោះនោះរហូតតែម្តង ។

ខែត្រព្រៃនគរគេដូរឈ្មោះទៅជា ខែត្រយ៉ាឌិញ ។ កំពាបស្រការត្រីដូរទៅជា បៀនវ៉ា, បារិយា ទៅជា បារាជ[៨២], ផ្សារដែក ទៅជា អានយ៉ាង រួចជាសាដែក, ពោធិលើ ទៅជា បាក់លីវ, ទឹកខ្មៅ ទៅជា កាម៉ៅ, បាយឆៅ ទៅជា បាយសាវ, ពាមមានជ័យ ទៅជា មីថាង, ស្រុកទ្រាំង ទៅជា សុកត្រាង, ពាមមេសែន ទៅជា ដុងណាយ ង៉ាយ, ក្រមួនស ទៅជា រ៉ាជយ៉ា, ព្រែកឫស្សី ទៅជា កាន់ថឺ, អូរមរ ទៅជា អូម៉ូន នៅក្នុងខែត្រកាន់ថឺ, កំពូលមាស ទៅជា ប៊ិញធុយ, មាត់ជ្រូក ទៅជា ចូវដុក ហើយភ្នំស្វាម ទៅជា នួយសាម, បារាជ ទៅជា ឡុងស្មៀង ឯភ្នំបាធី ទៅជា នួយបាធី ។ ខែត្រមួញខាំ ទៅជា ហាទៀង ហើយ ពាម ដែលគេហៅថា មួញខាំ ដែរ ក៏ទៅជា ហាទៀង ដែរ ។ ព្រះត្រពាំង ទៅជា ត្រាវិញ, កំពង់ឫស្សី ទៅជា បេនត្រែ, លង់ហោ ទៅជា វិញឡុង, មេសរ ទៅជា មីថ, កោះកុង ទៅជា ហ្គូកុង, កំពង់គោ ទៅជា ទ្រឿងអាញ់ សព្វថ្ងៃគឺ តាន់អាន, បានលិច ទៅជា បេនលុក, រោងដំរី ទៅជា តៃនិញ ឯភ្នំរោងដំរី ដែលគេហៅពីមុនថា ភ្នំដើងមេដែង ទៅជា ភ្នំតៃនិញ, កោះត្រឡាច ទៅជា កោះពូឡូកុងឌ័រ, កោះត្រល់ ទៅជា ភូគ្គុក, ភ្នំឃ្មួក ទៅជា នួយការ៉ុយ, ពាមជើងកញ្ជើ ទៅជា កាន់យ៉ើ (ជ្រោយសាំងហ្សាក់), ឈើទាលមួយដើម ទៅជា ធូដូម៉ូត, បន្ទាយដីឫស្សី ទៅជា ហុងង្វៀង, កំពង់កោះក្របី ទៅជា បេនង៉ែ (សាយហ្គន), ផ្សារធំ ទៅជា ចឹឡឹង តាមពាក្យចិនដែលមានន័យដូចគ្នាដែរ, កន្សែរដាក់ពាង ទៅជា បៀនវ៉ា, ដូងណាយ ទៅជា តុងថាញ់ និងដុងណាយ, កនការ ទៅជា បាថាក់ គឺជាស្រុកមួយនៅលើត្រើយទន្លេមេគង្គខាងលិច ។

នៅពេលនោះ ពួកអាណ្ណាមក៏ដូចជាពួកសៀម មិនបានបោះបង់ចោលគំនិតដែលចង់បានទឹកដីកម្ពុជាទេ ក៏ប៉ុន្តែព្រះបាទអង្គឌួង ដែលប្រកបទៅដោយប្រាជ្ញាឈ្លាសវៃ បានព្យាយាមធ្វើយ៉ាងណាមិនឲ្យពួកនោះមានឱកាសល្អឡើយ ។ ព្រះអង្គមានព្រះទ័យបារម្ភនឹងពួកសៀមតិចជាងពួកអាណ្ណាម ព្រោះទ្រង់ធ្លាប់បានស្គាល់ចិត្តសាស្ត្រ និងគម្រោងការរបស់សៀមរួចមកហើយ ឯពួកអាណ្ណាមវិញ ទ្រង់មិនទាន់យល់អំពីការគិតគូររបស់គេនៅឡើយ ម៉្លោះហើយទ្រង់បានខិតខំថ្លឹងថ្លែងអធិរាជទាំង២ ធ្វើយ៉ាងណាមិនឲ្យមានលម្អៀងនឹងគ្នាទេ ។ ពួកអាណ្ណាមបានចាត់គ្នីគ្នាគេឲ្យតាមដានព្រះអង្គជាប់ ព្រោះគេយល់ច្បាស់ណាស់ថា នៅកម្ពុជាបើគេមិនស្រលាញ់សៀមទេ គេក៏ស្អប់អាណ្ណាមណាស់ដែរ ។

---

[៨២] ពួកអេស្ប៉ាញ៉ុល និងព័រទុយហ្កេហៅថា បារីភ ជាទីដែល បេឡូសូ បានចុះចតកប៉ាល់ពេលវិលត្រលប់មកពីម៉ានីលវិញ នៅក្នុងឆ្នាំ ១៥៩៧ មុនពេលដែលមានឃាតកម្មទៅលើព្រះរាមាជើងព្រៃបន្ទិច ។

នៅក្នុងឆ្នាំ១៨៤៨ ព្រះរាជាបានបញ្ជូនអ្នកអង្គម្ចាស់ប្រទ្បីង[៨៣] និងអង្គភីម[៨៤] ដែលទើបតែគោរដុករួច កាលពីឆ្នាំមុន ហើយបានសាងផ្នូសប៉ុន្មានខែនៅក្នុងវត្តក្រាំងពន្លៃ ទៅកាន់បាងកក ។ ហេតុការណ៍នេះ បានធ្វើឲ្យស្តេចអាណ្ណាមខឹងជាខ្លាំង ។

កំហឹងនេះបានស្តែងចេញឲ្យគេឃើញតាមរយៈការលំបាកដែលពួកអាណ្ណាម បានបង្កឡើងចំពោះទូកខ្មែរ នៅពេលធ្វើដំណើរចុះឡើងតាមទន្លេ ចេញចូលកម្ពុជា ដែលត្រូវឆ្លងកាត់គយ និងការត្រួតពិនិត្យពីមន្ត្រីអាណ្ណាម ច្រើនអន្លើ ហើយក៏មានការលំបាកដែលបង្កឡើងដោយពួកពាណិជ្ជករអាណ្ណាមផងដែរ ។ នេះសឲ្យឃើញនូវឆន្ទៈរបស់ស្តេចអាណ្ណាម ដែលចង់បិទខ្មែរមិនឲ្យចេញទៅសមុទ្ររួច ហើយធ្វើឲ្យកម្ពុជាទៅជាឯកោពីពិភពលោក ។

ព្រះបាទអង្គឌួងទ្រង់គោរពបូជាសាសនាណាស់ ហើយមានចំណេះដឹងខ្ពង់ខ្ពស់លើសគេឯងនៅក្នុងព្រះរាជាណាចក្រ ។ ទ្រង់មានសុភនិច្ច័យល្អ ហើយជាមិត្តរបស់កវីបណ្ឌិតទាំងឡាយ ។ ព្រះអង្គមានគំនិតរីកចម្រើន ហើយមានគម្រោងការល្អៗ ក៏ប៉ុន្តែព្រះរាជាណាចក្រពេលនោះចុះក្រខ្សោំងពេកណាស់ទៅហើយ ប្រជាជនក៏នៅសេសសល់តិចតួច មិនអាចឲ្យទ្រង់ធ្វើអ្វីកើត ក្រៅតែអំពីស្រោចស្រង់សេវកាមាត្យជាព្រះរាជបរិពារ ព្រះរាជវាំង និងព្រះរាជវង្សានុវង្សឲ្យនៅស្ថិតស្ថេរតទៅប៉ុណ្ណោះ ។ អ្នកដែលនៅបម្រើព្រះអង្គ តាំងពីស្រីស្នំក្រមការរហូតដល់អ្នកអង្គម្ចាស់ក្សត្រី និងមហាក្សត្រីផង ទទួលបាននូវរង្វាន់ និងប្រាក់បៀវត្សយ៉ាងតិចតួចបំផុត ។ នៅពេលដែលព្រះវររាជមាតាសុគតទៅ ប្រាក់កាសដែលព្រះអង្គបានសន្សំសំចៃ មាននៅសល់ត្រឹមតែប្រាក់៦ណែន ស្មើនឹង ៤៨០ហ្វ្រង់, (សព្វថ្ងៃ គឺនៅតែ ២៣៥ហ្វ្រង់) ប៉ុណ្ណោះ ។

ព្រះរាជាបានប្រគល់ភារកិច្ចទារយកភាសីទៅឲ្យពួកចិនដែលតែងតែកេងកិប ក៏ប៉ុន្តែមិនសូវជាសង្កត់សង្កិនប្រជារាស្ត្រណាស់ណាទេ ។ ប្រាកដណាស់ថា ប្រជារាស្ត្រក្រជាងពួកមេភាសីទាំងនោះ ។

ពាណិជ្ជកម្មប្រព្រឹត្តទៅតែតាមការដោះដូរ ។ ពួកចិនយកទំនិញពីស្រុកចិន ឬពីសិង្ហបុរី មកដូរយកស្រូវ ឬស្បែកសត្វ ស្នែង ម្រ័ក្សណ៍ និងផលិតផលព្រៃឈើផ្សេងទៀត ហើយចំណេញ៥ដង ។ មនុស្សជាច្រើន

---

[៨៣] ក្រោយព្រះរាជពិធីគោរដុករួច អ្នកអង្គម្ចាស់ប្រទ្បីង បានប្តូរព្រះនាមថា ព្រះអង្គវតី ។ ក្រោយមកទ្រង់បានឡើងជាព្រះឧបរាជ មានព្រះនាមថា នរោត្តម រួចឡើងគ្រងរាជសម្បត្តិក្រោមព្រះនាមដដែលនេះ ។

[៨៤] អ្នកអង្គម្ចាស់អង្គភីម ជាបុត្រាទីពាររបស់ព្រះបាទអង្គឌួង ។ ក្រោយព្រះរាជពិធីគោរដុក ទ្រង់បានប្តូរព្រះនាមថា ស៊ីវត្ថា ជាព្រះនាមដែលគេស្គាល់ព្រះអង្គច្រើនជាងគេ ។ នៅពេលដែលព្រះរៀមនរោត្តម ឡើងសោយរាជ្យ ទ្រង់បានបះបោរប្រឆាំង ។ ទ្រង់សុគតទៅនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៨៩១ នៅភូមិភ្នំក្រែក ខាងជើងខែត្រសម្បូរ លើគ្រើយទន្លេមេគង្គខាងស្តាំ ជាទីកន្លែងដែលព្រះអង្គបានគង់នៅជាមួយបក្សពួកជាង ២០ឆ្នាំមកហើយ ។

បានស្លាប់ទៅដោយមិនដែលមានប្រាក់មួយកាក់សោះក្នុងហោប៉ៅ ធ្លាប់ស្គាល់តែប្រាក់កាក់ធ្វើពីស័ង្កសី[៨៥] ដែលគេបោះនៅ អាណ្ណាម មានរន្ធ៤ជ្រុងនៅកណ្តាល និងមានអក្សរចិននៅពីលើ ។ មាសដែលមានតែបន្តិចបន្តួច គេយកទៅធ្វើជាគ្រឿងអលង្ការសម្រាប់ពួកមន្ត្រី និងភរិយា និងធ្វើប្រអប់ស្លាដែលជាសញ្ញាបញ្ជាក់អំពីអំណាចអស់ទៅហើយ ។ គេលែងយកសន្លឹកមាសដែលពួកចិនកិនឲ្យសំប៉ែតរួចកាត់ជារាងការ៉េមានជ្រុង ប្រវែងប្រហែល ៣សង់ទីម៉ែត្រ ហើយលក់ថ្លៃណាស់ មកស្រោបព្រះពុទ្ធបដិមាទៀតហើយ ។ កាលពីមុន គេធ្លាប់ឃើញមន្ត្រីធំម្នាក់ ឬស្ត្រីដែលគោរពបូជាព្រះពុទ្ធសាសនា ចំណាយថវិកាផ្ទាល់ខ្លួនទិញមាសសន្លឹកនោះយកមកស្រោបព្រះពុទ្ធបដិមាធំៗ ។ ឥឡូវនេះគ្មានអ្នកណាមានសមត្ថភាពធ្វើដូច្នេះបានទេលើកលែងតែព្រះរាជា ។ អ្នកដែលគោរពបូជាព្រះពុទ្ធសាសនាខ្លាំង គេអាចធ្វើបានត្រឹមតែយកសន្លឹកមាសតូចៗមកស្រោបពីលើទ្រូងព្រះពុទ្ធរូប ហើយដល់យូរៗទៅទើបព្រះពុទ្ធរូបនោះអាចត្រូវបានស្រោបជុំជិត ដោយមានអ្នកឯទៀតៗ បេះតែយកសន្លឹកមាសមកស្រោបតៗគ្នា ។ កម្ពុជាលែងជាប្រទេសមួយសម្បូរសប្បាយ មានកេរ្តិ៍ឈ្មោះល្បីសុះសាយរហូតទៅដល់ស្រុកចិនដូចពីមុនទៀតហើយ ។ សង្គ្រាមជាមួយបរទេស ជាពិសេស គឺសង្គ្រាមរវាងគ្នាឯងនឹងគ្នាឯង បានធ្វើឲ្យប្រទេសហិនហោចទៅៗ ៖ គេបាននាំយកភោគផលទាំងអស់របស់កម្ពុជា យកមាសប្រាក់ទាំងអស់ ព្រមទាំងប្រជាជនផងទៅកូសាំងស៊ីន ទៅស្រុកសៀម បន្សល់ទុកនៅតែអ្នកស្រុកស្គាំងស្គម ទីទ័លក្រនៅលើដីដែលខ្សោះអ្វីៗអស់ទៅហើយ អ្នកទាំងអស់នោះភ័យខ្លាចតែពួកសៀម ឬអាណ្ណាមលេចខ្លួនមកទៀត កាប់សម្លាប់ប្រជាជន រំលោភនារីមេម៉ាយ និងកុមារី[៨៦] ដុតបំផ្លាញវត្តអារាម ផ្ទះសម្បែង កាប់ដើមឈើស៊ីផ្លែ និងដើមត្នោតចោល រួចដុតភូមិទាំងមូល មុននឹងកៀរអ្នកស្រុកយកទៅជាឈ្លើយ ទាំងពាន់ៗនាក់ ។

ព្រះបាទអង្គឌួង នៅពេលដែលអស់រតនសម្បត្តិហើយនៅសល់តែពន្ធអាករដែលប្រមូលបានពីពួកខ្ញុំ ទ្រង់ស្ទើរតែមិនអាចស្តារព្រះរាជាណាចក្រ និងប្រជារាស្ត្រ ឲ្យងើបក្រោកឈរឡើងវិញបានទេ ។ ដោយពួកអាណ្ណាមដែលកាន់កាប់ទឹកដីកូសាំងស៊ីន នៅលើទន្លេមេគង្គខាងក្រោម កាត់ផ្តាច់រារាំងមិនឲ្យកម្ពុជា ធ្វើដំណើរចុះទៅសមុទ្របាន ទ្រង់ក៏សម្រេចព្រះរាជហឫទ័យ បើកច្រកមួយចេញទៅខាងឈូងសមុទ្រសៀមវិញ ដើម្បីអាចដឹកផលិតផលដែលបានមកពីពន្ធអាករជាវត្ថុយកទៅក្រៅបាន ហើយរក្សាបាននូវទំនាក់ទំនងជាមួយពិភពលោក ។ ព្រះអង្គបានជ្រើសរើសយកកំពង់ផែកំពត រួចហើយទ្រង់បានឲ្យគេធ្វើសំពៅសមុទ្រធំមួយ ប្រគល់ឲ្យជនជាតិម៉ាឡេម្នាក់ ដែល

---

[៨៥] ដើម្បីឲ្យបានមួយ ពីយ៉ាសមិុកស៊ីក (លុយជំនាន់ដើម) ដែលមាន២៩ក្រាមជាប្រាក់សុទ្ធ គេត្រូវការកាក់៦ចង្កោម មានទាំងអស់ ៣៦០០កាក់ ។

[៨៦] ពួកសៀមច្រើនរំលោភតែស្រីក្រមុំ និងមេម៉ាយ ម៉្លោះហើយ កាលណាមានទ័ពសៀមចូលមក គេនាំគ្នាប្រញាប់ប្រញាល់រៀបចំការកូនស្រីឲ្យហើយ ។ ពួកអាណ្ណាមមិនសូវជាអាក្រក់ពេកទេ ។

ជាអ្នកដើរសមុទ្រដ៏ពូកែ ស្គាល់សិង្ហបុរី ស្គាល់កំពង់ផែទាំងឡាយនៅឡើបកោះម៉ាឡាកា និងសៀម ច្បាស់ ។ រួចហើយ ដើម្បីតភ្ជាប់កំពង់ផែនេះនឹងរាជធានីឧត្តុង្គ ទ្រង់បានឲ្យគេសង់ផ្លូវវែងមួយចម្ងាយ១៨០គីឡូម៉ែត្រ មានស្ពានធ្វើអំពីឈើ និងសាលាសំណាក់សង់នៅក្បែរត្រពាំងមួយ និងដាក់បង្គោលគីឡូម៉ែត រួចទ្រង់ប្រគល់ឲ្យភូមិដែលនៅក្បែរៗផ្លូវនោះមើលថែរក្សាឲ្យបានល្អ និងឲ្យផ្លាស់វេនគ្នាយាមសាលាសំណាក់ ដើម្បីបម្រើអ្នកធ្វើដំណើរ ។

ព្រះអង្គ ក៏បានចំណាយថវិកាឲ្យគេលើកដីសង់ផ្លូវពីរាជវាំងឧត្តុង្គ មកកាន់កំពង់ហ្លួង ផងដែរ ។

ក៏ប៉ុន្តែគួរឲ្យស្តាយណាស់ ពីព្រោះប្រភពធនធានរបស់ព្រះអង្គពេលនោះមានកំណត់ ។ នៅតាមបណ្តាខែត្រជាច្រើន គេមិនដែលបានធ្វើកំណែនប្រជាជនឲ្យធ្វើពលកម្មដោយទៀងទាត់ អស់ជាច្រើនឆ្នាំ ច្រើនសតវត្សរ៍មកហើយ ម្ល៉ោះហើយនៅពេលដែលមានកំណែនម្តងៗ អ្នកស្រុកមិនចង់ចូលរួមទេ ហើយអាជ្ញាធរក៏មិនសូវហ៊ានបង្ខិតបង្ខំប៉ុន្មានដែរ ។ ការមិនចូលរួមរបស់ប្រជាជននេះបានធ្វើឲ្យរាំងស្ទះដល់គម្រោងការរបស់ព្រះរាជាបង្ខំឲ្យទ្រង់កាត់បន្ថយគម្រោងផែនការសាងសង់ផ្លូវ ស្ពាន ដែលព្រះអង្គបានសន្យាថានឹងធ្វើ ដើម្បីទុកជាកេរ្តិ៍ដំណែលជូនប្រជាជនពេលអត់ពីព្រះអង្គទៅ ។

ដោយទ្រង់មិនអាចកសាងអ្វីបានដោយសារខ្វះថវិកា ព្រះអង្គក៏មិនអាចរៀបចំអំណាចរាជាធិបតេយ្យឡើងវិញបានដែរ ពីព្រោះថាកម្ពុជាពេលនោះបាក់បែកខ្ទេចខ្ទាំខ្ទាំងណាស់ ព្រះអង្គបានបែរទៅធ្វើកំណែទម្រង់ផ្សេងៗវិញ ។ មុនដំបូងទ្រង់បានសើរើពិនិត្យច្បាប់ឡើងវិញ កែសម្រួលជាច្រើន ហើយបានចេញព្រះរាជក្រឹត្យបំពេញបន្ថែម ។ ព្រះអង្គបានបង្កើតសាលាឧទ្ធរណ៍តាំងពីឆ្នាំ១៨៤៧ ដែលព្រះអង្គបានយាងទៅចូលរួមផ្ទាល់ព្រះអង្គផង បើសិនជាចាំបាច់ ។ ទ្រង់បានទទួលការយល់ព្រមពីព្រះសង្ឃក្នុងការរៀបចំកម្មវិធីសិក្សាឲ្យបានល្អប្រសើរជាងមុន ហើយវត្តនីមួយៗមានសិស្សយ៉ាងច្រើនមកសិក្សា ។ ព្រះអង្គបានដកអ្នកល្ងង់ខ្លៅ និងអ្នកគ្មានសមត្ថភាពចេញពីកិច្ចការរាជការ ហើយបានបដិសេធជំនូនផ្សេងៗ ដែលពួកចៅហ្វាយខែត្រតែងតែថ្វាយព្រះរាជា នៅពេលដែលទ្រង់ប្រទានត្រា ។ ទ្រង់ម៉ឺងម៉ាត់ណាស់ចំពោះអ្នកណាដែលបំពានច្បាប់ ហើយបានដាក់ទោសធ្ងន់ៗ ដល់មន្ត្រីធំណាដែលមិនព្រមគោរពព្រះរាជបញ្ជា ។ ក៏ប៉ុន្តែព្រះអង្គប្រកបទៅដោយយុត្តិធម៌ មានព្រះទ័យល្អចំពោះអ្នកក្រីក្រ ទ្រង់មានអំណត់អត់ធន់ចំពោះអ្នកទាំងនោះ លើកលែងតែការប្តឹងផ្តល់ដែលធ្វើឡើងមិនត្រឹមត្រូវ សរសេរមិនត្រូវតាមក្បួនខ្នាត នោះព្រះអង្គមិនអត់ឱនឲ្យទេ ពីព្រោះព្រះអង្គមិនចង់ឲ្យសរសេរចម្លងតាមតែគ្នា មិនច្បាស់លាស់ ចង់ប្តឹងផ្តល់ត្រូវរត់ទៅរកអ្នកចេះដឹងឲ្យគេសរសេរពាក្យឲ្យ ។

ព្រះអង្គបានហាមប្រាមមន្ត្រីរាជការមិនឲ្យផឹកសុរា អ្នកណាជក់អាភៀនត្រូវបណ្តេញចោល ទ្រង់តឹងតែងត្រង់ចំណុចនេះរហូតទាល់តែគ្មានមន្ត្រីណាម្នាក់ជក់អាភៀនទេ នៅក្នុងរជ្ជកាលរបស់ព្រះអង្គ ។ ទ្រង់បានហាមមិនឲ្យធ្វើធ្នស់បិទជិតស្ទឹងទេ ដើម្បីឲ្យមានត្រីមួយចំនួនរួចផុតពីអ្នកនេសាទ និងដើម្បីឲ្យត្រីអាចធ្វើចរាចរទៅមកបានផង ។ តាមស្មារតីគោរពព្រះពុទ្ធសាសនា ទ្រង់ក៏បានហាមប្រាមការបរបាញ់សត្វផងដែរ ។

នៅក្នុងឆ្នាំ១៨៤៨ ទ្រង់បានសម្រេចប្តូរពិធីការឲ្យគេហៅព្រះរាជាថា "ព្រះករុណាពិសេស" និង"អង្គម្ចាស់ជីវិតលើត្បូង"វិញ ។ ព្រះរាជមាតាទទួលព្រះឋានៈថាព្រះវររាជជននី ហើយទ្រង់មានត្រាមួយមានរូបកិន្នរីផង ។ ព្រះរាជបុត្រីច្បង ព្រះអង្គថ្វាយព្រះឋានៈថាសម្តេចព្រះរាជធីតា ព្រះជាយារបស់ព្រះអង្គ អ្នកម្នាងប៉ែន ដែលជាមាតារបស់ព្រះរាជបុត្រាច្បង ទ្រង់បានលើកឲ្យឡើងជាព្រះជាតិក្សត្រី ។ អ្នកម្នាងពៅ មាតារបស់ព្រះរាជបុត្រាបន្ទាប់ ទ្រង់លើកឲ្យឡើងជាព្រះអគ្គរាអក្សរ ។ រួចហើយទ្រង់បានរៀបចំព្រះរាជសង្ហារសម្គាល់អ្នកទាំងអស់នោះ ព្រមទាំងពាក្យពេចន៍ដែលត្រូវប្រើផង គឺឆ្លើយថាព្រះបាទម្ចាស់ចំពោះបុរសៗ និងព្រះម៉ែចំពោះនារីៗ ។ ទ្រង់ក៏បានរៀបចំឋានៈស្ត្រីៗនៅក្នុងព្រះបរមរាជវាំងផងដែរ ហើយបានសម្រេចឲ្យហៅភរិយារបស់មន្ត្រីសក្តិ៤ ដល់សក្តិ១០ថាជំទាវ ហើយបានអនុញ្ញាតឲ្យអ្នកទាំងនោះបង់កន្សែងពណ៌ ពាក់រយ៉ាមាស ដោតផ្កាលើសក់ ហើយមានប្រអប់ស្លាដូចរបស់ប្តីដែរ នៅពេលចូលមកក្នុងវាំង ។

ព្រះអង្គបានឲ្យកាត់បន្ថយក្បួនដង្ហែមន្ត្រីធំៗ ហើយចេញបញ្ជាឲ្យពួកមន្ត្រីទាំងនោះត្រូវស្លៀកខោវែងធំទូលាយមានជរមាសឬស្លៀកសំពត់សូត្រ នៅក្នុងពេលមានពិធីផ្សេងៗ ពាក់អាវពណ៌ ក្រវាត់ក្រណាត់ប៉ាក់ឌិនពណ៌មាស ក្រវាត់ដាវនៅចង្កេះ ទោណាមកណាជិះគ្រែស្នែង បាំងក្លស់ពណ៌ក្រហម១ជាន់ ។

ការកែទម្រង់នេះមើលទៅដូចជារឿងកំប៉ិកកំប៉ុកទេ ក៏ប៉ុន្តែត្រូវបានគេអបអរសាទរណាស់ ព្រោះវាបានជួយរៀបចំឲ្យព្រះរាជវាំងរបស់ព្រះរាជាកម្ពុជាមានរបៀបរបបឡើងវិញ និងជួយស្តារកិត្តិនាមដែលបានបាត់បង់អស់កាលជាយូរណាស់មកហើយ នៅចំពោះមុខប្រជារាស្ត្រ ។

នៅក្នុងឆ្នាំ១៨៤៩ ជំងឺប៉េស្ត បានកើតរាលដាលយ៉ាងខ្លាំង ក្នុង១ថ្ងៃៗមានមនុស្សនៅជុំវិញរាជធានីឧត្តុង្គស្លាប់រហូតដល់ទៅ៥រយនាក់ ។ ជំងឺនេះរាតត្បាតអស់ពេល៣ខែ បន្ទាប់មកក៏រលាយបាត់ទៅវិញ នៅក្នុងរដូវវស្សា ។

ក្នុងឆ្នាំនោះដែរ ដោយមានមេត្តាធម៌ដល់ប្រជារាស្ត្ររបស់ព្រះអង្គ ទ្រង់បានបញ្ជាឲ្យគេសង់សាលាឆទាន ដើម្បីទ្រង់បានយាងទៅចែកបាយសម្ល និងក្រមាដល់អ្នកបួស និងទុគ៌តជន ។

ព្រះអង្គបានរៀបចំខែត្រសាជាថ្មី ខែត្រណាធំទ្រង់ឲ្យចែកជា២ ឬ៣ ឬ៤ស្រុក ។ រួចហើយទ្រង់បានដាក់ឲ្យស្ថិតនៅក្រោមឱវាទមន្ត្រីធំៗត្រួតត្រា ។

ព្រះអង្គបានកំណត់កាលបរិច្ឆេទព្រះរាជពិធីទ្វារទសមាសទាំង១៧ ហើយបានឲ្យយកចិត្តទុកដាក់គោរពថ្ងៃសីល និងសិក្ខាបទ ។

នៅក្នុងឆ្នាំ១៨៥៣ ព្រះរាជាមានបំណងផ្លាស់ប្រាក់បាតថ្ងៃដែលចេះតែក្រទៅៗចេញ ហើយបានឲ្យបោះពុម្ពកាក់សំប៉ែតជាប្រាក់សុទ្ធ៣ប្រភេទ ដែលមានតម្លៃនៅពេលនោះស្មើនឹង៤ហ្វ្រង់ ១ហ្វ្រង់ និង៥កាក់ ។ នៅលើមុខម្ខាង មានរូបហង្សកវែងដូចរូបហង្ស ដែលគេតែងតែដាក់នៅលើចុងដងទង់ខាងមុខព្រះវិហារ ។ នៅលើ

មុខម្ខាងទៀត មានរូបប្រាសាទបុរាណកំពូល៣ ដែលតំណាងអង្គរវត្ត ។

បើតាមសម្ដីមន្ត្រីចាស់ម្នាក់ដែលព្រះរាជាខស្សហ៍ពិគ្រោះយោបល់ បាននិយាយប្រាប់ខ្ញុំថា មើលពីខាងក្រៅគេឃើញ ព្រះរាជា ដូចជាសប្បាយរីករាយណាស់ ក៏ប៉ុន្តែក្នុងព្រះហឫទ័យរបស់ព្រះអង្គវិញ ទ្រង់ដូចជាគ្មានទំនុកចិត្តចំពោះអនាគតកាលសោះ ម្យ៉ាងទ្រង់ខ្លាចពួកសៀមដែលព្រះអង្គចាត់ទុកដូចជាសត្រូវ[៨៧] ស្មើរតែដូចពួកអាណ្ណាម ដែលព្រះអង្គស្អប់ខ្ពើមណាស់អីចឹងដែរ ។ ពួកអាណ្ណាមនេះមានទំនៀមទម្លាប់ សាសនា សម្លៀកបំពាក់សក់បួង និងទម្លាប់ផ្សេងៗ ដែលព្រះអង្គមិនចូលចិត្តសោះ ណាមួយពួកនេះឈ្លានពានអាណាខែត្រភាគខាងត្បូងឥតឈប់ឈរផង ។ ព្រះអង្គជាអ្នកគាំទ្រសន្តិភាព មិនចូលចិត្តសង្គ្រាម ព្រោះទ្រង់ឈ្វេងយល់ថាសង្គ្រាមមិនអាចដណ្ដើមយកខែត្រដែលបាត់បង់ទៅនោះមកវិញបានទេ ។ ក៏ប៉ុន្តែ ដើម្បីរារាំងសត្រូវកុំឲ្យចូលមករុកគួនព្រះរាជាណាចក្រ ទ្រង់បានបញ្ជាឲ្យគេសង់បន្ទាយការពារជាច្រើន ។ ព្រះអង្គបានមានព្រះបន្ទូលថា «មិនត្រូវគិតពីរឿងដណ្ដើមយកអ្វីដែលបាត់បង់ទៅហើយមកវិញទេ ប៉ុន្តែត្រូវការពារអ្វីដែលនៅសល់ឲ្យបាន» ។ ព្រះអង្គបារម្ភណាស់ចំពោះអនាគត ហើយបានពិភាល់ថាកម្ពុជានឹងត្រូវបែងចែកគ្នារវាងសៀម និងអាណ្ណាម ។ ពួកសៀមនឹងយកទឹកដីពោធិសាត់ កំពង់ស្វាយ ខត្តុគ្គ សម្បូរ ក្រចេះ ត្បូងឃ្មុំ ឯអាណ្ណាមវិញនឹងយកអាណាខែត្រខាងត្បូងទាំងអស់រួមមាន បាភ្នំ ទ្រាំង ភ្នំពេញ ផង ។ បើសិនជាមានសង្គ្រាមមួយផ្ទុះឡើង ទោះជាជាមួយ សៀម ឬជាមួយកូសាំងស៊ីនក៏ដោយ ក៏សង្គ្រាមនោះនឹងធ្វើឲ្យការបែងចែកទឹកដីគ្នានេះកើតមានកាន់តែឆាប់ ម្ល៉ោះហើយព្រះអង្គមិនចង់ឲ្យកើតមានសង្គ្រាមជាមួយនរណាម្នាក់ទេ ។

គំនិតដែលគិតថាថ្ងៃណាមួយ ជាពិសេសកាលណាអត់ពីព្រះអង្គទៅកម្ពុជាអាចនឹងត្រូវបាត់បង់ នៅជិតជាប់នឹងព្រះទ័យរបស់ព្រះអង្គជានិច្ច ហើយបានធ្វើឲ្យព្រះអង្គគិតរកទៅរកសុំជំនួយការពារពីប្រទេសអឺរ៉ុបណាមួយដើម្បីផ្ទើរវាសនាស្រុកខ្មែរ និងសន្តតិវង្សព្រះរាជា វិញម្ដង ។ គំនិតសុំជំនួយរបស់ព្រះអង្គពេលនោះ មិនមែនជាការសុំអាណាព្យាបាលក្នុងន័យដូចដែលយើងយល់សព្វថ្ងៃនេះទេ គឺសុំឲ្យការពារព្រះរាជាណាចក្រកុំឲ្យនគរផ្សេងដណ្ដើមយកបាន ទោះជានៅក្នុងអាស៊ី ឬក៏នៅអឺរ៉ុបក្ដី ។

ទ្រង់បាននឹកគិតទៅដល់ប្រទេសបារាំង ដែលមិនទាន់មានដែនដីជាកម្មសិទ្ធនៅចុងបូព៌ានៅឡើយ ហើយដែលព្រះអង្គធ្លាប់បានឮល្បីកិត្តិនាមកាលពីពេលដែលព្រះអង្គគង់នៅឯរាជធានីបាងកក ។ ដល់មកខែវិច្ឆិកា ឆ្នាំ

[៨៧] ទ្រង់ខ្លាចរអាពួកសៀម ព្រោះថា ព្រះអង្គមិនអាចតែងតាំងរដ្ឋមន្ត្រីណាម្នាក់ដោយគ្មានការអនុញ្ញាតពីស្ដេចសៀមបានទេ ។ ជាក់ស្ដែង គឺនៅក្នុងឆ្នាំ១៨៤៨ ព្រះអង្គបានបញ្ជូនខកញ៉ាចក្រី និងខកញ៉ាក្រឡាហោម ទៅស្រុកសៀម ដើម្បីសុំការឯកភាពពីស្ដេចសៀម តែងតាំងជាចៅហ៊្វាទល្ហៈ និងជាសម្ដេចចៅពញា តែស្ដេចសៀមក្នុងនាមជាស្ដេចអធិរាជ បែរជាតែងតាំងមន្ត្រី២រូបពីខែត្របាត់ដំបង ឲ្យទទួលតួនាទីនេះ ជំនួសវិញ ។

១៨៥៣ ក្រោយពីបានពិចារណាល្អិនល្អន់រួចហើយ ព្រះបាទអង្គឌួងបានចាត់បច្ចាញាតិ២រូបរបស់ពួកព័រទុយហ្គេ ដែលកាន់សាសនាកាតូលិក គឺចៅពញាកុយ និងចៅពញាប៉ែន ឲ្យធ្វើដំណើរជាសម្ងាត់ទៅសិង្ហបុរី នាំយកសារលិខិត សរសេរជាភាសាបារាំងដោយព្រះសង្ឃកាតូលិក (អេវ៉ែក) នៅកម្ពុជាឈ្មោះ មីសួ តាមសម្ដីរបស់ព្រះអង្គ ទៅប្រគល់ជូនកុងស៊ុលបារាំងនៅទីនោះ ឲ្យផ្ញើបញ្ជូនបន្តទៅថ្វាយព្រះចៅអធិរាជណាប៉ូឡេអុងទី៣ «ដើម្បីសុំដែងមិត្តភាព និងការគោរពដ៏ជ្រាលជ្រៅពីព្រះអង្គ» ។ ជាប់ជាមួយនឹងសារលិខិតនេះមានវត្ថុអនុស្សាវរីយ៍ជាច្រើនហិប រួមមានភ្លុកដំរីធំ១៤ កុយរមាស២ ជ័រវល្លិ៍/បារទម្ងន់៣០០គីឡូក្រាម ស្កររ៧/បារទម្ងន់ ៣០០គីឡូក្រាម និងម្រេច៧/បារទម្ងន់ ៣០០គីឡូក្រាមផងដែរ ។ កុងស៊ុលបារាំងប្រចាំសិង្ហបុរីបានទទួលយកព្រះសារលិខិត និងអំណោយទាំងអស់ពីទូតទាំង២ រួចបានផ្ញើសារឆ្លើយតបមកព្រះបាទអង្គឌួងវិញថាខ្លួននឹងផ្ញើព្រះរាជសារ និងអំណោយ ទាំងអស់ទៅប្រទេសបារាំងតាមនាវាចម្បាំងក្ដោង៣ឈ្មោះ ឡាកាព្រីស៊ីយ៉ឺ មានវរសេនីយ៍ត្រី រ៉ូគឺម៉ូរ៉ែល ជាមេបញ្ជាការ ដែលនឹងនាំរបស់ទាំងអស់នេះទៅសាលាខែត្រទូឡុង ក្លាមនៅពេលដែលកប៉ាល់ទៅដល់ ដើម្បីឲ្យបញ្ជូនបន្តទៅថ្វាយព្រះចៅអធិរាជ (១៨៥៤) ។

នៅឆ្នាំបន្ទាប់មក លោក ដឺម៉ុងទីញី បេសកជនរបស់បារាំងប្រចាំស្រុកសៀម និងស្រុកចិនបានទទួលបញ្ជាឲ្យមកចុះសន្ធិសញ្ញាមេត្រីភាព និងពាណិជ្ជកម្មមួយជាមួយព្រះរាជាកម្ពុជាតាមបំណងប្រាថ្នារបស់ព្រះបាទអង្គឌួង ។ ឯកអគ្គរាជទូតនេះទើបតែបានចុះសន្ធិសញ្ញាពាណិជ្ជកម្មមួយជាមួយស្ដេចសៀម ព្រះមហាមង្គុត ដែលថ្វាយដំណឹងតាមរយៈ អេវ៉ែកមីសួ តាំងពីខែឧសភា ថានឹងមកកម្ពុជាឆាប់ៗនេះ តែបានប្រហែសនិយាយប្រាប់គេឯងនៅបាងកកឲ្យដឹងពីគម្រោងការថានឹងមកចុះសន្ធិសញ្ញាជាមួយព្រះបាទអង្គឌួង ។ ដំណឹងនេះបានលេចឮទៅដល់ស្ដេចសៀមៗមិនយល់ព្រមឲ្យកម្ពុជាដែលទ្រង់ចាត់ទុកជានគរសាមន្តរាជមួយ អាចចុះសន្ធិសញ្ញាណាមួយបានដោយគ្មានការឯកភាពពីព្រះអង្គទេ ។ ស្ដេចសៀមបានចាត់មន្ត្រីម្នាក់ឲ្យចុះកប៉ាល់ជាមួយលោក ដឺម៉ុងទីញី ជាសម្ងាត់ ដើម្បីត្រួតពិនិត្យមើលសកម្មភាពរបស់រាជទូតបារាំងនេះផង និងដើម្បីនាំសារណែនាំមួយមកថ្វាយព្រះរាជាកម្ពុជាផង ដែលអ្នកខ្លះនិយាយថាគឺជារាជសារហាមឃាត់មិនឲ្យព្រះអង្គធ្វើអ្វីជាមួយបារាំង ។ លោក ដឺម៉ុងទីញី បានឡើងកប៉ាល់មកចុះនៅកំពត នៅក្នុងខែសីហា ឆ្នាំ១៨៥៦ ។ រាជសាររបស់ស្ដេចសៀមពោរពេញទៅដោយពាក្យគំរាមកំហែង ដែលធ្វើឲ្យព្រះបាទអង្គឌួងវិតក្កយ៉ាងខ្លាំង ។ ទ្រង់មានបំណងចង់ចុះសន្ធិសញ្ញាជាមួយបារាំងជាសម្ងាត់សិន កាលណាបានសច្ចានុមតិរួចហើយសឹមផ្សព្វផ្សាយឲ្យគេដឹងឮ នៅពេលនោះទ្រង់នឹងគ្មានបារម្ភអំពីសៀមឬអាណ្ណាមទៀតទេ ព្រោះបានទទួលការការពារពីប្រទេសអឺរ៉ុបមួយរួចហើយ ។ ក៏ប៉ុន្តែឥឡូវ ព្រះរាជបំណងនេះបានត្រូវគេដឹងមុនអស់ទៅហើយនៅបាងកក តាំងពីមុនពេលដែលរាជទូតបារាំងចេញដំណើរមកម្ល៉េះ ។ ឯកអគ្គរាជទូតបារាំងអាចនឹងកាត់បន្ថយប្រសិទ្ធភាពនៃការគំរាមកំហែងរបស់ស្ដេចសៀមមកលើព្រះរាជាកម្ពុជា ហើយជួយរំងាប់ការព្រួយបារម្ភរបស់ព្រះបាទអង្គឌួងបាន

ដោយធ្វើដំណើររហូតមកដល់ខុត្តុង្គ រួចហើយរាយការណ៍ថ្វាយអំពីអំណាចដ៏ខ្លាំងក្លារបស់បារាំង ។ ក៏ប៉ុន្តែផ្ទុយទៅវិញ លោក ដឺម៉ុងទីញី ដែលមិនបានយល់ច្បាស់អំពីល្បិចកលរបស់សៀមមកលើព្រះរាជាកម្ពុជាមានការប្រហែស បែរទៅជាមិនចង់ធ្វើដំណើរលើផ្លូវដ៏ឆ្ងាយចម្ងាយជាង១៤០គីឡូម៉ែត្រ កាត់ទីរហោឋានតាមដែលគាត់ពុំគេនិយាយប្រាប់ទេ ។ គាត់ឈប់នៅនឹងកំពត ហើយបានចាត់ព្រះសង្ឃកាតូលិក (អាបេ) ហេ ស្រ្តិស ដែលអេវ៉េកមីស្ហ ទើបនឹងតែងតាំងមកឈរជើងនៅទីនេះ ឲ្យនាំយកសន្ធិសញ្ញាពាណិជ្ជកម្មមួយ ចម្លងតាមសន្ធិសញ្ញាដែលបានចុះជាមួយសៀម មកថ្វាយព្រះបាទអង្គឌួងឡាយព្រះហស្តលេខា ។ សន្ធិសញ្ញានោះ គ្មានអត្ថន័យគ្រប់គ្រាន់សមតាមបំណងរបស់ព្រះបាទអង្គឌួងទេ ព្រោះមិនមែនជាសន្ធិសញ្ញាមេត្រីភាពដែលទ្រង់ចង់បាន ហើយក៏មិនបានធានាអត្ថិភាពរបស់កម្ពុជា ក្រោមអាណាព្យាបាលភាពរបស់ប្រទេសបារាំងដែរ បើទោះជាថា មានតែក្នុងពាក្យសម្តីក៏ដោយចុះ ។ ព្រះបាទអង្គឌួងបានឲ្យគេសង់ផ្ទះសំណាក់មួយសម្រាប់ទទួលលោក ដឺម៉ុងទីញី នៅកំពត ហើយទ្រង់រង់ចាំទទួលគាត់នៅខុត្តុង្គ ។ ព្រះអង្គខកព្រះទ័យជាខ្លាំងនៅពេលឃើញកូនសង្ឃកាតូលិកតូចមួយ មកចូលគាល់ព្រះអង្គទៅវិញ ជាជាងបានឃើញឯកអគ្គរាជទូតដែលព្រះអង្គកំពុងតែរង់ចាំទាំង អេវ៉េកមីស្ហ ក៏មិនយល់ស្របតាមដែរ ម្ល៉ោះហើយទ្រង់បានប្រកែកមិនយល់ព្រមចុះហត្ថលេខាលើសន្ធិសញ្ញា ដែលគ្មានកិច្ចធានាអ្វីបន្តិចសោះនោះទេ មិនតែប៉ុណ្ណោះថែមទាំងធ្វើឲ្យព្រះអង្គមានការប៉ះទង្គិចយ៉ាងខ្លាំង ជាមួយពួកសៀមទៀតផង ។

ភាពខ្វះការប៉ិនប្រសប់ និងការធ្វេសប្រហែសរបស់ឯកអគ្គរាជទូតនៃព្រះចៅអធិរាជបារាំងបានធ្វើឲ្យព្រះរាជាកម្ពុជាជួបប្រទះនឹងការលំបាកយ៉ាងខ្លាំងដែលព្រះអង្គកំពុងតែខ្លាចរអាផង ហើយក៏ធ្វើឲ្យបារាំងបាត់បង់ឱកាសក្នុងការដាក់អាណាព្យាបាលមកលើកម្ពុជាតាំងពីឆ្នាំ១៨៥៦ គឺនៅមុនសង្រ្គាមឥណ្ឌូចិនជាច្រើនឆ្នាំ ។ ប្រសិនបើបារាំងបានដាក់អាណាព្យាបាលមកលើកម្ពុជាតាំងតែពីពេលនោះមក បារាំងអាចប្រើកម្ពុជាធ្វើជាមូលដ្ឋានសម្រាប់ប្រតិបត្តិការ ដែលនឹងផ្តល់ការងាយស្រួលជាច្រើនដល់សង្រ្គាមនោះ ។ ហើយបើសិនណាជាបារាំងបានមកឈរជើងនៅកម្ពុជា ហើយធ្វើសកម្មភាពដោយមានការគាំទ្រពីព្រះរាជាកម្ពុជាផងនោះ ម្ល៉េះសមបារាំងអាចដណ្តើមយកកូសាំងស៊ីនទាំងមូលបានក្នុងពេលតែមួយជាមួយគ្នាទៅហើយ ។

ពេលនោះមានការបះបោរមួយរបស់អ្នកស្រុកនៅរលាប្អៀរ និងបរិបូណ៌ ដឹកនាំដោយមេបះបោរឈ្មោះអាសុខ និងអាជ្រុម ។ ព្រះបាទអង្គឌួងបានចេញបញ្ជាឲ្យគេចាប់ពួកមេបះបោរនោះជាមួយបក្សពួកមួយចំនួនសម្លាប់ចោល ។

មានការបះបោរមួយទៀតកើតឡើងនៅរវាងឆ្នាំ១៨៥៧ ដោយពួកខ្មែររស់នៅក្នុងខែត្រតៃនិញ នៅកូសាំងស៊ីន ដែលបានទទួលការគាំទ្រពីខ្មែរជាច្រើននាក់មកពីកម្ពុជា ។ ហេតុការណ៍នេះបានធ្វើឲ្យព្រះរាជាមានព្រះទ័យព្រួយបារម្ភជាខ្លាំង ខ្លាចតែពួកអាណ្ណាមឆ្លៀតឱកាសគាំទ្រជនជាតិគេហើយតាមវាយពួកបះបោរចូលមកដល់ព្រះរាជាណាចក្រ ។ ព្រះអង្គបានចាត់ឲ្យសង់បន្ទាយការពារនៅតាមព្រំដែនខាងត្បូង ហើយបានហាម

ប្រាមប្រជារាស្ត្រនៅកម្ពុជាលើ មិនឲ្យផ្តល់ជំនួយទៅពួកខ្មែរនៅកូសាំងស៊ីន ដែលទ្រង់ចាត់ទុកថា ជាប្រជារាស្ត្ររបស់ព្រះអង្គដែរ បើទោះជាថាពួកនោះធ្លាប់បានជួយវាយពួកអាណ្ណាមឲ្យបរាជ័យ ដោយជិះតែលើក្របី ហើយមានអាវុធមិនគ្រប់គ្រាន់ក៏ដោយ ។ នៅពេលនោះ ការចាកចោលស្រុកមួយលើកទៀតបានកើតមានឡើងនៅកូសាំងស៊ីន ។ ប្រជាជនខ្មែរដ៏កម្សត់ជាច្រើននាក់ ដែលងើបបះបោរឡើងប្រឆាំងនឹងការគាបសង្កត់ពីពួកអាជ្ញាធរអាណ្ណាម និងញាតិជិតខាងយួន ដែលលួចឆក់សម្បត្តិទ្រព្យសម្បត្តិ វាយដំធ្វើបាប បំបែកបំបាក់ឥតមានលស់ពេល បាននាំគ្នារត់កាត់ព្រំដែន ឆ្លងមកជ្រកកោននៅកម្ពុជាវិញ ។

នៅក្នុងឆ្នាំបន្ទាប់មកទៀត ពួកចាមនៅខែត្រត្បូងឃ្មុំ ដែលធ្លាប់បានបះបោរ២លើករួចមកហើយ ប្រឆាំងនឹងព្រះរាជាកម្ពុជា ម្តងនៅក្នុងឆ្នាំ១៥៩៩ និងម្តងទៀតនៅក្នុងឆ្នាំ១៦៦០ បាននាំគ្នាចាប់កាន់អាវុធប្រឆាំងនឹងចៅហ្វាយខែត្រ ដែលមិនយល់ព្រមអនុញ្ញាតឲ្យពួកនេះបង្កើតរដ្ឋតូចមួយនៅក្នុងវង្វង់ទឹកដីខែត្ររបស់គាត់ ។ ពួកនេះស្តាប់តែបញ្ជារបស់មេគេប៉ុណ្ណោះ[៨៨] ។ ព្រះរាជាបានបញ្ជូនលោកយោធាសង្គ្រាម ឲ្យទៅបង្ក្រាបពួកនេះ តែត្រូវពួកនេះសម្លាប់បាន ព្រោះគាត់មានកងការពារតែប៉ុន្មាននាក់ប៉ុណ្ណោះ ។ ព្រះរាជា បានកេណ្ឌទ័ពមួយកងភ្លាម រួចដឹកនាំចេញទៅត្បូងឃ្មុំដោយផ្ទាល់ព្រះអង្គ ។ ពួកចាមដែលជួនកាលត្រូវទ័ព ព្រះរាជាវាយប្រហារឲ្យបរាជ័យ ជួនកាលទៀតទទួលបានជ័យជម្នះវិញ ប៉ុន្តែនៅទីបញ្ចប់ក៏ត្រូវបរាជ័យ បែកខ្ញែកគ្នា រួចបង្ខំឲ្យគេចទៅជ្រកកោននៅឯចូវដុក បង្កើតបានជាភូមិចាម៥ ដែលគេប្រទះឃើញមានរហូតដល់សព្វថ្ងៃនេះ ។ ពួកចាមដែលមិនអាចគេចខ្លួនបាន ត្រូវគេប្រមូលចាប់យកទៅទុកនៅពោធិសាត់ នៅលង្វែក នៅកំពង់ត្រឡាច និងនៅកំពង់ហ្លួង ។ អ៊ីៗហាក់ដូចជាបានចប់ទៅហើយ ស្រាប់តែពួកចាមដែលរត់ភៀសខ្លួនទៅរស់នៅឯចូវដុកនោះ បាននាំគ្នាឡើងមកតាមទន្លេយ៉ាងរហ័ស ការពារដោយកម្លាំងថ្មើរជើងមួយកងឆ្លងកាត់ភ្នំពេញ រហូតទៅដល់ដំរំដែលគេដាក់ពួកចាមនាំមកពីត្បូងឃ្មុំ ជម្លៀសពួកនោះយកទៅអស់ ។ ប្រតិបត្តិការនេះត្រូវបាន គេត្រៀមអស់ពេលជាយូរមកហើយៗទទួលពួកចាមនៅកម្ពុជាប្រុងតែលួចរត់គេចផង ម៉្លោះហើយក៏ប្រព្រឹត្តទៅយ៉ាងលឿន រហូតទាល់តែព្រះរាជាកម្ពុជាមិនអាចចាត់វិធានការអ្វីទប់ទល់ទាន់ ធ្វើឲ្យពួកអ្នកកាន់សាសនាមហាម៉ាត់នាំគ្នារត់ឆ្លងចូលទៅកូសាំងស៊ីនអស់ទៅ ។ ចាស់ៗបាននិយាយថា ហេតុការណ៍នេះអាចកើតឡើងបាន មកពីភាគច្រើននៃពួកចាម

[៨៨] មេសំខាន់៣នាក់របស់ពួកបះបោរនោះត្រូវជាកូនរបស់ចាមម្នាក់ មានឈ្មោះថា ទួនសែតអស្មិត ឬទួនផា ។ ទួនផា នេះ បានវាយពួកអាណ្ណាមនៅបិញធន់ រួចហើយបានមកតាមវាយពួកអាណ្ណាមនៅកម្ពុជាទៀត នៅក្នុងរជ្ជកាលស្តេចអង្គច័ន្ទ ។ ព្រះបាទអង្គច័ន្ទបានលើកទួនផាឲ្យឡើងធ្វើជារដ្ឋមន្ត្រី ប៉ុន្តែដល់ក្រោយមកបានបោះបង់ចោលទៅវិញ នៅក្នុងឆ្នាំ១៨២០ តាមការញុះញង់របស់អាណ្ណាម ។ កូនគាត់ទាំង៣នាក់ គឺទួនហ៊ឹម ទួនស៊ូ និងទួនអ៊ិត មានឥទ្ធិពលទៅលើពួកអ្នកកាន់សាសនាដូចគ្នា ។ ចំណែកឯកូនទី៤ ដែលការពារពួកចាម និងម៉ាឡេ ខ្លាំងណាស់ដែរនៅក្នុងព្រះរាជវាំងកម្ពុជា បានឡើងជាសម្តេចចៅពញានៅក្នុងរជ្ជកាលស្តេចនរោត្តម ។

ដែលព្រះរាជាបានចាប់ជាឈ្លើយនោះច្រើនតែជាស្ត្រី កុមារ និងមនុស្សចាស់ ពួកបុរសៗបានរត់គេចទៅកូសាំងស៊ីនអស់ទៅហើយៗការដែលព្រះអង្គធ្វើដូច្នេះ ព្រោះមិនចង់ឲ្យពួកគេចាកចោលព្រះរាជាណាចក្រ ។

ឯកសារមួយនិយាយថា ព្រះរាជាខ្វល់ខ្វាំងណាស់ ណាមួយខ្លាស់នឹងល្បិចពួកចាមផង ទ្រង់បានព្រមានឲ្យអាណ្ណាមដែលគ្រប់គ្រងចូវដុកបញ្ជូនពួកបះបោរនោះមកថ្វាយព្រះអង្គវិញ ។ ចៅហ្វាយខែត្រអាណ្ណាមនោះប្រកែកមិនព្រមធ្វើតាមសំណើរបស់ព្រះអង្គទេ ព្រះបាទអង្គឌួងក៏បញ្ជូនទ័ពមួយកងតូច ដឹកនាំដោយស្តេចត្រាញ់ដែនដីទ្រាំង ឈ្មោះ កែប ដើម្បីទៅនាំយកពួកចាមទាំងនោះមកវិញ ។ ពួកចាមនោះបានព្រួតដៃគ្នាជាមួយទ័ពអាណ្ណាម ដែលគេបញ្ជូនឲ្យមកជួយច្បាំងជាមួយទ័ពខ្មែរ តែមិនអាចទប់ទល់មិនឲ្យទ័ពខ្មែរ ឆ្លងចូលទៅឆ្ងាយពីព្រំដែនបានទេ ។ ដូច្នេះសង្គ្រាមបានកើតមានឡើងម្តងទៀតជាមួយអាណ្ណាម ដែលនឹងធ្វើឲ្យមានអន្តរាគមន៍ពីសៀមដោយចៀសមិនរួច ប្រសិនបើគ្មានវត្តមានរបស់បារាំងនៅកូសាំងស៊ីនទេ[៨៩] ។

នៅពេលនោះ ពួកអាណ្ណាមគ្មានលទ្ធភាពទប់ទល់ជាមួយនឹងទ័ពខ្មែរទេ ។ ក្រោយពីត្រូវរ៉ូវគ្នាជាមួយពួកអង់គ្លេស និងចាប់បង្ខំព្រះចៅអធិរាជចិនឲ្យចុះសន្ធិសញ្ញារួចហើយ ពួកបារាំងបានវិលត្រលប់ពីស្រុកចិនមកវិញហើយដើម្បីជាការសងសឹកឲ្យពួកសាសនទូតរបស់បារាំង និងពួកអាណ្ណាមកាន់សាសនាកាតូលិក ដែលត្រូវពួកមន្ត្រីដេញចេញពីស្រុក និងបង្ខំឲ្យអាណ្ណាមអនុវត្តតាមកិច្ចសន្យាកាលពីមុនផងនោះ ពួកបារាំងបានទម្លាក់គ្រាប់បែកទៅលើទីក្រុងទូរ៉ានទៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៨៥៨ ចូលកាន់កាប់សាយហ្គនទៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៨៥៩ ហើយកំញើញថា នឹងដណ្តើមយកកូសាំងស៊ីនទាំងមូលថែមទៀត ។

ព្រះបាទអង្គឌួង មានការភ្ញាក់ផ្អើលជាខ្លាំង នៅពេលទទួលបានដំណឹងនេះ ហើយទ្រង់ដូចជាមានការព្រួយបារម្ភ មិនដឹងថាតើហេតុការណ៍នោះនឹងនាំមកនូវផលល្អឬផលអាក្រក់ចំពោះកម្ពុជា ម្ល៉ោះហើយទ្រង់មានការប្រុងប្រយ័ត្នយ៉ាងខ្លាំង ។ ព្រះអង្គចង់ដឹងអំពីគោលបំណងរបស់ពួកបារាំង ថាតើគេធ្វើនេះគ្រាន់តែដើម្បីសងសឹកទៅនឹងការប្រមាថមើលងាយរបស់អាណ្ណាម រួចកាន់កាប់ចំណុចណាមួយនៅតាមឆ្នេរសមុទ្រ ឬក៏គេចង់ដណ្តើមយកកូសាំងស៊ីនផ្នែកខាងក្រោមទាំងអស់ ។ បើដូច្នោះមែន បារាំងនឹងក្លាយទៅជាអ្នកមានព្រំដែនជាប់នឹងកម្ពុជា ហើយដើរតួជំនួសអាណ្ណាមក្នុងការទាមទារសិទ្ធិអធិរាជភាពមកលើកម្ពុជាទេដឹង? តាមពិតទៅ សកម្មភាពរបស់បារាំងនៅពេលនោះគ្មានអ្វីជាក់លាក់ទេ ហើយកំហុសរបស់លោក ដឺម៉ុងទីញី បានធ្វើឲ្យព្រះបាទអង្គឌួងទីទើណាមួយ បារាំងក៏មិនបានបញ្ជូនតំណាងឲ្យមករាយការណ៍ថ្វាយ ដើម្បីឲ្យទ្រង់អស់សង្ស័យផងដែរ ។ បើទោះជា

[៨៩] រាជពង្សាវតារបានកត់សម្គាល់ថាមានផ្កាយដុះកន្ទុយមួយនៅក្នុងឆ្នាំ១៨៥៨ ដែលលេចឡើងនៅទិសពាយ័ព្យ ហើយមានកន្ទុយវែងចុះទៅខាងទិសអគ្នេយ៍ ។ ផ្កាយដុះកន្ទុយនេះមានប្រវែង៩០ អង្សាដែលគេអាចមើលឃើញច្បាស់នៅស្រុកបារាំងក្នុងរដូវក្តៅ ។

យ៉ាងណាក្តី ការដែលបារាំងវាយដណ្តើមយកសាយហ្គនបានៗ ធ្វើឲ្យព្រះអង្គមានសេចក្តីក្លាហានឡើងវិញ ។ ហើយនៅពេលឃើញថាទ័ពបារាំងមិនបានឈរជើងនៅទីនោះ គឺវិលត្រលប់មក ទូរ៉ាន វិញ ប៉ុន្តែបានធ្វើការវាយប្រហារទៅលើអតីតសត្រូវរបស់ព្រះអង្គគ្រប់ទីកន្លែង ព្រះអង្គក៏សម្រេចចិត្តចាប់វាយមកលើអាណ្ណាមនៅចូវដុកចូលមកក្នុងកូសាំងស៊ីន របៀបជាកងជំនួយឲ្យពួកបារាំង ដោយគ្មានការចរចាឯកភាពគ្នាជាមុនទេ ។ គេនិយាយថានោះហើយជាការសម្ងាត់នៃសង្គ្រាម ដែលហាក់ដូចជាផ្ទុយទៅនឹងនយោបាយរបស់ព្រះអង្គដែលមានពីមុន ។

បន្តិចក្រោយមក ព្រះរាជាបានយាងទៅកំពត ដើម្បីទៅទតមើលសំពៅពាណិជ្ជកម្មមួយ ដែលទ្រង់បានឲ្យគេធ្វើឡើងរួចប្រគល់ឲ្យជនម៉ាឡេម្នាក់នៅត្រីកាកាន់កាប់ ។ នៅទីនោះព្រះអង្គបានជួបជាមួយអ្នកស្រាវជ្រាវ មូហូត ជជែកជាមួយបានបន្តិច ទ្រង់ក៏បញ្ជាឲ្យគេផ្តល់មធ្យោបាយសម្រាប់គាត់ធ្វើដំណើរមកឧត្តុង្គទៀត ។

នៅពេលយាងត្រលប់មកកាន់រាជធានីវិញ ក្រោយពេលដែលលោក មូហូត ចូលគាល់ព្រះអង្គនៅនឹងព្រះរាជដំណាក់ធ្វើពីឈើបានបន្តិច ព្រះបាទអង្គឌួងក៏ធ្លាក់ព្រះកាយប្រឈួន ហើយបានសុគតទៅនៅឆ្នាំ១៨៦០ នៃគ្រិស្តសករាជ ត្រូវនឹងមហាសករាជ១៧៨២ ចុល្លសករាជ១២២២ (ក្នុងខែកត្តិក ថ្ងៃ៥កើត ចុងខែវិច្ឆិកា) ។

ការចូលទិវង្គតរបស់ព្រះរាជាបានធ្វើឲ្យចលនារបស់ខ្មែរនៅចូវដុក ត្រូវបញ្ចប់ ហើយខកញ៉ាកែបក៏នាំទ័ពវិលត្រលប់ចូលមកកម្ពុជាវិញ ។

## ៤៣- ព្រះបាទនរោត្តម (១៨៦០-១៩០៤)

ព្រះបាទអង្គឌួងមានរាជបុត្រា៣ព្រះអង្គ គឺអ្នកអង្គម្ចាស់អង្គវតី (ប្រទ្បីង) ជាព្រះរាជបុត្រាច្បង ពេលនោះមានព្រះជន្ម២៦ព្រះវស្សាហើយ, អ្នកអង្គម្ចាស់អង្គស (អ្វួ)[៩០] ជាព្រះរាជបុត្រាបន្ទាប់ មានព្រះជន្ម ២០ព្រះវស្សា និងអ្នកអង្គម្ចាស់វត្ថា (ស៊ីវត្ថា-អង្គភឹម) ជារាជបុត្រាទី៣ មានព្រះជន្ម១៩ព្រះវស្សា ទាំង៣ព្រះអង្គនេះមាន ព្រះមាតាផ្សេងៗគ្នា ។

ព្រះវររាជមាតារបស់ព្រះបាទអង្គឌួង ដែលត្រូវជាព្រះអយ្យកាខាងព្រះបិតារបស់អ្នកអង្គម្ចាស់ទាំង៣អង្គបានកោះប្រជុំក្រុមប្រឹក្សាមន្ត្រីធំៗ ហើយបានជ្រើសតាំងអ្នកអង្គម្ចាស់អង្គវតីជាព្រះរៀម និងជាព្រះឧបរាជ ផង

---

[៩០] នៅពេលដែលអ្នកអង្គម្ចាស់អង្គវតី ត្រូវបានលើកឲ្យឡើងជាមហាឧបរាជ ស្តេចសៀមបានលើកអ្នកអង្គម្ចាស់សនេះ ឲ្យឡើងជាព្រះកែវហ្វ៊ា ។ ព្រះអង្គបានទទួលយកបុត្រី របស់ព្រះអនុជក្សត្រីមួយអង្គរបស់ព្រះក្សត្រីអង្គម៉ី ជាព្រះជាយា ដែលត្រូវជាព្រះភាគិនេយ្យ របស់ព្រះអង្គ តែមានព្រះជន្មច្រើនជាងព្រះអង្គ១ឆ្នាំ ។ អ្នកអង្គម្ចាស់សនេះ ប្រុងតែនឹងដើរតាមអ្នកអង្គម្ចាស់វត្ថាធ្វើការបះបោរទៅហើយ តែទ្រង់បានត្រូវគេលើកឲ្យឡើងជាព្រះឧបរាជនៅក្នុងឆ្នាំ១៨៦៨ រួចបានសោយរាជ្យបន្តពីព្រះរៀម នរោត្តម នៅក្នុងឆ្នាំ១៩០៤ ។

ឲ្យឡើងសោយរាជ្យបន្ត តាមបណ្ដាំរបស់ព្រះបាទអង្គឌួង ។

នៅថ្ងៃរៀបចំព្រះរាជពិធីរាជាភិសេក ព្រះរាជាថ្មីបានប្រកាន់យកព្រះនាមថានរោត្តម ដែលស្ដេចសៀមបានដាក់ថ្វាយនៅពេលព្រះអង្គបានឡើងជាព្រះឧបរាជនៅក្នុងឆ្នាំ១៨៥៦ ។ នៅពេលដែលបានទទួលដំណឹងពីការជ្រើសតាំងព្រះរាជាថ្មីនេះភ្លាម ស្ដេចសៀមបានបញ្ជូននូវការយល់ព្រមរបស់ព្រះអង្គមកភ្លាម ហើយបានសន្យាមិនច្បាស់លាស់ថា ទ្រង់នឹងយាងមកចូលរួមជាអធិបតីដោយផ្ទាល់ព្រះអង្គឯង ។ ក៏ប៉ុន្តែព្រមជាមួយគ្នានោះ ស្ដេចសៀម ដែលដឹងច្បាស់អំពីការប្រណែនរបស់អ្នកអង្គម្ចាស់វត្ថាចំពោះព្រះវៀម បានអនុញ្ញាតឲ្យព្រះអង្គយាងត្រលប់ចូលមកកម្ពុជាវិញផងដែរ ។

នៅពេលឡើងគង់លើរាជបល្ល័ង្កភ្លាម ព្រះបាទនរោត្តមបានបញ្ជាឲ្យគេសង់ព្រះរាជវាំងសម្រាប់ព្រះអង្គនៅឧត្តុង្គ នៅពីខាងលិចស្រះស្រង់ រួមទាំងដំណាក់សម្រាប់មហេសី និងស្រីស្នំក្រមការ សាលរបាំសម្រាប់ការសំដែងល្ខោន និងព្រះរាជបណ្ណាល័យមួយផង ដែលមានជញ្ជាំងធ្វើពីបាយអ ដំបូលប្រក់ស្បូវ ។ ព្រះអង្គបានយាងចូលគង់នៅក្នុងព្រះរាជវាំងថ្មីនេះនៅក្នុងខែសីហា ឆ្នាំ១៨៦០ ។

ព្រះរាជាទ្រង់ស្រលាញ់អ្នកអង្គម្ចាស់វត្ថាណាស់ ចាត់ទុកដូចជាព្រះអនុជរួមព្រះមាតា ។ ព្រះអង្គបានប្រទានប្រាក់១០០ណែន (៨ពាន់ហ្វ្រង់), ចិញ្ចៀនមាស និងគ្រឿងអលង្ការផ្សេងៗថែមទៀត រួចបានសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ព្រះអង្គជាមួយព្រះក្សត្រីសិរីវង្ស ដែលត្រូវជាព្រះអនុជរួមព្រះបិតាទាំងអស់គ្នាទៀតផង ។ ក៏ប៉ុន្តែ អ្នកអង្គម្ចាស់វត្ថា ដែលរំពឹងគិតថាក្រុមប្រឹក្សាមហាមន្ត្រីចូលចិត្តព្រះអង្គច្រើនជាងព្រះវៀមទាំង២ បែរជាចាប់ផ្ដើមប្រើកលឧបាយប្រឆាំងនឹងព្រះរាជា ប្រឆាំងនឹងរដ្ឋមន្ត្រីរបស់ព្រះអង្គ ប្រឆាំងនឹងចៅហ៊្វាមាស ជាមន្ត្រីមានវ័យចំណាស់ជាងគេហើយក៏ជាមេគេដែរ ដែលអ្វីៗអាស្រ័យលើការសម្រេចចិត្តរបស់គាត់ ។ អ្នកអង្គម្ចាស់វត្ថា មានបំណងចង់ធ្វើឃាតចៅហ៊្វាមាសនេះចោល ដើម្បីជាការដាក់ទោស ព្រោះគឺគាត់នេះហើយ ដែលបានជ្រើសរើសព្រះវៀមឲ្យឡើងគ្រងរាជបល្ល័ង្ក ហើយបានប្រើឥទ្ធិពលការពារព្រះវៀមទៀត ។ ចៅហ៊្វាមាស បានយាងអ្នកអង្គម្ចាស់វត្ថាឲ្យទៅផ្ទះគាត់ ដើម្បីអប់រំណែនាំព្រះអង្គ ធ្វើឲ្យព្រះអង្គមានការភ័យខ្លាច រួចនៅស្ងៀមបាន១ឆ្នាំដែរ ។ ប៉ុន្តែបន្ទាប់មក ទ្រង់ក៏ចាប់ផ្ដើមប្រើកលឧបាយឡើងវិញ ។

អ្នកអង្គម្ចាស់វត្ថាពេលនោះជាយុវជនសង្ហាម្នាក់ ប៉ិនប្រសប់ក្នុងការនិយាយស្ដីទៅកាន់មនុស្សម្នា ហើយត្រូវបាននារីៗ និងប្រជារាស្ត្រស្រលាញ់ចូលចិត្តច្រើន ។ ទ្រង់មានប្រាជ្ញាឈ្លាសវៃ មានការចេះដឹងខ្ពស់ និយាយខ្មែរបានល្អជាងព្រះបាទនរោត្តម ដែលចូលចិត្តប្រើតែភាសាសៀម ក៏ប៉ុន្តែទ្រង់មានការប្រណែនច្រើន ។ ទ្រង់ប៉ិនប្រសប់ក្នុងការថ្លែងសុន្ទរកថាបានល្អណាស់ ពូកែនិយាយថែមថយបញ្ចិតបញ្ចៀងលើព្រឹត្តិការណ៍ប្រចាំថ្ងៃ ឌីដងឲ្យព្រះរាជាជាព្រះវៀម លើកអំពីទម្លាប់ធូររលុងរបស់ព្រះអង្គ អំពីសេចក្ដីស្នេហារបស់ព្រះអង្គជាមួយបងប្អូនស្រីៗ និងជាមួយជាយារបស់ព្រះបិតា ជាដើម ។ ទ្រង់មានមហិច្ឆតាខ្ពស់ ហើយមិនចេះគិតខ្លាចរអែងអ្វីឡើយ

អាចនឹងបំផ្លិចបំផ្លាញព្រះរាជាណាចក្របាន ដោយហេតុតែចង់ដណ្តើមយកអំណាចនេះ ។

ក្នុងចំណោមបក្សពួករបស់អ្នកអង្គម្ចាស់វត្ថាមានញាតិខាងព្រះមាតាម្នាក់ គឺស្នងសូរ ដែលបានដើរបំផុសបំផុលប្រជារាស្ត្រនៅដីបាភ្នំ ស្រុះស្រែងជ្រើសរើសគ្នីគ្នា ។ ព្រះរាជាបានចេញបញ្ជាឲ្យស្នងសូរចូលខ្លួនមកខុត្តគដើម្បីប្រគល់ឲ្យចៅហ៊្វាមាសកាត់ទោស ។ ស្នងសូរមិនព្រមចូលខ្លួនតាមព្រះរាជបញ្ជាទេ ហើយបានរត់ទៅជ្រកកោននៅក្នុងដំណាក់របស់អ្នកអង្គម្ចាស់វត្ថា ដែលឈប់ចូលគាល់ព្រះរាជាដែរ ។ ម្យ៉ាងទៀត មានលេចឮពាក្យចចាមអារ៉ាមនិយាយថា ស្តេចសៀមបានបញ្ជូនអ្នកអង្គម្ចាស់វត្ថាមកកម្ពុជា ដើម្បីត្រួតពិនិត្យតាមដានមើលរាជវង្ស និងមន្ត្រីរាជការទាំងអស់ តើមានអ្នកណាមិនស្មោះត្រង់នឹងពួកសៀម ដែរឬទេ?

បន្តិចក្រោយមក ដោយអ្នកអង្គម្ចាស់វត្ថា និងព្រះជាយាមិនបានទៅចូលរួមព្រះរាជពិធីមួយ ដែលគេរៀបចំថ្វាយសពព្រះបាទអង្គឌួង ព្រះបាទនរោត្តម បានបញ្ជាឲ្យព្រះអនុជនេះយាងចេញពីព្រះរាជាណាចក្រ ធ្វើដំណើរជាមួយមិត្តភក្តិទាំងអស់ទៅបាងកក ជាមួយទូតដែលស្តេចសៀមឲ្យនាំយកកោដ្ឋមាសមួយ មកថ្វាយព្រះរាជាដើម្បីដាក់ធាតុព្រះបិតា ។ អ្នកអង្គម្ចាស់វត្ថា និងព្រះជាយាបានប្រកែកមិនព្រមគោរពតាមទេ ធ្វើឲ្យព្រះរាជាខ្វាល់ជាខ្លាំង អត់ទ្រាំមិនបាន ក៏បញ្ជាឲ្យពួកមន្ត្រីចាប់ខ្លួនព្រះអង្គ ។ ពួកមន្ត្រីទាំងនោះទីទើ មិនដឹងថាត្រូវគោរពតាមនរណាមួយគឺព្រះបាទនរោត្តមដែលជាព្រះរាជាគង់លើរាជបល្ល័ង្ក មួយទៀត គឺអ្នកអង្គម្ចាស់វត្ថា ដែលប្រជារាស្ត្រស្រលាញ់ចូលចិត្ត ។ ទាល់តែគេបង្កើតកងកម្លាំងមួយ ដែលមានសុទ្ធតែពួកអ្នកកាន់សាសនាកាតូលិកជាបច្ចាញាតិរបស់ពួកព័រទុយហ្គេ ទើបពួកនេះសម្រេចចិត្តដាច់ខាតចាប់ខ្លួនព្រះអង្គ ។ អ្នកអង្គម្ចាស់វត្ថាបានតតាំងតបវិញ ក៏ប៉ុន្តែត្រូវគេឡោមជុំជិត ទ្រង់ក៏លោតឡើងលើសេះបំបោលកាត់ខ្សែត្រៀម ហើយរត់គេចខ្លួនព្រះអង្គចេញទៅជាមួយនឹងស្រីក្មេងម្នាក់ ដែលព្រះអង្គបានចាប់ពង្រត់ចេញពីព្រះរាជវាំង ជាហេតុធ្វើឲ្យគេកាត់ស្មានថា នោះហើយជាមូលហេតុអាថ៌កំបាំងនៃទំនាស់រវាងបងប្អូនទាំង ២ព្រះអង្គ ។ គេបានចាប់ព្រះមាតារបស់អ្នកអង្គម្ចាស់វត្ថា ឃុំទុកក្នុងព្រះរាជវាំង ដោយចោទថា ព្រះនាងបានឃុបឃិតជាមួយព្រះរាជបុត្រា ។

សង្គ្រាមបានផ្ទុះឡើងរវាងបងប្អូនទាំង២ព្រះអង្គ ហើយជាថ្មីម្តងទៀត ការបែកបាក់គ្នា ដើម្បីដណ្តើមអំណាចរវាងសមាជិក ២អង្គ របស់ព្រះរាជវង្សានុវង្សនៃព្រះរាជាណាចក្រកម្ពុជា បានកើតមានសាជាថ្មី ដោយគ្មានគិតថា ព្រះរាជាណាចក្រកំពុងតែជួបប្រទះគ្រោះវិនាសហិនហោចអ្វីទេ ។ មុនដំបូងទ័ពរបស់ចៅហ្វាយខែត្របាភ្នំខាងព្រះរាជាត្រូវទ័ពរបស់ស្នងសូរ និងរាមាយោធា[៩១] វាយឲ្យបរាជ័យ តែបន្ទាប់មកក៏ទទួលជ័យជម្នះតិចតួចមកវិញ ដែលមិនសូវជាធំដុំប៉ុន្មានទេ ធ្វើឲ្យព្រះបាទនរោត្តមអស់សង្ឃឹមជាខ្លាំង ណាមួយប្រជារាស្ត្រក៏ឈរមើលការធ្វើ

[៩១] មេដឹកនាំក្រុមបះបោរទាំង២នាក់នេះជាមិត្តជិតស្និទ្ធ និងជាដៃស្តាំរបស់អ្នកអង្គម្ចាស់វត្ថា មានដើមកំណើតចេញពីខែត្របាភ្នំ ។ អ្នកម្នាងជាព្រះមាតារបស់អ្នកអង្គម្ចាស់ ក៏មានដើមកំណើតនៅបាភ្នំនេះដែរ ហើយបានយកអ្នកទាំង២ទៅនៅបម្រើបុត្រាព្រះនាង ។

សង្គ្រាមនេះដោយមិនកាន់ជើងខាងណាជាងខាងណាដែរ ទ្រង់ក៏ចុះទូកចេញដំណើរតាមទន្លេ និងបឹងទន្លេសាប ទៅកាន់ខែត្របាត់ដំបងបាត់ទៅ ដោយបាននាំយកកេតនភណ្ឌព្រះរាជាណាចក្រទៅជាមួយផង (ខែសីហា ឆ្នាំ១៨៦១) ។

ដំណើរយាងចាកចោលរាជធានីនេះបានធ្វើឲ្យសត្រូវរបស់ព្រះរាជាទទួលបានជ័យជម្នះ ។ រាមាយោធា ដែលជាវីរបុរសតែម្នាក់គត់ នៅក្នុងសង្គ្រាមបង្ហូរឈាមគ្នាឯងនេះ ហើយដែលបង្ហាញឲ្យឃើញនូវថាមពល និងល្បិចខ្លះៗ បានវាយដណ្ដើមយកឧត្តុង្គបាន ក៏ប៉ុន្តែបន្ទាប់មកមិនដឹងថាត្រូវធ្វើអ្វីតទៅទៀត ដើម្បីបន្តវាតអំណាចទៅលើព្រះនគរទាំងមូល ចាប់បង្ខំឲ្យចៅហ្វាយខែត្រទាំងអស់ទទួលស្គាល់គោរពខ្លួនផងទេ ។ គាត់ជាអ្នកពូកែខាងធ្វើចម្បាំង ក៏ប៉ុន្តែមិនដឹងមិនយល់អំពីការគ្រប់គ្រងប្រទេស និងអំពីនយោបាយបន្តិចទាល់តែសោះ ។ ពេលនោះស្រាប់តែពួកចាម និងម៉ាឡេនៅត្បូងឃ្មុំ ដែលធ្លាប់បានបះបោររួចមកហើយកាលក្នុងរជ្ជកាលព្រះបាទអង្គឌួង ដល់ច្បាំងចាញ់បានរត់គេចទៅនៅឯចូវដុកនោះ បានស្រុះស្រួលត្រូវរ៉ូវគ្នាជាមួយពួកអ្នកកាន់សាសនានៅលង្វែក និងកំពង់ហ្លួង ដែលទើបតែប្រកែកមិនព្រមផ្ដល់ការគាំទ្រដល់ព្រះរាជា បានសំណូមពរឲ្យព្រះមហាក្សត្រិយានី ជាព្រះអយ្យកា ដែលគង់នៅឧត្តុង្គជាមួយនឹងរាជវង្សានុវង្សមួយចំនួន និងស្រីស្នំក្រមការទាំងអស់ជួយគាំទ្រព្រះរាជា ។ គេបានបង្វិលទ្រព្យរបស់ដែលគេបានរឹបអូសយកឋានៈគួនាទី មុខតំណែងពីមុនទៅឲ្យពួកនោះវិញ រួចហើយពួកគេក៏ចាប់ចេញធ្វើសកម្មភាព ។ ព្រះមហាក្សត្រិយានីបានកោះហៅ រាមាយោធាឲ្យចូលគាល់ រួចបានស្ដីបន្ទោសចំពោះអំពើក្បត់របស់ខ្លួន ហើយបានបញ្ជាឲ្យដកថយចេញពីឧត្តុង្គជាបន្ទាន់ ។ រាមាយោធា ក៏នាំទ័ពរបស់ខ្លួនចេញមកកាន់ភ្នំពេញវិញ ។

មកដល់ភ្នំពេញ រាមាយោធាបានជួបជាមួយនាវាចម្បាំងតូចមួយ ដែលទើបតែឡើងមកពីកូសាំងស៊ីន ដើម្បីផ្ដល់កិច្ចការពារដល់បេសកកម្មកាតូលិករបស់បារាំង ហើយដោយភ័យខ្លាំងណាស់ គាត់បានសន្យាសុខចិត្តជួសជុលការខូចខាតទាំងអស់ ដែលបណ្ដាលមកអំពីការដុតពញាឮក្នុងពេលវាយគ្នាកាលពីប៉ុន្មានសប្ដាហ៍មុន ។ រាមាយោធា បានប្រគល់សំណងជាប្រាក់៤៣ពាន់ហ្វ្រង់ជូនទៅ អេវ៉េកមីស្ហ ភ្លាម ហើយបានសន្យាថានឹងជូន១ម៉ឺន ២ពាន់ ទៀត នៅខែក្រោយ ។ តាមពិតទៅ នាវាចម្បាំងតូចនេះត្រូវបានបញ្ជូនឲ្យមកភ្នំពេញ ដើម្បីគ្រាន់តែការពារពួកសាសនទូត កាតូលិកជាតិបារាំងប៉ុណ្ណោះ ក៏ប៉ុន្តែពួកបះបោរមើលឃើញថា ជាអន្តរាគមន៍ជួយព្រះបាទនរោត្តមទៅវិញ ។ ក៏ប៉ុន្តែនោះហើយជាអ្វីដែលគេចង់បាន ណាមួយពួកកាតូលិកក៏ទទួលបញ្ជាពី អេវ៉េក របស់គេឲ្យធ្វើការប្រយុទ្ធជួយព្រះរាជាផងដែរ នៅពេលដែលព្រះរាជាបានចេញព្រះរាជបញ្ជាឲ្យចាប់ខ្លួនអ្នកអគ្គម្ចាស់វត្ថា និងព្រះជាយាសិរីវង្ស ។

នៅពេលនោះ សង្គ្រាមបានចាប់ផ្ដើមឡើងនៅភាគខាងត្បូង តាមបណ្ដោយព្រំដែន ហើយបានបន្តទៅយ៉ាងយូរ ដោយគ្មានបានផលអ្វីប៉ុន្មានទេ ។ ចៅហ្វាយខែត្រដីបាភ្នំបានចេញធ្វើការប្រយុទ្ធយ៉ាងអង់អាចក្លាហាន ជួនក៏ត្រូវរាមាយោធាវាយឲ្យបរាជ័យ ជួនក៏ទទួលបាននូវជ័យជម្នះខ្លះវិញ ។ ពេលនោះ មានទាហានបារាំង៥នាក់ បាន

ទទួលច្បាប់ឲ្យឈប់សម្រាកនៅកូសាំងស៊ីន មុនដំបូងអ្នកទាំង៥ បានចូលបម្រើពួកបះបោរ ។ ក៏ប៉ុន្តែលុះដល់បានទទួលពត៌មានច្បាស់លាស់ពីសភាពការណ៍ពិតពី អេវ៉ែកមីស្ទូ ក៏ត្រលប់មកជួយខាងខុត្តគ្គវិញ ។ ពេលនោះប្រជាជនខ្មែររីករាយត្រេកអរខ្លាំងណាស់ វាហាក់ដូចជាថាគេនឹងអាចគាស់រំលើងអ្វីៗទាំងអស់បាន នៅពេលដែលមានពួកទាហានបារាំង៥នាក់នោះបញ្ឆោ ។ ព្រះអង្គស ជាព្រះអនុជបន្ទាប់របស់ព្រះរាជាសព្វថ្ងៃនេះ ដែលពេលនោះទ្រង់ជាព្រះកែវហ្វ៊ា ហើយក៏ជាព្រះរាជានុសិទ្ធិផងដែរពេលអវត្តមានព្រះរាជាដែលកំពុងតែគង់នៅឯបាងកក បានប្រគល់នាវាមួយកងឲ្យពួកនោះទៅវាយដណ្តើមយកបន្ទាយរបស់ រាមាយោធា នៅមាត់ក្រសារ ។ នៅពេលទទួលបានដំណឹងថាពួកបារាំងជាអ្នកបញ្ជាដឹកនាំទ័ពនាវានោះ រាមាយោធា មិនបាននៅតទល់ទេ តែបាននាំទ័ពរត់គេចអស់ទៅ ។

ពេលនោះ ព្រះបាទនរោត្តមបានចាប់គិតឃើញថា ព្រះអង្គមិនគួរនឹងយាងចេញពីព្រះនគរសោះ ដល់ឃើញព្រះអនុជព្រះកែវហ្វ៊ា ចាត់ចែងកិច្ចការព្រះរាជាណាចក្រហើយដឹកនាំសង្គ្រាមប្រឆាំងនឹងអ្នកអង្គម្ចាស់វត្តាផង ព្រះអង្គពិភាល់ថាព្រះអនុជមានបំណងប្រឆាំងនឹងព្រះអង្គ ហើយឲ្យគេជ្រើសតាំងជាព្រះមហាក្សត្រ ជំនួសព្រះអង្គវិញ ។ ការដែលព្រះរាជាទ្រង់គិតដូច្នេះខុសស្រឡះ ក៏ប៉ុន្តែបើទោះជាយ៉ាងណាក្តីអ្នកអង្គម្ចាស់ស៊ីសុវត្ថិបានត្រូវរងគ្រោះដោយសារព្រះរាជាជាព្រះរៀមរហូត ។

ពេលនោះពួកមន្ត្រីៗនៅខុត្តគ្គបានជំរុញឲ្យ អេវ៉ែកមីស្ទូ សរសេរលិខិតមួយទៅកុងស៊ុលបារាំងប្រចាំរាជធានីបាងកក ឲ្យទៅជួបស្តេចសៀម សំណូមពរសុំព្រះអង្គចាត់ឲ្យកប៉ាល់មួយដឹកព្រះបាទនរោត្តមមកចុះចតនៅកំពត ហើយនិងសុំឲ្យបញ្ជូនទ័ពមួយកងមកតាមបាត់ដំបង សម្រាប់ជួយការពារព្រះរាជានៅខុត្តគ្គផង ។ ស្តេចសៀមរីករាយណាស់នឹងបានលូកដៃចូលមកក្នុងកម្ពុជាជាថ្មីម្តងទៀត ហើយសង្ឃឹមថានឹងអាចស្តារឥទ្ធិពលចាស់របស់សៀមមកលើកម្ពុជាឡើងវិញបាន ។ ទ្រង់បានចាត់ឲ្យគេជូនដំណើរព្រះបាទនរោត្តមមកកំពត ។ ព្រះរាជាយាងចូលមកខុត្តគ្គវិញនៅក្នុងខែមីនា ឆ្នាំ១៨៦២ ហើយក៏ចាប់ទទួលអំណាចទាំងអស់ពីមុនមកភ្លាមដែរ ។ ការដែល អេវ៉ែកមីស្ទូ ធ្វើដូច្នេះ គឺជួយនឹងនយោបាយរបស់បារាំង ថ្វីបើបានធ្វើឲ្យព្រះរាជាយាងត្រលប់មកកាន់ព្រះនគរវិញក៏ដោយ ព្រោះវាបានធ្វើឲ្យមានអន្តរាគមន៍របស់សៀមឡើងវិញ ដែលនៅពេលនោះ បារាំងមានវត្តមាននៅកូសាំងស៊ីនរួចទៅហើយ ហើយជិតជាងបាងកកផង ។ ម្ល៉ោះហើយគេបានស្តីបន្ទោស អេវ៉ែកមីស្ទូ បន្តិចបន្តួច ហើយស្តេចសៀមក៏មិនបានបញ្ជូនទ័ពមកដែរ ។

ក្រោយមក គេសម្លាប់រាមាយោធាបាន[៩៧] ហើយស្នងសូរក៏ត្រូវចាប់ខ្លួន ដាក់ក្នុងទ្រុងដែរ ប៉ុន្តែបានរត់រួច

[៩៧] គេបានកាត់ក្បាលយកមកថ្វាយព្រះរាជា រួចឲ្យជនក្បត់ម្នាក់ទៀតទូលដើរកាត់ផ្សារ រួចយកទៅដោតចុងឫស្សីដែលបោះនៅពីខាងមុខព្រះរាជវាំង ។

ទៅវិញ ហើយគេចខ្លួនទៅកូសាំងស៊ីនបាត់ទៅ ។ អ្នកអង្គម្ចាស់វត្ថាក៏គេចព្រះអង្គបាត់ បក្សពួកមួយចំនួនបានត្រូវគេដឹកយកទៅដាក់នៅឯកោះត្រឡាច (ពូឡូកុងឌ័រ) ការបះបោរក៏ស្ងាត់បាត់ទៅ ។ ក៏ប៉ុន្តែ ចាប់ពីទ្រង់បានយាងត្រលប់មកវិញនេះ ព្រះរាជាកម្ពុជាហាក់ដូចជាកាន់តែចំណុះស្តេចសៀមខ្លាំងឡើងៗ រហូតដល់មើលទៅឃើញថា វើស៊ីដង់សៀមទេ ដែលមានសិទ្ធិអំណាចមែនទែន ។

នៅក្នុងឆ្នាំដដែលនោះ មានជនកំបុតជើងត្រឹមភ្លៅម្នាក់ឈ្មោះថា បា បានបំបះបំបោរយុវជនក្មេងៗនៅក្នុងខែត្រសំរោងទង ឲ្យសែងខ្លួនទៅរាជធានីឧត្តុង្គ ហើយបើកការវាយប្រហារទៅលើព្រះរាជវាំង ។ ក៏ប៉ុន្តែទ័ពរបស់ បា ត្រូវបរាជ័យ បែកខ្ញែកគ្នាអស់ ឯបា បានរត់គេចខ្លួនរួចរហូតទៅដល់ខែត្រពោធិសាត់ ។ គេតាមចាប់មេបះបោរនេះបាន រួចដឹកតាមរទេះមករាជធានីវិញ ប៉ុន្តែ បា បានស្លាប់តាមផ្លូវទៅហើយ ។ គេបានយកខ្មោចជនក្បត់នេះដាក់តាំងជាសាធារណៈអស់ពេល៣ថ្ងៃ រួចយកមកព្យួរនៅខាងកើតផ្សារដែក ដាក់ក្បាលសំយុងចុះក្រោម ទ្រូងត្រូវគេវះចំហធ្លុង ។

នៅសម័យនោះគេបានរៀបចំពិធីបូជាព្រះសពរបស់ព្រះបាទអង្គឌួង ហើយរើសអដ្ឋិធាតុដាក់ក្នុងកោដិមាសមួយ ដែលស្តេចសៀមបានផ្ញើមកឲ្យកាលពីឆ្នាំមុន ។

កាលពីមុន គឺក្នុងខែមីនា ឆ្នាំ១៨៦១ លោកឧត្តមនាវី ស្ហាកនេ ដែលជាមេបញ្ជាការនៅសាយហ្គន បានបញ្ជូននាយទាហានជើងទឹកម្នាក់ឲ្យមកថ្វាយដំណឹងដល់ព្រះបាទនរោត្តមថា រដ្ឋាភិបាលបារាំងបានសម្រេចមកតាំងនៅកូសាំងស៊ីនយូរអង្វែង ហើយមានចេតនាចង់រក្សាទំនាក់ទំនងល្អជាមួយកម្ពុជា ។ នៅក្នុងការសន្ទនា ពេលចូលគាល់ព្រះរាជា នាយទាហជើងទឹកនោះបានទូលព្រះអង្គថាលោកឧត្តមនាវី ចង់ឲ្យព្រះរាជាណាចក្រកម្ពុជាមានចំណងមេត្រីភាពសេរីជាមួយបរទេស មិនចំណុះអ្នកណាមួយទេ ហើយនៅពេលនោះ បារាំង នឹងទៅជាមិត្តរបស់ប្រជាជនកម្ពុជាវិញ ។ ព្រះរាជាបានឆ្លើយតបទៅវិញថា កម្ពុជាមានសេរីភាពពេញលេញជាមួយសៀម ហើយគ្មានបានចុះសន្ធិសញ្ញាអ្វីដែលចងកម្ពុជាដែរ ក៏ប៉ុន្តែព្រះអង្គ បានមានបន្ទូលដោយឥតលាក់លៀមប្រាប់ទៅនាយទាហានជើងទឹកនោះដែរថា សៀមនៅមានគុណលើកម្ពុជាច្រើន ក្នុងការដែលគេបានជួយដណ្តើមយកយើងចេញពីដៃពួកអាណ្ណាមមកវិញ នៅពេលដែលពួកអាណ្ណាមនេះ បានគ្រប់គ្រងកម្ពុជាតាមរបៀបរបបស្រុកគេទៅហើយ ដោយប្រើប្រាស់មន្ត្រីរបស់គេទៀត ។ តាមពិតទៅ គេសង្កេតឃើញថា ព្រះបាទនរោត្តម ហាក់ដូចជាចំណុះបញ្ជារបស់ស្តេចសៀមកាន់តែខ្លាំងឡើងៗ ចាប់តាំងតែពីពេលដែលព្រះអង្គបានយាងត្រលប់ចូលមកក្នុងរាជធានីឧត្តុង្គវិញ អាចប្រហែលជាស្តេចសៀម បានចាត់មន្ត្រីរបស់គេណាម្នាក់ឲ្យមកនៅអែបនឹងព្រះអង្គជាប់ ដែលយើងមិនទាំងស្គាល់ផងក៏មិនដឹង ។

ប្រទេសបារាំងមិនអាចគាំទ្រឲ្យប្រជាជនមួយដែលនៅជិតបង្កើយនឹងកូសាំងស៊ីន ក្លាយទៅជាចំណុះអធិរាជមួយដែលនៅឆ្ងាយដាច់ហើយដែលតែងតែ និងកំពុងមានបំណងចង់ដណ្តើមយកនគរទៅដាក់បញ្ចូលជា

ទឹកដីរបស់គេបានទេ ។ ដោយស្តេចសៀមបញ្ជូនរ៉េស៊ីដង់សៀមម្នាក់គឺពញារាជជាសម្ងាត់ឲ្យមកនៅឧត្តុង្គ អែបនឹងព្រះរាជា លោកឧត្តមនាវីក៏សម្រេចបញ្ជូនរ៉េស៊ីដង់បារាំងម្នាក់មកដែរ ដោយចេញមុខតែម្តង ។ នៅក្នុងខែមេសា ឆ្នាំ១៨៦២ លោកអនុនាវីឯក ឌូដាដឺឡាគ្រេ បានចេញកប៉ាល់ពីយ៉ាឌិញមកចុះនៅកំពង់ហ្លួង ជាមួយបេសកកម្មត្រូវបង្ហាញខ្លួននៅគ្រប់ទីកន្លែង ធ្វើដំណើរទៅសព្វទិសទីក្នុងប្រទេស ធ្វើដំណើរឡើងចុះតាមទន្លេ និងចូលគាល់ព្រះរាជាឲ្យបានញឹកញាប់ ដោយមិនចាំបាច់មានអន្តរការីនៅចន្លោះកណ្តាលរវាងព្រះរាជានិងគាត់ទេ ។

មិនយូរប៉ុន្មានលោកអនុនាវីឯកក៏ក្តាប់បានរឿងរ៉ាវទាំងអស់ដែលគេខិតខំលាក់នឹងគាត់ ហើយពិនិត្យឃើញថា នៅឧត្តុង្គ ស្តេចសៀមមានអំណាចខ្លាំងជាងព្រះបាទនរោត្តមទៅទៀត ។ គាត់បានរាយការណ៍អំពីស្ថានភាពនេះ ទៅទេសាភិបាលកូសាំងស៊ីន ។ លោកឧត្តមនាវី ឡាហ្គ្រង់ឌីយែរ ដែលជំនួសលោកឧត្តមនាវី បូណា បានសម្រេចថាត្រូវបញ្ចប់ស្ថានភាពនេះ ព្រោះថាបើបណ្តោយទុកយូរៗទៅ ឥទ្ធិពលរបស់សៀមនឹងកាន់តែរឹងមាំឡើងៗ ហើយបណ្តាលឲ្យមានគ្រោះថ្នាក់ចំពោះកម្ពុជា ក៏ដូចជាចំពោះបារាំង ។

នៅក្នុងខែកក្កដា ឆ្នាំ១៨៦៣ លោកឧត្តមនាវី ឡាហ្គ្រង់ឌីយែរ បានមកឡើងគោកនៅកំពង់ហ្លួង រួចបានធ្វើដំណើរទៅដល់ឧត្តុង្គមួយម៉ោងក្រោយមក ។ គាត់បានចូលគាល់ព្រះរាជា ទូលប្រាប់ព្រះអង្គអំពីស្ថានភាពស្រុកទេស ហើយក្រោយពីបានស្តាប់ការប្រកាសរបស់ព្រះរាជាថាព្រះអង្គនៅឯករាជពីប្រទេសសៀម គាត់បានស្នើព្រះអង្គឲ្យដាក់កម្ពុជានៅក្នុងអាណាព្យាបាលបារាំង ដែលនៅជិតខាងជាង ហើយដែលនឹងការពារកម្ពុជាឲ្យរួចផុតពីសត្រូវគឺអាណ្ណាម និងសៀម ធានាឲ្យព្រះរាជាណាចក្រស្ថិតស្ថេរតទៅសម្រាប់កូនចៅជំនាន់ក្រោយ ។ ព្រះរាជាបានយល់ព្រមទទួលយកអាណាព្យាបាលរបស់បារាំង ក៏ប៉ុន្តែទ្រង់នៅមានការញញើតញញើមខ្លះ ដោយទ្រង់បារម្ភខ្លាចដល់ពេលមួយបារាំងបោះបង់កូសាំងស៊ីនចោល ហើយទុកឲ្យកម្ពុជានៅទទួលរងកំហឹងរបស់អាណ្ណាម និងសៀម សាជាថ្មីទៀត ។ អ្វីដែលបណ្តារដ្ឋនៅឥណ្ឌូចិនបានដឹង គឺបារាំងមិនដែលរក្សាទឹកដីដែលខ្លួនដណ្តើមយកបានទេ ហើយរឿងនេះ រ៉េស៊ីដង់សៀមបានលើកយកមកទូលប្រាប់ព្រះរាជាម្តង ហើយម្តងទៀតក្រោមគ្រប់រូបភាព ។

មកដល់ពេលនោះ ដើម្បីធ្វើសៀមសប្បាយចិត្ត ឈប់គិតពីកម្ពុជា ហើយផ្តល់សេរីភាពឲ្យព្រះអង្គធ្វើការចរចាជាមួយបារាំង ព្រះបាទនរោត្តមបានសម្រេចប្រគល់ខែត្រពោធិសាត់ និងកំពង់ស្វាយទៅឲ្យសៀម នៅក្នុងថ្ងៃទី២ ខែមីនា ឆ្នាំ១៨៦៣ ។ សៀមបានយល់ព្រមទទួលយកខែត្រទាំង២ តែបានប្រកាសថាទុកឲ្យកម្ពុជាប្រើប្រាស់ជាប្រយោជន៍តទៅទៀតសិន ។ តាមពិតស្តេចសៀមចង់បានខែត្រទាំង២ណាស់ទៅហើយ ក៏ប៉ុន្តែមិនហ៊ានទទួលយកដោយខ្លាចអន្តរាគមន៍របស់បារាំង ណាមួយធ្វើយ៉ាងនេះដើម្បីអាចរក្សាឥទ្ធិពលរបស់ខ្លួន លើរាជវាំងឧត្តុង្គតទៅទៀតផង ។

ពេលនោះព្រះបាទនរោត្តម ដែលមានការប្រណែននឹងព្រះអនុជអ្នកអង្គម្ចាស់សដែលបានចាត់ចែងកិច្ចការ

ព្រះនគរបានយ៉ាងល្អនៅពេលអវត្តមានរបស់ព្រះអង្គ ហើយបារម្ភខ្លាចព្រះអនុជនេះទទួលបានប្រជាប្រិយភាពខ្លាំងជាង បានស្នើសុំឲ្យស្តេចសៀមកោះហៅព្រះអនុជយកទៅបាងកក ។ ស្តេចសៀម បានចាត់ឲ្យមន្ត្រីសៀមម្នាក់មករាជធានីឧត្តុង្គនៅក្នុងខែវិច្ឆិកា ឆ្នាំ១៨៦៣ ដើម្បីនាំអ្នកអង្គម្ចាស់សទៅ បើទោះជាព្រះអង្គប្រកែកមិនចង់យាងទៅក៏ដោយ ។ ស្តេចសៀមគិតថាខ្លួនអាចប្រើប្រាស់អ្នកអង្គម្ចាស់សនេះ ដើម្បីធ្វើជាឧបករណ៍សម្រាប់កកូរកកាយកម្ពុជាបាននៅពេលក្រោយៗទៀត ។

ស្តេចសៀមមិនសូវជាសប្បាយចិត្តប៉ុន្មានទេ ព្រោះព្រះអង្គចង់ឲ្យបារាំងចរចាជាមួយនឹងព្រះអង្គផ្ទាល់អំពីរឿងរ៉ាវដែលទាក់ទិនជាមួយកម្ពុជា និងព្រះរាជាឧត្តុង្គ ដែលព្រះអង្គបានចាត់ទុកថាគ្រាន់តែជាព្រះរាជាវង្សបន្ទាប់ពីព្រះអង្គប៉ុណ្ណោះ ។ នៅពេលដែលបានជ្រាបពីហេតុការណ៍នេះ ព្រះបាទនរោត្តម បានប្រកែកដោយព្រះទ័យក្រេវក្រោធ ហើយមិនចង់ឲ្យមានដូច្នេះតទៅទៀតទេ ទើបព្រះអង្គទាមទារឲ្យសៀមបញ្ជូនកេតនភណ្ឌរបស់ព្រះរាជាកម្ពុជាមកឲ្យវិញ ក្នុងនោះមានទាំងព្រះខ័នរាជ្យផង ដែលព្រះអង្គបាននាំយកទៅកាលពីខែសីហា ឆ្នាំ១៨៦១ ហើយទុកចោលនៅក្នុងរាជវាំងបាងកក មិនបានយកមកវិញទេ ។ ស្តេចសៀមបានឆ្លើយតបមកថា ទ្រង់នឹងយាងមកផ្ទាល់ព្រះអង្គ ដើម្បីរៀបចំអភិសេកព្រះរាជាកម្ពុជា ។ និយាយយ៉ាងនេះ ជាការបញ្ជាក់ឲ្យឃើញសាជាថ្មីនូវសិទ្ធិអធិរាជភាពរបស់សៀមមកលើកម្ពុជា និងថាស្តេចសៀមមានសិទ្ធិធ្វើអ្វីៗទាំងអស់មកលើព្រះរាជានៅឧត្តុង្គ ។ លោកឧត្តមនាវីបានប្រកែកមិនយល់ស្របតាម ហើយស្តេចសៀមក៏រក្សាកេតនភណ្ឌទាំងអស់ទុកទៅ (ខែវិច្ឆិកា ឆ្នាំ១៨៦៣) តែក៏មិនបានបដិសេធថា មិនឲ្យមកវិញនោះទេ ធ្វើឲ្យព្រះរាជាចេះតែរង់ចាំដូច្នេះរហូតទៅ ។ ស្តេចសៀមបានគិតថា មើលទៅប្រហែលជារដ្ឋាភិបាលទីក្រុងប៉ារីសនឹងមិនឲ្យសច្ចាប័ន លើសន្ធិសញ្ញាដែលបារាំងបានចុះហត្ថលេខាជាមួយស្តេចនរោត្តមទេ សមនឹងមានការយឺតយ៉ាវក្នុងការបញ្ជូនសំបុត្រទៅស្រុកបារាំងផង ការឲ្យសច្ចាប័ននេះ ហាក់ដូចជាត្រូវនឹងគំនិតគិតឃើញរបស់ខ្លួន ។

រហូតមកដល់ខែមករា ឆ្នាំ១៨៦៤ សៀមនៅតែមិនទាន់បញ្ជូនកេតនភណ្ឌរបស់ព្រះរាជាកម្ពុជាមកឲ្យវិញទេ ព្រះបាទនរោត្តមក៏សម្រេចឲ្យធ្វើការប្រកាសព្រះអង្គជាព្រះរាជា ដោយឲ្យរៀបចំស្វេតច្ឆត្រ ៧ជាន់ដាក់នៅពីលើព្រះរាជបល្ល័ង្ក ។ ដោយគ្មានព្រះខ័នរាជ្យ ការប្រកាសនេះហាក់បីដូចជាមិនគ្រប់គ្រាន់ទេ ក៏ប៉ុន្តែមានប្រសិទ្ធភាពសមល្មមដែរ ដោយប្រជារាស្ត្រទាំងអស់បានស្វាគមន៍អបអរ ។

នៅពេលនោះរាជវាំងបាងកកក៏មិនដឹងថាតើត្រូវធ្វើដូចម្តេចដែរ ស្រាប់តែបានទទួលដំណឹងនៅក្នុងខែមីនាថា រដ្ឋាភិបាលបារាំងបានឲ្យសច្ចាប័នលើសន្ធិសញ្ញាដែលបានចុះកាលពីខែកក្កដា ឆ្នាំ១៨៦៣ហើយ ។ ដោយមិនអាចត្រលប់ក្រោយបាន បាងកកក៏ស្នើទៅឧត្តមនាវីបារាំងនៅកូសាំងស៊ីនថាឲ្យរៀបចំព្រះរាជពិធីអភិសេកព្រះរាជាកម្ពុជាក្រោមអធិបតីភាពរបស់តំណាងពីរដ្ឋាភិបាលបារាំង និងសៀមរួមគ្នា ។ លោកឧត្តមនាវី ឡាហ្ក្រង់ឌីយែរ បានយល់ព្រមតាមសំណើនេះ ដែលធ្វើឲ្យគេនឹកដល់ការអភិសេកព្រះបាទអង្គឌួង ដោយតំណាងរបស់សៀម

និងអាណ្ណាមដែរ ពេលនេះបារាំងបានមកជំនួសអាណ្ណាម ម្ល៉ោះហើយត្រូវបន្តសិទ្ធិគ្រប់គ្រង លើកម្ពុជាជំនួសអាណ្ណាមវិញ ។ ដោយហេតុនេះ ព្រះបាទនរោត្តមត្រូវបានគេរៀបចំព្រះរាជពិធីអភិសេក ថ្វាយយ៉ាងឱឡារិកនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៨៦៤ ដោយមានកេតនភណ្ឌគ្រប់គ្រាន់ដែលបញ្ជូនមកពីបាងកក ។

នៅពេលនោះមានជនម្នាក់ឈ្មោះ អាស្វា បានប្រកាសខ្លួនថា ជាអ្នកអង្គម្ចាស់ភីម ដែលត្រូវជាបុត្រារបស់អតីតព្រះឧបរាជអង្គឯម បានចាប់បះបោរឡើង អង្គភីមនេះបានសុគតទៅហើយនៅបាងកកកាលពីឆ្នាំ១៨៥៥ ក្នុងព្រះជន្ម៣១ព្រះវស្សាដោយសាររោគឆ្អុត ។ តាមពិតអាស្វានោះជាខ្ញុំម្នាក់ដែលធ្លាប់បានប្រកាសខ្លួនថាជាអ្នកមានបុណ្យ ហើយត្រូវបានគេចាប់ខ្លួនបញ្ជូនយកមកថ្វាយព្រះបាទអង្គឌួងម្តងរួចមកហើយ នៅក្នុងឆ្នាំ១៨៥៩ ក៏ប៉ុន្តែព្រះអង្គបានលស់លាត្រាប្រណីទោស បញ្ជូនទៅឲ្យម្ចាស់វិញទៅ ។ ចាប់ពីពេលនោះមក ជននេះបានដើរគ្មានទិសដៅទៅសព្វទីកន្លែង ដោយប្រកាន់ថាខ្លួនជាអ្នកមានបុណ្យ ។ ឥឡូវនេះជននោះប្រកាសខ្លួនថា ជាអ្នកអង្គម្ចាស់មួយអង្គ ដែលអ្នកណាក៏ដឹងដែរថាទ្រង់បានសុគតទៅហើយ ។ ជននោះបានសរសេរលិខិត១ច្បាប់ទៅឲ្យលោកឧត្តមនាវី[៩៣] ទាមទារនូវសិទ្ធិទាំងឡាយដែលខ្លួនត្រូវទទួលបាន ។ លោកឧត្តមនាវីមិនបានឆ្លើយតបទៅវិញទេ ជននោះក៏ចាប់ផ្តើមប្រមែប្រមូលបក្សពួកនៅក្នុងខេត្តត្រាំង បាទីពាម និងព្រៃកប្បាស អ្នកខ្លះចូលរួមដោយជឿតាមការឃោសនា ខ្លះទៀតមានបំណងចង់ធ្វើចោរកម្ម ធ្វើឲ្យច្របូកច្របល់ពេញប្រទេស ។ មនុស្សមួយចំនួន ដែលអាស្វា ទទួលយកមកបញ្ចូលក្នុងជួរកងកម្លាំងរបស់ខ្លួន គឺជាអតីតទាហានរបស់ រាមាយោធា និងស្នងសូរ ។ ពួកបះបោរបានសម្លាប់ខុកញ៉ាចក្រីកែប ចៅហ្វាយខេត្តត្រាំង នៅក្នុងការប្រយុទ្ធមួយ រួចហើយបានដុតបំផ្លាញខេត្តកំពត ខ្ទេចខ្ទី ។ បន្ទាប់មក ដោយកងកម្លាំងរបស់ខ្លួនកើនកាន់តែច្រើនឡើង អាស្វាក៏ធ្វើដំណើរមកកាន់ភ្នំពេញ ក៏ប៉ុន្តែបានត្រូវទ័ពព្រះរាជាកាត់វាយតាមផ្លូវ ធ្វើឲ្យបរាជ័យ រួចដកថយទៅកាន់កូសាំងស៊ីនវិញទៅ ។ អាស្វាបានទទួលការការពារពីពួកអាណ្ណាមនៅក្នុងខេត្តវិញឡុង ចូវដុក និងហាទៀង និងពីស្តេចត្រាញ់របស់ខេត្តទាំងនោះផងដែរ ព្រោះអាណ្ណាមគិតថាសង្គ្រាម ស៊ីវិលនឹងធ្វើឲ្យកម្ពុជាចេះតែរេចរឹលទៅៗ ។ ប៉ុន្តែនៅទីបំផុតពួកអាណ្ណាមក៏ចាប់អាស្វាប្រគល់ឲ្យលោក ដឺឡាគ្រេ នៅចូវដុក នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ១៨៦៦ ។

---

[៩៣] នៅក្នុងសេចក្តីសំបុត្រនោះ អាស្វាបានអះអាងថា ខ្លួនគេគឺជាអ្នកអង្គម្ចាស់អង្គភីម ត្រូវជារាជបុត្ររបស់ព្រះអង្គឯម ដែលជាព្រះរាមរបស់ព្រះអង្គឌួង ។ ខ្លួនគេបានបែកបាក់ព្រាត់ឆ្ងាយពីព្រះមាតា និងព្រះជាយាព្រះនាមសួន ហើយត្រូវគេនាំខ្លួនយកទៅបាងកកនៅពេលដែលគេរៀបចំព្រះរាជពិធីអភិសេកព្រះបាទអង្គឌួង ធ្វើឲ្យគេកើតទុក្ខជាខ្លាំង ស្ទើរតែឆ្កួត ក៏ឲ្យមិត្តភក្តិក្លែងបន្លំថាខ្លួនស្លាប់ហើយៗបានយកសពខ្មែរម្នាក់ផ្សេងទៀតមកដាក់នៅក្នុងមឈូស ជំនួសវិញ ។ ឯព្រះអង្គភីម ផ្ទាល់ បានរត់គេចខ្លួនទៅរស់នៅជាមួយពួកស្មៀង និងព្នង ទើបតែចេញមកវិញនេះដើម្បីកេណ្ឌទ័ពទាមទារយកសិទ្ធិរបស់ខ្លួនមកវិញ ។ នៅកម្ពុជាសព្វថ្ងៃនៅមានអ្នកខ្លះយល់ថារឿងនេះជាការពិត ។

នៅពេលដែលព្រឹត្តិការណ៍នេះបញ្ចប់ទៅនៅភាគនិរតីព្រះរាជាណាចក្រ មានព្រឹត្តិការណ៍មួយផ្សេងទៀតបានកើតឡើងនៅឧត្តុង្គ ។ ថ្ងៃមួយព្រះរាជាបានទទួលភ្នាក់ងារម្នាក់មកពីបាងកក សុំយាងព្រះអង្គឲ្យធ្វើដំណើរទៅកំពត ដើម្បីទៅទទួលស្តេចសៀមដែលរង់ចាំជួបជាមួយព្រះអង្គ ។ ព្រះរាជាបានប្រាប់លោក ឌូដាដឺឡាគ្រេ អំពីការអញ្ជើញនេះ ហើយបានមានព្រះបន្ទូលថានេះគឺជាកិត្តិយសមួយចំពោះព្រះអង្គហើយ ទ្រង់នឹងយាងទៅតាមការអញ្ជើញ ។ លោក ឌូដាដឺឡាគ្រេ មិនចង់ឲ្យព្រះរាជាយាងទៅទេ ហើយបានទូលតបទៅវិញថាស្តេចសៀមមិនបានយាងមកទេ ។ ព្រះរាជាមិនព្រមស្តាប់ឡើយ ហើយបានយាងទៅកំពត ដោយមានលោក ឌូដាដឺឡាគ្រេ ជូនដំណើរទៅផង ។ ទៅដល់កំពត ព្រះអង្គទទួលបានសារលិខិតរបស់ស្តេចសៀមមួយច្បាប់ ទូលព្រះអង្គថា ស្តេចសៀមមិនបានយាងមកតាមការណាត់ទេ ហើយសូមឲ្យព្រះអង្គយាងត្រលប់ទៅរាជធានីវិញចុះ ។ ព្រះបាទនរោត្តមទ្រង់ខ្វល់ជាខ្លាំង ក៏យាងត្រលប់ទៅឧត្តុង្គវិញទាំងខ្មាស់អៀន ដែលត្រូវរំខានអត់ប្រយោជន៍ដូច្នេះ ។

នៅសម័យនោះ គឺនៅចុងឆ្នាំ១៨៦៥ មានខ្មែរម្នាក់ទៀតបានប្រកាសខ្លួនថាជាពោធិកំបោរ[៩៤] ត្រូវជាបុត្រារបស់ព្រះអង្គច័ន្ទ បង្ហាញខ្លួននៅក្រចេះ រួចនៅតាមបណ្តាខេត្តខាងកើត ចុះរហូតទៅដល់ទឹកដីកូសាំងស៊ីននៅត្រាវិញ (បាសាក់) ។ ប្រជាជនជាច្រើននាក់បានជឿតាមសម្តីរបស់ជននេះ ហើយនាំគ្នាដើរតាមជាហូរហែ ។

លោកឧត្តមនាវីជាចៅហ្វាយក្រុងសាយហ្គុនបានកោះហៅឈ្មោះនេះឲ្យទៅជួប ហើយបានឃាត់ខ្លួន ទុក ។ តាមពិតជននោះមានឈ្មោះថា ពោធិ អ្នកខ្លះនិយាយថាកើតនៅត្បូងព្រះឃ្លាំងក្នុងខេត្តកំពង់ស្វាយ តែអ្នកខ្លះថាជននេះមានកំណើតជាជនជាតិភាគតិចរដែ ។ ទោះជាយ៉ាងណាក្តី ជននេះបានធ្វើដំណើរចេញពីភូមិពួករដែ មកមុននឹងមកដល់ក្រចេះ ។ ជននោះមានប្រពន្ធ៤នាក់ នារីព្នងម្នាក់ នារីអាណ្ណាមម្នាក់ និងនារីខ្មែរ២នាក់ ។ មកដល់ក្រចេះគាត់បានយកប្រពន្ធខ្មែរម្នាក់ទៀត ។ ពោធិបានសម្លាប់ចៅហ្វាយខេត្តក្រចេះ និងសម្បុកដែលប្រកែកមិនព្រមគោរពបញ្ជារបស់ខ្លួន រួចបានទៅសង់បន្ទាយមួយនៅក្នុងភូមិឈើទាលភ្លោះ នៅក្នុងខេត្តកញ្ជរ ។ ពេលនោះអាណាខេត្តទាំងឡាយនៅខាងកើតទន្លេមេគង្គ បានចុះចូលជាមួយនឹងជនក្បត់នេះ ។ ព្រះរាជាបានបញ្ជាឲ្យលោកក្រឡាហោមចេញតាមវាយទៅលើពោធិកំបោរដល់បាភ្នំ នៅក្នុងខែមិថុនា ឆ្នាំ១៨៦៦ ។ មុនដំបូងទ័ពពោធិកំបោរទទួលបានជ័យជម្នះ ប៉ុន្តែបន្ទាប់មកក៏បរាជ័យវិញ ហើយបានគេចខ្លួនបាត់ទៅ ។ ប៉ុន្មានថ្ងៃក្រោយមក ពោធិកំបោរបានបង្ហាញខ្លួនឡើងវិញ ក៏ត្រូវទ័ពបារាំងវាយ លើកទី១ នៅថ្ងៃទី២៥-២៦ ខែវិច្ឆិកា ឆ្នាំ១៨៦៦ លើកទី២ នៅក្នុងខែមករា ឆ្នាំ១៨៦៧ ។ ពោធិកំបោរបានបាត់ខ្លួនម្តងទៀត បន្តិចក្រោយមកលេចឃើញនៅក្នុងខេត្តបា-

[៩៤] អ្នកអង្គម្ចាស់ពោធិកំបោរ នេះ បានសុគតទៅក្រោយពីប្រសូត្របានប៉ុន្មានម៉ោង នៅឧត្តុង្គ ។

រាយណ៍ និងកំពង់លែង ហើយធ្វើការគំរាមកំហែងមកលើរាជធានីឧត្តុង្គ ។ ពោធិកំបោរបានត្រូវវាយឲ្យបរាជ័យជាច្រើនលើកច្រើនសា ក៏បាត់ខ្លួនម្តងទៀតរួចមកដល់កំពង់ធំ ។ នៅកំពង់ធំនោះ អ្នកស្រុកស្រីៗបានជំរុញឲ្យប្តីខ្លួនដេញតាម ចាប់ពោធិកំបោរបាននៅក្នុងត្រពាំងទឹក រួចសម្លាប់ចោលទៅ ។ គេបានកាត់ក្បាលពោធិកំបោរប្រឡាក់អំបិលផ្ញើថ្វាយព្រះរាជា ដែលទ្រង់បានចេញបញ្ជាឲ្យយកទៅដោតនៅចុងដើមឫស្សីមួយ នៅភ្នំពេញ (ខែធ្នូ ឆ្នាំ១៨៦៧) ។

កន្លងមក នៅពេលដែលមានព្រឹត្តិការណ៍អស់នេះកើតឡើង ក្រោយពីបានពិនិត្យឃើញថាពួកអាជ្ញាធរអាណ្ណាមតែងតែជួយពួកបះបោរ ដោយផ្តល់ឲ្យជ្រកកោនលើទឹកដីឬជួនកាលជួយទាំងកម្លាំងថែមទៀត បញ្ជាក់ឲ្យឃើញថា ពួកនេះមានបំណងចង់បង្កការរំខានដល់សកម្មភាពរបស់បារាំងនៅកម្ពុជា លោកឧត្តមនាវី ឡាហ្គ្រង់ឌីយែរ បានសម្រេចប្រកាសថា ត្រូវបញ្ចប់ការដណ្តើមយកកូសាំងស៊ីនភាគខាងក្រោមទាំងមូលតែម្តង ដោយកាត់យកខែត្រ៣ថែមទៀតដែលខ្មែរបានបោះបង់ចោលឲ្យអាណ្ណាម គឺចូវដុក វិញឡុង និងហាទៀងដាក់បញ្ចូលជាមួយខែត្រ៣មុន គឺបៀនហ៊ វ៉ាឌិញ និងឌិញ ទឿង ។ ការកាត់យកទឹកដីនេះប្រព្រឹត្តទៅនៅក្នុងខែមិថុនា ឆ្នាំ១៨៦៧ ៖ វិញឡុង បានធ្លាក់ចូលមកក្នុងដៃបារាំងនៅថ្ងៃទី២០, ចូវដុក ក្នុងថ្ងៃទី២២, ហើយហាទៀងនៅក្នុងថ្ងៃទី២៤ ដោយគ្មានអស់គ្រាប់កាំភ្លើង១គ្រាប់ ។ ចៅហ្វាយលើទឹកដីទាំងនោះ គឺផានថានយ៉ាង ដោយពិនិត្យឃើញថាមិនអាចតទល់នឹងពួកបារាំង បានប្រកែកមិនព្រមចូលបម្រើបារាំងតាមសំណើរបស់លោកឧត្តមនាវី ឡាហ្គ្រង់ឌីយែរ ទេតែបានចេញបញ្ជាឲ្យប្រគល់ទីក្រុងទាំងអស់នោះឲ្យបារាំងវិញ រួចហើយបានផឹកថ្នាំសម្លាប់ខ្លួនបាត់ទៅ ដើម្បីជាការដាក់ទោសចំពោះអសមត្ថភាពក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ។

ដោយហេតុនេះ បារាំងមានព្រំប្រទល់ជាប់ពីខាងត្បូងកម្ពុជាហើយ ហើយក៏មិនអាចមានរឿងអ្វីកើតឡើងដែលបារាំងមិនបានដឹងនោះទេ ។ ស្ថានភាពនេះអាចឲ្យយើងផ្តល់ជំនួយប្រកបទៅដោយប្រសិទ្ធភាពដល់ព្រះរាជាកម្ពុជា ជាអាវុធយុទ្ធភណ្ឌដែលព្រះអង្គត្រូវការក្នុងការប្រយុទ្ធតទល់នឹងពួកបះបោរ ជួនកាល ជាទ័ពដឹកនាំដោយនាយទាហានបារាំងតែម្តង ក៏មាន ។

ដោយមានការចាក់ចុចពីតំណាងស្តេចសៀមនៅឧត្តុង្គ ព្រះបាទនរោត្តម បានលួចចុះសន្ធិសញ្ញាមួយ ជាសម្ងាត់ជាមួយសៀម ប្រហាក់ប្រហែលនឹងសន្ធិសញ្ញាដែលព្រះអង្គបានចុះជាមួយបារាំងដែរ ។ នៅខែមីនា ឆ្នាំ១៨៦៧ ពេលពិនិត្យឃើញថាបារាំងមានការសង្ស័យអំពីសន្ធិសញ្ញានេះ អភិបាលរាជធានីបាងកក បានប្រកាសយ៉ាងប្រញាប់ថាគេបានចុះសន្ធិសញ្ញាមួយនេះជាមួយព្រះបាទនរោត្តមនៅក្នុងសម័យមួយ ដែលពួកគេមិនបានដឹងថាកម្ពុជាបានចុះសន្ធិសញ្ញាមួយជាមួយបារាំងរួចទៅហើយទេ ។ នៅពេលបានដឹងពីសន្ធិសញ្ញាជាមួយបារាំងនេះ គេបានប្រកាសបដិសេធសន្ធិសញ្ញារបស់គេជាអសារបង់ហើយដើម្បីកុំឲ្យរំខានដល់ការអនុវត្តន៍សន្ធិសញ្ញាជាមួយបារាំងផង ។ ក៏ប៉ុន្តែនៅពេលនោះដែរ ស្តេចសៀមដែលទើបតែបានចុះសន្ធិសញ្ញាមួយជាមួយ

កុងស៊ុលបារាំងប្រចាំរាជធានីបាងកក បានទទួលស្គាល់ថាទឹកដីអង្គរ និងបាត់ដំបងជារបស់សៀម ទាំងដែលកុងស៊ុលនោះមិនបានដឹងអំពីស្ថានភាពពិតប្រាកដ ហើយក៏មិនបានជូនដំណឹងដល់លោកឧត្តមនាវីជាអភិបាលក្រុងសាយហ្គន ឲ្យដឹងផងទេ ។

គេបានដឹងអំពីការមានសន្ធិសញ្ញានេះនៅឯសាយហ្គន នៅក្នុងខែកក្កដា ឆ្នាំ១៨៦៧ ។ រដ្ឋាភិបាលបារាំងនាសម័យនោះដែលមិនបានយកចិត្តទុកដាក់ដល់រឿងនេះ បានឲ្យសច្ចាប័នដោយមិនបានគិតវែងឆ្ងាយ ជាហេតុធ្វើឲ្យខេត្តដ៏មានសារសំខាន់ទាំង២នេះ ដែលលោកឧត្តមនាវី និងលោកដឺឡាហ្គ្រង់ឌីយែរ មានបំណងទាមទារយកមកប្រគល់ឲ្យកម្ពុជាវិញតាំងតែពីពេលនោះម្ល៉េះ ត្រូវបាត់បង់ទៅអស់កាល៤០ឆ្នាំ ថែមទៀត ។ លោកឧត្តមនាវី មិនសប្បាយចិត្តទេ រីឯលោក ដឺឡាគ្រេ ដែលជាតំណាងអាណាព្យាបាលបារាំងប្រចាំនៅរាជធានីឧត្តុង្គវិញ បានខឹងសម្បាជាខ្លាំង ។ ដើម្បីកុំឲ្យលោកដឺឡាគ្រេ ខឹងខ្លាំងពេក ព្រះរាជាកម្ពុជាបានប្រកែកថា ទ្រង់មិនបានដឹងអ្វីទេ ហើយថា ព្រះរាជាកម្ពុជាមុនៗមិនដែលបាន ទទួលស្គាល់ការដែលស្តេចសៀមយកខេត្តបាត់ដំបង និងអង្គរនេះម្តងណាទេ ដូចនេះ ប្រទេសបារាំងដែលជាអ្នកការពារកម្ពុជាក៏គ្មានសិទ្ធិអ្វីយកទឹកដីកម្ពុជាទៅប្រគល់ឲ្យគេដោយគ្មានការឯកភាពពីព្រះអង្គដែរ ។ ព្រះរាជបន្ទូលរបស់ព្រះរាជានេះត្រឹមត្រូវណាស់ គឺដោយសារព្រះអង្គបានទទួលឥទ្ធិពលខ្លះៗពីលោកតំណាង ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ បារាំងមានចំណងការទូតជាមួយសៀម ម្ល៉ោះហើយមិនអាចធ្វើអ្វីបានឡើយ ។ មកដល់សព្វថ្ងៃនេះ យើងបានដោះស្រាយកំហុសឆ្គងខាងលើនេះរួចវិញហើយៈ បាត់ដំបង អង្គរ ស៊ីសុផុន ម្លូព្រៃ ទន្លេរពៅ ស្ទឹងត្រែង និងទឹកដី ទាំងអស់នៅខាងត្បូងភ្នំដងរែក ព្រមទាំងខេត្តកោះកុង នៅលើឈូងសមុទ្រសៀមផង បានវិលត្រលប់មកជាដីកម្ពុជាវិញហើយ ក្រោយរយៈពេលកន្លះសតវត្សរ៍ ។ ព្រះបាទនរោត្តម និងព្រះវររាជមាតា ដែលមានបំណងឲ្យបារាំងទាមទារយកទឹកដីទាំងនោះមកឲ្យកម្ពុជាវិញយ៉ាងខ្លាំងនោះ បានសុគតអស់ទៅហើយ ដោយមិនបានឃើញទឹកដីទាំងនោះ វិលត្រលប់មកវិញផងទេ ។

ព្រះបាទនរោត្តម បានសម្រេចលើករាជធានីមកតាំងនៅភ្នំពេញវិញ តាំងពីឆ្នាំ១៨៦៣មកម្ល៉េះ ។ ព្រះអង្គបានយាងមកពិនិត្យទីតាំងថ្មីនៅត្រង់កណ្តាលភូមិតាកែវ ចំពីខាងមុខទន្លេចតុមុខនៅដំណាច់ឆ្នាំមុន បន្ទាប់មក ទ្រង់ក៏ចាត់ឲ្យរៀបចំពង្រាបដីភ្លាម ។ ដើម្បីមានថវិកាចំណាយក្នុងការរៀបចំរាជធានីថ្មីនេះ ព្រះរាជាបានរៀបចំឲ្យមានការយកពន្ធលើបុគ្គល យកពន្ធបនអាភៀនឡើងវិញ ដែលព្រះបិតាព្រះអង្គបានការពារមិនឲ្យយក ហើយក៏បានរៀបចំប៉ុស្តិ៍គយមួយចំនួន ដែលគេបិទក្នុងមួយរយៈពេលប្រទេសមានអសន្តិសុខកន្លងមកឡើងវិញផងដែរ ។ វិធានការទី៣នេះគ្មានការតវ៉ាអ្វីទេ ។ មន្ត្រីចាស់ៗដែលធ្លាប់តែឃើញគ្រឿងញៀននេះធ្វើចរាចរដោយសេរី ក្នុងព្រះរាជាណាចក្រ បានមានប្រតិកម្មតបទៅនឹងវិធានការទី២ ។ ក៏ប៉ុន្តែវិធានការទី១ គឺការបង្កើតពន្ធដារប្រភេទថ្មីមួយដែលមិនដែលមានពីមុនមក មានផលវិបាកអាក្រក់ជាងគេ គឺបានធ្វើឲ្យប្រជាជនទូទាំងប្រទេស មិនពេញចិត្ត ។ ពេលនោះ បើសិនជាគ្មានវត្តមានរបស់បារាំងនៅជួយទេ ប្រហែលជាព្រះបាទនរោត្តមត្រូវបានព្រះអនុជវត្តា

ឬស៊ីសុវត្ថិ បើពុំនោះទេគឺពួកបះបោរអាស្វា និងពោធិកំបោរ ទម្លាក់ពីលើរាជបល្ល័ង្ក បាត់ទៅហើយ[៩៥] ។ គឺអំណាច និងការគាំទ្ររបស់បារាំង ដែលជួយព្រះអង្គឲ្យគង់នៅលើរាជបល្ល័ង្កជាប់ និងបានជួយឲ្យស្រុកនេះ មានសន្តិភាព ឡើងវិញ ឲ្យពាណិជ្ជកម្មចាប់កំណើតជាថ្មី ហើយអភិវឌ្ឍន៍រីកលូតលាស់ គ្មានអ្នកណាគិតស្មានដល់ ខុសពីប៉ុន្មានឆ្នាំ មុនឆ្ងាយណាស់ ។ ព្រះរាជាណាចក្រមានសុភមង្គល អ្នកតូចតាចក៏មានប្រាក់កាសចាយ អ្នកស្រុកក៏លែងរអ៊ូរទាំ ហើយចាប់គោរពព្រះរាជាឡើងវិញ និងទម្លាប់ខ្លួន ជាមួយនឹងអាណាព្យាបាលរបស់បារាំង ។

សន្តិភាពបានកើតមានឡើងរវាងស្តេចនរោត្តមជាមួយនឹងអនុជរបស់ព្រះអង្គ គឺអ្នកអង្គម្ចាស់ស៊ីសុវត្ថិ ដែលមានឋានៈជាព្រះកែវហ្វ៊ានៅក្រោមរជ្ជកាលរបស់ព្រះបិតាព្រះអង្គ នៅពេលដែលព្រះអង្គជាព្រះឧបរាជ ។ អ្នកអង្គម្ចាស់ស៊ីសុវត្ថិ បានគង់នៅឯសាយហ្គនចាប់តាំងពីខែឧសភា ឆ្នាំ១៨៦៦មក ហើយព្រះរាជា ទ្រង់ ប្រទានប្រាក់ឧបត្ថម្ភចំនួន១៨០ណែន (ប្រហែលជា១ម៉ឺនហ្វ្រង់)ក្នុង១ឆ្នាំៗ ដែលអាចឲ្យព្រះអង្គរស់ជាមួយ មហេសី និងសេនាអាមាត្យបានយ៉ាងស្រួល ។ ដល់មកខែឧសភា ឆ្នាំ១៨៧០ ព្រះរាជាបានតែងតាំងព្រះអនុជ ជាព្រះឧបរាជទាំងបន្ទុំព្រះទ័យ តាមសំណើរបស់លោកទេសាភិបាលទឹកដីកូសាំងស៊ីន ។

និយាយអំពីព្រះអនុជមួយព្រះអង្គទៀត គឺអ្នកអង្គម្ចាស់វត្ថា ក្រោយពីទទួលបរាជ័យដណ្តើមយករាជ សម្បត្តិពីព្រះបាទនរោត្តមមិនបានរួចមក បានគេចព្រះអង្គទៅគង់នៅឯដីកំពង់ធំ ខែត្រកំពង់ស្វាយ រួចទៅនៅ ខែត្រស្ទោង បន្ទាប់មកទៀតទ្រង់បាននាំបក្សពួកប្រហែលជា១០០នាក់ ទៅគង់នៅខែត្រសម្បូរតាមមាត់ទន្លេ មេគង្គត្រើយខាងស្តាំ ។ នៅទីនោះមិនសូវមានប្រជាជនរស់នៅទេ តែអ្នកស្រុកបានបង់ពន្ធជាស្រូវថ្វាយ ។ គ្មាននរណាគិតពីព្រះអង្គទៀតទេ តែព្រះអង្គចេះតែទន្ទឹងរង់ចាំ ក្រែងមានឱកាសបានយាងមកសោយរាជ្យ សម្បត្តិវិញ រហូតទាល់តែទ្រង់សុគតទៅ នៅក្នុងភូមិក្រាក់ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៨៩១ ក្នុងព្រះជន្មាយុ ៥០ ព្រះវស្សា ។

នៅក្នុងឆ្នាំ១៨៧២ មានអតីតជំនួយការរបស់ពោធិកំបោរម្នាក់ បានចេញបង្ហាញខ្លួននៅក្នុងខែត្រត្បូងឃ្មុំ ជាមួយទ័ព៨រយនាក់ ។ ពួកនេះចេញពីស្រុកពួកស្មៀងដែលមិនចេះចំណុះគេ តែត្រូវបង្ខំចិត្តវិលត្រលប់ទៅទី នោះវិញ ដោយមានទ័ពលោកទេសាភិបាលកូសាំងស៊ីនដេញប្រកិតពីក្រោយ ។

នៅខែកក្កដា និងខែសីហា ឆ្នាំដដែល ព្រះរាជាទ្រង់បានយាងធ្វើព្រះរាជទស្សនកិច្ចយ៉ាងយូរ នៅហុងកុង

---

[៩៥] លោកឌូដាដឺឡាគ្រេបានសរសេរនៅក្នុងថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៨៦៥ ថា ៖ "ព្រះរាជាមិនសូវមានប្រជាប្រិយភាពប៉ុន្មានទេ ដោយសារអតីតកាលរបស់ព្រះអង្គ និងដោយសារទ្រង់ចំណាយច្រើនលើសលប់" ។ ឯលោក ប៉ូធីយេ ក៏បាននិយាយដែរនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៨៦៧ ថា ៖ "អ្នកណាៗក៏ស្អប់ព្រះរាជាដែរ គ្មាននរណាម្នាក់ចូលចិត្តព្រះអង្គទេ" ។ តាមពិតទៅ ទាំងប្រជារាស្ត្រទាំង នាម៉ឺនសព្វមុខមន្ត្រី គេចូលចិត្តព្រះអនុជស៊ីសុវត្ថិ ខ្លាំងជាង ។

ម៉ាការ៉ៅ កង់តុង និងម៉ានីល ដោយជិះនាវាចម្បាំងឈ្មោះ ឡឺប៊ូវីយ៉ាន ដែលលោកទេសាភិបាលដឺកូសាំងស៊ីន ប្រគល់ថ្វាយសម្រាប់ដូនដំណើរ[៩៦] ។

ពេលយាងត្រលប់មកពីទស្សនកិច្ចវិញ ព្រះរាជាកម្ពុជាហាក់ដូចជារំភើបនឹងអ្វីៗដែលព្រះអង្គបានទតឃើញណាស់ ហើយយល់ឃើញថាព្រះអង្គត្រូវរៀបចំប្រទេសរបស់ព្រះអង្គឲ្យមានការវិវត្តន៍ដូចគេ ។ ក៏ប៉ុន្តែព្រះរាជបំណងនេះមានតែក្នុងមួយរយៈខ្លីប៉ុណ្ណោះ មិនបានប៉ុន្មានផងទ្រង់ក៏ត្រលប់មកប្រកាន់តាមទម្លាប់ចាស់វិញ ហើយមិនបានធ្វើអ្វី គិតអ្វី ជាប្រយោជន៍ដល់ប្រជារាស្ត្ររបស់ព្រះអង្គបន្តិចណាទេ ទោះបីជាស្ដេចសៀមបានបង្ហាញឲ្យឃើញឧទាហរណ៍ខ្លះៗក៏ដោយ ។ នោះហើយជាគ្រោះថ្នាក់ ។ តើប្រទេសបារាំងសុខចិត្តបណ្ដោយឲ្យជាតិសាសន៍មួយ ដែលគេបានស្រោចស្រង់ចេញពីការប្រញីដណ្ដើមហែកហួរគ្នា ហើយសព្វថ្ងៃស្ថិតនៅក្រោមអាណាព្យាបាលរបស់គេឲ្យរលត់រលាយទៅបានដែរឬទេ? ប្រាកដណាស់ថា បារាំងនឹងជំរុញព្រះរាជាឲ្យចាប់ផ្ដើមធ្វើកំណែទម្រង់ខ្លះៗជាបន្ទាន់ ដោយមិនមានធ្វើឲ្យប៉ះពាល់ដល់ព្រះ រាជបុព្វសិទ្ធិរបស់ព្រះអង្គទេ ដូចជានាំព្រះអង្គឲ្យរៀបចំខ្លួនធ្វើការកែប្រែខ្លះដែលនឹងធ្វើឲ្យមានការផ្លាស់ប្ដូរបន្តិចម្ដងៗ ដើម្បីប្រែក្លាយប្រជាជនកម្ពុជា ទៅជាប្រជាជនមួយប្រកបទៅដោយមធ្យោបាយអាចរស់រានមានជីវិតរហូតទៅ ។

ប្រទេសបារាំងមិនមានញញើតទេ ដើម្បីបញ្ជាក់ឲ្យឃើញអន្តរាគមន៍របស់ខ្លួនមកលើកម្ពុជាថា ពិតជាត្រឹមត្រូវ ។ គេបានសម្រេចចិត្ត ធ្វើសកម្មភាពទៅលើប្រជារាស្ត្រ តាមរយៈព្រះរាជា ដោយហេតុនោះហើយបានជាព្រះបាទនរោត្តមបានចុះព្រះហស្តលេខាលើព្រះរាជក្រឹត្យមួយចំនួននៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៨៧៧ លុបបំបាត់ឋានៈឧបរាជចេញ ដូចដែលគេបានអនុវត្តរួចមកហើយនៅស្រុកសៀម លុបឋានៈឧភយោរាជដែលអស់ន័យទៅហើយ លុបឋានៈព្រះវររាជជននីដែលនៅឯបាងកកឯណោះគឺជាឋានៈរបស់ព្រះវររាជមាតា តែគ្មានអំណាចអ្វីទេ ព្រមទាំងលុបបំបាត់ឋានៈ និងមុខងាររមន្ត្រីមួយចំនួនធំ ដែលគ្មានការងារអ្វីជាសំខាន់ ។

ចំនួនខែត្រក៏ត្រូវកែប្រែ និងកាត់បន្ថយ ។ ការយកពន្ធដារឈប់ប្រគល់ឲ្យពួកចិនប្រមូលទៀតហើយ ព្រោះពួកនេះតែងតែកាត់យកមួយចំណែកធំសម្រាប់ខ្លួនឯង ។ ល្បែងស៊ីសងមួយចំនួនត្រូវហាមឃាត់ ដូចជា ល្បែងសត្វ ៣៦បែប ល្បែងឯទៀតៗត្រូវរៀបចំត្រួតពិនិត្យ ។ កំណែនធ្វើការចំនួន៩០ថ្ងៃអាចគេចផុតបាន ដោយបង់ប្រាក់ចំនួន២០ហ្វ្រង់ ស្មើនឹង៤ពីយ៉ាស[៩៧] ។ កំណែទម្រង់តុលាការ ដោយចាត់តាំងតែចៅក្រមដែលបានសិក្សា

---

[៩៦] ព្រះរាជាទ្រង់បាននាំយកពួកភ្លេងមួយក្រុម មានឈ្មោះថាតាហ្កាល់ ពីម៉ានីលមកកម្ពុជា ដែលជាប្រភពនៃក្រុមភ្លេងមួយក្រុមដែលតែងសំដែងជូនសាធារណជនទស្សនា នៅវត្តភ្នំ រាល់ថ្ងៃអាទិត្យចាប់ពីម៉ោង៥កន្លះដល់ម៉ោង៦កន្លះ និងរាល់ថ្ងៃព្រហស្បតិ៍ចាប់ពីម៉ោង ៨កន្លះ ដល់ម៉ោង ៩កន្លះ ។

[៩៧] សព្វថ្ងៃនេះ ៤ពីយ៉ាស ស្មើនឹង ៩ហ្វ្រង់កន្លះ ។

ចេះចាំច្បាប់ច្បាស់លាស់ ។ លុបបំបាត់មិនឲ្យមានខ្ញុំបម្រើដែលមិនឲ្យរំដោះខ្លួនចេញ និងរៀបចំលុបបំបាត់ចោលទាំងស្រុង រង់ចាំតែព្រះរាជាចេញច្បាប់កំណត់ឲ្យផ្តល់ប្រាក់បៀវត្សឲ្យ ដែលពួកខ្ញុំទាំងនោះអាចកាត់សងបំណុលរបស់គេបាន ។

កំណែទម្រង់ទាំងអស់នេះនឹងធ្វើឲ្យស្ថានភាពកម្ពុជាកាន់តែល្អប្រសើរឡើង ប្រសិនបើគេអនុវត្តបានត្រឹមត្រូវ ព្រោះថាវាមានអត្ថប្រយោជន៍ផ្ទាល់ភ្លាមតែម្តង ហើយនឹងទាក់ទាញឲ្យមានកំណែទម្រង់ផ្សេងៗជាបន្តទៀត ដែលនឹងនាំមកនូវការរីកចម្រើន ហើយនឹងធ្វើឲ្យប្រទេសឈានឡើងមានឋានៈស្មើនឹងបណ្តាប្រទេសស៊ីវិល័យឯទៀតៗ និងមានជីវិតរស់រានជាអង្វែងតទៅ ។ ក៏ប៉ុន្តែឥទ្ធិពលរបស់បារាំងទៅលើព្រះរាជាពេលនោះ ដែលធ្លាប់តែគ្មានកម្រៃជាយូរណាស់មកហើយ ដែលមានឆន្ទៈតែមិនច្បាស់លាស់ មិនទៀងទាត់ ខ្វះការប៉ិនប្រសប់ ហើយអកម្ម គ្មានគំនិតជាប់បន្ត ដោយហេតុនេះព្រះអង្គនៅខ្សោយខ្លាំងណាស់ ។ បារាំងគ្មានឥទ្ធិពលបន្តិចបន្តួចទៅលើពួកមន្ត្រីដែលកំពុងតែព្រួយខ្លាចចំពោះការផ្លាស់ប្តូរដែលគ្រោងទុកជាមុន ពីព្រោះនោះគឺការបញ្ចូលរបៀបថ្មី ដែលធ្វើឲ្យពួកគេងឿងឆ្ងល់ ប៉ះពាល់ដល់ទម្លាប់ភ័យព្រួយខ្លាចបាត់បង់ផលប្រយោជន៍របស់គេ ។ ពួកស្រីៗនៅក្នុងព្រះរាជវាំង មានពួកអ្នកអង្គម្ចាស់ក្សត្រី ពួកស្រីស្នំ ពួកភីលៀង បានប្រឆាំងយ៉ាងខ្លាំងចំពោះការប្រែប្រួលទាំងឡាយ បានព្រួតគ្នាធ្វើប្រតិកម្មតបមួយ ដែលបារាំងមិនដឹងតទល់យ៉ាងណា ឬក៏មិនបានឲ្យតម្លៃដល់ ដោយធ្វេសប្រហែស ។

ចំណែកប្រជាជនវិញ មិនមានព្រួយបារម្ភអ្វីទេ ដោយគិតថាបារាំងមកជួយរៀបចំសណ្តាប់ធ្នាប់ឲ្យជួយធ្វើឲ្យមានសន្តិសុខនៅក្នុងព្រះរាជាណាចក្រ ខុសពីអាណ្ណាម និងសៀម ។ ប្រជាជនធ្លាប់បានឃើញបារាំងធ្វើដំណើរពាសពេញស្រុក ហើយគាត់រីករាយនឹងឃើញអ្នកតំណាងអាណាព្យាបាលរស់នៅភ្នំពេញ ក្បែរព្រះរាជាតែគ្មានរវីរវល់លូកដៃចូលក្នុងកិច្ចការអ្វីៗទេ ។ ការបើកឲ្យធ្វើនាវាចរតាមទន្លេពីកូសាំងស៊ីនឡើងវិញ ដែលពីមុនអាណ្ណាមបិទជិត ធ្វើឲ្យមាននាវាប្រើចំហាយជាច្រើនឡើងមកដល់ទឹកដីព្រះរាជាណាចក្រ ធ្វើឲ្យពាណិជ្ជកម្មរីកចម្រើន និងធ្វើឲ្យប្រជាជនកម្ពុជារីករាយសប្បាយចិត្តជាខ្លាំង ហើយគេបាននិយាយថា នេះគឺដោយសារបារាំងម៉្លោះហើយអ្នកស្រុកស្រលាញ់បារាំងណាស់ ។

ក៏ប៉ុន្តែ ដើម្បីបញ្ជាក់ពីអាណាព្យាបាល និងវត្តមានរបស់បារាំងនៅកម្ពុជា និយាយឲ្យខ្លីថាដើម្បីអាចធ្វើការកែប្រែស្រុកនេះស្របទៅតាមកម្មវិធីមួយ ដោយផ្លាស់ប្តូរស្ថាប័នចាស់គំរិលចេញ បារាំងត្រូវការឲ្យមានភ្នាក់ងារដែលមានការគិតគូរក្នុងការបំពេញភារកិច្ចរបស់ខ្លួន មានស្ថាប័នថ្មីបំពេញកាតព្វកិច្ចច្បាស់លាស់ ជាពិសេសគឺត្រូវឲ្យព្រះរាជាស្តាប់ការផ្តល់យោបល់ មានមន្ត្រីដែលស្តាប់ព្រះរាជបញ្ជា ហើយបារាំងខ្លួនឯងក៏ឈប់លែងជាទីប្រឹក្សាគ្មានឥត្ថិពល តែជាអ្នកគ្រប់គ្រងរដ្ឋបាលមានសិទ្ធិចាត់ចែងការងារក្នុងនាមព្រះរាជា ហើយក៏អាចបញ្ជាពួកមន្ត្រីឲ្យអនុវត្តភារកិច្ច បានផងដែរ ។

នៅស្រុកសៀមឯណោះវិញ នៅពេលដែលព្រះរាជាបានកកសម្រេចថានឹងធ្វើការកែទម្រង់ដូច ដែល

បារាំងមានគម្រោងចង់ធ្វើ និងមានកាតព្វកិច្ចត្រូវធ្វើនៅកម្ពុជា ដោយសៀមគ្មានប្រទេសអាណាព្យាបាលដូចកម្ពុជា ព្រះរាជាបានអំពាវនាវរកប្រទេសនៅអឺរ៉ុបឲ្យមកជួយ ហើយបានប្រគល់ការដឹកនាំ បច្ចេកទេសលើគ្រប់សេវាទៅឲ្យគេកាន់កាប់ទាំងអស់ ។ ចំពោះកម្ពុជាដែលមានបារាំងជាអាណាព្យាបាល គេក៏ត្រូវការជាចាំបាច់ណាស់នូវអ្នកបច្ចេកទេសអឺរ៉ុបមកធ្វើការបម្រើផលប្រយោជន៍ ត្រឹមត្រូវទៅតាមបច្ចេកទេសដែលគេកំពុងតែប្រើនៅអឺរ៉ុបដែរ ហើយអ្នកបច្ចេកទេសនោះសមណាស់តែមានសញ្ជាតិជាប្រទេសអាណាព្យាបាលគឺបារាំង ។

ព្រះបាទនរោត្តមបានយល់ច្បាស់ណាស់អំពីសារសំខាន់ទាំងអស់នេះ ក៏ប៉ុន្តែទ្រង់អាចមិនទាន់បានយល់ច្បាស់ទាំងអស់នៅឡើយ ព្រោះគ្មានអ្នកណាផ្តល់គំនិតថ្វាយ គ្មានអ្នកណាផ្តល់ទីប្រឹក្សាល្អិតល្អន់ ជាពិសេស គឺមកពីបារាំងមិនហ៊ានបន្ទិតបន្ទំព្រះអង្គខ្លាំងពេក ។ ម្ល៉ោះហើយព្រះអង្គមានការញញើតញញើម មិនហ៊ានសម្រេចយ៉ាងណាជាយ៉ាងណាទេ ណាមួយទ្រង់ចង់ស្ថិតនៅជាព្រះរាជាផ្តាច់ការផង ចង់ក្តាប់ក្នុងព្រះហស្តនូវជីវិតសេចក្តីស្លាប់ និងទ្រព្យធនទាំងអស់របស់ប្រជារាស្ត្រព្រះអង្គផង ហើយគ្មានសេចក្តីក្លាហាននឹងអនុវត្តកំណែទម្រង់ទាំងនោះទេ ។ ព្រះអង្គចង់ក្តាប់ផលនៃពន្ធដារទាំងអស់ ហើយចាត់ចែងទៅតាមតែព្រះទ័យ ដោយមិនបានគិតធ្វើអ្វីជាផលប្រយោជន៍ដល់ប្រជារាស្ត្រ ឬធ្វើអ្វីជាប្រយោជន៍សាធារណៈសោះឡើយ ។ ធ្វើយ៉ាងនេះ មិនសមនឹងការស្ថិតនៅក្រោមអាណាព្យាបាលរបស់បារាំងទេ[៩៨] ។

ដោយអត់ទ្រាំនឹងពិនិត្យមើលរបាយការណ៍ស្តីពីការយឺតយ៉ាវនេះតទៅទៀតមិនបាន លោក ហ្វ៊ុលហ៊្វេរី ដែលកាលនោះជានាយករដ្ឋមន្ត្រីបារាំង បានចាត់ឲ្យលោក ស្ហាលថុមសុន ជាទេសាភិបាល និងជាតំណាងដ៏ខ្ពង់ខ្ពស់នៃប្រទេសបារាំងនៅកូសាំងស៊ីន សហការជាមួយអ្នកតំណាងអាណាព្យាបាលបារាំងនៅភ្នំពេញ ចូលគាល់ព្រះបាទនរោត្តម ហើយយាងព្រះអង្គឲ្យឡាយព្រះហស្តលេខាលើអនុសញ្ញាមួយ ដើម្បីប្រគល់កិច្ចដឹកនាំព្រះរាជាណាចក្រ ដែលកន្លងមកព្រះអង្គក្តោបក្តាប់តែមួយព្រះអង្គឯង ឲ្យអាណាព្យាបាលបារាំងចាត់ចែងជំនួសវិញម្តង ។ ដោយមិនបានគិតអ្វីវែងឆ្ងាយ លោកទេសាភិបាលកូសាំងស៊ីនបានឡើងជិះកប៉ាល់ជាមួយទាហាន ១០០នាក់ មកឡើងគោកនៅខាងអាគ្នេយ៍ព្រះរាជវាំង ។ គាត់បានចុះពីកប៉ាល់ ហើយចូលគាល់ព្រះបាទនរោត្តមសំដែងការគួរសមតាមរបៀបពិធីការ រួចបានដកខ្លួនចេញទៅវិញ ។ បន្តិចក្រោយមក ព្រះរាជាបានយាងទៅជួបជាមួយលោក ទេសាភិបាលនៅក្នុងវិមានអាណាព្យាបាល ។

---

[៩៨] នៅក្នុងខែកុម្ភៈ ឆ្នាំ១៨៧៧ អ្នកអង្គម្ចាស់វត្ថា បានបង្ហាញវត្តមានឡើងវិញ នៅក្នុងខែត្របាភ្នំ ដោយមានទ័ពមួយកង ។ គេបានបញ្ជូនទ័ពមួយកងទៅវាយទ័ពនោះឲ្យបរាជ័យ ដណ្តើមយកបន្ទាយបាភ្នំបាន ក៏ប៉ុន្តែសង្គ្រាមនោះបានធ្វើឲ្យមនុស្សស្លាប់ និងខូចខាតទ្រព្យសម្បត្តិអស់ជាច្រើន ។ ហេតុការណ៍នេះបញ្ជាក់ថា នៅពេលនោះប្រជាជនមិនសូវជាចូលចិត្តព្រះបាទនរោត្តម ប៉ុន្មានទេ ។

លោក ថុមសុន ជាមនុស្សខ្វះការប៉ិនប្រសប់ គ្មានបទពិសោធន៍ជាអ្នកការទូតម្នាក់ដែលឆ្លាតវាងវៃ មានអំណត់ យល់ដឹងពីកាលៈទេសៈ ដើម្បីដោះស្រាយបញ្ហាឲ្យបានល្អជាមួយព្រះរាជាកម្ពុជា ដែលទ្រង់ក៏មិនយល់ដឹងច្បាស់អំពីរបៀបធ្វើការរបស់បារាំងដែរ ។ គាត់មិនចេះប្រើវិធីសាស្ត្រពន្យារពេលដែលនឹងនាំមកនូវលទ្ធផលល្អនៅពេលក្រោយទេ ។ គាត់បានសម្រេចចិត្តថាត្រូវបង្ខំសភាពការណ៍ ចាប់បង្ខំឲ្យព្រះរាជាឡាយព្រះហស្តលេខាដោយធ្វើឲ្យព្រះអង្គភ័យខ្លាច តាមការបង្ហាញកម្លាំងទ័ព ។ គាត់បានចាត់មន្ត្រីម្នាក់ នាំយកអនុសញ្ញា ដែលលោករដ្ឋមន្ត្រីមហាផ្ទៃ ក្លូប៊ូកូវស្គី បានរៀបចំប្រញិបប្រញាប់ជាមួយគាត់មុននឹងចេញពីសាយហ្គន មកដើម្បីឲ្យព្រះរាជាឡាយព្រះហស្តលេខា ។

មុនដំបូង ព្រះរាជាមិនយល់ថាតើគេចង់ឲ្យព្រះអង្គធ្វើអ្វីទេ ។ ពួកមន្ត្រីទាំងឡាយគិតថា បារាំង ចង់លុបបំបាត់ព្រះរាជាណាចក្រចោល ហើយដឹកនាំប្រទេសដោយគ្មានពួកគេ គឺទុកកម្ពុជាជាអាណានិគមរបស់បារាំង ម៉្លោះហើយពួកគេបានថ្វាយយោបល់ដល់ព្រះរាជា សូមកុំឲ្យព្រះអង្គយល់ព្រមតាម ។ មានការតឹងតែងអស់ពេលប៉ុន្មានថ្ងៃ រហូតដល់មានឱសានវាទៈ ព្រះរាជាបានប្រកែកមិនព្រមទទួលលោកទេសាភិបាល ដោយយកលេសថាព្រះអង្គប្រឈួន ។ បារាំងគំរាមថា បើព្រះអង្គមិនយល់ព្រមទេ គេនឹងយកព្រះអង្គទៅដាក់នៅប្រទេសអាល់ហ្សេរី ។ ព្រះអង្គបានត្រូវហ៊ុមព័ទ្ធដោយនាយទាហាន និងមន្ត្រីបារាំង ជាច្រើនរូបក្នុងនោះមានលោក ហ៊្វូរ៉ែស អ្នកតំណាងអាណាព្យាបាលបារាំងនៅកម្ពុជា លោក លូស ដែលក្រោយមកជារ៉េស៊ីដង់ជាន់ខ្ពស់នៅកម្ពុជា (១៨៩៨) ហើយគេធ្វើឲ្យព្រះអង្គអាចទតពីព្រះបរមរាជវាំងទៅឃើញកប៉ាល់ ដែលចាំតែដឹកយកព្រះអង្គទៅធ្វើឲ្យព្រះរាជាភ័យញ័ររន្ធត់ អត់មិនបានក៏ឡាយព្រះហស្តលេខាលើអនុសញ្ញា ដែលបារាំងយកមកបង្ខំព្រះអង្គទៅនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៨៨៤ ។ តាមពិតទៅ មានព្រឹត្តិការណ៍ដ៏គួរឲ្យសោកស្តាយមួយ បានកើតឡើង ដែលធ្វើឲ្យព្រះរាជាទ្រង់ភិតភ័យជាខ្លាំងៈ លោក កុលដឺម៉ុងតេរ៉ូ ដែលជាអ្នកបកប្រែរបស់ព្រះអង្គ បានប្រែពាក្យមួយម៉ាត់ ខុសមកពីពាក្យនោះមានន័យ២យ៉ាង ។ លោក ប៉ាវី អ្នករុករកបារាំងសម្រាប់ប្រទេសលាវ បានកែតម្រូវលើការបកប្រែនោះ ជាហេតុធ្វើឲ្យគេឃាត់ខ្លួនលោក កុលដឺម៉ុងតេរ៉ូ ហើយឲ្យទាហាន២នាក់ ដែលឈរសងខាងបានវាយធ្វើបាបគាត់បន្តិចបន្តួច ។

ព្រះរាជាមិនបានដឹងថា បើសិនជាព្រះអង្គរក្សាបាននូវពាក្យដែលព្រះអង្គបានសន្យាកាលពីឆ្នាំ១៨៧៧ ព្រះអង្គមិនចាំបាច់ត្រូវគេបង្ខំឲ្យចុះអនុសញ្ញាឆ្នាំ១៨៨៤នេះទេ ។ ក៏ប៉ុន្តែគ្មាននរណាម្នាក់បានជួយរំលឹកព្រះអង្គអំពីរឿងនេះសោះ តាំងតែពីពេលនោះមក ។ ហើយព្រះអង្គរឹតតែមិនបានដឹងសោះថា ទ្រង់នឹងមិនមានខាតបង់អ្វីទាំងអស់ ជាមួយអនុសញ្ញាថ្មីនេះ ។ បើនិយាយអំពីអ្នកតំណាងរបស់ប្រទេសបារាំងប្រចាំនៅកម្ពុជាវិញ អស់លោកមិនបានគិតថាអស់លោកគ្មានបានធ្វើអ្វីសោះក្នុងរយៈពេល៧ឆ្នាំកន្លងទៅនេះ ដើម្បីធ្វើឲ្យការកែទម្រង់ដែលមានកត់ត្រានៅលើក្រដាសរួចហើយ ប្រែក្លាយទៅជាការពិត ។ អស់លោកមិនដែលបានរំលឹកព្រះរាជាអំពីអ្វីដែលព្រះអង្គបានសន្យារួចមកហើយទេ ។ ជាពិសេស អស់លោកមិនដែលពន្យល់ព្រះរាជា ឲ្យទ្រង់ជ្រាបអំពីគោល

បំណងល្អដែលបារាំងចង់ធ្វើ ហើយក៏មិនបានចង្អុលបង្ហាញឲ្យព្រះអង្គជ្រាបថា តើត្រូវចាត់វិធានការដូចម្ដេចទេ ។ អស់លោកអ្នកតំណាងអាណាព្យាបាល បានមករស់នៅក្បែរព្រះរាជវរបៀបដូចជាកុលស៊ុល អ៊ីចឹងមិនមែនរបៀបជារ៉េស៊ីដង់ ដែលប្រទេសបារាំងផ្ដុកផ្ដាក់ឲ្យមកជំរុញការកសាងទេ ។

ពេលត្រលប់មកកាន់វិមានអាណាព្យាបាលវិញ លោកទេសាភិបាលកូសាំងស៊ីនបានចេញបញ្ជាឲ្យគេរៀបចំសេចក្ដីសម្រេចផ្សេងៗដែលគាត់យល់ថាចាំបាច់ ហើយបានបង្ខាំងលោក ឌៀប ជាអ្នកបកប្រែរបស់ព្រះរាជា ដែលសព្វថ្ងៃនេះជារដ្ឋមន្ត្រីខាងទ័ពជើងទឹក ឲ្យធ្វើការតែមិនឲ្យមានទំនាក់ទំនងទៅខាងក្រៅទេ ។ ដោយមិនបានប្រុងប្រៀបរៀបចំទុកជាមុន មិនបានគិតឲ្យល្អិតល្អន់ កិច្ចការដែលគេបានធ្វើពេលនោះក៏ខ្វះនូវប្រសិទ្ធភាព ហើយក៏គ្មានអនាគតវែងឆ្ងាយប៉ុន្មានដែរ ។ គេអាចពិនិត្យមើលឃើញនូវការប្រញិបប្រញាប់ដែលគួរឲ្យអស់សំណើច ហើយប៉ាន់ស្មានបាននូវអ្វីដែលគេបានស្រមើស្រមៃ ។

ពេលវេលាបានកន្លងផុតទៅប៉ុន្មានខែហើយ បារាំងហៀបតែនឹងចាប់ផ្ដើមធ្វើការសើរើរៀបចំព្រះរាជាណាចក្រឡើងវិញទៅហើយ ស្រាប់តែលោកតំណាងអាណាព្យាបាលទទួលដំណឹងថាមានការបង្កបង្កើតជាទ័ពទឹងនៅកន្លែងជាច្រើនក្នុងប្រទេស ហើយគំរាមកំហែងមកលើទីតាំងរ៉េស៊ីដង់ថ្មីៗរបស់បារាំង ។

ដូច្នេះ សង្គ្រាមបានផ្ទុះឡើង ហើយគេបានចេញបញ្ជាពីកូសាំងស៊ីនមកឲ្យកាន់កាប់ទីប្រជុំជនឲ្យបានហើយឲ្យចាត់បញ្ចេញទ័ពចល័តតាមវាយទៅលើពួកបះបោរ ។ ពួកនេះត្រូវបរាជ័យជានិច្ច ហើយបានរត់គេចខ្លួនរាល់ពេលដែលបានជួបទាហានបារាំង ។

ការបះបោរនេះបានកើតឡើងក្រោមការញុះញង់ពីពួកមន្ត្រី និងតាមបញ្ជាពីព្រះរាជា ហើយស៊ីពេលអស់ ១៨ខែ ។ មិនមានការប្រយុទ្ធអ្វីធំដុំប៉ុន្មានទេ ក៏ប៉ុន្តែវាបានធ្វើឲ្យប្រទេសហិនហោចយ៉ាងឆាប់រហ័ស ។ តាមពិតបារាំងជាអ្នកខ្លាំងជាង ហើយព្រះរាជាដែលគង់នៅក្នុងរាជធានីភ្នំពេញ ទ្រង់ស្ថិតនៅក្នុងកណ្ដាប់ដៃរបស់បារាំង ។ បារាំងអាចចាប់ខ្លួនព្រះរាជា ប្រកាសលើកព្រះឧបរាជឲ្យឡើងកាន់ការជំនួស និងអាចបញ្ចប់សង្គ្រាមបានដោយនាំយកព្រះរាជាទៅប្រទេសបារាំង ឬទៅកាន់ទឹកដីនៅអាហ្វ្រិក ។ ក៏ប៉ុន្តែបារាំង មិនធ្វើដូច្នេះទេ គឺពេញចិត្តនឹងចាត់ការទៅលើព្រះរាជា ពួកនាម៉ឺនមន្ត្រី នៅក្នុងប្រទេសតែម្ដង ធ្វើឲ្យទាំងអស់គ្នាយល់ស្របតាម ហើយចាប់ធ្វើការកែទម្រង់ដែលចាំបាច់វិញ ។

ការបះបោរបានរីករាលដាលទៅពេញទូទាំងកម្ពុជា នៅចុងឆ្នាំ១៨៨៥ បារាំងមានប៉ុស្តិ៍យោធាទាំងអស់ ៥២ នៅក្នុងព្រះរាជាណាចក្រ ។ សង្គ្រាមនោះ គឺព្រះរាជាបានបង្កឡើង ក៏ប៉ុន្តែពួកអ្នកស្រុកស្រលាញ់ចូលចិត្តបារាំង សប្បាយរីករាយទទួលបារាំងថាជាអ្នកការពារ ។ សង្គ្រាមនោះបានធ្វើឲ្យបារាំងបាត់បង់កម្លាំងអស់ប្រហែលជា ១ពាន់នាក់ ដែលភាគច្រើនត្រូវស្លាប់ដោយជំងឺគ្រុន និងកម្ដៅព្រះអាទិត្យ មិនមែនស្លាប់ដោយគ្រាប់កាំភ្លើងសត្រូវទេ ។ ក៏ប៉ុន្តែសង្គ្រាមនោះបានធ្វើឲ្យខ្មែរប្រហែល១ម៉ឺននាក់ស្លាប់ ដោយអត់ឃ្លាន ដោយទុរ្ភិក្ស

និងការខ្វះខាត ដោយជំងឺគ្រុន និងជំងឺផ្សេងៗទៀតនៅពេលរត់គេចទៅរស់នៅក្នុងព្រៃរបោះ និងព្រៃនាម ។

គេបានបញ្ជូនទ័ពពីសាយហ្គនមក ដែលធ្វើបាបអ្នកស្រុកហើយ ដុតរោលឲ្យអ្នកស្រុកអត់ទ្រាំមិនចូលរួមធ្វើសង្គ្រាមមិនបាន ។ ក៏ប៉ុន្តែសង្គ្រាមដែលផ្ទុះឡើងក្រោមការញុះញង់របស់ពួកមន្ត្រី តាមបញ្ជារបស់ព្រះរាជាដែលផ្ទុយនឹងឆន្ទៈរបស់អ្នកស្រុកស្រែចម្ការដែលចង់បានសន្តិភាព បានចាប់ផ្ដើមស្ងប់ស្ងាត់នៅចុងឆ្នាំបន្ទាប់ ។ គេចាប់បិទបុ័ស្តិ៍យោធាជាបន្តបន្ទាប់ ហើយព្រះរាជាណាចក្រទាំងមូលមានសភាពស្ងប់ស្ងាត់ឡើងវិញ នៅក្នុងខែមករា ឆ្នាំ១៨៨៧ ដោយមិនមានការបង្ហូរឈាមច្រើនពេកទេ តែក៏បានធ្វើឲ្យខូចខាតជីវិតអ្នកស្រុក និងទាហានបារាំង អស់ចំនួនច្រើនគួរសមដែរ បណ្ដាលមកពីចលាចល ការផ្លាស់ប្ដូរទីកន្លែង ការរត់ចូលព្រៃ និងជំងឺ ។

ពួកបះបោរចាប់វិលត្រលប់ចូលក្នុងស្រុកវិញ មកចុះចូលសារភាពនៅតាមទីកន្លែងដែលមានរ៉េស៊ីដង់បារាំងនៅ ហើយដោយបារាំងបានស្រុះស្រួលមូលមតិជាមួយព្រះរាជា និងពួកនាម៉ឺនសព្វមុខមន្ត្រី បង្អង់មិនទាន់អនុវត្តការកែទម្រង់ ដើម្បីធ្វើការសិក្សាឲ្យល្អិតល្អន់សិន សន្តិភាពក៏បានវិលត្រលប់មកក្នុងស្មារតីប្រជាជនម្នាក់ៗឡើងវិញដែរ ។ មានតែរ៉េស៊ីដង់បារាំងនៅកំពត ក្រចេះ កំពង់ធំ និងពោធិសាត់ប៉ុណ្ណោះ ដែលលោក ពីកេ[៩៩] ជារ៉េស៊ីដង់ធំនៅកម្ពុជា បានបញ្ជាឲ្យបន្តធ្វើការសិក្សាអំពីទឹកដី ទំនៀមទម្លាប់របស់អ្នកស្រុកដោយមិនឲ្យលូកដៃជ្រៀតជ្រែកទៅក្នុងការគ្រប់គ្រងរដ្ឋបាលក្នុងស្រុកទេ ហើយត្រូវរក្សាទំនាក់ទំនងល្អជាមួយអភិបាលខេត្ត ត្រួតពិនិត្យសកម្មភាពអភិបាលខេត្តទាំងនោះ ជាពិសេស ត្រូវបេះធ្វើឲ្យប្រជាជនស្រលាញ់ផង ។

នៅឆ្នាំ១៨៨៨ ព្រះរាជាដែលយល់កាន់តែច្បាស់ជាងមុន បានប្រគល់ការគ្រប់គ្រងព្រះរាជាណាចក្រដែលនៅតែស្ថិតនៅក្រោមអំណាចរបស់ព្រះអង្គ ទៅឲ្យបារាំងចាត់ចែងជំនួសវិញ ។ ព្រះអង្គបានឲ្យលោកតំណាងអាណាព្យាបាលធ្វើជាអធិបតីលើក្រុមប្រឹក្សារដ្ឋមន្ត្រី តែបានស្នើសុំឲ្យគេថ្វាយជូននូវប្រាក់ ៤សែន ពីយ៉ាស (ប្រហែល១លាន៧សែនហ្វ្រង់) ។ ការកែទម្រង់ទាំងឡាយត្រូវមានការយល់ព្រមពីព្រះអង្គ សេចក្ដីសម្រេចផ្សេងៗត្រូវមានព្រះហស្តលេខា និងត្រារបស់ព្រះអង្គផង ។

ចាប់ពីពេលនោះមក អាណាព្យាបាលបានដំណើរការទៅ មិនជាល្អមិនជាអាក្រក់ណាស់ណាទេ គឺសមស្របទៅនឹងផលប្រយោជន៍របស់ព្រះរាជាណាចក្រដែរ ។ បារាំងកាន់កាប់ការងាររដ្ឋបាល មាននមធ្យោបាយគ្រប់

---

[៩៩] លោកពីកេនេះ មុនដំបូងជាអនុនាវីកប៉ាល់ បន្ទាប់មកជាអ្នកធ្វើការងាររដ្ឋបាល រួចជាចាងហ្វាងមហាផ្ទៃនៅកូសាំងស៊ីន ។ នៅពេលចូលនិវត្តន៍ គាត់បានត្រូវគេលើកឲ្យធ្វើជាភ្នាក់ងារទារពន្ធនៅ Flèche រួចជារ៉េស៊ីដង់ធំនៅកម្ពុជា ។ គាត់បានមកដល់កម្ពុជានៅខែមីនា ឆ្នាំ១៨៨៦ ដើម្បីទទួលដំណែងជំនួសលោកវរសេនីយ៍ទោ បាដេន ដែលបានមកកាន់តំណែងស្ដីទីជាង១ឆ្នាំមកហើយ ដោយមានលោក ហ៊ូរ៉ែស ជាទីប្រឹក្សា ។ ពេលនោះ លោករ៉េស៊ីដង់ពេញសិទ្ធិគឺលោក អែម៉ូនីញេ ដែលជាប់ចូលរួមធ្វើបេសកកម្មវិទ្យាសាស្ត្រ មួយ ។

គ្រាន់នឹងចាប់ផ្ដើមធ្វើកំណែទម្រង់ដែលចាំបាច់ ហើយការរៀបចំស្រុកទេសបានចាប់ផ្ដើមធ្វើដំណើរទៅមុខយ៉ាងយឺតៗ ។ មកដល់សព្វថ្ងៃនេះ ព្រះរាជាណាចក្រមានផ្លូវ មានស្ពាន ខ្លះៗហើយ ។ គេចាប់ធ្វើការសិក្សាលើកិច្ចការធំៗ ចាប់សាងសង់សាលារៀន ហើយរដ្ឋាភិបាលបារាំងបានចាប់ផ្ដើមតាំងពីដប់ពីរឆ្នាំមកហើយក្នុងការគិតគូរពីគម្រោងសាងសង់ផ្លូវដែកមួយ ។ គេក៏បានសើរើពិនិត្យច្បាប់ឡើងវិញដែរ ។

ព្រះបាទនរោត្ដម បានសុគតទៅនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩០៤ ក្នុងព្រះជន្មាយុ ៧០ព្រះវស្សា ។

## ៤៣- ព្រះបាទស៊ីសុវត្ថិ (១៩០៤- ...)

ព្រះអនុជរបស់ព្រះបាទនរោត្ដម គឺព្រះបាទស៊ីសុវត្ថិ ដែលជាព្រះឧបរាជ ទ្រង់មានព្រះជន្ម ៦៥ ព្រះវស្សាហើយ ហើយបានត្រូវគេលើកឲ្យឡើងសោយរាជ្យបន្តនៅក្នុងថ្ងៃជាមួយគ្នានោះ ។ ព្រះអង្គបានទទួលព្រះរាជពិធីរាជាភិសេកនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩០៦ ដោយមានលោក បូ ជាទេសាភិបាល បំពាក់មកុដរាជថ្វាយ ក្នុងនាមនៃសាធារណរដ្ឋបារាំង ។

ព្រះរាជាថ្មីបានយាងទៅធ្វើទស្សនកិច្ចនៅប្រទេសបារាំងនៅខែបន្ទាប់ រួចបានយាងត្រលប់មកវិញនៅខែសីហា ឆ្នាំ១៩០៦ ។ ទ្រង់មានព្រះទ័យរីករាយខ្លាំងណាស់ចំពោះព្រះរាជទស្សនកិច្ចនេះ ដែលបានឃើញថាប្រទេសដែលជាអាណាព្យាបាលលើកម្ពុជា ហើយដែលកម្ពុជាផ្ញើវាសនាជាមួយនោះ ជាប្រទេសធំមួយ ។

សន្ធិសញ្ញាមួយជាមួយប្រទេសសៀម ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧ បានមកបំពេញបន្ថែមឲ្យសន្ធិសញ្ញាឆ្នាំ១៩០៤ ដោយបាននាំយកទឹកដីមួយចំនួនដែលកម្ពុជាបានបាត់បង់ទៅ ត្រលប់មកវិញ ធ្វើឲ្យទឹកដីព្រះរាជាណាចក្រពេលនោះប្រហាក់ប្រហែលទៅនឹងទឹកដីកាលពីសតវត្សរ៍ទី១៦ដែរ ។ ខែត្របាត់ដំបង ជាមួយនឹងស្រុក៤ ក្នុងបណ្ដាស្រុកទាំង៥ មានសិរីសោភ័ណ មង្គលបុរី សៀមរាប និងត្នោត[១០០] បានក្លាយមកជាទឹកដីរបស់កម្ពុជាឡើងវិញ ហើយព្រំប្រទល់ដែនរបស់កម្ពុជា បានត្រូវលើកទៅទល់នឹងភ្នំដងរែកនៅខាងជើង, នៅខាងលិចរហូតជិតដល់អារញ្ញតាមផ្លូវទៅវឌ្ឍនៈ និងទៅទល់នឹងមុនសាលាប៉ាកាតបន្តិច តាមផ្លូវទៅចន្ទគាប៊ុន ។

ជាមួយនឹងទឹកដីដែលសន្ធិសញ្ញាឆ្នាំ១៩០៤ជាមួយសៀមបានប្រគល់មកឲ្យបារាំង ហើយបារាំងបានដាក់បញ្ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា មានទន្លេរពៅ មូលព្រៃ កោះកុង, ជាមួយនឹងការកាត់ខែត្រស្ទឹងត្រែងរបស់

---

[១០០] អារញ្ញ និងវឌ្ឍនៈ ដែលមានរ៉ែមាសកំពុងតែយកផលដោយក្រុមហ៊ុនអង់គ្លេសមួយ បាននៅជារបស់សៀមតទៅទៀត ។ នោះគឺជាការខុសឆ្គងមួយ ពីព្រោះថាវាជា មជ្ឈមណ្ឌលចោរកម្ម និងការឃុបឃិតគ្នារវាងសត្រូវរបស់របបថ្មី ដែលធ្វើឲ្យមានការលំបាកជាច្រើនដល់នគរបាលព្រំដែន ។ បើសិនជាវឌ្ឍនៈបានមកកម្ពុជា នោះប្រហែលជាគ្មានការលំបាកក្នុងការគ្រប់គ្រងអ្នកស្រុកទេ ។ ក៏ប៉ុន្តែវាមានផលប្រយោជន៍របស់ពួកបរទេស ដែលបារាំងត្រូវតែគិតគូរកុំឲ្យប៉ះពាល់ដល់ ។

លាវក្រោមការគ្រប់គ្រងរបស់បារាំង ឲ្យមកព្រះរាជាណាចក្រខ្មែរវិញ ទឹកដីកម្ពុជាពេលនោះបានកើនឡើងទ្វេ ដោយសារតែការត្រួតត្រារបស់បារាំង ។

ប្រជាជនកម្ពុជារួបរួមគ្នាជាប្រជាជាតិមួយដោយសារតែព្រះរាជា ។ ប្រជាជននេះមានសាមគ្គីគ្នា តែនៅពេលណាដែលទុក្ខវេទនានៅត្រង់កន្លែងណាមួយ ធ្វើឲ្យមានការប៉ះពាល់ដល់ទីកន្លែងផ្សេងៗទៀត ។ ដរាបណាការឈ្លានពានចូលមកក្នុងទឹកដីមួយ ឬការឆក់ប្លន់នៅតាមព្រំប្រទល់ដែនមួយ មិនធ្វើឲ្យប៉ះពាល់ដល់ព្រះរាជាទេ ប្រជារាស្ត្រក៏មិនបានគិតថា ហេតុការណ៍នោះ ធ្វើឲ្យខូចខាតដល់ផលប្រយោជន៍របស់គេដែរ ។ គេស្តាប់ការដំណាលរឿងដែលពួតៗគ្នាមកដល់គេ ដោយមិនបានគិតថាត្រូវចូលរួមជួយសងសឹកផងទេ ។ សព្វថ្ងៃនេះ បារាំងកំពុងតែខិតខំជួយធ្វើយ៉ាងណាឲ្យប្រជាជននេះមានថាមពលឡើងវិញ ឲ្យមានទំនុកចិត្តលើខ្លួនឯង និងឲ្យពួកគេមានស្មារតីសាមគ្គីជាតិ និងគំនិតឆ្នៃប្រឌិតឡើងវិញ ។ បារាំងមិនចង់ធ្វើជាម្ចាស់លើប្រជាជននេះទេ ក៏ប៉ុន្តែ ចង់ធ្វើជាមេកោយ ដូចដែលគេតែងតែនិយាយនៅកម្ពុជាថា ជាគ្រូអាចារ្យ និងជាអ្នកការពារ[១០១] ។

[១០១] មានចំណុចជាច្រើនដែលត្រូវលើកយកមករៀបរាប់ ការទិតៀនជាច្រើនដែលត្រូវនិយាយ ការខ្វះការប៉ិនប្រសប់មួយចំនួនដែលត្រូវលើក និងកំហុសឆ្គងដែលត្រូវបញ្ជាក់ ។ ក៏ប៉ុន្តែក្រោយពីបានពិចារណារួច ខ្ញុំគិតថាស្នាដៃនេះមិនគួរបើនឹងលើកយកសកម្មភាពគ្រប់គ្រងដែលកំពុងតែដំណើរការទៅ មកធ្វើការទិតៀនទេ ។ ខ្ញុំទើបតែបានទទួលពត៌មានចុងក្រោយនេះថា គេទើបតែបានរៀបចំការបោះឆ្នោតជ្រើសតាំងសភាពិគ្រោះយោបល់មួយ ដែលមានតំណាងរាស្ត្រចំនួន៤២នាក់ ជ្រើសរើសចេញពីគ្រប់ខែត្រ ប៉ុន្តែខ្ញុំមិនបានដឹងអ្វីវែងឆ្ងាយទេ ។ និយាយប៉ុននេះមិនគ្រប់គ្រាន់ទេ ក៏ប៉ុន្តែខ្ញុំអាចបានត្រឹមជម្រាបអំពីការខិតខំប្រឹងប្រែងដ៏មានសារសំខាន់នេះ ដែលទាមទារឲ្យមានការប៉ិនប្រសប់ ហើយចេះអនុវត្ត ។

# ជំពូកទី៤
# កំណត់សម្គាល់ស្ដីអំពីប្រជាជនដែលមានទំនាក់ទំនងជាមួយកម្ពុជា ពីសតវត្សរ៍ទី១៦ រហូតដល់សព្វថ្ងៃ

## ១- *អាណ្ណាម, តុងកឹង, កូសាំងស៊ីន និងនគរចាម្ប៉ា*

*ប្រមាណជានៅជំនាន់ដែលរាជធានីលង្វែករបស់កម្ពុជា ធ្លាក់ទៅក្នុងដៃពួកសៀម អាណាចក្រអាណ្ណាម ដែលទើបតែដណ្ដើមយកបានទឹកដីនគរចាម្ប៉ាស្ទើរតែទាំងអស់ បញ្ចូលមកជារបស់ខ្លួន ត្រូវបែកចេញជា២ ដាច់ពីគ្នាមួយ គឺដាងចុង ឬដាងគិញ ឬតុងកឹង និងមួយទៀតគឺកូសាំងស៊ីន ជាអតីតនគរចាម្ប៉ា ឬអាណ្ណាមសព្វថ្ងៃនេះ[១] ។*

*នៅសតវត្សរ៍ទី១៧ អាណាចក្រអាណ្ណាមមានស្ដេចមួយអង្គសោយរាជ្យ ដែលមិនសូវជាស្វាហាប់ប៉ុន្មានទេ ម្ល៉ោះហើយក៏គ្មានអំណាចដែរ គឺឡេគិញតុង ។ គេមិនគោរពព្រះអធិរាជនេះទេ ក៏ប៉ុន្តែនៅតុងកឹងគេគោរពមន្ត្រីរបស់ព្រះអង្គឈ្មោះថា ទ្រិញតុង ហើយនៅកូសាំងស៊ីនគេគោរពស្ដេចត្រាញ់ឈ្មោះ ង្វៀងហ័ង ។ មនុស្សទាំង២នាក់នេះ ម្នាក់ត្រូវជាមា និងម្នាក់ទៀតជាក្មួយ ហើយត្រូវបានព្រះចៅអធិរាជតែងតាំងឡើងដូចគ្នា ក៏ប៉ុន្តែជាសត្រូវនឹងគ្នាដែរ ហើយម្នាក់ៗខិតខំប្រឹងប្រែងធ្វើយ៉ាងណាដើម្បីកុំឲ្យគេចំណុះព្រះចៅអធិរាជតទៅទៀត ។*

*នៅឯតុងកឹង ពួកទ្រិញមានការលំបាកព្រោះនៅជាប់នឹងព្រះចៅអធិរាជ ហើយប្រជាជននៅជាប់ចិត្តស្រលាញ់សន្តតិវង្សឡេដែលបានបណ្ដេញពួកចិនចេញពីនគរថែមទៀត ម្ល៉ោះហើយពួកទ្រិញមិនអាចដណ្ដើមយកអំណាចដោយគ្មានគ្រោះថ្នាក់បានទេ ។ ក៏ប៉ុន្តែនៅកូសាំងស៊ីនវិញ ពួកង្វៀងហាក់ដូចជាទទួលបាននូវការគាំទ្រពីសំណាក់ប្រជាជន ដែលពាក់កណ្ដាលជាពួកអាណ្ណាម ដែលមួយចំនួនធំ បានបោះបង់ស្រុកកំណើតមករស់នៅទីនេះ ហើយពាក់កណ្ដាលទៀតជាពួកចាម ដែលទើបតែទទួលបាននូវអារ្យធម៌អាណ្ណាម តិច ឬច្រើន ម្យ៉ាងទៀតពួកង្វៀង បានកសាងរាជាណាចក្រអាណ្ណាមមួយបាននៅលើទឹកដីចាម្ប៉ា ដែលពីមុនជាសត្រូវរបស់តុងកឹង ។ រាជាណាចក្រថ្មីនេះមានឈ្មោះតាមរាជធានីរបស់ពួកចាមពីមុនថា ឆានឆេង ដែលក្លាយមកជាកូសាំងស៊ីន ។*

*នៅពេលដែលសំពៅហុល្លង់ឈ្មោះ ឡឺគ្រុល បានមកចូលចតនៅតុងកឹងជាលើកដំបូងនៅក្នុងឆ្នាំ១៦៣៧ នាយសំពៅហុល្លង់បានកត់សម្គាល់ឃើញនូវទំនាស់នេះ ពីព្រោះថារាជវាំងហាណូយពេលនោះមិនសូវស្វាគមន៍បរទេសណាដែលធ្វើដំណើរចេញពីស្រុកពួកង្វៀងទេ ។ ពួកសាសនទូតដែលបានមកដល់កូសាំងស៊ីនតាំងតែពីឆ្នាំ១៥៩៦ ដូចជាដូមីនីកាំងអេស្ប៉ាញ៉ុលឈ្មោះ ឌីយ៉ឺហ្គោអាត់វ៉ាស្ដូ, ពួកសេស៊ុីតប៉ុយសូនីនៅក្នុងឆ្នាំ១៦១៥,*

---

[១] *ខ្មែរហៅតុងកឹងថា គាងក្បូ ឬតុងកឹង ឬដុងគិញ ហើយហៅអាណ្ណាមថា ស្រុកយួន ។*

ពួកសេស៊ុីតមកពីរ៉ូដនៅក្នុងឆ្នាំ១៦២៤, (សេស៊ុីតឈ្មោះ បាល់ឌីណូទី បានមកដល់តុងកឹងតាំងតែពីឆ្នាំ១៦២០) បានដឹងច្បាស់អំពីទំនាស់រវាងបក្សពួកទាំង២នេះ ហើយបានត្រូវពួកមន្ត្រីអាណ្ណាមចោទប្រកាន់ មិនគ្រាន់តែថាជាចារបុរសរបស់ពួកអឺរ៉ុបប៉ុណ្ណោះទេ តែខាងរាជវាំងកូសាំងស៊ុីនចោទថាជាចារបុរសរបស់ពួកទ្រិញ ហើយខាងរាជវាំងតុងកឹងចោទថា ជាចារបុរសរបស់ពួកង្វៀងទៅវិញ ។

ការបែកបាក់របស់អាណាចក្រអាណ្ណាមនេះបានសំដែងឲ្យឃើញច្បាស់ឡើងនៅក្នុងសង្គ្រាមមួយ រវាងភាគខាងជើង និងភាគខាងត្បូងតាំងពីឆ្នាំ១៦០៣ម៉្លេះ[២] ។ ក្នុងសង្គ្រាមនោះ តុងកឹងបានចេញធ្វើ ប្រតិបត្តិការវាយមកលើភាគខាងត្បូងជាច្រើនលើកច្រើនសា រហូតទាល់តែមកដល់ឆ្នាំ១៦៤២ទើបសម្រេចចិត្តបោះបង់កូសាំងស៊ុីនចោល ដោយលើកមូលហេតុថាអាកាសធាតុក្តៅពេក ទាហានស្លាប់អស់ជាច្រើន ដោយសារអត់ទ្រាំនឹងកម្តៅមិនបាន ។ មានសង្គ្រាមជាបន្តរហូតមកទៀតអស់កាលជាង២សតវត្សរ៍ ដែលធ្វើឲ្យការលះបង់របស់ពួកតុងកឹងលេចកាន់តែច្បាស់ឡើងៗ ហើយការបែងចែកស្រុកជា២នៅតែមានដដែលរវាងតុងកឹង និងកូសាំងស៊ុីន ។

នៅពេលនោះទើបគេទទួលស្គាល់ថាពួកអ្នកស្រុកខាងត្បូង ដែលមើលទៅហាក់ដូចជាមិនខ្លាំងក្លា ដូចពួកខាងជើងគឺ ពូកែខាងធ្វើសង្គ្រាមជាង អង់អាចក្លាហាន ហើយមានវិន័យល្អ ។ តាមពិត ពួកកូសាំងស៊ុីននោះមួយក្រុមគឺជាកូនចៅ ជាបច្ចាញាតិរបស់ពួកអាណ្ណាមពីមុនដែលមានថាមពលខ្លាំងក្លា ពូកែខាងចាកចោលស្រុកមកបង្កបង្កើតនគរថ្មី ឯមួយក្រុមទៀតគឺជាបច្ចាញាតិរបស់ពួកចាមដែលទទួលយកអារ្យធម៌អាណ្ណាម តែនៅមានជាប់ឈាមជ័រជាពូជអ្នកចម្បាំងតាំងពីដូនតាមក ពូកែលើសគេនៅលើឧបទ្វីបឥណ្ឌូចិន ។ លោកឪពុក គ្រីស្តូហ្វ័រប៊ូរីបានរៀបរាប់ថា ពួកទាហានកូសាំងស៊ុីនមានអាវុធយុទ្ធភណ្ឌល្អៗ យកមកពីប្រទេសជប៉ុន ហើយបានទទួលការហ្វឹកហាត់ប្រាកដប្រជា ព្រមទាំងមានកាំភ្លើងធំរហូតដល់ទៅ៦០ដើម[៣] ទៀតផង ជាកាំភ្លើងប្រើការបាន ដែលពួកគេយកពីនាវារបស់ពួកអឺរ៉ុបដែលមកលិចលង់នៅលើឆ្នេរអាណ្ណាម ហើយពួកកូសាំងស៊ុីននេះចេះប្រើកាំភ្លើងទាំងនោះប្រសប់ជាងពួកហុល្លង់ និងព័រទុយហ្គេជាម្ចាស់ដើមទៅទៀត ។ គាត់បាននិយាយផងដែរថាស្តេចអាណ្ណាមមានទ័ព៨ម៉ឺននាក់ មានសេះជាច្រើន ហើយថាពួកអាណ្ណាមអង់អាចក្លាហាន និងពូកែជាងពួក ជប៉ុន និងចិនទៀតផង ។

ម្យ៉ាងទៀត ពួកកូសាំងស៊ុីនមាននាវាចម្បាំងច្រើនជាងពួកតុងកឹង ហើយមានរបៀបរៀបរយ ប្រសើរជាង

---

[២] សង្គ្រាមនោះ បានផ្ទុះឡើងប្រហែលដោយមកពីស្តេចត្រាញ់នៅអាណ្ណាម មិនបានលើកសួយសារអាករទៅថ្វាយ ព្រះចៅអធិរាជនៅតុងកឹងឲ្យបានទៀងទាត់ ។

[៣] នៅក្នុងឆ្នាំ១៦៧៩ ទ័ពថ្មើរជើងមានគ្នា៣ម៉ឺននាក់ ក្នុងនោះ៩ពាន់នាក់ជាទាហានផ្ទាល់របស់ព្រះរាជា ៥ពាន់នាក់ ជាទាហានរបស់ព្រះវជ្ជទាយាទ ៣ពាន់នាក់ ជាទាហានរបស់អ្នកអគ្គម្ចាស់ទី២ និង២ពាន់នាក់ ជាទាហានរបស់អ្នកអគ្គម្ចាស់ទី៣ ។

ព្រោះមានព្រះរាជបុត្រាជាព្រះវរជ្ជទាយាទជាមេបញ្ជាការ ។ នៅក្នុងឆ្នាំ១៦៧៨ កងនាវាចម្បាំងនេះមានទូកចែវលឿនៗចំនួន១៣០គ្រឿង ទូកនីមួយៗមានចែវ៦០ គឺ៣០ម្ខាងៗ ចែវមួយមានអ្នកចែវម្នាក់ ។ នាយទាហានឈរនៅកន្សៃទូកឬនៅក្បាលទូក ហើយត្រួតពិនិត្យមើលពួកអ្នកចែវទាំងអស់ឲ្យចែវព្រមៗគ្នា និងហាមមិនឲ្យនិយាយគ្នា បើពុំនោះទេនឹងត្រូវមានទោសអស់ជីវិត ។ អ្នកចែវម្នាក់ៗក៏ជាទាហានម្នាក់ផងដែរ មានកាំភ្លើងមូស្កឹតុង ១ដើម កាំបិត១ ធ្នូ១ និងព្រួញ១បំពង់នៅក្រោមជើង ហើយស្តាប់បញ្ជាតាមកាយវិការរបស់មេ ដែលកាន់ដំបង ១ដើម សម្រាប់ឲ្យចង្វាក់ ។ ក្រុមនាវាចម្បាំងនេះហ្វឹកហាត់រាល់ថ្ងៃ នៅពីមុខទឹកន្លែងស្នាក់នៅរបស់អ្នកអង្គម្ចាស់ឧត្តមនាវីឯក ។ ម្នាក់ៗស្លៀកពាក់ឯកសណ្ឋាន មានខោសូត្រពណ៌ស និងពាក់មួកជក់ត្នោត ហើយពាក់អាវចង្កៀតមួយបែប ក្នុងពេលមានការប្រយុទ្ធ ។ ទូកនីមួយៗមានមេបញ្ជាការ៣នាក់ អ្នកកាន់កាំភ្លើងធំ៦នាក់ អ្នកកាច់ចង្កូត ២នាក់ និងអ្នកវាយគង២នាក់ដែរ ។ មានកន្លែងបង្ហូរទឹកនៅពីខាងមុខ១ និងតូចៗ ២នៅចំហៀង ។ ទូកទាំងអស់សុទ្ធតែលាបម្រ័ក្សណ៍ពណ៌ខ្មៅពីខាងក្រៅ ឯខាងក្នុងវិញលាបម្រ័ក្សណ៍ពណ៌ក្រហម ។ ទូកទាំងអស់នោះស្អាតណាស់ គេអាចឆ្លុះមើលមុខបាន ។

ពួកអាណ្ណាមនៅភាគខាងត្បូងនេះ មើលទៅដូចជាមានការសិក្សាអប់រំ ការគោរពទំនៀមទម្លាប់ប្រពៃណីពីបុរាណ អន់ខ្សោយជាងពួកភាគខាងជើង ហើយរាជវាំងនៅរាជធានីវេ ហាក់ដូចជាមិនសូវមានពិធីការអ្វីច្រើនដូចនៅហាណូយទេ[៤] ។

ពួកអាណ្ណាមភាគខាងត្បូងនេះ គេងាយនឹងបញ្ចុះបញ្ចូលឲ្យទទួលយកទម្លាប់របៀបរបបថ្មី ហើយបោះបង់ចោលរបៀបរបបចាស់ ជាពួកតុងកឹងដែលនឹងរំខានពួកគេក្នុងអំឡុងនៃដំណើរផ្សងព្រេងចេញពីទឹកដីមកក្រៅ ។

លោកឪពុក គ្រីស្តូហ្វូរ៉ូ បាននិយាយថាពួកនេះស្វាគមន៍រាក់ទាក់ទទួលបរទេស ហៅរកទៅមក ហើយអនុញ្ញាតឲ្យពួកបរទេសមានសេរីភាពរស់នៅទៅតាមទម្លាប់ ហើយស្លៀកពាក់តាមចំណង់ចំណូលចិត្ត ។ ដូ គឺ ស្តេចត្រាញ់របស់ពួកនេះ បានផ្តល់កិច្ចការពារដល់ពួកសាសនទូតកាតូលិក ខុសពី ដូ នៅតុងកឹង ដែលមានអធ្យាស្រ័យល្អបន្តួរបន្ទាយឲ្យដែរ ក៏ប៉ុន្តែបានបណ្តោយឲ្យពួកមន្ត្រីរាជការរំខានទៅវិញ ។

---

[៤] លោកឪពុកសេស៊ីតគ្រីស្តូហ្វ័រ៉ូបានកត់សម្គាល់ថាពួកអាណ្ណាម ដែលសព្វថ្ងៃនេះក្រងបួបួងសក់នៅក្រោយក នៅសម័យនោះ គឺទុកសក់វែងៗណាស់ ធ្លាក់រាយមកលើស្មា និងខ្នង ប្រុសក៏ដូចស្រី ជួនកាលវែងធ្លាក់ដល់ដី ។ អភិជនម្នាក់នៅអូបោនឈ្មោះ តាវែនីញេ ក៏បាននិយាយដូចគ្នានេះដែរ នៅក្នុងសៀវភៅរបស់គាត់ស្តីអំពីតុងកឹង ដែលបោះពុម្ពផ្សាយ ៥០ឆ្នាំក្រោយមក ។

អ្នកនិពន្ធដដែលនេះបានរៀបរាប់ថា ពួកអាណ្ណាមស្លៀកពាក់សម្លៀកបំពាក់វែង ទូលាយ មានដៃធំ ហើយរុំខ្លួននឹងក្រណាត់មួយជុំ ។ គេទុកក្រចកឲ្យលូតវែង ហើយពួកគេ ខ្លាចណាស់អ្នកណាដែលសូត្រធម៌ក្បាលទទេ រហូតទាល់តែពួកលោកសង្ឃនៃក្រុមហ៊ុនព្រះយេស៊ូស្នើសុំការអនុញ្ញាតពីសម្តេចប៉ាបប៉ូល-ទី៥ ឲ្យពួកអ្នកសូត្រធម៌ទទូរក្បាល ។

តុងកឹងនៅពេលនោះគ្មានពេល និងកម្លាំងគ្រប់គ្រាន់ដើម្បីបង្ក្រាបកូសាំងស៊ីនឲ្យស្ថិតនៅក្នុងអំណាចរបស់ខ្លួនបានទេ ព្រោះនៅជាប់ទៅនឹងស្រុកចិនដែលតែងតែមានបំណងចង់យកតុងកឹងនេះ បញ្ចូលទៅក្នុងការត្រួតត្រារបស់ខ្លួន ហើយបានផ្ដល់ជម្រកឲ្យសន្តតិវង្សម៉ាក់ស្នាក់នៅ ជួយឲ្យពួកនេះបង្កការបះបោរផ្សេងៗប្រឆាំងនឹងសន្តតិវង្សឡេ ។ ម្យ៉ាងទៀតកូសាំងស៊ីនពេលនោះមានមេដឹកនាំជាអាណ្ណាមទៀតផង ខុសពីមុន ដែលជានគរចាម្ប៉ា ។

ផ្ទុយទៅវិញ កូសាំងស៊ីន (អតីតចាម្ប៉ា) មានកម្លាំង និងលទ្ធភាពគ្រប់គ្រាន់ ដើម្បីពង្រីកទឹកដីចុះទៅក្រោម គឺខាងត្បូង និងនិរតី ថែមទៀត ។ ពួកចាមមានតែនៅបិញធន់ប៉ុណ្ណោះ ជាទីកន្លែងដែលមានរដ្ឋចាមតូចមួយ តាំងពីយូរអង្វែងណាស់មកហើយ ដែលចិនហៅថាព្យូតុងឡុង រដ្ឋនេះមានស្ដេចគ្រប់គ្រង តែមិនចំណុះអាណាចក្រ ចាម្ប៉ាទេ[៥] ។

ពួកអ្នកស្រុកនៃរដ្ឋចាមតូចនេះ ដែលតែងតែបង្កសង្គ្រាមជាញឹកញយជាមួយអាណាចក្រចាម្ប៉ាធំ មិនបានប្រែចូលកាន់សាសនាអ៊ីស្លាមទាំងស្រុងគ្រប់គ្នាទេ បើទោះជាសាសនានេះបានផ្សព្វផ្សាយចូលមកក្នុងនគរចាម្ប៉ាតាំងតែពីសតវត្សរ៍ទី១២ ឬ១៣ ហើយបានក្លាយទៅជាសាសនាផ្លូវការចាប់ពីសតវត្សរ៍ទី១៤ ឬ១៥ក៏ដោយ ។ ពួកនេះនៅរក្សាជំនឿតាមបែបព្រហ្មញ្ញសាសនា ម្ល៉ោះហើយមិនបានចូលដៃចូលជើង ជួយធ្វើសង្គ្រាមអាណាចក្រចាម្ប៉ាធំប្រឆាំងនឹងតុងកឹងទេ ព្រោះមានអរិភាពដោយកាន់សាសនាខុសគ្នានេះ ហើយនៅពេលដែលពួកតុងកឹងវាយដណ្ដើមយកអាណាខេត្តរបស់អាណាចក្រចាម្ប៉ាមួយម្ដងៗ ពួកអាណ្ណាមនេះ ក៏មិនធ្វើអ្វីឲ្យប៉ះពាល់ដល់រាជាណាចក្រចាមនៅ បណ្ឌុរង្គ នេះដែរ ។

នៅក្នុងឆ្នាំ១៦៨៤ ពួកហុល្លង់ បានមកកម្ពុជាម្ដងទៀត បន្ទាប់ពីត្រូវវាយបណ្ដេញដោយពួកខ្មែរ ក្រោមការជួយឧបត្ថម្ភពីពួកអគារពាណិជ្ជកម្មព័រទុយហ្គេ ពួកកាតូលិកជប៉ុនដែលត្រូវគេធ្វើទុក្ខបុកម្នេញនៅឯស្រុក ហើយបានភៀសខ្លួនមករស់នៅកម្ពុជា និងជាសត្រូវរបស់ពួកអ្នកដែលឆ្លៀតឱកាសនៃការធ្វើទុក្ខបុកម្នេញនេះ រួមដៃជាមួយនឹងពួកម៉ាឡេ កាន់សាសនាអ៊ីស្លាម ។ ពួកហុល្លង់នោះ បានទៅចតនាវានៅនឹងឆ្នេរសមុទ្រកូសាំងស៊ីន ហើយបានទទួលការស្វាគមន៍រាក់ទាក់ពីស្ដេចចាមមួយអង្គ ដែលបានអនុញ្ញាតឲ្យនាវាហុល្លង់ចូលចតនឹងកំពង់ផែ ក៏ប៉ុន្តែ បានហាមប្រាមមិនឲ្យហុល្លង់វាយប្រហារទៅលើពួកព័រទុយហ្គេ នៅលើទឹកដីកូសាំងស៊ីនទេ និងមិនអនុញ្ញាត

[៥] តាមមើលទៅរដ្ឋចាមនៅបណ្ឌុរង្គតូចនេះ មិនចំណុះអាណាចក្រចាមធំ ដូចជារាជាណាចក្រពួកវៀង មិនចំណុះអាណាចក្រពួកឡេ នៅក្នុងសតវត្សរ៍ទី១៨ អ៊ីចឹងដែរ ។ អ្នកស្រុករបស់រដ្ឋចាមតូចនេះ មិនទទួលស្គាល់ថា គេជាអាណាខេត្តមួយរបស់អាណាចក្រចាម្ប៉ានោះទេ តែបានគិតថាគេជាខេត្តឯករាជមួយ មានស្ដេចឯករាជសោយរាជ្យ ។ មានសិលាចារឹកមួយរបស់អាណាចក្រចាម្ប៉ាបាននិយាយថា «ពួកអ្នកស្រុករបស់រដ្ឋតូចនេះចូលចិត្តប្រព្រឹត្តបាបកម្ម ទុច្ចរិត លួងខ្មៅ ហើយបានក្បត់ព្រះរាជាចាម្ប៉ា» ។

ឲ្យហុល្លង់ធ្វើពាណិជ្ជកម្មផ្តាច់មុខតែម្នាក់ឯង នៅក្នុងព្រះរាជាណាចក្រដែរ ។

ដូច្នេះយើងឃើញថា នៅសម័យនោះ ពួកអាណ្ណាមនៅកូសាំងស៊ីនមិនបានបំផ្លាញរាជាណាចក្រចាម្ប៉ាអស់ទាំងស្រុងទេ ។ គេបានអនុញ្ញាតឲ្យរដ្ឋចាមតូចមួយនៅរស់រានមានជីវិត ក្រោមការដឹកនាំរបស់ស្តេចចាមមួយអង្គ ដែលគ្មានទំនាស់អ្វីជាមួយមេដឹកនាំអាណ្ណាមដែលគេដាក់ឲ្យនៅអែបដើម្បីត្រួតពិនិត្យ ជួយដឹកនាំ និងផ្តល់យោបល់ឡើយ ។ រាជាណាចក្រចាមតូចនេះមានឈ្មោះនៅលើផែនទីដែលលោកឪពុកសេស៊ុត ៦នាក់ បានគូសឡើង នៅក្នុងឆ្នាំ១៦៣៥ ប៉ុន្តែដាក់ខុសទីតាំង ដោយទទួលពត៌មានមិនច្បាស់[៦] ។

រាជាណាចក្រចាមតូចនេះនៅមានបន្តរហូតដល់ឆ្នាំ១៧៩២ ។ រាជពង្សាវតារអាណ្ណាមបាននិយាយថា ដោយមិនសប្បាយចិត្តនឹងការគាបសង្កត់ពីពួកអាណ្ណាម ស្តេចចាមព្រះនាមតាមានគំនិតថា ពួកតៃសឺនប្រហែលជានឹងបង្កើតរបបថ្មីមួយប្រសើរជាង ក៏ចូលដៃចូលជើងជាមួយពួកនេះ ហើយបានជួយគាំទ្រពួកនេះ តាំងពីចាប់បះ-បោរដំបូងម្ល៉េះ ជាពិសេសជួយក្នុងសង្គ្រាមឈ្លបនៅបិញធន់ ។ នៅពេលដែលមានការហ៊ុមព័ទ្ធទីក្រុងគីញ៉ើន មន្ត្រីចាម២នាក់ ដែលចូលដៃជាមួយស្តេចយ៉ាឡុង បានចាប់ស្តេចចាមនេះប្រគល់ឲ្យស្តេចយ៉ាឡុង ដែលបានបញ្ជាឲ្យគេសម្លាប់ព្រះអង្គចោល ហើយលុបបំបាត់ព្រះរាជាណាចក្រចាមតូចនេះចេញ ។ ចាប់តាំងពីពេលនោះរហូតមក រដ្ឋចាមតូចនេះត្រូវដឹកនាំដោយពួកអាណ្ណាម តាមរបៀបរបបអាណ្ណាម ដើម្បីផលប្រយោជន៍អាណ្ណាមតែមួយ ។

បើទោះជាយ៉ាងណាក្តី យើងបានដឹងប្រហាក់ប្រហែលថា មុនពេលមានការដណ្តើមយកទឹកដីចាម្ប៉ា ជាប្រវត្តិសាស្ត្រ ដែលបានរៀបរាប់ខាងលើនេះ មានការដណ្តើមយកទឹកដីដាក់ស្តែងដោយប្រជាជនអាណ្ណាមបន្តិចម្តងៗជាមុនរួចទៅហើយ ។ ពួកអាណ្ណាមបានជ្រៀតចូលទៅកាន់កាប់ទឹកដីនៅវាលទំនាបជាបន្តបន្ទាប់ រុញច្រានពួកចាមឲ្យដកខ្លួនរត់ចេញ រួចហើយពួកអ្នកចំណូលថ្មីនេះក៏ប្រមូលផ្តុំគ្នាបង្កើតបានជាសហគមន៍ឡើង រៀបចំចាត់ចែងគ្រប់គ្រងទឹកដីដែលដណ្តើមបាន បន្ទាប់មកទើបរាជវាំងអាណ្ណាមបញ្ជូនមន្ត្រីឲ្យមកតាមត្រួតពិនិត្យ និងគ្រប់គ្រងជនរួមឈាមរបស់គេ ។ ចំណែកពួកចាមជាម្ចាស់ស្រុកវិញ បានដកខ្លួនគេចទៅរស់នៅតាមព្រៃភ្នំ ក្រំថ្មលាយឡំជាមួយពួកម៉យ ដែលជាហេតុធ្វើឲ្យនគរចាម្ប៉ាកាន់តែចុះខ្សត់ខ្សោយទៅៗ ។ នៅទីបញ្ចប់ រាជវាំងវ៉ៃបានចាត់តាំងមន្ត្រីធំរបស់គេម្នាក់ឲ្យទៅរស់នៅអែបនឹងស្តេចចាម ដើម្បីត្រួតពិនិត្យកិច្ចការគ្រប់បែបយ៉ាង រួចបានឲ្យធ្វើឃាតស្តេចចាមនោះចោលក្រោយពីមានការបះបោររបស់អ្នកស្រុក ទើបគេផ្លាស់ប្តូរមន្ត្រីចាមទាំងអស់ដោយដាក់មន្ត្រីអាណ្ណាមជំនួសវិញ នោះហើយជាអវសាននៃអត្ថិភាពរបស់រាជាណាចក្រចាម ។

---

[៦] បានជាខ្ញុំនិយាយថាដាក់ខុសទីតាំងនៅលើផែនទីនោះ ពីព្រោះគេគូសថា រាជាណាចក្រនោះលាតសន្ធឹងពីដៃខាងកើតរបស់ទន្លេមេគង្គរហូតទៅដល់ព្រំដែនបិញធន់សព្វថ្ងៃ ដែលតាមពិតទៅស៊ីងសាយហ្គន និងព្រៃគពេលនោះនៅជាទឹកដីរបស់កម្ពុជានៅឡើយ ។

ការកាច់បំបាក់ប្រជាជនដែលទទួលបរាជ័យតាមបែបជាប្រព័ន្ធយ៉ាងនេះ បានធ្វើឲ្យមានការចាកចោលស្រុកមួយដែលប្រព្រឹត្តទៅយឺតៗ ក៏ប៉ុន្តែជាប់ជារៀងរាល់ថ្ងៃ អ្នកដែលទ្រាំទ្រមិនព្រមចាកចេញត្រូវធ្លាក់ខ្លួនក្រ ហើយស្រុតចុះជាលំដាប់ រហូតទាល់តែគេភ្លេចអស់អតីតកាល ប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ពីបុរាណ សាសនារបស់ខ្លួន នៅសេសសល់តែពិធីតាមជំនឿខ្លះៗប៉ុណ្ណោះ ។

នៅពេលដែលរាជវង្សចាម រត់គេចខ្លួនជាមួយប្រជាជន៥ពាន់នាក់ មកជ្រកកោននៅកម្ពុជានៅក្នុងឆ្នាំ ១៦៩២ ដើម្បីសុំការអនុញ្ញាតពីព្រះស្រីជ័យជេដ្ឋាតាំងលំនៅដ្ឋាននៅក្នុងព្រះរាជាណាចក្រ សុំដីបង្កបង្កើនផល រាជវង្សចាមនោះ មិនមែនជារាជវង្សស្ដេចកូសាំងស៊ីនទេ គឺជារាជវង្សស្ដេចសោយរាជ្យនៅបណ្ឌុរង្គ ហើយពួកនេះមានសេសសល់បច្ចាញាតិនៅកម្ពុជារហូតដល់សព្វថ្ងៃ ។ រាជវង្សនៃមហាណាចក្រចាមប្រហែលបានគេចខ្លួនចេញមុននោះ នៅពេលដែលពួកអាណ្ណាមចាប់ផ្ដើមយកអាណាខែត្រចាមដំបូងៗ រួចហើយបានទៅបង្កជាសន្តតិវង្សមួយ នៅអាចេ ភាគពាយ័ព្យកោះស៊ូម៉ាត្រា ហើយក៏ភ្លេចជាតិកំណើតរបស់ខ្លួន តាំងពីពេលនោះរហូតមក ។ យើងអាចសន្និតិបានថា ព្រះរាជាចាមនៅបណ្ឌុរង្គ ដែលពួកហុល្លង់បានជួបនៅពាក់កណ្ដាលសតវត្សរ៍ទី១៧ ប្រហែលជាសោយរាជ្យមុនព្រះរាជាដែលនាំព្រះរាជវង្សមកជ្រកកោននៅកម្ពុជានៅក្នុងឆ្នាំ១៦៩២ តែប៉ុន្មានរជ្ជកាលប៉ុណ្ណោះ ។

លេបយកនគរចាម្ប៉ាមិនទាន់ទាំងបានអស់ស្រួលបួលផង ពួកអាណ្ណាមនៅកូសាំងស៊ីន (អាណ្ណាមបច្ចុប្បន្ន) ក្រោមការដឹកនាំរបស់សន្តតិវង្សង្វៀង បានចាប់ផ្ដើមវាតទឹកដីចូលមកក្នុងកម្ពុជារួចទៅហើយ ។ មុនដំបូងដូចដែលយើងបានឃើញពីខាងលើរួចមកហើយ ស្ដេចអាណ្ណាមបានបញ្ជូនបុត្រីមួយអង្គមកថ្វាយព្រះជ័យជេដ្ឋា នៅក្នុងឆ្នាំ ១៦១៨ ។ នៅក្នុងឆ្នាំ១៦២៣ ស្ដេចអាណ្ណាមបានទទួលទឹកដីសាយហ្គុនពីព្រះរាជបុត្រសុណិសា ដើម្បីកសាងផ្សារមួយ ហើយប្រមូលពន្ធគយនៅទីនោះ ។ នៅក្នុងឆ្នាំ១៦៥៨ ស្ដេចអាណ្ណាមគាំទ្រអ្នកអង្គម្ចាស់បទុមរាជា និងអង្គតន់ប្រឆាំងនឹងព្រះរាជាច័ន្ទ ដែលកាន់សាសនាអ៊ីស្លាម ។ ក្នុងចន្លោះពេលនោះ ស្ដេចអាណ្ណាម បានជំរុញឲ្យពួកខិលខូច ពួកអ្នកទោសដែលរត់រួចពីប្រវាក់ខ្នោះឃ្នាង និងពួកជនដែលកើតចេញពីគ្រួសារពួកអ្នកដែលធ្លាប់បានចាកចេញពីតុងកឹងមកកាន់កូសាំងស៊ីន ធ្វើការចាកចោលស្រុកបន្តដំណើរចេញពីកូសាំងស៊ីន មកកាន់កម្ពុជា ជ្រៀតជ្រករស់នៅលាយឡំជាមួយប្រជាជនខ្មែរ តាំងទីលំនៅជាអចិន្ត្រៃយ៍ រួចហើយប្រកាសខ្លួនថា ជាប្រជារាស្ត្ររបស់ព្រះរាជានៅរាជធានីវ៉េ មិនមានកាតព្វកិច្ចអ្វីបន្តិចសោះចំពោះព្រះរាជាកម្ពុជា ដើម្បីឲ្យរួចផុតពីការបង់ពន្ធដារ និងកំណែនផ្សេងៗ ។ បន្តិចក្រោយមក ព្រះរាជានៅវ៉េ បានបញ្ជូនមន្ត្រីអាណ្ណាមឲ្យចុះមកមើលពួកនោះ អាចនិយាយថា ឲ្យមកជួយណែនាំពួកនោះឲ្យចេះគោរពច្បាប់របស់ស្រុកខ្មែរ ព្រោះពួកមន្ត្រីទាំងនោះ បានត្រូវចាត់ថា ឲ្យមកជួយរៀបចំសណ្ដាប់ធ្នាប់ និងជួយចៅហ្វាយខែត្រខ្មែរ ក៏ប៉ុន្តែផ្ទុយស្រឡះ ពួកគេមកធ្វើការក្នុងនាមជាចៅហ្វាយខែត្រអាណ្ណាមទៅវិញ ។ ស្ថិតនៅក្រោមសម្ពាធជាប់ជាប្រចាំរបស់ពួកលួចឆក់ ចាប់ចង ខិលខូច ពី

កូសាំងស៊ីន មករស់ជានិគមជននៅកម្ពុជា ក៏ប៉ុន្តែស្មោះត្រង់ជាមួយស្តេចអាណ្ណាម ស្រុកបារាជ ដុងណាយ និងព្រៃគក៏ប្រែក្លាយបន្តិចម្តងៗទៅជាទឹកដីអាណ្ណាម បាត់បង់អស់ប្រជាជនខ្មែរ ។ នៅក្នុងឆ្នាំ១៥៨០ ស្តេចអាណ្ណាមបានបញ្ជូនទាហានចិនដែលគាំទ្រសន្តតិវង្សមិញចំនួន៣ពាន់នាក់ ដែលរត់គេចចេញពីស្រុកចិន មកចុះចតនៅលើឆ្នេរអាណ្ណាម រួចបន្តដំណើរមកដល់ទូរ៉ាន ឲ្យមករស់នៅលើទឹកដីបារាជ និងមីថ ព្រោះព្រះអង្គមិនដឹងថា ឲ្យពួកនោះធ្វើអ្វី ណាមួយខ្លាចពួកនោះផង ។ ការដែលបានធ្វើខ្លួនជាអ្នកការពារពួកអ្នកចំណូលថ្មីចិន ដោយប្រគល់ទឹកដីដែលជារបស់ខ្មែរទៅឲ្យរស់នៅ ស្តេចអាណ្ណាមបានកាត់យកទឹកដីខ្មែរមួយដុំថែមទៀត ទោះបីថាមិនត្រឹមត្រូវតាមច្បាប់ក៏ដោយ តែជាក់ស្តែងគឺវាអឺចឹងទៅហើយ ហើយកសាងបានអ្នកគាំទ្រមួយចំនួនថែមទៀត នៅខាងក្នុងទឹកដីដែលដណ្តើមយកបាននោះ ។ នៅសម័យជាមួយគ្នានោះមានចិនម្នាក់ឈ្មោះ ម៉ាក់គូ ជាអ្នកគាំទ្រពួកមិញដែរ បានមករស់នៅ នៅទីពាម (ហាទៀង) តាំងខ្លួនជាមេចោរសមុទ្រ ហើយបានកាត់យកទឹកដីព្រះរាជាណាចក្រកម្ពុជាមួយចំណែក កសាងក្សត្រប្រទេសមួយឡើង ។ ដើម្បីធានាស្ថិរភាពរបស់ទឹកដីខ្លួននេះ ម៉ាក់គូ បានឡើងចូលគាល់ស្តេចរាជធានីវេ ។ ព្រះរាជាវេ បានអបអរសាទរគមន៍កិត្តិយសនេះណាស់ ហើយដីមួយដុំទៀតរបស់កម្ពុជា ក៏ត្រូវកាត់ទៅឲ្យអាណ្ណាម (នៅ១៧១៥) ។

ក្រៅអំពីមធ្យោបាយដណ្តើមយកដីដោយសន្តិភាព ឬដោយស្របច្បាប់ខាងលើ នៅមានរឿងដែលពួកឧត្តមសេនីយ៍អាណ្ណាមដែលបញ្ជានៅសាយហ្គន បានដឹកនាំសកម្មភាពរបស់ជនរួមឈាមគេប្រកបទៅដោយការប៉ិនប្រសប់ សម្របសម្រួលយ៉ាងណាធ្វើឲ្យការខិតខំប្រឹងប្រែងរបស់អាជ្ញាធរផ្សេងៗរបស់អ្នកបន្ទាប់បន្សំ ដែលបានបេ្តជ្ញាដាច់ខាត និងរបស់ពួកអ្នកចាកចោលស្រុក ដែលធ្វើសកម្មភាពដើម្បីផលប្រយោជន៍សព្វៗខ្លួន ឲ្យចូលបម្រើផលប្រយោជន៍រួមរបស់អាណ្ណាម ។ ឧត្តមសេនីយ៍ទាំងនោះមិនដែលអាក់ខានក្នុងការធ្វើអន្តរាគមន៍ លូកដៃចូលមកក្នុងសង្គ្រាមផ្ទៃក្នុងដែលផ្ទុះឡើងនៅកម្ពុជា ផ្តល់ការគាំទ្រដល់ស្តេចខ្មែរណាដែលបានអំពាវនាវសុំជំនួយពីគេប្រឆាំងនឹងស្តេចណាដែលស្ទុះស្វែងរកជំនួយពីសៀមទេ ហើយរាល់តែលើក គេកាត់យកស្រុកមួយ ឬពីរជាថ្នូរនឹងតម្លៃនៃការធ្វើអន្តរាគមន៍នោះជានិច្ច ។ និយាយពីពួកសៀមវិញ គេក៏ធ្វើដូចគ្នានេះដែរពីទិសខាងជើងមក ហើយប្រជាជាតិទាំង២ដែលស្ថិតនៅសងខាងព្រះរាជាណាចក្រកម្ពុជានេះ បានក្លាយទៅអ្នកជិតខាង និងជាសត្រូវនឹងគ្នាហាក់បីដូចជាគេមានព្រំដែនជាប់នឹងគ្នាអ៊ីចឹង ដោយសារតែការដណ្តើមយកទឹកដីពីកម្ពុជាដូចគ្នានេះ ។

សង្គ្រាមដ៏យូរអង្វែងដែលស្តេច ង្វៀងអាញ់ (យ៉ាឡុង) នៃរាជវង្សង្វៀងដែលសោយរាជ្យនៅរាជធានីវេ ត្រូវធ្វើប្រឆាំងនឹងវេវឿង ជាបងប្អូនជីដូនមួយ និងជាដៃគូដណ្តើមរាជសម្បត្តិ បន្ទាប់មកប្រឆាំងនឹងស្តេចនៅតុងកឹង ជាសត្រូវស្ទួពូជដែល វេវឿង បានហៅឲ្យមកជួយ ហើយនៅទីបំផុតប្រឆាំងនឹងពួកតៃសឺន ឬពួកអ្នកស្រុកព្រៃភ្នំខាងលិចដែលបះបោរឡើងនៅក្នុងឆ្នាំ១៧៧៣ បានធ្វើឲ្យសង្គ្រាមនេះកើតមានអស់ពេលជិត៣០ឆ្នាំទាំងអស់នេះបាន ធ្វើឲ្យពួកអាណ្ណាមជាប់រវល់ ហើយបោះបង់គម្រោងការដណ្តើមយកកម្ពុជាដែលគេបានចាប់

ផ្ដើមចោលសិន បើហោចណាស់ក៏មួយរយៈកាលដែរ ។ ព្រោះថាយកល្អ គេត្រូវខិតខំរក្សាឲ្យបាននូវអ្វីគេមានរួចហើយ ហើយដណ្ដើមយកមកវិញនូវអ្វីដែលពួកបះបោរបានដណ្ដើមយកទៅ អ្វីដែលគេបាត់បង់ត្រូវយកមកវិញដែលគេបានប្ដេជ្ញាថាត្រូវតែរក្សាឲ្យបាន ។ ហើយវាគឺជាការប្រសើរជាងបើសិនជាគេអាចដណ្ដើមយកតុងកឹងមកដាក់បញ្ចូលជាទឹកដីអាណ្ណាមបាន ជាជាងប្រឹងរត់ទៅដណ្ដើមយកទឹកដីដែលនៅជារបស់កម្ពុជានៅឡើយ ។

សង្គ្រាមនេះបានប្រព្រឹត្តទៅអស់កាល៣០ឆ្នាំ ហើយមាននៅពាសពេញអាណាចក្រអាណ្ណាម ដែលពេលនោះ ត្រូវបែងចែកចេញជារដ្ឋ៣ គឺតុងកឹង (អាណ្ណាមកិតទាំងណានគឺ ឬកូសាំងស៊ីនសព្វថ្ងៃផង) និងរដ្ឋចាម្ប៉ាតូចមួយ ដែលនៅបន្តរស់រានមានជីវិតនៅត្រង់បិញធន់ ។ សង្គ្រាមនេះបានបញ្ចប់ទៅដោយការបង្រួបបង្រួមប្រទេសឡើងវិញនៅក្រោមការគោរពបូជាតែមួយ គឺជាព្រឹត្តិការណ៍ធំមួយនៅឥណ្ឌូចិន ដែលគួរតែត្រូវលើកយកមករៀបរាប់ត្រួសៗ ។

ពេលនោះស្ដេចពេញសិទ្ធិរបស់អាណ្ណាមគឺឡេហ៊ានតុង សោយរាជ្យនៅហាណូយ ប៉ុន្តែគឺជួ (មន្ត្រី ឬស្ដេចត្រាញ់) ត្រកូលទ្រិញទេដែលជាអ្នកដឹកនាំប្រទេស ម្នាក់ចាប់ពីឆ្នាំ១៨៤០មក ម្នាក់ទៀតចាប់តាំងពីឆ្នាំ១៧៦០ ។ វ៉ូវឿង ដែលជាជួនៅកូសាំងស៊ីន សោយរាជ្យនៅរាជធានីវ៉េ ។ នៅក្នុងឆ្នាំ១៧៦៥ ជួនៅតុងកឹង ទទួលមរណភាព ហើយកូនរបស់គាត់ម្នាក់បានទទួលដំណែងបន្តពីគាត់ ។ នៅពេលនោះ វ៉ូវឿង បានសម្រេចចិត្ត ជ្រើសតាំងបុត្ររបស់មហេសីទី២ ជារជ្ជទាយាទទទួលដំណែងបន្តគឺ មិនបានជ្រើសតាំងព្រះរាជបុត្រាច្បង ដែលជាបុត្រាជាមួយព្រះមហាក្សត្រីទេ ។ នៅពេល វ៉ូវឿង ស្លាប់ទៅ ប៉ុន្មានខែក្រោយមក មន្ត្រីធំម្នាក់ក៏ដណ្ដើមយកការគ្រប់គ្រងមកលើ វ៉េវឿង ដែលទើបតែមានអាយុ១៣ឆ្នាំ ដែលត្រូវទទួលដំណែងបន្តពី វ៉ូវឿង ហើយបានចាប់ព្រះរាជបុត្រាច្បង ដែលបានបំបែកចេញពីរាជបល្ល័ង្កដាក់គុក រួចសម្លាប់ចោលទៅ ។

មន្ត្រីដែលជារាជានុសិទ្ធិនោះជាមនុស្សក្រអឺតក្រទម ផ្ដាច់ការ ហើយគ្មានអធ្យាស្រ័យល្អទេ ។ ការដឹកនាំរបស់គាត់ បានធ្វើឲ្យប្រជារាស្ត្រខឹងសម្បាមិនពេញចិត្ត ហើយចាប់ផ្ដើមរើបម្រះឡើង ។ ពេលនោះមានបងប្អូនរបស់គាត់៣នាក់ ឈ្មោះថា ញ៉ាក់ វ៉េ និងលូ មានដើមកំណើតនៅតុងកឹង តែគេបាននាំយកគ្រួសារឲ្យមករស់នៅកូសាំងស៊ីន ពួកនោះមានត្រកូលង្វៀង បាននាំគ្នារត់គេចខ្លួនទៅកាន់ជួរភ្នំអាណ្ណាមជាទីកន្លែងដែលពួកអ្នករងគ្រោះនយោបាយ ហើយក៏ប្រហែលជាមានពួកខិលខូចផងដែរ បាននាំគ្នាគេចខ្លួនមកពួនសម្ងំនៅ ។ អ្នកទាំង៣នាក់បានជ្រើសរើសបានទ័ពចំនួន៣ពាន់នាក់ពីក្នុងចំណោមពួកអ្នកភៀសខ្លួនទាំងនោះ ហើយបានប្រកាសខ្លួនថាជាពួកតៃសឺន មានន័យថា “ពួកអ្នកភ្នំនៅបូព៌ា” និងបានចាប់ផ្ដើមធ្វើសង្គ្រាមឡើង (១៧៧៣) ។ ពួកនេះបានដណ្ដើមយកទីក្រុងគីញ៉ឹនដែលជាកំពង់ផែរបស់បិញឌិញ រួចហើយបានបន្តធ្វើដំណើរមកកាន់រាជធានីវ៉េ វាយកម្ទេចពួកណាដែលប្រឆាំង ហើយបង្កើនកម្លាំងទ័ពជាមួយពួកអ្នកដែលមិនសប្បាយចិត្តដែលគេបានជួបតាមផ្លូវធ្វើឲ្យទ័ពកើនចំនួនច្រើនក្រៃលែង ។

ដោយមានការភ័យខ្លាច ស្តេចវ៉េវៀងបានហៅរកជំនួយពីតុងកឹង ដែលជាសត្រូវស្លូពូជរបស់ពួកង្វៀន នៅកូសាំងស៊ីន ។ ពួកនេះសប្បាយចិត្តណាស់នឹងមានឱកាសបញ្ជូនទ័ពមួយកងមក ក៏ប៉ុន្តែទ័ពនោះមិនបានប្រឈមមុខជាមួយពួកតៃសឺនទេ បែរជាមកដណ្តើមយករាជធានីវ៉េទៅវិញ ហើយបានចាប់ផ្តើមរៀបចំ ដើម្បីវាយដណ្តើមយកអាណ្ណាមទាំងមូល ។ ការផ្ទុះនេះបានធ្វើឲ្យអរិភាពពីមុនរើឡើងវិញ ហើយប្រជាជនក៏បះបោរប្រឆាំងឡើង ។ ដោយមិនអាចទ្រាំទ្ររក្សាស្រុកនេះបាន ពួកតុងកឹងក៏ដកខ្លួនចេញ និងបោះបង់ទឹកដីទុកឲ្យពួកតៃសឺនវិញ ។ ញ៉ាក់ជាមេធំ និងជាមេទ័ពស្រួចរបស់ពួកតៃសឺនក៏ប្រកាសខ្លួនជាស្តេចឡើង មានឈ្មោះថា ថាយឌុក នៅក្នុងឆ្នាំ ១៧៧៥ ។ ចំណែកស្តេចវ៉េវៀងវិញដែលរត់ភៀសខ្លួនចេញពីរាជធានី ពួកតៃសឺនបានតាមរកឃើញហើយចាប់បាននៅកូសាំងស៊ីន រួចសម្លាប់ចោលទៅជាមួយ និងកូន នៅឯសាយហ្គន នៅក្នុងឆ្នាំ១៧៧៦ ។ ពេលនោះមាននៅសល់តែង្វៀនអាញ់ម្នាក់ត្រូវជាចៅរបស់ វ៉ូវៀង ដែលគេបានចាប់ឪពុកដាក់គុក ហើយសម្លាប់ចោលទៅ ដែលថ្ងៃក្រោយមកបានឡើងសោយរាជ្យមានឈ្មោះថា យ៉ាឡុង ។ នៅពេលទទួលបានដំណឹងអំពីមរណភាពរបស់វ៉េវៀង ជាព្រះបិតុលា ដែលបានប្រកាសលើកខ្លួនជារជ្ជទាយាទនៃរាជបល្ល័ង្កអាណ្ណាម ង្វៀនអាញ់ បានរត់ភៀសខ្លួនមកនៅកម្ពុជា ហើយបានកសាងទ័ពមួយឡើងដោយមានការជួយគាំទ្រពីលោក ពីញ៉ូ ហៅថា ពីញ៉ូដឺបេហែន[៧] ជាសាសនទូតកាតូលិកហើយជា អេវ៉េកអាដ្រង់ ប្រឆាំងនឹងពួកតៃសឺន ។

ង្វៀនអាញ់បានធ្វើដំណើរចេញពីកោះតូចមួយនៅក្នុងឈូងសមុទ្រសៀមមានឈ្មោះថា ធឺចាវ ដែលជាទីកន្លែងលាក់ខ្លួនបានប៉ុន្មានខែ មកចុះចតដោយលួចលាក់នៅកូសាំងស៊ីន រួចវាយដណ្តើមយកផ្សារដែក វិញឡុង និងសាយហ្គនបាន នៅក្នុងឆ្នាំ១៧៧៦ ។ ប្រជាជនទះដៃអបអរសាទរទទួលង្វៀនអាញ់គ្រប់ទិសទី ក៏ប៉ុន្តែង្វៀនអាញ់នៅញញើតញញើម មិនទាន់ហ៊ានទទួលយកឋានៈជាស្តេចឬជាជួដែលខ្លួនត្រូវទទួលភ្លាមតែម្តងទេ សុខចិត្តប្រកាសខ្លួនថាជា «ឧត្តមសេនីយ៍អគ្គបញ្ជាការ ជារាជានុសិទ្ធិទទួលបន្ទុកកិច្ចការព្រះនគរ» និងទទួលយកឋានៈដ៏សាមញ្ញមួយទៀតគឺ «សេនាប្រមុខពួកអ្នកភ្នំខាងកើត» ។

នៅពេលនោះ ពួកតៃសឺនទាំង៣នាក់បងប្អូនកំពុងតែជាប់ដៃរវល់វាយដណ្តើមយកតុងកឹង រួចហើយរៀបចំការគ្រប់គ្រងឡើងវិញ ជាហេតុធ្វើឲ្យការវាយដណ្តើមយកកូសាំងស៊ីនរបស់ង្វៀនអាញ់អាចប្រព្រឹត្តទៅ

[៧] បេហែន ជាឈ្មោះភូមិមួយនៅពីកាឌី ហើយជាភូមិកំណើតរបស់គ្រួសារពីញ៉ូ ។ ពួកពីញ៉ូ យកឈ្មោះភូមិនេះមកភ្ជាប់នឹងឈ្មោះខ្លួន ដើម្បីបង្ហាញឲ្យគេយល់ថាខ្លួនជាអភិជន ។ ហេតុការណ៍នេះ ប្រហែលជាបណ្តាលមកពីមានលិខិត១ច្បាប់ ដែលពួកអ្នកសរសេរជីវប្រវត្តិបានចម្លងចេញមួយចំណែក ហើយពួកសាសនទូតយល់ច្រឡំ ក៏ប៉ុន្តែគ្រួសារពីញ៉ូដឹងខ្លួនឯងច្បាស់ណាស់ ពីព្រោះថាពួកនេះមិនមានសិទ្ធិទទួលម្កុដជាអង្គម្ចាស់ (comte) សោះទេ ។ ពួកសាសនទូតបាននិយាយថាលោកពីញ៉ូបានត្រូវស្តេចល៊ុយទី១៦ លើកឲ្យឡើងជាអ្នកអង្គម្ចាស់ ក៏ប៉ុន្តែគ្មានឯកសារស្តីពីក្រុមអភិជនបារាំង ឬឯកសារបណ្ណសារដ្ឋានជាតិណាមួយបញ្ជាក់អំពីរឿងនេះសោះ ។

បានសម្រេចដោយជោគជ័យ ។ ក្រោយពីរៀបចំអំណាចរបស់ខ្លួននៅភាគខាងជើងរួចហើយ ពួកតៃសឺនបានទទួលដំណឹងថាង្វៀងអាញ់ទើបនឹងដណ្តើមបានខេត្របិញធន់ ខាញ់បាវ និងភូយេន ហើយបានធ្វើដំណើរមកជិតដល់គីញ៉ឹន ហើយក៏រួតរះដឹកនាំទ័ពត្រលប់មកត្បូង វាយដណ្តើមយកទឹកដីដែលបាត់បង់ពីមុន មកវិញទាំងអស់រួមទាំងសាយហ្គនផង នៅពាក់កណ្តាលឆ្នាំ១៧៨២ ។

ង្វៀងអាញ់ត្រូវរត់គេចខ្លួនចេញ ធ្វើឲ្យកូសាំងស៊ិនធ្លាក់ខ្លួនរងាម្តងទៀត ប៉ុន្តែមិនហ៊ានកម្រើកអ្វីទេ ។ បងប្អូនតៃសឺន ក៏ត្រលប់ទៅតុងកឹងវិញ ដោយវាយបង្ក្រាបស្រុកតាមផ្លូវឲ្យរាបទាប ធ្វើឲ្យអ្នកស្រុកទះដៃអបអរទទួលថា ជាអ្នកខ្លាំងពូកែ ។ ក្រោមកណ្តាប់ដៃរបស់ពួកតៃសឺន អាណាចក្រអាណ្ណាម បានត្រូវបង្រួបបង្រួមមកជារដ្ឋតែ១ឡើងវិញ ក៏ប៉ុន្តែពួកគេទាំង៣នាក់ជាមនុស្សប្រកបទៅដោយមហិច្ឆតា ហើយច្រណែនគ្នាទៅវិញទៅមក ។ ពួកគេបានសម្រេចទុកតុងកឹងឲ្យស្តេចឡឺជាវថុងសោយរាជ្យ ហើយចែកគ្នាគ្រប់គ្រងទឹកដីដែលនៅសល់ ៈ ញ៉ាក់បានប្រកាសខ្លួនជាអធិរាជនៃទឹកដីកណ្តាលដោយមានទូរ៉ានជារាជធានី, វើ កាន់កាប់ភាគខាងជើង ចាប់ពីព្រំដែនជាមួយតុងកឹងមក រួមទាំងរាជធានីវើ ផង, ឯតាយកភាគខាងត្បូង រួមមានទាំង ណាមគី (កូសាំងស៊ិនខាងត្បូង) ផង ។ ក៏ប៉ុន្តែវើមិនស្កប់ស្កល់នឹងទឹកដីដែលខ្លួនទទួលបាននោះទេ ។ គាត់បានដណ្តើមយកខេត្រង៉េណាន ដែលស្ថិតនៅពីខាងជើងទឹកដីដែលគេបានយល់ព្រមប្រគល់ឲ្យគាត់ ស្តេចតុងកឹងបានបញ្ជូនទ័ព១កងមក តែគាត់វាយទ័ពនោះឲ្យបរាជ័យ មិនតែប៉ុណ្ណោះគាត់បានបន្តវាយយកតុងកឹងថែមទៀត វាយឈ្នះកងទ័ពព្រះរាជា ហើយធ្វើដំណើរចូលទៅក្នុងរាជធានីហាណូយ ធ្វើឲ្យព្រះរាជាភៀសព្រះកាយទៅគិញបាក់ (បាក់និញ) តែចៅហ្វាយខេត្រនៅទីនោះ បានប្រកែកមិនហ៊ានទទួលឲ្យព្រះអង្គជ្រកនៅទេ ។ វើ ក៏ប្រកាសខ្លួនឡើងជាស្តេចតុងកឹង ពួកអ្នកស្រុកដែលភ្ញាក់ផ្អើលនឹងព្រឹត្តិការណ៍នេះ ស្វាគមន៍អបអរជាខ្លាំង តែពួកមន្ត្រីត្រូវបាក់មុខបាក់មាត់យ៉ាងអាម៉ាស់ ។ ព្រះរាជាធ្លាក់ពីរាជបល្ល័ង្ក ក៏រត់ទៅស្រុកចិនទៅ ដោយបានទទួលការអនុញ្ញាតឲ្យជ្រកកោននៅប៉េកាំង ។

និយាយពីង្វៀងអាញ់វិញ ដែលបានគេចខ្លួនចេញនៅពេលដែលពួកតៃសឺនដណ្តើមបានសាយហ្គន ក្រោយពីបានធ្វើដំណើរពនេចរ ពីកន្លែងមួយទៅកន្លែងមួយ អស់ពេលជាច្រើនខែ ក៏វិលត្រលប់មកកូសាំងស៊ិនវិញ ដណ្តើមយកសាយហ្គនបាននៅក្នុងឆ្នាំ១៧៧៧ ហើយបានឆ្លៀតពេលដែលពួកតៃសឺនជាប់ដៃរវល់នៅ ភូយេន វាយដណ្តើមយកទឹកដីមកវិញ ។ ក្នុងពេលនោះង្វៀងអាញ់បានវាយប្រហារមកលើកម្ពុជា រួចក្រោយមក បានចូលជួយកម្ពុជានៅពេលដែលកម្ពុជាត្រូវសៀមវាយប្រហារ ។ បន្ទាប់មកទៀតង្វៀងអាញ់បានធ្វើការចរចាជាមួយពួកសៀម ដើម្បីអាចបែរមកទប់ទល់នឹងពួកតៃសឺនវិញ ដែលទើបតែបានឆ្លងកាត់ព្រំដែនចូលមក ក៏ប៉ុន្តែត្រូវបរាជ័យ ។ ពួកតៃសឺនដណ្តើមយកសាយហ្គនបានម្តងទៀត រួចយកបានកូសាំងស៊ិនភាគខាងក្រោមទាំងមូល (ឆ្នាំ១៧៨១) ។

យ៉ាឡុង បានគេចខ្លួនទៅពួនសម្ងំនៅកោះភូកុក នៅក្នុងឈូងសមុទ្រសៀម ចេញចូលៗជាច្រើនដង នៅទី

បញ្ចប់បានដណ្ដើមយកសាយហ្គន និងកូសាំងស៊ីនទាំងមូលមកវិញ ក្រោយពីបានគេចខ្លួនទៅជ្រកកោននៅបាងកកអស់ពេល២ឆ្នាំ ។

នៅពេលដែលពួកតៃសឺនបែកបាក់ និងធ្វើសង្គ្រាមនឹងគ្នា យ៉ាឡុងក៏ឆ្លៀតឱកាសវាយបណ្ដេញពួកនោះចេញជាសម្រេចតែម្ដង ។ នៅពេលនោះហើយដែល អេវ៉ែកពីញ៉ូ ដែលជួយគាំទ្ររជ្ជទាយាទនេះ ហើយបានដើរតាមគ្រប់ទីកន្លែងជួយរៀបចំធ្វើសង្គ្រាម បើទោះជាថាតាមគោលការណ៍សាសនា និងវិជ្ជាជីវៈគាត់ត្រូវជាមនុស្សសន្តិភាពម្នាក់ក៏ដោយ ។ គាត់ជាគ្រូបង្ហាត់បុត្រាច្បងរបស់យ៉ាឡុងដោយផ្ទាល់ និងបានធ្វើដំណើរទៅស្រុកបារាំងសុំស្ដេចល៊ុយទី១៦ផ្ដល់ជំនួយឲ្យយ៉ាឡុង ហើយបានវិលត្រលប់មកពីប៉ុងឌីចេរីមកវិញជាមួយនឹងនាយទាហានជាង ១០នាក់ និងពលទាហានប្រមាណជា១០០នាក់ដែលគាត់ជ្រើសរើសបាន មកប្រឡូកជាមួយនឹងការផ្សងព្រេងនេះ ។ តាមពិតប្រទេសបារាំង និងក្រុងប៉ុងឌីចេរី មិនសូវជាទុកចិត្ត អេវ៉ែកពីញ៉ូ ប៉ុន្មានទេ ហើយមិនបានផ្ដល់ជំនួយតាមគាត់សុំនោះឡើយ ។ ម៉្លោះហើយគាត់ក៏ជ្រើសរើសទ័ពស្ម័គ្រចិត្តដោយខ្លួនឯង រួចក៏នាំគ្នាចុះកប៉ាល់ចម្បាំង២គ្រឿងប្រកបទៅដោយអាវុធយុទ្ធភណ្ឌ យកមកប្រគល់ឲ្យយ៉ាឡុង ។ នាយទាហានទាំងអស់នោះសុទ្ធតែជាអ្នកផ្សងព្រេង អង់អាចក្លាហាន ហើយស្មោះត្រង់នឹងអេវ៉ែក និងស្ដេច ដែលគេបម្រើ ។ គេបាននាំគ្នារៀបចំកងទ័ពតាមរបៀបបារាំងតាមដែលអាចធ្វើទៅបាន កសាងបន្ទាយតាមគំរូបន្ទាយនៅវ៉ូបង់ ធ្វើសំពៅតាមបែបចិន ដែលធានាបាននូវជ័យជម្នះសម្រាប់ពួកអាណ្ណាម ។ ពួកនេះបានជំរុញឲ្យអ្វីៗប្រព្រឹត្តទៅតាមចំណង់ចិត្តរបស់គេ ឬហោចណាស់ក៏ប្រសើរជាងពេលដែលគ្មានគេដែរ ។ និយាយពី អេវ៉ែកពីញ៉ូ វិញ គាត់បានក្លាយទៅជាទីប្រឹក្សាធំរបស់ព្រះរាជា ហើយបើទោះជាថាព្រះរាជាមិនបានស្ដាប់គាត់គ្រប់ពេលក៏ដោយ ក៏គាត់មានឥទ្ធិពលច្រើនទៅលើព្រះអង្គ ។ ហេតុការណ៍នេះបានធ្វើឲ្យពួកមន្ត្រីអាណ្ណាម ប្រណែនមិនពេញចិត្ត ចងគំនុំគុំកួន ដែលនឹងកើនឡើងជាលំដាប់រហូតដល់ក្លាយទៅជាការស្អប់នៅក្នុងរាជ្យស្ដេចមិញម៉ាង បុត្រារបស់ស្ដេចយ៉ាឡុង ដែលសោយរាជ្យបន្តពីព្រះបិតា ដោយសុំឲ្យស្ដេចនេះបណ្ដេញពួកបារាំងទាំងអស់នោះចេញ មិនគិតថា ពួកនោះបានចំណាយថាមពល ពេលវេលាដ៏ល្អប្រសើរក្នុងជីវិត និងជីវិតផ្ទាល់របស់គេ ដើម្បីផលប្រយោជន៍ស្រុកមួយដែលមិនមែនជាស្រុករបស់គេផងទេ ។

ក្រោយពីដណ្ដើមយកកូសាំងស៊ីនភាគខាងត្បូងរួចមក ស្ដេចយ៉ាឡុង បានចាប់ផ្ដើមវាយយកកូសាំងស៊ីនកណ្ដាល (អាណ្ណាម) ដណ្ដើមយកភូយេនរួចគីញ៉ើន នៅក្នុងខែសីហា ឆ្នាំ១៧៩៨ ។ អេវ៉ែកពីញ៉ូ បានស្លាប់ប៉ុន្មានខែក្រោយមក ហើយស្ដេចយ៉ាឡុងបានរៀបចំទុកដាក់គាត់ប្រកបទៅដោយកិត្តិយស ប្រៀបបីដូចគាត់ជាអង្គម្ចាស់មួយអង្គដែរ ហើយបានសង់ផ្នូរធំមួយជូនគាត់ ដែលមាននៅសល់រហូតដល់សព្វថ្ងៃ នៅជាយក្រុងសាយហ្គន ។

ការប្រយុទ្ធបានបន្តទៅមុខទៀត បន្ទាប់ពីទូរ៉ាន គឺរាជធានីវ៉េដែលត្រូវដណ្ដើមបាន ហើយង្វៀងអាញ់ ក៏ឡើងសោយរាជ្យក្រោមព្រះនាមថាយ៉ាឡុង ស្ដេចរបស់កូសាំងស៊ីន និងណាមគី នៅក្នុងឆ្នាំ១៨០១ ។ ឡើងគ្រង

រាជបល្ល័ង្កមិនទាន់បានប៉ុន្មានផង ស្ដេចយ៉ាឡុងបានធ្វើដំណើរបន្តទៅវាយយកតុងកឹង វាយឲ្យពួកតៃសឺនចុះខ្សោយ រួចដណ្ដើមយកហាណូយ និងប្រទេសទាំងមូល ។

ដូច្នេះ បច្ចាញាតិម្នាក់របស់ជួនៅកូសាំងស៊ីនបានវាយបច្ចាញាតិរបស់ជួនៅតុងកឹងឲ្យបរាជ័យ ហើយធ្វើខ្លួនឲ្យទៅជាស្ដេច ដែល អេវ៉ែកពីញ៉ូ និងពួកសាសនទូតតែងតែនិយាយថាជាស្ដេចស្របច្បាប់ តែតាមការពិតគឺជាស្ដេចជ្រែករាជ្យទេ ។ ព្រោះថាទ្រង់មិនបានទទួលស្គាល់សិទ្ធិអំណាចរបស់ពួកទ្រិញ ហើយក៏បានបដិសេធសិទ្ធិស្នងរាជ្យបន្តរបស់សន្តតិវង្សឡេ ក៏ប៉ុន្តែដោយព្រះអង្គជាអ្នកឈ្នះ ព្រះអង្គគឺជាម្ចាស់ ។ ទ្រង់បានផ្ដល់សក្តិយសឲ្យពួកមន្ត្រី បែងចែកដីស្រែ បែងចែកផលទទួលបានមកពីការយកពន្ធដាររបស់ពួកឡេ និងទ្រិញ ហើយទ្រង់ឲ្យគេរៀបចំអភិសេកព្រះអង្គជាព្រះចៅអធិរាជរបស់អាណ្ណាម ។

សង្គ្រាមបានបញ្ចប់ហើយ អាណាចក្រអាណ្ណាម អាចព្យាបាលរបួសរបស់ខ្លួនឲ្យសះជាបាន[៨] ហើយពង្រីកទឹកដីខាងជើងទៅទល់នឹងស្រុកចិន ខាងត្បូងទៅទល់នឹងកម្ពុជា ។

គឺនៅក្នុងរាជ្យស្ដេចមិញម៉ាងនេះឯង ដែលពួកអាណ្ណាមចាប់ផ្ដើមដណ្ដើមយកដីកម្ពុជា ។ យើងបានឃើញ

---

[៨] នៅសល់ពួកបារាំងដែលបានខិតខំបម្រើស្រុកអាណ្ណាមអស់ពីចិត្តពីថ្លើម ។ ពួកនេះសមណាស់តែទទួលបាននូវកិត្តិយស ប៉ុន្តែពួកគេ បែរជាត្រូវទទួលការជេរប្រទេចផ្ដាសា ទៅវិញ ។ ពួកអ្នកស្រុកដែលកាន់សាសនាកាតូលិក ជាពួកដែល អេវ៉ែក ការពារ ហើយដែលស្មោះត្រង់ជានិច្ចនឹងស្ដេចយ៉ាឡុង ត្រូវគេរំខាន បំបែកបំបាក់ ។ គេចោទថា ពួកសាសនទូតបានខ្វេះភ្នែកក្មេងៗយកទៅធ្វើថ្នាំ ហើយពួកអ្នកស្រុកដែលត្រូវពួកមន្ត្រីបោកប្រាស់ ក៏ចាប់ស្អប់ពួកកាតូលិកជាបណ្ដើរៗ ។ សូម្បីតែស្ដេចយ៉ាឡុង ខ្លួនព្រះអង្គ ក៏បានផ្ដាំបុត្រាមុនពេលទ្រង់សុគត (ឆ្នាំ១៨២០) ថា កុំឲ្យទុកចិត្តពួកបារាំងដែរ ដែលគឺពួកបារាំងនេះហើយ ជាអ្នកបានជួយដណ្ដើមយកអាណាចក្រមកថ្វាយ ។ បុត្រាដែលទទួលបណ្ដាំ ហើយដែលស្នងរាជ្យបន្តពីបិតានេះ មិនមែនជាបុត្រាដែលមាន អេវ៉ែក ជាគ្រូនោះទេ ព្រោះបុត្រានេះបានសុគតទៅហើយ ។ គឺមិញម៉ាង ជាបុត្រាបន្ទាប់ ដែលទទួលរាជ្យសម្បត្តិ ហើយចាប់បំបែកបំបាក់ពួកបារាំង ធ្វើឲ្យពួកនេះអស់ចិត្តនឹងបម្រើ រួចហើយក៏ដាច់ចិត្តវិលត្រលប់ទៅស្រុកវិញទៅ អ្នកខ្លះត្រូវធ្លាក់ខ្លួនក្រជាងកាលពីទើបមកដល់កូសាំងស៊ីនទៅទៀត ណាមួយវ័យក៏ចាស់ បាក់អស់កម្លាំង ស្ទើរតែក្លាយទៅជាជនបរទេសចំពោះស្រុកខ្លួនឯងទៅហើយ ក្រុមគ្រួសារក៏មើលមិនស្គាល់ ។

នៅក្នុងឆ្នាំ១៨៣១ មានពួកបារាំងដែលធ្លាប់បានមកបម្រើអាណ្ណាមម្នាក់ គឺលោក សៃញ៉ូ បានត្រូវរដ្ឋាភិបាលបារាំងចាត់ឲ្យមកអាណ្ណាម ក្នុងឋានៈជាកុងស៊ុលបារាំងប្រចាំរាជធានីវេ៉ ក៏ប៉ុន្តែស្ដេចមិញម៉ាង ភ្លេចអស់គុណូបការៈដែលគាត់ធ្លាប់បានធ្វើមកលើ ហើយបានប្រកែកមិនព្រមទទួលគាត់ទេ គាត់ក៏ឡើងកប៉ាល់ចេញទៅវិញទៅ ។ ចាប់ពីពេលនោះមក ចំណងទាក់ទងរវាងបារាំងនិងអាណ្ណាមក៏ត្រូវកាត់ផ្ដាច់ ។ ចំណងទាក់ទងនេះ កើតមានឡើងវិញនៅក្រោមរជ្ជកាលចៅរបស់មិញម៉ាង គឺទូឌឹក នៅពេលដែលលោកឧត្តមនាវីរង រីហ្គោលដឺហ្សឺនូយី ត្រូវបានបញ្ជូនឲ្យមកធ្វើការសងសឹកនឹងការដែលស្ដេចនេះបញ្ជាឲ្យសម្លាប់ពួកសាសនទូត ហើយវាយដណ្ដើមយក ទូរ៉ាន បាននៅក្នុងថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៨៥៨ ។

ពីខាងលើរួចមកហើយ អំពីការដែលពួកឧត្តមសេនីយ៍អាណ្ណាមបានជ្រើសរើសព្រះក្សត្រីអង្គមី ឲ្យឡើងសោយរាជ្យ រួចធ្វើបាបបុត្រីពាអង្គទៀតរបស់ព្រះអង្គអេង ការគ្រប់គ្រងឃោរឃៅដោយឲ្យមន្ត្រីខ្មែរស្លៀកពាក់តាមរបៀបអាណ្ណាម ទុកសក់វែងក្រង ។ យើងក៏បានឃើញហើយដែរអំពីការបះបោរប្រឆាំងរបស់ប្រជារាស្ត្រខ្មែរ ចំពោះសង្គ្រាមដែលស្តេចអង្គឌួងបានធ្វើប្រឆាំងនឹងអាណ្ណាមដោយមានការគាំទ្រពីពួកសៀម ហើយនិងអំពីសន្ធិសញ្ញាសន្តិភាពរវាងអាណ្ណាម និងសៀម នៅពេលដែលអាណ្ណាមត្រូវបរាជ័យក៏ប៉ុន្តែនៅតែខ្លាំង ហើយខ្មែរឈ្នះក៏ប៉ុន្តែខ្សោះអស់កម្លាំង ជាពិសេស គឺអស់សង្ឃឹមចំពោះអនាគត ។

ប្រជាជាតិទាំង៣បានចុះសន្ធិសញ្ញាសន្តិភាព ហើយព្រះអង្គឌួងបានត្រូវអភិសេកឲ្យឡើងសោយរាជ្យនៅក្នុងឆ្នាំ១៨៤៧ ។ កម្ពុជាពេលនោះមានប្រទេសជាអាណាព្យាបាល២ ដែលសង្កេតតាមដានគ្នាទៅវិញទៅមក ហើយប្រុងតែនឹងលេបយកទឹកដីកម្ពុជាទាំងអស់ទៅហើយបើសិនជាគ្មានគូបដិបក្ខម្ខាងទៀតទេ ឬបើសិនជាគេអាចស្រុះស្រួលគ្នាក្នុងការបែងចែកនោះ ។

មានហេតុការណ៍បញ្ជាក់ច្បាស់ណាស់ថាសៀម និងអាណ្ណាមបានប្រុងប្រៀបខ្លួន រង់ចាំតែឱកាសមកដល់នឹងអាលចាប់ដណ្តើមយកកម្ពុជាបន្ត ទទួលសង្គ្រាមបានផ្ទុះឡើងរវាងពួកបារាំងជាសម្ព័ន្ធភាពរបស់ពួកអេស្ប៉ាញជាមួយនឹងពួកអាណ្ណាម ដែលបានសម្លាប់ពួកសាសនទូតកាតូលិកយ៉ាងរង្គាល ។ អាណ្ណាមបានសន្យាថា នឹងដាក់ទោសឃាតកដែលសម្លាប់ពួកសាសនទូតនេះ ក៏ប៉ុន្តែមិនដែលបានដាក់ម្តងណាទេ មិនតែប៉ុណ្ណោះ បានបណ្តោយឲ្យពួកមន្ត្រីបន្តបំបែកបំបាក់តទៅទៀត មិនមានខ្លាចញញើតបារាំងបន្តិចណាឡើយ[៩] ។

[៩] ខ្ញុំសូមបញ្ជាក់ថា ពួកសាសនទូតកាតូលិក បានធ្វើឲ្យមានការច្របូកច្របល់នៅក្នុងទំនៀមទម្លាប់របស់ស្រុកទេស ដោយបានហាមប្រាមមិនឲ្យអនុវត្តជំនឿគោរពជីដូនជីតា ដាក់សែ្តង គឺហាមពួកអ្នកចូលសាសនាថ្មី មិនឲ្យចូលរួមក្នុងពិធីបុណ្យក្នុងភូមិ ដែលជាពិធីបុណ្យសាសនា មិនឲ្យស្បថនៅមុខតុលាការតាមទម្លាប់របស់ច្បាប់អាណ្ណាម ជាពិសេស គឺឲ្យរក្សាទំនាក់ទំនងល្អជាមួយពួកអឺរ៉ុប និងហាងពាណិជ្ជកម្មអឺរ៉ុប ដែលពួកអាណ្ណាមយល់ឃើញថា គឺជាអន្តរាគមន៍របស់បរទេស ។ មុនដំបូងព្រះរាជាបានចេញបញ្ជាឲ្យបណ្តេញពួកសាសនទូតកាតូលិកចេញពីនគរ ហើយហាមមិនឲ្យស្វាគមន៍រាក់ទាក់ទទួលពួកនេះទេ ។ ទ្រង់បានឲ្យគេដឹកពួកសាសនទូតណា ដែលលាក់ខ្លួនជាមួយពួកអាណ្ណាមកាតូលិក ដែលគេបានរកឃើញហើយឃាត់ខ្លួនបានយកទៅកាន់សិង្ហបុរីដោយផ្ទាល់ព្រះអង្គ ។ ប៉ុន្តែពួកសាសនទូតទាំងអស់នោះ បានលួចធ្វើដំណើរចូលមកក្នុងប្រទេសអាណ្ណាមវិញ ហើយបានបន្តធ្វើដំណើរផ្សព្វផ្សាយសាសនាតទៅទៀត ។ ការធ្វើបែបនេះវាជាការធម្មតាទេនៅអឺរ៉ុប ហើយគេស្ញើចសរសើរសាសនទូតណាដែលបានខិតខំលះបង់ខ្លួន សុខចិត្តរងទទួលទារុណកម្ម ហើយនៅពេលដែលសាសនទូតម្នាក់ស្លាប់ទៅ សាសនទូតម្នាក់ទៀតដែលពោរពេញទៅដោយជំនឿ ក៏ចូលខ្លួនបន្តការងារឡើង ។ គេបាននាំគ្នាជេរស្តេចអាណ្ណាម និងពួកមន្ត្រីរបស់ព្រះអង្គ ក៏ប៉ុន្តែគេមិនបានគិតថា នៅសម័យជាមួយគ្នានោះ នៅឯស្រុកបារាំងក្រោមស្តេចល្វី-ទី១៤ ទី១៥ និងទី១៦ គេកំពុងតែនាំគ្នាបំបែកបំបាក់ពួកបារាំងណាដែលបែរចូលកាន់សាសនា ប្រូតេស្តង់ ដែលមិនមែនជាជនបរទេសទេ ។ ដូច្នេះ បើសិនជាមានពុទ្ធសាសនិកជនទៅឃោសនាផ្សព្វផ្សាយសាសនាព្រះពុទ្ធនៅប្រើតាញ

ពេលនោះស្ដេចរបស់អាណ្ណាមគឺទូឌឹក ហើយសោយរាជ្យនៅរាជធានីវេ ។ ព្រះចៅអធិរាជចិនបានចាត់មន្ត្រីឲ្យមកសំដែងការទទួលស្គាល់ស្របទៅតាមទម្លាប់ នៅក្នុងឆ្នាំ១៨៤៨ ។ ទ័ពបារាំងបានវិលត្រលប់មកពីប៉េកាំងវិញ ក្រោយពីបានដាក់ទណ្ឌកម្មប្រទេសចិនដែលមិនគោរពពាក្យសន្យាជាមួយនឹងទ័ពអង់គ្លេស ។ ទ័ពនោះបានធ្វើដំណើរស្របតាមឆ្នេរសមុទ្រអាណ្ណាម ប្រុងត្រលប់ទៅស្រុកបារាំងវិញ ។ ប៉ុន្តែគេមានការខូចខាតដោយសារពួកអាណ្ណាមច្រើនណាស់ ដែលមិនអាចនឹងមិនដាក់ទោសឬមិនបង្ខំឲ្យចុះសន្ធិសញ្ញាណាមួយបានទេ ។ រាជវាំងអាណ្ណាម ធ្វើដូចជាមិនដឹងមិនឮ ហើយបានបដិសេធមិនព្រមទទួលពួកអ្នកដែលបារាំងបានបញ្ជូនឲ្យមកចរចាទេ ។ ដោយហេតុនោះហើយ សង្គ្រាមក៏ចាប់ផ្ដើមឡើង ដោយមានទ័ពអេស្ប៉ាញប៉ុន្មានវរសេនាតូចមកជួយបារាំងផង ។ បារាំងដណ្ដើមយកទូរ៉ានបាននៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៨៥៨ រួចដណ្ដើមយកសាយហ្គននៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំបន្ទាប់ ក្រោយពីការប្រយុទ្ធដ៏សាហាវ ។ ដោយមានបំណងចង់ប្រមូលផ្ដុំកម្លាំងដណ្ដើមយកកូសាំងស៊ីន ភាគខាងត្បូងជាង លោកឧត្ដមនាវីបារាំងបានសម្រេចចិត្តបោះបង់ទូរ៉ានចោលវិញ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំដដែលនោះ ។

ពេលនោះចិនមិនបានគោរពតាមសន្ធិសញ្ញាដែលបានចុះជាមួយគ្នាពីឆ្នាំ១៨៥៨ទេ លោកឧត្ដមនាវីដែលដឹកនាំការប្រយុទ្ធនៅសាយហ្គនត្រូវបង្ខំចិត្តប្រគល់បញ្ជាការទៅឲ្យនាយកប៉ាល់ម្នាក់ ឯខ្លួនគាត់បានដឹកនាំកម្លាំងមួយផ្នែកធំត្រលប់ទៅស្រុកចិនវិញ ។ ឆ្លៀតឱកាសដែលទ័ពបារាំងនៅសល់តិចនោះ ពួកអាណ្ណាមបានសាកល្បងវាយដណ្ដើមយកសាយហ្គនមកវិញ តែមិនបាន ។

ក្រោយពីបង្ក្រាបពួកចិនរួចហើយ ទ័ពបារាំងបានត្រលប់មកដល់សាយហ្គនជាថ្មីនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៨៦១ រួចហើយក៏ចាប់វាយដណ្ដើមយកទឹកដីអាណ្ណាមដែលបានផ្អាកអស់មួយរយៈ ជាបន្តឡើងវិញទៀត ។ លោកឧត្ដមនាវីត្រី ប៉ាង៉ 
បានដណ្ដើមយកមីថបាននៅក្នុងថ្ងៃទី១២ ខែមេសា បន្ទាប់លោកឧត្ដមនាវីត្រី បូណាបានដណ្ដើមយកបៀនហ៊ា នៅក្នុងថ្ងៃទី៩ ខែកញ្ញា រួចវិញឡុងនៅក្នុងថ្ងៃទី២៨ ខែមីនា ឆ្នាំ១៨៦២ ។ នៅក្នុងថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៨៦២ ស្ដេចទូឌឹកបានយល់ព្រមចុះសន្ធិសញ្ញាជាមួយបារាំង ហើយប្រគល់ខែត្រ៣នៃកូសាំងស៊ីនប៉ែកខាងលិចជាប់នឹងអាណាចក្រអាណ្ណាម ទៅឲ្យបារាំងជារៀងរហូត គឺបៀនហ៊ា យ៉ាឌិញ (សាយហ្គន) និងមីថ ។ ខែត្រ៣ទៀតនៅជារបស់អាណ្ណាមនៅឡើយ គឺអាងយ៉ាង (ចូវដុក) ហាទៀង និងឌិញទៀង (វិញឡុង) ស្ថិតនៅដាច់ពីអាណ្ណាមដោយមានកម្ពុជាពីខាងជើង ឈូងសមុទ្រសៀមពីខាងលិច សមុទ្រចិនពីខាងត្បូង និងខែត្រយ៉ាឌិញរបស់បារាំងពីខាងកើត ។ និយាយពីពួកអេស្ប៉ាញ៉ុលម្ដង ពួកគេបានដកខ្លួនចេញទៅវិញព្រោះថា គេបាន

---

វ៉ង់ដេ ម៉ែន ឬទីកន្លែងផ្សេងទៀតរបស់បារាំង ឬនៅអេស្ប៉ាញ អ៊ីតាលី នៅក្នុងសតវត្សរ៍ទី១៩នេះ ពួកនេះក៏ប្រហែលជាត្រូវបារាំងកាប់សម្លាប់មិនខុសគ្នាអ្វីពីពួកសាសនទូតកាតូលិកនៅអាណ្ណាមដែរទេ ។

សងសឹកចំពោះការប្រមាថទៅលើពួកសាសនទូតរបស់គេរួចហើយ ហើយបារាំងក៏បានចេញសងការខូចខាតខ្លះនៅក្នុងសង្គ្រាមនោះឲ្យផងដែរ ។

ក៏ប៉ុន្តែទឹកដីកូសាំងស៊ីន ដែលអាណ្ណាមយល់ព្រមប្រគល់ឲ្យបារាំងតាមរយៈសន្ធិសញ្ញាឆ្នាំ១៨៦២នោះ មិនបានសុខទេ ព្រោះថាជាទឹកដីដែលបារាំងដណ្តើមយកពីអាណ្ណាម ហើយអាណ្ណាមក៏មិនដែលបោះបង់គំនិតក្នុងការទាមទារយកមកវិញដែរ ។ អាចនឹងមានការប្រយុទ្ធច្រើនទៀតកើតឡើង ។ ពួកអាណ្ណាម បានបន្តរឿងឡើងដោយគាំទ្រការបះបោររបស់អាស្វា និងពោធិកំបោរ ដ្តល់ជម្រកឲ្យស្នាក់នៅក្នុងបណ្តាខែត្រដែលនៅជារបស់អាណ្ណាមនៅឡើយ នៅពេលដែលកម្ពុជាបានធ្លាក់ចូលក្នុងអាណាព្យាបាលរបស់បារាំងតាំងតែពីថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ មកម្ល៉េះ ។ ពួកអាណ្ណាមបានបន្តឲ្យមានការលុកលុយធ្វើបាបទៅលើពួកអ្នក ដែលស្ថិតនៅក្រោមកិច្ចការពាររបស់បារាំង និងបានធ្វើឲ្យមានការរំដើបរំជួលប្រកបទៅដោយគ្រោះថ្នាក់ឥតដាច់ ។ នៅពេលដែលបារាំងរិះរកវិធីសម្របសម្រួលអស់ចិត្តហើយ ហើយពិនិត្យទៅឃើញថា ពួកមន្ត្រីអាណ្ណាមនៃអាណាខែត្រខាងលិចនៅតែសន្សំចិត្តស្នេហាជាតិ ចង់បានខែត្រដែលប្រគល់ឲ្យបារាំងយកមកវិញ បារាំងមិនអាចទុកចិត្តលើសម្តីរបស់អាណ្ណាមបានទេ ក៏រៀបចំទ័ពមួយកងធំវាយដណ្តើមយកខែត្រទាំង៣ ដែលសន្ធិសញ្ញាឆ្នាំ១៨៦២ បានទុកឲ្យនៅជារបស់អាណ្ណាម ព្រមទាំងទីក្រុងផង ក្នុងពេលតែ៥ថ្ងៃប៉ុណ្ណោះ គឺដណ្តើមយកបាន វិញឡុង នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៨៦៧, ចូវដុក នៅថ្ងៃទី២២, និងហាទៀង នៅថ្ងៃទី២៤[១០] ។

ដូច្នេះទឹកដីកូសាំងស៊ីនភាគខាងត្បូងដែលពួកអាណ្ណាម បានប្រើពេលអស់២សតវត្សរ៍ ដើម្បីដណ្តើមយកពីកម្ពុជា មិនមែនដណ្តើមយកដោយគ្រាន់តែប្រើកម្លាំងទ័ពវាយនោះទេ តែជាពិសេសគឺដោយបញ្ជូនប្រជាជនទាំងគ្រួសារៗឲ្យចូលទៅនៅតែម្តង ឥឡូវនេះបានធ្លាក់ទៅជារបស់បារាំងអស់ហើយ ធ្វើឲ្យកម្ពុជានៅមានសល់សត្រូវតែមួយប៉ុណ្ណោះ គឺពួកសៀម ។ យើងបានឃើញរួចមកហើយថាតើបារាំងបានដោះស្រាយយ៉ាងណាជាមួយសៀម ហើយបានទាមទារយកទឹកដីដ៏ធំធេងមកឲ្យកម្ពុជាវិញនៅក្នុងឆ្នាំ១៩០៤ និង១៩០៧ ទឹកដីដែលគេគិតថា មិនអាចនឹងត្រលប់មកជារបស់កម្ពុជាវិញបានទេ ។

ស្តេចទូឌឹកបានយល់ព្រមចុះសន្ធិសញ្ញាសន្តិភាពមួយទៀតនៅក្នុងថ្ងៃទី១៥ ខែមីនា ឆ្នាំ១៨៧៤ ទទួលស្គាល់អធិបតេយ្យភាពពេញលេញរបស់បារាំងមកលើទឹកដីមួយកន្លែង ដែលមានកម្ពុជានៅពីខាងជើង ឈូង

[១០] ទីក្រុងទាំង៣នេះហើយ និងក្រុងមួយចំនួនទៀត ដែលបារាំងដណ្តើមយកបាននៅពេលនោះ សុទ្ធតែបានត្រូវគេសង់ឡើងតាមប្លង់ដែលនាយទាហានបារាំងបានរៀបចំ ជាពិសេស គឺលោក វិកទ័រអូលីវីយេ៉ដឺពុយម៉ាណែល ដែលបម្រើស្តេចយ៉ាឡុងពីឆ្នាំ១៧៨៩ រហូតដល់ឆ្នាំ១៨២០ ។

សមុទ្រសៀមនៅពីខាងលិច សមុទ្រខាងត្បូង និងបិញធន់ នៅខាងកើត ។

នៅពេលនោះស្រាប់តែមានកើតភាពល្អក់កករឡើងនៅឯតុងកឹងរវាងអាណ្ណាម និងបារាំង ដោយពួកមន្ត្រីអាណ្ណាមបានបន្តការរំខានដល់ពាណិជ្ជកម្មគ្រឿងសព្វាវុធដែលលោក ឌុយពុយ[១១] ធ្វើជាមួយអាជ្ញាធរចិន នៅយុនណាន ។ មុនដំបូងលោកឧត្តមនាវីជាទេសាភិបាលកូសាំងស៊ីនមានការរារែកនឹងធ្វើសង្គ្រាមនេះដែរ ក៏ប៉ុន្តែ បន្ទាប់មក នៅក្នុងឆ្នាំ១៨៧៣-១៨៧៤ លោក ហ្វ្រង់ស៊ីសហ្គានីញេ ដែលមានទាហានតែជាង៤រយនាក់ បានដណ្តើមយកបន្ទាយទាំងអស់របស់តុងកឹង ហើយកាន់កាប់ស៊ឹងទន្លេ និងផ្លូវថ្នល់តូចធំទាំងអស់ ។ ការវាយដណ្តើមយកទាំងនោះបានប្រព្រឹត្តទៅអស់ពេលតែ២២ថ្ងៃប៉ុណ្ណោះ គឺជាការប្រយុទ្ធប្រកបទៅដោយជោគជ័យមួយ ដែលគេមិនដែលប្រទះឃើញសោះ ចាប់តាំងតែពីពេលដែលពួកអ្នកផ្សងព្រេង អេស្ប៉ាញ៉ុល និងព័រទុយហ្គេ ចេញមកដណ្តើមយកទឹកដីនៅខាងក្រៅអឺរ៉ុប ។

ពេលនោះ ពួកអាណ្ណាមនៅតុងកឹងគ្មានលទ្ធភាពនឹងធ្វើអ្វីតបតនឹងបារាំងវិញទេ ក៏រត់ទៅពឹងពាក់ពួកចោរ ១ ក្រុម មានឈ្មោះថា ក្រុមទង់ខ្មៅ ដែលបោះជំរំនៅលើទន្លេក្រហម ទារយកពន្ធដារពីទូកកប៉ាល់ ដែលធ្វើចរាចរក្នុងទន្លេ ។ តាមពិតពួកចោរនោះគឺជាអតីតទាហានចិន ដែលវាយប្រយុទ្ធធ្វើឲ្យពួកតៃពិញកាន់សាសនាអ៊ីស្លាមបរាជ័យ នៅភាគនិរតីស្រុកចិន ។ នៅពេលចប់សង្គ្រាម ពួកនេះក៏ត្រូវគេនិរទេសបណ្តេញចេញពីស្រុក ព្រោះមិនព្រមចំណុះគេ ទើបប្រមូលផ្តុំគ្នាក្រោមមេបញ្ជាការម្នាក់ ។ មុនដំបូង មេរបស់ពួកនេះ គឺជាមិត្តភក្តិម្នាក់របស់លោក ឌុយពុយ ហើយថែមទាំងបានជួយសម្របសម្រួលពាណិជ្ជកម្មរបស់គាត់ទៀតផង ។ នៅពេលរដ្ឋាភិបាលអាណ្ណាមនៅតុងកឹងអំពាវនាវឲ្យជួយ ពួកនេះក៏បែរមកប្រឆាំងនឹងលោក ឌុយពុយ វិញ ។ តាមពិតទៅ បើសិនជាបារាំងពេលនោះឆ្លាតបន្តិច ហើយហ៊ានផ្តោះប្តូរផលប្រយោជន៍ឲ្យខ្លាំងបន្តិច ពួកចោរទាំងនោះប្រហែលជាមិនបោះបង់បារាំងចោលទេ ។ ដល់ពួកនោះបែរទៅគាំទ្រពួកតុងកឹងវិញ បារាំងក៏ត្រូវប្រឈមមុខជាមួយទ័ពចិនដែលធ្លាប់ប្រយុទ្ធហើយធ្លាប់តែទទួលបាននូវជ័យជម្នះទៀតផង មិនដូចពីមុន ដែលជួបតែទ័ពកងសេនាជនអាណ្ណាមដែលមិនចេះច្បាំងសោះ ។ ពួកនោះបានសម្លាប់លោក ហ្វ្រង់ស៊ីសហ្គានីញេ នៅក្នុងថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៨៧៣ ធ្វើឲ្យការចរចាដែលគាត់បានចាប់ផ្តើមធ្វើឡើងត្រូវបរាជ័យជាច្រើនលើកច្រើនសា ។ នៅទីបញ្ចប់ សន្ធិសញ្ញាភីឡាស្ត្រឺបានត្រូវភាគីទាំងសងខាងចុះហត្ថលេខា ដោយមិនបានធ្វើឲ្យអ្នកណាម្នាក់ពេញចិត្តទេ ហើយទុកឲ្យអ្វីៗស្ថិតនៅមិនច្បាស់លាស់តទៅ ។

ក៏ប៉ុន្តែគេអាចរក្សាសន្តិភាពបាន ព្រោះថារដ្ឋាភិបាលបារាំងពេលនោះមិនទាន់មានបំណងច្បាស់ថា នឹង

[១១] លោក ឌុយពុយ នេះ កើតនៅក្នុងឆ្នាំ១៨២៩ ហើយបានស្លាប់នៅម៉ូណាកូ នៅចុងខែវិច្ឆិកា ឆ្នាំ១៩១២ ។

ដណ្តើមយកតុងកឹងនៅឡើយទេ ចំណែករដ្ឋាភិបាលអាណ្ណាម និងពួកមន្ត្រីតុងកឹងវិញ គេគ្មានគំនិតនឹងអនុវត្តមាត្រារបស់សន្ធិសញ្ញាភីឡាស្ត្រឹ ដែលគេចាត់ទុកថាគឺជាការអាម៉ាស់មួយចំពោះពួកគេ ម្ល៉ោះហើយគេមិនបានយកចិត្តទុកដាក់នឹងកុងស៊ុលរបស់បារាំងដែលសន្ធិសញ្ញាបានសម្រេចឲ្យមាននោះទេ ។ អាណ្ណាម នៅតែយកពន្ធលើទំនិញរបស់បារាំង គឺខ្ពស់ជាងការកំណត់នៅក្នុងខពិសេសរបស់សន្ធិសញ្ញា ហើយរដ្ឋាភិបាលនៅរាជធានីវ៉េបានបដិសេធមិនព្រមបណ្តេញពួកទង់ខ្មៅ ឬហេគី ដែលក្លាយមកជាសត្រូវផ្ទាល់របស់បារាំងចេញពីតុងកឹងទេ ។

និយាយពីពួកចិនវិញ ពួកនេះតែងតែគិតថាពួកគេមានសិទ្ធិអធិរាជភាពមកលើអាណ្ណាមជានិច្ច ។ ចិន បានគ្រប់គ្រងមកលើតុងកឹងរហូតមកដល់គ្រិស្តសករាជ៩៣៨ ហើយបានដណ្តើមយកតុងកឹងច្រើនលើសពី ១០ដងក៏ប៉ុន្តែមិនដែលដណ្តើមយកបានទាំងស្រុងម្តងណាទេ ។ ចិនតែងតែគាំទ្រការបះបោរប្រឆាំងនឹងតុងកឹងជានិច្ចហើយនៅទីបញ្ចប់ អាចត្រឹមតែធ្វើឲ្យស្តេចតុងកឹងស្ទើរតែគ្រប់អង្គ និងស្តេចកូសាំងស៊ីនទាំងអស់ ក្រោយពេលដែលអាណ្ណាមដណ្តើមយកនគរចាម្ប៉ាបានហើយ យល់ព្រមទទួលស្គាល់នូវអនុត្តរភាពរបស់ខ្លួន ប៉ុន្តែមិនមែនអធិរាជភាពនោះទេ ។ នៅពេលដែលតុងកឹងធ្វើសង្គ្រាមជាមួយបារាំង ចិនបានឯកភាពជាមួយរាជវាំងវ៉េប្រកាសប្រាប់បារាំងថា អាណ្ណាមជានគរសាមន្តរាជមួយរបស់ចិន ដូច្នេះបើត្រូវចុះសន្ធិសញ្ញាណាមួយទាក់ទងទៅនឹងផលប្រយោជន៍របស់អាណ្ណាមនោះ បារាំងត្រូវចុះជាមួយរាជវាំងប៉េកាំង ។

បន្តិចក្រោយមក សង្គ្រាមក៏ចាប់ផ្តើមឡើងវិញ ហើយអាណ្ណាមបានដណ្តើមយកបន្ទាយហាណូយ ដែលពួកបារាំងដណ្តើមបានកាលពីខែមេសា ឆ្នាំ១៨៨២ក្នុងរយៈពេល ២ម៉ោង ដោយកម្លាំងទ័ពមិនតិចជាង ៥រយនាក់ហើយយកទៅដាក់ក្រោមអាជ្ញាធរអាណ្ណាមវិញ ។ បន្ទាប់មក គឺហុងហាយ និងណាមឌិញ បានត្រូវធ្លាក់ទៅក្នុងដៃអាណ្ណាមថែមទៀត ។ ហេតុការណ៍កំពុងតែវិវត្តទៅយឺតៗបែបនេះ ស្រាប់តែភ្លាមនោះពួកទង់ខ្មៅ បានលេចចេញមកយ៉ាងច្រើន មានគ្នារហូតដល់ទៅ១ម៉ឺន៥ពាន់នាក់ ។ ទ័ពបារាំងគ្មានជំនួយទេ បានត្រូវអាណ្ណាម វាយនៅកានយ៉ាយ ហើយមេបញ្ជាការឈ្មោះ រីវីយែរ ក៏ត្រូវសត្រូវសម្លាប់បាននៅពេលដឹកនាំទ័ពចេញប្រយុទ្ធ នៅក្នុងថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៨៨៣ ។

ចាប់ពីពេលនោះមកគេលែងឃើញមានការប្រយុទ្ធរបៀបរប៉េះរប៉ោះ ដោយម្ខាងគឺបារាំងដែលមានគ្នាត្រឹមតែ១រយ២រយនាក់ តតាំងជាមួយនឹងទ័ពអាណ្ណាម ឬចិនរាប់ពាន់នាក់ទៀតហើយ ។ ម្តងនេះគឺជាសង្គ្រាមអាណានិគមពិតៗតែម្តង មានកម្លាំងទាហានអឺរ៉ុបរាប់រយរាប់ពាន់នាក់ ដឹកនាំដោយឧត្តមសេនីយ៍ ដែលមានបញ្ជាការដ្ឋានច្បាស់លាស់ មានអគ្គភាពពិសេស មានទ័ពសេះ កាំភ្លើងធំ និងមានការផ្គត់ផ្គង់ទៀតទាត់ ។

សង្គ្រាមនេះបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ១៨៨៣ ហើយបានបញ្ចប់ទៅវិញជាមួយនឹងសន្ធិសញ្ញាថ្ងៃទី៦ខែមិថុនា ដែលសម្រេចដាក់តុងកឹងនៅក្រោមអាណាព្យាបាលបារាំង ប្រគល់ការងាររដ្ឋបាលទាំងអស់ឲ្យបារាំងគ្រប់គ្រង និងមានបុគ្គលិកជាបារាំង ។ សន្ធិសញ្ញានោះក៏បានដាក់អាណ្ណាមនៅក្រោមអាណាព្យាបាលមួយបែបផង

ដែរ ដែលមើលទៅហាក់ដូចជាធូរស្រាលជាង ក៏ប៉ុន្តែ របៀបចរឹងមាំមិនខុសគ្នាទេ ។

សង្គ្រាមនៅតែមានជាបន្តទៅទៀត ក៏ប៉ុន្តែជាមួយតែពួកទង់ខ្មៅប៉ុណ្ណោះ ដែលមិនចង់ចាកចេញពីតុងកឹងទៅទេ ដោយការឃុបឃិតលាក់កំបាំងពីរដ្ឋាភិបាល និងមន្ត្រីអាណ្ណាម ។ នៅទីបញ្ចប់សន្ធិសញ្ញាសន្តិភាព ត្រូវបានចុះជាមួយរដ្ឋាភិបាលចិននៅក្នុងខែមិថុនា ឆ្នាំ១៨៨៥ ប្រគល់ទឹកដីអាណ្ណាមចាប់ពីព្រំដែនចិន រហូតមកដល់ព្រែកដីកហាទៀង ឲ្យបារាំង ។ ចាប់ពីពេលនោះមក បារាំងអាចចាប់ផ្ដើមធ្វើឲ្យឥណ្ឌូចិនទាំងមូល ក្លាយទៅជាស្រុកមួយមានអារ្យធម៌ជឿនលឿន រួមមានទាំងកម្ពុជាផង ដែលបារាំងមិនបានច្បាំងជាមួយទេ ព្រោះបានយល់ព្រមដាក់ខ្លួនមកនៅក្នុងអាណាព្យាបាលបារាំងដោយខ្លួនឯងរួចទៅហើយ ។ ជាពិសេស គឺជួយប្រជាជនខ្មែរឲ្យក្រោកងើបឡើងចេញផុតពីរណ្ដៅដ៏សែនជ្រៅ ហើយធានាអនាគតល្អឲ្យស្រុកនេះ ។

## ២- ពួកថៃ ឬ សៀម

ការដែលសៀមដណ្ដើមយកឈៀងម៉ៃបានពីលាវនៅរវាងឆ្នាំ១៥៧៣ និងការវាយបែកបន្ទាយលង្វែកខ្ទាត់ខ្ទាយនៅក្នុងឆ្នាំ១៥៩៣ បានធ្វើឲ្យឈ្មោះស្ដេចសៀម ព្រះណារេត និងពួកសៀម មានកិត្តិនាមល្បីរន្ទឺ ។ កាលពីឆ្នាំ១៥៥៥ ពួកប៉េហ្គានបានវាយផ្ដួលរំលំរាជធានីអយុធ្យាខ្ទេចខ្ទី រួចនាំជ័យភណ្ឌមួយចំនួនធំយកទៅ ហើយថែមទាំងបាននាំយកអ្នកស្រុកជាឈ្លើយទៅជាង១០ម៉ឺននាក់ផង រហូតដល់ប៉េហ្គូ និងហង្សាវតី ។ ក៏ប៉ុន្តែការដុតបំផ្លាញឈៀងម៉ៃ និងមឿង (ដី) របស់លាវ ឬសៀមឯទៀតៗ នៅក្នុងអាងទន្លេមេណាមខាងលើ ជាពិសេស គឺការដណ្ដើមយកបានរាជធានីលង្វែកនៅក្នុងឆ្នាំ១៥៨៣ បានធ្វើឲ្យកេរ្ដិ៍ឈ្មោះរបស់ពួកសៀម និងស្ដេចរបស់គេឡើងខ្ពស់ត្រដែតនៅក្នុងដួងចិត្តសាធារណជន ។

គេបាននិទានថា ដើម្បីបំពេញបំណងសងសឹកជាមួយនឹងស្ដេចខ្មែរដែលទ្រង់បានចោទថាក្បត់សៀម ព្រះណារេត បានលាងព្រះបាទានឹងឈាមរបស់ព្រះរាជាកម្ពុជានៅថ្ងៃស្អែកឡើង បន្ទាប់ពីដណ្ដើមយកលង្វែករួច ។ រាជពង្សាវតារសៀមបានចាត់ទុកហេតុការណ៍ខាងលើថាជារឿងពិត ។ ក៏ប៉ុន្តែយើងបានឃើញពីខាងលើរួចមក ហើយថា ព្រះសត្ថាដែលបានដាក់រាជសម្បត្តិថ្វាយព្រះជ័យជេដ្ឋាជាព្រះរាជបុត្រា ព្រះរាជាទាំង២អង្គនេះ មិនដែលត្រូវសៀមចាប់បានទេ ពីព្រោះព្រះអង្គបានចាកចោលរាជធានីលង្វែកតាំងពីមុនពេលដែលសៀមចូលមកដល់ម៉្លេះ ហើយបានសុគតនៅក្នុងឆ្នាំបន្ទាប់នៅឯស្ទឹងត្រែង ឬក៏នៅឯសម្បូរ[១៧] ឯណោះ ដែលគេឃើញមានចេតិយរបស់ព្រះអង្គរហូតមកដល់សព្វថ្ងៃ ។ ម្យ៉ាងទៀត គេមិនដែលប្រទះឃើញមានឯកសារណាមួយនៅកម្ពុជា

---

[១៧] តាមការនិទានតៗគ្នា គេជឿថា ស្ដេចទាំង២អង្គ សុគតនៅសម្បូរ ច្រើនជាងនៅស្ទឹងត្រែង ។

និយាយពីអំពើឃោរឃៅនេះទេ ហើយគេមិនងាយនឹងបំភ្លេចបានដែរ បើសិនជាមានកើតឡើងមែននោះ ។

នៅសម័យនោះ ពួកថៃនៅមិនទាន់ចេញផុតពីភាពអនារ្យធម៌នៅឡើយ ព្រោះមានអារ្យធម៌ទាបជាង ប្រជាជនកម្ពុជា ឬហោចណាស់ក៏ទាបជាងកម្ពុជាមុនពេលដែលចាកចោលឥន្ទបត្ថមហានគរ ឬមុនពេលដែលនាយត្រសក់ផ្អែមឡើងសោយរាជ្យដែរ គឺនៅសតវត្សរ៍ទី១២ ។ នៅសម័យក្រោយនោះ កម្ពុជាត្រូវធ្លាក់ចុះអាប់ឱន ឯសៀមបានរីកចម្រើនយឺតៗ គឺយឺតណាស់ព្រោះថារហូតមកដល់សតវត្សរ៍ទី១៧ទៅហើយ ទើបរាជធានីរបស់សៀម មានតែកំពែងធ្វើពីឥដ្ឋប៉ុណ្ណោះព័ទ្ធជុំវិញការពារ មិនមានកំពែងធ្វើពីថ្មដូចរាជធានីខ្មែរពីមុននោះទេ ប៉មនិងគូទឹក ព័ទ្ធជុំវិញដែលជារបាំងការពារពិតប្រាកដក៏គ្មានដែរ ។ គ្មានអ្វីដែលអាចប្រដូចបាន នឹងប្រាសាទបាយ័ន ឬភិមានអាកាស ឬរាជវាំងផ្សេងៗទៀត ដែលមានអាងទឹកមានទីលានដ៏គួរឲ្យស្ញើចសរសើរ ដូចនៅអង្គរធំទេ ។ បើពិចារណាបែបនេះ រាជធានីអយុធ្យាឬរាជធានីដទៃទៀតប្រហែលជាមិនល្អលើសពីរាជធានីលង្វែកប៉ុន្មានឡើយ បើល្អជាងគឺអាចល្អជាងឈៀងម៉ៃមួយប៉ុណ្ណោះ ។ ក៏ប៉ុន្តែព្រះរាជាដូចជាមានតេជានុភាពខ្លាំងណាស់ ហើយមានទម្លាប់ពិធីការច្រើន ដោយចម្លងតាមព្រះរាជាណាចក្រខ្មែរពីមុន ។ វាហាក់ដូចជាថា តេជានុភាពនេះ បានត្រូវគេភ្លេចបាត់បង់អស់ទៅហើយនៅឯកម្ពុជាឯណោះ ហើយបែរជាមកសណ្ឋិតនៅឯស្រុកសៀមនេះវិញម្តង ។ ប្រជារាស្ត្រសៀមបានចាត់ទុកព្រះណារេតនេះ ដែលបានច្បាំងឈ្នះលាវ និងខ្មែរ ហើយដណ្តើមយកឈៀងម៉ៃនិងលង្វែកបាន ថាជាព្រះរាជាដ៏អស្ចារ្យមួយអង្គរបស់គេ ណាមួយព្រះអង្គក៏ជាអ្នកដែលបានកសាងចេតិយនៅក្នុងរាជធានី ហើយម្យ៉ាងទៀត ទ្រង់បានរៀបចំបទបញ្ញាសម្រាប់នាម៉ឺនសព្វមុខមន្ត្រី កំណត់សក្តិយស និងគ្រឿងឥស្សរិយយសឲ្យមន្ត្រីម្នាក់ៗ កែប្រែពិធីការសម្រាប់បណ្តារាជទូត ព្រមទាំងរបៀបរបបសវនាការផងដែរ ដែលព្រះរាជាគង់នៅលើទីដ៏ខ្ពស់ ទតមកក្រៅតែតាមបង្អួចតូចមួយ ក្នុងមួយរយៈពេលខ្លីប៉ុណ្ណោះ ។ ពិធីការ នេះ គឺជាពិធីការនៅស្រុកខ្មែរកាលពីសម័យចុះអាប់ឱន ដែលព្រះរាជា ទ្រង់ភ័យខ្លាចគេលួចធ្វើឃាត នៅពេលយាងចេញទៅណាម្តងៗទ្រង់ពាក់អាវក្រោះ មានកងរក្សាព្រះអង្គហែហមច្រើនកុះករ ធ្វើយ៉ាងណាកុំឲ្យគេបាញ់ធ្នូស្នាដល់ ។ នេះមិនមែនជាពិធីការរបស់ព្រះរាជាវរ្ម័នទេ ដូចដែលយើងអាចពិនិត្យមើលឃើញក្នុងចម្លាក់នៅប្រាសាទបាយ័ន ឬអង្គរវត្តស្រាប់ ដែលកាលនោះព្រះអង្គគ្មានខ្លាចរអាទាល់តែសោះ ក្នុងការបង្ហាញព្រះភ័ក្ត្រចំពោះប្រជានុរាស្ត្រ ប្រកបទៅដោយព្រះតេជានុភាព និងប្រជាប្រិយភាព ។

ពិតប្រាកដណាស់ថាពួកសៀមទទួលបានជោគជ័យធំធេងនៅសតវត្សរ៍ទី១៧ ដែលជាហេតុធ្វើឲ្យអំណាចរបស់គេត្រូវបានពង្រឹង ពង្រីក និងវាតទៅឆ្ងាយ ។ ក៏ប៉ុន្តែនៅពេលដែលព្រះណារេតឡើងសោយរាជ្យ នៅក្នុងឆ្នាំ ១៥៥៨ សៀមនៅជានគរសាមន្តរាជមួយរបស់ប៉េហ្គូនៅឡើយទេ តាំងតែពីពេលដែលស្តេចប៉េហ្គូមួយអង្គ បានវាយយកអយុធ្យាដាក់ជាចំណុះមក ។ ក្រោយពីទទួលបានជ័យជម្នះលើពួកលាវ និងខ្មែរ ជាសត្រូវនៅពីខាងជើង និងខាងត្បូងរួចមក ព្រះណារេត បានមានបំណងចង់វាយពួកប៉េហ្កាន ឲ្យបរាជ័យវិញម្តង ។ តាមពិត សៀម

ធ្លាប់បានវាយឈ្នះពួកនេះជាច្រើនលើករួចមកហើយ ក៏ប៉ុន្តែពួកនេះនៅតែប្រកាន់ថាខ្លួនមានសិទ្ធិអធិរាជភាពលើស្រុកសៀមដដែល ។ ព្រះណារេតបានចាប់ផ្ដើមវាយយក ម៉ាតាបាន នៅលើផ្លូវតាមមាត់សមុទ្រ រួចវាយយកអតីតរាជធានីហង្សាវតីដែលមានរបងការពាររឹងមាំ រួចបានបន្តដំណើរទៅកាន់អវៈ ដែលជាទីតាំងព្រះរាជវាំងស្ដេចប៉េហ្គូ ។ ក៏ប៉ុន្តែព្រះណារេតបានសុគតទៅនៅពាក់កណ្ដាលផ្លូវ ព្រះឯកទស្សរថ ជាព្រះរាជបុត្រា ក៏កោះហៅទ័ពឲ្យវិលត្រលប់ចូលក្នុងប្រទេសវិញ សោយរាជ្យបាន៦ឆ្នាំ ក៏ត្រូវព្រះបិតុលាដែលជាអនុជរបស់ព្រះណារេតក្បត់ ហើយធ្វើឃាដដណ្ដើមយករាជសម្បត្តិទៅ ។ ព្រះបិតុលានោះ ក្រោយមកក៏ត្រូវមន្ត្រីម្នាក់ធ្វើឃាដដែរ មន្ត្រីនោះ បានឡើងសោយរាជ្យលើរាជបល្ល័ង្កក្រោមព្រះនាមថា ចៅប្រាសាទថោង ។

ដូច្នេះយើងឃើញថា សៀមមិនមានទំនៀមទម្លាប់ផ្នែកនយោបាយល្អប្រសើរជាងកម្ពុជាប៉ុន្មានទេនៅសម័យនោះ ជាក់ស្ដែងដូចជាការលួចធ្វើឃាតឬការលបវាយឆ្នក់គ្នាបានត្រូវគេចាត់ទុកដូចជាការប្រយុទ្ធធម្មតា មិនមានធ្វើឲ្យពួកអ្នកអគ្គម្ចាស់ឬមន្ត្រីធំអាប់ឱនកេរ្តិ៍ឈ្មោះអ្វីឡើយ ។ វាហាក់ដូចជាថាប្រជាជន និងមន្ត្រីតូចតាចនៅស្រុកសៀម និងស្រុកខ្មែរពេលនោះមិនបានយកចិត្តទុកដាក់នឹងសង្គ្រាមរវាងគូប្រជែងដណ្ដើមអំណាចគ្នានោះទេ ហើយបានចាត់ទុកថានោះជារឿងរបស់ពួកស្ដេច គេមានភារកិច្ចត្រឹមតែចាំទះដៃអបអរទទួលយកអ្នកណាដែលឈ្នះលើគូបដិបក្ខប៉ុណ្ណោះ ហើយមិនបានគិតថាតើឈ្នះដោយប្រើមធ្យោបាយអ្វី មានសុជីវធម៌ ឬអត់នោះទេ ។ មានការប្លែកបន្តិចនៅកម្ពុជា ដែលជាប្រទេសមួយមានប្រពៃណីទំនៀមទម្លាប់ល្អយូរមកហើយ គឺប្រ-ជាជនមានចិត្តជំពាក់នឹងស្ដេចច្រើនជាងពួកសៀម និងអាណ្ណាម ដោយទទួលស្គាល់ការឈ្លោះប្រកែកដណ្ដើមយករាជបល្ល័ង្កបានតែអ្នកណាដែលជាអ្នកអគ្គម្ចាស់ ដែលជាប់សាច់សារលោហិតរាជវង្សានុវង្សប៉ុណ្ណោះ ។ ដោយហេតុនោះហើយ បានជាយើងពិនិត្យឃើញថា បើទោះជាមានភាពច្របូកច្របល់ មានសង្គ្រាមស៊ីវិលដែលធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាត្រូវបំផ្លិចបំផ្លាញខ្ទេចខ្ទាំយ៉ាងណាក្ដី ក៏មានតែរាជវង្សានុវង្សមួយប៉ុណ្ណោះដែលគង់នៅលើរាជបល្ល័ង្ក ដឹកនាំប្រជារាស្ត្រកម្ពុជា ខុសពីនៅស្រុកសៀម និងអាណ្ណាម ដែលបានផ្លាស់ប្ដូរសន្តតិវង្សជាច្រើនលើកច្រើនសា ។ តើគេអាចសន្និដ្ឋានបានទេ នៅពេលដែលបារាំងបានមកដល់ឥណ្ឌូចិនថានោះហើយគឺជាកត្តាដែលធ្វើឲ្យពួកអាណ្ណាម និងពួកសៀមចេះតែពង្រីកទឹកដីរបស់គេធំទៅៗ ព្រោះគេមានចិត្តស្រលាញ់ទឹកដីជាង ឯចំណែកពួកខ្មែរដែលស្រលាញ់រាជវង្សានុវង្ស គិតតែការពាររាជវង្សានុវង្សប៉ុណ្ណោះមិនបានគិតដល់ការការពារទឹកដីទេ ឬយ៉ាងណា?

បើទោះជាយ៉ាងណាក្ដី ការផ្លាស់ប្ដូរសន្តតិវង្សសៀម នៅពេលនោះ គឺជាលើកទីមួយហើយនៅក្នុងប្រវត្តិសាស្ត្រ ហើយនឹងមានការផ្លាស់ប្ដូរតទៅទៀត ។

អស់ពីចៅប្រាសាទថោងទៅ បុត្រាច្បងព្រះនាមថា ចៅហ៊្វាសាយ បានឡើងសោយរាជ្យបន្តពីបិតា តែបានត្រូវ ព្រះនរាយណ៍ ជាព្រះអនុជ និងព្រះបិតុលាមួយអង្គ ឃុបឃិតគ្នាធ្វើគុតចោលទៅ ។ ព្រះបិតុលានោះ

បានឡើងសោយរាជ្យបន្ត មានព្រះនាមថាសុទ្ធម្មរាជា រួចត្រូវបានព្រះនារាយណ៍ ធ្វើគុតយករាជសម្បត្តិ នៅក្នុងឆ្នាំ ១៦៥៥ ។ ព្រះនារាយណ៍បានឲ្យគេសម្លាប់អនុជ២អង្គទៀត ដែលប៉ុនប៉ងក្បត់ព្រះអង្គ ។

ព្រះនារាយណ៍បានចាប់បន្តគម្រោងការរបស់ព្រះណារេត ដោយបានលើកទ័ពទៅបោះទីតាំងនៅពីមុខរាជធានីអវៈ ។ ដល់មិនអាចធ្វើអ្វីបាន ព្រះអង្គក៏បែរមកវាយយកឈៀងម៉ៃ ដែលស្តេចអវៈ បានដណ្តើមយកទៅ ហើយបានដាក់បញ្ចូលជាដីរបស់សៀមជារៀងរហូតមក ។

ស្តេចសៀម ព្រះនារាយណ៍នេះ មានព្រះទ័យទូលាយ មិនដែលមានបុរេនិច្ឆ័យខាងសាសនាទេ ។ ទ្រង់បានទទួលស្វាគមន៍រាក់ទាក់ពួកអឺរ៉ុបដែលបានធ្វើដំណើរមកដល់ស្រុកសៀម ។ ទ្រង់សព្វព្រះទ័យនឹងអ្នកផ្សងព្រេងមានដើមកំណើតជាក្រិកម្នាក់ ដែលមានទំនាស់ជាមួយពួកអង់គ្លេស ដែលគេធ្លាប់បានបម្រើអស់ពេលជាយូរមកហើយ ។ ទ្រង់បានបង្ហាញឲ្យឃើញនូវព្រះទ័យមានអធ្យាស្រ័យល្អចំពោះពួកសាសនទូតកាតូលិក បើកទូលាយសេរីភាពខាងជំនឿដែលគេបានជួបប្រទះនៅឯស្រុកបារាំង ដោយឲ្យគេសង់វិហារឲ្យ ហើយទ្រង់បានស្នើសុំចងមេត្រីភាពជាមួយបារាំង ។ ដោយត្រូវពួកសាសនទូតបារាំងបោកប្រាស ជាពិសេស គឺអេវ៉ែក នៅសៀម ស្តេចល្វីទី១៤ ទ្រង់បានបញ្ជូនអគ្គរាជទូតម្នាក់មកកាន់អយុធ្យាជាមួយនឹងលោកឪពុក សេស៊ុីត ៦នាក់ ដោយបានជំនឿថា នៅពេលដែលពួកសេស៊ុីតនេះមកដល់ ព្រះនារាយណ៍នឹងបោះបង់ព្រះពុទ្ធសាសនាចោល ប្តូរកាន់សាសនាកាតូលិកវិញ ។ ព្រះនារាយណ៍ បានសំដែងឲ្យឃើញថា ព្រះអង្គសព្វព្រះទ័យខ្លាំងណាស់ ហើយមានមោទនភាពបំផុតនឹងបានចងស្ពានមានមេត្រីជាមួយស្តេចល្វីទី១៤ ដែលពួករាជទូត អេវ៉ែកកុងស្តង់តាំងហ្វូលកុង និងពួកសេស៊ុីតបានដាក់រហស្សនាមថ្វាយថា “ព្រះមហារាជសុរិយា” ។ ទ្រង់បានប្រគល់ដីបាងកកឲ្យទៅបារាំងយល់ព្រមទទួលទាហានបារាំងជាច្រើនរយនាក់ ជាមួយនឹងឧត្តមសេនីយ៍ម្នាក់ ក៏ប៉ុន្តែ ទ្រង់នៅតែកាន់ព្រះពុទ្ធ សាសនាដដែលរក្សាទំនៀមទម្លាប់ មានរាជបរិពារ និងស្រីស្នំក្រមការជាច្រើន ។ ទ្រង់បានអនុញ្ញាតឲ្យអភិវឌ្ឍន៍ពាណិជ្ជកម្មជាមួយបរទេសឡើង ដើម្បីឲ្យប្រជារាស្ត្រទទួលបាននូវអារ្យធម៌ថ្មី ខិតខំបង្កបង្កើនផលធ្វើការងារ និងសិក្សារៀនសូត្រ ក៏ប៉ុន្តែមិនដែលបង្ហាញឲ្យឃើញថា ទ្រង់មានព្រះទ័យចង់ប្តូរសាសនាម្តងណាទេ ។

ការខិតខំប្រឹងប្រែងរបស់ព្រះនារាយណ៍នេះ មិនត្រូវបានប្រជារាស្ត្រសៀម យល់ច្បាស់លាស់ទេ ជាពិសេស គឺពួកមន្ត្រីដែលប្រណែននឹងអំណាចដែលកុងស្តង់តាំងហ្វូលកុងទទួលបាន មិនពេញចិត្តនឹងឥទ្ធិពលដែលពួកបរទេសមានមកលើព្រះរាជា ហើយភ័យព្រួយខ្លាចមានការប្រែប្រួលខ្លាំង ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគេ ។ ពួកមន្ត្រីនោះក៏នាំគ្នាឃុបឃិតប្រឆាំងនឹងកុងស្តង់តាំងហ្វូលកុង ហើយសម្លាប់គាត់ចោលទៅតែប៉ុន្មានថ្ងៃប៉ុណ្ណោះមុនពេលដែលព្រះរាជាសុគត ព្រោះភ័យខ្លាចហើយធ្លាក់ព្រះអង្គប្រឈួន ។

ពេលនោះ មានសន្តតិវង្សថ្មីមួយទៀតឡើងសោយរាជ្យ គឺឃាតកម្នាក់ក្នុងបណ្តាឃាតកដែលបានសម្លាប់កុងស្តង់តាំងហ្វូលកុង បានឡើងគ្រងរាជបល្ល័ង្កនៅក្នុងឆ្នាំ១៦៨៨ មានព្រះនាមថាព្រះភេទរាជា ។ ព្រះរាជាថ្មីនេះ

ចាប់អារម្មណ៍នឹងការបំផ្លិចបំផ្លាញឲ្យអស់ នូវស្នាដៃអារ្យធម៌ទាំងឡាយ ដែលព្រះរាជាមុនបានខិតខំកសាងឡើង ។ អស់ពីព្រះភេទរាជាទៅ ដៃគូម្នាក់របស់ព្រះអង្គគឺចៅខ្លួ បានឡើងសោយរាជ្យបន្តនៅក្នុងឆ្នាំ១៦៩៧ បន្ទាប់មកគឺបុត្រារបស់ចៅខ្លួដែលឡើងសោយរាជ្យនៅក្នុងឆ្នាំ១៧០៦ ។ យើងបានឃើញពីខាងលើរួចមកហើយថា នៅសម័យនោះហើយដែលពួកសៀមបានលូកដៃចូលមកក្នុងរឿងកម្ពុជា ហើយបានជួយធ្វើសង្គ្រាមដេញកម្ចាត់ពួកអាណ្ណាមចេញពីកម្ពុជា ។

នៅពេលដែលអស់ពីស្តេចជ្រែករាជ្យនេះទៅ ចលាចលបានកើតមានឡើងទៀតនៅក្នុងស្រុកសៀម ហើយបានបន្ទាយរយៈពេលអស់ប្រហែល២០ឆ្នាំ ។ រាជវង្សស្តេចសោយរាជ្យបានត្រូវប្តូរម្តងទៀត ហើយសៀម ក៏ត្រូវធ្លាក់ទៅជាចំណីមួយរបស់ភូមា នៅពេលដែលស្តេចអាឡោងផ្រា[១៣] បានមកឡោមព័ទ្ធរាជធានីអយុធ្យាក្រោយពីបានផ្តួលរំលំអំណាចរបស់ពួកប៉េហ្គាន រួចបានបង្រួបបង្រួមស្រុកដាក់មកក្រោមអំណាចរបស់ព្រះអង្គតែមួយអង្គឯង ។ ពេលនោះភូមាដណ្តើមយកអយុធ្យាមិនបានទេ ដោយស្តេចអាឡោងផ្រា ធ្លាក់ខ្លួនប្រឈួនជាខ្លាំង ហើយត្រូវបង្ខំព្រះទ័យដកទ័ពចេញទៅវិញ ។ ក៏ប៉ុន្តែប៉ុន្មានឆ្នាំក្រោយមក ស្តេចអវៈមួយអង្គ ដណ្តើមយករាជធានីនេះបានក្រោយពីឡោមព័ទ្ធអស់ពេល២ឆ្នាំ រួចបានដុតបំផ្លាញខ្ទេចខ្ទីទៅជាផេះ ។ នេះគឺជាលើកទី២ហើយដែលអយុធ្យាត្រូវសត្រូវវាយដណ្តើមយកបាន ។ ពួកប៉េហ្គានបានវាយយកបានម្តង នៅក្នុងឆ្នាំ១៥៥៥ ក្រៅពីនោះ មិនដែលមានសត្រូវណាដណ្តើមយកបានទេ បានត្រឹមតែឡោមព័ទ្ធប៉ុណ្ណោះ ពួកខ្មែរក៏ធ្លាប់បានឡោមព័ទ្ធម្តងឬ២ដងដែរ នៅក្នុងឆ្នាំ១៥៥៧ និងឆ្នាំ១៥៦០ ។

រាជធានីអយុធ្យានេះស្ថិតនៅជិតពួកភូមាខ្លាំងណាស់ ដែលជាសត្រូវគួរឲ្យខ្លាចរអាមួយរបស់សៀម តាំងតែពីសម័យព្រះខុថងនៅក្នុងឆ្នាំ១៣៥០មក ជាហេតុធ្វើឲ្យសៀមសម្រេចចិត្តលើករាជធានីចេញពីសុខោទ័យចុះមកតាំងនៅអយុធ្យានេះ បើទោះជាថាត្រូវនៅឆ្ងាយពីសមុទ្របន្តិច មានការលំបាកនឹងធ្វើពាណិជ្ជកម្មក៏ដោយ ។ ឥឡូវនេះ ក្រោយពីបានប្រគល់ឲ្យបារាំងចាប់ពីឆ្នាំ១៦៨៥មក បាងកកបានត្រូវគេចាក់ដីលុបកន្លែងជង្ហុក ហើយបានក្លាយទៅជាទីដែលអាចរស់នៅបាន គ្មានជំងឺគ្រុនដែលធ្វើឲ្យគេខ្លាចដូចពីមុនទៀតទេ ។ ទីនេះអាចនឹងត្រូវយកធ្វើជាទីតាំងរាជធានីបានទៅអនាគត ។

នៅពេលដែលកូនកាត់សៀម និងចិនកង់តុងម្នាក់គឺភ្យាតាក បានប្រមែប្រមូលកម្ទេចកម្ទីដែលសេសសល់ពីការដុតបំផ្លាញរបស់ភូមា ហើយឡើងសោយរាជ្យលើរាជបល្ល័ង្កសៀម ស្តេចជ្រែករាជ្យនេះបានសម្រេចតាំងរាជធានីនៅនឹងបាងកកនេះឯង ស្របទៅតាមគំនិតពូកែរកស៊ីរបស់អ្នកមានសន្តានជាចិន ក្រោយពីវាយ

---

[១៣] ពួកអឺរ៉ុបហៅថាអាឡុំផ្រា Alomphra ។ គឺជាស្តេចជ្រែករាជ្យមួយអង្គដែលបានបង្កើតសន្តតិវង្សស្តេចភូមាតៗមក ។ ព្រះអង្គមានដើមកំណើតចេញមកពីស្រុកម៉ូហ្សូបូ ស្ថិតនៅចម្ងាយប្រហែលជា ៨០គីឡូម៉ែត្រ ពីអវៈ ។

ដណ្ដើមយកបានពីដៃភូមាមកវិញ បណ្ដេញទ័ពសត្រូវឲ្យដកថយចេញទៅ និងបានបោសសម្អាតពួកចោរព្រៃក្នុងស្រុករួចអស់ ។ ពេលនោះ មែរគុយ និងគេណាស់សេរីមនៅជារបស់ភូមានៅឡើយ[១៤] ហើយសៀមត្រូវបាត់បង់អស់ កំពង់ផែសំខាន់ៗពីរជាមួយនឹងការបាត់បង់ទីក្រុងពីរនេះ ដែលស្ថិតនៅមាត់ឆ្នេរសមុទ្របឹងហ្កាល់ ហើយតភ្ជាប់ស្រុកសៀមទៅនឹងប្រទេសឥណ្ឌា និងលោកខាងក្រៅ ។ ម៉្លោះហើយគេត្រូវតែស្វះស្វែងរកទីតាំងរាជធានីយ៉ាងណាដើម្បីឲ្យគេអាចមានច្រកចេញទៅក្រៅបាន បើហោចណាស់ក៏តាមឈូងសមុទ្រសៀមដែរ ។ ក្នុងន័យនេះ បាងកកគឺជាចម្លើយល្អ ព្រោះថាស្ថិតមិនឆ្ងាយប៉ុន្មានពីសមុទ្រ ហើយគឺបាងកកនេះឯងដែលបានធ្វើឲ្យស្រុកសៀមមានការអភិវឌ្ឍន៍ទាំងខាងសម្ភារ និងស្មារតី សមស្របទៅតាមគំនិតរបស់ព្រះរាជាពីរអង្គចុងក្រោយដែលចង់បើកទូលាយឲ្យទទួលអារ្យធម៌ពីខាងក្រៅ និងធ្វើឲ្យសង្គមមានការប្រែប្រួលឡើង ។

យើងបានឃើញពីខាងលើរួចមកហើយថាព្រះរាជាកម្ពុជា ព្រះនរាយណ៍រាជា (ព្រះឧទ័យ) បានមើលទាបមើលថោក មិនព្រមទទួលស្គាល់ភ្យាតាក ដែលកើតចេញពីចិនម្នាក់ជានឹងមួយទាសីសៀមម្នាក់ ថាជាស្ដេចទេ ហើយហេតុការណ៍នេះបានធ្វើឲ្យកើតមានសង្គ្រាមមួយរវាងសៀម និងខ្មែរឡើង ។ សង្គ្រាមនេះ ប្រហែលជាមិនទាន់ចប់ទេបើសិនជាភ្យាតាកមិនទាន់សុគត ។ ព្រះអង្គត្រូវគេសម្លាប់ទាំងពូជ ដោយមកពីទ្រង់ហាក់ដូចជាស្រវឹងនឹងបានឡើងសោយរាជ្យ ធ្វើអ្វីៗជួយតែពួកអ្នកក្រីក្រដូចជាដាក់ទានឲ្យ ដើម្បីជួយសម្រាលការលំបាកជាដើម ហើយតឹងរ៉ឹងចំពោះពួកអ្នកមាន និងមន្ត្រីរហូតទាល់តែពួកនេះបះបោរឡើង ទម្លាក់ព្រះអង្គពីលើរាជបល្ល័ង្កហើយធ្វើគុតចោលទៅ ។ គឺមន្ត្រីរបស់ព្រះអង្គម្នាក់ដែលបានឡើងសោយរាជ្យបន្តពីព្រះអង្គ[១៥] ។

មន្ត្រីដែលដណ្ដើមរាជសម្បត្តិពី ភ្យាតាក នោះគឺព្រះភូទី ទ្រង់ជាអ្នកបង្កើតសន្តតិវង្ស ដែលសោយរាជ្យនៅស្រុកសៀមរហូតមកដល់សព្វថ្ងៃនេះ ។ គឺនៅក្នុងរជ្ជកាលរបស់ព្រះភូទីនេះ និងក្នុងរជ្ជកាលព្រះភេនឱនក្លាង ជាបុត្រាព្រះអង្គ និងក្នុងរជ្ជកាលរបស់ព្រះប្រាសាទថោងជាព្រះនត្តា (ព្រះអង្គគឺជាស្ដេចជ្រែករាជ្យមួយអង្គទៀត) នេះហើយដែលសៀមបានលូកដៃខ្លាំងចូលមកក្នុងរឿងរ៉ាវកម្ពុជា បង្កសង្គ្រាមជាមួយអាណ្ណាម ។ ពេលនោះ ថ្វីបើកម្ពុជា ត្រូវអាណ្ណាមត្រួតត្រា អាណ្ណាមបានលើកក្សត្រមួយអង្គឲ្យឡើងសោយរាជ្យ ហើយបានបង្ខំឲ្យព្រះរាជា

---

[១៤] ភ្យាតាក មានបំណងចង់ដណ្ដើមយកស្រុកទាំង២មកវិញដែរ ក៏ប៉ុន្តែពេលនោះសៀមជាប់រវល់ធ្វើសង្គ្រាមជាមួយខ្មែរ ។ ក៏ប៉ុន្តែទ្រង់បានដណ្ដើមយកភិស្ណុលោក ឈៀងម៉ៃ និងលីហ្គ័រ ពីភូមាមកវិញបាន ។

[១៥] ដំណើររឿងបែបនេះ ជាដំណើររឿងដែលគេបានទទួលស្គាល់ជាផ្លូវការ ។ ក៏ប៉ុន្តែនៅស្រុកសៀម មានការបកស្រាយមួយផ្សេងដោយឡែក ដែលលើកឡើងថាភ្យាតាក មិនដែលប្រើហិង្សាទេ ហើយក៏មិនបានឆ្កួតដែរ ។ ពួកមន្ត្រី និងពួកអ្នកមានភ័យខ្លាចចំពោះភាពមានយុត្តិធម៌របស់ព្រះអង្គ និងព្រះទ័យស្រលាញ់សន្ដោស ចំពោះរាស្ត្រតូចតាច ។ ព្រះអង្គបានត្រូវពួកនេះ ទម្លាក់ពីរាជបល្ល័ង្កដោយពួកគេខ្លាចព្រះអង្គធ្វើកំណែទម្រង់ ហើយរៀបចំរបបនយោបាយថ្មីមួយឡើង ដែលអាចធ្វើឲ្យពួកគេបាត់បង់បុព្វសិទ្ធិ និងផលប្រយោជន៍ផ្សេងៗ ។

និងនាម៉ឺនសព្វមុខមន្ត្រីស្មៀកពាក់ និងបួងសក់តាមរបៀបអាណ្ណាមក៏ដោយ ក៏ប៉ុន្តែនៅទីបញ្ចប់ គឺអ្នកអង្គម្ចាស់រដ្ឋទាយាទស្របច្បាប់មួយអង្គដែលធ្លាប់រស់នៅស្រុកសៀម បានឡើងសោយរាជ្យនៅក្នុងឆ្នាំ១៨៤៧ ។

ស្តេចសៀមទី១ គឺព្រះភូទី បានគាំទ្រព្រះអង្គអេង ហើយបានចាត់ឲ្យចៅហ៊្វាបែនជួយជ្រោមជ្រែងឲ្យព្រះអង្គ បានឡើងសោយរាជ្យ បានកាត់យកខេត្របាត់ដំបង អង្គរ ស៊ីសូផុន និងមង្គលបុរីដាក់បញ្ចូលជាទឹកដីសៀម ។

ស្តេចសៀមចុងក្រោយ គឺប្រាសាទថោង មានមេទ័ពម្នាក់មានថ្វីដៃពូកែល្បីល្បាញ ។ ទ្រង់បានចាត់ឲ្យមេទ័ពនោះ ទៅវាយដណ្តើមយករាជធានីវៀងច័ន្ទរបស់លាវ ដែលមិនព្រមទទួលស្គាល់អធិរាជភាពរបស់សៀម (១៨២៨) ។ ភ្យាតាកធ្លាប់បានវាយយករាជធានីនេះម្តងរួចមកហើយកាលពីឆ្នាំ១៧៧៧ ហើយបាននាំយកព្រះកែវមរកត មកស្រុកសៀម ប៉ុន្តែមិនបានដុតបំផ្លាញ ឬចាប់យកប្រជាជនទេ គឺគ្រាន់តែបានរុះរើកំពែងទីក្រុងប៉ុណ្ណោះ ។ ប្រាសាទថោងបានកាត់យកខេត្រទន្លេរពៅ និងម្លូព្រៃ ហើយមានបំណងចង់យកកំពង់ស្វាយ និងពោធិសាត់ ថែមទៀត ក៏ប៉ុន្តែ ទ្រង់បានសុគតបាត់ទៅ ។

គឺព្រះអនុជរួមព្រះបិតាមួយអង្គ ជាបុត្រាជាមួយព្រះមហាក្សត្រី ដែលព្រះប្រាសាទថោង បានដណ្តើមយករាជសម្បត្តិ ហើយចង់បំបែកចេញពីរាជសម្បត្តិទុកឲ្យបុត្រាព្រះអង្គវិញ ដែលបានសោយរាជ្យបន្តមកមានព្រះនាមថា ព្រះបរមមណ្ឌែមហាមង្គុត ។ ព្រះរាជាអង្គនេះធ្លាប់បានបួសជាសង្ឃអស់ពេល២៥ឆ្នាំ ។ ទ្រង់ជាបញ្ញវន្តម្នាក់ មានគតិយុត្តិធម៌ ត្រឹមត្រូវ ចង់ចេះចង់ដឹងពីអ្វីៗដែលមាននៅអឺរ៉ុប ហើយមានចេតនា ចង់កសាងប្រទេសជាតិ បើហោចណាស់ក៏ឲ្យមានរដ្ឋាភិបាលមួយ ដូចបណ្តាប្រទេសនៅបស្ចិមប្រទេសដែរ ។ ទ្រង់បានបើកស្រុកសៀមឲ្យបរទេសគ្រប់ជាតិសាសន៍ចេញចូលទូលាយ ហើយបានត្រៀមរៀបចំរជ្ជកាលដ៏ត្រចះត្រចង់មួយថ្វាយបុត្រាព្រះអង្គគឺព្រះរាជាចុល្លាឡុងកន ដែលឡើងសោយរាជ្យបន្តពីព្រះអង្គនៅក្នុងថ្ងៃទី១ ខែតុលា ឆ្នាំ១៨៦៨[១៦] ។

ព្រះរាជាអង្គនេះគឺពិតជាតួអង្គសៀមម្នាក់ ដែលវ័យឆ្លាតជាងគេទាំងអស់ ។ ដោយមានឈាមជ័រចេញពីក្រុមគ្រួសារសៀម ក្នុងនោះមានជាប់ខ្សែចិនមួយចំណែកធំផង ទ្រង់បាន និងកំពុងតែធ្វើអ្វីទាំងអស់ ដែលព្រះរាជាមួយអង្គអាចធ្វើបានដើម្បីប្រជារាស្ត្រមួយដែលមិនទាន់មានការរីកចម្រើននៅឡើយ ដោយធ្វើឲ្យពួកគេចេះស្រលាញ់ការងារ ចេះមានបំណងចង់បាននូវអ្វីដែលប្រសើរ និងបានស្ទួចិត្តពួកគេឲ្យមានឆន្ទៈ ចង់ប្រែក្លាយប្រទេសឲ្យថ្កុំថ្កើងឡើង ។ ព្រះអង្គប៉ិនប្រសប់ណាស់ក្នុងការដោះស្រាយបញ្ហារវាងបារាំង និងអង់គ្លេស ដែលនៅអមសងខាង ចេះប្រកែកនឹងសំណើរបស់ពួកនោះ ប៉ុន្តែទ្រង់ក៏ចេះប្រគល់អ្វីទៅឲ្យដែរ ក្នុងករណីដែលជៀសមិនរួច

[១៦] ព្រះរាជាអង្គនេះ សុគតនៅក្នុងថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩១០ ។ បុត្រារបស់ព្រះអង្គ ដែលប្រសូត្រនៅថ្ងៃទី១ ខែមករា ឆ្នាំ១៨៨១ បានឡើងសោយរាជ្យបន្ត មានព្រះនាមថា បរមិន្ទ្រមហាវជីរវុឌ្ឍ ។

ធ្វើយ៉ាងណាឲ្យតែអំណាចរបស់ព្រះអង្គនៅរឹងមាំ ។ ទ្រង់បានប្រមូលផ្តុំបណ្តាខែត្រទាំងអស់ ឲ្យរួបរួមមូលនៅជុំវិញរាជធានី ប្រមូលផ្តុំកម្លាំងប្រជាជាតិឲ្យប្រជារាស្ត្រ និងរាជវង្សគោរពព្រះអង្គ ហើយអ្វីដែលលំបាកនោះ គឺធ្វើឲ្យពួកបរទេសគោរពព្រះអង្គផងដែរ ។ សព្វថ្ងៃនេះ ព្រះចុល្លាឡុងកនគ្មាននរណានឹងខ្លាចរអាទៀតទេ ពីព្រោះព្រះអង្គពូកែក្នុងការដឹកនាំ ហើយសម្រេចបាននូវតួនាទីដ៏សំខាន់មួយនៅលើពិភពលោក ។ កម្លាំងរបស់ប្រទេសសៀមសព្វថ្ងៃស្ថិតនៅលើការប្រណាំងប្រជែងរវាងបារាំង និងអង់គ្លេស ។ គឺជារដ្ឋ "ទ្រនាប់" មួយ ស្ថិតនៅចន្លោះប្រជាជាតិបដិបក្ខទាំងពីរ ដែលមិនយល់ព្រមឲ្យភាគីម្ខាងទៀតលេបត្របាក់យកប្រទេសនេះទេ ពោលគឺ បារាំងក៏មិនយល់ព្រមឲ្យអង់គ្លេសលេបយកសៀម ឯអង់គ្លេសវិញក៏មិនសុខចិត្តឲ្យបារាំងលេបយកសៀមដែរ ។ ជួនកាលអ្នកទាំងពីរបានឯកភាពគ្នា សន្យាធានាអត្ថិភាពឲ្យសៀមថែមទៀតផង ។ សៀមស្ថិតនៅចន្លោះទឹកដី ដែលអង់គ្លេស និងបារាំងដណ្តើមយកបាន ដូចគ្នានឹងកម្ពុជាកាលពីសតវត្សរ៍ទី១៨ និង១៩ អ៊ីចឹងដែរ ដែលកាលណោះស្ថិតនៅចន្លោះកូសាំងស៊ីនភាគខាងត្បូងហើយនិងទឹកដីដែល សៀមដណ្តើមយកបាន តែខុសគ្នាត្រង់ថា បារាំង និងអង់គ្លេសមិនដែលមានគំនិតចង់យកទឹកដីសៀមដាក់ជារបស់ខ្លួន ឬក៏បែងទឹកដីសៀមចែកគ្នាទេ បើទោះជាថាពួកគេមានមហិច្ឆតាខ្លាំងក្លាយ៉ាងណាក៏ដោយ ហើយអ្នកទាំងពីរចង់ឃើញសៀមរស់រានមានជីវិតនៅចន្លោះគេទាំងពីរជារៀងរហូត ។

នៅក្នុងឆ្នាំ១៨៦៧ សៀមបានប្រកាសបោះបង់អាណាព្យាបាល និងអធិរាជភាពមកលើកម្ពុជា ។ នៅឆ្នាំ១៨៩៣ ក្រោយពីត្រូវបារាំងបណ្តេញចេញពីប៉ុស្តិ៍ទាំងឡាយ ដែលគេបានបង្កើតឡើងនៅស្រុកលាវ លើច្រាំងទន្លេមេគង្គខាងឆ្វេងរួចមក ហើយបានឃើញកប៉ាល់ចម្បាំងរបស់បារាំងបើកឡើងតាមទន្លេមេណាម កាត់របាំងគ្រាប់ដែលបាញ់ចេញពីបន្ទាយការពារ (ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៨៩៣) និងបានឃើញការគំរាមកំហែងរបស់កាំភ្លើងធំបារាំងមកលើរាជវាំងរបស់ខ្លួន សៀមបានចុះសន្ធិសញ្ញាមួយ យល់ព្រមប្រគល់ត្រើយខាងឆ្វេងទន្លេមេគង្គឲ្យបារាំង ហើយបានប្រគល់ខែត្រចន្ទបុរីមួយឲ្យជាកិច្ចធានា ។ នៅក្នុងឆ្នាំ១៩០៤ សៀមបានយល់ព្រមប្រគល់ខែត្រមូលព្រៃ និងទន្លេរពៅនៅត្រើយខាងស្តាំទន្លេមេគង្គ ភាគខាងជើងកម្ពុជា និងខែត្រកោះកុង និងត្រាតនៅលើឆ្នេរឈូងសមុទ្រសៀមដែលសៀមគ្មានសិទ្ធិគ្រប់គ្រងសោះ ទៅឲ្យបារាំងថែមទៀត ។ នៅក្នុងឆ្នាំ១៩០៧ សៀមបានយល់ព្រមប្រគល់ខែត្របាត់ដំបង ស៊ីសុផុន សៀមរាប មង្គលបុរី ព្រះរាជាណាចក្របាសាក់ ហើយទទួលស្គាល់ថា បារាំងមានព្រំដែនខាងពាយ័ព្យត្រឹមជួរភ្នំដងរែក ។ នៅភាគខាងលើទន្លេមេគង្គឯណោះវិញ សៀមបានយល់ព្រមប្រគល់ទឹកដីនៅលើត្រើយខាងស្តាំ ដែលស្តេចហ្លួងប្រាបាង បានទាមទារយកទៅវិញ ។ ដោយហេតុនេះ សៀមបានបញ្ចប់ការលំបាកផ្សេងៗដែលគេបានបង្កឥតឈប់ឈរកន្លងមក ហើយមិនដែលបានដោះស្រាយរួចម្តងណាទេ ។ ធ្វើបែបនេះ ព្រះរាជាសៀមបានសម្របសម្រួលទៅតាមការចាំបាច់មួយចំនួន ដែលព្រះអង្គមិនអាចជៀសវាងរួច ក៏ប៉ុន្តែសម្បទានដែលសៀមបានប្រគល់ឲ្យបារាំង គឺត្រូវបានធ្វើឡើងជាថ្នូរនឹងសិទ្ធិយុត្តា-

ធិការ ដែលបារាំងមានកន្លងមកទៅលើប្រជាជនបារាំង និងអាស៊ីមួយចំនួន ដែលរស់នៅក្នុងទឹកដីជាកម្មសិទ្ធិរបស់បារាំង ក្រោមការត្រួតត្រារបស់កុងស៊ុលបារាំងនៅសៀម ។ ក្រោយមក បារាំងបានប្រគល់ទៅឲ្យសៀមវិញ នូវខែត្រចន្ទបុរី ក្រោយពីគ្រប់គ្រងអស់ពេល ១១ឆ្នាំ ខែត្រត្រាត ដែលមានវ៉េស៊ីដង់បារាំងនៅតាំងពី៣ឆ្នាំមុន និងទឹកដីហ្លួងប្រាបាងមួយចំណែកដែលស្ដេចហ្លួងប្រាបាង បានកាន់កាប់ជាច្រើនឆ្នាំមកហើយ ។ ព្រះរាជាសៀមបានប្រកបអាជីពសមស្របជាប្រជាជាតិមួយមានអារ្យធម៌ជឿនលឿន ជាប្រជាជាតិដែលអាចដឹកនាំខ្លួនឯងបាន ធ្វើឲ្យប្រទេសជឿនលឿនទាំងឡាយទទួលស្គាល់យុត្តាធិការរបស់សៀម ហើយដែលអាជ្ញាធរនយោបាយនិងយុត្តិធម៌ត្រូវបានពង្រឹង និងពង្រីក ។ ដោយរួបរួមគ្នាបែបនេះ ពួកថៃបានទទួលបាននូវមធ្យោបាយគ្រប់គ្រាន់ដើម្បីកែប្រែទឹកដីដែលពួកគេកាន់កាប់ ហើយអំពើល្អរបស់រដ្ឋាភិបាល បានត្រូវផ្សព្វផ្សាយទៅសព្វទិសទីនៃព្រះរាជាណាចក្រ ។

នៅក្នុងពេលជាមួយគ្នានោះ ព្រះរាជាសៀមបានបោះបង់បណ្ដារដ្ឋសានទៅឲ្យអង់គ្លេស ពីព្រោះថា រដ្ឋទាំងអស់នោះមិនដែលបានទទួលស្គាល់អធិរាជភាពរបស់សៀមម្ដងណាទេ បើទោះបីជាសៀមធ្លាប់បានប្រយុទ្ធចាប់បង្ខំ និងលើកហេតុផលថាសាន និងសៀមជាជាតិសាសន៍តែមួយ និងថាពាក្យសានជាការអានពាក្យសៀមមិនច្បាស់ យ៉ាងណាក៏ដោយ ។ ម្យ៉ាងទៀត គឺដោយសារអង់គ្លេស បានដណ្ដើមយកប្រទេសភូមាភាគខាងក្រោមរួចហើយកាលពីឆ្នាំ១៨២៨ និងដណ្ដើមយកប្រទេសភូមាភាគខាងលើទៀតនៅក្នុងឆ្នាំ១៨៨៥ ហើយមានបំណងចង់បើកផ្លូវមួយទៅកាន់ស្រុកចិន ។ សៀមក៏បានបោះបង់ទៅឲ្យអង់គ្លេសផងដែរ នូវបណ្ដារដ្ឋភាគខាងត្បូងទាំងឡាយដែលស្ថិតនៅតាមឧបទ្វីបកោះម៉ាឡាកា ដែលសៀមធ្លាប់មានអធិរាជភាពទៅលើតាំងពីសតវត្សរ៍ទី១៤ រៀងរហូតមក ចាប់ពីពេលដែលកម្ពុជាអស់សិទ្ធិអំណាចទៅ ។ អង់គ្លេសបានចូលកាន់កាប់សិង្ហបុរី រួចបានកាត់យករដ្ឋម៉ាឡេមួយម្ដងៗ រួមមានត្រឹងហ្គានូ កេឡាន់តាន់ ប៉ាហ៊ាង កេដាក់ និងសាំសាំ ហើយរដ្ឋខ្លះ អង់គ្លេសដាក់រ៉េស៊ីដង់ឲ្យមើលខុសត្រូវ រដ្ឋខ្លះទៀតបញ្ចូលជាសហភាពរដ្ឋនៅក្រោមអាណាព្យាបាលរបស់អង់គ្លេស ។

បើពិនិត្យលើការរៀបរាប់ខាងលើរំលឹកហាក់ដូចជាថា សៀមបានយល់ព្រមបោះបង់ទឹកដីច្រើនហួសហេតុពេកហើយ ។ តាមពិតទៅ បណ្ដារដ្ឋទាំងអស់នោះមិនមែនចំណុះសៀមពិតប្រាកដប៉ុន្មានទេ រដ្ឋមួយចំនួន បានទទួលឯករាជ្យភាពរួចជាកពីអនុត្តរភាពរបស់សៀមជាយូរមកហើយ ហើយរដ្ឋភាគច្រើនបានឈប់ទទួលស្គាល់សៀមថាជាមជ្ឈមណ្ឌលសកម្មភាព ឬជាប្រភពពន្លឺដែលទាក់ទាញពួកគេទៀតហើយ ។ ជាក់ស្ដែងដូចជាសិង្ហបុរីនាពេលនោះគឺជាមណ្ឌលទាក់ទាញខ្លាំងជាងបាងកកទៅទៀត ហើយពួកអ្នកស្រុកនេះ ដែលឲ្យតម្លៃតែទៅលើអ្នកណាដែលមានកម្លាំង បានមើលឃើញពួកអង់គ្លេសថាខ្លាំងជាង មានអំណាចជាងសៀម ម្ល៉ោះហើយពួកគេត្រូវខ្វល់ខ្វាយ ហើយទទួលរាក់ទាក់ពួកនេះយ៉ាងល្អបំផុត ។

ចាប់ពីត្រឹមការរៀបរាប់ក្នុងសំណេរនេះមក ពួកអង់គ្លេសបានទទួលបាននូវទឹកដីមួយចំណែកយ៉ាងធំនៅ

ខាងលិច លាតសន្ធឹងពីត្បូងទៅជើងនៅតាមឆ្នេរសមុទ្របឹងហ្គាល់ ដែលអាចឲ្យពួកគេកសាងផ្លូវរទេះភ្លើងមួយបាន ចាប់ពីសិង្ហបុរីទៅដល់រ៉ង់ហ្គូន ។ នេះគឺជាសម្បទានចុងក្រោយរបស់សៀមទៅឲ្យអង់គ្លេស ដែលសៀមត្រូវតែយល់ព្រមតាម ពីព្រោះថាគេគ្មានកម្លាំងអ្វីនឹងប្រកែកប្រឆាំងបានទេ ណាមួយផ្លូវរទេះភ្លើងនោះក៏គួរឲ្យចាប់ចិត្ត ហើយបានបម្រើផលប្រយោជន៍របស់សៀម និងអង់គ្លេស ដូចគ្នា ។

## ៣- ស្រុកចិន

នៅក្នុងឆ្នាំ១៣៦៦ ពួកចិនបានផ្តួលរំលំសន្តតិវង្សម៉ុងហ្គោល-យ៉េន ដែលគូប៊ីឡៃខាន់ ចៅរបស់ហ្សង់ស៊ីសខាន់ បានបង្កើតឡើង កាលពីឆ្នាំ១២៦០ ។ សន្តតិវង្សថ្មី គឺសន្តតិវង្សមៀងប្ញមិញ ដែលអ្នកស្រុកទទួលស្គាល់ថាជាសន្តតិវង្សជាតិព្រោះមានកំណើតជាចិនបានឡើងសោយរាជ្យបន្ត ។ ប៉ុន្តែថ្វីបើពួកម៉ុងហ្គោលមិនបានគ្រប់គ្រងស្រុកចិនក៏ដោយ ក៏ប៉ុន្តែពួកនេះនៅកាន់កាប់ផ្លូវគមនាគមន៍នៅឡើយ ម្ល៉ោះហើយអាណាចក្រចិនពេលនោះបានត្រូវកាត់ផ្តាច់ពីពិភពលោកខាងក្រៅ ។ និគមកាន់សាសនាកាតូលិកត្រូវរលាយបាត់ទៅនៅក្នុងបណ្តាខេត្រភាគខាងកើត ហើយការរីកចម្រើននៃសាសនាមហាម៉ាត់ក៏បានបំផ្លិចបំផ្លាញសាសនាកាតូលិកឲ្យនៅឯភាគខាងលិចឲ្យរលត់រលាយទៅដែរ ។

រាជធានីចិនចាប់ពីឆ្នាំ១៣៦៨ដល់ឆ្នាំ១៤១១គឺណង់កាំង ដែលបន្ទាប់មកគេហៅថាប៉េកាំង ។ ក្នុងរយៈពេលជិត១សតវត្សរ៍ ចាប់ពីបានបណ្តេញពួកតាកតារ-ម៉ុងហ្គោលចេញទៅ រដ្ឋាភិបាលចិននៅប៉េកាំងនេះគ្មានលទ្ធភាពនឹងគ្រប់គ្រងអាណាចក្រមួយដ៏ធំបែបនេះបានទេ ។ ពួកតាកតារបានបុករុកពីខាងជើង ព្រោះចង់វិលត្រលប់មកវិញ ឯពួកអាណ្ណាមបានរំខានពីខាងត្បូងមក ក៏ប៉ុន្តែពួកអធិរាជចិនមិនដឹងថាត្រូវធ្វើយ៉ាងណាត្រូវរើសអ្នកណាឲ្យកាន់កិច្ចការទេ ទុកឲ្យអំណាចនោះស្ថិតនៅតែក្នុងដៃពួកមនុស្សកម្រៀវប៉ុណ្ណោះ ។

នៅក្នុងឆ្នាំ១៥៥០ ចិនបានវាយរុញច្រានពួកតាកតារដែលចង់ចូលមកលុកលុយអាណាចក្រ ឲ្យដកថយទៅវិញ ។ ក៏ប៉ុន្តែនៅពេលដែលពួកតាកតារបានរួបរួមគ្នានៅក្រោមបញ្ជាការរបស់មេតែម្នាក់ ពួកនេះបានវាយចិនឲ្យបរាជ័យវិញនៅក្នុងឆ្នាំ១៦១៨ ។ ដប់ឆ្នាំក្រោយមក ពួកម៉ាន់ជូបានវាយដណ្តើមយករាជធានីលាវទុងបាន ហើយបង្ខំឲ្យចិនកោរសក់ក្បាលពីខាងមុខតែទុកសក់ខាងក្រោយវែង ហើយក្រងផង ដែលជាម៉ូតរបស់ពួកតាកតារនាសម័យនោះ[១៧] ។ ចំពោះប្រទេសអាណ្ណាមវិញ ចិនមិនដែលបានផ្តល់ជំនួយឲ្យច្បាស់លាស់ដល់

---

[១៧] មុននោះពួកចិនទុកសក់វែងហើយបួងដូចពួកអាណ្ណាម ខ្មែរ សៀម និងពួកអ្នកស្រុកឥណ្ឌូចិនដែលមិនទាន់មានអារ្យធម៌ឯទៀតៗ កាលពីសតវត្សរ៍ទី១៧ ។

សន្តតិវង្សឡេប្តុក៏សន្តតិវង្សម៉ាក់ដែលបានស្រែករកជំនួយនោះទេ ហើយក៏មិនដែលបានធ្វើអន្តរាគមន៍ប្រឆាំងនឹងពួកជូវ ឬមន្ត្រីធំនៅតុងកឹងដែលកាន់កាប់កិច្ចការជំនួសព្រះរាជា ឬក៏ធ្វើអន្តរាគមន៍ប្រឆាំងនឹងពួកមន្ត្រីនៅកូសាំងស៊ីនដែលបានធ្វើខ្លួនឲ្យទៅជាឯករាជដាច់ចេញពីព្រះរាជាផងដែរ ។ តាមពិតទៅសន្តតិវង្សមិញ មានកិច្ចការជាច្រើនដែលត្រូវធ្វើនៅស្រុកចិន ដូចជាត្រូវប្រឈមមុខជាមួយក្រុមពួកអ្នកបះបោរប្រឆាំង ដែលកកើតឡើងឥតដាច់ ម្ល៉ោះហើយគ្មានពេលឯណា នឹងលូកដៃធ្វើអន្តរាគមន៍ចូលក្នុងរឿងរ៉ាវរបស់អ្នកក្រៅ ឬអ្នកដែលនៅឯចុងអាណាចក្រនោះទេ ។ មិនតែប៉ុណ្ណោះ ចិនគ្មានទាំងឱកាសនឹងប្រមូលផ្តុំកម្លាំងប្រឆាំងទប់ទល់ជាមួយពួកតាកតារ ដែលលើកគ្នាមកវាយមហាកំផែងដូចជាទឹកបាក់ទំនប់ថែមទៀតផង ។

នៅក្នុងឆ្នាំ១៦៤៣ នៅពេលដែលព្រះរាជាអង្គច័ន្ទសោយរាជ្យនៅកម្ពុជាប្រែព្រះទ័យទៅកាន់សាសនាមហាម៉ាត់របស់ពួកម៉ាឡេ និងចាម, ហើយនៅឯអាណ្ណាមប្រទេសបានត្រូវបែកបាក់គ្នា ចែកចេញជាតុងកឹងនិងកូសាំងស៊ីន នៅឯស្រុកចិនឯណោះ ជនកម្រៀវម្នាក់ ដែលជាមេក្រុមបះបោរបានដណ្តើមយកបានរាជធានីប៉េកាំងក្រោយពីការប្រយុទ្ធអស់ពេល៣ថ្ងៃ ធ្វើឲ្យព្រះចៅអធិរាជនៃសន្តតិវង្សមិញទី១៦ និងចុងក្រោយគេធ្វើអត្តឃាតទៅ ដោយទ្រង់អស់សង្ឃឹមខ្លាំងពេក ។

នៅពេលនោះមានមេទ័ពចិននៃរាជវង្សមិញម្នាក់ ដែលមិនព្រមចុះចូលជាមួយជនកម្រៀវ ថ្វីបើជាជាតិចិនដូចគ្នា បានស្រែកហៅរកជំនួយពីពួកតាកតារម៉ាន់ជូ (ពោលគឺពួកតាកតារនៅទិសខាងលិច) ហើយបានប្រគល់ស្រុកចិនឲ្យពួកនោះ ។ ពួកអ្នកគ្មានអារ្យធម៌ទាំងនោះបានលើកកូនរបស់មេទ័ពគេដែលទើបតែទទួលមរណភាពឲ្យឡើងសោយរាជ្យ មានព្រះនាមថា ជេនឈី (១៦៤៤) ។

ព្រះចៅអធិរាជថ្មីនេះ បានចាប់ផ្តើមធ្វើសង្គ្រាមជាមួយបណ្តាអាណាខេត្រភាគខាងត្បូង ដែលប្រកែកមិនព្រមទទួលស្គាល់ការគ្រប់គ្រងរបស់ព្រះអង្គហើយនៅស្មោះស្ម័គ្រជាមួយពួកមិញ ដោយវាយដណ្តើមយកបានខេត្រឈេកាង ហ៊ូគៀន បន្ទាប់មកគឺ កង់តុង ។ ពេលនោះមានបក្សពួករបស់ពួកមិញម្នាក់ឈ្មោះថា កុកស៊ីញហ្គាដែលក្លាយទៅជាមេចោរសមុទ្រ បានដណ្តើមយកកោះតៃវ៉ាន់ ដែលពេលនោះនៅជាទឹកដីរបស់ពួកហុល្លង់នៅឡើយ តាមសន្ធិសញ្ញាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៦៧១[១៨] ។ ព្រះចៅអធិរាជ កាងហ៊ី បានត្រៀមប្រុងតែនឹងធ្វើសង្គ្រាមជាមួយទៅហើយទទួល កុកស៊ីញហ្គា ធ្លាក់ខ្លួនឈ្លក់ ហើយស្លាប់បាត់ទៅនៅក្នុងថ្ងៃទី២ ខែកក្កដា ឆ្នាំ១៦៦២ ។ បុត្រារបស់ កាងហ៊ី ព្រះនាមថា ឈេងគីង ដែលឡើងសោយរាជ្យបន្តពីព្រះបិតា បានច្បាំងទប់ទល់នឹង

---

[១៨] ពួកហុល្លង់បានទទួលយកកោះតៃវ៉ាន់ ឬហ្វ័រម៉ូស នេះពីចិន ជាថ្នូរជាមួយនឹងកោះប៉ុងហ៊ូ ឬប៉េស្កាឌ័រ ដែលហុល្លង់កាន់កាប់ជាច្រើនឆ្នាំរួចមកហើយ ។

ពួកហុល្លង់ ដែលចង់មកទាមទារយកបន្ទាយហ្សេឡង់ឌីយ៉ា និងហ្វាយ៉ូវ៉ាន ដែលកាងហ៊ី មានបំណងដណ្តើមយកមកវិញ ។ ឈេងគីង បានបន្តធ្វើសង្គ្រាមជាមួយពួកតាកតាររហូតដល់ឆ្នាំ១៦៨១ ។ ពីរឆ្នាំក្រោយមក បុត្រារបស់ឈេងគីង ដែលឡើងសោយរាជ្យបន្ត បានចុះចូលជាមួយអធិរាជ តាកតារ ។

ក្នុងចន្លោះពេលនោះ មានចិនម្នាក់ក្នុងបណ្តាអ្នកដែលបានចុះចូលជាមួយពួកតាកតារមុនគេ ហើយជាស្តេចត្រាញ់គ្រប់គ្រងលើទឹកដីយុនណាន និងសេឈន់ មិនសប្បាយចិត្ត ក៏លើកទង់ប្រឆាំងឡើង ចំពេលដែលមានបច្ចាញាតិម្នាក់របស់ហ្សង់ស៊ីសខាន់បង្ហាញខ្លួនឡើងនៅឯទល់ដែន ហើយកុកស៊ិញហ្កាកំពុងតែវាតត្បាតឆ្នេរសមុទ្រភាគខាងត្បូងដែរ ។ មេបះបោរនោះត្រូវគេវាយឲ្យបរាជ័យ រួចបានស្លាប់បាត់ទៅដោយអស់សង្ឃឹម ។

នៅពេលនោះដែរ ពួកអេឡឺត ឬម៉ុងហ្គោលទិសខាងលិច កំពុងតែមានអំណាចនៅពីខាងជើងស្រុកចិន ដោយមានពួកកុលខានៅបាំងចំកណ្តាល ។ ដើម្បីអាចលូកដៃមកក្នុងស្រុកចិនបាន ពួកអេឡឺតក៏ចាប់វាយពួកកុលខា ។ ពេលនោះព្រះចៅអធិរាជកាងហ៊ី បានបញ្ជូនទ័ពទៅជួយពួកកុលខា ដែលហៀបតែនឹងបរាជ័យទៅហើយ ធ្វើឲ្យពួកម៉ាន់ជូ ដែលបរាជ័យម្តងរួចទៅហើយកាលពីឆ្នាំ១៦៩០ ត្រូវបរាជ័យម្តងទៀតនៅក្នុងឆ្នាំ១៦៩៦ ហើយស្រុកចិនក៏រួចផុតពីការលុកលុយរបស់ពួកអ្នកមិនទាន់ស៊ីវិល័យនេះម្តងទៀត ។

ជាច្រើនឆ្នាំក្រោយមក មិនដឹងជាដោយហេតុអ្វី ពួកចិនបានធ្វើសង្គ្រាមជាមួយនឹងភូមា ចំពេលដែលស្តេចអាឡោងផ្រា ទើបតែវាយដណ្តើមយកប៉េហ្គូបាន ហើយដឹកនាំប្រទេសប្រកបទៅដោយការប៉ិនប្រសប់ និងយុត្តិធម៌ ។ ចិនបានវាយលុកភូមា៤ដង ពីឆ្នាំ១៧៦៥ ដល់ឆ្នាំ១៧៦៩ ក៏ប៉ុន្តែត្រូវបរាជ័យរាល់លើក ។ នៅទីបញ្ចប់ចិនក៏បោះបង់ចោលគម្រោងការដណ្តើមយកភូមាដាក់ជាទឹកដីចិន ឬដាក់នៅក្រោមអធិរាជភាពរបស់ខ្លួន រួចបានចុះសន្ធិសញ្ញាសន្តិភាព និងពាណិជ្ជកម្មមួយនៅក្នុងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៧៦៩ ។ សន្ធិសញ្ញានោះបានកំណត់មហិច្ឆតារបស់ចិនទៅលើភូមាត្រឹមពេលនោះជារៀងរហូតមក ។ គេបាននិយាយថា មូលហេតុដែលធ្វើឲ្យពួកភូមាទទួលបានជ័យជម្នះទៅលើពួកប៉េហ្គាន ដែលតែងតែបង្កការលំបាកដល់ភូមា អស់កាលជាច្រើនឆ្នាំមកហើយនោះ គឺដោយសារនៅក្នុងជួរកងទ័ពភូមាមានពួកអ្នកកាន់កាំភ្លើងធំបារាំង ធ្វើដំណើរចេញពីឥណ្ឌាមក និងជាពិសេសគឺមានពួកអ្នកផ្សងព្រេង ឬពួកអ្នករត់ចោលជួរព័រទុយហ្កេ ដែលរត់គេចមកក្រោយពីអាណាចក្រព័រទុយហ្កេត្រូវដួលរលំទៅ បានមកស៊ីឈ្នួលធ្វើសង្គ្រាមបម្រើស្តេចស្រុកណាក៏ដោយ ដែលយល់ព្រមឲ្យលុយ ។

ដោយជាប់រវល់នឹងរឿងផ្ទៃក្នុងច្រើនយ៉ាងនេះ ទើបបានជាចិនគ្មានពេលទំនេរនឹងគិតគូរពីអាណ្ណាម ជាស្រុកជិតខាងទេ ណាមួយអាណ្ណាមនេះក៏មិនបានផ្តល់ឱកាសឲ្យចិនធ្វើអន្តរាគមន៍ផងដែរ ។ ម្យ៉ាងទៀតពួកអឺរ៉ុបបានធ្វើដំណើរចូលមកដល់សមុទ្របីងហ្កាល់ ម៉ាឡាកា ឈូងសមុទ្រសៀម សមុទ្រខាងត្បូង និងសមុទ្រជប៉ុន ហើយបានដណ្តើមកាន់កាប់ពាណិជ្ជកម្មតាមសមុទ្រ ស្ទើរតែទាំងអស់នៅចុងបូព៌ាប្រទេស ។ ពួកអឺរ៉ុបបានបើកអគារពាណិជ្ជកម្មគ្រប់ទីកន្លែង ហើយក៏មិនញញើតនឹងវាយប្រហារមកលើសំពៅរបស់ចិន ដែលមកប្រដែងរកស៊ី

ឬធ្វើការឆក់ប្លន់នៅតាមឆ្នេរសមុទ្រដែលគេចុះចតនោះដែរ ។ សរុបសេចក្តីមក ការធ្វើដំណើរមកដល់របស់ពួកអឺរ៉ុប និងការកើតមានពួកចោរសមុទ្រ ដោយអតីតបក្សពួករបស់សន្តតិវង្សមិញ បានធ្វើឲ្យពួកចិនបាត់បង់អស់នូវសេចក្តីក្លាហាន ។ ចំនួនសំពៅពាណិជ្ជកម្មចិនថយចុះ ហើយមិនសូវហ៊ានធ្វើដំណើរផ្សងព្រេងទៅឆ្ងាយដូចពីមុនកាលនៅក្រោមសន្តតិវង្សជាតិមិញ ឬនៅក្រោមសន្តតិវង្សម៉ុងហ្គោលនោះទេ ។ ព្រះចៅអធិរាជតាកតាវម៉ាន់ជូមិនអាចចេញបញ្ជាឲ្យស្តេចប្រទេសឯទៀតៗអនុវត្តតាមឡើយ ដូចជាឲ្យបញ្ឈប់សង្គ្រាម ឬឲ្យរក្សាសន្តិភាព ដូចដែលគូប៊ីឡៃខាន់បានចេញបញ្ជាមួយនៅក្នុងឆ្នាំ១២៨៨ ឲ្យស្តេចសៀមដាក់អាវុធចុះ រួចបន្ទាប់មកធ្វើអន្តរាគមន៍រវាងនគរចាម្ប៉ា និងតុងកឹង ថែមទៀត ។ ព្រះអង្គគ្មានអំណាចអ្វីនឹងធ្វើការសងសឹក ចំពោះការប្រមាថមកលើជនជាតិចិននៅម៉ាឡេស៊ី ដូចដែល គូប៊ីឡៃខាន់ បានធ្វើម្តងនៅកោះជ្វា កាលពីឆ្នាំ១២៩៣ឡើយ ។ ហើយព្រះអង្គក៏គ្មានអំណាចអ្វីនឹងបញ្ជូនរាជទូតមកកម្ពុជា ដើម្បីទាមទារឲ្យកម្ពុជាបញ្ជូនពួកអ្នកភៀសខ្លួន ឬពួកអ្នកដើរសំពៅចិនទៅឲ្យវិញ ដូចដែលចិនធ្លាប់បានធ្វើម្តងកាលពីឆ្នាំ១២៩៥ ផងដែរ ។ មិនតែប៉ុណ្ណោះ ចិនក៏មិនដែលបានបញ្ជូនមន្ត្រីជាន់ខ្ពស់ ឲ្យនាំយកត្រា អាយដាយ ឬសញ្ញាប័ត្របញ្ជាក់ថ្វាយដល់ព្រះរាជា ដែលទើបឡើងគ្រងរាជ្យ នៅតុងកឹង ឬកូសាំងស៊ីន សោះទេ ។

ការដែលសន្តតិវង្សម៉ុងហ្គោល ត្រូវធ្លាក់ចេញពីអំណាចនៅក្នុងឆ្នាំ១៣៦៨ គឺមិនបានបម្រើផលប្រយោជន៍ របស់ចិននៅខាងក្រៅប្រទេសទេ ។ ដោយឡែក ការមកដល់របស់ពួកអឺរ៉ុបបានធ្វើឲ្យឥទ្ធិពលខាងផ្នែកស្មារតីរបស់ចិនទៅលើបណ្តាប្រជាជាតិដែលមានអារ្យធម៌អន់ខ្សោយជាង បានថយចុះជាលំដាប់ ពីព្រោះនៅពេលដែលបានជួបជាមួយពួកអឺរ៉ុប ប្រជាជាតិទាំងនោះដែលធ្លាប់តែទទួលស្គាល់ថា ចិនល្អ ខ្ពង់ខ្ពស់ជាង បានបែរមកទទួលស្គាល់ថា មានពួកស្បែកសល្អប្រសើរជាងពួកស្បែកលឿងទៅទៀត ។ អនុត្តរភាពដែលចិនធ្លាប់តែមានមកលើប្រទេសទាំងឡាយណាដែលសំពៅចិនធ្វើដំណើរទៅដល់ បានត្រូវធ្លាក់ចុះយ៉ាងរហ័ស ជាហេតុធ្វើឲ្យចិនបិទកំពង់ផែរបស់គេមិនឲ្យនាវាបរទេស ជាពិសេសគឺនាវាពួកអឺរ៉ុបចូលចតទេ ដោយខ្លាចមិនអាចទប់ទល់បាន ។ មិនយូរប៉ុន្មាន កេរ្តិ៍ឈ្មោះចិនក៏ត្រូវសាបរលាបទៅ បណ្តាប្រទេសនៅចុងបូព៌ាប្រទេសបានស្គាល់ត្រឹមតែពួកចិនដែលរត់ចោលស្រុក ដែលភាគច្រើនៗតែបានក្លាយទៅជាចោរសមុទ្រ នៅចាំតែឆក់ប្លន់សំពៅពាណិជ្ជកម្មតាមឆ្នេរសមុទ្រ ហើយនៅទីបញ្ចប់បានទៅរស់នៅអាណ្ណាម កម្ពុជា សៀម ឬនៅប្រជុំកោះអាំងស៊ូឡាំង បង្កបានជានិគមចិនធំឡើងៗ រហូតដល់អាចដណ្តើមយកទីក្រុងបាតាវីយ៉ាបាន ។ ពួកចិនដែលមានដើមកំណើតនៅហៃណានច្រើនជាអ្នកពូកែរកស៊ី តែក៏ជាចោរសមុទ្រដ៏អង់អាចក្លាហានណាស់ដែរ ដែលតែងតែធ្វើឲ្យពួកអ្នកដើរសមុទ្រទាំងឡាយចងចាំឥតភ្លេចថា មានពួកចិន និងសំពៅចិនដែលមានកាំភ្លើងធំ និងកាំភ្លើងតូចជាច្រើន ។ រហូតមកដល់ឆ្នាំ១៨៦០ មុនពេលដែលកប៉ាល់ប្រើចំហាយរបស់ពួកអឺរ៉ុបមកដល់ គេនៅប្រទះឃើញមានសំពៅចោរសមុទ្រជាច្រើន សំពៅខ្លះបើកបរដោយបក្សពួកសន្តតិវង្សមិញដែលមិនចុះចូលជាមួយសន្តតិវង្សម៉ាន់ជូ សំពៅខ្លះទៀត

បើកបរដោយពួកហៃណាន បានធ្វើការឆក់ប្លន់នៅលើផ្លូវពីសិង្ហបុរីទៅស្រុកសៀម សាយហ្គន ម៉ាកាវ និងតុងកឹង ធ្វើឲ្យដំណើរត្រង់តំបន់នេះប្រកបទៅដោយគ្រោះថ្នាក់ និងការកាប់សម្លាប់រង្គាល ។ នៅលើផែនទីសម័យនោះ គេសង្កេតឃើញមានឈ្មោះ កោះចោរឆក់ កោះចោរសមុទ្រ កោះចោរលួចជាច្រើននៅតាមផ្លូវ ដែលជាជម្រករបស់ពួកចោរចិនទាំងអស់នោះ ។

ក្រៅពីពួកចោរសមុទ្រ និងចោរលួចប្លន់ទាំងអស់នោះ បណ្ដាប្រទេសខាងក្រៅនៅចុងបូព៌ាប្រទេស និងអឺរ៉ុប ដូចជាភ្លេចអំពីវត្តមានរបស់ចិនអស់ទៅហើយ នៅក្នុងសតវត្សរ៍ទី១៨ និងដើមសតវត្សរ៍ទី១៩ ។ នេះក៏ដោយសារចិនខ្លួនឯងមានឆន្ទៈចង់ផ្ដាច់ខ្លួនឲ្យឆ្ងាយពីលោកខាងក្រៅ ជាពិសេសគឺដោយសារគេបារម្ភខ្លាចពួកអឺរ៉ុប ដែលប្រកបទៅដោយល្បិចកល និងសេចក្ដីក្លាហានហួសហេតុ ។ នៅក្នុងឆ្នាំ១៥៥៣ ចិនបានធ្វើសម្បទានប្រគល់កោះម៉ាកាវ ឲ្យទៅពួកព័រទុយហ្គេ ដែលបានកាន់កាប់កោះនេះតាំងតែពីឆ្នាំ១៥៨៣ មកម៉្លេះ ។ នៅក្នុងឆ្នាំ១៥៨៣ ចិនបានយល់ព្រមឲ្យពួកសាសនទូតសេស៊ុីត ចូលផ្សព្វផ្សាយសាសនានៅណានកាំង ក៏ប៉ុន្តែក្រោយមក បានបណ្ដេញពួកនេះចេញទៅវិញ ដោយហេតុថាពួកកាតូលិកនេះ ហាក់ដូចជាបានចូលដៃចូលជើងជាមួយសត្រូវដែលប្រឆាំងប្រជែងយករាជសម្បត្តិ ។ ព្រះចៅអធិរាជពេលនោះ បានអនុញ្ញាតឲ្យពួកសេស៊ុីតតែ២-៣នាក់ប៉ុណ្ណោះ ដែលគិតគូរតែខាងវិទ្យាសាស្ត្រ ពិសេសគឺតារាសាស្ត្រ ស្នាក់នៅនឹងប៉េកាំង ។ បន្ទាប់មក ចិនបានចាប់ផ្ដើមបើកទ្វារឲ្យពួកអឺរ៉ុបឡើងវិញបន្តិចម្ដងៗ ។ នៅរវាងឆ្នាំ១៧៨៨ រដ្ឋាភិបាលចិនបានអនុញ្ញាតឲ្យពួកអង់គ្លេស និងបារាំងបើកអគារពាណិជ្ជកម្មនៅកង់តុង ក៏ប៉ុន្តែព្រះចៅអធិរាជមិនអាចធ្វើឲ្យពួកចៅហ្វាយខេត្ត និងមន្ត្រីនៅក្រោមបង្គាប់ដាក់ទោសទណ្ឌដល់ពួកអ្នកដែលបានធ្វើបាបជនរួមជាតិ និងពួកអង់គ្លេសបានទេ ។ បាតុភាពប្រឆាំងមិនមែនលេចចេញមកពីស្រទាប់ប្រជាជន ដែលទទួលផលល្អពីវត្តមានរបស់ពួកអឺរ៉ុបនោះទេ តែលេចចេញមកពីស្រទាប់ពួកអ្នកបញ្ញវន្ត និងពួកមន្ត្រីដែលភ័យខ្លាចក្រែងទំនៀមទម្លាប់ របៀបរបប និងអារ្យធម៌អឺរ៉ុប មានឥទ្ធិពលអាចមកប្រែក្លាយរបៀបរបបចាស់ដែលពួកគេកំពុងតែរស់នៅ ព្រោះគេចង់រក្សានូវអ្វីៗ ដែលជីដូនជីតារបស់គេបានបន្សល់ទុកមកឲ្យ ។ តាមពិតទៅ ពួកនោះបានដឹងច្បាស់ណាស់ នូវអំពើដែលពួកអឺរ៉ុបកំពុងតែធ្វើនៅចុងបូព៌ាប្រទេស និងនៅឥណ្ឌា ហើយការដែលគេមានការភ័យព្រួយខ្លាចពួកបិសាចលោកខាងលិចមកដណ្ដើមយកស្រុកចិននោះ មិនខុសទេ ។ និយាយពីពួកពាណិជ្ជករចិនវិញ ពួកនេះភាគច្រើនចេះអាន និងចេះសរសេរ ក៏ប៉ុន្តែគេមិនមែនជាបញ្ញវន្តដែលស្នេហាជាតិប៉ុន្មានទេ ម៉្លោះហើយ ពួកនេះមិនសូវជាអភិរក្សណាស់ណាដែរ ។ ពួកនេះមានអធ្យាស្រ័យល្អចំពោះពួកបរទេស ហើយអាចនឹងបង្ខំឲ្យពួកមន្ត្រី និងពួកបញ្ញវន្តស្ដាប់មតិសាធារណជនផង បើទោះជាមានការចោទប្រកាន់ថាសាធារណជនគិតមិនបានឆ្ងាយ ប្រៀបដូចជាមនុស្សខ្វាក់ក៏ដោយ ។ ម៉្លោះហើយ មានការតស៊ូផ្ទៃក្នុងមួយកើតឡើងរវាងម្ខាង គឺពួកអ្នកអភិរក្សនិយមដែលមានពួកមន្ត្រី និងបញ្ញវន្ត និងម្ខាងទៀតគឺពួកអ្នកដែលចង់ឲ្យស្រុកចិនបើកចំហ តែពួកក្រោយនេះ មិនសូវជាអង់អាចប៉ុន្មានទេ ។ នៅទីបញ្ចប់ពួក

អ្នកអភិរក្សនិយមក៏ឈ្នះ ហើយឆ្លៀតពេលដែលពួកបេសកជនកាតូលិក ប្រព្រឹត្តខុសឆ្គងខ្លះ នៅក្នុងឆ្នាំ១៨១៥ ក៏សម្រេចសុំបានការអនុញ្ញាតពីព្រះចៅអធិរាជ ឲ្យបណ្ដេញពួកនោះចេញទាំងអស់ទៅ ។ ពេលនោះ រាជវាំងនៅឯ ប៉េកាំង មិនបានស្ដាប់តាមពួកមន្ត្រី និងបញ្ញវន្ត ដែលអភិរក្សនិយមជាងខ្លួនទៅទៀតនោះទាំងស្រុងទេ ថ្វីបើគេខ្លាច ពួកអឺរ៉ុបធ្វើអន្តរាគមន៍គាំទ្រដល់ជនរួមឈាមគេក្ដី ម្ល៉ោះហើយ គេបានអនុញ្ញាតឲ្យបេសកជនកាតូលិកនៅនឹង ប៉េកាំងជាបន្តទៅទៀត ។ ក៏ប៉ុន្តែ នៅឆ្នាំ១៨២៨ ដោយពិនិត្យឃើញថា ប្រទេសបារាំង ដែលធ្លាប់តែការពារ ពួកសាសនទូតបរទេស មិនយល់ទាស់ទេ គេក៏បណ្ដេញពួកកាតូលិកចេញទៅតាមបំណងរបស់ពួកអ្នកអភិរក្ស និយម ។ ដល់មកឆ្នាំ១៨៣៤ រាជវាំងចិន បានប្រកែកមិនព្រមបន្តសន្ធិសញ្ញាពាណិជ្ជកម្ម ដែលប្រគល់សិទ្ធផ្ដាច់មុខ ឲ្យក្រុមហ៊ុនអង់គ្លេសនៅឥណ្ឌាភាគខាងកើតតទៅទៀតទេ ។ ពេលនោះ ដោយពិនិត្យឃើញថា ប្រទេសឯទៀត នៅតែបន្តធ្វើពាណិជ្ជកម្មជាមួយចិនបាន អង់គ្លេសបានឆ្លៀតឱកាស ដែលស្ដេចត្រាញ់នៅកង់តុង ចាប់អាភៀន ចំនួន២ម៉ឺន ៤ពាន់កេស របស់ពាណិជ្ជករអង់គ្លេសម្នាក់ ដែលមានតម្លៃរហូតដល់ទៅ៥០លានហ្វ្រង់ ដុតបំផ្លាញ ចោល ក៏ប្រកាសសង្គ្រាមនឹងស្រុកចិនឡើង ។ គេក៏នាំគ្នាហៅសង្គ្រាមនោះថា សង្គ្រាមអាភៀនទៅ ។

ក្នុងសង្គ្រាមនោះប្រទេសចិនត្រូវបរាជ័យ ហើយត្រូវបានគេចាប់បង្ខំឲ្យចុះហត្ថលេខាលើសន្ធិសញ្ញា ណង់កាំង នៅក្នុងថ្ងៃទី២៩ ខែសីហា ឆ្នាំ១៨៤២ ដោយយល់ព្រមបើកកំពង់ផែសៀងហៃ នីងប៉ូ ហ៊្វូឈូ និងអាម៉ុយឲ្យបរទេស ហើយប្រគល់កោះហុងកុងឲ្យអង់គ្លេស ។ ដល់ឃើញចិនយល់ព្រមបើកកំពង់ផែឲ្យតែ អង់គ្លេសម្នាក់ឯងដូច្នេះ បារាំង និងអាមេរិកាំង ប្រណែន ក៏ឆ្លៀតពេលចូលធ្វើអន្តរាគមន៍ ហើយទទួលបាននូវ សន្ធិសញ្ញាពិសេសរៀងៗខ្លួន ។ នៅក្នុងសន្ធិសញ្ញាជាមួយបារាំងមានសេចក្ដីបញ្ជាក់ច្បាស់ថា ប្រទេសចិននឹងត្រូវ បន្តបើកចំហឲ្យមានការផ្សព្វផ្សាយទាំងសាសនាកាតូលិក ទាំងសាសនាគ្រិស្ដ ទៀតផង ។

ពួកសត្រូវរបស់សន្តតិវង្សម៉ាន់ជូ ដែលតាមពិតទៅដូចជាមានអធ្យាស្រ័យល្អជាមួយនឹងពួកបរទេស ហើយចង់បើកចំហប្រទេសចិនចំពោះពាណិជ្ជកម្មពិភពលោក បានឆ្លៀតយកឱកាសដែលចិនបរាជ័យក្នុងសង្គ្រាម នេះ ដើម្បីបង្កើនការវាយប្រហារមកលើពួកតៃស៊ីង បំផុសបំផុលមហាជនឲ្យងើបឡើងប្រឆាំង និងគាំទ្រសន្ត តិវង្សមិញដែលមានសញ្ជាតិជាជនជាតិចិន ហើយដែលគេនិយាយថានៅមានសេសសល់បច្ឆាញាតិនៅឡើយ ។ នៅភាគខាងត្បូងស្រុកចិនមានកើតសមាគមសម្ងាត់ជាច្រើន ដែលមានបណ្ដាញរហូតមកដល់អាំងស៊ូឡាំង និងឥណ្ឌូចិន ទៀតផង ។ សមាគមសម្ងាត់ទាំងនោះបានចាប់កម្រើករំដើបរំជួលឡើង ហើយមិនយូរប៉ុន្មានក៏មាន កុបកម្មមួយរបស់ពួកតៃពីងកើតឡើងនៅក្នុងបណ្ដាខែត្រភាគនិរតី បញ្ជាក់ឲ្យឃើញថាពួកគេជាសត្រូវរបស់ សន្តតិវង្សម៉ាន់ជូ គេប្រឆាំងនឹងការដែលពួកម៉ាន់ជូនេះបង្ខំឲ្យគេក្រងសក់ទៅក្រោយ ហើយកោរសក់ពីលើ លើថ្ងាស និងក្រោមកញ្ចឹងក ។ ពួកនេះពន្លែងសក់ឲ្យនៅស៊ើងទ្រើង មិនក្រងទៀតទេ ។ មុនដំបូងពួកតៃពីងចាប់ ផ្ដើមវាយប្រហារទៅលើទ័ពរបស់ព្រះចៅអធិរាជដែលគេបានជួបប្រទះ បន្ទាប់មកបានវាយដណ្ដើមយកទីក្រុង

មួយចំនួន ។ ពួកនេះបានត្រូវប្រជាជនទះដៃអបអរសាទរគ្រប់ទិសទី ។ នៅទីបញ្ចប់ ពួកតៃពីង ដណ្តើមយកអតីតរាជធានីណង់កាំងបាន នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៨៥៣ ។

ឥឡូវនេះសន្តតិវង្សម៉ាន់ជូហៀបតែដួលរលំទៅហើយ ។ នៅពេលដែលរាជវាំងកំពុងតែជួបនឹងវិបត្តិអនាធិបតេយ្យដែលកើតមានជាទូទៅ ហើយគំនិតស្មារតីកំពុងតែពុះកញ្ជ្រោល ពួកបញ្ញវន្ត និងមន្ត្រីក៏បណ្តោយខ្លួនឲ្យលង់ទៅតាមកំហឹងដែលគេមានចំពោះពួកបរទេស ហើយចាប់ប្រព្រឹត្តអំពើឃោរឃៅដូចពីអតីតកាលវិញ ។ ឃាតកម្មទៅលើបេសកជនកាតូលិកម្នាក់នៅក្នុងឆ្នាំ១៨៥៦ រួចបន្ទាប់មកការចាប់ខ្លួនពួកជនជាតិចិនជាអ្នកដើរកប៉ាល់របស់អ្នកស្រុកអាយដែលមានជាក់ទង់ជាតិអង់គ្លេស បានធ្វើឲ្យកើតមានសង្គ្រាមឡើងម្តងទៀតរវាង ម្ខាងគឺពួកបារាំង និងអង់គ្លេស ម្ខាងទៀត គឺចិន ។ សង្គ្រាមនេះមានរយៈពេលជាច្រើនខែ សម្ព័ន្ធភាពបារាំងអង់គ្លេសទទួលជោគជ័យជាបន្តបន្ទាប់ ហើយបានធ្វើដំណើររហូតទៅដល់ប៉េកាំង ។ ចិនត្រូវបរាជ័យម្តងទៀត ហើយត្រូវចាប់បង្ខំឲ្យចុះសន្ធិសញ្ញាសន្តិភាពមួយទៀតនៅក្នុងខែមិថុនា ឆ្នាំ១៨៥៨ទេ ។ មួយឆ្នាំក្រោយមក សង្គ្រាមបានផ្ទុះឡើងសាជាថ្មី ពីព្រោះពួកចិនមិនចង់ឲ្យសច្ចាប័នទៅលើសន្ធិសញ្ញាខែមិថុនា ឆ្នាំ១៩៥៨ ។ រាជធានីប៉េកាំងត្រូវដណ្តើមយកបាននៅក្នុងឆ្នាំ១៨៦០ ព្រះរាជដំណាក់រដូវរងាបានត្រូវគេបំផ្លាញចោល ហើយគេបានលើកទង់ជាតិបារាំង និងអង់គ្លេស ដែលគេនិយាយថាជាតំណាងអារ្យធម៌ស៊ីវិល័យ នៅក្នុងរាជធានីនៃ អាណាចក្រចិន ។

គឺនៅពេលដែលវិលត្រលប់មកពីធ្វើសង្គ្រាមលើកទី១ ជាមួយចិននោះឯងដែលទ័ពបារាំងបានវាយប្រហារដោយកាំភ្លើងធំទៅលើទីក្រុងទូរ៉ាន ហើយដណ្តើមយកបានសាយហ្គន ដោយមានការគាំទ្រពីពួកអេស្ប៉ាញ៉ុល ដែលមកពីម៉ានីល ។ នៅពេលដែលវិលត្រលប់មកពីសង្គ្រាមលើកទី២ បារាំងដណ្តើមយកបាន និងកាន់កាប់ខែត្រពារបស់កូសាំងស៊ីន ដែលតាមពិតទៅបារាំងគ្មានបំណងចង់បានទេបើសិនជាអាណ្ណាម មិនបំបែកបំបាក់សាសនទូតកាតូលិក ហើយបើគ្មានទ័ពនៅក្នុងសមុទ្រចិនទេនោះ ។

បរាជ័យផ្ទួនៗរបស់ចិនដោយ "ពួកអ្នកព្រៃមកពីបស្ចិម" បានធ្វើឲ្យមតិសាធារណជនអស់ជំនឿលើរដ្ឋាភិបាលនៃសន្តតិវង្សម៉ាន់ជូ ដែលចុះខ្សោយណាស់ទៅហើយក្រោមសន្ទុះពួកបះបោរ ។ ការឃោសនាប្រឆាំងឲ្យទម្លាក់សន្តតិវង្សនេះចោលបានផ្ទុះឡើងយ៉ាងកាចសាហាវ ។ ពួកអ្នកដែលកាន់ជើងសន្តតិវង្សមិញបាននាំគ្នាទៅចូលបម្រើក្នុងជួរកងទ័ពពួកតៃពីងយ៉ាងកុះករ បង្កបានជាទ័ពដ៏ធំមួយ មានទាំងទាហានបែបជាកំណែនប្រញាប់ដែលនឹងត្រូវរំសាយទៅវិញកាលណាចប់សង្គ្រាម[១៩] ។ នយោបាយរបស់ពួកអ្នកមិនសប្បាយចិត្តបានត្រូវពង្រឹងឲ្យកាន់តែរឹងមាំឡើងដោយភាពកំសាករបស់ប្រជារាស្ត្រដែលគ្មានការទុកចិត្តទៅលើព្រះអធិរាជនីទាំង២អង្គ

[១៩] ទ័ពពួកតៃពីង ពេលនោះ មានរហូតដល់ទៅ ១០ម៉ឺននាក់ ។

ដែលបានដណ្តើមយកអំណាច ជាពិសេសគឺពួកមន្ត្រី ដែលបានក្បត់នឹងបុព្វហេតុដែលពួកគេបានបម្រើកាលពីថ្មីៗ ហើយដែលកំពុងតែមានមុខតំណែងសព្វថ្ងៃ ។ ពួកតៃពីងដណ្តើមយកនីងប៉ូបាននៅក្នុងថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៨៦១ ហើយបានទៅបោះទ័ពនៅពីមុខកំពង់ផែសៀងហៃ ជាកំពង់ផែដែលអង់គ្លេស និងបារាំងដោះដូរទំនិញជាមួយចិន នៅក្នុងខែមករា ឆ្នាំ១៨៦២ ។ ការដែលធ្វើយ៉ាងនេះមានន័យថា គឺចាប់បើកការវាយប្រហារមកលើពួកអឺរ៉ុប ហើយ ទាំងដែលពួកនេះបានខិតខំធ្វើខ្លួនជាអព្យាក្រឹតនៅក្នុងជម្លោះផ្ទៃក្នុងរបស់ចិននេះ និងទាំងដែលពួកនេះអាចចាត់ទុកបានថាជាសត្រូវបន្ទាប់បន្សំមួយរបស់សន្តតិវង្សម៉ាន់ជូ ហើយថាពួកតៃពីងបានគ្រប់គ្រងទឹកដីអាណាចក្របានមួយចំណែករួចទៅហើយក៏ដោយ ។ ក៏ប៉ុន្តែ ថ្វីបើពួកគេចង់បើកចំហស្រុកចិនក៏ដោយ ក៏ពួកតៃពីងចង់បង្ហាញឲ្យឃើញ តាមរយៈការវាយប្រហារមកលើពួកបរទេសដែលត្រួតត្រាទឹកដីភាគខាងត្បូងនេះ ថាមានតែពួកគេនេះទេដែលអាចយកជ័យជម្នះលើសត្រូវបរទេស ហើយអាចការពារឯករាជ្យជាតិបាន ។ ពួកបារាំង និងអង់គ្លេសបាននាំគ្នារៀបចំកម្លាំងឡើងវិញ ប្រឆាំងនឹងការប្រយុទ្ធរបស់ពួកតៃពីង ដែលធ្លាប់តែច្បាំងនឹងពួកចិនគ្នាឯង ហើយច្បាំងម្តងៗមានមនុស្សស្លាប់តិចជាង១០០នាក់ ធ្វើឲ្យពួកនេះបរាជ័យដូចជាទ័ពរបស់ព្រះចៅអធិរាជដែរ ។ ពួកសម្ព័ន្ធមិត្របានដណ្តើមកាន់កាប់បន្ទាយរបស់ពួកតៃពីងបានទាំងអស់ ហើយដណ្តើមយកណង់កាំងបាននៅក្នុងខែឧសភា ឆ្នាំ១៨៦៤ ។

ក្រោយសង្គ្រាម សន្តិភាពក៏មានឡើងវិញនៅក្នុងមហាអាណាចក្រ ដោយសន្ធិសញ្ញាសន្តិភាពរវាងពួកអឺរ៉ុបនឹងរដ្ឋាភិបាលចិន ដែលត្រូវអាម៉ាស់ជាខ្លាំង ព្រោះបរាជ័យជាច្រើនលើកច្រើនគ្រាក្នុងការប្រយុទ្ធជាមួយពួកតៃ-ពីង និងជាមួយទ័ពបារាំងអង់គ្លេស ដែលកន្លងមកចិនបានចាត់ទុកថាជាពួកមនុស្សព្រៃ គ្មានអារ្យធម៌ ។ តាមពិតទៅពួកសាសនទូតកាតូលិកដែលទទួលបាននូវការការពារពីពួកសម្ព័ន្ធមិត្រក៏មានកំហុសផងដែរ ជាពិសេស គឺពួកគ្រិស្តសាសនិក ដែលចង់គេចវេះឲ្យរួចផុតពីច្បាប់របស់ចិន ។ នៅពេលកំហឹងរបស់ពួកអ្នកបញ្ញវន្ត និងប្រជាជនផ្ទុះឡើង ហេតុការណ៍នេះ បានបង្កឲ្យមានព្រឹត្តិការណ៍ដ៏គួរឲ្យភ័យរន្ធត់ ។ ចិននាំគ្នាកាប់សម្លាប់ពួកសាសនទូត ចាប់ពួកគ្រិស្តសាសនិកដាក់គុក ក្រោយពីមានការចោទប្រកាន់ទៅតុលាការថាមានការលួចពង្រត់កុមារ ការលាងបាបកុមារ ដោយលួចលាក់រួចហើយកុមារត្រូវគេអារកសម្លាប់ចោល ។ បាតុភាពទាំងអស់នេះ បានធ្វើឲ្យល្អក់កករដល់ទំនាក់ទំនងរវាងពួកអឺរ៉ុប និងចិន ។ ពួកពាណិជ្ជករចិនមិនបានកាន់ជើងពួកអឺរ៉ុបទេ ព្រោះប្រកាន់ពូជសាសន៍ ក៏ប៉ុន្តែចង់ឲ្យចិនបើកចំហស្រុកទទួលយកការរីកចម្រើន ដែលមិនជាទីពេញចិត្តរបស់ពួកបញ្ញវន្តទេ ។ និយាយពីសមាគមសម្ងាត់ដ៏ច្រើនសន្ធឹកសន្ធាប់ ចាប់តាំងពីសម័យបះបោររបស់ពួកតៃពីងមក ពួកនេះនៅតែមានឥទ្ធិពលដដែល ហើយបានបន្តធ្វើសង្គ្រាមសម្ងាត់ប្រឆាំងនឹងពួកអឺរ៉ុប ទាមទារឲ្យកាប់សម្លាប់ពួកអឺរ៉ុបឥតឈប់ឈរ ។ នៅចំពោះមុខនិន្នាការអច្ឆន្ទិកនិយមបែបនេះ ដែលមានជាច្រើននៅក្នុងរាជវាំង រដ្ឋាភិបាលចិន ពួកចៅហ្វាយខេត្ត និងពួកស្តេចត្រាញ់ចិនមិនអាចនឹងធ្វើអ្វីកើតឡើយ ដើម្បីបំពេញបំណងឲ្យសមទៅនឹងចិត្តរបស់ពួកអឺរ៉ុប ក្រៅតែពីមាន

វិធានការទៅលើពួកមេបះបោរផ្ទាល់ ដែលក្នុងនោះ ជួនកាលក៏មានទាំងពួកសាសនទូត និងពួកអ្នកប្រាជ្ញអឺរ៉ុបផងដែរ ។ គេមិនហ៊ានប៉ះពាល់ពួកមន្ត្រីដែលប្រឆាំងនឹងពួកអឺរ៉ុបទេ ។

យើងបានឃើញពីខាងលើរួចមកហើយ ថាចិនបានគិតថាគេមានតួនាទីមួយក្នុងការធ្វើអន្តរាគមន៍ លូកដៃចូលមកក្នុងរឿងរ៉ាវរាជវាំងវៀតណាមជាមួយបារាំង ព្រោះគេធ្លាប់មានសិទ្ធិអធិរាជភាពមកលើអាណ្ណាម និងជាអ្នកតែងតាំងស្តេចនៅស្រុកនេះជាច្រើនសតវត្សរ៍មកហើយ ។ គេថាគេអាចបញ្ជូនទ័ពគេឲ្យមកវាយបារាំងបាន ហើយសន្ធិសញ្ញាទាំងឡាយជាមួយអាណ្ណាម ត្រូវឲ្យចិនចុះហត្ថលេខាដែរ ។ ដើម្បីឲ្យចិនឈប់រវីរវល់រារាំងទំនាក់ទំនងរបស់បារាំងជាមួយតុងកឹង លះបង់អនុត្តរភាពខាងផ្លូវសតិអារម្មណ៍មកលើអាណ្ណាម បារាំងត្រូវតែប្រកាសសង្គ្រាមជាមួយចិន ដណ្តើមយកកោះហ្វ័រម៉ូស និងកោះប៉េស្កាឌ័រ ហើយឲ្យនាវាចម្បាំងបារាំងបាញ់ពន្លិចកប៉ាល់ចិនជាច្រើន ។ ទីបញ្ចប់ចិនសុខចិត្តចុះសន្ធិសញ្ញាសន្តិភាព ហើយអ្វីៗហាក់ដូចជារៀបរយស្រួលបួលទៅហើយ ស្រាប់តែពួករុស្ស៊ីមកទាមទារយកកំពង់ផែអាកធួរ អាល្លឺម៉ង់មកយកតេងឈាវហ៊្វូ ហើយជប៉ុន ដែលចង់ដណ្តើមយកប្រទេសកូរ៉េ បានប្រកាសសង្គ្រាមនឹងចិនឡើងនៅក្នុងឆ្នាំ១៨៩៣ ដណ្តើមយកបានហ្វ័រម៉ូស ឯបារាំងយកបាន ក្វាងឈាវវ៉ាន ។ មកដល់ពេលនោះ នយោបាយចាស់គំរិលប្រឆាំងនឹងអឺរ៉ុបត្រូវបរាជ័យទៅ ហើយប្រទេសចិនបានចាប់ផ្តើមធ្វើការផ្លាស់ប្តូរ ហើយប្រទេសអឺរ៉ុបជាច្រើនបានទទួលសិទ្ធិកសាងផ្លូវដែកជាច្រើន ។

នៅថ្ងៃមួយ ពួកបះបោរដែលមានឈ្មោះថា “ក្រុមបុកស័រ” បាននាំគ្នាក្រោកឡើងយ៉ាងសន្ធឹកសន្ធាប់ ចាប់អគ្គរាជទូតអាល្លឺម៉ង់សម្លាប់ ហើយបានបើកការវាយប្រហារមកលើស្ថានទូតបរទេសទាំងអស់ បិទច្រកចេញចូល ហើយហ៊ុមព័ទ្ធជាប់ ។ បណ្តាប្រទេសអឺរ៉ុបទាំងឡាយដែលមានតំណាងរបស់ខ្លួនត្រូវរងការវាយប្រហារ ក៏ចាប់បញ្ជូនទ័ពមក ក្នុងនោះមានទាំងជប៉ុនចូលរួមផងដែរ ហើយគេក៏នាំគ្នាបើកការវាយប្រហារឆ្ពោះទៅរករាជធានីប៉េកាំង ។ បណ្តាស្ថានទូតដែលត្រូវពួកបះបោរព័ទ្ធជាប់ មានកម្លាំងទាហានជើងគោក និងជើងទឹកប្រមាណជា១០០នាក់នៅការពារ បានត្រូវរងការវាយប្រហាររាល់ថ្ងៃ រួចក្រោយពីមានការវាយលុកធំមួយ ក៏ស្ងប់ស្ងាត់បាត់ទៅវិញ ពីព្រោះពួកសត្រូវមិនចុះសម្រុងគ្នា ដោយមានការបែកបាក់ជាបក្សពីរនៅឯរាជវាំង ។ បក្សទី១ គឺបក្សពួកអ្នកអភិរក្សនិយម ដែលឃោរឃៅហើយមានបំណងចង់កាប់សម្លាប់ពួកអឺរ៉ុបឲ្យអស់ បើទោះជាថា ការធ្វើដូច្នេះ នឹងនាំឲ្យប្រទេសចិនត្រូវប្រឈមមុខនឹងសង្គ្រាមជាមួយបណ្តាប្រទេសអឺរ៉ុប សង្គ្រាមតាមមាត់ឆ្នេរសមុទ្រអាចធ្វើឲ្យពួកអឺរ៉ុបចូលលុកលុយប្រទេសទាំងមូល មកទម្លាក់សន្តតិវង្សម៉ាន់ជូចេញ ហើយបែងចែកទឹកដីគ្នារវាងបារាំង អាល្លឺម៉ង់ រុស្ស៊ី អង់គ្លេស ជប៉ុន ហើយក៏អាចមានអាមេរិកផងក៏ដោយ ។ បក្សមួយក្រុមទៀត គឺពួកអ្នកដែលចង់ចរចាជាមួយពួកអឺរ៉ុប ហើយឲ្យចិនធ្វើការកែទម្រង់ស៊ីជម្រៅតែម្តង ។ ពេលនោះ ព្រះអធិរាជិនីដែលត្រូវជាព្រះអយ្យកា ទ្រង់មិនសព្វព្រះទ័យនឹងពួកអឺរ៉ុបទេ ហើយបារម្ភណាស់ ភ័យខ្លាចតែបាត់បង់រាជបល្ល័ង្ក ។ ព្រះអង្គគិតថាត្រូវពួកទាំង២បក្សក្បត់ហើយ ហើយទ្រង់មិនមានទុកចិត្តបក្សណាមួយទេ ។ ទ្រង់ក៏បង្អែបង្អង់ពីមួយថ្ងៃ

ទៅមួយថ្ងៃ ពីមួយម៉ោងទៅមួយម៉ោង រង់ចាំមើលក្រែងមានព្រឹត្តិការណ៍ណាមួយកើតឡើង ដើម្បីមកជួយសង្គ្រោះព្រះអង្គ ។ នៅទីបញ្ចប់ ពួកសម្ព័ន្ធមិត្តក៏នាំគ្នាធ្វើដំណើរមកដល់មាត់ទ្វាររាជធានីប៉េកាំង ដណ្តើមយករាជធានីនេះបានដោយគ្មានខូចខាតកម្លាំងអ្វីបន្តិច រួចហើយក៏បែងចែកទឹកដីគ្នាគ្រប់គ្រង និងបំផ្លិចបំផ្លាញគ្មានសល់ ។ ចៃដន្យអាក្រក់ រាជវាំងរដូវរងាដែលកាន់កាប់ដោយពួកអាល្លឺម៉ង់ បានត្រូវភ្លើងឆេះភ្លឺទ្វាល ។ ដំណាក់ អគារស៊ីវិល និងប្រាសាទទាំងឡាយត្រូវភ្លើងឆេះ ដួលរលំខ្ទេចខ្ទី ហាក់បីដូចជានាំយកទៅជាមួយជារៀងរហូត នូវអារ្យធម៌ចាស់គំរឹល និងអតីតកាលទាំងឡាយ រួមទាំងកម្រងសំណេរផ្សេងៗ ពង្សាវតារ និងស្នាដៃសិល្បៈរបស់ប្រជាជនមួយក្នុងប្រវត្តិសាស្ត្រ ៤ពាន់ឆ្នាំកន្លងមក ។

ពេលនោះ ព្រះអធិរាជិនី បានរត់គេចភៀសព្រះកាយជាមួយព្រះរាជវង្សានុវង្ស និងរាជបរិពារផង ទៅភាគខាងជើង អស់សង្ឃឹមយ៉ាងខ្លាំងដែលត្រូវបាត់បង់ទឹកដី និងរាជសម្បត្តិ ។ ក៏ប៉ុន្តែបន្តិចក្រោយមក ព្រះអង្គបានឈ្វេងយល់ដឹងអំពីកំហុសឆ្គង ភាពខ្វះការប៉ិនប្រសប់ និងភាពញញើតញញើមរបស់ព្រះអង្គ ដែលនាំឲ្យមានការខូចខាតទាំងអស់នេះ ។ ប្រាជ្ញាស្មារតីរបស់ព្រះអង្គហាក់ដូចជាភ្ញាក់ស្វាងឡើងវិញ ទ្រង់ក៏បែរទៅរកបក្សពួកអ្នកដែលចង់ឲ្យមានការរីកចម្រើន ។ ព្រះអង្គបានយល់ព្រមទទួលយកសំណើសុំសន្តិភាពរបស់ពួកសម្ព័ន្ធមិត្តដែលកាន់កាប់រាជធានីប៉េកាំង ក្រោយពីពួកនេះកម្ចាត់កម្ចាយក្រុមបុកស័រឲ្យបាត់បង់ទៅបន្តិចម្តងៗ ។ ព្រះអង្គបានយល់ព្រមអនុវត្តតាមមាគ៌ាដែលពួកនោះត្រួសត្រាយផ្លូវ ហើយទ្រង់ស្តាប់តាមមតិរបស់ពួកមន្ត្រីដែលឯកភាពដើរតាមពួកអឺរ៉ុប ។

ក៏ប៉ុន្តែមានមនុស្សជាច្រើនដែលស្អប់ព្រះអធិរាជិនីកញ្ចាស់នេះ ព្រោះមិនកាន់ពាក្យសច្ចៈ ហើយកាចសាហាវ ។ ចំនួនពួកអ្នកមិនសប្បាយចិត្ត ពួកអ្នកចេះដឹង ពួកអ្នកដែលត្រូវគេកាត់កាលចោលបានកើនឡើងជាលំដាប់ ហើយរំដើបរំជួលខ្លាំងឡើងៗ ជាពិសេសក្នុងចំណោមអ្នកដែលនៅជុំវិញព្រះអង្គ ។ ព្រះអង្គមិនដឹងថា តើត្រូវធ្វើយ៉ាងណាទេ ក្រៅតែពីប្រព្រឹត្តខុសកាន់តែច្រើនឡើងៗ ។ ក្រុមសមាគមសម្ងាត់ដែលបានចាប់កំណើតឡើងតាំងតែពីពេលសន្តតិវង្សមិញអស់អំណាចទៅ ហើយមានបណ្តាញរហូតដល់ទៅខាងក្រៅស្រុកចិន ដូចជាមាននៅអាំងស៊ូឡាំង ឥណ្ឌូចិន សៀម និងអាមេរិកជាដើម បានពុះកញ្ច្រោលកាន់តែខ្លាំងឡើងៗដែរ ។ ពួកនាយទុនចិនបានប្រមូលប្រាក់យ៉ាងច្រើនប្រគល់ឲ្យពួកអ្នកបដិវត្តន៍ដែលកើតមានច្រើនឡើងៗ នៅពាសពេញអាណាចក្រ ។ និយាយឲ្យខ្លីទៅបដិវត្តន៍បានផុសចេញមកហើយ ហើយទម្លាប់ចាស់ពីមុនទាំងឡាយ បានត្រូវគេថ្កោលថា មិនល្អ ។ គេនាំគ្នាកាត់សក់ក្រងចេញ នាំគ្នាស្លៀកពាក់តាមរបៀបអឺរ៉ុប ឈប់ជក់អាភៀន ហើយស្រីៗបានចាប់ផ្តើមចូលរួមប្រឡូកក្នុងការប្រយុទ្ធយ៉ាងស្វិតស្វាញ ធ្វើឲ្យមានការភ្ញាក់ផ្អើលជាខ្លាំង មិនត្រឹមតែក្នុងសំណាក់ប្រជាជនចិនខ្លួនឯងទេ តែក្នុងចំណោមពួកអឺរ៉ុបផងដែរ ។ នៅទីបញ្ចប់ គេបានបោះបង់ព្រះអធិរាជិនីចាស់ចោល ហើយប្រកាសប្រទេសចិនជាសាធារណរដ្ឋឡើង បើទោះជាមានអនាធិបតេយ្យ មានការងើបបះបោររបស់ពួកទាហានដែលគ្មាន

ប្រាក់ខែខ្លះៗក៏ដោយ ។ សណ្តាប់ធ្នាប់ចាប់កើតមានឡើងវិញបន្តិចម្តងៗ ។

សព្វថ្ងៃនេះ ប្រទេសចិនកំពុងតែបោះជំហាននៅលើមាគ៌ាថ្មីសន្ធាងមួយ ។ ពួកមន្ត្រីរបស់ចិន តាំងតែពីឯកអគ្គរដ្ឋទូត រដ្ឋមន្ត្រី និងអភិបាលខែត្រឡើងទៅ សុទ្ធតែជាមនុស្សជំនាន់ថ្មី មានការរីកចម្រើន ធ្លាប់បានរៀនសូត្រវិទ្យាសាស្ត្រទំនើប ហើយបានបោះបង់ទម្លាប់នយោបាយ សង្គម និងគ្រួសារបែបចាស់ចោល ។ ពួកគេមានបំណង ចង់ជួយស្រោចស្រង់ប្រទេសចិនឲ្យមានការរីកចម្រើនដូចជាប្រទេសជប៉ុន ។ សភាតំណាងរាស្ត្រទីមួយបានជួបប្រជុំគ្នាជាលើកដំបូង បើទោះជាមានការខ្វែងគំនិតគ្នារវាងបក្សនយោបាយ ហើយបើទោះជាថា បដិវត្តន៍បានសម្រេចបណ្តេញតំណាងជាង៣០០នាក់ចេញ (ចុងខែតុលា ឆ្នាំ១៩១៣) ក៏ដោយ ក៏វាជាពន្លឺនៃសេចក្តីសង្ឃឹមមួយ សម្រាប់អនាគតនៅលើពិភពលោកនេះដែរ ។

នៅពេលដែលព្រឹត្តិការណ៍ធំៗទាំងឡាយ ដូចដែលបានរៀបរាប់ខាងលើបានប្រព្រឹត្តទៅចប់សព្វគ្រប់នៅក្នុងសតវត្សរ៍ទី១៨ ហើយប្រទេសចិនបានបើកទ្វារចំហឲ្យពិភពលោកខាងក្រៅ ចិនលែងហៅពួកអឺរ៉ុប ថាជាពួកមនុស្សព្រៃទៀតហើយ ហើយបែរមកហៅត្រឹមតែថាជាពួកព្រាយទិសខាងលិចវិញប៉ុណ្ណោះ ។ ពេលនោះ ប្រជាជនចិនបាននាំគ្នាចាកចេញពីស្រុក តាមគ្រប់ច្រកល្ហក គ្រប់កំពង់ផែដែលបើកចំហ ទៅពាសពេញពិភពលោក ។ មានចិនមករស់នៅអាំងស៊ូឡាំងចំនួន១០ម៉ឺននាក់ នៅឥណ្ឌូចិន១០ម៉ឺននាក់ នៅម៉ាឡាកា១០ម៉ឺននាក់ដែរ ។ នៅសៀម មានចិនបុកកូនកាត់ចិន២លាននាក់ ។ ប្រទេសអូស្ត្រាលី កាលនោះជាអាណានិគមអង់គ្លេស ដូចជាមិនបានដឹងថាអង់គ្លេសបានខិតខំធ្វើសង្គ្រាមដើម្បីបើកចំហស្រុកចិនទេ បែរជាបិទទ្វារមិនព្រមទទួលពួកចិនទៅវិញ ។ ចំណែកអាមេរិក ដែលធ្លាប់បានចាប់បង្ខំឲ្យជប៉ុនបើកទ្វារចំហ និងគាំទ្រសកម្មភាពរបស់ពួកសម្ព័ន្ធមិត្រនៅស្រុកចិនក៏ដូចគ្នាដែរ គឺបានប្រកែកមិនព្រមទទួលយកជប៉ុន និងចិនទៅក្នុងស្រុកខ្លួនទេ មិនតែប៉ុណ្ណោះ បានទាំងហាមមិនឲ្យកូនជប៉ុន និងចិនទៅរៀនក្នុងសាលារៀនរបស់គេថែមទៀត ហើយបានគំរាមថា នឹងធ្វើឲ្យមានចលាចល និងការកាប់សម្លាប់ដូចដែលពួកសាន់ហ្វ្រង់ស៊ីស្កាំង បានធ្វើម្តងមកហើយលើពួកស្បែកលឿង នៅក្នុងឆ្នាំ១៨៨៦ ។

បើទោះជាយ៉ាងណាក្តី មានចិនជាចំនួនច្រើននៅចុងបូព៌ាប្រទេស ដូចជានៅកោះជ្វា កូសាំងស៊ីន ហ្វីលីពីន កម្ពុជា ហើយពួកនេះបានកាន់កាប់ពាណិជ្ជកម្មដុំ និងរាយ ឧស្សាហកម្មប្រហែលជា២ភាគ៣ និងកម្លាំងពលកម្មស្ទើរតែទាំងអស់ ។ ការដែលបារាំងខិតខំច្បាំងដណ្តើមយកឥណ្ឌូចិន បានផ្តល់ផលប្រយោជន៍ឲ្យចិនច្រើនជាងឲ្យបារាំង ។ ដូចដែល អេរីកក្លូវីស បាននិយាយរួចហើយថាពួកចិនអាចនឹងនិយាយមកកាន់បារាំងបានថា "ពួកអ្នកឯងបានប្រយុទ្ធដើម្បីពួកយើង" ។ តាមពិតទៅ បើសិនជាគ្មានពួកចិន គ្មានពួកកម្មករចិនទេ បារាំងក៏គ្មាននរណាដើម្បីសាងសង់ផ្ទះនៅឥណ្ឌូចិនបានដែរ ។ បើសិនជាគ្មានពាណិជ្ជករចិនតូចតាច រកស៊ីនៅឆ្ងាយពីទីប្រជុំជន ដែលបារាំងមិនអាចទៅរស់នៅបាន ហើយពួកបារាំងពេញចិត្តនឹងទទួលយកតែប្រាក់ចំណេញបន្តិចបន្តួច នោះទំនិញមួយចំណែកធំរបស់បារាំងនឹងត្រូវសល់នៅក្នុងឃ្លាំង ហើយការរីកចម្រើននឹងប្រព្រឹត្តទៅយឺតៗ ។

ចំណុចគួរកត់សម្គាល់មួយ គឺចិនលែងមានអនុត្តរភាពផ្នែកនយោបាយ នៅចុងបូព៌ាប្រទេសទៀតហើយ ហើយក៏គ្មានឥទ្ធិពលអ្វីផ្ទាល់ទៅលើប្រជាជាតិជិតខាងទៀតដែរ ។ ពោលគឺចិនត្រូវបាក់មុខ បាត់កិត្យានុភាព ដែលធ្លាប់តែមានអស់កាលជាយូរណាស់មកហើយ ។ ដូចដែលលោក ហ៊្សុលហ៊ែរី បាននិយាយរួចមកហើយថា ពេលនេះជាងពេលណាៗទាំងអស់ ចិនលែងជាប្រទេសធំមួយដែលមានអធិរាជភាពទៅលើប្រទេសជិតខាង លែងទទួលរាជទូត លែងផ្ញើត្រា និងលិខិតតែងតាំងទៅថ្វាយស្តេចដែលទើបឡើងគ្រងរាជបល្ល័ង្កថ្មី លែងជាចំណុចកណ្តាលនៃភពផែនដី និងលែងជាជាតិសាសន៍ល្អប្រសើរជាងអ្នកដទៃទៀតហើយ ។ ក៏ប៉ុន្តែចិននៅតែជាអាណាចក្រដ៏ធំមួយ ជាមួយនឹងប្រជាជនសរុបជាង៣៥០លាននាក់ នៅរាយពាសពេញនគរដែលមានវិសាលភាពមិនតិចជាង៤លានគីឡូម៉ែត្រក្រឡា និងមានចំណូលថវិកាមិនតិចជា២កោដិហ្វ្រង់ទេ ។

ប្រទេសចិនបានធ្លាក់ចូលក្នុងភាពថមថយ ក៏ប៉ុន្តែចិនបានធ្លាក់ទៅដល់បាតរណ្តៅហើយ ហើយឥឡូវនេះចិនកំពុងតែចាប់ផ្តើមងើបឡើងវិញ ប្រាកដខ្លួន និងប្រកាន់ខ្ជាប់នូវមាគ៌ាឆ្ពោះទៅរកអនាគតល្អនាពេលដ៏ខ្លីខាងមុខសម្រាប់ប្រជាជនខ្លាំងក្លាមួយ ដែលនឹងធ្វើឲ្យពិភពលោកមានការភ្ញាក់ផ្អើល ពីព្រោះថាគឺជាប្រជាជនអង់អាចក្លាហាន បើទោះជារដ្ឋាភិបាលពុករលួយ ក៏ដោយ ។ ចិនមានប្រជាជនច្រើន មានធនធានមនុស្ស និងប្រាក់កាសសម្បូរបែប ដោយសារថាមពល និងការអត់ធ្មត់ក្នុងការងារ ថ្នាក់ដឹកនាំសព្វថ្ងៃស្រឡាញ់វិទ្យាសាស្ត្រ និងការលូតលាស់ ។

ប្រជាជនចិនជាប្រជាជនដែលមានអនាគតវែងឆ្ងាយ ដែលនឹងធ្វើឲ្យអឺរ៉ុបមានការស្តាយក្រោយជាមិនខាន ដោយសារតែខ្លួនបានផ្តល់ការអប់រំឲ្យនេះ ។

## ៤- ប្រទេសជប៉ុន

ប្រជាជនជប៉ុនបានរៀបរាប់ថាគេមានដើមកំណើតតាំងតែពី ៣.៥០០ឆ្នាំមុនមកម្ល៉េះ ក៏ប៉ុន្តែប្រវត្តិសាស្ត្ររបស់ជប៉ុនពិតប្រាកដបានចាប់ផ្តើមពីត្រឹមសតវត្សរ៍ទី៦មុនគ្រិស្តសករាជ តែប៉ុណ្ណោះ ។ វាហាក់ដូចជាថានៅសម័យនោះមានស្តេចនៃកោះគ្យូស៊ូតូចមួយ បានវាយដណ្តើមយកប្រជុំកោះទាំងមូល រួចដណ្តើមយកបានកោះធំឈ្មោះ នីផុន ដែលក្រោយមកគឺជារាជាណាចក្រជប៉ុនឬនីប៉ុន នោះឯង ។ ស្តេចនោះបានសុគតទៅនៅក្នុងឆ្នាំ៥៨៥មុនគ្រិស្តសករាជ ។

ជាច្រើនឆ្នាំក្រោយមក ព្រះមហាក្សត្រីជារាជានុសិទ្ធិនៃរាជាណាចក្រនីប៉ុនបានវាយដណ្តើមយកកូរ៉េបាន រួចបានលើករាជធានីមកតាំងនៅនីងអូសាកូវិញដែលមានប្រជាជន៧០ម៉ឺននាក់ បន្ទាប់មកនៅក្យូតូ នៅឆ្ងាយពីសមុទ្រដែលពួកមីកាដូជាស្តេចសោយរាជ្យតៗមកគង់នៅ ហើយក្លាយព្រះអង្គទៅជាស្តេចកម្ជិល ដែលប្រជារាស្ត្រ នៅតែគោរព ក៏ប៉ុន្តែមិនដឹកនាំប្រទេសទេ ។ ពួកដៃមីញ៉ូ គឺពួកស្តេចត្រាញ់សក្តិភូមិ សោយរាជ្យនៅលើទឹកដី

ហើយទទួលផលពីការដោះដូរពាណិជ្ជកម្មឬពីចោរកម្ម ។ មានកើតកោលាហលឥតឈប់ឈរ ដែលជាហេតុធ្វើឲ្យជប៉ុនមិនអាចរីកចម្រើនបាន រហូតដល់សតវត្សរ៍ទី១២នៃគ្រិស្តសករាជ គឺនៅចំពេលដែលកម្ពុជាកំពុងតែស្គាល់ការរីកចម្រើនដល់កំពូល ហើយហៀបតែនឹងបាក់ស្រុតចុះទៅវិញទៅហើយ មានដៃមីញ៉ូម្នាក់បានប្រមែប្រមូលកម្លាំងវាយបង្ក្រាបពួកដៃមីញ៉ូឯទៀតៗ រួចលើកខ្លួនជាសៃហ្គូន គឺចៅហ្វាវាំង ចាប់បន្ទំអ្នកឯទៀតឲ្យស្បថស្បែជាមួយរហូតមក ។

មេដឹកនាំថ្មីនេះ ដែលធ្វើអ្វីៗក្នុងនាមព្រះចៅអធិរាជ មានសត្រូវជាច្រើន ។ ពេលនោះ គូប៊ីឡៃខាន់ បានឡើងជាអធិរាជរបស់ចិន ហើយទើបតែដណ្ដើមយកកូរ៉េបាន ក៏មានបំណងចង់វាយយកជប៉ុនផងដែរ ។ សៃហ្គូននាពេលនោះបានប្រមែប្រមូលកម្លាំងទាំងអស់ដើម្បីទប់ទល់នឹងកាលៈទេសៈដ៏លំបាកនេះ ស្រាប់តែចៃដន្យល្អខ្យល់ព្យុះកំបុតត្បូងមួយបានបំផ្លាញសំពៅទាំង៤ពាន់ដែលដឹកទ័ពម៉ុងហ្គោលចិន ២៨ម៉ឺននាក់ បណ្ដាលឲ្យខូចខាតខ្ទេចខ្ទី ។ ហេតុការណ៍នេះបានជួយប្រទេសជប៉ុនឲ្យរួចផុតពីគ្រោះថ្នាក់ ហើយក៏បានធ្វើឲ្យប្រជារាស្ត្របែរខ្នងដាក់មីកាដូ ដែលគេចាត់ទុកដូចជាអាទិទេពរស់មួយអង្គថែមទៀត ។

អំណាចកាន់តែកើនឡើងរបស់សៃហ្គូន ដែលជំនួសមុខឲ្យមីកាដូដែលនៅតែជាស្ដេចសោយរាជ្យដដែល ប៉ុន្តែមិនកាន់អំណាច មិនមែនគ្មានការប្រឆាំងសោះនោះទេ ។ ពួកអ្នកកាន់សាសនានិកាយផ្សេងៗ ដែលដណ្ដើមគ្នាបែងចែកការគោរពពីប្រជាជនជប៉ុន ជាពិសេសគឺពួកដៃមីញ៉ូដែលស្ថិតនៅជាស្ដេចត្រាញ់សក្តិភូមិមានភោគទ្រព្យច្រើន ពួកនេះមិនយល់ព្រមគោរពមេម្នាក់ដែលគេមិនបានជ្រើសតាំងឡើងទេ ហើយខារខាំងការឆក់ប្លន់របស់ពួកគេថែមទៀត ម្ល៉ោះហើយមានការប្រណែនឈ្នានិសប្រឹងប្រែងរស់ឯករាជ្យ ដូចជាស្ដេចតែសព្វៗខ្លួន ។

នៅពេលនោះ មានគង្វាលសេះក្មេងម្នាក់បានក្លាយខ្លួនទៅជាមេទ័ព រួចជារដ្ឋមន្ត្រីទី១របស់សៃហ្គូន បានចាប់ផ្ដើមវាយដណ្ដើមយកកូរ៉េ ដែលគូប៊ីឡៃខាន់ដណ្ដើមយកដាក់ជារបស់ចិនបានពីមុន ហើយបានបន្តធ្វើសង្គ្រាមជាមួយចិនតទៅទៀត ។ ទ័ពជប៉ុនទទួលបានជោគជ័យនៅក្នុងសង្គ្រាមនេះ ក៏ប៉ុន្តែនៅពេលដែលវិលត្រលប់មកដល់ជប៉ុនវិញ ពួកមេទ័ពទាំងឡាយបានបាត់បង់ទឹកដី ក្រុមគ្រួសារ និងបន្ទាយរបស់ខ្លួនអស់ ព្រោះសៃហ្គូនបានកាត់បញ្ចូលទៅជារបស់គេ ឬបំផ្លិចបំផ្លាញកម្ទេចចោលអស់ ឯក្រុមគ្រួសារវិញសៃហ្គូនបានចាប់យកទៅទុកនៅកន្លែងគេជាចំណាប់ខ្មាំង (ចុងសតវត្សរ៍ទី១៦) ។ នៅពេលនោះ រាជធានីរបស់ជប៉ុនគឺយេដូ ហើយចាប់តាំងពីពេលនោះមក មីកាដូ ក៏លែងរវីរវល់នឹងកិច្ចការប្រទេសជាតិជារៀងរហូត ។

តាមមើលទៅម៉ាកូប៉ូឡូដូចជាបានមកដល់ជប៉ុននេះដែរ នៅសតវត្សរ៍ទី១៣ ក៏ប៉ុន្តែរឿងរ៉ាវដែលគាត់រៀបរាប់ហាក់ដូចជាមិនសូវពិតទេ ។ ពួកព័រទុយហ្គេបានមកដល់ជប៉ុននៅក្នុងសតវត្សរ៍ទី១៦ ។ នៅក្នុងឆ្នាំ ១៥៤២ ហ្វែរណាន់ដេម៉ង់ដេប៉ង់តូ បានរៀបរាប់ថាគាត់បានចុះធ្វើទស្សនកិច្ចនៅលើកោះមួយ ហើយគាត់បានធ្វើអំណោយជាស្នាមួយថ្វាយស្ដេចនៅលើកោះតូចនោះ ។ គាត់ថាគាត់មានការភ្ញាក់ផ្អើលជាខ្លាំង នៅពេលដែលគាត់

បានវិលត្រលប់មកកាន់កោះនោះម្តងទៀតមួយឆ្នាំក្រោយមក ដោយឃើញមានស្នាដាច្រើន ដែលគេកសាងឡើង តាមគំរូស្នាដែលគាត់បានឲ្យពីឆ្នាំមុន ។

ពួកសាសនទូតកាតូលិក បានមកដល់ជប៉ុនក្រោយ ហ្វ៉ែរណង់ដេម៉ង់ដេប៉ង់តូបន្តិច ហើយបានផ្សព្វផ្សាយសាសនាប្រកបដោយជោគជ័យ ធ្វើឲ្យជប៉ុនជាច្រើននាក់ក្លាយទៅជាកាន់សាសនាកាតូលិក ។ នៅពេលដែលពួកហុល្លង់ បានមកដល់ជប៉ុនហើយបង្កើតហាងមួយនៅលើកោះហ៊ីរ៉ង់ដូ ពេលនោះពួកព័រទុយហ្គេមានអគារពាណិជ្ជកម្មជាច្រើន រួចទៅហើយ ។ នៅពេលនោះក្រុមហ៊ុនអង់គ្លេសនៅប្រទេសឥណ្ឌាបូព៌ា ក៏បានទទួលការអនុញ្ញាតពីសៃហ្គូន ឲ្យបើកអគារពាណិជ្ជកម្មប្រហែលជា១០ ផងដែរ ។ ដល់ពេលនោះ ពួកជប៉ុន បានចាប់ផ្តើមលែងទុកចិត្តពួកអឺរ៉ុបដ៏ក្លាហានតទៅទៀតហើយ ដោយបានព្រួគេនិយាយអំពីរឿងដែលពួកអឺរ៉ុបបានធ្វើកន្លងមក ហើយដែលច្រើនតែបញ្ចប់ដោយការចាប់បង្ខំស្តេចណាដែលរាក់ទាក់ទទួល និងដោយការដណ្តើមយកអាណាខេត្តណាដែលគេបានអនុញ្ញាតឲ្យពួកនោះដាក់ជើងជាន់ ។ ជប៉ុនចាប់ផ្តើមអស់ជំនឿទៅលើពួកសាសនទូត ដែលគេបានទុកចិត្តកន្លងមក ដោយសារថាពួកសាសនទូតនេះ បានមកផ្សព្វផ្សាយសាសនាលោកខាងលិចមួយ ដែលធ្វើឲ្យពួកអ្នករដ្ឋវាសី បះបោរប្រឆាំងនឹងច្បាប់របស់ស្រុកទេស ហើយកាន់ជើងពួកបរទេសទាំងនោះខ្លាំងជាងជប៉ុនគ្នាឯងទៅទៀត ។ ពួកជប៉ុនគិតថា បើសិនណាជាគេបណ្តោយឲ្យសាសនាថ្មីនេះផ្សព្វផ្សាយទៅពាសពេញប្រទេស ហើយទុកឲ្យពួកអឺរ៉ុប ទទួលបាននូវផលកម្រៃច្រើនសន្ធឹកសន្ធាប់ពីទំនាក់ទំនងជាមួយគ្នានេះ នោះប្រទេសជប៉ុននឹងទទួលរងនូវគ្រោះថ្នាក់ជាមិនខាន ។ ម្ល៉ោះហើយ គេក៏ចាប់ផ្តើមបណ្តេញពួកសាសនទូតចេញ ចាប់ធ្វើទុក្ខបុកម្នេញពួកអ្នកស្រុកណាដែលចូលកាន់សាសនាកាតូលិក ហើយនៅក្នុងឆ្នាំ១៦១៣ គេបានហាមមិនឲ្យពួកស្បែកសចុះចតនៅលើឆ្នេរសមុទ្រជប៉ុនថែមទៀត ។ នៅក្នុងឆ្នាំ១៦៣៦ ពាណិជ្ជកម្មនៅក្នុងប្រទេសជប៉ុន បានចុះត្រដាបត្រដួសជាខ្លាំងលើកលែងតែចំពោះពួកហុល្លង់ដែលកាន់សាសនាប្រូតេស្តង់ចេញ ព្រោះពួកនេះមិនដែលប៉ុនប៉ងនឹងទាក់ទាញពួកជប៉ុនឲ្យចូលកាន់សាសនាគេទេ ម្ល៉ោះហើយក៏បានទទួលការអនុញ្ញាតឲ្យបើកអគារពាណិជ្ជកម្មមួយ នៅលើកោះដេស៊ីម៉ា តែពួកនោះត្រូវគេតាមដានត្រួតពិនិត្យជាប់ ដូចជាពួកអ្នកកើតឃ្លង់ ឬអ្នកទោសអ៊ីចឹង (១៦៤០) ។ គេបានហាមប្រាមមិនឲ្យប្រជាជនជប៉ុនធ្វើពាណិជ្ជកម្មតាមសមុទ្រ មិនឲ្យមាននាវាសមុទ្រ ហើយមិនឲ្យចាកចេញពីប្រទេសជប៉ុនទេ បើពុំនោះនឹងត្រូវទទួលទោសប្រហារជីវិត ។ មានប្រជាជនជប៉ុនជាច្រើន ដែលចូលកាន់សាសនាកាតូលិកហើយដែលត្រូវរងការធ្វើទុក្ខបុកម្នេញ បានគេចខ្លួនរួចទៅកាន់ស្រុកចិន តុងកឹង កូសាំងស៊ីន ឬអាណ្ណាម និងកម្ពុជាផងដែរ ។ ពួកទាំងអស់នោះ បានមកជួបជុំជាមួយពួកអ្នកដែលកាន់សាសនាកាតូលិកដូចគ្នា ហើយបាននាំគ្នាបង្កើតជានិគមពួកអ្នកដែលស្មោះត្រង់នឹងពួកអឺរ៉ុបឡើង ។ ប៉ុន្តែគេក៏បានជួបប្រទះនឹងពួកអ្នក ដែលទទួលបាននូវការអនុគ្រោះពីបណ្តាអ្នកធ្វើទុក្ខបុកម្នេញគេផងដែរ ។ ដូចជានៅកម្ពុជាជាដើម ពួកជប៉ុនបានជួបពួកហុល្លង់ដែលគេស្អប់ជាខ្លាំង ព្រោះពួកនេះបានទទួលនូវការអនុគ្រោះនៅឯប្រទេសជប៉ុន ម្ល៉ោះហើយគេក៏ចាប់កាន់ជើង

ពួកព័រទុយហ្គេជាសត្រូវ ដែលកាន់សាសនាដូចគេដែរ ប្រឆាំងនឹងពួកហុល្លង់នេះ ហើយគេមិនខ្វាចនឹងធ្វើការកាប់សម្លាប់អ៊ីទាំងអស់ (១៦៤២ និង១៦៤៤) ។ នៅពេលនោះហើយដែលពួកជប៉ុនបានយល់ព្រមបម្រើស្តេចស្រុកអាយ ដូចជាពួកព័រ ទុយហ្គេដែរ ដូចដែលយើងបានឃើញមាននៅស្រុកសៀម ក៏ដូចជានៅកម្ពុជា ដែលព្រះបទុមរាជាមានកងការពារជាជប៉ុនប្រមាណជា១០០នាក់ នៅពេលដែលព្រះអង្គយាងធ្វើដំណើរទៅកាន់ស្ទឹងអាតូពី ដើម្បីស្វះស្វែងរករ៉ែមាស ដែលគេបាននិយាយទូលថ្វាយ ។ ពួកជប៉ុនទាំងអស់នោះ នៅចុងបញ្ចប់ ច្រើនតែទៅនៅលាយឡំជាមួយពួកព័រទុយហ្គេ ផ្សារភ្ជាប់ជាតិសាសន៍ និងវាសនាជាមួយគ្នាទៅ ។ នៅតុងកឹងឯណោះវិញ ពួកជប៉ុនបានចងសម្ព័ន្ធភាពជាមួយជាមួយពួកអាណ្ណាម ហើយក៏រលាយបាត់រូបជាមួយពួកនោះ ។ ប៉ុន្តែនៅកម្ពុជា ពួកជប៉ុន ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីខ្មែរ បានកូនពូនជាចៅដែលក្លាយមកជាខ្មែរ អស់ទៅហើយ ជាក់ស្តែងគឺមានភូមិមួយនៅខាងលើភ្នំពេញ ពួកអ្នកស្រុកបានចង្អុលបង្ហាញលោកឪពុក ប៊ូយ៉ឺវ៉ូ ឲ្យឃើញពួកអ្នកទាំងនោះ ដែលនៅមានសេសសល់មកដល់សព្វថ្ងៃ ។

ដូចជាប្រទេសចិនដែរ ជប៉ុនបានបិទទ្វារមិនព្រមទទួលឲ្យពួកអឺរ៉ុបចូលមកក្នុងប្រទេសទេ រហូតដល់ឆ្នាំ ១៨៥៣ នៅពេលដែលលោក ប៉ារី ជាមេបញ្ជាការកងនាវាចម្បាំងអាមេរិកបានចាប់បង្ខំសៃហ្គូនឲ្យបើកកំពង់ផែឲ្យអាមេរិកធ្វើពាណិជ្ជកម្ម ។ បន្ទាប់មកទើបមានការបើកទ្វារឲ្យបារាំងនៅក្នុងឆ្នាំ១៨៥៨ រួចបន្ទាប់មកឲ្យអង់គ្លេស រុស្ស៊ី និងបរទេសឯទៀតៗ ។ ក៏ប៉ុន្តែពួកអភិជនដែលប្រឆាំងនឹងការប្រែប្រួលថ្មីហើយស្អប់ពួកអឺរ៉ុប បានបំផុសប្រជាជនឲ្យបះបោរប្រឆាំងឡើង នាំគ្នាធ្វើការកាប់សម្លាប់មកលើពួកអឺរ៉ុប ដែលជាហេតុធ្វើឲ្យបារាំង និងអង់គ្លេសធ្វើការសងសឹកវិញ តបតទៅនឹងការជេរប្រមាថ និងឧក្រិដ្ឋកម្មមកលើជាតិសាសន៍គេនៅក្នុងឆ្នាំ ១៨៦៣ ដោយទម្លាក់គ្រាប់បែកលើទីប្រជុំជនសំខាន់ៗមួយចំនួន ។ បដិវត្តន៍មួយក៏ផ្ទុះឡើង ។ ក្រោយពីការធ្វើសង្គ្រាមអស់ពេល៤ឆ្នាំ សៃហ្គូន បានត្រូវគេទម្លាក់ចេញពីអំណាច ទុកឲ្យមីកាដូដឹកនាំប្រទេសក្នុងនាមជាស្តេចសោយរាជ្យឡើងវិញ ទទួលខុសត្រូវលើអំណាច មិនដូចពីមុនដែលមានគ្រាន់តែជាទីគោរពប៉ុណ្ណោះទេ ។ ទ្រង់បានបោះបង់រាជធានីនៅខាងក្នុងទឹកដី ហើយបានយាងមកគង់នៅយេដូវិញ ដែលបានប្រែឈ្មោះថា តូក្យូ រហូតមក (១៨៦៨) ។ ចាប់ពីពេលនោះមក អាណាចក្រជប៉ុនដែលគ្មានឈ្មោះបោះសំឡេង អ្វីសោះនៅលើពិភពលោក កាលពី៥០ឆ្នាំមុន បានប្រែក្លាយទៅជាប្រទេសមួយមានអារ្យធម៌ មានសាលាសិក្សាច្បាប់ សិក្សាវិជ្ជាពេទ្យ វិទ្យាសាស្ត្រពិត និងអនុវត្តន៍ សាលាចម្បាំង សាលាអាវុធ ឧស្សាហកម្មដ៏រីកចម្រើន មានកងទ័ពជើងគោក នាវាក្រោះ និងកងនាវាចម្បាំងដ៏ល្បីរន្ទឺ ។

នៅក្នុងឆ្នាំ១៨៧២ គេសម្ពោធផ្លូវដែកទី១ ។ នៅក្នុងឆ្នាំ១៨៧៣ គេបង្ខំឲ្យមន្ត្រីទាំងអស់ស្លៀកពាក់ តាមរបៀបអឺរ៉ុបនៅពេលណាចេញក្រៅគេហដ្ឋាន ។ បទបញ្ញត្តិផ្សេងៗប្រឆាំងនឹងពួកគ្រិស្តសាសនិកបានត្រូវគេប្រកាសជានិរាករណ៍នៅក្នុងឆ្នាំ១៨៧៦ ហើយនៅក្នុងឆ្នាំ១៨៨៩ រដ្ឋធម្មនុញ្ញមួយបានត្រូវគេប្រកាសឲ្យប្រើ ។

ជប៉ុនមានជ័យជម្នះនៅក្នុងសង្គ្រាមជាមួយចិននៅក្នុងឆ្នាំ១៨៩៥ ហើយជាសម្ព័ន្ធមិត្តរបស់ពួកអឺរ៉ុបនៅក្នុងសង្គ្រាមប្រឆាំងក្រុមបុកស័រនៅក្នុងឆ្នាំ១៩០០ ដែលចូលរួមប្រយុទ្ធដ៏អង់អាចក្នុងការដណ្តើមយករាជធានីប៉េកាំង ។ បន្ទាប់មក ជប៉ុនបានធ្វើការវាយប្រហារប្រកបដោយជោគជ័យទៅលើពួករុស្ស៊ីដែលជាជនជាតិអាស៊ីដូចគ្នា ព្រោះរុស្ស៊ីចង់ដណ្តើមយកម៉ាន់ជូរី និងយកប្រទេសកូរ៉េដាក់ជាចំណុះ ។ ដល់ពេលនោះ ជប៉ុន បានក្លាយទៅជាប្រទេសឧស្សាហកម្មមួយ មានទាហានខ្លាំងពូកែ ដែលបណ្តាប្រទេសនៅអឺរ៉ុប និងអាមេរិកត្រូវតែគិតគូរដល់ ។ ជប៉ុនមានផលិតផលដែលអាចប្រណាំងប្រជែងជាមួយផលិតផលពួកស្បែកស នៅលើទីផ្សារអន្តរជាតិបាន ហើយជ័យជម្នះផ្នែកយោធា បានរៀបចំឲ្យជប៉ុនមានជ័យជម្នះថែមទៀតខាងផ្នែកពាណិជ្ជកម្ម បើហោចណាស់ក៏នៅចុងបូព៌ាប្រទេសដែរ ។

ឥឡូវនេះជប៉ុនបានកាន់កាប់ហ្វ័រម៉ូស ដែលជាទីតាំងជួរមុខមួយសម្រាប់ការឈានទៅរកកោះហៃណាន និងតុងកឹង ហើយជប៉ុនកំពុងតែចែចូវយកហ្វីលីពីនថែមទៀត ដែលពីមុនជាទឹកដីកាន់កាប់ដោយពួកអេស្បាញ៉ុល ឥឡូវនេះជារបស់អាមេរិក ។ ប្រជាជនជប៉ុនដែលមានច្រើនហួសចំណុះ កំពុងតែធ្វើអន្តោប្រវេសន៍ចូលមកក្នុងប្រទេសកូរ៉េដែលទើបកាន់កាប់បាន ហើយជប៉ុនកំពុងតែស្រមៃចង់ធ្វើជាអ្នករៀបចំខាងផ្នែកទ័ព ឧស្សាហកម្ម និងនយោបាយ នៅក្នុងប្រទេសចិនទៀត ។ ដោយមានការព្រមព្រៀងពីពួកអ្នកភៀសខ្លួនអាណ្ណាម ជប៉ុន បានធ្វើឲ្យប្រទេសអាណ្ណាម និងតុងកឹងរំដើបរំជួល តាំងតែពីឆ្នាំ១៩០៧មក ។

ពួកជប៉ុនធ្លាប់បានមកដល់កម្ពុជាកាលពីសតវត្សរ៍ទី១៧មួង តែមិនមានតួនាទីអ្វីជាសំខាន់ទេ រួចក៏បាត់មុខរហូត ក៏ប៉ុន្តែជប៉ុនបានបញ្ជូននាយទាហានរបស់គេទៅស្រុកសៀម ដើម្បីរៀបចំកងទ័ពប្រឆាំងនឹងពួកអឺរ៉ុបជាពិសេស គឺបារាំង តែមិនបានជោគជ័យទេ ។ ជប៉ុនមិនទាន់មានផែនការអ្វីច្បាស់លាស់នៅឡើយនៅឥណ្ឌូចិន ក៏ប៉ុន្តែពួកពាណិជ្ជករ ពួកនាយទាហានជប៉ុនមានវត្តមាននៅតុងកឹង និងនៅកូសាំងស៊ីន ហើយកំពុងតែសិក្សា អំពីស្រុកទេស រួចរាយការណ៍ឲ្យអគ្គបញ្ជាការរបស់គេ រង់ចាំតែមានឱកាសអ្វីមួយកើតឡើង គេនឹងចាប់អនុវត្តគម្រោងការណាមួយសមស្របទៅតាមកាលៈទេសៈ ដែលអាចនឹងដាស់ជាតិសាសន៍ណាដែលកំពុងតែស្ពឹកស្រពន់នៅចុងបូព៌ាប្រទេសនេះ ឲ្យងើបក្រោកឡើងប្រកបទៅដោយថាមពលដែលមិនមាននរណាអាចស្មានបាន ។

ចំពោះមុខនេះកម្ពុជាគ្មានទំនាក់ទំនងអ្វីជាមួយជប៉ុនទេ ហើយក៏ប្រហែលជានឹងមិនមានតទៅទៀតក្នុងពេលដ៏ខ្លីខាងមុខនេះដែរ ។

## ៥- ប្រទេសលាវ

យើងបានឃើញពីខាងលើរួចមកហើយថា ព្រះចៅសុរិយាវង្សធម្មិកៈរាជាបរមបពិត្រ បានឡើងសោយរាជ្យបន្តពីព្រះវៀម នៅក្នុងឆ្នាំ១៦៣៨ ។ ព្រះរាជាអង្គនេះសោយរាជ្យនៅរាជធានីវៀងច័ន្ទ នៅពេលដែល

លោក ហេរ្វ៉ាវ៉ាន់វូសុហ្វ មកដល់ស្រុកលាវនៅក្នុងឆ្នាំ១៦៤១ ។ រាជពង្សាវតារលាវនិយាយថា ស្តេចនេះសោយរាជ្យបាន៥៩ឆ្នាំ ហើយសុគតនៅក្នុងគ្រិស្តសករាជ១៦៩៥ ត្រូវនឹងមហាសករាជ១០៥២ ។

ដើម្បីរារាំងការវិវាទដោយព្រះរៀមផ្សេងៗទៀតរបស់ព្រះអង្គ ដែលមានបំណងចង់ទម្លាក់ព្រះអង្គ ចេញពីរាជបល្ល័ង្ក ទ្រង់បាននិរទេសព្រះរៀមទាំងអស់នោះទៅក្រៅប្រទេស ។ មានព្រះរៀមមួយអង្គបានភៀសខ្លួនទៅគង់នៅឯរាជធានីវេ ហើយសុគតនៅទីនោះទៅ ដោយបន្សល់ទុកបុត្រា៣អង្គ ។

ស្តេចដែលឡើងសោយរាជ្យបន្តពីព្រះចៅសុរិយាវង្សគឺបុត្រសុណិសារបស់ព្រះអង្គ ព្រះនាមថា ភ្យាច័ន្ទ ដែលត្រូវមេទ័ពម្នាក់ ឈ្មោះថា ភ្យាណាកន ដណ្តើមយករាជបល្ល័ង្កបាន ភ្យាច័ន្ទ ក៏ផឹកថ្នាំពុលសម្លាប់ខ្លួនទៅ ។

នៅពេលនោះ ព្រះភាគិនេយ្យមួយអង្គរបស់ព្រះចៅសុរិយាវង្ស ជាបុត្រារបស់ព្រះរៀមដែលសុគត នៅឯរាជធានីវេ បានយាងមកដល់ស្រុកលាវជាមួយនឹងទ័ពអាណ្ណាមមួយកង ដែលស្តេចអាណ្ណាម ឡេឌុយហ៊ាប ប្រគល់ឲ្យ ។ ព្រះភាគិនេយ្យនោះបានវាយព្រះរាជាថ្មីនៅវៀងច័ន្ទ នុនអធិរាជ ឲ្យបរាជ័យនៅក្នុងការប្រយុទ្ធលើកទី១ ធ្វើឲ្យ នុនអធិរាជ រត់គេចខ្លួនបាត់ទៅ ទើបព្រះភាគិនេយ្យនោះឡើងសោយរាជ្យ នៅក្នុងឆ្នាំ១៦៩៦ ។

ពេលនោះ បុត្រា២អង្គរបស់ព្រះចៅសុរិយាវង្សជាមួយស្រីស្នំម្នាក់ ដែលគ្មានសិទ្ធិឡើងសោយរាជ្យ បាននាំគ្នារត់គេចខ្លួនទៅនៅឯហ្លួងប្រាបាង ដោយខ្លាចព្រះរាជាថ្មីធ្វើបាប ដូចដែលព្រះបិតាខ្លួនធ្លាប់បានធ្វើបាបបិតារបស់ព្រះរាជាថ្មីនោះ កាលពីមុន ។ ព្រះរាជាថ្មីបានចាត់ឲ្យព្រះអនុជរបស់ព្រះអង្គតាមទៅបណ្តេញអ្នកទាំង២ចេញពីហ្លួងប្រាបាង ហើយបានយកទីក្រុងនោះដាក់មកនៅក្នុងការត្រួតត្រារបស់ព្រះអង្គ ។ បងប្អូនទាំង២នាក់បាននាំគ្នារត់ភៀសខ្លួនទៅ ក៏ប៉ុន្តែបានកេណ្ឌទ័ពថៃនៅក្នុងមឿងហ៊្វូ និងថេង រួចវិលត្រលប់មកដណ្តើមយកហ្លួងប្រាបាង បានវិញនៅក្នុងឆ្នាំ១៧០៧ ទើបបងប្អូនម្នាក់ក្នុងចំណោមទាំង២នាក់ ឈ្មោះថា កេបកេត ឡើងសោយរាជ្យនៅទីនោះទៅ ។ ដោយហេតុនោះ ប្រទេសលាវ ដែលពីមុនជារាជាណាចក្រដ៏ធំមួយ លាតសន្ធឹងចាប់ពីក្រោមចំប៉ាសាក់បន្តិចរហូតទៅដល់ព្រំដែនចិន បានត្រូវបែងចែកចេញជា២ ។ ព្រះរាជាណាចក្រទាំង២ មានព្រំដែនរួមគ្នានៅត្រង់ណាមសៀងខាង ប្រហែលត្រង់ខ្សែរយៈទទឹង១៨អង្សាខាងជើង ។

ព្រះចៅកេបកេតដែលសោយរាជ្យនៅហ្លួងប្រាបាង បានប្រើអំណាចបំពាន ក៏ត្រូវប្រជារាស្ត្របណ្តេញចេញពីរាជបល្ល័ង្ក ហើយជ្រើសរើសយកចៅក្រមុំនយ ហៅថានក ជាកូនរបស់ស្តេច១អង្គដែលកាលពីមុនបាននាំប្រជារាស្ត្រនៅសេសសល់ពីការស្លាប់រង្គាលដោយអាសន្នរោគទៅតាំងនៅវៀងច័ន្ទ ។ រាជពង្សាវតារនិយាយថា បានជាគេហៅព្រះរាជាអង្គនេះថានកដូច្នេះ ដោយមកពីព្រះអង្គច្រើនតែអវត្តមាន ។ ចៅនក នេះ បានត្រូវនាម៉ឺនសព្វមុខមន្ត្រី ដកចេញពីរាជបល្ល័ង្កហ្លួងប្រាបាងនៅក្នុងឆ្នាំ១៧២៣ ហើយលើកព្រះឥន្ទ្រសែនអនុជ របស់ចៅកេបកេត ឲ្យឡើងសោយរាជ្យជំនួសវិញ ។

ចៅក្រមុំនយហៅនកបានទៅបួសជាព្រះសង្ឃនៅឯឈៀងម៉ៃ ។ លុះដល់ពួកភូមាចូលលុកលុយស្រុកចៅ

ឈៀងម៉ៃ បានរត់គេចខ្លួនបាត់ទៅព្រោះមិនអាចបញ្ឈប់ទ័ពទប់ទល់នឹងសត្រូវបាន អ្នកស្រុកក៏លើកចៅនក ឲ្យឡើងជាចៅការពារពួកគេវិញ ។

នៅឯហ្លួងប្រាបាង អ្នកដែលឡើងសោយរាជ្យបន្តពីចៅរាជាឥន្ទ្រសែនបរមបពិត្រស្រីខត្តនៈចក្រពត្រារាជាចៅទិន្នារ នៅក្នុងឆ្នាំ១៧៤៩ គឺព្រះរាជបុត្រាពៅរបស់ព្រះអង្គព្រះនាមថា ឥន្ទ្រព្រហ្ម ។ ចៅឥន្ទ្រព្រហ្ម បានត្រូវគេរៀបចំអភិសេកនៅក្នុងឆ្នាំ១៧៥០ ក្រោយពីព្រះអង្គបានប្រយុទ្ធរុញច្រានពួកអាណ្ណាមដែលលើកគ្នាមកវាយឲ្យបរាជ័យដកថយចេញទៅវិញ ព្រោះព្រះអង្គប្រកែកមិនព្រមលើកសួយសារអាករទៅថ្វាយ ។ ព្រះអង្គសោយរាជ្យបានប៉ុន្មានខែ ក៏ដាក់រាជសម្បត្តិថ្វាយព្រះរៀមរបស់ព្រះអង្គ ចៅនុតទីយកុមារវិញ ព្រោះព្រះអង្គយល់ថា រាជសម្បត្តិនេះត្រូវថ្វាយទៅព្រះរៀមទើបសម ។

ព្រះរាជាដែលសោយរាជ្យនៅវៀងច័ន្ទ មិនអាចធ្វើអ្វីប្រឆាំងនឹងការបែងចែកស្រុកជា២នេះបានទេ ព្រោះការប្រកួតប្រជែងគ្នាកើតមានជារឿងរហូត ជាពិសេសនៅពេលដែលគេបកេត និងឥន្ទ្រសែនសោយរាជ្យនៅហ្លួងប្រាបាង ណាមួយមឿងទាំងឡាយ ក៏មិនចង់ចំណុះស្តេចដែលនៅឆ្ងាយផងដែរ ។

នៅក្នុងឆ្នាំ១៧៥៣ ស្តេចនុននៃវៀងច័ន្ទបានចងសម្ព័ន្ធមេត្រីភាពជាមួយស្តេចភូមាដែលសោយរាជ្យនៅអវៈ ហើយបាននាំគ្នាលើកទ័ពមកវាយហ្លួងប្រាបាង ដណ្តើមយករាជធានីបាន ដុតបំផ្លាញខ្ទេចខ្ទី រួចចាប់អ្នកស្រុក ១ម៉ឺននាក់យកទៅជាឈ្លើយ ជាមួយនឹងស្តេចសុរិយាវង្ស ដែលជាព្រះអនុជពៅរបស់ស្តេចទាំង ២អង្គមុន ។ ពេលនោះ ចៅនុត បានភៀសខ្លួនទៅជ្រកកោននៅឯបាងកក ដែលស្តេចក្បាតាកទើបតែមកតាំងនៅ ទុកឲ្យរាជធានីហ្លួងប្រាបាងដែលខូចខាតអស់ជាងពាក់កណ្តាលទៅហើយនោះ ត្រូវអត់អ្នកដឹកនាំអស់ពេល៤ឆ្នាំ ។ បន្ទាប់មក ចៅនុតបានវិលត្រលប់មករៀបចំអំណាចឡើងវិញ សោយរាជ្យបាន២៦ឆ្នាំ រហូតដល់សោយទិវង្គតនៅក្នុងឆ្នាំ ១៧៨៣ ។

ក្នុងចន្លោះពេលនោះ ស្តេចអវៈមានបំណងចង់ដណ្តើមយកទឹកដីមឿងលូ និង មេន របស់ចិនដាក់មកជារបស់ភូមា ក៏ចាត់តាំងស្តេចសុរិយាវង្សរបស់លាវ ឲ្យដឹកនាំទ័ពភូមាមួយកង ជាមួយពួកលាវដែលភូមាបានចាប់ជាឈ្លើយចំនួន៦រយនាក់ទៅផង ។ ចេញផុតពីនគរបានបន្តិច ដោយមិនចង់ធ្វើសង្គ្រាមបម្រើផលប្រយោជន៍ភូមាដែលជាសត្រូវនឹងលាវ ស្តេចសុរិយាវង្សបានទុកទ័ពភូមាចោល ហើយបាននាំជនរួមឈាម ៦រយនាក់ ធ្វើដំណើរមកកាន់ហ្លួងប្រាបាងវិញ ។ ធ្វើដំណើរមកដល់មឿងថេង ព្រះអង្គបានចាត់សេនាឲ្យនាំសារលិខិតទៅថ្វាយចៅនុតជាព្រះរៀមអំពីការភៀសខ្លួនរបស់ព្រះអង្គចេញមក ហើយបានស្នើសុំការអនុញ្ញាតចូលគាល់ ។ ចៅនុត បានសាកសួរមតិសេនាមន្ត្រី ដែលថ្វាយយោបល់ថា ជាមួយនឹងទ័ព៦រយនាក់ដែលស្មោះស្ម័គ្របូរផ្តាច់ជីវិត ព្រះសុរិយា-វង្ស អាចនឹងក្លាយទៅជាគូបដិបក្ខដ៏ប្រកបទៅដោយគ្រោះថ្នាក់ ចៅនុត ក៏ប្រកែកមិនព្រមឲ្យព្រះអនុជយាងចូលមកក្នុងព្រះនគរទេ ។

ដោយត្រូវព្រះវៀមហាមឃាត់មិនឲ្យត្រលប់ចូលនគរដូច្នេះ ចៅសុរិយាវង្ស បានសម្រេចចិត្តធ្វើការសងសឹក ហើយចាប់ផ្ដើមកេណ្ឌទ័ពអាណ្ណាមលាយមួយថៃ រួចបានលួចដឹកនាំចូលក្នុងរាជធានីហ្លួងប្រាបាងយ៉ាងឆាប់រហ័ស ដណ្ដើមយករាជធានីបាននៅវេលាម៉ោង១១យប់ ។ ក៏ប៉ុន្តែចៅសុរិយាវង្សបានសម្រេចចិត្តមិនធ្វើការសងសឹកវិញទេ រួចបានស្បថស្បែចំពោះព្រះវៀមដែលបាននាំរាជវង្សានុវង្សរត់គេចចេញពីនគរបាត់ទៅ ។ ដល់ចៅនុត ត្រលប់មកវិញ សុរិយាវង្ស បានក្លាយទៅជាសេនាមួយដ៏ស្មោះស្ម័គ្ររបស់ព្រះវៀម ។

នៅឆ្នាំ១៧៦៥ ចៅនុតទីយកុមារ ដែលនឿយណាយនឹងរាជសម្បត្តិ ក៏ដាក់រាជ្យថ្វាយ ចៅសុរិយាវង្សអភិសេកជាស្ដេចហ្លួងប្រាបាងតទៅ ។ ចំណែកខ្លួនព្រះអង្គ បានថយទៅគង់នៅថាហូខួយ សង់វាំងមួយនៅទីនោះ ។

ដើម្បីសងសឹកនឹងស្ដេចវៀងច័ន្ទ ដែលបានចងសម្ព័ន្ធមេត្រីភាពជាមួយពួកភូមា មកវាយហ្លួងប្រាបាងកាលពីឆ្នាំ១៧៥៣ ចៅសុរិយាវង្សបានកេណ្ឌទ័ព រួចយាងទៅបោះជំរំនៅពីមុខវៀងច័ន្ទ ។ ស្ដេចវៀងច័ន្ទបានស្រែកសុំជំនួយពីស្ដេចអវៈម្ដងទៀត ស្ដេចអវៈបានដឹកនាំទ័ពមកជួយភ្លាម ដណ្ដើមយកហ្លួងប្រាបាងបាន ហើយដុតបំផ្លាញខ្ទេចខ្ទី រួចទើបបែរទ័ពសំដៅមកវៀងច័ន្ទ ។ សុរិយាវង្ស បានដកទ័ពចេញពីវៀងច័ន្ទ ដែលទ្រង់ឡោមព័ទ្ធអស់ពេល២ខែរួចមកហើយ ដើម្បីបែរក្បាលទៅរកទ័ពភូមាវិញ ។ ក៏ប៉ុន្តែទ័ពខាងវៀងច័ន្ទបានចេញវាយពីខាងក្រោយមកដែរ ទ័ពចៅសុរិយាវង្សត្រូវស្ថិតនៅក្រោមការវាយប្រហារទាំង២ខាង ក៏ត្រូវបរាជ័យ ហើយបង្ខំសុំចរចាសន្តិភាពទៅ (១៧៧១) ។

ប្រាំឆ្នាំក្រោយមក ចៅសុរិយាវង្ស បានចងសម្ព័ន្ធមេត្រីភាពជាមួយនឹងស្ដេចសៀម ដែលកំពុងរងការគាបសង្កត់ពីពួកភូមា (១៧៧៦) ធ្វើឲ្យប្រទេសមានសន្តិភាពរហូតដល់ពេលដែលទ្រង់ចូលទីវង្គត នៅក្នុងឆ្នាំ១៧៩១ ។

ពេលនោះព្រះអនុជបន្ទាប់ គឺចៅអនុរុទ្ធ បានឡើងសោយរាជ្យបន្តមក ព្រះអនុជទី២ ព្រះនាម នក្ខៈ បានឡើងជាព្រះឧបរាជ ហើយព្រះអនុជទី៣ ព្រះនាម មន្ថៈ បានឡើងជាព្រះរាជវង្សា ពោលគឺ ជាប្រធាននៃព្រះរាជវង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រីទាំងឡាយ ។

ចៅអនុរុទ្ធសោយរាជ្យបានប្រហែលជា១ឆ្នាំ នន្ទអាសែន ជាឧបរាជនៅវៀងច័ន្ទបានលើកទ័ពមកឡោមព័ទ្ធហ្លួងប្រាបាង រួចដណ្ដើមយកបាន នៅក្នុងឆ្នាំ១៧៩១នោះ[២០] ។ ពេលនោះ ព្រះអនុរុទ្ធ បានភៀសព្រះកាយទៅគង់នៅឯបាងកក រហូតដល់ពេលដែលមានមន្ត្រីធំ២នាក់ អត់ទ្រាំនឹងភាពអនាធិបតេយ្យនៅក្នុងព្រះរាជាណាចក្រ

[២០] បើតាមរាជពង្សាវតាររៀបរាប់ គេនិយាយថា នន្ទអាសែន វាយយករាជធានីមិនបានទេ តែព្រះអនុជក្សត្រីមួយអង្គរបស់ចៅអនុរុទ្ធ គឺនាងកែវ បានបើកដៃឲ្យ ព្រោះព្រះនាងស្រលាញ់ នន្ទអាសែន ដែលព្រះនាងបានរៀបអាពាហ៍ពិពាហ៍ជាមួយប៉ុន្មានខែក្រោយមក ។

ហ្លួងប្រាបាំងមិនបាន ក៏នាំគ្នាទៅស្នើសុំស្តេចស្រុកចិនឲ្យជួយធ្វើអន្តរាគមន៍ ដើម្បីឲ្យស្តេចសៀមអនុញ្ញាតឲ្យចៅអនុរុទ្ធ វិលត្រលប់មកគ្រប់គ្រងប្រទេសវិញ ។ ស្តេចស្រុកសៀមបានឯកភាពតាមសំណូមពរ ហើយចៅអនុរុទ្ធក៏វិលមកគង់លើរាជបល្ល័ង្កហ្លួងប្រាបាំងជាថ្មីនៅក្នុងឆ្នាំ១៧៩៦ រៀបចំស្រុកឲ្យមានច្បាប់ និងសណ្តាប់ធ្នាប់ ឡើងវិញ ។ ក្រោយពីអវត្តមានពីព្រះនគរអស់ពេលប្រហែល៥ឆ្នាំ ទ្រង់បានសោយរាជ្យម្តងទៀតបាន ២២ឆ្នាំ សរុបទាំងអស់បាន ២៥ឆ្នាំ ហើយទ្រង់សុគតទៅនៅក្នុងឆ្នាំ១៨១៨ ក្នុងព្រះជន្មាយុ ៨២ព្រះវស្សា ។

អស់ពីចៅអនុរុទ្ធទៅ ចៅមន្ថៈ ដែលជាបុត្រាមួយអង្គរបស់ព្រះសុរិយាវង្ស ដែលសុគតនៅក្នុងឆ្នាំ១៧៩១ ហើយដែលត្រូវតែងតាំងជាព្រះរាជវង្សា បានឡើងសោយរាជ្យបន្តនៅហ្លួងប្រាបាំង ។

រាជពង្សាវតារបានរៀបរាប់ថា នៅក្នុងរជ្ជកាលរបស់ចៅមន្ថៈនេះ ប្រទេសជាតិរីកចម្រើន អ្នកស្រុករស់នៅសប្បាយរីករាយ មានសុខសន្តិភាពជាមួយប្រទេសជិតខាង បានប្រហែលជា១០ឆ្នាំ រហូតដល់ឆ្នាំ១៨២៧ ស្រាប់តែស្តេចសៀមនៅបាងកកបានស្នើសុំឲ្យហ្លួងប្រាបាំងចូលរួមទ័ពជាមួយវាយមកលើវៀងច័ន្ទ ។ ក្នុងពេលជាមួយគ្នានោះ ស្តេចវៀងច័ន្ទក៏បានស្នើសុំឲ្យចងសម្ព័ន្ធភាពមួយប្រឆាំងនឹងសៀមវិញដែរ ដែលកំពុងតែរៀបចំកម្លាំងដើម្បីធ្វើសង្គ្រាមកម្ទេចអតីតរាជធានីលាវទាំងស្រុងតែម្តង ។

មូលហេតុដែលធ្វើឲ្យសៀមចង់ធ្វើសង្គ្រាមជាមួយនឹងស្តេចវៀងច័ន្ទនេះ គឺដោយសារស្តេចវៀងច័ន្ទ បានប្រកែកឈប់ទទួលស្គាល់អធិរាជភាពរបស់ស្តេចសៀមតទៅទៀត ។ នៅក្នុងឆ្នាំ១៨២៦ សៀមបានបង្ខំឲ្យស្តេចវៀងច័ន្ទបញ្ជូនមនុស្សកំណែនមួយចំនួន ទៅជួយជីកព្រែកតាឈិននៅឯបាងកក ហើយព្រះរាជបុត្រាស្តេចវៀងច័ន្ទ ជាអ្នកដឹកនាំកម្លាំងទាំងអស់នោះទៅ ។ ពេលនោះមានមន្ត្រីសៀមម្នាក់ដែលមើលការខុសត្រូវលើការដ្ឋាន មិនពេញចិត្តនឹងពួកលាវ និងព្រះរាជបុត្រា បានឲ្យគេចាប់ព្រះរាជបុត្រាមកធ្វើទណ្ឌកម្មវាយនឹងក្តគោ ។ ការដាក់ទណ្ឌកម្មបែបនេះគឺជាការប្រមាថមួយ ដែលធ្វើឲ្យស្តេចវៀងច័ន្ទអត់ទ្រាំទទួលអធិរាជភាពរបស់សៀមតទៅទៀតលែងបាន ទើបទ្រង់សម្រេចឈប់ចំណុះតទៅទៀត ។ គឺដោយហេតុនោះហើយទើបបានជាសៀមប្រកាសសង្គ្រាមឡើង ហើយសត្រូវទាំង២ បានស្រែកសុំជំនួយពីស្តេចហ្លួងប្រាបាំងដូចគ្នា ។

ពេលនោះស្តេចហ្លួងប្រាបាំង មិនកាន់ជើងខាងណាទេ ព្រោះមិនអាចកាត់ស្មានដឹងថា ភាគីខាងណានឹងទទួលជ័យជម្នះ ម្ល៉ោះហើយ ព្រះអង្គមិនចង់ឲ្យជំពាក់ជាប់វិនឡើយ ។

ទ័ពសៀម ដែលដឹកនាំដោយចៅពញាបឌិន ដែលរាជពង្សាវតារសៀមពេលនោះហៅថា ក្សាសុភាវតី បានធ្វើដំណើរទៅដល់វៀងច័ន្ទយ៉ាងរហ័ស វាយកម្លាំងឡោមព័ទ្ធរាជធានីជាប់ក្នុងថ្ងៃដែលទៅដល់នោះ ហើយវាយដណ្តើមយករាជធានីបានក្រោយពីការប្រយុទ្ធដ៏សាហាវមួយ ដែលធ្វើឲ្យទ័ពស្លាប់រង្គាលទាំងសងខាង ។

សៀមបានដុតបំផ្លាញខ្ទេចខ្ទី រហូតទាល់តែថា នៅពេលដែលសៀមដកថយចេញទៅ គ្មានអគារណាមួយដែលសៀមមិនបានបំផ្លាញនោះទេ សូម្បីតែដើមឈើមួយដើម ឬដើមត្នោតមួយដើមក៏គ្មានសេសសល់ដែរ

ព្រោះសៀមមានចេតនាមិនចង់រាជធានីនេះ ងើបឡើងវិញបាន តទៅទៀតឡើយ ។ តាមការនិទានតៗគ្នា គេនិយាយរហូតដល់ទៅថា សៀមហាមមិនឲ្យអ្នកណាមករស់នៅទីនេះទេ បើពុំនោះនឹងត្រូវទទួលទោសប្រហារជីវិត បើដើរឆ្លងកាត់ក៏អាចឈប់សំចតបានត្រឹមតែ១ថ្ងៃប៉ុណ្ណោះ ។ សៀវភៅក្បួនខ្នាតផ្សេងៗ សាស្ត្រាពង្សាវតាររឿងព្រេងនិទាន ច្បាប់ បានត្រូវសៀមដុតបំផ្លាញខ្ទេចខ្ទី ឬនាំយកទៅជាមួយទាំងអស់ ព្រោះសៀមចង់ឲ្យវៀងច័ន្ទរលត់រលាយបាត់ទៅត្រឹមពេលនោះតែម្តង ។

ស្តេចវៀងច័ន្ទព្រះនាម ខួង បានរត់ភៀសព្រះកាយទៅគង់នៅស្រុកអាណ្ណាម រួចទៅគង់នៅសៀងហួង តាមយោបល់ស្តេចអាណ្ណាម ។ ព្រះអង្គបានត្រូវចៅនយ ជាចៅហ្វាយខែត្រសៀងហួងចាប់ប្រគល់ទៅឲ្យសៀម ដោយដាក់ក្នុងទ្រុងដែក បណ្តើរឲ្យអ្នកស្រុកជេរត្មះតិះដៀលនៅតាមទីសាធារណៈ ។ គេនិយាយថា ចៅខួងបានសុគតនៅក្នុងទ្រុងដែកនោះប៉ុន្មានខែក្រោយមក ដោយកំហឹងឈឺចាប់ និងការខ្មាសអៀន ។

នៅក្នុងពេលដែលសៀមព័ទ្ធរាជធានីជាប់ ស្តេចនៅវៀងច័ន្ទគិតថាសៀមពិតជាឈ្នះមិនខាន ទ្រង់ក៏បញ្ជូនទ័ព១កងតូច ចំនួន៣ពាន់នាក់ទៅទប់ទល់ ។ នៅពេលដែលទ័ពសៀមត្រលប់ទៅវិញអស់ ទ័ពដែលបរាជ័យនោះបានរត់ទៅសុំជ្រកកោននឹងស្តេចហ្លួងប្រាបាង ដែលគិតថា ត្រូវតែផ្តល់ជម្រកឲ្យពួកអ្នកដែលបរាជ័យ ម្យ៉ាងទៀតទ្រង់អាចឆ្លៀតយកឱកាសដែលសៀមឈ្នះសង្គ្រាមនេះ ដើម្បីប្រមូលប្រជាជនយកមកដាក់ក្នុងរាជធានីរបស់ព្រះអង្គឲ្យបានកាន់តែច្រើនឡើងថែមទៀត ទើបទ្រង់ព្រមទទួលពួកនោះទៅ ។

ស្តេចសៀមដឹងរឿងនេះខឹងណាស់ ក៏សួរថាហេតុអ្វីក៏ទ្រង់ធ្វើដូច្នេះ ។ ដើម្បីរំងាប់កំហឹងរបស់ស្តេចសៀម ស្តេចលាវ បានបញ្ជូនបុត្រា៤អង្គឲ្យទៅនៅនឹងស្តេចសៀមដើម្បីជាការធានា ។

មុនពេលដែលទ័ពសៀមមកដល់ ដោយស្តេចហ្លួងប្រាបាង ប្រកែកមិនព្រមជួយ ស្តេចវៀងច័ន្ទ បានស្នើសុំជំនួយពីស្តេចអាណ្ណាមវិញ ។ ស្តេចអាណ្ណាមបានបញ្ជូនទ័ព១កងមកជួយ តែទ័ពនោះមកដល់យឺត ក្រោយពេលដែលសៀមដណ្តើមយកបានរួចទៅហើយ ហើយសៀមបានទាំងដកថយចេញទៅវិញទៀតផង ។ ប៉ុន្តែស្តេចអាណ្ណាម មិនយល់ព្រមទទួលស្គាល់ជ័យជម្នះរបស់សៀមទេ ហើយបានប្រកាសសង្គ្រាមជាមួយសៀមតែម្តង ។ សៀមបានបញ្ជូនចៅហ៊្វាបឌិន ឲ្យទៅធ្វើសង្គ្រាមម្តងទៀត ។ ពេលនោះ ទ័ពអាណ្ណាមបានចូលលុកលុយរាជធានីហ្លួងប្រាបាង ដុតបំផ្លាញខ្ទេចខ្ទី ដោយចោទថាស្តេចហ្លួងប្រាបាងចូលដៃចូលជើងជាមួយសៀម នៅក្នុងឆ្នាំ១៨៣៣ ។ ចៅម៉ាំងជាស្តេចនៅហ្លួងប្រាបាង បានសុគតទៅ៣ឆ្នាំក្រោយមក នៅក្នុងឆ្នាំ១៨៣៦ ។

អាណ្ណាម ក៏ចាប់ ចៅនយ ចៅហ្វាយខែត្រសៀងហួង ដែលបានចាប់ស្តេចរបស់ខ្លួនប្រគល់ឲ្យ បឌិន ជាចំណាប់ខ្មាំងផងដែរ ហើយនាំយកទៅរាជធានីវ៉េជាមួយ និងកូនប្រុសទាំង៦នាក់ រួចធ្វើទោសឲ្យអ្នកស្រុកមើលឃើញកុំឲ្យយកតម្រាប់តាម ។ ចៅសាន ជាបងប្អូនជីដូនមួយនឹងចៅនយ បានឡើងកាន់អំណាចបន្ត ក្រោយមកបានក្បត់អាណ្ណាម ដែលលើកខ្លួនឲ្យធ្វើជាចៅហ្វាយខែត្រ ហើយរត់ទៅជ្រកកោននៅឯបាងកកបាត់ទៅ ។

កូនទាំង៦នាក់របស់ ចៅនយ បានត្រូវស្ដេចទូឌឹក ដោះលែងឲ្យមានសេរីភាពមកវិញ នៅក្នុងឆ្នាំ១៨៤៨ ហើយកូនច្បងឈ្មោះ ប៉ូ បានត្រូវសៀមលើកឲ្យឡើងសោយរាជ្យជាស្ដេចនៅវៀងច័ន្ទ ។ ស្ដេចដែលឡើងសោយរាជ្យបន្តពីចៅប៉ូ គឺប្អូនទី៣ ឈ្មោះ ចៅអង្គ ។ ស្ដេចនេះបានសុគតទៅនៅក្នុងសង្គ្រាមជាមួយពួកហូ ដែលចូលលុកលុយទឹកដី ហើយដុតបំផ្លាញទីក្រុងភ្នំនស្ទើរខ្ទេចខ្ទីអស់ ។

នៅសម័យដែលវៀងច័ន្ទត្រូវសៀមវាយយកបាននោះ មានរាជវង្សានុវង្សមួយអង្គធ្វើជាចៅនៅចំប៉ាសាក់ ដែលជានគរសាមន្តរាជមួយរបស់សៀមដែរ ។ ការដែលវៀងច័ន្ទត្រូវរងការបំផ្លិចបំផ្លាញបានធ្វើឲ្យក្សត្រប្រទេសមួយនេះទទួលបាននូវប្រជាជនជាច្រើន ហើយអតីតរាជធានីចំប៉ាសាក់ដែលស្ថិតនៅពីខាងក្រោមបាសាក់សព្វថ្ងៃបន្តិច បានក្លាយទៅជាមជ្ឈមណ្ឌលមួយដ៏សំខាន់ ។ វាហាក់ដូចជាថាព្រះរាជាណាចក្រតូចនេះបានកកើតឡើងដើម្បីស្នងបន្តពីវៀងច័ន្ទ ដែលត្រូវរលត់រលាយបាត់ទៅ ។ តាមពិតទៅ គេអាចនិយាយថាហ្លួងប្រាបាង និងចំប៉ាសាក់បានទាញយកផលប្រយោជន៍ពីការធ្លាក់ចុះនៃរាជធានីវៀងច័ន្ទដ៏ល្អ និងសម្បូរសប្បាយ ។ មុនដំបូង នឹមត្រួតត្រារបស់សៀមមកលើពួកលាវនៅចំប៉ាសាក់ ហាក់ដូចជាមិនសូវធ្ងន់ធ្ងរប៉ុន្មានទេ ចៅរបស់គេនៅរក្សាបាននូវឯករាជ្យមួយចំណែកធំ ។ នឹមត្រួតត្រារបស់សៀមបានរឹតបន្តឹងបន្តិចម្ដងៗ នៅក្រោយបេសកកម្មរបស់ ឌូដាដឺឡាគ្រេ (១៨៦៦-១៨៦៨) រហូតដល់ថាពួកចៅលាវត្រូវឡើងទៅគាល់ស្ដេចសៀមឲ្យបានរឿយៗ បន្ទាប់មកត្រូវផ្ញើជំនូនទៅថ្វាយ ហើយនៅទីបញ្ចប់បង់ពន្ធឲ្យ និងដាក់ព្រះឆាយាល័ក្ខណ៍ស្ដេចសៀមនៅក្នុងសាលសវនាការជាសាធារណៈ ។

ស្ដេចនៅហ្លួងប្រាបាង ក៏ត្រូវសៀមរំខានដែរ ក៏ប៉ុន្តែហាក់ដូចជាមានសិទ្ធិជាអធិរាជនៅលើទឹកដីរបស់ខ្លួនជាង ហើយរក្សាឯករាជ្យបានល្អបង្គួរ ព្រោះគេនៅជិតខាងនឹងរដ្ឋសាន ដែលជាសត្រូវនឹងសៀម ។ ក៏ប៉ុន្តែ គេក៏ត្រូវតែផ្ញើបញ្ញើទៅថ្វាយស្ដេចអាណ្ណាម និងស្ដេចសៀមដែរ បញ្ញើនោះគេចាត់ទុកថា ជាភស្តុតាងនៃមេត្រីភាពតែប៉ុណ្ណោះ មិនមែនជាសួយសារអាករ ដើម្បីបញ្ជាក់ពីភាពចំណុះអ្វីទេ ។

ព្រះរាជាចំប៉ាសាក់ព្រះនាម ម៉ាង មានបុត្រា៧ព្រះអង្គ និងបុត្រី៣ព្រះអង្គ ។ បុត្រារបស់ព្រះអង្គ ៣អង្គបានសោយរាជ្យបន្តពីព្រះអង្គមក គឺបុត្រាទី១ ព្រះនាម សឿម សោយរាជ្យពីឆ្នាំ១៨៣៦ ដល់ឆ្នាំ១៨៥១, បុត្រាទី២ ព្រះនាម ច័ន្ទ សោយរាជ្យពីឆ្នាំ១៨៥១ ដល់ឆ្នាំ១៨៧២ ស្ដេចនេះបានស្វាគមន៍ទទួលទស្សនកិច្ចរបស់លោក មូហូត ដែលទទួលមរណភាពនៅឯហ្លួងប្រាបាងក្នុងខែកុម្ភៈ ឆ្នាំ១៨៦១ រួចបានទទួលលោក ឌូដាដឺឡាគ្រេ និងបេសកជនរបស់គាត់ក្នុងខែមេសា ឆ្នាំ១៨៦៧, បុត្រាទី៣ ព្រះនាម អ៊ុនកាម សុគតនៅក្នុងឆ្នាំ១៨៩៦ ក្នុងព្រះជន្មាយុ ៦០ព្រះវស្សា ។ គឺស្ដេចក្រោយនេះឯង ដែលបានយល់ព្រមទទួលយកអាណាព្យាបាលរបស់បារាំង ក្រោយពីបារាំងបានគ្រប់គ្រងលើត្រើយខាងឆ្វេងទន្លេមេគង្គ ហើយទទួលឲ្យមានរ៉េស៊ីដង់បារាំងម្នាក់ ដើម្បីជួយព្រះអង្គនៅក្នុងការងាររដ្ឋបាល និងជួយនៅក្នុងការធ្វើកំណែទម្រង់ផ្សេងៗ ។ បុត្រារបស់ព្រះអង្គព្រះនាម

ស៊ីសាវង្ស ធ្លាប់បានយាងទៅគង់នៅទីក្រុងប៉ារីសអស់ពេលជាច្រើនឆ្នាំ អាចនិយាយភាសាបារាំងបានល្អ ទ្រង់មានព្រះជន្ម ២១ព្រះវស្សានៅពេលដែលត្រូវគេប្រកាសឲ្យឡើងសោយរាជ្យ ហើយអភិសេកដោយពួកបារាំងនៅចំពោះមុខមហាជនដ៏ច្រើនកុះករដែលរីករាយអបអរសាទរគមន៍ ។ ព្រះអង្គនៅសោយរាជ្យរហូតមកដល់សព្វថ្ងៃនេះ (១៩១១) ក្រោមព្រះនាមថា សម្តេចព្រះចៅស៊ីសាវង្ស ។

ពួកសៀមបានចាត់ទុកខ្លួនគេជាចៅហ្វាយនាយលើស្រុកលាវ តាំងតែពីពេលដែលគេបានដុតបំផ្លាញវៀងច័ន្ទខ្ទេចខ្ទីមក ហើយបានអះអាងថា គេមានសិទ្ធិអធិរាជភាពមកលើពួកចៅទាំងអស់ដែលបែងចែកទឹកដីអតីតព្រះរាជាណាចក្រនេះចែកគ្នាគ្រប់គ្រង ។ នៅពេលដែលបារាំងបង្ហាញដែនទីរបស់គេស្តីអំពីបណ្តាក្សត្រប្រទេសលាវ សៀមបានបញ្ចេញដែនទីព្រះរាជាណាចក្រសៀមមួយមកបង្ហាញវិញ ។ ក៏ប៉ុន្តែបេសកកម្មឌូដាដឺឡាគ្រេ ដែលបានធ្វើដំណើរចេញពីភ្នំពេញ ឡើងតាមទន្លេមេគង្គរហូតទៅដល់ទុងឈួននៅស្រុកចិនពីឆ្នាំ ១៨៦៦ ដល់ឆ្នាំ១៨៦៥[៧១] បានបញ្ជាក់ថាអធិរាជភាពរបស់សៀមនោះ គ្រាន់តែជាការស្រមើស្រមៃ ហើយថាមានតែអនុត្តរភាពរបស់ប្រទេសសៀមប៉ុណ្ណោះដែលស្ថិតនៅ ព្រោះពួកចៅលាវទាំងអស់ មិនដែលបង់ពន្ធដារឬសួយសារអាករអ្វីឲ្យទៅសៀមទេ បានត្រឹមតែជូនការគោរពជាមួយនឹងបាច់ផ្កាធ្វើអំពីមាស ឲ្យទៅចៅនៅបាងកកប៉ុណ្ណោះ ហើយមានក្សត្រប្រទេសលាវជាច្រើនបានគេចរួចផុតពីអនុត្តរភាពរបស់សៀមទៀតផង ដោយអះអាងថា គេស្ថិតនៅក្រោមអនុត្តរភាពរបស់ភូមាទៅវិញ ។

ចាប់ពីត្រឹមឆ្នាំ១៨៨៦មក សៀមបានដាក់ខាហ្លួង ឬភ្នាក់ងាររបស់ស្តេច នៅក្នុងខេត្តសៀមរាប និងស៊ឹង-ត្រែង ហើយបន្តិចក្រោយមកបានរៀបចំប៉ុស្តិ៍យោធានៅលើទឹកដីដែលគេមិនដែលដណ្តើមយកបាន មិនដែលបានកាន់កាប់ ហើយមិនដែលទាំងបានដើរឆ្លងកាត់ផង ទឹកដីទាំងនោះក៏ត្រូវពួកអាណ្ណាម អះអាងដោយគ្មានមូលហេតុថា គេមានអធិរាជភាពមកលើផងដែរ ។ តាមពិតសៀម និងអាណ្ណាមមានបំណងចង់ដណ្តើមយកទឹកដីលាវទាំងអស់ដែលនៅពីខាងកើតទន្លេមេគង្គរហូតទៅដល់ជួរភ្នំអាណ្ណាម ។ ក៏ប៉ុន្តែរដ្ឋាភិបាលបារាំងមិនមានបន្ទែបន្ទន់ទេ គេបានបញ្ជូនកម្លាំងទៅកាន់កាប់ទឹកដីទាំងអស់នោះ ហើយបានបញ្ជាឲ្យបណ្តេញពួកសៀមចេញពីប៉ុស្តិ៍ដែលសៀមបង្កើតឡើងនៅលើត្រើយខាងឆ្វេងរបស់ទន្លេមេគង្គ ។ ពួកសៀមបានប្រកែកមិនព្រមដកថយចេញហើយថែមទាំងបានសម្លាប់អធិការម្នាក់នៃកងល្បាតមូលដ្ឋានរបស់បារាំងទៀតផង ។

សង្គ្រាមបានផ្ទុះឡើងនៅក្នុងខែមីនា ឆ្នាំ១៨៩៣ ។ បារាំងបានបញ្ជូនទ័ពពីសាយហ្គន និងដើរកាត់កម្ពុជាសំដៅទៅកាន់ចំណុចសំខាន់ៗ នៅលើត្រើយខាងឆ្វេងទន្លេមេគង្គភាគខាងត្បូង ចំណែកនៅខាងជើងឯណោះ

---

[៧១] លោក ឌូដាដឺឡាគ្រេ បានស្លាប់នៅទុងឈួននេះ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៨៦៨ ។

ដោយមានការឯកភាពពីស្តេចនៅហ្វូងប្រាបាងផង ភ្នាក់ងាររបស់បារាំងបានពង្រីកអាណាព្យាបាលរបស់ខ្លួន លើទូទាំងប្រទេស ។ បារាំងបានចូលកាន់កាប់ស្ទឹងត្រែងដោយគ្មានខូចខាតអ្វីទាំងអស់រួចឈានទៅកាន់កាប់កោះខោន កោះខុង មឿងមឿន នៅចំពីមុខបាសាក់ សុវណ្ណខេត្រ វៀងច័ន្ទ និងចំណុច២ទៀត នៅចន្លោះវៀងច័ន្ទ និងហ្លួងប្រាបាង ដោយគ្មានបានឃើញមុខសត្រូវបន្តិចណាសោះ ។

ក្នុងពេលជាមួយគ្នានោះ ដើម្បីគាំទ្រដល់ប្រតិបត្តិការឲ្យបានសម្រេចតាមបំណង បារាំងបានបញ្ជូននាវាចម្បាំងឡើងតាមទន្លេមេណាម ទម្លាយរបាំងដែលសៀមរៀបចំរារាំងមិនឲ្យកប៉ាល់ឡើងទៅលើរួច ក្រោមគ្រាប់កាំភ្លើងបាញ់ស្រោចចេញពីបន្ទាយការពាររបស់សៀម រួចឡើងទៅកំភ្លើញបាញ់គ្រាប់ផ្លោងដាក់រាជវាំងបាងកក (ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៨៩៣) ។ ពេលនោះសៀមបានយល់ព្រមចរចា ហើយយល់ព្រមប្រគល់ទឹកដីនៅត្រើយខាងឆ្វេងទន្លេមេគង្គទាំងអស់[២២] ឲ្យបារាំង ព្រមទាំងទឹកដីមួយចំណែករបស់ហ្លួងប្រាបាងនៅត្រើយខាងស្តាំទៀតផង ។

សន្ធិសញ្ញានោះគេចុះហត្ថលេខានៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៨៩៣ ហើយចាប់ពីពេលនោះមកគេបានសើរើកែប្រែ២ដង ដូចដែលខ្ញុំបានជម្រាបពីខាងលើរួចមកហើយ ដោយបានកាត់ខេត្រមលូព្រៃ និងទន្លេរពៅនៅពីខាងត្បូងរាជាណាចក្របាសាក់ និងខេត្រ២ទៀតនៅមាត់ឈូងសមុទ្រសៀម គឺខុង និងត្រាត ឲ្យបារាំង ។ សន្ធិ-សញ្ញាមួយទៀតត្រូវបានចុះហត្ថលេខានៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩០៤ ដែលប្រគល់ខេត្ររបស់រាជាណាចក្របាសាក់ទាំងអស់លើកលែងតែខេត្រ៣ចេញដែលនៅជិតអ៊ូប៊ុនរួមទាំងបាសាក់ផង ទៅឲ្យបារាំងហើយ ។ ដល់មកថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧ មានសន្ធិសញ្ញចុងក្រោយមួយ បានប្រគល់ខេត្របាត់ដំបង មង្គលបុរី សិរីសោភ័ណ និងអង្គរ ឬសៀមរាប ឲ្យបារាំងថែមទៀត ។

ខ្ញុំបានជម្រាបជូនរួចមកហើយ នៅក្នុងកំណត់ត្រាទាក់ទងជាមួយនឹងស្រុកសៀម អំពីផលប៉ះពាល់របស់សន្ធិសញ្ញាទាំងអស់ទៅលើព្រះរាជាណាចក្រពួកថៃ ។ ចំពោះស្រុកលាវវិញ សន្ធិសញ្ញាទាំងអស់នោះមានផលវិបាកធំធេង ជាពិសេសគឺបានអនុញ្ញាតឲ្យមហាណាចក្រលាវភាគខាងត្បូងកកើតឡើងវិញសាជាថ្មីនៅជុំវិញ

[២២] ក្នុងនោះរួមមានទាំងបណ្តាខេត្ររបស់ព្រះរាជាណាចក្របាសាក់ ដែលស្ថិតនៅលើត្រើយខាងឆ្វេងនោះផង ។ អ្វីដែលនៅសេសសល់នៅលើត្រើយខាងស្តាំទន្លេមេគង្គសម្រាប់ព្រះរាជាលាវនោះ គ្មានអ្វីជាសំខាន់ទេ ។ នោះគឺជាកំហុសមួយរបស់បារាំងចំពោះព្រះរាជាមួយអង្គដែលមានសំណូមពរតែមួយ គឺឲ្យបារាំងយកទឹកដីលាវទាំងមូល ដាក់ចូលជារបស់បារាំង ហើយទ្រង់យល់ព្រមទទួលអាណាព្យាបាលរបស់បារាំងដោយសោមនស្ស ព្រោះថា បារាំងបានកាត់យកទឹកដីអស់២ភាគ៣ទៅហើយ តែបារាំងទុកឲ្យព្រះអង្គ ស្ថិតនៅក្នុងកណ្តាប់ដៃរបស់សៀម ទៅវិញ ។ ដល់មកថ្ងៃក្រោយមក ពេលដែលបារាំងបានជួសជុលកំហុសឆ្គងនេះតាមរយៈសន្ធិសញ្ញាខែកុម្ភៈ ឆ្នាំ១៩០៤ ព្រះរាជាបានចូលទិវង្គតបាត់ទៅហើយ ។

អតីតរាជធានីវៀងច័ន្ទ ឲ្យរាជាណាចក្រលាវភាគខាងជើងរស់រានរឹងប៉ឹងឡើងជុំវិញរាជធានីហ្លួងប្រាបាង និងឲ្យបណ្តាអាណាខេត្តរបស់លាវទាំងអស់មើលមកបារាំងឃើញថាជាអាណាព្យាបាលមួយ ដែលបានជួយការពារខ្លួនគេប្រឆាំងនឹងសត្រូវជិតខាង មិនតែប៉ុណ្ណោះបារាំងបានទាំងនាំមកឲ្យគេនូវពាណិជ្ជកម្ម ឧស្សាហកម្ម និងសន្តិសុខដែលអាចឲ្យពួកគេធ្វើដំណើរទៅមុខ ឆ្ពោះទៅរកអារ្យធម៌រីកចម្រើនមួយ ដែលគេមិនអាច និងឈោងចាប់ដោយខ្លួនឯងបាន ។

## ៦- ប៉េហ្គូ ឬ ប្រទេសភូមា

ខ្ញុំបានជម្រាបពីខាងលើរួចមកហើយ ថាពួកមន គាលិង្គ ឬប៉េហ្គាន មានដើមកំណើតហិណ្ឌូ ដែលធ្វើដំណើរមកពីទិសខាងត្បូង បានមកជួបជាមួយពួកម៉ារ៉ាម៉ា មាមម៉ា ឬភូមា មានដើមកំណើតចេញមកពីតំបន់ទីបេ ដែលមកពីទិសខាងជើង នៅលើទឹកដីសុវណ្ណភូមិ ហើយនៅបន្តឈ្លោះគ្នាដណ្តើមទឹកដីភូមាសព្វថ្ងៃនៅឡើយ នៅក្នុងសតវត្សរ៍ទី១៦ ។ ខ្ញុំក៏បានជម្រាបផងដែរថា ពួកប៉េហ្គានបានស្រែកហៅរកជំនួយពីពួកថៃ ឬសៀម ដែលបានមកតាំងទីលំនៅ នៅខាងកើត បង្កើតបានជារដ្ឋសានផ្សេងៗ និងបានមកតាំងទីនៅខាងត្បូងត្រង់ព្រះរាជាណាចក្រសៀមសព្វថ្ងៃ ដោយដណ្តើមយករដ្ឋមនខ្មែរទាំងឡាយ ។ ខ្ញុំសូមនិយាយបន្ថែមបន្តិចទៀតថា ពួកប៉េហ្គាននោះមិនដែលបានស្រែករកជំនួយពីពួកចិន ដែលជាអ្នកជិតខាងនៅខាងជើង ឬក៏ស្រែករកជំនួយ ពីពួកអារ៉ាកាន[២៣] ដែលមានឈាមជ័រប្រហាក់ប្រហែលនឹងពួកភូមាដែរ ហើយជាអ្នកជិតខាងនៅខាងទិសពាយ័ព្យម្តងណាទេ ។ ក៏ប៉ុន្តែពួកនេះមិនតឹងរ៉ឹងជាមួយពួកអឺរ៉ុបទេ និងបានហៅរកពួកនេះជាញឹកញយ ។

នៅក្នុងសតវត្សរ៍ទី១៦ ដោយមានជំនួយពីពួកព័រទុយហ្គេ ពួកភូមាដែលមានរាជធានីនៅអវៈ[២៤] បានច្បាំងឈ្នះពួកប៉េហ្គាន ដណ្តើមយករាជធានីប៉េហ្គូបាន ហើយចាប់តាំងពីនោះមកក៏គិតថាគ្មានអ្វីនឹងមកឈ្លោះដណ្តើម

---

[២៣] ពួកអារ៉ាកាននេះបានដាក់ឈ្មោះខ្លួនឯងថា យ៉េកែន ក៏ប៉ុន្តែឈ្មោះតាមភាសាសំស្ក្រឹតគឺ ឧទ្យាឌី ។ នៅលើផែនទីដែលគូរដោយលោក ដូលេមេ ស្រុកពួកនេះមានឈ្មោះថា ស្រុកពួកអ្នកស៊ីសាច់មនុស្ស pays des anthropophages ហើយគេគិតថាឈ្មោះ អារ៉ាកាននេះ ប្រហែលជាក្លាយចេញមកពីសំស្ក្រឹតថា យក្ស ដែលស៊ីសាច់មនុស្សដែរ ។

បើទោះជាយ៉ាងណាក្តី រដ្ឋអារ៉ាកាន ជារដ្ឋស៊ីវិល័យមួយ សម្បូរសប្បាយ ហើយរាំងពួកនេះល្អត្រចះត្រចង់ នៅពេលដែលលោកគ្រូពេទ្យ ហ្គេធីយ៉េស៊ូតិន បានមកដល់នៅក្នុងឆ្នាំ១៦៦២ និងនៅពេលដែលពួកភូមា ក្រោមរាជ្យស្តេចមិងដារ៉ាហ្សេប្រូ ដណ្តើមយកបាន ហើយដុតបំផ្លាញនៅក្នុងឆ្នាំ១៧៨៣ ។

[២៤] អវៈជារាជធានីរបស់ភូមាអស់កាល៣៦៩ឆ្នាំ ចាប់ពីឆ្នាំ១៣៦៤រហូតដល់ឆ្នាំ១៧៣៣ ។ មុននោះរាជធានីគឺព្រោម ឬប៊ីរ៉ាម៉ា នៅក្នុងសតវត្សរ៍ទី១ និងទី២ រួចប៉ាកាន ក្នុងរយៈកាល១២សតវត្សរ៍ និងប៉ានីយ៉ូ នៅសតវត្សរ៍ទី១៦ ។

យកទៀតទេ នៅភាគខាងត្បូង ។

ភូមាដូចជាមិនបានយកចិត្តទុកដាក់ចំពោះថាមពលរបស់ពួកប៉េហ្គាន ចំពោះកំហឹងឈឺចាប់ ដែលគេបានបង្កឲ្យមានឡើងនៅក្នុងស្រទាប់ប្រជាជនប៉េហ្គានទេ ហើយហាក់ដូចជាភ្លេចថាជ័យជម្នះរបស់គេបានមកពីជំនួយរបស់ពួកអឺរ៉ុប ដែលអាចនឹងទៅស៊ីឈ្នួលអ្នកដទៃផ្សេងផងដែរ ។ ចំណែកពួកប៉េហ្គានវិញ មិនព្រមទទួលស្គាល់បរាជ័យរបស់ខ្លួន មិនពេញចិត្តនឹងការដឹកនាំរបស់ពួកភូមាទេ ។ គេបង្កការបះបោរជាច្រើនលើកច្រើនសា ក៏ប៉ុន្តែហេតុការណ៍ទាំងអស់នោះមុនដំបូងបានត្រឹមតែធ្វើឲ្យពួកភូមាគាស់រំលើងឫសគល់ចោល ហើយនឹងធ្វើឲ្យអម្រែកនឹមត្រួតត្រារបស់ភូមាមកលើស្មារបស់ពួកគេរឹតតែធ្ងន់ឡើងៗប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក្តី គេនៅតែសន្សំចិត្តសង្ឃឹមថា នឹងអាចដណ្តើមយកឯករាជ្យមកវិញបាននៅថ្ងៃណាមួយជាមិនខាន ។

នៅថ្ងៃមួយ ការបះបោរបានពុះកញ្ជ្រោលខ្លាំង រហូតដល់មានអ្នកចូលរួមជាច្រើន កាន់អាវុធប្រឆាំងគ្រប់ដៃ ខែត្រដែលឡា ម៉ាតាបាន តុងហ្គោ និងព្រោម បានងើបឡើងព្រមៗគ្នា មិនតែប៉ុណ្ណោះពួកប៉េហ្គានមានលុយទិញអាវុធល្អៗពីពួកអឺរ៉ុបដែលមកចុះចតនៅនឹងតាមកំពង់ផែនានា ដែលពួកភូមានៅភាគខាងជើងមិនអាចទិញបាន ហើយថែមទាំងជួលពួកហុល្លង់ និងព័រទុយហ្គេដែលរត់ចោលជួរឲ្យជួយច្បាំងគេបានទៀតផង ។ ពេលនោះពួកប៉េហ្គាន មានអាវុធល្អៗជាង ហើយមានមេបញ្ជាការជាពួកនាយទាហានអឺរ៉ុប ប្រសើរជាងពួកភូមា ដែលមានតែមេកោយដែលគោរពព្រះពុទ្ធសាសនា ។ គេរៀបចំបង្កើតជាកងឯកភាពពិសេស រួចហើយគេនាំគ្នាចេញដំណើរប្រកបដោយសេចក្តីអង់អាចក្លាហានទៅវាយឲ្យពួកភូមាបរាជ័យជាច្រើនលើក ទើបនាំគ្នាមកបោះជំរំនៅពីមុខរាជធានីអវៈ ។ ទីបញ្ចប់ អវៈក៏ធ្លាក់ក្នុងកណ្តាប់ដៃពួកប៉េហ្គាន ហើយស្តេចឪ្យុបទីត្រូវគេចាប់បានជាមួយព្រះរាជវង្សានុវង្ស ។ មូលហេតុដែលធ្វើឲ្យមានជ័យជម្នះនេះគឺដោយសារពួកអឺរ៉ុបមានវិន័យល្អជាង អង់អាចក្លាហានជាងចេះជួយគ្នាទៅវិញទៅមកនៅពេលប្រយុទ្ធ មានះរក្សាទីតាំង មិនរត់ចោលគ្នីគ្នា ។ កាលណាគេត្រូវការធ្វើសកម្មភាពខ្លាំងក្លាណាមួយ ដែលមានគ្រោះថ្នាក់អាចត្រូវទាមទារឲ្យធ្វើពលិកម្មកម្លាំងខ្លះ ឬបើសិនជាគេត្រូវការហៅរកជំនួយនៅត្រង់ចំណុចដែលរងការគំរាមណាមួយ គេហៅរកពួកអឺរ៉ុបនោះឯង ។ គេអាចជួលកម្លាំងពួកអឺរ៉ុបនេះបានរាប់រយ ជួនកាលដល់រាប់ពាន់នាក់ ហើយជួនកាលគេប្រទះឃើញពួកនោះស្លាប់នៅក្នុងសមរភូមិដោយមានអាវុធជាប់ក្នុងដៃរហូតដល់ទៅ១-២រយនាក់ ។ ពួកទ័ពអឺរ៉ុបទាំងនោះ ច្រើនតែកាន់កាំភ្លើងធំ តែក៏មានអ្នកកាន់កាំភ្លើងដៃផងដែរ ហើយពេលណាចប់ការប្រយុទ្ធ នៅចន្លោះសង្គ្រាម គេឃើញពួកនោះរៀបចំស្លដែកធ្វើកាំភ្លើង និងគ្រាប់ ។ ជាទូទៅ វត្តមានរបស់ពួកអឺរ៉ុបនៅជាមួយកងទ័ពណាមួយគឺជាមូលហេតុ ដែលធ្វើឲ្យកងទ័ពនោះទទួលបាននូវជ័យជម្នះជាដរាប ។

នៅពេលដែលទទួលបានជ័យជម្នះលើពួកភូមារួច ស្តេចប៊ិញហ្គាដែឡារបស់ប៉េហ្គានក៏រៀបចំដណ្តើមយកទឹកដីភូមា ។ ព្រះអង្គបានផ្លាស់ចៅហ្វាយខែត្រភូមាចេញ ដាក់ចៅហ្វាយខែត្រប៉េហ្គានជំនួស ប្រគល់ទ័ពឲ្យពី

២រយទៅ ៣រយនាក់ ហើយរៀបចំឲ្យយោធភូមិមានគ្នាដល់ទៅ ៥រយនាក់ នៅកាន់កាប់ចំណុចយុទ្ធសាស្ត្រផ្សេងៗ ។ ពេលរៀបចំស្រុកទេសរួចហើយ ទ្រង់បានប្រគល់ការគ្រប់គ្រងលើទឹកដីដែលដណ្តើមបាននេះ (គឺភូមាភាគខាងលើ) ឲ្យទៅព្រះអនុជព្រះនាមអាប៉ូរ៉ាសាទទួលខុសត្រូវ ទើបទ្រង់យាងត្រលប់មកកាន់រាជធានីប៉េហ្គូ វិញ ដោយនាំយកស្តេចជាឈ្លើយសឹកទៅជាមួយផង ។

ក៏ប៉ុន្តែព្រះអង្គឆាប់វិលត្រលប់ទៅវិញលឿនពេក ។ នៅឆ្នាំបន្ទាប់នោះ អាឡោងផ្រា ដែលជាមេភូមិរបស់ភូមាមួយ ស្ថិតនៅត្រើយខាងឆ្វេងទន្លេឥរាវតី មានឈ្មោះថា ម៉ាន់ចាបូ បានងើបបះបោរឡើង លួចសម្លាប់ទ័ពដែលកាន់កាប់ប៉ុស្តិ៍មួយនៅក្បែរនោះ តែបាននិយាយពន្យល់ឲ្យពួកប៉េហ្គាននៅស្ងៀម ហើយបានចាប់ផ្តើមជ្រើសរើសទ័ពដោយសម្ងាត់ រួចលើកគ្នាទៅវាយយករាជធានីអវៈបាន សង្គ្រាមក៏ផ្ទុះឡើង ។ ពេលនោះពួកពាណិជ្ជករបារាំងបានប្រកាសគាំទ្រស្តេចប៉េហ្គូ ចំណែកពួកពាណិជ្ជករអង់គ្លេសនៅលើកោះណេហ្គ្រេ គាំទ្រពួកភូមា ។ ទ័ពទាំងសងខាងក៏ចាប់តាំងរៀបចំបំពាក់កាំភ្លើងឲ្យកម្លាំងរៀងៗខ្លួន ហើយសង្គ្រាមនៅភូមា ដែលមានទ្រង់ទ្រាយធំមួយមិនដែលមានពីមុនមកក៏ចាប់ផ្តើមឡើង ។

ពួកប៉េហ្គានត្រូវបរាជ័យ ភូមាដណ្តើមយករាជធានីបាន ហើយបានចាប់ស្តេចប៉េហ្គាន អារកធ្វើគុតចោលទៅ ។ ភូមាបានរៀបចំព្រះរាជាណាចក្រឡើងវិញ ដោយមានរាជធានីនៅម៉ាន់ចាបូ (១៧៥៧) ។

គេបានលើកអាឡោងផ្រា ដែលបានរំដោះប្រទេសពីពួកប៉េហ្គាន ឲ្យឡើងសោយរាជ្យ ។ ដើម្បីកុំឲ្យពួករាជបុត្ររបស់ស្តេចភូមាពីមុន ដែលរត់គេចខ្លួនទៅនៅឯស្រុកសៀមវិលត្រលប់មកទាមទារយករាជសម្បត្តិវិញ អាឡោងផ្រា បានរៀបចំអន្ទាក់ ចាប់បុត្រាទាំងអស់នោះបាន ហើយសម្លាប់ចោលទៅ ។ នៅពេលដែលរៀបចំពង្រឹងអំណាចរបស់ខ្លួនបានស្រួលបួលរួចហើយ អាឡោងផ្រា ក៏ចាប់ផ្តើមវាតអំណាច ដោយធ្វើសង្គ្រាមជាមួយស្តេចតាវ៉យដែលមានជាតិសាសន៍ដូចគ្នាមុនគេ ព្រោះស្តេចនេះមិនព្រមទទួលស្គាល់អំណាចរបស់ខ្លួន រួចបានវាយយក រ៉ង់ហ្គូន ស៊ីរីយ៉ាំ និងដាឡា ដែលបាននាំគ្នាបះបោរប្រឆាំង ។ អាឡោងផ្រា បានបញ្ជាឲ្យគេសម្លាប់ពួកអង់គ្លេសនៅលើកោះណេហ្គ្រេ ដែលទ្រង់បានចាត់ទុកជាមិត្ត ឬបើហោចណាស់ក៏ជាសម្ព័ន្ធមិត្រដែរ នៅក្នុងខែវិច្ឆិកា ឆ្នាំ ១៧៥៧ ដោយពួកនេះបានលក់អាវុធទៅឲ្យពួកប៉េហ្គាន ។ ព្រះអង្គបានវាយដណ្តើមយកកំពង់ផែ មែរគុយ របស់សៀមនៅលើឆ្នេរសមុទ្របឹងហ្គាល់ ដោយចោទប្រកាន់ថាបានទទួលពួកក្បត់ដែលភៀសខ្លួនមកឲ្យស្នាក់នៅ ធ្វើឲ្យទ្រង់អត់ឱនមិនបាន តាមមកវាយដល់ទីនេះ ។ នៅពេលនោះព្រះអង្គបានឆ្លងកាត់ព្រំដែន ធ្វើដំណើររហូតមកដល់អយុធ្យា ដែលពួកភូមា និងប៉េហ្គាននាំគ្នាហៅថាទ្វារវតី ។ ប៉ុន្តែអាឡោងផ្រាធ្លាក់ខ្លួនឈឺ ២ថ្ងៃក្រោយពេលដែលរៀបចំលេណដ្ឋានការពាររួច ព្រះអង្គក៏ចេញបញ្ជាឲ្យធ្វើដំណើរវិលត្រលប់មកភូមាវិញតាមមាត់សមុទ្រ ។ ទ្រង់បានសុគតទៅនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៧៦០ ក្នុងព្រះជន្មាយុ ៥០ព្រះវស្សា ពីរថ្ងៃ មុននឹងមកដល់ម៉ាតាបាន ។

ព្រះរាជបុត្រាច្បងព្រះនាម ណាំដូហ្សេប្រូវ បានឡើងសោយរាជ្យបន្តពីព្រះអាឡោងផ្រា ក៏ប៉ុន្តែទ្រង់ឡើងសោយរាជ្យមិនទាន់ទាំងបានប៉ុន្មានផង ក៏ត្រូវធ្វើការប្រយុទ្ធទប់ទល់នឹងមេទ័ពម្នាក់ឈ្មោះ នុតទូម ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ ហើយបានដណ្តើមយកទីក្រុងមួយចំនួន ក្នុងនោះមានទាំងអវៈផងដែរ ។ សង្គ្រាមស៊ីវិលបានបន្តអស់ពេល២ឆ្នាំ រហូតដល់ពេលដែលចាប់មេទ័ព នុតទូម សម្លាប់ចោល ហើយដណ្តើមអវៈបានមកវិញ នៅក្នុងឆ្នាំ១៧៦២ ។ ស្តេចណាំដូហ្សេប្រូវ សុគតទៅនៅក្នុងខែមីនា ឆ្នាំ១៧៦៤ ។ ព្រះអនុជរបស់ព្រះអង្គព្រះនាមថា សេិមហ៊្វូអាន ដែលធ្លាប់បះបោរប្រឆាំងនឹងព្រះអង្គម្តងនៅក្នុងឆ្នាំ១៧៦០ បានស្នងរាជ្យបន្តមក ។ សេិមហ៊្វូអាននេះជាមេទ័ពមួយអង្គរបស់ អាឡោងផ្រា នៅពេលដែលវាយយកអយុធ្យា ទ្រង់ក៏ចាប់បន្តគម្រោងការរបស់ព្រះបិតាប្រឆាំងនឹងសៀមឡើងវិញ ។ នៅពេលដែលទ្រង់ចេញដំណើរទៅបង្ក្រាបពួកកាសៃ នៅភាគពាយ័ព្យភូមា កាប់សម្លាប់ ដុតបំផ្លិចបំផ្លាញពួកនេះ ដែលប្រកែកមិនព្រមចំណុះព្រះអង្គ ទ្រង់បានបញ្ជាឲ្យទ័ព២កង ចេញដំណើរទៅសៀម មួយកងទៅតាមទិសខាងជើង មួយកងទៀតទៅពីខាងលិចតាមតាវ៉យ ។ ទ័ពទាំង២កងបានទៅជួបគ្នាវាយសៀម រួចបោះជំរំនៅពីមុខអយុធ្យា ដែលកាលណោះគឺជារាជធានី មួយមានរបងធ្វើពីឥដ្ឋ មានគូទឹកធំមួយព័ទ្ធជុំវិញ និងមានប៉មការពារពីមួយកន្លែងទៅមួយកន្លែងទៀត ។ ភូមា ព័ទ្ធអយុធ្យាអស់ពេល៣ខែ ស្តេចសៀមបានលួចរត់ចេញរួច អយុធ្យាក៏ធ្លាក់ក្នុងកណ្តាប់ដៃភូមា នៅក្នុងឆ្នាំ១៧៦៧ ដែលរងការដុតបំផ្លាញខូចខាតអស់ជាច្រើន ។

ទ័ពភូមាវិលត្រលប់មកពីអយុធ្យាវិញតាមម៉ាតាបាន ដោយបាននាំយកជ័យភណ្ឌជាច្រើនមកជាមួយផងស្រាប់តែលេចឮដំណឹងថាមានទ័ពចិន៥ម៉ឺននាក់ ធ្វើដំណើរចេញពីតាលីហ៊្វូ ដែលជាស្រុកដើមរបស់ពួកថៃ ចូលមកលុកលុយភូមាភាគខាងលើ ។ ស្តេចសេិមហ៊្វូអានបានបញ្ជូនទ័ពមួយកងឲ្យទៅទប់ទល់ជាមួយពួកចិន ។ ទ័ពនេះ ត្រូវបរាជ័យនៅក្នុងការប្រយុទ្ធដំបូង ក៏ប៉ុន្តែបានកាប់សម្លាប់ពួកចិនស្លាប់ស្ទើរគ្មានសល់ម្នាក់ត្រលប់ទៅ យុនណានវិញ នៅក្នុងការប្រយុទ្ធលើកទី២ ។ ទ័ពចិនខ្លះស្លាប់នៅក្នុងពេលប្រយុទ្ធ ខ្លះទៀតត្រូវចាប់បាន ហើយសម្លាប់ចោលក្រោយពេលប្រយុទ្ធ សល់ពីនោះត្រូវចាប់បានជាឈ្លើយហើយនាំយកមកធ្វើជាខ្ញុំ ។ នៅពេលនោះ ភូមាបានលើករាជធានីពីអវៈ មកតាំងនៅឯ អមរបុរ[២៥] វិញ ហើយបាននាំគ្នាជួសជុល ឬកសាងវត្តឡើងវិញ ។

យុគសម័យសន្តិភាពមួយបានបើកទំព័រហើយ ស្រាប់តែពួកភូមា ចង់ដាក់ទណ្ឌកម្មពួកសៀមដែលនៅក្រោមការដឹកនាំរបស់ស្តេចភ្យាតាក ជាកូនសៀមកាត់ចិន ព្រោះមិនគោរពសន្ធិសញ្ញាដែលបានចុះហត្ថលេខាជាមួយគ្នាកាលពីឆ្នាំ១៧៦៧ ។ ភូមាចាប់ផ្តើមចូលលុកលុយអាណាខេត្រភាគខាងលិចរបស់សៀម តែត្រូវបរា-ជ័យ ក៏ដកថយមកម៉ាតាបានវិញដើម្បីរង់ចាំជំនួយ ហើយចង់ជ្រើសរើសទ័ពបន្ថែមនៅនឹងប៉េហ្គូ ។ ពួកប៉េហ្គាន

---

[២៥] អមរបុរៈនេះ ស្ថិតនៅប្រហែលជា៣០គីឡូម៉ែត្រពីខាងជើងអវៈ រាជធានីទាំង២ស្ថិតនៅលើត្រើយខាងឆ្វេងទន្លេឥរ៉ាវតីដូចគ្នា ។

បានបះបោរប្រឆាំង (១៧៧១) ហើយសង្គ្រាមក៏ផ្ទុះឡើង អស់ពេលជាច្រើនឆ្នាំ ។ សង្គ្រាមបានបញ្ចប់ទៅនៅក្នុងឆ្នាំ១៧៧៥ ជាមួយនឹងបរាជ័យរបស់ពួកប៉េហ្កាន ការធ្វើឃាតស្ដេចប៉េហ្កាន ហើយនិងការចេញច្បាប់ដ៏តឹងរ៉ឹងមួយដោយភូមា ។

នៅក្នុងឆ្នាំ១៧៨១ នាម៉ឺនសព្វមុខមន្ត្រីបាននាំគ្នាឃុបឃិតបះបោរប្រឆាំងនឹងស្ដេចភូមាព្រះនាម ចេង-គូសា ដែលកាចសាហាវ ផ្ដាច់ការហើយឆ្កួតហួសហេតុ ដែលទើបតែបានសម្លាប់ព្រះអនុជ និងព្រះអគ្គមហេសី ។ ស្ដេចនេះ បានត្រូវឪពុករបស់ព្រះអគ្គមហេសីធ្វើគុតបាននៅក្នុងព្រះរាជវាំងណាក់ ។ គេក៏លើកបុត្រាទី៤របស់អាឡោងផ្រា ឲ្យឡើងសោយរាជ្យបន្ត ។

នៅពេលនោះ ពួកបារាំង និងអង់គ្លេសដែលមានអគារពាណិជ្ជកម្មនៅទីក្រុងរ៉ង់ហ្គូន កើតការប្រជែងគ្នា ក៏ខិតខំអែបអបព្រះរាជាតែរៀងខ្លួន ។ ទំនាស់នេះបានក្លាយទៅជាកាន់តែស្រួចស្រាល់ឡើង នៅពេលដែលមានបដិវត្តន៍នៅស្រុកបារាំង[២៦] ព្រោះថាអង់គ្លេសពេលនោះមានអំណាចខ្លាំងណាស់នៅឥណ្ឌា ចំណែកឯបារាំងវិញបានបោះបង់ដីដែលដណ្ដើមបានទាំងប៉ុន្មានឲ្យទៅអង់គ្លេសអស់ ដោយមិនអាចរក្សាទុកបាន ហើយមានបំណងចង់មកយកភូមានេះជាជំនួសបឹងហ្កាល់វិញ ។ មុនដំបូងបារាំងបានទទួលការអនុញ្ញាតឲ្យមានអគ្គរាជទូតបណ្ដោះអាសន្នមួយនៅរ៉ង់ហ្គូន រួចឲ្យមានរ៉េស៊ីដង់ម្នាក់ បន្ទាប់មកឲ្យមានកម្លាំងការពាររ៉េស៊ីដង់នោះ ហើយនិងបុព្វសិទ្ធិខ្លះចំពោះពួកពាណិជ្ជករ ។

ពេលនោះ បារាំងជាប់រវល់នឹងរឿងរ៉ាវនៅឯអឺរ៉ុបខ្លាំងណាស់ គ្មានផលប្រយោជន៍អ្វីខ្លាំងក្លា នៅឯចុងបូព៌ាប្រទេស និងមិនអាចមកគាំទ្រការខិតខំប្រឹងប្រែងរបស់ពួកពាណិជ្ជករបារាំង នៅភូមានេះបានទេ ។ ពេលនោះ គេមិនទាន់ស្គាល់បារាំងច្រើនប៉ុន្មានទេនៅភូមា គេស្គាល់បារាំងតែតាមរយៈពួកពាណិជ្ជករមួយចំនួនប៉ុណ្ណោះ ។ ប៉ុន្តែគេស្គាល់អង់គ្លេសច្បាស់ ហើយគេខ្លាចពួកនេះ បារម្ភខ្លាចតែអង់គ្លេសយកភូមាធ្វើដូចជាឥណ្ឌា អ៊ីចឹងដែរ ។ ជម្លោះតូចមួយបានផ្ទុះឡើង តែគេបានសម្រុះសម្រួលគ្នា ដោយប្រគល់ភូមាដែនទឹកឲ្យទៅអង់គ្លេស ដែលរង់ចាំតែឱកាសនេះដោយអន្ទះសាដើម្បីដាក់បញ្ចូលទៅក្នុងអាណាចក្រអង់គ្លេសនៅឥណ្ឌា នៅក្នុងឆ្នាំ១៨២៤ ។ រ៉ង់ហ្គូនបានក្លាយទៅជាទីក្រុងដ៏ធំមួយ និងជារដ្ឋធានីរបស់អ្វីដែលគេបានហៅថាជាភូមាអង់គ្លេស ក្នុងនោះមានទាំងទឹកដីអតីតប៉េហ្គូផងដែរ ហើយនិងឆ្នេរសមុទ្រទាំងអស់នៅចន្លោះជួរភ្នំ និងសមុទ្របឹងហ្កាល់ ចាប់តាំងពីព្រំដែន រដ្ឋអា-ស្សាមរហូតដល់បួរក្រា នៅក្នុងទៀបកោះម៉ាឡាកា ១៨២៦-១៨២៨ ។ គួរកត់សម្គាល់ថា ពួកប៉េហ្កាន ដែលស្អប់ភូមាខ្លាំងណាស់នោះ មិនមានយល់ទាស់អ្វីនឹងឃើញពួកអង់គ្លេសមកកាន់កាប់ទឹកដីរបស់គេ ជំនួសពួកភូមា

[២៦] ពួកអង់គ្លេសភ្លេចហើយថា ពួកគេក៏បានសម្លាប់ស្ដេចគេដែរកាលពីឆ្នាំ១៦៤៨ តែបែរជាចោទបារាំងនៅចំពោះមុខរាជវាំងភូមាថាបារាំងជាពួកអ្នកសម្លាប់ស្ដេចខ្លួនឯង ហើយបានបន្ទោសបារាំងពីរឿងធ្វើគុតស្ដេចល្វីទី១៦ ។

នោះទេ ។

ចាប់ពីពេលនោះមកប្រទេសភូមាដែលមិនមែនជាអង់គ្លេស គ្មានផ្លូវចុះទៅកាន់សមុទ្រទេ ហើយបានចុះខ្សោយ លែងជារដ្ឋមួយសំខាន់ទៀតហើយ នៅតណ្ហចិន ខុសពីភូមាអង់គ្លេសដែលមានការគ្រប់គ្រងល្អ មានសន្តិសុខជាង ហើយស្ថិតនៅឆ្ងាយផុតពីកំហឹងរបស់ពួកអ្នកកាន់អំណាច និងចិត្តសាវ៉ារបស់រាជវាំង ។ មានពួកប៉េហ្កានជាច្រើននាក់ដែលរស់នៅក្នុងភូមាមិនមែនអង់គ្លេស រួមទាំងពួកភូមាខ្លួនឯងផងដែរដែលស្រលាញ់របបគ្រប់គ្រងរបស់អង់គ្លេស បាននាំគ្នារត់មករស់នៅក្នុងទឹកដីភូមាអង់គ្លេស ។ ពាណិជ្ជកម្មស្ទើរតែទាំងអស់របស់ស្រុកអាឡោងជ្រៅ បានប្រព្រឹត្តទៅដោយឆ្លងកាត់ភូមាអង់គ្លេសនេះ ។

ពេលនោះ កិច្ចខិតខំប្រឹងប្រែងរបស់ពួកពាណិជ្ជករបារាំង ដើម្បីទទួលបាននូវទំនុកចិត្តរបស់ស្តេចភូមា បានទទួលលទ្ធផលល្អហើយ ក៏ប៉ុន្តែបារាំងគ្មានច្រកឯណានឹងចូលទៅដល់ខាងត្បូងទេ ណាមួយបារាំងក៏មិនទាន់កាន់កាប់ស្រុកលាវបាននៅឡើយផង ។ ម្យ៉ាងទៀត បារាំងពេលនោះជាប់រវល់ក្នុងការរៀបចំស្រុកខ្លួនឯងដែរ មិនអាចផាកមកលូកដៃក្នុងរឿងរ៉ាវនៅចុងបូព៌ាប្រទេសបានទេ បើមិនទាន់ដោះស្រាយរឿងនៅក្នុងស្រុករួចនោះ ។ ក៏ប៉ុន្តែបារាំងបានចុះហត្ថលេខាលើអនុសញ្ញាពាណិជ្ជកម្មមួយជាមួយភូមា នៅក្នុងថ្ងៃទី២៤ ខែមករា ឆ្នាំ១៨៧៣ អនុ-សញ្ញានោះ អនុញ្ញាតឲ្យបារាំងដាក់ភ្នាក់ងារម្នាក់នៅក្នុងរាជធានីភូមា ។ ក្រោយនោះបន្តិច មានសន្ធិសញ្ញាមួយទៀត ដែលចុះហត្ថលេខាថ្ងៃទី១៥ ខែមករា ឆ្នាំ១៨៨៥ បានមកបំពេញបន្ថែមពីលើអនុសញ្ញាមុនផ្តល់ដោយសេរីភាពច្រើនជាងឲ្យបារាំង ក៏ប៉ុន្តែត្រូវពួកអង់គ្លេសតាមដានត្រួតពិនិត្យជាប់ ។ រដ្ឋាភិបាលវ៉ង់ហ្គូន និងរដ្ឋាភិបាលកាល់គូតា បានទទួលដំណឹងអំពីសន្ធិសញ្ញានេះតាមរយៈកុងស៊ុលអ៊ីតាលី ដែលភ្នាក់ងារបារាំងបានប្រហែសនិយាយប្រាប់ដោយមិនស្មានថា អាចនឹងមានគ្រោះថ្នាក់សោះទេ ក៏ចាប់ផ្តើសកម្មភាពភ្លាម មិនអាចឲ្យរដ្ឋាភិបាលប៉ារីសធ្វើការឆ្លើយតបទាន់ពេលបានឡើយ ព្រោះនៅឆ្ងាយពេក ។ ម្យ៉ាងទៀតពួកអង់គ្លេសដែលបារម្ភខ្លាចតែបារាំងឆ្លៀតយកឱកាសដែលកាន់កាប់ស្រុកលាវ ដើម្បីឈានទៅដណ្តើមយកបណ្តារដ្ឋសាន រួចឈានមកវាតអាណាព្យាបាលលើភូមាថែមទៀតនោះ ក៏ឆ្លៀតយកឱកាសដែលមានព្រឹត្តិការណ៍សាហាវឃោរឃៅ កើតមានឡើងនៅក្នុងរាជវាំង ម៉ាន់ដាឡៃ ដោយចោទថា នោះជាអំពើព្រៃផ្សៃគួរឲ្យស្អប់ខ្ពើមចំពោះឧក្រិដ្ឋកម្មរបស់ស្តេចធេបូ ដែលមិនអាចទទួលយកបាន រួចបានដណ្តើមយកភូមាភាគខាងជើងនៅចុងឆ្នាំ១៨៨៦[២៧] ក្នុងនាមសីលធម៌ដែលបំបាក់មុខ ។

ទីបំផុត អ្វីៗបានកន្លងហួសទៅ ហើយរាជបល្ល័ង្ករបស់ស្តេចចុងក្រោយនៃរាជវង្ស អាឡោងជ្រៅ ដែលបាន

[២៧] គឺអេវ៉េក បារាំងនៅភូមា លោក ប៊ីហ្គង់ដេ ដែលធ្វើជាអ្នកបកប្រែភាសាឲ្យនៅក្នុងកិច្ចចរចា រវាងពួកអង់គ្លេស និងពួកភូមា ហើយបានបម្រើឲ្យផលប្រយោជន៍អង់គ្លេស ។

គ្រប់គ្រងទឹកដីភូមាអស់កាលជាង១៣០ឆ្នាំ ក៏ដួលរលំបាត់ទៅ នៅក្នុងឈាម និងការអាម៉ាស់ ។ ហើយអាណាចក្រអង់គ្លេសនៅឥណ្ឌា ដែលទើបតែដណ្តើមយកអាស្សាម និងអារ៉ាកាន ក៏បានពង្រីកចូលមកក្នុងឥណ្ឌូចិន រហូតដល់ទន្លេមេគង្គភាគខាងលើពីខាងកើត រួមមានដីមួយចំណែកធំរបស់ឧទ្វីបកោះម៉ាឡាកា និងឆ្នេរសមុទ្របីងហ្កាល់ទាំងអស់ ។

## ៧- ពួកអឺរ៉ុបនៅចុងបូព៌ាប្រទេស

យើងបានឃើញនៅក្នុងកំណត់សម្គាល់មុនរួចហើយ ស្តីពីតួនាទីរបស់ពួកអឺរ៉ុបនៅចុងបូព៌ាប្រទេស ជាពិសេស គឺពួកព័រទុយហ្គេ ថាតើពួកនេះបានធ្វើអ្វីខ្លះ ប្រកបដោយថាមពលដូចម្តេច នៅក្នុងសតវត្សរ៍ទី១៥ ចាប់ពីឆ្នាំ១៤៩៨មក ចាប់តាំងពីឈូងសមុទ្រពែក្សរហូតទៅដល់ប្រទេសជប៉ុន ។ យើងបានឃើញកម្លាំងរបស់ពួកព័រទុយហ្គេ ហើយនិងការអង់អាចរបស់គេ រួចឃើញឱនភាពរបស់ពួកនេះនៅក្រោមការវាយប្រហាររបស់ពួកហុល្លង់ ដែលព័រទុយហ្គេបានច្បាំងជាមួយតាំងតែពីនៅឯអឺរ៉ុបឯណោះ ក្រោយពីការដាក់បញ្ចូលប្រទេសព័រទុយហ្កាល់ទៅក្នុងព្រះរាជាណាចក្រអេស្ប៉ាញនៅក្នុងឆ្នាំ១៥៨០ និងការហាមប្រាមរបស់ស្តេចហ្វីលីពទី២មិនឲ្យកប៉ាល់ហុល្លង់ចូលចតនៅតាមកំពង់ផែក្នុងឧបទ្វីប ។ ក៏ប៉ុន្តែមិនមែនមានតែពួកហុល្លង់មួយប៉ុណ្ណោះទេដែលបានមកប្រកួតប្រជែងជាមួយពួកព័រទុយហ្គេនៅចុងបូព៌ាប្រទេសនេះ នៅមានពួកអឺរ៉ុបផ្សេងទៀតជាច្រើន ជាអាទិ៍ គឺពួកអង់គ្លេស ពួកដាណឺម៉ាក់ តាមពិតគឺពួកន័រវើសទេ (តែស្ថិតនៅក្រោមការត្រួតត្រារបស់ដាណឺម៉ាក់) និងពួកបារាំងផងដែរ ដែលបានបញ្ជូននាវាពាណិជ្ជកម្មឲ្យមកស្វែងយល់ពីទឹកដីតាមឆ្នេរសមុទ្រ ដើម្បីចាប់ផ្តើមធ្វើពាណិជ្ជកម្ម ។ ពួកអ្នកមកក្រោយនេះបានសង្កេតឃើញថា ទីកន្លែងសំខាន់ៗបានត្រូវពួកព័រទុយហ្គេកាន់កាប់អស់ហើយ ដោយពួកនេះបានមកដល់តាំងតែពីឆ្នាំ១៤៩៨ម្ល៉េះ ។ ដោយមិនអាចចូលទិញទំនិញ យកមកពីឥណ្ឌានៅក្រុងលីស្បោនបាន ពួកហុល្លង់បានធ្វើដំណើរតាមមករហូតដល់ចុងបូព៌ាប្រទេសនេះ នៅក្នុងឆ្នាំ១៥៩៩ ហើយពិនិត្យឃើញថា ត្រូវតែធ្វើសង្គ្រាមវាយប្រហារទៅលើកប៉ាល់របស់ពួកអេស្ប៉ាញ៉ុល និងព័រទុយហ្គេ ដុតបំផ្លាញទំនិញចោល មិនត្រូវទិញយកទំនិញទាំងអស់នោះទេ[២៨] ។

លទ្ធផលដំបូងៗខាងពាណិជ្ជកម្មរបស់នាវាចម្បាំងនៃបណ្តាប្រទេសអស់នោះ មិនមែនសុទ្ធតែល្អប្រសើរជាទូទៅនោះទេ ព្រោះពួកអ្នកដែលបានមកដល់មុនគេបានកាន់កាប់ទីកន្លែងសំខាន់ៗអស់ហើយ ហើយមានតួនាទី

---

[២៨] វ៉ែរណាល់ និយាយថាពួកហុល្លង់បានចាប់នាវាពាណិជ្ជកម្មរបស់ព័រទុយហ្គេច្រើនជាង៣០០គ្រឿងនៅក្នុងសតវត្សរ៍ទី១៧ ។ គឺដោយហេតុនោះហើយ បានជាហុល្លង់ជំនួសពួកព័រទុយហ្គេនៅស្ទើរគ្រប់ទីកន្លែង ។

មួយក្នុងការបម្រើអ្នកដែលមកដល់ថ្មី ។ ប៉ុន្តែពួកនាយកប៉ាល់ក៏ដូចជាពួកពាណិជ្ជករដែរ គេគិតថា នៅមានកន្លែងសម្រាប់ទាំងអស់គ្នា រកកម្រៃចំណេញច្រើនណាស់ដែលត្រូវប្រមូល ហើយគេមិនទាន់មានគំនិតចង់ដណ្ដើមយកទឹកដីអ្នកស្រុកអាយនៅឡើយទេ លើកលែងតែពួកព័រទុយហ្គាល់មួយ ដែលបានកាន់កាប់កោះហ្គូអា ម៉ាឡាកា និងទីក្រុងសំខាន់ខ្លះទៀត ហើយនិងបានទទួលការអនុញ្ញាតពីពួកចិនឲ្យតាំងទីពេញសិទ្ធិនៅនឹងម៉ាកាវ ក្នុងឆ្នាំ១៥៥៣ ដោយបង់ពន្ធគយឲ្យចិនចំនួនជាប្រាក់៥០០ណែន (ត្រូវជា៤ពាន់ហ្វ្រង់) ក្នុង១ឆ្នាំៗ[២៩] (ព័រទុយហ្គាល់បានមកតាំងនៅលើកោះម៉ាកាវនេះតាំងតែពីឆ្នាំ១៥៣៧ម្ល៉េះ) ។ គេគិតតែពីរឿងបង្កើតរោងចក្រ អគារពាណិជ្ជកម្ម ឬហាងធំៗ ។ នៅទីបញ្ចប់គេយល់ថា ដើម្បីឲ្យបានសម្រេច គេមិនគ្រាន់តែត្រូវបញ្ជូននាវាពាណិជ្ជកម្ម៣-៤គ្រឿង ទៅកាន់ឥណ្ឌាប៉ុណ្ណោះទេ ប៉ុន្តែត្រូវបំពាក់អាវុធឲ្យនាវាទាំងអស់នោះឲ្យទៅជានាវាចម្បាំងផង ហើយបង្កើនឲ្យរឹតតែច្រើន ដើម្បីអាចការពារផ្លូវចេញចូលអឺរ៉ុបបាន ហើយឲ្យរឹតតែច្រើនថែមទៀតនៅឯចុងបូព៌ាប្រទេស ។ កន្លងមកមាននាវាដែលគេរៀបចំដូចខាងលើនេះនៅឯអាំស្ទែរដាំ ឡុង រូអង់ តែមិនមែនជាកងនាវាមួយនោះទេ ។ គឺនៅពេលនោះហើយ ដែលគេបាននាំគ្នាបង្កើតក្រុមហ៊ុនឥណ្ឌាភាគខាងកើតឡើង នៅក្នុងប្រទេសនីមួយៗ មានអ្នកសុំការអនុញ្ញាតពីរដ្ឋាភិបាលឲ្យគេមានសិទ្ធិធ្វើពាណិជ្ជកម្មផ្ដាច់មុខនៅចុងបូព៌ា រួចហើយក៏ធ្វើខ្លួនគេឲ្យទៅជាឯករាជឡើង ។

ចំពោះពួកព័រទុយហ្គាល់វិញ ខុសពីហ្នឹង គឺជានិច្ចជាកាលគេធ្វើនាវាចរ ឬធ្វើពាណិជ្ជកម្មដើម្បីតែស្ដេចរបស់គេប៉ុណ្ណោះ ម្ល៉ោះហើយពាណិជ្ជកម្មត្រូវស្ថិតនៅក្រោមឥទ្ធិពលនយោបាយ ។ យ៉ាងណាមិញគេអាចពិនិត្យមើលឃើញច្បាស់ថា នៅពេលដែលប្រទេសព័រទុយហ្គាល់បានត្រូវដាក់បញ្ចូលទៅក្នុងប្រទេសអេស្ប៉ាញ ដោយពេលនោះ រដ្ឋាភិបាលអេស្ប៉ាញយកចិត្តទុកដាក់ចំពោះតែអាណានិគមដែលគេមាននៅឯអាមេរិកខាងត្បូង និងអាមេរិកកណ្ដាលខ្លាំងជាង គេមិនសូវជាគាំទ្រសកម្មភាពរបស់ពួកព័រទុយហ្គាល់ ដែលទើបតែបានក្លាយមកជាប្រជាជនអេស្ប៉ាញដែរ នៅឯចុងបូព៌ាប្រទេសប៉ុន្មានទេ ។

---

[២៩] ដីដែលចិនសម្បទានឲ្យនៅពេលនោះ មានទំហំប្រហែលជា៣១គីឡូម៉ែត្រក្រឡាតែប៉ុណ្ណោះ ។ ព័រទុយហ្គាល់ត្រូវបង់ពន្ធនេះ រហូតដល់ឆ្នាំ១៨៤៨ ទើបលោកអភិបាល ហ្វ៉េរ៉េរ៉ា ដឺអាម៉ារ៉ាល់ បានប្រកែកឈប់បង់ពន្ធលើបួរដី ដែលខ័ណ្ឌចែកម៉ាកាវ ពីទឹកដីកោះទាំងមូល ដែលចិនដាក់តាំងពីឆ្នាំ១៥៧៣មក ។ ហេតុការណ៍នេះបានធ្វើឲ្យគាត់ស្លាប់ ដោយគេ ធ្វើឃាតនៅក្នុងខែសីហា ឆ្នាំ១៨៤៩ នៅនឹងមាត់ទ្វារចូលទីក្រុង ហើយគេកាត់យកក្បាលទៅកង់តុងទៅ ។ នៅក្នុងឆ្នាំ១៥៨៣ ពួកព័រទុយហ្គាល់បានដាក់ឈ្មោះឲ្យទីក្រុងដែលពួកគេបានកសាងឡើងថា ព័រតូដឺសង់តូណូមេដឺដេអូស រួចក្រោយមកកែថា ស៊ីតាដេដឺសង់តូណូមេដឺដេអូដឺម៉ាកាវ ។

ពួកចិនហៅថា ង៉ាវមេន តាមភាសាគួនហួ និងហ្វូមួន តាមភាសាកង់តុង តែអ្នកស្រុកច្រើនហៅថា អាម៉ាហ្គាវ ។

ក្រុមហ៊ុនឥណ្ឌាភាគខាងកើតមួយដែលកើតមុនគេ គឺជាក្រុមហ៊ុនរបស់ពួកហុល្លង់ បង្កើតឡើងនៅក្នុងឆ្នាំ១៥៩៤ ។ បន្ទាប់មកគឺក្រុមហ៊ុនរបស់អង់គ្លេស បង្កើតនៅក្នុងឆ្នាំ១៥៩៩ ។ ក្រុមហ៊ុនទី៣ជារបស់បារាំងបង្កើតឆ្នាំ១៦០៤ រួចក្រុមហ៊ុនទី៤ជារបស់ដាណឺម៉ាក់ បង្កើតឆ្នាំ១៦១២ ។ បណ្ដាក្រុមហ៊ុនដែលគេបង្កើតឡើងដំបូងៗគេនេះមានអាយុមិនវែងប៉ុន្មានទេ ក្រុមហ៊ុនខ្លះក៏ដួលរលំភ្លាមទៅ ខ្លះទៀតរកបានចំណេញខ្លះតែមិនអាចបែងចែកចំណេញនោះឲ្យសមាជិកភាគហ៊ុនបានឡើយ ។ ក្រុមហ៊ុនភាគច្រើនត្រូវបានក្រុមហ៊ុនដែលកើតឡើងក្រោយៗមកទៀតជំនួសវិញ ។ មកដល់ត្រង់នេះ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនមែនមានបំណងលើកយកប្រវត្តិសាស្ត្ររបស់ក្រុមហ៊ុនផ្សេងៗមករៀបរាប់នោះទេ គឺខ្ញុំគ្រាន់តែចង់ជម្រាបជូនខ្លះៗដើម្បីឲ្យបានដឹងអំពីសកម្មភាពរបស់ក្រុមហ៊ុនទាំងនោះជាទូទៅ និងឲ្យដឹងថាតើគេបានទទួលលទ្ធផលដូចម្ដេចខ្លះ តែប៉ុណ្ណោះ ។

មុនដំបូង ក្រុមហ៊ុនទាំងអស់នោះជាក្រុមហ៊ុនរបស់ពួកពាណិជ្ជករ ហើយភ្នាក់ងាររបស់គេមានឋានៈជាចៅកែ ពាណិជ្ជករ ពាណិជ្ជកររង ឬអ្នករកកម្រៃដើងសា ។ ពួកនេះច្រើនតែសុំដីតិចតួចពីស្ដេចនគរនីមួយៗដើម្បីសង់វាសនៈ អគារពាណិជ្ជកម្ម រោងចក្រ ឬក៏ឃ្លាំងស្ដុកទំនិញតែប៉ុណ្ណោះ ហើយគេបានទាំងយល់ព្រមបង់ពន្ធដារខ្លះៗលើទំនិញដែលគេលក់ដូរនោះទៀតផង ។

មុនដំបូង ក្រុមហ៊ុនរបស់ប្រទេសណាក៏ដូចជារបស់ប្រទេសណាដែរ គេបានចាប់ផ្ដើមឡើងយ៉ាងដូច្នេះ ។ ក៏ប៉ុន្ដែកាលពីពេលដែលមានតែពួកព័រទុយហ្កេប៉ុណ្ណោះនៅចុងបូព៌ាមុនគេ សភាពការណ៍បានធ្វើឲ្យកើតមានហេតុការណ៍ផ្សេង លើសពីការដែលគ្រាន់តែបង្កើតអគារពាណិជ្ជកម្ម និងការធ្វើពាណិជ្ជកម្ម ។ ពួកនេះបានលូកដៃចូលទៅក្នុងផ្ទៃរបស់ប្រទេសនីមួយៗ ផ្ដល់ជំនួយឲ្យទៅស្ដេចម្ខាងច្បាំងប្រឆាំងនឹងស្ដេចម្ខាងទៀតហើយ ទទួលបានដីសម្បទានរឹតតែធំឡើង ជួនកាលទទួលបានទីក្រុងមួយ ឬទឹកដីមួយទាំងមូលតែម្ដង ។ ជួនកាលទៀត ដូចជានៅកាលីគុត កូសាំង ក្រង់កាន័រ កាណាអ័រ ឌីយូជាដើម ពួកនេះទទួលបានដីទំនេរមួយកន្លែងនៅក្បែរទីក្រុងមួយនៅលើនោះពួកគេក៏កសាងបន្ទាយមួយ រួចទីក្រុងថ្មីមួយទៀត ។ ពួកគេបានក្លាយបន្តិចម្ដងៗ ទៅជាមហាអំណាចយោធាមួយ ដែលធ្វើឲ្យស្ដេចស្រុកអាយខ្លបខ្លាច រហូតទាល់តែស្ដេចខ្លះបានទាមទារឲ្យចុះកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរនៅពេលប្រគល់ដីសម្បទានឲ្យថា មិនសង់បន្ទាយទេ ។

នៅពេលដែលពួកហុល្លង់បានបង្ហាញខ្លួនឡើងនៅចុងបូព៌ា របៀបរបបពាណិជ្ជកម្មពីមុនបានផ្លាស់ប្ដូរអស់ទៅហើយ ។ ចាប់តាំងតែពីមានការប្រកួតប្រជែងគ្នាដំបូងម្ល៉េះ គឺចាប់ពីពេលដែលស្ដេចហ្វីលីព ទី២ បានហាមប្រាមមិនឲ្យនាវាហុល្លង់ចូលចតនៅតាមកំពង់ផែរបស់ព័រទុយហ្កេ និងអេស្ប៉ាញ នៅចុងបូព៌ាឯនេះ គេហាក់ដូចជាមានអារម្មណ៍ថា ពួកអឺរ៉ុបដែលមកដល់លែងជាពាណិជ្ជករទៀតហើយ តែមកជាអ្នកដណ្ដើមយកទឹកដីវិញម្ដង ។ គេគិតថាប្រទេសឥណ្ឌាក៏ដូចជាអាំងស៊ុយឡាំង ឥណ្ឌូចិន ចិន និងជប៉ុនផងដែរ នឹងទទួលបាននូវរបៀបរបបធ្វើឲ្យមានអារ្យធម៌ថ្មីមួយ និងទទួលបាននូវការណែនាំឲ្យចូលកាន់សាសនាថ្មីមួយ ហើយមានមហាអំណាចថ្មីមួយមកដល់

ដែលគេមិនដែលស្គាល់ពីមុនមកសោះ ។

នៅកន្លែងខ្លះស្ដេចស្រុកអាយរអ៊ូរទាំថា ពួកព័រទុយហ្គេនេះបានមកធ្វើឲ្យល្អក់កករនៅក្នុងស្រុក ដោយនាំឲ្យអ្នកស្រុកបែរទៅកាន់សាសនាកាតូលិកវិញ មករំខានដល់របររកស៊ីរបស់ពួកពាណិជ្ជករ ដែលកាន់សាសនាមហាម៉ាត់ និងជួនកាល កាន់ជើងគូប្រឆាំងរបស់ខ្លួនគេទៀតផង ។ ស្ដេចទាំងអស់នោះបាននាំគ្នាប្ដឹងទៅពួកហុល្លង់ ដែលទើបតែមកដល់ ដើម្បីឲ្យជួយវាយប្រហារទៅលើពួកព័រទុយហ្គេ ដូចជានៅកាណាអ៊័រ ណាហ្គាប៉ាតាណាំ សាន់តូមេ ជាដើម ។ ជួនកាលគេគ្រាន់តែប្ដឹងឲ្យជួយការពារពីការវាយប្រហាររបស់ពួកព័រទុយហ្គេប៉ុណ្ណោះ ។ ដោយហុល្លង់ និងអេស្ប៉ាញ កំពុងតែច្បាំងគ្នានៅឯអឺរ៉ុប ហើយដោយប្រទេសព័រទុយហ្គាល់បានត្រូវគេដាក់បញ្ចូលទៅក្នុងអេស្ប៉ាញហើយ គេគិតថាវាគឺជាការធម្មតាទេដែលព័រទុយហ្គេ និងហុល្លង់ច្បាំងគ្នានៅចុងបូព៌ានេះ ។ បើសិនជាចង់ដឹងឲ្យបានរឹតតែច្បាស់លាស់ថែមទៀត អំពីទំនាក់ទំនងរវាងហុល្លង់ជាមួយនឹងព័រទុយហ្គេ នាសម័យនោះថាតើហុល្លង់បានផ្ដល់ជំនួយឲ្យស្ដេចស្រុកអាយប្រឆាំងនឹងព័រទុយហ្គេដូចម្ដេច ហើយតើថាពួកព័រទុយហ្គេ បានចងសម្ព័ន្ធមេត្រីភាពជាមួយស្ដេចស្រុកអាយប្រឆាំងនឹងហុល្លង់វិញយ៉ាងដូចម្ដេច ដើម្បីអាចវាយតម្លៃបានថា តើវាបាននាំមកនូវផលអាក្រក់ ដល់ប្រជាជាតិទាំង២ ដូចម្ដេចខ្លះ សូមអញ្ជើញអានសៀវភៅរបស់លោក ហ្គេដេស៊ូតិន ។ ជំនួយ និងចំណងមេត្រីភាពទាំងអស់នោះ មិនមែនសុទ្ធតែបានមកដោយទទេនោះទេ ។ ដើម្បីជាការតបស្នងចំពោះជំនួយរបស់ពួកបរទេស ស្ដេចស្រុកអាយបានផ្ដល់ដីសម្បទាន ឬទីក្រុងមួយជាថ្នូរ ដីសម្បទាន ឬទីក្រុងនោះមិនយូរមិនឆាប់ បានក្លាយទៅជារដ្ឋតូចមួយរបស់ពួកព័រទុយហ្គេ ឬហុល្លង់ ជារដ្ឋសម្រាប់តែពួកបរទេស ដែលក្រោយមកបង្កជាការលំបាកផ្សេងៗ ជៀសមិនរួច ទាមទារឲ្យដោះស្រាយតាមការសម្របសម្រួល ។ ដោយពួកបរទេសនេះមានគ្នាតិច ស្ដេចស្រុកអាយគិតថាគេអាចវាយឲ្យបរាជ័យបាន ដោយកម្លាំងប្រជាជនដ៏ច្រើនលើសលប់របស់គេ ។ ប៉ុន្ដែចំពោះពួកព័រទុយហ្គេឬហុល្លង់វិញ គេគិតថាពួកគេអង់អាចក្លាហាន ហើយមានអាវុធល្អៗជាង និងមានមេបញ្ជាការខ្លាំងពូកែជាង ហើយជាទូទៅពួកអឺរ៉ុបតែងតែចង់ដោះស្រាយ ដោយការប្រយុទ្ធឲ្យសត្រូវបរាជ័យ ជាជាងការចរចាគ្នា ។ កាលណាគេវាយសត្រូវឲ្យបរាជ័យ គេទទួលបានផលច្រើនជាងការចុះសន្ធិសញ្ញា ។ ហើយកាលណាគេវាយដណ្ដើមយកបានទីក្រុងណាមួយ ពួកទាហានតែងតែសប្បាយនឹងធ្វើការបំផ្លិចបំផ្លាញ ប្រមែប្រមូលយកទ្រព្យសម្បត្តិអស់គ្មានសល់ ។

ជួនកាលពួកអឺរ៉ុបមិនបានរង់ចាំឲ្យមានការប្ដឹងតវ៉ា ឬមានការបង្ករឿង ដើម្បីយកលេសនឹងធ្វើការវាយប្រហារទៅលើប្រទេសមួយ ហើយដណ្ដើមយកតែម្ដងនោះទេ ជាក់ស្ដែងដូចជាករណីពួកព័រទុយហ្គេកាលនៅក្រោមការដឹកនាំរបស់អាល់ប៊ុយកែក បានដណ្ដើមយកកោះហ្គូអានៅក្នុងឆ្នាំ១៥១០ រួចម៉ាឡាកាក្នុងឆ្នាំ១៥១១ ជាដើម ។ ការវាយដណ្ដើមយកម៉ាឡាកានេះបានធ្វើឲ្យមានប្រតិកម្មជាខ្លាំងនៅចុងបូព៌ា នេះមិនមែនដោយសារថាម៉ាឡាកានេះ ជាច្រកចេញចូលសំខាន់មួយសម្រាប់នាវាចរនៅលើពិភពលោក ជាចំណុចកណ្ដាលនៃពិភពទាំង៣

គឺពិភពហិណ្ឌូ ពិភពម៉ាឡេ និងពិភពឥណ្ឌូចិន ដែលបន្តរហូតទៅដល់ស្រុកចិនដ៏ធំ ហើយនិងប្រទេសជប៉ុនទៀតផង នោះទេ ក៏ប៉ុន្តែពីព្រោះព័រទុយហ្គេវាយដណ្តើមយកម៉ាឡាកាបានដោយគ្មានជម្លោះ គ្មានមូលហេតុអ្វីសមស្របសោះ ។ អាល់ប៊ុយកែកអាចនឹងពន្យល់បានពីមូលហេតុវាយយកកោះហ្គូអា និងកោះទ្រីណាសេរីម ក៏ប៉ុន្តែគេមិនអាចពន្យល់មូលហេតុនៃការវាយយកម៉ាឡាកាបានទេ បើពុំនោះ គឺដោយសារទីក្រុងនេះមានទីតាំងល្អសំខាន់លេខមួយ មានស្តេច និងប្រជាជនកាន់សាសនាមហាម៉ាត់ ខុសពីព័រទុយហ្គេដែលកាន់សាសនាកាតូលិក ។

ដោយមានទីតាំងរួចហើយនៅហ្គូអា ម៉ាកាវ និងម៉ាឡាកា ពួកព័រទុយហ្គេបានក្លាយទៅជាមហាអំណាចដ៏ខ្លាំងក្លាមួយ ប៉ុន្តែពួកនេះ ត្រូវប្រយុទ្ធតតាំងជាមួយពួកហុល្លង់ដែលទើបតែនឹងដល់ តែបានក្លាយទៅជាមិត្តរបស់ស្តេចស្រុកអាយ ហើយបានចាប់ផ្តើមវាយដណ្តើមយកបន្ទាយផ្សេងៗរបស់ព័រទុយហ្គេនៅឥណ្ឌា និងម៉ាឡាកា ដោយមានការគាំទ្រពីពួកជ្វាផង ។

ពួកព័រទុយហ្គេបានត្រូវគេបណ្តេញចេញពីប្រទេសជប៉ុន ព្រោះពួកនេះគិតគូរតែពីរឿងទាក់ទាញអ្នកស្រុកឲ្យផ្លាស់ប្តូរសាសនាច្រើនជាងការរកស៊ី គិតគូរពីរឿងដណ្តើមយកអំណាចខ្លាំងជាងការដណ្តើមទីផ្សារ និងម្យ៉ាងទៀតព្រោះលោកសង្ឃកាតូលិក និងសាវ័ករបស់គេច្រើនតែជាអ្នកបង្កបញ្ហា មិនមែនជាអ្នកចូលចិត្តសន្តិភាព ។ នៅពេលដែលគេចាប់បន្ទំពួកសេស៊ីត១១៧នាក់ ពួកហ្វ្រង់ស៊ីស្កាំង២២នាក់ និងពួកបព្វជិតព័រទុយហ្គេ២០០នាក់ឲ្យចុះកប៉ាល់ចេញពីជប៉ុនយកទៅដាក់នៅម៉ាកាវនៅក្នុងឆ្នាំ១៦១៧ ពេលនោះនៅក្នុងប្រទេសជប៉ុនមានប្រជាជនចំនួន១លាន៧សែននាក់ដែលបានប្តូរចូលកាន់សាសនាកាតូលិក ។ តាមពិត ពួកជប៉ុន គ្មានបំណងបណ្តេញពួកពាណិជ្ជករព័រទុយហ្គេចេញពីស្រុកទេ ក៏ប៉ុន្តែពួកលោកសង្ឃកាតូលិកបានលួចត្រលប់ចូលមកវិញដោយលាក់កំបាំង ហើយពួកអ្នកដែលបានប្តូរទៅកាន់សាសនាកាតូលិកចំនួនទាំង ១.៧៥០.០០០ នាក់ បាននាំគ្នារំដើបរំជួលឡើង ជាហេតុដែលធ្វើឲ្យគេបណ្តេញចេញទាំងអស់គ្នាទៅ ។ ចំណែកពួកហុល្លង់វិញ ពួកនេះគោរពសាសនាអ្នកស្រុកអាយ មិនរវីរវល់នឹងការទាក់ទាញមនុស្សឲ្យប្តូរចូលកាន់សាសនាកាតូលិកទេ បើទោះជាថាគេជាអ្នកជឿជាក់ក្នុងសាសនាកាតូលិកនេះក៏ដោយ ម្ល៉ោះហើយគេទទួលបានការអនុញ្ញាតឲ្យតាំងទីលំនៅលើកោះហ៊ីរ៉ាដូ (ដេស៊ីម៉ា) នៅចំពីមុខណាហ្កាសាគី ឲ្យបើកអគារពាណិជ្ជកម្ម រកស៊ីនៅទីនោះ ហើយបើរដ្ឋាភិបាលត្រូវការប្រាក់គេឲ្យខ្ចី ។ ក្រោយមក ពួកអង់គ្លេសក៏ទទួលបាននូវបុព្វសិទ្ធិ ដូចគ្នានេះដែរ ហើយចាប់ពីពេលនោះមកពាណិជ្ជកម្មនៅប្រទេសជប៉ុន បានក្លាយទៅជាមុខរបរដ៏ល្អប្រសើរមួយ ។

នៅពេលដែលពួកអង់គ្លេស និងបារាំងចាប់ផ្តើមមានតួនាទីសំខាន់នៅចុងបូព៌ា ពេលនោះពួកព័រទុយហ្គេនៅមានសេសសល់តែទឹកដីបន្តិចបន្តួច ដែលគេកាន់កាប់ពីមុន និងទឹកដីអាណាចក្រឥណ្ឌាខ្លះៗ ប៉ុណ្ណោះ ។ ពេលនោះ ពួកហុល្លង់ដែលបានប្រយុទ្ធនឹងពួកអង់គ្លេសដែលចង់វាតទីនៅលើសមុទ្រចុងបូព៌ាដែរ បានបើកការវាយប្រហារទៅលើនាវារបស់ពួកព័រទុយហ្គេដណ្តើមយកទំនិញ ហើយបានធ្វើនាវាចរនៅពាសពេញអាំងស៊ុយឡាំង

ដណ្តើមយកហ្សាកាតា កូអិន និងបាតាវីយ៉ា នៅក្នុងឆ្នាំ១៦១៨ ។ ពួកបារាំង និងអង់គ្លេស មិនបានរំខានដល់ការងារនេះទេ ហើយគេបានទាំងទះដៃអបអរទៀតផង ចំពោះការដែលហុល្លង់បានបណ្តេញព័រទុយហ្គេចេញពីសិង្ហបុរី ម៉ាឡាកា ប្រជុំកោះប៉ុងហ្វ៊ូឬប៉េស្កាឌ័រនៅក្នុងច្រកកោះហ្វ័រម៉ូស និងជាពិសេសនៅពេលដែលហុល្លង់បានទទួលកោះហ្វ័រម៉ូសពីចិន ជាថ្នូរនឹងកោះប៉េស្កាឌ័រ ។

គឺចេញពីបាតាវីយ៉ា ដែលបានក្លាយទៅជាមូលដ្ឋាននៃទឹកដីដណ្តើមបានទាំងអស់នៅចុងបូព៌ាប្រទេសនេះឯង ដែលនាវាហុល្លង់បានធ្វើដំណើរទៅគ្រប់ទិសទី មានឥណ្ឌា ឥណ្ឌូចិន ជប៉ុន ចិន បញ្ឆោដោយអ្នកដើរកប៉ាល់ពោរពេញទៅដោយសេចក្តីក្លាហាន និងគ្មានការប្រុងប្រយ័ត្នក្នុងអារម្មណ៍ ទៅត្រួតពិនិត្យការរកស៊ីតាមអគារពាណិជ្ជកម្មរបស់គេ ឬដឹកទំនិញទៅមក ពីប្រទេសមួយទៅប្រទេសមួយ ផ្ទេរផ្ទុរចុះឡើងមុននឹងសម្រេចដឹកយកតែរបស់ដែលមានតម្លៃពីចុងបូព៌ាទៅអឺរ៉ុប ដែលលក់ចេញបានតម្លៃយ៉ាងខ្ពស់ ។

នៅពេលដែលពួកព័រទុយហ្គេ និងហុល្លង់អស់ឥទ្ធិពលទៅ បានទុកកន្លែងឲ្យអ្នកក្រោយៗម្តង ម្យ៉ាងគឺដោយសារពួកព័រទុយហ្គេគ្មានកម្លាំងនឹងច្បាំងដណ្តើមតទៅទៀត ឯពួកហុល្លង់វិញគេបានប្រមូលផ្តុំកម្លាំងនៅតែត្រឹមភាគខាងកើត និងខាងត្បូងឧបទ្វីបម៉ាឡេប៉ុណ្ណោះ ពេលនោះប្រជាជនឥណ្ឌាត្រូវប្រឈមមុខជាមួយមហាអំណាចថ្មី២ទៀត គឺបារាំងដែលនៅក្រោមការដឹកនាំរបស់លោក ឌុយផ្លិច និងអង់គ្លេសដែលនៅក្រោមការដឹកនាំរបស់ល័រក្លីវ និងពួកអ្នកបន្តវេនរបស់គាត់ ។ ដោយសារចង់មានអគារពាណិជ្ជកម្ម មានភូមិ ទីក្រុងមានអំណាចដូចព័រទុយហ្គេ ពួកអ្នកមកដល់ថ្មីនេះ ក៏ចាប់អនុវត្តតាមនយោបាយរបស់ពួកព័រទុយហ្គេដែរ ដោយចូលរួមក្នុងសង្គ្រាមរវាងរដ្ឋស្រុកអាយ ធ្វើអន្តរាគមន៍ចូលក្នុងសង្គ្រាមស៊ីវិលរវាងស្តេចរាជវង្សតែមួយ ដែលឈ្លោះដណ្តើមអំណាចគ្នា ។ មុនដំបូង នយោបាយនេះមានបំណងត្រឹមតែដណ្តើមយកទឹកដី នៅក្នុងពេលដែលមានភាពច្របូកច្របល់ និងសង្គ្រាមប៉ុណ្ណោះ ។ ក៏ប៉ុន្តែដល់យូរៗទៅ នយោបាយនេះចេះតែទាក់ទិនឆ្ងាយទៅៗ រហូតដល់ថា ប្រទេសឥណ្ឌាទាំងមូលត្រូវក្លាយទៅជាភ្នក់ភ្លើងឆេះសន្ធោសន្ធៅ ដែលនៅក្នុងនោះ ពួកបារាំង និងពួកអង់គ្លេស ដែលជាសត្រូវនឹងគ្នាស្រេចទៅហើយនៅឯអឺរ៉ុប បានមកជួបគ្នាក្នុងនាមជាគូបដិបក្ខនៅឯឥណ្ឌាវិញ ម្នាក់ៗស្ថិតនៅក្នុងជួរទ័ពរបស់ស្តេចស្រុកអាយប្រឆាំងគ្នា មុនដំបូងគ្រាន់តែជាអ្នកស៊ីឈ្នួលច្បាំងទេ តែក្រោយមក ច្បាំងកាប់សម្លាប់គ្នាដណ្តើមទឹកដីតែម្តង ។

នយោបាយនេះបានធ្វើឲ្យរដ្ឋស្រុកអាយជាច្រើនធ្លាក់ចូលក្នុងដៃបារាំង និងអង់គ្លេស ហើយនៅពេលដែលអាណាចក្រម៉ុងហ្គោលត្រូវដួលរលំបាត់ទៅ ទុកឲ្យពួកមហាសេដ្ឋីបែងចែកទឹកដីគ្នា គេបានចោទសំណួរឡើងថា តើប្រទេសឥណ្ឌានឹងទៅជារបស់បារាំងឬរបស់អង់គ្លេស ។ ទីបញ្ចប់ ឥណ្ឌាក៏បានក្លាយទៅជារបស់អង់គ្លេស ឯពួកបារាំង និងព័រទុយហ្គេនៅមានសល់តែទីក្រុង លំនៅ គេហដ្ឋាន និងទីតាំងដាច់ៗពីគេប៉ុណ្ណោះ នៅលើឧបទ្វីបហិណ្ឌូស្ថាននេះ ។

យើងបានឃើញពីខាងលើរួចហើយ អំពីអំណាចរបស់អាណាចក្រម៉ុងហ្គោល ដែលបាប៊ែរ ត្រូវជាបច្ឆាញាតិរបស់ទីមួខាន់ (តាមែរឡង់) បានបង្កើតឡើងនៅដើមសតវត្សរ៍ទី១៦ នៅពីខាងជើងប្រទេសឥណ្ឌា ។

នៅក្នុងឆ្នាំ១៥២៤ បាប៊ែរបានធ្វើដំណើរឆ្លងកាត់ព្រំដែនចូលទៅវាយពួកប៉ាតង់ដីឡូឌី ដែលសោយរាជ្យនៅទីក្រុងដែលីឲ្យបរាជ័យនៅក្នុងសមរភូមិប៉ានីប៉ាត់ ។ បន្ទាប់មកបាប៊ែរបានវាយពួករាជបុត្រ ដែលបានអះអាងថា ខ្លួនជាពូជពង្សអតីតក្សត្រឥណ្ឌា នៅជិតអាក្រា នៅក្នុងឆ្នាំ១៥២៧ ។ បុត្រារបស់បាប៊ែរឈ្មោះថា ហ៊ូម៉ាយុន បានឡើងកាន់អំណាចបន្តនៅក្នុងឆ្នាំ១៥៣០ ហើយបានបន្តវាយដណ្តើមយកម៉ាល់វ៉ា និងគុជរដ្ឋ (តែត្រូវមេទ័ពអាហ្វហ្គានម្នាក់ទម្លាក់ពីរាជបល្ល័ង្កដណ្តើមយកអំណាច ឆ្នាំ១៥៤១) ក៏រត់ភៀសខ្លួនទៅរស់នៅឯស្រុកពែរ្ស រួចត្រលប់មកសោយរាជ្យវិញនៅក្នុងឆ្នាំ១៥៥៤ ។ ហ៊ូម៉ាយុន បានកសាងរាជវាំងដ៏ល្អនៅក្នុងរាជធានីដែលី ។ បុត្រារបស់បាប៊ែរ ឈ្មោះថា អាក់បារ ដែលគេហៅថាមហាអាក់បារ បានឡើងសោយរាជ្យបន្តពីព្រះបិតាក្នុងជន្មាយុ១៥ព្រះវស្សា នៅក្នុងឆ្នាំ១៥៥៥ ។ អាក់បាបានវាយពួកអាហ្វហ្គានដែលប្រុងចូលលុកលុយឲ្យបរាជ័យ វាយសំណង់នៅក្នុងរាជធានីអាក្រាធ្វើពីឥដ្ឋចោល ហើយសង់បន្ទាយរឹងមាំមានជញ្ជាំងធ្វើអំពីថ្មពណ៌ក្រហម បង្ក្រាបការបះបោររបស់ពួកមេកោយធំៗ ដណ្តើមយកបឹងហ្គាល់នៅពីខាងកើត រួចកាប៊ុល និងកាស្មៀរ ពីខាងពាយ័ព្យ ចាប់បង្ខំប្រជារាស្ត្រឲ្យគោរពច្បាប់ ឲ្យជីកព្រែក កសាងផ្លូវថ្នល់ ហើយបានចេញច្បាប់គ្រប់គ្រងអាណាចក្រប្រកបដោយជោគជ័យ ។ ស្តេចអង្គនេះមានបំណងចង់បង្កើតសាសនាមួយដែលមានការអនុគ្រោះ ច្រើនជាង ក៏ប៉ុន្តែទ្រង់ត្រូវសុគតបាត់ទៅក្រោមការយំសោកស្តាយស្រណោះពីប្រជាជនឥណ្ឌាទាំងមូល ។ ពួកអឺរ៉ុបបានចាត់ទុកអាក់បាថា គឺជាស្តេចម៉ុងហ្គោលមួយអង្គដែលខ្លាំងក្លាជាងគេ ព្រោះថាព្រះអង្គខ្លាំងទាំងនៅក្នុងការធ្វើសង្គ្រាម ខ្លាំងទាំងនៅពេលមានសន្តិភាព ។ មរណភាពរបស់អាក់បាបានធ្វើឲ្យអាណាចក្រម៉ុងហ្គោល ចុះខ្សោយ ។ បុត្រារបស់អាក់បា ដែលធ្លាប់បានបះបោរប្រឆាំងនឹងព្រះអង្គ បានត្រូវកូនៗធ្វើចម្បាំងជាមួយ បង្ខំឲ្យរត់គេចខ្លួនទៅនៅឯឡាហ៊័រ ។ ចៅរបស់អាក់បាឈ្មោះ សាជេហាន ក៏ត្រូវកូនទាំង៤នាក់ ដែលខ្លួនបានកាត់ទឹកដីបែងចែកឲ្យ ហើយធ្វើសង្គ្រាមជាមួយ ហើយត្រូវកូនម្នាក់ឈ្មោះថា អូរែងហ្សេប ដែលមានជ័យជម្នះលើបងប្អូនទាំង៣នាក់ទៀតចាប់បង្ខាំងក្នុងវាំង ហើយឡើងសោយរាជ្យជំនួសវិញ ។ ព្រះរាជាក្រោយនេះ ជាមនុស្សឆ្លាត ហើយក្លាហាន យល់ដឹងអំពីនយោបាយច្រើន គ្មានការសង្កា មានល្បិចបន្តិច តែរស់នៅសាមញ្ញ ។ ទ្រង់មានកិត្តិនាមល្បីល្បាញខ្លាំងណាស់ ក៏ប៉ុន្តែការត្រួតត្រាទៅលើប្រទេសឥណ្ឌារបស់ព្រះអង្គមិនសូវជាស្រួលប៉ុន្មានទេ ។ ដោយកន្លងមកមានការបះបោររបស់រាជបុត្រាប្រឆាំងនឹងព្រះបិតាដូច្នេះ ម្ល៉ោះហើយពួកចៅហ្វាយខេត្រ ស្តេចត្រាញ់ក៏មិនសូវមានស្មារតីចំណុះព្រះរាជាប៉ុន្មានដែរ ។ ហេតុការណ៍នេះបានធ្វើឲ្យអាណាចក្រម៉ុងហ្គោល ត្រូវបែកបាក់ ហើយអូរែងហ្សេបហាក់ដូចជាបានដឹងអំពីរឿងនេះ នៅពេលដែលកូន២នាក់បានចាប់កាន់អាវុធប្រឆាំងនឹងព្រះអង្គ ។ អូរែងហ្សេបបានចាប់កូនទាំង២ដាក់គុក រួចបានឲ្យគេដាក់ថ្នាំពុលឲ្យផឹក ក៏ប៉ុន្តែបន្ទាប់មក ក៏យំសោកសង្រេង ស្តាយ

ស្រណោះក្រោយ រហូតដល់ធ្លាក់ខ្លួនមានជំងឺ ។ ពេលនោះពួកម៉ារ៉ាត់ ពួករាជបុត្រ និងពួកហិណ្ឌូបានងើបបះបោរឡើង ហើយកូនរបស់អូរែងហ្សេបម្នាក់បានចូលដៃជាមួយនឹងពួកម៉ារ៉ាត់ ទៀតផង ក៏ប៉ុន្តែអូរែងហ្សេបបានវាយបំបាក់ពួកបះបោរឲ្យបរាជ័យ ហើយដើម្បីរាំងខ្ទប់ការប្រឆាំងផ្សេងៗ បន្ទូរបន្ថយការមិនពេញចិត្ត និងបង្ហាញឲ្យឃើញថា បណ្ដាការបះបោរ និងសង្គ្រាមស៊ីវិលទាំងអស់នេះ មិនបានធ្វើឲ្យកម្លាំង របស់ព្រះអង្គចុះខ្សោយនោះទ្រង់បានវាយយកវីសៀពួរនៅក្នុងឆ្នាំ១៦៨៧ យកព្រះរាជាណាចក្រហ្គុលកុង នៅ ក្នុងខែកុម្ភៈ ឆ្នាំ១៦៨៨ ។ ព្រះអង្គសុគតនៅខែកុម្ភៈឆ្នាំ១៧០៧ ដែលគ្របដណ្ដប់ទៅដោយជោគជ័យ និងខក្រិដ្ឋកម្ម ។ អូរែងហ្សេបសោយរាជ្យបាន៥០ឆ្នាំនៅលើអាណាចក្រដ៏ធំមួយ ដែលទ្រង់បានដណ្ដើមយករាជាណាចក្រចំនួន ១០ទៀត មកបញ្ចូលបន្ថែម អាណាចក្រនោះលាតសន្ធឹងនៅលើខ្សែរយៈបណ្ដោយ និងខ្សែរយៈទទឹងចម្ងាយ ២៥អង្សា ។ អាណាចក្រដ៏ធំនោះមានប្រជាជន ៦៤លាននាក់ ដែលផ្ដល់ចំណូលច្រើនជាង ១កោដិរូពី ។ ពួកម៉ុងហ្គោលបានចាត់ទុក អូរែងហ្សេប ដូចជា ព្រះដែលហ្មឹងម៉ាត់ ចំពោះអ្នកដទៃក៏ដូចជាចំពោះខ្លួនឯង ហើយមិនញញើតនឹងកាត់អវៈយវៈមួយចោលទេ ដើម្បីផលប្រយោជន៍អាណាចក្រ ។ តែអូរែងហ្សេបបានដាក់ថ្នាំពុលសម្លាប់ឪពុក ក្បត់ពួកសម្ព័ន្ធមិត្រ កាប់សម្លាប់បងប្អូន និងក្មួយ បំពុលកូនទាំង២ និងប្អូនស្រី ដើម្បីតែឋានៈជា អាលែមហ្គួរ មានន័យថាជាអ្នកដណ្ដើមយកលោកសន្និវាសប៉ុណ្ណោះ ។ នៅពេលដែល អូរែងហ្សេប សុគតទៅ មហាណាចក្រពេលនោះបានចុះខ្សោយខ្លាំងណាស់ទៅហើយ ដោយសារតែភាពហ្មឹងម៉ាត់របស់ព្រះអង្គ ដែលធ្វើឲ្យកើតមានការខឹងសម្បាជាច្រើន មានមហិច្ឆតាគ្រប់ទីកន្លែង ។ ចំណងដែលចងភ្ជាប់មហាណាចក្រត្រូវបានរសាយ ហើយការប្រេះស្រាំបានកើតមានឡើងជាទូទៅ ។

កាលពីនៅក្រោមមហាអាក់បារ អាណាចក្រម៉ុងហ្គោលត្រូវបែងចែកចេញជា១៦រដ្ឋាភិបាល ។ មកដល់រជ្ជកាលរបស់អូរែងហ្សេប មាន២១រដ្ឋាភិបាល ក្នុងនោះមានរាជធានី៣ គឺឡាហ៊ រ ដែល្ហី និងអាគ្រា មានប្រជាជនមានជាតិសាសន៍ខុសៗគ្នាចំនួន២០ ។ នៅតាមកំពង់ផែ និងទីក្រុងធំៗ គេបានផ្ដល់ដីសម្បទានតូចតាចទៅឲ្យពួកព័រទុយហ្គេ ហុល្លង់ បារាំង អង់គ្លេស និងដាណឺម៉ាក់ តែដីទាំងអស់នោះមានសារសំខាន់ខាងពាណិជ្ជកម្មខ្លាំងណាស់ ។ កាលនោះ ពួកពាណិជ្ជករអឺរ៉ុបទាំងអស់នោះមិនទាន់បង្កគ្រោះថ្នាក់អ្វីនៅឡើយទេ ព្រោះថា ថ្វីបើមានចម្បាំងរវាងគ្នាឯងនឹងគ្នាឯងក៏ដោយ ក៏ពួកម៉ុងហ្គោលបានត្រួតត្រាពួកបរទេសយ៉ាងតឹងរ៉ឹងបំផុត ។ ប៉ុន្តែអស់ពី អូរែងហ្សេបទៅស្ដេចសោយរាជ្យក្រោយៗមកមិនសូវមានអំណាច ម្ល៉ោះហើយសភាពការណ៍ក៏ប្រែក្រឡាស់អស់ ។

កូន និងចៅរបស់អូរែងហ្សេបបានធ្វើដូចជាជីដូនជីតារបស់គេដែរ គឺឈ្លោះប្រកែកកាប់សម្លាប់គ្នាដណ្ដើមអំណាច បងសម្លាប់ប្អូនកូនសម្លាប់ឪពុក (១៧១៣) រួចប្រព្រឹត្តការសេពសុរា អាភៀន មានស្រីញី ពេលនោះអំណាចរបស់ថ្នាក់កណ្ដាលបានចុះខ្សោយជាខ្លាំង រហូតដល់ថាពួកស្ដេចត្រាញ់ ណាបាប៊ី និងពួកចៅហ្វាយខែត្រ (ស៊ូបាប៊ី) ចាប់ផ្ដើមរើបម្រះគេចខ្លួនចេញពីកាតព្វកិច្ច ពីការបង់ពន្ធដារឲ្យ ។ នៅពេលនោះណាឌៀសា មានសញ្ជាតិ

ពែក្យបានបង្ហាញខ្លួនឡើងប្រៀបបានទៅនឹងគ្រោះចង្រៃ ដុតបំផ្លាញរាជធានីដែលថ្មីខ្ទេចខ្ទីដូចជាមនុស្សព្រៃ (១៧៣៩) មុននឹងដកថយចេញទៅ ។

អាណាចក្របានចាប់បែកបាក់យ៉ាងលឿននៅពេលដែលពួកបារាំង និងអង់គ្លេសចាប់ផ្ដើមសង់បន្ទាយដើម្បីការពារខ្លួនប្រឆាំងនឹងពួកបំបែកខ្លួន ដែលមកយាយីអគារពាណិជ្ជកម្មនៅ កាល់គូតា ចាន់ដែណាហ្គ័រ ។ល ។ បន្ទាប់មកពួកបារាំង និងអង់គ្លេស បានជ្រើសរើសទាហានអឺរ៉ុប បង្កបានជាកងទ័ពតូចមួយសម្រាប់ការពារ ក្រោយមកទៀតរើសទាហានជាអ្នកស្រុកអាយបន្ថែម ជាមួយឌុយផ្លិច (រូចគ្លីវ) ដែលអាចឲ្យគេបើកការប្រយុទ្ធបាន ឬចងសម្ព័ន្ធមេត្រីភាពជាមួយពួកណាបាប៊ី ដែលបះបោរឡើង ។

ក្រោយមកទៀត ការប្រកួតប្រជែងបានកើតមានរវាងពួកបារាំងជាមួយនឹងពួកអង់គ្លេស ហើយសង្គ្រាមរវាងសាសន៍ទាំង២ក៏កើតមានឡើងនៅឥណ្ឌាក៏ដូចនៅអឺរ៉ុបដែរ មានការដុតបំផ្លាញ ការកាប់សម្លាប់ ការក្បត់ស្ដេចស្រុកអាយ ការដណ្ដើមយកដីដោយការប្រយុទ្ធ ដោយកម្លាំង និងដោយទឹកលុយ ពីស្ដេចស្រុកអាយណាដែលមានមហិច្ឆតា ។

ហេតុការណ៍ដែលបានរៀបរាប់ខាងលើនេះ បានប្រព្រឹត្តទៅចាប់តាំងពីពាក់កណ្ដាលសតវត្សរ៍ទី១៨ រហូតដល់សតវត្សរ៍ទី១៩ ក្នុងនោះពួកអង់គ្លេសដណ្ដើមបានទឹកដីលឿនជាង ព្រោះបារាំងរវល់តែជាប់ច្បាំងនៅឯអឺរ៉ុបប្រជារាស្ត្រប្រឆាំងនឹងស្ដេច ម្ល៉ោះហើយរក្សាបានតែទឹកដីបន្តិចបន្តួចនៅឥណ្ឌានេះ គឺសល់តែប៉ុងឌីចេរី ការីកាល់ចាន់ដែណាហ្គ័រ ម៉ាហេ យ៉ាណាអុង និងទីតាំងមួយចំនួនទៀតដែលមិនសូវមានតម្លៃប៉ុណ្ណោះ ។ មកដល់ឆ្នាំ១៩១០ អង់គ្លេសកាន់កាប់ទឹកដីឥណ្ឌាបានចំនួន២ភាគ៣ ចំនួន១ភាគ៣ទៀតមានរ៉េស៊ីដង់តាំងនៅ មានប្រជាជនទាំងអស់ ២៣០លាននាក់ លើប្រជាជនសរុប ២៩០លាននាក់ និង ៦០លាននាក់ទៀត ស្ថិតនៅក្នុងអាណាព្យាបាល ។ ផលចំណូលបានមកពីប្រជាជន ២៣០លាននាក់នេះ មិនតិចជាង ១កោដិហ្វ្រង់ទេ ។

គេអាចនិយាយថាប្រភពដើមនៃមហាអំណាច និងអាណាចក្រដ៏ធំនេះមានដើមកំណើតតាំងពីជំនាន់សាហ្សេហានមកម្ល៉េះ គឺនៅក្នុងឆ្នាំ១៦៤០ តាមរយៈរាជលិខិតមួយដែលអនុញ្ញាតឲ្យអង់គ្លេសធ្វើពាណិជ្ជកម្មនៅក្នុងរដ្ឋម៉ុងហ្គោលទាំងឡាយ ហើយបានប្រគល់ដី៤រ៉ៃនៅស៊ូរ៉ាត់ តែបានដាក់កំហិតថាមិនឲ្យសង់បន្ទាយ ឬដាក់ទាហានទេ ។ ដល់មកឆ្នាំ១៦៨០ គេបានកែសម្រួលព្រះរាជសារនោះដោយអនុញ្ញាតឲ្យអង់គ្លេសមានកម្លាំងការពារចំនួន ៣០នាក់ ។ ក្រោយមក ដីចំនួន ៤រ៉ៃ បានក្លាយទៅជា ១លានម៉ែត្រការ៉េ ហើយកម្លាំងការពារ ៣០នាក់ បានកើនដល់៣សែននាក់ ទៅជាកងទ័ពធំមួយ ។

នៅក្នុងចន្លោះពេលនោះ ឆ្លៀតឱកាសដែលព្រឹត្តិការណ៍នៅអឺរ៉ុបនាចុងសតវត្សរ៍ទី១៨បានដាក់ប្រទេសហុល្លង់នៅក្នុងអនុត្តរភាពរបស់ប្រទេសបារាំង ពួកអង់គ្លេសបានដណ្ដើមយកម៉ាឡាកានៅក្នុងឆ្នាំ១៧៩៥ ។ សូមរំលឹកថាម៉ាឡាកានេះពួកហុល្លង់បានដណ្ដើមយកពីពួកព័រទុយហ្គេនៅក្នុងឆ្នាំ១៦៤១ ហើយពួកព័រទុយហ្គេ បាន

ដណ្ដើមយកពីស្ដេចជ្វាកាន់សាសនាមហាម៉ាត់មួយអង្គនៅក្នុងឆ្នាំ១៥១១ ។

នៅក្នុងឆ្នាំ១៨១៩ អង់គ្លេសបានទិញសិទ្ធិដាក់ទីតាំងនៅលើកោះសិង្ហបុរីពីស៊ុលតង់ម៉ាឡេនៅហ្សូហ៊័រ ត្រង់កន្លែងដែលកាលពីមុនស្ដេចម៉ាឡេមួយអង្គបានកសាងរាជធានីមួយ ដែលក្រោយមកបានក្លាយទៅជាទីប្រជុំជនមួយមានអ្នកស្រុកតែ១៥០នាក់ ប៉ុណ្ណោះ ។ ក្រុមហ៊ុនឥណ្ឌាភាគខាងកើតបានទិញពីស្ដេចម៉ាឡេនោះ យកកោះទាំងមូលតែម្ដងនៅក្នុងឆ្នាំ១៨២៤ ក្នុងតម្លៃ៦ម៉ឺនដុល្លារអេស្ប៉ាញ៉ុល (ប្រហែល៣៣៧.៥០០ ហ្វ្រង់) ដោយបង់ប្រតិលាភប្រចាំឆ្នាំឲ្យ២៤.០០០ដុល្លារ (១៣៥.០០០ហ្វ្រង់) ។ នៅក្នុងឆ្នាំ១៧៩៨ អង់គ្លេស បានទិញខេត្រវែលេស្លីពីព្រះរាជាកេដាហ៍ ហើយបានដាក់ខេត្រនេះភ្ជាប់ទៅនឹងកោះប៉េណាំង ដែលគេដណ្ដើមយកបានពីព្រះរាជាដដែលនោះកាលពីឆ្នាំ១៧៨៦ និងកោះឌិញឌិញ ដែលស្ថិតនៅចម្ងាយ ១០០គីឡូម៉ែត្រ ទៅខាងត្បូងផងដែរ ។ ទីក្រុងជកថោនស្ថិតនៅលើកោះនោះឯង ។ នៅឆ្នាំ១៨២៥ អង់គ្លេសបានហៅទឹកដីដែលរួមមាន សិង្ហបុរី ប៉េណាំង ម៉ាឡាកា និងវែលេស្លីទាំងអស់នេះថាជាស្រុកសេតធីលមិន (ទីតាំងនៅច្រកសមុទ្រ) ហើយដាក់ឲ្យនៅក្រោមការ ត្រួតត្រារបស់អភិបាលមួយរូប អភិបាលនោះចំណុះឲ្យស្ដេចត្រាញ់នៅឥណ្ឌា ។ គួរកត់សម្គាល់ថា នៅពេលដែល អ្វីៗកំពុងតែរៀបរយល្អទៅៗ នៅក្នុងទឹកដីដែលអង់គ្លេសត្រួតត្រានោះ ភាពអនាធិបតេយ្យ បានកើតមានកាន់តែច្រើនឡើងៗដែរ នៅលើទឹកដីពួកស្ដេចស្រុកអាយដែលនៅឯករាជ ។ ម្យ៉ាងទៀត ពួកអង់គ្លេស ពួកម៉ាឡេ និងចិន ក៏បាននាំគ្នាចូលមករស់នៅក្នុងទឹកដីទាំងអស់នោះកាន់តែច្រើនឡើងៗ ធ្វើឲ្យភាពអនាធិបតេយ្យកាន់តែរីករាលដាល ហើយរដ្ឋទាំងអស់នោះក៏ត្រូវខិតបន្តិចម្ដងៗ ទៅរកភាពជាទឹកដីរបស់អង់គ្លេស ។ នៅក្នុងឆ្នាំ១៨៧៤ ដោយយកលេសថា អនាធិបតេយ្យនៅក្នុងបណ្ដារដ្ឋឯករាជទាំងនោះរំខានដល់សណ្ដាប់ធ្នាប់នៅក្នុងទឹកដីដែលខ្លួនកាន់កាប់ អង់គ្លេសបានចាប់ផ្ដើមដាក់កុងស៊ុល ម្នាក់នៅអែបនឹងស្ដេចរដ្ឋឯករាជទាំងអស់នោះ ដំបូងថាធ្វើជាទីប្រឹក្សា បន្ទាប់មកដើម្បីជួយ ហើយនៅទីបញ្ចប់ ដើម្បីដឹកនាំតែម្ដង ។ ពេលនោះ ភ្នាក់ងាររបស់អង់គ្លេសនៅប៉េរ៉ាក់ចង់ធ្វើឲ្យដំណើរការនេះវិវត្តទៅលឿនពេក ក៏ត្រូវអ្នកស្រុកបះបោរប្រឆាំង ហើយចាប់សម្លាប់បាត់ទៅ ។ គ្រោះថ្នាក់នេះមិនបានធ្វើឲ្យអង់គ្លេសរាថយទេ ផ្ទុយទៅវិញ គេបានធ្វើការបង្ក្រាបយ៉ាងតឹងតែង ហើយដំណើរការដណ្ដើមយកទឹកដីចេះតែបន្តទៅមុខទៀត ។ នៅក្នុងឆ្នាំ១៨៩២ បណ្ដារដ្ឋម៉ាឡេ ដែលស្ថិតនៅក្រោមឥទ្ធិពលរបស់អង់គ្លេស បានត្រូវបង្រួបបង្រួមគ្នាជាសហព័ន្ធមួយហៅរដ្ឋម៉ាឡេ នៅក្រោមការត្រួតត្រារបស់អគ្គរ៉េស៊ីដង់អង់គ្លេសម្នាក់ ដែលគ្រាន់តែជាតំណាងរបស់អភិបាល ស្រុកសេតធីលមិនប៉ុណ្ណោះ ។ ពេលនោះប្រទេសសៀមបានធ្វើការកត់សំគាល់ខ្លះៗ ព្រោះបណ្ដារដ្ឋម៉ាឡេ ទាំងអស់នោះ ពីមុនចំណុះសៀម ហើយកំពុងតែស្ថិតនៅក្រោមអនុត្តរភាព និងកិច្ចការពាររបស់សៀមនៅឡើយ ។ ប៉ុន្តែអង់គ្លេសមិនបានអើពើទេ ហើយភាគខាងត្បូងរបស់ម៉ាឡាកាទាំងមូល និងរដ្ឋទាំងអស់ នៅក្នុងតំបន់ក្រោមឥទ្ធិពលអង់គ្លេស បានត្រូវដាក់ឲ្យស្ថិតនៅក្រោមអាណាព្យាបាល ។ ពេលនោះការនាំចូលរបស់ស្រុកទាំងអស់នោះបានកើនឡើង ពី១៦ លានហ្វ្រង់ នៅក្នុងឆ្នាំ១៨៩០

ទៅដល់៥៥លានហ្វ្រង់ នៅក្នុងឆ្នាំ១៩០៧ ហើយការនាំចេញបានកើនពី ១៨លាន ទៅ៨០លាន ក្នុងរយៈពេលដូចគ្នានេះ ។ ចំនួនប្រជាជនបានកើនឡើង ២ដងក្នុងពេល២៥ឆ្នាំ ។

ការដណ្តើមយកដីរបស់អង់គ្លេសនៅមិនទាន់ឈប់ទេ ។ អង់គ្លេសបានទាមទារឲ្យសៀម ប្រគល់រដ្ឋ២នៅលើឆ្នេរសមុទ្រចិន ពីខាងជើងរដ្ឋសហព័ន្ធ គឺទីងកានូ និងកេឡាន់តាន់ ប្រគល់រដ្ឋកេដាហ៍នៅលើឆ្នេរសមុទ្របីងហ្កាល់ និងចំណែកណាមួយរបស់រដ្ឋរ៉ាម៉ាន់ និងប៉ាតានីនៅលើឆ្នេរឈូងសមុទ្រសៀមទៀតផង ។ រដ្ឋទាំង៥នេះពីមុនចំណុះសៀម តែសៀមបានយល់ព្រមប្រគល់ឲ្យតាមការទាមទារ ។ ពួកអង់គ្លេសនៅតែមិនទាន់អស់ចិត្តគេនៅចង់បានខែត្រលីហ្គ័របុ្របានដុងរបស់សៀម ដែលលាតសន្ធឹងពីឈូងសមុទ្រសៀមទៅដល់សមុទ្របីងហ្កាល់ និងរដ្ឋសាមសាមនៅលើបួរដីក្រា ខាងត្បូងព្រំដែនភូមាថែមទៀត ។ អង់គ្លេសទទួលបានដីទាំងអស់នេះ ព្រោះវាចាំបាច់សម្រាប់ការកសាងផ្លូវរថភ្លើងតភ្ជាប់ពីភូមាទៅសិង្ហបុរី ដែលនឹងមានសារសំខាន់យ៉ាងខ្លាំងក្នុងការធ្វើឲ្យតំបន់មានអារ្យធម៌លូតលាស់ ព្រោះម្យ៉ាងទៀត គេនឹងស្តាយក្រោយបើមិនបានធ្វើយ៉ាងនេះទេ ។

ក្នុងចន្លោះពេលនោះ អង់គ្លេសបានយករដ្ឋសារ៉ាវ៉ាក់ និងរដ្ឋសាបា នៅលើកោះប៊័រណេអូ ដាក់បញ្ចូលទៅក្នុងអាណាណិគមរបស់ខ្លួនផងដែរ នៅពេលដែលគេចាត់ទុកកោះដ៏ធំនេះថាស្ថិតនៅក្រោមឥទ្ធិពលរបស់ហុល្លង់ក៏ដោយ ។

សង្គ្រាមជាមួយចិននៅក្នុងឆ្នាំ១៨៣៤បានធ្វើឲ្យអង់គ្លេសទទួលបានកោះហុងកុង នៅត្រង់មាត់ពាមរបស់ទន្លេកង់តុង ហើយសង្គ្រាមនៅក្នុងឆ្នាំ១៨៥៦បានធ្វើឲ្យអង់គ្លេសទទួលបានដីសម្បទាន១កន្លែងនៅស៊ាងហៃ ដែលបារាំង និងអាមេរិកមានដីសម្បទានរួចទៅហើយ ។

សរុបសេចក្តីមក យើងឃើញថាប្រទេសអឺរ៉ុបនីមួយៗសុទ្ធតែបានទទួលចំណែករៀងៗខ្លួននៅក្នុងការបែងទឹកដីដ៏សម្បើមនៅប្រទេសឥណ្ឌា និងចុងបូព៌ាប្រទេសនេះ ។

ពួកព័រទុយហ្គេ ដែលបានបើកអគារពាណិជ្ជកម្មស្ទើរតែគ្រប់ទីកន្លែង បានមកស្គាល់ឆ្នេរសមុទ្ររបស់ពិភពចាស់នេះមុនគេ ធ្វើនាវាចរទៅគ្រប់ទិសទី ស្គាល់ឈ្មោះអ្នកស្រុកទាំងអស់នៅទីនេះនៅពេលដែលគ្មាននរណាម្នាក់នៅអឺរ៉ុបបានស្គាល់ បានកសាងហាងពាណិជ្ជកម្មធំៗមុនគេ ហើយកាន់កាប់ទីក្រុង កោះផ្សេងៗមុនគេ ឥឡូវនេះព័រទុយហ្គេបាត់បង់ទៅវិញចង់អស់ទៅហើយ ។ គេនៅមានសល់តែទីតាំងខ្លះនៅឥណ្ឌា ហ្គូអា ប៉ង់ហ្ស៊ីម ដាម៉ែន ឌីយូ និងវិរាសនៈមួយចំនួនតែប៉ុណ្ណោះ សរុបទាំងអស់គឺមានប្រជាជនប្រហែល ១លាននាក់ ក្នុងនោះមានពួកកូនកាត់រាប់ពាន់នាក់ដែលនៅកាន់សាសនាកាតូលិកដដែល ហើយបន្តវេនជំនួស ធ្វើឲ្យនឹកដល់ពេលដែលគេមានអំណាចកាលពីសតវត្សរ៍ទី១៦ដល់១៨ ។ គេប្រទះមានឃើញបច្ចាញាតិរបស់ពួកព័រទុយហ្គេ ចំនួនតិចតួចនៅសិរីលង្កា ។ ព័រទុយហ្គេនៅរក្សាកោះម៉ាកាវបាន ដែលចិនបានលក់ឲ្យកាលពីឆ្នាំ១៥៦៦ តែកោះនោះសព្វថ្ងៃជាទីក្រុងគ្មានសកម្មភាព គ្មានពាណិជ្ជកម្ម មើលទៅហាក់ដូចជាមានអត្ថិភាពគ្រាន់តែដើម្បីរំលឹកអំណាច និងសេចក្តី

ក្លាហានកាលពីអតីតកាលប៉ុណោះ ។

ពួកហុល្លង់ ក្រោយពីបានធ្វើការប្រយុទ្ធប្រឆាំងនឹងពួកព័រទុយហ្គេ នាសតវត្សរ៍ទី១៧នៅគ្រប់កំពង់ផែទាំងអស់នៅឥណ្ឌា និងសិរីលង្កា ហើយបានឯកភាពជាមួយស្តេចកាន់ឌីបណ្តេញពួកនេះចេញ ហើយតាមពួកព័រទុយហ្គេរហូតទៅដល់អាំងស៊ុយឡាំងដណ្តើមយកម៉ាឡាកា (១៥១០) និងទីតាំង៤កន្លែងរបស់ព័រទុយហ្គេបាន ហើយបានសម្រេចចិត្តកសាងអាណាចក្រអាណានិគមដ៏មានអំណាចមួយនៅទីនោះឡើង ។ ដើម្បីបើកផ្លូវពីសមុទ្រម៉ាឡាកា ទៅឥណ្ឌា មុនដំបូងហុល្លង់បានដណ្តើមយកអាត់ឈីន័រ រួចហើយបានបណ្តេញពួកអង់គ្លេសចេញពីបង់តាំនៅក្នុងឆ្នាំ១៦៨៣ ។ ចាប់ពីសម័យនោះរហូតដល់ពេលដែលបារាំងវាយដណ្តើមយកហុល្លង់ រួចហើយប្រកាសសាធារណរដ្ឋបាតាវឡើង ហុល្លង់ស្ទើរតែគ្មានសង្គ្រាមអ្វីជាមួយជាតិសាសន៍ស្បែកស ដូចគ្នាទៀតទេ គិតតែខិតខំពង្រីកទឹកដីដោយដណ្តើមយកបណ្តាកោះដែលពីមុនជាចំណែករបស់ ម៉ាហ្សាប៉ាហ៊ីត ។

គ្រប់គ្រងកោះជ្វាបានហើយ ពួកហុល្លង់បានដណ្តើមយកចំណែកមួយនៃកោះស៊ូម៉ាត្រា កោះសេឡែប និងកោះតូចៗរាប់រយដែលនៅក្នុងប្រជុំកោះអូស្ត្រាឡាស៊ី ។ នៅឆ្នាំ១៧៩៥ ក្នុងសង្គ្រាមមួយជាមួយបារាំង អង់គ្លេសបានដណ្តើមយកទីតាំងរបស់ហុល្លង់ ដែលបានបង្កើតឡើងនៅចុងខាងត្បូងទ្វីបអាហ្វ្រិកកាលពីឆ្នាំ១៦៥២ និងទឹកដីដែលហុល្លង់កាន់កាប់ទាំងអស់នៅឥណ្ឌា នៅម៉ាឡាកា និងនៅអូស្ត្រាឡាស៊ី ។ អង់គ្លេស បានប្រគល់ទឹកដីទាំងអស់នោះទៅឲ្យហុល្លង់វិញនៅក្នុងឆ្នាំ១៨១៥ ទុកតែម៉ាឡាកា និងជ្រោយចុងអាហ្វ្រិក ដែលគេគិតថានៅមានសារសំខាន់ចំពោះគេ ។

ឥឡូវនេះ អាំងស៊ុយឡាំងឬអូស្ត្រាឡាស៊ីទាំងមូល បានធ្លាក់ចូលទៅក្នុងអំណាចរបស់ហុល្លង់ហើយ គេគ្មានអ្វីនឹងព្រួយបារម្ភពីពួកជាតិសាសន៍ស្បែកសទៀតទេ ព្រោះពួកនោះសុទ្ធតែមានដីរួចទៅហើយនៅចុងបូព៌ាប្រទេសនេះ ហើយមិនចង់ពង្រីកវាតទៅទៀតទេ ។ ហុល្លង់បានរៀបចំអាណាចក្ររបស់គេបានយ៉ាងល្អ ធ្វើឲ្យប្រែក្លាយទៅជាទឹកដីមួយដ៏មានតម្លៃ ។ ចំនួនប្រជាជនបានកើនឡើង៤ដងក្នុងពេលតែ១សតវត្សរ៍ ហើយអាណានិគមហុល្លង់បានប្រាកដខ្លួនឡើងជាទឹកដីមួយដែលមានការគ្រប់គ្រងល្អជាងគេ និងសម្បូរសប្បាយជាងគេ ។

ក្នុងបណ្តាប្រទេសដែលជាម្ចាស់ស្រុកដើមទាំងអស់នៅឥណ្ឌូចិន មានតែស្រុកសៀមមួយប៉ុណ្ណោះ ដែលរក្សាបាននូវឯករាជ្យរបស់ខ្លួន នេះក៏ដោយសារតែការប្រកួតប្រជែងរវាងបារាំង និងអង់គ្លេស ដែលបានឯកភាពគ្នាទុកស្រុកសៀមនេះមួយជាទ្រនាប់នៅចន្លោះទឹកដីទាំងសងខាង ។ ប៉េហ្គូ ភូមា បណ្តារដ្ឋតូចៗមែរគុយ និងតេណាសេរីម មុនដំបូងជារបស់ពួកប៉េហ្កាន រួចជារបស់សៀម ហើយទៅជារបស់ប៉េហ្កានទៀត នៅទីបញ្ចប់ភូមា និងបណ្តារដ្ឋសានទាំងអស់ បានត្រូវក្លាយទៅជាទឹកដីរបស់អង់គ្លេស ។

និយាយពីនគរចាម្ប៉ាវិញ ស្រុកនេះបានត្រូវអាណ្ណាមលេបយកបាត់ទៅហើយ ។

ក៏ប៉ុន្តែអាណ្ណាម ដែលបានលេបយកទឹកដីចាម្ប៉ា ដណ្តើមយកបណ្តាខេត្រភាគខាងត្បូងរបស់កម្ពុជា

ហើយដណ្តើមយកតុងកឹងបាននោះ ក៏ត្រូវបានបារាំងដណ្តើមកាត់យកទឹកដីភាគខាងត្បូងអស់ទៅវិញដែរ រួចហើយទាំងអាណ្ណាមទាំងតុងកឹងក៏ត្រូវដាក់នៅក្រោមអាណាព្យាបាលរបស់បារាំង ថែមទៀត ។

ស្រុកលាវដែលអាណ្ណាម និងសៀមដណ្តើមគ្នា បានក្លាយទៅជាអាណានិគមបារាំងដែរ លើកលែងតែហ្លួងប្រាបាងមួយចេញ ដែលបារាំងយកដាក់ក្រោមអាណាព្យាបាល ។

កម្ពុជាក៏ត្រូវដាក់ក្រោមអាណាព្យាបាលរបស់បារាំង ហើយបារាំងបានទាមទារយកបណ្តាខេត្តមួយចំនួនដែលសៀមបានយកទៅអស់កាលជាង១សតវត្សរ៍មកឲ្យកម្ពុជាវិញ ធ្វើឲ្យវិសាលភាពទឹកដីកម្ពុជាកើនឡើងពាក់កណ្តាល លើសពីកាលដែលបារាំងទើបតែមកដល់ ។

អេស្ប៉ាញនៅបន្តមានទឹកដីនៅបេនដាយ ភាគខាងជើងកោះប៊័រណេអូនៅឡើយ ហើយកាលពីប៉ុន្មានឆ្នាំមុនពួកនេះកាន់កាប់ប្រជុំកោះហ្វីលីពីនទាំងមូល មានរាជធានីនៅម៉ានីល ។ តែក្រោយពីសង្គ្រាមជាមួយអាមេរិក អេស្ប៉ាញបានបាត់បង់ហ្វីលីពីនអស់ទៅ នៅសល់តែបេនដាយមួយប៉ុណ្ណោះ ដែលគ្មានសារសំខាន់អ្វីបន្តិចសោះ នៅចន្លោះសារ៉ាវ៉ាក់ និងសាបា ដែលជាទឹកដីរបស់អង់គ្លេស ។

គឺតាមរយៈព្រឹត្តិការណ៍ដូចបានរៀបរាប់ពីខាងលើទាំងអស់នេះឯង ដែលប្រជាជនស្បែកស មានអារ្យធម៌ជឿនលឿនជាងប្រជាជនអាស៊ីដែលមានអារ្យធម៌នឹងថ្កល់ បានមកដណ្តើមយកទឹកដីធំជាងអឺរ៉ុប ៣ដង តែក្នុងពេលមិនដល់២សតវត្សរ៍ផង ហើយបានមកជួយដាស់ពួកអ្នកស្រុកដែលកំពុងលង់លក់ឲ្យភ្ញាក់រលឹក ស្ទុះស្ទាឡើងវិញក្រោកពីការស្ពឹកស្រពន់ ។ មុនដំបូងពួកនេះមករបៀបជាពាណិជ្ជករ រួចជាអ្នកមកផ្សព្វផ្សាយ ជំនឿសាសនា បន្ទាប់មកបានក្លាយខ្លួនយ៉ាងឆាប់រហ័សទៅជាពួកអ្នកដណ្តើមទឹកដី ហើយនៅចុងបញ្ចប់ ក៏ជាប់ចិត្ត ជាប់ថ្លើមនឹងទឹកដីនោះ ក្លាយខ្លួនទៅជាអ្នកការពារឲ្យទៅវិញ ។ ឥឡូវនេះ ស្ថិតនៅក្រោមកម្លាំងជំរុញមួយដ៏រឹងមាំ ពួកគេបានយល់ច្បាស់ថា គេមានកាតព្វកិច្ចមួយត្រូវបំពេញចំពោះពួកអ្នកស្រុក ដែលគេគ្រប់គ្រង ពួកអ្នកស្រុកទាំងអស់នោះមានសិទ្ធិត្រូវទទួលបាននូវសេរីភាព និងឯករាជភាព ។ ម្ល៉ោះហើយពួកគេក៏ចាប់ផ្តើមជួយរៀបចំអ្នកស្រុកឲ្យទទួលបាននូវអារ្យធម៌ (កសាងសាលារៀនឲ្យ) ជួយរៀបចំអភិវឌ្ឍន៍ធនធានដូចជាបើកកំពង់ផែជាដើម (ពាណិជ្ជកម្មអន្តរជាតិ) កែលម្អទឹកដី ជីកព្រែក សង់ផ្លូវ ស្ពាន (ផ្លូវដែក) ហើយនៅទីបញ្ចប់រៀបចំឲ្យចេះប្រើកម្លាំង ដែលមានក្នុងធម្មជាតិតាមដែលពួកគេចេះប្រើបាន នូវអ្វីដែលមិនដែលដឹងពីមុនមក ហើយចេះមានសណ្តាប់ធ្នាប់ និងចេះគ្រប់គ្រងដោយមិនចាំបាច់មានវត្តមានពួកស្បែកស ដូចជាឲ្យចេះប្រើម៉ាស៊ីនប្រើចំហាយ ចេះប្រើវថភ្លើង មានរោងជាង មានអគ្គិសនី មានកម្លាំងចលករ មានគមនាគមន៍ និងមានគំនិត ។

យើងសង្ឃឹមថាប្រជាជននៅឥណ្ឌា ឥណ្ឌូចិន និងចុងបូព៌ាប្រទេសទាំងអស់ នឹងចេះប្រើប្រាស់អ្វីដែលពួកអឺរ៉ុបបានបង្ហាត់បង្រៀន ទទួលបាននូវកម្លាំងឆ្នៃប្រឌិតរបស់ខ្លួនមកវិញ ហើយធ្វើដំណើរឈានទៅមុខតាមផ្លូវដែលពួកអឺរ៉ុបបានត្រួសត្រាយឲ្យរួចមកហើយនេះ ពីមួយជំនាន់ទៅមួយជំនាន់ទៀតដោយនាំមកនូវការរក

ឃើញថ្មី ការអនុវត្តន៍ និងការអភិវឌ្ឍន៍ថ្មីៗ បញ្ជាក់ឲ្យឃើញច្បាស់នូវតម្លៃរបស់ខ្លួនក្នុងនាមជាជាតិសាសន៍មួយ ។ សូមអ្នកទាំងអស់ប្រកបទៅដោយសេចក្តីក្លាហាន ការប្រឹងប្រែង និងយុត្តិធម៌ ។

---